# ព្រះវិនយវណ្ណនា

ជាធម្មបណ្ណាការ ឧទ្ទិសចំពោះ ព្រះពុទ្ធសាសនា

ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ភ្នំពេញ

ព.ស.២៥៤៥ គ.ស.២០០១

www.budinst.gov.kh www.elibraryofcambodia.org

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង
**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
**អង្គការរីស្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**
**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

**www.budinst.gov.kh** **www.elibraryofcambodia.org**

LIBRARY
BUDDHIST INSTITUTE

www.budinst.gov.kh www.elibraryofcambodia.org

២៤១.២៧៦

## សេចក្តីបញ្ជាក់
## ចំពោះការបោះពុម្ពឡើងវិញ

សៀវភៅ " **ព្រះវិន័យ វណ្ណនា** " ត្រូវបានបោះពុម្ពឡើងវិញក្នុងឆ្នាំ ២០០១ ដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ។

គោលបំណងនៃការបោះពុម្ពឡើងវិញនេះគឺសំដៅ :

- ផ្តល់ឱ្យសិស្ស និងគ្រូ ព្រមទាំងអ្នកស្រាវជ្រាវ មានឯកសារស្រាវជ្រាវបន្ថែមគ្រប់គ្រាន់ ។
- រក្សាមរតក វប្បធម៌ អក្សរសាស្ត្រសាសនា អក្សរសាស្ត្រជាតិ ឱ្យគង់វង្សឡើងវិញ និងរីកចម្រើន ។

ការបោះពុម្ពក្នុងគ្រាទី ៥ នេះ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ រក្សាអត្ថន័យខ្លឹមសារទាំងស្រុង ដោយធ្វើការថតចម្លងពីសៀវភៅច្បាប់ដើមដែលមាន ។ ហេតុនេះ ប្រសិនបើមានកំហុស អក្ខរាវិរុទ្ធក្តី កំហុសក្នុងការរៀបរៀងឃ្លាក្តី នោះគឺជាលក្ខណៈដែលមានក្នុងច្បាប់ដើមពីមុនមក ។

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ សូមអភ័យទោសជាមុនចំពោះកង្វះខាតផ្សេងៗ ដែលអាចនឹងកើតមាន ដោយអចេតនាក្នុងការបោះពុម្ពឡើងវិញនេះ ។

LIBRARY BUDDHIST INST

ភ្នំពេញ ខែ កក្កដា ឆ្នាំ ២០០១
វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

៦៥២២/០២

www.budinst.gov.kh www.elibraryofcambodia.org

# បុព្វសិក្ខាវណ្ណនា

លោកជេដ្ឋំ ច សម្ពុទ្ធំ ធម្មំ ពុទ្ធេន បូជិតំ
គណំ អរិយសំឃស្ស នមាមិ រតនត្តយំ ។
បុព្វសិក្ខា ច យា បុព្វេ សំខេបេនេវ ទស្សិតា
ខេមកនុត្តមេនេវ នវានមនុសិក្ខិតុំ ។
ភិក្ខូនំ ញាតុកាមានំ ជោតកំ ក្រិទ្ធុំ វិត្ថារតោ
វណ្ណនំ ការិស្សំ តស្សា វិនយញ្ញូ ដិនេរិតំ ។
តស្មា ហិ សាធវោ ភិក្ខូ សុខកាមា ច សាសនេ
វិនយម្ហិ ច សិក្ខន្តុ អប្បមត្តា ច សាធុកំ ។

ខ្ញុំនមស្ការនូវព្រះរតនត្រ័យ គឺព្រះសម្ពុទ្ធជាធំក្នុងលោក ទាំងព្រះធម៌ដែលព្រះពុទ្ធបូជាហើយ ទាំងពួកនៃព្រះអរិយសង្ឃ ។ បុព្វសិក្ខាណា ដែលយើងសំដែងពីមុនដោយសង្ខេប ដើម្បីញ៉ាំងពួកភិក្ខុដែលបួសថ្មី ឲ្យសិក្សាតាមលំដាប់ជាខេមរភាសា ។

ខ្ញុំនឹងធ្វើនូវបុព្វសិក្ខាវណ្ណនានេះ ឲ្យពិស្តារបន្តិច ជាងបុព្វសិក្ខាសង្ខេបនោះ សម្រាប់ភិក្ខុទាំងឡាយអ្នកប្រាថ្នាឲ្យចេះដឹងនូវព្រះវិន័យ ដែលព្រះជិនស្រីសំដែងទុកហើយ ។ ហេតុដូច្នោះ ពួកភិក្ខុជាសប្បុរស អ្នកប្រាថ្នាសេចក្តីសុខ ចូរកុំប្រមាទឡើយ ហើយសិក្សានូវព្រះវិន័យក្នុងសាសនាដោយប្រពៃចុះ ។

www.budinst.gov.kh www.elibraryofcambodia.org

ពហុស្សុត បណ្ឌិត អ្នកប្រាជ្ញដែលជាអ្នកទ្រទ្រង់ព្រះវិន័យ ព្រោះលោកបានរៀនព្រះវិន័យសាសនានោះៗ ទើបនឹងបានច្បាស់សេចក្តីទៅ ។

ពាក្យថា បុព្វសិក្ខា នេះ សង្គ្រោះជាឈ្មោះគម្ពីរ គឺក្បួនច្បាប់សម្រាប់កុលបុត្រសិក្សាជាដំបូង ទើបបានឈ្មោះថា បុព្វសិក្ខា ព្រោះហេតុនោះ ទើបបានពោលថា កុលបុត្រអ្នកជាឧបសម្បទាបេក្ខៈ ឬ បានឧបសម្បទាហើយ គប្បីសិក្សាសេចក្តីតាំង ៧ ប្រការនេះជាមុន ។

ឯសេចក្តីតាំង ៧ ប្រការនោះគឺ ៖

រតនត្តយបទំ: ពណ៌នាដោយគុណព្រះរតនត្រ័យ ១

អាបត្តាទិនាមិកបទំ: ពណ៌នាដោយឈ្មោះនៃអាបត្តិជាដើម ១

បដិបត្តិសិក្ខាបទំ: ពណ៌នាដោយសិក្ខាបទជាប្រធាននៃផ្លូវបដិបត្តិដោយច្រើន ១

កាលិកបទំ: ពណ៌នាដោយកាលិក ១

ពិន្ទាធិដ្ឋា[illegible]ទិបទំ: ពណ៌នាដោយវិធីមានពិន្ទុនិងអធិដ្ឋានជាដើម

វិជហាណា[illegible]បទំ: ពណ៌នា[illegible]អធិដ្ឋានជាដើម ១

អាបត្តិទេ[illegible]នាទិបទំ: [illegible]សំដែងអាបត្តិជាដើម ១

ត្រូវជាសេចក្តី ៧ ប្រការដូច្នេះ

www.budinst.gov.kh www.elibraryofcambodia.org

# រតនត្តយបព្វៈ

ពាក្យថា រតនត្តយៈនោះ ប្រែថាប្រជុំបីនៃ រតនៈ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ វត្ថុទាំង ៣ នេះឈ្មោះថា រតនៈ ព្រោះជារបស់ប្រសើរជាង សវិញ្ញាណករតនៈ និង អវិញ្ញាណករតនៈ ដែលមានក្នុងត្រៃភព ។

មួយទៀត ព្រោះជារបស់ធ្វើសេចក្ដីត្រេកអរឲ្យកើតឡើងដល់ត្រៃលោក ។

## ពុទ្ធរតនកថា

បុច្ឆាសួរថា- ពុទ្ធៈនោះ អ្វីជាពុទ្ធៈ ?

វិសជ្ជនាថា... ពុទ្ធៈបើពោលតាមបរមត្ថវោហារ បានដល់ វិសុទ្ធខន្ធសន្តាន គឺ ខន្ធរូប ខន្ធវេទនា ខន្ធសញ្ញា ខន្ធសង្ខារ ខន្ធវិញ្ញាណ ដែលជារបស់មានមកអំពីកាលមុន ជារបស់បរិសុទ្ធចាកបាបធម៌ ឧបក្កិលេស គឺមិនមានអកុសលចេតសិក គ្រាន់តែជាអព្យាកតចេតសិក ដែលកើតអំពីកុសលចេតសិក នោះឯងជា ពុទ្ធៈ បើពោលតាមលោក-វោហារ ជាជាសត្វវិសេសឯក មិនមែនព្រហ្ម មិនមែនមារ មិនមែនទេវតា មិនមែនអមនុស្ស គឺជាមនុស្សជាតិ តែជាមនុស្សអស្ចារ្យ មាន

www.budinst.gov.kh www.elibraryofcambodia.org

ប្រាជ្ញាឈ្លាស មានប្រាជ្ញាលើសជាង សមណព្រាហ្មណ៍ ទេវតា មារ ព្រហ្ម អាចធ្វើព្រះអង្គឯងឲ្យបរិសុទ្ធចាកបាបធម៌ គឺកិលេសបាន ទាំងទូន្មានសត្វដទៃឲ្យបានសេចក្ដីបរិសុទ្ធបានផង នោះឯងជាពុទ្ធៈ ។

បុ. ពុទ្ធៈនោះ ប្រែថាដូចម្ដេច?

វិ. ពុទ្ធៈនោះ ប្រែថាព្រះអង្គទ្រង់ជ្រាបច្បាស់នូវសង្ខារទាំងពួង ដោយព្រះអង្គឯង ហើយអាចឲ្យពួកសត្វដទៃដឹងច្បាស់នូវសង្ខារផង, ព្រះអង្គរីកហើយពេញទី ។

បុថុជ្ជនដូចយើង ឈ្មោះថាជាមនុស្សខ្លៅមិនដឹងច្បាស់នូវសង្ខារ ទើបក្រៀមក្រំចិត្តក្នុងកាលដែលសង្ខារនោះវិបត្តិ ។

បុ. អ្វីជាសង្ខារ?

វិ. វត្ថុទាំងពួងជារបស់ខាងក្នុង និងខាងក្រៅ ប្រកបដោយវិញ្ញាណនិងមិនមានវិញ្ញាណ ដែលមានឡើងកើតឡើងដោយហេតុខាងក្នុងមានកម្មជាដើម ដោយហេតុខាងក្រៅមានរដូវជាដើម នេះឯងឈ្មោះថាសង្ខារ ។

បុ. ព្រះអង្គត្រាស់ដឹងនូវសង្ខារនោះដូចម្ដេច?

វិ. ព្រះអង្គទ្រង់ជ្រាបសេចក្ដីកើតឯងរបស់សង្ខារ, ទ្រង់ជ្រាបហេតុដែលឲ្យកើតសង្ខារ, ទ្រង់ជ្រាបទីរលត់សង្ខារ, ទ្រង់ជ្រាបផ្លូវទៅកាន់ទីរលត់សង្ខារ, នេះឯងឈ្មោះថាព្រះអង្គទ្រង់ជ្រាបច្បាស់នូវសង្ខារ ។

www.budinst.gov.kh www.elibraryofcambodia.org

បុ. ព្រះអង្គទ្រង់ជ្រាប សេចក្ដីកើតឯងនៃសង្ខារដូចម្ដេច ?

វិ. ព្រះអង្គទ្រង់ជ្រាបថា សង្ខារទាំងពួងមិនទៀងពិត រមែងប្រែប្រួលទៅផ្សេងៗ មានហើយមិនមានវិញ កើតហើយរលត់ទៅ ធម៌ទាំងពួងមិនមែនខ្លួនប្រាណ ព្រោះមិនបានប្រព្រឹត្តទៅក្នុងអំណាចបង្គាប់នៃអ្នកឯណា ព្រោះមិនទៀង ព្រោះមិនមែនខ្លួន គ្រាន់តែជាកងទុក្ខដូច្នេះជាសេចក្ដីពិត ជាសេចក្ដីកើតឯងនៃសង្ខារ ព្រះអង្គទ្រង់ជ្រាបច្បាស់ដូច្នេះ ដោយបរិញ្ញាភិសម័យ យ៉ាងនេះឈ្មោះថា ព្រះអង្គជ្រាបច្បាស់នូវសេចក្ដីកើតឯងនៃសង្ខារ ។

បុ. ព្រះអង្គជ្រាបច្បាស់នូវហេតុដែលឲ្យកើតសង្ខារដូចម្ដេច ?

វិ. ព្រះអង្គជ្រាបច្បាស់ថា តណ្ហាគឺសេចក្ដីអន្ទះអន្ទែងដោយការចង់បាន នេះឯង ជាអ្នកសាងសង្ខារទាំងក្នុង ព្រោះតណ្ហាមានហើយជាហេតុឲ្យសត្វធ្វើកម្មជាកុសលនិងអកុសល ដែលនឹងតាក់តែងសង្ខារជាកងទុក្ខ ព្រះអង្គលះតណ្ហានោះបាន ដោយបហានាភិសម័យ យ៉ាងនេះឈ្មោះថា ព្រះអង្គជ្រាបច្បាស់នូវហេតុដែលឲ្យកើតសង្ខារ ។

បុ. ព្រះអង្គទ្រង់ជ្រាបច្បាស់នូវទីរលត់សង្ខារនោះដូចម្ដេច ?

វិ. ព្រះអង្គទ្រង់ជ្រាបច្បាស់ថា ព្រះនិព្វានជាទីរលត់តណ្ហា ដែលជាហេតុឲ្យកើតទុក្ខ ហើយធ្វើព្រះនិព្វានឲ្យជាក់ច្បាស់ក្នុងព្រះទ័យ ដោយ

www.budinst.gov.kh www.elibraryofcambodia.org

សច្ចិកិរិយាភិសម័យ យ៉ាងនេះឈ្មោះថា ព្រះអង្គទ្រង់ជ្រាបច្បាស់នូវទីរលត់នៃសង្ខារ ។

ឬ. ព្រះអង្គទ្រង់ជ្រាបច្បាស់នូវផ្លូវទៅកាន់ទីរលត់នៃសង្ខារនោះដូចម្ដេច ?

វិ. ព្រះអង្គទ្រង់ជ្រាបច្បាស់ថា មគ្គប្រកបដោយអង្គ ៨ មានសម្មាទិដ្ឋិជាដើម ដែលកើតឡើងហើយ កំណត់ដឹងនូវសេចក្ដីទុក្ខ លះតណ្ហា ឃើញព្រះនិព្វាន នេះឯងជាផ្លូវដល់នូវសេចក្ដីរលត់កងទុក្ខ ព្រះអង្គចំរើនមគ្គនោះឲ្យកើតឡើងក្នុងព្រះហឫទ័យ ដោយភាវនាភិសម័យ យ៉ាងនេះឈ្មោះថា ព្រះអង្គទ្រង់ជ្រាបច្បាស់នូវផ្លូវទៅកាន់ទីរលត់នៃសង្ខារ ។

ព្រះអង្គទ្រង់ជ្រាបច្បាស់នូវហេតុទាំង ៤ ប្រការនេះហើយ ទើបមានសេចក្ដីបរិសុទ្ធិ ជាបដល់មិនត្រេកអរ ប្រកាន់ថា យើងដឹង យើងឃើញ សូម្បីសង្ខារគឺកងកាយរបស់ព្រះអង្គនឹងវិបត្តិយ៉ាងណា ៗ ក៏មិនតោមនស្សដូចបុថុជ្ជន យ៉ាងនេះឈ្មោះថា ព្រះអង្គជ្រាបច្បាស់នូវសង្ខារទាំងពួង ។

ឬ. បុគ្គលដែលលោកហៅថា ពុទ្ធ: នោះមានប៉ុន្មានពួក ?

វិ. មាន ៤ ពួកគឺ:

១– ពហុស្សុត: លោកហៅថា សុតពុទ្ធ ព្រោះជាអ្នកដឹងនូវសេចក្ដីល្អអាក្រក់ជាដើម ដោយការបានស្ដាប់និងបានរៀនបរិយត្តិធម៌ ។

www.budinst.gov.kh www.elibraryofcambodia.org

២– អរិយសាវក លោកហៅថា សាវកពុទ្ធ ព្រោះលោកបាន ស្តាប់ពាក្យប្រដៅ ពាក្យទូន្មានរបស់ព្រះពុទ្ធ ហើយជ្រាបច្បាស់នូវ បង្ខារតាមដំណើរព្រះពុទ្ធ ។

៣ – ព្រះសយម្ភូ លោកហៅថា បច្ចេកពុទ្ធ អ្នកត្រាស់ដឹងឯង ទូន្មានអ្នកដទៃមិនបាន ដូចមនុស្សគយល់សប្ត ព្រោះជ្រាបច្បាស់នូវ សង្ខារបានចំពោះតែព្រះអង្គឯង ។

៤– ព្រះពុទ្ធ លោកហៅថា សព្វញ្ញុពុទ្ធ ព្រះអង្គត្រាស់ដឹងឯង ហើយទូន្មានអ្នកដទៃ ឲ្យដឹងតាមបាន ព្រោះព្រះអង្គជ្រាបច្បាស់នូវ សង្ខារនិងធម៌ទាំងពួង ។ ដែលពោលមកក្នុងបទពុទ្ធៈនេះ សង្គ្រោះយក តែសព្វញ្ញុពុទ្ធប៉ុណ្ណោះ ។

បុ. ព្រះពុទ្ធជាម្ចាស់នៃយើងនេះ (ក្នុងបច្ឆិមជាតិ) ព្រះអង្គកើត ឡើងក្នុងទីណា ? ក្នុងមនុស្សពួកណា?

វិ. ព្រះអង្គកើតឡើងក្នុងមជ្ឈិមប្រទេស, ក្នុងពួកមនុស្សអរិយកៈ ។ មជ្ឈិមប្រទេសនោះ ប្រែថាប្រទេសជាកណ្តាល ព្រោះថាជាទីកើតនៃ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ អគ្គសាវក ពុទ្ធុបដ្ឋាក ពុទ្ធបិតា ពុទ្ធមាតា ចក្រពត្រាធិរាជ និងគហបតិ អ្នកមានទ្រព្យច្រើន ។ ដូចកណ្តាល នៃទីស្នាមជាទីប្រជុំជនទាំងពួង ។ មជ្ឈិមប្រទេសនោះ នៅក្នុងទិស

www.budinst.gov.kh www.elibraryofcambodia.org

ឯលិចនៃប្រទេសកម្ពុជានេះ គឺប្រទេសសៀម ប្រទេសមន ប្រទេសភូមា ប្រទេសឈាវ៉ាជាដើម ។ ឯប្រទេសទាំងអម្បាលនេះ ឈ្មោះជាបច្ចន្តប្រទេស ។ មនុស្សកើតក្នុងប្រទេសទាំងនេះ ឈ្មោះជាមិលក្ខៈ ។ មនុស្សកើតក្នុងមជ្ឈិមប្រទេស ឈ្មោះជាអរិយកៈ ឥឡូវគេហៅប្រទេសនោះថា ឥណ្ឌៀ ។

បុ. ព្រះអង្គកើតក្នុងមជ្ឈិមប្រទេស ក្នុងនគរណា ជាជាតិអ្វី ជាគោត្រអ្វី ព្រះនាមដើមជាអ្វី ជាបុត្របុគ្គលណា ព្រះអង្គមានបុត្រភរិយាឬទេ ព្រះអង្គបានត្រាស់ជាព្រះពុទ្ធក្នុងកាលណា ?

វិ. ព្រះអង្គជាអ្នកនគរកបិលពស្តុ ក្នុងដែនសក្កៈ ព្រះអង្គជាជាតិក្សត្រពួកសក្យរាជ ជាគោតមគោត្រ ព្រះនាមដើមជា សិទ្ធត្ថៈ ព្រះបិតាទ្រង់ព្រះនាម សុទ្ធោទន នៅក្នុងនគរកបិលពស្តុ ព្រះមាតាទ្រង់ព្រះនាម សិរិមហាមាយា ព្រះឱរសនៃព្រះអង្គព្រះនាម រាហុល ព្រះទេពីព្រះនាម ពិម្ពាយសោធរា កាលព្រះជន្មាយុបាន ២៩ វស្សា ព្រះអង្គលះគ្រហស្ថសម្បត្តិចេញបព្វជ្ជា បំពេញព្យាយាម ស្វែងរកមោក្ខធម៌ដើម្បីវិសុទ្ធអស់ ៦ វស្សា ទើបបានត្រាស់ដឹងព្រះអនុត្តរសម្មាសម្ពោធិញ្ញាណ "ដំណត់ពីនោះទៅព្រះអង្គទ្រង់បំពេញពុទ្ធកិច្ច ទូន្មានវេនេយ្យនិករ ដរាបដល់ ៤៥ វស្សា ទើបទ្រង់រំលត់ខន្ធបរិនិព្វាន នានគរកុសិនារា" ។

www.budinst.gov.kh www.elibraryofcambodia.org

ឫ. ព្រះមាតា បិតា បុត្រ ភរិយា និងសុខសម្បត្តិដែលជាទីស្រឡាញ់ ហេតុអ្វីទើបព្រះអង្គលះបង់បាន ?

វិ. ព្រះអង្គលះបង់បានដោយហេតុដូច្នេះ គឺព្រះអង្គឃើញ ជរា សេចក្ដីចាស់ ព្យាធិ សេចក្ដីឈឺចាប់ មរណៈ សេចក្ដីស្លាប់ជាកងទុក្ខដ៏ដូចជាភ្លើងដុតសត្វដទៃនិងអត្តភាពព្រះអង្គ តែអ្នកដទៃនោះឃើញមនុស្សចាស់ មនុស្សឈឺ មនុស្សស្លាប់ ហើយខ្ពើមរអើម មិនដឹងថា របស់ ៣ យ៉ាងនេះជារបស់សម្រាប់ខ្លួន ចំណែកព្រះអង្គឃើញថា របស់ ៣ យ៉ាងនេះសម្រាប់សត្វដទៃ និងសម្រាប់អត្តភាពព្រះអង្គ និងខ្ពើមដូចមនុស្សដទៃគេខ្ពើមក៏មិនគួរ និងស្រឡាញ់ក៏មិនគួរ និងព្រងើយកន្តើយក៏មិនគួរ ព្រះអង្គឃើញថា ជរា ព្យាធិ មរណៈ នេះជាភ័យធំគួរខ្លាច តែនឹងគេចវេះទៅដោយផ្លូវណាក៏មិនរួច ព្រោះជារបស់សម្រាប់អាស្រ័យនឹងរូបកាយ ព្រះអង្គទើបទ្រង់ព្រះចិន្តាថា ធម៌មិនមានចាស់ មិនមានឈឺ មិនមានស្លាប់ ជាទីគេចវេះ អំពីសេចក្ដីចាស់ ឈឺស្លាប់ គង់នឹងមានប្រាកដ ដូចភ្លើងជារបស់ក្ដៅមានហើយក៏មានទឹកជារបស់ត្រជាក់វិញ មានងងឹតហើយ ក៏មានរស្មីភ្លឺវិញ ហើយព្រះអង្គពិចារណាថា សេចក្ដីចាស់ឈឺស្លាប់ កើតមកអំពីអ្វី ទ្រង់ឃើញថា កើតមកអំពីជាតិ គឺសេចក្ដីកើត ទ្រង់ពិចារណាតទៅថា ជាតិកើតមកអំពីអ្វី ក៏មិនឃើញដោយព្រះបញ្ញាសោះ ដូចជារបស់ ៣ យ៉ាងដែលកើតមក

www.budinst.gov.kh www.elibraryofcambodia.org

អំពីជាតិ ទើបព្រះអង្គត្រាស់ព្រះហឫទ័យថា ការនៅក្នុងសុខសម្បត្តិនេះ នឹងរកធម៌ជាទីគេចវេះ អំពីសេចក្ដីទុក្ខទាំងអម្បាលនេះ មិនបានប្រាកដ ព្រោះប្រថ្នាទៅដោយបុត្រភរិយាទ្រព្យសម្បត្តិដែលនាំឲ្យវង្វេង ឲ្យចំរើនទុក្ខច្រើនឡើង សិរីសម្បត្តិនេះជាទីបង្អៀតបង្អលណាស់ ហើយទើបទ្រង់ឃើញថា បព្វជ្ជា ការទ្រង់ភេទជាបព្វជិតនៅតែម្នាក់ឯងនោះ មិនប្រថ្នាដោយហេតុដែលនាំឲ្យកើតសេចក្ដីត្រេកអរៈតាមមនស្ស ទើបព្រះអង្គលះសុខសម្បត្តិចេញ ទ្រង់ភេទជាបព្វជិត ស្វែងរកធម៌ដែលអស់ទុក្ខទាំងពួង ព្រោះហេតុដូច្នោះ ទើបលោកពោលថា ព្រះពុទ្ធអង្គកើត ២ ដង គឺកើតដោយរូបកាយម្ដង កើតដោយនាមកាយម្ដង គឺតាំងពីចុះកាន់ព្រះគភ៌ព្រះមាតា នៅក្នុងព្រះគភ៌ ១០ ខែ ហើយប្រសូតចាកព្រះគភ៌ ក្នុងព្រៃលុម្ពិនីជាចន្លោះទេវទហនគរ នឹងនគរកបិលពស្តុ មានព្រះកាយព្រមដោយទ្វត្តឹសមហាបុរិសលក្ខណៈ ដ៏គួរជាភាជនៈនៃព្រះពុទ្ធគុណ ទ្រង់ព្រះនាមថា សិទ្ធត្ថៈ នៅជាកុមារបាន ១៦ វស្សា ព្រះបិតាប្រគល់រាជ-សម្បត្តិឲ្យសោយនៅក្នុងប្រាសាទទាំង ៣ សមគួរដល់រដូវទាំង ៣ បាន ១៣ ឆ្នាំ ហើយទ្រង់លះបង់សម្បត្តិ ចេញទ្រង់ភេទជាបព្វជិត បំពេញសេចក្ដីព្យាយាមស្វែងរកកុសល(១) អស់ ៦ វស្សា ស្ដេចយាងទៅគង់ក្រោមដើមអស្សត្ថព្រឹក្ស ដែលហៅថាដើមពោធិ៍ ប្រថាប់ផ្ទឹង

---

១- កុសល គឺសព្វញ្ញុតញ្ញាណ ។

www.budinst.gov.kh www.elibraryofcambodia.org

នៃវញ្ញក ដរាបដល់សម្រេចវិជ្ជា ២ ខាងដើម ទីទីវិបស្សនាញាណ ទៀត រាបដរាបដល់គោត្រភូញាណ ទល់នឹងសោតាបត្តិមគ្គប៉ុណ្ណោះ ឈ្មោះជាកើតហើយដោយរូបកាយ តែហៅថាព្រះពុទ្ធមិនទាន់បាន ។ តាំងអំពីសោតាបត្តិមគ្គ សោតាបត្តិផល រហូតដល់អរហត្តមគ្គកើតឡើង ឈ្មោះថាកំពុងកើតដោយនាមកាយ តាំងអំពីអរហត្តផល គឺសេចក្ដីជ្រាបច្បាស់នូវសង្ខារ កើតឡើងហើយ ឈ្មោះថាព្រះអង្គកើតហើយដោយនាមកាយ តែនៅមិនទាន់ឈ្មោះថា ព្រះអង្គកើតពេញទី ព្រោះមិនទាន់បានបំពេញពុទ្ធកិច្ច តាំងអំពីព្រះអង្គទ្រង់សំដែងព្រះធម្មចក្កប្បវត្តនសូត្រប្រោសបញ្ចវគ្គិយភិក្ខុ ដែលនៅក្នុងព្រៃឥសិបតនមិគទាយវ័ន ព្រះកោណ្ឌញ្ញត្ថេរបានសោតាបត្តិផល ដឹងច្បាស់នូវសង្ខារដោយឯកទេសតាមព្រះអង្គ ដរាបដល់ព្រះអង្គរំលត់ខន្ធ ដោយអនុបាទិសេសនិព្វាន-ធាតុ ត្រង់ចន្លោះដើមរាំងទាំងគូក្នុងសាលវ័ន ។ ឧទ្យាននៃស្ដេចមល្លកជ ឈ្មោះថាព្រះអង្គកើតពេញទី ព្រោះបានបំពេញពុទ្ធកិច្ចជាស្រេចហើយ ។

បុ. អ្វីហៅថា រូបកាយ អ្វីហៅថា នាមកាយ ?

វិ. មហាភូតរូប ៤ ឧបាទាយរូប ២៤ ឈ្មោះថា រូបកាយ ។ វេទនា សញ្ញា សង្ខារ វិញ្ញាណ ៤ នេះ ឈ្មោះថា នាមកាយ ។

បុ. នាមកាយមិនកើតព្រមគ្នានឹងរូបកាយទេឬ ?

វិ. កើតព្រមគ្នា តែថានាមកាយ ដែលឲ្យកើតជាព្រះពុទ្ធ គឺ

www.budinst.gov.kh www.elibraryofcambodia.org

អរហត្តមគ្គ អរហត្តផល ដែលជាពូជសន្តានគុណ ដែលសម្លាប់ខ្មាំងកាយ ដ៏កាច មានលោភៈជាដើម ដែលកប់បញ្ចូលក្នុងសន្តានគុណនោះមិនទាន់ កើត ទើបមិនហៅថា ជាព្រះពុទ្ធ ។ លុះតែអរហត្តមគ្គ អរហត្តផល កើតឡើងហើយ ទើបឈ្មោះថាព្រះពុទ្ធ ព្រោះហេតុនោះបានជាថា ព្រះពុទ្ធកើតពីដែន ។

ប្ញ. ព្រះអង្គស្វែងរកកុសលធម៌នោះ ដូចម្តេច?

វិ. ព្រះអង្គស្វែងរកដោយឧបាយផ្សេងៗ ដរាបដល់អត់ដង្ហើម ផ្តាច់បង់នូវអាហារក៏មិនបានសម្រេចធម៌វិសេសណាមួយ លុះកាលជា ឯក្រោយ ព្រះអង្គទើបទ្រង់នឹករឭកដល់អានាបានស្សតិឈាន ដែលព្រះ អង្គបានកាលនៅជាកុមារម្តង ជារបស់អស្ចារ្យចំឡែកណាស់ ឃើញ ថាជាផ្លូវនៃសេចក្តីត្រាស់ដឹងបាន ទើបព្រះអង្គត្រឡប់សោយអាហារវិញ ហើយស្តេចយាងទៅគង់ក្រោមដើមអស្សត្ថព្រឹក្ស ចំរើនអានាបានស្សតិ តាំងសតិឆ្ពោះដង្ហើមចេញចូលតែម្យ៉ាង មិនបានបញ្ជូនចិត្តទៅកាន់ទី ដទៃ រម្ងាប់ កាមឆន្ទ សេចក្តីស្រឡាញ់ សេចក្តីគាប់ចិត្ត, ព្យាបាទ បំណងញ៉ាំងសត្វឲ្យវិនាស, ថីនមិទ្ធ សេចក្តីងុយងោកងក់, ឧទ្ធច្ច កុក្កុច្ច សេចក្តីអណ្តែតអណ្តូងកាយមាយចិត្ត, វិចិកិច្ឆា សេចក្តី សន្ទិះសង្ស័យ, តាំងអម្បាលនេះដែលជានីវរណៈ គ្រឿងឃាត់សមាធិ គ្រឿងសៅហ្មងចិត្តជារបស់ធ្វើប្រាជ្ញាឲ្យវិនាសទៅ ទើបបានបឋមជ្ឈាន

www.budinst.gov.kh www.elibraryofcambodia.org

ជាឈានប្រកបដោយអង្គ ៥ គឺវិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតា ចាស់ក្លាជានិងចេតសិកធមមិនដែល ហើយព្រះអង្គធ្វើព្យាយាមចំរើន ៗ ឡើង ទៅដោយលំដាប់ រម្ងាប់វិតក្កៈ វិចារៈ ជារបស់គ្រោតគ្រាតចេញ សល់នៅតែ បីតិ សុខៈ ឯកគ្គតា ជាទុតិយជ្ឈាន, ហើយរម្ងាប់បីតិ ជារបស់គ្រោតគ្រាតចេញ សល់នៅតែសុខៈ នឹង ឯកគ្គតា ជាតតិយជ្ឈាន, ហើយលះសុខៈ ជារបស់គ្រោតគ្រាតចេញ សល់នៅតែឯកគ្គតា នឹងឧបេក្ខា ដែលទាំងពីរជាចតុត្ថជ្ឈាន ហើយព្រះអង្គធ្វើឈានទាំង ៤ នោះឲ្យស្ទាត់ជំនាញដោយការនឹកនឹងការចូលជាដើម លុះចិត្តថ្លាបរិសុទ្ធល្អិតល្អដោយអំណាចចតុត្ថជ្ឈានហើយ ទើបព្រះអង្គបង្អោនព្រះទ័យទៅដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ គឺបញ្ញាដែលរលឹកតាមលំដាប់ខន្ធនៃព្រះអង្គ នឹងសត្វដទៃដែលធ្លាប់នៅហើយក្នុងជាតិមុន ភពមុន គឺរលឹកបានច្រើនអនេកជាតិ តាំងអំពីជាតិទី ១ លុះដល់អនេកសំវដ្តវិវដ្តកប្ប ៗ សេចក្តីសង្ស័យថា ភពមុន ជាតិមុន មានឬមិនមាននោះ គឺអស់ទៅ ទ្រង់ឃើញច្បាស់ថា ជាតិមុន ភពមុន មានប្រាកដពិត តែទ្រង់ឃើញថា សង្សារវដ្តមានខាងដើម សូម្បីបុគ្គលរលឹកតាមទៅក៏មិនដឹង ដូច្នេះឈ្មោះថាវិជ្ជាជាបឋម ព្រះអង្គបានក្នុងបឋមយាម, លុះមជ្ឈិមយាម ទ្រង់បង្អោនព្រះទ័យទៅដើម្បីចុតូបបាតញ្ញាណ គឺប្រាជ្ញាដែលជ្រាប ដែលឃើញចុតិបដិសន្ធិនៃសត្វ ព្រះអង្គក៏បានឃើញសត្វទាំងឡាយ ដែល

www.budinst.gov.kh www.elibraryofcambodia.org

ប្រព្រឹត្តទុច្ចរិតទាំង ៣ ប្រកបដោយមិច្ឆាទិដ្ឋិ លុះចុតិហើយទៅកើតក្នុង អបាយភូមិ ដោយអកុសលកម្មនោះ និងសត្វទាំងឡាយ ដែលប្រព្រឹត្ត សុចរិតទាំង ៣ ប្រកបដោយសម្មាទិដ្ឋិ លុះចុតិហើយទៅកើតក្នុង សុគតិភូមិ ដោយកុសលកម្មនោះ ព្រះអង្គជ្រាបច្បាស់ដោយទិព្វចក្ខុ-ញាណដូច្នេះ ។

សេចក្តីសង្ស័យថា ធម្មជាតិអ្វីជារបស់តាក់តែងសត្វឲ្យបានល្អបាន អាក្រក់ និងសេចក្តីសង្ស័យថា ជាតិមកអំពីណាក៏អស់ទៅ ដោយ ឃើញច្បាស់ថា កម្មគឺបុណ្យនិងបាប ជារបស់តាក់តែងសត្វឲ្យល្អ អាក្រក់ ជាតិមកអំពីកម្មភព នេះជាវិជ្ជាគំរប់ ២ ព្រះអង្គបានក្នុងមជ្ឈិម-យាម លុះវិជ្ជាទាំង ២ ជំរះផ្លូវប្រាជ្ញាឲ្យបរិសុទ្ធហើយ ទើបព្រះអង្គបង្អោន ព្រះទ័យទៅ ដើម្បីអាសវក្ខយញ្ញាណ ប្រាជ្ញាជ្រាបនូវធម៌ជាគ្រឿងធ្វើឲ្យ ក្ស័យទៅនៃអាសវៈ បានដល់មគ្គផលនិព្វាន គឺព្រះអង្គប្រារព្ធនូវជរា ព្យាធិ មរណៈ ដែលជាទុក្ខ ដូចភ្លើងដុតសត្វដែលបានឃើញអំពីមុននោះ ទើបពិចារណារកបច្ច័យនៃទុក្ខនោះ ក៏បានឃើញថា ជរា ព្យាធិ មរណៈ នោះកើតអំពីជាតិ, ជាតិកើតអំពីកម្មភព គឺកុសលអកុសល, ភពកើតអំពី ឧបាទាន សេចក្តីប្រកាន់ខ្ជាប់ ៤ ប្រការ គឺ កាម-ទិដ្ឋិ សីលព្វត-អត្តវាទ-, ឧបាទាន ៤ នេះកើតអំពីតណ្ហា គឺសេចក្តីតក់ស្លុត ដោយសេចក្តីប្រាថ្នា, តណ្ហាកើតអំពីវេទនា គឺការទទួលអារម្មណ៍ជាសុខជាទុក្ខ និងឧបេក្ខា,

www.budinst.gov.kh www.elibraryofcambodia.org

វេទនាកើតអំពីផស្សៈ គឺសេចក្ដីពាល់ត្រូវដោយទ្វារ មានចក្ខុទ្វារជាដើម និងញាណមានចក្ខុវិញ្ញាណជាដើម និងអារម្មណ៍មានរូបារម្មណ៍ជាដើម លុះកើតព្រមគ្នាដូច្នេះ ហៅថាផស្សៈ, ផស្សៈកើតអំពីអាយតនៈ ៦ គឺ ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត, អាយតនៈ ៦ កើតអំពីនាមរូប (សភាវៈដែលបង្អោនទៅរកអារម្មណ៍បាន ឈ្មោះថានាម, សភាវៈដែលវិបត្តិទៅដោយរដូវមានក្ដៅណាស់ ត្រជាក់ណាស់ជាដើម ឈ្មោះថារូប.) នាមរូបកើតអំពីវិញ្ញាណ គឺបដិសន្ធិចិត្ត, វិញ្ញាណកើតអំពីសង្ខារ របស់តាក់តែងសត្វឲ្យល្អ អាក្រក់ គឺកុសលនិងអកុសល, សង្ខារកើតអំពីអវិជ្ជា គឺសេចក្ដីមិនដឹងច្បាស់ថានេះទុក្ខ នេះហេតុឲ្យកើតទុក្ខ នេះទីរលត់ទុក្ខ នេះផ្លូវឲ្យដល់នូវទីរលត់ទុក្ខ, ហើយព្រះអង្គឃើញថាអវិជ្ជា និងតណ្ហា ទាំង ២ នេះ ជាឫសគល់នៃសង្សារវដ្ដ ហើយទ្រង់ចំរើនវិបស្សនាឲ្យលើសលប់ឡើងទៅ ដើម្បីលះអវិជ្ជា តណ្ហានោះ ។

បុ. ព្រះអង្គចំរើនវិបស្សនានោះដូចម្ដេច?

វិ. ព្រះអង្គទ្រង់ចាប់ អវិជ្ជា សង្ខារ វិញ្ញាណ នាមរូប អាយតនៈ ផស្សៈ វេទនា តណ្ហា ឧបាទាន ភព ជាតិ ទាំងអស់នេះមួយៗឡើង ពិចារណានឹកវិនិច្ឆ័យថា មិនមែនសត្វ មិនមែនបុគ្គល មិនមែនខ្លួន មិនមែនប្រាណ មិនមែនគេ មិនមែនយើង ជាសភាវៈមួយ ៗ អាស្រ័យគ្នានិងគ្នា កើតឡើងហើយរលត់ទៅ រលត់ទៅហើយកើតឡើង កាល

www.budinst.gov.kh www.elibraryofcambodia.org

អវិជ្ជាមាន ជាបច្ច័យឲ្យកើតសង្ខារ សង្ខារមាន ជាបច្ច័យឲ្យកើតវិញ្ញាណ វិញ្ញាណមាន ជាបច្ច័យឲ្យកើតនាមរូប នាមរូបមាន ជាបច្ច័យឲ្យកើត អាយតនៈ អាយតនៈមាន ជាបច្ច័យឲ្យកើតផស្សៈ ផស្សៈមាន ជាបច្ច័យឲ្យ កើតវេទនា វេទនាមាន ជាបច្ច័យឲ្យកើតតណ្ហា តណ្ហាមាន ជាបច្ច័យឲ្យ កើតឧបាទាន ឧបាទានមាន ជាបច្ច័យឲ្យកើតភព ភពមាន ជាបច្ច័យឲ្យ កើតជាតិ ជាតិមាន ជាបច្ច័យឲ្យកើតទុក្ខ គឺជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ ឧបាយាសៈ ដូចជាភ្លើងដុតឲ្យក្ដៅគ្រប់ភពគ្រប់ជាតិ នេះជាធម៌អាស្រ័យគ្នានឹងគ្នាកើតឡើងដូច្នេះ វិលវល់ក្នុងសង្សារវដ្ដ និង ជារបស់អ្វីជា ខាងដើម កណ្ដាល ខាងចុង នោះមិនបាន ជាបានតែកងទុក្ខ ប៉ុណ្ណោះ កើតឡើងហើយរលត់ទៅ វិលវល់នៅក្នុងសង្សារវដ្ដ និងជាសត្វ ជាបុគ្គលរងទុក្ខនោះមិនបាន ព្រោះជាសភាវៈមួយ ៗ អាស្រ័យគ្នានឹងគ្នា កើតឡើងប៉ុណ្ណោះ ហើយព្រះអង្គឃើញថានេះជាទុក្ខ ទុក្ខនេះនឹងគប្បី កំណត់ដឹងបានពិត ហើយព្រះអង្គបានកំណត់ដឹងដោយបរិញ្ញាភិសម័យ ដូច្នេះ ហើយព្រះអង្គដឹងថា អវិជ្ជា តណ្ហា ពីរនេះឯងជាឫសគល់នៃ សង្សារវដ្ដ ជាហេតុឲ្យកើតកងទុក្ខដូចពោលមកនេះ អវិជ្ជា តណ្ហានេះ គប្បីលះបានពិត ព្រះអង្គលះបង់បានដោយបហានាភិសម័យ ព្រះអង្គ ឃើញថារំលត់អវិជ្ជា តណ្ហា ២ នេះបានហើយ សង្ខារ វិញ្ញាណ នាមរូប ជាដើមដែលជាផលក៏រលត់អស់ ធម៌ជាទីរលត់ទុក្ខនេះ នឹងគប្បីឃើញ

www.budinst.gov.kh www.elibraryofcambodia.org

ច្បាស់ដោយពិត ព្រះអង្គឃើញច្បាស់នូវធម៌ដែលរលត់ទុក្ខបានដោយសច្ចិកិរិយាភិសម័យ ព្រះអង្គឃើញថាបញ្ញាការឃើញយ៉ាងនេះជាផ្លូវឲ្យដល់នូវទីរលត់ទុក្ខ បញ្ញានេះជារបស់ដ៏គប្បីឲ្យមានឲ្យចំរើនឡើងបានពិត ហើយព្រះអង្គបានធ្វើឲ្យមានឲ្យចំរើនឡើងដោយភាវនាភិសម័យ ។ ការកំណត់ដឹងទុក្ខ លះអវិជ្ជា តណ្ហា ឃើញព្រះនិព្វានច្បាស់ ដោយការកើតឡើងនៃមគ្គចិត្ត យ៉ាងនេះ កើតឡើងក្នុងខណៈចិត្តតែមួយ ឈ្មោះថាមគ្គកើតឡើង មគ្គនេះកើតឡើងក្នុងកាលណា កាលនោះអាសវៈទាំង ៣ ជាគ្រឿងត្រាំក្នុងសន្ដានគឺៈ កាមាសវៈ ភវាសវៈ ជាតួតណ្ហា មួយអន្លើដោយអវិជ្ជាសវៈក៏អស់សូន្យទៅ ផលកើតឡើង ទាប់តែមគ្គនោះទៀត មគ្គផលនេះឯងឈ្មោះថា អាសវក្ខយញ្ញាណ បញ្ញាដឹងសេចក្ដីអស់ទៅនៃអាសវៈគ្រឿងត្រាំក្នុងសន្ដាន អាសវក្ខយញ្ញាណនេះឈ្មោះថាវិជ្ជាតំរប់ ៣ ព្រះអង្គបានក្នុងវេលាបច្ចូសសម័យនៃថ្ងៃវិសាខបុណ្ណមី ។ ដូចពោលមកនេះ ឈ្មោះថាព្រះអង្គស្វែងរកធម៌ជាទីអស់ទៅនៃទុក្ខ ។

សួ. អ្វីជាហេតុបណ្ដាលឲ្យព្រះអង្គឃើញ ជរា ព្យាធិ មរណៈជាទុក្ខ ដូចជាក្លែងផុតព្រះអង្គនឹងសម្ដែង ឲ្យក្ដៅព្រះហឫទ័យ លះសុខសម្បត្តិចោលចេញ ស្វែងរកធម៌ដែលរលត់ទុក្ខដូច្នេះ ជនដទៃហេតុអ្វីមិនឃើញដូចព្រះអង្គនោះ?

www.budinst.gov.kh www.elibraryofcambodia.org

វិ. ព្រះអង្គធ្លាប់សង្កត់សង្កិនញាំញីសន្ដាន ឃើញសេចក្ដីពិត ៣ ប្រការគឺ អនិច្ចតា សភាពជារបស់មិនទៀង, ទុក្ខតា សភាពជាទុក្ខ, អនត្តតា សភាពជារបស់មិនមែនខ្លួនប្រាណ, ដោយប្រាជ្ញាដ៏ធ្លាប់បំពេញកុសលផ្សេងៗ មាន ទាន សីល ជាដើម មកក្នុងភពមុនជាច្រើនអស់កាលយូរ ទើបទ្រង់បាននូវនិស្ស័យ ដែលបណ្ដាលឲ្យព្រះអង្គឃើញដូច្នេះ ហើយស្វែងរកធម៌ដែលអស់ទុក្ខ ។ ឯជនដទៃមិនបានប្រតិបត្តិដូចព្រះអង្គ ទើបឃើញវត្ថុនៃសេចក្ដីទុក្ខ ថាជាវត្ថុនៃសេចក្ដីសុខ ហើយក៏វង្វេងនៅក្នុងវត្ថុនោះ ៗ ។

បុ. ក្នុងពុទ្ធសិក្ខាថា ព្រះអង្គត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ ដោយលះនីវរណៈ ៥ តាំងព្រះហឫទ័យស្ថិតនៅក្នុងសតិបដ្ឋាន ៤ ចំរើនពោជ្ឈង្គ ៧ ទើបបានត្រាស់ជាព្រះពុទ្ធ ។ ក្នុងបទនេះថា ត្រាស់ដឹងបានដោយវិជ្ជា ៣ ទើបហៅថាព្រះពុទ្ធ ហេតុដូចម្ដេចបានជាមិនដូចគ្នា ?

វិ. គ្រាន់តែជាទេសនាមុខប៉ុណ្ណោះ ដោយអត្ថ ពាក្យទាំងពីរនោះក្រលគ្នាក៏ដូចគ្នា នឹងពោលឲ្យច្បាស់ នីវរណៈ ៥ គឺៈ កាមច្ឆន្ទ ចក្ដីស្រឡាញ់នឹងជាប់ចិត្តក្នុងកាមគុណ ១ ព្យាបាទ ចំណងព្យាបាទវត្ថុឲ្យវិនាស ១ ថីនមិទ្ធ សេចក្ដីងោកងងុយដេក ១ ឧទ្ធច្ច-កុក្កុច្ច សេចក្ដីអណ្ដែតអណ្ដូងរាយមាយ ១ វិចិកិច្ឆា សេចក្ដីសន្ទិះសន្ស័យ ១ ទាំង ៥ នេះ ហៅថានីវរណៈ ព្រោះជារបស់ឃាត់កុសលធម៌

www.budinst.gov.kh www.elibraryofcambodia.org

មានសមាធិជាដើម មិនឲ្យកើតឡើងបាន ជារបស់ធ្វើចិត្តឲ្យសៅហ្មង ជារបស់ធ្វើប្រាជ្ញាឲ្យថយកម្លាំង ព្រះអង្គលះនីវរណៈ ទាំង ៥ នេះ ដោយវិក្ខម្ភនប្បហានៈ គឺសង្កត់ទុកដោយអានាបានស្សតិឈានជាមុនហើយ កាលមគ្គកើតឡើងសម្លាប់អវិជ្ជា តណ្ហា ដែលជាប្រធាននៃកិលេស ជាឫសគល់នៃសង្សារវដ្តស្លាប់ហើយ នីវរណៈ ៥ ដែលជាកិលេសកប់ចូលក្នុង អវិជ្ជា តណ្ហានោះ ក៏ស្លាប់បង់ដោយសមុច្ឆេទប្បហានៈដែរ ព្រោះហេតុនោះទើបឈ្មោះថាលះនីវរណៈ ៥ ។

សតិប្បដ្ឋាន ៤ គឺ កាយានុបស្សនា ការឃើញរឿយ ៗ នូវកាយ ថាជារបស់អស់ទៅ ទីងសូន្យទៅ ១ វេទនានុបស្សនា ការឃើញរឿយ ៗ នូវវេទនា ថាជារបស់អស់ទៅ ទីងសូន្យទៅ ១ ចិត្តានុបស្សនា ការឃើញរឿយ ៗ នូវចិត្ត ថាជារបស់អស់ទៅទីងសូន្យទៅ ១ ធម្មានុបស្សនា ការឃើញរឿយ ៗ នូវធម៌ ថាជារបស់អស់ទៅ ទីងសូន្យទៅ ១ ទាំង ៤ នេះឈ្មោះថាសតិប្បដ្ឋាន ។ សតិប្បដ្ឋាន ប្រែថា ការដំកល់ទុកនូវសតិ ឬថាសតិចូលទៅតាំងនៅក្នុងអារម្មណ៍ សតិ ប្រែថា សេចក្ដីរលឹក សតិនេះជាតួចេតសិកតែ ១ មិនមែន ២ ហេតុដូចម្ដេចទើបឈ្មោះថាសតិប្បដ្ឋាន ៤ ដូច្នេះ ដែលពោលថាសតិប្បដ្ឋាន ៤ នោះ ដោយអំណាចអារម្មណ៍ជាទីចូលទៅតាំងនៅនៃសតិ អារម្មណ៍នៃសតិនោះមាន ៤ គឺ កាយ ១ វេទនា ១

www.budinst.gov.kh www.elibraryofcambodia.org

ចិត្ត ១ ធម៌ ១ សតិប្រារព្ធយកឯកៈទេសនៃកាយ មានខ្យល់ដង្ហើមចេញចូលជាដើម ឬប្រារព្ធសកលកាយ មាន សក់ រោម ក្រចក ធ្មេញជាដើម ជាអារម្មណ៍ ទឹងឃើញការអស់ទៅសូន្យទៅ ទឹងការកើតរលត់នៃកាយ ឬឃើញថា កាយជារបស់បដិកូល ឬឃើញថាគ្រាន់តែជាធាតុក្តី ឬឃើញថាគ្រាន់តែជាកាយក្តី ដូច្នេះឈ្មោះថាកាយានុបស្សនាសតិបដ្ឋាន ។ សតិប្រារព្ធយកវេទនា ៣ គឺ សុខ ទុក្ខ ឧបេក្ខា ណាមួយជាអារម្មណ៍ ហើយឃើញការអស់ទៅសូន្យទៅ ទឹងការកើតរលត់នៃវេទនា ឬឃើញថាគ្រាន់តែជាវេទនាប៉ុណ្ណោះ ដូច្នេះឈ្មោះថា វេទនានុបស្សនាសតិ-បដ្ឋាន ។ សតិប្រារព្ធយកចិត្តប្រកបដោយរាគៈត្រេកអរ ឬចិត្តប្រាសចាករាគៈជាដើម ណាមួយជាអារម្មណ៍ ឬឃើញការអស់ទៅសូន្យទៅ ទឹងការកើតរលត់នៃចិត្ត ឬឃើញថាគ្រាន់តែជាចិត្តប៉ុណ្ណោះ ដូច្នេះឈ្មោះថា ចិត្តានុបស្សនាសតិបដ្ឋាន ។ សតិប្រារព្ធយកធម៌គឺ ឧបាទាយរូប ឬសញ្ញា ឬសង្ខារក្ខន្ធ ដែលផុតចាក កាយ វេទនា ចិត្ត ណាមួយ ជាអារម្មណ៍ ទឹងឃើញការអស់ទៅសូន្យទៅ ទឹងការកើតរលត់នៃធម៌ ឬឃើញថាគ្រាន់តែជាធម៌ប៉ុណ្ណោះ ដូច្នេះឈ្មោះថា ធម្មានុបស្សនាសតិ-បដ្ឋាន ។

ក៏ក្នុងអង្គនៃបដិច្ចសមុប្បាទ១២ មានអវិជ្ជាជាដើម មាន ជរា មរណៈ ជាទីបំផុតនោះ អវិជ្ជា សង្ខារ អាយតនៈ ផស្ស តណ្ហា ឧបាទាន

កត ។ បាកាយរូបក្នុងរូប នឹងសញ្ញា វេទនា ឯកគ្គតា ជីវិតិន្ទ្រិយ៍ក្នុងនាម ឬក្នុងឧបបត្តិភព នឹងជាតិ ឈ្មោះថាជាធម៌ វិញ្ញាណនោះឈ្មោះថាជាចិត្ត វេទនាឈ្មោះថាជាវេទនា មហាភូតរូបក្នុងរូប ឬក្នុងឧបបត្តិភព នឹងជាតិ ឈ្មោះថាជាកាយ ព្រោះហេតុនោះព្រះដ៏មានព្រះភាគ កាលព្រះអង្គលើកអង្គនៃបដិច្ចសមុប្បាទ មានអវិជ្ជាជាដើម មួយ ៗ ឡើងពិចារណាវិនិច្ឆ័យដូចពោលមកហើយក្នុងកាលមុន ឈ្មោះថាព្រះអង្គតាំងព្រះហ្ឫទ័យផ្ដោះដោយប្រពៃក្នុងសតិបដ្ឋាន ៤ ។

ពោជ្ឈង្គ ប្រែថា អង្គជាហេតុនៃសេចក្ដីត្រាស់ដឹងច្បាស់នូវសច្ចា ពោជ្ឈង្គ ៧ នោះគឺ សតិ សេចក្ដីរលឹក បានដល់សតិបដ្ឋាននោះឯង, ធម្មវិចយ សេចក្ដីជ្រើសរើសរកនូវធម៌ថា នេះជាកុសល នេះជាអកុសលជាដើម បានដល់ប្រាជ្ញាដែលប្រារព្ធនូវអង្គនៃបដិច្ចសមុប្បាទ មានអវិជ្ជាជាដើម នឹងអារម្មណ៍នៃសតិបដ្ឋាន មានកាយជាដើមជាអារម្មណ៍ នឹងឃើញការអស់ទៅសូន្យទៅនៃអារម្មណ៍នោះឯង, វីរិយ សេចក្ដីព្យាយាមដ៏ខ្លាំងក្លា បានដល់ការលះអកុសលមាននីវរណៈ ៥ ជាដើម នឹងធ្វើកុសលមានសតិបញ្ញាជាដើមឲ្យកើតឡើង, បីតិ សេចក្ដីឆ្អែតចិត្តក្នុងកុសលធម៌ ដែលបានដោយសតិ នឹងធម្មវិចយៈនោះ, បស្សទ្ធិ សេចក្ដីស្ងប់កាយស្ងប់ចិត្ត បានដល់សេចក្ដីមិនក្រវល់ក្រវាយចិត្តចេតសិកក្នុងខណៈកុសលធម៌មានសតិ បញ្ញា នឹងសមាធិជាដើមកើតឡើង

www.budinst.gov.kh www.elibraryofcambodia.org

សមាធិ សេចក្ដីតាំងចិត្តក្នុងអារម្មណ៍តែមួយ. បានដល់ឯកគ្គតាអប្បនាឈាន ទាំង ៤ នោះ, ឧបេក្ខា សេចក្ដីសំឡឹងដោយមជ្ឈត្ត បានដល់ការមិនខ្វល់ខ្វាយក្នុងទំនឹងតាំងចិត្តឲ្យជាសមាធិទៀត គ្រាន់តែសំឡឹងនូវចិត្តដែលស្ងប់ហើយប៉ុណ្ណោះ ធម៌ទាំង ៧ នេះឈ្មោះថាពោជ្ឈង្គ ព្រោះហេតុនោះ ព្រះមានព្រះភាគទ្រង់ធ្វើដំណើរក្នុងវិជ្ជា ៣ ហើយដល់នូវសេចក្ដីត្រាស់ដឹងជាបច្ចាស់នូវសង្ខារ ក៏ឈ្មោះថាព្រះអង្គចំរើនពោជ្ឈង្គ-៧, ។ ឯពាក្យថាចំរើនពោជ្ឈង្គ ៧ នោះ ជាពាក្យពោលដោយនិរសេសកំណត់តាមពោជ្ឈង្គនិយម តែថាក្នុងខណៈអរហត្តមគ្គ អរហត្តផលកើតឡើងដល់ព្រះមានព្រះភាគនោះ. ព្រះអង្គដល់នូវសេចក្ដីត្រាស់ដឹងច្បាស់នូវសង្ខារនោះ ក៏ឈ្មោះថាព្រះអង្គចំរើនពោជ្ឈង្គបានដែរ ព្រោះបើពោជ្ឈង្គព្រះអង្គបានលះបង់ហើយ ដោយតតិយជ្ឈាន ។

១ ទៀត កិច្ចក្នុងព្រហ្មចរិយៈពោលដោយសង្ខេបមាន ២ គឺបហានៈនិងភាវនា ពាក្យថាព្រះមានព្រះភាគ លះនីវរណៈ ៥ នោះ ជាពាក្យសំដែងបហានកិច្ច ថាមិនលះតែនីវរណៈ ៥ ប៉ុណ្ណោះទេ បានលះទាំងអាសវៈ ៣ ដោយវិក្ខម្ភនបហានៈ សង្កត់ទុកដោយវិជ្ជា ២ ខាងដើម និងដោយសមុច្ឆេទបហានៈ លះដាច់ប្រាកដដោយវិជ្ជាទី ៣ ផង, ពាក្យថាព្រះមានព្រះភាគចំរើនពោជ្ឈង្គ ៧ នោះ ជាពាក្យសំដែងភាវនាកិច្ច

www.budinst.gov.kh www.elibraryofcambodia.org

ថាមិនមែនតែចំរើនពោជ្ឈង្គ ៧ ប៉ុណ្ណោះទេ ព្រះអង្គធ្វើនូវវិជ្ជា ៣ ឲ្យចំរើនឡើងផង ។

ពាក្យថា ព្រះមានព្រះភាគតាំងព្រះហឫទ័យក្នុងសតិប្បដ្ឋាន ៤ នោះ ជាពាក្យសំដែងបដិបទាផ្លូវបដិបត្តិ ដែលឲ្យកើតបហានៈ នឹងភាវនា ។ ព្រះមានព្រះភាគទ្រង់សំដែងសតិប្បដ្ឋាន ៤ មិនតឹងមិនធូរ តាមចរិតរបស់បុគ្គលនោះៗ គឺឯចរិតរបស់បុគ្គលពោលដោយសង្ខេបមាន ២ ពួកគឺ: តណ្ហាចរិត ១ ទិដ្ឋិចរិត ១ ។ តណ្ហាចរិតមាន ២ គឺ: គ្រោតគ្រាត ១ ល្អិត ១ ។ ទិដ្ឋិចរិតក៏មាន ២ គឺ: គ្រោតគ្រាត ១ ល្អិត ១ ។ កាយានុបស្សនាសតិប្បដ្ឋាន ជាទីសប្បាយរបស់បុគ្គលជាតណ្ហាចរិតគ្រោតគ្រាត, វេទនានុបស្សនាសតិប្បដ្ឋាន ជាទីសប្បាយរបស់បុគ្គលជាតណ្ហាចរិតល្អិត, ចិត្តានុបស្សនាសតិប្បដ្ឋាន ជាទីសប្បាយរបស់បុគ្គលជាទិដ្ឋិចរិត គ្រោតគ្រាត, ធម្មានុបស្សនាសតិប្បដ្ឋាន ជាទីសប្បាយរបស់បុគ្គលជាទិដ្ឋិចរិតល្អិត ។ ឯពាក្យថា លះនីវរណៈ ៥ តាំងព្រះហឫទ័យក្នុងសតិប្បដ្ឋាន ៤ នឹងចំរើនពោជ្ឈង្គ ៧ ធម៌ ៣ នេះ នីមួយៗ ក្នុងកាលជាបុព្វភាគ រមែងកើតមានក្នុងខណៈចិត្តផ្សេងៗ គ្នាខ្លះ តែក្នុងកាលមគ្គកើតឡើង រមែងកើតមានក្នុងខណៈចិត្តជាមួយគ្នា ដោយពាក្យថា ព្រះមានព្រះភាគលះនីវរណៈ ៥ តាំងព្រះហឫទ័យក្នុងសតិប្បដ្ឋាន ៤ ចំរើនពោជ្ឈង្គ ៧ ហើយត្រាស់ដឹងសម្មាសម្ពោធិដូច្នេះនោះ សំដែងថាព្រះមានព្រះភាគ កាលនៅជាព្រះ

www.budinst.gov.kh www.elibraryofcambodia.org

ពោធិសត្វនោះ ទ្រង់ប្រកបដោយទិដ្ឋិចរិតយ៉ាងល្អិត ទីងតាំងព្រះហឫទ័យក្នុងធម្មានុបស្សនាសតិប្បដ្ឋានដោយច្រើន ក្នុងកាលជាបុព្វភាគ ព្រោះកុសលធម៌នឹងអកុសល ២ នេះ ពោលដោយសង្ខេប ឈ្មោះថាធម៌ជាអារម្មណ៍នៃធម្មានុបស្សនាសតិប្បដ្ឋាន ។

ឯអកុសលធម៌លើកនីវរណៈ៥ ឡើងជាប្រធាន, ខាងកុសលធម៌លើកពោជ្ឈង្គ ៧ ឡើងជាប្រធាន ។ ១ ទៀត បុគ្គលមានប្រាជ្ញាច្រើន រមែងប្រកបដោយទិដ្ឋិចរិតយ៉ាងល្អិត ដូចក្នុងវិជ្ជាទី ៣ ពោលថា ព្រះមានព្រះភាគធ្វើអត្ថនៃបដិច្ចសមុប្បាទមានអវិជ្ជាជាដើម ឲ្យជាអារម្មណ៍នៃវិបស្សនាញាណនោះ សំដែងថាព្រះមានព្រះភាគ កាលនៅជាពោធិសត្វនោះ ព្រះអង្គប្រកបដោយលោកិយបញ្ញាច្រើន ជាទិដ្ឋិចរិតដ៏ល្អិត ទីងតាំងព្រះហឫទ័យក្នុងធម្មានុបស្សនាសតិប្បដ្ឋាន ដោយច្រើន ក្នុងកាលជាបុព្វភាគ ព្រោះអត្ថបដិច្ចសមុប្បាទមានអវិជ្ជាជាដើម ឈ្មោះថាធម៌ជាអារម្មណ៍នៃធម្មានុបស្សនាសតិប្បដ្ឋានដោយច្រើន ដែលសំដែងមកទាំងនេះ ដើម្បីនឹងឲ្យដឹងថា ពាក្យដែលសំដែងថា ព្រះមានព្រះភាគបានលះនីវរណៈ៥ តាំងព្រះហឫទ័យក្នុងសតិប្បដ្ឋាន ៤ ចំរើនពោជ្ឈង្គ ៧ ទើបបានត្រាស់ជាព្រះពុទ្ធ, ប្រកបនឹងពាក្យថា ព្រះពុទ្ធទ្រង់ធ្វើជំរះណីវរក្នុងវិជ្ជាទាំង ៣ ទើបបានត្រាស់ជាព្រះពុទ្ធ ពាក្យទាំង ២ នេះ ត្រូវគ្នាមិនខុសគ្នាឡើយ អ្នកប្រាជ្ញគប្បីដឹងថា ពាក្យដែលពណ៌នាអំពីការកើតនៃព្រះពុទ្ធរតនៈមក

www.budinst.gov.kh www.elibraryofcambodia.org

ដូច្នេះ ដើម្បីនឹងឲ្យដឹងសេចក្តីអធិប្បាយក្នុងបុព្វសិក្ខា ដែលសំដែងទុកដោយសង្ខេបថា ព្រះមានព្រះភាគនោះ ព្រះអង្គកើតហើយក្នុងពួកមនុស្សអរិយកៈ ក្នុងមជ្ឈិមប្រទេស ដោយព្រះជាតិជាក្សត្រិយ៍ ដោយគោត្រជាគោតមគោត្រ ជាបុត្រសក្យៈ ចេញចាកសក្យៈត្រកូលបួសហើយ ព្រះអង្គស្វែងរកកុសលសន្តិវរបទ ចំណែកធម៌ម្យ៉ាប់ទុក្ខជឺប្រសើរ មិនមានធម៌ដទៃលើសលប់ជាង ព្រះអង្គបានលះនីវរណៈ៥ ជាគ្រឿងសៅហ្មងចិត្ត ជារបស់ធ្វើប្រាជ្ញាឲ្យថយកម្លាំង ព្រះអង្គមានព្រះហឫទ័យតាំងស៊ប់ក្នុងសតិប្បដ្ឋានទាំង ៤ ញុំាងពោជ្ឈង្គទាំង ៧ ឲ្យកើត ឲ្យចំរើនឡើងដោយជាក់ច្បាស់ ហើយសម្រេចសម្មាសម្ពោធិញ្ញាណ បញ្ញាជាគ្រឿងគ្រាស់ដឹងឯងប្រពៃ ដ៏ប្រសើរមិនមាននរណាលើស ក្រោមដើមអស្សត្ថព្រឹក្សមហាពោធិដ្ឋាន ប្របាន្ទេរស្ទឹង នេរញ្ជរា ដូច្នេះ ។

សួ. ព្រះពុទ្ធមានគុណដូចម្តេច ?

វិ. ព្រះពុទ្ធមានគុណច្រើនជាអនេកពុំអាចនឹងពណ៌នាបាន ធំក្រៃលែងធំ ដូចផែនដីនិងផ្ទៃអាកាស មនុស្សយើងនឹងពណ៌នាគុណព្រះពុទ្ធនោះ បីដូចជាសត្វស្លាបតូចហើរក្នុងអាកាស មិនអាចនឹងពណ៌នាឲ្យអស់ឲ្យផុតបាន សូម្បីបុរាណាចារ្យលោកក៏បានពោលទុកថា សូម្បីព្រះពុទ្ធដូចគ្នា ពុំបានសំដែងរឿងដទៃឡើយ សំដែងតែគុណព្រះពុទ្ធផងគ្នាប៉ុណ្ណោះអស់មួយកប្ប កប្បនោះនឹងអស់ទៅទេក្នុងចន្លោះ គុណ

www.budinst.gov.kh www.elibraryofcambodia.org

របស់ព្រះតថាគត ក្នុងចន្លោះកាលដ៏យូរប៉ុណ្ណោះមិនអស់ឡើយ ។ ព្រោះហេតុនោះឯងទើបថាគុណព្រះពុទ្ធច្រើនក្រៃលែងច្រើន មិនអាចនឹងពណ៌នាបាន។ បើកាត់ឲ្យខ្លីមាន ៣ យ៉ាងគឺ ព្រះបញ្ញាគុណ ១ ព្រះវិសុទ្ធិគុណ ១ ព្រះករុណាគុណ ១ ប៉ុណ្ណោះឯងជាប្រធាននៃគុណទាំងពួង។ គុណទាំងពួងក៏ប្រជុំចុះក្នុងគុណទាំង ៣ នេះទាំងអស់ ។

គឺឯព្រះបញ្ញាគុណនោះ បានដល់សេចក្ដីដឹងច្បាស់នូវសង្ខារដូចពោលមកហើយ គឺ មគ្គញ្ញាណ ដែលជាទីតាំងនៃសព្វញ្ញុតញ្ញាណ មួយអន្លើដោយញាណដ៏សេស មាន ចតុវេសារជ្ជញ្ញាណ ទសពលញ្ញាណ អនាវរណញ្ញាណជាដើម ដែលកើតអំពីមគ្គញ្ញាណ ឲ្យសំរេចគុណដល់សត្វលោក គឺជ្រាបថា របស់នេះជាប្រយោជន៍ របស់នេះមិនជាប្រយោជន៍ដល់សត្វ ។ របស់ដែលមិនជាប្រយោជន៍ ទ្រង់ណែនាំឲ្យសត្វលះបង់ ។ របស់ដែលជាប្រយោជន៍ ទ្រង់ណែនាំឲ្យសត្វធ្វើឲ្យចំរើនឡើងដោយអនុសាសនី នេះឯងឈ្មោះថាព្រះបញ្ញាគុណ ។

ព្រះវិសុទ្ធិគុណនោះ គឺសេចក្ដីបរិសុទ្ធិ បានដល់ការលះកិលេសគ្រឿងសៅហ្មងជាចំស្រឡះព្រមទាំងវាសនា សូម្បីលោកធម៌ ៨ មកដល់ចំពោះព្រះភក្ត្រក៏មិនត្រេកអរមិនទោមនស្ស ព្រះហឫទ័យនៅតែថ្លាបរិសុទ្ធដដែល នេះឯងឈ្មោះថាព្រះវិសុទ្ធិគុណ ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះករុណាគុណនោះ បានដល់សេចក្ដីអាណិតប្រណីសត្វ ដែលក្ដៅដោយភ្លើងទុក្ខភ្លើងកិលេស ដែលនៅក្នុងសមុទ្រធំ ពោលគឺសង្សារ-វដ្ដ និងឲ្យសត្វរំលត់ភ្លើងទុក្ខភ្លើងកិលេសរួចចាកសង្សារវដ្ដ ជាគុណមានដល់ព្រះអង្គ កាលនៅជាព្រះពោធិសត្វ និងកាលត្រាស់ដឹងហើយនេះឯងឈ្មោះថា ព្រះករុណាគុណ ។ ថាបើព្រះពុទ្ធមានតែព្រះបញ្ញា-គុណម្យ៉ាង ព្រះវិសុទ្ធិគុណនិងព្រះករុណាគុណមិនមាន ព្រះអង្គក៏នឹងមិនបានទូន្មានសត្វលោក ។ សត្វលោកក៏នឹងមិនដឹងកុសលអកុសលផ្លូវសុគតិ ទុគ្គតិ និងសីល សមាធិ បញ្ញា ដែលជាផ្លូវព្រះនិព្វាន ឬមានតែព្រះបញ្ញាគុណនិងព្រះករុណាគុណប៉ុណ្ណោះ គង់នឹងទូន្មានសត្វដោយព្រះហឫទ័យបង្អោនទៅតាមស្រឡាញ់តាមស្អប់ ។ ការទេសនាប្រដៅក៏នឹងមិនបរិសុទ្ធ ព្រោះមិនមានព្រះវិសុទ្ធិគុណ។ បក្ខព្រះបញ្ញា-គុណ និងព្រះករុណាគុណ ។

មួយទៀត ថាបើមានតែព្រះវិសុទ្ធិគុណនិងព្រះករុណាគុណ ព្រះបញ្ញាគុណមិនមានសោត ក៏មិនអាចទូន្មានសត្វបាន ។ មួយទៀតបើមិនមានព្រះករុណាគុណ មានតែព្រះបញ្ញាគុណ និងព្រះវិសុទ្ធិគុណព្រះអង្គក៏មិនទ្រង់ទូន្មានសត្វ និងសោយតែឯកការសុខ នៅតែមួយព្រះអង្គឯង ឬរំលត់ខន្ធបរិនិព្វានឆាប់រហ័ស សត្វទាំងឡាយក៏មិនដឹងកុសលាកុសល ផ្លូវសុគតិ ទុគ្គតិ និងសីល សមាធិ បញ្ញា ផ្លូវព្រះ

www.budinst.gov.kh www.elibraryofcambodia.org

ចិញ្ចាន ៗ ព្រះករុណាគុណរបស់ព្រះអង្គកាលនៅជាពោធិសត្វនៅឡើយ ដូច្នេះ ព្រះអង្គនៅជាពោធិសត្វ មានឧបនិស្ស័យគួរដល់អរហត្តផល សាវកបារមីញាណ ហើយបានជួបនឹងព្រះពុទ្ធទាំងឡាយ មានព្រះពុទ្ធ ព្រះនាម ទីបង្ករ ជាដើម សូម្បីនឹងប្រាថ្នាឲ្យរួចបាកទុក្ខតែមួយព្រះអង្គ ហើយទទួលព្រះសទ្ធម្មទេសនា អំពីសំណាក់ព្រះពុទ្ធ ទ្រង់ព្រះនាម ទីបង្ករ នោះ ក៏នឹងបានសម្រេចអរហត្តផលសាវកបារមីញាណ រួច អំពីសង្សារទុក្ខតែមួយព្រះអង្គឯងទៅហើយ តែព្រះអង្គឃើញសត្វទាំងឡាយក្តៅក្រហាយ ដោយភ្លើងទុក្ខមានជាតិជាដើម ភ្លើងកិលេសមាន រាគៈជាដើម ហែលនៅក្នុងមហាសមុទ្រ គឺសង្សារវដ្ត ហើយ ព្រះអង្គមានព្រះហឫទ័យប្រណីប្រាថ្នារំលត់ភ្លើងទុក្ខ ភ្លើងកិលេសនៃសត្វផង ទាំងជួយស្រង់អំពីមហាសមុទ្រ គឺសង្សារវដ្ត ទើបលះបង់ព្រះ-អរហត្តផល ដែលព្រះអង្គគួរបានក្នុងសំណាក់ព្រះពុទ្ធ ទីបង្ករ នោះចេញ បង្អោនព្រះហឫទ័យទៅដើម្បីសព្វញ្ញុតញ្ញាណ ហើយបំពេញបារមីពុទ្ធការកធម៌គឺ ទាន សីល នេក្ខម្មៈ បញ្ញា វិរិយៈ ខន្តិ សច្ចៈ អធិដ្ឋាន មេត្តា ឧបេក្ខា នាំឲ្យទ្រង់សោយទុក្ខក្នុងសង្សារវដ្តជាអនេកទុក្ខ ក្នុងអនេកជាតិ ដូច្នេះឈ្មោះថា ព្រះករុណាគុណ ៗ ព្រះករុណា-គុណជាហេតុឲ្យសម្រេចព្រះបញ្ញាគុណ ព្រះវិសុទ្ធិគុណ ដល់ព្រះអង្គ

www.budinst.gov.kh www.elibraryofcambodia.org

នឹងអនុគ្រោះដល់សត្វដទៃផង ៗ ព្រះករុណាគុណដែលមានអំពីកាល ព្រះអង្គត្រាស់ដឹងហើយនោះ អនុគ្រោះដល់សត្វដទៃមួយចំពូក នឹងប្រកាសឲ្យសត្វដទៃដឹងគុណព្រះរតនត្រ័យ ព្រោះហេតុនោះ ទើបសំដែងថា គុណ ៣ ប្រការនេះ ជាប្រធាននៃគុណទាំងពួង ៗ គុណឯទៀតក៏ប្រជុំចុះក្នុងគុណទាំង ៣ នេះទាំងអស់ ៗ

មួយទៀត ព្រះពុទ្ធអង្គឧប្បត្តិឡើងក្នុងលោក ក៏ជាគុណដល់លោក ព្រោះហេតុព្រះអង្គបរិបូណ៌ព្រមដោយសម្បទា ៣ គឺ ហេតុសម្បទា ១ ផលសម្បទា ១ សត្តូបការសម្បទា ១ ៗ

ហេតុសម្បទា មានប៉ុន្មាន? មាន ២ គឺ មហាករុណាសមាយោគៈ១ ពោធិសម្ភារសម្ភរណៈ ១ ៗ

មហាករុណាសមាយោគៈ ដូចម្តេច? ការដែលព្រះអង្គប្រកបព្រមដោយករុណាប្រណីសត្វយ៉ាងធំ ដែលមានមកអំពីបាទមូលនៃព្រះពុទ្ធទ្រង់ព្រះនាម ទីបង្ករ នោះ ខ្ជាប់មាំមួនក្នុងសន្តានមិនបានប្រែប្រួលគ្រប់ភពដកបដល់បច្ចុប្បន្នជាតិនេះ ដូច្នេះឈ្មោះថា មហាករុណាសមាយោគៈ ៗ

ពោធិសម្ភារសម្ភរណៈ នោះដូចម្តេច? ការដែលព្រះអង្គសាងសន្សំបំពេញពោធិសម្ភារបារមីពុទ្ធការកធម៌គឺ ទាន សីល នេក្ខម្មៈ បញ្ញា វិរិយៈ ខន្តិ សច្ចៈ អធិដ្ឋាន មេត្តា ឧបេក្ខា ដែលសត្វដទៃកម្រនឹងធ្វើបានអស់កាលអន្លែងរាប់ដោយកោដិនៃកប្បជាច្រើននោះ ដូច្នេះឈ្មោះថា

www.budinst.gov.kh www.elibraryofcambodia.org

ពោធិសម្ភារសម្ភរណៈ ។ សម្បទា ២ នេះ ជាគុណគឺព្រះអង្គដល់ព្រម ជាហេតុខាងដើម គាប់ឲ្យសម្រេចផលសម្បទា និងសត្វូបការសម្បទា ខាងចុង ទើបឈ្មោះថា ហេតុសម្បទា ។

ផលសម្បទា មានប៉ុន្មាន? មាន ៤ គឺ ញាណសម្បទា ១ បហានសម្បទា ១ អានុភាវសម្បទា ១ រូបកាយសម្បទា ១ ។

ញាណសម្បទា នោះដូចម្តេច? មគ្គញាណព្រះបញ្ញាជ្រាបសច្ចារ ក្នុងមគ្គទាំង ៤ ដែលជាទីតាំងនៃសព្វញ្ញុតញ្ញាណ និងញាណដទៃ មាន ទសពលញ្ញាណ អនាវរណញ្ញាណ និងចតុវេសារជ្ជញ្ញាណជាដើម ដែលឲ្យសម្រេចតាមសេចក្តីប្រាថ្នា ក្នុងញេយ្យធម៌ទាំងពួងដោយស្រួល និងប្រកបដោយទូលាយទេសនាទូន្មានសត្វមិនទើសទាល់ ព្រះញាណ អម្បាលនេះ ឈ្មោះថាញាណសម្បទា ។

បហានសម្បទា នោះដូចម្តេច? ការដែលព្រះអង្គលះកិលេស ព្រមទាំងវាសនា ដាច់មិនមានសេសសល់ដល់តិចតួច មិនឲ្យកើតឡើង ទៀតជាធម្មតា នេះឯងឈ្មោះថា បហានសម្បទា ។

អានុភាវសម្បទា នោះដូចម្តេច? ការដែលព្រះអង្គជាអធិបតីក្នុង ហេតុ ដែលនឹងឲ្យសំរេចតាមសេចក្តីប្រាថ្នា គឺព្រះអង្គមានឥស្សរភាព និងសំដែងឫទ្ធិបាន តាមប្រាថ្នាគ្រប់ប្រការ ដូច្នេះឈ្មោះថា អានុភាវ-សម្បទា ។

www.budinst.gov.kh www.elibraryofcambodia.org

រូបកាយសម្បទា នោះដូចម្តេច? ការដែលព្រះអង្គបរិបូណ៌ដោយព្រះកាយ ដ៏ប្រដាប់ដោយទ្វត្តឹសមហាបុរិសលក្ខណៈ និងអសីត្យានុព្យញ្ជនៈ ដ៏គួរជាទីនយនាភិសេកស្រោចស្រង់ចក្ខុនៃសត្វលោកទាំងពួង ដូច្នេះឈ្មោះថា រូបកាយសម្បទា ។ សម្បទាទាំង ៤ នេះ ជាគុណគ៏ព្រះអង្គដល់ព្រម សំរេចមកអំពីហេតុសម្បទា ទើបឈ្មោះថាផលសម្បទា ។

សត្តូបការសម្បទា នោះមានប៉ុន្មាន? មាន ២ គឺ អាសយៈ ១ បយោគៈ ១ ។

អាសយៈ នោះដូចម្តេច? ការដែលព្រះអង្គមានព្រះរាជហឫទ័យត្រជាក់ដោយព្រះករុណា ប្រាថ្នាឲ្យសត្វទាំងឡាយបានប្រយោជន៍ជានិច្ច សូម្បីសត្វដែលធ្វើខុសដូចទេវទត្តជាដើម ព្រះអង្គក៏ទ្រង់ព្រះករុណា នេះ ១ មួយទៀត ការដែលព្រះអង្គឃើញសត្វដទៃ មានបញ្ចិន្ទ្រិយមិនទាន់ចាស់ក្លា ព្រះអង្គក៏ទ្រង់រង់ចាំ លុះតែសត្វមានបញ្ចិន្ទ្រិយចាស់ក្លា គួរនឹងត្រាស់ដឹងបាន ១ ពីរប្រការនេះឈ្មោះថា អាសយៈ ។

បយោគៈ នោះដូចម្តេច? ការដែលព្រះអង្គមានព្រះរាជហឫទ័យបរិសុទ្ធស្អាត មិនសំឡឹងឃើញតែអាមិស មានលាភនិងសក្ការៈជាដើម ទ្រង់សំដែងធម៌ដោយយានត្រៃមុខគឺ សីល សមាធិ បញ្ញា ដែលជាផ្លូវព្រះនិព្វាន ទ្រង់ចែកចូវធម៌នោះៗ ឲ្យកើតឡើងដល់សត្វដទៃ ដែលមានឧបនិស្ស័យត្រាស់ដឹងតាម សម្រេចលោកុត្តរផល នាំអត្តភាពឲ្យផុតចាក

www.budinst.gov.kh www.elibraryofcambodia.org

ទុក្ខទាំងពួងបាន ដូច្នេះឈ្មោះថា បយោគៈ ។ អាសយៈ និង បយោគៈ ទាំងពីរនេះ ជាគុណសម្បត្តិរបស់ព្រះអង្គ ជាឧបការៈដល់សត្វដទៃ ទើបឈ្មោះថាសត្តូបការសម្បទា នេះហើយ ព្រះពុទ្ធកើតឡើងក្នុងលោក ជាគុណដល់លោក ព្រោះព្រះអង្គបរិបូណ៌ព្រមដោយសម្បទា ៧ ដូចសំដែងមកនេះឯង ។

មួយទៀត អរហត្តាទិគុណនៃព្រះពុទ្ធ ដែលកើតឡើងហើយក្នុងលោក គឺជាកិត្តិគុណក្នុងលោក ប្រាកដដល់ទេវតា និងមនុស្សសត្វផងទាំងឡាយច្រើនជាងគុណទាំងពួង ព្រោះហេតុនោះ ក្នុងបុព្វសិក្ខា ទើបបានសំដែងថា ឯកិត្តិសព្ទដ៏ប្រពៃនៃព្រះមានព្រះភាគនោះ ខ្ចរខ្ចាយឡើងទៅដូច្នេះថា ឥតិបិ សោ ភគវា អរហំ ។ល។ ភគវាតិ ដូច្នេះ ។

គ្រានេះនឹងអធិប្បាយក្នុងបទថា អរហំ ជាដើម លោកប្រកបបទទុកក្នុងអនុស្សរណន័យ សំរាប់រឭកនូវគុណនៃព្រះពុទ្ធដូច្នេះថា សោ ភគវា ឥតិបិ អរហំ ។ល។ សោ ភគវា ឥតិបិ ភគវា ប្រែថា សោ ភគវា រីព្រះមានព្រះភាគនោះ អរហំ ទ្រង់ព្រះនាម អរហំ ឥតិបិ ពិតដូច្នេះ ប្រែយ៉ាងនេះគ្រប់ៗ បទដកបដល់បទថា សោ ភគវា ឥតិបិ ភគវា ។ អធិប្បាយថា សោ ភគវា រីព្រះមានព្រះភាគនោះ អរហំ ទ្រង់ព្រះនាម អរហំ ព្រោះព្រះអង្គឆ្ងាយចាកកិលេសផង ព្រោះព្រះអង្គជាបុគ្គលដ៏គួរផង ដ្បិតព្រះមានព្រះភាគនោះ

www.budinst.gov.kh www.elibraryofcambodia.org

ស្ថិតនៅហើយក្នុងទីឆ្ងាយក្រៃពេក ចាកកិលេសទាំងពួង ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា អរហំ ។ កិលេសនោះ ប្រែថា គ្រឿងធ្វើចិត្តឲ្យសៅហ្មង បានដល់ លោភៈ ទោសៈ មោហៈ និងមាយា សាថេយ្យៈ គឺការបិទបាំងទោសនិងអួតអាងជាដើម ដែលកើតឡើងហើយធ្វើចិត្តឲ្យសៅហ្មងកករល្អក់ជាអកុសលចិត្ត ។ ដែលសំដែងថា ព្រះអង្គឆ្ងាយចាកកិលេសនោះ មិនមែនកិលេសឃ្លាតព្រះអង្គទៅនៅទីណាមួយ ឬព្រះអង្គរត់ចោលកិលេសមកនោះទេ ព្រោះកិលេសជាអរូបធម៌ មិនមានរូបមិនមានខ្លួន ដែលព្រះអង្គឆ្ងាយចាកកិលេសនោះ គឺព្រះអង្គមិនមានកិលេសគ្រឿងសៅហ្មងក្នុងព្រះសន្តាន ព្រោះសព្វកិលេសព្រមទាំងវាសនា ព្រះអង្គកំចាត់បង់បានអស់ហើយ ដោយមគ្គញាណនោះៗ ។

ឯវាសនានោះ ប្រែថា ប្រក្រតី ដែលកិលេសអប់រំបានដល់អាការៈនៃកាយ-វាចា របស់ព្រះខីណាស្រពលោកមិនមានកិលេស ដូចអាការៈនៃមនុស្សមានកិលេសដែរ ។ វាសនានេះ មានតែព្រះសព្វញ្ញុពុទ្ធប៉ុណ្ណោះទេ ដែលកំចាត់បង់បានដាច់ស្រឡះ ព្រមទាំងកិលេស ដោយអរហត្តមគ្គ ។ ព្រះបច្ចេកពុទ្ធនិងព្រះអរហន្ត ដែលជាសាវកនឹងលះវាសនាមិនបាន លះបានតែកិលេសប៉ុណ្ណោះ ព្រោះហេតុនោះ ព្រះសារីបុត្តជាអគ្គសាវក កាលអំពីពុទ្ធជាតិលោកធ្លាប់កើតក្នុងកំណើតវានរ វាសនាអាការៈនៃវានរ ក៏ជាប់តាមមក សូម្បីជាព្រះអរហន្តហើយ

www.budinst.gov.kh www.elibraryofcambodia.org

វេលាដើរទៅដល់ថ្លុកអណ្តូង លោកក៏លោតរំលងដូចពានរ ។

មួយទៀតព្រះបិលិន្ទវច្ឆត្ថេរ កាលលោកជាបុថុជ្ជននៅឡើយ រមែងពោលថា វសលិៗ ជាភាសាពាល តាមនិយមក្នុងមគធភាសា សូម្បីលោកជាព្រះអរហន្តខីណាស្រពហើយ លោកក៏នៅពោលថា វសលិៗ ព្រោះវាសនា ព្រះអរហន្តសាវកលោកលះមិនបាន ។ ព្រោះហេតុនោះ ការលះកិលេសនៃព្រះពុទ្ធ មិនសាធារណៈទូទៅ ដល់ព្រះបច្ចេកពុទ្ធ នឹងព្រះអរហន្តសាវកឡើយ ។ ព្រះមានព្រះភាគ ហេតុតែព្រះអង្គ ឆ្ងាយចាកកិលេសដូច្នេះ ព្រះអង្គមានព្រះរាជហឫទ័យដ៏បរិសុទ្ធស្អាតមិនញាប់ញ័រដោយលោកធម៌ទាំង ៨ គឺ លាភ មិនមែនលាភ យស មិនមែនយស និន្ទា សរសើរ សុខ ទុក្ខ មកដល់ចំពោះព្រះអង្គ ព្រះអង្គក៏មិនមានអនុរោធ ពិរោធ រមែងព្រងើយប្រកបដោយឆឡង្គុបេក្ខា សូម្បីរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ ល្អក្រក់ដូចម្តេច ៗ មកខ្ទប់ចក្ខុ សោតៈ ឃានៈ ជីវ្ហា កាយ មនោទ្វារ ព្រះអង្គក៏មិនសោមនស្ស ទោមនស្ស រមែងសំឡឹងដោយឧប្បត្តិញ្ញាណុបេក្ខា ។

មួយទៀត ព្រះអង្គមានព្រះរាជហឫទ័យដូចផែនដី សូម្បីកាយព្រះអង្គមានគេលាបប្រឡាក់ដោយលំអិតខ្លឹមចន្ទន៍សុគន្ធជាតជារបស់ក្រអូប ព្រះកាយមានគេលាបប្រឡាក់ដោយទុគ្គន្ធជាតជារបស់ស្អុយមិនស្អាត ព្រះអង្គក៏មិនសោមនស្ស ទោមនស្ស ក្នុងសុគន្ធជាតនឹងទុគ្គន្ធជាតនោះ មាន

www.budinst.gov.kh www.elibraryofcambodia.org

ព្រះហឫទ័យដ៏ស្មើដូច្នេះ ព្រោះព្រះអង្គឆ្ងាយចាកកិលេស ។

មួយទៀត ព្រះមានព្រះភាគនោះ ទ្រង់ព្រះនាម អរហំ ព្រោះព្រះអង្គជាបុគ្គលគួរមែនពិត ដ្បិតព្រះមានព្រះភាគនោះ ព្រះអង្គគួរនឹងទ្រង់បញ្ញត្តនូវសិក្ខាបទដល់សាវក នឹងសំដែងធម៌ដល់សត្វលោក ព្រោះព្រះអង្គឆ្ងាយចាកកិលេសហើយ មិនទ្រង់បញ្ញត្តសិក្ខាបទ នឹងសំដែងធម៌តាមអំណាចកិលេស ព្រះអង្គប្រារព្ធយកធម៌នឹងវិន័យជាប្រធាន ហើយទ្រង់បញ្ញត្តនូវសិក្ខាបទនឹងសំដែងធម៌ ។

មួយទៀត ព្រះអង្គគួរក្នុង លាភ យស នឹងសេចក្ដីសរសើរ សេចក្ដីសុខ ព្រោះព្រះអង្គមិនមានសេចក្ដីត្រេកអរ ។

មួយទៀត ព្រះអង្គគួរនឹងទទួលនូវចតុប្បច្ច័យទាំង ៤ មានចីវរជាដើម នឹងសក្ការបូជាយ៉ាងវិសេស ដែលទេវតានឹងមនុស្សទាំងឡាយធ្វើ ព្រោះព្រះអង្គជាកំពូលទក្ខិណេយ្យបុគ្គល ធ្វើផលនៃទាននឹងសក្ការបូជាឲ្យបរិបូណ៌ឧត្តមវិសេស ព្រោះហេតុព្រះអង្គជាបុគ្គលគួរដល់សក្ការបូជាវិសេសនោះ បានជាកាលព្រះអង្គឧប្បត្តិឡើងហើយក្នុងលោក ទេវតានឹងមនុស្សទាំងឡាយ ដែលមានបញ្ញា បូជាព្រះអង្គដោយបច្ច័យ ៤ នឹងគ្រឿងសក្ការបូជាវិសេសផ្សេងៗ លុះព្រះអង្គរំលត់ខន្ធបរិនិព្វានហើយ សត្វលោកគឺ ទេវតានឹងមនុស្សក៏នៅធ្វើសក្ការបូជាព្រះអង្គ ដរាបដល់សព្វថ្ងៃនេះ ព្រោះហេតុដូច្នេះទើបឈ្មោះថា ព្រះអង្គជាបុគ្គលគួរ ។

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងបុព្វសិក្ខា ប្រែបទ អរហំ ថាព្រះអង្គគួរ មុននោះ តាមសទ្ទរូប ហើយប្រែថា ឆ្ងាយចាកកិលេសទុកជាខាងក្រោយ ក្នុងរឿងនេះប្រែថា ឆ្ងាយចាកកិលេសមុនតាមន័យក្នុងបាលី ដើម្បីសំដែងថា ព្រះអង្គគួរនោះ ព្រោះឆ្ងាយចាកកិលេស ។

ព្រះមានព្រះភាគទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ នោះ ព្រោះព្រះអង្គត្រាស់ដឹង គឺត្រាស់ដឹងដោយព្រះអង្គឯងនូវធម៌ទាំងពួង ដោយប្រពៃហើយ ។

អធិប្បាយសេចក្ដីទាំងពួង អ្នកប្រាជ្ញគប្បីដឹងដូចបទថា ពុទ្ធោ ដែលសំដែងខាងដើម ប្លែកតែក្នុងរឿងនេះ មានបទថា សម្មា សំ មួយអន្លើដោយធម៌ទាំងពួង ជួសសព្ទាទាំងពួងប៉ុណ្ណោះ សម្មា ប្រែថា ប្រពៃ អធិប្បាយថា សេចក្ដីត្រាស់ដឹងរបស់ព្រះអង្គប្រពៃពិត មិនបានវិបរិត ទំនងបន្ទោបង់កិលេសាសវៈចេញបាន ពាក្យថា សំ ប្រែថា ឯងនោះ អធិប្បាយថា ព្រះអង្គត្រាស់ដឹងដោយព្រះអង្គឯង មិនមានអ្នកណាក្នុងត្រៃភពនេះជាគ្រូ ។

ឯធម៌ទាំងពួងដែលព្រះអង្គត្រាស់ដឹងនោះគឺ អាយតនៈ វិញ្ញាណ-កាយ ផស្សៈ វេទនា សញ្ញា ចេតនា តណ្ហាកាយ វិតក្កៈ វិចារៈ មួយបទ ៦ ៗ ខន្ធ ៥ កសិណ ១០ អនុស្សតិ ១០ សញ្ញា ១០ អាការ មានសក់ រោម ជាដើម អាយតនៈ ១២ ធាតុ ១៨ ភព ៩

www.budinst.gov.kh www.elibraryofcambodia.org

ឈាន៤ អប្បមញ្ញា៤ អរូបសមាបត្តិ៤ អង្គបដិច្ចសមុប្បាទ មាន
អវិជ្ជាជាដើម មានជរាមរណៈជាទីបំផុត ដោយអនុលោម, បដិលោម
អម្បាលនេះឈ្មោះថា ធម៌ទាំងពួងផងសង្ខារទាំងពួង ព្រះអង្គជ្រាបធម៌
ទាំងពួងនេះគឺ ជ្រាបថាជាអភិញ្ញេយ្យធម៌ គប្បីដឹងច្បាស់ដោយបញ្ញា ៗ
គប្បីដឹងច្បាស់ តើដូចម្ដេច? ចំណែកធម៌ដែលជាបរិញ្ញេយ្យ គប្បីកំណត់
ដឹង គឺទុក្ខ ក៏កំណត់ដឹងថាជាទុក្ខ, ចំណែកធម៌ដែលជាបហាតព្វៈ គប្បី
លះបង់ គឺសមុទ័យ ក៏លះបាន, ចំណែកធម៌ដែលជាសច្ឆិកាតព្វៈ គប្បី
ធ្វើឲ្យច្បាស់ប្រាកដ គឺនិរោធ ក៏ធ្វើឲ្យជាក់ច្បាស់បាន, ចំណែកធម៌
ដែលជាភាវេតព្វៈ គប្បីធ្វើឲ្យកើតឲ្យចំរើនឡើង គឺមគ្គ ក៏ធ្វើឲ្យមានឲ្យចំ-
រើនឡើងបាន, ដូច្នេះឈ្មោះថាជ្រាបប្រពៃ ឱប្រកបក្នុងអាយតនៈ១
គឺចក្ខុល្មមជានិទស្សនៈ ( ឧទាហរណ៍ ) ចក្ខុនេះជារបស់គប្បីកំណត់ដឹង
ថាជាទុក្ខ ព្រោះមិនទៀង មិនមែនខ្លួន ទើបជាទុក្ខ ៗ តណ្ហាក្នុងភព
មុនដែលឲ្យកើតចក្ខុមកនេះ ជាសមុទ័យ ហេតុឲ្យកើតទុក្ខ តណ្ហានេះ
ជារបស់គប្បីលះ ៗ សេចក្ដីមិនបានប្រព្រឹត្តទៅនៃទុក្ខនិងសមុទ័យនោះ
ឈ្មោះថានិរោធ និរោធនេះ ជារបស់គប្បីធ្វើឲ្យជាក់ច្បាស់ ៗ សេចក្ដី
ដឹងច្បាស់នូវទុក្ខសមុទ័យនិរោធនោះ ឈ្មោះថាមគ្គ មគ្គនេះគប្បីធ្វើឲ្យមាន
ឲ្យចំរើនឡើង ៗ ព្រះមានព្រះភាគត្រាស់ដឹងដូច្នេះ ឈ្មោះថា
ដឹងប្រពៃ មិនមានអ្នកណាជាគ្រូព្រះអង្គ ព្រះអង្គត្រាស់ដឹងឯង

www.budinst.gov.kh www.elibraryofcambodia.org

ហេតុនោះ ទើបទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ត្រាស់ដឹងនូវធម៌ទាំងពួងដ៏ប្រពៃដោយព្រះអង្គឯង ។ អ្នកប្រាជ្ញគប្បីប្រកបក្នុងកាយគនៈក្រៅនោះ នឹងធម៌ដ៏សេសសល់ដូច្នេះគ្រប់ៗបទ ។ គឺឯបទថា អរហំ នោះ សំរេចដោយបហានៈ ការលះកិលេស ។ បទថា សម្មាសម្ពុទ្ធោ នោះ សម្រេចដោយការនា ការធ្វើបញ្ញាឲ្យចំរើនឡើង ។

ព្រះមានព្រះភាគទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ នោះ ព្រោះព្រះអង្គបរិបូណ៌ហើយដោយវិជ្ជានឹងចរណៈ វិជ្ជា ៣ នឹងវិជ្ជា ៨ នឹងចរណៈ ១៥ ។

វិជ្ជា ៣ នោះគឺ បុព្វេនិវាសានុស្សតិញ្ញាណ បញ្ញារលឹកតាម នូវខន្ធដែលព្រះអង្គនឹងសត្វដទៃនៅហើយក្នុងភពមុន ១ ចុតូបបាតញ្ញាណ បញ្ញាជ្រាបច្បាស់នូវចុតិនឹងបដិសន្ធិនៃសត្វ ១ អាសវក្ខយញ្ញាណ បញ្ញាជ្រាបច្បាស់នូវធម៌ជាគ្រឿងអស់អាសវៈ ១ ។ ៣ នេះឈ្មោះថាវិជ្ជា ស្បិតជាការដឹងច្បាស់ដោយវិសេស វិជ្ជា ៣ នេះបានពោលពិស្តារហើយក្នុងខាងដើម ។

វិជ្ជា ៨ នោះគឺៈ វិបស្សនាញាណ បញ្ញាឃើញកាយនេះជាគ្រាន់តែជាធាតុ ៦ មានវិញ្ញាណអាស្រ័យនៅ មិនមែនសត្វ មិនមែនបុគ្គល ១ មនោមយិទ្ធិ ឫទ្ធិសំរេចដោយចិត្តគឺ និម្មិតនូវរូបដទៃចេញចាកកាយនេះ ដូចទាញបណ្ដូលស្មៅយាប្លង ១ ឥទ្ធិវិធិ ការ

ថ្វែនឫទ្ធិសំរេចដោយអធិដ្ឋាន គឺមនុស្សម្នាក់ អធិដ្ឋានឲ្យជាមនុស្សច្រើន មនុស្សច្រើន អធិដ្ឋានឲ្យជាមនុស្សម្នាក់ជាដើម ១ ទិព្វសោតញាណ ទិព្វសោត ឮសំឡេងមនុស្សនិងសំឡេងទិព្វ ក្នុងទីឆ្ងាយ ឬទីជិត ១ ចេតោបរិយញ្ញាណ កំណត់ដឹងចិត្តនៃអ្នកដទៃថា ជាចិត្តប្រកបដោយរាគៈ និងប្រាសចាករាគៈជាដើម ១ មួយអន្លើដោយវិជ្ជា ៣ ដូចសំដែងហើយនោះទើបរួមជា ៨ ៗ ទាំង ៨ នេះ ឈ្មោះថាវិជ្ជា ព្រោះជាការដឹងវិសេសដឹងផ្សេង ៗ ត្រាស់ដឹងច្បាស់ ៗ វិជ្ជា ៨ នេះ ពណ៌នាមកដោយសង្ខេប ៗ វិជ្ជា ៣ នុះ ពណ៌នាមកដោយពិស្តារ ៗ

ចរណៈមាន ១៥ គឺ សីលសំវរៈ សេចក្តីសង្រួមកាយវាចា ១ ឥន្ទ្រិយសំវរៈ សេចក្តីសង្រួមឥន្ទ្រិយទាំង ៦ មានចក្ខុន្ទ្រិយ ជាដើម មិនឲ្យអភិជ្ឈាទោមនស្សបាបធម៌កើតឡើងបាន ១ ភោជនេមត្តញ្ញុតា សេចក្តីជាអ្នកដឹងប្រមាណក្នុងភោជន ១ ជាគរិយានុយោគៈ សេចក្តីព្យាយាមជារបស់មនុស្សអ្នកភ្ញាក់ ១ មួយអន្លើដោយសប្បុរិសធម៌ ៧ គឺ សទ្ធា សេចក្តីជឿចំពោះរបស់ដែលគួរជឿ ១ ហិរិ សេចក្តីខ្មាសចំពោះទុច្ចរិតបាបធម៌ ១ ឱត្តប្បៈ សេចក្តីតក់ស្លុតចំពោះទុច្ចរិតបាបធម៌ ១ ពាហុសច្ចៈ សេចក្តីជាអ្នកចេះដឹងច្រើន ១ វិរិយៈ សេចក្តីព្យាយាម ១ សតិ សេចក្តីរឭក ១ បញ្ញា សេចក្តីដឹងទូទៅ ១ មួយអន្លើដោយឈាន ៤ គឺ បឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន

www.budinst.gov.kh www.elibraryofcambodia.org

ចតុត្ថជ្ឈាន ធម៌មានប្រភេទ ១៥ នេះ ឈ្មោះថា ចរណៈ ព្រោះជាធម៌សំរាប់បុគ្គលសញ្ចារទៅកាន់ទិសដែលមិនធ្លាប់ទៅ គឺព្រះនិព្វាន ។ វិជ្ជា ៣ វិជ្ជា ៨ និងចរណៈ ១៥ នេះ រមែងមានបរិបូណ៌ មិនខ្វះក្នុងព្រះមានព្រះភាគ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រះអង្គបរិបូណ៌ហើយដោយវិជ្ជា និងចរណៈ ។ វិជ្ជាសម្បទា ការបរិបូរណ៍ដោយវិជ្ជានៃព្រះមានព្រះភាគនោះ រមែងធ្វើនូវសព្វញ្ញុតា គឺភាពនៃព្រះអង្គជាសព្វញ្ញូឲ្យបរិបូណ៌ ។ ចរណសម្បទា ការបរិបូរណ៍ដោយចរណៈ រមែងធ្វើនូវមហាករុណិកតាគឺភាពនៃព្រះអង្គដែលមានករុណាធំឲ្យបរិបូណ៌បាន ព្រះអង្គគង់ជ្រាបនូវវត្ថុដែលជាប្រយោជន៍ និងមិនមែនប្រយោជន៍ នៃសព្វសត្វ ដោយសព្វញ្ញុតា និងញុំាងសត្វឲ្យវៀរចាកវត្ថុដែលមិនជាប្រយោជន៍ ហើយប្រកបសត្វក្នុងវត្ថុដែលជាប្រយោជន៍ ដោយមហាករុណិកតា ទាំងនេះព្រោះព្រះអង្គបរិបូណ៌ហើយ ដោយវិជ្ជានិងចរណៈ ព្រោះហេតុនោះ សាវកនៃព្រះមានព្រះភាគ ទើបឈ្មោះថា សុប្បដិបន្នោ លោកបដិបត្តិល្អហើយ មិនជា ទុប្បដិបន្នោ លោកបដិបត្តិអាក្រក់ ដូចសាវកនៃគ្រូដែលវិបត្តិចាកវិជ្ជានិងចរណៈ ជា អត្តន្តបៈ អ្នកធ្វើខ្លួនឲ្យក្តៅក្រហាយទទេជាដើម ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះមានព្រះភាគទ្រង់ព្រះនាមថា សុគតោ នោះ ព្រោះព្រះអង្គយាងទៅកាន់ទីដ៏ប្រពៃ គឺព្រះនិព្វានដ៏ជាអម្រឹតស្ថាន ។

មួយទៀត ព្រះអង្គទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គយាងទៅហើយដោយប្រពៃពិត ដ្បិតកិលេសណា ដែលព្រះអង្គលះហើយ ដោយសោតាបត្តិមគ្គ ព្រះអង្គមិនត្រឡប់មកកាន់កិលេសនោះទៀត កិលេសណា ៗ ដែលព្រះអង្គលះហើយ ដោយសកទាគាមិមគ្គ អនាគាមិមគ្គ ឬអរហត្តមគ្គក្ដី ព្រះអង្គ ក៏មិនត្រឡប់មកកាន់កិលេសនោះ ៗ ទៀត ព្រោះហេតុនោះ ព្រះអង្គទើបទ្រង់ព្រះនាមថា សុគតោ ព្រះអង្គយាងទៅហើយដោយប្រពៃ ។

មួយទៀត សុគតោ ប្រែថា ព្រះអង្គយាងទៅហើយប្រពៃមែនពិត ព្រោះព្រះអង្គទៅហើយចាកធម៌ណា ធម៌នោះមិនត្រឡប់មកកាន់ព្រះអង្គបានទៀត កាលព្រះអង្គដល់ហើយនូវទីណា ទីនោះមិនកំរើក ធម៌ដែលព្រះអង្គលះបង់ទៅហើយនោះគឺ កិលេសដែលព្រះអង្គលះហើយដោយមគ្គនោះ ៗ កិលេសនោះមិនត្រឡប់មកកើតក្នុងព្រះហ្ឫទ័យបានទៀត ទីដែលព្រះអង្គដល់ហើយនោះ គឺព្រះនិព្វាន ព្រះនិព្វានជាអកុប្បធម៌ មិនកំរើកត្រឡប់ជាសកតាទិធម៌ដែលប្រកបដោយកតៈ នឹងត្រឡប់ជាជាតិធម៌ ជរាធម៌ជាដើមឡើយ ព្រះអង្គទៅចាកកិលេស ដល់ហើយនូវព្រះនិព្វាន ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា សុគតោ

www.budinst.gov.kh www.elibraryofcambodia.org

ទ្រង់យាងទៅហើយដោយប្រពៃ

ព្រះមានព្រះភាគទ្រង់ព្រះនាមថា លោកវិទូ នោះ ព្រោះព្រះអង្គទ្រង់ជ្រាបច្បាស់នូវលោកដោយប្រការទាំងពួង ។ ព្រោះថា ព្រះមានព្រះភាគនោះ ជ្រាបច្បាស់ហើយនូវទុក្ខាទិលោក ដោយប្រការទាំងពួង គឺជ្រាបសភាវៈជារបស់នៃលោកគឺទុក្ខ, សមុទ័យ ហេតុជាដែនកើតនៃលោក គឺតណ្ហា, និរោធ ធម៌ជាទីរលត់នៃលោកគឺព្រះនិព្វាន, និងនិរោធុ-បាយ ធម៌ជាឧបាយរំលត់លោក គឺមគ្គ សមដោយព្រះពុទ្ធត្រាស់ចំពោះរោហិតស្សទេវបុត្រថា "ក្នុងទីបំផុតលោកណា ដែលសត្វមិនកើត មិនចាស់ មិនស្លាប់ មិនច្យុត មិនឧប្បត្តិទេ តថាគតមិនពោលនូវទីបំផុតលោកនោះថា ជាទីដែលបុគ្គលគប្បីដឹង គប្បីឃើញ . គប្បីដល់ដោយដំណើរទៅជាប្រក្រតី មានទៅដោយបាទាជាដើមឡើយ ។ បើតថាគតមិនទាន់ដល់នូវទីបំផុតនៃលោកទេ រមែងមិនពោលនូវកិរិយាធ្វើនូវទីបំផុតនៃទុក្ខឡើយ ។ មួយទៀត តថាគត រមែងបញ្ញត្តនូវលោក, លោកសមុទ័យ ហេតុជាដែនកើតនៃលោក, លោកនិរោធ ទីដែលជាទីរលត់នៃលោក, និងលោកនិរោធគាមិនីបដិបទា ផ្លូវដំណើរទៅដល់ទីរលត់លោក ទាំង ៤ នេះ នៅក្នុងកឡេវរសរីរកាយប្រវែងមួយព្យាម ដែលប្រកបដោយសញ្ញានិងចិត្តនេះឯង មិនមែនបញ្ញត្តក្នុងទីដទៃទេ" ។ ព្រះពុទ្ធទ្រង់ជ្រាបលោក ដោយប្រការទាំងពួងដូច្នេះ ទើបទ្រង់ព្រះនាមថា លោកវិទូ

www.budinst.gov.kh www.elibraryofcambodia.org

ព្រះអង្គជ្រាបច្បាស់នូវលោក ន័យដូច្នេះ បានក្នុងសង្ខារលោក ។

មួយទៀត សូម្បីសត្វលោក ក៏ព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់ ។ ជ្រាបច្បាស់នោះដូចម្តេច? ព្រះអង្គជ្រាបច្បាស់ដូច្នេះថា សត្វលោកគឺទេវតា មនុស្ស ពួកនេះ មានអាសយៈ ធម៌ជាទីមកដេកត្រាំក្នុងចិត្ត ដូច្នេះ គឺពួកខ្លះជាសស្សតាសយៈ ពួកខ្លះជាឧច្ឆេទាសយៈ ពួកខ្លះជាអនុលោមិកខន្ត្យាសយៈ ពួកខ្លះជាយថាភូតញ្ញាណាសយៈ ទាំងជ្រាបច្បាស់ថា សត្វលោកចំពួកនេះ មានអនុស័យ គឺកិលេសដេកត្រាំក្នុងខន្ធសន្តាន មានរាគានុស័យជាដើម, ជ្រាបថា សត្វចំពួកនេះ ប្រកបដោយសុចរិតនិងទុច្ចរិត ឬជ្រាបចរិតទាំង ៦ នៃសត្វក៏, ជ្រាបថា សត្វនេះមាន អធិមុត្តិ គឺអធ្យាស្រ័យទន់ទាប និងឧត្តមដូច្នេះក្តី នឹងជ្រាបថា សត្វនេះមានឥន្ទ្រិយ គឺសទ្ធាជាដើមដ៏ចាស់ក្លា សត្វពួកនេះមានឥន្ទ្រិយដ៏ទន់ខ្សោយ សត្វពួកនេះមានអាការៈដ៏ល្អ គឺជាវិវដ្តាសយៈ សត្វពួកនេះមានអាការៈដ៏អាក្រក់គឺជាវដ្តាសយៈ សត្វពួកនេះគប្បីឲ្យដឹងបានដោយងាយ ព្រោះមានសទ្ធានិងបញ្ញា សត្វពួកនេះគប្បីឲ្យដឹងបានដោយក្រ ព្រោះមិនមានសទ្ធានិងបញ្ញា សត្វពួកនេះជាភព្វសត្តសត្វគួរនឹងត្រាស់ដឹង ព្រោះប្រាសចាកអាវរណធម៌ គ្រឿងឃាត់ គឺកម្ម កិលេសនិងវិបាក សត្វពួកនេះជាអភព្វសត្ត សត្វមិនគួរត្រាស់ដឹង ព្រោះប្រកបដោយអាវរណធម៌ មានកម្មជាដើម ព្រះអង្គជ្រាបច្បាស់នូវសត្វលោក ដូច្នេះឯង ទើបទ្រង់

www.budinst.gov.kh www.elibraryofcambodia.org

ព្រះនាមថា លោកវិទូ ព្រោះជ្រាបច្បាស់នូវលោក ។

មួយទៀត លោកដោយប្រភេទមាន ៣ គឺ សង្ខារលោក បានដល់នាមរូបជាដើម ១ សត្វលោក បានដល់ទេវតានិងមនុស្សជាដើម ១ ឱកាសលោក បានដល់ផែនដីនិងអាកាសជាដើម ១ ព្រះអង្គទ្រង់ជ្រាបនូវលោកទាំង ៣ នេះ ថាជាបលុជ្ជនធម៌ មានការធ្លុះធ្លាយបាក់បែក មិនឋិតថេរជាធម្មតា ព្រោះហេតុនោះ ព្រះអង្គទើបទ្រង់ព្រះនាមថា លោកវិទូ ទ្រង់ជ្រាបច្បាស់នូវលោក ។

ព្រះមានព្រះភាគទ្រង់ព្រះនាមថា អនុត្តរោ នោះ ព្រោះមិនមានអ្នកណាក្នុងត្រៃភពប្រសើរជាងព្រះអង្គដោយគុណ ព្រោះថា ព្រះមានព្រះភាគនោះ គ្របសង្កត់នូវលោកទាំងពួងដោយគុណគឺ សីល សមាធិ បញ្ញា វិមុត្តិ និង វិមុត្តិញាណទស្សនៈ ។ ព្រះអង្គមិនមានបុគ្គលស្មើ រមែងស្មើដោយព្រះពុទ្ធដែលរកបុគ្គលស្មើគ្មាន ព្រះអង្គមិនមានបុគ្គលប្រៀបបាន មិនមានបុគ្គលប្រៀបដោយគុណ មានសីលជាដើម ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា អនុត្តរោ ជាបុគ្គលមិនមានអ្នកណាប្រសើរជាង បណ្ឌិតគប្បីសំដែងសេចក្តីដោយ អគ្គប្បសាទ-សូត្រ ជាដើម ។

ព្រះមានព្រះភាគទ្រង់ព្រះនាមថា បុរិសទម្មសារថិ នោះប្រែថា ព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មាន ព្រោះថា ព្រះមានព្រះភាគនោះ

www.budinst.gov.kh www.elibraryofcambodia.org

ព្រមនឹងទូន្មានពួកទេវតា មនុស្សនិងអមនុស្ស ដែលជាបុរសគួរទូន្មាននោះ ដោយវិធីឧបាយដ៏វិចិត្រផ្សេងៗ ។ សត្វពួកណា គាប់ចិត្តធម៌ពីរោះ ព្រះអង្គក៏ទ្រង់ទូន្មានដោយធម៌ពីរោះ គឺសំដែងសុចរិត ៣ មានកាយ-សុចរិតជាដើម និងសំដែងផលនៃសុចរិត ឈ្មោះថាជាធម៌ពីរោះឲ្យសត្វនោះត្រេកអរប្រព្រឹត្ត ។ សត្វពួកណាគាប់ចិត្តធម៌គ្រោតគ្រាត ព្រះអង្គក៏ទ្រង់ទូន្មានដោយធម៌គ្រោតគ្រាត គឺប្រកាសទុច្ចរិត ៣ និងផលនៃទុច្ចរិតនោះឲ្យសត្វខ្លាចលះបង់ ។ សត្វពួកណា គាប់ចិត្តទាំងធម៌ពីរោះទាំងធម៌គ្រោតគ្រាត ព្រះអង្គក៏ទ្រង់ទូន្មានដោយធម៌ទាំងពីរោះទាំងគ្រោតគ្រាត គឺទ្រង់សំដែងនូវសុចរិតនិងទុច្ចរិត ព្រមទាំងផលនៃសុចរិតនិងទុច្ចរិតនោះ ឲ្យសត្វលះបង់នូវពុតកំណាចគឺទុច្ចរិត ហើយឋិតនៅក្នុងកុសល-សុចរិត ។ សត្វពួកណាមិនទទួលវិនយឧបាយ វិធីទូន្មានដ៏វិចិត្ររបស់ព្រះអង្គដូច្នេះ សត្វពួកនោះ ឈ្មោះថា អបុរិសទម្មោ មិនមែនជាបុរសគួរទូន្មាន ។ បុរសមិនគួរទូន្មាន ព្រះអង្គក៏មិនទ្រង់ទូន្មាន បុរសពួកនោះឈ្មោះថា គឺព្រះមានព្រះភាគលះបង់ហើយ ដោយមិនទ្រង់ទូន្មានប្រដៅ បុរសពួកនោះ ឈ្មោះថា ស្លាប់ចាកកុសលធម៌និងសេចក្តីសុខក្នុងលោកទាំងពីរ ។ ព្រះអង្គឈ្លាសក្នុងឧបាយទូន្មានសត្វលោក ដូចនាយហត្ថាចារ្យ ឬអស្សាចារ្យ ដែលជាអ្នកឈ្លាសទូន្មានគជសារ និងអស្សតរជាសត្វគួរទូន្មាន ឲ្យលះបង់ពុតកំណាចដូច្នេះ ទើបព្រះអង្គទ្រង់

www.budinst.gov.kh www.elibraryofcambodia.org

ព្រះនាមថា បុរិសទម្មសារថិ ជាអ្នកទូន្មាននូវបុរសដែលគួរទូន្មាន ៗ

មួយទៀត អនុត្តរោ បុរិសទម្មសារថិ ២ នេះ ជាព្រះនាមថា មួយគ្នា ប្រែថា ព្រះមានព្រះភាគទ្រង់ទូន្មានបុរសដែលគួរទូន្មាន មិនមានអ្នកណាលើស ដូចជាគជសារនឹងអស្សតរ ដែលនាយហត្ថាចារ្យនឹងអស្សា-ចារ្យ ដ៏ឈ្លាស ក្នុងឧបាយទូន្មានដ៏ស្ទាត់ជំនាញដោយប្រពៃ នាយហត្ថាចារ្យ អស្សាចារ្យ ប្រាថ្នានឹងឲ្យស្ទុះទៅទិសណា ក៏ស្ទុះទៅទិសនោះបានតែក្នុងមួយរាវៈ ៗ ចំណែកខាងបុរសដែលព្រះអង្គទូន្មានហើយនោះ សូម្បីអង្គុយនៅដោយបល្ល័ង្កតែមួយ ក៏រមែងស្ទុះទៅកាន់ទិសទាំង ៨ គឺ សមាបត្តិ ៨ បាន ព្រោះហេតុនោះ ទើបព្រះអង្គទ្រង់ព្រះនាមថា អនុត្តរោ បុរិសទម្មសារថិ ៗ

មួយទៀត ព្រះអង្គទ្រង់ទូន្មានទេវតានឹងមនុស្ស ជាបុរសដែលគួរទូន្មានដោយអនុសាសនីបាដិហារ្យ ជាឧបាយទូន្មានមិនកំហែងដោយអាជ្ញាឲ្យសត្វលោយទុក្ខវេទនា ដូចនាយហត្ថាចារ្យ អស្សាចារ្យ នឹងមនុស្សជាឥស្សរាធិបតី ទូន្មាននូវគជសារ អស្សតរ នឹងជនទៅក្នុងអំណាចនៃខ្លួន ដោយពាក្យជេរនឹងអាជ្ញា គឺចាប់ចងប្រហារដោយគ្រឿងប្រហារផ្សេង ១ ៗ សូម្បីព្រះអង្គទូន្មានសត្វពួកខ្លះ ដោយឥទ្ធិបាដិហារ្យក្តី អាទេសនាបាដិហារ្យក្តី ក៏ជាឧបាយប្រោសប្រាណឲ្យអស់ពុតកំណាចមានះ រឹងរូសចេញ ហើយក៏ទ្រង់ទូន្មានដោយអនុសាសនីបាដិហារ្យ

www.budinst.gov.kh www.elibraryofcambodia.org

គឺប្រទានទេសនាពាក្យប្រដៅឲ្យសត្វបដិបត្តិតាម លះពុតកំណាច គឺទុច្ចរិតសង្កិលេសធម៌ ដោយមគ្គការនានោះ ៗ ។ សត្វនោះមិនត្រឡប់វិលមកប្រកបដោយទុច្ចរិតសង្កិលេសធម៌ ដែលជាពុតកំណាចទៀតឡើយ ដូចគជសារនឹងអស្សតរ ដែលនាយទូន្មានហើយ ហើយត្រឡប់មានពុតកំណាចទៀតម្ដង ៗ ព្រោះហេតុនោះ ព្រះអង្គទើបទ្រង់ព្រះនាមថា អនុត្តរោ បុរិសទម្មសារថិ ព្រះអង្គទ្រង់ទូន្មានបុរសដែលគួរទូន្មានពុំមានអ្នកណាលើស ។

ព្រះមានព្រះភាគទ្រង់ព្រះនាមថា សត្ថា ទេវមនុស្សានំ ប្រែថា ព្រះអង្គជាសាស្ដានៃទេវតា នឹងមនុស្សសត្វទាំងឡាយ ។ មែនពិតព្រះអង្គទ្រង់ប្រដៅដោយប្រយោជន៍ ៣.គឺ ទិដ្ឋធម្មិកត្ថៈ ប្រយោជន៍ ក្នុងបច្ចុប្បន្ន សម្បរាយិកត្ថៈ ប្រយោជន៍ក្នុងភពមុខ និងបរមត្ថៈ ប្រយោជន៍យ៉ាងក្រៃលែងគឺព្រះនិព្វាន តាមគួរដល់អធ្យាស្រ័យរបស់វេនេយ្យ-សត្វ ។ ព្រះអង្គទ្រង់ទូន្មានដោយទិដ្ឋធម្មិកត្ថៈនោះ ដូចជាព្រះអង្គទ្រង់ប្រដៅ ទីឃជាណុកោឡិយបុត្រ នឹងឧជ្ជយព្រាហ្មណ៍ ដោយសម្បទា ៤ គឺ ឧដ្ឋានសម្បទា ការខំស្វាហាប់ប្រកបកិច្ចការដែលជានាទីដ៏គួរដែលខ្លួនត្រូវធ្វើនិងស្វែងរកទ្រព្យដោយខំប្រឹងប្រែង ។ អារក្ខ-សម្បទា ការឃ្លាំសរក្សាកិច្ចការងារដែលខ្លួនប្រកបធ្វើ នឹងទ្រព្យដែលស្វែងរកបានមកដោយសេចក្ដីខំស្វាហាប់នោះ មិនឲ្យវិនាសសាបសូន្យ ។

www.budinst.gov.kh www.elibraryofcambodia.org

**សមជីវិតា** ការចិញ្ចឹមជីវិតតាមសមគួរដល់កម្លាំងទ្រព្យដែលមានច្រើននិងតិច ។ **កល្យាណមិត្តតា** ភាពជាអ្នកមានកល្យាណមិត្រ ដូច្នេះក៏មាន ។ ទ្រង់បន្ទូលឲ្យដឹងស្គាល់អបាយមុខ ឧបាយដែលឲ្យវិនាសសាបសូន្យ ៤ ប្រការ គឺជាអ្នកលេងស្រី ១ ជាអ្នកលេងសុរា ១ ជាអ្នកលេងល្បែងភ្នាល់ ១ ជាអ្នកគប់មិត្រអាក្រក់ ១ និងទ្រង់ចែកអបាយមុខ ៦ ទៀតគឺ ការសេពសុរា ១ ដើរលេងក្នុងវេលាយប់ ១ ដើរមើលមហោស្រព ១ លេងល្បែងភ្នាល់ ១ គប់មិត្រអាក្រក់ ១ ខ្ជិលច្រអូស ១ ឲ្យសិង្គាលមាណពគហបតិបុត្រដឹង ដើម្បីលះបង់ ដូច្នេះឈ្មោះថាទូន្មានដោយទិដ្ឋធម្មិកត្ថៈ ។

ឯព្រះអង្គទ្រង់ទូន្មានដោយសម្បរាយិកត្ថៈនោះ ដូចទូន្មានឲ្យជា-ណុះកោឡិយបុត្រជាដើម ដោយសម្បទា ៤ គឺ សទ្ធា សីលៈ ចាគៈ បញ្ញា ។

មួយទៀត ព្រះអង្គទ្រង់សំដែង មត្តេយ្យតា បដិបត្តិប្រពៃចំពោះមាតា បេត្តេយ្យតា បដិបត្តិប្រពៃចំពោះបិតា សាមញ្ញតា បដិបត្តិប្រពៃចំពោះសមណៈ ដែលជាអ្នកបដិបត្តិរម្ងាប់ កាយ វាចា ចិត្ត ចាកបាប ព្រហ្មញ្ញតា បដិបត្តិប្រពៃចំពោះព្រហ្ម ដែលជាអ្នកបណ្ដេតបង់នូវបាបក្នុងត្រៃទ្វារ ដែលបាននាមតាមអរិយវោហារថា ព្រាហ្មណ៍ **អបចាយនៈ** ការប្រព្រឹត្តិឱនលំទោនដល់បុគ្គលគួរគោរព និងសំដែង

www.budinst.gov.kh www.elibraryofcambodia.org

ញាតិសង្គហៈ សេចក្ដីសង្គ្រោះញាតិ បុត្តទារសង្គហៈ សេចក្ដីសង្គ្រោះបុត្រភរិយា ទាំងបុញ្ញកិរិយាវត្ថុទាំង ៣ គឺ ទាន ការឲ្យ ១ សីល កិរិយាសង្រួម កាយ វាចា ឲ្យហាត់ចត់ ប្រាសចាកទោស ១ ភាវនា កិរិយាធ្វើកុសលឲ្យកើតមានក្នុងចិត្ត ១ ។ ទុច្ចរិតប្បហានៈ កិរិយាលះសេចក្ដីប្រព្រឹត្តអាក្រក់ សុចរិតសមាទានៈ ការសមាទានខ្ជាប់សុចរិតជាដើម ដោយន័យដ៏វិចិត្រផ្សេងៗ ដែលមានមកក្នុងសុត្តន្តប្រទេសនោះៗ ដូច្នេះឈ្មោះថា ទូន្មានដោយសម្បរាយិកត្ថៈ ។

ព្រះអង្គទ្រង់សំដែងនូវត្រៃសិក្ខាគឺ សីល សមាធិ បញ្ញា និងសំដែងបដិបទាផ្សេងៗ ដែលជាឧបការៈដល់ត្រៃសិក្ខា ជាផ្លូវដែលសត្វដំណើរទៅកាន់ព្រះនិព្វានជាទីក្សេមចាកទុក្ខ ដោយអនេកន័យដ៏វិចិត្រផ្សេង ៗ ដែលមានមកក្នុងគម្ពីរបរិយត្តិធម៌នោះៗ ដូច្នេះឈ្មោះថា ទ្រង់ទូន្មានដោយបរមត្ថៈ ។ ព្រោះតែព្រះអង្គប្រដៅសត្វដោយប្រយោជន៍ ៣ ដូច្នេះ ទើបទ្រង់ព្រះនាមថា សត្ថា ទេវមនុស្សានំ ។ ឯព្រះអង្គទូន្មានដោយទិដ្ឋធម្មិកត្ថៈ និង សម្បរាយិកត្ថៈនោះ មិនជាអស្ចារ្យណាស់ទេ ព្រោះគ្រូដទៃគេអាចប្រដៅបានខ្លះដោយឯកទេសដែរ ។ ដែលព្រះអង្គទ្រង់ទូន្មានដោយបរមត្ថៈនោះ ទើបជាមហាអស្ចារ្យ ព្រោះគ្រូដទៃមិនអាចនឹងសំដែងបានដូចព្រះអង្គ សូម្បីតែដោយឯកទេសក៏គ្មាន ។

មួយទៀត ព្រះមានព្រះភាគ ដូចជាអាចារ្យអ្នកប្រដៅអក្ខរសម័យ

www.budinst.gov.kh www.elibraryofcambodia.org

ចំណែកខាងវេនេយ្យសត្វដែលនៅមិនធ្លាប់ស្តាប់ពុទ្ធភាសិត មិនដឹងនូវប្រយោជន៍ ២ គឺ ដឹងប្រភេទកុសលនឹងអកុសល ដឹងប្រភេទនៃសង្ខារមានខន្ធជាដើម ប្រកបដោយវិបល្លាស សំគាល់ថា សង្ខារជារបស់ទៀង ជាសុខ ជាខ្លួន ប្រាណ សត្វ បុគ្គល នឹងជារបស់ល្អ ដូចជាកុមារតូចដែលនៅមិនទាន់សិក្សាក្នុងអក្ខរសម័យ សូម្បីឃើញអក្សរ ក៏សំគាល់ថាជាគំនូរក្បាច់ក្បូរដ៏វិចិត្រ លុះវេនេយ្យសត្វបានស្តាប់ពុទ្ធភាសិត ចំពោះព្រះភក្ត្រ ឬអាស្រ័យឧគ្គហបរិបុច្ឆា នឹងស្តាប់ទេសនាអំពីសំណាក់ពហូស្សូតដែលសំដែងត ៗ មក ទើបដឹងប្រភេទនៃធម៌ជាកុសលនឹងអកុសល នឹងប្រភេទនៃសង្ខារមាននាមរូបជាដើម ហើយញែកចែកក្នុងសង្ខារ ជានាមរូប ឬខន្ធ ៥ ពិចារណាដោយសម្មសនញ្ញាណ ឃើញសាមញ្ញលក្ខណៈក្នុងសង្ខារថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ឬឃើញថាជារបស់បដិកូលគួរខ្ពើម លះវិបល្លាសៗបានដោយតទង្គប្បហានៈតែ ១ ខណៈៗក្តី ឬដោយសមុច្ឆេទប្បហានៈ លះដាច់ស្រឡះក្តី ដូចកុមារតូចបានសិក្សាអក្ខរសម័យក្នុងសំណាក់អាចារ្យ ហើយបានឃើញអក្សរក៏មើលស្គាល់ បានដឹងសេចក្តី លះបង់វិបល្លាស ដែលឃើញថាគំនូរក្បាច់ក្បូរដ៏វិចិត្រនោះបាន ។ ព្រះមានព្រះភាគសូម្បីព្រះអង្គបរិនិព្វានកន្លងទៅហើយ អនុសាសនៈដែលជាអនុសាសនីបាដិហារ្យ ក៏ប្រតិស្ឋានទៅ ជាគុណដល់ទេវតានឹងមនុស្សក្នុងខាងក្រោយ ទ្រង់ក៏បាននាមថាជា សាស្តានៃ

www.budinst.gov.kh www.elibraryofcambodia.org

ទេវតានិងមនុស្សក្នុងខាងក្រោយផង ព្រោះហេតុនោះ ព្រះមានព្រះភាគទើបទ្រង់ព្រះនាមថា សត្ថា ទេវមនុស្សានំ ។ ពាក្យថា ទេវមនុស្សានំ នោះ ជាពាក្យពោលដោយអំណាចកំណត់សត្វដ៏ឧក្រិដ្ឋ និងកំណត់សត្វដែលជាភព្វបុគ្គល គួរត្រាស់ដឹងចតុរារិយមគ្គារិយផល ហេតុដូច្នោះ ព្រះមានព្រះភាគទ្រង់ព្រះនាមថា ជាសាស្តានៃអមនុស្ស និងតិរច្ឆានពួកខ្លះផង ព្រោះព្រះអង្គប្រទានអនុសាសនី ទូន្មានដល់អមនុស្សនិងតិរច្ឆានអម្បាលនោះ ដូចអាឡវកយក្ស និងអបឡាលនាគរាជជាដើម ដែលបានទទួលអនុសាសនីនៃព្រះអង្គ មានបសាទស្រទ្ធាជឿស៊ប់ក្នុងព្រះរតនត្រ័យ លះបង់នូវពុតកំណាច គឺទុច្ចរិតចេញបាន ។

ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា ពុទ្ធោ នោះ ប្រែថា ព្រះអង្គត្រាស់ដឹងច្បាស់ នូវញេយ្យធម៌ទាំងពួង ។

មួយទៀត ប្រែថា ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ទាំង ៤ ដោយព្រះអង្គឯង ហើយញុំាងសត្វដទៃឲ្យត្រាស់ដឹងតាមផង ទើបទ្រង់ព្រះនាមថា ពុទ្ធោ ព្រះអង្គមានព្រះគុណរីកពេញហើយ អធិប្បាយទាំងពួង អ្នកប្រាជ្ញគប្បីដឹងដូចន័យដែលសំដែងហើយក្នុងខាងដើមនោះចុះ ក្នុងរឿងនេះ ប្លែកតែពាក្យថាញេយ្យធម៌ជួសសន្ធារប៉ុណ្ណោះ ។

ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា ភគវា នោះ ប្រែថា ព្រះមានព្រះភាគ ភាគៈ នោះបានដល់កុសលធម៌ មានទានសីលជាដើម

www.budinst.gov.kh www.elibraryofcambodia.org

ដែលជាធម៌ដល់នូវចំណែកដ៏ឧត្តមយ៉ាងឧក្រិដ្ឋ និងជាកុសលញ៉ាំងលោកិយសុខនិងលោកុត្តរសុខឲ្យកើតឡើង ភាគៈនោះរមែងមានដល់ព្រះអង្គ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា ភគវា ។

មួយទៀត ភគវា ប្រែថា ព្រះអង្គញែកចេញសំដែងនូវធម៌ទាំងពួង ដោយប្រភេទថាជា កុសល អកុសល និង អព្យាកតធម៌ ធម៌មិនមែនជាកុសលនិងអកុសលជាដើម ហើយក៏ចែកនូវធម៌ទាំងអម្បាលនោះជា ចិត្ត ចេតសិក ហើយក៏បែងជាភូមិ ៤ ជាដើម ដើម្បីនឹងឲ្យកុលបុត្រដឹងច្បាស់ប្រាកដក្នុងធម៌មានកុសលជាដើមនោះ ហើយញែកចែកធម៌អម្បាលនោះជាខន្ធ អាយតនៈ ធាតុ ឥន្ទ្រិយ អរិយសច្ច បដិច្ចសមុប្បាទ ជាដើម ដើម្បីជាអារម្មណ៍នៃវិបស្សនាបញ្ញា និងចែកសាមញ្ញលក្ខណៈគ្រឿងសំគាល់ជាសាមញ្ញ ដែលមាននូវទៅក្នុងធម៌ទាំងពួងគឺ អនិច្ចតា សភាពមិនទៀង ទុក្ខតា សភាពជាទុក្ខ និង អនត្តតា សភាពមិនមែនខ្លួន ទាំង ៣ នេះជាលក្ខណៈគ្រឿងសំគាល់នៃវិបស្សនាបញ្ញា កាលទ្រង់បញ្ជាក់សេចក្តីពិតក្នុងធម៌ទាំងនោះ ទើបទ្រង់ចែកសច្ចៈរបស់ពិតនៃព្រះអរិយៈ ៤ គឺ ទុក្ខ សមុទ័យ និរោធ មគ្គ កាលទ្រង់ប្រាថ្នានឹងឲ្យឃើញថា ជាទុក្ខដោយហេតុនេះៗ ទើបទ្រង់ចែកនូវអត្ថនៃសច្ចៈ ៤ នោះថា ធម៌មានខន្ធជាដើមនោះ ជាទុក្ខដោយអត្ថថា បៀតបៀនសត្វ ១ ដោយអត្ថថា ធម៌គឺបច្ច័យទាំងឡាយមាន

www.budinst.gov.kh www.elibraryofcambodia.org

តណ្ហាជាដើមប្រជុំព្រមគ្នា ធ្វើឲ្យកើតឡើង១ ដោយអត្ថថា ញ៉ាំងសត្វឲ្យក្តៅក្រហាយ១ ដោយអត្ថថា ជារបស់ប្រែប្រួល១ ទើបជាទុក្ខ ។ តណ្ហាជាសមុទ័យ គឺហេតុជាដែនកើតនៃទុក្ខនោះ ដោយអត្ថថា ប្រមូលមកគឺញ៉ាំងទុក្ខឲ្យកើត១ ដោយអត្ថថា ជាហេតុប្រគល់ឲ្យនូវទុក្ខជាផលរបស់ខ្លួន១ ដោយអត្ថថា ប្រកបសត្វដោយទុក្ខ១ ដោយអត្ថថា រាំងសត្វមិនឲ្យបានមគ្គផល១ ទើបជាសមុទ័យ ។ ព្រះនិព្វានជានិរោធ ទីរលត់ទុក្ខនោះ ដោយអត្ថថា រលាស់ចោលនូវឧបធិ ធម៌ដែលត្រូវរងនូវទុក្ខទាំងពួង១ ដោយអត្ថថា វិវេកស្ងាត់ចាកសង្ខារធម៌ទាំងពួង១ ដោយអត្ថថា មិនមានធម៌ណាមួយជាបច្ច័យប្រជុំគ្នាធ្វើឲ្យកើតឡើង១ ដោយអត្ថថា ជារបស់មិនស្លាប់ ព្រោះជារបស់ទៀង១ ទើបឈ្មោះថានិរោធ ។ សម្មាបដិបទា ឈ្មោះថាមគ្គ ជាផ្លូវ ដោយអត្ថថា នាំសត្វចេញចាកវដ្តទុក្ខ១ ដោយអត្ថថា ជាហេតុញ៉ាំងសត្វឲ្យដល់នូវព្រះនិព្វាន១ ដោយអត្ថថា ជាគ្រឿងឃើញនូវព្រះនិព្វាន ជាធម៌ដ៏សុខុមក្រៃលែង១ ដោយអត្ថថា ជាអធិបតីនៃសម្បយុត្តធម៌ក្នុងកិរិយាឃើញនូវព្រះនិព្វាន១ ទើបឈ្មោះថាមគ្គ ។ ព្រះមានព្រះភាគទ្រង់ចែកនូវធម៌ទាំងឡាយដោយន័យដូច្នេះជាដើម ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា ភគវា ។ ពាក្យថា ភគវា នេះជាព្រះនាមព្រះមានព្រះភាគ សម្រាប់ហៅដោយគោរព ចំពោះព្រះមានព្រះភាគ ដែលជាសាស្តាដ៏វិសេសឧត្តមជាងសត្វទាំងឡាយ ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះនាមទាំងអំពី អរហំ ដរាបដល់ ភគវា នេះ មិនមែនព្រះពុទ្ធមាតា ព្រះពុទ្ធបិតា ព្រះញាតិទាំងពួងឬទេវតាវិសេសណាមួយថ្វាយព្រះអង្គទេ ព្រះនាមទាំងនេះ ជានេមិត្តកនាម មកអំពីនិមិត្ត គឺគុណកើតឡើងព្រមគ្នាជាមួយនាមកាយ ក្នុងអរិយជាតិ និងការសំដែងធម្មចក្កប្បវត្តនសូត្រនៃព្រះអង្គ ។ ព្រះនាមទាំងនេះ ព្រះនាមខ្លះដូចជាព្រះនាមព្រះទីណាស្រេចដែលជាសាវកក៏មាន តែដំណើរសេចក្ដីប្លែកគ្នាបន្តិច អ្នកប្រាជ្ញគប្បីដឹងដោយដំណើរសេចក្ដីដែលសំដែងមកហើយចុះ ។ គុណដែលបានក្នុងព្រះនាមទាំងនេះ សំដែងដោយសង្ខេបមាន ២ គឺ អត្តហិតសម្បត្តិ ការដល់ព្រមដោយធម៌ជាប្រយោជន៍ចំពោះព្រះអង្គ ១ បរហិតបដិបត្តិ ការបដិបត្តិជាអនុកូលដល់សត្វដទៃ ១ ។

បទថា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ ទាំងនេះប្រកាសគុណ គឺ អត្តហិតសម្បត្តិ ព្រោះបទទាំងនេះសំដែងញាណនិងបហានៈ ដែលជាផលសម្បទា ។

បទថា អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ទាំងនេះប្រកាសគុណគឺ បរហិតបដិបត្តិ ព្រោះបទទាំងនេះ សំដែងសត្តូបការសម្បទា ។

ឯបទថា ពុទ្ធោ ភគវា នេះ ប្រកាសគុណទាំង ២ គឺ អត្តហិត-

www.budinst.gov.kh www.elibraryofcambodia.org

សម្បត្តិ និងបរហិតបដិបត្តិ ព្រោះបទទាំងពីរនេះ សំដែងពោធិសម្ភារ-សម្ភរណៈ និងញាណដែលជាហេតុសម្បទានិងផលសម្បទា និងសំដែងសត្តូបការសម្បទា ។ កាលបើមានដូច្នេះ បទទាំងឡាយអម្បាលនោះ បានឈ្មោះថា ប្រកាសមហាករុណាសមាយោគៈ និងអានុភាវសម្បត្តិ រូបកាយសម្បត្តិ ។ មួយទៀត បទថា អរហំ សំដែងបហានៈ គឺការលះបង់នូវកិលេស បទថា សម្មាសម្ពុទ្ធោ សំដែងការនោះ ការធ្វើកុសលឲ្យកើតឲ្យមានឡើង ព្រោះហេតុនោះ ទើបព្រះនាមទាំង ២ នេះជាព្រះនាមធំ ព្រះអង្គបានត្រាស់ដឹងដោយព្រះនាមនេះ មានគុណសុត្តន្តប្រទេសនោះៗ ដោយច្រើន ។ មួយទៀត បទទាំងអស់នេះជាហេតុតៗគ្នាដូច្នេះ ព្រះអង្គឆ្ងាយចាកកិលេស ព្រោះទ្រង់ត្រាស់ដឹងប្រពៃដោយព្រះអង្គឯង ។ ទ្រង់ត្រាស់ដឹងប្រពៃដោយព្រះអង្គឯង ព្រោះព្រះអង្គដល់ព្រមហើយដោយវិជ្ជានិងចរណៈ ។ ព្រះអង្គដល់ព្រមហើយដោយវិជ្ជានិងចរណៈ ព្រោះព្រះអង្គយាងទៅប្រពៃហើយ ។ ព្រះអង្គយាងទៅប្រពៃហើយ ព្រោះព្រះអង្គជ្រាបច្បាស់នូវលោក ។ ដែលព្រះអង្គទូន្មាននូវបុរសដែលគួរទូន្មានពុំមានអ្នកណាលើស ព្រោះព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ។ ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រោះព្រះអង្គមានព្រះគុណរីកពេញហើយ ។ ព្រះអង្គមានព្រះគុណរីកពេញហើយ ព្រោះព្រះអង្គមានភាគគឺព្រះបារមីធម៌ហើយទ្រង់ចែកដល់សត្វទាំងឡាយ ។

www.budinst.gov.kh www.elibraryofcambodia.org

បើនឹងពិចារណា គឺចំរើនពុទ្ធានុស្សតិ រលឹកដល់គុណនៃព្រះពុទ្ធ គប្បីរលឹកដូច្នេះថា សោ ភគវា ឥតិបិ អរហំ ព្រះមានព្រះភាគនោះ ទ្រង់ព្រះនាមថា អរហំ យ៉ាងដូច្នេះទៅគ្រប់ៗបទ លុះដល់ សោ ភគវា ឥតិបិ ភគវា ព្រះមានព្រះភាគទ្រង់ព្រះនាមថា ភគវា ព្រោះហេតុនោះ ពាក្យសំដែងនោះ សំដៅយកពាក្យប្រែនឹងអធិប្បាយដែលសំដែងមកហើយមុននោះ ឲ្យកាន់យកអត្ថគឺសេចក្តីទៀងរលឹករំពឹងឲ្យឃើញគុណព្រះពុទ្ធ តាមដំណើរសេចក្តីដែលបានពណ៌នាមកហើយ កុំកាន់យកតែព្យញ្ជនៈទៀងទន្ទេញបរិកម្ម ធ្វើយ៉ាងដូច្នេះ មិនមិនឃើញគុណព្រះពុទ្ធអង្គទេ មិនរលឹកគ្រប់ ៗ បទក៏បាន ឬរលឹកបទណាមួយតាមចូលចិត្តក៏បាន ។

ពុទ្ធគុណកថា ចប់

# ធម្មរតនកថា

## ពណ៌នាព្រះធម្មរតនៈ

សុ. ធម៌នោះ គឺជាធម៌ សភាវៈដែលល្អក៏ពោលថាធម៌ សភាវៈដែលអាក្រក់ក៏ពោលថាធម៌ សភាវៈដែលមិនល្អមិនអាក្រក់ក៏ពោលថាធម៌ ដូចបាលីថា "កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា" ដូច្នេះ, សភាវៈដូចម្ដេចឈ្មោះថាធម៌ក្នុងធម្មរតនៈនេះ ?

វិ. សភាវៈដែលល្អហើយពិត ជាធម៌ក្នុងធម្មរតនៈនេះ សភាវៈដែលល្អតែមិនពិត មិនមែនជាធម៌ សភាវៈពិតតែមិនល្អ ក៏មិនមែនជាធម៌ សភាវៈមិនល្អហើយមិនពិត ក៏មិនមែនជាធម៌ ។ ការដែលឃើញថាផលបុណ្យនិងបាបមិនមាន ឥធលោកក៏មិនមាន ដូច្នេះជាដើម ឈ្មោះថាសភាវៈមិនល្អហើយមិនពិត ។ ការដែលឃើញថាព្រះអាទិត្យជាពន្លឺបំភ្លឺលោក ដី ទឹក ភ្លើង ខ្យល់ជាទីអាស្រ័យនៃសត្វ ហើយក្រាបសំពះបូជារបស់ទាំងនោះ ដូច្នេះឈ្មោះថាសភាវៈពិតតែមិនល្អ ។ ការប្រតិបត្តិរបស់បុគ្គលពួកខ្លះដូច្នេះ កាលបើរាគៈ ទោសៈ កើតឡើងក្នុងចិត្ត ក៏ឃើញថារាគៈ ទោសៈ ជារបស់មិនល្អ ហើយបែរមុខរកឧបាយគិតដូច្នេះថា ព្រះជាម្ចាស់ជាអ្នកសាងលោកនៅក្នុងទីទាំងពួង ដឹង ឃើញនូវការទាំងពួង ព្រះអង្គឃើញយើងលុះដោយអំណាចរាគៈ ទោសៈ មិនបានក៏បាត់បង់ ព្រះអង្គនឹងកត់បញ្ជី

www.budinst.gov.kh www.elibraryofcambodia.org

ចុះឈ្មោះយើងទុកហើយនឹងពិន័យទោសជាខាងក្រោយ គិតដូច្នេះហើយ ក៏កំចាត់កតៈ ទោសៈ ចេញបាន ដូច្នេះ ឈ្មោះថាសេចក្តីល្អមែន តែមិនពិត ព្រោះបានបែរមុខតទល់កំចាត់កតៈ ទោសៈ ដែលជាកិលេស ឈ្មោះថាសេចក្តីល្អ តែព្រះជាម្ចាស់ទ្រង់សាងលោកដូច្នោះក៏ទេ ។ ឯសេចក្តីមិនលោភ មិនក្រោធ មិនវង្វេងដែលបុគ្គលធ្វើឲ្យកើតឡើងដោយឧបាយដ៏ពិតប្រាកដ មិនមែនសេចក្តីមិនលោភ មិនក្រោធមិនវង្វេង ដែលមានគន្លងវេលាដេកលក់ជាដើមក្តី ឬការកើតឡើងឯង នៃសេចក្តីមិនលោភ មិនក្រោធ មិនវង្វេង ព្រោះមិនមានសង្ខារជាទីតាំងក្តី ឈ្មោះថាសេចក្តីល្អពិត ។

ឬ. សេចក្តីមិនលោភ មិនក្រោធ មិនវង្វេង ដែលបុគ្គលធ្វើឲ្យមានឲ្យកើតឡើងដោយឧបាយដែលពិតប្រាកដ ឈ្មោះថាសេចក្តីល្អពិតនោះដូចម្តេច?

វិ. ដូចជាបុគ្គលដែលគិតឃើញថា ពពួកកាយដែលមានវិញ្ញាណគ្រប់គ្រង នឹងជួបនូវសេចក្តីសុខ-ទុក្ខ ឈ្មោះថាសត្វនេះ ទោះបីជាមនុស្សក្តី តិរច្ឆានក្តី រមែងខ្លាចទុក្ខ ស្រឡាញ់សុខដូចៗគ្រប់រូប កាលកំណត់ឃើញដូច្នោះហើយ មិនបៀតបៀនសត្វដទៃឲ្យបានសេចក្តីទុក្ខ ដោយកាយនិងវាចារបស់ខ្លួន ត្រិះរិះរកសេចក្តីសុខឲ្យដល់សត្វដទៃ សង្កត់សង្កិនសេចក្តី លោភ ក្រោធ ចេញដោយឧបាយដូច្នេះ ដោយឃើញថាការប្រព្រឹត្តដូច្នេះ ជាសេចក្តីល្អ នឹងឲ្យបានសេចក្តីសុខទៅខាងមុខ ឈ្មោះ

www.budinst.gov.kh www.elibraryofcambodia.org

ជាសេចក្ដីល្អហើយពិត ៗ មួយទៀត ការដែលគិតរំពឹងដល់សេចក្ដីស្លាប់ មានសេចក្ដីតក់ស្លុតចិត្តក្ដី ឬពិចារណាថា រូបកាយនេះពេញដោយគ្រឿងស្មោកគ្រោកមាន សក់ រោម ក្រចក ធ្មេញ ស្បែក ជាដើម មានបដិកូល-សញ្ញាកើតឡើង រម្ងាប់បង់នូវតម្រេក ក្រោធ វង្វេង បានក្ដី ឬឃើញល្អិតពុះ:ពាថាសព៌ាង្គកាយ មិនទៀង ជាទុក្ខ មិនមែនជារបស់ខ្លួន ដោយហេតុនោះៗ ហើយមិនមានសេចក្ដីលោភ ក្រោធ វង្វេង ដោយឃើញថា បដិបត្តិយ៉ាងនេះ អាចនឹងនាំខ្លួនឲ្យបានសេចក្ដីសុខខាងមុខ នឹងរួចចាកទុក្ខទាំងពួង ដូច្នេះក្ដី ឈ្មោះថាសេចក្ដី មិនលោភ មិនក្រោធ មិនវង្វេង កើតមានឡើងដោយឧបាយដ៏ពិតប្រាកដ ឈ្មោះថាសេចក្ដីល្អហើយពិត ដូចសំដែងមកដូច្នេះ ៗ

ទាន គឺបរិច្ចាគទានក្ដី សីល គឺការវៀរចាកទុច្ចរិតក្ដី ភាវនា គឺការញ៉ាំងកុសលឲ្យកើតឡើងដែលជាសេចក្ដីល្អហើយពិតដូច្នេះក្ដី ឬរបៀបពាក្យដែលប្រកាសសេចក្ដីល្អហើយពិតនោះក្ដី ឈ្មោះថាធម៌ ៗ

បុ. ធម៌ ប្រែថាដូចម្ដេច?

រិ. ធម៌ ប្រែថាសភាវៈទ្រទ្រង់នូវសត្វ ដែលទ្រទ្រង់នូវខ្លួន ៗ មួយទៀត ថាសភាវៈដែលបុគ្គលគប្បីទ្រទ្រង់ទុក ៗ សេចក្ដីមិនលោភមិនក្រោធមិនវង្វេង ដែលកើតឡើងដោយឧបាយពិតប្រាកដ ដូចសំដែងមកហើយនោះ បើបុគ្គលណាធ្វើឲ្យកើតឡើងក្នុងសន្ដានចិត្ត បុគ្គលនោះឈ្មោះថា

www.budinst.gov.kh www.elibraryofcambodia.org

ធម្មចារី អ្នកទ្រទ្រង់នូវធម៌ ធម៌នេះឯងតែងទ្រទ្រង់អ្នកនោះ មិនឲ្យធ្លាក់ទៅក្នុងទីដែលប្រកបដោយសេចក្ដីទុក្ខ មាននរកជាដើម ព្រោះហេតុនោះទើបព្រះមានព្រះភាគទ្រង់ត្រាស់ភាសិតទុកថា ៖

"ធម្មោ ហវេ រក្ខតិ ធម្មចារឹ
ធម្មោ សុចិណ្ណោ សុខមាវហាតិ
ឯសានិសំសោ ធម្មេ សុចិណ្ណេ
ន ទុគ្គតឹ គច្ឆតិ ធម្មចារី ។

ធម៌ពិតជារក្សានូវបុគ្គល អ្នកប្រព្រឹត្តធម៌ ធម៌ដែលបុគ្គលប្រព្រឹត្តល្អហើយ តែងនាំមកនូវសេចក្ដីសុខ នេះជាអានិសង្សក្នុងធម៌ដែលបុគ្គលប្រព្រឹត្តល្អហើយ បុគ្គលអ្នកប្រព្រឹត្តនូវធម៌ រមែងមិនទៅកាន់ទុគ្គតិ" ។

ធម៌ ដែលប្រែថា សភាវៈគឺបុគ្គលគប្បីទ្រទ្រង់នោះ បានដល់បរិយត្តិធម៌ដែលប្រកាសសេចក្ដីល្អហើយពិតនោះ ព្រោះបរិយត្តិធម៌ជារបៀបបទដែលបុគ្គលគប្បីរៀនសូត្រទ្រទ្រង់ចាំទុក ។

មួយទៀត បរិយត្តិធម៌ ប្រែថា ទ្រទ្រង់បុគ្គលអ្នកទ្រទ្រង់នូវខ្លួនផងក៏បាន ដ្បិតថា បរិយត្តិធម៌ បើបុគ្គលណា ទ្រទ្រង់ដោយប្រាថ្នានឹងបដិបត្តិតាម ព្រះធម៌តែងទ្រទ្រង់នូវបុគ្គលនោះ ឲ្យបានចំរើនដោយពាហុសច្ចៈនឹងឲ្យរួចចាកទីប្រកបដោយទុក្ខមានអបាយទុក្ខជាដើម ។ សេចក្ដីមិនលោភ មិនក្រោធ មិនវង្វេង ដែលជាសេចក្ដីល្អហើយពិតនោះ ដែលឋិតថេរក៏មាន មិនឋិតថេរក៏មាន ។ ដែលមិនឋិតថេរនោះ គឺកើតឡើង

www.budinst.gov.kh www.elibraryofcambodia.org

ហើយរលត់ទៅ មានសេចក្តីលោភ ក្រោធ វង្វេង កើតឡើងបានទៀត បានដល់លោកិយកុសលធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ គឺកាមាវចរភូមិ ១ រូបាវចរភូមិ ១ អរូបាវចរភូមិ ១ ។ ដែលឋិតថេរនោះ គឺកើតឡើងហើយ សូន្យរលត់ទៅ សេចក្តីលោភ ក្រោធ វង្វេង ក៏មិនត្រឡប់កើតឡើងវិញបានឡើយ បានដល់លោកុត្តរធម៌ដែលនឹងសំដែងទៅខាងមុខ ។

មួយទៀត ធម៌សំដែងដោយសង្ខេបមាន ៣ គឺ បរិយត្តិសទ្ធម្ម ១ បដិបត្តិសទ្ធម្ម ១ បដិវេធសទ្ធម្ម ១ ។

## បរិយត្តិសទ្ធម្មកថា

របៀបពាក្យដែលប្រកាសបដិបត្តិសទ្ធម្ម និងបដិវេធសទ្ធម្ម ឈ្មោះថា បរិយត្តិសទ្ធម្ម ។ បរិយត្តិសទ្ធម្មនោះចាត់ដោយបុគ្គលអ្នកសំដែងមាន ៤ ពួកគឺ ពុទ្ធភាសិត ១ សាវកភាសិត ១ ឥសិភាសិត ១ ទេវតាភាសិត ១ ។

ធម៌ដែលព្រះពុទ្ធអង្គទ្រង់សំដែង ឈ្មោះថាពុទ្ធភាសិត បានដល់ព្រះវិន័យ ព្រះសូត្រ និងព្រះអភិធម្ម ។ ធម៌ដែលសាវកបញ្ចូលក្នុងបរិស័ទ ៤ សំដែង មានអនង្គណសូត្រ និងសម្មាទិដ្ឋិសូត្រជាដើម ឈ្មោះថាសាវកភាសិត ។ ធម៌ដែលឥសីបរិព្វាជកខាងក្រៅដែលដឹងភូមិធម៌សំដែង ដូចបរិព្វាជកវគ្គជាដើម ឈ្មោះថាឥសិភាសិត ។

www.budinst.gov.kh www.elibraryofcambodia.org

ធម៌ដែល ទេវតា មារ ព្រហ្ម សំដែង ឈ្មោះថាទេវតាភាសិត បានដល់របៀបពាក្យក្នុងទេវតាសំយុត្តជាដើម ដែលជាពាក្យគឺ ទេវតា ទេវបុត្ត និងមារ ព្រហ្ម សំដែង ។

បរិយត្តិសទ្ធម្ម ដែលចាត់ដោយភាសិត ៤ នោះ មានអង្គ ៩ គឺ សុត្តៈ១ គេយ្យៈ១ វេយ្យាករណៈ១ គាថា១ ឧទាន១ ឥតិវុត្តកៈ១ ជាតកៈ១ អព្ភូតធម្ម១ វេទល្លៈ១ ។

របៀបពាក្យដែលសំដែងសេចក្តីបានជារឿងមួយៗ គួរនឹងទាញមកជាគ្រឿងសាធកៈ[១] បាន អំពីបាលីប្រទេសនោះៗ ដូច្នេះឈ្មោះថាសុត្តៈ ដូចព្រះបាលីជាឧទ្ទេសវារៈថា ៖

"បញ្ចិមានិ ភិក្ខវេ ពលានិ កតមានិ បញ្ច សទ្ធាពលំ វីរិយពលំ សតិពលំ សមាធិពលំ បញ្ញាពលំ" ដូច្នេះ ឈ្មោះថាសុត្តៈ ។ ឬព្រះបាលីថា "ឥធ ភិក្ខវេ អរិយសាវកោ សទ្ធោ ហោតិ សទ្ទហតិ តថាគតស្ស ពោធឹ ឥតិបិ សោ ភគវា អរហំ ។ល។ ភគវាតិ" ដូច្នេះជាដើម ក៏ឈ្មោះថាសុត្តៈ ។ សូម្បីរបៀបពាក្យដែលសំដែងសេចក្តីបានជារឿងមួយៗ ដូច្នេះ ទោះក្នុងវិន័យឬក្នុងអភិធម្ម ក៏ឈ្មោះថាសុត្តៈក្នុងរឿងនេះដែរ ។

---

១ – គ្រឿងអាង ។ – ដែលញ៉ាំងប្រយោជន៍ឲ្យសម្រេច ។

www.budinst.gov.kh www.elibraryofcambodia.org

របៀបពាក្យដែលជាចុណ្ណិយបទខ្លះ គាថាខ្លះ លាយគ្នា ដូចជាសគាថកវគ្គ ក្នុងសំយុត្តនិកាយ ឈ្មោះថា គេយ្យៈ ។

របៀបពាក្យដែលជាចុណ្ណិយបទសុទ្ធ មិនលាយដោយគាថា ដូចក្នុងធម្មចក្កប្បវត្តនសូត្រជាដើម ឈ្មោះថា វេយ្យាករណៈ ។

របៀបពាក្យដែលលោកនិពន្ធជាគាថាសុទ្ធ មិនលាយដោយចុណ្ណិយបទ ដូចកាមសូត្រ គុហដ្ឋកសូត្រជាដើម ឈ្មោះថា គាថា ។

របៀបពាក្យដែលព្រះមានព្រះភាគទ្រង់អាស្រ័យសោមនស្សញ្ញាណបន្លឺឡើង ឈ្មោះថា ឧទាន ដូចព្រះបាលីថា ៖

"យទា ហវេ បាតុភវន្តិ ធម្មា
អាតាបិនោ ឈាយតោ ព្រាហ្មណស្ស
អថស្ស កង្ខា វបយន្តិ សព្វា
យតោ បជានាតិ សហេតុធម្មំ"

ជាដើម ឧទាននេះជាគាថាក៏មាន ជាចុណ្ណិយបទក៏មាន ។

របៀបពាក្យដែលព្រះពុទ្ធអង្គទ្រង់សំដែងជាឧទ្ទេសការៈឡើងជាមុន សំដែងឧទ្ទេសការៈនោះហើយ ទើបសំដែងឱ្យនិគមន៍ជាខាងក្រោយទៀត ឈ្មោះថាឥតិវុត្តកៈ ដូចព្រះបាលីថា ៖

"ឥមា ច ធាតុយោ ភិក្ខវេ មយា ធម្មោ ទេសិតោ អនិគ្គហិតោ អសង្កិលិដ្ឋោ អនុបវជ្ជោ

www.budinst.gov.kh www.elibraryofcambodia.org

អព្យដិកត្តុផ្លោ ។ សមណោហិ ព្រាហ្មណោហិ វិញ្ញាហីតិ ឥតិ ខោ បនេតំ វុត្តំ, កិញ្ចេតំ បដិច្ច វុត្តំ, ឆយិមា ភិក្ខវេ ធាតុយោ បថវីធាតុ ។ល។ វិញ្ញាហីតិ ឥតិ យន្តំ វុត្តំ, ឥទមេតំ បដិច្ច វុត្តំ" ។

របៀបពាក្យដែលព្រះពុទ្ធអង្គទ្រង់សំដែងបុព្វចរិតដ៏ប្រកបដោយពាក្យថា "ភូតបុព្វំ ភិក្ខវេ" ដូច្នេះ ឈ្មោះថា ជាតកៈ ដូចទីឃាវុជាតក និងមឃទេវជាតកជាដើម ។

របៀបពាក្យប្រកបដោយអច្ឆរិយព្ភូតធម៌ ដូចព្រះបាលីថា "ចត្តា-រោមេ ភិក្ខវេ អច្ឆរិយា អព្ភុតធម្មា អានន្ទេ" ជាដើម ឈ្មោះថា អព្ភូតធម៌ ។

របៀបពាក្យដែលអ្នកសួរបានសេចក្ដីដឹងច្បាស់នឹងសេចក្ដីត្រេកអរ សួរតៗទៀតទៅ ឈ្មោះថា វេទល្លៈ ដូចជាចុល្លវេទល្លសូត្រ មហាវេទល្ល-សូត្រ សម្មាទិដ្ឋិសូត្រ សក្កបញ្ហាសូត្រ ជាដើម ។

មួយទៀត គេយ្យៈនិងវេយ្យាករណៈជាដើម លោកក៏ហៅថា សុត្តៈដែរ ។ ទាំង ៩ នេះ ឈ្មោះថា ជាអង្គនៃបរិយត្តិសទ្ធម្ម ។ បរិយត្តិ-សទ្ធម្មនេះ កាលព្រះធម្មសង្គីតិកាចារ្យមិនទាន់បានធ្វើសង្គាយនា នឹងធ្វើសង្គាយនានោះ លោកហៅថា ធម្មវិន័យ ដូច្នេះ ។

www.budinst.gov.kh www.elibraryofcambodia.org

របៀបពាក្យដែលប្រកាសនូវសេចក្តីបដិបត្តិដោយកាយ វាចា ដែលព្រះពុទ្ធអង្គទ្រង់តែងតាំងទុកជាពុទ្ធអាជ្ញា ជាអាណាទេសនា ឈ្មោះថា វិន័យ ។

របៀបពាក្យដែលព្រះពុទ្ធអង្គទ្រង់សំដែងប្រកាសនូវសេចក្តីបដិបត្តិ ដែលប្រព្រឹត្តទៅក្នុង កាយ វាចា ចិត្ត មិនបានតែងតាំងជាអាជ្ញា គ្រាន់តែសំដែងដោយវោហារទេសនាខ្លះ បរមត្ថទេសនាខ្លះ ឈ្មោះថា ធម៌ ។

មួយទៀត កាលសម័យលោកធ្វើសង្គាយនានោះ ចំណែកវិន័យ លោកហៅថា ឧភតោវិន័យ ប្រែថា វិន័យមាន ២ យ៉ាងគឺ ភិក្ខុវិន័យ ១ ភិក្ខុនីវិន័យ ១ ។ ចំណែកធម៌ លោកហៅថា បញ្ចនិកាយ ប្រែថានិកាយ ៥ គឺ ទីឃនិកាយ ១ មជ្ឈិមនិកាយ ១ សំយុត្តនិកាយ ១ អង្គុត្តរនិកាយ ១ ខុទ្ទកនិកាយ ១ ។

មួយទៀត បរិយត្តិសទ្ធម្មនេះ តាំងពីធ្វើសង្គាយនាមកហើយ លោកហៅថា តេបិដកំ ពុទ្ធវចនំ ជាវោហារប្រាកដនៅក្នុងគម្ពីរអដ្ឋកថា ។ តេបិដកំ ពុទ្ធវចនំ ប្រែថា ពុទ្ធវចនៈ គឺប្រជុំនៃបិដក ៣ លោកចាត់យកឧភតោវិន័យ ជាវិន័យបិដក, ចាត់យកនិកាយ ៥ ជាបិដក ២ ។ ចំណែករបៀបពាក្យដែលប្រកាសធម៌ល្អិតសុខុមខ្លះ មិនល្អិតសុខុមខ្លះដែលព្រះមានព្រះភាគទ្រង់សំដែងជា គេយ្យៈខ្លះ វេយ្យាករណៈខ្លះ គាថាខ្លះ ឧទានខ្លះ ឥតិវុត្តកៈខ្លះ ជាតកៈខ្លះ អព្ភូតធម៌ខ្លះ វេទល្លៈខ្លះ និងដែលព្រះ

www.budinst.gov.kh www.elibraryofcambodia.org

សង្គីតិកាចារ្យលោកចាត់ទុកជារបៀបពាក្យ មាននិទានខ្លះ មិនមាននិទានខ្លះ ប្រដាប់ដោយអង្គគឺសុត្តៈ ច្រើនខ្លះតិចខ្លះ ដូច្នេះឈ្មោះថាសុត្តន្តបិដកៗ លោកចាត់របៀបពាក្យដែលប្រកាសធម៌សុទ្ធមល្អិតមិនមាននិទាន ប្រដាប់ដោយអង្គ ២ គឺ សុត្តៈ និងវេយ្យាករណៈ ដូច្នេះ ឈ្មោះថា អភិធម្មបិដកៗ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យកាលពន្យល់បរិយត្តិសទ្ធម្ម ទើបពោលថា "បិដកត្តយសង្គហិតំ សព្វំ ពុទ្ធវចនំ បរិយត្តិសទ្ធម្មោ នាម ប្រែថា ព្រះពុទ្ធវចនៈទាំងអស់ដែលលោកសង្គ្រោះដោយប្រជុំព នៃបិដក ឈ្មោះថា បរិយត្តិសទ្ធម្ម" ។ ឯពាក្យថា ពុទ្ធវចនំ ប្រែថាព្រះពុទ្ធវចនៈនោះ អ្នកប្រាជ្ញគប្បីដឹងថា ពាក្យដែលសាវក ឬឥសី ឬទេវតា សំដែងហើយ តែព្រះពុទ្ធទ្រង់អនុមោទនាតាមក៏ឈ្មោះថា ពុទ្ធវចនៈ រាប់បញ្ចូលជាបរិយត្តិសទ្ធម្ម ។

មួយទៀត បរិយត្តិសទ្ធម្មនេះ លោកសំដែងថា ចាត់ដោយខន្ធ ជាពួកៗមាន ៨៤.០០០ ខន្ធ ទើបបានសម្មតហៅថា ៨៤.០០០ ព្រះធម្មក្ខន្ធ ។ សព្វថ្ងៃនេះពុំមានអ្នកណាត្រួតត្រារាប់មើលឲ្យដឹងថាលើសឬខ្វះបានឡើយ បរិយត្តិសទ្ធម្មនេះ អំពីដើមមក លោកទ្រទ្រង់ទុកដោយមុខបាឋ កាលប្រតិស្ឋានតាំងនៅក្នុងពួកព្រះអរិយៈជាអ្នកមានសន្តានដ៏បរិសុទ្ធ ព្រះបរិយត្តិសទ្ធម្មនេះក៏ជាធម៌បរិសុទ្ធស្អាត ប្រាសចាកសទ្ធម្មប្បដិរូប (ធម៌ប្លម) ដូចមាសក្នុងព្រះឃ្លាំងហ្លួងដ៏បរិសុទ្ធប្រាសចាករបស់ប្លម ។ លុះយូរមក

www.budinst.gov.kh www.elibraryofcambodia.org

ព្រះពុទ្ធសាសនាកន្លងទៅហើយបាន ៤០០ ឆ្នាំ ព្រះថេរៈទាំងឡាយ ក្នុងលង្កាទ្វីប ឃើញកុលបុត្រទាំងឡាយមានបញ្ញាតិច មិនអាចនឹងទ្រទ្រង់ទុកបានដោយមុខបាឋ ទើបចារឹកជាអក្សរទុកក្នុងស្លឹករឹត ។ លុះយូរមកកុលបុត្រមានបញ្ញាតិចចុះមកទៀត ទើបលោកតែងគម្ពីរអដ្ឋកថាអធិប្បាយបំភ្លឺព្រះបាលី តែងគម្ពីរដីកា អធិប្បាយបំភ្លឺអដ្ឋកថា ។ ព្រះបរិយត្តិសទ្ធម្មនេះ កាលប្រតិស្ឋានស្ថិតនៅក្នុងបុថុជ្ជន អ្នកមានសន្តានមិនបរិសុទ្ធ ដូចព្រះអរិយៈ ប្រៀបបីដូចជាមាសព្រាក់នៅក្នុងដៃប្រជា-ជន ។ បុគ្គលចំពូកខ្លះជាកល្យាណបុថុជ្ជនមានសន្តានដ៏ស្អាតត្រង់ គោរពក្នុងព្រះបរិយត្តិសទ្ធម្មដ៏ច្រើន ។ បុគ្គលចំពូកខ្លះមានសន្តានមិនបានស្អាតត្រង់ គោរពក្នុងព្រះបរិយត្តិសទ្ធម្មដ៏តិច ។ ព្រោះហេតុនោះ សទ្ធម្មបដិរូប (ធម៌ប្លម) ក៏ចូលប្លមព្រះសទ្ធម្មផង ។ បុគ្គលចំពូកខ្លះតាក់តែងឡើងហើយគាំថាជាពុទ្ធវចនៈ ក៏មានដូចកុលុម្ពសូត្រ រាជោវាទសូត្រ តិក្ខិន្ទ្រិយសូត្រជាដើម មានឈ្មោះប្រាកដនៅក្នុងអដ្ឋកថា សូត្រដូច្នោះ បុគ្គលជាអ្នកប្រាជ្ញរចនាទុកគាំថាពុទ្ធភាសិតខ្លះ សាវកភាសិតខ្លះ មាននៅជាច្រើន ដូចជា អគារវគារសូត្រ វិជ្ជានសូត្រ និងគម្ពីរដទៃ ៗ ។ ហេតុដូច្នោះ បើកុលបុត្រអ្នកមានប្រាជ្ញា កាលបើឃើញគម្ពីរនិងបាឋៈដែលលោកគាំថាជាពុទ្ធភាសិត និងសាវកភាសិតឯណាៗក្តី បើមាន

www.budinst.gov.kh www.elibraryofcambodia.org

សេចក្តីសន្ទិះសង្ស័យ គួរតែប្រើបដិបត្តិតាមមហាបទេស ៤ ដែលព្រះពុទ្ធ
អង្គទ្រង់សំដែងទុក ជាគ្រឿងកាត់សេចក្តីធម្មវិន័យ ហើយត្រូវតែមើល
ព្យញ្ជនៈ និង អត្ថ បើវិបត្តិហើយ កុំគប្បីជឿ បើមិនវិបត្តិសោតក៏គួរ
ជឿ ។ មួយទៀត ព្យញ្ជនៈបរិបូណ៌ព្រមហើយ តែអត្ថវិបត្តិ ក៏មិនគួរ
ជឿ ។ របៀបពាក្យណាចង្អុលអត្ថ គឺសេចក្តីបដិបត្តិមិនប្រព្រឹត្តទៅដើម្បី
វិន័យនាំចេញនូវអកុសល សង្កិលេសមានរាគៈជាដើម មិនបានរម្ងាប់នូវ
សេចក្តីលោភ សេចក្តីក្រោធ សេចក្តីវង្វេង ចេញបាន និងមិនប្រព្រឹត្ត
ទៅដើម្បីអភិញ្ញាសេចក្តីដឹងនៃត្រៃពេក ដឹងរបស់ពិត ៤ គឺអរិយសច្ច របៀប
ពាក្យនោះឈ្មោះថា វិបត្តិដោយអត្ថ មិនគួរជឿ ។ របៀបពាក្យណាសំដែង
អត្ថ គឺសេចក្តីបដិបត្តិប្រព្រឹត្តទៅដើម្បីវិន័យ នាំចេញបាននូវរាគៈ ទោសៈ
មោហៈ ដ៏ជាអកុសលសង្កិលេស និងប្រព្រឹត្តទៅដើម្បីអភិញ្ញាសេចក្តី
ដឹងនៃត្រៃពេក ដឹងនូវសេចក្តីពិតគឺសច្ចៈ ៤ របៀបពាក្យនោះ ឈ្មោះថា
បរិបូណ៌ព្រមដោយអត្ថសម្បត្តិ ជារបស់គួរជឿ ។

មួយទៀត គប្បីកាត់សេចក្តីបរិយត្តិសទ្ធម្ម ដោយទាក់ទងដែលព្រះ
ពុទ្ធអង្គទ្រង់សំដែងដល់នាងមហាបជាបតី ដែលនឹងសំដែងក្នុងបដិបត្តិ
សទ្ធម្មនោះផងចុះ ។ បរិយត្តិសទ្ធម្មនេះ ប្រែថាព្រះសទ្ធម្មគឺរបៀបពាក្យ
ដែលបុគ្គលគប្បីដល់ដោយជុំវិញ គឺសិក្សាសូត្ររៀនឲ្យដឹងតាមអត្ថា

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទុំផ្សាយក្នុងសំណាក់នៃគ្រូបាធ្យ ៗ មួយទៀត បរិយត្តិសទ្ធម្មនេះ ជាធម៌អាស្រ័យហេតុខាងក្នុងពីរប្រការ គឺទុស្សាហ៍ខំនិងបញ្ញា អាស្រ័យហេតុខាងក្រៅ គឺកាលសម្បត្តិ ទើបប្រព្រឹត្តទៅដោយបរិសុទ្ធបរិបូណ៌បាន ៗ

បរិយត្តិសទ្ធម្មកថា ចប់

www.budinst.gov.kh www.elibraryofcambodia.org

# បដិបត្តិសទ្ធម្មកថា

បុ. វត្ថុអ្វី ជាបដិបត្តិសទ្ធម្ម?

វិ. ត្រៃសិក្ខា គឺ សីល សមាធិ បញ្ញា, សិក្ខា ៣ នេះ ឈ្មោះថា បដិបត្តិសទ្ធម្ម ។

សីល គឺសេចក្តីសង្រួម កាយ វាចា តាមសិក្ខាបទបញ្ញត្តិ បានដល់ បាតិមោក្ខសំវរសីល ដែលជាជេដ្ឋកសីល សម្រេចដោយអរិយសម្មតិ និងវិរតិ ការវៀរចាកវចីទុច្ចរិត ៤ កាយទុច្ចរិត ៣ មិច្ឆាជីវៈ ១ ដែលហៅថា អាជីវដ្ឋមកសីល សីលមានអាជីវៈជាគំរប់ ៨ ដែលជាអាទិព្រហ្មចរិយកាសិក្ខា សម្រេចដោយសមាទានចេតនា ឈ្មោះថាសីលសិក្ខា ។

សមាធិ សេចក្តីតាំងចិត្តនៅក្នុងអារម្មណ៍តែមួយ គឺកុសលេកគ្គតា ភាពនៃចិត្តមានអារម្មណ៍តែមួយ ជាកុសលដែលកើតឡើងដោយសមថកម្មដ្ឋាន មានកសិណបរិកម្ម និងអសុភបរិកម្មជាដើម ដែលហៅថាអប្បនាសមាធិ ព្រោះជាសមាធិដែលជាប់ក្នុងអារម្មណ៍ ឬហៅថាអប្បនាឈាន ព្រោះជារបស់ដែលជាប់សំឡឹងអារម្មណ៍មានកសិណជាដើមក្តី និងឧបចារសមាធិ ដែលជាសមាធិមិនទាន់ដល់នូវអប្បនាក្តី ឈ្មោះថាសមាធិសិក្ខា ។

បញ្ញា សេចក្តីដឹងច្បាស់នូវសង្ខារ គឺនាមរូប និងបញ្ចក្ខន្ធជាដើម

www.budinst.gov.kh www.elibraryofcambodia.org

ជាជារបស់ មិនទៀង ជាទុក្ខ មិនមែនខ្លួន បានដល់វិបស្សនាបញ្ញា តាំងអំពីឧទយព្វយញ្ញាណដរាបដល់អនុលោមញ្ញាណ ដែលកើតឡើងដោយវិបស្សនាកម្មដ្ឋាននោះ ឈ្មោះថាបញ្ញាសិក្ខា ។

សីល សមាធិ បញ្ញា ទាំង ៣ នេះ ឈ្មោះថា សិក្ខា ព្រោះជាកិច្ចការក្នុងសាសនា ដែលបុគ្គលអ្នកប្រាថ្នានូវសេចក្តីអស់ទៅនៃទុក្ខ គប្បីសិក្សាឲ្យស្ទាត់ហើយបដិបត្តិតាម ។ សិក្ខាសព្ទនេះ ប្រែថា ការសិក្សាក៏បាន ប្រែថា ធម្មជាតិដែលបុគ្គលគប្បីសិក្សាក៏បាន តែក្នុងបទនេះត្រូវប្រែថា ធម្មជាតិដែលបុគ្គលគប្បីសិក្សា ព្រោះសីល សមាធិ បញ្ញា ជាធម្មជាតិ ដែលបុគ្គលគប្បីសិក្សា ដ្បិតលោកពោលត្រៃសិក្ខានេះ ថាជាបដិបត្តិសទ្ធម្ម ។ សេចក្តីបដិបត្តិដ៏សេសដែលជាឧបការៈដល់ត្រៃសិក្ខា ជាវត្តប្បវត្តិ ដែលព្រះពុទ្ធអង្គទ្រង់តែងតាំងទុកក្នុងវិនយខន្ធ មានបព្វជ្ជាខន្ធកនិងឧបោសថខន្ធកជាដើមក្តី និងសេចក្តីបដិបត្តិដែលព្រះពុទ្ធអង្គទ្រង់សំដែងទុក ក្នុងព្រះសូត្រ មានអបណ្ណកបដិបទា ៣ គឺ ឥន្ទ្រិយសំវរៈ ភោជនេមត្តញ្ញុតា ជាគរិយានុយោគៈ និងអរិយវង្សបដិបទាជាដើមក្តី សេចក្តីបដិបត្តិទាំងអស់នេះ ក៏ពោលថាបដិបត្តិសទ្ធម្មដែរ ព្រោះហេតុដូច្នោះ ព្រះអដ្ឋកថាចារ្យ កាលលោកពន្យល់បដិបត្តិសទ្ធម្ម ទើបលោកសំដែងថា ៖

www.budinst.gov.kh www.elibraryofcambodia.org

"តេរស ធុតង្គគុណា ចុទ្ទស ខន្ធកវត្តានិ
ទ្វាសីតិ មហាវត្តានិ សីល សមាធិវិបស្សនាតិ
បដិបត្តិសង្គហោ នាម

ប្រែថា ធុតង្គគុណទាំងឡាយ ១៣ វត្តទាំងឡាយដែលមកក្នុងខន្ធកវត្ត ១៤ មហាវត្តទាំងឡាយ ៨២ សីល សមាធិ វិបស្សនា ដូច្នេះ ទាំងអស់នេះ ឈ្មោះថា បដិបត្តិសង្គហ" ។

ធុតង្គគុណ ១៣ នោះគឺ បំសុកូលិកង្គៈ តេចីវរិកង្គៈ បិណ្ឌបាតិកង្គៈ សបទានចារិកង្គៈ ឯកាសនិកង្គៈ បត្តបិណ្ឌិកង្គៈ ខលុបច្ឆាភត្តិកង្គៈ សោសានិកង្គៈ អារញ្ញិកង្គៈ រុក្ខមូលិកង្គៈ អព្ភោកាសិកង្គៈ យថាសន្ថតិកង្គៈ នេសជ្ជិកង្គៈ ធុតង្គទាំង ១៣ នេះ កើតអំពីអរិយវង្សប្បដិបទា ។

ខន្ធកវត្ត ១៤ នោះគឺៈ អាគន្តុកវត្ត អាវាសិកវត្ត គមិកវត្ត អនុមោទនវត្ត ភត្តគ្គវត្ត បិណ្ឌបាតចារិកវត្ត អារញ្ញិកវត្ត សេនាសនវត្ត ជន្តាឃរវត្ត វច្ចកុដិវត្ត ឧបជ្ឈាយវត្ត សទ្ធិវិហារិកវត្ត អាចរិយវត្ត អន្តេវាសិកវត្ត ។

មហាវត្ត ៨២ នោះ គឺ វត្តដែលព្រះអង្គទ្រង់បញ្ញត្តដល់ភិក្ខុបរិវាសិកៈ តាំងអំពីឃាត់មិនឲ្យឧបសម្បទដល់កុលបុត្រ ដរាបដល់ឃាត់ថា កាលភិក្ខុជាបកតត្តៈបង្រ្កមនៅលើផែនដី កុំបង្រ្កមលើទីបង្រ្កមណ៍ជាទីបំផុត រាប់បាន ៦៦ និងវត្តដែលព្រះអង្គទ្រង់ឃាត់ថា កុំនៅក្នុងអាវាសដែលប្រក់បាំងក្នុងទីជាមួយគ្នាមួយអន្លើដោយភិក្ខុបរិវាសិកៈចាស់ជាង និងដោយភិក្ខុ

www.budinst.gov.kh www.elibraryofcambodia.org

ជាមូលាយបដិកស្សនារហៈ និងភិក្ខុជាមានត្តារហៈ ភិក្ខុជាមានត្តចារី ភិក្ខុជាអព្ភានារហៈ រាប់បាន ៥ ផ្សំនឹងវត្ត ៦៦ ត្រូវជា ៧១ មួយអន្លើនឹងវត្តដែលព្រះពុទ្ធអង្គទ្រង់បញ្ញត្តដល់ភិក្ខុ ដែលសង្ឃធ្វើឧក្ខេបនីយកម្ម ឃាត់មិនឲ្យត្រេកអរសាមីចិកម្ម មានការក្រាបសំពះជាដើម នៃភិក្ខុជាបកតត្តៈរាប់ជា ១ មួយអន្លើនឹងវត្តមានឃាត់មិនឲ្យចោទភិក្ខុជាបកតត្តៈដោយសីលវិបត្តិជាដើម ១០ទៀត រួមគ្នាជា ១១ ទើបគ្រប់ជាមហាវត្ត ៨២ ៗ មហាវត្ត៨២នេះជាវត្តគប្បីប្រព្រឹត្តក្នុងកាលម្តង ៗ មិនត្រូវប្រព្រឹត្តក្នុងកាលទាំងពួង ព្រោះហេតុនោះ ទើបមិនបានរាប់បញ្ចូលក្នុងខន្ធកវត្ត ១៤ ៗ សីលសមាធិនោះដូចសំដែងមកហើយ តែបញ្ញាក្នុងបទនេះហៅថាវិបស្សនា ព្រោះលោកបំណងឲ្យឃើញថា ត្រៃសិក្ខាដែលចាត់ជាបដិបត្តិសទ្ធម្មនេះ ជាលោកិយធម៌ មិនមែនជាលោកុត្តរធម៌ ៗ បដិបត្តិសទ្ធម្មនេះ កាលប្រតិស្ឋានទៅក្នុងព្រះអរិយៈលោកមានសន្តានដ៏បរិសុទ្ធ និងកល្យាណបុថុជ្ជនលោកមានសន្តានដ៏ស្អាតគ្រប់ប្រកបដោយប្រាជ្ញា និងអាស្រ័យកាលសម្បត្តិក៏បរិបូណ៌បរិសុទ្ធប្រាសចាកទោសគឺសទ្ធម្មបដិរូប ដូចមាសដែលប្រតិស្ឋានទៅក្នុងដៃនៃមនុស្សស្អាតគ្រប់ឈ្លាសវៃមើលដឹងរបស់ពិតនិងរបស់ប្លម ឬអាស្រ័យកាលសម្បត្តិផង ក៏បរិបូណ៌បរិសុទ្ធប្រាសចាកទោស គឺជារូបបដិរូបរបស់ធ្វើប្លម ៗ បដិបត្តិសទ្ធម្មនេះ កាលអាស្រ័យកាលវិបត្តិ ក៏មិនបរិបូណ៌និងអាស្រ័យបុថុជ្ជនអ្នកមានសន្តានមិនស្អាតគ្រប់ប្រកបដោយអគារវៈច្រើន

www.budinst.gov.kh www.elibraryofcambodia.org

ដោយសំឡឹងលោកាមិស ក៏ជាការមិនបានបរិបូណ៌បរិសុទ្ធប្រាសចាក ទោស បដិបត្តិសទ្ធម្មបដិរូបក៏កើតឡើង ដូចពួកកុទិដ្ឋិប្រកបញត្តនូវវត្ថុ ១០ ប្រការ ក្នុងកាលមុននោះ ព្រោះហេតុនោះបដិបត្តិសទ្ធម្ម ដែលតាំងតៗគ្នា មកអស់កាលយូរដរាបមកដល់កាលឥឡូវនេះ ម្តេចឡើយក៏មិនសាបសូន្យ សៅហ្មង សេចក្តីបដិបត្តិជាការមិនពិត និងសេចក្តីបដិបត្តិប្លមដែលឈ្មោះ ថា សទ្ធម្មបដិរូប ក៏កើតឡើងផ្សេងៗ ដូចប្រកាន់ថាដើរចង្ក្រមតាមបត្តិជ្ញាក់ អស់យូរៗបរិកាស មានត្តបេញម្តង ជំរះខ្លួនឲ្យបរិសុទ្ធ និងបដិបត្តិបែបដទៃ ទៀតក្នុងផ្លូវសីលគឺមានជាច្រើន និងប្រកាន់បរិកម្មថា អ.សំ.វិ.សុ.លោ. បុ.ស.ពុ.ក ឈ្មោះថាចំរើនពុទ្ធគុណក្តី និងអញ្ជើញព្រះបរិត្តទាំង ៨ និង តាំងចិត្តទុកក្នុងខ្លួនជាដើម ហើយបរិកម្មថា អរហំៗ មិនដឹងអធិប្បាយថា ជាអ្វីឡើយ ហើយឃើញពណ៌ផ្សេងៗ សំគាល់ថា ព្រះមកប្រោស ហើយ ក៏ប្រកាន់ថា សំរេចក្នុងភូមិសមាធិប៉ុណ្ណោះ និងបដិបត្តិក្នុងសមាធិបញ្ញា ដែលខុសទៅជាបែបដទៃៗ ដែលជ្រោកជ្រាកនិងល្អិតជាងពោលមកនេះ ក៏មានច្រើន កាលបើដូច្នេះ អ្នកស្វែងរកបដិបត្តិសទ្ធម្មដែលពិតប្រាកដ គប្បីធ្វើខ្លួនឲ្យជាមនុស្សស្លូតត្រង់ ស្វែងរកនូវបរិយត្តិសទ្ធម្មដែលពិត ប្រាកដនោះចុះ ក៏គង់នឹងបានដឹងបានឃើញ ។

មួយទៀត បើមានសេចក្តីសង្ស័យក្នុងផ្លូវបដិបត្តិនិងបរិយត្តិចំពូកខ្លះ

www.budinst.gov.kh www.elibraryofcambodia.org

ហើយ គប្បីកាត់សេចក្តីសង្ស័យដោយទទួល ដែលព្រះពុទ្ធអង្គទ្រង់ប្រដៅនាងបជាបតិគោតមីថ្វាយព្រះថា ម្នាលនាងគោតមី បើនាងដឹងថា ធម៌ទាំងឡាយណា ប្រព្រឹត្តទៅដើម្បីសរាគៈប្រកបដោយតម្រេកនៃចិត្ត មិនប្រព្រឹត្តទៅដើម្បីវិរាគៈ សេចក្តីប្រាសចាកតម្រេកនៃចិត្ត, ប្រព្រឹត្តទៅដើម្បីសំយោគៈ សេចក្តីប្រកបព្រមដោយទុក្ខ មិនប្រព្រឹត្តទៅដើម្បីវិសំយោគៈ សេចក្តីប្រាសចាកទុក្ខ, ប្រព្រឹត្តទៅដើម្បីអាចយៈសេចក្តីសន្សំរឿយៗនូវវដ្តៈ មិនប្រព្រឹត្តទៅដើម្បីអបចយៈសេចក្តីមិនសន្សំរឿយៗនូវវដ្តៈ ប្រព្រឹត្តទៅដើម្បីមហិច្ឆតា ភាពជាអ្នកមានសេចក្តីប្រាថ្នាច្រើន មិនប្រព្រឹត្តទៅដើម្បីអប្បិច្ឆតា ភាពជាអ្នកមានសេចក្តីប្រាថ្នាតិច, ប្រព្រឹត្តទៅដើម្បីអសន្តុដ្ឋិ សេចក្តីមិនសន្តោស ត្រេកអរដោយវត្ថុដែលខ្លួនមាន មិនប្រព្រឹត្តទៅដើម្បីសន្តុដ្ឋិ សេចក្តីសន្តោសត្រេកអរដោយវត្ថុដែលខ្លួនមាន, ប្រព្រឹត្តទៅដើម្បីសង្គណិកា ភាពជាអ្នកច្រឡូកច្រឡំដោយពួក មិនប្រព្រឹត្តទៅដើម្បីបវិវេក សេចក្តីស្ងាត់ចាកពួក, ប្រព្រឹត្តទៅដើម្បីកោសជ្ជៈសេចក្តីខ្ជិលច្រអូស មិនប្រព្រឹត្តទៅដើម្បីវិរិយារម្ភៈសេចក្តីប្រារព្ធនូវព្យាយាម, ប្រព្រឹត្តទៅដើម្បីទុព្ភរតា ភាពជាអ្នកដែលគេចិញ្ចឹមបានដោយក្រ មិនប្រព្រឹត្តទៅដើម្បីសុភរតា ភាពជាអ្នកដែលគេចិញ្ចឹមបានដោយងាយ ៗ ម្នាលនាងគោតមី នាងគប្បីចាំទុកដោយដាច់ខាតចុះថា

www.budinst.gov.kh www.elibraryofcambodia.org

នុ៎ះមិនមែនជាធម៌ នុ៎ះមិនមែនជាវិន័យ នុ៎ះមិនមែនជាសត្ថុសាសនៈ ពាក្យប្រដៅរបស់ព្រះសាស្តាទេ ។ ម្នាលនាងគោតមី បើនាងដឹងថា ធម៌ទាំងឡាយណា ប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេកនៃចិត្ត មិនបានប្រព្រឹត្តទៅដើម្បីតម្រេកនៃចិត្ត, ប្រព្រឹត្តទៅដើម្បីប្រាសចាកទុក្ខ មិនប្រព្រឹត្តទៅដើម្បីប្រកបដោយទុក្ខ, ប្រព្រឹត្តទៅដើម្បីមិនសន្សំធ្វើឲ្យច្រើនឡើងនូវវដ្តៈ មិនប្រព្រឹត្តទៅដើម្បីសន្សំធ្វើឲ្យច្រើនឡើងនូវវដ្តៈ, ប្រព្រឹត្តទៅដើម្បីជាអ្នកមានសេចក្តីប្រាថ្នាតិច មិនប្រព្រឹត្តទៅដើម្បីជាអ្នកមានសេចក្តីប្រាថ្នាច្រើន, ប្រព្រឹត្តទៅដើម្បីសន្តោសត្រេកអរ ដោយវត្ថុដែលខ្លួនមាន មិនប្រព្រឹត្តទៅដើម្បីមិនសន្តោស, ប្រព្រឹត្តទៅដើម្បីបវិវេក សេចក្តីស្ងាត់ចាកពួក មិនប្រព្រឹត្តទៅដើម្បីជាអ្នកច្រឡូកច្រឡំដោយពួក, ប្រព្រឹត្តទៅ ដើម្បីប្រារព្ធ នូវសេចក្តីព្យាយាម មិនបានប្រព្រឹត្តទៅដើម្បីសេចក្តីខ្ជិលច្រអូស, ប្រព្រឹត្តទៅ ដើម្បីភាពជាអ្នកដែលគេចិញ្ចឹមងាយ មិនប្រព្រឹត្តទៅដើម្បីភាពជាអ្នកដែលគេចិញ្ចឹមបានដោយក្រ ។ ម្នាលនាងគោតមី នាងគប្បីចាំទុកដោយដាច់ខាតចុះថា នុ៎ះជាធម៌ នុ៎ះជាវិន័យ នុ៎ះជាសត្ថុសាសនៈ ពាក្យប្រដៅរបស់ព្រះសាស្តា" ។ សុត្តគោតមីនេះ ជាលក្ខណៈសម្រាប់កាត់សេចក្តីនៃព្រះសទ្ធម្ម និង សទ្ធម្មបដិរូប ។

ក៏ឯបដិបត្តិសទ្ធម្មនេះ ប្រែថា សទ្ធម្ម គឺសេចក្តីចរទៅ ដំណើរទៅ

www.budinst.gov.kh www.elibraryofcambodia.org

ព្បិតថា ត្រៃសិក្ខានេះ ជាផ្លូវនៃព្រះនិព្វាន កាលបើកុលបុត្រសិក្សា ហើយបដិបត្តិតាម ក៏ឈ្មោះថា ចរទៅ ដំណើរទៅ តាមផ្លូវព្រះនិព្វាន ។ បដិបត្តិសទ្ធម្មនេះ ជាធម៌អាស្រ័យហេតុខាងក្នុង គឺសទ្ធានឹងបញ្ញា ទាំងពីរប្រការ ទើបកើតឡើងបរិបូណ៌បរិសុទ្ធបាន ។

**បដិបត្តិសទ្ធម្មកថា ចប់**

www.budinst.gov.kh www.elibraryofcambodia.org

# អធិគមសទ្ធម្មកថា

ប. អធិគមសទ្ធម្ម នោះ ដូចម្តេច ?

វិ. មគ្គ ៤ ផល ៤ និព្វាន ១ ឈ្មោះថាអធិគមសទ្ធម្ម ។

មគ្គ ប្រែថា ផ្លូវ ធម៌ ៨ ប្រការគឺ សម្មាទិដ្ឋិ ការឃើញប្រពៃ គឺឃើញសច្ចៈ ៤, សម្មាសង្កប្បោ ការត្រិះរិះប្រពៃ គឺត្រិះរិះប្រកប ដោយនេក្ខម្មៈ អព្យាបាទ អវិហិង្សា, សម្មាវាចា វាចាប្រពៃ គឺការ វៀរចាកវចីទុច្ចរិត ៤, សម្មាកម្មន្តោ ការងារប្រពៃ គឺការវៀរចាក កាយទុច្ចរិត ៣, សម្មាអាជីវោ ការចិញ្ចឹមជីវិតប្រពៃ គឺការលះបង់ នូវមិច្ឆាជីវៈ ការចិញ្ចឹមជីវិតខុស, សម្មាវាយាមោ ការព្យាយាមប្រពៃ គឺសម្មប្បធាន ៤, សម្មាសតិ ការរលឹកប្រពៃ គឺសតិប្បដ្ឋាន ៤, សម្មា សមាធិ ការតាំងចិត្តទុកប្រពៃគឺឈាន ៤ ។ ចេតសិកធម៌ ៨ នេះ ឈ្មោះថាអង្គនៃមគ្គជាទីប្រជុំនៃធម៌ ៨ ដែលកើតឡើងព្រមគ្នាធ្វើកិច្ចរបស់ ខ្លួនៗនោះ ឈ្មោះថាមគ្គព្រោះជាផ្លូវនៃព្រះនិព្វាន ដោយវោហារបញ្ញត្តិ នៃព្រះពុទ្ធអង្គ ព្រោះហេតុនោះ ព្រះពុទ្ធអង្គទើបទ្រង់សំដែងថា មគ្គជា របស់ព្រះអរិយៈប្រកបដោយអង្គ ៨ ។

ផល ប្រែថា ការបែកចេញ គឺសេចក្តីចាស់ក្លាមកអំពីមគ្គ បាន

www.budinst.gov.kh www.elibraryofcambodia.org

ផលការរម្ងាប់នៃប្រយោគ ក្នុងកិរិយាបញ្ចាកកិលេស នៃសម្មាទិដ្ឋិ ជាដើម នេះឈ្មោះថា ផល ។

ដែលឈ្មោះថា មគ្គ ៤ ផល ៤ នោះ គឺ សោតាបត្តិមគ្គ សោតា-បត្តិផល សកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល អរហត្តមគ្គ អរហត្តផល ។

ឯមគ្គ ៤ ផល ៤ នោះ តាមនិយមដែលលះកិលេសនោះៗ បាន នឹងគុណវិសេសដែលសំរេចមកអំពីការលះកិលេស ។

នឹងសំដែងអំពីកិលេសដែលមគ្គនោះៗត្រូវលះបង់សិនៗ សំយោជនៈ មាន ១០ គឺ សក្កាយទិដ្ឋិ ការឃើញខុសអាស្រ័យខន្ធ ឈ្មោះថា សក្កាយៈ គឺការឃើញរូបថាជាខ្លួន ខ្លួនជារូប ដូចប្រទីបកំពុងនេះ ឃើញ អណ្តាតជាពន្លឺ ពន្លឺជាអណ្តាត, នឹងឃើញថាខ្លួនមានរូប ដូចដើមឈើ មានស្រមោល, នឹងឃើញថារូបក្នុងខ្លួន ដូចជាក្លិនក្នុងផ្កាឈើ, នឹងឃើញ ថាខ្លួនក្នុងរូប ដូចកែវមណីក្នុងប្រអប់; ឃើញវេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាខ្លួន ខ្លួន ជាវេទនា ជាសញ្ញា ជាសង្ខារ ជាវិញ្ញាណ, ខ្លួនមាន វេទនា សញ្ញា សង្ខារ វិញ្ញាណ ដូច្នេះជាដើម ១ ។

វិចិកិច្ឆា ការសង្ស័យក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ នឹងក្នុង កាលទាំងបី ១ សីលព្វតបរាមាសៈ ការបរាមាសអង្អែល គឺប្រកាន់ ថាបរិសុទ្ធដោយសីលវត្តខាងក្រៅសាសនា គឺប្រក្រតី ទំនៀម ដូចវត្តគោ

ជាដើម ១ កាមរាគៈ ការត្រេកត្រអាលក្នុងកាមគុណមានអារម្មណ៍ដែលគួរឃើញជាដើម ១ បដិឃៈ ការថ្នាំងថ្នាក់នៃចិត្ត ១ រូបរាគៈ ការត្រេកអរក្នុងរូប គឺរូបាវចរឈាននិងរូបាវចរភព ១ អរូបរាគៈ ការត្រេកអរក្នុងអរូបធម៌ គឺអរូបាវចរឈាន និង អរូបាវចរភព ១ មានៈ ការសំគាល់ឃើញថាយើងប្រសើរ យើងដូចគេ យើងទាបជាងគេ ជាដើម ១ ឧទ្ធច្ចៈ ការអណ្ដែតអណ្ដូងមិនស្ងប់ចិត្ត ១ អវិជ្ជា ការមិនដឹងច្បាស់នូវអរិយសច្ចជារបស់ពិត ៤ យ៉ាង ១ កិលេស ១០ នេះឈ្មោះថា សំយោជនៈ ព្រោះជាគ្រឿងប្រកប គ្រឿងគន់នូវខន្ធ ដោយខន្ធ និងគន់នូវកម្មដោយផល ៗ មួយទៀត ព្រោះជាគ្រឿងប្រកបសត្វទុកដោយទុក្ខ ទើបបានឈ្មោះថា សំយោជនៈ ៗ

សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ កាមរាគៈ បដិឃៈ ទាំង ៥ នេះឈ្មោះថា ឱរម្ភាគិយសំយោជនៈ ប្រែថា សំយោជនៈចំណែកខាងក្រោមគឺ កាមភព ព្រោះជាគ្រឿងធ្វើសត្វឲ្យកើតក្នុងកាមភពដែលជាចំណែកខាងក្រោម ៗ

សំយោជនៈ ចំណែកខាងចុង ៥ គឺ រូបរាគៈ អរូបរាគៈ មានៈ ឧទ្ធច្ចៈ អវិជ្ជា នេះឈ្មោះថា ឧទ្ធម្ភាគិយសំយោជនៈ ប្រែថា សំយោជនៈចំណែកខាងលើ ព្រោះជាកិលេសដ៏ល្អិតមានដល់សត្វដែលកើតក្នុងរូបភពនិងអរូបភព និងធ្វើសត្វឲ្យកើតក្នុងរូបភពនិងអរូបភព ៗ

www.budinst.gov.kh www.elibraryofcambodia.org

សំយោជនៈ ៣ គឺ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ សោតា-
បត្តិមគ្គ លះដាច់ ព្រមទាំងលះកាមរាគៈ បដិឃៈ ដែលជាអបាយគាមី
ជាកិលេសគ្នា ញុំាងសត្វឲ្យទៅកើត ក្នុងអបាយភូមិបាន ។ កាមរាគៈ
បដិឃៈ ទាំងពីរនេះជាចំណែកគ្រោតគ្រាត សកទាគាមិមគ្គ លះដាច់
ព្រោះសកទាគាមិមគ្គធ្វើ រាគៈ ទោសៈ មោហៈ ឲ្យស្រាលស្តើង ទើប
លះកិលេសដូច្នេះបាន ។ កាមរាគៈ បដិឃៈ សំយោជនៈពីរនេះ ដែលជា
កិលេសដ៏ល្អិតសល់នៅនោះ គឺអនាគាមិមគ្គលះបាន ដោយដាច់ខាត ។
ឧទ្ធម្ភាគិយសំយោជនៈទាំង ៥ នោះ អរហត្តមគ្គ លះបង់បានដោយ
មិនមានសេសសល់ ដូច្នេះ ឈ្មោះថាមគ្គ ៤ ដោយនិយមនៃកិលេស-
ប្បហានៈ ការលះកិលេសនោះដូច្នេះឯង អ្នកប្រាជ្ញគប្បីដឹងចុះ ។
ចំណែកផលដែលសំដែងមកថាមាន ៤ នោះ ក៏តាមនិយមនៃមគ្គ ព្រោះថា
សោតាបត្តិមគ្គកើតឡើង ក៏សម្រេចកិច្ចរបស់ខ្លួន គឺសម្លាប់សំយោជនៈ ៣
ដាច់ហើយរលត់ទៅ សោតាបត្តិផល ដែលជាគុណគឺការស្ងប់រម្ងាប់
នៃសេចក្តីខ្វល់ខ្វាយក្នុងកិច្ចដែលខំសម្លាប់ នូវសំយោជនៈនោះទៀត ក៏
កើតឡើងក្នុងលំដាប់នៃសោតាបត្តិមគ្គនោះ ។ សូម្បីសកទាគាមិផល
អនាគាមិផល អរហត្តផល ទាំងអម្បាលនេះក៏ដូចគ្នា ព្រោះជាគុណ គឺ
ការស្ងប់ នៃប្រយោគក្នុងកិច្ចដែលខំរេញ្ញតកកិលេស សម្លាប់កិលេស
នោះ ៗ កើតឡើងក្នុងលំដាប់នៃមគ្គនោះ ៗ ដូច្នេះឯង ទើបបានឈ្មោះថា

www.budinst.gov.kh www.elibraryofcambodia.org

ផលដែរដោយនិយមនៃប្រយោគបរិសុទ្ធិ ការស្ងប់នៃប្រយោគនោះដូច្នេះ ។

មួយទៀត មគ្គជាហេតុ គឺលោកុត្តរកុសល ផលជាសេចក្តីចាស់ក្លានៃមគ្គគឺលោកុត្តរវិបាក ផលកើតអំពីមគ្គ មគ្គកើតអំពីគោត្រភូ គោត្រភូកើតអំពីអនុលោម អនុលោមកើតអំពីឧបចារៈ ឧបចារៈកើតអំពីសង្ខា-រុបេក្ខាញាណ គឺវិបស្សនាបញ្ញាដែលមានកំឡាំងក្លាជាងវិបស្សនាញាណទាំង ៧ មានឧទយព្វយានុបស្សនាញាណជាដើម ។ មគ្គនិងផលកើតឡើងក្នុងវិថីចិត្តជាមួយគ្នា ។ ចិត្តជាកុសលក្តី ជាអកុសលក្តី កើតឡើងក្នុងខណៈនៃជវន គឺការស្ទុះទៅនៃចិត្ត ។ ជវនចិត្តស្ទុះទៅ គឺកើតឡើងតាំងនៅរលត់ទៅ តែប្រាំពីរដងជាយ៉ាងក្រៃពេក ។ ព្រះយោគាវចរឃើញថាសង្ខារមិនទៀងជាទុក្ខ មិនមែនរបស់ខ្លួន ដោយបញ្ញាដ៏ចាស់ក្លា ជាប់ដល់ព្រងើយកន្តើយក្នុងសង្ខារទាំងពួង ។ ការឃើញដូច្នេះ ឈ្មោះថាសង្ខា-រុបេក្ខាញាណ ។ សង្ខារុបេក្ខាញាណ កាលបើមានកម្លាំងខ្លាំងក្លាហើយ ក្នុងខណៈនៃមគ្គនិងកើតឡើងនោះ ចិត្តដែលសម្បយុត្តដោយសង្ខារុបេក្ខា-ញាណចុះកាន់ភវង្គហើយ មនោទ្វារាវជ្ជនចិត្ត ដែលជាកិរិយា ក៏កើតឡើង ជវនចិត្តប្រព្រឹត្តទៅប្រាំពីរដង ជវនចិត្តជាដំបូង ឈ្មោះថា បរិកម្ម ជវនចិត្តជាគំរប់ពីរ ឈ្មោះថា ឧបចារៈ ជវនចិត្តជាគំរប់បី ឈ្មោះថា អនុលោម ជវនចិត្តជាគំរប់បួន ឈ្មោះថា គោត្រភូ ជវនចិត្តជាគំរប់ប្រាំជាកិច្ចៈនៃមគ្គ ជវនចិត្តជាគំរប់ប្រាំមួយ-ប្រាំពីរ ឈ្មោះថា ផល ។ បញ្ញាដែលមានក្នុង

www.budinst.gov.kh www.elibraryofcambodia.org

ចិត្តក្ខណៈទាំង ៣ គឺបរិកម្ម ឧបចារៈ អនុលោម នោះរួមចូលគ្នា ឈ្មោះថា អនុលោមញាណ ព្រោះជារបស់អនុលោមដល់វិបស្សនាញាណទាំង ៨ មានឧទយព្វយានុបស្សនាញាណជាដើម ក្នុងខាងក្រោម និងជារបស់អនុលោមដល់ពោធិបក្ខិយធម៌ ៣៧ ក្នុងខាងលើ ។ បញ្ញាក្នុងខណៈចិត្តឈ្មោះថាគោត្រភូនោះ ហៅថាគោត្រភូញាណ ព្រោះជាបញ្ញាគ្របសង្កត់នូវគោត្រ គឺភូមិនៃបុថុជ្ជន និងចូលកាន់អរិយភូមិ ។ បញ្ញាក្នុងខណៈនៃមគ្គចិត្តនោះ ឈ្មោះថា មគ្គញាណ ព្រោះធ្វើនូវកិច្ច ៤ ប្រការគឺបរិញ្ញា កំណត់ដឹងនូវទុក្ខ ១ បហានៈលះកិលេស ១ សច្ឆិកិរិយា ឃើញព្រះនិព្វាន ១ ភាវនា ញុំាងមគ្គឲ្យកើតឡើង ១ ។ បញ្ញាក្នុងខណៈផលចិត្តនោះ ឈ្មោះថា ផលញ្ញាណ ព្រោះជាការស្ងប់នៃប្រយោគក្នុងកិច្ចដែលនឹងលះនូវកិលេស ។ ឯអនុលោមញាណ ៣ នោះ ជាលោកិយកុសល លោកិយ-បញ្ញា ធ្វើនូវសង្ខារឲ្យជាអារម្មណ៍ ដោយសេចក្តីថាមិនទៀង ជាទុក្ខ មិនមែនជារបស់ខ្លួន និងជាញាណទីបំផុតនៃវុដ្ឋានគាមិនីវិបស្សនា ដែលមានសង្ខារជាអារម្មណ៍ សំដែងដោយវិសេស គោត្រភូញាណជាទីបំផុតនៃវុដ្ឋានគាមិនីវិបស្សនា តែថាជាលោកិយបញ្ញាលះបង់នូវសង្ខារចេញ ចាប់យកព្រះនិព្វានជាអារម្មណ៍ និងជាញាណកាន់នៅក្នុងកិច្ចជាអាវជ្ជនៈនៃមគ្គ ។ លោកិយបញ្ញាដែលឃើញព្រះនិព្វានមុន មានតែគោត្រភូញាណមួយប៉ុណ្ណោះ តែថាលះកិលេសមិនបាន ។ មគ្គញាណជាលោកុត្តរកុសល

www.budinst.gov.kh www.elibraryofcambodia.org

លោកុត្តរប្បញ្ញា ធ្វើព្រះនិព្វានជាអារម្មណ៍សម្លាប់នូវកិលេសបាន ទើបបាន ជាលោកុត្តរកុសល លោកុត្តរប្បញ្ញា ។ ផលញ្ញាណក៏ជាលោកុត្តរប្បញ្ញា ធ្វើព្រះនិព្វានជាអារម្មណ៍ តែជាមិនសម្លាប់កិលេស គ្រាន់តែជាអានិសង្ស គឺការស្ងប់រម្ងាប់នៃសេចក្តីខ្វល់ខ្វាយក្នុងកិច្ចដែលនឹងសម្លាប់កិលេស ប៉ុណ្ណោះ ទើបបានជាលោកុត្តរវិបាក ជាផលដ៏ចាស់ក្លាកើតមកអំពីមគ្គ ។

មួយទៀត ផលចិត្តក្នុងមគ្គវិថីនេះជា ៣ ក៏មាន ព្រោះអនុលោមចិត្ត កើតតែពីរដង មិនបានកើតបីដងដូចវារៈមុន គោត្រភូចិត្តកើតក្នុងវារៈ គំរប់ ៣ មគ្គចិត្តកើតក្នុងវារៈជាគំរប់ ៤ ផលចិត្តទើបជា ៣ ដូច្នេះ ក៏ឯ ផលចិត្តនោះចុះកាន់ភវង្គៈហើយ មនោទ្វារាវជ្ជនចិត្តកើតឡើងហើយ តទៅ មគ្គប្បច្ចវេក្ខណញ្ញាណ គឺបញ្ញាដែលពិចារណាមគ្គក៏កើតឡើងស្ទុះទៅ ៧ ដងដូចគ្នា សូម្បីផលប្បច្ចវេក្ខណញ្ញាណ បញ្ញាដែលពិចារណាផល នឹងបហីនកិលេសប្បច្ចវេក្ខណញ្ញាណ បញ្ញាពិចារណាកិលេស ដែលមគ្គ លះហើយក្តី នឹងអវសិដ្ឋកិលេសប្បច្ចវេក្ខណញ្ញាណ បញ្ញាពិចារណា កិលេសដែលសល់នៅក្តី នឹងនិព្វានប្បច្ចវេក្ខណញ្ញាណ បញ្ញាពិចារណា នូវព្រះនិព្វានក្តី ទាំងអស់នេះក៏កើតឡើងតាមលំដាប់ ដោយនិយមដូច សំដែងមកហើយក្នុងមគ្គប្បច្ចវេក្ខណញ្ញាណនោះ បច្ចវេក្ខណញ្ញាណទាំង ៥ នេះ រមែងកើតមានដល់ព្រះអរិយៈ ជាចំណែកខាងក្រោម ៣ ពួកគឺ ព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី តែព្រះអរហន្តនោះ

www.budinst.gov.kh www.elibraryofcambodia.org

មានតែ ៤ ព្រោះអស់ផ្តាច់កិលេសបច្ចវេក្ខណញ្ញាណ មិនមាន ដែលសំដែងមកនេះ មិនបាននិយម ជាមគ្គ ផលណាមួយឡើយ គ្រាន់តែសំដែងដោយសាមញ្ញ ដើម្បីនឹងឲ្យដឹងលំដាប់ករៈ នៃមគ្គចិត្តនឹងផលចិត្តប៉ុណ្ណោះ ៗ ឯមគ្គទាំង ៤ មគ្គនីមួយៗកើតក្នុងចិត្តវារៈមួយៗ គ្រប់ៗ មគ្គមិនកើតច្រើនដងដូចជាផល ចំណែកផលទាំង ៤ នោះ ផលនីមួយៗក្នុងមគ្គវិថីនីមួយៗ កើតឡើង ២ ដងខ្លះ ៣ ដងខ្លះ ដូចសំដែងមកហើយក្នុងផលសមាបត្តិវិថី គឺការដែលព្រះអរិយៈនោះៗ នឹងចូលកាន់ផលសមាបត្តិ រមែងប្រព្រឹត្តទៅតែតាមផលនិយមនៃខ្លួនៗ ៗ ផលចិត្តនោះកើត ៣ ដងខ្លះ ៤ ដងខ្លះ ព្រោះមគ្គចិត្តនោះមិនមានក្នុងវិថីនៃផលសមាបត្តិ ព្រោះជាកិច្ចដែលនឹងសម្លាប់នូវកិលេសដែលមគ្គនោះៗសម្លាប់ហើយទៀត ក៏មិនមានដល់ព្រះអរិយៈដែលបានហើយនូវផលនោះ ៗ មួយទៀតព្រះអរិយៈដែលបាននូវសោតាបត្តិផលហើយ ឈ្មោះជាព្រះសោតាបន្ន ព្រះសោតាបន្ននោះ អង្គខ្លះគង់លើអាសនៈដែលបានផលនោះឯង ចំរើននូវវិបស្សនាតទៅឡើងទៅបានសកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល នឹងអរហត្តមគ្គ អរហត្តផល ដោយលំដាប់ក៏មាន អង្គខ្លះក្រោកចាកអាសនៈនោះហើយ ក្នុងសម័យដទៃចំរើននូវវិបស្សនាតទៅឡើងទៅទើបបានសំរេចនូវមគ្គនឹងផលនោះៗដោយលំដាប់ក៏មាន ។ ឯសោតាបត្តិមគ្គ សោតាបត្តិផល ប្រែថា មគ្គ ថា ផល នៃលោកអ្នកសំរេចនូវធម៌

www.budinst.gov.kh www.elibraryofcambodia.org

ជាដំបូងឈ្មោះថា សោតៈ គឺ មគ្គ ។ សោតៈសព្ទនេះ ប្រែថា "ក្រសែនៃទឹក" តែក្នុងបទនេះ សោតៈសព្ទ ជាឈ្មោះនៃមគ្គ ព្រោះថាមគ្គ ដូចជាក្រសែនៃទឹក ដែលនឹងនាំសត្វទៅកាន់ព្រះនិព្វាន ព្រោះហេតុនោះ ព្រះពុទ្ធអង្គ ទ្រង់ត្រាស់ថា :

"និព្វាននិន្នា ភិក្ខវេ សម្មាទិដ្ឋិ និព្វានបោណា និព្វានបព្ភារា សេចក្តីថា ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិ ការឃើញប្រពៃ ដែលជាប្រធាននៃអដ្ឋង្គមគ្គ រមែងជាធម៌ដ៏ទេរទៅកាន់ព្រះនិព្វាន ជាធម៌ទោរទៅកាន់ព្រះនិព្វាន ជាធម៌ឱនទៅកាន់ព្រះនិព្វាន ដូចជាខ្សែនៃទឹកដែលហូរទៅកាន់មហាសមុទ្រ" ដូច្នោះ ។ ព្រះអរិយៈដែលសម្រេចនូវមគ្គផលខាងដើម ឈ្មោះថាជាបឋមបុគ្គលចុះកាន់ប្រឡាយព្រះនិព្វានគឺមគ្គ ព្រោះហេតុដូច្នោះ ទើបបានប្រែថាដូច្នេះ ។ សកទាគាមិមគ្គ សកទាគាមិផល ប្រែថា មគ្គ ជាផល នៃព្រះអរិយៈដែលមកកាន់លោកនេះម្តងទៀត ព្រោះថាព្រះអរិយៈដែលសម្រេចនូវផលជាគំរប់ពីរនេះ រមែងមកកើតក្នុងកាមភពនេះម្តងទៀត ហើយទើបធ្វើនូវទីបំផុតនៃទុក្ខ គឺដល់នូវព្រះអរហត្ត ហើយរលត់ខន្ធដោយអនុបាទិសេសនិព្វានធាតុ ។ អនាគាមិមគ្គ អនាគាមិផល ប្រែថា មគ្គ ជាផល នៃព្រះអរិយៈ ដែលមិនមកកាន់លោកនេះទៀត. ព្រោះថាអរិយៈដែលបាននូវផលជាគំរប់បីនេះ រមែងទៅកើតក្នុងព្រហ្មលោក ឈ្មោះថាសុទ្ធាវាស ហើយបរិនិព្វានក្នុងព្រហ្ម-

www.budinst.gov.kh www.elibraryofcambodia.org

លោកនោះ មិនបានត្រឡប់ចាកព្រហ្មលោកនោះ មកកើតក្នុងកាមភពនេះជាធម្មតា ។ អរហត្តមគ្គ ប្រែថា មគ្គជាទីមកនៃភាពជាព្រះអរហន្ត ។ អរហត្តផល ប្រែថា ផលគឺភាពជាព្រះអរហន្ត ។ ព្រះអរិយៈដែលបាននូវផលជាគំរប់បួន នេះ ឈ្មោះថា ព្រះអរហន្ត ជាអ្នកឆ្ងាយចាកកិលេស រំលត់ទុក្ខហើយមិនមានភពថ្មី ។ ឯមគ្គនោះ ជាអ្នកសម្លាប់នូវកិលេស ដូចព្រះមហាក្សត្រធ្វើសង្គ្រាមនឹងព្រះមហាក្សត្រ ដែលជាសត្រូវក្នុងរាជធានីដទៃ ចាប់ក្សត្រដែលជាសត្រូវពិឃាតបង់ ។ ផលជាអានិសង្ស នៃមគ្គដែលព្រះអរិយៈ នឹងគប្បីបាន គប្បីសោយ ដូចរាជសម្បត្តិដែលព្រះមហាក្សត្រនោះ ពិឃាតនូវក្សត្រជាសត្រូវ ហើយបានសោយ ប្រកបដោយសេចក្តីសុខសម្រាន្តដូច្នោះ ។

បុ. មគ្គ នោះ លះនូវកិលេសណា? កិលេសនោះ ជាអតីត ឬអនាគត ឬបច្ចុប្បន្ន?

វិ. កិលេសដែលជាអតីតក៏រលត់កន្លងផុតទៅហើយ កិលេសដែលជាអនាគតក៏មិនទាន់កើតឡើង កិលេសទាំងពីរចំណែកនេះ មិនមែនជាវិស័យដែលមគ្គត្រូវលះ កិលេសដែលជាបច្ចុប្បន្ន ក៏មិនមានក្នុងខណៈនៃមគ្គ ព្រោះថាកិលេសនោះមិនមានតាំងពីក្នុងខណៈនៃលោកិយវិបស្សនាខាងដើម បើនឹងថាកិលេសមានក្នុងខណៈនៃមគ្គហើយ លោក មគ្គនោះក៏នឹងជាសាសវៈប្រកបដោយអាសវៈគឺកិលេស ។ មួយទៀត

www.budinst.gov.kh www.elibraryofcambodia.org

ហើយមិនដូច្នោះ កុសលនិងអកុសលទាំងពីរ ដែលជាសត្រូវនឹងគ្នាក៏គង់កើតព្រមគ្នាក្នុងខណៈចិត្តតែមួយបាន ។ ពាក្យដែលថាមគ្គលះកិលេសនោះ សំដៅយកកិលេសដែលអាចកើតក្នុងខន្ធទាំង៥ មានរូបក្ខន្ធជាដើម ដែលជាភូមិនៃវិបស្សនា ដែលឈ្មោះថា ភូមិលទ្ធុប្បន្នកិលេស កិលេសបានភូមិគឺខន្ធ ៥ ហើយកើតឡើង ដូចរសនៃបឋវីធាតុនិងអាបោ-ធាតុដែលជ្រួតជ្រាបទៅក្នុងឫស ដើម មែក ស្លឹក ផ្កា ផ្លែ នៃឈើទាំងពួងដូច្នោះ ។ កាលមគ្គកើតឡើងក្នុងខន្ធសន្តាននៃបុគ្គលណាហើយ ខន្ធ-សន្តាននៃបុគ្គលនោះ ក៏បានពាល់ត្រូវសម្ផស្សនៃមគ្គដែលបានកើតឡើងនោះ ខន្ធសន្តាននៃលោកនោះ ឈ្មោះថា ខន្ធសន្តានដែលស្លាប់ ដោយស្លាប់កិលេសហើយ មិនតពូជផល គឺកុសល អកុសល តទៅ បីដូចជាដើមឈើ មានផ្កានិងផ្លែជាពិស បុរសម្នាក់ចោះចាក់ ដោយក្រើសបៃហលដែលលាបប្រឡាក់ដោយថ្នាំពិសក្នុងទិសទាំង៤ ។ ដើមឈើនោះកាលបើត្រូវសម្ផស្សនៃថ្នាំពិសនោះហើយ ក៏ស្លាប់ព្រោះរសនៃបឋវីធាតុ អា-បោធាតុ ដែលជ្រួតជ្រាបនោះស្ងួតទៅដោយសម្ផស្សនៃថ្នាំពិសនោះហើយជាដើមឈើមិនបានបញ្ចេញផ្កា ផ្លែតទៅទៀត ដូច្នោះឯង ។

មគ្គវិការតា ចប់

www.budinst.gov.kh www.elibraryofcambodia.org

# និព្វានវិភាវនា

បុច្ឆា. និព្វាន ប្រែថា ដូចម្តេច?

វិសជ្ជនា. និព្វាន ប្រែថា ធម៌ជាទីរលត់នៃកិលេសគ្គិ ភ្លើងគឺកិលេស និងទុក្ខគ្គិ ភ្លើងគឺទុក្ខ ។ រាគៈ សេចក្តីតម្រេក ទោសៈ សេចក្តីប្រទូសរ៉ាយ មោហៈ សេចក្តីវង្វេង ទាំងបីនេះ ឈ្មោះថាកិលេសគ្គិ ព្រោះកើតឡើងជាមួយនឹងចិត្ត ធ្វើចិត្តឲ្យសៅហ្មងកករល្អក់ផង នឹងឲ្យចិត្តក្តៅក្រហាយសោប់សេល់ផង ទើបឈ្មោះថាកិលេសគ្គិ ។

ជាតិ សេចក្តីកើត ជរា សេចក្តីចាស់ មរណៈ សេចក្តីស្លាប់ សោកៈ សេចក្តីក្រៀមក្រំនៃចិត្ត បរិទេវៈ សេចក្តីខ្សឹកខ្សួល ទុក្ខៈ សេចក្តីលំបាកកាយ ទោមនស្សៈ សេចក្តីតូចចិត្តឈឺចិត្ត ឧបាយាសៈ សេចក្តីចង្អៀតចង្អល់ចិត្ត ទាំងអស់នេះឈ្មោះថាទុក្ខគ្គិ ព្រោះជាហេតុនៃសេចក្តីទុក្ខនឹងជាគូទុក្ខ ធន់មិនបាន ដុតសត្វឲ្យក្តៅក្រហាយដូចគំនរភ្លើង ទើបឈ្មោះថាទុក្ខគ្គិ ។ កិលេសគ្គិនិងទុក្ខគ្គិ ទាំងអម្បាលនេះ កាលដល់ព្រះនិព្វាន អាស្រ័យព្រះនិព្វានហើយក៏រលត់ទៅ នឹងមិនមានក្នុងព្រះនិព្វាន ។ ព្រោះហេតុនោះ និព្វាននេះ ប្រែថាធម៌ជាទីរលត់នៃភ្លើងគឺកិលេសនិងភ្លើងគឺទុក្ខ ដ្បិតថាភ្លើងទុក្ខ គឺជាតិ ជរា មរណៈ រលត់មិនមានក្នុងព្រះនិព្វាននោះ អ្នកប្រាជ្ញគប្បីដឹងចុះថា ខន្ធទាំង ៥ គឺ រូប វេទនា

www.budinst.gov.kh www.elibraryofcambodia.org

សញ្ញា សង្ខារ វិញ្ញាណ មិនមានក្នុងព្រះនិព្វាន ដោយហេតុថា ជាតិ សេចក្តីកើតនោះ គឺការមានឡើង កើតឡើងនៃបញ្ចក្ខន្ធ ឈ្មោះថា ជាតិ សេចក្តីចាស់ជុំវិញនៃបញ្ចក្ខន្ធ ឈ្មោះថា ជរា កាលបើជាតិនិងជរាលែង ក៏បានឈ្មោះថាបញ្ចក្ខន្ធលែង មិនមានក្នុងព្រះនិព្វាន ដ្បិតព្រះនិព្វានជាវិសង្ខារ ប្រាសចាកសង្ខារគឺនាមរូបឬបញ្ចក្ខន្ធ ព្រោះហេតុនោះព្រះពុទ្ធអង្គទ្រង់ត្រាស់សំដែងថា ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ និរោធោ និព្វានំ ប្រែថា ឯតំ សន្តំ ធម្មជាតនេះ ជារបស់ស្ងប់ម្ងាប់ ជារបស់ល្អិត ឯតំ បណីតំ ធម្មជាតនេះ ជារបស់ប្រណីតឧត្តម យទិទំ គឺថា សព្វសង្ខារសមថោ ធម៌ជាទីរម្ងាប់នូវសង្ខារទាំងពួង សព្វូបធិប្បដិនិស្សគ្គោ ធម៌ជាទីរម្ងាប់នូវសង្ខារទាំងពួង តណ្ហាក្ខយោ ធម៌ជាទីអស់ទៅនៃតណ្ហា និរោធោ ធម៌ជាទីស្ងប់ស្ងាត់ និព្វានំ ធម៌ជាទីរលត់ ពាក្យទាំងអម្បាលនេះជាឈ្មោះនៃព្រះនិព្វានទាំងអស់ ដោយពាក្យថា សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ នេះ សំដែងថាសព្វវត្ថុទាំងពួង ដែលជាហេតុខាងក្នុងគឺ កុសល អកុសល និងកិលេសក្តី និងផលខាងក្នុងគឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលជាវិបាកខន្ធក្តី និងហេតុខាងក្រៅ មានផ្លូវជាដើមក្តី និងផលខាងក្រៅ មានដើមឈើ ផែនដី មេឃ អាកាស

www.budinst.gov.kh www.elibraryofcambodia.org

ព្រះអាទិត្យ ព្រះចន្ទជាដើមក្តី ក៏មិនមានក្នុងព្រះនិព្វាន ព្រោះថាសេចក្តីព្យាយាមឈ្មោះថាសង្ខារ កុសល អកុសល ក៏ឈ្មោះថាសង្ខារ វត្ថុទាំងពួងដែលកើតដោយហេតុខាងក្នុង គឺ កុសល អកុសល ដូចបញ្ចក្ខន្ធក្តី ឬវត្ថុដែលកើតដោយហេតុខាងក្រៅ មានរដូវជាដើម ដូចដើមឈើ ឬផែនដីជាដើមក្តី ក៏ឈ្មោះថា សង្ខារ សង្ខារទាំងអម្បាលនេះមិនមានក្នុងព្រះនិព្វាន ព្រះនិព្វានទើបឈ្មោះថា សព្វសង្ខារសមថោ ធម៌ជាទីរម្ងាប់នូវសង្ខារទាំងពួង កិលេសក៏ឈ្មោះថាឧបធិ កុសល អកុសល ក៏ឈ្មោះថាឧបធិ បញ្ចក្ខន្ធ ក៏ឈ្មោះថាឧបធិ កិលេសកាម ឬវត្ថុកាមក៏ឈ្មោះថា ឧបធិ ឧបធិទាំងអម្បាលនេះ មិនមានក្នុងព្រះនិព្វាន ព្រះនិព្វានទើបឈ្មោះថា សព្វូបធិប្បដិនិស្សគ្គោ ធម៌ជាទីលះបង់នូវឧបធិទាំងពួង ៗ មួយទៀតពាក្យទាំងពីរនោះ ជាពាក្យសំដែងថា ព្រះនិព្វានមិនមានព័ណ៌ខៀវលឿងជាដើម ឬសណ្ឋានវែងខ្លីជាដើម ឯណានីមួយ ឬមិនមានទីប្រតិស្ឋានក្នុងទិសណា តំបន់ណា មិនមានធម៌ណាមួយជាអារម្មណ៍ គ្រាន់តែជាអារម្មណ៍នៃអរិយមគ្គញាណ ព្រោះហេតុដូច្នោះ ព្រះពុទ្ធអង្គទើបទ្រង់បញ្ចេញនូវឧទានគាថាថា អត្ថិ ភិក្ខវេ តទាយតនំ ម្នាលភិក្ខុទាំងឡាយ អាយតនៈនោះមាន យត្ថ ក្នុងអាយតនៈឯណា នេវ បឋវី ក៏មិនមែនជាដីមែនពិត ន អាបោ មិនមែនជាទឹក ន តេជោ មិនមែនជាភ្លើង ន វាយោ មិន

www.budinst.gov.kh www.elibraryofcambodia.org

មែនជាខ្យល់ ន អាកាសានញ្ចាយតនំ មិនមែនជា អាកាសានញ្ចាយតនៈ ន វិញ្ញាណញ្ចាយតនំ មិនមែនជាវិញ្ញាណ-ញ្ចាយតនៈ ន អាកិញ្ចញ្ញាយតនំ មិនមែនជាអាកិញ្ចញ្ញាយតនៈ ន នេវសញ្ញានាសញ្ញាយតនំ មិនមែនជានេវសញ្ញានាសញ្ញា-យតនៈ នាយំ លោកោ មិនមែនជាលោកនេះ ន បរោ លោកោ មិនមែនជាលោកខាងមុខ ន ឧភោ ចន្ទិមសុរិយា មិនមែនជាព្រះចន្ទនិងព្រះអាទិត្យទាំងពីរ តទបហំ ភិក្ខវេ នេវ អាគតឹ វទាមិ ម្នាលភិក្ខុទាំងឡាយ តថាគតមិនសំដែងនូវអា-យតនៈនោះ ថាមានកិរិយាមក ដូចមកអំពីភូមិនោះដល់ភូមិនេះ ន គតឹ តថាគតមិនបានសំដែងថា មានកិរិយាទៅ ដូចទៅអំពីភូមិនេះ ដល់ភូមិដទៃ ន ឋិតឹ តថាគតមិនបានសំដែងថា មានកិរិយា ឈប់នៅ ន ចុតឹ តថាគតមិនបានសំដែងថា មានកិរិយាច្យុតិឃ្លាត ចេញ ន ឧបបត្តឹ តថាគតមិនបានសំដែងថា មានការចូលទៅ ដល់នូវទីណាមួយ អប្បតិដ្ឋំ អាយតនៈនោះ ជាធម្មជាតមិនបានតាំងនៅ ក្នុងទីណា ឬមិនមានទីតាំងនៅក្នុងទិសណា តំបន់ណា អប្បវត្តំ ជាធម្មជាតមិនមានបវត្តិការប្រព្រឹត្តទៅ អនារម្មណំ ជាធម្មជាតមិន មានអ្វីជាអារម្មណ៍ ឯសេវន្តោ ទុក្ខស្ស នុ៎ះឯងជាទីបំផុត នៃទុក្ខ ។ ព្រះសូត្រនេះសំដែងលក្ខណៈនៃព្រះនិព្វាន ព្រោះពាក្យថា

www.budinst.gov.kh www.elibraryofcambodia.org

ដី ទឹក ភ្លើង ខ្យល់ ក៏មិនមាន គឺមិនមានក្នុងព្រះនិព្វាន ព្រះនិព្វានជា អរូបធម៌ ដោយពាក្យថា អាកាសានញ្ចាយតនៈ ជាដើម ក៏មិនមាននោះ សំដែងថានាមធម៌គឺ វេទនា សញ្ញា សង្ខារ វិញ្ញាណ សូម្បីល្អិតសុខុមបំផុតជាមិនមាន ដូច នេវសញ្ញានាសញ្ញាយតនៈ ក៏ មិនមានក្នុងព្រះនិព្វាន ។ ព្រះនិព្វានជាអនាមធម៌ មិនមែនជាអារម្មណិក-នាមធម៌ គឺនាមប្រកបដោយអារម្មណ៍ជាគ្រឿងទាញ ។ ក៏ឯប្រភេទនៃធម៌ សំដែងនាមរូបដំបូងនុ៎ះ លោកចាត់ព្រះនិព្វានចូលក្នុងប្រភេទនៃនាមធម៌ នោះ សំដៅសេចក្តីថា ព្រះនិព្វានជាអារម្មណ៍នៃអរិយមគ្គបញ្ញា គឺព្រះ អរិយៈជាម្ចាស់លោកនឹងបង្អោនចូលមកដោយចិត្ត ដែលសម្បយុត្តដោយ មគ្គនឹងផលបានប៉ុណ្ណោះ មិនមែនសំដែងថា ព្រះនិព្វានជាអារម្មណិក នាមធម៌គឺ វេទនា សញ្ញា សង្ខារ វិញ្ញាណ វត្ថុណាមួយ ក៏មិនមាន ។ ដែលសំដែងថា វេទនា សញ្ញា សង្ខារ វិញ្ញាណ វត្ថុណាមួយ មានក្នុងព្រះនិព្វានក៏មិនមាន ផ្សេងពាក្យថា លោកនេះក៏មិនមានជាដើម នោះ គឺសំដែងថា ព្រះនិព្វាន មិនមានទីប្រតិស្ឋានតាំងនៅក្នុងទិស ណា តំបន់ណា នឹងមិនបានប្រតិស្ឋានតំកល់ទុកក្នុងទិសណា តំបន់ ណាដោយពាក្យនេះ ឃាត់សេចក្តីយល់ខុសនៃមនុស្សពាលដែលពោល ថាព្រះនិព្វានជានគរកែវដ៏វិសេសក្សេមក្សាន្តចាកសភ័យ ទើបឃាត់សេចក្តី

www.budinst.gov.kh www.elibraryofcambodia.org

ប្រកាន់ថាព្រះនិព្វានដូចជារូបក្រឡាច រូបព្រហ្ម មិនមានចិត្តសញ្ញាដេកស្ងៀម នៅក្នុងកាលតាំងពួនផង ។

បុ. បើព្រះនិព្វានដូចពាក្យសំដែងមកនេះ សេចក្តីសុខឡើយទេ មិនកើត មិនមាន នៃសត្វក្តៅតាំងពួន ជាព្រះនិព្វានឬ?

វិ. មិនដូច្នោះទេ បើថាសេចក្តីសុខឡើយដូច្នោះជាព្រះនិព្វាន ព្រះនិព្វានក៏ឈ្មោះថាមិនមាន ។ ពាក្យដែលព្រះពុទ្ធអង្គទ្រង់សំដែងថា អាយតនៈគឺព្រះនិព្វាននោះរមែងមាន ពាក្យនោះក៏ខុស ។ ព្រះនិព្វានជារបស់មានពិត ទើបជាទុក្ខនិរោធអរិយសច្ច របស់ពិតនៃព្រះអរិយៈមួយចំណែក ជាអសាធារណធម៌ មិនទូទៅដល់បុថុជ្ជន បុថុជ្ជនមិនអាចឃើញបាន ព្រោះមិនមានបញ្ញាចក្ខុគឺអរិយមគ្គញ្ញាណ ។ ព្រះអរិយៈលោកឃើញច្បាស់ ឃើញច្បាស់ដោយអរិយមគ្គញ្ញាណ ដូចបុគ្គលដែលបានចេតោបរិយញ្ញាណដឹងវារៈចិត្តនៃអ្នកដទៃដូច្នោះ ។ ឯបុថុជ្ជនមិនឃើញធម៌ណាមួយ នឹងសំដែងថាធម៌នោះមិនមានក៏មិនបាន ។ មួយទៀតបើសំដែងថាព្រះនិព្វានមិនមានហើយ សម្មាបដិបត្តិគឺអរិយមគ្គប្រកបដោយអង្គ ៨ មានសម្មាទិដ្ឋិជាដើម ដែលសង្គ្រោះដោយត្រៃសិក្ខានោះ ក៏ជាការឥតប្រយោជន៍មិនចេញផល គឺ ឲ្យដល់ព្រះនិព្វានបាន ។ មួយទៀតបើថា អរិយមគ្គមិនមែនជាការឥតប្រយោជន៍ ព្រោះឲ្យដល់នូវសេចក្តីមិនមាននៃបញ្ចក្ខន្ធ ដែលជាទីតាំងនៃសេចក្តីទុក្ខទាំងមុខនោះក៏មិនត្រូវ ព្រោះថាការដែលសម្រេចនូវព្រះ

www.budinst.gov.kh www.elibraryofcambodia.org

និព្វានក្នុងកិរិយាមិនកើតមិនមាននៃបញ្ចក្ខន្ធ ដែលជាអតីតនិងអនាគតមិន
មាន ៗ មួយទៀត និងសំដៅយកសេចក្តីថា ការមិនកើតមិនមាននៃ
បញ្ចក្ខន្ធ ដែលជាបច្ចុប្បន្ន ជាព្រះនិព្វានក៏មិនត្រូវ ព្រោះខណៈនៃអរិយ-
មគ្គប្បញ្ញាកើតឡើងឃើញព្រះនិព្វាននោះ បញ្ចក្ខន្ធក៏មានប្រាកដក្នុងទី
ចំពោះមុខមិនបានសូន្យទៅ ៗ មួយទៀត ការសម្រេចនូវសឧបាទិសេស-
និព្វាន ក៏កើតមានក្នុងខណៈនៃមគ្គ អាស្រ័យនូវបញ្ចក្ខន្ធដែលជាបច្ចុប្បន្នៗ
មួយទៀត និងសំដៅសេចក្តីថា ការមិនមានមិនប្រព្រឹត្តទៅនៃកិលេសជា
បច្ចុប្បន្ន ជាព្រះនិព្វាន អរិយមគ្គក៏ជារបស់មិនមានប្រយោជន៍ ព្រោះថា
មុនដែលព្រះអរិយមគ្គកើតឡើង កិលេសក៏មិនមាន មិនប្រព្រឹត្តទៅដោយ
អំណាចលោកិយវិបស្សនាបញ្ញា ៗ មួយទៀត បើនិងសំដៅសេចក្តីថាការ
មិនមានកិលេសជាព្រះនិព្វាន ការដេកលក់ស្និទ្ធក៏ហៅថាព្រះនិព្វានបាន
ព្រោះកិលេសមិនមានក្នុងវេលាលក់ស្និទ្ធនោះ ៗ មួយទៀត បើសំដៅថា
រាគក្ខយៈ ការអស់រាគៈ ទោសក្ខយៈ ការអស់ទោសៈ មោហក្ខយៈ ការអស់
មោហៈ តាមជម្ពុខាទកសូត្រជាដើម ថាជាព្រះនិព្វាន ទោសក៏មានច្រើន
គឺព្រះនិព្វានក៏និងជាវត្ថុនៃកាល មានកាលខានវេលាមួយពេល មួយស្របត
តែត្រឹមអស់កិលេសប៉ុណ្ណោះ ៗ មួយទៀត ក៏និងធ្លាក់ចុះក្នុងលក្ខណៈនៃ
សង្ខតធម៌ ៗ មួយទៀត ក៏និងជាធម៌បានងាយមិនមានសម្មាវាយាមៈក៏
គង់សម្រេចបាន ៗ កាលបើធ្លាក់ចុះក្នុងលក្ខណៈនៃសង្ខតធម៌ ព្រោះមាន

www.budinst.gov.kh www.elibraryofcambodia.org

មួយកាល មួយខណៈ ព្រះនិព្វានក៏មិនកប់ចូលក្នុងសង្ខតធម៌ ព្រោះជាប់ជំពាក់ក្នុងសង្ខតធម៌ ក៏មិនជាធម្មជាតក្តៅដោយភ្លើងកិលេស ភ្លើងទុក្ខ ព្រោះជារបស់ក្តៅ ព្រះនិព្វានក៏មិនជាទុក្ខ ។ មួយទៀត បើថាតាមក្ខយៈ ការអស់រាគៈជាដើម ជាព្រះនិព្វាន ព្រះនិព្វានក៏មិនមានច្រើន ការអស់រាគៈ ទោសៈ មោហៈ ក៏ហៅថាព្រះនិព្វានមួយ ១ ។ មួយទៀត ព្រះនិព្វានក៏មិនជាធម្មជាតជ្រៅជ្រាក សូម្បីមនុស្សពាលក៏ដឹងបានដោយងាយ ។ មួយទៀតព្រះនិព្វានក៏មិនមែនជាអារម្មណ៍នៃគោត្រភូញាណនិងមគ្គបាន ។ មួយទៀតមិនសំដៅថា តាំងអំពីការអស់កិលេសណា កិលេសៈនោះមិនកើតឡើងតទៅទៀត ការអស់កិលេសដូច្នោះជាព្រះនិព្វានហើយ ក៏មិនត្រូវ ព្រោះការអស់កិលេសដូច្នោះមិនកើតមិនមាន ។ ប្រសិនបើជាកើតជាមានក៏មិនរួចពាក់ទោសដូចសំដែងមកនោះ ។ មួយទៀត អរិយមគ្គក៏មិនជាព្រះនិព្វាន ព្រោះថាមគ្គនិងផលព្រះមានព្រះភាគទ្រង់សំដែងដោយឈ្មោះថា រាគក្ខយោ ទោសក្ខយោ មោហក្ខយោ ដូចឈ្មោះព្រះនិព្វានក៏មាន ។ រាគក្ខយោ ទោសក្ខយោ មោហក្ខយោ ថាបើជាឈ្មោះនៃមគ្គ ត្រូវប្រែថា ធម៌ជាហេតុអស់ទៅនៃរាគៈ ទោសៈ មោហៈ ព្រោះការសម្លាប់កិលេសជាកិច្ចនៃមគ្គ បើជាឈ្មោះនៃផលត្រូវប្រែថា ការអស់ រាគៈ ទោសៈ មោហៈ ព្រោះព្រះអរហត្តផល កើតក្នុងទីបំផុតនៃការអស់កិលេស បើជាឈ្មោះនៃព្រះនិព្វានត្រូវប្រែថា ធម៌

www.budinst.gov.kh www.elibraryofcambodia.org

ជាទីអស់ រាគៈ ទោសៈ មោហៈ ព្រោះថាកិលេសមកដល់ព្រះនិព្វានដែលជាអារម្មណ៍នៃមគ្គហើយអស់ទៅ តាំងអំពីអរិយមគ្គកើតឡើង កិលេសមិនកើតតទៅទៀតបាន អរិយមគ្គទើបជាអនុប្បត្តិនិរោធលត់តែម្តងនៃកិលេសដែលមិនកើតបានទៀត ៗ ចំណែកព្រះនិព្វានរមែងជាឧបនិស្ស័យនៃអរិយមគ្គនោះ គឺថា ជាអារម្មណបច្ច័យដ៏មានកម្លាំងនៃអរិយមគ្គនោះដោយបរិយាយ ព្រះនិព្វាននោះព្រះមានព្រះភាគទ្រង់សំដែងថា រាគក្ខយោ ទោសក្ខយោ មោហក្ខយោ ធម៌ជាទីអស់ រាគៈ ទោសៈ មោហៈ សំដែងដូច្នេះដោយផលូបចារវោហារ គឺសំដែងហេតុដោយផល ៗ ក្នុងបទនេះសំដៅយកព្រះនិព្វានជាហេតុ មគ្គជាផល ដើម្បីនឹងអធិប្បាយបទថា រាគក្ខយោ ទោសក្ខយោ មោហក្ខយោ ប៉ុណ្ណោះ ៗ បើនឹងសំដែងដោយហេតុផលតាមអរិយសច្ចកថា មគ្គជាហេតុ ព្រះនិព្វានជាផល ៗ មួយទៀតភាពចន្លោះទទេនឹងការមិនកើតមិនមាននៃបញ្ចក្ខន្ធជាដើម នឹងគ្រាន់តែការអស់ទៅនៃកិលេសជាព្រះនិព្វាន ចុះត្រង់បទដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា ព្រះនិព្វានជារបស់ជ្រៅនឹងត្រាស់ថាជាអសង្ខតធម៌តើដូចម្តេចទៅ ? ដ្បិតព្រះពុទ្ធអង្គទ្រង់ត្រាស់ថា ព្រះនិព្វានជាធម៌ជ្រៅដូច្នេះ គម្ភីរោ ចាយំ ធម្មោ ធម៌គឺព្រះនិព្វានជាធម៌ជ្រៅ ទុទ្ទសោ ដែលបុគ្គលឃើញបានដោយក្រ ទុរនុពោធោ ដែលបុគ្គលត្រាស់ដឹងតាមដោយក្រ សន្តោ ជាធម៌ស្ងប់ម្ងាប់ បណីតោ

www.budinst.gov.kh www.elibraryofcambodia.org

ជាធម៌ហ្មត់ចត់ អតក្កាវចរោ មិនជាទីស្ទង់ប្រមើលដោយសេចក្ដីត្រិះរិះ គឺជាបុថុជ្ជននឹងត្រិះរិះគិតគ្នេរយកឯងមិនបាន ឯ និបុណោ ជារបស់ល្អិត បណ្ឌិតវេទនិយោ ជាធម៌ដែលបណ្ឌិតគឺព្រះអរិយៈគប្បីដឹងច្បាស់ បុថុជ្ជនមិនអាចដឹងច្បាស់ ៗ គឺឯព្រះពុទ្ធអង្គទ្រង់សំដែងថាជាអសង្ខតធម៌នោះ ដោយន័យច្រើនយ៉ាង អធិប្បាយដោយសេចក្ដីសង្ខេបដូច្នេះថា ធម៌ទាំងពួងបើសំដែងដោយន័យមានពីរប្រភេទគឺ សង្ខតធម៌ ១ អសង្ខត-ធម៌ ១ ៗ សង្ខតធម៌ប្រែថាធម៌ដែលបច្ច័យគឺដូចនឹងកុសលនឹងអកុសលជាដើម តាក់តែងឲ្យកើតឲ្យមានឡើង បានដល់សង្ខារទាំងពួង ដូចរូបកាយខាងក្រៅក្ដី នឹងអារម្មណិកនាមធម៌ ដែលជាកុសលដរាបដល់មគ្គផលក្ដី នឹងអកុសលទាំងពួងក្ដី នឹងអព្យាកតធម៌ ដែលជាអារម្មណិកធម៌ក្ដី ឈ្មោះថាសង្ខតធម៌ ព្រោះប្រកបដោយសង្ខតលក្ខណៈ ៣ ដូច្នេះ គឺការកើតឡើងរមែងប្រាកដមួយយ៉ាង ការរលត់ទៅរមែងប្រាកដមួយយ៉ាង ការតាំងនៅហើយប្រែទៅជាយ៉ាងដទៃ រមែងប្រាកដមួយយ៉ាង ព្រោះប្រកបដោយសង្ខតលក្ខណៈ ៣ ដូច្នេះ ទើបឈ្មោះថាសង្ខតធម៌ ៗ អ-សង្ខតធម៌ ប្រែថាធម៌ដែលបច្ច័យណាមួយមិនបានតាក់តែងឲ្យកើតឲ្យមានឡើង បានដល់ព្រះនិព្វានតែមួយ ព្រោះព្រះនិព្វានប្រកបដោយអសង្ខត-លក្ខណៈ ៣ ដូច្នេះ គឺការកើតឡើងក៏មិនប្រាកដមួយយ៉ាង ការរលត់ទៅក៏មិនប្រាកដមួយយ៉ាង ការតាំងនៅហើយប្រែប្រួលទៅជាយ៉ាងដទៃក៏មិន

www.budinst.gov.kh www.elibraryofcambodia.org

ប្រាកដមួយយ៉ាង ព្រោះព្រះនិព្វានប្រកបដោយអសង្ខតលក្ខណៈដូច្នេះ ទើបឈ្មោះថាអសង្ខតធម៌ ។ ការសូន្យទទេ ការមិនមានបញ្ចក្ខន្ធ មិនការគ្រាន់តែអស់ទៅនៃកិលេសនោះ នឹងជារបស់ជ្រៅរបស់ឃើញក្រពុំខាង នឹងជាអសង្ខតធម៌ដូចម្តេចទៅបាន ។ ព្រោះហេតុនោះអ្នកប្រាជ្ញគប្បីដឹងចុះថា ព្រះនិព្វានជាធម្មជាតមួយមានទៅប្រាកដ មិនមែនជាការសោះសូន្យទទេ មិនមែនជាមិនមានសង្ខារ មិនមែនគ្រាន់តែការមិនមានកិលេសជាព្រះនិព្វានទេ ។

ឬ. ព្រះនិព្វានមានពិត ហេតុអ្វីទើបព្រះមានព្រះភាគមិនទ្រង់សំដែងដោយរូប បង្អួលអង្គព្រះនិព្វានឲ្យច្បាស់ដូចមគ្គនិងផល ?

.វិ. ព្រះនិព្វានសំដែងឲ្យច្បាស់ដូច្នោះមិនបាន ព្រោះព្រះនិព្វានជាធម៌ល្អិតសុខុមណាស់ ។ ឯពាក្យដែលថា ព្រះនិព្វានជាធម៌ល្អិតសុខុមនោះមែនប្រាកដមានទៅ នាំឲ្យព្រះមានព្រះភាគមានសេចក្តីខ្វល់ខ្វាយតិចក្នុងការសំដែងធម៌ ក្នុងវេលាដែលព្រះអង្គទើបនឹងបានត្រាស់ដឹងជាដំបូងប្រាកដ ព្រោះព្រះនិព្វានជាធម៌ដែលព្រះអរិយៈគប្បីឃើញដោយបញ្ញាចក្ខុ គឺអរិយមគ្គបញ្ញា ព្រោះហេតុនោះព្រះនិព្វានទើបជារបស់អ-សាធារណៈមិនទូទៅដល់បុថុជ្ជន ។ មួយទៀត ព្រះនិព្វានជាអប្បកតៈមិនមានដែនកើត គឺមិនមានទីបំផុតខាងដើមថា មានឡើងកាលព្រះពុទ្ធអង្គឯណា៖-មុននោះមិនមាន ។ មួយទៀត នឹងថាព្រះនិព្វានជាបកតៈ មានធម៌

www.budinst.gov.kh www.elibraryofcambodia.org

ជាផែនកើត ព្រោះព្រះអរិយមគ្គឲ្យកើតឡើងក៏មិនត្រូវ ដ្បិតព្រះនិព្វាន នោះ ជាធម៌ដែលព្រះអរិយៈគប្បីដល់ គប្បីបានដោយអរិយមគ្គមែនទេ មិនមែនជាធម៌ដែលអរិយមគ្គឲ្យមានឲ្យកើតឡើង ព្រោះហេតុនោះ ព្រះនិព្វានទើបជាអប្បភវៈមិនមានផែនកើត ។ ព្រោះព្រះនិព្វានមិនមានផែនកើត ទើបជាអជរាមរណៈមិនមានសេចក្ដីចាស់ សេចក្ដីស្លាប់ ។ ព្រោះមិនមានធម៌ជាផែនកើត និងមិនមានសេចក្ដីចាស់ សេចក្ដីស្លាប់ ព្រះនិព្វានទើបជាធម៌ថេរទៀង ។ ដោយហេតុដូចសំដែងមកនេះ ព្រះនិព្វានជារបស់មានពិតប្រាកដដោយបរមត្ថ ព្រោះជាធម៌ដែលបុគ្គលគប្បីបានដោយញាណដ៏វិសេសដែលសម្រេចដោយសេចក្ដីព្យាយាម ដែលមិនបន្ធូរបន្ថយ ។ មួយទៀត ព្រោះមានព្រះពុទ្ធដីកាថា អត្ថិ ភិក្ខវេ ម្នាលភិក្ខុទាំងឡាយព្រះនិព្វានមានដោយពិត អជាតំ ឈ្មោះថា អជាតៈ ព្រោះជាធម្មជាតមិនកើតឡើងដោយប្រជុំព្រមនៃហេតុ និងបច្ច័យ អភូតំ ឈ្មោះថា អភូតៈ ព្រោះមិនមែនជាធម្មជាតប្រាសចាកហេតុហើយកើតឡើងឯង អកតំ ឈ្មោះថា អកតៈ ព្រោះជាធម្មជាតដែលហេតុណាមួយមិនបានធ្វើ អសង្ខតំ ឈ្មោះថា អសង្ខតៈ ព្រោះជាធម្មជាតដែលហេតុនិងបច្ច័យណាមួយ មិនបានតាក់តែងឡើង ។ ដោយពុទ្ធវចនៈដូច្នេះ អ្នកប្រាជ្ញគប្បីដឹងថាព្រះនិព្វានជាធម្មជាតមានមែនពិត ។ ឯពាក្យថា ព្រះនិព្វានជាធម៌ដែលបុគ្គលគប្បីបានដោយញាណដ៏វិសេសនោះ

www.budinst.gov.kh www.elibraryofcambodia.org

សំដែងថាព្រះនិព្វានជាបច្ចត្តសិទ្ធិ សម្រេចដោយជាក់ច្បាស់ដល់ព្រះអរិយៈតែមួយពួក ដោយអាងសព្វញ្ញូវចនៈនោះសំដែងថា ព្រះនិព្វានជាអនុមានសិទ្ធិសម្រេចដល់បុថុជ្ជនដោយអនុមានគ្រាន់តែ ជាមានតាមពុទ្ធវចនៈ ។ លោកិយបញ្ញាដែលឃើញនូវព្រះនិព្វាន គឺមានមកតាំងអំពីគោត្រភូញាណ ដែលកើតក្នុងជវនវារៈខាងដើមនៃមគ្គជវនវារៈដែលមិនបានត្រឡប់មកជាលោកិយប្បញ្ញាវិញទៀត ។ ក្រៅពីនោះលោកុត្តរបញ្ញា គឺមគ្គញ្ញាណ ផលញ្ញាណមួយចំណែក ឃើញនូវព្រះនិព្វាន

និព្វានវិភាវនី ចប់ ។

www.budinst.gov.kh www.elibraryofcambodia.org

# ធម្មគុណកថា

–១–

ប. ព្រះធម៌មានគុណដូចម្តេច ?

វិ. គុណនៃព្រះធម៌មានច្រើនណាស់ ហួសវិស័យដែលបុថុជ្ជននឹងព័ណ៌នាបាន តែបើកាត់ឲ្យខ្លី សភាពដែលល្អពិត ដូចសំដែងមកហើយនោះឯង ជាគុណធំក្នុងព្រះធម៌ ។ មួយទៀតបើនឹងសំដែងគុណតាមប្រភេទនៃព្រះសទ្ធម្មទាំង ៣ បរិយត្តិសទ្ធម្មមានគុណយ៉ាងខ្ពស់ គឺប្រកាសបំភ្លឺសត្វ ឲ្យសត្វស្គាល់បដិបត្តិសទ្ធម្ម ចំណែកបដិបត្តិសទ្ធម្មមានគុណយ៉ាងខ្ពស់ឧត្តមក្រៃពេក គឺឲ្យសត្វដំណើរដល់បដិវេធសទ្ធម្ម ។ ចំណែកបដិវេធសទ្ធម្ម មានគុណយ៉ាងខ្ពស់ក្រៃពេក គឺសម្លាប់កិលេសនោះ ៗ ឲ្យសត្វបាននូវសេចក្តីសុខ ដល់នូវការអស់ទៅនៃទុក្ខ ។ មួយទៀត ស្វាក្ខាតតាទិគុណ ជាគុណនៃព្រះធម៌ដ៏ខ្ពស់ជាអនុស្សតិដ្ឋាន ទីតាំងនៃសេចក្តីរលឹក ។

ព្រោះនេះទើបអធិប្បាយក្នុងបទទាំង ៦ មាន ស្វាក្ខាតោ ភគវតា ធម្មោ ជាដើម តាមលំដាប់ក្នុងបុព្វសិក្ខា ពាក្យក្នុងអដ្ឋកថាសំដែងទុកដូច្នេះថា សូម្បីព្រះបរិយត្តិសទ្ធម្ម រមែងដល់នូវសេចក្តីសង្គ្រោះក្នុងបទថា ស្វាក្ខាតោ ភគវតា ធម្មោ ផង លោកុត្តរធម៌តែមួយយ៉ាងប៉ុណ្ណោះ រមែងដល់នូវសេចក្តីសង្គ្រោះក្នុងបទទាំង ៥ ក្រៅនោះ

www.budinst.gov.kh www.elibraryofcambodia.org

តាំងអំពី សន្ទិដ្ឋិកោ ដរាបដល់ បច្ចត្តំ វេទិតព្វោ វិញ្ញូហិ ។ តាមពាក្យអដ្ឋកថានោះ បាននឹងបាលីថា ស្វាក្ខាតោ ។ល។ វិញ្ញូហិ នេះ ប្រកាសនូវគុណនៃព្រះបរិយត្តិសទ្ធម្ម និងអធិគមសទ្ធម្មពីរប្រការ ប៉ុណ្ណោះ មិនបានសំដៅយកបដិបត្តិសទ្ធម្មផងទេ សូម្បីដូច្នេះនឹងពណ៌-នាថា ប្រកាសនូវគុណនៃបដិបត្តិសទ្ធម្មផងក៏បាន ប្រែតាមអដ្ឋកថានោះថា ស្វាក្ខាតោ ភគវតា ធម្មោ បរិយត្តិសទ្ធម្ម ដែលព្រះមានព្រះភាគសំដែងទុកប្រពៃហើយ ព្រោះជាធម៌ពីរោះក្នុងខាងដើមកណ្ដាលនិងទីបំផុត ។ ម្យ៉ាងទៀត ព្រោះជាធម៌ប្រកាសនូវព្រហ្មចរិយៈ មានអត្ថនិងព្យញ្ជនៈ ពេញបរិបូណ៌បរិសុទ្ធពុំមានសេសសល់ ទើបឈ្មោះថាព្រះមានព្រះភាគសំដែងប្រពៃហើយ ។ ព្រះបរិយត្តិសទ្ធម្ម សូម្បីជាគាថា ៤ បាទ ក៏ឈ្មោះថា ពីរោះខាងដើមដោយបាទជាបឋម ឈ្មោះថា ពីរោះក្នុងកណ្ដាលដោយបាទជាគំរប់ពីរ និងគំរប់បី ឈ្មោះថាពីរោះក្នុងទីបំផុតដោយបាទជាគំរប់បួន ព្រោះថាក្នុងបាទនៃគាថាតាំងបួននោះ បាទណាមួយ ដែលសំដែងនូវសេចក្ដីបរិត និងសំដែងនូវសេចក្ដីមិនមែនជាប្រយោជន៍ មិនមាន ។

មួយទៀត បរិយត្តិសទ្ធម្ម ឈ្មោះថាពីរោះក្នុងខាងដើម ព្រោះសំដែងសីលជាគុណខាងដើមនៃព្រហ្មចរិយៈ ឈ្មោះថាពីរោះក្នុងកណ្ដាល ព្រោះសំដែងសមាធិជាគុណត្រង់កណ្ដាលនៃព្រហ្មចរិយៈ ឈ្មោះថាពីរោះក្នុង

www.budinst.gov.kh www.elibraryofcambodia.org

ទីបំផុត ព្រោះសំដែងបញ្ញាជាគុណខាងចុងនៃព្រហ្មចរិយៈ ។ មួយទៀត បដិបត្តិសទ្ធម្មគឺឈ្មោះថាល្អប្រពៃខាងដើមដោយសីល ព្រោះសីលជាគ្រឿងឃាត់បង់នូវកិលេសដ៏គ្រោតគ្រាតនៃ វីតិក្កមៈ សេចក្តីប្រព្រឹត្តកន្លងបញ្ញត្តិ ដែលកើតដោយកាយនិងវាចា ឈ្មោះថាល្អប្រពៃត្រង់កណ្តាលដោយសមាធិ ព្រោះសមាធិជាគ្រឿងឃាត់កិលេសយ៉ាងកណ្តាល គឺបរិយុដ្ឋានកិលេស ដ៏ផុសផុលឡើងគាំងទៅដោយជុំវិញនៃចិត្ត ឈ្មោះថាល្អប្រពៃក្នុងទីបំផុតដោយបញ្ញា ព្រោះបញ្ញាជាគ្រឿងឃាត់បង់នូវកិលេសយ៉ាងល្អិត គឺអនុសយកិលេសដែលដេកត្រាំក្នុងសន្តាន ។ មួយទៀត បរិយត្តិសទ្ធម្ម ឈ្មោះថាពីរោះខាងដើម ដោយកិរិយាស្តាប់ ព្រោះថាក្នុងខណៈដែលស្តាប់ដោយគោរព រមែងបាននូវសេចក្តីសង្វេគនិងសេចក្តីជ្រះថ្លា ក្នុងចិត្តសង្វេគនិងក្នុងចិត្តជ្រះថ្លា ហើយសង្កត់សង្កិនបាននូវនីវរណៈទាំង ៥ ឈ្មោះថាពីរោះត្រង់កណ្តាលដោយការបដិបត្តិ ព្រោះបុគ្គលអ្នកបដិបត្តិ កាលបដិបត្តិបាននូវសេចក្តីសង្វេគ បានសេចក្តីជ្រះថ្លា រមែងសង្កត់សង្កិនកិលេសនោះៗ បាន និងឃើញគុណនៃព្រះធម៌ ឈ្មោះថាពីរោះក្នុងទីបំផុតដោយផលនៃការបដិបត្តិ គឺនាំមកនូវភាពជាមនុស្សឈ្មោះថា តាទិ គឺមិនមានសោមនស្ស ទោមនស្ស ក្នុងអារម្មណ៍នោះៗ ជាគុណយ៉ាងខ្ពស់ក្រៃពេក ។ ព្រះធម៌ឈ្មោះថា ដែលព្រះមានព្រះភាគសំដែងហើយដោយប្រពៃ ព្រោះថាជាគ្រឿងពីរោះក្នុងខាងដើមកណ្តាលនិងទីបំផុត ដូច្នេះ ។

www.budinst.gov.kh www.elibraryofcambodia.org

មួយទៀត វិធីដែលនឹងសំដែងបរិយត្តិសទ្ធម្ម ឈ្មោះថាព្រះមានព្រះភាគសំដែងហើយដោយប្រពៃ ព្រោះជាគ្រឿងប្រកាសនូវព្រហ្មចរិយៈដ៏ប្រកបដោយអត្ថនឹងព្យញ្ជនៈបរិបូណ៌បរិសុទ្ធមិនសល់នោះ អធិប្បាយថា សាសនៈគឺពាក្យទូន្មានមួយយ៉ាង មគ្គមួយយ៉ាង ឈ្មោះថាព្រហ្មចរិយៈក្នុងបទនេះ ។ សាសនព្រហ្មចរិយៈនឹងមគ្គព្រហ្មចរិយៈណា ដែលព្រះមានព្រះភាគទ្រង់សំដែងដោយន័យផ្សេងៗ ព្រហ្មចរិយៈទាំងនោះឈ្មោះថា សាត្ថំ ប្រកបដោយអត្ថ ព្រោះដល់ព្រមដោយសេចក្ដី ដែលបុគ្គលអ្នកបដិបត្តិគប្បីដឹងឃើញ គប្បីបានដោយបញ្ញា ឈ្មោះថា សព្យញ្ជនំ ប្រកបដោយព្យញ្ជនៈ ព្រោះដល់ព្រមដោយព្យញ្ជនៈនឹងអក្ខរៈ នឹងបទដែលចងជាបទបាលីប្រកាសសេចក្ដីនោះ ។ ឯព្រហ្មចរិយៈឈ្មោះថា កេវលបរិបុណ្ណំ បរិបូណ៌មិនសល់នោះ ព្រោះមិនមានវត្ថុដែលគួរបំពេញថែមទៀត ដូចសតិប្បដ្ឋាន ៤ ជាដើម ក៏គង់នៅជា ៤ មិនមានអ្នកប្រាជ្ញណា អាចពោលទោសថាខ្វះខាតហើយបំពេញឲ្យទៅជា ៥ ឡើងបាន ។ ក៏ឯព្រហ្មចរិយៈឈ្មោះថា បរិសុទ្ធំ ជារបស់បរិសុទ្ធនោះ ព្រោះជារបស់មិនមានទោសដែលគួរកាត់ចេញបាន ដូចអរិយមគ្គ ប្រកបដោយអង្គ ៨ ក៏គង់នៅជា ៨ ដដែល ។ ក្នុងអង្គមគ្គទាំង ៨ នោះ អង្គមគ្គណាមួយដែលអ្នកប្រាជ្ញអាចនឹងជំទាស់ថា លើស ហើយនឹងដកចេញឲ្យនៅតែ ៧ ឬ ៦ ក្ដី ឬអ្នកប្រាជ្ញអាចនឹងគាំងថាអង្គនៃមគ្គនេះមានទោស

www.budinst.gov.kh www.elibraryofcambodia.org

ដូច្នេះ មិនគួរជាអង្គ អវយវៈនៃមគ្គ ហើយផ្លាស់យកធម៌ដទៃជាអង្គ អវយវៈមកជួសក្តីដូច្នេះ ក៏មិនបាន ។ ព្រោះហេតុនោះ ព្រហ្មចរិយៈ ទើបឈ្មោះថាបរិសុទ្ធពេញបរិបូណ៌មិនសល់ ។ វិធីដែលសំដែងថាបរិយត្តិ-សទ្ធម្ម ឈ្មោះថា ដែលព្រះមានព្រះភាគ សំដែងហើយដោយប្រពៃ ព្រោះប្រកាសនូវព្រហ្មចរិយៈ ព្រមដោយអត្ថ នឹងព្យញ្ជនៈ ដ៏បរិសុទ្ធ បរិបូណ៌ប្រពៃពុំមានសេសសល់ ដូចសំដែងមកនេះ ។

មួយទៀត បរិយត្តិសទ្ធម្មនោះ ឈ្មោះថាដែលព្រះពុទ្ធអង្គទ្រង់សំដែង ដោយប្រពៃ ព្រោះមិនមានអត្ថវិបល្លាសដូចធម៌នៃតិរ្ថិយ ។ ដ្បិតថាអត្ថនៃ ធម៌របស់តិរ្ថិយដែលជាគ្រូដទៃ រមែងដល់នូវវិបល្លាស គឺធម៌ដែលតិរ្ថិយ ពោលថាជាអន្តរាយិកធម៌ ជាធម៌ធ្វើឲ្យអន្តរាយដល់សុគតិជាដើម នឹងបាន ធ្វើឲ្យអន្តរាយដូចតិរ្ថិយពោលនោះមិនមាន ។ ឯធម៌ដែលតិរ្ថិយពោលថា ជានិយ្យានិកធម៌ ដូចជាអត្តកិលមថានុយោគបដិបទា បដិបត្តិទរមានខ្លួនឲ្យ លំបាក គឺធ្វើកំដៅកាយឲ្យស្ងួតកិលេស នេះឯងអាចនាំសត្វចេញចាក ទុក្ខបាន សេចក្តីនេះនឹងថាជានិយ្យានិកៈនាំសត្វចេញចាកសង្សារទុក្ខបាន ពិតនោះក៏ទេ ។ ព្រោះហេតុនោះ ធម៌នៃតិរ្ថិយ ទើបឈ្មោះថា ទុរក្ខា-តោ គឺតិរ្ថិយពោលហើយដោយអាក្រក់ ពោលហើយមិនល្អ ។ ឯ អត្ថនៃធម៌ដែលព្រះមានព្រះភាគសំដែងនោះ នឹងបានដល់នូវវិបល្លាស ក៏ទេ ។ ធម៌ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថាជាអន្តរាយិកធម៌ ជា

www.budinst.gov.kh www.elibraryofcambodia.org

ធម៌ធ្វើឲ្យអន្តរាយដល់សួគ៌ជាដើម ដូចជាអន្តរាយិកធម៌ ៤ មានកម្មន្តរា-
យិកធម៌ជាប្រធាន រមែងជាធម៌ធ្វើឲ្យអន្តរាយដល់សួគ៌និងមគ្គផលពិត ៗ
គឺឯសភាវធម៌ ដែលព្រះពុទ្ធអង្គទ្រង់ត្រាស់ថាជានិយ្យានិកធម៌ នាំសត្វ
ចេញចាកសង្សារទុក្ខ ដូចជាអដ្ឋង្គិកមគ្គ គឺរមែងនាំសត្វចេញចាកសង្សារ-
ទុក្ខបានពិត ៗ ព្រោះហេតុដូច្នោះ ធម៌នៃព្រះមានព្រះភាគ ទើបឈ្មោះ
ថា ស្វាក្ខាតោ គឺព្រះមានព្រះភាគសំដែងហើយដោយប្រពៃ ៗ

មួយទៀត លោកុត្តរធម៌ គឺឈ្មោះថា ស្វាក្ខាតោ កករកា
គឺព្រះមានព្រះភាគ សំដែងហើយដោយប្រពៃ ព្រោះបដិបទា សេចក្តី
បដិបត្តិមានសភាពសមគួរដល់ព្រះនិព្វាន ព្រះនិព្វានក៏មានសភាពសមគួរ
ដល់សេចក្តីបដិបត្តិ ដ្បិតព្រះនិព្វានជាស្ថានដែលគប្បីដល់ដោយបដិបត្តិ
សោត គឺជាធម្មជាតបរិសុទ្ធមិនមានកិលេសគឺ រាគៈ ទោសៈ មោហៈ ៗ
បដិបទា ដែលជាផ្លូវដំណើរទៅកាន់ព្រះនិព្វាន គឺត្រៃសិក្ខា ចំណែក
សីលក៏ឃាត់កិលេសគឺ រាគៈ ទោសៈ មោហៈ ដ៏គ្រោតគ្រាតដែលជា
វីតិក្កមៈ សេចក្តីកន្លងសិក្ខាបទបញ្ញត្តិ ដោយកាយនិងវាចា ៗ ចំណែក
សមាធិសោត ក៏ឃាត់កិលេស គឺ រាគៈ ទោសៈ មោហៈ យ៉ាងកណ្តាល
ដែលឈ្មោះថាបរិយុដ្ឋាន ផុសផុលឡើង តាំងនៅដោយជុំវិញនៃចិត្ត ៗ
ចំណែកបញ្ញាសោត ក៏ឃាត់កិលេសគឺ រាគៈ ទោសៈ មោហៈ យ៉ាង
ល្អិត ដែលឈ្មោះថាអនុស័យ បីដូចជាដេកត្រាំនៅក្នុងសន្តាន ៗ

www.budinst.gov.kh www.elibraryofcambodia.org

នេះឯង ជាផ្លូវបដិបត្តិដើម្បីដល់នូវព្រះនិព្វាន ពីសមុទ្ររមែងក្រមួលហូរមក ចូលក្នុងទីជាមួយគ្នា មិនមែនតាស់តែងរៀបគ្នាដូច្នេះ ដូចជាទឹកក្នុងស្ទឹងគង្គាហូរចុះក្នុងទីជាមួយគ្នា នឹងទឹកក្នុងស្ទឹងយមុនា ស្មើដោយពណ៌នឹងរសដូចគ្នាដូច្នោះ ។ ព្រោះហេតុនោះ ព្រះធម៌ទើបឈ្មោះថាគឺព្រះមានព្រះភាគសំដែងហើយដោយប្រពៃ បទថា ធម្មោ ជាប្រធាននៃបទទាំងពួង តាំងអំពី សន្ទិដ្ឋិកោ ទៅ ។ សន្ទិដ្ឋិកោ ប្រែថា ជាធម៌ដែលបុគ្គលគប្បីឃើញឯងច្បាស់ ។ អធិប្បាយថា លោកុត្តរធម៌ ៩ នោះ គឺព្រះអរិយៈអង្គណា ៗ បានហើយ ដល់ហើយ ព្រះអរិយៈអង្គនោះ ៗ គប្បីឃើញឯង ដោយបច្ចវេក្ខណញ្ញាណ មិនបាច់ជឿអ្នកដទៃប្រាប់ លះបង់នូវភាពនៃធម៌ដែលខ្លួនគប្បីដល់ដោយការជឿអ្នកដទៃ ព្រោះហេតុនោះអធិគមសទ្ធម្មទាំងពួង ទើបឈ្មោះថា សន្ទិដ្ឋិកោ ជាធម៌ដែលបុគ្គលគប្បីឃើញឯង ។ អកាលិកោ ប្រែថាជាធម៌មិនមានកាល មិនមានវេលា អធិប្បាយថា ព្រះធម៌គឺព្រះអរិយមគ្គ កើតឡើងហើយក្នុងសន្តាននៃបុគ្គលណា នឹងបង្អង់នៅអស់កាល ៥ ថ្ងៃ ៧ ថ្ងៃ ឬ ១ ថ្ងៃ កន្លះថ្ងៃ ហើយទើបឲ្យផលក៏ទេ រមែងឲ្យផលក្នុងលំដាប់ដែលខ្លួនប្រព្រឹត្តទៅនោះឯង គឺជវនក្ខណៈនៃចិត្តដែលសម្បយុត្តដោយមគ្គ រលត់ហើយ ជវនក្ខណៈនៃចិត្តដែលសម្បយុត្តដោយផល ក៏កើតឡើងក្នុងលំដាប់ មិនមានជវនក្ខណៈនៃចិត្តដទៃទៀតក្នុងចន្លោះបាន ។ ព្រោះហេតុនោះ

www.budinst.gov.kh www.elibraryofcambodia.org

មគ្គធម៌ទើបឈ្មោះថា អកាលិកោ ជាធម៌មិនមានកាល មិនមានវេលា ។ ឯហិបស្សិកោ ប្រែថា ជាធម៌គួរដល់ឯហិបស្សវិធី គឺបីដូចជានឹងហៅអ្នកដទៃថា អ្នកចូលមកមើលបាន អធិប្បាយថា អធិគមសទ្ធម្មទាំងពួង ជាធម៌មានពិត និងជាធម៌បរិសុទ្ធថ្លាស្អាតពិត ទើបគួរនឹងហៅឲ្យអ្នកដទៃមកមើលបាន ដូចជាបុគ្គលមានក្ដាប់ដៃទទេ មិនអាចនឹងហៅអ្នកដទៃថា ប្រាក់ មាស របស់យើងមាន ចូរអ្នកមកមើលចុះដូច្នេះបានទេ ព្រោះក្នុងក្ដាប់ដៃមិនមានរបស់អ្វី ឬ ក្នុងក្ដាប់ដៃនោះមានរបស់ដែរ តែជាមូត្រឬលាមក ក៏មិនអាចនឹងហៅថាអ្នកចូលមកមើលដូច្នេះ ដើម្បីញុំាងចិត្តអ្នកដទៃឲ្យរីករាយដោយប្រកាសនូវរបស់គាប់ចិត្តបានឡើយ ។ មែនពិត មូត្រនិងលាមកនោះជារបស់គួរខ្ពើមឆ្អើម ដោយស្មោកនិងស្អុយរលួយ ព្រោះថាជារបស់មិនស្អាត ។ ចំណែកលោកុត្តរធម៌ទាំង ៩ នេះ ជាធម៌មានពិត ដោយសភាពរបស់ខ្លួន និងបរិសុទ្ធថ្លាស្អាត ដូចចន្ទ-មណ្ឌល ដ៏ពេញវង់ ឬដ៏អាកាស ប្រាសចាកមេឃវលាហក ។ មួយទៀត បរិសុទ្ធ បីដូចកែវមណី ដែលបុគ្គលដាក់ទុកក្នុងសំពត់កម្ពល ។ ព្រោះហេតុនោះ អធិគមសទ្ធម្មទាំងពួង ទើបឈ្មោះថា ឯហិ បស្សិកោ គួរនឹងហៅអ្នកដទៃ ឲ្យចូលមកមើលបាន ។ ឱបនយិកោ ប្រែថា ជាធម៌ដែលបុគ្គលគប្បីបង្អោនចូលមកបាន ។ អធិប្បាយថា ធម៌នេះ ដែលពួកព្រះអរិយៈ គួរបង្អោនចូលមកដាក់ក្នុងចិត្តនៃខ្លួន ៗ បាន ដោយ

www.budinst.gov.kh www.elibraryofcambodia.org

ចំណាប់នៃភាវនា គឺប្រាជ្ញាបរិពេញនូវសេចក្ដីព្យាយាម បើដូចបុគ្គល ប្រញាប់លត់ភ្លើងដែលឆេះសំពត់ នឹងឆេះក្បាល ហើយនឹងធ្វើមគ្គផល ឲ្យកើតមានឡើង ។ ព្រោះហេតុនោះ ព្រះធម៌ទើបឈ្មោះថា ឱបន-យិកោ ដែលបុគ្គលគប្បីបង្អោនចូលមកបាន ។ អធិប្បាយដូច្នេះ បានក្នុងសង្ខតលោកុត្តរធម៌ គឺមគ្គផល ។ ចំណែកអសង្ខតលោកុត្តរធម៌ គឺព្រះនិព្វានដែលព្រះអរិយៈគួរបង្អោនចូលមកដោយចិត្តនៃខ្លួនបាន គឺថា ព្រះអរិយៈគប្បីធ្វើឲ្យជាក់ច្បាស់ ក្នុងយកជាអារម្មណ៍ ដោយអរិយមគ្គ-ចិត្ត ។ ព្រោះហេតុនោះ សូម្បីព្រះនិព្វាន ក៏ឈ្មោះថា ឱបនយិកោ ដែលបុគ្គលគួរបង្អោនចូលមកបានដូចគ្នា ។ បច្ចត្តំ វេទិតព្វោ វិញ្ញូហិ ប្រែថាជាធម៌ ដែលអ្នកប្រាជ្ញវិសេសទាំងឡាយ គប្បីដឹងច្បាស់ ចំពោះខ្លួន ។ អធិប្បាយថា អធិគមសម្បទាទាំងពួងនេះ ដែលអ្នកប្រាជ្ញ គឺព្រះអរិយៈជាឧគ្ឃដិតញ្ញូ វិបចិតញ្ញូ ឬនេយ្យៈ ៣ ពួកនេះ នឹងគប្បីឃើញច្បាស់ ចំពោះខ្លួន ។ ថា មគ្គគឺយើងឲ្យកើតឲ្យមានហើយ ផលគឺយើងបានសម្រេចហើយ ព្រះនិព្វានជាទីរលត់ទុក្ខ គឺយើងធ្វើឲ្យជាក់ច្បាស់ហើយដូច្នេះ ។ មែនពិត មគ្គដែលឧបជ្ឈាយ៍ឲ្យកើតមានឡើងហើយ នឹងរំដោះនូវកិលេសនៃសទ្ធិវិហារិក ដែលជាសិស្សក៏មិនបាន ។ សទ្ធិវិហារិកនឹងនៅជាសុខសម្រាន្ត ដោយសារផលសមា-បត្តិនៃឧបជ្ឈាយ៍នោះផងក៏មិនបាន នឹងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន

www.budinst.gov.kh www.elibraryofcambodia.org

ដែលគេបង្ហាញនោះធ្វើឲ្យជាក់ច្បាស់ហើយដឹងក៏មិនបាន ។ ព្រោះហេតុនោះលោកុត្តរធម៌នោះ ទើបជាធម៌ដែលអ្នកដទៃមិនគប្បីឃើញដែរបាន ដូចអាករណៈគ្រឿងប្រដាប់សិរីនៃអ្នកដទៃ ជាធម៌មានចំពោះវិញ្ញូបុគ្គល ដែលគប្បីឃើញ គប្បីសោយ ក្នុងចិត្តរបស់ខ្លួនមួយចំណែក ដ្បិតជាលោកុត្តរធម៌ មិនមែនជាវិស័យនៃមនុស្សពាល ព្រោះហេតុដូច្នោះ លោកុត្តរធម៌ទើបជា បច្ចត្តំ វេទិតព្វោ វិញ្ញូហិ ដែលអ្នកដឹងវិសេសទាំងឡាយ គប្បីដឹងច្បាស់ចំពោះខ្លួន ។

មួយទៀត ធម៌ដែលឈ្មោះថា ស្វាក្ខាតោ គឺព្រះមានព្រះភាគសំដែងទុកដោយប្រពៃហើយ ព្រោះជាធម៌ដែលបុគ្គលគប្បីឃើញឯង ។ ដែលឈ្មោះថា សន្ទិដ្ឋិកោ ជាធម៌ដែលបុគ្គលគប្បីឃើញឯង ព្រោះជាធម៌មិនមានកាល មិនមានវេលា ។ ដែលឈ្មោះថា អកាលិកោ មិនមានកាល មិនមានវេលា ព្រោះជារបស់គួរហៅអ្នកដទៃមកមើលបាន ។ ក៏ឯធម៌ណាឈ្មោះថា ឯហិ បស្សិកោ ជាធម៌គួរនឹងហៅអ្នកដទៃឲ្យមកមើលបាន ធម៌នោះក៏រមែងជា ឱបនយិកោ ដែលបុគ្គលគប្បីបង្អោនចូលមកដាក់ក្នុងចិត្តបាន ហើយនឹងគប្បីបង្អោនចូលមកដោយចិត្តបាន ព្រោះជាធម៌ដែលអ្នកដឹងវិសេសទាំងឡាយ គប្បីដឹងច្បាស់ចំពោះខ្លួន ។ សំដែងមកដូច្នេះ ជាពាក្យសំដែងនូវបទខាងក្រោយជាហេតុនៃបទ

www.budinst.gov.kh www.elibraryofcambodia.org

មុខនាៗ ក៏ឯគុណនៃព្រះធម៌ដែលពណ៌នាសេចក្តីតាំងអំពីបទ សន្ទិ. ដ្ឋិកោ មកនេះ សុទ្ធតែជាគុណនៃលោកុត្តរធម៌ ជាធម៌ខ្ពស់ ជាវិស័យនៃព្រះអរិយៈមួយពួក មិនមែនជាវិស័យនៃបុថុជ្ជន ៗ កាលបើសំដែងដល់បុថុជ្ជនក៏ងងឹតងងល់មិនប្រាកដដល់បុថុជ្ជន ដូចសំដែងរូបដ៏វិសេសអស្ចារ្យក្នុងអាកាសដល់មនុស្សមានចក្ខុខ្វាក់អំពីកំណើត ៗ ព្រោះហេតុនោះកល្យាណបុថុជ្ជន អ្នកប្រាជ្ញានឹងឃើញគុណនៃព្រះធម៌ តាមបទនៃព្រះបាលីនេះ គឺគប្បីលើកយកគុណនៃបដិបត្តិសទ្ធម្មចំណែកជាលោកិយ ដែលជាវិស័យនៃខ្លួនចូលមកប្រៀបក្នុងបទថា សន្ទិដ្ឋិកោ ជាដើម ហើយរំពឹងមើលចុះ ក៏នឹងឃើញបាន ៗ កាលបើឃើញគុណនៃបដិបត្តិសទ្ធម្មថាជា សន្ទិដ្ឋិកោ ហើយ ក៏នឹងអនុមាននឹងតាមក្នុងលោកុត្តរធម៌ថាជាសន្ទិដ្ឋិកោ បានខ្លះដោយបរិយាយ ចំដូចជាបុថុជ្ជនចំរើនកាយគតា-សតិពិចារណាកាយនេះ ពេញដោយវត្ថុមិនស្អាតគ្រឿងស្មោកគ្រោកផ្សេងៗ គឺសក់ រោម ក្រចក ធ្មេញ ជាដើម ដកបដល់មូត្រជាទីបំផុត ចំណែកអាការទាំង ៣១ នេះ សូម្បីតែចំណែកមួយ ៗ សុទ្ធសឹងជាគ្រឿងស្មោកគ្រោក ហើយនឹងបានសមាធិ ការតាំងចិត្តខ្ជាប់ យ៉ាងតិចបានខណិកៈ ឬឧបចារៈ ក្នុងចំណែកណាមួយក្តី ឬ បញ្ញាដែលឃើញទោសនៃកាយជាមិនស្អាតក្តី ៗ ចំណែកសមាធិក្តីជាធម៌ថាស្អាត ព្រោះប្រែសង្កត់កាមច្ឆន្ទៈ ដែលជាភក់ៈ សេចក្តីត្រេកអរក្នុងកាយខ្លួននិងកាយអ្នកដទៃ

www.budinst.gov.kh www.elibraryofcambodia.org

សមាធិដ៏ថ្លាស្អាតកើតឡើងក្នុងចិត្ត ឃើញច្បាស់ដល់ខ្លួនឯង ៗ ចំណែក បញ្ញាសោតកំចាត់នូវនិតិរោហៈ ដែលឃើញថាកាយល្អ ជាអសុភានុបស្សនា ដ៏ថ្លាស្អាតកើតឡើងជាមួយនឹងចិត្ត ឃើញច្បាស់ប្រាកដដល់ខ្លួន សមាធិនឹងបញ្ញានេះ ឈ្មោះថាលោកិយបដិបត្តិសម្មា ៗ លោកិយបដិបត្តិសម្មានេះ ក៏ជា សន្ទិដ្ឋិកោ ដែលបុគ្គលអ្នកបដិបត្តិគប្បីឃើញឯងដូច្នេះប្រាកដ ៗ កាលបើឃើញថាលោកិយបដិបត្តិសម្មាជា សន្ទិដ្ឋិកោ ដូច្នេះហើយ ក៏គង់នឹងឃើញថាជា អកាលិកោ មិនមានកាល មិនមានវេលា ថាបដិបត្តិប្រពៃត្រូវល្អហើយថ្ងៃនេះ ព្រឹកនេះ សមាធិនឹងបញ្ញា ទើបនឹងកើតឡើងដូច្នេះ ៗ កាលឃើញថាជា អកាលិកោ ហើយ ក៏គង់នឹងឃើញថាជា ឯហិ បស្សិកោ គួរនឹងហៅថា អ្នកចូលមកមើលចុះ ព្រោះសមាធិនឹងបញ្ញាជារបស់មាននៅប្រាកដ នឹងជារបស់ច្បាស់ កាលបើឃើញថាជា ឯហិ បស្សិកោ ហើយ ក៏គង់នឹងឃើញថាជា ឱបនយិកោ ដែលបុគ្គលគប្បីបង្អោនចូលមកក្នុងចិត្តបាន ព្រោះសមាធិនឹងបញ្ញាកើតឡើងក្នុងចិត្តខ្លួន ៗ កាលឃើញថាជា ឱបនយិកោ ហើយក៏គង់នឹងឃើញថាជា បច្ចត្តំ វេទិតព្វោ វិញ្ញូហិ លោកអ្នកដ៏វិសេសទាំងឡាយនឹងគប្បីដឹងច្បាស់ចំពោះខ្លួន ព្រោះសមាធិនឹងបញ្ញា ជារបស់កើតឡើងឃើញច្បាស់ដោយខ្លួនឯង ក្នុងលើចមិនបានឃើញដូច្នេះ ៗ មួយទៀត

www.budinst.gov.kh www.elibraryofcambodia.org

បើបុគ្គលចំរើនក្នុងវិបស្សនាបញ្ញាហើយសោត រមែងនឹងឃើញគុណនៃ
បដិបត្តិសម្ម ដោយបទបាលីថា ស្វាក្ខាតោ ភគវតា ធម្មោ
សន្ទិដ្ឋិកោ ទៅដោយងាយ តែជាបើវិបស្សនាបញ្ញាជារបស់ល្អិត
សុខុម ១៦ កាយគន្ធៈ ជាដើម ដែលជាអារម្មណ៍នៃវិបស្សនាបញ្ញានោះ
កម្របុគ្គលនឹងតប្បំរឹង ព្រោះហេតុនោះ ទើបបានលើកឡើងកាយគតាសតិ-
ភាវនា មកពោលអានល្មមជាបដិបត្តិមុខ គឺជាប្រធាននៃបដិបត្តិ ។

ធម្មគុណកថា ចប់

ធម្មរតនកថា ចប់

www.budinst.gov.kh www.elibraryofcambodia.org

# សង្ឃរតនកថា

## ពណ៌នាព្រះសង្ឃរតនៈ

ឬ. អ្វីហៅថាសង្ឃ ? សង្ឃនោះមានប៉ុន្មានយ៉ាង ? សង្ឃនោះប្រែថាដូចម្ដេច ?

វិ. ពួកបុគ្គលដែលបានស្ដាប់នូវឱវាទានុសាសនៈ គឺពាក្យទូន្មានប្រដៅនៃព្រះពុទ្ធអង្គដោយគោរព ហើយត្រាស់ដឹងតាមព្រះមានបុណ្យ ទើបឈ្មោះថាសង្ឃក្នុងទីនេះ ។ ដែលហៅថាសង្ឃនោះមាន ២ យ៉ាង គឺ សម្មតិសង្ឃ ១ អរិយសង្ឃ ១ ។ ភិក្ខុតាំងពី ៤ អង្គឡើងទៅអង្គុយក្នុងសីមាមិនលះហត្ថបាសគ្នា មានអំណាចឲ្យសម្រេចសង្ឃកម្មនោះៗ បាន មានឧបោសថកម្មជាដើម ឈ្មោះថាសម្មតិសង្ឃ ប្រែថាសង្ឃដោយសម្មតិ ។ ពួកសាវកនៃព្រះមានបុណ្យ ដែលជាអរិយសាវក ឈ្មោះជាអរិយសង្ឃ ប្រែថាពួកនៃព្រះអរិយៈ ។ នឹងសំដែងអំពីសាវកនៃព្រះមានបុណ្យជាមុន សាវក ប្រែថា បុគ្គលអ្នកស្ដាប់នូវពាក្យប្រដៅនៃព្រះមានបុណ្យ គឺឯបុគ្គលដែលឈ្មោះថាសាវកនោះមាន ២ ពួក គឺបុថុជ្ជនសាវក ១ អរិយសាវក ១ បុគ្គលចំពួកណាដែលបានស្ដាប់ឱវាទចំពោះព្រះភក្ត្រនៃព្រះមានបុណ្យ ឬស្ដាប់អំពីសំណាក់សាវកនៃព្រះមានបុណ្យក្ដី មិនបានត្រាស់ដឹងមគ្គផលធម៌វិសេសណាមួយ

www.budinst.gov.kh www.elibraryofcambodia.org

បានតែសទ្ធាសេចក្តីជឿ ក្នុងគុណព្រះរតនត្រ័យ ស្ថិតនៅក្នុង
សរណគមន៍ បុគ្គលពួកនោះ ឈ្មោះថាបុថុជ្ជនសាវក សាវកជា
បុថុជ្ជន ។ បុគ្គលពួកណាបានស្តាប់ធម្មទេសនាដែលព្រះមានបុណ្យ
ទ្រង់សំដែងដោយព្រះអង្គឯងក្តី ឬសាវកនៃព្រះមានបុណ្យណាមួយ
ក្នុងពុទ្ធកាល ឬខាងក្រោយពុទ្ធកាលសំដែងក្តី អ្នកនោះរមែងបាន
លោកុត្តរាភិសម័យមគ្គផល ក្នុងខណៈកាលស្តាប់នោះក្តី ឬបដិបត្តិតាម
ពាក្យប្រដៅហើយបានក្នុងខាងក្រោយក្តី តាំងអំពីកាលនេះ ឈ្មោះថា
អរិយសាវក ប្រែថា សាវកអ្នកឆ្ងាយចាកសត្រូវគឺ កិលេស ក្នុងបទនេះ
មិនសង្គ្រោះយកបុថុជ្ជនសាវកទេ សង្គ្រោះយកតែអរិយសាវក ១ ពួក
ប៉ុណ្ណោះ ។ ឯអរិយសាវកនោះ រាប់ជាគូមាន ៤ គូ គឺ សោតាបត្តិមគ្គដ្ឋៈ
សោតាបត្តិផលដ្ឋៈ គូ ១ សកទាគាមិមគ្គដ្ឋៈ សកទាគាមិផលដ្ឋៈ គូ ១
អនាគាមិមគ្គដ្ឋៈ អនាគាមិផលដ្ឋៈ គូ ១ អរហត្តមគ្គដ្ឋៈ អរហត្តផលដ្ឋៈ គូ ១
រាប់រៀងបុគ្គលបាន ៨ រីឯឈ្មោះព្រះអរិយៈមាន ៤ គឺសោតាបន្ន ១
សកទាគាមី ១ អនាគាមី ១ អរហន្ត ១ ឈ្មោះ ៤ នេះ អាស្រ័យ
លោកដែលតាំងនៅហើយក្នុងផល ពោលដោយគុណគឺលះកិលេស
នោះ ៗ ដោយមគ្គនោះ ៗ ហើយតាំងនៅក្នុងផល ព្រះសោតាបន្នលះ
សំយោជនៈ បាន ៣ គឺសក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១
ដូចសំដែងហើយក្នុងសោតាបត្តិមគ្គ ព្រមទាំងលះកាមរាគ ព្យាបាទ

www.budinst.gov.kh www.elibraryofcambodia.org

ចំណែកដ៏ប្រាកដប្រជាដែលមិនឲ្យកើតទុគ្គតិ ៣ ជាអបាយតាមអកុសល ឲ្យផុតអបាយ លោកជាបុគ្គលមានធម៌ជាគ្រឿងមិនឲ្យធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង ជាបុគ្គលគង់នឹងបានត្រាស់ដឹង នូវអរហត្តផលទៅខាងមុខ ជាព្រះអរិយៈដល់នូវព្រះនិព្វានជាដំបូង ខណៈកាលលោកដល់សោតាបត្តិមគ្គ ឈ្មោះថាសោតាបត្តិមគ្គដ្ឋៈ ប្រែថាជាអ្នកតាំងនៅក្នុងសោតាបត្តិមគ្គ ខណៈកាលលោកដល់សោតាបត្តិផល ឈ្មោះថាសោតា-បត្តិផលដ្ឋៈ ប្រែថាលោកអ្នកស្ថិតនៅក្នុងសោតាបត្តិផល ។ មួយទៀតដែលឈ្មោះថាសោតាបន្នោះ ប្រែថាលោកជាអ្នកដល់នូវប្រឡាយនៃព្រះនិព្វានគឺមគ្គ ព្រោះព្រះសោតាបន្នមាន ៣ ពួក គឺឯកពីជី មានពូជគឺភពតែ ១ ព្រោះត្រូវកើតក្នុងមនុស្សលោក ឬទេវលោកទៀតតែម្ដង ហើយធ្វើឲ្យច្បាស់នូវព្រះអរហត្តផល អស់ភពខាងមុខ ចំពួក ១ ឈ្មោះកោលំកោលៈ គឺត្រូវកើតពីរភព ឬ ៣ ភពទៀត ទើបធ្វើឲ្យច្បាស់នូវព្រះអរហត្តផលចំពួក ១ ឈ្មោះសត្តក្ខត្តុបរមៈ គឺទៅត្រាច់ផ្លាត់ក្នុងមនុស្សលោកនិងទេវលោក ៧ ដងឬ ៧ ជាតិ ជាយ៉ាងច្រើនបំផុត មិនដល់ជាតិជាគំរប់ ៨ ទើបធ្វើឲ្យច្បាស់នូវព្រះអរហត្តផលដោយខន្ធបរិនិព្វានក្នុងភពគំរប់ ៧ ពិតប្រាកដចំពួក ១ ត្រូវជា ៣ ចំពួកដូច្នេះ ។ ព្រះសកទាគាមីលោករមែងធ្វើ រាគៈ ទោសៈ មោហៈ ដែលជាអកុសលមូលឲ្យតិចឲ្យស្ដើងឲ្យស្រាលទៅ ដូចដើមស្មៅដុះក្នុងម្លប់ លោកមកកើតក្នុងកាមភព

www.budinst.gov.kh www.elibraryofcambodia.org

នេះម្ដងទៀត ហើយធ្វើឲ្យច្បាស់នូវអរហត្តផលជាទីបំផុតនៃទុក្ខ រលត់ខន្ធបរិនិព្វាន ក្នុងខណៈដែលលោកដល់សកទាគាមិមគ្គ ឈ្មោះថាសកទាគាមិមគ្គដ្ឋៈ ប្រែថាលោកអ្នកតាំងនៅក្នុងសកទាគាមិមគ្គ ក្នុងខណៈដែលលោកដល់សកទាគាមិផលហើយ ឈ្មោះថាសកទាគាមិផលដ្ឋៈ ប្រែថាលោកអ្នកតាំងនៅក្នុងសកទាគាមិផល ឬមួយឈ្មោះថាសកទាគាមី ប្រែថាលោកអ្នកមកកាន់កាមភពម្ដងទៀត ។ ព្រះអនាគាមី លោករមែងលះសំយោជនៈពីរ គឺកាមរាគ ព្យាបាទបាន រលត់ខន្ធហើយ រមែងទៅកើតក្នុងសុទ្ធាវាសព្រហ្មលោកទាំង ៥ ណាមួយ ហើយរលត់ខន្ធ បរិនិព្វានក្នុងសុទ្ធាវាសនោះ គឺមិនត្រឡប់ចាកព្រហ្មលោកនោះជាធម្មតា ក្នុងខណៈដែលលោកដល់អនាគាមិមគ្គ ឈ្មោះថាអនាគាមិមគ្គដ្ឋៈ ប្រែថាលោកស្ថិតនៅក្នុងអនាគាមិមគ្គ ក្នុងខណៈដែលលោកដល់អនាគាមិផល ឈ្មោះថាអនាគាមិផលដ្ឋៈ ប្រែថាលោកស្ថិតនៅក្នុងអនាគាមិផល ឬមួយឈ្មោះថាអនាគាមី ប្រែថា លោកមិនមកកាន់កាមភពនេះទៀត ព្រះអនាគាមីនោះមាន ៥ ចំពូកគឺ ឈ្មោះថា អន្តរាបរិនិព្វាយី លោករលត់ក្នុងចន្លោះ គឺថាកើតក្នុងសុទ្ធាវាសព្រហ្មលោកហើយ ឋិតនៅមិនទាន់ដល់ពាក់កណ្ដាលអាយុ លោករមែងញ៉ាំងអរហត្តមគ្គឲ្យកើតឡើង ដើម្បីលះសំយោជនៈខាងលើបានចំពូក ១ ឈ្មោះថាឧបហច្ចបរិនិព្វាយី លោកអ្នកចូលទៅដល់ហើយរលត់ គឺលោកមានអាយុជាងពាក់កណ្ដាលឡើង

www.budinst.gov.kh www.elibraryofcambodia.org

ទៅ ដល់កាលទៀបនឹងអស់អាយុ ញុំាងអរហត្តមគ្គឲ្យកើតឡើង ដើម្បីលះសំយោជនៈខាងលើទាំង ៥ បានចំពូក ១ ឈ្មោះថា អសង្ខារបរិនិព្វាយី លោកលែងដោយអសង្ខារ គឺថាលោកញុំាងអរហត្តមគ្គឲ្យកើតឡើង ដើម្បីលះសំយោជនៈ ៥ ខាងលើ បានដោយងាយ មិនបាច់ប្រកបសេចក្តីព្យាយាមជាយ៉ាងធំក្រៃពេក ចំពូក ១ ឈ្មោះថា សសង្ខារបរិនិព្វាយី លោកអ្នកលែងដោយសសង្ខារ គឺថាលោកញុំាងអរហត្តមគ្គឲ្យកើតឡើងបានដោយក្រ គឺត្រូវប្រកបសេចក្តីព្យាយាមយ៉ាងធំក្រៃពេក ចំពូក ១ ឈ្មោះថា ឧទ្ធំសោតអកនិដ្ឋគាមី លោកអ្នកមានក្រសែវដ្ដខាងលើ ទៅកាន់ភពឈ្មោះអកនិដ្ឋៈ គឺច្យុតចាកអវិហាព្រហ្មលោកហើយ ទៅកាន់អតប្បាព្រហ្មលោក លុះច្យុតចាកអតប្បាព្រហ្មលោកហើយ ទៅកាន់សុទស្សាព្រហ្មលោក លុះច្យុតចាកសុទស្សាព្រហ្មលោកហើយ ទៅកាន់សុទស្សីព្រហ្មលោក លុះច្យុតចាកសុទស្សីព្រហ្មលោកហើយ ទៅកាន់អកនិដ្ឋព្រហ្មលោក ហើយញុំាងអរហត្តមគ្គឲ្យកើតឡើងលះសំយោជនៈខាងលើ ក្នុងព្រហ្មលោកនោះចំពូក ១ ត្រូវជា ៥ ចំពូកវុំះ ៗ ព្រះអរហន្តរមែងលះសំយោជនៈខាងលើបាន ៥ គឺរូបរាគអរូបរាគ មានះ ឧទ្ធច្ចៈ អវិជ្ជាដែលជាកិលេសយ៉ាងល្អិត អស់ក្នុងសន្តានមុន រលត់ទាំងហើយ បរិនិព្វាន ក្នុងខណៈកាលដែលលោកដល់អរហត្តមគ្គ ឈ្មោះថា អរហត្តមគ្គផលៈ ប្រែថាលោកស្ថិតនៅក្នុងអរហត្តមគ្គ

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងខណៈដែលលោកដល់អរហត្តផល ឈ្មោះថាអរហត្តផលដ្ឋៈ ប្រែថា លោកស្ថិតនៅក្នុងអរហត្តផល ពួកមួយ ឈ្មោះថាអរហន្ត ប្រែថា លោកជាអ្នកគួរ ជាអ្នកឆ្ងាយចាកកិលេស ព្រះអរហន្តនោះ ដោយគុណនាមដែលប្រាកដមាន ៤ ចំពូក គឺ សុក្ខវិបស្សកោ លោកមានវិបស្សនាជាវ៉ះ ស្ងួត ព្រោះមិនមានជ័រ គឺ សមថភាវនា បានចំរើនវិបស្សនា បានដល់នូវព្រះអរហត្ត មិនប្រកបដោយបុទ្ធិវិសេសណា នីមួយចំពូក ១ ឈ្មោះថាតេវិជ្ជោ លោកប្រកបដោយវិជ្ជា ៣ ចំពូក ១ ឈ្មោះថាឆឡភិញ្ញោ លោកប្រកបដោយអភិញ្ញា ៦ ចំពូក ១ ឈ្មោះថាបដិសម្ភិទប្បត្តោ លោកដល់បដិសម្ភិទាទាំង ៤ ចំពូក ១ ជា ៤ ចំពូកដូច្នេះ ប្រភេទ ៤ នេះរមែងបានក្នុងព្រះអរិយៈពួកខាងក្រោម ដោយបរិយាយពួកនៃព្រះអរិយៈដែលជាសាវកនៃព្រះមានបុណ្យ ដូចសំដែងមកនេះ ឈ្មោះថាអរិយសង្ឃក្នុងបទនេះ ទើបបានសមដូចព្រះបាលីថា កតមោ សាវកសង្ឃោ សង្ឃោ នោះ ប្រែថា ពួក ជាជុំគ្នា គឺថាព្រះអរិយៈអម្បាលនេះ សូម្បីនៅឆ្ងាយអំពីគ្នា អន្លើមួយ ប្រទេស ១ អន្លើមួយ ភព ១ ផ្សេងគ្នា ដោយជាតិទីឯកេ។ ក៏ឈ្មោះថាជាពួកតែមួយ ឈ្មោះថាជុំគ្នា ដោយគុណគឺសីល និងទិដ្ឋិសេចក្ដីឃើញស្មើគ្នា ដូចពាក្យថា មិគសង្ឃោ ប្រែថាពួកសត្វម្រឹគ សកុណសង្ឃោ ប្រែថា ពួកសត្វបក្សី ដោយលោកវោហារ ដែលជាដូច្នេះ អាស្រ័យជាតិនិងអវយវៈសណ្ឋានកាយ

www.budinst.gov.kh www.elibraryofcambodia.org

ដែលដូចគ្នា ប្រហែលគ្នា ជាពួកជាគណសព្វការទៅលើផែនដីក្តី លើអាកាសក្តី លោកហៅថាគណៈហៅថា ពួកម្រឹគ ពួកបក្សី ព្រោះជាសត្វទាំងនោះដូចគ្នា ប្រហែលគ្នា ជិតគ្នា កំឯព្រះអរិយៈនៅផ្សេងស្ថានគ្នាក្តី តែគុណគឺសីលនិងទិដ្ឋិនោះដូចគ្នា ប្រហែលគ្នា ជិតគ្នា ព្រោះហេតុនោះ ដោយអរិយវោហារ ទើបហៅថា សង្ឃ ជាពួក ជាជិតគ្នា ដោយគុណ ។

បុ. ព្រះសង្ឃមានគុណដូចម្តេច?

វិ. គុណនៃព្រះសង្ឃមានច្រើន តែនឹងបំប្រួញឲ្យខ្លីចុះមក គុណដែលជាប្រធាននៃគុណទាំងពួងក៏មាននៃតែមួយយ៉ាង គឺ សុបដិបត្តិ សេចក្តីបដិបត្តិប្រពៃ ។

លំដាប់នេះនឹងប្រែ អធិប្បាយគុណបាលីថា សុបដិបន្នោ ជាដើម ដើម្បីនឹងឲ្យសាធុជនដឹងគុណនៃព្រះសង្ឃ ដែលជាអនុស្សតិដ្ឋាន ។

កតរោ សាវកសង្ឃោ ព្រះសង្ឃសាវកនៃព្រះមានបុណ្យ ថ្វីប្រែថា ពួកសាវកនៃព្រះមានបុណ្យ សុបដិបន្នោ លោកបដិបត្តិប្រពៃហើយ គឺថាលោកដំណើរទៅកាន់ សម្មាបដិបទា អនិវត្តិបដិបទា អនុលោមបដិបទា អបច្ចនិកាបដិបទា និង ធម្មានុធម្មបដិបទា ។ មគ្គ ប្រកបដោយអង្គ ៨ ដែលសង្គ្រោះដោយខន្ធ ៣ គឺ សីល សមាធិ បញ្ញា នេះឯង ឈ្មោះថា សម្មាបដិបទា ព្រោះជាការបដិបត្តិប្រពៃពិតមិនវិបល្លាស, ឈ្មោះថា អនិវត្តិបដិបទា

www.budinst.gov.kh www.elibraryofcambodia.org

ការបដិបត្តិមិនត្រឡប់ ព្រោះអ្នកណាដំណើរដល់ហើយ អ្នកនោះឈ្មោះថា ព្រះអរិយៈមិនត្រឡប់មកជាបុថុជ្ជនទៀត ឈ្មោះថា អនុលោមបដិបទា ការបដិបត្តិជាអនុលោមដល់ព្រះនិព្វាន ឈ្មោះថា អប្បច្ចនិកបដិបទា ការបដិបត្តិមិនជាសត្រូវដល់ព្រះនិព្វាន ឈ្មោះថា ធម្មានុធម្មបដិបទា ការបដិបត្តិនូវធម៌តាមធម៌ គឺបដិបត្តិសមគួរដល់ព្រះនិព្វាន ។ ព្រះសង្ឃជាអ្នកដំណើរតាម សម្មាបដិបទា ដែលប្រកបដោយគុណដូចសំដែងមកនេះឯង ទើបឈ្មោះថា សុបដិបន្នោ លោកបដិបត្តិល្អហើយ ។

កតកតា សាវកសង្ឃោ ព្រះសង្ឃសាវកនៃព្រះមានបុណ្យ ឧជុបដិបន្នោ លោកដំណើរទៅកាន់ផ្លូវបដិបត្តិត្រង់ សម្មាបដិបទាដូចសំដែងមកនេះឯង ឈ្មោះថា ឧជុបដិបទា ជាផ្លូវបដិបត្តិត្រង់មិនវៀចមិនកោង មិនវែកជាផ្លូវត្រង់ទៅកាន់ព្រះនិព្វាន ព្រះសង្ឃដំណើរតាមសម្មាបដិបទានោះ ទើបឈ្មោះថា ឧជុបដិបន្នោ លោកដំណើរទៅកាន់ផ្លូវបដិបត្តិត្រង់ ។

កតរតោ សាវកសង្ឃោ ព្រះសង្ឃសាវកនៃព្រះមានបុណ្យ ញាយបដិបន្នោ លោកដំណើរទៅកាន់ផ្លូវបដិបត្តិដើម្បីត្រាស់ដឹង សម្មាបដិបទា សេចក្តីបដិបត្តិប្រពៃនោះឯង ឈ្មោះថា ញាយបដិបទា ព្រោះជាផ្លូវបដិបត្តិសម្រាប់ ដឹងច្បាស់ចាក់ធ្លុះនូវព្រះនិព្វាន ជារបស់ព្រះ

www.budinst.gov.kh www.elibraryofcambodia.org

អរិយៈជាម្ចាស់ ព្រះសង្ឃដំណើរតាមផ្លូវបដិបត្តិនោះ ទើបឈ្មោះថា ញាយប្បដិបន្នោ លោកដំណើរទៅហើយកាន់ផ្លូវបដិបត្តិដើម្បីត្រាស់ដឹង ។

ភគវតោ សាវកសង្ឃោ ព្រះសង្ឃសាវ័កនៃព្រះមានបុណ្យ សាមីចិបដិបន្នោ លោកដំណើរទៅកាន់ផ្លូវបដិបត្តិប្រពៃពិត សម្មាបដិបទា ផ្លូវបដិបត្តិប្រពៃនោះឯង ឈ្មោះថា សាមីចិបដិបទា ព្រោះជាផ្លូវបដិបត្តិប្រពៃពិត សមគួរដល់ព្រះនិព្វាន ព្រះសង្ឃលោកដំណើរទៅតាមផ្លូវបដិបត្តិនោះ ទើបឈ្មោះថា សាមីចិបដិបន្នោ លោកដំណើរទៅកាន់ផ្លូវបដិបត្តិប្រពៃពិត ព្រះអរិយៈបុគ្គលណាតាំងនៅក្នុងមគ្គ ព្រះអរិយៈបុគ្គលនោះ បណ្ឌិតគប្បីដឹងថា សុប្បដិបន្នោ លោកបដិបត្តិល្អហើយ ព្រោះលោកដល់ព្រមដោយនូវសម្មាបដិបទា គឺមគ្គ ព្រះអរិយៈទាំងឡាយណាដែលតាំងនៅក្នុងផល ព្រះអរិយៈទាំងឡាយនោះ បណ្ឌិតគប្បីដឹងថា សុប្បដិបន្នោ លោកបដិបត្តិល្អហើយ គឺស្រេចផ្លូវបដិបត្តិដែលជាអតីតកន្លងទៅហើយ ព្រោះធម៌ដែលលោកគប្បីដល់ គប្បីបានដោយសម្មាបដិបទានោះ លោកដល់ហើយលោកបានហើយ ។

មួយទៀត ព្រះសង្ឃឈ្មោះថា សុប្បដិបន្នោ លោកបដិបត្តិល្អ ព្រោះជាអ្នកបដិបត្តិតាមពាក្យដែលព្រះមានបុណ្យប្រដៅក្នុងធម្មវិន័យដែលព្រះអង្គសំដែងល្អហើយ ។ មួយទៀតឈ្មោះថា សុប្បដិបន្នោ ព្រោះ

www.budinst.gov.kh www.elibraryofcambodia.org

លោកមិនដើរទៅកាន់អបណ្ណកបដិបទា ដំណើរតាមផ្លូវបដិបត្តិមិនខុស ឈ្មោះថា ឧជុប្បដិបន្នោ លោកបដិបត្តិត្រង់ហើយ ព្រោះលោកមិនល្អៀងទៅផិតកាន់ផ្លូវលាមក ២ ប្រការ គឺ កាមសុខល្លិកានុយោគ និងអត្តកិលមថានុយោគ ដែលជាផ្លូវដើរបដិបត្តិខុស លោកដំណើរតាមមជ្ឈិមាបដិបទាផ្លូវបដិបត្តិយ៉ាងកណ្ដាល ។ មួយទៀតឈ្មោះថា ឧជុប្បដិបន្នោ ព្រោះលោកបដិបត្តិត្រង់ ដើម្បីលះបង់នូវទោស គឺសេចក្ដីកោង កាយវាចាចិត្ត ព្រះសង្ឃឈ្មោះថា ញាយប្បដិបន្នោ លោកបដិបត្តិ ដើម្បីធម៌ដែលបុគ្គលគប្បីដឹង ព្រោះលោកបដិបត្តិ ដើម្បីត្រាស់ដឹងដល់ព្រះនិព្វាន ជាធម៌គឺព្រះអរិយបុគ្គលគប្បីដឹង ឈ្មោះថា សាមីចិប្បដិបន្នោ លោកបដិបត្តិប្រពៃពិត ព្រោះជាបុគ្គលទាំងឡាយបដិបត្តិយ៉ាងដូចម្ដេច ទើបលោកជាអ្នកគួរ សាមីចិកម្មគឺអភិវាទក្រាបសំពះជាដើម លោកគឺបដិបត្តិយ៉ាងនោះ ។

មួយទៀត ព្រះសង្ឃឈ្មោះថា សុប្បដិបន្នោ លោកបដិបត្តិល្អនោះ គឺលោកធ្វើសីលប្រៀបបីដូចជារបងកំពែង ដែលការពារសឹកសត្រូវគឺទុច្ចរិតសង្កិលេស ដែលជាអកុសលដ៏គ្រោតគ្រាត កើតក្នុងកាយទ្វារ វចីទ្វារ ហើយលោកធ្វើសមាធិ ប្រៀបដូចផែនសិលាដ៏ បិទបាំងទុកនូវសត្រូវក្នុងខាងក្នុង គឺបរិយុដ្ឋានសង្កិលេស ដែលជាអកុសលកើតឡើង គ្របសង្កត់ចិត្ត លោកធ្វើបញ្ញាជាដូចប្រទីបពន្លឺ ឲ្យភ្លឺក្នុងសន្ដាន

www.budinst.gov.kh www.elibraryofcambodia.org

តាំងពួកដោយចំណែក២ មានខន្ធជាដើម ឃើញច្បាស់ថាមិនទៀង ជាទុក្ខ មិនមែនខ្លួន ដោយហេតុនេះៗហើយ ទើបធ្វើបញ្ញាប្រៀបដូចជាសស្ត្រា មានមុខមុតថ្លាពិឃាដសម្លាប់អនុស័យសង្កិលេស ដែលជាចំណែកល្អិត យ៉ាងតាមថាព្រះសោតាបន្នបុគ្គល អស់សក្កាយទិដ្ឋិដោយឃើញច្បាស់ថា បញ្ចក្ខន្ធមិនមែនខ្លួនប្រាណ អស់វិចិកិច្ឆា សេចក្តីសង្ស័យក្នុងកាលទាំង ៣ ក្នុងរតនៈទាំង ៣ ដោយឃើញគុណព្រះពុទ្ធច្បាស់ ទើបលោកុត្តរធម៌កើតឡើងប្រាកដក្នុងសន្តាន លុះលោកបានសម្រេចជាព្រះអរិយសង្ឃ អស់សីលព្វតបរាមាស ព្រោះឃើញច្បាស់ថាខ្លួនបរិសុទ្ធដោយត្រៃសិក្ខា ដែលជាសម្មាបដិបទាផ្លូវបដិបត្តិប្រពៃ មិនបរិសុទ្ធដោយសីលព្វតដែលជាផ្លូវបដិបត្តិយ៉ាងដទៃ ព្រះសង្ឃឈ្មោះថា ឧជុបដិបន្នោ លោកបដិបត្តិត្រង់នោះ គឺលោកបដិបត្តិត្រង់ព្រមទាំង កាយ វាចា ចិត្ត ព្រោះលះបាននូវការកោង ដោយកាយ វាចា ចិត្ត ឈ្មោះថា ញាយបដិបន្នោ លោកបដិបត្តិដើម្បីចេញចាកសង្សារវដ្ត គឺលោកមិនបដិបត្តិដើម្បីលាភនិងយស សេចក្តីសសើរក្នុងបច្ចុប្បន្ននិងសួគ៌សុគតិភព ដែលសោយសុខនោះៗ ក្នុងខាងមុខ លោកបដិបត្តិដើម្បីនឹងចេញចាកភពទាំងពួងនិងទុក្ខទាំងពួង មួយចំណែកប៉ុណ្ណោះ ព្រះសង្ឃឈ្មោះថា សាមីចិបដិបន្នោ លោកបដិបត្តិប្រពៃពិត គឺលោកបដិបត្តិពត់កាយ វាចា ចិត្ត ដោយត្រៃសិក្ខា គឺ

សីល សមាធិ បញ្ញា ដែលជាសម្មាបដិបទា សេចក្តីបដិបត្តិប្រពៃពិត គួរដល់លោកុត្តរធម៌ យទិទំ ដូចម្តេចនេះ ចត្តារិ បុរិសយុគានិ គូនៃបុរសទាំងឡាយមាន ៤ គូ អដ្ឋ បុរិសបុគ្គលា បុរសបុគ្គលទាំងឡាយមាន ៨ គឺរាប់ជាគូមាន ៤ គូ បើរាប់រៀងខ្លួនបុគ្គលមាន ៨ ឯស ភគវតោ សាវកសង្ឃោ នេះឯងឈ្មោះថាព្រះសង្ឃសាវកនៃព្រះមានបុណ្យ អាហុនេយ្យោ លោកគួរនូវអាហុនៈ អាហុនៈនោះ ប្រែថារបស់ដែលបុគ្គលនាំមក សូម្បីអំពីឆ្ងាយហើយថ្វាយក្នុងបុគ្គលទាំងឡាយដែលជាអ្នកមានសីល គឺបច្ច័យទាំង ៤ នោះឯង ព្រះសង្ឃលោកគួរទទួលនូវអាហុនៈនោះ ព្រោះលោកជាអ្នកធ្វើនូវអាហុនៈនៃទាយកនោះ ឲ្យមានផលច្រើនក្រៃពេក បានដោយគុណនៃខ្លួន ព្រោះហេតុនោះ លោកទើបឈ្មោះថា អាហុនេយ្យោ លោកគួរទទួលនូវអាហុនៈ ។ បាហុនេយ្យោ លោកគួរនូវបាហុនៈ របស់សម្រាប់ទទួលភ្ញៀវ គឺអាគន្តុកទាន ដែលបុគ្គលតាក់តែងទុកព្រមដោយគ្រឿងសក្ការៈ ដើម្បីប្រយោជន៍នឹងទទួលញាតិមិត្រ ជាទីស្រឡាញ់គាប់ចិត្តដែលមកអំពីទិសានុទិស អាគន្តុកទានៈរបស់សម្រាប់ទទួលភ្ញៀវនោះ គួរនឹងលើកវៀរចេញ នូវញាតិមិត្រនឹងមនុស្សដែលមកជាភ្ញៀវទាំងនោះ ហើយថ្វាយចំពោះព្រះសង្ឃ ព្រះសង្ឃនោះឯង គួរនឹងទទួលនូវរបស់សម្រាប់ទទួលភ្ញៀវនោះ ព្រោះមនុស្សដែលមកជាភ្ញៀវដទៃស្មើដោយ

www.budinst.gov.kh www.elibraryofcambodia.org

ព្រះសង្ឃនោះមិនមាន ផ្សែកថា ព្រះសង្ឃដែលមកជាភ្ញៀវនោះ រមែងប្រាកដមានតែក្នុងពុទ្ធកាលប៉ុណ្ណោះ មិនមានក្នុងកាលទាំងពួង ហើយលោករមែងប្រកបដោយធម៌ ដែលធ្វើនូវការគួរស្រឡាញ់ គួរគាប់ចិត្តមានសីលគុណជាដើម ដែលមិនសៅហ្មងដាច់ធ្លុះធ្លាយ ព្រោះដូច្នេះ របស់សម្រាប់ទទួលភ្ញៀវនោះ ទើបគួរថ្វាយដល់ព្រះសង្ឃ ព្រះសង្ឃនោះឯង គួរទទួលនូវរបស់សម្រាប់ទទួលភ្ញៀវនោះ ព្រោះហេតុដូច្នេះ ព្រះសង្ឃទើបឈ្មោះថា បាហុនេយ្យោ លោកគួរទទួលនូវរបស់សម្រាប់ទទួលភ្ញៀវ ។ ទក្ខិណេយ្យោ លោកគួរនូវទក្ខិណាទានជាគ្រឿងចំរើនដោយសម្បត្តិ ទានគឺបុគ្គលជឿនូវបរលោក ហើយគប្បីឲ្យឈ្មោះថាទក្ខិណាក្នុងបទនេះ ព្រះសង្ឃលោករមែងគួរនូវទក្ខិណានោះ ៗ មួយទៀត លោករមែងទំនុកបំរុងដល់ទក្ខិណាទាននោះ គឺថាលោករមែងជំរះទក្ខិណាទានរបស់ទាយកឲ្យបរិសុទ្ធបាន ព្រោះធ្វើទក្ខិណាទាននោះឲ្យមានផលច្រើនក្រៃពេក ព្រោះហេតុដូច្នោះ ទើបឈ្មោះថាទក្ខិណេយ្យោ ជាអ្នកគួរនូវទក្ខិណា ។ អញ្ជលិករណីយោ លោកជាបុគ្គលគួរនូវអញ្ជលីកម្ម ក្រពុំហត្ថដែលលោកទាំងពួងដំកល់ទុកលើសិរះហើយធ្វើ សូម្បីយ៉ាងណាប សត្វលោករមិលមើលព្រះសង្ឃដោយចក្ខុប្រកបដោយមេត្តាប៉ុណ្ណោះ ចក្ខុនោះរមែងប្រាសចាកទោសមានទៀនិញាយជាដើមក្នុងអនេកជាតិ អនុត្តរំ បុញ្ញក្ខេត្តំ

www.budinst.gov.kh www.elibraryofcambodia.org

លោកាសស្ស ព្រះសង្ឃជាស្រែបុណ្យ ចំព្រោះពូជ គឺកុសលនៃ
សត្វលោកទាំងពួង មិនមានស្រែដទៃលើសជាង ឬស្មើបាន ដូចជាទី
បណ្តុះព្រោះពូជស្រូវសាលី ឬស្រូវដំណើបនៃក្សេត្រ ឬគាមាត្យ លោក
រមែងហៅថា ស្រែស្រូវសាលី ស្រែស្រូវដំណើប នៃក្សេត្រនិងគាមាត្យ
ដូចម្តេចក្តី ព្រះសង្ឃជាទីពន្លកទីចំរើនបុណ្យនៃលោកទាំងពួងទើបឈ្មោះ
ជាស្រែបុណ្យនៃលោក មិនមានអ្នកណាស្មើលើស ព្រោះបុណ្យកុសល
ដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍និងសេចក្តីសុខ មានប្រការផ្សេងៗនៃ
សត្វលោក រមែងពន្លកល្អចំរើនឡើងក៏ព្រោះតែអាស្រ័យព្រះសង្ឃ ដែល
ជាព្រះសង្ឃជាស្រែបុណ្យ នៃលោកមិនមានស្រែដទៃក្រៃលែងជាងនោះ
ផ្សេងព្រះសង្ឃជាស្រែបរិសុទ្ធប្រាសចាកទោស គឺកិលេសដែលជាគ្រឿង
ប្រទូសរ៉ាយក្នុងសន្តាននៃខ្លួន នឹងមានការបូជានៃលោក ដូចស្រែបរិសុទ្ធ
ប្រាសចាកទោស គឺស្មៅនិងគ្រួសខ្សាច់ ដែលជារបស់ប្រទូសរ៉ាយដល់
សន្ទូង ក៏ឯគុណនៃព្រះសង្ឃ ដែលមានក្នុងបទបាលីទាំងអម្បាលនេះ
សំដែងបង្រួញឲ្យខ្លីក៏មាន ២ ប៉ុណ្ណោះ គឺអត្តហិតៈ គុណចំនុកបំរុងដល់
ខ្លួនឯង ១ បរហិតៈ គុណចំនុកបំរុងដល់អ្នកដទៃ ១ គុណចំនុកបំរុងដល់ខ្លួន
ឯងនោះ បាននឹងបទថា សុបដិបន្នោ ឧជុបដិបន្នោ ញាយ-
បដិបន្នោ សាមីចិបដិបន្នោ ។ ដូច្នេះ គុណចំនុកបំរុងដល់អ្នកដទៃ
នោះ បាននឹងបទដ៏សេស តាំងអំពី អាហុនេយ្យោ ជាដើមទៅ

www.budinst.gov.kh www.elibraryofcambodia.org

ក៏ឯអ្នកដែលរំពឹងដល់គុណនៃព្រះសង្ឃ ទឹងរំពឹងតាមបទគ្រប់ ៩ បទក៏បាន ឬទឹងរំពឹងតែបទណាមួយក៏បាន ឬ ២ បទក៏បាន តែឲ្យដឹងអត្ថាធិប្បាយឲ្យច្បាស់ កុំកាន់យកតែព្យញ្ជនៈ មកទន្ទេញដោយកហាក្ដិចដូច្នេះមិនសម្រេចប្រយោជន៍ណាមួយឡើយ ។

សង្ឃរតនគាថា ចប់

រតនត្តយបទ ចប់

www.budinst.gov.kh www.elibraryofcambodia.org

# វិនយកថា

## អាបត្តិនាមាទិបព្វ

ឥតោ បរំ ទុតិយាទិ បព្វានំ វណ្ណនាកថា

វិនយោ យត្ថ ទេវញ្ញោ សិក្ខិតព្វ វសាធុកំ ។

លំដាប់នេះ នឹងពណ៌នាក្នុងបព្វៈគំរប់ ២ ជាដើម ដែលមានមកក្នុងវណ្ណនាឯណា ដែលជាវិន័យ ១ យ៉ាង មិនមែនជាធម៌ដទៃ កុលបុត្រដែលជាអ្នកមានសេចក្ដីប្រាថ្នាដើម្បីនឹងសិក្សា គប្បីសិក្សាដោយប្រពៃចុះ ។

នឹងពណ៌នាក្នុងអាបត្តិនាមាទិបព្វៈ សំដែងដោយឈ្មោះនៃអាបត្តិជាដើម អាបត្តិទាំងពួងដែលភិក្ខុត្រូវហើយ នឹងលើកឈ្មោះឡើងមុនជា ហើយពោលដោយកងមាន ៧ គឺ បារាជិក ១ សង្ឃាទិសេស ១ ថុល្លច្ច័យ ១ បាចិត្តិយ ១ បាដិទេសនិយៈ ១ ទុក្កដ ១ ទុព្ភាសិត ១ ដោយលំដាប់នៃទោសធ្ងន់ ទោសស្រាលដូច្នេះ ។

## អាបត្តិនាមកថា

អាបត្តិនោះ ប្រែថា ការត្រូវ ការដល់ នូវវីតិក្កមទោស គឺការប្រព្រឹត្តកន្លងសិក្ខាបទ ។ មួយទៀត ប្រែថាធម្មជាតិ គឺភិក្ខុគប្បីត្រូវ គប្បីដល់ ដោយប្រព្រឹត្តអនាចារ ជាការក្រៅបញ្ញត្តិ ។

បារាជិកសព្ទនេះ បើសំឡឹងយកបុគ្គលជាប្រធាន ប្រែថាអ្នកដល់នូវសេចក្ដីចាញ់ បើសំឡឹងយកអាបត្តិជាប្រធាន ប្រែថាអាបត្តិញ៉ាំង

www.budinst.gov.kh www.elibraryofcambodia.org

បុគ្គលឲ្យតាលតាញ់ ដ្បិតអាបត្តិនេះ ភិក្ខុណាត្រូវហើយ ភិក្ខុនោះឈ្មោះថា ជាអ្នកតាលតាញ់ ជាអ្នកចុតិ ឃ្លាតចាកព្រះសទ្ធម្ម ។

សង្ឃាទិសេស ប្រែថាកងនៃអាបត្តិ មានសង្ឃដែលភិក្ខុគប្បីប្រាថ្នា ក្នុងកាលខាងដើម និងកាលដ៏សេស ដ្បិតអាបត្តិកងនេះ ភិក្ខុណាត្រូវហើយ ភិក្ខុនោះត្រូវអាស្រ័យសង្ឃក្នុងកាលខាងដើម គឺឲ្យបរិវាស និងកាលដ៏សេស គឺមូលាយបដិកស្សនៈ ហើយឲ្យមានត្តជាកណ្តាល និងឲ្យអព្ភានកម្ម ក្នុងកាលដ៏សេស ទើបចេញចាកអាបត្តិនោះបាន ។

ថុល្លច្ច័យ ប្រែថាទោសធ្ងន់ ទោសអាក្រក់ ដ្បិតថាបណ្តាអាបត្តិទាំងពួង ដែលភិក្ខុត្រូវហើយ សំដែងក្នុងសំណាក់នៃភិក្ខុដទៃ សូម្បីតែមួយអង្គក៏ធ្លាក់ទៅបាន អាបត្តិកងនេះអាក្រក់ជាងអាបត្តិដែលជាទេសនាគាមិនីទាំងពួង ។

បាចិត្តិយ ប្រែថាអាបត្តិញុំាងកុសលធម៌ឲ្យធ្លាក់ ដ្បិតថាភិក្ខុណាក្លែងត្រូវអាបត្តិកងនេះហើយ ភិក្ខុនោះឈ្មោះថាធ្លាក់ចាកកុសលធម៌ ប្រាសចាកអរិយមគ្គ ដល់នូវមោហដ្ឋាន ទីវង្វេងនៃចិត្ត ។

បាដិទេសនិយៈ ប្រែថាអាបត្តិដែលភិក្ខុគប្បីត្រឡប់សំដែងយ៉ាងដទៃ ដ្បិតអាបត្តិនេះ ភិក្ខុត្រូវហើយមិនបានសំដែងដូចអាបត្តិដទៃ គប្បីត្រឡប់ប្រើបាឡីសំដែងដូច្នេះថា: គារយ្ហំ អាវុសោ ធម្មំ អាបជ្ជឹ អសប្បាយំ បាដិទេសនីយំ តំ បដិទេសេមិ ដូច្នេះ ។

www.budinst.gov.kh www.elibraryofcambodia.org

ទុក្កដ ប្រែថាធ្វើអាក្រក់ ផ្សិតកិច្ចណាត្រូវហើយ កិច្ចនោះឈ្មោះថាធ្វើអាក្រក់ ធ្វើមិនល្អ ធ្វើខុស ចំពោះតែអរិយមគ្គ ដូចពុទ្ធលទ្ធីធ្វាបក្ខ ទីភេលច្ចុទីកំពុង លោកវែមងតិតអធៀលថា ជាមនុស្សធ្វើអាក្រក់ ធ្វើមិនល្អ ធ្វើខុស ។

ទុព្ភាសិត ប្រែថាពោលអាក្រក់ ផ្សិតថាពាក្យណាជាពាក្យអាក្រក់ ជាពាក្យដែលអ្នកប្រាជ្ញតិះដៀល កិច្ចពោលពាក្យនោះទើបត្រូវអាបត្តិនេះ ។

មួយទៀត បារាជិកាបត្តិ ជាអតេកិច្ឆា រក្សាតទៅដោយឧបាយឯណានីមួយមិនបាន ស្មើនឹងកាន់យកភេទគ្រហស្ថ ហើយត្រឡប់មកសូមឧបសម្បទទៀតក៏មិនបាន អាបត្តិក្រៅនោះ ៦ កង ជាសតេកិច្ឆា ល្មមរក្សាតទៅបាន គឺថាត្រូវហើយធ្វើខ្លួនឲ្យបរិសុទ្ធ ដោយវុដ្ឋានវិធីនឹងទេសនាវិធីបាន ។ មួយទៀត បារាជិក សង្ឃាទិសេស ២ នេះ ឈ្មោះថាគរុកាបត្តិ ជាអាបត្តិធ្ងន់ បារាជិកជាអាបត្តិធ្ងន់ដោយទោសជាមូលច្ឆេទ សង្ឃាទិសេសជាអាបត្តិធ្ងន់ដោយទោសផង ដោយវិធីចេញចាកអាបត្តិនោះផង អាបត្តិក្រៅនោះ ៥ កង ឈ្មោះថាលហុកាបត្តិ ជាអាបត្តិស្រាល ដោយវិធីដែលនឹងចេញ ។

មួយទៀត សង្ឃាទិសេសាបត្តិ ឈ្មោះថាវុដ្ឋានគាមិនី ដល់នូវវុដ្ឋានវិធី គឺអាស្រ័យសង្ឃអនុញ្ញាត ឲ្យនូវបរិវាសនឹងមានត្ត ប្រព្រឹត្តកិច្ចទើបរួចចាកទោស ជាមនុស្សបរិសុទ្ធបាន អាបត្តិក្រៅនោះ ៥ កង

www.budinst.gov.kh www.elibraryofcambodia.org

ឈ្មោះថាទេសនាគាមិនី ដល់នូវទេសនាវិធី គឺសំដែងក្នុងសំណាក់នៃភិក្ខុ សូម្បី ១ រូបក៏បរិសុទ្ធបាន ។ មួយទៀត សូម្បីអាបត្តិបារាជិកក៏ឈ្មោះថា ទេសនាគាមិនីដែរ ដ្បិតថាភិក្ខុណាត្រូវហើយ ភិក្ខុនោះប្តេជ្ញាខ្លួនតាមត្រង់ ចំពោះមុខនៃភិក្ខុដទៃ ហើយលះភេទភិក្ខុចេញ កាន់យកភេទគ្រហស្ថ ក៏រួចចាកទោសនោះបាន អាបត្តិនោះមិនជាសគ្គាវរណៈឃាត់ផ្លូវសួគ៌ដល់ អ្នកនោះ ។ មួយទៀត បារាជិក សង្ឃាទិសេស ២ នេះ ឈ្មោះថាទុដ្ឋុល្លាបត្តិ ជាអាបត្តិអាក្រក់ទន់ទាបដោយទោស អាបត្តិ ៥ កងក្រៅនោះ ឈ្មោះថា អទុដ្ឋុល្លាបត្តិ មិនជាអាបត្តិអាក្រក់ ទន់ទាប ដោយទោស ។ មួយទៀត បារាជិក ឈ្មោះថាអនវសេសាបត្តិ ជាអាបត្តិមិនមានសេស ភិក្ខុត្រូវ ហើយក៏ឃ្លាតចាកព្រហ្មចរិយៈដោយពិត អាបត្តិ ៦ កងក្រៅនោះ ឈ្មោះ ថាសាវសេសាបត្តិ ជាអាបត្តិនៅមានសេសសល់ គឺវុដ្ឋានវិធី និងទេស-នាវិធី ជាចំណែកដ៏សេសដែលនឹងឲ្យបរិសុទ្ធបាន ។ មួយទៀត អាបត្តិ បារាជិក សង្ឃាទិសេស ២ នេះ ជាសីលវិបត្តិ ជាទោសធំ ភិក្ខុត្រូវ ហើយឈ្មោះថាដល់នូវសេចក្តីវិបត្តិសីល, ក្នុងអាបត្តិ ៥ កងក្រៅនោះ អាបត្តិណា ដែលភិក្ខុត្រូវហើយមានទោសផង តាំងអាចារៈមារយាទរបស់ សមណៈក៏ខូចទៅផង ដូច្នេះឈ្មោះថាអាចារវិបត្តិ, ក្នុងអាបត្តិ ៥ កងនោះ អាបត្តិណា ដែលភិក្ខុត្រូវដោយទិដ្ឋិសេចក្តីឃើញវិបរិត ជាអន្តគាហិក-ទិដ្ឋិ ដូច្នេះឈ្មោះថា ទិដ្ឋិវិបត្តិ ដូចបាចិត្តិយាបត្តិ នៃភិក្ខុអ្នកពោលបង្កាច់

ព្រះដ៏មានបុណ្យ ដូចក្នុងអាជីវសិក្ខាបទជាតួយ៉ាង, ក្នុងអាបត្តិ ៥ កង នោះ អាបត្តិណា ភិក្ខុត្រូវហើយ អាជីវៈ ការចិញ្ចឹមជីវិតវិនាសទៅ ដូចអាបត្តិព្រោះកុលទូសកកម្ម អាបត្តិនោះឈ្មោះថា អាជីវវិបត្តិ ។ មួយទៀត អាបត្តិបារាជិក សង្ឃាទិសេស ដែលភិក្ខុត្រូវ ព្រោះអាស្រ័យអាជីវៈក៏ឈ្មោះថាអាជីវវិបត្តិដែរ ព្រោះហេតុនោះ ក្នុងគម្ពីរបរិវារៈ លោកលើកយកសិក្ខាបទតាំង ៦ ឡើងដំកល់ទុក ដើម្បីឲ្យឃើញ នូវអាជីវវិបត្តិដូច្នេះថា ភិក្ខុអួតឧត្តរិមនុស្សធម្ម ដែលមិនមានក្នុងខ្លួន ព្រោះហេតុនៃអាជីវៈត្រូវបារាជិក, ភិក្ខុដល់នូវសញ្ចរិត្ត នាំការព្រោះហេតុនៃអាជីវៈត្រូវសង្ឃាទិសេស, ភិក្ខុអួតឧត្តរិមនុស្សធម្មដោយបរិយាយជាដើមថា អ្នកណានៅក្នុងវិហារ អ្នកនោះ ជាព្រះអរហន្តដូច្នេះ ព្រោះហេតុនៃអាជីវៈ អ្នកស្តាប់ដឹងសេចក្តីក្នុងខណៈនោះ ភិក្ខុនោះត្រូវថុល្លច្ច័យ, ភិក្ខុមិនឈឺសូមបណីតភោជន អំពីមនុស្សមិនមែនញាតិធាន់ ព្រោះហេតុនៃអាជីវៈត្រូវបាចិត្តិយ, នាងភិក្ខុនីមិនឈឺ សូមវត្ថុ ៨ ប្រការមានសប្បិជាដើម អំពីមនុស្សមិនមែនញាតិធាន់ ព្រោះហេតុនៃអាជីវៈត្រូវបាដិទេសនិយៈ, ភិក្ខុមិនឈឺ សូមសម្លនិងបាយ អំពីមនុស្សមិនមែនញាតិធាន់ ព្រោះហេតុនៃអាជីវៈត្រូវទុក្កដ ដូច្នេះ ។ ដោយលោកលើកសិក្ខាបទ ៦ ឡើង សំដែងទុកនេះ គប្បីដឹងចុះថា ក្នុងសិក្ខាបទដែលជាសីលវិបត្តិ អាចារវិបត្តិ

www.budinst.gov.kh www.elibraryofcambodia.org

ទិដ្ឋិវិបត្តិនោះ អាបត្តិណា ដែលភិក្ខុត្រូវ ដោយអាស្រ័យអាជីវៈជាហេតុ អាបត្តិនោះ គឺជាអាជីវវិបត្តិដែរ ។

មួយទៀត បាចិត្តិយនោះមាន ២ គឺ និស្សគ្គិយបាចិត្តិយ ១ សុទ្ធិក-បាចិត្តិយ ១ ។ និស្សគ្គិយបាចិត្តិយនោះ ប្រែថាបាចិត្តិយមានកិរិយាលះជាវិនយកម្ម បានដល់បាចិត្តិយាបត្តិ ក្នុងនិស្សគ្គិយុទ្ទេស នៃភិក្ខុបាតិមោក្ខ ៣០ សិក្ខាបទ, នៃភិក្ខុនីបាតិមោក្ខដែលជាអសាធារណៈ ១២ សិក្ខាបទ, ដ្បិតបាចិត្តិយាបត្តិអម្បាលនេះ ភិក្ខុត្រូវព្រោះអាស្រ័យភណ្ឌៈដែលខូចទៅដោយពុទ្ធប្បញ្ញត្តិ ភិក្ខុនោះត្រូវយកភណ្ឌៈនោះមកលះក្នុងទីកណ្ដាលសង្ឃ ឬគណៈ ឬក្នុងសំណាក់នៃភិក្ខុ ១ រូបជាវិនយកម្មសិន ទើបសំដែងអាបត្តិនោះធ្លាក់ ព្រោះហេតុនោះ បាចិត្តិយាបត្តិអម្បាលនេះ ទើបឈ្មោះថានិស្សគ្គិយបាចិត្តិយ ។ សុទ្ធិកបាចិត្តិយនោះ ប្រែថាបាចិត្តិយសុទ្ធ មិនមានវិនយកម្មណាមួយ ជាបុព្វកិច្ចនៃទេសនាវិធី បានដល់បាចិត្តិយា-បត្តិក្នុងបាចិត្តិយុទ្ទេស ក្នុងភិក្ខុបាតិមោក្ខ ៩២ សិក្ខាបទ, ក្នុងភិក្ខុនីបាតិមោក្ខ ដែលជាអសាធារណៈ ៩៦ សិក្ខាបទ, សិក្ខាបទអម្បាលនេះឯង ឈ្មោះថាសុទ្ធិកបាចិត្តិយ ។ មួយទៀត សុទ្ធិកបាចិត្តិយមាន ២ គឺបកតិបាចិត្តិយ បាចិត្តិយ ដោយប្រក្រតី ១ ភេទនកបាចិត្តិយ បាចិត្តិយមានការទំលាយភណ្ឌៈចេញមុនជាដើម ហើយទើបសំដែងអាបត្តិធ្លាក់ ១ ។

អាបត្តិនាមកថា ចប់

www.budinst.gov.kh www.elibraryofcambodia.org

# សិក្ខាបទឧបរិច្ឆេទគាថា

នឹងសំដែងដោយកំណត់សិក្ខាបទនៃអាបត្តិនោះ ៗ ។ សិក្ខាបទនៃបារាជិកាបត្តិ ចំណែកភិក្ខុ ៤ ចំណែកភិក្ខុនីដែលជាអសាធារណៈ មិនទូទៅដល់ភិក្ខុផង ៤ រួមជា ៨ ចំណែកសាធារណៈទូទៅដល់ភិក្ខុ ៤ ទៀត ផ្សំគ្នាទាំងអស់ត្រូវជា ១២ សិក្ខាបទអម្បាលនេះឡើងកាន់បាតិមោក្ខុទ្ទេស ។ សិក្ខាបទនៃសង្ឃាទិសេសាបត្តិ ចំណែកភិក្ខុ ១៣ ចំណែកភិក្ខុនី ដែលជាអសាធារណៈ ១០ រួមជា ២៣ ចំណែកដែលជាសាធារណៈ ៧ ទៀត ផ្សំគ្នាទាំងអស់ត្រូវជា ៣០ សិក្ខាបទនេះ ឡើងកាន់បាតិមោក្ខុទ្ទេស ។ ការបញ្ញត្តិនៃថុល្លច្ចយាបត្តិ មានច្រើនមិនមានកំណត់មិនបានឡើងកាន់បាតិមោក្ខុទ្ទេស ហេតុដែលមិនមានកំណត់នោះ នឹងមានច្បាស់ទៅខាងមុខ ។ សិក្ខាបទនៃនិស្សគ្គិយបាចិត្តិយាបត្តិ ចំណែកភិក្ខុ ៣០ ចំណែកភិក្ខុនីដែលជាអសាធារណៈ ១២ រួមគ្នាទាំងអស់ត្រូវជា ៤២ បើផ្សំសាធារណៈ ១៨ សិក្ខាបទចូលផង ត្រូវជា ៦០ សិក្ខាបទនេះឡើងកាន់បាតិមោក្ខុទ្ទេស ។ សិក្ខាបទនៃសុទ្ធិកបាចិត្តិយាបត្តិ ចំណែកភិក្ខុ ៩២ ចំណែកភិក្ខុនី ដែលជាអសាធារណៈ ៩៦ រួមគ្នាត្រូវជា ១៨៨ បើផ្សំសាធារណៈ ៧០ សិក្ខាបទផង រួមគ្នាត្រូវជា ២៥៨ សិក្ខាបទទាំងនេះឡើងកាន់បាតិមោក្ខុទ្ទេស ។ សិក្ខាបទនៃបាដិទេសនិយាបត្តិ ចំណែកភិក្ខុ ៤ ចំណែកភិក្ខុនី ៨ រួមគ្នាត្រូវជា ១២ ឡើងកាន់បាតិមោក្ខុទ្ទេស ។ ការបញ្ញត្តិនៃទុក្កដាបត្តិ មានច្រើន

www.budinst.gov.kh www.elibraryofcambodia.org

មិនមានកំណត់ ផ្សេងជាទុក្កដាបត្តិ ពោលដោយការគណនយ៉ាងសង្ខេប មាន ២ គឺមកក្នុងបាឡីព្រះពុទ្ធអង្គទ្រង់បញ្ញត្ត ១ យ៉ាង ឈ្មោះថាបាឡិ-ទុក្កដ មកក្នុងអដ្ឋកថា រួចចាកបាឡី ដែលព្រះសង្គីតិកាចារ្យលោកដឹងពុទ្ធាធិប្បាយតាំងទុក ១ យ៉ាង ឈ្មោះថាបាឡិមុត្តកទុក្កដ សេចក្ដីពិស្ដារនឹងមានច្បាស់ទៅខាងមុខ ព្រោះហេតុនោះ សិក្ខាបទនៃទុក្កដាបត្តិទៀងកាន់បាតិមោក្ខុទ្ទេសតែសេខិយសិក្ខាបទប៉ុណ្ណោះ ក្រៅនោះមិនទៀងកាន់បាតិមោក្ខុទ្ទេសទេ ។ សិក្ខាបទនៃទុព្ភាសិតាបត្តិ ដែលមាននិទានខាងដើមតាំងឲ្យព្រះអង្គទ្រង់បញ្ញត្តនោះមិនមាន ផ្សេងទុព្ភាសិតាបត្តិនេះ មានមកក្នុងវិភង្គនៃធម្មសកវសិក្ខាបទ ១ យ៉ាង ព្រោះហេតុនោះ ដល់ទៅខាងមុខកាលវិនិច្ឆ័យធម្មសកវសិក្ខាបទហើយ ទុព្ភាសិតាបត្តិ ក៏នឹងវិនិច្ឆ័យឲ្យបានជំនឹង ៗ មួយទៀត ឧទ្ទេសសំរាប់លើកសិក្ខាបទឡើងសូត្ររាល់ ៗ ថ្ងៃឧបោសថក្នុងកន្លះខែម្ដង ដែលឈ្មោះថាបាតិមោក្ខុទ្ទេសនោះ ដោយឈ្មោះដែលមាននៅក្នុងបាតិមោក្ខមាន ៩ គឺ និទានុទ្ទេស ១ បារាជិកុទ្ទេស ១ សង្ឃាទិសេសុទ្ទេស ១ អនិយតុទ្ទេស ១ និស្សគ្គិយុទ្ទេស ១ បាចិត្តិយុទ្ទេស ១ បាដិទេសនិយុទ្ទេស ១ សេខិយុទ្ទេស ១ សមថុទ្ទេស ១ ។

## និទានុទ្ទេស

ក្នុងនិទានុទ្ទេសខាងដើមនេះ មិនជាឧទ្ទេសសំរាប់បង្អួលឈ្មោះសិក្ខា
១០១០ គ្រាន់តែជាពាក្យប្រកាសញត្តិនៃឧបោសថកម្មនិងប្រកាសពាក្យ

www.budinst.gov.kh www.elibraryofcambodia.org

ដែលជានិទានខាងដើមនៃឧទ្ទេសដទៃប៉ុណ្ណោះ ៗ ពាក្យថា "សុណាតុ មេ ។ល។ បាតិមោក្ខំ ឧទ្ទិសេយ្យ" នេះឈ្មោះថាញត្តិ ប្រែថាបពិត្រព្រះសង្ឃដ៏ចំរើន ព្រះសង្ឃចូរស្ដាប់ខ្ញុំ ថ្ងៃនេះជាថ្ងៃឧបោសថទី ១៤-១៥ ជាបើឧបោសថកម្ម មានកាលដ៏សមគួរ គឺប្រកបដោយអង្គ៤ ហើយ ព្រះសង្ឃគប្បីធ្វើឧបោសថ គប្បីសំដែងព្រះបាតិមោក្ខ ។ អង្គ៤ នោះគឺថ្ងៃទី ១៤-១៥ ថ្ងៃសាមគ្គី ថ្ងៃទាំង៣នេះ ថ្ងៃណាមួយ ចាត់ជាអង្គ១ ភិក្ខុតាំងអំពី៤រូបឡើងទៅ មិនត្រូវឧក្ខេបនីយកម្ម ជាបកតត្ត បិតនៅក្នុងសីមាជាមួយគ្នា មិនលះហត្ថបាសគ្នាជាអង្គ១ ភិក្ខុទាំងនោះ មិនត្រូវសភាគាបត្តិ មានវត្ថុស្មើគ្នា មានឆាន់ភោជនក្នុងវេលារសៀលដូចគ្នាជាដើមជាអង្គ១ វជ្ជនីយបុគ្គល ២១ មានគ្រហស្ថនិងបណ្ឌកជាដើម មិនមានខាងក្នុងហត្ថបាសសង្ឃជាអង្គ១ ឧបោសថប្រកបដោយអង្គ៤នេះ ទើបគួរពោលថា បត្តកល្លំ ថាមានកាលដ៏សមគួរបាន បើមិនប្រកបដោយអង្គ៤ បានតែអង្គ២ ឬអង្គ៣ មិនគួរពោលថា បត្តកល្លំ ។ មួយទៀត បើភិក្ខុអ្នកសំដែងនោះទូជានព្រះសង្ឃមួយរូបក្តី ឲ្យសូត្រថា កន្តេ បើចាស់ជាងព្រះសង្ឃទាំងអស់ ឲ្យសូត្រថា អាវុសោ បើថ្ងៃទី១៥ ឲ្យសូត្រថា បណ្ណរសោ បើថ្ងៃទី១៤ ឲ្យសូត្រថា ចាតុទ្ទសោ... តាំ សុំយស្ស ។ល។ ផាសុ ហោតិ ពាក្យទាំងនេះ ឈ្មោះថានិទាន ជាពាក្យសួរពាក្យប្រាប់អ្នកស្ដាប់បាតិ-

www.budinst.gov.kh www.elibraryofcambodia.org

មោក្ខ សេចក្តីនេះដូចម្តេច បុព្វករណៈ បុព្វកិច្ច កម្មដែលត្រូវធ្វើមុន
សង្ឃធ្វើហើយឬ គឺបោសរោងឧបោសថ ១ បើវេលាយប់អុចប្រទីប ១
ក្រាលអាសនៈ ១ ដាក់ទឹកប្រើ ទឹកឆាន់ ១ បួននេះឈ្មោះថាបុព្វករណៈ
ព្រោះគួរធ្វើមុនប្រជុំសង្ឃ ការនាំឆន្ទៈនៃភិក្ខុដែលគួរនាំឆន្ទៈមក ១ នាំ
បរិសុទ្ធិនៃភិក្ខុដែលគួរនាំបរិសុទ្ធិ ១ ប្រាប់រដូវ ១ រាប់ភិក្ខុ ១ ឲ្យឱវាទដល់
ភិក្ខុនី ១ ប្រាំនេះឈ្មោះថាបុព្វកិច្ច ព្រោះត្រូវធ្វើមុនសំដែងបាតិមោក្ខ
បុព្វករណៈ បុព្វកិច្ចទាំង ៩ នេះ សង្ឃធ្វើហើយ ឬ តាំងអំពីបាឡីថា
បារិសុទ្ធិំ ទៅ ជាពាក្យប្រែថា សេចក្តីថា បពិត្រលោកដ៏មានអាយុ
លោកទាំងឡាយ ចូរប្រាប់នូវសេចក្តីបរិសុទ្ធិរបស់ខ្លួនចុះ ខ្ញុំព្រះករុណា
នឹងសំដែងនូវបាតិមោក្ខ យើងគ្រប់គ្នាចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃ
នូវបាតិមោក្ខនេះចុះ ។ តពីនេះទៅ ជាដំណើរដែលត្រូវប្រកាស
សេចក្តីបរិសុទ្ធិ និងមិនបរិសុទ្ធិរបស់ខ្លួន យស្ស សិយា ។ល។
វេទិស្សាមិ សេចក្តីថាបើអាបត្តិនៃភិក្ខុណាទៅមាន ភិក្ខុនោះគប្បីធ្វើឲ្យ
ច្បាស់ ប្រាប់កណ្តាលជំនុំសង្ឃ ឬភិក្ខុ ១ រូបដែលអង្គុយនៅជិត ថាខ្ញុំត្រូវ
អាបត្តិឈ្មោះនោះ ៗ ខ្ញុំក្រោកអំពីទីនេះហើយ នឹងសំដែងនូវអាបត្តិនោះ ៗ
ថាបើសង្ស័យឲ្យប្រាប់ដូច្នេះថាខ្ញុំសង្ស័យក្នុងអាបត្តិឈ្មោះនេះ ៗ កាលណា
ខ្ញុំមិនសង្ស័យ ខ្ញុំនឹងសំដែងនូវអាបត្តិក្នុងកាលនោះ កាលបើអាបត្តិមិនមាន
គប្បីស្ងៀម អាការដែលប្រាប់អាបត្តិដោយស្ងៀមយ៉ាងដូច្នេះ ឈ្មោះ

www.budinst.gov.kh www.elibraryofcambodia.org

ចាំប្រាប់នូវសភាពនៃខ្លួនបរិសុទ្ធ ខ្ញុំនឹងដឹងច្បាស់នូវលោកទាំងឡាយ
ជាអ្នកបរិសុទ្ធដោយការស្ងៀមយ៉ាងនេះ ឯពាក្យថា យថា ខោ
។ល។ ហោតិ នេះ ជាពាក្យប្រាប់ឲ្យដឹងច្បាស់ នូវអនុសាវនៈនឹង
ខេត្រនៃអាបត្តិ សេចក្តីថា ដូចភិក្ខុ១រូបតែភិក្ខុ១រូបសួរចំពោះខ្លួន នឹង
ពោលដោះសារដូចម្តេច ពាក្យដែលយើងឲ្យឮហើយរឿយៗ ក្នុងភិក្ខុ
បរិស័ទមានសភាពដូច្នេះ លុះដល់៣ដងថា តតិយម្បិ បុច្ឆាមិ
កច្ចិត្ថ បរិសុទ្ធា ដូច្នេះគ្រប់ៗខ្សែទៅ ដូច្នោះ បើភិក្ខុរូបណា
កាលខ្ញុំសួរ ឲ្យបានឮអស់វារៈ៣ដងថា តតិយម្បិ បុច្ឆាមិ
កច្ចិត្ថ បរិសុទ្ធា ដូច្នេះ បើរឭកឃើញហើយ មិនបានធ្វើឲ្យច្បាស់
មិនប្រាប់នូវអាបត្តិដែលខ្លួនមាននោះ សម្បជានមុសាវាទ ការពោល
មិនពិតនៃអ្នកដឹង រមែងមានដល់ភិក្ខុនោះ គឺភិក្ខុនោះ ត្រូវអាបត្តិទុក្កដ
ព្រោះខ្លួនបិទអាបត្តិទុក ទើបកាត់ជាសម្បជានមុសាវាទ បពិត្រលោកដ៏
មានអាយុទាំងឡាយ ឯសម្បជានមុសាវាទទុក្កដនេះ ព្រះដ៏មានបុណ្យ
ព្រះអង្គទ្រង់បានសំដែងហើយ ថាជាធម៌ធ្វើឲ្យអន្តរាយដល់ឈាននឹងមគ្គ
ផល ព្រោះហេតុនោះ ភិក្ខុកាលរឭកឃើញនូវអាបត្តិដែលមាន គប្បី
ធ្វើឲ្យច្បាស់ ដ្បិតថាការធ្វើឲ្យច្បាស់នេះ រមែងនាំមកនូវសេចក្តីសុខ
ដល់ភិក្ខុនោះ ។

និទានុទ្ទេស ចប់

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងបារាជិកុទ្ទេស ចំណែកភិក្ខុមានសិក្ខាបទ ៤ ចំណែកភិក្ខុនីមានសិក្ខាបទ ៨ ក្នុងសង្ឃាទិសេសុទ្ទេស ចំណែកភិក្ខុមានសិក្ខាបទ ១៣ ចំណែកភិក្ខុនីមានសិក្ខាបទ ១៧ ក្នុងអនិយតុទ្ទេស មានសិក្ខាបទ ២ អនិយតុទ្ទេសនេះ ក្នុងភិក្ខុនីបាតិមោក្ខមិនមាន ក្នុងនិស្សគ្គិយុទ្ទេស ចំណែកភិក្ខុមានសិក្ខាបទ ៣០ ចំណែកភិក្ខុនីក៏មាន ៣០ ដែរ ក្នុងបាចិត្តិយុទ្ទេស ចំណែកភិក្ខុមានសិក្ខាបទ ៩២ ចំណែកភិក្ខុនីមាន ១៦៦ ក្នុងបាដិទេសនិយុទ្ទេស ចំណែកភិក្ខុមានសិក្ខាបទ ៤ ចំណែកភិក្ខុនីមាន ៨ ក្នុងសេខិយុទ្ទេស ភិក្ខុនិងភិក្ខុនីមានសិក្ខាបទ ៧៥ ដូចគ្នា ក្នុងសមថុទ្ទេស មិនមានសិក្ខាបទ មានតែធម៌ ៧ ប្រការ មានសម្មុខាវិន័យជាដើម ឈ្មោះថាសមថៈ ព្រោះជារបស់សំរាប់រម្ងាប់អធិករណៈ ៤ មានវិវាទាធិករណៈជាដើមប៉ុណ្ណោះ សំដែងមកក្នុងបាតិមោក្ខុទ្ទេស ចំណែកភិក្ខុមាន ៩ ឧទ្ទេស ចំណែកភិក្ខុនីមាន ៨ ឧទ្ទេស សំដែងតាមឈ្មោះដែលមានទៅក្នុងបាលីបាតិមោក្ខ បើសំដែងតាមពុទ្ធបញ្ញត្តិមាន ៥ គឺនិទានុទ្ទេសទី ១ បារាជិកុទ្ទេសទី ២ សង្ឃាទិសេសុទ្ទេសទី ៣ អនិយតុទ្ទេសទី ៤ តាំងអំពីនិស្សគ្គិយុទ្ទេស ដរាបដល់សមថុទ្ទេសជាទី ៥ ឈ្មោះវិត្ថារុទ្ទេស ជា ៥ ឧទ្ទេសដូច្នេះ ទ្រង់បញ្ញត្តតាំង ៥ ឧទ្ទេសនេះ ដើម្បីនឹងឲ្យដឹងច្បាស់នូវបាតិមោក្ខ ដោយសង្ខេបនឹងពិស្តារ ក្នុងវេលាដែលមានអន្តរាយ សេចក្តីនេះនឹងដឹងច្បាស់ក្នុងឧបោសថកថាខាងមុខ ។

ឧទ្ទេស ចប់

www.budinst.gov.kh www.elibraryofcambodia.org

មួយទៀត ក្នុងបុព្វសិក្ខាសំដែងសចិត្តកៈ និងវជ្ជៈទុក ក្នុងកថានេះ នោះនឹងលើកទុកសិន នឹងទុកសំដែងក្នុងសមុដ្ឋានកថាខាងមុខ ។

សិក្ខាបទបរិច្ឆេទកថា ចប់

---

## សមុដ្ឋានាទិកថា

នឹងសំដែងក្នុងវិធីមានសមុដ្ឋានជាដើម សមុដ្ឋានៈ នោះ ប្រែថា ទីកើតនៃអាបត្តិ ក្នុងសិក្ខាបទនោះៗ ក៏ឯសមុដ្ឋានទីកើតនៃអាបត្តិ ក្នុងសិក្ខាបទទាំងពួងនោះមាន ៦ គឺកាយជាទី ១ វាចាជាទី ២ កាយវាចាជាទី ៣ កាយចិត្តជាទី ៤ វាចាចិត្តជាទី ៥ កាយវាចាចិត្តជាទី ៦ រួមគ្នាត្រូវជា ៦ ។ កាយ ១ យ៉ាង ឬ វាចា ១ យ៉ាង ជាសមុដ្ឋានទីកើត ១ ដូច្នេះឈ្មោះថាមានអង្គ ១ កាយនឹងវាចា កាយនឹងចិត្ត ឬ វាចានឹងចិត្ត ជាសមុដ្ឋានទីកើត ១ ដូច្នេះឈ្មោះថាមានអង្គ ២ ។ ទាំងកាយទាំងវាចាទាំងចិត្ត ជាសមុដ្ឋានទីកើត ១ ដូច្នេះឈ្មោះថាមានអង្គ ៣ បីខាងដើមគឺ កាយ ១ វាចា ១ កាយវាចា ១ នេះឈ្មោះថា អចិត្តកសមុដ្ឋាន ព្រោះមិនមានចិត្ត អាបត្តិក្នុងសិក្ខាបទណា ត្រូវដោយសមុដ្ឋានទាំង ៣ នេះណាមួយ សិក្ខាបទនោះជាអចិត្តកៈ ៗ បីខាងចុង គឺកាយចិត្ត ១ វាចាចិត្ត ១ កាយវាចាចិត្ត ១ នេះឈ្មោះថាសចិត្តកសមុដ្ឋាន ប្រកបដោយចិត្ត អាបត្តិក្នុងសិក្ខាបទណាត្រូវដោយសមុដ្ឋានទាំង ៣ នេះណាមួយ មិនមានសមុដ្ឋានខាងដើមលាយផងទេ សិក្ខាបទនោះ ជាសចិត្តកៈ ៗ

www.budinst.gov.kh www.elibraryofcambodia.org

អាបត្តិទាំងពួង ក៏ត្រូវដោយសមុដ្ឋានទីកើត ១ ខ្លះ ២ ខ្លះ ៣ ខ្លះ ៤ ខ្លះ ៦ ខ្លះ ។ អាបត្តិក្នុងសិក្ខាបទណា ត្រូវដោយសមុដ្ឋានទី ៤ តែម្យ៉ាង ដូចក្នុងបឋមបារាជិក, ត្រូវដោយសមុដ្ឋានទី ៥ តែម្យ៉ាង ដូចក្នុងធម្មទេសនាសិក្ខាបទ, ត្រូវដោយសមុដ្ឋានទី ៦ តែម្យ៉ាង ដូចក្នុងសង្ឃភេទសិក្ខាបទ, សិក្ខាបទទាំង៣នេះ ឈ្មោះថាមានសមុដ្ឋានទីកើត ១ ។ អាបត្តិក្នុងសិក្ខាបទណា ក៏ត្រូវដោយសមុដ្ឋានទី ១ ឬ ទី ៤ ដូចក្នុងឯឡកលោមសិក្ខាបទក្តី ត្រូវដោយសមុដ្ឋានទី ២ ឬ ទី ៥ ដូចក្នុងបទសោធម្មសិក្ខាបទក្តី ត្រូវដោយសមុដ្ឋានទី ៣ ឬ ទី ៦ ដូចក្នុងបឋមកឋិនសិក្ខាបទក្តី ត្រូវដោយសមុដ្ឋានទី ៤ ឬ ទី ៦ ដូចក្នុងថេយ្យសត្ថសិក្ខាបទក្តី ត្រូវដោយសមុដ្ឋានទី ៥ ឬ ទី ៦ ដូចក្នុងចោរីវុដ្ឋាបនសិក្ខាបទក្តី សិក្ខាបទទាំង៥នេះ ឈ្មោះថាមានសមុដ្ឋានទីកើត ២ ។ អាបត្តិក្នុងសិក្ខាបទណា ត្រូវដោយសមុដ្ឋានខាងដើមគឺទី ១ ទី ២ ឬ ទី ៣ ដូចភូតារោចនសិក្ខាបទក្តី ត្រូវដោយសមុដ្ឋានខាងចុងគឺទី ៤ ទី ៥ ឬ ទី ៦ ដូចក្នុងអទ្ធានសិក្ខាបទក្តី សិក្ខាបទទាំង ២ នេះ ឈ្មោះថាមានសមុដ្ឋានទីកើត ៣ ។ អាបត្តិក្នុងសិក្ខាបទណា ត្រូវដោយសមុដ្ឋានទី ១ ទី ៣ ទី ៤ ឬ ទី ៦ ដូចក្នុងទ្ធានសិក្ខាបទក្តី ត្រូវដោយសមុដ្ឋានទី ២ ទី ៣ ទី ៥ ឬ ទី ៦ ដូចក្នុងអននុញ្ញាតសិក្ខាបទក្តី សិក្ខាបទទាំង ២ នេះ ឈ្មោះថាមានសមុដ្ឋានទីកើត ៤ ។ អាបត្តិក្នុងសិក្ខាបទណា ត្រូវដោយសមុដ្ឋាន ៦ គឺទី ១ ទី ២

ទី ៣ ទី ៤ ទី ៥ ឬ ទី ៦ ដូចក្នុងសញ្ចរិត្តសិក្ខាបទ សិក្ខាបទនេះ ឈ្មោះថាមានសមុដ្ឋានទីកើត ៦ ។

អាបត្តិទាំងពួង ពោលដោយសមុដ្ឋានមាន ១៣ អាបត្តិទាំង ១៣ នោះ មានឈ្មោះទាំង ១៣ ដោយសមុដ្ឋាន តាមសិក្ខាបទដែលជាបឋមបញ្ញត្តិដូច្នេះថា បឋមបារាជិកសមុដ្ឋាន អទិន្នាទានសមុដ្ឋាន សញ្ចរិត្តសមុដ្ឋាន សមនុភាសនសមុដ្ឋាន បឋមកឋិនសមុដ្ឋាន ឯឡកលោមសមុដ្ឋាន បទសោធម្មសមុដ្ឋាន អទ្ធានសមុដ្ឋាន ថេយ្យសត្ថសមុដ្ឋាន ធម្មទេសនាសមុដ្ឋាន ភូតារោចនសមុដ្ឋាន ចោរីវុដ្ឋាបនសមុដ្ឋាន អននុញ្ញាតសមុដ្ឋាន ជា ១៣ ដូច្នេះ ។

អាបត្តិក្នុងសិក្ខាបទណា កើតអំពី កាយនិងចិត្ត សិក្ខាបទនោះ ឈ្មោះថា បឋមបារាជិកសមុដ្ឋាន ។

អាបត្តិក្នុងសិក្ខាបទណា កើតអំពីសចិត្តកសមុដ្ឋាន ៣ ខាងចុង សិក្ខាបទនោះឈ្មោះថា អទិន្នាទានសមុដ្ឋាន ។

អាបត្តិក្នុងសិក្ខាបទណា កើតអំពី សមុដ្ឋានទាំង ៦ សិក្ខាបទនោះ ឈ្មោះថា សញ្ចរិត្តសមុដ្ឋាន ។

អាបត្តិក្នុងសិក្ខាបទណា កើតអំពីសមុដ្ឋានទី ៦ តែ ១ សិក្ខាបទ នោះ ឈ្មោះថា សមនុភាសនសមុដ្ឋាន ។

www.budinst.gov.kh www.elibraryofcambodia.org

អាបត្តិក្នុងសិក្ខាបទណា កើតអំពីសមុដ្ឋានទី ៣ នឹងទី ៦ សិក្ខាបទនោះ ឈ្មោះថា បឋមកឋិនសមុដ្ឋាន ។

អាបត្តិក្នុងសិក្ខាបទណា កើតអំពីសមុដ្ឋានទី ១ នឹងទី ៤ សិក្ខាបទនោះ ឈ្មោះថា ឯឡកលោមសមុដ្ឋាន ។

អាបត្តិក្នុងសិក្ខាបទណា កើតអំពីសមុដ្ឋានទី ២ នឹងទី ៥ សិក្ខាបទនោះ ឈ្មោះថា បទសោធម្មសមុដ្ឋាន ។

អាបត្តិក្នុងសិក្ខាបទណា កើតអំពីសមុដ្ឋានទី ១ ទី ៣ ទី ៤ នឹងទី ៦ សិក្ខាបទនោះ ឈ្មោះថា អទ្ធានសមុដ្ឋាន ។

អាបត្តិក្នុងសិក្ខាបទណា កើតអំពីសមុដ្ឋានទី ៤ នឹងទី ៦ សិក្ខាបទនោះ ឈ្មោះថា ថេយ្យសត្ថសមុដ្ឋាន ។

អាបត្តិក្នុងសិក្ខាបទណា កើតអំពីសមុដ្ឋានទី ៥ តែ ១ សិក្ខាបទនោះ ឈ្មោះថា ធម្មទេសនាសមុដ្ឋាន ។

អាបត្តិក្នុងសិក្ខាបទណា កើតអំពីអចិត្តកសមុដ្ឋាន ៣ ខាងដើម សិក្ខាបទនោះឈ្មោះថា ភូតារោចនសមុដ្ឋាន ។

អាបត្តិក្នុងសិក្ខាបទណា កើតអំពីសមុដ្ឋានទី ៥ នឹងទី ៦ សិក្ខាបទនោះ ឈ្មោះថា ចោរីវុដ្ឋាបនសមុដ្ឋាន ជាមានសមុដ្ឋានដូចចោរីវុដ្ឋាបន-សិក្ខាបទនៃនាងភិក្ខុនី ។

អាបត្តិក្នុងសិក្ខាបទណា កើតអំពីសមុដ្ឋាន ទី ២ ទី ៣ ទី ៥ នឹង

www.budinst.gov.kh www.elibraryofcambodia.org

ទី ៦ សិក្ខាបទនោះ ឈ្មោះថា អននុញ្ញាតសមុដ្ឋាន ជាមានសមុដ្ឋានដូចអននុញ្ញាតសិក្ខាបទនៃនាងភិក្ខុនី គ្រប់ជា ១៣ សិក្ខាបទដូច្នេះ ។

ឯពាក្យថា វិធីមានសមុដ្ឋានជាដើមនោះ សង្គ្រោះយក កិរិយា សញ្ញា ចិត្ត វជ្ជៈ កម្ម អង្គៈ អាណត្តិ ផង ។

គឺឯអាបត្តិក្នុងសិក្ខាបទទាំងពួង ពោលដោយកិរិយាមាន ៥ គឺ កិរិយា ១ អកិរិយា ១ កិរិយាកិរិយា ១ សិយា កិរិយា សិយា អកិរិយា ១ សិយា កិរិយា សិយា កិរិយាកិរិយា ១ ជា ៥ ដូច្នេះ ។

អាបត្តិក្នុងសិក្ខាបទណា កើតដល់ភិក្ខុដែលធ្វើ នូវសេចក្តីប្រព្រឹត្តិកន្លងដោយកាយ ឬវាចា ដូចក្នុងបឋវីខណនសិក្ខាបទជាដើម សិក្ខាបទនោះ ឈ្មោះថា កិរិយា គឺកើតព្រោះធ្វើ ។

អាបត្តិក្នុងសិក្ខាបទណា កើតដល់ភិក្ខុដែលមិនធ្វើ នូវកម្មជាដើមដែលខ្លួនគប្បីធ្វើដោយកាយនឹងវាចា ដូចក្នុងបឋមកឋិនសិក្ខាបទ មិនធ្វើវិកប្បនឹងអធិដ្ឋាន ទុកអតិរេក ចីវរឲ្យកន្លង ១០ ថ្ងៃទៅដូច្នេះ សិក្ខាបទនោះ ឈ្មោះថា អកិរិយា គឺកើតព្រោះមិនធ្វើ ។

អាបត្តិក្នុងសិក្ខាបទណា ត្រូវដល់ភិក្ខុដែលធ្វើផង នឹងមិនធ្វើផង ដូចក្នុងចីវរប្បដិគ្គហណសិក្ខាបទ ធ្វើនូវការទទួលចីវរអំពីដៃនាងភិក្ខុនីមិនមែនញាតិ មិនធ្វើនូវការផ្លាស់ប្តូរជាមុនទើបត្រូវអាបត្តិ សិក្ខាបទនេះ ឈ្មោះថា កិរិយាកិរិយា កើតព្រោះធ្វើនឹងមិនធ្វើ ។

www.budinst.gov.kh www.elibraryofcambodia.org

អាបត្តិក្នុងសិក្ខាបទណា កើតដល់ភិក្ខុដែលធ្វើក៏មាន ដែលមិនធ្វើក៏មាន ដូចក្នុងរូបិយប្បដិគ្គហណសិក្ខាបទ ត្រូវដោយធ្វើនូវការទទួលរូបិយៈក៏មាន ត្រូវដោយមិនធ្វើនូវការហាមឃាត់រូបិយដែលគេឲ្យដល់ខ្លួនក៏មាន សិក្ខាបទនេះ ឈ្មោះថា សិយា កិរិយា សិយា អកិរិយា កើតព្រោះធ្វើក៏មាន ព្រោះមិនធ្វើក៏មាន ។

អាបត្តិក្នុងសិក្ខាបទណា កើតដល់ភិក្ខុដែលធ្វើខ្លះក៏មាន ធ្វើផងមិនធ្វើក៏មាន ដូចក្នុងកុដិការសិក្ខាបទ មានកាលត្រូវអាបត្តិដោយឲ្យសង្ឃសំដែងទីហើយ ធ្វើកុដិឲ្យលើសប្រមាណ មានកាលត្រូវអាបត្តិដោយមិនឲ្យសង្ឃសំដែងទីមុន នឹងធ្វើឲ្យលើសប្រមាណ សិក្ខាបទនេះ ឈ្មោះថា សិយា កិរិយា សិយា កិរិយាកិរិយា មានកាលកើតព្រោះធ្វើខ្លះក៏មាន ព្រោះធ្វើផងមិនធ្វើក៏មាន ។

មួយទៀត សិក្ខាបទទាំងពួង ពោលដោយសញ្ញាមាន ២ គឺសញ្ញា-វិមោក្ខ ១ នោសញ្ញាវិមោក្ខ ១ ។ ក្នុងសិក្ខាបទណារួចចាកអាបត្តិបាន ដោយសំគាល់នឹងមិនកន្លងបញ្ញត្តិ ដូចទឹកមានតួសត្វសំគាល់ថា មិនមាន ហើយបរិភោគ មិនត្រូវអាបត្តិ សិក្ខាបទនេះឈ្មោះថា សញ្ញាវិមោក្ខ ។ ក្នុងសិក្ខាបទណាមិនរួចចាកអាបត្តិបានដោយសំគាល់ ដូចថ្ងៃរសៀល ហើយសំគាល់ថានៅមិនទាន់រសៀល ហើយឆាន់របស់ដែលជាយាវ-កាលិកក៏ត្រូវអាបត្តិ សិក្ខាបទនោះឈ្មោះថា នោសញ្ញាវិមោក្ខ ។

www.budinst.gov.kh www.elibraryofcambodia.org

មួយទៀត សិក្ខាបទទាំងពួង ពោលដោយចិត្តមាន ២ គឺសចិត្តកៈ ១ អចិត្តកៈ ១ ។ អាបត្តិក្នុងសិក្ខាបទណា កើតដោយសចិត្តកសមុដ្ឋាន ៣ ខាងចុង គឺកាយចិត្ត វាចាចិត្ត ទីងកាយវាចាចិត្តតែមួយ មិនលាយដោយអចិត្តកសមុដ្ឋានណាមួយ សិក្ខាបទនេះឈ្មោះថា សចិត្តកៈ ។ អាបត្តិក្នុងសិក្ខាបទណា កើតដោយអចិត្តកសមុដ្ឋាន ៣ ខាងដើម គឺកាយ ទីងវាចា ទីងកាយវាចាតែ ១ យ៉ាងក្តី ឬឯណានីមួយ ជាសមុដ្ឋាន ១ ទីងមានសចិត្តកសមុដ្ឋានណាមួយមកលាយផងក្តី សិក្ខាបទដូច្នេះឈ្មោះថា អចិត្តកៈ ។ សិក្ខាបទណាជាសញ្ញាវិមោក្ខ សិក្ខាបទនោះជា សចិត្តក ។ សិក្ខាបទណាជានោសញ្ញាវិមោក្ខ សិក្ខាបទនោះជា អចិត្តកៈ ។

មួយទៀត សិក្ខាបទទាំងពួង ពោលដោយវជ្ជៈ គឺទោសមាន ២ គឺលោកវជ្ជៈ ១ បណ្ណត្តិវជ្ជៈ ១ ។ អាបត្តិក្នុងសិក្ខាបទណា សូម្បីជាអចិត្តកៈ ដូចសុរាបានសិក្ខាបទជាដើម ចិត្តក្នុងខណៈដែលត្រូវ ក្នុងចំណែកខាងសចិត្តកៈ គឺមានចិត្តដឹងនោះ ជាអកុសលចិត្ត ដូចសុរាបានសិក្ខាបទជាអចិត្តកៈ សូម្បីភិក្ខុមិនដឹងថាសុរា ឲ្យកន្លងបំពង់កចូលទៅក៏ត្រូវអាបត្តិ តែក្នុងចំណែកចិត្តដែលដឹងថាជាសុរាហើយឲ្យកន្លងបំពង់កចូលទៅ ក៏ត្រូវអាបត្តិនោះជាអកុសលចិត្ត ចំណែកលោកមូល សិក្ខាបទនេះឈ្មោះថា លោកវជ្ជៈ ជាមានទោស គឺអ្នកប្រាជ្ញគប្បីរៀរ គប្បីតិះដៀលក្នុងលោក ដែលថាមានចិត្តដឹងនោះប្រាថ្នាយកដីងក្តែលទីងគប្បីសេព ដូចដឹងថា

សុរាជាដើម ហើយក្រេបផឹកដោយលោភចិត្ត មិនប្រាថ្នាយកចិត្តដឹងបញ្ញត្តិ គឺដឹងថាមិនគួរ បើដឹងថាមិនគួរហើយពុះពារអាជ្ញាព្រះពុទ្ធអង្គ ប្រព្រឹត្តកន្លងសិក្ខាបទដោយចិត្តណា ចិត្តនោះជាបដិឃចិត្ត ចំណែកទោសមូល ព្រោះហេតុនោះសុរាបានសិក្ខាបទ និងឧយ្យុត្តសិក្ខាបទ និងឧយ្យោធិកសិក្ខាបទ ទាំងនេះទើបជាអចិត្តកលោកវជ្ជៈ ។ ក៏ឯចិត្តដែលដឹងវត្ថុនៃអាបត្តិ ក្នុងសិក្ខាបទណា សូម្បីជាកុសលក៏មាន សិក្ខាបទនោះឈ្មោះថាបណ្ណត្តិវជ្ជៈ ថាមានទោសគឺអ្នកប្រាជ្ញគប្បីវៀរដោយពុទ្ធបញ្ញត្តិ ។

មួយទៀត សិក្ខាបទទាំងពួង ពោលដោយកម្មមាន ៣ គឺ កាយកម្មក៏មាន វចីកម្មក៏មាន ទាំងកាយកម្មវចីកម្មក៏មាន ។

អាបត្តិក្នុងសិក្ខាបទណា ភិក្ខុត្រូវដោយកាយទ្វារ ១ ចំពូក ដូចអាបត្តិកើតអំពីសមុដ្ឋានទី ១ ឬទី ៤ សិក្ខាបទនោះឈ្មោះថា កាយកម្ម ។ អាបត្តិក្នុងសិក្ខាបទណាភិក្ខុត្រូវដោយវចីទ្វារ ១ ចំពូក ដូចអាបត្តិកើតអំពីសមុដ្ឋានទី ២ និងទី ៥ សិក្ខាបទនោះ ឈ្មោះថា វចីកម្ម ។ អាបត្តិក្នុងសិក្ខាបទណាភិក្ខុត្រូវដោយទ្វារទាំង ២ គឺកាយនិងវាចា សិក្ខាបទនោះឈ្មោះថា កាយកម្ម វចីកម្ម ថាជាកាយកម្មផង ថាជាវចីកម្មផង ។

មួយទៀត តិក្កៈមាន ២ គឺកុសលតិក្កៈ ៣ ពួក កំណត់ដោយកុសលចិត្ត ១ យ៉ាង វេទនាតិក្កៈ ៣ ពួក កំណត់ដោយវេទនា ១ យ៉ាង ។

ភិក្ខុកាលនឹងត្រូវអាបត្តិមានចិត្តជាកុសលត្រូវក៏មាន មានចិត្តជា

www.budinst.gov.kh www.elibraryofcambodia.org

អកុសលត្រូវក៏មាន មានចិត្តជាអព្យាក្រឹត គឺមិនជាកុសល នឹងអកុសល ដូចជាផលកត្រូវក៏មាន ។ មួយទៀត ដោយទុក្ខវេទនាត្រូវអាបត្តិក៏មាន ដោយសុខវេទនាត្រូវអាបត្តិក៏មាន ដោយឧបេក្ខាវេទនាត្រូវអាបត្តិក៏មានដូច្នេះ ។ សិក្ខាបទណាបើពោលថា ឯកចិត្តំ ជាមានចិត្តតែ ១ ឲ្យគប្បីដឹងថាបាននឹងអកុសលចិត្ត, ក្នុងសិក្ខាបទណាបើពោលថា ទ្វិចិត្តំ ជាមានចិត្ត ២ ឲ្យគប្បីដឹងថាបាននឹង

កុសលនឹងអព្យាក្រឹត, ក្នុងសិក្ខាបទណាដែលពោលថា តិ

ចិត្ត ៣ ឲ្យគប្បីដឹងថាបានដល់ចិត្តជាកុសលអកុសលនឹងអព្យាក្រឹត ។

ក្នុងសិក្ខាបទណាដែលពោលថា ឯកា វេទនា ជាមានវេទនា ១ ឲ្យគប្បីដឹងថាបានដល់ទុក្ខវេទនា, បើពោលថា ទ្វេ វេទនា ជាមានវេទនា ២ ឲ្យគប្បីដឹងថាបានដល់សុខវេទនានឹងឧបេក្ខាវេទនា, បើពោលថា តិស្សោ វេទនា ជាមានវេទនា ៣ ឲ្យគប្បីដឹងថាបាននឹងសុខ ទុក្ខ ឧបេក្ខា ។

មួយទៀត សិក្ខាបទទាំងពួង ជាសាណត្តិកៈក៏មាន ជាអនាណត្តិកៈក៏មាន ។ អាបត្តិក្នុងសិក្ខាបទណា ភិក្ខុធ្វើឯងក៏ត្រូវ ប្រើអ្នកដទៃឲ្យធ្វើក៏ត្រូវ សិក្ខាបទនោះឈ្មោះថាសាណត្តិកៈ ជាប្រកបដោយបង្គាប់ ។ អាបត្តិក្នុងសិក្ខាបទណា ភិក្ខុធ្វើឯងទើបត្រូវ ប្រើអ្នកដទៃឲ្យធ្វើមិនត្រូវ សិក្ខាបទនោះឈ្មោះថាអនាណត្តិកៈ ជាមិនប្រកបដោយបង្គាប់ ។ ឯសមុដ្ឋានវិធីជា

www.budinst.gov.kh www.elibraryofcambodia.org

ដើមដូចពោលមកនេះ ទ្រង់ប្រកបក្នុងសិក្ខាបទដែលទ្រង់ពោលទៅខាងមុខនោះ ទុកជារបស់សំរាប់កាត់អាបត្តិក្នុងសិក្ខាបទនោះៗ ដើម្បីកើតសេចក្ដីឈ្លាសវាងវៃសង្កេតកំណត់អាបត្តិក្នុងសិក្ខាបទនោះៗ ។

សមុដ្ឋានាទិកថា ចប់

LIBRARY BUDDHIST INSTITUTE

## អាការៈដែលភិក្ខុនឹងត្រូវអាបត្តិ

អាការៈដែលភិក្ខុនឹងត្រូវអាបត្តិមាន ៦ យ៉ាង គឺ អលជ្ជិតា ត្រូវដោយសេចក្ដីមិនអៀនខ្មាសនឹងបាប ១ អញ្ញាណតា ត្រូវដោយមិនដឹងបញ្ញត្តិ ១ កុក្កុច្ចបកតតា ត្រូវដោយសេចក្ដីរង្កៀសសង្ស័យហើយធ្វើ ១ អកប្បិយេ កប្បិយសញ្ញិតា ត្រូវដោយសេចក្ដីសំគាល់ថាគួរក្នុងវត្ថុដែលមិនគួរ ១ កប្បិយេ អកប្បិយសញ្ញិតា ត្រូវដោយសេចក្ដីសំគាល់ថាមិនគួរក្នុងវត្ថុដែលគួរ ១ សតិសម្មោសា ត្រូវដោយភ្លេចស្មារតី ១ ត្រូវជា ៦ ប្រការដូច្នេះ ។

ត្រូវដោយសេចក្ដីមិនអៀនខ្មាសនឹងបាបនោះដូចម្ដេច? ភិក្ខុដែលជាអលជ្ជីមិនអៀនខ្មាសនឹងបាប លុះដោយអគតិទាំង ៤ គឺឆន្ទាគតិ ទោសាគតិ មោហាគតិ ភយាគតិ ញាំញីក្នុងសិក្ខាបទតូចធំ មិនខ្លាចបាបដូច្នេះ ឈ្មោះថាត្រូវអាបត្តិដោយមិនខ្លាចបាប ។

ត្រូវដោយមិនដឹងបញ្ញត្តិនោះដូចម្ដេច ? ភិក្ខុជាមនុស្សល្ងង់មិនដឹងថា

www.budinst.gov.kh www.elibraryofcambodia.org

វត្ថុនេះគួរធ្វើ វត្ថុនេះមិនគួរធ្វើ វត្ថុណាមិនគួរធ្វើក៏ធ្វើវត្ថុនោះ វត្ថុអ្វីគួរធ្វើ ក៏ធ្វើឲ្យខុសៗទៅ ខុសពាក្យធម៌វិន័យឲ្យកើតអាបត្តិ ឬមិនដឹងសិក្ខាបទបញ្ញត្តិនៃព្រះដ៏មានបុណ្យ ក៏ធ្វើកន្លងព្រះបញ្ញត្តិ ដូច្នេះឈ្មោះថាត្រូវដោយសេចក្តីមិនដឹងបញ្ញត្តិ ។

ត្រូវដោយសេចក្តីសង្ស័យដូចម្តេច ? ភិក្ខុមានសេចក្តីសង្ស័យគួរសួរវិន័យធរឲ្យកាត់សេចក្តីជាមុន សឹមធ្វើ មិនដូច្នោះក៏ធ្វើដោយអំពើចិត្តខ្លួន ដោយសេចក្តីសង្ស័យក៏ត្រូវអាបត្តិ ។ ការសង្ស័យៈហើយធ្វើនោះ បើវត្ថុដែលមិនគួរ ក៏ត្រូវអាបត្តិគ្រប់ៗសិក្ខាបទ តែវត្ថុណាគួរជាសង្ឃាទិសេស ថុល្លច្ច័យ បាចិត្តិយនិងទុក្កដ ក៏ត្រូវអាបត្តិតាមវត្ថុនោះ ។ បើវត្ថុដែលគួរ ក៏គង់ត្រូវអាបត្តិទុក្កដ ព្រោះការសង្ស័យ ដូច្នេះឈ្មោះថាត្រូវដោយសេចក្តីសង្ស័យ ។

ត្រូវដោយសេចក្តីសំគាល់ថាគួរ ក្នុងវត្ថុដែលមិនគួរដូចម្តេច ? ភិក្ខុសំគាល់ក្នុងសាច់ដែលជាអកប្បិយ គឺសាច់ខ្លាឃ្មុំនិងសាច់ខ្លាធំ ប្រហែលនិងសាច់ជ្រូកនិងសាច់គោ សំគាល់ថាសាច់ជ្រូកសាច់គោជាកប្បិយគួរឆាន់ ក៏ឆាន់លេបចូលទៅត្រូវអាបត្តិ ឬភោជនជាអកប្បិយមិនគួរឆាន់ សំគាល់ថាកប្បិយគួរឆាន់ ហើយឆាន់លេបចូលទៅក៏ត្រូវអាបត្តិ ឬរសៀល ហើយសំគាល់ថានៅព្រឹក ឆាន់អាហារដែលជាយាវកាលិក ក៏ត្រូវអាបត្តិ ដូច្នេះឈ្មោះថាត្រូវដោយសេចក្តីសំគាល់ថា គួរក្នុងវត្ថុដែលមិនគួរ ។

www.budinst.gov.kh www.elibraryofcambodia.org

ត្រូវដោយសេចក្ដីសំគាល់ថាមិនគួរ ក្នុងវត្ថុដែលគួរនោះដូចម្ដេច ? ភិក្ខុសំគាល់ក្នុងសាច់ដែលគួរ គឺសាច់ជ្រូកឬសាច់គោ ថាសាច់ខ្លាឃ្មុំ ឬសាច់ខ្លាធំជាអកប្បិយមិនគួរឆាន់ ហើយឆាន់លេបចូលទៅ ក៏ត្រូវអាបត្តិ ឬភោជនជាកប្បិយគួរឆាន់ សំគាល់ថាជាអកប្បិយមិនគួរឆាន់ ហើយឆាន់លេបចូលទៅ ក៏ត្រូវអាបត្តិ ឬវេលានៅព្រឹក សំគាល់ថាវេលាល្ងាចរសៀល ហើយឆាន់យាវកាលិកចូលទៅ ក៏ត្រូវអាបត្តិ ដូច្នេះឈ្មោះថាត្រូវដោយសេចក្ដីសំគាលថាមិនគួរក្នុងវត្ថុដែលគួរ ។

ត្រូវដោយវង្វេងស្មារតីនោះដូចម្ដេច ? ភិក្ខុដេកក្នុងទីប្រក់ប៉ាំងជាមួយនឹងអនុបសម្បន្ន គ្រប់ ៣ រាត្រីហើយ លុះដល់រាត្រីជាគំរប់ ៤ ហើយភ្លេចស្មារតីទៅដេករួមក្នុងទីប្រក់ប៉ាំងទៀត ក៏ត្រូវអាបត្តិ ឬ ភ្លេចទៅប្រាសចាកត្រៃចីវរណាមួយក្នុង ១ រាត្រី ក៏ត្រូវអាបត្តិ ឬ ទទួលប្រគេនភេសជ្ជៈទុកឲ្យកន្លង៧ថ្ងៃទៅ ក៏ត្រូវអាបត្តិ ឬ ទទួលអតិរេកចីវរទុកក្នុងមិនបានអធិដ្ឋាន វិកប្ប ឲ្យកន្លង ១០ ថ្ងៃទៅ សំពត់នោះជានិស្សគ្គិយនត្រូវបាចិត្តិយ ដូច្នេះឈ្មោះថាត្រូវដោយវង្វេងស្មារតី ។

ចប់ អាការៈដែលភិក្ខុនឹងត្រូវអាបត្តិ ៦ យ៉ាងតែប៉ុណ្ណោះ

អាបត្តិតាមវិបត្តិគំរប់ពីរ ចប់

www.budinst.gov.kh www.elibraryofcambodia.org

# បដិបត្តិមុខបទ

បដិបត្តិមុខបទៈ គឺបទ ពោលអំពីសិក្ខាបទ ដែលជាផ្លូវនៃសេចក្តីបដិបត្តិដោយច្រើន ក៏ឯគន្ថបុព្វសិក្ខានៃបទៈនេះ តាំងអំពីសិក្ខាបទនៃបារាជិកាបត្តិ ដរាបដល់សិក្ខាបទនៃទុក្កដាបត្តិ បានញែកទុកជា ២ ចំណែក គឺសចិត្តកៈ ១ អចិត្តកៈ ១ ដើម្បីឱ្យដឹងងាយ ត្បិតបុព្វសិក្ខានោះជាពាក្យសង្ខេបណាស់ ឯបុព្វសិក្ខាវណ្ណនានេះ មិនបានសំដែងតាមលំដាប់គន្ថបុព្វសិក្ខានោះទេ ខ្ញុំសំដែងតាមលំដាប់សិក្ខាបទដែលមានមកក្នុងបាតិមោក្ខុទ្ទេស លើកទុកតែបញ្ញត្តិនៃថុល្លច្ចយាបត្តិខ្ញុំបញ្ញត្តិនៃទុក្កដាបត្តិ ដែលមិនបានឡើងកាន់បាតិមោក្ខុទ្ទេស បណ្តាសិក្ខាបទដែលមានមកក្នុងបាតិមោក្ខុទ្ទេសនោះ សិក្ខាបទដែល ផ្លូវនៃសេចក្តីបដិបត្តិដែលលើកឡើងពោលក្នុងបុព្វសិក្ខាក្តី ដែលមិនបានលើកឡើងពោលក្នុងបុព្វសិក្ខាក្តី ខ្ញុំពោលដោយពិស្តារបន្តិចតាមគួរ ហើយពណ៌នាតាមបាលីខ្លះ តាមអដ្ឋកថាឈ្មោះកង្ខាវិតរណីខ្លះ ខ្ញុំពោលអត្ថនិងវិធីមានសមុដ្ឋានជាដើមផង ខ្ញុំពោលសិក្ខាបទដែលមិនជាផ្លូវនៃសេចក្តីបដិបត្តិផង តែខ្ញុំពោលដោយសង្ខេប ល្មមឱ្យដឹងសេចក្តីតាមបទមាតិកា ខ្ញុំមិនប្រកបអត្ថនិងវិធីមានសមុដ្ឋានជាដើមផង កាលបើដូច្នេះ ក៏ខ្ញុំបានសមតាមពាក្យដែលពោលថា បដិបត្តិមុខបទៈ ក៏ឯសេចក្តីបញ្ញត្តិ

www.budinst.gov.kh www.elibraryofcambodia.org

ផលមិនមានមកក្នុងបាតិមោក្ខ នឹងពោលដោយសង្ខេបខ្លះ ដោយពិស្តារ តាមគម្ពីរសមន្តបាសាទិកាខ្លះ តាមគម្ពីរដទៃខ្លះ ។

## បារាជិកុទ្ទេស

នឹងពណ៌នាក្នុងបារាជិកសិក្ខាបទនោះមុន គឺឯបារាជិកសិក្ខាបទនៃភិក្ខុ មាន ៤ គឺ មេថុន១ អទិន្នាទាន១ មនុស្សវិគ្គហៈ១ ឧត្តរិមនុស្សធម្ម១ ។

មេថុនសិក្ខាបទជាបឋមនោះ សេចក្តីថា ភិក្ខុណាមួយជាអ្នកដល់ព្រមហើយដោយអធិសីលសិក្ខា នឹងសិក្ខាបទជាទីចិញ្ចឹមជីវិត ជាមួយភិក្ខុទាំងឡាយ ហើយមិនបានពោលលាខ្លួនសិក្ខា មិនធ្វើឲ្យប្រាកដខ្លួនភាព ជាមនុស្សទុព្វល មិនប្តេជ្ញាខ្លួនជាគ្រហស្ថមុន ហើយសេពមេថុន ដោយហោចទៅសូម្បីតែសត្វតិរច្ឆាន ភិក្ខុនោះត្រូវបារាជិកមិនមានសង្វាស ជាមួយនឹងភិក្ខុដទៃ ។ ពាក្យថាភិក្ខុនោះ គឺកុលបុត្តអ្នកបានអរិយសម្មតិ ដ៏មានតមកអំពីព្រះពុទ្ធអង្គ ជាសម្មតិសំរាប់គ្រប់គ្រងបាតិមោក្ខសំវរសីល ជារបស់ធំ គឺសង្ឃព្រមព្រៀងគ្នាឲ្យឧបសម្បទ ដោយញត្តិចតុត្ថកម្មវាចា មិនកំរើក គឺព្រមដោយវត្ថុសម្បត្តិ ញត្តិសម្បត្តិ អនុសាវនសម្បត្តិ សីមាសម្បត្តិ បរិសសម្បត្តិ ដ៏គួរដល់ហេតុជាទីតាំងដូច្នេះឯង ឈ្មោះថាភិក្ខុ ភិក្ខុប្រែថាអ្នកសូម គឺថាបានក្តី មិនបានក្តី សូមតាមលំអានព្រះអរិយៈ ឈរត្រឹមទៀងស្ងៀមដណ្តប់ជាបរិមណ្ឌល បិទត្រៃបរ ចំពោះមុខផ្ទះនៃត្រកូលជាសំគាល់ មិនស្រែកសូមដោយវាចា ។

www.budinst.gov.kh www.elibraryofcambodia.org

ពាក្យថា ណាមួយនោះ គឺថា ខ្ពស់ ទាប ស ខ្មៅ ណា ៗ ក្តី ប្រកបការងារដូចម្តេចក្តី មានជាតិ មាននាម មានគោត្រ មានប្រក្រតី មានវិហារធម៌ មានគោចរដូចម្តេចក្តី ជាថេរៈ ឬ ភិក្ខុថ្មី ឬ ភិក្ខុកណ្តាលក្តី មិនកំណត់ បើសេពមេថុន ត្រូវបារាជិកគ្រប់រូប ។

ពាក្យថា មិនពោលលានូវសិក្ខា ទាំងមិនធ្វើឲ្យច្បាស់ នូវភាពជាមនុស្សទុព្វលនោះ គឺមិនបានលានូវសិក្ខាបទ ព្រមដោយចិត្ត ទាំងខេត្រ ទាំងកាល ទាំងប្រយោគ ទាំងបុគ្គល ទាំងព្រមដោយវិជានន: គឺសេចក្តីដឹងខ្លួន ឯព្រមដោយចិត្តនោះ គឺគិតចង់ឃ្លាតចាកភាពជាឧបសម្បន្ន ហើយពោលពាក្យលាសិក្ខា មិនពោលលេង មិនពោលភ្លាំងភ្លាត់ ទើបឈ្មោះថាលាសិក្ខាបទមួយយ៉ាង, ក៏ឯខេត្រនោះមានច្រើនដល់ ២២ បទ ទាំងពោលតែបទដែលគួរនឹងប្រើ ពោលថា សិក្ខំ បច្ចក្ខាមិ ខ្ញុំពោលលានូវសិក្ខាក្តី វិនយំ បច្ចក្ខាមិ ខ្ញុំពោលលានូវវិន័យក្តី ទាំងពោលថា គិហីតិ មំ ធារេហិ លោកចូរចាំទុកនូវខ្ញុំថាជាគ្រហស្ថក្តី ឧបាសកោតិ មំ ធារេហិ លោកចូរចាំទុកនូវខ្ញុំថាជាឧបាសកក្តី ពោលតាមបទដូច្នេះ មិនពោលតាមបទដទៃដូចថា រុក្ខំ បច្ចក្ខាមិ ជាដើម ដូច្នេះ ឈ្មោះថាលាសិក្ខាព្រមដោយខេត្រ, ព្រមដោយកាលនោះ គឺពោលពាក្យលាដោយ វត្តមានកាល[1]ថា បច្ចក្ខាមិ ខ្ញុំពោលលា ធារេហិ លោកចូរចាំទុកក្តី ពោលដោយពាក្យមិនអាស្រ័យកាលដូចថា

១ – វត្តមានកាល គឺបច្ចុប្បន្នកាលដែលកំពុងប្រព្រឹត្តទៅ ។

www.budinst.gov.kh www.elibraryofcambodia.org

អលំ មេ សិក្ខាយ មិនគួរទៀតដោយសិក្ខាដល់ខ្ញុំដូច្នេះជាដើមក្តី មិនពោលដោយពាក្យជាអតីតកាលថា បច្ចក្ខាសិ ខ្ញុំពោលលាហើយ ជានេសិ លោកចាំទុកហើយក្តី មិនពោលដោយអនាគតកាលថា បច្ចក្ខិស្សំ ខ្ញុំនឹងពោលលា ជានេស្សសិ លោកនឹងចាំទុកក្តី មិនពោលដោយពាក្យជាបរិកប្បថា បច្ចក្ខេយ្យំ ខ្ញុំគប្បីពោលលាក្តី ដូច្នេះឈ្មោះថាលាសិក្ខាព្រមដោយកាល, ក៏ឯព្រមដោយប្រយោគនោះ គឺប្រយោគនៃកាយដែលពោលបញ្ចេញថា ខ្ញុំពោលលានូវសិក្ខាជាដើម ពោលដោយភាសាណា ៗ មិនកំណត់ តែមិនលាដោយកាយប្រយោគ មានសរសេរសំបុត្រលាជាដើម ដូច្នេះឈ្មោះថា លាសិក្ខាព្រមដោយប្រយោគ, ព្រមដោយបុគ្គលនោះ គឺអ្នកលាសិក្ខាមិនជាមនុស្សឆ្កួត មិនជាមនុស្សមានចិត្តអណ្តែតអណ្តូង មិនជាមនុស្សឈឺ គឺទុក្ខវេទនាជន់គ្របសង្កត់ ជាមនុស្សប្រក្រតីល្អ អ្នកស្តាប់ពាក្យលាសោតក៏ជាមនុស្សជាតិ មិនជាតិរច្ឆាន មិនជាទេវតា មិនជាមនុស្សឆ្កួត មិនជាមនុស្សមានចិត្តអណ្តែតអណ្តូង មិនជាមនុស្សឈឺ គឺទុក្ខវេទនាជន់គ្របសង្កត់ ជាមនុស្សនៅចំពោះមុខ មិនត្រូវប្រាប់ដោយទូតនឹងសំបុត្រ ដូច្នេះឈ្មោះថាព្រមដោយបុគ្គល, ព្រមដោយសេចក្តីដឹងនោះ គឺអ្នកលាសិក្ខានិយមចំពោះអ្នកណា អ្នកនោះបានឮបានដឹងសេចក្តីក្នុងខណៈនោះ មិនទុកទៅយូរហើយទើបដឹងដូច្នេះក្តី បើមិននិយមបុគ្គលហើយលាសិក្ខា

www.budinst.gov.kh www.elibraryofcambodia.org

ចំពោះមុខមនុស្សច្រើនផងគ្នា ក្នុងមនុស្សទាំងអំបាលនោះ មនុស្សណាមួយដឹងសេចក្តីក្នុងខណៈនោះក្តី ដូច្នេះទើបឈ្មោះថាព្រមដោយសេចក្តីដឹង ភិក្ខុលាសិក្ខាព្រមដោយចិត្តជាដើម ដូចពោលមកនេះឯង ទើបឈ្មោះថាលាសិក្ខា បើមិនព្រមមិនឈ្មោះថាលាសិក្ខា ។

គឺឯសេពមេថុននោះ គឺឲ្យនិមិត្តរបស់ខ្លួន សូម្បីតិចតួចប្តុំដោយវត្ថុណាមួយក្តី ឲ្យចូលទៅក្នុងវច្ចមគ្គទ្វារធ្ងន់ បស្សាវមគ្គៈទ្វារស្រាល មុខមគ្គៈទ្វារមាត់ ទ្វារណាមួយនៃអ្នកដទៃដែលមិនស្លាប់ ឬ ស្លាប់ហើយ ឯទ្វារមគ្គនោះនឹងត្រាប់សសាប់ដោយវត្ថុណាមួយក្តី មិនត្រាប់មិនសសាប់ក្តី ជាទ្វារគឺសត្វមិនពាន់កកេរដោយច្រើន ឲ្យគន្ធឹងចំងទឹកចំសើម គឺខ្យល់ប្រក្រតីមិនពាល់ត្រូវ សូម្បីប៉ុនសំដីល្ង ១ ឬប៉ុនចុងសក់ ដោយចិត្តត្រេកអរក្តី ឬ អ្នកដទៃកំហែងសង្កត់សង្កិនក្នុងនិមិត្តខ្លួន ហើយត្រេកអរក្នុងកាលទាំង ៤ គឺកាលដែលអង្គជាតកំពុងចូលទៅក្តី ដែលចូលស៊ប់ទៅហើយក្តី ដែលកំពុងឋិតនៅក្តី ដែលដកថយចេញក្តី ណាមួយ ឬ អង្គជាតនៃខ្លួនដែលឲ្យចូលទៅក្នុងទ្វារធ្ងន់នៃខ្លួនឯងក្តី ឬ ខ្ទង់ទន់ខ្នងចុះបៀមអង្គជាតនៃខ្លួន ដោយសេចក្តីត្រេកអរក្តី អាការដែលពោលមកទាំងអំបាលនេះ ឈ្មោះថាសេពមេថុន ភិក្ខុសេពមេថុនដូច្នេះ ត្រូវបារាជិក មិនមានសង្វាស គឺរួមសង្ឃកម្មគួបចំជាមួយនឹងភិក្ខុដទៃគេទៅមិនបាន ។

www.budinst.gov.kh www.elibraryofcambodia.org

ក៏ឯវែទក្រទ្វារដែលនឹងត្រូវបារាជិកនោះគឺស្រីមនុស្ស ស្រីអមនុស្ស តិរច្ឆានញី មានទ្វារ ៣ គឺទ្វារធ្ងន់ ទ្វារស្រាល ទ្វារមាត់ មួយពួកៗ មានទ្វារ ៣ៗ ត្រូវជា ៩, ឧភតោព្យញ្ជនក មនុស្សមានភេទស្រី ភេទប្រុសទាំង ២ យ៉ាង ដែលជាមនុស្ស ជាអមនុស្ស ជាតិរច្ឆានញី ក៏មានទ្វារ ៣ៗ ត្រូវជា ១៨, មនុស្សប្រុស អមនុស្សប្រុស តិរច្ឆានឈ្មោល មានទ្វារ ២ គឺទ្វារធ្ងន់នឹងទ្វារមាត់ មួយពួកៗ មានទ្វារ ២ៗ ត្រូវជា ៦, មនុស្សបណ្ឌក អមនុស្សបណ្ឌក តិរច្ឆានបណ្ឌក មានទ្វារ ២ៗ ត្រូវជា ៦, រួមជា ១២ ផ្សំទាំងអស់ត្រូវជាទ្វារមគ្គ ៣០ ឲ្យកើតអាបត្តិបារាជិក ៗ

ក៏ឯការកំណត់សត្វតិរច្ឆាននោះដូច្នេះ សត្វមិនមានជើងបាននឹងទីឃជាតិមានពស់ថ្លាន់នឹងពស់ផ្ទុះជាដើម ឯជាតិសត្វទឹកមានត្រី នឹងអណ្តើកនឹងកង្កែបជាដើម ដែលមានទ្វារមគ្គទាំង ៣ ណាមួយ ល្មមឲ្យអង្គជាតិចូលទៅបាន សូម្បីប៉ុនសំដីល្ងនឹងប៉ុនចុងសក់ ១ អំបាលនេះជាវត្ថុនៃបារាជិក តូចចុះទៅជាងនោះជាវត្ថុនៃទុក្កដ សត្វទ្វិបាទជើង ២ បាននឹងក្អែក មាន់ ព្រាប ជាដើម សត្វចតុប្បាទជើង ៤ បាននឹងឆ្មា នឹងកំប្រុក កណ្ដុរ ស្ការ ត្រកួត ជាដើម ទាំងអំបាលនេះជាសត្វតូចឲ្យគប្បីដឹងថាជាវត្ថុនៃបារាជិកនឹងទុក្កដដូចពោលហើយក្នុងមុន ៗ

កិត្តឲ្យផ្តុត ឬ ពកដែលដុះទៀនក្នុងអង្គជាតិនៃខ្លួនមានកាយប្រសាទ

www.budinst.gov.kh www.elibraryofcambodia.org

នៅមិនទាន់ស្លាប់នៅដឹងសម្ផស្សឲ្យចូលទៅក្នុងទ្វារមគ្គទាំង ៣០ ដូច ពោលហើយណាមួយ សូម្បីទ្វារនោះមានស្បែកនឹងសាច់ជាដើមរបើក ទៅអស់ហើយគ្រាន់តែសណ្ឋាននៃនិមិត្តមាននៅប្រាកដប៉ុណ្ណោះដូច្នេះ កាលមានចិត្តគិតថានឹងសេព ហើយសេពក៏ត្រូវបារាជិក ភិក្ខុឲ្យកេម ឬផ្លូក ឬពកដែលកើតក្នុងអង្គជាតិខ្លួន មានកាយប្រសាទវិនាសហើយ មិនដឹងសម្ផស្ស ឲ្យចូលទៅក្នុងទ្វារមគ្គដូចពោលហើយនោះ ត្រូវ ទុក្កដ បើទ្វារមគ្គនោះរបើកទៅអស់ហើយ សូម្បីគ្រាន់តែសណ្ឋាននៃ និមិត្តក៏មិនសល់ ភិក្ខុព្យាយាមក្នុងទីដូច្នេះ សន្និបថាជាដំបៅ ត្រូវ ថុល្លច្ច័យ ទ្វារភ្នែក ទ្វារច្រមុះ ទ្វារត្រចៀក នឹងស្រោមនៃក្បាល សសាល់ គឺនិមិត្តនឹងដំបៅដែលធ្វើដោយសស្ត្រាក្នុងកាយនៃមនុស្ស អំបាលនេះក្តី ឯស្រោមនៃសសាល់ នឹង ខ្នងច្រមុះនៃសត្វតិរច្ឆានធំ មានដំរីនឹងសេះជាដើមក្តី ឯនិមិត្តនៃមនុស្សស្លាប់តាំងអំពីសត្វកកេរពាក់ កណ្តាល នៅមិនទាន់ហើមប៉ោងឡើងក្តី នឹងអណ្តាត ឬ ធ្មេញដែល ចេញមកក្រៅបបូរមាត់ក្តី អំបាលនេះជាខេត្រជាវត្ថុនៃអាបត្តិថុល្លច្ច័យ ទ្វារភ្នែក ទ្វារច្រមុះ នឹងដំបៅក្នុងកាយសត្វតិរច្ឆានក្តី នឹងនិមិត្តដ៏តូច នៃសត្វតិរច្ឆានមានពស់នឹងត្រីជាដើម ដែលមិនល្មមប្រមាណនៃអង្គជាតិ ដំណើរចូលទៅបានក្តី នឹងសរីរាវយវៈដ៏សេសមានក្លៀកជាដើមនៃមនុស្ស នឹងតិរច្ឆានក្តី នឹងនិមិត្តក្នុងសាកសពដែលហើមឡើងក្តី នឹងដុំសាច់

www.budinst.gov.kh www.elibraryofcambodia.org

ដែលលេះធ្លាក់ចុះអំពីនិមិត្តក្តី អំបាលនេះជាទីទ្រជាវត្ថុនៃអាបត្តិទុក្កដ ភិក្ខុសន្ទត់អត្ថជាតិចូលទៅក្នុងមាត់សាកសពដែលហា មិនឲ្យទង្គិចខាងក្រោម ឬខាងទាំង ៤ នោះត្រូវទុក្កដ ពោលមកនេះជាប្រភេទនៃអាបត្តិ ។

ឯវិធីដែលមិនត្រូវអាបត្តិក្នុងសិក្ខាបទនេះ គឺភិក្ខុមិនដឹង ឬមិនត្រេកអរ ឬឆ្កួត មានចិត្តអណ្តែតអណ្តាន ឬមានវេទនាគ្របសង្កត់ ឬភិក្ខុជាអាទិកម្មិកៈអ្នកដើមបញ្ញត្តិ អំបាលនេះមិនត្រូវអាបត្តិ ។ ភិក្ខុផ្តេកលក់ អ្នកដទៃមកលបផ្តើមផ្តុំក្នុងនិមិត្តខ្លួន ភិក្ខុនោះមិនដឹងខ្លួន ឈ្មោះថាមិនដឹង មិនត្រូវអាបត្តិ ភិក្ខុណាសូម្បីដឹងតែមិនត្រេកអរ ឈ្មោះថាមិនត្រេកអរ មិនត្រូវអាបត្តិ ។

ភិក្ខុឆ្កួតកក់ខ្លាំងដោយពុះពោរនៃប្រមាត់ ឬមានគេធ្វើឲ្យចិត្តអណ្តែតអណ្តាន ឈ្មោះថាជាមនុស្សមានចិត្តអណ្តែតអណ្តាន ២ ចំពូកនេះ ដែលមិនដឹងមិនមានស្មារតីឃើញភ្លើង ឬមាស ឬលាមក ឬខ្ទឹមចន្ទន៍ក៏ដូចគ្នា ដូច្នេះជាប្រមាណក្នុងវិធីដែលមិនត្រូវអាបត្តិ ។ ភិក្ខុណាមិនដឹងអ្វីសោះ ព្រោះសោចសល់ទៅដោយទុក្ខវេទនាដ៏ខ្លាំង ដូច្នេះឈ្មោះថា គឺទុក្ខវេទនាគ្របសង្កត់មិនត្រូវអាបត្តិ ភិក្ខុណាជាដើមហេតុ ដែលឲ្យព្រះមានព្រះភាគបញ្ញត្តិសិក្ខាបទនោះ ដូចសុទិន្នភិក្ខុ ទៅសេពមេថុនធម្មមុនភិក្ខុដទៃដូច្នេះ ឈ្មោះថាអាទិកម្មិកៈអ្នកដើមបញ្ញត្តិ មិនត្រូវអាបត្តិ ពោលមកនេះឈ្មោះថាពោលដោយអនាបត្តិ ។

www.budinst.gov.kh www.elibraryofcambodia.org

មួយទៀតសិក្ខាបទនេះជាអនាណត្តិកៈ ព្រោះមិនត្រូវបារាជិកដោយ
បង្គាប់អ្នកដទៃឲ្យសេពមេថុនអ្នកដទៃ គឺប៉ុន្តែជាបង្គាប់ ឬញុះកិក្តុងគ្នាឲ្យ
សេពមេថុនសូម្បីមិនត្រូវបារាជិកក៏មែន តែគង់មិនរួចទុក្កដាបត្តិ ព្រោះជា
អកប្បិយសមាចារ មានអង្គ ២ គឺ សេវនចិត្តំ ចិត្តគិតនឹងសេពមេថុន ១
មគ្គេន មគ្គបដិបាទនំ ញុំាងអង្គជាតិឲ្យចូលទៅក្នុងទ្វារមគ្គពាល់
ត្រូវក្នុងទីណាមួយជាអង្គ ១ បើព្រមដោយអង្គ ២ ដូច្នេះទើបត្រូវបារាជិ-
កាបត្តិ បើមិនព្រមក៏មិនត្រូវ សិក្ខាបទនេះមានសមុដ្ឋាន ១ ឈ្មោះជា
បឋមបារាជិកសមុដ្ឋាន គឺកើតអំពីកាយនឹងចិត្តជាសមុដ្ឋាន ១ ជាកិរិយា
ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាលោកវជ្ជៈ ជាកាយកម្ម ជាអកុសល-
ចិត្ត ជាទ្វិវេទនា មានវេទនា ២ គឺសុខនឹងឧបេក្ខា ។

បឋមបារាជិកៈ ចប់

អទិន្នាទានសិក្ខាបទទីពីរ សេចក្តីថាភិក្ខុណាលួចឯង ឬ ប្រើ
គេឲ្យលួចនូវទ្រព្យដែលមានជីវិតនឹងមិនមានជីវិត មានតម្លៃអំពី ១ បាទ
ឡើងទៅដោយបាទក្នុងមគធៈប្រទេស ដែលតាំងនៅក្នុងស្រុកឬក្នុងព្រៃ
និងក្នុងទឹកឬលើគោក ក្នុងអាកាសឬទីណាមួយក្តី ដែលមានម្ចាស់របស់
គេហួងហែង ដោយថេយ្យចិត្ត ដោយអាការនៃកិរិយាលួចផ្សេង ១ គឺ
ប្លន់ចូល ចំបាំង បំបាត់ប្រវាញ់ ផ្លាស់ប្តូរ ឥ ដណ្តើម កំហែង
សង្កត់សង្កិន ទោះត្រូវដៃពេលណាមួយក្តី ភិក្ខុនោះត្រូវបារាជិក ។

វ៉ែលថា ១ បាទនោះ ក្នុងបាលីថា ៥ មាសកជា ១ បាទ ក្នុងនគររាជគ្រឹះ ដោយបាលីថា. តេន ខោ បន សមយេន រាជគហេ បញ្ចមាសកោ បាទោ ហោតិ ក្នុងអដ្ឋកថាថា ២០ មាសកជា ១ កហាបណៈ ក្នុងនគររាជគ្រឹះ ក្នុងកាលនោះ, ព្រោះហេតុនោះ ៥ មាសកទើបជា ១ បាទ ដោយលក្ខណៈនោះគប្បីដឹងចុះថាចំណែកគំរប់ ៤ នៃកហាបណៈជាមួយបាទ ក្នុងជនបទទាំងពួង, ក៏ឯចំណែកគំរប់ ៤ នៃកហាបណៈនោះគប្បីដឹងដោយអំណាចនៃបុរាណនីលកហាបណៈមិនមែនកហាបណៈដទៃមានរុទ្រទាមកកហាបណៈជាដើម សូម្បីព្រះពុទ្ធជាអម្ចាស់ទាំងឡាយ ក្នុងអតីតនិងអនាគត ព្រះអង្គក៏បញ្ញត្តទុតិយបារាជិកដោយបាទចំណែកគំរប់ ៤ នៃនីលកហាបណៈនោះដោយបាលីថា: បញ្ចមាសកោ បាទោតិ តទា រាជគហេ វីសតិមាសកោ កហាបណោ ហោតិ តស្មា បញ្ច មាសកោ បាទោ ឯតេន លក្ខណេន សព្វជនបទេសុ កហាបណស្ស ចតុត្ថោ ភាគោ បាទោតិ វេទិតព្វោ សោ ច ខោ បោរាណស្ស នីលកហាបណស្ស វសេន ន ឥតរេសំ រុទ្រទាមកាទីនំ តេន ហិ បាទេន អតីតា ពុទ្ធាបិ បារាជិកំ បញ្ញាបេសុំ អនាគតាបិ បញ្ញាបេស្សន្តិ ។

ក៏ឯវិនិច្ឆ័យបាទ មគធៈ ជាប្រាក់ ក្នុងកម្ពុជប្រទេសនេះ តាមអដ្ឋ-

គថាទីងដីកា ទីងពោលទៅខាងមុខក្នុងទីបំផុតនៃការវិនិច្ឆ័យទាំងពួង ។

ក៏ឯអវហារ អាការដែលខ្ទីងលួចនោះ គប្បីដឹងដោយបាលី ៦ បទ ដូច្នេះ គឺ អាទិយនៈ ១ ហរណៈ ១ អវហរណៈ ១ ឥរិយាបថ-វិកោបនៈ ១ ឋានាចាវនៈ ១ សង្កេតវីតិនាមនៈ ១ ។ អធិប្បាយក្នុងបទទាំង ៦ នោះតាមអដ្ឋកថាដូច្នេះ ៖

អាទិយនៈ នោះថាកាន់យក បានដឹងភិក្ខុចោទប្រកាន់យកស្រែចំការឬរដំណាំចីជីរបស់អ្នកដទៃថាជារបស់ខ្លួន ក្នុងខណៈដែលចោទនោះត្រូវអាបត្តិទុក្កដ មិនត្រូវបារាជិកដោយមុសាវាទ ព្រោះជាបុព្វៈប្រយោគនៃអទិន្នាទាន កាលម្ចាស់របស់សង្ស័យ ថាយើងនឹងបានឬមិនបាន ភិក្ខុនោះត្រូវថុល្លច្ច័យ កាលម្ចាស់របស់លះបង់ធុរៈ ថានឹងមិនបានជារបស់យើងហើយ ភិក្ខុនោះឈ្នះក្តីធុរៈថាជាក់ជាមិនឲ្យ ទើបត្រូវបារាជិក បើភិក្ខុនៅមានចិត្តគិតថានឹងឲ្យ គ្រាន់តែសំដែងអានុភាពឲ្យខ្លាចប៉ុណ្ណោះក្តី ឬម្ចាស់របស់នៅមិនទាន់ដាក់ធុរៈក្តី ក៏នៅមិនទាន់ត្រូវបារាជិក កាលណាបើដាក់ធុរៈទាំងសងខាង គឺភិក្ខុច្បាស់ថាមិនឲ្យ ម្ចាស់របស់ក៏កាត់ថាមិនបានវិញហើយចុះ ទើបត្រូវបារាជិក ។

ហរណៈ នោះថានាំទៅ បានដឹងភិក្ខុជួយនាំរបស់នៃអ្នកដទៃទៅដោយក្បាលជាដើម បើមានថេយ្យចិត្តគិតនឹងលួច ចាប់ពាល់ឬបោសអង្អែលរបស់នៅលើក្បាលនោះ ត្រូវទុក្កដ គ្រប់ប្រយោគ ធ្វើរបស់នោះ

www.budinst.gov.kh www.elibraryofcambodia.org

ឲ្យកំរើកទៅមកនៅលើក្បាល ត្រូវថុល្លច្ច័យ គ្រប់ប្រយោគ ដាក់ចុះនូវរបស់នោះមកដល់ស្មា ត្រូវបារាជិក ឯកំណត់ក្បាលនោះ ខាងមុខត្រឹមចំពង់ក ខាងក្រោយត្រឹមជើងសក់ ខាងទាំងសងខាងត្រឹមគុម្ពត្រចៀក ភិក្ខុកំរើករបស់ចុះមកតាមក្បាលមិនឲ្យឃ្លាតអំពីក្បាល ល្មមតែហួសទៅក្រៅក្បាលដែលកំណត់ទុកនោះ ត្រូវបារាជិក ចាប់លើកឡើងផុតក្បាល សូម្បីតែមួយសរសៃសក់ក៏ត្រូវបារាជិក របស់ដែលរែកលើស្មានឹងកណ្ដៀកដោយបង្កេះនឹងយួរដោយដៃ ក៏គប្បីវិនិច្ឆ័យ ដូចជារបស់ដែលនៅលើក្បាលនោះចុះ ។

ឧទាហរណៈ នោះថានាំយក បានដឹងភិក្ខុទទួលរបស់បញ្ញើគេទុក លុះម្ចាស់របស់គេមកទារ ភិក្ខុក្លែងពោលពាក្យបំភាន់ថា យើងមិនដឹងមិនបានទទួលទុកទេ ពោលដូច្នេះដោយថេយ្យចិត្តត្រូវទុក្កដ ធ្វើឲ្យម្ចាស់របស់កើតមានសេចក្ដីសង្ស័យត្រូវថុល្លច្ច័យ លុះម្ចាស់របស់ដាក់ធុរៈ ភិក្ខុក៏ដាក់ធុរៈទាំងសងខាងដូចពោលហើយក្នុងអាទិយនៈនោះ ភិក្ខុនោះក៏ត្រូវបារាជិក ។

ឥរិយាបថវិកោបនៈ នោះថាញុំាងឥរិយាបថឲ្យកំរើក បានដឹងភិក្ខុមានថេយ្យចិត្តនឹងលួចនាំរបស់ព្រមទាំងមនុស្សដែលនាំរបស់នោះទៅផង ហើយដេញមនុស្សដែលនាំរបស់ទៅនោះ ឲ្យលើកជំហានជាដំបូងឈាន

www.budinst.gov.kh www.elibraryofcambodia.org

ទៅតាមប្រាជ្ញានៃខ្លួនត្រូវចុល្លច្ឆ័យ ដេញឲ្យលើកទុកតិយបាទ គឺជំហាន ជាន់រវៃសឈានទៅទៀត ត្រូវបាកជិត ។

ជាគាថាវន: នោះថាឲ្យកើតតាកទ គឺឲ្យឃ្លាតតាកទ បានទីដ៏ក៏ក្តុ គិតទីដ៏ល្អរបស់ដែលតាំងនៅលើគោក ឬក្នុងទឹក ឬជំនាប ឬទីដំបន់ណាមួយ ហើយតាប់ពាល់ត្រូវរបស់នោះត្រូវទុកក្នុង ធ្វើរបស់នោះឲ្យកើតទៅមកត្រូវចុល្លច្ឆ័យ ធ្វើរបស់នោះឲ្យឃ្លាតតាកទ ត្រូវបាកជិត ។ ឯកំណត់ហានទីតាំងនោះដូច្នេះ បើរបស់នោះជាផ្តាំងតាំងនៅក្នុងទឹក ឬក្នុងកក់មានហាន ៦ គឺមាត់ផ្តាំងខាងលើហាន ១ បាតផ្តាំងដែលពាល់ត្រូវផ្ទៃជាហាន ១ ខាងទាំង ៤ ជាហាន ៤ ត្រូវជា ៦ ហានដូច្នោះ ទាញមកខាងមុខឲ្យចំណែកផ្តាំងដែលពាល់ត្រូវផ្ទៃខាងណោះ ហួសចំណែកផ្តាំងដែលពាល់ត្រូវផ្ទៃខាងណោះមួយសរសៃសក់ក្តី ឬ រុញទៅខាងមុខឲ្យចំណែកផ្តាំងខាងណោះ ហួសចំណែកផ្តាំងដែលពាល់ត្រូវផ្ទៃខាងណោះមួយសរសៃសក់ក្តី ឬ ទាញទៅខាងឆ្វេងឲ្យចំណែកផ្តាំងដែលពាល់ត្រូវផ្ទៃខាងស្តាំ ហួសចំណែកផ្តាំងដែលពាល់ត្រូវផ្ទៃខាងឆ្វេងមួយសរសៃសក់ក្តី ឬ ទាញមកខាងស្តាំ ឲ្យចំណែកផ្តាំងដែលពាល់ត្រូវផ្ទៃខាងឆ្វេង ហួសចំណែកផ្តាំងដែលពាល់ត្រូវផ្ទៃខាងស្តាំមួយសរសៃសក់ក្តី ឬលើកទៀនឲ្យបាតផ្តាំងហួសផ្ទៃមួយសរសៃសក់ក្តី ឬសង្កត់ផ្តាំងឲ្យលិចចុះទៅឲ្យមាត់ផ្តាំងហួស

www.budinst.gov.kh www.elibraryofcambodia.org

...វណកដែលបាចឆ្នាំងពាល់ត្រូវផ្ចុះទៅមួយសរសៃសក់ក្ដី ដូច្នេះឈ្មោះ ...ភកំរើកចាកទីឋាន គឺឃ្លាតចាកទី ត្រូវបារាជិក ។

ឲ្យគប្បីដឹងច្បាស់នូវឋានដែលជាទីតាំងនៃរបស់តាំងពួន ដូច្នេះ ...របស់ដែលដាក់លក់ទុកក្នុងទីតាំងពួន តែខ្លះមានឋាន ១ ខ្លះមានឋាន ២ ខ្លះមានឋាន ៣ ខ្លះមានឋាន ៤ ខ្លះមានឋាន ៥ ជារបីប្រាក់នៅក្នុងឆ្នាំង ភិក្ខុយកភាជនៈជួសយក ឬ យកដៃក្ដាប់យកក្ដី ប្រាក់នៅក្នុងភាជនៈនិងក្នុង...ដៃនោះជាប់មិនជាប់គ្នានឹងប្រាក់ដែលនៅក្នុងឆ្នាំងនោះ មិនទាន់លើក...ឡើង ក៏ត្រូវបារាជិក ។

សង្កេតវីតិនាមនៈ នោះថាឲ្យកន្លងសង្កេត បាននិងគយដែល...ម្ចាស់ផែនដីតាំងបញ្ញត្តិទុកក្នុងចន្លោះភ្នំ ក្នុងកំពង់ទឹក ក្នុងទ្វារស្រុកណា...មួយ ថាអ្នកណាមកក្នុងទីនេះ ឲ្យហៅយកថ្លៃគយ ភិក្ខុទៅដល់គយ ដូច្នេះហើយគិតនឹងមិនឲ្យថ្លៃគយ មានថេយ្យចិត្តចាប់ពាល់អន្ទួលកណ្ដូ...ដែលខ្លួនយកទៅគួរដល់តម្លៃគយ ១ បាទ នោះត្រូវទុក្កដ លើកជំហានជាបឋមឈានកន្លងគយទៅ ត្រូវថុល្លច្ច័យ លើកជំហានជាគំរប់ ២ កន្លង...ទៅទៀតត្រូវបារាជិក ។

មួយទៀត ភិក្ខុចូលទៅក្នុងទីបរិវេណជាដើម បានឃើញកណ្ដូររបស់...ក្ខុកដទៃដែលគួរជាទីស្រឡាញ់ ហើយកំណត់ទ្វារវិល្វង ឬ មុខផ្ទះជាដើម...ទីណាមួយទុកជាទីសង្កេតហើយគិតថា ក្នុងកាលទីនេះ បើម្ចាស់របស់

www.budinst.gov.kh www.elibraryofcambodia.org

គេឃើញអញ អញនឹងធ្វើជារើសលើកមើលលេង ហើយនឹងឲ្យទៅម្ចាស់គេវិញ បើម្ចាស់របស់មិនឃើញអញ អញនឹងលួចយក កំណត់ដូច្នេះ ហើយនាំរបស់នោះដើរទៅ លើកជំហានជាបឋមកន្លងទ្វារល្វែងជាដើម ដែលសង្កេតទុកនោះ ត្រូវថុល្លច្ច័យ លើកជំហានជាគំរប់ ២ ឈានទៅទៀត ត្រូវបារាជិក ដូចពោលមកនេះឈ្មោះសង្កេតវីតិនាមនៈ ។

មួយទៀត អវហារប្រភេទអាការលួច ព្រះអដ្ឋកថាចារ្យលោកតាំងទុកថាមាន ២៥ ចាត់ជាពួក ៗ មាន ៥ ពួកដូច្នេះ នានាភណ្ឌបញ្ចកៈ ពួក ១ ឯកភណ្ឌបញ្ចកៈ ពួក ១ សាហត្ថិកបញ្ចកៈ ពួក ១ បុព្វបយោគបញ្ចកៈ ពួក ១ ថេយ្យាវហារបញ្ចកៈ ពួក ១ ។

ក៏ឯនានាភណ្ឌបញ្ចកៈ នោះថា កិរិយាលួចមានពួក ៥ មានរបស់ផ្សេង ៗ ជាទីកំណត់ គឺ អាទិយនៈ ទាញយករបស់ដែលមានវិញ្ញាណនឹងមិនមានវិញ្ញាណរបស់គេ ១ ហរណៈ ជួយនាំយករបស់ដែលមានវិញ្ញាណ នឹងមិនមានវិញ្ញាណរបស់គេទៅ ១ អវហរណៈ បិទបាំងលួចយករបស់មានវិញ្ញាណនឹងមិនមានវិញ្ញាណ ដែលគេផ្ញើទុក ១ ឥរិយា-បថវិកោបនៈ ធ្វើឥរិយាបថនៃអ្នកនាំរបស់ទៅឲ្យកំរើក ១ ឋានាចាវនៈ ធ្វើរបស់ដែលមានវិញ្ញាណ នឹងមិនមានវិញ្ញាណឲ្យឃ្លាតចាកឋាន ១ ។ អវហារ ៥ ពួកនេះ ឈ្មោះថា នានាភណ្ឌបញ្ចកៈ ព្រោះកំណត់ដោយរបស់ផ្សេង ៗ គឺរបស់មានវិញ្ញាណនឹងមិនមានវិញ្ញាណ វិនិច្ឆ័យពិស្តារឲ្យគប្បីដឹងដូចសំដែងហើយក្នុងបទទាំង ៦ ខាងដើមនោះចុះ ។

www.budinst.gov.kh www.elibraryofcambodia.org

ក៏ឯ ឯកភណ្ឌបញ្ចកៈ នោះជាពួក ៥ នៃកិរិយាលួចវត្ថុមានវិញ្ញាណក ១ ជាទីកំណត់ គឺ អាទិយនៈ ទោចយករបស់ដែលមានវិញ្ញាណគឺទាសៈនិងសត្វចិញ្ចឹមរបស់គេ ១ ហរណៈ ជួយនាំយកទាសៈសត្វចិញ្ចឹមរបស់គេទៅ ១ អវហរណៈ បិទបាំងលាក់បង្វេះយកទាសៈនិងសត្វចិញ្ចឹមរបស់ដែលគេផ្ញើទុក ១ ឥរិយាបថវិកោបនៈ ធ្វើឥរិយាបថនៃទាសៈនិងសត្វដែលគេចិញ្ចឹមរបស់គេឲ្យកំរើក ១ ឋានាចាវនៈ ទាសៈនិងសត្វចិញ្ចឹមរបស់គេឲ្យឃ្លាតចាកទី ១ ពួក ៥ នេះឈ្មោះថា ភណ្ឌបញ្ចកៈ កំណត់ដោយរបស់មានវិញ្ញាណម្យ៉ាង វិនិច្ឆ័យដោយអាការ ដូចបានពោលមកហើយអំពីមុន ។

ក៏ឯ សាហត្ថិកបញ្ចកៈ នោះជា ពួកនៃអាការៈលួចមាន ៥ មានលួចដោយដៃខ្លួនជាដើម គឺ សាហត្ថិកៈ ១ អាណត្តិកៈ ១ និស្សគ្គិយៈ ១ សាធកៈ ១ ធុរនិក្ខេបៈ ១ ត្រូវជា ៥ ។

សាហត្ថិកៈ នោះជា កិរិយាលួចកើតដោយដៃខ្លួនឯង គឺភិក្ខុលួចរបស់ដែលឋិតនៅលើគោក និងក្នុងទឹក ឬក្នុងទីណាមួយ ជារបស់អ្នក ដោយខ្លួនឯង ។

អាណត្តិកៈ នោះជា កិរិយាលួចកើតដោយបង្គាប់ គឺភិក្ខុបង្គាប់ឲ្យភិក្ខុលួច ថាលោកចូរលួចយកវត្ថុនេះ អ្នកបង្គាប់ត្រូវទុក្កដក្នុងខណៈបង្គាប់ ដែលនឹងលួច សំគាល់ថាវត្ថុនោះក្តី សំគាល់ថាវត្ថុដទៃក្តី ហើយលួច

www.budinst.gov.kh www.elibraryofcambodia.org

បានតាមបង្គាប់ ដូច្នេះ ត្រូវបារាជិកទាំង២នាក់ ទាំងអ្នកលួច ទាំងអ្នកបង្គាប់ បើអ្នកលួចសំគាល់ថា វត្ថុនោះក្តី សំគាល់ថា វត្ថុដទៃក្តី ហើយលួចបានវត្ថុដទៃក្រៅពីវត្ថុដែលកំណត់នោះ ដូច្នេះ អ្នកបង្គាប់មិនត្រូវបារាជិក ត្រូវតែអ្នកលួច ។ មួយទៀត ដូចភិក្ខុជាអាចារ្យបង្គាប់ពុទ្ធរក្ខិតថា អ្នកចូរប្រាប់ធម្មរក្ខិតឲ្យប្រាប់ដល់សង្ឃរក្ខិតឲ្យលួចរបស់ឈ្មោះនេះ ដូច្នេះ ត្រូវទុក្កដកន្លងខណៈបង្គាប់ ពុទ្ធរក្ខិតទៅប្រាប់ធម្មរក្ខិត ក៏ត្រូវទុក្កដ ធម្មរក្ខិតទៅប្រាប់សង្ឃរក្ខិត សង្ឃរក្ខិតទទួលនឹងលួច អាចារ្យអ្នកបង្គាប់ដើមត្រូវថុល្លច្ច័យ សង្ឃរក្ខិតលួចវត្ថុនោះ បានតាមបង្គាប់ ដូច្នេះ ត្រូវបារាជិកព្រមគ្នាទាំង ៤ នាក់ បើពុទ្ធរក្ខិតរំលងធម្មរក្ខិត ទៅប្រាប់សង្ឃរក្ខិត សង្ឃរក្ខិត ក៏លួចបានតាមកំណត់ដូច្នេះ អាចារ្យអ្នកបង្គាប់ដើមមិនត្រូវបារាជិក ត្រូវតែពុទ្ធរក្ខិតអ្នកបង្គាប់ នឹងសង្ឃរក្ខិតអ្នកលួចប៉ុណ្ណោះ ភិក្ខុបង្គាប់អ្នកដទៃឲ្យលួច ហើយមានវិប្បដិសារៈក្តៅក្រហាយចិត្តហាមឃាត់ឲ្យបានឮ អ្នកទទួលបង្គាប់មិនស្តាប់ទំចរចេសតែលួច ដូច្នេះ អ្នកបង្គាប់មិនត្រូវបារាជិក ត្រូវតែអ្នកលួច ដូច្នេះ ឈ្មោះថា អាណត្តិកៈ ។

ក៏ឯ និស្សគ្គិយៈ នោះថា លួចដោយកិរិយាបោះចោលវត្ថុនោះទៅ គឺភិក្ខុកំណត់ទីទុកមានទ្វារល្ហងជាដើម ថាអានក្នុងល្ហងនេះ បើម្ចាស់គេឃើញ យើងនឹងធ្វើជាមើលល្ហង បើម្ចាស់គេមិនឃើញ យើងនឹងលួចយក កាលម្ចាស់របស់គេមិនឃើញ ហើយបោះចោលកន្លងទ្វារល្ហងចេញមក

www.budinst.gov.kh www.elibraryofcambodia.org

បើវត្ថុនោះនឹងធ្លាក់ហួសអំពីផ្ទាវល្វែងទៅបានប្រាកដ និមិត្តតែវត្ថុនោះប្រូតផុតអំពីដៃ ត្រូវបារាជិក ។ មួយទៀត ភិក្ខុទៅដល់គយ យកវត្ថុដែលត្រូវបង់ថ្លៃគយនោះ បោះកន្លងគយទៅ ថាបើវត្ថុនោះនឹងធ្លាក់ទៅខាងក្រៅជាប្រាកដ និមិត្តតែរបស់នោះផុតអំពីដៃ ក៏ត្រូវបារាជិក ដូច្នេះឈ្មោះថា និស្សគ្គិយៈ ។

ក៏ឯ អត្ថសាធកៈ នោះថា ញ៉ាំងអត្ថប្រយោជន៍ឲ្យសំរេចមុនកិរិយាលួច បានដល់ភិក្ខុបង្គាប់ភិក្ខុថា លោកអាចលួចវត្ថុនេះ របស់អ្នកឯណោះបានក្នុងកាលណា ចូរលួចកាលណោះចុះ ដូច្នេះ បើអ្នកទទួលបង្គាប់នោះមិនមានអន្តរាយក្នុងចន្លោះគង់នឹងលួចបានប្រាកដ អ្នកបង្គាប់ក៏ត្រូវបារាជិកក្នុងខណៈបង្គាប់ អ្នកលួចត្រូវបារាជិកក្នុងវេលាដែលលួច ។ មួយទៀត ភិក្ខុយកស្បែកជើងជាដើម ដែលល្មមជប់ប្រេងគ្រប់ថ្លៃបានមួយបាទ ដាក់ក្នុងឆ្នាំងប្រេងរបស់អ្នកដទៃ និមិត្តតែស្បែកជើងធ្លាក់ផុតអំពីដៃ ក៏ត្រូវបារាជិក ដូចពោលមកនេះឈ្មោះថា អត្ថសាធកៈ ។

ក៏ឯ ធុរនិក្ខេបៈ នោះថា សម្រេចជាការលួច ដោយដាក់ធុរៈ ដូចភិក្ខុទោចយកទ្រព្យជាដើម នឹងរបស់អ្នកដទៃផ្ញើទុក ម្ចាស់របស់គេមកទារមិនឲ្យក្តី នឹងរបស់ដែលខ្ចីគេមក ឬរបស់ជាកណ្តាលទេយ្យ គឺរបស់ណា ៗ ដែលភិក្ខុខ្ចីរបស់គេឲ្យបាត់ទៅ មិនសងឲ្យម្ចាស់របស់គេវិញ កាលម្ចាស់របស់មកទារមិនឲ្យ ដូច្នេះ ត្រូវបារាជិក ព្រោះដាក់ធុរៈព្រមគ្នា

www.budinst.gov.kh www.elibraryofcambodia.org

ទាំងសងខាង ដូចបានពោលមកហើយ យ៉ាងនេះឈ្មោះថា ធុរនិក្ខេបៈ ។ ៥ ពួកនេះឈ្មោះថា សាហត្ថិកបញ្ចកៈ ។

ក៏ឯ បុព្វបយោគបញ្ចកៈ នោះគឺ ពួកនៃកិរិយាលួចមាន ៥ មាន ប្រយោគមុនជាខាងដើម គឺ បុព្វបយោគ ១ សហបយោគ ១ សំវិធាវហារ ១ សង្កេតកម្ម ១ និមិត្តកម្ម ១ ត្រូវជា ៥ ។

បុព្វបយោគ នោះថា កិរិយាលួចមានប្រយោគមុន បានដល់ អាណត្តិកៈ គឺការបង្គាប់ឲ្យអ្នកដទៃលួចទ្រព្យគេ ដូចពោលមកហើយក្នុង អាណត្តិកៈ ឈ្មោះថាបុព្វបយោគ ព្រោះសេចក្តីបង្គាប់នោះជាប្រយោគ មុន អំពីប្រយោគនៃអ្នកដទៃទទួលបង្គាប់នឹងកាន់យករបស់ទ្រព្យ ។

សហបយោគ នោះថា ជាអវហារ កិរិយាលួចព្រមដោយប្រយោគ ដែលកាន់យករបស់ បានដល់កិច្ចធ្វើរបស់ក្នុងទឹកឲ្យនិះលើគោកជាដើមឲ្យ ឃ្លាតចាកទី និងរុះរោះបង្គោលព្រំជាដើម ឲ្យចូលទៅក្នុងទីស្រែចំការ របស់គេដោយខ្លួនឯង ត្រូវបារាជិក ដូច្នេះឈ្មោះថាសហបយោគ ព្រោះ សម្រេចកិរិយាលួចព្រមដោយប្រយោគដែលធ្វើរបស់គេឲ្យឃ្លាតចាកទី ។

សំវិធាវហារ នោះថា គឺភិក្ខុលួចជាមួយគ្នាទាំងអស់ ដោយបបួលគ្នា ទៅលួច គឺភិក្ខុច្រើនគ្នា បបួលគ្នាទៅលួចវត្ថុណាហើយ សូម្បី តែភិក្ខុមួយអង្គលួចវត្ថុនោះបាន ក៏ត្រូវបារាជិកជាមួយគ្នាទាំងអស់ ។

សង្កេតកម្ម នោះថាធ្វើសង្កេត គឺភិក្ខុបង្គាប់ភិក្ខុដោយកំណត់កាល

www.budinst.gov.kh www.elibraryofcambodia.org

មានវេលាព្រឹកជាដើម ថាលោកចូរលួចវត្ថុនេះ វត្ថុនោះ ក្នុងវេលាព្រឹក ហើយអ្នកទទួលបង្គាប់ទៅលួចបានក្នុងវេលាព្រឹកតាមកំណត់បង្គាប់ ដូច្នេះ ត្រូវបារាជិក ទាំងអ្នកប្រើ ទាំងអ្នកលួច បើអ្នកទទួលបង្គាប់ទៅលួចបាន ក្នុងវេលាដទៃមានវេលាល្ងាចជាដើម ដូច្នេះ ខុសសង្កេត អ្នកប្រើមិនត្រូវ បារាជិក ត្រូវតែអ្នកលួច យ៉ាងនេះឈ្មោះថាសង្កេតកម្ម ព្រោះជាអវហារ ដល់អ្នកប្រើ តាមដែលធ្វើសង្កេត ។

និមិត្តកម្ម នោះថា ធ្វើនិមិត្តក្នុងកិរិយាលួចមានប៉ប្រិចភ្នែកជាដើម បាននឹងកិត្តុបង្គាប់ថា លោកចូរលួចក្នុងខណៈដែលយើងប៉ប្រិចភ្នែក ឬ ញាក់មុខដូច្នេះ អ្នកលួចក៏លួចក្នុងខណៈប៉ប្រិចភ្នែកនិងញាក់មុខ នៃអ្នក បង្គាប់នោះ ដូច្នេះត្រូវបារាជិក ទាំងអ្នកលួច ទាំងអ្នកបង្គាប់ បើអ្នក លួចទៅលួចមុន ឬលួចក្រោយប៉ប្រិចភ្នែក ញាក់មុខនោះ អ្នកបង្គាប់ មិនត្រូវបារាជិក ត្រូវតែអ្នកលួច ដូច្នេះឈ្មោះថានិមិត្តកម្ម ព្រោះជា អវហារ ដល់អ្នកធ្វើនិមិត្តឲ្យអ្នកលួច អ្នកលួចត្រូវតាមកំណត់ ៥ ពួក ដូចពោលមកនេះ ឈ្មោះថាបុព្វបយោគបញ្ចកៈ ។

កឹង ថេយ្យាវហារបញ្ចកៈ នោះថា ពួកនៃកិរិយាលួចមាន ៥ មាន ថេយ្យាវហារជាដើម គឺថេយ្យាវហារ ១ បសយ្ហាវហារ ១ បរិកប្បាវហារ ១ បដិច្ឆន្នាវហារ ១ កុសាវហារ ១ ត្រូវជា ៥ ។

ថេយ្យាវហារ នោះថា លួចដោយមានសភាពដូចជាចោរ ដូចកិត្តុ

www.budinst.gov.kh www.elibraryofcambodia.org

កាត់ទំលុះមានជញ្ជាំងជាដើម លបលួចមិនឲ្យម្ចាស់របស់ឃើញ កាន់យកក្តី ទីនប់បាត់ដោយក្លែងជញ្ជីងកាឡ តាឡ្យៀគោរី ទីនក្រោកស្លាប់សំណាជាដើម ដូច្នេះ ត្រូវបារាជិក ដូចពោលមកនេះឈ្មោះថា ថេយ្យាវហារ ។

គឺឯ បសយ្ហាវហារ នោះថា កំហែងលួចយក បានដល់កិត្តុកំហែង សង្កត់សង្កិនដណ្តើមបើបង្ខំយករបស់អ្នកដទៃ ដូចជាចោរប្លន់អ្នកស្រុកជាដើម ទីនកាន់យកសួយសារអាករលើសជាងចំណែកដែលខ្លួនត្រូវបាន ដូចរាជាមាត្យទារយកសួយសារអាករលើសអំពីបញ្ញត្តិ ដូច្នេះ ត្រូវបារាជិក ដូចពោលមកនេះឈ្មោះថា បសយ្ហាវហារ ។

បរិកប្បាវហារ នោះថា លួចយកសំរេចដោយសេចក្តីកំណត់ បរិកប្បាវហារនេះ មាន ២ គឺ កំណត់របស់ ១ កំណត់ឱកាស ១ ។ កំណត់របស់នោះដូច្នេះ ភិក្ខុប្រាថ្នាទីនលួចសំពត់សាដក លបចូលទៅក្នុងល្វែងរលាយបំកំណត់ថា បើជាសំពត់អញនឹងយក បើជាអម្បោះអញមិនយក ហើយលើកការុងឡើង បើក្នុងការុងនោះជាសំពត់សាដកសោត ត្រូវបារាជិកក្នុងខណៈដែលលើក បើជាអម្បោះសោតមិនទាន់ត្រូវបារាជិក លុះចេញមកខាងក្រៅស្រាយការុងចេញ មើលដឹងថាជាអម្បោះហើយ យកទៅទុកដូចដើមវិញ ក៏នៅមិនទាន់ត្រូវបារាជិក សូម្បីដឹងថាជាអម្បោះហើយ គិតថាអញបានវត្ថុក៏យកវត្ថុនោះ ហើយនាំដើរទៅ ឲ្យវិន័យធរគប្បីកាត់អាបត្តិ ដោយលើកនូវជំហានទីមួយទីពីរ

បើដាក់ចុះលើថ្ម ហើយត្រឡប់កាន់យកទៀត ទំមិត្តក៏លើកឡើងពី ត្រវាកជីក បើម្ចាស់របស់គេស្រែកថាចោរ ៗ ហើយគេដេញតាមទៅ ភិក្ខុបោលរបស់ហើយរត់ទៅក៏គង់នៅក្សួបាន បើម្ចាស់របស់គេឃើញ គេកាន់យករបស់គេទៅវិញ ក៏គង់នៅក្សួនៅឡើយ បើមនុស្សដទៃ កាន់យកទៅសោត ភិក្ខុនោះត្រូវគណ្ហាទេយ្យ លុះម្ចាស់របស់ត្រឡប់ ទៅវិញ ភិក្ខុឃើញរបស់នោះ ហើយកាន់យកដោយចិត្តប្រកួលសញ្ញា ដោយគិតថារបស់នេះយើងកាន់យកអំពីមុនហើយ សម័យនេះជាទ្រព្យ របស់យើង សូម្បីដូច្នេះ ក៏ត្រូវគណ្ហាទេយ្យគប្បីសងគេ កំណត់ថា របស់ពត់យើងនឹងយក ដូចពោលមកនេះ ឈ្មោះថាគណ្ហាបរិកប្ប គឺកំណត់របស់ ។

ក៏ឯ ឱកាសបរិកប្ប កំណត់ឱកាសនោះ គឺកំណត់ទ្វារវិល្វងនឹង មុខផ្ទះជាដើម ដូចពោលហើយក្នុងសន្និដ្ឋានតាមមនៈនោះ កំណត់វត្ថុ ឬ ឱកាសទាំង ២ ណាមួយហើយលួច ដូចពោលមកនេះឈ្មោះថា បរិកប្បាវហារ ។

ក៏ឯ បដិច្ឆន្នាវហារ នោះថា បិទបាំងទុកហើយលួចយក ឲ្យគប្បីដឹង ដូច្នេះ ភិក្ខុណាឃើញរបស់អ្នកដទៃ មានចិញ្ចៀនជាដើម គេដោះ ដាក់ទុកក្នុងស្នួនជាដើម កាន់យកដីឬស្លឹកឈើបិទបាំងទុកដោយគិតថា ក្រោះក្រោយអញនឹងកាន់យក ចុះណ្ណោះនៅមិនទាន់ឈ្មោះថាលើកឡើង

www.budinst.gov.kh www.elibraryofcambodia.org

ព្រោះហេតុនោះ នៅមិនទាន់ចូលជាអវហារនៅឡើយ កាលណាបើម្ចាស់គេមករកមិនឃើញ ហើយគេមានអាល័យនៅតែថា ព្រឹកនេះសឹមយើងនឹងដឹង ហើយត្រឡប់ទៅផ្ទះ គ្រានោះ ភិក្ខុមកលើកយករបស់នោះឡើង មិនមែនតែលើកឡើង គឺជាអវហារ បើភិក្ខុនោះកាន់យកដោយសកសញ្ញាសំគាល់ថា របស់នោះជារបស់យើង យើងបានបិទបាំងទុកហើយ ឬ កាន់យកដោយបង្សុកូលសញ្ញាសំគាល់ថា ម្ចាស់របស់ទៅហើយ គេចោលរបស់នេះហើយ យ៉ាងនេះជាភណ្ឌទេយ្យ សូម្បីក្នុងថ្ងៃគំរប់ ២ ម្ចាស់របស់មកគន់រកមិនឃើញ គេដាក់ធុរៈហើយត្រឡប់ទៅ ភិក្ខុមកកាន់យក គឺត្រូវភណ្ឌទេយ្យ គ្រាក្រោយម្ចាស់ដឹងគេមកទារ ភិក្ខុមិនឲ្យ ម្ចាស់របស់ដាក់ធុរៈកាលណា គឺជាអវហារដល់ភិក្ខុកាលណោះ ព្រោះថារបស់នោះម្ចាស់របស់គេមិនឃើញ ដោយប្រយោគនៃភិក្ខុ ។ ក៏ឯភិក្ខុមិនបានបិទបាំងដូច្នោះ របស់ទុកនៅតាមទីឋាន ភិក្ខុមានថេយ្យចិត្តយកជើងជាន់ទុកឲ្យលិចចុះទៅ ក្នុងភក់ ឬ ក្នុងខ្សាច់ក្ដី មិនមែនតែរបស់លិចចុះទៅ សុតចាកទីដើមគឺជាអវហារ ដូចពោលមកនេះ ឈ្មោះថាបដិច្ឆន្នាវហារ ។

ក៏ឯ កុសាវហារ នោះថា កិរិយាលួចដោយបោះស្លាក ឲ្យគេប្ដូរ ដោយន័យនេះ ភិក្ខុណាឃើញស្លាកគេធ្វើនឹងបន្ទោះឬស្សី ឬស្លឹកឈើគេសរសេរឈ្មោះភិក្ខុទុកហើយដាក់លើសំពត់ជាចំណែកនៃគ្នា ភិក្ខុប្រាថ្នា

www.budinst.gov.kh www.elibraryofcambodia.org

នឹងលើកយកចំណែករបស់អ្នកដទៃ ដែលមានថ្លៃតិចនឹងថ្លៃប្រេចន ឬ មានថ្លៃស្មើគ្នា ដែលទុកនៅជិតចំណែករបស់ខ្លួន ក៏គុលើកស្លាករបស់ខ្លួនឡើង ដោយប្រាថ្នាថានឹងដាក់ក្នុងចំណែកនៃអ្នកដទៃ ក៏នៅរក្សានៅឡើយ ដាក់ស្លាករបស់ខ្លួនចុះក្នុងចំណែកអ្នកដទៃ ក៏នៅរក្សានៅឡើយ លុះខណៈលើកស្លាករបស់អ្នកដទៃឡើងចាកចំណែកអ្នកដទៃ និមិត្តតែលើកក៏ជាអវហារ, ថាបើភិក្ខុលើកស្លាកចំណែកនៃអ្នកដទៃមុន ដោយប្រាថ្នានឹងដាក់ក្នុងចំណែករបស់ខ្លួន កាលដែលលើកឡើងក៏នៅរក្សានៅឡើយ កាលដាក់ចុះក៏នៅរក្សានៅឡើយ លុះលើកស្លាករបស់ខ្លួនចាកចំណែករបស់ខ្លួន កាលលើកឡើងក៏នៅរក្សានៅឡើយ លុះតែលើកឡើងហើយដាក់ស្លាករបស់ខ្លួនចុះក្នុងចំណែកនៃអ្នកដទៃកាលណា និមិត្តតែផុតអំពីដៃក៏ជាអវហារ, អាការដែលលួចយ៉ាងនេះឯង ឈ្មោះថាកុសាវហារ ៥ ពួកនេះឈ្មោះថា ថេយ្យាវហារបញ្ចកៈ ក្នុងបញ្ចកៈទាំង ៥ នេះ ក្នុងបញ្ចកៈនីមួយ ៗ មានអាការៈនៃការលួច ៥ ៗ ទើបត្រូវជាអវហារ ២៥ ដោយពិស្តារតាមអដ្ឋកថា ។

ក៏ឯ នានាភណ្ឌបញ្ចកៈ នឹងឯកភណ្ឌបញ្ចកៈមិនបានថ្លែងអំពីគ្នា បើលើកយកឯកភណ្ឌបញ្ចកៈចេញ គង់សល់នៅតែអវហារ ២០ ។

មួយទៀត សហបយោគនឹងសាហត្ថិកបយោគ បុព្វបយោគនឹងអាណត្តិកបយោគក៏មិនថ្លែកគ្នា បើផ្សំជាមួយគ្នា គង់សល់អវហារ ១៨ ។

www.budinst.gov.kh www.elibraryofcambodia.org

មួយទៀត អាទិយនៈ នឹងអវហារណៈ នឹងធុរនិក្ខេបៈ ក៏មិនប្លែកអំពីគ្នា បើលើកធុរនិក្ខេបៈចេញ គង់សល់នៅអវហារ ១៧ ជាបើទុកធុរនិក្ខេបៈ លើកអាទិយនៈ នឹងអវហារណៈចេញ សល់នៅអវហារ ១៦ ។

មួយទៀត ភិក្ខុគិតនឹងទៅលួចទ្រព្យរបស់អ្នកដទៃ ក្នុងបុព្វប្រយោគ តាំងពីតួន តាំងអំពីដើរទៅជាដើម ត្រូវអាបត្តិទុក្កដគ្រប់ៗ ប្រយោគ ចាប់បញ្ចោសអង្អែលក៏ត្រូវទុក្កដ ធ្វើទ្រព្យដែលជាវត្ថុខាងក្រោមឲ្យកំរើក ត្រូវថុល្លច្ច័យ លុះលួចយកទ្រព្យ ១ មាសក ឬថយជាង ១ មាសក ត្រូវទុក្កដ បើទ្រព្យលើសជាង ១ មាសកឡើងទៅ ថយអំពី ៥ មាសក ចុះមក ត្រូវថុល្លច្ច័យ បើទ្រព្យនោះគ្រប់ ៥ មាសក ឬលើសជាង ៥ មាសកឡើងទៅ ត្រូវបារាជិក ។

មួយទៀត អទិន្នាទានសិក្ខាបទនេះល្អិតសុខុមណាស់ ព្រះអដ្ឋកថាចារ្យវិនិច្ឆ័យទុកដោយន័យវិចិត្រផ្សេងៗ ក្នុងគម្ពីរសមន្តបាសាទិកា ដែលពោលមកនេះដោយសង្ខេប ហើយលោកប្រដៅទុកថា ជាសិក្ខាបទល្អិតសុខុមក្រនឹងកាត់សេចក្តីបាន ព្រោះហេតុនោះ កាលបើមានគេមកចោទភិក្ខុដោយអទិន្នាទាន សូមវិន័យធរសាកសួរដោយអវហារប្រកបទៅ បើឃើញថាជាអវហារហើយ ក៏កុំគាលកាត់សេចក្តីដោយប្រញាប់ពេក គប្បីសាកសួរដោយអង្គ ៥ ស្ថាន គឺ វត្ថុ ១ កាល ១ ប្រទេស ១ អគ្ឃៈ ១ បរិភោគ ១ ដូច្នេះជាមុនសិន ។

www.budinst.gov.kh www.elibraryofcambodia.org

វត្ថុនោះ គឺ របស់ដែលភិក្ខុលួចមក ឲ្យសាកសួរមើលថា វត្ថុនោះ មានម្ចាស់របស់ ឬមិនមាន ថាបើមានម្ចាស់របស់ ក្នុងវេលាដែលលួចមកនោះ ម្ចាស់របស់មានអាល័យ ឬកាត់អាល័យហើយ បើម្ចាស់របស់នៅមានអាល័យឲ្យកាត់តាមថ្លៃរបស់ បើម្ចាស់របស់កាត់អាល័យហើយ កុំគប្បីកាត់អាបត្តិបារាជិក កាលម្ចាស់របស់ទារយកក៏គប្បីប្រគល់ឲ្យទៅ ដូច្នេះ ជាសេចក្តីគាប់ប្រសើរ នេះឯងឈ្មោះថា សាកសួរវត្ថុ ។ កាលនោះ គឺសម័យដែលលួចរបស់នោះមក ព្រោះថារបស់នោះ មានកាលខ្លះមានតម្លៃស្មើ កាលខ្លះមានតម្លៃច្រើន ។

ឯប្រទេសនោះ គឺ ទីឋានដែលភិក្ខុលួចរបស់នោះមក របស់លួចមកក្នុងប្រទេសណា ឲ្យកាត់តាមតម្លៃ ក្នុងប្រទេសនោះ ៗ អគ្ឃៈនោះ គឺ តម្លៃរបស់ដែលលួចមក របស់ថ្មី លុះត្រាក្រោយចាស់ហើយក៏ថយតម្លៃ ៗ បរិភោគនោះ គឺរបស់នោះ បរិភោគប្រើប្រាស់ហើយ ឬ នៅ បើរបស់នោះគេបរិភោគប្រើប្រាស់ហើយ ក៏ថយតម្លៃ ក៏ឯទី ៥ ស្ថាននោះ គប្បីឲ្យសាកសួរមើល ៗ

ឯវិធីដែលមិនត្រូវបារាជិកាបត្តិក្នុងសិក្ខាបទនេះ គឺភិក្ខុសំគាល់ថាជាទ្រព្យរបស់ខ្លួនហើយកាន់យក ១ គឺនឹងកាន់យកដោយវិស្សាសៈស្និទស្នាលគ្នា ១ ខ្ចីមកប្រើប្រាស់ ១ របស់នោះជារបស់យក្ស ប្រេត ឬជារបស់សត្វតិរច្ឆានមិនមែនជារបស់មនុស្ស ១ កាន់យកដោយចិត្តឆ្កួតសញ្ញា

សំគាល់ថាមិនមានម្ចាស់របស់ ១ នឹងកិច្ចគេជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។

សិក្ខាបទនេះជាសាណត្តិកៈ ព្រោះប្រើអ្នកដទៃឲ្យលួចក៏ត្រូវអាបត្តិ មានអង្គ៥គឺ អញ្ញស្ស មនុស្សជាតិកស្ស វសេន បរបរិគ្គហិតំ ទ្រព្យអ្នកដទៃជាមនុស្សជាតិហួងហែង ១ បរបរិគ្គហិតសញ្ញិតា សំគាល់ថាជារបស់អ្នកដទៃហួងហែងរក្សា ១ គរុបរិក្ខារោ របស់នោះតម្លៃមួយបាទ ឬ តម្លៃលើសជាងមួយបាទឡើងទៅ ១ ថេយ្យចិត្តំ ចិត្តគិតលួច ១ វុត្តប្បការកំ អវហារកំ វសេន អវហារណំ លួចបានមកដោយអវហារណាមួយ ដូចពោលមកហើយ ១ ព្រមដោយអង្គ៥នេះទើបត្រូវបារាជិក ។ មួយទៀត សិក្ខាបទនេះ មានសមុដ្ឋាន ៣ ឈ្មោះអទិន្នាទាន សមុដ្ឋាន គឺ អាបត្តិកើតអំពីកាយចិត្ត ១ វាចាចិត្ត ១ កាយវាចាចិត្ត១ ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត មានវេទនា ៣ ។

ទុតិយបារាជិក ចប់

---

មនុស្សវិគ្គហសិក្ខាបទ គំរប់ ៣ សេចក្តីថា ភិក្ខុណាក្លែងដាក់បង់នូវកាយនៃមនុស្ស តាំងអំពីបឋមវិញ្ញាណតាំងចុះ កើតជាកលលរូប ក្នុងគភ៌មាតាឲ្យដាច់ចាកជីវិត គឺសម្លាប់ឲ្យស្លាប់ សូម្បីប្រកបថ្នាំក្តៅ ពិសផាត់ប្រហាច់ជាដើម ឬដាក់កល់គ្រឿងសស្ត្រាវុធផ្សេង ១ ទុកដើម្បី

www.budinst.gov.kh www.elibraryofcambodia.org

នឹងប្រហារជីវិតមនុស្ស ឬពណ៌នាសរសើរសេចក្ដីស្លាប់ថា អ្នកមានប្រយោជន៍អ្វី ដោយសេចក្ដីរស់នៅអាក្រក់លាមក មិនស្មើមុខនឹងគេស្លាប់ទៅប្រសើរជាជាង ស្លាប់ហើយនឹងបានទៅសុគតិ ឬប្រាប់ឧបាយឲ្យស្លាប់ គឺបង្គាប់ថាអ្នកចូរចាក់ក ចូរលេបថ្នាំពិសជាដើម បើភិក្ខុមានសេចក្ដីប្រាថ្នានឹងឲ្យស្លាប់ហើយធ្វើឧបាយផ្សេងៗ ដើម្បីនឹងឲ្យគេស្លាប់ដូចសំដែងមកនេះ មនុស្សនោះស្លាប់ក្នុងខណៈនោះ ឬយូរទៅទើបស្លាប់ដោយហេតុនោះក្ដី ភិក្ខុនោះក៏ត្រូវបារាជិក ។ មនុស្សជាវត្ថុនៃបារាជិក ។ អមនុស្សគឺ យក្ខ ប្រេត ជាវត្ថុនៃថុល្លច្ច័យ ។ តិរច្ឆានជាវត្ថុនៃបាចិត្តិយ ។

ក៏ឯប្រយោគនៃបាណាតិបាត មាន ៦ គឺ សាហត្ថិកប្បយោគ ១ និស្សគ្គិយប្បយោគ ១ អាណត្តិកប្បយោគ ១ ថាវរប្បយោគ ១ វិជ្ជាមយប្បយោគ ១ ឥទ្ធិមយប្បយោគ ១ ដូច្នេះ ។

សាហត្ថិកប្បយោគនោះថា ប្រកបសេចក្ដីព្យាយាមនឹងសម្លាប់សត្វដ៏មានជីវិតដោយដៃខ្លួនឯង គឺភិក្ខុប្រាថ្នានឹងសម្លាប់សត្វដោយខ្លួនឯង នឹងប្រហារដោយកាយមានដៃនឹងជើងជាដើម ឬវត្ថុជាប់ដោយកាយ មានដាវលំពែងជាដើម ឈ្មោះថាសាហត្ថិកប្បយោគ ជាប្រយោគធ្វើឲ្យគេស្លាប់ដោយដៃខ្លួនឯង ។

និស្សគ្គិយប្បយោគនោះថា ប្រកបដោយកិរិយាគឺបោះពួយទៅ បាននឹងភិក្ខុមានបំណងនឹងឲ្យអ្នកដែលនៅឆ្ងាយស្លាប់ ហើយបាញ់ ពួយ

www.budinst.gov.kh www.elibraryofcambodia.org

គ្រវែង ចោលទៅ នូវសស្ត្រាវុធមាន ធ្នូ ស្នា ទីងលំពែង យន្ត ដុំសិលា ជាដើម ដោយកាយ ឬវត្ថុជាប់ដោយកាយ ឈ្មោះថានិស្សគ្គិយប្បយោគ ជាប្រយោគធ្វើឲ្យគេស្លាប់ដោយគ្រវែង បោះ ពួយ ។

ក្នុងសាហត្ថិកនិងនិស្សគ្គិយប្បយោគទាំង ២ នេះ ចាត់ជាពីរ ៗ គឺ ចំពោះនឹងមិនចំពោះ ចំពោះនោះ បាននឹងភិក្ខុចំពោះអ្នកណា ហើយ ប្រហារខ្លួនឯងក្តី ឬបោះគ្រវែងទៅក្តី ត្រូវអ្នកនោះស្លាប់ ក៏ជាកម្មពន្ធ គ្រឿងចងនឹងកម្មតាមវត្ថុនោះ បើត្រូវអ្នកដទៃស្លាប់មិនជាកម្មពន្ធ ព្រោះ ថាចំពោះមនុស្សណា ត្រូវមនុស្សនោះស្លាប់ ទើបត្រូវបារាជិក ។ បើ ត្រូវមនុស្សដទៃ ឬ អមនុស្សនឹងតិរច្ឆាន មិនត្រូវអាបត្តិ ។ បើចំពោះ អមនុស្សនឹងតិរច្ឆាន ហើយអមនុស្សនឹងតិរច្ឆាននោះស្លាប់ ត្រូវថុល្លច្ច័យ នឹងបាចិត្តិយតាមវត្ថុ ។ បើត្រូវមនុស្ស ឬអមនុស្ស ឬតិរច្ឆានដទៃស្លាប់ មិនត្រូវអាបត្តិ ។ មិនចំពោះនោះគឺ ភិក្ខុមិនចំពោះ ដោយគិតថា នោះនរណា ៗ ក៏ដោយ ក៏ឲ្យស្លាប់ចុះ ហើយប្រហារឬបោះពួយទៅ បើត្រូវព្រះអរហន្ត ឬ មាតាបិតានៃខ្លួនស្លាប់ ជាអនន្តរិយកម្មផង ជា បារាជិកផង បើត្រូវអមនុស្ស ឬយក្ខ ប្រេត សត្វតិរច្ឆាន ស្លាប់ ត្រូវ អាបត្តិតាមវត្ថុនោះ ៗ ក្នុងប្រយោគដែលចំពោះនឹងមិនចំពោះ ២ នេះ អ្នកដែលភិក្ខុប្រហារនោះស្លាប់ក្នុងខណៈនោះ ឬមួយស្លាប់ខាងក្រោយ ដោយរោគនោះក្តី ជាកម្មពន្ធដល់ភិក្ខុអ្នកប្រហារក្នុងខណៈប្រហារនោះ ៗ

www.budinst.gov.kh www.elibraryofcambodia.org

ឯអាណត្តិកប្បយោគនោះ ជាប្រយោគកើតអំពីបង្គាប់ គឺកិច្ចបង្គាប់អ្នកដទៃថា "អ្នកចូរសម្លាប់បុគ្គលនេះៗ" ដូច្នេះ ក្នុងប្រយោគនេះត្រូវបរិបូណ៌ដោយនិយម ៦ យ៉ាងគឺ និយមវត្ថុ ១ និយមកាល ១ និយមឱកាស ១ និយមអាវុធ ១ និយមឥរិយាបថ ១ និយមកិរិយាវិសេស ១ ។ និយមវត្ថុនោះ គឺកំណត់បុគ្គលដែលខ្លួនសម្លាប់ គឺកំណត់បុគ្គលណា ហើយបង្គាប់ឲ្យសម្លាប់បុគ្គលនោះ អ្នកទទួលបង្គាប់សម្លាប់អ្នកនោះស្លាប់ ត្រូវអាបត្តិទាំងអ្នកបង្គាប់ទាំងអ្នកសម្លាប់ បើអ្នកសម្លាប់ ទៅសម្លាប់បុគ្គលដទៃដោយសំគាល់ថាបុគ្គលនោះ អ្នកបង្គាប់រួចទោស ។ និយមកាលនោះគឺកំណត់កាលមានវេលាព្រឹកជាដើម អ្នកសម្លាប់ ទៅសម្លាប់ក្នុងវេលាដទៃមានវេលាល្ងាចជាដើម ដូច្នេះខុសសង្កេត ។ និយមឱកាសនោះគឺកំណត់ទី ឲ្យសម្លាប់មនុស្សនៅក្នុងស្រុក ក្នុងភនជាដើម អ្នកសម្លាប់ទៅសម្លាប់ក្នុងទីដទៃ មានផ្ទះខ្លួនក្រៅភូមិជាដើម ក៏ខុសសង្កេត ។ និយមអាវុធនោះគឺកំណត់អាវុធ ឲ្យសម្លាប់ដោយដាវ លំពែង អ្នកសម្លាប់ទៅសម្លាប់ដោយអាវុធដទៃៗ មានស្នទីងឈើសំរួចជាដើម ក៏ខុសសង្កេត ។ និយមឥរិយាបថនោះ គឺកំណត់ឥរិយាបថ ឲ្យសម្លាប់មនុស្សឈរ មនុស្សដើរ អ្នកសម្លាប់ ទៅសម្លាប់មនុស្សអង្គុយ មនុស្សដេក ក៏ខុសសង្កេត ។ និយមកិរិយាវិសេសនោះ គឺកំណត់ការធ្វើពិសេស ឲ្យសម្លាប់ដោយចាក់ ឬកាប់ អ្នកសម្លាប់ទៅសម្លាប់ដោយកិរិយាដទៃ មានវាយ ឬអារកជាដើម

www.budinst.gov.kh www.elibraryofcambodia.org

ក៏ខុសសង្កេត ៗ ពាក្យដែលពោលថាខុសសង្កេតនោះ អ្នកបង្គាប់មិនត្រូវអាបត្តិ ត្រូវតែអ្នកសម្លាប់ បើត្រូវតាមសង្កេត ក៏ត្រូវអាបត្តិទាំង ២ នាក់ ៗ មួយទៀត បើអ្នកទទួលបង្គាប់នោះ ទៅសម្លាប់មិនបាន ហើយត្រឡប់មកប្រាប់ដល់អ្នកបង្គាប់ អ្នកបង្គាប់ត្រឡប់បង្គាប់ថែមជាថ្មីទៀតថា "បើអ្នកអាចសម្លាប់បានកាលណា ចូរសម្លាប់កាលណោះចុះ" ដូច្នេះ សូម្បីយូរដល់កប់រយឆ្នាំក្តី អ្នកសម្លាប់គង់នឹងសម្លាប់បានប្រាកដ អ្នកបង្គាប់ត្រូវអាបត្តិក្នុងខណៈបង្គាប់ អ្នកសម្លាប់ត្រូវអាបត្តិក្នុងខណៈសម្លាប់ៗ

ឯថាវរបយោគនោះថា ប្រយោគខ្ជាប់ខ្ជួន គឺភិក្ខុនឹងសម្លាប់អ្នកដទៃដោយគ្រឿងសម្លាប់ដ៏ខ្ជាប់ខ្ជួន បាននឹងជីកអណ្តូង ជីកអន្លុង នឹងគ្រឿងយន្ត នឹងដាក់កល់គ្រឿងសស្ត្រាវុធមាន ដាវ លំពែង ជាដើមទុក នឹងលាយថ្នាំពិសក្នុងបឹងនឹងស្រះ ទាំងអំបាលនេះជាដើម ដើម្បីនឹងឲ្យអ្នកដទៃដើរមកធ្លាក់ស្លាប់ ត្រូវស្លាប់ ក្រេបផឹកស្លាប់, ឬនាំយក រូបសំឡេង ក្លិនរស សម្ផស្ស ធម្មារម្មណ៍ ដែលគួរស្រឡាញ់ គួរខ្លាច ដើម្បីនឹងឲ្យអ្នកដទៃរីងស្ងួត ឬភ័យតក់ស្លុតស្លាប់, ឬដាក់អន្ទាក់នឹងអង្គប់ទុក អំបាលនេះឈ្មោះថា ថាវរបយោគ ៗ

មួយទៀត ភិក្ខុសរសេរសំបុត្រពណ៌នាសេចក្តីស្លាប់ថា "អ្នកណាស្លាប់ យ៉ាងនេះៗ នឹងបានលាភ បានយស បានទៅសុគតិ" ដូច្នេះ ក៏កប់បញ្ចូលក្នុងថាវរបយោគ ៗ ក្នុងថាវរបយោគនេះ ភិក្ខុចំពោះអ្នកណា បើ

www.budinst.gov.kh www.elibraryofcambodia.org

អ្នកនោះស្លាប់ ក៏ត្រូវអាបត្តិតាមវត្ថុនោះ បើអ្នកដទៃស្លាប់មិនត្រូវអាបត្តិ ។ បើភិក្ខុមិនចំពោះ គឺ គិតថា ខណៈណា ។ ក៏ចូរស្លាប់ចុះ ដូច្នេះ ក៏ត្រូវកម្មពន្ធ តាមវត្ថុដែលស្លាប់ គឺព្រះអរហន្ត ឬមាតាបិតានៃភិក្ខុនោះស្លាប់ ក៏ត្រូវអនន្តរិយកម្មផង ត្រូវបារាជិកផង បើមនុស្សដទៃ នឹងយក្ខ ប្រេត តិរច្ឆានស្លាប់ ក៏ត្រូវបារាជិក, ថុល្លច្ច័យ, បាចិត្តិយ, តាមវត្ថុនោះ ៗ ។ គ្រឿងដែលជា ថាវរប្បយោគនេះ ដូចអន្លាក់ នឹងសំប្រុតជាដើម អន្លាក់នឹងសំប្រុត ភិក្ខុឲ្យទៅគេទទេ ឬលក់ឲ្យគេ អ្នកដែលបានយកទៅដាក់តែងដាក់វែងជាថ្មី ក៏ត្រូវទោសទាំង ២ នាក់ បើភិក្ខុមានចិត្តក្តៅក្រហាយនឹងបាប ថាសត្វស្លាប់ជាច្រើនណាស់ យកមកអំពីទីណា ក៏យកទៅទុកដូចដើម ទើបរួចទោស បើគេទិញទៅ ក៏យកថ្លៃទៅទិញយកមកវិញ ទើបរួចទោស បើអន្លាក់ភិក្ខុធ្វើឯង សំប្រុតភិក្ខុសរសេរឯង យកមកដុតភ្លើងឲ្យអស់ ទើបរួចទោស បើដងអន្លាក់ភ្លើងឆេះមិនអស់ អ្នកដទៃមកកាន់យកទៅប្រហារអ្នកដទៃស្លាប់ ម្ចាស់ដើមក៏មិនរួចទោស សំប្រុតភ្លើងឆេះមិនអស់ អ្នកណាមួយយកមករៀបផ្គុំមើលដឹងសេចក្តី ហើយស្លាប់តាមសំប្រុតនោះ ម្ចាស់សំប្រុតដើមក៏មិនរួចទោស ។

ឯវិជ្ជាមយប្បយោគនោះថា ប្រយោគដ៏ហើយដោយវិជ្ជា គឺ ភិក្ខុកាយមន្ត អាគមផ្សេងៗ នឹងប្រើអំណាច ភូត បិសាច ណាៗ ក្តី ធ្វើឲ្យអ្នកដទៃចុកសៀតស្លាប់ ដូច្នេះឈ្មោះថាវិជ្ជាមយប្បយោគ ចំពោះអ្នកណា អ្នក

www.budinst.gov.kh www.elibraryofcambodia.org

នោះស្លាប់ មិនខុសសង្កេតមិនរួចទោស បើអ្នកដទៃស្លាប់ ខុសសង្កេតរួចទោស បើមិនចំពោះ ត្រូវអាបត្តិតាមវត្ថុដែលស្លាប់នោះ ។

ឯឥទ្ធិមយប្បយោគនោះថា ប្រយោគសម្រេចដោយឫទ្ធិដែលកើតអំពីកម្ម ដូចឫទ្ធិនាគ ឫទ្ធិគ្រុឌ ឫទ្ធិយក្ខ ឫទ្ធិទេវតា ឫទ្ធិព្រះរាជា បើភិក្ខុមានក្លុកជាអាគុង ទីងសំឡឹងមើលអ្នកណា ដោយចំណងនឹងឲ្យស្លាប់ បើអ្នកនោះស្លាប់ត្រូវអាបត្តិ ដោយឥទ្ធិមយប្បយោគ ។

មួយទៀត ភិក្ខុជីកអណ្តូងជាដើម ដើម្បីនឹងឲ្យសត្វធ្លាក់ស្លាប់ ក្នុងប្រយោគដែលជីកនោះ មិនត្រូវបាចិត្តិយ ត្រូវតែទុក្កដគ្រប់ៗប្រយោគ ព្រោះជាបុព្វប្បយោគនៃបាណាតិបាត បើជីកមិនចំពោះ សត្វណាៗមកធ្លាក់ចុះ គឺគង់ត្រូវទុក្កដ បើយក្ខ ប្រេត មានកាយជាតិរច្ឆាននឹងអមនុស្ស ឬតិរច្ឆានមានកាយជាមនុស្ស ឬសត្វតិរច្ឆានក្តី ធ្លាក់ចុះកើតទុក្ខវេទនា គឺត្រូវទុក្កដ បើមនុស្សធ្លាក់ចុះកើតទុក្ខវេទនា គឺត្រូវថុល្លច្ច័យ បើយក្ខជាដើមធ្លាក់ស្លាប់ គឺត្រូវថុល្លច្ច័យ បើមនុស្សធ្លាក់ស្លាប់ ត្រូវបារាជិក ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុមិនក្លែងនឹងឲ្យស្លាប់ ដូចអង្រែពីរផ្អែកដាក់គ្នា ភិក្ខុចាប់យកអង្រែ ១ អង្រែ ១ រលំសង្កត់ទារកស្លាប់ មិនត្រូវអាបត្តិ ភិក្ខុមិនដឹងថាគេនឹងស្លាប់ដោយហេតុនេះ ដូចភិក្ខុឲ្យបិណ្ឌបាត្រលាយដោយថ្នាំពិសដល់ភិក្ខុដទៃឆាន់ ភិក្ខុអ្នកឆាន់នោះស្លាប់ មិនត្រូវអាបត្តិ ភិក្ខុមិនមានចិត្តបំណងនឹងឲ្យស្លាប់ ដូចឲ្យគេសង្គ្រះដល់អ្នក

www.budinst.gov.kh www.elibraryofcambodia.org

ដរាបណាគេស្លាប់ មិនត្រូវអាបត្តិ ទីនកិច្ចគេជាដើម មិនត្រូវអាបត្តិ សិក្ខាបទនេះជាសាណត្តិកៈ ត្រូវព្រោះបង្គាប់មានអង្គ ៥ គឺ មនុស្ស-ជាតិកោបាណោ សត្វមានជាតិជាមនុស្ស ១ បាណសញ្ញិតា ដឹងថាសត្វមានជីវិត ១ វធកចិត្តំ ចិត្តបំណងនឹងសម្លាប់ ១ ឧបក្កមោ ព្យាយាមដោយប្រយោគតាំង ៦ ណាមួយ ១ តេន មរណំ សត្វនោះស្លាប់ដោយព្យាយាម ១ ព្រមដោយអង្គ ៥ នេះ ទើបត្រូវបារាជិក ។ សិក្ខាបទនេះជាអចិត្តសមុដ្ឋាន ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ទុក្ខវេទនា ។

តតិយបារាជិក ចប់

ឧត្តរិមនុស្សធម្មសិក្ខាបទ គំរប់ ៤ សេចក្តីថា ភិក្ខុណាមិនបានត្រាស់ដឹងឡើយ តែជាមនុស្សប្រាថ្នាលាភ ប្រាថ្នាសេចក្តីសរសើរ ហើយពោលអួតឧត្តរិមនុស្សធម្ម ដែលជាគ្រឿងអាចដឹងឃើញនៃព្រះអរិយៈជាម្ចាស់ បង្អោនចូលមកក្នុងខ្លួនដោយពាក្យកុហកថា "យើងដឹង យើងឃើញឧត្តរិមនុស្សធម្មដូច្នេះ ៗ" ដោយកាយ ឬ វាចា ឬ ទាំងកាយវាចា ដល់អ្នកដទៃជាមនុស្សជាតិ គេដឹងសេចក្តីក្នុងខណៈនោះ ត្រាក្រោយមានគេសាកសួរក្តី មិនមានគេសាកសួរក្តី ភិក្ខុនោះក៏ត្រូវបារាជិក ក្នុងខណៈអួតនោះ សូម្បីប្រាថ្នាសេចក្តីបរិសុទ្ធ គឺសឹកជាគ្រហស្ថជាដើម

www.budinst.gov.kh www.elibraryofcambodia.org

ហើយនិងក្រឡប់ប្ដូរថា “ខ្ញុំមិនដឹង មិនឃើញទេ ក្លែងនិយាយថាដឹង ថាឃើញ ខ្ញុំនិយាយកុហកបញ្ឆោតទេ” ដូច្នេះក៏មិនរួចពាស វៀវគសំគាល់ថាខ្លួនបានឧត្តរិមនុស្សធម្មនោះ ហើយពោលតាមសំគាល់នោះ មិនត្រូវអាបត្តិ ៗ

ឧត្តរិមនុស្សធម្មនោះ ជាធម៌នៃមនុស្សដ៏លើសលុប គឺមហគ្គតធម៌ និងលោកុត្តរធម៌ ៗ រូបាវចរជ្ឈាន ៤ គឺ បឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន, អរូបាវចរជ្ឈាន ៤ គឺ អាកាសានញ្ចាយតនជ្ឈាន វិញ្ញាណញ្ចាយតនជ្ឈាន អាកិញ្ចញ្ញាយតនជ្ឈាន នេវសញ្ញានាសញ្ញា-យតនជ្ឈាន, និងវិជ្ជា ៦ គឺ មនោមយិទ្ធិញាណ ការដឹងឫទ្ធិសម្រេចដោយចិត្ត គឺនិម្មិតកាយដទៃចេញពីកាយខ្លួន ឥទ្ធិវិធិញាណ ការដឹងផ្លែងឫទ្ធិផ្សេងៗ ទិព្វសោតញាណ ការដឹងដោយត្រចៀកទិព្វ ចេតោបរិយញាណ ការដឹងកំណត់ចិត្តអ្នកដទៃ បុព្វេនិវាសញាណ ការដឹងជាតិក្នុងកាលមុន ចុតូបបាតញាណ ការដឹងនូវចុតិ និងបដិសន្ធិនៃសត្វ អំពាលនេះជាមហគ្គតធម៌ ៗ សោតាបត្តិមគ្គ សោតាបត្តិផល សកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល អរហត្តមគ្គ អរហត្តផល ព្រះនិព្វាន អំពាលនេះ ជាលោកុត្តរធម៌ ៗ វិមោក្ខ ៣ គឺសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ អប្បណិហិតវិមោក្ខ, សមាធិ ៣ គឺ សុញ្ញតសមាធិ អនិមិត្តសមាធិ អប្បណិហិតសមាធិ, មគ្គភាវនា ៣៧ គឺ

www.budinst.gov.kh www.elibraryofcambodia.org

សតិបដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គ មានអង្គ ៨ ក្តី, បហានៈ ៣ គឺ លះរាគៈ លះទោសៈ លះមោហៈ, វិនីវរណតា ៣ គឺ ចិត្តប្រាសចាក រាគៈ ទោសៈ មោហៈ, និងវិជ្ជាគំរប់ ៣ គឺ អាសវក្ខយញ្ញាណ ទាំងអស់រាប់បញ្ចូលក្នុងមគ្គ ។ សមាបត្តិ ៣ គឺ សុញ្ញតសមាបត្តិ អនិមិត្តសមាបត្តិ អប្បណិហិតសមាបត្តិ អំបាលនេះជាឈ្មោះនៃផល ។ មហគ្គតធម៌ និងលោកុត្តរធម៌ ទាំងអំបាលនេះ ឈ្មោះថាឧត្តរិមនុស្សធម្ម ដ្បិតថាអ្នកណាបាន អ្នកនោះឈ្មោះថាប្រសើរជាងសាមញ្ញជន ឧត្តរិមនុស្សធម្មនេះ មិនមានក្នុងខ្លួន ភិក្ខុពោលថា យើងបានដល់បឋមជ្ឈានជាដើមក្តី យើងបានឥទ្ធិវិធញ្ញាណ ជាដើមក្តី និងពោលថាយើងបានសោតាបត្តិមគ្គ សោតាបត្តិផល ជាដើមក្តី យើងបានមគ្គ បានផល យើងជាព្រះសោតាបន្ន ជាដើមក្តី យើងជាព្រះអរិយៈ យើងលះរាគៈបានហើយជាដើមក្តី ពោលអួតឧត្តរិមនុស្សធម្មដូច្នេះ ដោយកាយ ឬវាចា កាលនឹងពោលក៏ដឹងថាខ្លួននឹងពោលកុហក កាលកំពុងពោល ក៏ដឹងថាខ្លួនកំពុងពោលកុហក ពោលអួតដល់អ្នកណា អ្នកនោះជាមនុស្ស ជាបព្វជិតក្តី ជាគ្រហស្ថក្តី ជាស្ត្រីក្តី ជាបុរសក្តី តែគេដឹងសេចក្តីក្នុងខណៈនោះ ថាលោកបានឈាន បានមគ្គ បានផល ជាដើម គេជឿថាពិតក្តី ថាមិនពិតក្តី ភិក្ខុនោះត្រូវបារាជិក បើអ្នកស្តាប់មិនដឹងដំណើរសេចក្តី ភិក្ខុនោះ

www.budinst.gov.kh www.elibraryofcambodia.org

ត្រូវថុល្លច្ច័យ បើតាស្រ័យខ្លួន តែពោលតាំងអ្នកដទៃថា អ្នកណានៅក្នុងវិហារ អ្នកនោះបានបឋមជ្ឈានជាដើម អ្នកស្តាប់ដឹងសេចក្តីក្នុងខណៈនោះ ភិក្ខុនោះត្រូវថុល្លច្ច័យ អ្នកស្តាប់មិនដឹងត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិក្នុងសិក្ខាបទនេះ គឺប្រាប់ដោយសំគាល់ថាខ្លួនបាន ខ្លួនដល់ ទឹងមិនមានប្រាថ្នាដើម្បីនឹងអួត ទឹងភិក្ខុឆ្កួតជាដើម មិនត្រូវអាបត្តិ ៗ សិក្ខាបទនេះ ជាអនាណត្តិកៈ មានអង្គ ៥ គឺ ឧត្តរិមនុស្សធម្មស្ស អត្តនិ អសន្តតា ១ ឧត្តរិមនុស្សធម៌មិនមានក្នុងខ្លួន ១ បាបិច្ឆតាយ តស្ស អារោចនំ អួតដោយប្រាថ្នាលាភ ប្រាថ្នាសេចក្តីសរសើរ ១ អនញ្ញាបទេសោ មិនតាំងអ្នកដទៃ ១ យស្ស អារោចេតិ តស្ស មនុស្សជាតិកតា ប្រាប់ដល់អ្នកណា អ្នកនោះជាមនុស្សជាតិ ១ តំ ខណំ វិជាននំ គេដឹងច្បាស់នូវសេចក្តីក្នុងខណៈនោះ ១ ព្រមដោយអង្គ ៥ នេះ ទើបត្រូវអាបត្តិបារាជិក បើមិនព្រមដោយអង្គ ៥ មិនត្រូវបារាជិក ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ។

ចតុត្ថបារាជិក ចប់

---

រួមបារាជិកទាំងអស់ ២៤ គឺមកក្នុងខ្មែរ ចំណែកភិក្ខុ ៤ ចំណែកខាងភិក្ខុនីដែលជាអសាធារណៈ ៤ ជា ៨ អភព្វបារាជិក ១១ គឺបណ្ឌក ៗ

www.budinst.gov.kh www.elibraryofcambodia.org

វេយ្យាសង្កាស មនុស្សល្មួចគេលួចសង្កាស ១ ភិក្ខុយកក្កុក: ភិក្ខុប្តូរ
ទៅកាន់លទ្ធិតិរ្ថិយ ១ តិរច្ឆាន ១ មាតុឃាត ១ បិតុឃាត ១ អរហន្ត-
ឃាត ១ សង្ឃភេទ ១ លោហិតុប្បាទ ១ ប្រទូស្តភិក្ខុនី ១ មាន
តាំងភេទស្រី ភេទប្រុស ១ ជា ១៩ នានភិក្ខុនីប្រាថ្នាភេទជាគ្រហស្ថ
សៀកសំពត់ដែលកំចឹកអម្ពូត់ ដោយអាការដូចជាគ្រហស្ថ ១ ជា ២០
នឹងអនុលោមបារាជិក ៤ គឺភិក្ខុមាននិមិត្តវែង ដាក់និមិត្តក្នុងទ្វារធ្ងន់របស់
ខ្លួនឯង ១ ភិក្ខុខ្នងទន់ ឱនចុះបៀមនិមិត្តរបស់ខ្លួនឯង ១ ភិក្ខុយកមាត់
បៀមអង្គជាតិប្រុសដទៃ ១ ភិក្ខុអង្គុយសង្កត់អង្គជាតិប្រុសដទៃ ១ ទើប
រួមជាបារាជិក ២៤ ដូច្នេះ ។

បារាជិកុទ្ទេស ចប់

## សង្ឃាទិសេសុទ្ទេស

សង្ឃាទិសេសសិក្ខាបទនៃភិក្ខុមាន ១៣ សេចក្ដីកសិក្ខាបទជា
បឋមនោះ សេចក្ដីថា ភិក្ខុមានសេចក្ដីត្រេក ក្នុងព្យាយាមក្នុងនិមិត្តខ្លួន
ឯង ដោយឧបាយណាមួយឲ្យសុក្កៈ គឺអសុចិឃ្លាតចាកឋាន ត្រូវអាបត្តិ
សង្ឃាទិសេស វៀរតែឃ្លាតចេញដោយយល់សប្តិ សុក្កៈមាន ១០ យ៉ាង
មានពណ៌លឿង ក្រហម ស ជាដើម ។ ភិក្ខុមានសេចក្ដីប្រាថ្នានឹងឲ្យ
ទឹកអសុចិណាមួយឃ្លាត ដោយចំណងឲ្យបាត់កេត នឹងឲ្យបានសេចក្ដី

www.budinst.gov.kh www.elibraryofcambodia.org

សុខជាដើមណាមួយក្តី ខំធ្វើព្យាយាមក្នុងនិមិត្តខ្លួនដោយដៃឯង ឬឲ្យអ្នកដទៃព្យាយាមក្នុងនិមិត្តខ្លួនក្តី ខំទំនោរគៀកនិមិត្តទុកដោយអវយវៈណាមួយក្តី ខំដេកផ្កាប់សង្កត់និមិត្តនឹងភ្លៅ ខំសំពត់ ឬ ពើងចង្កេះក្នុងអាកាសក្តី ដោយហោចទៅ សូម្បីដាក់និមិត្តក្នុងចន្លោះភ្លៅ ដោយគិតនឹងឲ្យអសុចិឃ្លាតចេញក្នុងកាលយល់សប្តិក្តី ហើយអសុចិឃ្លាតចេញតាក់ហាំងមិនច្រើនប៉ុន្មាន ល្មមតែរុយតូច ១ ក្រេបផឹកបាន ទោះមិនទាន់ចុះដល់ផ្លូវបស្សាវៈ ក៏ត្រូវសង្ឃាទិសេស ។

ក្នុងអដ្ឋកថា តាំងឧទាហរណ៍ទុកថា អសុចិឃ្លាតចេញតាក់ហាំងហើយ គង់នឹងចុះកាន់ប្រទ្វារបស្សាវៈប្រាកដ ព្រោះហេតុនោះ និមិត្តដែលអសុចិហូរចុះកាន់ផ្លូវបស្សាវៈ ហើយនឹងចេញមកខាងក្រៅក្តី មិនចេញក្តី ត្រូវសង្ឃាទិសេស បើភិក្ខុខំឲ្យឃ្លាតចេញ ហើយព្យាយាមដូចសំដែងមកនេះ អសុចិមិនបានឃ្លាតចេញ ត្រូវថុល្លច្ច័យ ។

វិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុមិនមានព្យាយាម ខំមិនមានបំណងឲ្យឃ្លាតចេញ យល់សប្តិឃើញជាប្រក្រតី អសុចិឃ្លាតចេញក្តី ភិក្ខុឆ្កួតជាដើមក្តី ទាំងអម្បាលនេះមិនត្រូវអាបត្តិ សិក្ខាបទនេះ ជាអនាណត្តិកៈ គឺបង្គាប់អ្នកដទៃឲ្យព្យាយាមក្នុងអង្គជាតិអ្នកដទៃនោះ មិនត្រូវសង្ឃាទិសេស មានអង្គ ៣ គឺ ចេតនា ចេតនាឲ្យឃ្លាតចេញ ១ ឧបក្កមោ ព្យាយាម ១ មោចនំ អសុចិឃ្លាតចេញ ១ ព្រម

ដោយអង្គ ៣ នេះ ទើបត្រូវសង្ឃាទិសេស សមុដ្ឋានវិធីជាដើម ដូច បឋមបារាជិក ។

សញ្ចេតនិកសិក្ខាបទ ជាបឋម ចប់

កាយសំសគ្គសិក្ខាបទ ជាគំរប់ ២ សេចក្តីថា ភិក្ខុណាមានចិត្ត តំរេក ដោយកាយសំសគ្គៈ បះបោសអង្អែលកាយមាតុគ្រាម គឺចាប់ដៃ ឬចាប់បៃសក់ ឬពាល់ត្រូវ បះបោសអង្អែលអវយវៈណាមួយនៃស្ត្រី មនុស្ស សូម្បីគេគគ្គីថ្ងៃនោះ ត្រូវសង្ឃាទិសេស ។ ខ្ទើយ ស្រីយក្ខ ស្រីប្រេត ជាវត្ថុនៃថុល្លច្ច័យ ។ តិរច្ឆានញី តិរច្ឆានឈ្មោល និងមនុស្សប្រុស ជាវត្ថុនៃទុក្កដ ។ រៀបនោះគឺ ចាប់សក់សុទ្ធក្តី និងលាយដោយវត្ថុដទៃ មានអំបោះនិងផ្កាឈើជាដើមក្តី គេចងគេទុកក្តី មិនចងគេទុកក្តី ឈ្មោះ ជារោម ព្រោះរោមសក់ក៏សង្គ្រោះជារោម ព្រោះហេតុនោះ ស្រិភិក្ខុ ដឹងថាជាស្រី ហើយពាល់ត្រូវដោយតំរេក ដោយហោចទៅតែរោម និងរោមប៉ះពាល់គ្នា គឺស្រីមកពាល់ភិក្ខុ ភិក្ខុមានតំរេក ព្យាយាមទទួល សម្ផស្ស ត្រូវសង្ឃាទិសេស ។ បើស្រី ភិក្ខុសង្ស័យថាស្រី ឬមិនមែនស្រី ឬសំគាល់ថាជាខ្ទើយ ជាប្រុស ជាតិរច្ឆានក្តី ហើយចាប់ពាល់ ឬ ពាល់ត្រូវដោយវត្ថុជាប់ដោយកាយខ្លួន ឬពាល់វត្ថុជាប់ដោយកាយស្រី មានសំពត់ស្បៀក សំពត់ដណ្តប់ជាដើម ដោយកាយខ្លួន ឬពាល់ត្រូវ

www.budinst.gov.kh www.elibraryofcambodia.org

ស្រីអមនុស្ស នឹងខ្ទើយ ដោយជំពាក អម្បាលនេះ ត្រូវថុល្លច្ច័យ ទាំងអស់ ៗ ភិក្ខុពាល់ត្រូវវត្ថុជាប់ដោយកាយស្រី ដោយវត្ថុជាប់ដោយកាយខ្លួន ឬស្រីបោះរបស់មក ភិក្ខុបោះរបស់ទទួល ឬពាល់ត្រូវខ្ទើយដោយវត្ថុជាប់នឹងកាយខ្លួនជាដើម ឬខ្ទើយ ភិក្ខុសង្ស័យ ឬសំគាល់ថាជាស្រី ថាជាប្រុសជាដើម ឬប្រុស ភិក្ខុសំគាល់ថាជាស្រី ជាខ្ទើយ ជាតិរច្ឆាន ឬសង្ស័យក្តី ហើយមានដំរេកពាល់ត្រូវកាយនឹងកាយនៃខ្ទើយជាដើមនោះក្តី ពាល់របស់ដែលជាប់នឹងកាយនោះក្តី បោះរបស់ទទួលគ្នាក្តី អម្បាលនេះ ត្រូវទុក្កដទាំងអស់ ៗ គឺឯអាបត្តិគិច ច្រើន ឲ្យរាប់តាមវត្ថុនឹងប្រយោគដែលពាល់ត្រូវ ភិក្ខុចាប់រួបដៃស្រីទុក ពាល់ត្រូវក្នុងទីនោះ ១ ថ្ងៃដរាបដល់ល្ងាចក្តី ឬមិនចាប់ទុក ស្ទាបពីក្បាលរហូតដល់ជើង មិនឲ្យដៃហួសខ្លួនឡើយ ឬរូបម្រាម ៥ ជាមួយគ្នាក្តី ទាំងអម្បាលនេះ ត្រូវអាបត្តិតែ ១ បើវត្ថុផ្សេង ៗ គ្នា ហើយរូបម្រាមទាំង ៥ ក៏ត្រូវអាបត្តិ ៥ ៗ

ឯវិធីដែលមិនត្រូវ អាបត្តិនោះ គឺស្រីមកពាល់ភិក្ខុ ភិក្ខុមានដំរេក តែមិនព្យាយាមដោយកាយ នោះដឹងសម្ផស្សក្តី ឬប្រាថ្នានឹងឲ្យរួច ហើយច្រានទៅ ឬពាល់ដោយមិនក្លុងក្តី មិនដឹងខ្លួនក្តី មិនមានស្មារតីក្តី មិនមានដំរេកក្តី ភិក្ខុឆ្កួតជាដើមក្តី អម្បាលនេះមិនត្រូវអាបត្តិ ៗ សិក្ខាបទនេះ ជាអនាណត្តិកៈ មានអង្គ ៥.គឺ មនុស្សិត្ថី ស្រីមនុស្ស ១ ឥត្ថីសញ្ញិតា សំគាល់ថាជាស្រី ១ កាយសំសគ្គរាគោ

www.budinst.gov.kh www.elibraryofcambodia.org

ឈោងដោយកាយសំសគ្គៈ ១ គេច រាគេច កយាមោ ព្យាយាម មេថុនរេកនោះ ១ ហត្ថគ្គាហាទិសមាបជ្ជំ ចាប់ដៃជាដើម ១ ាមដោយអត្ថ៥នេះ ទើបត្រូវសង្ឃាទិសេស សមុដ្ឋានវិធីជាដើម ចបឋមបារាជិក ។

កាយសំសគ្គសិក្ខាបទ គំរប់ ២ ចប់

ទុដ្ឋុល្លវាចសិក្ខាបទគំរប់ ៣ សេចក្តីថា ភិក្ខុមានចិត្តដំរេកត្រេកអរ ហើយនិយាយនឹងស្ត្រី ដោយពាក្យអាក្រក់ប្រកបដោយមេថុន ដូចប្រុសកម្លោះនិយាយចំពោះស្រីក្រមុំ ស្រីដឹងសេចក្តីក្នុងខណៈនោះ ត្រូវសង្ឃា-ទិសេស ស្រីមនុស្ស ដែលដឹងពាក្យអាក្រក់ ល្អ ប្រកបដោយមេថុន ឈ្មោះវត្ថុឲ្យកើតសង្ឃាទិសេស ។ ឯវត្ថុឲ្យកើតថុល្លច្ច័យ ទីង៏ឲ្យកើតទុក្កដ ដូចក្នុងសិក្ខាបទមុន ។ ពាក្យពោលដែលអាស្រ័យទ្វារធ្ងន់ ទ្វារស្រាល និងអាស្រ័យមេថុនក្នុងរូបស្ត្រី អំពាលនេះឈ្មោះថាពាក្យអាក្រក់ ពាក្យទន់ទាប ជាទីតាំងនៃសង្ឃាទិសេស ។ ក្នុងកាយស្ត្រី តាំងអំពីដងកាំបិតចុះទៅ អំពីជង្គង់ឡើងមក ជាទីតាំងនៃថុល្លច្ច័យ ។ អវយវៈ ក្រៅនោះជាទីតាំងនៃទុក្កដ ។ អាការៈដែលនឹងពោលទុដ្ឋុល្លវាចា មាន ៩ គឺសរសើរ និងតិះដៀលទ្វារធ្ងន់ ទ្វារស្រាលនៃស្ត្រី, សូមមេថុនដោយពាក្យអង្វរថា កាលណាហើយនឹងបានមេថុនធម្មជាមួយនាង, សួរថានាងឲ្យមេថុនធម្ម

www.budinst.gov.kh www.elibraryofcambodia.org

ផលសហាយ ផលប្តីនាងដូចម្តេច, បានឮថា នាងឲ្យមេចុងធម្មផល សហាយ ផលប្តី ដូច្នេះ, ឬប្រដៅថា នាងឲ្យមេចុងដូច្នេះៗ ទើប សហាយ មិនប្តីនាងស្រឡាញ់, គិតដោះថា មេមានសិទ្ធរណី គឺសាច់ ដុះ, មេមានទ្វារធ្ងន់ ទ្វារស្រាលជាប់គ្នា, មេមានទាំងនិមិត្តស្រី និមិត្ត ប្រុស, អាការៈនៃពាក្យពោលទាំង ៩ នេះ ពាក្យណាមួយ គិតដឹងថា ជាស្រី មានសេចក្តីផែក ធ្វើដោយកាយវិការណាមួយ ឬពោល ដោយវាចាក្តី ស្រីដឹងសេចក្តីក្នុងខណៈនោះ ត្រូវសង្ឃាទិសេស ៗ បើ ស្រីមិនដឹងសេចក្តីក្នុងខណៈនោះ ត្រូវថុល្លច្ច័យ ៗ ស្រី គិតសង្ស័យក្តី សំគាល់ថាជាបណ្ឌក ជាបុរស ជាតិរច្ឆានក្តី ឬបណ្ឌក ដឹងថាជាបណ្ឌក ក្តី ហើយពោលទុដ្ឋុល្លវាចា ដូច្នេះ ត្រូវថុល្លច្ច័យ ៗ បណ្ឌកគិតសង្ស័យ ឬសំគាល់ថា ជាបុរស ជាតិរច្ឆាន ជាស្រីក្តី ប្រុស ឬ តិរច្ឆាន គិត សំគាល់ខុសក្តី ត្រូវក្តី ហើយពោលទុដ្ឋុល្លវាចា ដូច្នេះ ត្រូវទុក្កដ ៗ ពោល ចំពោះអវយវៈស្រី អំពីដងកាំបិត ចុះទៅ អំពីជង្គង់ ឡើងមកក្តី និង ពោលចំពោះទ្វារធ្ងន់ ទ្វារស្រាល នៃបណ្ឌកក្តី ត្រូវថុល្លច្ច័យ ៗ ពោល ចំពោះអវយវៈស្រី អំពីដងកាំបិតឡើងទៅ ខាងក្រោមអំពីជង្គង់ចុះទៅក្តី ពោលចំពោះអវយវៈទាំងពួង នៃបណ្ឌកជាដើមក្តី ពោលចំពោះរបស់ ជាប់នឹងកាយ ត្រូវទុក្កដ ៗ ឯត្រូវអាបត្តិតិច-ច្រើន ឲ្យរាប់តាម និងពាក្យដែលពោល ៗ

www.budinst.gov.kh www.elibraryofcambodia.org

វិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុធ្វើអត្ថជាប្រធានក្តី ធ្វើធម៌ជាប្រធានក្តី ធ្វើពាក្យទូន្មានជាប្រធានក្តី ពោលដោយមិនមានដំរេក ភិក្ខុឆ្កួតជាដើមក្តី អម្បាលនេះមិនត្រូវអាបត្តិ ជាអនាណត្តិកៈ មាន ៤ គឺ មនុស្សិត្ថី ស្រីមនុស្ស១ ឥត្ថីសញ្ញិតា ដឹងថាជាស្ត្រី១ ទុដ្ឋុល្លវាចស្សាទរាគោ ដំរេកក្នុងការពោលពាក្យអាក្រក់១ តេន ច ឱភាសនំ ពោលតាមសេចក្តីដំរេកនោះ១ តំ ខណំ វិជាននំ ស្រីដឹងសេចក្តីក្នុងខណៈនោះ១ ព្រមដោយអង្គ ៥ នេះទើប សង្ឃាទិសេស សមុដ្ឋានវិធីជាដើម ដូចអទិន្នាទាន ប្លែកតែមាន ឆាតិ ។

ទុដ្ឋុល្លវាចសិក្ខាបទ គំរប់ ៣ ចប់

អត្តកាមបារិចរិយសិក្ខាបទគំរប់ ៤ សេចក្តីថា ភិក្ខុណាមានចិត្ត ក ហើយពោលសរសើរការបំរើដោយកាមដើម្បីខ្លួន ក្នុងទីជិតស្រី យពាក្យប្រកបដោយមេថុនថា ម្នាលប្អូនស្រី បើស្រីណាបំរើអ្នក សីលមានធម៌ល្អ ប្រព្រឹត្តព្រហ្មចរិយដូចយើងនេះ ដោយមេថុនធម្ម តាបំរើនោះ ជាកំពូលនៃការបំរើទាំងពួង ដូច្នេះ បើស្រីដឹងសេចក្តី ខណៈនោះ ត្រូវសង្ឃាទិសេស សិក្ខាបទនេះ មានអង្គ ៥ គឺ មនុស្សិត្ថី ស្រីមនុស្ស១ ឥត្ថីសញ្ញិតា សំគាល់ថាស្រី១

អត្តកាមបារិចរិយាយ ភគោ ត្រេកអរនឹងការបំរើដោយកាម ដល់ខ្លួន ១ គេ២ ភគេ២ វណ្ណភណង់ ពោលសរសើរដោយ ដំរែកនោះ ១ គំ ១ណាំ វិជាធំ ស្រីដឹងសេចក្ដីក្នុងខណៈនោះ ១ វិញ្ញូយក្រោយនោះ ដូចសិក្ខាបទមុន ប្លែកតែសិក្ខាបទនេះ ជាដោយសេចក្ដី សរសើរ ការបំរើដោយមេថុន ១ យ៉ាងប៉ុណ្ណោះ ។

អត្តកាមបារិចរិយសិក្ខាបទ គំរប់ ៤ ចប់

សញ្ចរិត្តសិក្ខាបទគំរប់ ៥ សេចក្ដីថា ភិក្ខុណាដល់នូវសញ្ចរិត្ត គឺ ប្រព្រឹត្តធ្វើជាមេអណ្ដើក ប្រាប់សេចក្ដីប្រាថ្នារបស់ប្រុសដល់ស្រី ប្រាប់ សេចក្ដីប្រាថ្នារបស់ស្រីដល់ប្រុស ដើម្បីនឹងឲ្យបានគ្នាជាប្ដីប្រពន្ធ ដោយ ហោចទៅ សូម្បីប្រាប់ដល់ស្រីពេស្យា នឹងគប្បីបានសង្វាសក្នុងមួយ ខណៈប៉ុណ្ណោះក្ដី ត្រូវសង្ឃាទិសេស ស្រី ប្រុស ជាជាតិមនុស្ស មិនមែន ប្រេត មិនមែនយក្ខ ជាគ្រហស្ថក្ដី ជាបព្វជិតក្ដី គេមិនទាន់បានគ្នាជា ប្ដីជាប្រពន្ធ ឬជាប្ដីជាប្រពន្ធហើយ ប៉ុន្តែលែងគ្នាហើយ ដោយហោចទៅ សូម្បីមាតាបិតានៃភិក្ខុនោះក្ដី អម្បាលនេះជាវត្ថុនៃសញ្ចរិត្ត អង្គនៃការ ធ្វើសញ្ចរិត្តនោះមាន ៣ គឺ បដិគ្គណ្ហាតិ ស្រីឬប្រុសឬមាតារបស់ស្រី ឬប្រុសពឹងភិក្ខុឲ្យមកប្រាប់ដល់ស្រី ឬប្រុសពឹងឲ្យមកប្រាប់មាតាបិតានៃ ស្រី ឬប្រុសណាមួយ ភិក្ខុទទួលពាក្យគេជាអង្គ ១ វីមំសតិ គេពឹង

www.budinst.gov.kh www.elibraryofcambodia.org

ឲ្យប្រាប់អ្នកណា ភិក្ខុប្រាប់អ្នកនោះថា អ្នកចូរជាប្តីជាប្រពន្ធគ្នា ជាសហាយនឹងគ្នាក្តី ជាអង្គ ១ បដិហារតិ អ្នកណាពឹងឲ្យទៅ ភិក្ខុត្រឡប់មកប្រាប់ដល់អ្នកនោះវិញជាអង្គ ១ គេបានគ្នាជាប្តីជាប្រពន្ធក្តី ជាសហាយក្តី មិនបានក្តី នោះមិនមែនជាហេតុ កាលបើព្រមដោយអង្គ ៣ ក៏ត្រូវសង្ឃាទិសេស ៗ បើបានតែអង្គ ២ គឺទទួលនឹងប្រាប់ ឬប្រាប់ហើយត្រឡប់មកប្រាប់ ណាមួយ ត្រូវថុល្លច្ច័យ ៗ បើបានតែអង្គ ១ គឺទទួលឬប្រាប់ឬត្រឡប់មកប្រាប់ ណាមួយ ត្រូវទុក្កដ ៗ បើប្រុសពឹងភិក្ខុឲ្យប្រាប់ដល់ស្រីដែលមាតារក្សា ភិក្ខុទៅប្រាប់ដល់ស្រីដែលបិតារក្សា វត្ថុៈ ខុសសង្កេត មិនត្រូវសង្ឃាទិសេស ភិក្ខុនាំសញ្ចរិត្តដល់បណ្ឌកៈ ត្រូវថុល្លច្ច័យ ៗ

វិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុនាំដំណើរសង្ឃ ដំណើរចេតិយ ដំណើរភិក្ខុឈឺក្តី ភិក្ខុឆ្កួតជាដើមក្តី មិនត្រូវអាបត្តិ សិក្ខាបទនេះ ជាហណត្តិកៈ ត្រូវព្រោះភិក្ខុទទួលពាក្យគេហើយ ប្រើឲ្យអ្នកដទៃទៅប្រាប់ដល់ស្រីឬប្រុស ឬប្រាប់ហើយនឹងប្រើអ្នកដទៃ ឲ្យត្រឡប់មកប្រាប់ដល់អ្នកពឹងវិញក្តី គង់ត្រូវអាបត្តិ ៗ មានអង្គ ៥ គឺ យេសុ បញ្ញត្តិំ សមាបជ្ជតិ តេសំ មនុស្សជាតិកតា នាំបញ្ចរិត្តកម្មអ្នកណា អ្នកនោះជាជាតិមនុស្ស ១ ន នាលំវចនីយតា គឺមិនមែនជាប្តីជាប្រពន្ធនឹងគ្នាអំពីមុន ឬជាប្តីប្រពន្ធហើយ តែលែងគ្នា

www.budinst.gov.kh www.elibraryofcambodia.org

ហើយ ១ បដិគ្គណ្ហាតិ ទទួលពាក្យគេ ១ វីមំសតិ ប្រាប់តាមគេផ្តាំ ១ បច្ចាហរណាតិ ត្រឡប់មកប្រាប់ដល់អ្នកពីន ១ ព្រមដោយអង្គ ៥ នេះ ទើបត្រូវសង្ឃាទិសេស មានសមុដ្ឋាន ៦ គឺ ភិក្ខុមិនដឹងបញ្ញត្តិ ឬមិនដឹងថាគេលែងគ្នាដាច់ហើយ ទឹងទទួលពាក្យបណ្តាំគេ ដោយកាយវិការមានញាក់មុខជាដើម ទឹងប្រាប់ដោយកាយវិការ ត្រឡប់មកប្រាប់ដោយកាយវិការ ដូច្នេះ នេះអាបត្តិកើតដោយកាយ ១ យ៉ាង ។ ភិក្ខុអង្គុយនៅ ប្រុសមកផ្តាំទុកថា ស្រីនេះទឹងមករកអ្នក អ្នកចូរដឹងចិត្តគេ ភិក្ខុទទួលពាក្យថា អើប្រពៃហើយ លុះស្រីមក ភិក្ខុក៏ប្រាប់ លុះប្រុសត្រឡប់មកទៀត ភិក្ខុក៏ប្រាប់ ដូច្នេះ អាបត្តិកើតអំពីវាចា ១ យ៉ាង ព្រោះភិក្ខុមិនបានធ្វើត្រណាដោយកាយ ។ មួយទៀត ភិក្ខុទទួលពាក្យរបស់ប្រុសដោយវាចា ហើយទៅកាន់ផ្ទះរបស់ស្រីដោយកិច្ចដទៃ ឬថាទៅក្នុងទីដទៃ ទៅជួបទឹងស្រីនោះ ហើយក៏ប្រាប់ដល់ស្រីនោះ ដោយវចីភេទ ហើយក៏ទៅដោយហេតុដទៃទៀត ត្រឡប់មកជួបទឹងប្រុសនោះហើយ ក៏ចូលទៅប្រាប់ដល់ប្រុសនោះ ដូច្នេះឈ្មោះថាកើតអំពីវាចា ១ យ៉ាង ។ ភិក្ខុមិនដឹងបញ្ញត្តិ សូម្បីជាព្រះឱណាស្រេចបិតាប្រើទៅហើយ លោកទៅប្រាប់ដល់មាតាដែលលែងគ្នាដាច់ហើយថាអ្នកចូរត្រឡប់មកបំរើបិតាចុះ ហើយត្រឡប់មកប្រាប់ដល់បិតាវិញដូច្នេះ អាបត្តិកើតអំពីកាយវាចា ៣ នេះឈ្មោះថា អចិត្តកសមុដ្ឋាន ភិក្ខុដឹងក្តី

www.budinst.gov.kh www.elibraryofcambodia.org

មិនដឹងក្តី ក៏ត្រូវអាបត្តិ ។ ភិក្ខុដឹងបញ្ញត្តិ ឬដឹងថា គេលែងគ្នាដាច់ហើយ នឹងតាំងសញ្ចរិត្តដោយន័យទាំង ៣ យ៉ាងនោះ សមុដ្ឋាន ៣ នេះ ឈ្មោះថាសចិត្តកសមុដ្ឋាន ព្រោះចិត្តដែលដឹងបញ្ញត្តិ នឹងដឹងថា លែងគ្នាដាច់ហើយ ឈ្មោះថាមានសមុដ្ឋាន ៦ ដូច្នេះ ជាកិរិយាត្រូវព្រោះធ្វើ នោសញ្ញាវិមោក្ខ មិនរួចដោយសំគាល់ ជាអចិត្តកៈ ដឹងក្តី មិនដឹងក្តី ក៏ត្រូវអាបត្តិ ជាបណ្ណត្តិវជ្ជៈ មានទោសតែបណ្តាំគប្បីវៀរតាមបញ្ញត្តិ ជាកាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ។

សញ្ចរិត្តសិក្ខាបទ គំរប់ ៥ ចប់

កុដិការសិក្ខាបទគំរប់ ៦ សេចក្តីថា ភិក្ខុធ្វើឯង ឬប្រើគេឲ្យធ្វើនូវកុដិ លាបដោយកំបោរនឹងដីស្អិត ខាងក្នុងដំបូល ឬក្រៅដំបូល ឬទាំងខាងក្នុងខាងក្រៅ ដោយគ្រឿងឧបករណ៍ មានកាំបិតនឹងពូថៅជាដើម ដែលសូមគេមកដោយខ្លួនឯង ជាកុដិមិនមានអ្នកណាជាម្ចាស់របស់ ចំពោះជាទីលំនៅនៃខ្លួន គប្បីធ្វើឲ្យត្រូវប្រមាណ គឺបណ្តោយ ១២ ចំអាម ទទឹង ៧ ចំអាម ដោយចំអាមព្រះសុគត កុំកស់ខាងក្រៅ ឲ្យកស់ចំណែកខាងក្នុងជញ្ជាំង ភិក្ខុគប្បីជម្រះទីនោះឲ្យល្អ ហើយទៅនិមន្តភិក្ខុមកអំពីសង្ឃ ឲ្យមកមើលទីដែលប្រកបដោយសេចក្តីប្រារព្ធ គឺអន្តរាយ គឺជាទីលំនៅនៃស្រមោចក្រហមស្រមោចខ្មៅជាដើម ឬមិន

www.budinst.gov.kh www.elibraryofcambodia.org

ដែលជាទីប្រកបដោយប្រាកព្ទ ឬជាទីល្មមបន្ទិលរទេះ នឹងដណ្តើរបាន ដោយជុំវិញ ឬបន្ទិលមិនបាន ភិក្ខុមកអំពីសង្ឃឃើញថាទីមិនមាន ប្រាកព្ទ ល្មមបន្ទិលរទេះ បន្ទិលដណ្តើរបានដោយជុំវិញ ហើយសោត ឲ្យ ភិក្ខុម្ចាស់របស់នាំភិក្ខុទាំងឡាយមកអំពីសង្ឃ ដើម្បីឲ្យសំដែងទីឲ្យ ថា ជាទីមិនមានសេចក្តីប្រាកព្ទ ឬល្មមបន្ទិលដណ្តើរនឹងរទេះបាន បើភិក្ខុ ជាម្ចាស់របស់នោះ មិននាំភិក្ខុមកសំដែងទីឲ្យ ឬធ្វើឲ្យហួសប្រមាណ ឯណានីមួយ ក្នុងប្រយោគដែលធ្វើទាំងពួង ត្រូវទុក្កដ នៅសល់ កំបោរ ២ ដុំទៀតនឹងហើយ ក្នុងដុំជាបឋមត្រូវថុល្លច្ច័យ ដុំជាគំរប់ ២ ស្រេចការ ត្រូវសង្ឃាទិសេស ធ្វើក្នុងទីប្រកបដោយប្រាកព្ទនឹងបន្ទិល រទេះដណ្តើរមិនបាន ត្រូវទុក្កដ ។

(១២ ចំអាមព្រះសុគត ត្រូវជា ៨ ហត្ថ ១១ ធ្នាប់ ២ ក្បៀសជាង ឈើសព្វថ្ងៃនេះ ។ ៧ ចំអាមព្រះសុគត ត្រូវជា ៤ ហត្ថ ១ ចំអាម ៤ ធ្នាប់ ៣ ក្បៀស នឹង ២ អនុក្បៀស ជាងឈើសព្វថ្ងៃនេះ) សិក្ខាបទនេះ មានអង្គ ៧ គឺ ឧល្លិត្តាជីធំ អញ្ញតរតា លាបបូក ខាងក្នុង ឬខាងក្រៅជាដើមណាមួយ ១ ហេដ្ឋិមប្បមាណសម្ភវេ មិនបានប្រកបដោយប្រមាណខាងក្រោម ១ អទេសិតវត្ថុកតា សង្ឃមិនបានសំដែងទីឲ្យ ១ បមាណាតិក្កន្តតា ធ្វើហួសប្រមាណ ១

www.budinst.gov.kh www.elibraryofcambodia.org

អត្តុទ្ទេសិកា ចំពោះខ្លួន ១ កំសាការតា កុដិជាទីលំនៅ ១ លេបឃដនា លាបជាប់គ្នាតាំងពីបូលទឹងជញ្ជាំង ១ សមុដ្ឋានវិធីជាដើម ដូចពោលហើយក្នុងសញ្ចរិត្តសិក្ខាបទ ។

កុដិការសិក្ខាបទ គំរប់ ៦ ចប់

មហល្លកសិក្ខាបទគំរប់ ៧ សេចក្តីថា ភិក្ខុធ្វើខ្លួនឯង ឬប្រើអ្នកដទៃឲ្យធ្វើ នូវវិហារធំមិនមានប្រមាណ មានអ្នកដទៃជាម្ចាស់របស់ចំពោះជាទីនៅរបស់ខ្លួន គប្បីនាំភិក្ខុទាំងឡាយមកសំដែងទីឲ្យ បើមិននាំភិក្ខុមកឲ្យសំដែងទីឲ្យសោត ភិក្ខុធ្វើស្រេចការត្រូវសង្ឃាទិសេស សេចក្តីក្រៅនោះដូចសិក្ខាបទមុន វៀរតែសិក្ខាបទនេះ មិនមានប្រមាណប៉ុណ្ណោះ ។

មហល្លកសិក្ខាបទ គំរប់ ៧ ចប់

អមូលកសិក្ខាបទជាគំរប់ ៨ សេចក្តីថា ភិក្ខុណាមានសេចក្តីក្រោធប្រទុស្តនឹងភិក្ខុផងគ្នា ហើយក្លែងចោទដោយបារាជិកទាំង ៤ ណាមួយ មិនមានមូល ដោយបំណងរកហេតុនឹងឲ្យភិក្ខុនោះវិនាសចាកព្រហ្មចរិយៈ គ្រាក្រោយមានគេសាកសួរក្តី មិនមានគេសាកសួរក្តី អធិករណ៍នោះមិនមានមូលប្រាកដហើយ តែភិក្ខុនោះខឹងប្តេជ្ញាថាយើងនិយាយកុហក ក៏ត្រូវសង្ឃាទិសេស ក្នុងខណៈចោទនោះ ៗ បារាជិកមិនមានមូលនោះ គឺមិនបានឃើញដោយភ្នែកប្រក្រតី ឬភ្នែកទិព្វ មិនបានឮដោយត្រចៀកប្រក្រតី ឬត្រចៀកទិព្វ មិនបានរង្កៀសដោយចិត្តថា ភិក្ខុនោះត្រូវ

www.budinst.gov.kh www.elibraryofcambodia.org

បារាជិកតាំង ៤ ណាមួយ ដោយខ្លួនបានឃើញអាការៈ ឬបានឮសំឡេង នឹងធំក្ទិនណាមួយ ដែលគួរនឹងរង្កៀស អម្បាលនេះឈ្មោះថាមិនមានមូល ពោលដោយសង្ខេប ទោសនោះមាន ៤ គឺ ទោសដោយបង្អុលវត្ថុ ១ បង្អុលអាបត្តិ ១ ឃាត់សង្វាស ១ ឃាត់សាមីចិកម្ម ១ ត្រូវជា ៤ ទោសថា “លោកសេពមេថុនជាដើម” ដូច្នេះ ឈ្មោះថាបង្អុលវត្ថុ ទោសថា “លោកត្រូវអាបត្តិព្រោះមេថុនធម្ម” ជាដើម ដូច្នេះឈ្មោះថាបង្អុលអាបត្តិ ទោសថា “នឹងធ្វើឧបោសថ បវារណា សង្ឃកម្មជាមួយលោកមិនបាន” នេះឈ្មោះថា ទោសដោយឃាត់សង្វាសដោយគ្រាន់តែឃាត់សង្វាសប៉ុណ្ណោះ នៅមិនទាន់ត្រូវអាបត្តិទេ លុះតែពោលពាក្យថា “លោកមិនជាសមណៈជាដើម” មកតនឹងចុងពាក្យមុនថា នឹងធ្វើឧបោសថ បវារណា សង្ឃកម្ម ជាមួយលោកមិនបានទើបត្រូវអាបត្តិ ។ បើមិនធ្វើអភិវាទនឹងក្រោកទៅទទួលនឹងអញ្ជលិកម្មនឹងសាមីចិកម្មមានបក់ជាដើម ដូច្នេះ ឈ្មោះថាទោសដោយឃាត់សាមីចិ-កម្ម ដូច្នេះនេះ ឲ្យគប្បីដឹងកន្លងវេលាដែលភិក្ខុធ្វើអភិវាទជាដើម ដោយលំដាប់ ហើយមិនធ្វើដល់ភិក្ខុ ១ អង្គ រំលងទៅធ្វើដល់ភិក្ខុដ៏សេស ដូច្នេះឈ្មោះថាទោស ប៉ុន្តែនៅមិនទាន់ត្រូវអាបត្តិទេ លុះតែភិក្ខុដែលគេមិនសំពះនោះសួរថា “ហេតុដូច្នេះម្តេចបានជាអ្នកមិនធ្វើអភិវាទជាដើមដល់យើង ហើយភិក្ខុពោលពាក្យថា លោកមិនជាសមណៈជាដើម បន្ត

www.budinst.gov.kh www.elibraryofcambodia.org

មកទៀត ទើបត្រូវអាបត្តិ ៗ ភិក្ខុចោទបុគ្គលណា ដែលបានឧប-
សម្បទាហើយជាអ្នកបរិសុទ្ធ មិនបរិសុទ្ធ ចោទដោយបារាជិកាបត្តិ
ណា ដឹងថាបុគ្គលនោះ មិនត្រូវបារាជិកាបត្តិនោះ មានបំណងនឹង
ឲ្យភិក្ខុនោះឃ្លាតចាកព្រហ្មចរិយៈ មិនឲ្យភិក្ខុធ្វើឱកាសដោយពាក្យថា
ករោតុ មេ អាយស្មា ឱកាសំ អហន្តំ វត្តុកាមោ
ប្រែថា លោកដ៏មានអាយុចូរធ្វើឱកាសដល់ខ្ញុំ ខ្ញុំចង់និយាយនឹងលោក
ដូច្នេះ ជាមុនហើយចោទ បើភិក្ខុនោះ ដឹងសេចក្តីក្នុងខណៈនោះ
ថាគេចោទខ្លួនដូច្នេះ ត្រូវសង្ឃាទិសេសផង ត្រូវទុក្កដផង គ្រប់ៗ
ពាក្យដែលចោទ បើអ្នកចោទឲ្យអ្នកត្រូវចោទនោះ ធ្វើឱកាសដល់ខ្លួន
មុនហើយ ទើបចោទត្រូវសង្ឃាទិសេសតែមួយយ៉ាង សូម្បីភិក្ខុចោទ
ចំពោះមុខដោយកាយវិការណាមួយ ក៏ដូចគ្នា ភិក្ខុចោទក្នុងទីកំបាំងមុខ
មិនជាប្រធាននៃអាបត្តិ ភិក្ខុបង្គាប់អ្នកដទៃដែលនៅជិតខ្លួនឲ្យចោទ អ្នក
ទទួលបង្គាប់ ទៅចោទអ្នកនោះតាមពាក្យអ្នកប្រើ ត្រូវអាបត្តិដល់អ្នកប្រើ
ដូចន័យសំដែងមកហើយ បើអ្នកទទួលបង្គាប់ទៅចោទថា យើង
ក៏បានឃើញ បានឮដែរ ត្រូវអាបត្តិទាំងពីរនាក់ ៗ ភិក្ខុមិនឲ្យគេធ្វើ
ឱកាសជាមុនហើយ ពោលដោយបំណងនឹងជេរ ត្រូវបាចិត្តិយផង
ទុក្កដផង បើឲ្យធ្វើឱកាសជាមុនហើយចោទ ត្រូវតែបាចិត្តិយប៉ុណ្ណោះ
ភិក្ខុធ្វើកម្មទាំង ៧ ប្រការក្នុងទីកំបាំងដោយកម្មាធិប្បាយ ត្រូវទុក្កដ ៗ

www.budinst.gov.kh www.elibraryofcambodia.org

មួយទៀត ភិក្ខុពោលថា លោកត្រូវអាបត្តិឈ្មោះនេះ លោកចូរសំដែងអាបត្តិនោះចេញ ដូច្នេះ ដោយវត្ថុមានពិប្បាយ ឯឃាត់ចោទសថ ឬបក់ណោដល់ភិក្ខុដទៃ មិនបាច់សូមឱកាស តែឲ្យស្គាល់ទោសត្រូវដែលនឹងឃាត់ សូម្បីភិក្ខុអ្នកសាកសួរសេចក្ដី លុះកាលបើវត្ថុដែលគេចោទឡើងហើយពោលថា កម្មរបស់លោកនោះមាន ដោយបំណងមិនសាកសួរ មិនបាច់សូមឱកាស សូម្បីភិក្ខុជាធម្មកថិកមិនចំពោះអ្នកណា សំដែងធម៌ទៅដោយន័យថា អ្នកណាធ្វើដូច្នេះ ៗ អ្នកនោះមិនជាសមណៈជាដើម ដូច្នេះ ក៏មិនបាច់សូមឱកាស បើភិក្ខុកំណត់ចំពោះ ពោលថា អ្នកឯណោះ ៗ ផង មិនជាសមណៈ មិនជាឧបាសក ដូច្នេះ ចុះចាកធម្មាសនៈហើយ ត្រូវសំដែងអាបត្តិចេញសិមទៅ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុសំគាល់ថាជាមនុស្សមិនបរិសុទ្ធ ក្នុងបុគ្គលបរិសុទ្ធក្ដី ថាជាមនុស្សបរិសុទ្ធ ក្នុងបុគ្គលមិនបរិសុទ្ធក្ដី ហើយទើបចោទ និងភិក្ខុឆ្កួតជាដើម មិនត្រូវអាបត្តិ ជាសាណត្តិកៈ មានអង្គ ៥ គឺ យំ ចោទេតិ វា ចោទាបេតិ វា តស្ស ឧបសម្បន្នោតិ សង្ខ្យូបគមនំ ចោទឯង ឬឲ្យអ្នកដទៃចោទនូវបុគ្គលណា បុគ្គលនោះជាឧបសម្បន្ន ១ តស្មិំ សុទ្ធសញ្ញិតា សំគាល់ថាអ្នកនោះ ជាមនុស្សបរិសុទ្ធ ១ យេន បារាជិកេន ចោទេតិ តស្ស ទិដ្ឋាទិវសេន អមូលកតា ចោទដោយបារាជិកណា បារាជិកនោះមិនមានមូល

www.budinst.gov.kh www.elibraryofcambodia.org

ដោយការឃើញជាដើម ១ ចាវនាធិប្បាយេន សម្មុខា ចោទនា ក ចោទាបនា ក ចោទឯង ឬប្រើអ្នកដទៃឲ្យចោទ ក្នុងទីចំពោះមុខ ដោយបំណងនឹងឲ្យឃ្លាតចាកព្រហ្មចរិយៈ ១ តស្ស តំ ខណំ វិជាននំ អ្នកត្រូវគេចោទដឹងក្នុងខណៈនោះ ១ ព្រមដោយអង្គ ៥ នេះ ទើបត្រូវសង្ឃាទិសេស ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាទុក្ខវេទនា ។

អមូលកសិក្ខាបទ គំរប់ ៨ ចប់

អញ្ញភាគិយសិក្ខាបទ គំរប់ ៩ សេចក្ដីថា ភិក្ខុណា មានសេចក្ដីក្រោធ ប្រទុស្តនឹងភិក្ខុដទៃ គិតនឹងឲ្យឃ្លាតចាកព្រហ្មចរិយៈ ក្លែងកាន់យកលេស មានជាតិជាដើម មកចោទភិក្ខុនោះ ដោយបារាជិកមិនមានមូល ដូចយ៉ាងអ្នកដែលមានជាតិជាក្សត្រិយ៍ជាដើម សេពមេថុន ឬត្រូវបារាជិកណា ៗ ហើយ កាន់យកជាតិនោះជាលេស មកដាក់ក្នុងភិក្ខុ ដែលជាជាតិក្សត្រិយ៍ដូចគ្នា ថាអ្នកជាក្សត្រិយ៍ សេពមេថុន នឹងត្រូវបារាជិកាបត្តិ ដោយហេតុនេះ ៗ យើងបានឃើញ បានឮ យើងរង្កៀសដូច្នេះ ត្រូវសង្ឃាទិសេសក្នុងខណៈចោទ សូម្បីនឹងប្ដេជ្ញាខ្លួនជាមានក្រោយ គឺមិនរួចចាកទោស ។

លេសមាន ១០ ប្រការ គឺជាតិ ១ នាម ១ គោត្រ ១ លិង្គ ១ អាបត្តិ ១ បាត្រ ១ ចីវរ ១ ឧបជ្ឈាយ៍ ១ អាចារ្យ ១ សេនាសនៈ ១ ។

www.budinst.gov.kh www.elibraryofcambodia.org

ជាតិនោះមាន ៤ គឺក្សត្រិយ៍ ១ ព្រាហ្មណ៍ ១ ពាណិជ ១ ពួកពិសេស ១ ។ នាមមាន ៣ គឺពុទ្ធរក្ខិត ១ ធម្មរក្ខិត ១ សង្ឃរក្ខិត ១ ។ គោត្រមាន ៤ គឺ គោតមគោត្រ ១ មោគ្គល្លានគោត្រ ១ កច្ចាយនគោត្រ ១ វាសិដ្ឋគោត្រ ១ ។ លិង្គមាន ៤ គឺ ខ្ពស់ ១ ទាប ១ ខ្មៅ ១ ស ១ ។ អាបត្តិនោះ ដូចភិក្ខុត្រូវទុក្កដ ហើយហៅថាត្រូវបាកដិក ១ ។ បាត្រមាន ៤ គឺ ភិក្ខុទ្រទ្រង់នូវបាត្រដែក ១ បាត្រដី ១ បាត្រខ្ទក ១ បាត្រដីជាប្រក្រតី ១ ។ ចីវរមាន ២ គឺ ភិក្ខុទ្រទ្រង់នូវចីវរបង្សុកូល ១ គហបតិចីវរ ១ ។ ចុះបដ្ឋាយ៍ក្តី អាចារ្យក្តី សេនាសនៈក្តី វិធីដែលហៅដូចពោលហើយក្នុងលេសទាំងឡាយមានជាតិជាដើមនោះ ។ សមុដ្ឋានវិធីជាដើម ដូចពោលហើយក្នុងអមូលកសិក្ខាបទ ។

អញ្ញភាគិយសិក្ខាបទ ។ គំរប់ ៩ ចប់

សង្ឃភេទសិក្ខាបទ គំរប់ ១០ សេចក្តីថា ភិក្ខុណា ព្យាយាមស្វែងរកបក្ខពួក ដើម្បីនឹងចំលាយសង្ឃដែលព្រមព្រៀងនៅក្នុងសីមាជាមួយគ្នា ឬលើកយកហេតុដែលនឹងចំលាយសង្ឃ គឺភេទករវត្ថុ ១៨ ឡើងសំដែង ភិក្ខុដទៃបានឃើញបានឮ គប្បីហាមប្រាមថា លោកកុំធ្វើយ៉ាងនេះ លោកចូរព្រមព្រៀងដោយសង្ឃចុះ ដ្បិតថាសង្ឃព្រមព្រៀង មិនមានទាស់ទែង មានឧទ្ទេសជាមួយគ្នាហើយ កំពឹងនៅដោយសេចក្តីសប្បាយ បើភិក្ខុមិនស្តាប់ពាក្យហាមឃាត់ ត្រូវទុក្កដ បើភិក្ខុដទៃ

www.budinst.gov.kh www.elibraryofcambodia.org

បានឃើញ បានឮ ហើយមិនហាមឃាត់ ត្រូវទុក្កដ ភិក្ខុដទៃហាមឃាត់ មិនស្តាប់ពាក្យហាមឃាត់ហើយ ឲ្យភិក្ខុទាំងឡាយនោះ ទន់ទាញភិក្ខុនោះទៅក្នុងកណ្តាលសង្ឃ គប្បីឲ្យឃាត់ទៀត ៣ ដង បើលះចេញគឺជាការល្អ បើមិនលះចេញត្រូវទុក្កដ ហើយសង្ឃគប្បីសូត្រសមនុភាសនកម្មដល់ភិក្ខុនោះដោយញត្តិចតុត្ថកម្មវាចា លុះសង្ឃសូត្រសមនុភាសនៈចប់ញត្តិហើយ ភិក្ខុនោះមិនលះត្រូវទុក្កដ កាលបើចប់អនុស្សាវនៈទី ១-២ ភិក្ខុនោះមិនលះត្រូវថុល្លច្ច័យ លុះចប់អនុស្សាវនៈគំរប់ ៣ ត្រូវសង្ឃាទិសេស ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺសង្ឃមិនបានសូត្រសមនុភាសនៈ ហើយភិក្ខុលះចេញ និងភិក្ខុឆ្កួតជាដើម សិក្ខាបទនេះមានអង្គ ៤ គឺ ភេទាយ បរក្កមនំ ព្យាយាមដើម្បីបំបែកសង្ឃ ១ ធម្មកម្មេន សមនុភាសនំ សង្ឃសូត្រកម្មនោះដោយធម៌ ១ កម្មវាចាបរិយោសានំ សូត្រចប់ចតុត្ថកម្មវាចា ១ អប្បដិនិស្សជ្ជនំ មិនបានបោះបង់ ១ ជាសមនុភាសនសមុដ្ឋាន អកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ទុក្ខវេទនា ។

សង្ឃភេទសិក្ខាបទ គំរប់ ១០ ចប់

---

ភេទានុវត្តកសិក្ខាបទ គំរប់ ១១ សេចក្តីថា ភិក្ខុទាំងឡាយ គាំទពី ៣ រូបចុះមក ជាបក្សពួកប្រព្រឹត្តតាមភិក្ខុដែលជាអ្នកទំលាយសង្ឃ

www.budinst.gov.kh www.elibraryofcambodia.org

នោះ ជួយស្រដីកំផែកភិក្ខុដទៃថា “លោកទាំងឡាយ កុំស្រដីអ្វីនឹងភិក្ខុនោះឡើយ ភិក្ខុនុ៎ះជាអ្នកពោលធម៌ពោលវិន័យ លោកកាន់យកនូវសេចក្ដីពេញចិត្តនឹងគាប់ចិត្តរបស់ពួកយើងហើយពោល លោកដឹងនូវសេចក្ដីពេញចិត្តនឹងគាប់ចិត្តរបស់យើង បានប្រឹក្សាជាមួយយើង កម្មនោះគួរដល់ពួកយើង” ដូច្នេះ ពួកភិក្ខុដទៃបានឃើញ បានឮ គប្បីហាមឃាត់ភិក្ខុដែលជាបក្ខពួកនោះអស់វារៈ ៣ ដង បើភិក្ខុពួកទាំងនោះហាមឃាត់មិនស្ដាប់ ឲ្យភិក្ខុទាំងនោះ គប្បីសូត្រសមនុភាសនៈដោយញត្តិចតុត្ថកម្មវាចា ដើម្បីឲ្យលះកម្មនោះចេញ បើលះចេញក៏ជាការល្អ បើមិនលះទេ លុះចប់អនុស្សាវនៈគំរប់ ៣ ពួកភិក្ខុដែលជាបក្ខពួកនោះត្រូវសង្ឃាទិសេស ។ សេចក្ដីក្រៅនោះដូចសិក្ខាបទមុន ។

ភេទានុវត្តកសិក្ខាបទ គំរប់ ១១ ចប់

---

ទុព្វចជាតិកសិក្ខាបទ គំរប់ ១២ សេចក្ដីថា ភិក្ខុមានជាតិជាអ្នកមុខរឹងប្រះដាក្រ កាលភិក្ខុទាំងឡាយ ពោលប្រដៅដោយសិក្ខាបទបញ្ញត្តិ ធ្វើខ្លួនមិនឲ្យអ្នកដទៃស្រដីដាស់តឿនបាន គឺពោលថា លោកទាំងឡាយកុំនិយាយពាក្យអ្វី ពោះល្អ ឬអាក្រក់ នឹងខ្ញុំ សូម្បីខ្ញុំក៏មិនពោលពាក្យអ្វីពោះល្អ ឬ អាក្រក់នឹងលោកទាំងឡាយដែរ លោកទាំងឡាយចូរស្ងៀម កុំដាស់តឿនយើងឡើយ ដូច្នេះ ភិក្ខុទាំងឡាយគប្បីហាមប្រាម កុំឲ្យជាមនុស្សមុខរឹង លុះភិក្ខុទាំងឡាយនិយាយដាស់តឿន ភិក្ខុនោះនៅ

www.budinst.gov.kh www.elibraryofcambodia.org

តែមុននឹងបេសដូច្នោះ ភិក្ខុទាំងឡាយគប្បីទូន្មានទៅកាន់កណ្ដាលសង្ឃ សូត្រសមនុភាសនៈអស់វារៈ ៣ ដង ដើម្បីឲ្យលះកម្មនោះចេញ បើលះចេញក៏ជាការល្អ បើមិនលះទេ លុះចប់អនុសាវនៈ គំរប់ ៣ ត្រូវសង្ឃាទិសេស ។ វិនិច្ឆ័យក្រៅនោះដូចសិក្ខាបទមុន ។

ទុព្វចជាតិកសិក្ខាបទ គំរប់ ១២ ចប់

កុលទូសកសិក្ខាបទ គំរប់ ១៣ សេចក្ដីថា ភិក្ខុអាស្រ័យនៅក្នុងស្រុកឬនិគមណាមួយហើយប្រទូស្ដត្រកូល គឺឲ្យផ្លែឈើ ផ្កាឈើ ជាដើម ដល់ត្រកូលឲ្យគេសាបសូន្យផលនៃទានដែលគេឲ្យមកដល់ខ្លួន ដូច្នេះ ឈ្មោះជាកុលទូសក ឯភិក្ខុជាមនុស្សមានមារយាទអាក្រក់ គឺដាំឈើ ដើម្បីនឹងសង្គ្រោះត្រកូលជាដើម សមាចារដ៏អាក្រក់នឹងត្រកូលដែលភិក្ខុប្រទូស្ដនោះ ប្រាកដដល់ភ្នែកនឹងត្រចៀកអ្នកដទៃ ឲ្យភិក្ខុទាំងឡាយដែលបានឃើញ បានឮ គប្បីធ្វើបព្វាជនីយកម្ម បណ្ដេញចេញពីស្រុកនិគមនោះ ដោយញត្តិចតុត្ថកម្មវាចា លុះភិក្ខុត្រូវបព្វាជនីយកម្ម ហើយត្រឡប់ពោលតិះដៀលសង្ឃអ្នកបណ្ដេញនោះ ថាធ្វើដោយអគតិទាំង ៤ គឺ ឆន្ទាគតិ ១ ទោសាគតិ ១ មោហាគតិ ១ ភយាគតិ ១ ដូច្នេះ ឲ្យភិក្ខុទាំងឡាយដទៃដែលបានឃើញ បានឮ គប្បីហាមឃាត់ កុំឲ្យតិះដៀលការកសង្ឃនោះ បើហាមប្រាមមិនស្ដាប់ ឲ្យភិក្ខុទាំងឡាយនោះ ទូន្មានទៅកណ្ដាលសង្ឃ សូត្រសមនុភាសនៈអស់វារៈ ៣ ដង ដើម្បីឲ្យលះពាក្យតិះដៀល

www.budinst.gov.kh www.elibraryofcambodia.org

នោះចេញ បើមិនលះទេ លុះចប់អនុស្សាវនៈគំរប់ ៣ ត្រូវសង្ឃាទិសេស ។ វិនិច្ឆ័យក្រៅនោះដូចសិក្ខាបទមុន ។

កុលទូសកសិក្ខាបទ គំរប់ ១៣ ចប់

---

តាំងអំពីសញ្ចរិត្តសិក្ខាបទ ដល់អញ្ញភាគិយសិក្ខាបទ ទាំង ៩ នេះ ឈ្មោះបឋមាបត្តិកា ព្រោះត្រូវអាបត្តិក្នុងខណៈដែលកន្លងជាដំបូង សិក្ខាបទ ៤ ក្រៅនោះ ឈ្មោះយាវតតិយកា ព្រោះត្រូវអាបត្តិក្នុងខណៈចប់អនុស្សាវនៈ គំរប់ ៣ ក្នុងសិក្ខាបទទាំង ១៣ នេះ សិក្ខាបទណាមួយ ភិក្ខុត្រូវហើយ ដឹងហើយ បិទទុកអស់ថ្ងៃប៉ុន្មាន គប្បីនៅបរិវាសអស់ថ្ងៃប៉ុណ្ណោះ លុះនៅបរិវាសហើយ ត្រូវប្រព្រឹត្តមានត្ត ៦ រាត្រីទៀត លុះប្រព្រឹត្តមានត្តហើយ គប្បីសុំអព្ភានកម្មក្នុងសង្ឃ មានភិក្ខុ ២០ អង្គជាគណៈសង្ឃ ឲ្យអព្ភានកម្មស្រេចហើយទើបរួចអាបត្តិនោះបាន ព្រោះហេតុនោះភិក្ខុត្រូវអាបត្តិហើយ កុំបិទទុកដោយអៀនខ្មាស គប្បីប្រញាប់ប្រាប់ដល់ភិក្ខុដែលជាសភាគៈក្នុងថ្ងៃនោះ កុំឲ្យអរុណរះឡើងទាន់ កាលបើប្រាប់បានក្នុងថ្ងៃនោះ មិនត្រូវប្រព្រឹត្តតែមានត្ត ៦ រាត្រី ហើយសូមអព្ភានកម្មក្នុងសង្ឃ រួចទោសទៅដោយងាយ ត្រូវ ហើយឲ្យប្រាប់សូម្បីដោយភាសារបស់ខ្លួន ថាខ្ញុំត្រូវអាបត្តិសង្ឃាទិសេសឈ្មោះនេះៗ ខ្ញុំប្រាប់អាបត្តិនោះដល់លោក លក្ខណៈដែលមិនបិទអាបត្តិទុកនោះដូច្នេះ អាបត្តិភិក្ខុត្រូវហើយដឹងថាត្រូវអាបត្តិផង ខ្លួនជាបកតត្ត សង្ឃមិនបានលើកវត្ត ដឹងថាខ្លួនជាបកតត្តផង មិនមាន

អន្តរាយទាំង ១០ ណាមួយ ដឹងថាមិនមានអន្តរាយផង ល្មមនឹងទៅប្រាប់ភិក្ខុដែលជាសភាគៈបាន ហើយដឹងថាល្មមនឹងប្រាប់បានផង ប្រាថ្នានឹងបិទ ហើយបិទទុកផង ដូច្នេះទើបឈ្មោះថាបិទ បើឃើញបំផ្សាយអាបត្តិហើយវៀនមិនប្រាប់ឲ្យអរុណរះឡើងមក ក៏ឈ្មោះថា បិទទុកប្រាកដ ដែលវៀននឹងបំផ្សាយអាបត្តិនោះ មិនជាប្រមាណទេ ភិក្ខុដែលជាសភាគៈដោយវត្ថុបដិបត្តិ ដឹងហើយមិនចំអកចំអន់តិះដៀលឡក ឡើយ ដូច្នេះឯងជាប្រមាណគួរប្រាប់ ។

សង្ឃាទិសេសុទ្ទេស ចប់តែប៉ុណ្ណេះ

---

## អនិយតុទ្ទេស

ពណ៌នាអំពីអនិយតសិក្ខាបទ អនិយតសិក្ខាបទមាន ២ គឺអលំកម្មនិយសិក្ខាបទជាបឋម សេចក្តីថា ភិក្ខុណាតែម្នាក់ឯង អង្គុយឬដេកក្នុងអាសនៈដែលស្ងាត់កំបាំងជាមួយនឹងស្ត្រី សូម្បីកើតក្នុងថ្ងៃនោះ (ទោះច្រើនគ្នា) អង្គុយ ឬដេក ឧបាសិកាដែលមានពាក្យគួរជឿ គឺជាអរិយសាវិកា បានឃើញភិក្ខុនោះ ហើយចោទដោយបារាជិក ព្រោះសេពមេថុន ឬដោយសង្ឃាទិសេស ព្រោះកាយសំសគ្គៈ ឬដោយបាចិត្តិយ ព្រោះអង្គុយក្នុងទីកំបាំងជាមួយនឹងស្រី ណាមួយ ភិក្ខុនោះប្ដេជ្ញា គឺទទួលដោយបទណា វិន័យធរគប្បីកាត់អាបត្តិតាមប្ដេជ្ញាក្នុងបទនោះ គឺប្ដេជ្ញាទទួលថា សេពមេថុន ឲ្យកាត់បារាជិក, ប្ដេជ្ញាទទួលថា ចាប់

www.budinst.gov.kh www.elibraryofcambodia.org

ពាល់ត្រូវស្រី ឲ្យកាត់ជា សង្ឃាទិសេស, ប្រៀបដូចជា អង្គុយ ដេកក្នុងទីកំបាំងនឹងស្រី ដែលអង្គុយឬដេក ឲ្យកាត់ជាបាចិត្តិយ, បើ ប្រៀបជាខ្លួនឈរ ឬស្រីឈរ មិនបានធ្វើអ្វីទេ កុំឲ្យវិន័យធរកាត់អាបត្តិអ្វី ឡើយ ផ្សេងការឃើញនោះ មានកាលក៏មែនដូចឃើញ មានកាល ក៏មិនមែនដូចឃើញ មិនជាក់ច្បាស់ ភិក្ខុប្រព្រឹត្តទីរហោរកមាតុគ្រាម ដោយសេចក្តីត្រេកក្នុងទីស្ងាត់ប្រកបដោយកិលេសអាស្រ័យមេថុន តាំង តាំងពីប្រយោគដែលតាក់តែងខ្លួនមានជូតមុខជាដើមទៅ ត្រូវទុក្កដគ្រប់ៗ ប្រយោគ លុះទៅដល់ទីអង្គុយឬដេក ហើយស្រីរៀបអង្គុយឬដេក ឬស្រីអង្គុយ ឬដេកនោះហើយ ភិក្ខុចូលអង្គុយឬដេក ឬដេកនឹង អង្គុយព្រមគ្នាតាំងពីកើត ត្រូវបាចិត្តិយ ។ បើភិក្ខុនោះពាល់ត្រូវស្រី ឬ សេពមេថុន ឲ្យវិន័យធរគប្បីកាត់អាបត្តិភិក្ខុនោះដោយគុណនោះ ។ សូម្បី ប្រុសអង្គុយនោះប្រែមាត់ត្រឡប់ដែលមាននសង្ខារកបិល ។ ភិក្ខុអង្គុយតាំង ក្នុងវេលាជាមួយនឹងស្រី ប្រុសនោះក៏ការពារអាបត្តិមិនបាន ប្រុសក្តីល្អ អង្គុយក្នុងវត្តកាស ១៦ ហត្ថ ឬមើលឃើញគ្នាបាន ជាមនុស្សមានចិត្តអណ្តក អណ្តាន សូម្បីអង្គុយលក់ ក៏ការពារអាបត្តិមិនបាន ប្រុសក្តីល្អតែដេក លក់ ក៏ការពារអាបត្តិមិនបាន ប្រុសក្តីឃ្លាត សូម្បីអង្គុយជិត ក៏ការពារ អាបត្តិមិនបាន ( សូម្បីស្រីមួយរយនាក់ ក៏ការពារអាបត្តិមិនបាន ) ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺមានប្រុសដឹងសេចក្តី ក្តីមិន

ម្នាក់ ដេកមិនលក់ក្តី ឬប្រុសដូច្នោះនៅក្នុងទីចបារៈក្តី ឬភិក្ខុឈរក្តី ឬស្រីឈរមិនអង្គុយក្តី ភិក្ខុមិនប្រាថ្នាក្នុងទីកំបាំងក្តី បញ្ជូនចិត្តទៅកាន់ទីដទៃក្តី អម្បាលនេះមិនត្រូវអាបត្តិបាចិត្តិយ ព្រោះអង្គុយក្នុងទីកំបាំងនឹងស្រី ភិក្ខុឆ្កួតជាដើម មិនត្រូវអាបត្តិ តាំង ៣ ប្រការនេះជាអនាណត្តិកៈ ៗ អង្គក្នុងសិក្ខាបទនេះ ឲ្យគប្បីដឹងតាមអាបត្តិដែលភិក្ខុប្តេជ្ញា ៗ សមុដ្ឋានទាំងជាដើម ដូចបឋមបារាជិក ៗ

### អលំកម្មនិយសិក្ខាបទ ចប់

អលំកម្មនិយសិក្ខាបទ ជាគំរប់ ២ សេចក្តីថា អាសនៈទីអង្គុយមិនបិទបាំងដោយវត្ថុអ្វី ជាទីវាលដូចកណ្តាលវត្ត កណ្តាលស្រុក មិនគួរសេពមេថុនបាន គួរតែនឹងនិយាយទុដ្ឋុល្លវាចានឹងមាតុគ្រាមបាន ប៉ុណ្ណោះ ភិក្ខុណាតែមួយរូបមិនមានប្រុសដទៃដឹងសេចក្តីនៅជាមួយផង អង្គុយ ឬដេកនឹងស្រីដែលដឹងពាក្យអាក្រក់នឹងពាក្យល្អ តែម្នាក់ឯងមិនមានស្រីដទៃដែលដឹងសេចក្តីនៅជាមួយផង ក្នុងអាសនៈដូច្នោះ ជាទីកំបាំងត្រចៀកមួយចំពូក ឧបាសិកាជាអរិយសាវិកា មានវាចាគួរជឿ បានឃើញភិក្ខុនោះ ហើយចោទដោយសង្ឃាទិសេស ព្រោះពោលទុដ្ឋុល្លវាចា ឬដោយបាចិត្តិយព្រោះអង្គុយក្នុងទីស្ងាត់ បទណាមួយ ភិក្ខុអ្នកអង្គុយនោះទទួលប្តេជ្ញាដោយបទណា ឲ្យវិន័យធរគប្បីកាត់អាបត្តិដោយបទនោះ ឬឧបាសិកាជាអរិយសាវិកាមានពាក្យគួរជឿនោះ ចោទដោយបទណា

www.budinst.gov.kh www.elibraryofcambodia.org

ទ្រព្យរបស់គេឬក៏គាត់អាបត្តិតាមបទនោះ បើភិក្ខុប្ដេជ្ញាខ្លួនថាឈរ មិនបានអង្គុយមិនបានដេក កុំឲ្យវិន័យធរគាត់អាបត្តិជាមុន វិនិច្ឆ័យក្រោយនោះដូចសិក្ខាបទមុន ប្លែកតែសិក្ខាបទនេះសូម្បីស្រី សូម្បីប្រុស ណាមួយដឹងសេចក្ដី មិនទាក់ មិនជួន ឈរ ឬអង្គុយទៅក្នុងឱកាសខាងក្នុង ១២ ហត្ថ សូម្បីមានចិត្តអណ្ដែតអណ្ដូង ឬដេកលក់ ក៏ការពារអាបត្តិព្រោះទោសអង្គុយក្នុងទីកំបាំងនោះបាន ឯមនុស្សថ្លង់សូម្បីភ្នែកល្អក្ដី មនុស្សភ្នែកខ្វាក់សូម្បីមិនថ្លង់ក្ដី អម្បាលនេះ ក៏ការពារអាបត្តិមិនបាន ឯសមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ។

ទុតិយានិយតសិក្ខាបទ ចប់

---

សិក្ខាបទទាំងពីរនេះឈ្មោះអនិយតៈ ប្រែថាមិនទៀង ព្រោះជាបារាជិកខ្លះ ជាសង្ឃាទិសេសខ្លះ ជាបាចិត្តិយខ្លះ ដោយបញ្ញត្តិនោះៗ តាមហេតុនៃភិក្ខុ ។

មួយទៀត សិក្ខាបទទាំងពីរនេះ មើលទៅដូចជាព្រះពុទ្ធអង្គទ្រង់បញ្ញត្តទុកឲ្យជាសណ្ដាប់ដល់វិន័យធរអ្នកនឹងកាត់សេចក្ដី អ្នកចោទក៏ នឹងអ្នកចម្លើយ ក្នុងសិក្ខាបទទាំងពួង ឲ្យកាត់តាមលំអានអនិយតសិក្ខាបទទាំងពីរនេះចុះ ។

អនិយតុទ្ទេស ចប់

---

www.budinst.gov.kh www.elibraryofcambodia.org

# ថុល្លច្ចយាបត្តិ

ពណ៌នាអំពីអាបត្តិថុល្លច្ច័យ សេចក្ដីថា បទមួយ គិតគុំលះ បទមួយ គិតគុំគប្បីចែកគរុភណ្ឌរបស់សង្ឃ បើលះ បើចែក ត្រូវអាបត្តិថុល្លច្ច័យ ព្រោះពុទ្ធប្បញ្ញត្តិឃាត់ទុកថា ៖

បញ្ចិមានិ ភិក្ខវេ អវិស្សជ្ជិយានិ ។ បេ ។ អវេភង្គិយានិ ន វិភជ្ជិតព្វានិ សង្ឃេន វា គណេន វា បុគ្គលេន វា វិភត្តានិបិ អវិភត្តានិ ហោន្តិ យោ វិភជ្ជេយ្យ អាបត្តិ ថុល្លច្ចយស្ស ដូច្នេះ គរុភណ្ឌនោះមាន ៥ ពួកដូច្នេះ អារាមោ ច្បារផ្លែឈើផ្កាឈើ អារាមវត្ថុ ទីដីច្បារ ពីរនេះជាពួក ១, វិហារោ កុដិ ផ្ទះជាដើម វិហារវត្ថុ ទីដីនៃវិហារ ពីរនេះជាពួកទី ២, មញ្ចោ គ្រែ បីឋំ តាំង ភិសិ ពូក ពិម្ពោហនំ ខ្នើយ បួននេះជាពួកទី ៣, លោហកុម្ភី ឆ្នាំងទង់ដែង លោហភាណកំ នាលិលោហៈ លោហវារកោ បំពង់លោហៈធំចុះទឹក ៥ នាលិមគធៈឡើងទៅ លោហកដាហំ ខាន់លោហៈតូចចុះទឹកមួយដូកដៃ លោហៈនោះជាឈ្មោះនៃស្ពាន់ទង់ដែងសំរឹទ្ធិ វាសី កាំបិតធំដែលកាប់កាត់របស់ធំ រួចពាកកាត់ឈើស្ងួតមិនល្អសអំពៅបានឡើងទៅ ផរសុ ពូថៅគ្រឿងធ្វើឈើ កុឋារី កឹងគ្រឿងធ្វើឈើ កុទ្ទាលោ ចបកាប់ចបជីកជាគ្រឿងជីកដី និខាទនំ ដែកគណ្ដារ ដែកស្ពាន ប្រាំបួន

www.budinst.gov.kh www.elibraryofcambodia.org

នេះជាពួកទី ៦, វល្លិ៍ វល្លិ៍តែងតាំងអំពីកន្ទុះល្ពៅទៀតទៅ វេត្រ
ឬស្សីតែងអំពី ៨ ធ្នាប់ទៀតទៅ មុញ្ជំ ស្មៅដំណោកកខ្សាយ បព្វជ្ជ
ស្មៅឃាប៊ួន តិណា ស្មៅផ្សេងៗ ដែលសម្រាប់ប្រក់ផ្ទះបាន អំពី
មួយក្ដាប់ទៀតទៅ មត្តិកា ដីប្រក្រតីខឹងដីមានពណ៌ផ្សេងៗជាគ្រឿង
សំរាប់លាប ធារុកណ្ឌំ គ្រឿងប្រើប្រាស់ធ្វើដោយឈើផ្សេងៗ ប្រវែង ៨
ធ្នាប់ទៀតទៅ មត្តិកាភណ្ឌំ គ្រឿងប្រើ ធ្វើដោយដីផ្សេងៗ
ទាំងអម្បាលនេះដែលហួងហែងទុក ទាំង ៨ វត្ថុនេះ ជាពួកទី ៥, របស់
ទាំង ២៥ នេះ របស់ណាមួយតាយកប្រគេនដល់សង្ឃក្ដី កើតក្នុង
សង្ឃក្ដី ឈ្មោះថារបស់សង្ឃជាគរុភណ្ឌ ជាអវិសជ្ជនិយៈ ជាអវេភង្គិយៈ
ដែលសង្ឃ គណៈ បុគ្គល មិនគប្បីលះ មិនគប្បីចែកបាន តោះលះ
តោះចែកទៅ ក៏មិនបានឈ្មោះថាលះថាចែក របស់នោះក៏គង់នៅជា
របស់សង្ឃដូចដើម, ភិក្ខុណាលះ ឬចែករបស់សង្ឃទាំងអម្បាលនេះ
ដោយប្រកាន់ថាខ្លួនជាធំត្រូវថុល្លច្ច័យ បើលះបើចែកដោយថេយ្យចិត្ត
ឲ្យរិះយកចៅកាត់អាបត្តិតាមដំឡៃរបស់នោះៗ គរុភណ្ឌទាំងអម្បាលនេះ
បើភិក្ខុណាក់ឃើញថា គ្រឿងប្រដាប់ទាំងនឹងកើតឧបការៈដល់សង្ឃ ហើយយក
របស់ដែលជាថាវរៈផ្លាស់ប្ដូរ យករបស់ដែលជាថាវរៈដូចគ្នាក្ដី យករបស់
គ្រៅនោះ ដែលជាអកប្បិយ ឬជាកប្បិយ សូម្បីមានដំឡៃច្រើន ផ្លាស់
ប្ដូររបស់គ្រៅនោះផងគ្នា ដោយគិតយកផ្លាស់ប្ដូរជាកប្បិយក្ដីក៏គួរ ឬគរុ-

www.budinst.gov.kh www.elibraryofcambodia.org

ទណ្ឌដែលជារបស់ទៅកចាប ហើយផ្លាស់ប្តូរបិណ្ឌបាតជាដើម យកមកបរិភោគដើម្បីរក្សាសេនាសនៈជាដើម ដែលជារបស់ល្អ ក្នុងវេលាអត់បាយជាដើមក៏គួរ ក្នុងគុរុភណ្ឌទាំងអម្បាលនេះ របស់ណាមួយមានឫស្សីជាដើម ភិក្ខុកាន់យកដើម្បីជាប្រយោជន៍ខ្លួន គប្បីធ្វើផាតិកម្មការសងជំនួសឲ្យស្មើគ្នា ឬលើសជាង ទើបគួរកាន់យក ។ ឆ្នាំង បាត្រដែក ផ្តិលស្ពាន់ ទីកោទឹក ដែលមិនចុះទឹកបាន ៤ នាលិមត្តៈក្តី ចង្កឹះថ្នាំភ្នែក បំពង់ថ្នាំនត្ថុ ឈើចង្កៀលត្រចៀក ម្ជុលដេរសំពត់ ម្ជុលកាស់ស្នឹកឈើ កាំបិតបត់តូច ដែកកណ្តារតូច ៗ មេសោកូនសោជាដើម គ្រឿងលោហៈក្តី គ្រឿងឈើក្តី ដែលនៅកំពុងធ្វើ ទាំងនេះជារបស់គួរចែកបាន វល្លិនិងឫស្សីជាដើម កាលបើធ្វើការសង្ឃ និងការចេតិយរួចហើយសល់ និងបង្អោនទៅកាន់ការបុគ្គលក៏គួរ ដែលសំដែងមកនេះជាសេចក្តីសង្ខេប បើប្រាថ្នាចង់ដឹងសេចក្តីពិស្តារ គប្បីមើលក្នុងចតុត្ថ-សមន្តបាសាទិកាឯណោះចុះ ។

បទមួយ កុំឲ្យគេធ្វើសត្ថកម្មក្នុងទីចង្អៀត បទមួយ កុំឲ្យគេធ្វើសត្ថ-កម្ម ឬវត្ថិកម្មក្នុងឱកាសទីពីរធ្នាប់អំពីទីជិតនៃទីចង្អៀតគឺទ្វារធ្ងន់ បើឲ្យគេធ្វើ ត្រូវថុល្លច្ច័យ ព្បិតទ្រង់ឃាត់ទុកថា ន ភិក្ខវេ សម្ពាធេ សត្ថកម្មំ ។ល។ សម្ពាធស្ស សាមន្តា ទ្វង្គុលេ សត្ថកម្មំ វា វត្ថិកម្មំ វា ការាបេតព្វំ យោ ការាបេយ្យ

www.budinst.gov.kh www.elibraryofcambodia.org

អាបត្តិ ថុល្លច្ចយស្ស ដូច្នេះ កាត់ ឬពុះ ឬចាក់ ឬក្រើដោយ សស្ត្រា ឬម្ជុល ឬបន្លា ឬលំពែង ឬកាំបិត ឬក្រចកក្តី ណាមួយក្នុងឧកាសដែលកំណត់ក្នុងទ្វារធ្ងន់នោះ ឈ្មោះថាសត្ថកម្មទាំងអស់, សូម្បីចងតែក្បាលសសាលដោយស្បែក ឬសំពត់ណាមួយក៏កុំគប្បីធ្វើ ផ្សិតអាការទាំងពួងនោះឈ្មោះថាវត្ថិកម្ម ឯក្នុងឧកាសទីពីរធ្នាប់អំពីទីជិតនៃទីចង្អៀតគឺទ្វារធ្ងន់នោះ ឃាត់តែសត្ថកម្មប៉ុណ្ណោះ មិនឃាត់វត្ថិកម្មឡើយ ឯវត្ថិកម្មឃាត់តែក្នុងទីចង្អៀតប៉ុណ្ណោះ គឺប៉ុន្តែថា ភិក្ខុនឹងបន្តក់ទឹកផ្កាក្នុងក្បាលសសាល ឬនឹងយកខ្សែណាមួយចងតែក្បាលសសាលក៏គួរ បើក្បាលសសាលនោះដាច់ចេញមកដោយទឹកផ្កា ឬខ្សែនោះ ឈ្មោះថាដាច់ដោយច្រៃ មិនមានទោស ។

នឹងធ្វើសត្ថកម្មគឺពុះពោះក្នុងអណ្ឌៈ(១) ដែលមានរោគចំរើនឡើងនោះមិនគួរ ព្រោះហេតុនោះ នឹងពុះពោះអណ្ឌៈទាញយកគ្រាប់ចេញមកដោយគិតនឹងឲ្យជារោគដូច្នេះក៏កុំគប្បីធ្វើ ឯនឹងកំដៅដោយភ្លើងនឹងលាបថ្នាំទាំងអម្បាលនេះមិនបានឃាត់ ក្នុងទ្វារធ្ងន់ នឹងយកគ្រួយស្លឹកឈើយកខ្សែក្រកូញទាញ ឬបំពង់ឫស្សីដែលលាបថ្នាំដាក់ចុះហើយ យកទឹកផ្កាបន្តក់ក្នុងបំពង់ ឬទឹកប្រេងដាក់ក្នុងបំពង់ឫស្សីនោះឲ្យហូរចូលទៅក្នុងទ្វារធ្ងន់ដូច្នេះក៏គួរ ថុល្លច្ច័យទាំង ៤ នេះជាសចិត្តកៈ ។

១– អណ្ឌៈ ក្នុងទីនេះសំដៅយកពងស្វាស ។

បទមួយ ភិក្ខុកុំឆាន់សាច់មនុស្ស បើឆាន់ត្រូវថុល្លច្ច័យ ដ្បិតទ្រង់ឃាត់ទុកថា ន ភិក្ខវេ មនុស្សមំសំ បរិភុញ្ជិតព្វំ ដូច្នេះ មិនតែសាច់មនុស្សប៉ុណ្ណោះទេ សូម្បីឆ្អឹងឈាមស្បែករោមក៏មិនគួរ សិក្ខាបទនេះជាអចិត្តកៈ ។

មួយទៀត អាបត្តិថុល្លច្ច័យមានច្រើន ដែលមិនបានឡើងកាន់បាតិមោក្ខុទ្ទេស ពោលដោយអាគតដ្ឋានទីបកមាន ៣ ស្ថាន គឺមកក្នុងខន្ធកៈ១ ឈ្មោះខន្ធកថុល្លច្ច័យ, មកក្នុងវិនីតវត្ថុនៃបារាជិក និងសង្ឃាទិសេស ១ ឈ្មោះថាវិនីតវត្ថុថុល្លច្ច័យ, មកក្នុងវិភង្គនៃបារាជិក និងសង្ឃាទិសេស១ ឈ្មោះថាវិភង្គថុល្លច្ច័យ, ព្រោះហេតុនោះបញ្ញត្តិនៃថុល្លច្ចយាបត្តិ ទើបមានច្រើន មិនមានកំណត់ ។

ខន្ធកថុល្លច្ច័យនោះថាដូច្នេះ ភិក្ខុកុំគប្បីកាន់លទ្ធិតិរ្ថិយសមាទាននីវត្តបដិបត្តិនៃតិរ្ថិយ អាក្រាតកាយ មិនស្លៀកដណ្តប់ ភិក្ខុណាបដិបត្តិដូច្នេះ ត្រូវថុល្លច្ច័យ ភិក្ខុកុំស្លៀកដណ្តប់ស្បូវក្រង កុំទ្រង់សំពត់ដែលក្រងចាក់ទៅដោយសំបកឈើ កុំទ្រង់សំពត់ដែលធ្វើដោយក្តារ កុំទ្រង់សំពត់កម្ពលដែលធ្វើដោយសក់មនុស្ស កុំទ្រង់សំពត់កម្ពលធ្វើដោយរោមកន្ទុយសត្វ កុំទ្រង់សំពត់ធ្វើដោយស្លាបមៀម កុំទ្រង់ស្បែកខ្លា កុំទ្រង់សំពត់ដែលធ្វើដោយដើមរក់ សំពត់ទាំងអស់នេះជាទង់នៃតិរ្ថិយ ភិក្ខុណាទ្រង់សំពត់ទាំងអម្បាលនេះ ត្រូវថុល្លច្ច័យ ។

www.budinst.gov.kh www.elibraryofcambodia.org

បទមួយថា ភិក្ខុកុំពាល់ត្រូវអង្គជាតិ នៃតិរច្ឆានញីដោយចិត្តត្រេក បើពាល់ត្រូវ ត្រូវថុល្លច្ច័យ ។

បទមួយថា ថ្ងៃឧបោសថ ថ្ងៃបវារណា ភិក្ខុអាវាសិកៈតាំងពីតែ ៤ ឬ ៥ អង្គឡើងទៅ ដឹងថាភិក្ខុអាវាសិកៈផងគ្នា ឬភិក្ខុអាគន្តុកៈមានទៅក្នុងសីមាជាមួយគ្នា តែថាមិនទាន់មកកាន់ពេលឧបោសថ ពេលបវារណា ចូលហត្ថបាស ក្លែងនឹងឲ្យភិក្ខុនោះវិនាសអន្តរាយចាកឧបោសថ ចាកបវារណា ហើយប្រញាប់ធ្វើឧបោសថនឹងបវារណាជាមុនត្រូវថុល្លច្ច័យ ថុល្លច្ច័យទាំងនេះក្តី ថុល្លច្ច័យបទមុន ៥ នោះក្តី ជាខន្ធកថុល្លច្ច័យ ។

វិនីតវត្ថុថុល្លច្ច័យនោះ ភិក្ខុប្រាថ្នានឹងឲ្យអសុចិហូរចេញ ដើរតាមផ្លូវទៅអសុចិមិនកម្រើកចាកទី ហើយកើតសង្ស័យ ទើបក្រាបទូលដល់ព្រះពុទ្ធអង្គ ព្រះពុទ្ធអង្គទ្រង់កាត់ថាត្រូវថុល្លច្ច័យ ។ បទមួយថា ភិក្ខុបបោសអង្គុលពាល់ត្រូវកាយស្រីដែលស្លាប់ហើយ ហើយកើតសង្ស័យ ទើបក្រាបទូលសួរដល់ព្រះពុទ្ធអង្គ ព្រះពុទ្ធអង្គទ្រង់កាត់ថាត្រូវថុល្លច្ច័យ ថុល្លច្ច័យដូច្នេះ ឈ្មោះថាវិនីតវត្ថុថុល្លច្ច័យ ។

ឯវត្តិថុល្លច្ច័យនោះ មានច្រើនប្រការ គឺជាអនុស្សាវនថុល្លច្ច័យខ្លះ វិមត្តិថុល្លច្ច័យខ្លះ យថាសញ្ញាថុល្លច្ច័យខ្លះ យថាខេត្តថុល្លច្ច័យខ្លះ យថាវត្ថុថុល្លច្ច័យខ្លះ យថាបយោគថុល្លច្ច័យខ្លះ យថារដ្ឋថុល្លច្ច័យខ្លះ ។

ឯអនុស្សាវនថុល្លច្ច័យនោះ ដូចអាបត្តិថុល្លច្ច័យ ព្រោះសង្ឃធ្វើ

www.budinst.gov.kh www.elibraryofcambodia.org

សមនុភាសនកម្ម ១១ ណាមួយ ដល់ភិក្ខុនីឯភិក្ខុនី ដើម្បីនឹងឲ្យលះកម្ម នោះៗ ចេញ ហើយភិក្ខុមិនលះចេញ លុះចប់អនុសាវនៈទី ២ ត្រូវថុល្លច្ច័យ ថុល្លច្ច័យដូច្នេះ ឈ្មោះថាអនុសាវនថុល្លច្ច័យ អនុសាវន-ថុល្លច្ច័យនេះ កាលបើចប់ អនុសាវនៈគំរប់ ៣ ត្រូវគរុកាបត្តិហើយ ថុល្លច្ច័យនោះរម្ងាប់បាត់ទៅឯង មិនត្រូវសំដែង ។

ស្រី ភិក្ខុសង្ស័យថាស្រី ឬ មិនមែនស្រី ហើយមានចិត្តជំរេកពាល់ត្រូវកាយស្រីនោះដោយកាយខ្លួន ត្រូវថុល្លច្ច័យ ថុល្លច្ច័យដូច្នេះឈ្មោះថា វិមតិថុល្លច្ច័យ ព្រោះត្រូវដោយសង្ស័យ ។

ស្រី ភិក្ខុសំគាល់ថាជាបណ្ឌកៈ ហើយមានចិត្តជំរេកពាល់ត្រូវកាយស្រីនោះ ដោយកាយខ្លួន ត្រូវថុល្លច្ច័យ ថុល្លច្ច័យដូច្នេះ ឈ្មោះថា យថាសញ្ញាថុល្លច្ច័យ ព្រោះត្រូវអាបត្តិតាមសេចក្តីសំគាល់ ។

ភិក្ខុមានចិត្តជំរេក សរសើរឬតិះដៀលអវយវៈស្រី ខាងក្រោមអំពីដងកាំបិតចុះទៅ ខាងលើអំពីជង្គង់ឡើងមក វៀរតែទ្វារធ្ងន់ទ្វារស្រាល ចេញ ត្រូវថុល្លច្ច័យ ថុល្លច្ច័យដូច្នេះ ឈ្មោះថា យថាវត្ថុថុល្លច្ច័យ ព្រោះត្រូវអាបត្តិតាមវត្ថុតែផង ។

ភិក្ខុចាប់ពាល់ត្រូវកាយបណ្ឌកៈដោយកាយខ្លួន ដោយចិត្តជំរេក ត្រូវថុល្លច្ច័យ ថុល្លច្ច័យដូច្នេះឈ្មោះថា យថាវត្ថុថុល្លច្ច័យ ព្រោះត្រូវអាបត្តិតាមវត្ថុ ។

www.budinst.gov.kh www.elibraryofcambodia.org

ភិក្ខុមានថេយ្យចិត្ត នាំខ្ញុំគេរត់ក្តី បបួលក្តី ដេញក្តី ឲ្យខ្ញុំគេនោះ លើកបាទាជាបឋម ត្រូវថុល្លច្ច័យ ថុល្លច្ច័យដូច្នេះឈ្មោះថា យថាបយោគ ថុល្លច្ច័យ ព្រោះត្រូវអាបត្តិតាមប្រយោគដែលប្រកប ។

ភិក្ខុចំពោះខ្លួនឯង ហើយតាំងយកអ្នកដទៃជាបរិយាយ អួតឧត្តរិមនុស្សធម្មថា អ្នកណានៅក្នុងវិហារ អ្នកនោះជាព្រះអរហន្តដូច្នេះជាដើម អ្នកស្តាប់ដឹងសេចក្តីក្នុងខណៈនោះ ភិក្ខុនោះត្រូវថុល្លច្ច័យ ថុល្លច្ច័យដូច្នេះ ឈ្មោះថា យថាវត្ថុថុល្លច្ច័យ ព្រោះត្រូវអាបត្តិតាមទោស ។ ព្រោះអាបត្តិថុល្លច្ច័យមានច្រើនយ៉ាងផ្សេងៗគ្នាដូច្នេះ ទើបមិនមានកំណត់ដូចបារាជិកនិងសង្ឃាទិសេសជាដើម ។

ថុល្លច្ច័យ ចប់

## និស្សគ្គិយុទ្ទេស

សំដែងអំពីនិស្សគ្គិយបាចិត្តិយ, និស្សគ្គិយបាចិត្តិយ មានសិក្ខាបទ ៣០ ចែកជា ៣ វគ្គ វគ្គជាបឋមឈ្មោះចីវរវគ្គ, ចីវរវគ្គនេះ មាន ១០ សិក្ខាបទ ៖

សិក្ខាបទទី ១ ឈ្មោះបឋមកឋិន សេចក្តីថា ចីវរភិក្ខុធ្វើស្រេច ហើយ កឋិនដោះហើយ គឺអានិសង្សកឋិនទាំង ៥ រម្ងាប់ហើយ បលិពោធ ២ ដាច់ហើយ ភិក្ខុទុកអតិរេកចីវរ (គឺចីវរដែលមិនបានវិកប្ប ឬអធិដ្ឋាន)

www.budinst.gov.kh www.elibraryofcambodia.org

បានតែត្រឹម ១១ ថ្ងៃ ជាយ៉ាងក្រៃពេក កាលភិក្ខុទុកអតិរេកចីវរនោះឲ្យហួស ១០ ថ្ងៃទៅ ដល់អរុណជាគំរប់ ១១ រះឡើងមក ចីវរនោះត្រូវនិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ។

កំណើតសំពត់មាន ៦ គឺ ខោមំ សំពត់ដែលត្បាញដោយសរសៃសំបកឈើ គារប្បាសិកំ សំពត់ដែលត្បាញដោយអំបោះកប្បាស កោសេយ្យំ សំពត់ដែលត្បាញដោយសរសៃសូត្រ កម្ពលំ សំពត់ដែលត្បាញដោយរោមសត្វ វៀរតែរោមមនុស្ស រោមកន្ទុយសត្វចេញ សាណំ សំពត់ដែលត្បាញដោយសំបកធ្មៃ ភង្គំ សំពត់ដែលត្បាញលាយដោយសរសៃវត្ថុទាំង ៥ មានសំបកឈើជាដើម ចីវរទាំង ៦ ប្រការនេះគឺ សំពត់ទុកូល នឹងសំពត់បត្តុណ្ណៈ នឹងសំពត់សោមារបដៈ នឹងសំពត់ចិនបដៈ នឹងសំពត់ឥទ្ធិជៈ នឹងសំពត់ទេវតាឲ្យ ទាំងអស់នេះជាអនុលោមតាមសំពត់ ៦ ប្រការខាងដើមនោះ ឈ្មោះថាចីវរ បើមិនបានអធិដ្ឋាននឹងវិកប្ប ឈ្មោះថាអតិរេកចីវរ រាប់អំពីថ្ងៃដែលបានចីវរនោះមកទុក លុះអរុណគំរប់ ១១ រះឡើងមក មិនបានអធិដ្ឋាន មិនបានវិកប្ប មិនលះចេញក្នុងខាងក្នុង ១០ ថ្ងៃនោះ ចីវរនោះត្រូវនិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ។ បើមិនលះមិនធ្វើវិនយកម្ម ដល់សង្ឃ ឬ គណៈ ឬ បុគ្គល ជាមុន យកមកបរិភោគគឺស្លៀកដណ្តប់ ត្រូវទុក្កដ ។ ឯវិធីអធិដ្ឋាន នឹងវិកប្ប នឹងលះចីវរដែលត្រូវនិស្សគ្គិយនោះ នឹងសំដែងទៅខាងមុខ ។ ចីវរភេទនឹងទៅ ១០

www.budinst.gov.kh www.elibraryofcambodia.org

ថ្ងៃហើយ ភិក្ខុដឹងថាកន្លង ១០ ថ្ងៃហើយក្តី សង្ស័យក្តី សំគាល់ថាមិនទាន់កន្លងក្តី ក៏គង់ត្រូវនិស្សគ្គិយបាចិត្តិយ, បើនៅមិនទាន់បានអធិដ្ឋាននិងវិកប្ប មិនទាន់បានលះឲ្យអ្នកដទៃ ហើយមិនវិនាសដោយហេតុណាមួយក្តី សំគាល់ថាអធិដ្ឋានជាដើមហើយក្តី កន្លង ១០ ថ្ងៃទៅ ក៏គង់ត្រូវនិស្សគ្គិយបាចិត្តិយ ។ ចីវរមិនទាន់កន្លង ១០ ថ្ងៃ សំគាល់ថាកន្លងហើយក្តី សង្ស័យក្តី យកមកប្រើប្រាស់ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះគឺ ភិក្ខុអធិដ្ឋានហើយ វិកប្បហើយ និងលះបង់ឲ្យអ្នកដទៃក្នុងខាងក្នុង ១០ ថ្ងៃ ចីវរនោះបាត់ទៅ វិនាសទៅ ភ្លើងឆេះទៅ ចោរដណ្តើមយកទៅ គេកាន់យកដោយវិស្សាសៈក្នុងខាងក្នុង ១០ ថ្ងៃក្តី និងភិក្ខុឆ្កួតជាដើមក្តី តាំងអំពីពេលនេះមិនត្រូវអាបត្តិ ។ សិក្ខាបទនេះជាអនាណត្តិកៈ មានអង្គ ៥ គឺ ជាតិប្បមាណសម្បន្នស្ស ចីវរស្ស អត្តនោ សន្តកតា ចីវរប្រកបដោយជាតិនិងប្រមាណជារបស់ខ្លួន ១ គណនូបគតា ចីវរនោះដល់នូវការរាប់ថ្ងៃបាន គឺជាដល់ថ្ងៃខ្លួនហើយ ឬបានពុះហើយថាជាសំពត់របស់ខ្លួន ១ ឆិន្នបលិពោធតា បលិពោធទាំងពីរដាច់ហើយ ១ អតិរេកចីវរតា ចីវរនោះជាអតិរេកចីវរ ១ ទសាហាតិក្កមោ កន្លង ១០ ថ្ងៃទៅ ១ ព្រមដោយអង្គ ៥ នេះ ទើបត្រូវនិស្សគ្គិយបាចិត្តិយ ។ ដោយជាឯកសមុដ្ឋាន គឺអាបត្តិកើត

www.budinst.gov.kh www.elibraryofcambodia.org

អំពីកាយវាចា ១ អំពីកាយវាចាចិត្ត ១ ជាអកិរិយា នោសញ្ញាវិមោក្ខ សចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ។

បឋមកឋិនសិក្ខាបទ ជាបឋម ចប់

---

សិក្ខាបទ ទី ២ ឈ្មោះទុតិយកឋិន មានការហៅឧទោសិត-សិក្ខាបទខ្លះ សេចក្តីថា ចីវរនៃភិក្ខុសំរេចហើយ កឋិនដោះហើយ បើភិក្ខុនៅប្រាសចាកត្រៃចីវរទាំង ៣ ផត់ ឬផត់ណាមួយ សូម្បីតែមួយរាត្រី ចីវរនោះ ត្រូវនិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ វៀរតែភិក្ខុមានជម្ងឺ បានអវិប្បវាសសម្មតិ នៅប្រាសចាកត្រៃចីវរបាន សង្ឃាដិ ឧត្តរាសង្គៈ អន្តរវាសកៈ ចីវរទាំង ៣ នេះ ភិក្ខុអធិដ្ឋានតាមឈ្មោះហើយ គឺហៅថាត្រៃចីវរ ត្រូវរក្សា បើមិនរក្សាទុក ទាល់ឲ្យអរុណថ្មីរះឡើងមក ឈ្មោះថានៅប្រាសចាកចីវរនោះ ។

ក៏ឯទីដែលនឹងរក្សាចីវរនោះមាន ១៥ គឺ ស្រុក ១ ផ្ទះ ១ ឃ្លាំង ១ បញ្ចា ១ រោងមូល ១ ប្រាសាទ ១ ប្រាសាទរលីង ១ នាវា ១ ពួករទេះ ១ ស្រែ ១ លានស្រូវ ១ ឧទ្យាន ១ វិហារ ១ គល់ឈើ ១ ទីវាល ១ ទីទាំងអម្បាលនេះ បើម្ចាស់របស់ម្នាក់ព័ទ្ធព័ទ្ធដោយកំផែង របង ឬគូរ ភិក្ខុទុកចីវរក្នុងទីទាំងអម្បាលនេះ គឺឲ្យនៅក្នុងទីព័ទ្ធព័ទ្ធនោះ បើទីទាំងអម្បាលនេះមិនបានព័ទ្ធព័ទ្ធ ទុកចីវរក្នុងទីណា ឲ្យនៅក្នុងទីនោះ កុំលះហត្ថបាសអំពីទីនោះ បើទីទាំងនោះមានម្ចាស់ផ្សេងៗគ្នា

www.budinst.gov.kh www.elibraryofcambodia.org

ជាទីព័ទ្ធព័ទ្ធ ទុកចីវរក្នុងទីណា ឲ្យនៅក្នុងទីនោះ ឬនៅក្នុងទីជាទីប្រជុំ នឹងច្រកទ្វារជាមណ្ឌលចេញ កុំលះហត្ថបាសអំពីទីនោះចេញ បើទីអម្បាលនោះគេមិនបានព័ទ្ធព័ទ្ធ ទុកចីវរក្នុងផ្ទះណា ឲ្យនៅក្នុងផ្ទះនោះ កុំលះហត្ថបាសអំពីផ្ទះនោះ បើភិក្ខុមិននៅក្នុងទីដូចសំដែងនេះ ចីវរដែលនៅប្រាសចាកនោះ ត្រូវនិស្សគ្គិយ ព្រមដោយអរុណខ្ទង់ឡើងមក ត្រូវលះចីវរនោះដល់សង្ឃ ឬគណៈ ឬបុគ្គល ទើបស្ញៀកដណ្តប់បាន វិធីលះជាដើម ដូចសំដែងទៅខាងមុខ ព្រោះហេតុនោះ តទៅខាងមុខគប្បីដឹងចុះថា របស់ត្រូវនិស្សគ្គិយហើយត្រូវលះជាមុន ទើបសំដែងអាបត្តិជាច់ តទៅនឹងមិនបានសំដែងទៀត ។ ត្រៃចីវរភិក្ខុនៅប្រាសចាកហើយ ដឹងថានៅប្រាសចាកហើយក្តី សង្ស័យក្តី សំគាល់ថាមិនបានប្រាសចាកក្តី ក៏គង់ត្រូវនិស្សគ្គិយបាចិត្តិយ ។ ត្រៃចីវរភិក្ខុនៅមិនទាន់បានបច្ចុទ្ធរណៈ មិនទាន់បានលះ មិនទាន់បាត់ទៅជាដើម ភិក្ខុសំគាល់ថាបច្ចុទ្ធរណៈហើយជាដើមក្តី សង្ស័យក្តី ដឹងថាមិនទាន់បច្ចុទ្ធរណៈជាដើមក្តី ហើយនៅប្រាសចាកចីវរនោះ ក៏គង់ត្រូវនិស្សគ្គិយបាចិត្តិយ ។ ត្រៃចីវរភិក្ខុមិនបាននៅប្រាសចាក សំគាល់ថានៅប្រាសចាកក្តី សង្ស័យក្តី យកមកបរិភោគត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះគឺ បច្ចុទ្ធរណៈចេញហើយក្តី លះបង់ហើយជាដើម ខាងក្នុងអរុណ នឹងភិក្ខុមានជម្ងឺដែលសង្ឃសម្មតិឲ្យនៅ

www.budinst.gov.kh www.elibraryofcambodia.org

ប្រាសចាកត្រៃចីវរក្តី ឬនឹងភិក្ខុឆ្កួតជាដើមក្តី មិនត្រូវអាបត្តិ ជាអនាណត្តិកៈ មានអង្គ ៤ គឺ អធិដ្ឋិតចីវរតា សំពត់ភិក្ខុអធិដ្ឋានជាត្រៃចីវរហើយ ១ អនត្ថតកឋិនតា មិនមានកឋិនសង្គ្រប់ ១ អលទ្ធសម្មុតិតា មិនបានអវិប្បវាសសម្មុតិ ១ រត្តិវិប្បវាសោ នៅប្រាសចាកចីវរនោះមួយរាត្រី លុះអរុណរះឡើងមក ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវនិស្សគ្គិយបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចបឋមកឋិនសិក្ខាបទមុន ប្លែកតែសិក្ខាបទមុន មិនបានអធិដ្ឋានមិនបានវិកប្ប ឈ្មោះជាអកិរិយា ត្រូវព្រោះមិនធ្វើ ក្នុងសិក្ខាបទនេះ ត្រូវព្រោះមិនបច្ចុទ្ធរណៈចេញក្នុងអរុណ ឈ្មោះជា អកិរិយា ត្រូវព្រោះមិនធ្វើ ។

ទុតិយកឋិនសិក្ខាបទ គំរប់ ២ ចប់

សិក្ខាបទ គំរប់ ៣ ឈ្មោះតតិយកឋិន សេចក្តីថា ចីវរនៃភិក្ខុសំរេចហើយ កឋិនដោះហើយ សំពត់អកាលចីវរ គឺសំពត់ដែលកើតក្រៅចីវរកាល ឬនឹងសំពត់ដែលទាយកឲ្យចំពោះជាអកាលចីវរ ប្រគេនក្នុងចីវរកាលក្តី សំពត់ដូច្នេះ បើកើតឡើងដល់ភិក្ខុ ភិក្ខុដែលប្រាថ្នាគប្បីទទួលហើយប្រញាប់ធ្វើក្នុងវាងក្នុង ១០ ថ្ងៃ បើសំពត់នោះមិនល្មមគ្រាន់ដល់ការធ្វើជាសង្ឃាដិ ឬឧត្តរាសង្គៈ ឬអន្តរវាសកៈ ចីវរណាមួយ បើប្រាថ្នាថានឹងបានសំពត់ញាតិនឹងមិត្រសំឡាញ់ជាដើម ភិក្ខុគប្បីទុកសំពត់មុននោះជាអតិរេកចីវរបានមួយខែ ដើម្បីនឹងផ្គុំគ្នានឹងសំពត់ដែលប្រាថ្នា

www.budinst.gov.kh www.elibraryofcambodia.org

ចង់បាននោះ បើទុកឲ្យហួសមួយថ្ងៃ ដោយមិនបានអធិដ្ឋានមិនបានវិកប្ប សូម្បីប្រាថ្នាថានឹងបានចីវរដទៃ ចីវរមុនគង់ត្រូវនិស្សគ្គិយបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចបឋមកឋិន ប្លែកតែសិក្ខាបទនេះកន្លងមួយថ្ងៃ ។

តតិយកឋិនសិក្ខាបទ តំរប់ ៣ ចប់

---

សិក្ខាបទ តំរប់ ៤ ឈ្មោះបុរាណចីវរ សេចក្តីថា ភិក្ខុណាប្រើភិក្ខុនី មិនមែនញាតិ ដែលបានឧបសម្បទាក្នុងឧភតោសង្ឃ គឺភិក្ខុសង្ឃនឹងភិក្ខុនីសង្ឃ ឲ្យគក់ ឲ្យជ្រលក់ ឬបោក នូវចីវរចាស់ គឺចីវរដែលស្លៀកដណ្តប់រួចហើយ សូម្បីស្លៀកតែម្តង ចីវរនោះត្រូវនិស្សគ្គិយបាចិត្តិយ ៖

បុរាណចីវរសិក្ខាបទ តំរប់ ៤ ចប់

---

សិក្ខាបទ តំរប់ ៥ ឈ្មោះចីវរបដិគ្គហណៈ សេចក្តីថា ភិក្ខុណាទទួលចីវរទំហំប្រវែងគួរវិកប្ប អំពីដៃភិក្ខុនីមិនមែនញាតិ ដែលបានឧបសម្បទាក្នុងឧភតោសង្ឃ ចីវរនោះត្រូវនិស្សគ្គិយបាចិត្តិយ វៀរតែប្តូរគ្នា សូម្បីតែដោយរបស់តិចតួច មិនត្រូវអាបត្តិ ។

ចីវរបដិគ្គហណសិក្ខាបទ តំរប់ ៥ ចប់

---

សិក្ខាបទ តំរប់ ៦ ឈ្មោះអញ្ញាតកវិញ្ញត្តិ សេចក្តីថា ភិក្ខុណាសូមឯង ឬប្រើអ្នកដទៃឲ្យសូមនូវចីវរដែលគួរវិកប្ប សូម្បីជាបច្ឆិមប្រមាណ អំពីគ្រហស្ថមិនមែនញាតិ ក្នុងប្រយោគដែលសូមត្រូវទុក្កដ បានមកត្រូវ

www.budinst.gov.kh www.elibraryofcambodia.org

និស្សគ្គិយបាចិត្តិយ ទៀតែមានសម័យ គឺកាលភិក្ខុមានចីវរគេដណ្តើមយកអស់ ឬមានចីវរបាត់អស់ ទើបសូមបាន មិនត្រូវអាបត្តិ ។ អ្នកដែលជាប់សាច់សាលោហិត ចំណែកខាងមាតាក្តី ឬខាងបិតាក្តី (រាប់អំពីចៅទួត) ដរាបដល់ត្រូវជីដូនជីតាជាត់រប់ ៧ ឈ្មោះថាញាតិ ។ ក្នុងមនុស្សមិនមែនញាតិត្រូវតែកបាចិត្តិយ គឺគេមិនមែនញាតិ ដឹងថាគេមិនមែនញាតិក្តី សង្ស័យក្តី សំគាល់ថាជាញាតិក្តី បើសូមគង់ត្រូវបាចិត្តិយ ។ គទៅខាងមុខក្នុងពាក្យថា តែកបាចិត្តិយដូច្នេះ គប្បីដឹងដោយន័យដូចសំដែងហើយនេះចុះ នឹងមិនពោលឲ្យពិស្តារតទៅទៀត នឹងពោលត្រឹមតែពាក្យថាតែកបាចិត្តិយប៉ុណ្ណោះ ។ គេជាញាតិ ភិក្ខុសំគាល់ថាមិនមែនញាតិក្តី សង្ស័យក្តី ហើយសូមសំពត់ ដូចពោលមកនោះ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺសូមក្នុងសម័យក្តី សូមអំពីញាតិ ឬមនុស្សបវារណាក្តី សូមដើម្បីអ្នកដទៃក្តី ផ្លាស់ប្តូរដោយទ្រព្យរបស់ខ្លួនដែលជាកប្បិយក្តី នឹងភិក្ខុឆ្កួតជាដើមក្តី ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ចីវររបស់ភិក្ខុដែលស្តេច ឬអ្នកលេង ឬចោរ អ្នកណាមួយដណ្តើមយកទៅ ឈ្មោះថាភិក្ខុមានចីវរគេដណ្តើមយកទៅអស់, ចីវរភិក្ខុដែលភ្លើងឆេះទៅក្តី អណ្តែតទឹកបាត់ទៅក្តី កណ្តុរ ឬ កណ្តៀរកាត់ក្តី ចាស់ដាច់ដាចខ្ទិចដោយស្លៀកដណ្តប់ក្តី ដូច្នេះឈ្មោះថាមានចីវរបាត់ ឈ្មោះថាមានសម័យ, ព្រះពុទ្ធអង្គទ្រង់អនុញ្ញាតឲ្យសូមចីវរអំពីគ្រហស្ថ

www.budinst.gov.kh www.elibraryofcambodia.org

មិនវែមខញ្ញត្តិបាន បើមិនទាន់បានសូម ទៅដល់អាវាសណាមុន ខិង កាន់យកសំពត់សិក្ខាបរិហារ ខិងសំពត់គ្រាលលើគ្រែ លើថ្វ គ្រោមពូក ជារបស់សង្ឃក្នុងអាវាសនោះ មកស្លៀកដណ្តប់ ដោយគិតខឹងប្រគល់ឱ្យវិញក៏គួរ បើមិនបានចីវរដូច្នេះ គប្បីបិទបាំងកាយដោយស្មៅ ឬស្លឹកឈើហើយសឹមមក កុំអាក្រាតកាយដើរមក បើអាក្រាតកាយដើរមក ត្រូវទុក្កដ, គ្រហស្ថមានសទ្ធាពោលថា " ខ្ញុំបវារណាដោយបច្ច័យ ៤ មានចីវរជាដើម បើលោកម្ចាស់ត្រូវការដោយបច្ច័យអ្វី គប្បីប្រាប់ ឬសូមខ្ញុំ ខ្ញុំខឹងប្រគេនបច្ច័យនោះដូច្នេះ" ឈ្មោះថាមនុស្សបវារណា គេបវារណាជាសង្ឃ ដឹងប្រមាណទើបគួរ គេបវារណាជាបុគ្គលចំពោះខ្លួន ដោយបច្ច័យណា ឱ្យសូមតែបច្ច័យនោះ ទាយកគេបវារណាដោយបច្ច័យទាំង ៤ ហើយគេកំណត់ដោយខ្លួនឯង ហើយគេប្រគេនចីវរតាមកាល ប្រគេនបបរ.បាយជាដើមសព្វ ១ ថ្ងៃ ត្រូវការដោយបច្ច័យណា គេប្រគេនបច្ច័យនោះដូច្នេះ កិច្ចដែលខឹងសូមមិនមាន ទាយកណាបវារណាហើយមិនបានឱ្យ ព្រោះជាមនុស្សទ្វេ ឬភ្លេចទៅ ទាយកដូច្នេះឱ្យគប្បីសូម ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺសូមអំពីញាតិខិងមនុស្សបវារណារបស់ខ្លួន សូមដើម្បីភិក្ខុដទៃក្តី ឬគេជាញាតិ ជាមនុស្សបវារណានៃភិក្ខុអង្គណា សូមដើម្បីភិក្ខុអង្គនោះក្តី មិនត្រូវអាបត្តិ ។ ជាអនាណត្តិកៈ

www.budinst.gov.kh www.elibraryofcambodia.org

ព្រោះពឹងឲ្យភិក្ខុសូមអំពីញាតិ ទើបមនុស្សបវារណានៃភិក្ខុ ឲ្យដល់ខ្លួន មិនត្រូវអាបត្តិ ។ មានអង្គ ៤ គឺ វិកប្បុបគចីវរតា ចីវរទំហំប្រវែងត្រូវនឹងវិកប្ប ១ សមយាភាវោ មិនមានសម័យ ១ អញ្ញាតកវិញ្ញត្តិ សូមអំពីមនុស្សមិនមែនញាតិ ១ តាយ ច បដិលាភោ បានមកដោយការសូមនោះ ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវនិស្សគ្គិយបាចិត្តិយ ។ សិក្ខាបទនេះជាសញ្ចរិត្តសមុដ្ឋាន ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ។

អញ្ញាតកវិញ្ញត្តិសិក្ខាបទ គំរប់ ៦ ចប់

---

សិក្ខាបទ គំរប់ ៧ ឈ្មោះតតុត្តរិ សេចក្តីថា ភិក្ខុមានចីវរដែលមនុស្សដណ្តើមយក ឬបាត់ទៅ ដូចសំដែងហើយក្នុងសិក្ខាបទមុន បើគ្រហស្ថមិនមែនញាតិនាំចីវរច្រើនមកបវារណាឲ្យភិក្ខុ ភិក្ខុនោះបើមានចីវរបាត់ទាំង ៣ គប្បីត្រេកអរតែចីវរ ២ គឺចីពរនិងស្បង់, បើបាត់ ២ គប្បីត្រេកអរតែ ១ បើបាត់តែ ១ កុំត្រេកអរឡើយ បើភិក្ខុត្រេកអរឲ្យហួសកំណត់ទៅសោត ក្នុងប្រយោគដែលសូម ត្រូវទុក្កដ ។ ចីវរដែលបានមកនោះ ត្រូវនិស្សគ្គិយបាចិត្តិយ ក្នុងមនុស្សមិនមែនញាតិ ត្រូវតិកបាចិត្តិយ ។ ញាតិភិក្ខុសំគាល់ថាមិនមែនញាតិក្តី សង្ស័យក្តី សូមហើយត្រេកអរឲ្យហួសកំណត់ត្រូវទុក្កដ ។

www.budinst.gov.kh www.elibraryofcambodia.org

ឯវិធីដែលមិនត្រូវអាបត្តិនោះគឺ ភិក្ខុពោលថាយើងនឹងរើសយកចីវរតែ ២ សល់ក្រៅអំពីនោះនឹងយកមកប្រគល់ឲ្យវិញ ហើយយកទៅប្រើមុនក្តី ម្ចាស់របស់ពោលថាដែលសល់នៅនោះ ចូរជារបស់លោកក្តី នឹងកាន់យកចីវរដែលទាយកគេមិនបានឲ្យ ព្រោះថាភិក្ខុមានចីវរចោរដណ្តើម ឬបាត់ទៅក្តី សូមអំពីញាតិ អំពីមនុស្សបវារណាក្តី ដូរយកដោយទ្រព្យខ្លួនដែលជាកប្បិយក្តី នឹងភិក្ខុគេជាដើមក្តី ទាំងអម្បាលនេះមិនត្រូវអាបត្តិ ។ ជាអនាណត្តិកៈ មានអង្គ ៤ គឺ តទុត្តរិតា ត្រេកអរឲ្យហួសកំណត់ ១ អច្ឆិន្នាទិការណតា មិនមានហេតុជាដើមជាចីវរគេដណ្តើមយកអស់ ១ អញ្ញាតកវិញ្ញត្តិ សូមអំពីមនុស្សមិនមែនញាតិ ១ តាយ ច បដិលាភោ បានមកដោយការសូមនោះ ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវនិស្សគ្គិយបាចិត្តិយ ។ សមុដ្ឋានវិធីជាដើមដូចសិក្ខាបទមុន ។

តទុត្តរិសិក្ខាបទ គំរប់ ៧ ចប់

សិក្ខាបទ គំរប់ ៨ ឈ្មោះ បឋមឧបក្ខដៈ សេចក្តីថា គ្រហស្ថមិនមែនញាតិគេចំពោះភិក្ខុ កាន់ដំឡៃចីវរមានប្រាក់មាសជាដើមទុកថា យើងនឹងយកដំឡៃចីវរប៉ុណ្ណោះ ទិញចីវរប្រគេនភិក្ខុឈ្មោះនេះ ភិក្ខុនោះទាយកគេមិនបានបវារណាមុន ដឹងដំណឹងឯង ប្រាថ្នាចង់បានចីវរល្អ ហើយ

www.budinst.gov.kh www.elibraryofcambodia.org

ចូលទៅនិយាយនឹងទាយកថាល្អហើយ អ្នកចូរយកថ្លៃចីវរនោះ ទិញ សំពត់ ឲ្យវែង ឲ្យធំ ឲ្យមានសាច់ណែន ឲ្យមានសាច់ម៉ដ្ឋ ឲ្យអាត្មាចុះ ទាយកថែមថ្លៃឲ្យទិញសំពត់ដែលល្អតាមពាក្យភិក្ខុ សំពត់ដែលបានមក ត្រូវនិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយៈ ។ ទាយកគេជាញាតិសំគាល់ថា មិនមែនញាតិ ឬសង្ស័យ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះគឺ ភិក្ខុដែលទាយកគេនឹងទិញឲ្យល្អ បង្គាប់ឲ្យគេទិញថយចុះមកក្តី ឬឲ្យគេកចីវរថ្លៃស្មើនឹងថ្លៃដែលគេ កំណត់ទុកក្តី ឬសូមអំពីញាតិ អំពីមនុស្សបវារណាក្តី ទិញយកដោយ ទ្រព្យរបស់ខ្លួនក្តី នឹងភិក្ខុឆ្កួតជាដើមក្តី តាំងអម្បាលនេះមិនត្រូវអាបត្តិ ។ សិក្ខាបទនេះជាអនាណត្តិកៈ ជាតិកបាចិត្តិយ មានអង្គ ៣ គឺ ចីវរេ ភិយ្យោកម្យតា ប្រាថ្នាចង់បានចីវរឲ្យល្អលើសជាងគេកំណត់ ១ អញ្ញាតកវិញ្ញត្តិ សូមអំពីទាយកមិនមែនញាតិ ១ តាយ ច បដិលាភោ បានចីវរមកដោយការសូមនោះ ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវនិស្សគ្គិយបាចិត្តិយ បើមិនព្រមមិនត្រូវអាបត្តិ ។ សមុដ្ឋានវិធី ជាដើម ដូចតតុត្តរិសិក្ខាបទ ។

បឋមឧបក្ខដសិក្ខាបទ ទី ៨ ចប់

---

សិក្ខាបទ ទី៩ ឈ្មោះ ទុតិយឧបក្ខដៈ សេចក្តីដូចបឋមឧបក្ខដៈ សិក្ខាបទមុន ប៉ុន្តែសិក្ខាបទមុននោះម្ចាស់របស់តែម្នាក់ ភិក្ខុធ្វើការ

www.budinst.gov.kh www.elibraryofcambodia.org

បៀតបៀនដល់មនុស្សម្នាក់ៗ ក្នុងសិក្ខាបទនេះម្ចាស់របស់ច្រើននាក់ ភិក្ខុទៅនិយាយឲ្យគេចូលហ៊ុនគ្នាវិញ ឈ្មោះថាធ្វើការបៀតបៀនដល់ជនច្រើននាក់ ប្លែកគ្នាតែប៉ុណ្ណោះ សេចក្ដីក្រៅពីនោះដូចសិក្ខាបទមុន

ទុតិយឧបក្ខដសិក្ខាបទ គំរប់ ៩ ចប់

---

សិក្ខាបទ គំរប់ ១០ ឈ្មោះរាជសិក្ខាបទ សេចក្ដីថា ព្រះរាជ រាជាមាត្យ ព្រាហ្មណ៍ គហបតី គេចំពោះភិក្ខុ ផ្ញើទូតឲ្យយកថ្លៃចីវរ ទៅទិញចីវរប្រគេនភិក្ខុ បើទូតនោះមិនទិញចីវរតាមពាក្យបង្គាប់ យកថ្លៃចីវរនោះទៅប្រគេនដល់ភិក្ខុដោយពោលថា "ថ្លៃចីវរនេះ គេចំពោះមកលោកម្ចាស់ ឲ្យខ្ញុំនាំមក សូមលោកម្ចាស់ទទួលយកថ្លៃចីវរនេះ" ដូច្នេះ ភិក្ខុនោះ គប្បីពោលនឹងទូតនោះថា យើងទទួលថ្លៃចីវរមិនបាន យើងទទួលបានតែចីវរដែលជារបស់គួរ ក្នុងកាលដែលគួរទទួល បើទូតនោះសួរភិក្ខុថា វេយ្យាវច្ចកររបស់លោកម្ចាស់មានខ្លះ ដូច្នេះសោត ភិក្ខុត្រូវការដោយចីវរ គប្បីសំដែងប្រាប់ខ្ញុំអ្នកវត្ត ឬឧបាសក ឲ្យជាវេយ្យាវច្ចករ ដោយពាក្យថា អ្នកនោះគេជាវេយ្យាវច្ចករនៃភិក្ខុទាំងឡាយ កុំពោលថា អ្នកចូរឲ្យដល់អ្នកនោះ អ្នកនោះគេនឹងទុកដាក់ អ្នកនោះគេនឹងដូរ គេនឹងទិញចីវរ ពោលដូច្នេះមិនគួរ បើទូតនោះប្រគល់ថ្លៃចីវរឲ្យវេយ្យាវច្ចករ ដែលភិក្ខុប្រាប់នោះហើយ

www.budinst.gov.kh www.elibraryofcambodia.org

គេត្រឡប់មកប្រាប់ដល់ភិក្ខុ ឬគេប្រើអ្នកដទៃឲ្យមកប្រាប់ថា លោកម្ចាស់ប្រាប់វេយ្យាវច្ចករណា វេយ្យាវច្ចករនោះ ខ្ញុំផ្ដាំឲ្យគេដឹងស្រេចហើយ លោកម្ចាស់ចូរនិមន្តទៅចុះ គេនឹងប្រគេនចីវរដល់លោកម្ចាស់ក្នុងកាលគួរ ដូច្នេះ ភិក្ខុមានសេចក្ដីត្រូវការដោយចីវរ គប្បីចូលទៅរកវេយ្យាវច្ចករ គប្បីទារ ២ ដង ឬ ៣ ដង ដោយពាក្យថាយើងត្រូវការដោយចីវរ តែកុំពោលថា អ្នកចូរឲ្យចីវរដល់យើង យកចីវរមកឲ្យយើង ប្ដូរចីវរឲ្យយើង ទិញចីវរមកឲ្យយើង ពោលដូច្នេះមិនគួរ ថាបើភិក្ខុទៅទារ ២ ដង ឬ ៣ ដង បានចីវរសម្រេចមកក៏ជាការប្រពៃ បើមិនបានចីវរមកសោត ភិក្ខុនោះគប្បីចូលទៅឈរស្ងៀមចំពោះមុខត្រឹម ៤ ដង ៥ ដង ៦ ដង ជាយ៉ាងច្រើន កុំអង្គុយលើអាសនៈ កុំទទួលអាមិស កុំសំដែងធម៌ឲ្យគេ បើគេសួរថា លោកម្ចាស់និមន្តមកមានធុរៈអ្វី គប្បីពោលថា អ្នកចូរដឹងចុះ បើភិក្ខុអង្គុយលើអាសនៈ ឬទទួលអាមិស ឬសំដែងធម៌ ឈ្មោះថាកាច់ឥរិយាបថឈរ ធ្វើហេតុដែលមកឲ្យវិនាសចេញ បើភិក្ខុឈរស្ងៀមចំពោះមុខ អស់វារៈ ៦ ដងជាយ៉ាងច្រើន បានចីវរសំរេចមកក៏ជាការល្អ បើមិនបានសំរេច តទៅភិក្ខុព្យាយាមឈរលើសជាង ៦ ដង ក្នុងប្រយោគព្យាយាមត្រូវទុក្កដ បានចីវរសម្រេចមក ចីវរនោះជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ បើមិនបានសម្រេចមកដោយឥរិយាបថឈរ ៦ ដងជាយ៉ាងច្រើនហើយ ថ្លៃចីវរគេនាំមកអំពីអ្នកណា ភិក្ខុគប្បីទៅរកអ្នកនោះខ្លួន

www.budinst.gov.kh www.elibraryofcambodia.org

ឯង ឬគប្បីបញ្ជូនទូត ឲ្យទៅប្រាប់ថា អ្នកបញ្ជូនដំឡៃចីវរមកចំពោះ
ភិក្ខុណា របស់នោះមិនសម្រេចប្រយោជន៍តិចតួចដល់ភិក្ខុនោះទេ អ្នក
ចូរទារយកដំឡៃរបស់អ្នកចុះ កុំឲ្យដំឡៃរបស់អ្នកវិនាសទៅឡើយ នេះ
ជាការសមគួរក្នុងការនោះ បើភិក្ខុមិនទៅដោយខ្លួនឯង ឬមិនប្រើបម្រើឲ្យ
ទៅប្រាប់ម្ចាស់របស់ដើម ត្រូវអាបត្តិទុក្កដ ឯកប្បិយការកៈ ដែលភិក្ខុ
សំដែងដូច្នេះ ព្រះពុទ្ធអង្គ ទ្រង់អនុញ្ញាតឲ្យទារបាន ៣ ដង ឈរបាន
៦ ដង ដោយកំណត់យ៉ាងឧក្រិដ្ឋ ព្រោះហេតុនោះអនុញ្ញាតឲ្យឈរ ២
ដង ជួសទារ ១ ដង ដោយហេតុនេះ បើភិក្ខុទារតែមួយចំពូក មិនឈរ
ទារបាន ៦ ដង បើគ្រាន់តែឈរមិនបានទារឡើយ ឈរបាន ១២ ដង
តើធ្វើតាំងពីប្រការ ទារម្តង ទាគឈរ ២ ដង ភិក្ខុអង្គណា ក្នុងមួយ
ថ្ងៃទៅរឿយៗ ទារគ្រប់ ៦ ដង ឬទៅតែម្តង ទារគ្រប់ ៦ ដងក្តី មួយ
ទៀត ក្នុងមួយថ្ងៃទៅរឿយៗ ឈរគ្រប់ ១២ ដង ឬទៅតែម្តង ឈរ
ក្នុងទីនោះៗ ១២ អន្លើ ភិក្ខុនោះ ឈ្មោះថាកាច់ឥរិយាបថឈរ កាច់ការ
ទារចេញអស់ ដែលទៅទារទៅឈរក្នុងថ្ងៃផ្សេងៗ មិនត្រូវពោល ។
កប្បិយការកៈដែលទាយកសំដែងឯង ភិក្ខុមិនបានសំដែងនោះ ភិក្ខុនឹង
ទារ ១ រយដងក៏គួរ ។ កប្បិយការកៈណា ដែលភិក្ខុនឹងទាយកមិនបាន
សំដែងឡើយ គឺកប្បិយការកៈទទួលដំឡៃយកមកសារខ្លួនឯង ចំពោះ
មុខភិក្ខុ ចំពោះមុខទាយកក្តី នឹងកប្បិយការកៈដែលទទួលដំឡៃទុកកំបាំង

www.budinst.gov.kh www.elibraryofcambodia.org

ក្តី ទាំងពីរចំពូកនេះ ភិក្ខុនឹងទារមិនបាន ក្នុងការទារនឹងការឈរ ហួសកំណត់ ត្រូវតែកបាចិត្តិយ ។ ទារនឹងឈរមិនទាន់គ្រប់កំណត់ សំគាល់ថាហួសក្តី សង្ស័យក្តី ព្យាយាមបានចីវរមកត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុទារតាមកំណត់ក្តី ឈរតាមកំណត់ក្តី មិនបានទារ កប្បិយការកៈនោះវិញមកប្រគេនដោយខ្លួនឯងក្តី ម្ចាស់របស់ដើមទារមកប្រគេនដោយខ្លួនឯងក្តី នឹងភិក្ខុឆ្កួតជាដើមក្តី ទាំងអម្បាលនេះមិនត្រូវអាបត្តិ ។ ជាអនាណត្តិកៈ មានអង្គ ៤ គឺ កប្បិយ-ការកស្ស ភិក្ខុណា និទ្ទិដ្ឋភាវោ កប្បិយការកៈភិក្ខុសំដែង ១ ទូតេន អប្បិតតា ទូតប្រាប់កប្បិយការកៈឱ្យដឹងហើយប្រាប់ភិក្ខុឱ្យដឹងផង ១ តតុត្តរិ វាយាមោ ព្យាយាមទារនឹងឈរឱ្យហួសកំណត់ ១ តេន វាយាមេន បដិលាភោ បានចីវរមកដោយព្យាយាមនោះ ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវនិស្សគ្គិយបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចអញ្ញាតកវិញ្ញត្តិសិក្ខាបទ ។

រាជសិក្ខាបទ ទី ១០ ចប់

ចីវរវគ្គជាបឋម ចប់

---

កោសិយវគ្គ ទី ២ មាន ១០ សិក្ខាបទ

កោសិយសិក្ខាបទ ជាបឋម សេចក្តីថា ភិក្ខុណា ធ្វើឯង ឬ ប្រើ

គេឲ្យស្ងោចនូវសំពត់សន្ថតលាយដោយសូត្រ សូម្បីតែមួយសរសៃដែលអណ្តែតតាមខ្យល់មកធ្លាក់ចូលក្នុងវេលាស្ងោច សន្ថតនោះត្រូវនិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ សន្ថតនោះ គឺ គ្រឿង កំរាលមួយចំពូក ដែលគេយករោមចៀម ឬ សរសៃសូត្រលាតតម្រួតគ្នាក្រាលលើផ្ទៃដែលស្មើ ហើយយកទឹកបាយជាដើមតាក់ចុះធ្វើ ឈ្មោះថាស្ងោចមិនបានត្បាញ ហៅថាសន្ថត ក្នុងសន្ថតដែលភិក្ខុធ្វើឲ្យសម្រេចដោយខ្លួនឯង ត្រូវចតុក្កបាចិត្តិយ ក្នុងពាក្យថាចតុក្កបាចិត្តិយ នឹងពោលទៅខាងមុខ ។ ភិក្ខុធ្វើឯងឬប្រើឲ្យគេធ្វើដើម្បីអ្នកដទៃក្តី បាននូវសន្ថតដែលបុគ្គលដទៃធ្វើមកប្រើប្រាស់ក្តី ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុធ្វើដើម្បីជាពិតានជាដើមក្តី និងភិក្ខុធ្វើតជាដើមក្តី មិនត្រូវអាបត្តិ ។ សិក្ខាបទនេះជាសាណត្តិកៈ មានអង្គ៣ គឺ កោសិយមិស្សកភាវោ សន្ថតលាយដោយសូត្រ១ អត្តនោ អត្ថាយ សន្ថតស្ស ការណការាបនំ ធ្វើឯងឬឲ្យគេធ្វើនូវសន្ថតដើម្បីខ្លួន១ បដិលាភោ បានមក១ ព្រមដោយអង្គ៣នេះ ទើបត្រូវនិស្សគ្គិយបាចិត្តិយ ។ សិក្ខាបទនេះមានសមុដ្ឋាន៦ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជ កាយកម្ម វចីកម្ម មានចិត្ត៣ មានវេទនា៣ ។

កោសិយសិក្ខាបទ ជាបឋម ចប់

www.budinst.gov.kh www.elibraryofcambodia.org

សុទ្ធកាឡកសិក្ខាបទ គំរប់ ២ សេចក្ដីថា ភិក្ខុណាស្លាប់ឯងឬប្រើគេឲ្យស្លាប់ នូវសន្ថតដោយរោមចៀមខ្មៅសុទ្ធ មិនមានពណ៌ដទៃលាយផង សន្ថតនោះជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ។

សុទ្ធកាឡកសិក្ខាបទ គំរប់ ២ ចប់

---

ទ្វេភាគសិក្ខាបទ គំរប់ ៣ សេចក្ដីថា ភិក្ខុណាស្លាប់ឯងឬប្រើគេឲ្យស្លាប់ នូវសន្ថតថ្មី គប្បីយករោមចៀមខ្មៅសុទ្ធ ២ ភាគ រោមចៀមសសុទ្ធ ១ ភាគ ជាគំរប់ ៣ រោមចៀមលឿង ១ ភាគជាគំរប់ ៤ បញ្ចូលផ្សំគ្នាស្លាប់ បើភិក្ខុមិនថ្លឹងរោមចៀម ជា ៤ ចំណែកដូច្នេះ ឲ្យគេស្លាប់សន្ថតថ្មី សន្ថតនោះជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ សន្ថតដែលត្រូវនិស្សគ្គិយទាំង ៣ ប្រការនេះ សូម្បីភិក្ខុលះហើយត្រឡប់បានមកវិញនឹងប្រើប្រាស់ក៏មិនគួរ ។

ទ្វេភាគសិក្ខាបទ គំរប់ ៣ ចប់

---

ឆព្វស្សសិក្ខាបទ គំរប់ ៤ សេចក្ដីថា ភិក្ខុស្លាប់ឯងឬប្រើគេឲ្យស្លាប់ នូវសន្ថតថ្មី គប្បីប្រើប្រាស់ឲ្យបាន ៦ វស្សាសិន បើមិនទាន់គ្រប់ ៦ វស្សា ភិក្ខុលះក្ដី មិនលះក្ដីនូវសន្ថតនោះ ហើយស្លាប់ឯងក្ដី ប្រើគេឲ្យស្លាប់ក្ដីនូវសន្ថតថ្មីដទៃទៀតខាងក្នុង ៦ វស្សា សន្ថតថ្មីនោះជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ វៀរតែភិក្ខុមានជម្ងឺបានសន្ថតសម្មតិ មិនត្រូវអាបត្តិ ។

ឆព្វស្សសិក្ខាបទ គំរប់ ៤ ចប់

www.budinst.gov.kh www.elibraryofcambodia.org

និសីទនសន្ថតសិក្ខាបទ គំរប់ ៥ សេចក្ដីថា ភិក្ខុណាស្លាច់ឯង ឬប្រើគេឲ្យស្លាច់នូវសន្ថតសម្រាប់និសីទ្ទិយដែលមានជាយ គប្បីកាត់យកសន្ថតចាស់ឲ្យមូលឬជាបួនជ្រុងមួយចំអាម ដោយចំអាមព្រះសុគត មកផ្សំបញ្ចូលផងក្នុងកន្លែងណាមួយ នៃសន្ថតថ្មី ឬរុះចេញផ្សំបញ្ចូលគ្នា ដើម្បីនឹងធ្វើសន្ថតថ្មីឲ្យខូចពណ៌ បើភិក្ខុមិនធ្វើដូច្នោះ ហើយស្លាច់ឯង ឬប្រើគេឲ្យស្លាច់នូវសន្ថតសម្រាប់និសីទ្ទិយថ្មី សន្ថតនោះជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ។

និសីទនសន្ថតសិក្ខាបទ គំរប់ ៥ ចប់

---

ឯឡកលោមសិក្ខាបទ គំរប់ ៦ សេចក្ដីថា ភិក្ខុណាមានដំណើរទៅផ្លូវឆ្ងាយ មានរោមចៀមកើតឡើងអំពីសង្ឃ ឬគណៈជាដើម កាលបើប្រាថ្នាគប្បីទទួលនូវរោមចៀមនោះ លុះទទួលហើយ មិនមានអ្នកជួយនាំទៅ គប្បីនាំទៅដោយខ្លួនឯង បានចម្ងាយ ៣ យោជន៍ ជាយ៉ាងច្រើន បើនាំទៅឆ្ងាយជាង ៣ យោជន៍ សូម្បីមិនមានអ្នកជួយនាំទៅ រោមចៀមនោះ ក៏គង់ជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ។

ឯឡកលោមសិក្ខាបទ គំរប់ ៦ ចប់

---

ឯឡកលោមធោវាបនសិក្ខាបទ គំរប់ ៧ សេចក្ដីថា ភិក្ខុណាប្រើភិក្ខុនី មិនមែនញាតិ ដែលឧបសម្បទាហើយក្នុងឧភតោសង្ឃ ឲ្យបោក

www.budinst.gov.kh www.elibraryofcambodia.org

ជ្រលក់ ឬឲ្យសិត នូវរោមចៀម រោមចៀមនោះជានិស្សគ្គិយ ភិក្ខុត្រូវ
បាចិត្តិយ ។

សិក្ខាបទទាំង ៦ នេះ មានសមុដ្ឋានវិធីជាដើមដូចកោសិយសិក្ខាបទ ។

សិក្ខាបទទាំង ៧ នេះ ពោលមកដោយសង្ខេប ។

ឯឡកលោមធោវាបនសិក្ខាបទ គំរប់ ៧ ចប់

---

រូបិយសិក្ខាបទ គំរប់ ៨ សេចក្តីថា ភិក្ខុណាទទួលឯង ឬប្រើគេ
ទទួលនូវរូបិយ គឺមាសនិងប្រាក់ដែលគេឲ្យ ឬធ្លាក់នៅក្នុងទីណាមួយ
មានគេកាន់ទុកក្តី កាន់យកដើម្បីប្រយោជន៍ខ្លួនឯង ឬត្រេកអរក្នុង
យដែលគេទុកដាក់ឲ្យក្តី រូបិយនោះជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ។

មាសជារូបពណ៌ណិក្តី មាសដុំក្តី ប្រាក់ជារូបពណ៌ណិក្តី ប្រាក់ដុំក្តី
ហាបណៈក្តី មាសកទង់ដែងក្តី មាសកស្ពាន់ក្តី មាសកធ្វើដោយឈើ
ាសកធ្វើដោយជ័រក្តី ដោយកាកល័ក្ខក្តី ឬដោយវត្ថុណាមួយ ដែលគេប្រើ
ិញដូរជួសប្រាក់បាន ប្រើជួសប្រាក់ក្នុងប្រទេសណា ក្នុងកាលណា
ឈ្មោះថាប្រាក់ក្នុងប្រទេសនោះ ក្នុងកាលនោះ មាសប្រាក់ទាំងនេះ
ោះថារូបិយ ជានិស្សគ្គិយវត្ថុ ។

www.budinst.gov.kh www.elibraryofcambodia.org

កែវមុក្តា កែវមណី កែវពិទូរ្យ ស័ង្ខ ដែលគេដុសខាត់ហើយ សិលាជាគ្រឿងប្រដាប់ កែវប្រពាឡ កែវទទឹម កែវមោរ៉ា ស្រូវប្រាំពីរប្រការ ខ្ញុំប្រុស ខ្ញុំស្រី ស្រែ ចំការ ទីជាច្បារផ្កាឈើ-ផ្លែឈើ ជាដើម តាំងអម្បាលនេះជាទុក្កដវត្ថុ ឲ្យកើតអាបត្តិទុក្កដ ។

អម្បោះវល្លិ៍ សំពត់កប្បាស អបរណ្ណជាតិ គឺសណ្តែក ល្ងផ្សេងៗ ភេសជ្ជៈ មានសប្បិ ប្រេង ទឹកឃ្មុំ ទឹកអំពៅជាដើម តាំងអម្បាលនេះជាកប្បិយវត្ថុ ភិក្ខុទទួលមិនត្រូវអាបត្តិ ។

ក្នុងនិស្សគ្គិយវត្ថុ ភិក្ខុទទួលឯង ឬឲ្យអ្នកដទៃទទួលដើម្បីខ្លួន ឬគេទុកដាក់ឲ្យក្នុងទីចំពោះមុខ គេពោលថា របស់នេះជារបស់លោកម្ចាស់ ឬរបស់នោះនៅក្នុងទីកំបាំង គ្រាន់តែម្ចាស់របស់លះឲ្យដោយកាយនឹងវាចា ឬឲ្យដោយកាយវិការឲ្យដឹងថា “ប្រាក់មាសរបស់ខ្ញុំ មាននៅក្នុងទីឯណោះ ប្រាក់មាសនោះ ចូរជារបស់លោកម្ចាស់ចុះ” ដូច្នេះ កាលគេពោលដូច្នោះ ភិក្ខុមិនឃាត់ដោយវាចា ក៏ឈ្មោះថាត្រេកអររូបិយដែលគេទុកដាក់ឲ្យ ជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ រាប់តាមវត្ថុនោះ រូបិយត្រូវនិស្សគ្គិយដូច្នេះហើយ គប្បីលះកណ្ដាលជំនុំសង្ឃមួយចំពូក ដោយពាក្យថា អហំ ភន្តេ រូបិយំ បដិគ្គហេសឹ ឥទំ មេ និស្សគ្គិយំ ឥមាហំ សង្ឃស្ស និស្សជ្ជាមិ ដូច្នេះ បពិត្រព្រះសង្ឃដ៏ចំរើន ខ្ញុំទទួលនូវរូបិយហើយ រូបិយនេះជារបស់

www.budinst.gov.kh www.elibraryofcambodia.org

ត្រូវនិស្សគ្គិយ ខ្ញុំលះរូបិយនេះដល់សង្ឃដូច្នេះ បើគ្រហស្ថណាមួយមក ក្នុងទីនោះនោះ ឲ្យសង្ឃគប្បីពោលនឹងគេថា អ្នកចូរដឹងវត្ថុនេះ បើគេសួរថារបស់នេះ នឹងឲ្យខ្ញុំយកអ្វីមក ភិក្ខុកុំគប្បីបង្គាប់ថា ឲ្យយកវត្ថុនោះៗមក គប្បីប្រាប់តែរបស់គួរ ថាសប្បិ នវនីតជាដើម ជារបស់គួរដល់ភិក្ខុ បើគ្រហស្ថនោះគេរករបស់ដែលគួរមកដោយរូបិយនោះ ភិក្ខុទាំងពួងគប្បីចែកគ្នាបរិភោគ វៀរតែភិក្ខុដែលទទួលរូបិយនោះ វត្ថុអ្វីដែលកើតអំពីរូបិយនោះ សូម្បីអ្នកដទៃបានមកប្រគេនក្តី ដោយហេតុនោះ សូម្បីតែម្លប់ដើមឈើ ដែលកើតអំពីរូបិយនោះក្តី ភិក្ខុអ្នកទទួលរូបិយនោះមិនគួរនឹងបរិភោគឡើយ ថាបើគ្រហស្ថនោះគេមិនចង់យករូបិយនោះទៅទិញរបស់មកឲ្យ សង្ឃគប្បីពឹងគេថាអ្នកចូរចោលរបស់នោះចេញ បើគេចោលក្នុងទីណាមួយ ឬគេកាន់យកទៅក្តី កុំគប្បីឃាត់គេឡើយ បើគ្រហស្ថនោះគេមិនចោលសោត សង្ឃគប្បីសម្មតិភិក្ខុដែលប្រកបដោយអង្គ ៥ ឲ្យជាអ្នកចោលរូបិយ ភិក្ខុបានសម្មតិនោះ កុំធ្វើនិមិត្តកំណត់សំគាល់ក្នុងទីដែលធ្លាក់ចុះ ឲ្យគប្បីខ្ពើមដូចលាមកហើយចោលរូបិយនោះទៅ បើភិក្ខុនោះ ធ្វើនិមិត្តកំណត់ទីដែលធ្លាក់នោះ ត្រូវទុក្កដ ។ ក្នុងរូបិយត្រូវតិកបាចិត្តិយ ។ មិនមែនរូបិយ ភិក្ខុសំគាល់ថារូបិយ ឬសង្ស័យហើយទទួល ឬទទួលនិស្សគ្គិយវត្ថុ ដើម្បីអ្នកដទៃមានសង្ឃនឹងចេតិយជាដើម ឬទទួលទុក្កដវត្ថុមានកែវមុក្តា កែវមណីជាដើម ដើម្បីខ្លួនឯងនឹងអ្នកដទៃក្តី ទាំងអម្បាលនេះត្រូវទុក្កដ ។

www.budinst.gov.kh www.elibraryofcambodia.org

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺគេប្រគេនរូបិយ ឬគេទុកដាក់ឲ្យក្នុងកំបាំង ឬចំពោះមុខ ពោលថារបស់នេះ ចូរជាបច្ច័យរបស់ព្រះករុណា បើភិក្ខុត្រេកអរដោយចិត្ត ចង់នឹងកាន់យក ហើយឃាត់ចេញដោយកាយ ឬវាចា ថារបស់នេះមិនគួរ ឬមិនឃាត់ដោយកាយនឹងវាចា មានចិត្តបរិសុទ្ធមិនត្រេកអរដោយគិតថារបស់នេះមិនគួរដល់យើងក្តី ដូច្នេះក៏គួរមិនមានទោស ។ ភិក្ខុកាន់យកឯង ឬឲ្យគេកាន់យកនូវរូបិយរបស់គ្រហស្ថដែលធ្លាក់នៅក្នុងអារាម ឬមានក្នុងទីលំនៅនៃខ្លួនដោយគិតថារបស់អ្នកណា អ្នកនោះគេនឹងមកយកទៅដូច្នេះ ដោយន័យក្នុងនេះសិក្ខាបទក្តី នឹងភិក្ខុឆ្កួតជាដើម ទាំងអម្បាលនេះមិនត្រូវអាបត្តិ ជាសាណត្តិកៈមានអង្គ ៣ គឺ ជាតរូបរជតភាវោ របស់នោះជាប្រាក់មាស ដែលជានិស្សគ្គិយវត្ថុ ១ អត្តុទ្ទេសិកតា ចំពោះជារបស់ខ្លួន ១ បដិគ្គហណាទីសុ អញ្ញតរភាវោ ទទួលឯង ឬប្រើគេឲ្យទទួល ឬគេទុកដាក់ឲ្យហើយត្រេកអរយក ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវនិស្សគ្គិយបាចិត្តិយ ។ សមុដ្ឋានវិធីជាដើមដូចសញ្ចរិត្តសិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាសិយា កិរិយា ត្រូវព្រោះធ្វើនូវការទទួលក៏មាន នឹងសិយា អកិរិយា ត្រូវព្រោះមិនធ្វើនូវការហាមឃាត់នូវរូបិយដែលគេទុកដាក់ឲ្យក៏មាន ។

រូបិយសិក្ខាបទ គំរប់ ៨ ចប់

www.budinst.gov.kh www.elibraryofcambodia.org

រូបិយសំវោហារសិក្ខាបទ គំរប់ ៩ សេចក្តីថា ភិក្ខុណា លក់ ទិញ ផ្លាស់ប្តូរដោយរូបិយមានប្រការផ្សេងៗ របស់នោះត្រូវនិស្សគ្គិយបាចិត្តិយ ព្រះពុទ្ធអង្គទ្រង់ឃាត់អាការដែលទទួលនិស្សគ្គិយវត្ថុ និងទុក្កដវត្ថុដោយសិក្ខាបទមុន ព្រះពុទ្ធអង្គទ្រង់ឃាត់អាការដែលផ្លាស់ប្តូរនិស្សគ្គិយវត្ថុ និងទុក្កដវត្ថុដោយសិក្ខាបទនេះ ព្រោះហេតុនោះ ភិក្ខុយកទុក្កដវត្ថុនឹងកប្បិយ-វត្ថុទិញផ្លាស់ប្តូរដោយទុក្កដវត្ថុក្តី យកទុក្កដវត្ថុផ្លាស់ប្តូរដោយអកប្បិយវត្ថុក្តី ត្រូវទុក្កដ ៗ ក៏ឯភិក្ខុយកនិស្សគ្គិយវត្ថុទិញផ្លាស់ប្តូរដោយនិស្សគ្គិយវត្ថុ ឬទុក្កដវត្ថុ ឬកប្បិយវត្ថុក្តី ឬយកទុក្កដវត្ថុនឹងកប្បិយវត្ថុផ្លាស់ប្តូរនិស្សគ្គិយវត្ថុក្តី តាំងអំពីកាលនេះ ត្រូវនិស្សគ្គិយបាចិត្តិយ ៗ របស់ដែលបានមកជានិស្សគ្គិយ គប្បីលះក្នុងកណ្តាលសង្ឃ នឹងគប្បីបដិបត្តិក្នុងរបស់ដែលលះនោះ ដូចក្នុងសិក្ខាបទមុន និងភិក្ខុឆ្កួតជាដើម មិនត្រូវអាបត្តិ ជាអនាណត្តិកៈ មានអង្គ ២ គឺ យំ អត្តនោ ធនេន បរិវត្តេតិ តស្ស ច ធនស្ស ច រូបិយភាវោ ចេវ របស់ដែលផ្លាស់ប្តូរមកក្តី ទ្រព្យរបស់ខ្លួន ដែលនឹងយកទៅផ្លាស់ប្តូរក្តី ទាំងណាមួយ ជារូបិយដែលជានិស្សគ្គិយវត្ថុ ១ បរិវត្តនញ្ច សម្រេចក្នុងការទិញលក់ផ្លាស់ប្តូរនោះ ១ ព្រមដោយអង្គ ២ នេះទើបត្រូវនិស្សគ្គិយបាចិត្តិយ ៗ សមុដ្ឋានវិធីជាដើម ដូចសិក្ខាបទមុន ប្លែកតែសិក្ខាបទនេះជាកិរិយា កើតអំពីផ្លូវកាយផ្លាស់ប្តូរ ។

រូបិយសំវោហារសិក្ខាបទ គំរប់ ៩ ចប់

www.budinst.gov.kh www.elibraryofcambodia.org

កយវិក្កយសិក្ខាបទ គំរប់ ១០ សេចក្ដីថា ភិក្ខុណាទិញលក់ផ្លាស់ប្ដូរ កប្បិយវត្ថុដោយកប្បិយវត្ថុមានប្រការផ្សេង ៗ មានចីវរនឹងបិណ្ឌបាតជាដើមជាមួយគ្រហស្ថ របស់នោះត្រូវនិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ។

ភិក្ខុពោលនឹងគ្រហស្ថថា អ្នកចូរឲ្យនូវរបស់នេះ ដោយរបស់នេះ អ្នកយករបស់នេះទៅ ឲ្យរបស់នោះមកយើងក្ដី យករបស់នេះដូរនឹងរបស់នេះក្ដី យករបស់នេះទៅ ចូរដូររបស់នេះឲ្យយើងក្ដី ដូច្នេះជាដើមក្ដី ទុកដ ៗ កាន់យកកប្បិយភណ្ឌនៃអ្នកដទៃមក ឈ្មោះថាទិញ ឲ្យកប្បិយភណ្ឌរបស់ខ្លួនទៅ ឈ្មោះថាលក់ ព្រោះហេតុនោះ ភិក្ខុឲ្យកប្បិយភណ្ឌរបស់ខ្លួនទៅហើយ កាន់យកកប្បិយភណ្ឌណានៃគ្រហស្ថមក វៀរចាកសហធម្មិកទាំង ៥ សូម្បីជារបស់មាតា ដោយការជាពាក្យផ្លាស់ប្ដូរ កប្បិយភណ្ឌនោះត្រូវនិស្សគ្គិយ កប្បិយវត្ថុដែលជានិស្សគ្គិយនោះដល់សង្ឃ ឬគណៈ ឬបុគ្គល ភិក្ខុឲ្យរបស់បរិភោគ ឬវត្ថុអ្វីដល់គ្រហស្ថហើយពោលថា អ្នកចូរបរិភោគរបស់នេះ អ្នកចូរកាន់យករបស់នេះ ហើយយករបស់នោះមកឲ្យយើង ឬដូររបស់នេះឲ្យយើង ហើយប្រើឲ្យយកទឹកជ្រលក់ជាដើមមកឲ្យភិក្ខុ ឬធ្វើបរិក្ខារមានធម្មក្រកជាដើម នឹងធ្វើនវកម្មមានជំរះដី ស្មៅ ជាដើម ដូច្នេះត្រូវនិស្សគ្គិយបាចិត្តិយ ។ បើរបស់នឹងកប្បិយៈមាន ភិក្ខុកប្បិយៈជាមុន បើរបស់មិនមាន កប្បិយ៍ត្រូវអាបត្តិបាចិត្តិយ តែប៉ុណ្ណោះ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុសួរថ្លៃថារបស់ថ្លៃប៉ុន្មានក្តី ប្រាថ្នានឹងកាន់យកកណ្តាំពីដៃអ្នកណា វៀរចាកអ្នកនោះចេញ ពីអ្នកដទៃដោយហោចទៅ សូម្បីជាកូនប្អូនអ្នកម្ចាស់របស់កណ្តានោះឲ្យជាកប្បិយការកៈផ្លាស់ប្តូរផ្សេង ប្រាប់ថាអ្នកចូរយករបស់នេះ ដូររបស់នោះ មកឲ្យយើងដូរចេះក្តី នឹងពោលឲ្យប្រែតាមកយវិក្កយៈ ដូចភិក្ខុដើរផ្លូវទៅមានតែអង្ករ ហើយប្រាថ្នាចង់បានបាយ និយាយនឹងម្ចាស់បាយថា អង្ករយើងមាន យើងមិនត្រូវការ យើងត្រូវការដោយបាយដូរចេះ ម្ចាស់បាយយកអង្ករទៅ ឲ្យបាយមកភិក្ខុក្តី និងភិក្ខុឆ្កួតជាដើមក្តី មិនត្រូវអាបត្តិ ។ ជាអនាបត្តិកៈមានអង្គ ៣ គឺ យំ អត្តនោ ធនេន បរិវត្តេតិ យេន ធនេន បរិវត្តេតិ តេសំ កប្បិយវត្ថុតា របស់ខ្លួនដែលយកទៅដូរក្តី របស់អ្នកដទៃដែលខ្លួននឹងដូរមកក្តី ទាំង ២ នេះជាកប្បិយភណ្ឌរបស់គួរ ១ អសហធម្មិកតា ម្ចាស់វត្ថុនោះជាគ្រហស្ថមិនមែនសហធម្មិក ១ កយវិក្កយាបជ្ជនំ ដូរដោយកិរិយាដូរ ដូចពោលហើយ ១ ព្រោះដោយអង្គ ៣ នេះ ទើបត្រូវនិស្សគ្គិយបាចិត្តិយ ។ វិនិច្ឆ័យក្រៅនោះ ដូចសំដែងហើយក្នុងរូបិយសិក្ខាបទ ។

កយវិក្កយសិក្ខាបទ ទី ១០ ចប់

កោសិយវគ្គទី ២ ចប់

---

www.budinst.gov.kh www.elibraryofcambodia.org

## បត្តវគ្គ តំរប់ ៣ មាន ១០ សិក្ខាបទ ។

បត្តសិក្ខាបទ ជាបឋម សេចក្តីថា អតិរេកបាត្រ គឺបាត្រមិនទាន់បានអធិដ្ឋាន មិនទាន់បានវិកប្ប ភិក្ខុទុកបានត្រឹម ១០ ថ្ងៃជាយ៉ាងក្រៃពេក កាលបើភិក្ខុទុកបាត្រនោះឲ្យហួស ១០ ថ្ងៃទៅ មិនបានអធិដ្ឋានមិនវិកប្ប អរុណតំរប់ ១១ រះឡើងមក បាត្រនោះជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ។

បាត្រមាន ២ យ៉ាង គឺបាត្រដែក ១ បាត្រដី ១ បាត្រប្រកបដោយប្រមាណជាសមណសារុប្បហើយ ទើបគួរអធិដ្ឋានមិនវិកប្ប ប្រមាណបាត្រដែលគួរអធិដ្ឋានមិនវិកប្បនោះ មិនសំដែងទៅខាងមុខ វិនិច្ឆ័យក្រៅនោះ ដូចបឋមកឋិនសិក្ខាបទ ។

បត្តសិក្ខាបទ ជាបឋម ចប់

---

ឩនបញ្ចពន្ធនសិក្ខាបទ តំរប់ ២ សេចក្តីថា បាត្របែកប្រេះប្រមាណពីរធ្នាប់ខាងក្រោមអំពីកណ្តាប់មាត់ឈ្មោះថាមានចំណង ១ អង្គុលី ភិក្ខុណា មានបាត្រ ដែលមានចំណងមិនទាន់គ្រប់ ៥ អង្គុលី ហើយសូមបាត្រថ្មីអំពីបុគ្គលមិនមែនញាតិ មិនមែនបវារណា បាត្រនោះជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ភិក្ខុនោះគប្បីលះបាត្រនោះទៅធ្វើវិនយកម្ម លះកណ្តាលជំនុំសង្ឃ សង្ឃត្រូវតាំងភិក្ខុឲ្យកាន់យកបាត្ររបស់ខ្លួនគ្រប់ៗអង្គទៅកាន់ទីប្រជុំ

www.budinst.gov.kh www.elibraryofcambodia.org

សម្មតិភិក្ខុអ្នកប្រកបដោយអង្គ ៥ ឲ្យជាអ្នកប្តូរបាត្រ ភិក្ខុដែលបានសម្មតិនោះ គប្បីយកបាត្រដែលលះនោះប្រគេនដល់ព្រះមហាថេរ យកបាត្រព្រះមហាថេរប្រគេនដល់អនុថេរ ប្តូរដូច្នេះតាមលំដាប់ចុះទៅ លុះដល់ភិក្ខុជាសង្ឃនវកៈអង្គុយក្នុងទីបំផុតនៃសាលា ហើយយកបាត្រនៃភិក្ខុជាសង្ឃនវកៈនោះ ឲ្យដល់ភិក្ខុអ្នកលះបាត្រនោះ ហើយបង្គាប់ថាបាត្រនេះជាបាត្ររបស់លោក លោកចូរបរិភោគដរាបដល់បែកចុះ កុំលះចោល កុំឲ្យទៅអ្នកដទៃ បដិបត្តិដូច្នេះជាសេចក្តីប្រពៃក្នុងបាត្រនោះ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺ ភិក្ខុមានបាត្របាត់នឹងបែក នឹងសូមអំពីញាតិនឹងបុគ្គលបវារណានៃខ្លួន នឹងសូមអំពីបុគ្គលជាញាតិ នឹងបវារណានៃភិក្ខុដទៃ នឹងសូមដើម្បីភិក្ខុដទៃក្តី នឹងកាន់យកដោយទ្រព្យខ្លួនក្តី នឹងភិក្ខុឆ្កួតជាដើមក្តី មិនត្រូវអាបត្តិ ជាអនាណត្តិកៈ មានអង្គ ៤ គឺ អធិដ្ឋានុបគបត្តស្ស ឩនបញ្ចពន្ធនតា បាត្រគួរអធិដ្ឋានកនចំណាន ៥ មិនទាន់គ្រប់ ១ អត្តុទ្ទេសិកតា ចំពោះខ្លួន ១ កតវិញ្ញត្តិ សូមអំពីបុគ្គលមិនជាញាតិ មិនជាបវារណា ១ តាយ បដិលាភោ បានមកដោយការសូមនោះ ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវនិស្សគ្គិយបាចិត្តិយ ។ សមុដ្ឋានវិធីជាដើមដូចធោវនសិក្ខាបទ ។

ឩនបញ្ចពន្ធនសិក្ខាបទ គំរប់ ២ ចប់

---

www.budinst.gov.kh www.elibraryofcambodia.org

ភេសជ្ជសិក្ខាបទ គំរប់៣ សេចក្តីថា ភេសជ្ជៈ ៥ ប្រការ គឺ សប្បិ ទឹកដោះគោរ ជាដើម ទឹកដោះខាប់ គោល់ ប្រេងល្ង ប្រេងគ្រាប់ស្ពៃ ប្រេងស្រគំ ប្រេងល្ហុង ទឹកឃ្មុំមានទឹកឃ្មុំផ្អែកជាដើម មធុ ទឹកឃ្មុំ ផាណិតំ ទឹកអំពៅ ៗ ភេសជ្ជៈទាំង ៥ នេះជាថ្នាំ ភិក្ខុមានជម្ងឺក្តី មិនមានជម្ងឺក្តី ទុកគប្បីបរិភោគបានក្នុងកាលទាំងពួង ភេសជ្ជៈទាំង ៥ នេះ ភិក្ខុទទួលប្រគេន ហើយគប្បីទុកឆាន់បាន ៧ ថ្ងៃជាយ៉ាងក្រៃពេក កាលបើភិក្ខុទុកភេសជ្ជនោះឲ្យលើស ៧ ថ្ងៃ លុះអរុណតំរប់ ៨ រះឡើងមក ត្រូវនិស្សគ្គិយបាចិត្តិយ រាប់តាមភេសជ្ជនោះ បើដាក់លាយចុះក្នុងភាជនៈជាមួយគ្នា ក៏ត្រូវអាបត្តិ ១ បើមិនដាក់លាយចុះក្នុងភាជនៈជាមួយគ្នា ត្រូវអាបត្តិតាមវត្ថុនោះ ៗ ក្នុងបទនេះនឹងសំដែងពិស្តារទៅខាងមុខ ។ ថ្នាំទាំង ៥ ប្រការនេះត្រូវនិស្សគ្គិយហើយ បើលះចេញហើយ កាលបានត្រឡប់មកវិញ មិនបរិភោគក្នុងកាយ មានលាបថ្នាំជាដើម ឬក្រេបផឹកចូលទៅមិនគួរ គប្បីបញ្ចូនទៅក្នុងប្រទីប ឬផ្សំថ្នាំទៅលាបកុដិ ដែលមិនមែនកាយគប្បីពាល់ត្រូវ ភិក្ខុដទៃមិនមែនម្ចាស់របស់ នឹងបរិភោគលាបកាយជាដើមនោះគួរ នឹងឆាន់ចូលទៅមិនគួរ ។ ថ្នាំទាំង ៥ ប្រការនេះណាមួយ ភិក្ខុលះឲ្យអនុបសម្បន្នដាច់ហើយ ខាន់ក្នុង ៧ ថ្ងៃ បានត្រឡប់មកទៀតនឹងឆាន់ក៏គួរ ៗ ថ្នាំទាំង ៥ នេះ ភិក្ខុទទួលប្រគេនហើយដោយគិតនឹងឆាន់ ហើយទុកហួស ៧ ថ្ងៃទៅ ទើបត្រូវនិស្សគ្គិយ ៗ បើមិនគិតនឹងឆាន់ នឹងយកទៅលាប

ដំឡៅជាដើម សូម្បីកន្លងទៅ៧ថ្ងៃទៅ ក៏មិនត្រូវនិស្សគ្គិយ ។ វិនិច្ឆ័យក្រៅនោះ តាំងអង្គនិងសមុដ្ឋានឲ្យគប្បីដឹងដូចពោលហើយក្នុងបឋមកឋិនសិក្ខាបទ ។

ភេសជ្ជសិក្ខាបទ គំរប់ ៣ ចប់

---

វស្សិកសាដិកសិក្ខាបទ គំរប់ ៤ សេចក្តីថា អំពីមួយរោចខែជេស្ឋ ដរាបដល់ពេញបូណ៌មីខែអាសាឍ ពីរបក្ខនេះឈ្មោះថាជាខែមួយ ជាខាងចុងរដូវក្តៅ ជាខែគួរនឹងស្វែងរកវស្សិកសាដិកចីវរ គឺសំពត់ងូតទឹកភ្លៀង ភិក្ខុគប្បីស្វែងរកគឺកៀនស្មារតីទាយកដែលធ្លាប់ឲ្យមកពីមុនថា ឥឡូវនេះជាកាលនៃរដូវសំពត់ងូតទឹកភ្លៀងហើយ តាំងពីមួយកើតខែអាសាឍដល់ថ្ងៃពេញបូណ៌មី ជាកន្លះខែនៃខែចុងរដូវក្តៅ ជាខែត្រូវដែលនឹងធ្វើសំពត់ងូតទឹកភ្លៀងដែលស្វែងរកបានមក ហើយនោះនឹងជាខែត្រូវដែលនឹងស្លៀកដណ្តប់ផង តែនៅមិនទាន់ជាខែត្រូវដែលត្រូវអធិដ្ឋាន តាំងពីមួយរោចខែអាសាឍដរាបអស់រដូវភ្លៀង ទើបជាខែត្រូវដែលត្រូវអធិដ្ឋាន បើមិនទាន់ដល់ចុងរដូវក្តៅមួយខែ ភិក្ខុខ្វល់ខ្វាយស្វែងរកសំពត់ងូតទឹកភ្លៀងជាមុនបានមក សំពត់នោះត្រូវនិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ។ មិនទាន់ដល់កន្លះខែចុងរដូវក្តៅ ភិក្ខុខ្វល់ខ្វាយធ្វើសំពត់ងូតទឹកភ្លៀង ដែលស្វែងរកបានមក នោះស្លៀកដណ្តប់ក្តី សំពត់នោះជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ។

www.budinst.gov.kh www.elibraryofcambodia.org

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុមានចីវរដែលចោរដណ្តើមយកទៅក្តី មានចីវរបាត់ក្តី ស្លៀកដណ្តប់ដោយមានអន្តរាយដទៃក្តី ទឹងភិក្ខុឆ្កួតជាដើមក្តី ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ជាអនាណត្តិកៈ ជាបរិយេសនាបត្តិ មានអង្គ៣គឺ វស្សិកសាដិកាយ អត្តុទ្ទេសិកតា វស្សិកសាដិកៈនោះចំពោះខ្លួនឯង ១ អសមយេ បរិយេសនតា ស្វែងរកក្រៅសម័យ ១ តាយ ច បដិលាភោ បានមកដោយការស្វែងរកនោះ ១ ។ ជានិវាសនាបត្តិ មានអង្គ ៤ គឺ សចីវរតា ភិក្ខុមានចីវរគ្រប់គ្រាន់ ១ អាបទាភាវោ មិនមានអន្តរាយ ១ វស្សិកសាដិកាយ សកភាវោ វស្សិកសាដិកៈជារបស់ខ្លួន ១ អសមយេ និវាសនំ ស្លៀកដណ្តប់ក្រៅសម័យ ១ ។ សមុដ្ឋានវិធីជាដើមដូចធោវនសិក្ខាបទ ។

វស្សិកសាដិកសិក្ខាបទ គំរប់ ៤ ចប់

---

ចីវរអច្ឆិន្នសិក្ខាបទ គំរប់ ៥ សេចក្តីថា ភិក្ខុណាឲ្យចីវរគួរវិកប្បជាបច្ចិមប្រមាណដល់ភិក្ខុដទៃ ដោយខ្លួនឯងប្រាថ្នានឹងឲ្យភិក្ខុធ្វើការខ្វល់ខ្វាយឧបដ្ឋាកជាដើមដល់ខ្លួន គ្រាក្រោយឃើញថាភិក្ខុនោះ មិនខ្វល់ខ្វាយឧបដ្ឋាកខ្លួន ហើយត្រឡប់ដណ្តើមយកឯង ដោយសំគាល់ថាជារបស់ខ្លួន ត្រូវនិស្សគ្គិយបាចិត្តិយ រាប់តាមវត្ថុ ។ ប្រើឲ្យអ្នកដទៃដណ្តើមយកត្រូវទុក្កដ ដោយបង្គាប់ ។ អ្នកដទៃដណ្តើមបានមកត្រូវនិស្សគ្គិយបាចិត្តិយ

www.budinst.gov.kh www.elibraryofcambodia.org

រាប់តាមពាក្យបង្គាប់នោះ ៗ ។ ក្នុងឧបសម្បន្នត្រូវតិកបាចិត្តិយ ៗ ក្នុងអនុបសម្បន្ន អ្នកដែលឲ្យនោះសំគាល់ថាជាឧបសម្បន្នក្តី សង្ស័យក្តី ឬដឹងថាជាអនុបសម្បន្នក្តី ឲ្យហើយដណ្តើមយកក្តី ឬឲ្យបរិក្ខារដទៃដល់ឧបសម្បន្នហើយដណ្តើមយកក្តី ដូច្នេះត្រូវទុក្កដ ៗ

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺអ្នកដែលបានទៅក្រោធ ឬ ខឹង ហើយត្រឡប់ឲ្យមកវិញដោយខ្លួនឯងក្តី ឬកាន់យកដោយវិស្សាសៈក្នុងអ្នកដែលបានទៅក្តី និងភិក្ខុឆ្កួតជាដើមក្តី មិនត្រូវអាបត្តិ លះឲ្យដាច់ហើយត្រឡប់ដណ្តើមយកមកវិញ ឲ្យវិនយធរគប្បីកាត់អាបត្តិ តាមដំរៀបរបស់ភសាណត្តិកៈ មានអង្គ ៥ គឺ វិកប្បនុបគបច្ឆិមចីវរតា ការទំហំប្រវែងគួរវិកប្បជាយ៉ាងទាប ១ សាមំ ទិន្នតា ចីវរនោះភិក្ខុឲ្យខ្លួនឯង ១ សកសញ្ញិតា សំគាល់ថាជារបស់ខ្លួន ១ ឧបសម្បន្នតា អ្នកដែលបានទៅជាឧបសម្បន្ន ១ កោធវសេន អច្ឆិន្ទនំ វា អច្ឆិន្ទាបនំ វា ដណ្តើមយកដោយខ្លួនឯង ឬឲ្យគេដណ្តើមយកដោយខឹង ១ ព្រមដោយអង្គ ៥ នេះ ទើបត្រូវនិស្សគ្គិយបាចិត្តិយ ៗ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាទុក្ខវេទនា ៗ

ចីវរច្ឆិន្ទនសិក្ខាបទ គំរប់ ៥ ចប់

www.budinst.gov.kh www.elibraryofcambodia.org

សុត្តវិញ្ញត្តិសិក្ខាបទ គំរប់ ៦ សេចក្តីថា ភិក្ខុណា សូមអម្បោះ ៦ ប្រការណាមួយមកខ្លួនឯង អំពីបុគ្គលមិនមែនញាតិ មិនមែនបវារណា ឲ្យជាងតម្បាញ មិនមែនញាតិ មិនមែនបវារណា ត្បាញចីវរ ក្នុងប្រយោគដែលជាងតម្បាញតាក់តែងនោះ ត្រូវអាបត្តិទុក្កដគ្រប់ៗប្រយោគ ៗ លុះត្បាញហើយ សំពត់ទំហំប្រវែងល្មមបានបច្ចិមប្រមាណ គួរវិកប្ប សំពត់នោះត្រូវនិស្សគ្គិយបាចិត្តិយ ៗ ភិក្ខុសំគាល់នូវសំពត់ដែលជាងតម្បាញមិនទាន់ត្បាញ ជាត្បាញហើយក្តី ឬសង្ស័យក្តី ត្រូវទុក្កដ ៗ

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺ ភិក្ខុសូមនូវអម្បោះដើម្បីដេរចីវរ ឬសំពត់កាយោគ នឹងវត្តពន្ធ យោគបាត្រ ថង់បាត្រ សំពត់តម្រងទឹក ឬឲ្យជាងតម្បាញជាញាតិនឹងបវារណា ត្បាញនូវអម្បោះដ៏គួរក្តី សូមដើម្បីអ្នកដទៃក្តី ទិញដោយទ្រព្យនៃខ្លួនក្តី និងភិក្ខុឆ្កួតជាដើមក្តី ទាំងអម្បាលនេះ មិនត្រូវអាបត្តិ សិក្ខាបទនេះជាអនាណត្តិកៈ មានអង្គ ៣ គឺ ចីវរត្ថាយ វិញ្ញាបិតសុត្តតា សូមអម្បោះដើម្បីត្បាញចីវរ ១ អត្តុទ្ទេសិកតា ចំពោះខ្លួន ១ អកប្បិយតន្តវាយេន អកប្បិយវិញ្ញត្តិយា វាយាបនំ ឲ្យជាងតម្បាញជាអកប្បិយនោះ ត្បាញដោយការសូមជាអកប្បិយ ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវអាបត្តិ ៗ សមុដ្ឋានវិធីជាដើម ដូចពោលបទសិក្ខាបទ ៗ

សុត្តវិញ្ញត្តិសិក្ខាបទ គំរប់ ៦ ចប់

www.budinst.gov.kh www.elibraryofcambodia.org

មហាបេសការសិក្ខាបទ គំរប់ ៧ សេចក្ដីថា គ្រហស្ថមិនមែនញាតិឲ្យជាងតម្បាញត្បាញចីវរចំពោះភិក្ខុណា ភិក្ខុនោះគេមិនបានបវារណាជាមុនហើយចូលទៅរកជាងតម្បាញប្រាប់ថា “ចីវរនេះគេឲ្យអ្នកត្បាញចំពោះយើង អ្នកចូរត្បាញឲ្យវែង ឲ្យធំ ឲ្យណែន ត្បាញឲ្យល្អ វៃឲ្យល្អ ក្រួតឲ្យល្អ សិតឲ្យល្អបុះ សិមយើងនឹងថែមវត្ថុណាមួយឲ្យដល់អ្នក” ភិក្ខុពោលដូច្នេះហើយ ថែមនូវវត្ថុណាមួយឲ្យដល់ជាងតម្បាញ ដោយហោចទៅ សូម្បីតែបិណ្ឌបាតក្ដី បើជាងតម្បាញនោះថែមអម្បោះឡើងហើយត្បាញឲ្យវែង ឲ្យធំ តាមពាក្យភិក្ខុបង្គាប់ ក្នុងប្រយោគដែលជាងតម្បាញតាក់តែងនោះត្រូវទុក្កដ ត្បាញហើយបានមក សំពត់នោះជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើមដូចសុត្តវិញ្ញត្តិសិក្ខាបទ ប្លែកតែសិក្ខាបទនេះ មានអង្គ ៤ គឺ អញ្ញាតកអប្បវារិតាធំ តន្តវាយេ ឧបសង្កមិត្វា វិកប្បមាបជ្ជនតា ភិក្ខុបង្គាប់ឲ្យជាងតម្បាញនៃទាយកមិនមែនញាតិ មិនមែនបវារណាឲ្យកំណត់ ១ ចីវរស្ស អត្តុទ្ទេ-សិកតា ចីវរចំពោះខ្លួន ១ តស្ស វចនេន សុត្តវឌ្ឍនំ ជាងតម្បាញថែមអម្បោះតាមពាក្យភិក្ខុ ១ ចីវរប្បដិលាភោ បាននូវចីវរមក ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវនិស្សគ្គិយបាចិត្តិយ ។ សមុដ្ឋានវិធីជាដើមដូចពោលបនសិក្ខាបទ ។

មហាបេសការសិក្ខាបទ គំរប់ ៧ ចប់

www.budinst.gov.kh www.elibraryofcambodia.org

អច្ចេកចីវរសិក្ខាបទ គំរប់ ៨ សេចក្តីថា អច្ចេកចីវរ គឺចីវររួសរាន់ ចីវរប្រញាប់ បានដល់មនុស្សដែលដល់នៅធ្វើសង្គ្រាម ឬមនុស្សមានកិច្ចដល់ទៅនៅយូរ ដល់មនុស្សមានជម្ងឺធ្ងន់ ដល់ស្រីមានគភ៌ ឬមនុស្សមានសទ្ធាជ្រះថ្លាឡើងថ្មី ថ្វាយជាសំពត់ចំណាំវស្សាដល់សង្ឃក្នុងថ្ងៃ ៥ កើតខែអស្សុជ សំពត់ដូច្នេះ ភិក្ខុបានចំណែកមកអំពីសង្ឃហើយ គប្បីសំគាល់ចាំទុកដើម្បីវស្សាដាច់ ដល់បានប្រគល់ឲ្យដល់សង្ឃវិញ បើវស្សាមិនដាច់ ទុកដាក់ដកបអស់ចីវរកាល មិនវិកប្ប.អធិដ្ឋានក៏បាន បើទុកឲ្យហួសចីវរកាលទៅ សំពត់នោះជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ៗ ចីវរកាលនោះតាំងអំពីមួយរោចខែអស្សុជ បើមិនបានក្រាលគ្រងកឋិនទុកបានដល់ពេញបូណ៌មីខែកត្តិក ជា ១ ខែ បើបានក្រាលគ្រងកឋិនទុកដល់ពេញបូណ៌មីខែផល្គុនជា ៥ ខែ ឈ្មោះថាចីវរកាល ៗ សមុដ្ឋានវិធីជាដើម ដូចបឋមកឋិន-សិក្ខាបទ ប៉ុន្តែសិក្ខាបទនេះមានអង្គ ៤ គឺ អច្ចេកចីវរស្ស អត្តនោសន្តកតា អច្ចេកចីវរមានប្រមាណយ៉ាងតូចគួរវិកប្បជារបស់ខ្លួន ១ ឧប្បន្នភាវោ ចីវរកើតឡើងអំពីថ្ងៃ ៥ កើតខែអស្សុជ ១ អនធិដ្ឋិត-អវិកប្បិតតា ចីវរមិនបានអធិដ្ឋានមិនបានវិកប្ប ១ ចីវរកាលា-តិក្កមោ កន្លងចីវរកាលទៅ ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវនិស្សគ្គិយ បាចិត្តិយ ៗ

អច្ចេកចីវរសិក្ខាបទ គំរប់ ៨ ចប់

www.budinst.gov.kh www.elibraryofcambodia.org

សាសង្កសិក្ខាបទ គំរប់៩ សេចក្តីថា កាលបើព្រមដោយអង្គ ៤ ព្រះពុទ្ធអង្គក៏ទ្រង់អនុញ្ញាត ឲ្យផ្ញើត្រៃចីវរទុកក្នុងស្រុកបាន ។ ឯអង្គ ៤ នោះគឺ ភិក្ខុចូលបុរិមិកាវស្សា ហើយបានបវារណាក្នុងថ្ងៃមហាបវារណា ជាអង្គ ១ តាំងអំពីមួយកើតខែអស្សុជ ដល់ពេញបូណ៌មីខែកត្តិកឈ្មោះ កត្តិកមាស មួយខែនេះជាអង្គគំរប់ ២ អរញ្ញិកសេនាសនៈប្រកបដោយប្រមាណ គឺអស់ពីខែត្រស្រុកមកដល់ខែត្រវត្តចម្ងាយ៥រយធ្នូ ជាយ៉ាងតូច ជាអង្គគំរប់ ៣ សេនាសនៈព្រៃនោះប្រកបដោយសេចក្តីរង្កៀស គឺក្នុងអារាមឬឧបចារនៃអារាម ឱកាសទីលំនៅ ទីស៊ី ទីអង្គុយ នៃចោរក៏ឃើញប្រាកដ សេនាសនៈប្រកបដោយភ័យគឺ ក្នុងអារាមឬឧបចារនៃអារាម ចោរចូលមកសម្លាប់ មកប្លន់ មកវាយដំមនុស្ស ក៏ឃើញប្រាកដ សេនាសនៈប្រកបដោយរង្កៀសនិងភ័យដូច្នេះ ជាអង្គគំរប់ ៤ ព្រមដោយអង្គ ៤ ដូច្នេះហើយ ភិក្ខុផ្ញើត្រៃចីវរក្នុងស្រុកគោចរគ្រាមជុំវិញអារាមស្រុកណាមួយបាន ១ ខែ ចីវរនោះមិនត្រូវនិស្សគ្គិយ បើមានហេតុភិក្ខុចេញចាកអរញ្ញិកសេនាសនៈទៅកាន់ទីដទៃ គប្បីទៅប្រាសចាកចីវរនោះបាន ៦ រាត្រីជាយ៉ាងច្រើន បើទៅប្រាសចាកចីវរលើស ៦ រាត្រីឡើងទៅ មិនត្រឡប់មកកាន់អរញ្ញិកសេនាសនៈ ឬស្រុកដែលទុកចីវរនោះខាងក្នុង ៦ រាត្រី អរុណគំរប់៧រះឡើងមក ចីវរដែលនៅក្នុងស្រុកនោះជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ វៀរតែភិក្ខុមានជម្ងឺបានសម្មតិអំពីសង្ឃ ឲ្យទៅប្រាសចាកត្រៃចីវរបាន ។ សមុដ្ឋានវិធីជាដើម ដូចទុតិយកឋិនសិក្ខាបទ ។

www.budinst.gov.kh www.elibraryofcambodia.org

បរិណតសង្ឃាបទ គំរប់ ១០ សេចក្តីថា ភិក្ខុដឹងថា លាភសង្ឃគឺបច្ច័យ ទាំង ៤ ដោយហោចទៅ សូម្បីតែលំអិតខឹងឈើស្ទួនអម្បោះជើងកម្បាញ ទាយកសូម្បីជាសហធម្មិកទាំង៥ ឬគ្រហស្ថសូម្បីជាមាតាបិតា គេបង្អោន ទៅហើយដើម្បីសង្ឃដោយវាចាថា “យើងនឹងថ្វាយ” ភិក្ខុដឹងដូច្នេះហើយ បង្អោនមកដើម្បីខ្លួន ក្នុងប្រយោគដែលពោលបង្អោនមកនោះ ត្រូវទុក្កដ ៗ លាភនោះបានមកដល់ដៃត្រូវនិស្សគ្គិយបាចិត្តិយ ។ ថាបើលាភនោះទាយក ថ្វាយដល់សង្ឃហើយសោត ភិក្ខុនឹងកាន់យកមិនគួរ គប្បីប្រគល់ឲ្យដល់ សង្ឃវិញ លាភគេបង្អោនទៅហើយដល់សង្ឃ ភិក្ខុសង្ស័យ បង្អោនមក ដើម្បីខ្លួនក្តី លាភគេបង្អោនទៅដល់សង្ឃពួក ១ ហើយបង្អោនទៅសង្ឃ ពួកដទៃ ឬ ចេតិយក្តី ដូច្នេះត្រូវទុក្កដ ។ លាភគេបង្អោនទៅដល់ចេតិយ ១ ហើយភិក្ខុបង្អោនទៅចេតិយដទៃឬបង្អោនទៅដល់សង្ឃ ដល់គណៈ ដល់ បុគ្គលក្តី ឬលាភគេបង្អោនទៅដល់បុគ្គលហើយ ដោយហោចទៅ សូម្បី បង្អោនឲ្យទៅឆ្កែ ១ ហើយ ភិក្ខុបង្អោនមកដល់បុគ្គល មកដល់ឆ្កែដទៃ ឬ បង្អោនទៅដល់សង្ឃ ដល់គណៈ ដល់ចេតិយក្តី ឬលាភគេមិនទាន់ បង្អោនទៅ ភិក្ខុសំគាល់ថាបង្អោនទៅហើយក្តី សង្ស័យក្តី បង្អោនមក ដើម្បីខ្លួន ដើម្បីអ្នកដទៃ ទាំងអម្បាលនេះ ត្រូវទុក្កដ ៗ

អនាបត្តិដែលមិនត្រូវអាបត្តិនោះ គឺ លាភគេបង្អោនទៅហើយ ភិក្ខុ សំគាល់ថាគេមិនទាន់បានបង្អោនទៅ ហើយបង្អោនមកដើម្បីខ្លួន ដើម្បី

www.budinst.gov.kh www.elibraryofcambodia.org

អ្នកដទៃក្តី ទាយកសួរថា ខ្ញុំនឹងឲ្យក្នុងទីណាស្រួល ភិក្ខុពោលថា «ទេយ្យធម៌របស់អ្នកនឹងគប្បីបានជាគ្រឿងបរិភោគ ជាគ្រឿងបរិក្ខារ បដិសន្ថារណៈឋិតនៅបានយូរ ក្នុងទីឯណា ឬចិត្តអ្នកជ្រះថ្លា ក្នុងទីណា អ្នកចូរឲ្យក្នុងទីនោះចុះ» ពោលដូច្នេះក្តី នឹងភិក្ខុឆ្កួតជាដើមក្តី ទាំងអម្បាលនេះមិនត្រូវអាបត្តិ ជាអនាណត្តិកៈ មានអង្គ ៣ គឺ សង្ឃបរិណតភាវោ លាភនោះទាយកបង្អោនទៅហើយក្នុងសង្ឃ ១ តំ ញត្វា អត្តនោ បរិណាមនំ ដឹងហើយបង្អោនមកដើម្បីខ្លួន ១ បដិលាភោ បានមក ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវនិស្សគ្គិយ-បាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ។

បរិណតសិក្ខាបទ គំរប់ ១០ ចប់

បត្តវគ្គទី ៣ ចប់

និស្សគ្គិយុទ្ទេស ចប់

---

## បាចិត្តិយុទ្ទេស

ឧទ្ទេសនៃសុទ្ធិកបាចិត្តិយាបត្តិ សុទ្ធិកបាចិត្តិយាបត្តិមាន៩២សិក្ខាបទ ចែកជា ៩ វគ្គ ។ វគ្គទី ១ ឈ្មោះមុសាវាទវគ្គ មាន ១០ សិក្ខាបទ ៖

មុសាវាទសិក្ខាបទ ជាបឋមនោះ សេចក្តីថា ភិក្ខុមុននឹងនិយាយ នឹងខណៈកំពុងនិយាយ ដឹងថាជាសេចក្តីមិនពិត ហើយកុហកដោយកាយ ដូចគេសួរថា ឃើញឬមិនឃើញ ខ្លួនឃើញពិត ហើយគ្រវីក្បាលឲ្យគេដឹងថាមិនឃើញក្តី ស្រដីកុហកដោយវាចាក្តី ត្រូវបាចិត្តិយ ។

www.budinst.gov.kh www.elibraryofcambodia.org

ភិក្ខុពោលកុហកដើម្បីអួតឧត្តរិមនុស្សធម៌ ត្រូវបារាជិក, ពោលកុហកដើម្បីចោទភិក្ខុដទៃ ដោយអាបត្តិបារាជិកមិនមានមូល ត្រូវសង្ឃាទិសេស, ពោលកុហកដើម្បីចោទភិក្ខុដទៃ ដោយអាបត្តិសង្ឃាទិសេសមិនមានមូល ត្រូវបាចិត្តិយ, ពោលកុហកដើម្បីចោទភិក្ខុដទៃ ដោយអាចារវិបត្តិ ត្រូវទុក្កដ ពោលកុហកដើម្បីអួតឧត្តរិមនុស្សធម៌ដោយបរិយាយ អ្នកស្តាប់ដឹងសេចក្តី ត្រូវថុល្លច្ច័យ, អ្នកស្តាប់មិនដឹងសេចក្តី ត្រូវទុក្កដ ។ ភិក្ខុពោលកុហក បានឃើញថាមិនបានឃើញ បានឮថាមិនបានឮ ដឹងដោយច្រមុះ អណ្តាត កាយ ថាមិនបានដឹង ដឹងដោយចិត្ត ថាមិនបានដឹងក្តី មិនឃើញ ថាបានឃើញ មិនឮ ថាបានឮ មិនដឹងដោយទ្វារទាំង ៣ ថាបានដឹង មិនដឹងដោយចិត្ត ថាដឹងក្តី ដូច្នេះ ត្រូវបាចិត្តិយ ក្នុងសិក្ខាបទនេះ ។

ឯវិធីដែលមិនត្រូវអាបត្តិ គឺមិនទាន់ត្រិះរិះ ពោលដោយរហ័សទៅក្តី គិតនឹងពោលពាក្យយ៉ាងដូច្នេះ ហើយភ្លាត់ទៅពោលពាក្យដទៃក្តី ឃ្លាតចាកពាក្យពិតទៅ នឹងភិក្ខុឆ្កួតជាដើមក្តី ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ជាអនាណត្តិកៈ មានអង្គ ៤ គឺ វិសំវាទនបុរេក្ខារតា គិតនឹងពោលពាក្យឲ្យឃ្លាតចាកពិតជាប្រធាន ១ វិសំវាទនចិត្តំ យមត្ថំ វត្ថុកាមោ តស្ស បុគ្គលស្ស វិញ្ញាបនប្បយោគោ ធ្វើប្រយោគកាយឬវាចា ឲ្យអ្នកស្តាប់ដឹងសេចក្តីដែលខ្លួនប្រាថ្នានឹងពោល

www.budinst.gov.kh www.elibraryofcambodia.org

ដោយគិតឲ្យឃ្លាតចាកសេចក្តីពិត ១ ព្រមដោយអង្គ ២ នេះ ទើបត្រូវបាចិត្តិយ បើមិនព្រមដោយអង្គ ២ នេះ មិនត្រូវអាបត្តិ ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ។

មុសាវាទសិក្ខាបទ ជាបឋម ចប់

ឱមសវាទសិក្ខាបទ ទី២ សេចក្តីថា ភិក្ខុណា ពោលពាក្យចាក់ដោត ដេរស្តីភិក្ខុដទៃ អ្នកដែលត្រូវបាកដក្តី ឬមិនបានត្រូវក្តី ដោយសំគាល់ថាជាភិក្ខុ ពោលដោយកាយប្រយោគនឹងវចីប្រយោគ មិនគាំង អ្នកដទៃ ដោយអក្កោសវត្ថុ ១០ ប្រការណាមួយ ពិតក្តី មិនពិតក្តី ត្រូវបាចិត្តិយ ។

អក្កោសវត្ថុ ១០ នោះ គឺជាតិទាបនឹងឧក្រិដ្ឋ ជាតិចណ្ឌាល ជាតិជាងឈើ ជាតិជាងចាំង ជាតិជាងដែង ជាតិព្រានម្រឹគ ជាតិជាងរថ ជាតិមនុស្សចាក់ផ្កា ចាក់សំរាមជាដើម ឈ្មោះថា ជាតិទាប, ជាតិក្សត្រ ជាតិព្រាហ្មណ៍ ឈ្មោះថា ជាតិឧក្រិដ្ឋ ១ ។ នាមគឺឈ្មោះដែលទាបនឹងឧក្រិដ្ឋ ឈ្មោះអវកណ្ណកជាដើម នឹងឈ្មោះដែលគេចំអកចំអន់ក្នុងប្រទេសនោះ ៗ ជាឈ្មោះទាប, ឈ្មោះប្រកបដោយពុទ្ធៈ ដោយធម្មៈ ដោយសង្ឃៈ ដែលគេរាប់អានក្នុងប្រទេសនោះ ៗ ដូចឈ្មោះពុទ្ធរក្ខិត ធម្មរក្ខិត សង្ឃរក្ខិត ជាឈ្មោះឧក្រិដ្ឋ ១ ។ គោត្រគឺសែ ដែលទាបនឹងឧក្រិដ្ឋ គោត្រដែលគេចំអកចំអន់ក្នុងប្រទេសនោះៗ ដូច

www.budinst.gov.kh www.elibraryofcambodia.org

កោសិយគោត្រ ភារទ្វាជគោត្រ ជាគោត្រទាប, គោត្រដែលគេរាប់អានក្នុងប្រទេសនោះៗ ដូចគោតមគោត្រ មោគ្គល្លានគោត្រ កច្ចាយនគោត្រ វាសិដ្ឋគោត្រ ជាគោត្រឧក្រិដ្ឋ ១ ។ កម្ម គឺការងារដែលទាបទីនឹងឧក្រិដ្ឋ ការងារដែលគេបំអកបំអន់ក្នុងប្រទេសនោះៗ ដូចការងារជាងចាំង មនុស្សចាក់ផ្កា ចាក់សំរាមជាដើម ជាការងារទាប, ការងារដែលគេរាប់អានក្នុងប្រទេសនោះៗ ដូចការធ្វើស្រែ ការជួញ ការចិញ្ចឹមគោ ជាការងារឧក្រិដ្ឋ ១ ។ សិប្បៈ គឺសិល្បសាស្ត្រ ដែលទាបទីនឹងឧក្រិដ្ឋ សិប្បៈដែលគេបំអកបំអន់ក្នុងប្រទេសនោះៗ ដូចជាងតាក់ ជាងឆ្លាំង ជាងកម្បាញ ជាងស្បែក ជាងសំណ ជាសិល្បសាស្ត្រទាប, សិប្បៈដែលគេរាប់អានក្នុងប្រទេសនោះៗ ដូចវិជ្ជាគេរ វិជ្ជាកប់ វិជ្ជាលេខ ជាសិល្បសាស្ត្រឧក្រិដ្ឋ ១ ។ អាពាធ គឺរោគផ្សេងៗ ទាំងអស់ជារបស់ទាប, តែរោគឈ្មោះមធុមេហៈ មានទឹកបស្សាវៈផ្អែម [illegible] ជារោគឧក្រិដ្ឋ ១ ។ លិង្គ គឺពណ៌សណ្ឋានកាយ ដែលទាបនឹងឧក្រិដ្ឋ កាយខ្ពស់ពេក ទាបពេក ខ្មៅពេក សពេក ជាលិង្គទាប, កាយមិនខ្ពស់ពេក មិនទាបពេក មិនខ្មៅពេក មិនសពេក ជាលិង្គឧក្រិដ្ឋ ១ ។ កិលេស គឺលោភៈ ទោសៈ មោហៈ កិលេសទាំងអស់ជារបស់ទាប ១ ។

អាបត្តិ គឺចំណែកដែលនឹងគប្បីដល់ សម្រាប់ មានបារាជិកាបត្តិជាដើម អាបត្តិទាំងពួងជារបស់ទាបទាំងអស់, តែសោតាបត្តិ និងសមាបត្តិ ជាឧ

www.budinst.gov.kh www.elibraryofcambodia.org

ជាអាបត្តិទុក្កដ ១ ។ អក្កោសៈ គឺពាក្យជេរដែលទាបនឹងទុក្កដ ដេរថា ឯងជាចណ្ឌ ឯងជាលា ឯងជាពេន ឯងជាគោ ឯងជាកំព្វាន ឯងជាសត្វនរក សុគតិរបស់ឯងមិនមាន ឯងមានតែទុគ្គតិមួយយ៉ាង ប៉ុណ្ណោះ ទីងជេរជល់បុរសនិមិត្ត ឥត្ថីនិមិត្ត ទីងពាក្យជេរប្រកបដោយ យៈ កៈ អក្ខរ ដោយបុរិសនិមិត្ត ឥត្ថីនិមិត្ត នេះជាពាក្យជេរដែលទាប, ដេរថាឯងជាអ្នកប្រាជ្ញ ឯងជាអ្នកឆ្លាត ឯងជាអ្នកមានបញ្ញា ឯងជាពហុស្សុត ឯងជាធម្មកថិក ទុគ្គតិរបស់ឯងមិនមាន មានតែសុគតិមួយ យ៉ាង ដូច្នេះជាពាក្យជេរទុក្កដ ១ ឈ្មោះថាអក្កោសវត្ថុ ១០ ប្រការដូច្នេះ ។

ភិក្ខុប្រាថ្នានឹងឲ្យភិក្ខុផងគ្នាបានសេចក្តីអាស្រូវ ហើយជេរភិក្ខុនោះ ដោយជាតិទីងគោត្រជាដើមដែលទាបនឹងទុក្កដណាមួយ ដោយអក្កោសវត្ថុដែលទាបនឹងទុក្កដ ពិតក្តី មិនពិតក្តី មិនបានប្រៀបប្រដាយ ជេរត្រង់ចំពោះមុខថា ឯងជាក្សត្រ ឯងជាព្រាហ្មណ៍ជាដើម ដូច្នេះត្រូវបាចិត្តិយ គ្រប់ៗពាក្យ ។ បើជេរប្រៀបប្រដាយមិនចំពោះមុខថា មនុស្សដំពូកខ្លះ ក្នុងលោកនេះជាមនុស្សចណ្ឌាល ជាព្រានជាដើមដូច្នេះក្តី ទីងពោលតាក់ ដោតជេរស្តីឧបសម្បន្ន គឺសាមណេរ គ្រហស្ថ ស្ត្រី បុរស ដោយត្រង់ក្តី ទីងជេរប្រៀបប្រដាយមិនត្រង់ក្តី តាំងអម្បាលនេះ ក៏ត្រូវអាបត្តិទុក្កដ គ្រប់ៗពាក្យ ។ ភិក្ខុមិនមានប្រាថ្នានឹងជេរឲ្យបានសេចក្តីអាប់យស បំណងនឹងឲ្យគេលេងទីងពោលឲ្យគេចំអន់លេងឧបសម្បន្នក្តី អនុបសម្បន្នក្តី

ដោយគ្រន់ប្តូរប្រៀបប្រាយ ដោយអក្កោសវត្ថុ ដែលមានមកក្នុងព្រះបាលី ឬមិនមានមកក្នុងព្រះបាលីថា ឯងជាក្សត្រ ឯងជាព្រាហ្មណ៍ ឯងជាតិរច្ឆាន ឯងជាអ្នកប្រាជ្ញ ឯងជាសៀម ឯងជាលាវ ឯងជាចោរ ជាដើមដូច្នេះ ត្រូវអាបត្តិទុក្កដ គ្រប់ៗពាក្យ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុមិនមានបំណងនឹងជេរនឹងឡកចំអកចំអន់ ពោលអត្ថ ពោលធម៌ ពោលពាក្យប្រដៅជាប្រធាន ពោលថាជាតិនេះអ្នកជាមនុស្សចណ្ឌាលហើយ កុំធ្វើបាបទៀយដូច្នេះ ទើងភិក្ខុឆ្កួតជាដើម ចាំងអម្បាលនេះ មិនត្រូវអាបត្តិ ជាអនាបត្តិកៈ មានអង្គ ៤ គឺ យំ អក្កោសតិ តស្ស ឧបសម្បន្នតា ជេរអ្នកណា អ្នកនោះជាឧបសម្បន្ន ១ អនញ្ញាបទេសេន ជាតិអាទីហិ អក្កោសនំ ជេរដោយអក្កោសវត្ថុមានជាតិជាដើម មិនអាងអ្នកដទៃ ១ មំ អក្កោសតីតិ ជាននា អ្នកដែលគេជេរដឹងថាគេជេរខ្លួន ១ អត្ថធម្មបុរេក្ខារតាទីនំ អភាវោ មិនបានពោលអត្ថ ពោលធម៌ ពោលពាក្យប្រដៅ ជាប្រធាន ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ប៉ុន្តែសិក្ខាបទនេះជាទុក្ខវេទនាប៉ុណ្ណោះ ។

ឱមសវាទសិក្ខាបទ គំរប់ ២ ចប់

បេសុញ្ញសិក្ខាបទ ទី ៣ សេចក្តីថា ភិក្ខុញុះញង់ គឺបានឮភិក្ខុមួយអង្គ ជេរភិក្ខុឯទៀត ដោយអក្កោសវត្ថុ ១០ មានជាតិជាដើម ហើយមានសេចក្តីប្រាថ្នា ២ ប្រការ គឺចង់ឲ្យអ្នកដែលគេជេរនោះ ស្រឡាញ់ខ្លួន ១ ឬចង់ឲ្យអ្នកទាំងពីរនោះបែកបាក់គ្នា ១ ទើបពោលពាក្យញុះញង់ គឺថែចូររើសនាំយកពាក្យនៃភិក្ខុអ្នកជេរឯណោះ ទៅប្រាប់ដល់ភិក្ខុដែលគេជេរឯណោះ ត្រូវបាចិត្តិយ គ្រប់ ៗ ពាក្យញុះញង់នោះ ៗ បើនាំយកពាក្យនៃភិក្ខុអ្នកពោលញុះញង់ជេរស្តី ប្រៀបប្រាយមិនត្រង់ មកប្រាប់ដល់ភិក្ខុដែលគេជេរ ឬនាំយកពាក្យដែលអនុបសម្បន្នជេរ មកប្រាប់ដល់ឧបសម្បន្នក្តី ដល់អនុបសម្បន្នក្តី ឬនាំយកពាក្យជេរនៃឧបសម្បន្នមកប្រាប់ដល់អនុបសម្បន្នក្តី ទាំងអម្បាលនេះ ត្រូវទុក្កដទាំងអស់ ៗ ក្នុងសិក្ខាបទនេះ សូម្បីភិក្ខុនី ក៏គង់ចាត់នៅជាអនុបសម្បន្ន ៗ

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុមិនបំណងនឹងឲ្យអ្នកដែលគេជេរស្រឡាញ់ខ្លួន ១ ឬមិនមានប្រាថ្នានឹងឲ្យអ្នកទាំងពីរបែកគ្នា ១ ពោលពាក្យតិះដៀលមនុស្សអាក្រក់មួយពួក មានភិក្ខុឆ្កួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ជាអនាបត្តិក: មានអង្គ ៣ គឺ ជាតិអាទីហិ អនញ្ញាបទេសេន អក្កោសន្តស្ស ភិក្ខុនោ វចនំ សុត្វា ភិក្ខុស្ស ឧបសំហរណំ បានឮភិក្ខុជេរស្តីដោយអក្កោសវត្ថុ មានជាតិជាដើម មិនកាន់អ្នកដទៃ ហើយនាំយកមកប្រាប់ដល់ភិក្ខុ

www.budinst.gov.kh www.elibraryofcambodia.org

ដែលគេដេរ១ បិយកម្យតា ភេទាធិប្បាយេសុ អញ្ញតរ
បំណងនឹងឲ្យអ្នកដែលគេដេរស្រឡាញ់ខ្លួន ឬ ខឹងនឹងឲ្យអ្នកទាំងពីរបែកពាក
គ្នា ណាមួយ ជាអង្គ១ តស្ស វិជាននំ អ្នកដែលគេដេរនោះ
ដឹងសេចក្តី១ ព្រមដោយអង្គទាំង ៣ នេះ ទើបត្រូវបាចិត្តិយ ៗ
សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ៗ

## បេសុញ្ញសិក្ខាបទ គំរប់ ៣ ចប់

បទសោធម្មសិក្ខាបទ គំរប់ ៤ សេចក្តីថា ភិក្ខុណាប្រដៅអនុបសម្បន្ន គឺសាមណេរនិងគ្រហស្ថ ស្ត្រីបុរស ឲ្យរៀនធម៌ដោយបទ ត្រូវបាចិត្តិយ ៗ បទ គឺបាទនៃគាថាមួយដូច អសេវនា ច ពាលានំ ១ អនុបទ គឺបាទគំរប់ ២ ដូច បណ្ឌិតានញ្ច សេវនា ១ អន្វក្ខរៈ គឺអក្សរតួមួយៗ ដូចតួ រូ តួ បំ ១ ៗ អនុព្យញ្ជនៈ គឺព្យញ្ជនៈក្រោយ ដូចព្យញ្ជនៈមុខ ដូច អនិច្ចំ អនិច្ចា ១ ៗ បួននេះឈ្មោះថាបទ ជាចំណែកឲ្យកើតអាបត្តិ និងជាកំណត់នៃអាបត្តិ ឲ្យគប្បីដឹងដោយស្រួលៗ គ្នា ដូចនេះ អក្សរតួមួយៗ ដូចតួ រូ តួ បំ ឈ្មោះថាអន្វក្ខរៈ ប្រជុំអក្សរចូលជាពាក្យមួយ ដូច រូបំ ឬ អនិច្ចំ ឈ្មោះថាអនុព្យញ្ជនៈ ប្រជុំអក្សរ និងអនុព្យញ្ជនៈ ចូលជាសេចក្តីជាមួយគ្នា ដូច រូបំ អនិច្ចំ ឈ្មោះថាបទ បទខាងដើមនោះឯង ឈ្មោះថាបទ បទជាគំរប់ ២ ដូច វេទនា អនិច្ចា

www.budinst.gov.kh www.elibraryofcambodia.org

ឈ្មោះថាអនុបទ ៗ ភិក្ខុកាលប្រាប់ធម៌ ដែលចងជាគាថា ថា អសេវនា ច ពាលានំ ឡើងមុនហើយ អនុបសម្បន្ន ក៏ថាតាម ភិក្ខុក៏ថាព្រមគ្នាជាមួយនឹងអនុបសម្បន្ន តទៅទៀតថា អសេវនា ច ពាលានំ ឡើងព្រមគ្នា ចប់ព្រមគ្នា ដូច្នេះត្រូវបាចិត្តិយ រាប់ដោយបទ ៗ ភិក្ខុប្រាប់ធម៌ម្ដង ២ បាទគាថាដូច្នេះថា អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា ហើយត្រឡប់ពោលទៀត ជាមួយនឹងអនុបសម្បន្ន អនុបសម្បន្ន ពោលបាទជាដំបូងមិនទាន់ ពោលទាន់ដល់បាទជាគំរប់ ២ ថា បណ្ឌិតានញ្ច សេវនា ចូលព្រមគ្នាជាមួយនឹងភិក្ខុ ដូច្នេះឈ្មោះថាពោលឡើងផ្សេងគ្នា ចប់ចុះព្រមគ្នា ដូច្នេះត្រូវបាចិត្តិយ រាប់ដោយអនុបទ ៗ ភិក្ខុប្រាប់អនុបសម្បន្នឲ្យពោលថា រូបំ អនិច្ចំ អនុបសម្បន្នពោលទាន់តែត្រឹម រូ ឡើងព្រមជាមួយនឹងភិក្ខុ ភិក្ខុពោលទៅលុះតែចប់ ដូច្នេះត្រូវបាចិត្តិយ រាប់ដោយអក្ខរៈ ន័យនេះរមែងបានក្នុងបាលី សូម្បីដែលចងជាគាថាផង ៗ ភិក្ខុប្រាប់អនុបសម្បន្នឲ្យពោលថា រូបំ អនិច្ចំ វេទនា អនិច្ចា ហើយភិក្ខុពោលបានតែ រូបំ អនិច្ចំ អនុបសម្បន្នប្រញាប់រហ័ស មាត់រហ័ស ពោលបានដល់វេទនា អនិច្ចា ដែលជាអនុបទ ព្រមចុះជាមួយនឹងពាក្យថា អនិច្ចំ នៃភិក្ខុ ដូច្នេះត្រូវបាចិត្តិយ រាប់ដោយអនុបទ ៗ ធម៌នោះគឺបាលី ដែលជាពុទ្ធភាសិត ព្រះពុទ្ធអង្គទ្រង់សំដែងដោយព្រះអង្គឯង ១ យ៉ាង

www.budinst.gov.kh www.elibraryofcambodia.org

សាវកភាសិត បាលីដែលសាវកពោលក្នុងពុទ្ធបរិស័ទមុខ ពោល ដូចអនង្គណសូត្រ និងសម្មាទិដ្ឋិសូត្រ ជាដើម ១ យ៉ាង ឥសីភាសិត បាលីដែលឥសី បរិព្វាជក ខាងក្រៅសាសនាពោល ដូចបរិព្វាជកវគ្គទាំងអស់ និងសោឡសបញ្ហា ជាដើម ១ យ៉ាង ទេវតាភាសិត បាលីដែលទេវតាពោល ដូចទេវតាសំយុត្ត និងទេវបុត្តសំយុត្ត ជាដើម ១ យ៉ាង ភាសិតទាំងបួននេះ ដែលប្រកបដោយអត្ថនិងធម៌អាស្រ័យព្រះវិញ្ញាន សំដែងព្រះវិញ្ញាន ។ ក្នុងអនុបសម្បន្នត្រូវតែកបាចិត្តិយ ៗ ឧបសម្បន្ន ភិក្ខុសំគាល់ថាជាអនុបសម្បន្ន ឬសង្ស័យ ហើយប្រដៅធម៌ ត្រូវទុក្កដ ៗ

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺរៀនបាលី ស្វាធ្យាយបាលី ជាមួយនិងអនុបសម្បន្ន និងរៀនបាលីក្នុងសំណាក់នៃអនុបសម្បន្ន ពោលព្រមគ្នាក្តី ទន្ទេញ សូត្រ គម្ពីរដែលស្ទាត់ដោយច្រើនជាមួយគ្នា ឬអនុប-សម្បន្នពោលភ្លាត់ ភិក្ខុប្រាប់ថា ឲ្យពោលដូច្នេះ ហើយពោលឡើងព្រមគ្នា និងភិក្ខុឆ្កួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ៗ ជាអនាណត្តិកៈ មានអង្គ ៣ គឺ អនុបសម្បន្នតា អនុបសម្បន្ន ១ វុត្តលក្ខណំ ធម្មំ បទសោ វាចេតា ប្រដៅធម៌មានលក្ខណៈដូចពោលហើយ ដោយបទ ១ ឯកតោ ឱសាបនំ ឲ្យចប់ចុះជាមួយគ្នា ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ៗ ជាបទសោធម្មសមុដ្ឋាន ជាកិរិយា ត្រូវអាបត្តិព្រោះធ្វើ ជានោសញ្ញាវិមោក្ខ មិនរួចទោសដោយសំគាល់

www.budinst.gov.kh www.elibraryofcambodia.org

ជាអចិត្តកៈ ទោះមិនដឹង មិនក្លែង ក៏ត្រូវអាបត្តិ ជាបណ្ណត្តិវជ្ជៈ មានទោស ព្រោះពុទ្ធប្បញ្ញត្តិ ជាវចីកម្ម មានចិត្ត ៣ មានវេទនា ៣ ។

បទសោធម្មសិក្ខាបទ គំរប់ ៤ ចប់

---

សហសេយ្យសិក្ខាបទ គំរប់ ៥ សេចក្តីថា ភិក្ខុណា សំរេចការដេក ក្នុងសេនាសនៈ ដែលប្រក់ជាំងអស់ បាំងជាំងអស់ ឬប្រក់ច្រើន បាំងច្រើន មានឧបចារៈជាមួយគ្នា ក្នុងខណៈមួយព្រមគ្នា ឬមុន ឬក្រោយ ជាមួយអនុបសម្បន្ន វៀរតែភិក្ខុផងគ្នា ដោយហោចទៅ សូម្បីតែសត្វតិរច្ឆាន មានទ្វារជាវត្ថុឲ្យកើតបារាជិកាបត្តិបាន ឲ្យលើសជាង ៣ រាត្រីទៅ ត្រូវបាចិត្តិយ រាប់អំពីរាត្រីគំរប់ ៤ ទៅ ។ សេនាសនៈដែលបាំងដោយគ្រឿងបាំងមានជញ្ជាំងជាដើម មិនជាប់នឹងដំបូល ខ្ពស់ឡើង ១ ហត្ថ ១ ចំអាម ដោយជុំវិញ គប្បីដឹងថា សេនាសនៈបាំងជាំងអស់ ព្រោះហេតុដូច្នោះ សេនាសនៈប្រកបដោយលក្ខណៈដូច្នេះ សូម្បីជាប្រាសាទ ៧ ជាន់ ឬជាផ្ទះមុខ ៤ មានល្វែងដល់មួយរយក្តី បើមានឧបចារៈតែទ្វារប្រើប្រាស់ជាមួយគ្នា ក៏ឈ្មោះថាជាទីសេយ្យាសនជាមួយគ្នា ។ ភិក្ខុណាដេកជាមួយនឹងអនុបសម្បន្នតែម្នាក់ ឬជាមួយអនុបសម្បន្នច្រើននាក់ក្តី ក្នុងសេនាសនៈជាមួយគ្នា ឬក្នុងទីដែលដូច្នេះក្តី អស់ ៣ រាត្រីហើយ លុះដល់ថ្ងៃជាគំរប់ ៤ កាលបើព្រះអាទិត្យអស្តង្គតទៅហើយ អនុបសម្បន្នដេក

www.budinst.gov.kh www.elibraryofcambodia.org

មុន ភិក្ខុនឹងចង់ទុការស្លុង ឬមិនចង់ក្តីហើយដេក ឬភិក្ខុដេកមុន អនុបសម្បន្នដេកក្រោយ ភិក្ខុមិនក្រោកឡើងត្រូវបាចិត្តិយ ព្រោះដោយប្រយោគដែលក្រោកឡើងនឹងដេកចុះនៃខ្លួននឹងអនុបសម្បន្ន ទាំងពីរនាក់ នឹងភពដោយរូបអនុបសម្បន្នដែលដេកនោះនោះ ។ ក្នុងអនុបសម្បន្ន ត្រូវភិក្ខុបាចិត្តិយ ៗ ឧបសម្បន្ន ភិក្ខុសំគាល់ថាជាអនុបសម្បន្ន ឬសង្ស័យ ហើយដេក ត្រូវទុក្កដ ៗ សេនាសនៈប្រក់ពាក់កណ្តាលបាំងពាក់កណ្តាល ប្រក់ទាំងអស់បាំងតិច ប្រក់ច្រើនបាំងតិច បាំងទាំងអស់ប្រក់តិច បាំងច្រើនប្រក់តិច ទាំងអម្បាលនេះ ជាវត្ថុឲ្យកើតអាបត្តិទុក្កដ ៗ

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺសេនាសនៈប្រក់ទាំងអស់ មិនបានបាំងឡើយ ឬមិនបានប្រក់ឡើយ បាំងទាំងអស់ ឬមិនបានប្រក់ដោយច្រើន មិនបានបាំងដោយច្រើន ទាំងអម្បាលនេះ មិនជាវត្ថុឲ្យកើតអាបត្តិ ។ ដេកថយជាង ២ រាត្រី ៣ រាត្រី ឬក្នុងរាត្រីជាគំរប់ ៣ ចេញទៅមុនអរុណរះហើយ ទើបនៅតទៅទៀត និងក្នុងរាត្រីជាគំរប់ ៣ អនុបសម្បន្នដេក ភិក្ខុអង្គុយ ឬភិក្ខុដេក អនុបសម្បន្នអង្គុយ ឬអង្គុយជាមួយគ្នាទាំងពីរ ហើយនៅតទៅទៀត និងភិក្ខុឆ្កួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិកៈ មានអង្គ ៣ គឺ បាចិត្តិយ-វត្ថុការសេនាសនំ សេនាសនៈជាវត្ថុឲ្យកើតបាចិត្តិយ ១ ការ អនុបសម្បន្នេន សហ និបជ្ជនំ ដេកជាមួយនឹងអនុបសម្បន្ន

ភិក្ខុនីសេនាសនៈដូច្នោះ ១ ចតុក្កធំវេស សុរិយត្ថង្គមធំ ព្រះអាទិត្យអស្តង្គតទៅហើយ ភិក្ខុនីថ្ងៃគំរប់បួន ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ បើមិនព្រមដោយអង្គ ៣ មិនត្រូវអាបត្តិ ។ ជាឯឡកលោមសមុដ្ឋាន អាបត្តិកើតអំពីកាយ អំពីកាយចិត្ត ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម មានចិត្ត ៣ មានវេទនា ៣ ។

សហសេយ្យសិក្ខាបទ គំរប់ ៤ ចប់

---

ទុតិយសហសេយ្យសិក្ខាបទ គំរប់ ៦ សេចក្តីថា ភិក្ខុណា កាលព្រះអាទិត្យអស្តង្គតហើយ សំរេចការដេកក្នុងសេនាសនៈដូចពោលហើយក្នុងសិក្ខាបទមុន ជាមួយមាតុគ្រាម គឺស្រីមនុស្ស សូម្បីកើតក្នុងថ្ងៃនោះ ត្រូវបាចិត្តិយ ។ វិនិច្ឆ័យទាំងពួងដូចសិក្ខាបទមុន ប្លែកតែកំណត់ក្រៃ ។ ក្នុងសិក្ខាបទមុនត្រូវអាបត្តិក្នុងថ្ងៃគំរប់ ៤ ។ ក្នុងសិក្ខាបទនេះ ត្រូវអាបត្តិតាំងអំពីយប់ដំបូងទៅ ។ ស្រីយក្ខ ស្រីប្រេត មានរូបប្រាកដ ខីនបណ្ឌក ខីនតិរច្ឆានញីជាវត្ថុឲ្យកើតមេថុនបាន ត្រូវទុក្កដ ក្នុងសិក្ខាបទនេះ ។ ដេកជាមួយគ្នា លុះដល់រាត្រីជាគំរប់ ៤ ឲ្យកើតបាចិត្តិយាបត្តិ ដូចពោលហើយក្នុងសិក្ខាបទមុន ។

ទុតិយសហសេយ្យសិក្ខាបទ គំរប់ ៦ ចប់

www.budinst.gov.kh www.elibraryofcambodia.org

ធម្មទេសនាសិក្ខាបទ គំរប់ ៧ សេចក្តីថា ភិក្ខុណា សំដែងធម៌មានលក្ខណៈដូចបានពោលហើយក្នុងបទសោធម្មសិក្ខាបទ ដល់មាតុគ្រាម គឺស្រីមនុស្ស ដែលដឹងពាក្យល្អ-អាក្រក់ និងពាក្យទ្រគោះ មិនទ្រគោះក្តី ឲ្យលើស ៦ ម៉ាត់ឡើងទៅ ត្រូវបាចិត្តិយ រាប់ដោយរូបមាតុគ្រាម ៗ សំដែងដោយបទនិងអក្ខរៈ រាប់ដោយបទនិងអក្ខរៈ វៀរលែងតែមានមនុស្សប្រុសដឹងសេចក្តី មានលក្ខណៈដូចពោលហើយក្នុងអនិយតគំរប់ ២ នៅជាមួយផង មិនត្រូវអាបត្តិ ។ បាទនៃគាថា ១ ជាមួយម៉ាត់ គប្បីដឹងប្រមាណនៃពាក្យ ក្នុងពាក្យទាំងអស់ដូច្នេះ ។ ក្នុងមាតុគ្រាម ត្រូវតិកបាចិត្តិយ ២ មិនមែនស្រីភិក្ខុសំគាល់ថាស្រី ឬសង្ស័យ និងសំដែងធម៌ដល់ស្រីយក្ខ ស្រីប្រេត បណ្ឌក និងតិរច្ឆានញីដែលមានកាយដូចជាមនុស្ស ទាំងអម្បាលនេះ ត្រូវទុក្កដ ៗ

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុសំដែងធម៌ត្រឹមតែ ៦ ម៉ាត់ ឬថយជាង ៦ ម៉ាត់ ឬបុរសមានលក្ខណៈដូចពោលហើយ នៅជាមួយផង ឬភិក្ខុក្រោកឡើងឯង ហើយត្រឡប់អង្គុយចុះវិញ សំដែងធម៌តទៅទៀត ឬស្រីក្រោកឡើងហើយអង្គុយចុះវិញ ភិក្ខុសំដែងធម៌តទៅទៀត ឬសំដែងដល់ស្រីដទៃតទៅ ឬភិក្ខុសួរបញ្ហា ឬស្រីសួរបញ្ហា ភិក្ខុដោះបញ្ហា ឬភិក្ខុសំដែងធម៌ដើម្បីមនុស្សដទៃ ស្រីមកអង្គុយស្តាប់ជាមួយផង និងភិក្ខុឆ្កួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ជាអនាណត្តិកៈ មាន [illegible]

វុត្តលក្ខណស្ស ធម្មស្ស ឆប្បញ្ច វាចាហិ ឧត្តរិ ទេសនា សំដែងធម៌មានលក្ខណៈ ដូចពោលហើយ លើសប្រាំមួយម៉ាត់ ១ វុត្ត-លក្ខណោ មាតុគាមោ មាតុគ្រាមមានលក្ខណៈ ដូចពោលមកហើយ ១ ឥរិយាបថបរិវត្តនាភាវោ មិនផ្លាស់ឥរិយាបថ ១ វិញ្ញុ-បុរិសាភាវោ មិនមានបុរសដឹងសេចក្តីនៅផង ១ អបញ្ហាវិសជ្ជនា មិនមែនជាការវិសជ្ជនានូវបញ្ហា ១ ព្រមដោយអង្គ ៥ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចបទសោធម្មសិក្ខាបទ ប្លែកតែសិក្ខាបទនេះជា កិរិយាកិរិយៈ គឺអាបត្តិកើតអំពីការធ្វើ និងមិនធ្វើ គឺភិក្ខុធ្វើនូវការសំដែងធម៌លើស ៦ ម៉ាត់ និងមិនធ្វើនូវការផ្លាស់ឥរិយាបថ ។

ធម្មទេសនាសិក្ខាបទ ទី ៧ ចប់

---

ភូតារោចនសិក្ខាបទ ទី ៨ សេចក្តីថា ភិក្ខុណា ប្រាប់ឧត្តរិ-មនុស្សធម្ម មានឈានជាដើម ដែលមានពិតក្នុងខ្លួនដល់អនុបសម្បន្ន មិនមែនភិក្ខុនិងភិក្ខុនី ត្រូវបាចិត្តិយ ព្រោះឧត្តរិមនុស្សធម្មមានពិត ។

ភូតារោចនសិក្ខាបទ ទី ៨ ចប់

---

ទុដ្ឋុល្លារោចនសិក្ខាបទ ទី ៩ សេចក្តីថា ភិក្ខុណា ប្រាប់អាបត្តិអា-ក្រក់របស់ភិក្ខុ ព្រមទាំងវត្ថុដល់អនុបសម្បន្នដូច្នេះថា ភិក្ខុនេះ[illegible]ធ្វើឲ្យ

www.budinst.gov.kh www.elibraryofcambodia.org

អសុចិហូរចេញ ត្រូវសង្ឃាទិសេសាបត្តិដូច្នេះជាដើម ត្រូវបាចិត្តិយ
វៀរលែងតែភិក្ខុដែលសន្និដ្ឋសម្មត គឺសន្និដ្ឋកំណត់ទីបំផុតនៃអាបត្តិ ១ យ៉ាង
ឬទីបំផុតនៃត្រកូល ១ យ៉ាង ឬកំណត់ទីបំផុតនៃអាបត្តិនិងត្រកូលផង ឬ
មិនកំណត់ទាំងពីរ ហើយអបលោកន៍ ៣ ផង ធ្វើកតិកាកំណត់ឲ្យប្រាប់ ឬ
ដើម្បីនឹងឲ្យភិក្ខុដែលត្រូវអាបត្តិរឿយ ៗ នោះ សង្រួមរក្សាខ្លួនល្អិតល្អន់ពោ
ភិក្ខុបានសម្មតិដូច្នេះ ប្រាប់តាមសម្មតិមិនត្រូវអាបត្តិ ។ ក្នុងបាលីថា
បារាជិក ៤ សង្ឃាទិសេស ១៣ ឈ្មោះថាអាបត្តិអាក្រក់លាមក ឯក្នុង
អដ្ឋកថា ថាក្នុងបាលីនេះពោលតែបារាជិក ដើម្បីនឹងសំដែងទុដ្ឋុល្លស័ព្ទ
ក៏ឯក្នុងសិក្ខាបទនេះ សង្គ្រោះយកសង្ឃាទិសេសផង ឈ្មោះថា
ទុដ្ឋុល្លាបត្តិ ។ ក្នុងអាបត្តិអាក្រក់ ត្រូវតែបាចិត្តិយ ។ មិនមែនអាបត្តិ
អាក្រក់ ភិក្ខុសំគាល់ថា អាបត្តិអាក្រក់ ឬសង្ស័យ ហើយប្រាប់ ឬប្រាប់
អាបត្តិទាំង ៥ កង មានថុល្លច្ច័យជាដើម ដែលមិនមែនជាទុដ្ឋុល្លាបត្តិ ឬ
ប្រាប់អជ្ឈាចារអាក្រក់ គឺការដែលកន្លងសិក្ខាបទទាំង ៥ ខាងចុងរបស់
អនុបសម្បន្ន ទាំងអម្បាលនេះ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺប្រាប់តែវត្ថុ ១ យ៉ាង ថាភិក្ខុនេះ
ធ្វើឲ្យអសុចិហូរចេញមក នឹងប៉ះពាល់អង្គៃលមាតុគ្រាមជាដើម ឬ
ប្រាប់តែអាបត្តិ ១ យ៉ាង ថាភិក្ខុនេះត្រូវអាបត្តិសង្ឃាទិសេស ត្រូវអាបត្តិ
ថុល្លច្ច័យ ជាដើមដូច្នេះក្តី ឬភិក្ខុដែលសន្និដ្ឋសម្មតកំណត់ឲ្យប្រាប់ទុកត្រឹម

www.budinst.gov.kh www.elibraryofcambodia.org

ឃា ប្រាប់តាមតែកំណត់ មិនឲ្យហួសកំណត់ទៅក្តី ឧទ្ទិសភិក្ខុគេជាដើម តាំងអម្បាលនេះ មិនត្រូវអាបត្តិ ៗ ជាអនាណត្តិកៈ មានអង្គ ៣ គឺ វុត្តលក្ខណស្ស ភិក្ខុនោ សវត្ថុកោ សង្ឃាទិសេសោ សង្ឃាទិសេសរបស់ភិក្ខុ ព្រមទាំងវត្ថុមានលក្ខណៈដូចពោលហើយ ១ អនុបសម្បន្នស្ស អារោចនំ ប្រាប់ដល់អនុបសម្បន្ន ១ ភិក្ខុ-សម្មុតិយា អភាវោ ភិក្ខុដែលសង្ឃមិនបានសម្មត ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ៗ សមុដ្ឋានវិធីជាដើម ដូចអទិន្នា-ទានសិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាទុក្ខវេទនាប៉ុណ្ណោះ ៗ

ទុដ្ឋុល្លារោចនសិក្ខាបទ គំរប់ ៩ ចប់

---

បឋវីខណនសិក្ខាបទ គំរប់ ១០ សេចក្តីថា ភិក្ខុណា ជីកដីដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យជីក ត្រូវបាចិត្តិយ ៗ ដីមាន ២ យ៉ាង គឺជាតបឋវី ១ អជាតបឋវី ១ ៗ ជាតបឋវី មាន ៣ យ៉ាង គឺដីសុទ្ធ ១ ដីលាយដោយរបស់ដទៃ ១ ដីគំនរ ១ ៗ ដីស្រួយសុទ្ធ ដីស្អិតសុទ្ធ ដោយប្រក្រតី ឈ្មោះថាដីសុទ្ធ ៗ ក្នុងផែនដីណាមានដីស្រួយ ឬដីស្អិត ច្រើន ២ ចំណែក ថ្ម អំបែង ក្រួស រ៉ៃន ខ្សាច់ តាំងអម្បាលនេះ ណាមួយតិចជាងចំណែកគំរប់ ៣ ផែនដីនោះឈ្មោះថាដីលាយដោយរបស់ដទៃ ៗ គំនរដីស្រួយ ឬដីស្អិត បើភ្លៀងធ្លាក់សន្តត់ហើយជាង ៤ ខែ ឈ្មោះថាដីគំនរ ដោយ

www.budinst.gov.kh www.elibraryofcambodia.org

បន្ទុកណា ផ្ទុះពាលមកហើយនោះ សូម្បីតែនរណាយកដោយរបស់ទៅ មិន
ត្រូវដែលត្រាំងទៅលើទ្រព្យ ក្រៀនទាក់សន្តិវង្វង់កម្មសិទ្ធ កន្លងទៅ ៤ ខែ
កាលដែលទឹកក្រៀនទឹកនោះកប់ជាផលដំណាំ ។ ផែនដីទាំង ៣ យ៉ាង
នេះ គឺក្នុងមួយឆ្នាំនេះ សូម្បីជាតុក្រពុំងទឹកដែលដុតបាក្រដាស់ដើម
ឈ្មោះថាផាតបប់ ។ គឺជាផែនដីដែលក្រុងនេះហើយ ប៉ុន្តែលាយដោយ
ផ្ទៃដើម ក្រូចឆ្មារចំណែកគល់បប់ ៣ ខែជាស្រូវ ប្តីស្នឹកនោះ ឬ គំនរ
ដីដែលក្រៀនទាក់សន្តិវង្វង់ដល់ ៤ ខែ ឈ្មោះថាអផាតបប់ ។ ផែនដី
មានជួនខ្មែរស្រុកទឹកអប្បសិរីនខ្សាច់ស្មួចមិនត្រូវពុក ។ ដីដែលផាត
បប់នោះ ឈ្មោះថាអកប្បីយបប់ ។ កិច្ចណាជាគង់ គឺធ្វើអកប្បីយបប់
នោះឲ្យកើត ដោយភាគរាជ្យ ទីធ្លាលាយ ទឹងតូច ទីងដុត ជាដើម កិច្ច
នោះត្រូវបាចិត្តយ កប់ដោយប្រយោគ ។ កិច្ចណានេះអ្នកដទៃជីកតំធ្វើឲ្យ
កើតដោយន័យដូចពោលមកហើយ គឺបញ្ញើណាក់រង្វង់ថា "អ្នក
ចូរជីករំលាយប្រាំងសនេះ ផែនដីនេះ ដូច្នេះ ជាដើម ត្រូវគ្រប់កំ
បន្ទាប់ ។ អ្នកទទួលបន្ទាប់សូម្បីជីកអស់ប៉ុណ្ណោះ ត្រូវបាចិត្តយដល់អ្នក
បន្ទាប់ តែមួយប៉ុណ្ណោះ ។ បើបន្ទាប់ច្រើន ក៏ត្រូវបាចិត្តយគល់ពាក្យ
ដែលបន្ទាប់នោះ ។ ផែនដីកិច្ចសន្សំប្រគំ មិនមែនផែនដី សំគាល់
ថាផែនដី ប្រុងឲ្យយក ធ្វើឲ្យកើត ត្រូវទុក្កដ ។

ឯដីដែលមិនត្រូវពាក្យនោះ គឺកិច្ចមិនបាននាំយមកស ចាំទីនេះ
នឹងបន្ទាប់ថាអ្នកចូរជីកស្រះបោក្ខរណី ជីកត្រពាំង ជីកអណ្តូង ដូច្នេះ

ជាដើមក្តី ដីកក់ ឬដីស្នាមក្រចកជើងគោ ដែលស្ងួតបែករបើកឡើង មិនបានជាប់នឹងដីចាស់ខាងក្រោម នឹងច្រាំង ស្ទឹង ទន្លេ របេះធ្លាក់ក្នុង ស្ទឹង ទន្លេ ជារបស់ធំក្តី នឹងគំនរដីស្អិតជាប់ដោយឧត្តិលៈជាដើម ទាំងអស់នេះឈ្មោះថាអជាតបឋវី ។ ព្រោះធ្វើអជាតបឋវីឲ្យកំរើកក្តី នឹងពោលថា អ្នកចូរជីកនៅរណ្តៅសសរនេះ អ្នកចូរឲ្យដីនេះ អ្នកចូរយកដីមកឲ្យយើង យើងត្រូវការដោយដី ចូរធ្វើដីឲ្យជាកប្បិយក្តី នឹងមិនតែងធ្វើឲ្យផែនដីបែកដោយភាគការប្រមៀលដើមឈើជាដើម នឹងយកមេជើងគូសដី ដោយមិនមានសតិ នឹងមិនដឹងថាជាជាតបឋវី ឬមិនដឹងខ្លួនថាជីកដីក្តី គូសដីក្តី នឹងកិច្ចគុតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាសាណត្តិកៈ មានអង្គ ៣ គឺ ជាតបឋវី ដឹងថាជាតបឋវី ១ បឋវីសញ្ញិតា ដឹងថាជាផែនដី ១ ខណនំ ១ ខណាបនំ អញ្ញតរំ ជីកឯងឬប្រើគេឲ្យជីកណាមួយជាដើម ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ មិនព្រមដោយអង្គ ៣ មិនត្រូវអាបត្តិ ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ថែកតែសិក្ខាបទនេះ ជាបណ្ណត្តិវជ្ជៈ មានចិត្ត ៣ មានវេទនា ៣ ។

បឋវីខណនសិក្ខាបទ គំរប់ ១០ ចប់

---

មុសាវាទវគ្គ ជាបឋម ចប់

---

ភូតគាមវគ្គ គំរប់ ២ មាន ១០ សិក្ខាបទ ៖

ភូតគាមសិក្ខាបទ ជាបឋម សេចក្តីថា កិច្ចធ្វើដើមឈើ ដើមស្មៅ

www.budinst.gov.kh www.elibraryofcambodia.org

ដើវល្លិ ឲ្យដាច់ផ្តាសទៅ គឺកាត់ខ្ទិចទំលាយជាដើម ត្រូវបាចិត្តិយ ។ ដើមឈើ ស្មៅ វល្លិ ដែលដុះលើគោក ឬក្នុងទឹកទាំងលើដើមឈើ ទាំងលើកំផែង ឯណាមួយ ដោយហោចទៅ សូម្បីតែតិណជាតិ គឺស្មៅ ដែលស្ទុះមល្អិតក្រៃពេក ដូចស្មៅដែលដុះលើកំផែងជាដើមក្តី ទាំងសេវាលជាតិ គឺសារាយ ចក ពពុះទឹក ដែលតូចប៉ុនគ្រាប់ស្ពៃស្រស់ទៀត ដែលតាំងនៅក្នុងទីនោះៗ ឈ្មោះថាភូតគាមទាំងអស់ ។ ភិក្ខុដឹងហើយធ្វើឲ្យកំរើក គឺដកឡើងពីគោក ឬលើកឡើងពីក្នុងទឹក ឬកាត់ទំលាយ ជាកកាប់ ជាដើម ធ្វើឯងឬប្រើអ្នកដទៃឲ្យធ្វើ ឲ្យកំរើកដោយន័យដូចពោលហើយ ក្នុងបរិវេណនៃសង្ឃាវាស ត្រូវបាចិត្តិយ ។ ដើមឈើ ស្មៅ វល្លិទាំងអស់នេះ គេរំលេចញែកពីភូតគាម គឺ ដក កាត់ចេញ ចាកទីហើយ នោះបើមានឫស ដើម មែក ថ្នាំង ត្រួយ ឬគ្រាប់ ណាមួយ ជាពូជក្តី ឈ្មោះថាពីជគាម ។ ពីជគាមនោះគេយកមកតាំងទុកក្នុងភាជន៍ ឬគេធ្វើជាគំនរទុក ឬគេដាំទុកក្នុងទីដទៃទៀត ដែលបែកតែឫសមួយមុខ នៅមិនទាន់ចេញពន្លក ឬចេញតែពន្លក ១ យ៉ាង មិនទាន់ចេញឫស ទាំងបើពន្លកស្លឹកប្រមាណមួយចំអាមលូតឡើង ឫសនៅមិនទាន់លេចចេញ ឬឫសលេចចេញហើយ ពន្លកមិនទាន់ខៀវដរាបណា ក៏ឈ្មោះថាពីជគាមដរាបនោះ ។ កាលឲ្យពីជគាមទាំងអម្បាលនោះកំរើក ត្រូវទុក្កដ ។ សង្ស័យក្នុងភូតគាម និងពីជគាមក្តី មិនមែនភូតគាម ពីជគាម សំគាល់ថាភូតគាម ពីជគាម ឬសង្ស័យ ឲ្យកំរើក ត្រូវទុក្កដ ។

www.budinst.gov.kh www.elibraryofcambodia.org

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភូតគាម ឬពីជគាម ភិក្ខុសំគាល់ថា
ខមែនហើយឲ្យកំរើក ទឹងកិច្ចឆ្កួតជាដើម មិនត្រូវអាបត្តិ ។ មិនក្លែងដូច
រៀលច្នុំទឹងដើមឈើជាដើម ឬស្តូវមែកឈើ ទឹងយកមេដើងធ្វើដែនដី
ហ្វូជាដើម ជាប់ទៅមិនត្រូវអាបត្តិ ព្រោះមិនក្លែងទឹងឲ្យដាច់ មិនមាន
តេ ដូចបញ្ចូនចិត្តទៅកាន់ទីដទៃនិយាយជាមួយគ្នា យកមេដើងឬដៃក្តិច
ហ្វូ ឬល្ងើ មិនត្រូវអាបត្តិ ព្រោះមិនមានសតិ មិនដឹង ដូចមិនដឹងថា ពីជ
មេ ឬភូតគាម នៅខាងក្នុង ទីរមិនដឹងថាខ្លួនធ្វើឲ្យដាច់ គ្រាន់តែយកដែក
ណ្តាឬចបជីកចាក់ក្តួលទៅក្នុងប្រហោង ឬកំនរបាម្បែង ដើម្បីទឹងទុកដាក់
ក្តីរលោកនៃៈហើយទោះទៅ ជាបើស្តូជាដើមក្នុងវិៈខាងដាច់ ឬ
នត្រូវអាបត្តិ ។ មិននិយមថាដើមឈើនេះឈើនោះ គ្រាន់តែពោលថា
គប្បីកាត់ឈើ កាត់វល្លិ៍ ទឹងពោលថាអ្នកចូរដឹងផ្កាឈើនេះ អ្នកចូរដឹង
ឈើនេះ អ្នកចូរកៀផ្កាឈើនេះ ផ្លែឈើនេះ អ្នកចូរយកផ្កាឈើនេះ
ឈើនេះមក យើងត្រូវការដោយផ្កាឈើនេះផ្លែឈើនេះ អ្នកចូរធ្វើ
ឈើនេះ ផ្លែឈើនេះឲ្យជាកប្បិយ ពោលដូច្នេះក្តី មិនត្រូវអាបត្តិ ។
ដ៏មានឫសជាដើមកើតនៅក្នុងទី ឈ្មោះថាភូតគាម ។ ដំរះឲ្យផុតចាក
គាមហើយ ឈ្មោះថាពីជគាម ជាវត្ថុឲ្យកើតទុក្កដ ។ ពីជគាមនេះ
លបើភិក្ខុទឹងបរិភោគ គប្បីឲ្យអនុបសម្បន្នកប្បិយជាមុន ដើម្បីឲ្យរួច
កពីជគាម ឯអាការដែលធ្វើកប្បិយនោះ ទឹងពោលទៅខាងមុខ ។

www.budinst.gov.kh www.elibraryofcambodia.org

សិក្ខាបទនេះ ជាសាណត្តិកៈ មានអង្គ ៣ គឺ ភូតគាមោ ភូតគាម-
ក្នុងគាមសញ្ញិតា ដឹងថាភូតគាម១ វិកោបនំ វា វិកោ-
ចាបនំ វា ធ្វើឲ្យកំរើកឯង ឬប្រើអ្នកដទៃធ្វើឲ្យកំរើក១ ព្រមដោយ
អង្គ ៣ នេះ ទើបត្រូវអាបត្តិបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចមុសា-
វាទសិក្ខាបទ ។

ភូតគាមសិក្ខាបទ ជាបឋម ចប់

---

អញ្ញវាទកសិក្ខាបទ គំរប់ ២ សេចក្តីថា ភិក្ខុត្រូវអាបត្តិជាសាវសេស
កាលសង្ឃសាកសួរក្នុងកណ្តាលសង្ឃ មិនបានប្រាថ្នានឹងប្រាប់សេចក្តី
នោះ ក៏គ្រាន់បិទបាំង ពោលបំភាន់ដោយពាក្យដទៃជាដើមថា អ្នកណាត្រូវ
ត្រូវខ្លួនអាបត្តិអ្វី ត្រូវទីត្រង់ណា ដូច្នេះជាដើមក្តី ឬនៅស្ងៀមធ្វើឲ្យសង្ឃ
លំបាកក្តី ត្រូវទុក្កដ ។ លុះសង្ឃលើកអញ្ញវាទកកម្ម ព្រោះពោលបំភាន់
ឬលើកវិហេសកកម្ម ព្រោះនៅស្ងៀម ធ្វើឲ្យសង្ឃលំបាក ដោយញត្តិ
ទុតិយកម្មវាចា ហើយសង្ឃសាកសួរទៀត ពោលពាក្យត្រឡប់ត្រឡិន
ទៅវិញទៅមក ឬនៅស្ងៀមទៀត ត្រូវបាចិត្តិយ ។ ធ្វើទាំង ២ យ៉ាង
ត្រូវបាចិត្តិយ ២

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុមិនដឹងអាបត្តិ ឬមិនបានដឹងថា
ខ្លួនត្រូវអាបត្តិ ឬសួរថាលោកពោលដូចម្តេច នឹងមិនបានពោលដោយ
គិតថា ភិក្ខុមិនបានធ្វើកម្មនោះប្រកបដោយធម៌ នឹងភិក្ខុឆ្កួតជាដើម ទាំង

www.budinst.gov.kh www.elibraryofcambodia.org

អម្បាលនេះ មិនត្រូវអាបត្តិ ។ សិក្ខាបទនេះមានអង្គ ៣ គឺ ធម្មកម្មេ អាភោបិតតា ការស្គាល់ថាលើកទោសនោះជាធម៌ ១ អាបត្តិយា វា វត្ថុជាក អនុយុញ្ជិយមានគា សង្ឃសាកសួរដោយអាបត្តិ ឬវត្ថុ ១ ជាធេតុការមកាយ អញ្ញេនញ្ញប្បដិចរណំ វា តុណ្ហីភាវោ វា ក្តែងពោលពាក្យបន្ទប់បន្ទាត់ ឬនៅស្ងៀមដោយប្រាថ្នាបិទបាំង ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាអនាណត្តិកៈ ។

អញ្ញវាទកសិក្ខាបទ គំរប់ ២ ចប់

---

៙ ឧជ្ឈាបនកសិក្ខាបទ គំរប់ ៣ សេចក្តីថា ភិក្ខុលើកទោស ត្មះតិះដៀល ខិន្នា ភិក្ខុដែលសង្ឃសម្មតឲ្យជាអ្នកធ្វើការសង្ឃ មានក្រាលអាសនៈនិងចែកលាភជាដើម តិះដៀល ឬខិន្នា ភិក្ខុដូច្នេះគឺសំណាក់ភិក្ខុមនគ្គា ជាភិក្ខុធ្វើដោយឆន្ទាគតិ ដូច្នេះ ដោយប្រាថ្នានឹងលើកទោសដល់ភិក្ខុ ឯភិក្ខុនោះមិនបានធ្វើដោយអគតិទាំង ៤ មានឆន្ទាគតិជាដើម ភិក្ខុអ្នកតិះដៀលត្រូវបាចិត្តិយ ។ ធ្វើទាំង ២ យ៉ាង ត្រូវបាចិត្តិយ ២ ។ ក្នុងសម្មតិកម្មដែលសង្ឃធ្វើដល់ភិក្ខុអ្នកធ្វើការសង្ឃនោះជាធម៌ ត្រូវតិកបាចិត្តិយ ។ ក្នុងកម្មដែលមិនមែនជាធម៌ ត្រូវតិកទុក្កដ ។ ភិក្ខុត្មះតិះដៀល ខិន្នា ភិក្ខុដែលសង្ឃសម្មតនោះ ក្នុងសំណាក់អនុបសម្បន្ន ឬត្មះតិះដៀល លើកទោស ឧបសម្បន្ន ដែលសង្ឃមិនបានសម្មតឲ្យធ្វើការសង្ឃដោយ

www.budinst.gov.kh www.elibraryofcambodia.org

ធម៌ ក្នុងសំណាក់អ្នកណាមួយក្តី ឬក៏តិះដៀលអនុបសម្បន្ន ដែលសង្ឃសម្មតក្តី មិនបានសម្មតក្តី ឲ្យធ្វើការសង្ឃដោយធម៌នោះ ក្នុងសំណាក់អ្នកណាមួយក្តី ទាំងអម្បាលនេះ ត្រូវអាបត្តិទុក្កដទាំងអស់ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុលើកទោស តិះដៀល នូវភិក្ខុជាអ្នកធ្វើការសង្ឃដោយអគតិទាំង ៤ មានឆន្ទាគតិជាដើម ដែលមិនត្រូវតាមធម៌ដោយប្រក្រតី ឬភិក្ខុឆ្កួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាបត្តិកៈ មានអង្គ ៦ គឺ ធម្មកម្មេន សម្មតតា ភិក្ខុអ្នកធ្វើការសង្ឃបានសម្មតិដោយកម្មជាធម៌ ១ ឧបសម្បន្នតា អ្នកធ្វើការសង្ឃនោះ ជាឧបសម្បន្ន ១ អគតិគមនតា ការមិនលុះក្នុងអគតិទាំងបួនណាមួយ ១ តស្ស អវណ្ណកាមតា ប្រាថ្នានឹងលើកទោសដល់អ្នកនោះ ១ យស្ស សន្តិកេ វទតិ តស្ស ឧបសម្បន្នតា លើកទោសឬតិះដៀល ក្នុងសំណាក់អ្នកណា អ្នកនោះជាឧបសម្បន្ន ១ ឧជ្ឈាបេតិ វា ខីយតិ វា បានឲ្យគេលើកទោស ឬតិះដៀលដោយខ្លួនឯង ១ ព្រមដោយអង្គ ៦ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាទុក្ខវេទនាប៉ុណ្ណោះ ។

ចប់ឧជ្ឈាបនសិក្ខាបទ គំរប់ ១៣ ។

---

បឋមសេនាសនសិក្ខាបទគំរប់ ១៤ សេចក្តីថា ភិក្ខុណា ដែលតាំងក្រាលសេនាសនៈឯង ឬប្រើអ្នកដទៃឲ្យតែងតាំង ក្រាល នូវគ្រែ

www.budinst.gov.kh www.elibraryofcambodia.org

តាំង ឬ ពូកស្បែក ពូកសំពត់ ឬ កៅអី ដែលជារបស់សង្ឃ ក្នុងវិហារ ក្នុងរដូវភ្លៀង ៤ ខែ ឬក្នុងមណ្ឌបដែលភ្លៀងលេចបាន ទីជិតឈើជាទីលំនៅជាទីពួននៃក្អែក ទីដីសត្វកាដក់ ជាដើម កាលចៀសចេញទៅ មិនរើទុកដាក់ឯង ឬមិនពឹងអ្នកដទៃឲ្យរើរបស់នោះទុកតាមសមគួរ ឬមិនបានផ្តាំផ្ញើប្រគល់ឲ្យភិក្ខុ ឬ សាមណេរ ឬ មនុស្សវេយ្យាវច្ច ឬ ឧបាសក ដែលជាលជ្ជី សំគាល់ថាជាធុរៈរបស់ខ្លួន ទាំងអម្បាលនេះ អ្នកឯណាមួយ ហើយចៀសចេញទៅ កន្លងលេឌ្ឌុបាត ដែលធ្លាក់ផុតដីនៃមជ្ឈិមបុរសបោះពីសេនាសនៈនោះទៅ ដោយដំហានជាបឋម ត្រូវទុក្កដ ។ ដំហានជាគំរប់ ២ ត្រូវបាចិត្តិយ ។ ព្រះពុទ្ធអង្គទ្រង់អនុញ្ញាតឲ្យតែងតាំងលាតក្រាលគ្រែតាំងជាដើម ក្នុងរដូវរងា ៤ ខែ រដូវក្តៅ ៤ ខែ ជា ៨ ខែ នេះសង្កេតថា មិនមែនជាកាលភ្លៀង ឬក្នុងមណ្ឌបទីជិតកក់ឈើដែលក្អែក តាដក់ មិនបន្ទោរឧច្ចារៈចុះ ក្នុងទីអម្បាលនេះ មិនទុកដាក់មុនហើយចៀសចេញទៅ មិនមានទោស ។ ភិក្ខុតាំងទុក ក្រាលទុក ដើម្បីភិក្ខុដទៃ ភិក្ខុដទៃនោះមិនបានអង្គុយក្នុងទីនោះ ឬមិនបានពោលថា អ្នកចូរទៅចុះ ដរាបណា គឺនៅជាភារៈរបស់អ្នកក្រាលដរាបនោះ ។ ឧបសម្បន្នអង្គុយលើគ្រែទីតាំងជាដើម ដែលខ្លួនតែងតាំងឯង ឬឲ្យអ្នកដទៃតែងតាំងលាតចេញហើយដោយប្រក្រតីឯណា របស់ទាំងនោះជាភារៈនៃអ្នកអង្គុយនោះដោយគិត ។ ភិក្ខុឈរនៅក្នុងវេនធានបង្គាប់ថា អ្នកចូរទៅ

www.budinst.gov.kh www.elibraryofcambodia.org

ភាជន៍ទុក ល្អាងទុក ក្នុងទីសម្រាប់នោះវេលាថ្ងៃនោះ ហើយចូលទៅទុ
ហើយភិក្ខុនោះចេញចាកកន្លែងឆាន់នោះទៅតាមចង់ចិត្ត ឬរំលងនូវតេជៀ
ភាគអាបត្តិភិក្ខុនោះ ដោយលើកនូវជំហាន ៗ ក្នុងសេនាសនៈរបស់សង្ឃ
ត្រូវអាបត្តិបាចិត្តិយ ៗ ក្នុងសេនាសនៈរបស់បុគ្គល ត្រូវអាបត្តិទុក្កដ ។
គ្រឿងកម្រាលក្រាលក្នុងផ្ទៃ ទីធ្នះគ្រឿងកម្រាលលើគ្រែ គ្រឿងកម្រាល
លើដី កន្ទេលផ្ចិត កន្ទេលស្លឹក កំណាត់ស្បែក សំពត់ជូតជើង
តាំងក្តារ ឬគ្រឿងឈើ គ្រឿងដី ដោយហោចទៅ សូម្បីគ្រឿងធ្វើ
ដោយស្លឹកឈើ តាំងអម្បាលនេះ ភិក្ខុដំកល់ទុកក្នុងអព្ភោកាស មាន
លក្ខណៈដូចសំដែងមកហើយ ចៀសចេញទៅ ត្រូវទុក្កដ ។

ក៏ឯភិក្ខុអ្នកនៅក្នុងព្រៃ កាលបើថ្ងៃណាភ្លៀងមិនលេចទឹកបាននោះ
មិនមាន នឹងយករបស់ទាំងអស់ទៅទុកលើមែកឈើ ឬសត្វមានកណ្ដៀរ
ជាដើម នឹងមិនបានកាត់ដូចម្ដេច សូម្បីនឹងធ្វើទុកដូច្នោះ ហើយនឹង
ចៀសចេញទៅកំឡុង ៗ ភិក្ខុកាន់អព្ភោកាសិកង្គធុតង្គនៅក្នុងវិហារ ក៏គប្បី
ធ្វើកុដិដោយចីវរក្បាលនឹងតាំងទុក ៗ

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺសេនាសនៈរបស់ខ្លួន នឹងរបស់
បុគ្គលអ្នកស្និទ្ធស្នាលគ្នា មិនត្រូវអាបត្តិ ទុកដាក់ឯង ឬធ្វើឲ្យអ្នកដទៃទុក
ដាក់ ឬគ្រាប់ប្រគល់ទុកហើយ ទើបទៅក្តី យកចេញទៅហាល ឬទៅដោយ
គិតថានឹងត្រឡប់មកទុកដាក់ ឬមានអ្នកមកឃាត់ឃាំងសេនាសនៈនោះ

www.budinst.gov.kh www.elibraryofcambodia.org

ទុក តិរច្ឆានមកបណ្តេញឲ្យក្រោក ឬអមនុស្សមកអង្គុយ ឬមនុស្សជាឥស្សរៈមកកាន់យក ឬសត្វសាហាវមានរាជសីហ៍ជាដើមមកឈរនៅក្នុងទីនោះ ទាំងអម្បាលនេះ ណាមួយ មិនបានទុកដាក់ក្តី ឬទៀសចេញទៅព្រោះខ្លាចអន្តរាយដល់ជីវិត និងព្រហ្មចរិយជាដើមក្តី និងកិច្ចធ្ងន់ជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាសាណត្តិកៈ មានអង្គ ៦ គឺ មញ្ចាទិកំ សង្ឃិកតា គ្រែនិងតាំងជាដើម ជារបស់សង្ឃ ១ វុត្តលក្ខណេ បទេសេ សន្ថរណំ វា សន្ថរាបនំ វា ក្រាលឯង ឬប្រើអ្នកដទៃឲ្យក្រាលក្នុងទីមានលក្ខណៈដូចពោលហើយ ១ អបលិពុទ្ធតា មិនមានអ្វីមកឃាត់ឃាំង ១ អាបទាយ អភាវោ មិនមានអន្តរាយ ១ ឯវបេក្ខតា មិនប្រាថ្នានឹងត្រឡប់មកទុកដាក់ ១ លេឌ្ឌុបាតាតិក្កមោ កន្លងនូវលេឌ្ឌុបាត ១ ព្រមដោយអង្គ នេះ ទើបត្រូវអាបត្តិ ។ សមុដ្ឋានវិធីជាដើម ដូចបឋមកឋិនសិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាកិរិយាកិរិយ ត្រូវព្រោះធ្វើ និងមិនធ្វើ គឺភិក្ខុធ្វើនូវការគ្រែនិងតាំងលាតក្រាលហើយ មិនធ្វើនូវការរៀបទុកវិញ ។

បឋមសេនាសនសិក្ខាបទ គំរប់ ៤ ចប់

---

ទុតិយសេនាសនសិក្ខាបទ គំរប់ ៥ សេចក្តីថា ភិក្ខុណា កាន់យកគ្រឿងក្រាលដេក ១០ យ៉ាង គឺ ពូក ១ គ្រឿងក្រាលក្រោមក្បាលនូវតំណាង

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទៃ ១ គ្រឿងកម្រាលលើគ្រែលើតាំងជាដើម ១ គ្រឿងកម្រាលលើផ្ទៃ ១ កន្ទេលស្លឹកត្នោតជាដើម ១ ស្បែកឯណានីមួយ ១ សំពត់និសីទនមានជាយ ១ បច្ចត្ថរណៈសំពត់បាក់រនៈនិងសំពត់គោជរៈ ១ គ្រឿងកម្រាលដីហើយដោយស្មៅ ១ គ្រឿងកម្រាលដីហើយដោយស្លឹកឈើ ១ តាំង ១០ នេះជារបស់សង្ឃ សូម្បីរបស់ណាមួយ កាន់យកដោយលំដាប់វស្សាខ្លួន មកលាតក្រាលឯង ឬប្រើអ្នកដទៃឲ្យលាតក្រាលក្នុងវិហារដែលជារបស់សង្ឃ នឹងចៀសទៅកាន់ទិស មិនបានសារទុកដាក់ឯង ឬមិនឲ្យអ្នកដទៃសារទុកដាក់ ឬមិនប្រាប់ប្រគល់ឲ្យអ្នកណាមួយ ដូចពោលហើយក្នុងសិក្ខាបទមុន កន្លងនូវឧបចារៈនៃអារាមចេញទៅ អារាមមិនមានរបង កន្លងនូវឧបចារៈចេញទៅ ក្នុងជំហានជាដំបូងត្រូវទុក្កដ ៗ ជំហានជាគំរប់ ២ ត្រូវបាចិត្តិយ ៗ ក្នុងទីឯណាមិនមានសេចក្ដីរង្កៀសដោយកណ្ដៀរ សូម្បីនឹងមិនប្រាប់ផ្ដាំប្រគល់ហើយ នឹងទៅចាកទីនោះក៏គួរ ៗ កិរិយាដែលប្រាប់ផ្ដាំប្រគល់នោះជាវត្តនៃតិកៈ ៗ ក្នុងវិហាររបស់សង្ឃត្រូវតិកបាចិត្តិយ ៗ ក្នុងវិហាររបស់បុគ្គលត្រូវតិកទុក្កដ ៗ លាតក្រាលឯង ឬឲ្យអ្នកដទៃលាតក្រាលទីដេកក្នុងឧបចារៈនៃវិហារ ក្នុងរោងឆាន់ ឬមណ្ឌបដែលបាំងនឹងមិនបានបាំង ឬក្នុងរុក្ខមូល ទីជាទីប្រជុំនៃជនដ៏ច្រើនក្ដី តែងតាំងឯង ឬប្រើអ្នកដទៃឲ្យតែងតាំងនូវគ្រែ ឬតាំង ក្នុងវិហារ នឹងឧបចារៈនៃវិហារដូចពោលមកហើយ មិនធ្វើការទុកដាក់ឯងជាដើម ហើយចៀសចេញទៅ ត្រូវទុក្កដទាំងអស់ ៗ

www.budinst.gov.kh www.elibraryofcambodia.org

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺវិហារជារបស់ខ្លួន ឬរបស់បុគ្គលអ្នកស្និទ្ធស្នាល មិនត្រូវអាបត្តិ ធ្វើការទុកដាក់ឯងជាដើម ឬមានអ្នកដទៃមកឃាត់ឃាំងដូចពោលហើយក្នុងសិក្ខាបទមុនទុកតាលនៅក្តី ឬគិតថានឹងមកទុកដាក់ក្នុងថ្ងៃនេះ ឬទៅកាន់ស្ទឹង ឬលើផ្ទែកក្បុំ គិតថានឹងទៅតទៅទៀតក៏ឈប់នៅក្នុងទីនោះ ប្រាប់ផ្តាំ ប្រគល់ក្តី ឬទឹកជន់ទីនោះជាដើម កំនត់ត្រឡប់មកមិនបានក្តី ឬមានអន្តរាយដល់ជីវិត ដល់ព្រហ្មចរិយក្តី នឹងកិច្ចធុរជាដើម ចាំងអម្បូលនេះមិនត្រូវអាបត្តិ ។ ជាសាណត្តិកៈ មានអង្គ ៧ គឺ វុត្តលក្ខណា សេយ្យា ទីដំណេកមានលក្ខណៈដូចពោលមកហើយ ១ គសង្ឃ សង្ឃិកតា ទីដំណេកនោះជារបស់សង្ឃ ១ វុត្តលក្ខណេ វិហារេ សន្ថរណំ វា សន្ថរាបនំ វា លាតក្រាលឯង ឬឲ្យអ្នកដទៃលាតក្រាលក្នុងវិហារមានលក្ខណៈដូចពោលហើយ ១ អបលិពុទ្ធតា មិនមានអ្នកណាឃាត់ឃាំង ១ អាបទាយអភាវោ មិនមានអន្តរាយ ១ អនបេក្ខស្ស ទិសាបក្កមនំ ចៀសទៅកាន់ទិស មិនប្រាថ្នានឹងត្រឡប់មក ១ ឧបចារសីមាតិក្កមោ កន្លងឧបចារសីមា ១ ព្រមដោយអង្គ ៧ នេះ ទើបត្រូវអាបត្តិបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចពោលហើយក្នុងសិក្ខាបទចាំលំដាប់មកនោះ ។

ទុតិយសេនាសនសិក្ខាបទ ទី ៤ ចប់

www.budinst.gov.kh www.elibraryofcambodia.org

សេចក្តីពន្យល់ក្នុងបទ តំរប់ ៦ សេចក្តីថា ភិក្ខុណា ដឹងថាភិក្ខុអ្នកចូលទៅមុន ជាអ្នកមិនគួរនឹងឲ្យក្រោកចេញ គឺជាភិក្ខុជាសង្ឃត្ថេរ ជាភិក្ខុឈឺក្តី ជាភិក្ខុគ្រូឧបជ្ឈាយ៍ ឬជាធម្មកថិក វិនយធរ គាចារ្យអ្នកបង្ហាញគណៈណាមួយ ដែលសង្ឃសន្មតវិហារឲ្យនៅជានិច្ចក្តី បើចង់ពួកនេះទៅក្នុងវិហារជារបស់សង្ឃ ឈ្មោះថាជាមនុស្សមិនគួរនឹងឲ្យក្រោក ភិក្ខុនឹងដូចនេះ មានប្រាថ្នានឹងឲ្យចង្អៀតចង្អល់ចិត្តឲ្យចេញទៅខ្លួនឯង យកទីដំណេកមកលាតក្រាលឯង ឬឲ្យអ្នកដទៃលាតក្រាល ក្នុងឧបចារៈគ្រែនិងតាំង ឬក្នុងឧបចារៈទីចូលចេញត្រូវទុក្កដ ៗ កាលអង្គុយ ឬដេក ក្នុងទីដំណេកនោះ ត្រូវបាចិត្តិយ ៗ ធ្វើតាំងពីរយ៉ាង ត្រូវបាចិត្តិយ ២ ៗ ធ្វើរឿយៗ ត្រូវបាចិត្តិយរាប់ដោយប្រយោគ ៗ ក្នុងវិហារធំ ដោយជុំវិញគ្រែនិងតាំង ១ ហត្ថ ១ ចំអាម ៗ ក្នុងវិហារតូច ល្មមដាក់ គ្រែនិងតាំងបានក្នុងទីណា អំពីទីនោះ ១ ហត្ថ ១ ចំអាម ឈ្មោះថាឧបចារៈគ្រែនិងតាំង ៗ អំពីផែនថ្មជាទីលាងជើង មកដល់គ្រែនិងតាំង ឈ្មោះថាឧបចារៈទីចូល ៗ អំពីគ្រែនិងតាំង មកដល់ទីបន្ទោបស្សាវៈ ឈ្មោះថាឧបចារៈទីចេញ ៗ ក្នុងវិហារជារបស់សង្ឃ ត្រូវតែបាចិត្តិយ ៗ ក្នុងវិហារជារបស់បុគ្គល ត្រូវតែទុក្កដ ៗ ក្រោលឯង ចុះប្រើអ្នកដទៃឲ្យក្រាលនូវទីដំណេក ឬទីអង្គុយ នឹងដេកក្នុងវិហារនោះ ក្រៅឧបចារៈដូចពោលហើយ ឬក្នុងឯកទេសជាដើម ឬក្នុងឧបចារៈនៃកុដិវិហារ ទាំងអម្បាលនេះ ត្រូវទុក្កដ ៗ

www.budinst.gov.kh www.elibraryofcambodia.org

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺលាត ក្រាល អង្គុយ ដេក ក្នុងសេនាសនៈជារបស់ខ្លួន ឬរបស់មនុស្សស្និទ្ធស្នាលក្តី ភិក្ខុឈឺ ឬភិក្ខុត្រជាក់ក្តៅបៀតបៀនហើយចូលទៅក្តី ឬមានអន្តរាយ មានភិក្ខុឈឺជាដើម ទាំងអម្បាលនេះមិនត្រូវអាបត្តិ ។ ជាអនាណត្តិកៈ មានអង្គ ៦ គឺ សង្ឃិកវិហារតា វិហារទីលំនៅជារបស់សង្ឃ ១ អនុដ្ឋាបនិយការជានធំ ដឹងថាភិក្ខុនៅមុខមិនគួរនឹងឲ្យក្រោក ១ សម្ពាធេតុកាមតា ប្រាថ្នានឹងឲ្យភិក្ខុនោះបង្អៀតបង្អល់ ១ ឧបចារេ និសីទនំ វា និបជ្ជនំ វា អង្គុយឬដេកក្នុងឧបចារៈ ១ ព្រមដោយអង្គ ៦ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចបឋមបារាជិក ប្លែកតែសិក្ខាបទនេះ ជាទុក្ខវេទនា រុណ្ណកៈ ។

អនុបខជ្ជសិក្ខាបទ ទី ៦ ចប់

---

និក្កឌ្ឍនសិក្ខាបទ ទី ៧ សេចក្តីថា ភិក្ខុណា ក្រោធទាស់ទែងនឹងភិក្ខុ ក៏យកទាញឯង ឬប្រើអ្នកដទៃឲ្យទាញ ចាកវិហារគឺកុដិជារបស់សង្ឃ ឲ្យកន្លងទ្វារចេញទៅ ត្រូវបាចិត្តិយ ។ ប្រាសាទច្រើនជាន់ ឬកុដិមុខ ៗ ក្លោងទ្វារច្រើន ក្នុងសេនាសនៈដូច្នេះ ទាញដោយប្រយោគតែ ១ មិនឈប់ក្នុងចន្លោះ ៗ ត្រូវបាចិត្តិយតែ ១ ។ ទាញដោយប្រយោគផ្សេង ៗ ឈប់ក្នុងចន្លោះ ៗ ត្រូវបាចិត្តិយ រាប់ដោយប្រយោគ សូម្បីមិន

www.budinst.gov.kh www.elibraryofcambodia.org

ពាល់ដោយដៃ ហើយរះផ្ញើឲ្យចេញដោយកាយក៏ដូចគ្នា បង្គាប់អ្នកដទៃឲ្យទាញ ខណៈដែលបង្គាប់ ត្រូវទុក្កដ បង្គាប់តែម្តងគេទាញឲ្យកន្លងទ្វារទៅស្មើរប្រហើនដង ត្រូវបាចិត្តិយ ដល់អ្នកបង្គាប់តែ ១ ។ បើប្រើអ្នកដទៃកំណត់ថា អ្នកចូរទាញឲ្យហួសទ្វារប៉ុណ្ណោះ ឬថាអ្នកចូរទាញទៅឲ្យដល់ទ្វារធំ ដូច្នេះ ត្រូវបាចិត្តិយ តាមដោយទ្វារ ៗ កុដិវិហារជារបស់សង្ឃត្រូវតិកបាចិត្តិយ ៗ កុដិវិហារជារបស់បុគ្គលត្រូវតិកទុក្កដ ៗ ទាញភិក្ខុឬបរិក្ខារនៃភិក្ខុចេញចាកឧបចារៈនៃវិហារ មានកេនធានជាដើម និងទាញអនុបសម្បន្ន ឬបរិក្ខារនៃអនុបសម្បន្នចេញចាកវិហារ ឬឧបចារៈនៃវិហារ ទាំងអម្បាលនេះ ត្រូវទុក្កដ តាមបរិក្ខារ ៗ

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺទាញចេញចាកវិហាររបស់ខ្លួន ឬរបស់អ្នកស្និទ្ធស្នាល ឬទាញទាំងចេញខ្លួនភិក្ខុអ្នកឈ្លោះ ឬបរិក្ខាររបស់អ្នកឈ្លោះ ចេញចាកសង្ឃរាមទាំងអស់ក្ដី ឬទាញអលជ្ជីភិក្ខុនិងភិក្ខុឆ្កួត និងសទ្ធិវិហារិក អន្តេវាសិក ជាអ្នកមិនបានប្រព្រឹត្តល្អ ឬទាញបរិក្ខារមនុស្សទាំងអម្បាលនេះចេញចាកទីលំនៅនៃខ្លួនក្ដី និងភិក្ខុឆ្កួតជាដើម ទាំងអម្បាលនេះមិនត្រូវអាបត្តិ ។ ជាសាណត្តិកៈ មានអង្គ ៣ គឺ សង្ឃិកវិហារតា វិហារជារបស់សង្ឃ ១ ឧបសម្បន្នស្ស កណ្ឌនការកភាវវិនិមុត្តតា ជាឧបសម្បន្ន ផុតចាកសភាពជាអ្នកឈ្លោះជាដើម ១ កោបេន និក្កឌ្ឍនំ វា និក្កឌ្ឍាបនំ វា ទាញឯងក្ដីប្រើអ្នកដទៃឲ្យទាញឧបសម្បន្ននោះ ដោយ

www.budinst.gov.kh www.elibraryofcambodia.org

សេចក្ដីទី ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋាន-វិធជាដើម ដូចអទិន្នាទានសិក្ខាបទ ប៉ុន្តែសិក្ខាបទនេះជាទុក្ខវេទនា ។

និក្កឌ្ឍនសិក្ខាបទ គំរប់ ៧ ចប់

---

វេហាសកុដិសិក្ខាបទ គំរប់ ៨ សេចក្ដីថា ក្នុងវិហាររបស់សង្ឃ វេហាសកុដិ គឺកុដិ ២ ជាន់ ឬបីជាន់ ជាន់ខាងលើមិនបានក្រាល ជាន់ខាងក្រោមជាទីបរិភោគ ខ្ពស់ប្រមាណត្រឹមក្បាលមធ្យមបុរស មិនទើសក្បាល នឹងធ្នឹមខាងលើ ភិក្ខុណា អង្គុយ ឬដេក លើគ្រែ ឬតាំង មានជើងដែលចុចចុះ គឺសិកចូលក្នុងមេគ្រែ មិនបានដាក់កន្លុះ ដែលគេដំកល់ទុកលើធ្នឹម នឹងគេជាន់លើ ត្រូវបាចិត្តិយ កប់ដោយប្រយោគ ដោយន័យដូចពោល ហើយក្នុងអនុប្បខជ្ជសិក្ខាបទ ប៉ុន្តែសិក្ខាបទនេះ មានសមុដ្ឋានវិធីជាដើម ដូចឯឡកលោមសិក្ខាបទ ។

វេហាសកុដិសិក្ខាបទ គំរប់ ៨ ចប់

---

មហល្លកវិហារសិក្ខាបទ គំរប់ ៩ សេចក្ដីថា ភិក្ខុធ្វើឯង ឬឲ្យអ្នកដទៃធ្វើ ឬជួសជុលនូវវិហារ គឺកុដិ លាបបូកតាំងខាងក្នុងខាងក្រៅ ខាងលើឬខាងក្រោមដោយកំបោរនិងដី ដែលជាវិហារធំ គឺមានម្ចាស់របស់ គប្បីលាបបូក ឬឲ្យអ្នកដទៃលាបបូករឿយ ៗ ក្នុងទី ២ ហត្ថ ១ ចំអាម ដោយជុំវិញមេទ្វារ ដើម្បីនឹងឲ្យទំពាំងទ្វារ នឹងសន្ទឹកទ្វារ ជាប់មាំមិនរង្គោះ ផ្សិតទី

www.budinst.gov.kh - www.elibraryofcambodia.org

នោះជាទីប៉ះទង្គិចដោយសន្ទឹកទ្វារគន្លឹះលាំបើកចាំង ទើបគប្បីលាបថែមឡើង ឬ ឲ្យអ្នកដទៃលាបថែមទៀត នូវទេកាសទៃបន្តិច ចំពោះមុខសន្ទឹកបន្ទះ ដោយជុំវិញ ដើម្បីនឹងធ្វើបរិកម្មបន្ទះឲ្យមានពណ៌ស្មើ ៗ គប្បីប្រើ ដីច្បូងលាយកំបោរ ឬ ល្បៀង ឬ សំណ ឬ ល្មៅ ឬ ស្ករឈើលាក់មួយ ប្រក់ឯងពីរជាន់ ជាទីកំណត់ ៣ គប្បីឲ្យអ្នកដទៃប្រក់ ចាប់ប្រក់ឲ្យហួស ៣ ជាន់ឡើងទៅ ត្រូវបាចិត្តិយ ៗ គប្បីឈរក្នុងទីប្រាសចាកវត្ថុទៀត គឺឲ្យ ផុតក្រោយចំណោលដែលគេព្រោះសាប នូវបុព្វណ្ណជាតិមានសណ្តែកជាដើម : ជាបើឈរក្នុងទីមានរបស់ទៀតដូច្នេះ ធ្វើការលាប ធ្វើការប្រក់ ត្រូវទុក្កដ ៗ កំណត់ទីឈរដូច្នេះ មនុស្សអង្គុយខាងលើមេដំបូល ឬ កំពូលដែលរនះហាន កំពូល នឹងក្រឡេចមើលមកដោយទីបំផុតសំយ៉ាប ឃើញមនុស្សខាង ក្រោមឈរនៅលើចំណែកដីឯណា បើមនុស្សឈរនៅលើចំណែក ខាងក្រោមឯណា នឹងមើលឡើងទៅ ឃើញមនុស្សអង្គុយខាងលើ ដូច្នោះដែរ គប្បីឈរលើចំណែកខាងលើដូច្នេះ ឈ្មោះថាធ្វើការប្រក់ ៗ សមុដ្ឋាននៃពីជាដើម ដូចសេចក្តីសិក្ខាបទ ៗ

មហល្លកវិហារសិក្ខាបទ ទី ៩ ចប់

---

សប្បាណកសិក្ខាបទ ទី ១០ សេចក្តីថា ភិក្ខុដឹងថាទឹកមាន សត្វ យកទៅស្រោចស្មៅ ស្រោចដីខ្លួនឯង ឬប្រើអ្នកដទៃឲ្យយក

www.budinst.gov.kh www.elibraryofcambodia.org

ស្រោច ត្រូវបាចិត្តិយ ៗ បើដាក់ឲ្យដាច់ឈ្នួរទឹកមួយក្អម ត្រូវអាបត្តិ បាចិត្តិយតែមួយ ៗ ស្រោចឲ្យដាច់ឈ្នួរទឹកទៀយ ៗ ត្រូវអាបត្តិរាប់ដោយប្រយោគ ៗ បើធ្វើប្រឡាយឲ្យត្រង់ឲ្យទឹកហូរទៅស្មៅអស់មួយថ្ងៃ ត្រូវអាបត្តិតែមួយប៉ុណ្ណោះ ៗ ទប់ទំនប់បង្ហូរទឹកឲ្យហូរទៅក្នុងទីដទៃ ត្រូវអាបត្តិរាប់ដោយប្រយោគ ៗ ពោលស្មៅនឹងស្លឹកឈើជាដើម ស្មៅច្រើនក្នុងទឹកដែលតិច សត្វនឹងស្លាប់ដោយការពោលស្មៅនឹងស្លឹកឈើនោះ ពោលដោយប្រយោគតែមួយត្រូវអាបត្តិតែមួយ ៗ ពោលម្ដង ៗ មួយមុខ ៗ រាប់ដោយប្រយោគដែលពោល ៗ បើឲ្យអ្នកដទៃស្រោច ត្រូវទុក្កដដោយបង្គាប់ ៗ អ្នកទទួលបង្គាប់នោះស្រោចស្មៅច្រើន ត្រូវបាចិត្តិយតែមួយដល់អ្នកបង្គាប់ ៗ ក្នុងទឹកមិនមានសត្វសំគាល់ថាមានសត្វ ឬសង្ស័យក្នុងទឹកដែលមានសត្វក្តី ក្នុងទឹកដែលមិនមានសត្វក្តី កាន់យកស្រោចត្រូវទុក្កដ ៗ

អនាបត្តិដែលមិនត្រូវអាបត្តិនោះ គឺស្រោចដោយសំគាល់ថា ទឹកមិនមានសត្វ ដោយមិនក្លែង មិនមានសតិ មិនដឹង និងភិក្ខុឆ្កួតជាដើម ទាំងអព្យាលះនេះមិនត្រូវអាបត្តិ ៗ ជាសាណត្តិកៈ មានអង្គ ៤ គឺ ឧទកស្ស សប្បាណកតា ទឹកមានសត្វ ១ សិញ្ចនេន មរណកាមៈស្សន្និដ្ឋិត ជានន់ ដឹងថាសត្វនឹងស្លាប់ ដោយការដាក់ទឹក ១ គញ្ញ ឧទកំ កាពិសមេវ ទឹកនឹងទីវៃទៅ ១ វិធា វេធគ ឯតាយ យេន តេការុចិនេះ ការណាំយេន តំណាជីង

សំពាញ់ចំ ក្រោយសេចក្តីជាដើម ដោយភិក្ខុណាមួយ ឬទៀតជាការបកកេបកខា ។ ព្រមដោយអង្គ ៤ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានទាំងឡាយជាដើម ដូចអទិន្នាទានសិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាបណ្ណត្តិវជ្ជៈ ៣០ ទោសព្រោះពុទ្ធប្បញ្ញត្តិ មានចិត្ត ៣ មានវេទនា ៣ ។

សព្វាណកសិក្ខាបទ គំរប់ ១០ បទ

ភូតគាមវគ្គគំរប់ ២ បទ

---

ឆត្តវគ្គ គំរប់ ៣ មាន ១០ សិក្ខាបទ ។

ឆត្តសិក្ខាបទ ជាបឋម សេចក្តីថា ភិក្ខុណា ដែលសង្ឃមិនបាន សន្មតឲ្យជាអ្នកប្រដៅ ហើយទៅប្រដៅនាងភិក្ខុនីដោយគរុធម៌ ៨ ត្រូវបាចិត្តិយ ។ ភិក្ខុប្រកបព្រមដោយអង្គ ៨ ដូច្នេះ គឺជាអ្នកសម្រេចដោយបាតិមោក្ខសំវរៈ ១ ជាពហុស្សុត ១ ចេះចាំបាតិមោក្ខទាំងពីរ ដោយពិស្តារ ១ សំឡេងពីរោះស្រួលបួល ១ ជាទីស្រឡាញ់នៃនាងភិក្ខុនី ១ មានកំឡាំងល្មមនឹងប្រដៅនាងភិក្ខុនីបាន ១ មិនធ្លាប់កន្លងគរុធម៌ជាមួយភិក្ខុនី ដែលស្លៀកដណ្តប់សំពត់កាសាវពស្ត្រ បួសចំពោះព្រះមានព្រះភាគអំពីកាលជាគ្រហស្ថ ១ មានវស្សា ២០ ឬលើសជាង ២០ ឡើងទៅ ១ ព្រមដោយអង្គ ៨ នេះ ទើបគួរសង្ឃសន្មតឲ្យជាអ្នកប្រដៅនាងភិក្ខុនី ។

គរុធម៌ ៨ ដូច្នេះ គឺភិក្ខុនីមានវស្សាសូម្បី ១០០ គប្បីធ្វើអភិវាទជាដើមដល់ភិក្ខុ សូម្បីទើបបំបួសក្នុងថ្ងៃនោះ ១ កុំគប្បីចាំវស្សាក្នុងអាវាស

www.budinst.gov.kh www.elibraryofcambodia.org

មិនមានភិក្ខុ ១ គប្បីប្រាថ្នាការសួរឧបោសថ នឹងការចូលទៅដើម្បីទទួលឱវាទអំពីភិក្ខុសង្ឃគ្រប់កន្លះខែ ១ នៅចាំវស្សាហើយគប្បីបវារណាក្នុងសង្ឃពីរពួក ១ ត្រូវគរុធម៌គឺសង្ឃាទិសេសហើយ គប្បីប្រព្រឹត្តបក្ខមានត្តក្នុងសង្ឃពីរពួក ១ គប្បីស្វែងរកឧបសម្បទាដល់នាងសិក្ខមានាអ្នកសិក្សាក្នុងធម៌ប្រាំមួយ អស់ពីរឆ្នាំហើយក្នុងសង្ឃពីរពួក ១ កុំគប្បីបរិភាសន៍ ជេរផ្តាសាភិក្ខុដោយបរិយាយណាមួយ ១ បិទគន្លងពាក្យភិក្ខុនីមិនឲ្យប្រដៅភិក្ខុ បើកឲ្យភិក្ខុប្រដៅភិក្ខុនីអំពីថ្ងៃនាងដើមទៅ ១ ។ គរុធម៌ទាំង ៨ នេះ ក្នុងមួយៗ ភិក្ខុនីគប្បីគោរពរាប់អាន កុំគប្បីប្រព្រឹត្តកន្លងដរាបអស់ជីវិត ។

ឱវាទសិក្ខាបទ ជាបឋម ចប់

អត្ថង្គតសិក្ខាបទ គំរប់ ២ សេចក្តីថា ភិក្ខុណា សូម្បីសង្ឃសន្មតឲ្យជាអ្នកប្រដៅភិក្ខុនីហើយ កាលព្រះអាទិត្យអស្តង្គតទៅហើយ ប្រដៅភិក្ខុនីដោយគរុធម៌ ឬដោយធម៌ដទៃ ត្រូវបាចិត្តិយ ។

អត្ថង្គតសិក្ខាបទ គំរប់ ២ ចប់

ឧបស្សយសិក្ខាបទ គំរប់ ៣ សេចក្តីថា ភិក្ខុចូលទៅកាន់ទីលំនៅនៃភិក្ខុនី ពោលប្រដៅភិក្ខុនី ដោយគរុធម៌ ត្រូវបាចិត្តិយ វៀរតែមានសម័យគឺ ភិក្ខុនីឈឺមកមិនបាន ។

ឧបស្សយសិក្ខាបទ គំរប់ ៣ ចប់

www.budinst.gov.kh www.elibraryofcambodia.org

អាមិសសិក្ខាបទ គំរប់ ៤ សេចក្តីថា ភិក្ខុណា ពោលតិះដៀលថា ភិក្ខុទាំងឡាយពោលប្រដៅភិក្ខុនី ព្រោះហេតុតែអាមិស មានបច្ច័យ ៤ ជាដើមដូច្នេះ ត្រូវបាចិត្តិយ ។

អាមិសសិក្ខាបទ គំរប់ ៤ ចប់

---

ចីវរទានសិក្ខាបទ គំរប់ ៥ សេចក្តីថា ភិក្ខុណា ឲ្យចីវរសម្បូរ គ្រាន់តែល្មម វិកប្ប ដល់ភិក្ខុនីមិនមែនញាតិ ត្រូវបាចិត្តិយ វៀរលែងតែផ្លាស់ប្តូរគ្នា សូម្បីប្តូរដោយតែតិចក្តី មិនត្រូវអាបត្តិ ។

ចីវរទានសិក្ខាបទ គំរប់ ៥ ចប់

---

ចីវរសិព្វនសិក្ខាបទ គំរប់ ៦ សេចក្តីថា ភិក្ខុណា ដេរចីវរជារបស់ភិក្ខុនីមិនមែនញាតិ ដេរឯងឬឲ្យអ្នកដទៃដេរ ត្រូវបាចិត្តិយ ។

ចីវរសិព្វនសិក្ខាបទ គំរប់ ៦ ចប់

---

សំវិធានសិក្ខាបទ គំរប់ ៧ សេចក្តីថា ភិក្ខុណា បបួលសន្យាពេល ដើរផ្លូវជាមួយគ្នានឹងភិក្ខុនី ហើយដើរផ្លូវជាមួយគ្នា ដោយហោចទៅ សូម្បីផុតកលនៃស្រុកមួយ ត្រូវបាចិត្តិយ វៀរលែងតែមានសម័យ គឺផ្លូវដែលត្រូវទៅដោយពួករទេះ ជាផ្លូវប្រកបដោយរង្កៀស គឺឱកាសដែលចោរតាំងនៅជាដើមប្រាកដ ឯផ្លូវដែលប្រកបដោយភ័យធំ គឺចោរសម្លាប់មនុស្សឃើញប្រាកដ មានសម័យដូច្នេះ មិនត្រូវអាបត្តិ ។

សំវិធានសិក្ខាបទ គំរប់ ៧ ចប់

---

www.budinst.gov.kh www.elibraryofcambodia.org

នាវាភិរូហនសិក្ខាបទ គំរប់ ៨ សេចក្ដីថា ភិក្ខុណា បបួល សន្យាតំណាត់នឹងភិក្ខុនី ឡើងជិះទូកជាមួយគ្នា ទៅច្រាសទឹកឬបណ្ដោយទឹក ត្រូវបាចិត្តិយ វៀរលែងតែឆ្លងកាត់ទទឹង ទៅពីត្រើយខាងណេះទៅត្រើយខាងណោះដោយត្រង់ ។

នាវាភិរូហនសិក្ខាបទ គំរប់ ៨ ចប់

---

បរិបាចនសិក្ខាបទ គំរប់ ៩ សេចក្ដីថា ភិក្ខុណា ដឹងហើយឆាន់បិណ្ឌបាតដែលភិក្ខុនីបបួលទាយកឲ្យដាក់បែងថ្វាយ ត្រូវបាចិត្តិយ វៀរលែងតែទាយកគេតាក់តែងទុកមុន ឬគេជាញាតិ ឬជាមនុស្សបវារណានៃភិក្ខុ មិនត្រូវអាបត្តិ ។

បរិបាចនសិក្ខាបទ គំរប់ ៩ ចប់

---

រហោនិសជ្ជសិក្ខាបទ គំរប់ ១០ សេចក្ដីថា ភិក្ខុណា តែម្នាក់ឯងមិនមានបុរសដឹងក្ដីនៅផង សម្រេចការអង្គុយ ការដេក ក្នុងទីកំបាំងភ្នែកជាមួយនឹងភិក្ខុនីម្នាក់ឯង មិនមានភិក្ខុនីដទៃនៅផង ត្រូវបាចិត្តិយ ។

រហោនិសជ្ជសិក្ខាបទ គំរប់ ១០ ចប់

---

សិក្ខាបទទាំង ១០ នេះ ភិក្ខុនីបានឧបសម្បទាក្នុងឧភតោសង្ឃជាបាចិត្តិយតែ ។ ឧបសម្បទាក្នុងឯកតោសង្ឃជាទុក្កដតែ ។ សិក្ខាបទទាំង ១០ នេះគោលដោយសមុដ្ឋាន ព្រោះឥឡូវនេះមិនមានភិក្ខុនី មិនបានបដិបត្តិ ។

ឱវាទវគ្គ គំរប់ ៣ ចប់

---

www.budinst.gov.kh www.elibraryofcambodia.org

## ភោជនវគ្គ គំរប់ ៤ មាន ១០ សិក្ខាបទ ៕

អាវសថបិណ្ឌសិក្ខាបទ ជាបឋម សេចក្តីថា ដុំបាយក្នុងរោងទាន គឺ ភោជន៥ប្រការ គឺ បាយ១ នំកុម្មាស១ សត្តុ១ ត្រី១ សាច់១ ទាំង៥ អម្បាលនេះ ណាមួយ ដែលមនុស្សអ្នកប្រាថ្នាបុណ្យ ក្នុងត្រកូលជាមួយគ្នា ឬត្រកូលផ្សេងគ្នា រួមចូលគ្នាជាពួកមួយ ដំកល់ទុកល្មមបានឆ្អែត ក្នុងសាលាក្តី មណ្ឌបក្តី ក្រោមដើមឈើក្តី ទីវាលក្តី ជាមួយគ្នា ឬផ្សេងៗគ្នា ឬញែកក្តី ថ្ងៃនេះដំកល់ទុកក្នុងទីមួយ ព្រឹកនេះដំកល់ទុកក្នុងទីមួយដូច្នេះ មិនចំពោះអ្នកបួស ជាឲ្យមនុស្សទាំងឡាយនេះ ឲ្យដល់មនុស្សប៉ុណ្ណោះ ឬមិនចំពោះរបស់ស៊ី ឲ្យខូចទៅ ក្នុងភោជនដូច្នេះ ភិក្ខុមិនឈឺ គឺអាចទៅបានស្រួលកន្លះយោជន៍ គប្បីទទួលទានបានក្នុងទីមួយក្នុងមួយថ្ងៃប៉ុណ្ណោះ តាំងពីថ្ងៃទីពីរហើយ ថាបើទទួលរបស់មនុស្សអម្បាលនេះ ក្នុងវត្តនោះ ឬទីដទៃទៀត ដោយប្រាថ្នាតែនឹងឆាន់ ត្រូវទុក្កដ ៗ ឆាន់ចូលទៅ ត្រូវបាចិត្តិយ គ្រប់ពំនូតដែលលេបចូលទៅ ៗ មិនមានជម្ងឺត្រូវត្រិកបាចិត្តិយ ។ មានជម្ងឺសំគាល់ថាមិនមានជម្ងឺ ឬសង្ស័យ ទទួលឆាន់ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុមានជម្ងឺក៏ដឹងថាមានជម្ងឺក្តី ភិក្ខុឆាន់តែម្តង ឬកាលទៅឆាន់ក្នុងពាក់កណ្តាលផ្លូវមួយថ្ងៃ ឬឆាន់ក្នុងទីដល់ហើយមួយថ្ងៃ សម្បីកាលត្រឡប់មកវិញឆាន់ក្នុងកណ្តាលផ្លូវមួយថ្ងៃ ឬមកដល់ហើយ ឆាន់ក្នុងទីដែលមកដល់មួយថ្ងៃក្តី គឺគង់បាននឹងទៅ

www.budinst.gov.kh www.elibraryofcambodia.org

ឆាន់ហើយចេញទៅមានអន្តរាយណាមួយក៏ត្រឡប់មកវិញ ដល់ដឹងថាផុតក្រមហើយ កាលដឹងទៅឆាន់មួយថ្ងៃទៀតក្តី ឬម្ចាស់ទានគេនិមន្តឲ្យឆាន់ក្តី ឬភិក្ខុឆាន់របស់ដែលគេតាក់តែងចំពោះខ្លួនក្តី ដឹងឆាន់របស់ដែលគេតាក់តែងមិនល្មមផ្អែកក្តី ឬឆាន់របស់ដទៃក្រៅពីភោជនទាំង ៥ ដឹងភិក្ខុឆ្អែតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិកៈ មានអង្គ ៣ គឺ អាវសថបិណ្ឌតា ដុំបាយក្នុងរោងទាន ១ អគិលានតា មិនមានជម្ងឺ ១ អនុវសិត្វា ភោជនំ នៅឆាន់ត្រាំក្រែង ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចឯឡកលោមសិក្ខាបទ ។

### អាវសថបិណ្ឌសិក្ខាបទ ជាបឋម ចប់

---

គណភោជនសិក្ខាបទ ទី ២ សេចក្តីថា ត្រូវបាចិត្តិយព្រោះឆាន់គណភោជន ។ ភិក្ខុតាំងពី ៤ អង្គឡើងទៅ ឈ្មោះថាគណៈ បើទាយកគេមកនិមន្តភិក្ខុ ៤ អង្គក្នុងទីជាមួយគ្នា ឬផ្សេងៗគ្នា មកនិមន្តដោយឈ្មោះភោជនទាំង ៥ ប្រការណាមួយ គឺអ្នកនិមន្តកាន់យកឈ្មោះភោជនទាំង ៥ ណាមួយ ហើយនិមន្តដោយអកប្បិយវោហារ ជាដើមថា និមន្ត ឆាន់បាយ ឆាន់ត្រី ឆាន់សាច់ លោកចូរទទួល បាយ ត្រី សាច់ នៃខ្ញុំដូច្នេះ ជាភាសាមគធៈក្តី ឬភាសាដទៃក្តី ភិក្ខុទាំងអម្បាលនេះ បើគេនិមន្តជាមួយគ្នា ឬផ្សេងៗគ្នាដូច្នេះហើយ ភិក្ខុទៅជាមួយគ្នា

www.budinst.gov.kh www.elibraryofcambodia.org

ឬទៅផ្សេងៗគ្នា មួយអន្លើមួន តែចូលជាមួយគ្នា ឯក្រោយបានជួប
មួយគ្នា ឬបានកន្លងទីផ្សេងៗគ្នា ដូច្នេះឈ្មោះថាគណភោជន ទាន់
គ្រប់គណៈ ផ្សេងថាយកកិរិយាចូលកន្លងទីជាមួយគ្នា ជាប្រមាណ
សូម្បីភិក្ខុកាន់យកឈ្មោះនៃ បាយ ត្រី សាច់ សូមគេដោយពាក្យថា
អ្នកចូរឲ្យ បាយ ត្រី សាច់ អំពីទីជាមួយគ្នា ឬផ្សេងៗគ្នា ហើយ
ទៅជាមួយ ឬផ្សេងគ្នា តែចូលកន្លងទីជាមួយគ្នា សូម្បីដូច្នេះក៏គង់
ឈ្មោះថាគណភោជន គណភោជនដែលបានមកអំពីទីនិមន្ត ឬ
វិញ្ញត្តិទាំងពីរនោះ កន្លងខណៈចូលព្រមគ្នាដូច្នេះ ត្រូវទុកដ ៗ ទាន់
ចូលទៅ ត្រូវបាចិត្តិយគ្រប់ៗដែលលេប វៀរតែមានសម័យ ៧ ប្រការ
ដូច្នេះគឺ គិលានសមយោ កាលភិក្ខុមានជម្ងឺ មានជើងបែកដើរបិណ្ឌ
បាតមិនបាន ១ ចីវរទានសមយោ កាលទាយកឲ្យចីវរគឺតាំងពីថ្ងៃមួយ
រោចខែអស្សុជដល់ពេញបូណ៌មីខែកត្តិក ចុងរដូវភ្លៀងមួយខែ បើបាន
ក្រាលគ្រងកឋិនហើយជា ៥ ខែ អស់ហេមន្តរដូវ ១ ចីវរការសម-
យោ កាលភិក្ខុធ្វើចីវរ គឺកាត់ដេរខ្វៀចីវរ ១ អទ្ធានគមនសមយោ
កាលដើរផ្លូវឆ្ងាយតាំងពីកន្លះយោជន៍ កាលនឹងទៅ ក៏គប្បីឆាន់បាន
ទៅតាមផ្លូវក៏គប្បីឆាន់បាន ទៅដល់ហើយក៏គប្បីឆាន់បាន តែមួយថ្ងៃ១
នាវាភិរុហនសមយោ កាលឡើងទៅកន្លងទូក គឺកាលនឹងឡើងទៅ
ក៏គប្បីឆាន់បាន ឡើងទៅហើយក៏គប្បីឆាន់បាន ចុះពីទូកក៏គប្បីឆាន់

www.budinst.gov.kh www.elibraryofcambodia.org

ក្ខុនតែមួយថ្ងៃ ១ មហាសមយោ សម័យធំ គឺក្នុងទីឯណា កាលណា ភិក្ខុ ២-៣ អង្គល្មមដើរបិណ្ឌបាតចិញ្ចឹមជីវិតបាន លុះភិក្ខុមួយអង្គមកទៀតជាគំរប់ ៤ មិនល្មមនឹងចិញ្ចឹមជីវិតបាន ១ សមណភត្តសមយោ កាលភត្តនៃសមណៈ គឺអ្នកបួសចំពួកណាមួយធ្វើភត្ត និមន្តភិក្ខុដោយ ាយ ១ មានសម័យតាំង ៧ នេះ ណាមួយ ទាល់គណភោជនបាន នត្រូវអាបត្តិ ។ ក្នុងគណភោជន ត្រូវតែកបាចិត្តិយ ។ មិនមែនគណ-ភោជន សំគាល់ថាគណភោជនក្តី ឬសង្ស័យក្តី ទាល់ត្រូវទុក្កដ ។

ឯវត្ថុដែលមិនត្រូវអាបត្តិនោះ គឺមិនមែនគណភោជន ដឹងថា នមែនគណភោជន ឬភិក្ខុ ២-៣ អង្គទទួលជាមួយគ្នាទាល់ ឬភិក្ខុ ទុំនដើរបិណ្ឌបាត ហើយមករួមជាមួយគ្នា ទាល់ជាមួយគ្នា ។ មួយ ត ក្នុងនិច្ចភត្តនិងសលាកភត្តជាដើម នឹងគ្រឿងទាល់ដទៃ ក្រៅតាក ជនតាំង ៥ នឹងភិក្ខុគិលានជាដើម តាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ អនាណត្តិកៈ មានអង្គ ៣ គឺ គណភោជនតា គណ ជន ១ សមយាភាវោ មិនមានសម័យ ១ អជ្ឈោហារណំ បបួលទៅ ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ មុដ្ឋានវត្ថុជាដើម ដូចឯក្បេរណោមសិក្ខាបទ ដូចសំដែងហើយ ក្នុង មសហសេយ្យសិក្ខាបទ ។

**គណភោជនសិក្ខាបទ គំរប់ ២ ចប់**

បរម្បរភោជនសិក្ខាបទ គំរប់ ៣ សេចក្តីថា ភិក្ខុដែលទាយកគេនិមន្ត ដោយភោជន ៥ យ៉ាង ណាមួយដោយន័យដូចសំដែងហើយ ក្នុងគណភោជន មិនវិកប្បមុន ហើយឆាន់ភោជនដែលទាយកនិមន្តក្រោយ មុនភោជនដែលទាយកនិមន្តមុន ឈ្មោះថាបរម្បរភោជន ក្នុងខណៈទទួលត្រូវទុក្កដ ៗ លេបចូលទៅត្រូវបាចិត្តិយ គ្រប់ករះដែលលេប វៀរតែមានសម័យ ៣ យ៉ាង គឺ គិលានសម័យ ១ ចីវរទានសម័យ ១ ចីវរការសម័យ ១ ដូចសំដែងមកហើយក្នុងគណភោជន បើមានសម័យទាំងអម្បាលនេះ ណាមួយឆាន់មិនត្រូវអាបត្តិ ៗ ក្នុងបរម្បរភោជន ត្រូវតែបាចិត្តិយ ៗ មិនមែនជាបរម្បរភោជន សំគាល់ថាបរម្បរភោជន ឬសង្ស័យ ហើយឆាន់ ត្រូវទុក្កដ ៗ

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺដឹងថាមិនមែនបរម្បរភោជនឆាន់មិនត្រូវអាបត្តិ វិកប្បភោជនដែលទាយកនិមន្តមុន ដល់សហធម្មិកទាំង ៥ ណាមួយមុន ក្នុងទីចំពោះមុខដូច្នេះថា មយ្ហំ ភត្តបច្ចាសំ តុយ្ហំ ទម្មិ ក្តី ឬថា មយ្ហំ ភត្តបច្ចាសំ តុយ្ហំ វិកប្បេមិ ក្តី ឬវិកប្បក្នុងទីកំបាំងមុខដូច្នេះថា មយ្ហំ ភត្តបច្ចាសំ ឥត្ថន្នាមស្ស ទម្មិ ក្តី ឬថា មយ្ហំ ភត្តបច្ចាសំ ឥត្ថន្នាមស្ស វិកប្បេមិ ដូច្នេះក្តី បទណាមួយ ហើយឆាន់ភោជនដែលបានក្នុងត្រកូលនិមន្តខាងក្រោយនោះមុន មិនត្រូវអាបត្តិ ឬឆាន់ភោជនដែលបានមុន ទាំង

www.budinst.gov.kh www.elibraryofcambodia.org

ក្រោយជាមួយគ្នាក្តី ឬធ្វើភោជនដែលគេនិមន្ត ២-៣ កន្លែងនោះ រួមបញ្ចូលជាមួយគ្នាឆាន់ក្តី ឬឆាន់តាមលំដាប់និមន្តក្តី ឬភូមិទាំងអស់ ឬពពួកមនុស្សទាំងអស់ គេនិមន្តឆាន់ក្នុងភូមិនោះ ក្នុងពពួកមនុស្សនោះ ដល់ខាងណាទីមួយមុន ឬទាយកគេនិមន្ត ភិក្ខុពោលថា យើងនឹងទទួលភិក្ខាដូច្នេះ មិនត្រូវអាបត្តិ ។ ឯក្នុងនិច្ចភត្ត នឹងសលាកភត្តជាដើម ឬក្នុងរបស់ឆាន់ដទៃ ក្រៅពីភោជនទាំង ៥ យ៉ាង នឹងភិក្ខុទុគ្គតជាដើមក្តី ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិកៈ មានអង្គ ៣ គឺ បរម្បរភោជនតា ភោជននោះ ជាបរម្បរភោជន ១ សមយាភាវោ មិនមានសម័យ ១ អជ្ឈោហារណំ ឆាន់ចូលទៅ ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចបឋមកឋិនសិក្ខាបទ ប្លែកតែសិក្ខាបទនេះជាកិរិយាកិរិយៈ ។

បរម្បរភោជនសិក្ខាបទ គំរប់ ៣ ចប់

កាណមាតាសិក្ខាបទ គំរប់ ៤ សេចក្តីថា ត្រកូលដែលគេធ្វើនំតាក់តែងទុក ដើម្បីនឹងបញ្ជូនកូនស្រីទៅកាន់ត្រកូលប្តី ឬគេតាក់តែងទុកដាក់ជាស្បៀងដើរផ្លូវ នាំមកប្រគេនតាមប្រាថ្នាដល់ភិក្ខុដែលចូលទៅបិណ្ឌ-បាត ភិក្ខុគប្បីទទួលតែ ២-៣ បាត្រ ស្មើត្រឹមកណ្តាប់មាត់បាត្រខាងក្រោម ថាបើភិក្ខុទទួលពេញបាត្រគំរប់ទាំង ៣ ឲ្យកំពុងជាកំពូលឡើងទៅ

www.budinst.gov.kh www.elibraryofcambodia.org

ត្រូវតែកបាចិត្តិយ រាប់ដោយទំទឹងសង្ឃដែលឋិតនៅលើកណ្តាប់មាត់បាត្រ ខាងក្រោម ៗ ភិក្ខុអង្គណាបានទទួលហើយពីបាត្រ ភិក្ខុអង្គនោះចេញ មក ឃើញភិក្ខុខាងក្រោយ គប្បីប្រាប់ថា ក្នុងទីនោះយើងទទួលពីបាត្រ ហើយ លោកគប្បីទទួលតែមួយបាត្រ សូម្បីភិក្ខុនោះឃើញភិក្ខុដទៃទៀត ក៏គប្បីប្រាប់ថា ភិក្ខុដែលមកមុនទទួលៈពេញពីបាត្រហើយ យើងក៏ ទទួលមួយបាត្រហើយ លោកកុំទទួលឡើយ ភិក្ខុណាទទួលមុនមួយ បាត្រហើយ សូម្បីភិក្ខុនោះក៏គប្បីប្រាប់គ្នាត ៗ ទៅដូច្នោះ ៗ ភិក្ខុណា ទទួលឯងពីបាត្រ ភិក្ខុនោះបើឃើញភិក្ខុដទៃគប្បីហាមឃាត់ បើមិនហាម ឃាត់ត្រូវទុក្កដ សូម្បីភិក្ខុបានពោលពាក្យហាមឃាត់ហើយ ទំពេសទទួលក៏ ត្រូវទុក្កដ ៗ ភិក្ខុនោះគប្បីទៅកាន់រោងឆាន់ ឬវិហារ ឬទីដែលធ្លាប់ត្រូវប៉ មកអាស្រ័យ ឯណាទីមួយ ដែលនៅជិតទីដែលបានរបស់មកនោះ ហើយដាក់លទុកដើម្បីខ្លួនមួយបាត្រ ដែលសល់ពីនោះប្រគេនដល់សង្ឃ ។ ឯនឹងឲ្យតាមមិត្រសំឡាញ់មិនបាន ។ ភិក្ខុណាទទួលមកមួយបាត្រហើយ ភិក្ខុនោះមិនប្រាថ្នា កុំគប្បីឲ្យឡើយ គប្បីធ្វើតាមចូលចិត្តចុះ ។

កាណមាតាសិក្ខាបទ គំរប់ ៦ ចប់

---

បឋមបវារណាសិក្ខាបទ គំរប់ ៧ សេចក្ដីថា ភិក្ខុណា កំពុងឆាន់ ភោជនទាំង ៥ ណាមួយ ហើយហាមឃាត់ភោជនទាំង ៥ ណាមួយ

www.budinst.gov.kh www.elibraryofcambodia.org

ដែលតាយកគេបិតនៅក្នុងហត្ថបាស ហើយបង្អោនចូលមកឲ្យ ភិក្ខុក្រោកពាក់ទាំងនោះ ហើយត្រឡប់ឆាន់ខាទនីយភោជនីយៈ ដែលជាអនតិរិត្ត គឺមិនបានធ្វើវិនយកម្ម ពឹងមិនមែនជាសំណល់នៃភិក្ខុឈឺ ក្នុងកាលថ្ងៃនោះ ត្រូវបាចិត្តិយ គ្រប់កំរៈដែលលេបៗ បវារណាមានអង្គ ៥ គឺ ៖

អសនំ បញ្ញាយតិ ភិក្ខុកំពុងឆាន់ ១ ភោជនំ បញ្ញាយតិ គេយកភោជនទាំងប្រាំ ណាមួយ មកប្រគេនទៀត ១ ហត្ថបាសេ ឋិតោ អ្នកឲ្យ នៅក្នុងហត្ថបាស ១ អភិហរតិ គេបង្អោនភោជន-មកចំពោះ ១ បដិក្ខេបោ បញ្ញាយតិ ភិក្ខុឃាត់ភោជន ១ ព្រមដោយអង្គ ៥ នេះ ទើបបានឈ្មោះថាហាមឃាត់ ឈ្មោះថាបវារណា ។

ភោជន ៥ យ៉ាង គឺបាយកើតមកអំពីធញ្ញជាតិទាំងប្រាំពីរ នំកុមាស សត្តុ ត្រី សាច់ ។ ឯធញ្ញជាតិទាំង ៧ នោះគឺ សាលិ ស្រូវស ១ វីហិ ស្រូវក្រហម ១ យវោ ស្រូវដំណើប ១ គោធុមោ ស្រូវង ១ កង្គុ ល្ពៅ ១ វរកោ ស្កួយ ១ កុទ្រូសកោ ស្មៅគែលលក ១ គេកាន់យកនៃធញ្ញជាតិទាំង ៧ នេះ ដណ្តាំជាបាយក្តី ជាបបរក្តី បើក្នុងវេលាកំពុងឆាន់ នៅក្តៅក្តី ត្រជាក់ក្តី ស្នាមដែលដួសមកនៅប្រាកដ នេះឈ្មោះថា ឱទនោ គឺបាយ ឲ្យកើតបវារណា ។ ក៏ឯបាយបាយាស ឬ យាគូ បបរលាយដោយរបស់រាវ លុះលើកចេញអំពី-ចង្ក្រាន នៅក្តៅនៅឡើយ កាចត្រូវលែងហុតបាន សូម្បីស្នាមក្នុង

ទុកាសដែលគេកាន់យកដោយដៃមិនប្រាកដ មិនឲ្យកើតបការណា ជាបើចំហាយក្តៅអស់ហើយ បបរនោះជាទន់ទោក សំដែងស្នាមបាន សោត ឲ្យកើតបការណាបានទៀត កិរិយាដែលស៊ីអំពីមុខ ក្រោមមិនបាន បើគេលាយដោយស្លឹកឈើ ផ្លែឈើ នឹងចំណាំងច្រើន ដាក់ស្មើ សម្ល មួយគ្នាប់ បើវេលាឆាន់ស្នាមប្រាកដសោត រមែងឲ្យកើតបការណា ៗ ក្នុងទិនមន្តមិនមានបបរ គេគិតនឹងប្រគេនបបរ គេយកទឹកនឹងទឹកឃ្មុំ ទឹកដោះជាដើម លាយចុះក្នុងបាយមកប្រគេនថា ចូរទទួលបបរ សម្ល ជារបស់ភាំ កំរមែងឲ្យកើតបការណាបានពិត ៗ ជាបើគេទាក់បាយចុះក្នុង ទឹកដែលពុះ ចំអិនមកប្រគេន របស់នោះសារគ្រោះថាជាបបរ បើគេ យកដុំសាច់ ដុំត្រី សម្បុចិនគ្រាប់ស្ពៃ ដាក់ចុះក្នុងបបរ រមែងឲ្យកើត បការណា ៗ បាយគេដណ្តាំដោយផ្លែចុស្ស៊ីជាដើម ឬដោយក្រមុនឈូក នឹងមើម នឹងផ្លែណាមួយ ដទៃក្រៅអំពីអន្តរនៃធញ្ញជាតិទាំង ៧ នោះ មិនឲ្យកើតបការណា ៗ នំកុមារនោះ គេធ្វើដោយធញ្ញជាតិ ៧ ប្រការជាដើម ឲ្យកើតបការណា ៗ នំកុមារនឹងបបរគេធ្វើដោយ របស់ដទៃ មានសណ្តែកបាយជាដើម មិនឲ្យកើតបការណា ៗ សម្ល នោះ គេលីងដោយធញ្ញជាតិទាំង ៧ ប្រការណាមួយ ធ្វើទៀងដោយ ហោចទៅ សម្បែកល់អង្គនឹងកន្ទក់ដែលគេបុកអន្តរនៃស្រូវដែលលីង ឲ្យក្រៀមឆ្អិន ធ្វើទៀងនោះសារគ្រោះថាជាសម្ល ឲ្យកើតបការណា ៗ

www.budinst.gov.kh www.elibraryofcambodia.org

ក៏ឯកខ្នក់ ឬអង្ករ ឬលាជនៃស្រូវដែលគេលីងឲ្យឆ្អិនមិនក្រៀម ឬឆ្អិន
ដោយកំដៅព្រះអាទិត្យ ឬបាយនិងសត្តុវជាដើម ដែលគេធ្វើដោយ
អង្ករនិងលាជនោះ មិនឲ្យកើតបវារណា ។ ក្នុងមំសៈ គឺសាច់ និងត្រី
នោះ កាលបើភិក្ខុកំពុងឆាន់យាគូ ហើយគេប្រគេនដុំសាច់ ឬដុំត្រី
សូម្បីប៉ុនគ្រាប់ស្ពៃដាក់ចុះក្នុងភាជនៈ ១ ឬផ្សេង ៗ នោះ បើភិក្ខុមិន
បានឆាន់ត្រីសាច់ទេ ហើយឃាត់របស់ដទៃណាមួយ ដែលល្មមឲ្យ
កើតបវារណានោះ មិនឈ្មោះថាឃាត់ តែដុំសាច់ ដុំត្រីនោះ ភិក្ខុ
ទំពាឆាន់ ១ ដុំ នៅក្នុងដៃ ឬក្នុងបាត្រ ១ ដុំ បើភិក្ខុឃាត់សាច់ត្រីដទៃ
នោះ ឈ្មោះថាឃាត់ទាំង ២ ដុំ ។ ភិក្ខុទំពាឆាន់ហើយក្នុងមាត់ សូម្បី
នៅសល់ប៉ុនគ្រាប់ស្ពៃ មិនមាន ថាបើឃាត់សាច់និងត្រីដទៃនោះ
មិនឈ្មោះថាឃាត់ ។ ភិក្ខុណាឆាន់របស់ឆាន់ជាកប្បិយ ឬអកប្បិយដទៃ
ឃាត់អកប្បិយមំសៈ និងអកប្បិយភោជន ដែលកើតអំពីកុលទូសកៈ
វេជ្ជកម្ម និងកើតអំពីអួតឧត្តរិមនុស្សធម្ម និងគ្រឿងអកប្បិយជាដើម ភិក្ខុ
នោះមិនឈ្មោះថាឃាត់ ព្រោះជារបស់មិនគួរបរិភោគ ។ បាយសូម្បី
១គ្រាប់ ភិក្ខុណាឆាន់ទៅហើយ ភោជនក្នុងបាត្រនិងមាត់ និងដៃណាមួយ
មាននៅ បើភិក្ខុនោះមានអាល័យនៅឡើយ ហើយឃាត់នូវភោជនដទៃ
មានលក្ខណៈដូចសំដែងហើយនោះ ឈ្មោះថាឃាត់ ។ បើភិក្ខុមិនមាន
អាល័យ គឺគ្រូណាដែលសល់នៅក្នុងបាត្រជាដើម តែនោះភិក្ខុមិនប្រាថ្នា

www.budinst.gov.kh www.elibraryofcambodia.org

ខឹងចាប់ ឬប្រាប់ថាខឹងឲ្យអ្នកដទៃ ឬប្រាប់ថាខឹងទៅចាប់ក្នុងចិត្តដទៃ ក៏ត្រូវ នោះសូម្បីឃាត់ ក៏មិនឈ្មោះថាឃាត់ ។

ខឹងសំដែងដោយហត្ថបាស បើភិក្ខុអង្គុយ កំណត់អំពីចុងបំផុតខាងក្រោយ បើឈរកំណត់អំពីចុងបំផុតខាងកែង បើដេកផ្អៀងខាងណា កំណត់អំពីចុងបំផុតខ្លួនខាងនោះ ទៅដល់ចំណែកចុងបំផុតអវយវៈដែលជិតនៃអ្នកឲ្យ ដែលអង្គុយ ឬឈរ ឬដេក វៀរតែដៃដែលគេលូកហុចមកខឹងឲ្យ ឲ្យបាន ២ ហត្ថ ១ ចំអាម ឈ្មោះថាហត្ថបាស ។ គេឈរនៅក្នុងហត្ថបាស ហើយបង្អោនចូលមក ហាមឃាត់ទើបជាបវារណា ។ បើផុតហត្ថបាសនោះចេញទៅ ហើយហាម មិនជាបវារណា ។

ខឹងសំដែងដោយការបង្អោនរបស់ចូលមក បើភិក្ខុអង្គុយនៅជាលំដាប់គ្នា មិនបង្អោនបាត្រដែលនៅក្នុងដៃ ឬនៅលើជើង គ្រាន់តែប្រាប់ថា "អ្នកចូរកាន់យកបាយជូនលោះសោត" បើភិក្ខុហាម មិនជាបវារណា សូម្បីក្នុងវេលាដែលគេលើកកញ្ជើបាយចូលមកដាក់លើទុកលើផ្ទៃខាងមុខ ហើយប្រាប់ជូនលោះក៏ដូចគ្នា កាលគេលើកឡើង ឬបង្អោនចូលមកបន្តិច ហើយគេពោលថា "លោកចូរទទួល" កាលបើឃាត់ ទើបជាបវារណា ម្នាក់កាន់កញ្ជើបាយអង្គាស អ្នកដទៃថាខឹងជួយពេក ហើយគ្រាន់តែប៉ុណ្ណោះ អ្នកអង្គាសនោះឯង លើកកញ្ជើបាយនោះទុក ព្រោះ...

នោះ វត្ថុនោះឈ្មោះថា គ្រាន់តែបង្អោនចូលមកប៉ុណ្ណោះ កាលបើហាមអ្នកកាន់កញ្ជើដែលបំរុងនឹងឲ្យអំពីកញ្ជើនោះ ជាបករណា ៗ ថាបើអ្នកអង្គាសគ្រាន់តែពាល់កញ្ជើនោះប៉ុណ្ណោះ មានអ្នកដទៃលើកកញ្ជើនោះ ៗ កាលបើឃាត់អ្នកកាន់យកដែលប្រាថ្នានឹងឲ្យអំពីកញ្ជើនោះ មិនជាបក-រណា ៗ លុះតែជួសដោយវែកទៀនហើយភិក្ខុឃាត់ ទើបជាបករណា ៗ សូម្បីមនុស្សលើក ២ នាក់ លើកទៀនស្មើគ្នា កាលដែលឃាត់នោះ គឺជាបករណាពិត ៗ បើគេប្រគេនភិក្ខុអង្គុយជាលំដាប់ ហើយភិក្ខុក្រៅនោះ ជួយបិទបាត្រ ឈ្មោះថាឃាត់របស់ដែលគេបង្អោនដល់អ្នកដទៃ ព្រោះហេតុនោះ មិនជាបករណា ៗ

នឹងពោលអំពីរឿងហាមឃាត់ ៗ ក្នុងរបស់ដែលគេបង្អោនចូលមកដោយកាយ ហាមមិនទៀង ៗ របស់គេបង្អោនចូលមកដោយកាយ លុះតែហាមដោយកាយវិការ មានពដៃជាដើម ឬដោយវចីវិការជាដើមថា ល្មមហើយ កុំឲ្យទៀយ ដូច្នេះ ទើបជាបករណា ៗ មនុស្សម្នាក់បង្អោនសម្លលាយដោយសាច់ចូលមកថា លោកចូរទទួលសម្ល ភិក្ខុបានឮ ហាមអ្នកនោះ នេះមិនជាបករណា ៗ បើគេពោលថា លោកចូរទទួលសម្លសាច់ ភិក្ខុហាម ទើបជាបករណា ៗ បើគេពោលថាចូរទទួលរបស់នេះ ភិក្ខុឃាត់ គឺគង់ជាបករណា ៗ សូម្បីគេធ្វើសាច់ឲ្យផ្សេងគ្នាហើយពោលថា ចូរទទួលសម្លសាច់ ថាបើដុំសាច់ចុះក្រោមស្ពៃមាននៅ

www.budinst.gov.kh www.elibraryofcambodia.org

សោត កាលយកទៅរបស់នោះចេញ រមែងជាបក់រណា ៗ បើមិនមានក៏គួរ ៗ បាយ សម្ល ត្រី សាច់ លាយដោយខ្ទរនឹងទំពាំងជាដើម ហើយគេកាន់យកមកពោលថា ព្រះករុណាចូរទទួលសម្លខ្ទរ សម្លទំពាំង សូប្បី ដូច្នេះ ទោះនឹងហាម ក៏មិនឈ្មោះថាហាម ព្រោះគេពោលឈ្មោះរបស់ដែលមិនគួរឲ្យកើតបក់រណា ៗ បើគេពោលថា លោកចូរទទួលសម្លត្រី សម្លសាច់ ឬថាចូរទទួលរបស់នេះ ទើបឲ្យកើតបក់រណា ៗ ក្នុងឥរិយាបថទាំង ៤ គឺ ដេក ដើរ ឈរ អង្គុយ នេះ ភិក្ខុឃាត់ក្នុងឥរិយាបថណា កុំញ៉ាំងឥរិយាបថនោះឲ្យកំរើក គប្បីឆាន់ចុះ មិនមានទោស ៗ របស់ឆាន់ដែលមិនបានធ្វើវិនយកម្មដោយអាការៈ ៧ ប្រការនឹងមិនមែនជាសំណល់ភិក្ខុឈឺ ឈ្មោះថាអនតិរិត្តៈ ឆាន់មិនបាន ៗ របស់ដែលធ្វើវិនយកម្មហើយ នឹងរបស់ជាសំណល់ភិក្ខុឈឺ ឈ្មោះអតិរិត្តៈ គួរឆាន់បាន ៗ

អាការនៃវិនយកម្មមាន ៧ យ៉ាង ដូច្នេះ គឺ កប្បិយកតំ ហោតិ របស់ដែលគេធ្វើឲ្យជាវត្ថុគួរ ១ បដិគ្គហិតកតំ ហោតិ របស់ដែលភិក្ខុបានទទួលហើយធ្វើឲ្យជារបស់គួរ ១ ឧច្ចារិតកតំ ហោតិ របស់ដែលភិក្ខុលើកឡើង ឬ បានបង្អោនទៅជិតដើម្បីធ្វើឲ្យជារបស់គួរ ១ ហត្ថបាសេ កតំ ហោតិ ភិក្ខុនៅក្នុងហត្ថបាសហើយធ្វើ ១ ភុត្តាវិនា កតំ ហោតិ ភិក្ខុឆាន់រួចហើយទើបធ្វើ ១

www.budinst.gov.kh www.elibraryofcambodia.org

កុត្តាវិជា បករិភោគ អាសជា អវុដ្ឋិភោគ កតំ ហោតិ របស់ដែលភិក្ខុឆាន់ហើយ ហាមភោជនះហើយ មិនទាន់ក្រោកចាកអាសនៈ ហើយធ្វើ ១ អលមេតំ សព្វន្តិ វុត្តំ ហោតិ របស់ដែលភិក្ខុពោលថា របស់ទាំងអស់នេះគួរហើយ ១ ។ លុះរបស់នោះធ្វើឲ្យជាកប្បិយៈហើយដោយអាការនៃវិនយកម្ម ៧ យ៉ាងដូច្នេះ កាលភិក្ខុកំពុងឆាន់ បើគេយកអាមិសផ្សេងមកថែមទៀត ភិក្ខុនោះនឹងធ្វើកប្បិយរបស់នោះទៀតមិនបាន ផ្សិតលោកៈពោលទុកថា វត្ថុណាមិនបានធ្វើកប្បិយ កប្បិធ្វើវត្ថុនោះ ភិក្ខុណាមិនបានធ្វើ ភិក្ខុនោះគប្បីធ្វើ ព្រោះហេតុដូច្នោះ របស់ដែលដាក់ចុះក្នុងភាជនៈនៃរបស់ដែលកប្បិយៈហើយពីមុននោះ នឹងកប្បិយរបស់នោះមិនគួរ គឺឯភិក្ខុនោះឬភិក្ខុដទៃនឹងធ្វើក្នុងភាជនៈដទៃទើបគួរ ធ្វើហើយដូច្នេះនឹងលាយដោយរបស់ដែលធ្វើអំពីមុន ឆាន់ក៏គួរ នឹងគួរដល់ភិក្ខុមួយអង្គនោះក៏ទេ សូម្បីភិក្ខុដទៃ ដែលហាមបាយហើយ បើតែភិក្ខុធ្វើវិនយកម្មឲ្យ នឹងឆាន់ក៏គួរ តែនឹងមិនលាយដោយរបស់ដែលមិនបានធ្វើកប្បិយយ៉ាងណា គប្បីធ្វើមាត់នឹងដៃឲ្យស្អាតយ៉ាងនោះហើយឆាន់ចុះ ។

ក្នុងអដ្ឋកថា ពោលថា របស់ដែលជាសំណល់ភិក្ខុឈឺនោះ មិនមែនតែរបស់ដែលភិក្ខុឈឺឆាន់សល់មួយចំពូកប៉ុណ្ណោះទេ សូម្បីវត្ថុណាមួយដែលគេចំពោះភិក្ខុឈឺ ហើយនាំមកទុកថា បើភិក្ខុចង់ឆាន់ថ្ងៃនេះ

www.budinst.gov.kh www.elibraryofcambodia.org

ឬកាលណាខ្លួនបានឆាន់កាលនោះ របស់ទាំងអស់នោះក៏ឈ្មោះថា ជ
សំណល់នៃភិក្ខុឈឺ ពាក្យដែលពោលនោះដូរណាស់ ។

ភិក្ខុហាមបាយហើយដោយន័យដូចពោលមក ឲ្យឥរិយាបថកំរើ ហើយ ទទួលអាមិសណាមួយដែលជាអនតិរិត្តៈដើម្បីនឹងឆាន់ ត្រូវទុក្កដ ព្រោះទទួល ៗ លេបចូលទៅត្រូវបាចិត្តិយគ្រប់ករៈដែលលេប ៗ ក្នុ អាមិសជាអនតិរិត្តៈត្រូវតែកបាចិត្តិយ ។ ទទួលយាមកាលិកជាដើម ដើម្ អាហារឆាន់ប្រាសចាកអាមិស ដើម្បីអាហារ ឬអាមិសជាអតិរិត្ត សំគាល់ថាជាអនតិរិត្តៈ ឬសង្ស័យហើយឆាន់ ទាំងអម្បាលនេះ ត្រូវ ទុក្កដទាំងអស់ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺទទួលអាមិសជាអនតិរិត្តៈ ដោយ គិតថានឹងឲ្យភិក្ខុដទៃធ្វើកប្បិយឲ្យ ហើយឆាន់ នឹងទទួលដើម្បីអ្នកដទៃ នឹង ឆាន់យាមកាលិក សត្តាហកាលិក យាវជីវិក ប្រាសចាកអាមិស ដោយវិធី បរិភោគដែលព្រះពុទ្ធអង្គទ្រង់អនុញ្ញាត ខ្លួនភិក្ខុឈឺជាដើម ទាំងអម្បាល នេះ ជាអនាបត្តិ ជាអនាណត្តិកៈ មិនត្រូវព្រោះបង្គាប់ ៗ មានអង្គ ៣ គឺ បវារិតភាវោ ភិក្ខុហាមឃាត់បាយហើយក្រោកចាកអាសនៈ ១ អាមិ- សស្ស អនតិរិត្តតា អាមិសមិនបានធ្វើវិនយកម្មឲ្យជាអតិរិត្តៈ ១ កាលេ អជ្ឈោហរណំ ឆាន់ក្នុងកាល ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ៗ សមុដ្ឋានវិធីជាដើម ដូចបឋមកឋិនសិក្ខាបទ ថ្ង

www.budinst.gov.kh www.elibraryofcambodia.org

នៃសិក្ខាបទនេះ ជាកិរិយាកិរិយៈ ត្រូវព្រោះធ្វើ និងមិនធ្វើ គឺភិក្ខុធ្វើនូវការហាមឃាត់ភោជនហើយ ឆាន់នូវអនតិរិត្តភោជន ដែលខ្លួនមិនបានធ្វើឲ្យជាអតិរិត្តភោជន ។

បឋមបវារណាសិក្ខាបទ គំរប់ ៥ ចប់

---

ទុតិយបវារណាសិក្ខាបទ គំរប់ ៦ សេចក្តីថា ភិក្ខុណា ដឹងថាភិក្ខុដទៃហាមឃាត់បាយហើយ ដូចសិក្ខាបទមុន ហើយយកអាមិសរបស់ឆាន់ដែលជាអនតិរិត្តៈ មិនបានធ្វើកប្បិយមកបង្ខំឬអង្វរ ឲ្យភិក្ខុដទៃឆាន់ ដោយប្រាថ្នានឹងចោទលើកទោស ដើម្បីនឹងឲ្យអៀនអន់ ។ កាលបង្អោនចូលទៅ ឬកាលភិក្ខុនោះទទួលនឹងឆាន់ ត្រូវទុក្កដដល់ភិក្ខុអ្នកបង្អោនចូលទៅ ។ ភិក្ខុនោះឆាន់ ក៏ត្រូវអាបត្តិទុក្កដដល់ភិក្ខុអ្នកបង្អោនចូលទៅ គ្រប់វារៈនៃភិក្ខុនោះលេបចូលទៅ ។ ភិក្ខុនោះឆាន់ហើយ អ្នកបង្អោនចូលទៅត្រូវបាចិត្តិយ ។ ភិក្ខុអ្នកហាមឃាត់បាយហើយ ដឹងថា ភិក្ខុនោះហាម-ឃាត់បាយហើយ ត្រូវបាចិត្តិយ ។ សង្ស័យត្រូវទុក្កដ ។ កាលបង្អោនយាមកាលិកចូលទៅ ដើម្បីជាអាហារត្ថ លុះភិក្ខុទទួលនឹងឆាន់នូវយាមកាលិកជាដើមក្តី ភិក្ខុមិនឃាត់បាយ សំគាល់ថាហាមឃាត់ក្តី បង្ស័យក្តី ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺឲ្យធ្វើជាអតិរិត្តៈ ឬឲ្យដោយពាក្យថា លោកចូរឲ្យគេធ្វើជាអតិរិត្តៈហើយសឹមឆាន់ ឬយកទៅឲ្យអ្នកដទៃក្តី

www.budinst.gov.kh www.elibraryofcambodia.org

ឬឲ្យយាមកាលិកជាដើមថា កាលមានហេតុហើយចូរឆាន់ចុះ ទឹងភិក្ខុគេ ជាដើម តាំងអម្បាលនេះ មិនត្រូវអាបត្តិ ជាអនាណត្តិកៈ មានអង្គ ៤ គឺ បវារិតតា ភិក្ខុហាមឃាត់បាយហើយ ១ បវារិតសញ្ញិតា ដឹងថាភិក្ខុនោះ ហាមឃាត់បាយហើយ ១ អាសាទនាបេក្ខតា សំឡឹងកនូវកិរិយាលើកទោស ១ អនតិរិត្តេន អភិហដ្ឋុំ បវារណាតា យករបស់ដែលជាអនតិរិត្តៈបង្អោនចូលទៅឲ្យ ១ ភោជនបរិយោសានំ ភិក្ខុនោះឆាន់ហើយ ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានដៃជាដើម ដូចអទ្ធានសិក្ខាបទ វិប្បកតែសិក្ខាបទនេះ ជាទុក្ខវេទនា ។

ទុតិយបវារណាសិក្ខាបទ តំរប់ ៦ ចប់

---

វិកាលភោជនសិក្ខាបទ តំរប់ ៧ សេចក្ដីថា ក្នុងវេលាវិកាល គឺតាំងអំពីព្រះអាទិត្យជ្រេពីត្រង់ទៅដរាបអរុណថ្មីរះឡើងមក ។ ខាទនីយៈដែលជាអាមិសណាមួយ តាំងអំពីឫសឈើ ផ្លែឈើឡើងទៅ ឬរបស់ឆាន់គឺភោជនៈតាំង ៥ ។ ភិក្ខុទទួលដើម្បីឆាន់ ត្រូវទុក្កដ ព្រោះទទួល ។ លេបចូលទៅត្រូវបាចិត្តិយគ្រប់ករៈដែលលេប ។ ក្នុងវេលាវិកាលត្រូវតិកបាចិត្តិយៈ ទទួលយាមកាលិកជាដើម ដើម្បីជាអាហារ ឬឆាន់ដើម្បីជាអាហារ ក្នុងវិកាល ឬក្នុងកាលគឺអំពីព្រឹកដល់ថ្ងៃត្រង់ សំគាល់ថាវិកាល ឬសង្ស័យ តាំងអស់នេះ ត្រូវទុក្កដ ។

www.budinst.gov.kh www.elibraryofcambodia.org

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺក្នុងកាលដ៏នឹងជាកាល បរិភោគមិនត្រូវអាបត្តិ កាលបើមានហេតុឆាន់យាមកាលិកជាដើមក្នុងវិកាលបាន ខនិកកុក្កុជជាដើម ទាំងអម្បាលនេះ ជាអនាបត្តិ សូម្បីភិក្ខុជាអ្នកច្រើនកើ ច្រើនរើកាហារចេញមកដល់បំពង់ក ហើយត្រឡប់ចូលទៅវិញ ក៏មិនត្រូវអាបត្តិ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកក្នុងខន្ធកៈ ជាអនាណត្តិកៈ មានអង្គ ៣ គឺ វិកាលតា ឈ្មោះវិកាល ១ យាវកាលិកតា របស់ឆាន់ជាយាវកាលិក ១ អជ្ឈោហរណំ លេបចូលទៅ ១ ព្រមដោយអង្គៈ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចឯឡក-លោមសិក្ខាបទ ដែលសំដែងហើយក្នុងបឋមសហសេយ្យសិក្ខាបទ ។

វិកាលភោជនសិក្ខាបទ គំរប់ ៧ ចប់

---

សន្និធិការកសិក្ខាបទ គំរប់ ៨ សេចក្តីថា របស់ឆាន់ដែលជាយាវកា-លិកណាមួយ ភិក្ខុទទួលប្រគេនទុកឲ្យកន្លងមួយរាត្រី ឈ្មោះថា សន្និធិ ។ ទទួលរបស់សន្និធិនោះ ដើម្បីនឹងឆាន់ ត្រូវទុក្កដ ព្រោះទទួល ។ លេបចូលទៅត្រូវបាចិត្តិយគ្រប់ក្រៈដែលលេប ។ សូម្បីបើបាត្រលាងមិនស្អាត លុះជូតដោយម្រាមដៃ ស្នាមនៅប្រាកដ ឬជ័រហាយចូលទៅក្នុងម្នុខបន្ទាបបាត្រ ជ័រហាយនោះ លុះយកបាត្រហាលក្នុងទីក្តៅ ឬទទួលបបរដែលក្តៅ ញើសហូរចេញមក សូម្បីភិក្ខុឆាន់ក្នុងបាត្រដូច្នោះ

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងថ្ងៃត្រង់តទៅទៀត ត្រូវបាចិត្តិយ ។ របស់ណាដែលភិក្ខុលះបង់ សាមណេរដាច់មិនមានអាល័យ ហើយសាមណេរទុកដាក់ ភិក្ខុនោះ បានរបស់នោះមកឆាន់ក៏គួរ ។ ក្នុងអាមិសជាសន្និធិ ត្រូវកិកបាចិត្តិយ ៗ ទទួលយាវកាលិកនឹងយាមកាលិក ណាមួយដែលជាសន្និធិ ដើម្បីឆាន់ក្តី ឬក្នុងអាមិស ដែលមិនជាសន្និធិ សំគាល់ថាជាសន្និធិ ឬសង្ស័យក្តី ទាំងអម្បាលនេះ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺដឹងថាមិនជាសន្និធិ ជាអនាបត្តិ ទុកយាវកាលិក យាមកាលិក សត្តាហកាលិក មិនឲ្យកន្លងកាល ក៏ក្តី ក៏ឆាន់តាមកាល មួយទៀត សូម្បីកាលមានហេតុហើយឆាន់យាវជីវិកក្តី នឹងភិក្ខុឆ្កួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិកៈ មានអង្គ ៣ គឺ អាមិសំ អាមិសជាយាវកាលិក ១ សន្និធិការកំ អាមិសនោះទទួលប្រគេនទុកទៅជាសន្និធិ ១ តស្ស អជ្ឈោហរណំ ឆាន់របស់នោះចូលទៅ ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចឯឡកលោមសិក្ខាបទ ដែលសំដែងហើយក្នុង បឋមសហសេយ្យសិក្ខាបទ ។

សន្និធិការកសិក្ខាបទ គំរប់ ៨ ចប់

---

បណីតភោជនសិក្ខាបទ គំរប់ ៩ សេចក្តីថា បាយដែលគេតក់តែង ឆ្ងាញ់ជាតិទាំង ៧ លាយដោយរបស់ឧត្តម ៩ ប្រការគឺ សប្បិ [illegible]

ប្រេង ទឹកឃ្មុំ ទឹកអំពៅ ត្រី សាច់ ទឹកដោះស្រស់ ទឹកដោះជូរ ណាមួយឈ្មោះថាបណីតភោជនៈ ។ ភិក្ខុណាមិនមានជម្ងឺ សូមបណីត-ភោជនៈ អំពីមនុស្សមិនមែនញាតិ មិនមែនបវារណា ដោយពាក្យជាដើមថា អ្នកចូរឲ្យបាយលាយសប្បិផង ឬថាអ្នកចូរឲ្យបាយលាយត្រីផង ដូច្នេះត្រូវអាបត្តិទុក្កដ ព្រោះវិញ្ញត្តិមុនអំពីបានមក ។ ទទួលនឹងឆាន់ ត្រូវទុក្កដព្រោះទទួល ។ លេបចូលទៅត្រូវបាចិត្តិយគ្រប់វារៈដែលលេប ។ សូមបានមកឆាន់ទាំង ៩ ត្រូវបាចិត្តិយទាំង ៩ ។ ភិក្ខុណាមិនមានជម្ងឺ សូមសប្បិ នវនីត ប្រេង ទឹកឃ្មុំ ទឹកអំពៅសុទ្ធ មិនលាយដោយបាយ ដើម្បីភេសជ្ជៈ គប្បីកាត់អាបត្តិបាចិត្តិយដល់ភិក្ខុនោះ ដោយមហានាម-សិក្ខាបទ ។ សូមត្រីជាដើម ៤ ប្រការសុទ្ធ មិនលាយ គប្បីកាត់អាបត្តិទុក្កដ ដោយសូបោទនវិញ្ញត្តិក្នុងសេខិយៈ ។ សូមភោជនលាយដោយសប្បិ ជាដើម គប្បីកាត់បាចិត្តិយដោយសិក្ខាបទនេះ ។ សូមបាយនឹងត្រីផង គេឲ្យបាយនឹងសាច់ ខុសសង្កេត មិនត្រូវអាបត្តិ ដោយសិក្ខាបទនេះ ។ មិនមានជម្ងឺ ត្រូវតិកបាចិត្តិយ ។ មានជម្ងឺ សំគាល់ថាមិនមានជម្ងឺ ឬសង្ស័យ សុំមកឆាន់ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺដឹងថាមានជម្ងឺជាអនាបត្តិ សូមក្នុងសម័យដែលមានជម្ងឺជា ហើយឆាន់ ឬឆាន់របស់សំណល់ភិក្ខុឈឺ ឬសូមអំពីមនុស្សជាញាតិ ជាបវារណា ឬសូមដើម្បីអ្នកដទៃ ឬដូរយកដោយ

www.budinst.gov.kh www.elibraryofcambodia.org

ទ្រព្យរបស់ខ្លួន នឹងកិច្ចធុរជាដើម តាំងអម្បាលនេះមិនត្រូវអាបត្តិ ។ ជាអនាណត្តិកៈ មានអង្គ ៤ គឺ បណីតភោជនតា បណីតភោជន ១ អគិលានតា មិនមានជម្ងឺ ១ អត្តវិញ្ញត្តិយា បដិលាភោ បានមកដោយវិញ្ញត្តិ ១ អជ្ឈោហារណំ ឆាន់ចូលទៅ ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវបាចិត្តិយ ៗ ជាអទ្ធានសមុដ្ឋាន អាបត្តិកើតអំពីកាយ អំពីកាយវាចា អំពីកាយចិត្ត អំពីកាយវាចាចិត្ត ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ។

បណីតភោជនសិក្ខាបទ គំរប់ ៩ ចប់

ទន្តបោណសិក្ខាបទ គំរប់ ១០ សេចក្តីថា របស់ឯណាគប្បីឆាន់តាំងពីអនុបសម្បន្នមិនបានទៅក្នុងហត្ថបាស ហើយឲ្យដោយកាយ ឬរបស់ជាប់ដោយកាយ ឬបោះឲ្យដល់ភិក្ខុផែលទទួលដោយកាយ ឬរបស់ជាប់ដោយកាយ របស់នោះឈ្មោះថា គេមិនបានប្រគេន ៗ ភិក្ខុណាកាន់យកឯងនូវរបស់ដែលមិនបានប្រគេនដូច្នោះ សូម្បីជារបស់ល្អិតដូចធូលី ដើម្បីនឹងឆាន់ត្រូវទុក្កដព្រោះទទួល ៗ ឆាន់ឲ្យកន្លងបំពង់កចូលទៅដោយមុខទ្វារ ឬឃានទ្វារ ត្រូវបាចិត្តិយ វៀរតែទឹកនឹងឈើស្ទន់ ៗ ទឹកមិនបាច់ប្រគេនឆាន់បានតាមសប្បាយ ឈើស្ទន់មិនបាច់ប្រគេន ព្រោះជារបស់មិនកន្លងបំពង់ក ថាបើកន្លងបំពង់កចូលទៅ សូម្បីមិនដឹងក៏ត្រូវអាបត្តិ

www.budinst.gov.kh www.elibraryofcambodia.org

បាចិត្តិយ ។ ក្នុងរបស់ដែលមិនបានទទួលប្រគេន ត្រូវតិកបាចិត្តិយ ។ ក្នុងរបស់ដែលទទួលប្រគេនហើយ សំគាល់ថាមិនបានទទួលប្រគេន ឬសង្ស័យ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺដឹងថាទទួលប្រគេនហើយឲ្យកន្លងបំពង់ក មិនត្រូវអាបត្តិ ។ ទឹកនិងឈើស្ទន់ប្រើមិនឲ្យកន្លងបំពង់ក និងថ្នាំមហាវិកតៈ ៤ ប្រការគឺ មូត្រ លាមក ផេះ ដី កាលមានហេតុគឺពស់ចឹក កប្បិយការកៈមិនមាន កាន់យកមកដោយខ្លួនឯងក្តី និងកិច្ចគជាដើម តាំងគម្យាលនេះ មិនត្រូវអាបត្តិ សូម្បីកប្បិយការកៈមាន តែជាមនុស្ស ប្រើលំបាក ឬមិនអាចនឹងធ្វើបាន ក៏កប់ចូលក្នុងចំណែកថាមិនមាន ។ កាលបើផេះមិនមាន កិច្ចនឹងដុតឈើស្ងួត ឬឈើស្ងួតមិនមាន សូម្បីនឹងកាប់កាច់ឈើស្រស់អំពីដើមឈើមកដុតធ្វើជាផេះក៏គួរ សូម្បីនឹងជីកផែនដី ដោយត្រូវការដីក៏គួរ ក៏ឯថ្នាំមហាវិកតៈទាំង ៤ នេះឈ្មោះថា កាលោធិស្ស ចំពោះកាលពស់ចឹក ក្នុងខណៈពស់ចឹកមួយយ៉ាងប៉ុណ្ណោះ នឹងកាន់យកដោយខ្លួនឯងក៏គួរ ក្នុងកាលដទៃគប្បីទទួលប្រគេនទាន់ ជាអនាបត្តិកៈ មិនត្រូវព្រោះបង្គាប់ មានអង្គ ៤ គឺ អប្បដិគ្គហិតកតា របស់មិនបានទទួលប្រគេន ១ អននុញ្ញាតកតា របស់នោះមិនមែនព្រះពុទ្ធអង្គអនុញ្ញាត ១ ធូរាធំអជ្ឈោហារកាលកោ របស់នោះមិនមែនជាអជ្ឈោហារិកដូចផ្សេងក្រុងជាដើម ១ អជ្ឈោហរណំ

លេបចូលទៅក្នុងបំពង់ក ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវអាបត្តិ បាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចឯឡកលោមសិក្ខាបទ ដែលពោលហើយក្នុងបឋមសហសេយ្យ ។

ទន្តពោនសិក្ខាបទ គំរប់ ១០ ចប់

---

ភោជនវគ្គ គំរប់ ៤ ចប់

---

អចេលកវគ្គ គំរប់ ៥ មាន ១០ សិក្ខាបទ ។

អចេលកសិក្ខាបទ ជាបឋម សេចក្តីថា ភិក្ខុឲ្យខាទនីយៈ ឬភោជនី-យាហារ ដែលជាអាមិសណាមួយដោយដៃខ្លួនឯង ដល់តិត្ថិយទាំងឡាយ មានអចេលកៈ អ្នកបួសអាក្រាតកាយ និងបរិព្វាជកនិងនាងបរិព្វាជិកា ជាដើម ដែលជាអ្នកបួសក្រៅព្រះពុទ្ធសាសនា មិនមែនសហធម្មិកទាំង ៥ អ្នកទាំងអម្បាលនេះណាមួយ ត្រូវបាចិត្តិយ រាប់តាមប្រយោគដែលឲ្យ ។

អចេលកសិក្ខាបទ ជាបឋម ចប់

---

ឧយ្យោជនសិក្ខាបទ គំរប់ ២ សេចក្តីថា ភិក្ខុបបួលភិក្ខុដទៃគ្នាទៅបិណ្ឌបាត ក្នុងស្រុក និគម ហើយនឹងឲ្យគេឲ្យអាមិសដល់ភិក្ខុនោះក្តី មិនឲ្យគេឲ្យក្តី ភិក្ខុប្រាថ្នានឹងដំបូចសេចលេង ឬនឹងអង្គុយក្នុងទីកំបាំងជាមួយមាតុគ្រាម ឬនឹងប្រព្រឹត្តអនាចារណាមួយ ហើយ

www.budinst.gov.kh www.elibraryofcambodia.org

បណ្ដេញភិក្ខុនោះចេញ ត្រូវទុក្កដ ។ ភិក្ខុនោះកន្លងឧបចារៈដោយជំហាន ជាបឋម អ្នកបណ្ដេញត្រូវទុក្កដ ។ កន្លងជំហានជាគំរប់ ២ អ្នកបណ្ដេញ ត្រូវបាចិត្តិយ ។ ក្នុងការសង្កេត ប្រមាណទស្សនូបចារៈ ១២ ហត្ថ សវនូបចារៈក៏ ១២ ហត្ថដូចគ្នា ។ បើជញ្ជាំង ឬទ្វារ ឬកំផែង បាំង ការកន្លង ទីបាំង ដោយរបស់បាំងអម្បាលនោះឯង ឈ្មោះថាកន្លងឧបចារៈ ។ ក្នុងឧបសម្បន្ន ត្រូវតែបាចិត្តិយ ។ ក្នុងអនុបសម្បន្ន ត្រូវតែទុក្កដ ។ ពោលគលិសាសនៈ(១) ប្រាប់ដល់ឧបសម្បន្ន នឹងអនុបសម្បន្ន ទាំង-ពីរថា អ្នកទាំងឡាយមកមើលចុះ មនុស្សនេះឈរដូចដង្គក់ អង្គុយដូចក្អែក នឹងក្រឡេកដូចពានរ ដូច្នេះ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺបណ្ដេញឲ្យទៅដោយហេតុដ៏សមគួរជាដើមថា ពីរអង្គនៅក្នុងដំបន់ជាមួយគ្នា នឹងមិនល្មមចិញ្ចឹមជីវិត ឬឃើញរបស់ល្អមានតម្លៃ ឬឃើញស្ត្រីនឹងកើតលោភចេតនា នឹងសេចក្ដីអផ្សុក ឬឲ្យយករបស់ទៅឲ្យមនុស្សមានជម្ងឺជាដើម ឬមិនប្រាថ្នាប្រព្រឹត្តអនាចារ បញ្ជូនក្រឡប់ទៅដោយកិច្ច នឹងកិច្ចធ្ងន់ជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ជាសាណត្តិកៈ ត្រូវព្រោះបង្គាប់ គឺបណ្ដេញដោយខ្លួនឯង ឬឲ្យអ្នកដទៃបណ្ដេញ មានអង្គ ៣ គឺ អនាចារំ អាចរិតុកា-មតា ប្រាថ្នានឹងប្រព្រឹត្តអនាចារ ១ គណុត្តមនៅ ឧបសម្បន្នស្ស

១ ពាក្យបញ្ជូលចិត្ត ។

ឧយ្យោជនតា បណ្ដាញឧបសម្បន្ន ដើម្បីប្រយោជន៍នោះ ១ ឧ
ឧយ្យោជេន្តស្ស ឧបចារាតិក្កមោ អ្នកត្រូវបណ្ដាញកន្ល
ឧបចារៈ ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋាន
ជាដើម ដូចអទិន្នាទានសិក្ខាបទ ។

ឧយ្យោជនសិក្ខាបទ គំរប់ ២ ចប់

---

សភោជនសិក្ខាបទ គំរប់ ៣ សេចក្ដីថា ក្នុងត្រកូលណា ប្ដីប្រពន្ធ មិនមែនព្រះអនាគាមី ជាអ្នកនឿយណាយ ចាកសេចក្ដីរេកត្រេកអ ហើយចូលទៅនៅក្នុងផ្ទះជាទីដំណេក ដែលគេមិនទាន់ចេញមកក្រៅ បើផ្ទះធំ ភិក្ខុកន្លងហត្ថបាសមេទ្វារផ្ទះចូលទៅ បើផ្ទះតូច ភិក្ខុកន្លងពាក់កណ្ដាលផ្ទះចូលទៅ អង្គុយក្នុងទីជិតនៃដំណេក មិនមានភិក្ខុដទៃជាគំរប់ពីរផង ត្រូវបាចិត្តិយ ។

សភោជនសិក្ខាបទ គំរប់ ៣ ចប់

---

បឋមរហោនិសជ្ជសិក្ខាបទ គំរប់ ៤ សេចក្ដីថា ភិក្ខុណាអង្គុយ ឬដេក ក្នុងទីដែលបាំងដោយគ្រឿងបាំង កំបាំងភ្នែកជាមួយនឹងមាតុគ្រាម សូម្បីកើតក្នុងថ្ងៃនោះ ត្រូវបាចិត្តិយ ។

បឋមរហោនិសជ្ជសិក្ខាបទ គំរប់ ៤ ចប់

---

www.budinst.gov.kh www.elibraryofcambodia.org

ទុតិយរហោនិសជ្ជសិក្ខាបទ តំរប់ ៥ សេចក្តីថា ភិក្ខុណា តែម្នាក់ឯង អង្គុយ ឬដេក ក្នុងទីវាល ក៏បាំងត្រចៀក ជាមួយនឹងមាតុគ្រាមដែលដឹងសេចក្តី ត្រូវបាចិត្តិយ ។

សមុដ្ឋានវិធីជាដើម នៃសិក្ខាបទទាំង ២ នេះ ដូចបឋមបារាជិក សេចក្តីក្រៅនោះ គប្បីដឹងដោយន័យដែលបានសំដែងហើយក្នុងអនិយតទាំងពីរ ។

ទុតិយរហោនិសជ្ជសិក្ខាបទ តំរប់ ៥ ចប់

---

ចារិត្តសិក្ខាបទ តំរប់ ៦ សេចក្តីថា ភិក្ខុណា ដែលទាយកគេនិមន្ត ដោយភោជនទាំង ៥ ប្រការ ភោជនណាមួយហើយ ភិក្ខុឆាន់ភោជនដែលគេនិមន្តនោះហើយ ឬនៅមិនបានឆាន់ក្តី មិនលាភិក្ខុដែលមាននៅ ហើយទៅកាន់ត្រកូលដទៃចាកត្រកូលអ្នកនិមន្តនោះ តាំងអំពីវេលាព្រឹករហូតដល់ថ្ងៃត្រង់ ៗ កាលចុះកាន់ឧបចារៈផ្ទះនៃត្រកូលដទៃនោះ ត្រូវទុក្កដ ៗ ឈានកន្លងធរណីទ្វារផ្ទះដោយបាទជាបឋម ត្រូវទុក្កដទៀត ៗ ឈានកន្លងដោយជំហានតំរប់ ២ ត្រូវបាចិត្តិយ វៀរតែមានចីវរទានសម័យ គឺសម័យគេឲ្យចីវរ នឹងចីវរកាលសម័យ សម័យធ្វើចីវរ ដូចពោលហើយក្នុងគណភោជនសិក្ខាបទ ៗ ភិក្ខុណា នៅក្នុងទស្សនូបចារៈក្នុង ទាំងក្នុងឧបចារៈសីមា ល្មមនឹងប្រាប់បានដោយពាក្យប្រក្រតី ភិក្ខុនោះ

www.budinst.gov.kh www.elibraryofcambodia.org

ឈ្មោះថាមានទៅ ផុតហួសអំពីទីនោះទៅឈ្មោះថាមិនមាន ។ ភិក្ខុ
ដែលគេនិមន្តហើយ ត្រូវតែកបាចិត្តិយ ។ គេមិនបាននិមន្ត សំគាល់ថា
គេនិមន្ត ឬសង្ស័យ ហើយទៅ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះគឺ ដឹងថាគេមិនបាននិមន្ត មិនត្រូវ
អាបត្តិ ឬមានសម័យទាំងពីរ ឬលាភិក្ខុដែលមានទៅ ថាយើងនឹងទៅ
ផ្ទះមនុស្សនោះ ហើយទៅ ឬភិក្ខុមិនមាន មិនលាហើយទៅ ឬផ្លូវត្រូវ
ផ្ទះនឹងបបោរៈផ្ទះរបស់អ្នកដទៃ ដើរទៅតាមផ្លូវនោះ ឬទៅកាន់អារាម
នៅក្នុងចន្លោះស្រុក ទៅកាន់ទីលំនៅនានាភិក្ខុនី ទៅកាន់ទីលំនៅតិរ្ថិយ
ទៅរោងឆាន់ ទៅផ្ទះដែលគេនិមន្ត ឬទៅផ្ទះអ្នកឲ្យសលាកភត្តជាដើម
នឹងទៅព្រោះមានអន្តរាយ និងភិក្ខុឆ្កួតជាដើម ទាំងអម្បាលនេះ មិនត្រូវ
អាបត្តិ ។ ជាអនាណត្តិកៈ មិនត្រូវព្រោះបង្គាប់ ។ មានអង្គ ៥ គឺ បញ្ចន្នំ
ភោជនានំ អញ្ញតរេន និមន្តនសាទិយនំ ត្រេកអរទទួលសេចក្តី
និមន្តន៍ដោយភោជនទាំង ៥ ណាមួយ ១ សន្តំ ភិក្ខុំ អនា-
បុច្ឆា មិនប្រាប់-លាដល់ភិក្ខុដែលមានទៅ ១ ភត្តិយឃរតោ
អញ្ញស្ស ឃរស្ស បវេសនំ ទៅកាន់ផ្ទះដទៃពាក្យផ្ទះអ្នកនិមន្ត ១
មជ្ឈន្តិកានតិក្កមោ មិនទាន់កន្លងវេលាថ្ងៃត្រង់ទៅ ១ សម-
យស្ស ច អាបទានំ ច អភាវោ មិនមានសម័យឬអន្តរាយ ១
ព្រមដោយអង្គ ៥ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចបឋម-

www.budinst.gov.kh www.elibraryofcambodia.org

គប់ខសិក្ខាបទ ប្លែកតែសិក្ខាបទនេះជាកិរិយាកិរិយៈ ត្រូវព្រោះធ្វើ ខាងមិនធ្វើ គឺភិក្ខុធ្វើនូវការទទួលនិមន្តន៍ដោយភោជន ខាងមិនធ្វើនូវការលាភិក្ខុដែលមាននៅហើយទៅ ។

ចារិត្តសិក្ខាបទ គំរប់ ៦ ចប់

មហានាមសិក្ខាបទ គំរប់ ៧ សេចក្តីថា បើតាយកបវារណាដោយបច្ច័យគឺ ថ្នាំមានសប្បិជាដើម អស់ ៤ ខែ ឬបវារណាថែមថ្មីទៀត ឬបវារណាជានិច្ចក្តី ភិក្ខុមិនមានជម្ងឺក្តីសប្បាយហត់ឡើយ គប្បីត្រេកអរទទួលចុះ បើគេបវារណាកំណត់ដោយរាត្រី ឬកំណត់ដោយថ្នាំទុកដកបណា គប្បីសូមគេតាមកំណត់ដកបនោះ បើភិក្ខុសូមគេឲ្យលើសកំណត់រាត្រី ខាងថ្នាំដែលគេកំណត់ទុកនោះ ខាងកិច្ចដែលត្រូវការដោយថ្នាំមិនមាន សូមថ្នាំមកក្តី ឬសូមថ្នាំដទៃពាក្យថ្នាំដែលត្រូវការក្តី ត្រូវបាចិត្តិយ ៗ ក្នុងកិរិយាដែលសូមលើសជាងកំណត់ត្រូវតែបាចិត្តិយ ៗ មិនលើសកំណត់ សំគាល់ថាលើសកំណត់ ឬសង្ស័យ ហើយសូមត្រូវទុក្កដ ៗ

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺដឹងថានៅមិនទាន់លើសកំណត់សូមមិនត្រូវអាបត្តិ កាលបើមានសេចក្តីត្រូវការ ប្រាប់គេតាមពិតហើយសូម មិនឲ្យលើសកំណត់ថ្នាំ កំណត់រាត្រីទៅ ឬសូមអំពីញាតិ ខាងមនុស្សបវារណាដោយបវារណាជាបុគ្គល ខាងបវារណាមិនមានទីបំផុត ឬសូមដើម្បីអ្នកដទៃ ឬចាត់ចែងយកដោយទ្រព្យរបស់ខ្លួន ខាងភិក្ខុឆ្កួតជាដើម

www.budinst.gov.kh www.elibraryofcambodia.org

ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិកៈ មិនត្រូវព្រោះបង្គាប់ ។ មាអង្គ ៤ គឺ សង្ឃប្បវារណតា គេបវារណាដល់សង្ឃ ១ តតោ ឧត្តរិ ភេសជ្ជវិញ្ញត្តិ សូមថ្នាំឲ្យលើសកំណត់នោះ ១ អភិលាបនតា មិនមានជម្ងឺ ១ បរិយន្តាតិក្កមោ កន្លងហួសកំណត់ទៅ ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចសញ្ចរិត្តសិក្ខាបទ ។

## មហានាមសិក្ខាបទ តំរប់ ៧ ចប់

១ យុត្តសិក្ខាបទ តំរប់ ៨ សេចក្តីថា ភិក្ខុណា ទៅមើលចតុរង្គិនីសេនា ក្បួនទ័ព ដែលលើកចេញចាកស្រុក ចាកនគរ ត្រូវទុក្កដ គ្រប់ៗបទវារៈ ។ ឈរក្នុងទស្សនូបចារៈក្រឡេកមើលឃើញ ត្រូវបាចិត្តិយ វៀរតែមានហេតុដ៏សមគួរ គឺញាតិក្នុងពួកសេនាមានជម្ងឺ ទៅសួរញាតិ មិនត្រូវអាបត្តិ ។ ដំរីមានមនុស្សសំរាប់ ១២ នាក់, សេះមានមនុស្សសំរាប់ ៣ នាក់, រថមានមនុស្សសំរាប់ ៤ នាក់, ពលថ្មើរជើងមានមនុស្ស ៤ នាក់កាន់អាវុធ, ឈ្មោះថាចតុរង្គិនីសេនា ។ ឈរក្នុងទីណាហើយ ឃើញក្នុងទីនោះ ឈ្មោះថាទស្សនូបចារៈ លះទស្សនូបចារៈហើយ រមិលមើលរឿយៗ ត្រូវបាចិត្តិយរាប់តាមប្រយោគដែលមើល ។ ក្នុងសេនាលើកក្បួនទ័ពត្រូវតិកបាចិត្តិយ ។ ទៅមើលសេនាមិនគ្រប់ដោយអង្គ ៤ តែពួកសេនា

ណាមួយ ត្រូវទុក្កដ ដោយន័យដូចពោលហើយ ៗ មិនមែនក្បួនសេនាព្យូហៈ លើកទ័ព សំគាល់ថាក្បួនសេនាលើកទ័ព ឬសង្ស័យ ទៅមើល ត្រូវទុក្កដ ៗ

ឯវិធីដែលមិនត្រូវអាបត្តិនោះគឺ ដឹងថាមិនមែនក្បួនសេនាព្យូហៈលើកទ័ព ទៅមើលមិនត្រូវអាបត្តិ ឬឈរក្នុងអារាមហើយឃើញ ឬឃើញគេលើកមកកាន់ទីលំនៅនៃខ្លួន ឬដើរស្ទួនផ្លូវទៅប្រទះ ឬមានហេតុ មានអន្តរាយ និងកិច្ចធុរៈជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ៗ ជាអនាណត្តិកៈ មិនត្រូវព្រោះបង្គាប់ ៗ មានអង្គ ៤ គឺ ឧយ្យុត្តសេនា ក្បួនចតុរង្គិនីសេនាលើកទ័ពចេញ ១ ទស្សនត្ថាយ គមនំ ទៅដើម្បីនឹងមើល ១ អនុញ្ញាតោកាសតោ អញ្ញត្រ ទស្សនំ មើលក្នុងទីដទៃ ក្រៅពីឱកាសដែលព្រះពុទ្ធអង្គទ្រង់អនុញ្ញាត ១ គឺជារូបបច្ចយស្ស វា អាបទាយ វា អភាវោ មិនមានហេតុដ៏សមគួរ ឬអន្តរាយ ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវបាចិត្តិយ ៗ សមុដ្ឋានវិធីជាដើម ដូចឯឡកលោមសិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាលោកវជ្ជៈ មានទោសតាមធម្មតាលោក ជាអកុសលចិត្ត មានវេទនា ៣ ៗ

ឧយ្យុត្តសិក្ខាបទ គំរប់ ៨ ចប

---

សេនាវាសសិក្ខាបទ គំរប់ ៩ សេចក្តីថា ហេតុណាមួយដែលនឹងគប្បីទៅកាន់កងទ័ព បើមានទៀនដល់ភិក្ខុ ភិក្ខុនោះគប្បីនៅក្នុងកងទ័ពបាន

www.budinst.gov.kh www.elibraryofcambodia.org

ត្រឹមពីរបីរាត្រី បើភិក្ខុណានៅក្នុងកងទ័ពលើស ៣ រាត្រីឡើងទៅ ក្នុងថ្ងៃទី ៤ ព្រះអាទិត្យអស្តង្គតហើយ ភិក្ខុឈរ ឬអង្គុយ ឬដេកនៅក្នុងកងទ័ពក្តី ឬខឹងហោះទៅលើអាកាសក្តី គង់ត្រូវបាចិត្តិយាបត្តិ ។

សេនាវាសសិក្ខាបទ គំរប់ ៩ ចប់

---

ឧយ្យោធិកសិក្ខាបទ គំរប់ ១០ សេចក្តីថា ភិក្ខុណាលះទៅនៅក្នុងកងទ័ពពីរបីរាត្រី ដោយហេតុដ៏សមគួរ បើគ្រាន់ទៅមើលទីដែលគេច្បាំងគ្នា ឬកាន់ទ័ពត្រៀមពល ឬទ័ពតាក់ពល ឬទៅមើលកងដំរី កងសេះ កងរថ កងថ្មើរជើង ត្រូវអាបត្តិទុក្កដ គ្រប់ៗបទការៈ ។ ឈរក្នុងទស្សនូបចារៈ មើលឃើញត្រូវបាចិត្តិយ ។ ដំរីពី ៣ ឡើងទៅឈ្មោះថា ហត្ថានិកៈ កងដំរី សេះពី ៣ ឡើងទៅឈ្មោះថា អស្សានិកៈ កងសេះ, រថ ពី ៣ ឡើងទៅឈ្មោះថា រថានិកៈ កងរថ, តាំង ៣ នេះ មានមនុស្សសំកប់ម្ហូបពោល ហើយគ្រប់ៗកង កងថ្មើរជើង តាំងពី ៤ អ្នកឡើងទៅ មានអាវុធក្នុងដៃ ឈ្មោះថា បត្តានិកៈ កងថ្មើរជើង ។

ឧយ្យោធិកសិក្ខាបទ គំរប់ ១០ ចប់

---

អចេលកវគ្គ គំរប់ ៥ ចប់

---

www.budinst.gov.kh www.elibraryofcambodia.org

## សុរាបានវគ្គ គំរប់ ៦ មាន ១០ សិក្ខាបទ ។

សុរាបានសិក្ខាបទ ជាបឋម សេចក្តីថា ទឹកស្រវឹងដែលគេធ្វើដោយសម្ភារៈមានម្សៅជាដើម ឈ្មោះថាសុរា ។ ទឹកដំរាំដែលគេធ្វើដោយផ្កាឈើជាដើម ឈ្មោះថាមេរ័យ ។ វត្ថុទាំងពីរនេះតាំងអំពីតូចទៅ ភិក្ខុផឹកសូម្បីដោយចុងស្បូវ ត្រូវបាចិត្តិយគ្រប់ៗ ប្រយោគ ។ កុនទឹកស្រវឹង ត្រូវតិកបាចិត្តិយ ។ មិនមែនទឹកស្រវឹងសំគាល់ថាទឹកស្រវឹង ឬសង្ស័យ ហើយផឹក ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺដឹងថាមិនមែនទឹកស្រវឹង ផឹកមិនត្រូវអាបត្តិ ផឹកថ្នាំឈ្មោះលោណសោវីរកៈ ទឹនថ្នាំសុត្តៈ ដែលមិនមែនជាគ្រឿងស្រវឹង តែមានពណ៌ទឹនក្លិនរសដូចទឹកស្រវឹង ឬសម្លសាច់ ប្រេងកន្ទុតព្រៃ ទឹនស្ករដែលគេដាក់ទឹកស្រវឹងបន្តិចចុះ ដើម្បីទឹនកាត់ក្លិន ផ្លាចទឹនអប់ក្លិន ដើម្បីឲ្យខ្ជាំងក្តី ក្លិនពណ៌រសមិនប្រាកដ ឬផឹកថ្នាំអរិដ្ឋៈ ដែលគេធ្វើដោយសេកកន្ទុតព្រៃជាដើម មិនស្រវឹងតែដូចទឹកស្រវឹងក្តី ទឹនភិក្ខុឆ្កួតជាដើម ទាំងអម្បាលនេះមិនត្រូវអាបត្តិ ។ ជាអនាណត្តិកៈ មិនត្រូវព្រោះបញ្ញាប់ ។ មានអង្គ ២ គឺ មជ្ជភាវោ ១ ទឹកស្រវឹង ១ តស្ស បានំ ផឹកទឹកស្រវឹងនោះ ១ ព្រមដោយអង្គ ២ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចឯឡកលោមសិក្ខាបទ ប៉ុន្តែសិក្ខាបទនេះ ជាលោកវជ្ជៈ មានទោសតាមធម្មតាលោក ជាអកុសលចិត្ត មានវេទនា ៣ ។

សុរាបានសិក្ខាបទ ជាបឋម ចប់

www.budinst.gov.kh www.elibraryofcambodia.org

អង្គុលិបតោទកសិក្ខាបទ គំរប់ ២ សេចក្តីថា ភិក្ខុប្រាថ្នានឹងដំបូច សើចលេង ហើយចាក់ប្រឡៀងឧបសម្បន្ន ត្រង់អវយវៈណាមួយ មានក្លៀកជាដើម ដោយម្រាមដៃ ឬអវយវៈណាមួយរបស់ខ្លួន ត្រូវបាចិត្តិយៗ ក្នុងឧបសម្បន្ន ត្រូវតែកបាចិត្តិយ ៗ ក្នុងអនុបសម្បន្ន ត្រូវតែកទុក្កដ ៗ ក្នុងសិក្ខាបទនេះ សូម្បីនាងភិក្ខុនីឈ្មោះថាអនុបសម្បន្ននៃភិក្ខុ ភិក្ខុឈ្មោះថាអនុបសម្បន្ននៃនាងភិក្ខុនី ៗ ការចាក់ប្រឡៀងដោយរបស់ដែលជាប់ដោយកាយ ឬចោលទៅឲ្យត្រូវខាងម្ខាង ឬទាំងសងខាង ត្រូវទុក្កដទាំងអស់ ៗ

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺមិនប្រាថ្នានឹងដំបូចសើចលេងហើយពាល់ត្រូវ ឬមានកិច្ចត្រូវចាប់ពាល់អ្នកដទៃ មិនភិក្ខុនីគេជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ៗ ជាអនាណត្តិកៈ មិនត្រូវព្រោះបង្គាប់ ៗ មានអង្គ ២ គឺ ហាសប្បាធិប្បាយតា បំណងនឹងសើចលេង ១ ឧបសម្បន្នស្ស កាយេន កាយាមសនំ ពាល់ត្រូវកាយឧបសម្បន្នដោយកាយរបស់ខ្លួន ១ ព្រមដោយអង្គ ២ នេះ ទើបត្រូវបាចិត្តិយ ៗ សមុដ្ឋានវិធីជាដើម ដូចបឋមបារាជិក ៗ

អង្គុលិបតោទកសិក្ខាបទ គំរប់ ២ ចប់

---

ហស្សធម្មសិក្ខាបទ គំរប់ ៣ សេចក្តីថា ភិក្ខុប្រាថ្នានឹងលេងទឹក ក្នុងទឹកជម្រៅតាំងពីត្រឹមភ្នែកគោឡើងទៅ ហើយចុះទៅដើម្បីនឹងលេងទឹក

www.budinst.gov.kh www.elibraryofcambodia.org

ត្រូវទុក្កដគ្រប់ ៗ ជំហាន ៗ មុជចុះក្តី ងើបឡើងក្តី ត្រូវបាចិត្តិយគ្រប់ប្រ-យោគ ៗ ហែលទៅក្នុងទឹកត្រូវបាចិត្តិយគ្រប់ការៈដៃ ការៈជើង ៗ បើហែលទៅលើទឹកដោយអវយវៈណាមួយ ត្រូវបាចិត្តិយគ្រប់ ៗ ប្រយោគនៃអវយវៈនោះ ៗ ក្នុងការលេងសប្បាយក្នុងទឹកលិចក្នែកគោរ ត្រូវតិក-បាចិត្តិយ ៗ មិនមែនការលេងសប្បាយក្នុងទឹក · សំគាល់ថាលេង ឬសង្ស័យ ត្រូវទុក្កដ ៗ ភិក្ខុលេងទឹកកក់ជាន់ក្នែកគោរ ឬលេងដោយទូក ឬខ្ទប់ទឹកលេងដោយដៃ ដោយជើង ដោយឈើ ដោយអំបែង ឬលេងទឹកនៅក្នុងភាជនៈមានទឹកជ្រក់ជាដើម ទឹងកក់ ទឹងបាចសាចលេងក្តី ត្រូវទុក្កដទាំងអស់ ៗ

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺសរសេរអក្សរពន្យល់សេចក្តីគួរ មិនប្រាថ្នានឹងលេង ចុះង្ងូតទឹកដោយប្រក្រតី ឬចុះមុជទឹកជាដើមដោយកិច្ច ឬហែលឆ្លងទៅកាន់ត្រើយ ឬមានអន្តរាយ ទឹងភិក្ខុឆ្គងជាដើម ទាំងអម្បាលនេះមិនត្រូវអាបត្តិ ៗ ជាអនាណត្តិកៈ មិនត្រូវព្រោះបង្គាប់ ៗ មានអង្គ ២ គឺ ឧបរិគោប្ផកតា ទឹកជ្រៅលិចក្នែកគោរ ១ ហសាធិប្បាយេន កីឡនំ ចុះលេងដោយប្រាថ្នានឹងលេងសប្បាយ ១ ព្រមដោយអង្គ ២ នេះ ទើបត្រូវបាចិត្តិយ ៗ សមុដ្ឋានវិធីជាដើម ដូចបឋមបារាជិក ៗ

ហាស្សធម្មសិក្ខាបទ គំរប់ ៣ ចប់

www.budinst.gov.kh www.elibraryofcambodia.org

អនាទរិយសិក្ខាបទ ទី ៥៤ ៈ សេចក្តីថា ភិក្ខុណា ដែលឧបសម្បន្ន ភិក្ខុផងគ្នាដាស់តឿន ស្តីប្រដៅ ណែនាំ ហាមប្រាម ដោយសិក្ខាបទដែលព្រះពុទ្ធអង្គបញ្ញត្ត មិនអើពើចំពោះបុគ្គលនោះ ឬចំពោះធម៌ ត្រូវអាបត្តិបាចិត្តិយ ។ គិតថា អ្នកនេះជាមនុស្សដែលអ្នកដទៃ គេលើកទោសចំអកចំអន់តិះដៀល ពាក្យរបស់អ្នកនេះយើងនឹងមិនធ្វើតាម ហើយធ្វើសេចក្តីមិនអើពើផ្សេងៗ ឈ្មោះថាមិនអើពើចំពោះបុគ្គល ។ គិតថាដូចម្តេច ធម៌នេះនឹងគប្បីវិនាសទៅក្តី ឬមិនចង់សិក្សាធម៌នោះក្តី ហើយធ្វើសេចក្តីមិនអើពើផ្សេងៗ ឈ្មោះថាមិនអើពើចំពោះធម៌ ។ ភិក្ខុឧបសម្បន្នត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុអនុបសម្បន្ន ត្រូវទុក្កដ ។ ឧបសម្បន្ន ឬអនុបសម្បន្ន ពោលដាស់តឿនដោយធម៌ដទៃ មិនមែនសិក្ខាបទបញ្ញត្តិជាដើមថា ភិក្ខុនេះមិនប្រព្រឹត្តទៅដើម្បីសល្លេខៈ គឺការស្រួសកិលេសផ្សេងៗ មិនអើពើ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុណា ខ្ញុំនឹងរៀនឧគ្គហៈដែលមានមកតាមប្រវេណី ទើបពោលតបថា ឧគ្គហៈនិងបរិបុច្ឆា ការសូត្ររៀនបាលីនិងអដ្ឋកថា នៃអាចារ្យរបស់យើងយ៉ាងនេះក្តី និងភិក្ខុឆ្កួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិកៈ មិនត្រូវព្រះបង្គាប់ ។ មានអង្គ ២ គឺ ឧបសម្បន្នស្ស បញ្ញត្តេន វចនំ ឧបសម្បន្ន ពោលដាស់តឿនដោយវិនយបញ្ញត្តិ ១ អនាទរិយករណំ ធ្វើសេចក្តី

មិនអើពើ ១ ព្រមដោយអង្គ ២ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាទុក្ខវេទនា ។

អនាទរិយសិក្ខាបទ គំរប់ ៤ ចប់

---

ភឹសាបនសិក្ខាបទ គំរប់ ៥ សេចក្ដីថា ភិក្ខុលងបន្លាចភិក្ខុដទៃផងគ្នា ឬនាំយករូបសំឡេងក្លិនរសផោដ្ឋព្វារម្មណ៍ ណាមួយចូលទៅ ឬពោលពាក្យលងដែលគួរខ្លាចជាដើមថា ទីនេះចោរកាច ខ្លាកាចដូច្នេះ ដើម្បីនឹងឲ្យខ្លាច ភិក្ខុនោះខ្លាចក្ដី មិនខ្លាចក្ដី អ្នកលងបន្លាចត្រូវបាចិត្តិយ ។ ក្នុងឧបសម្បន្នត្រូវតែកបាចិត្តិយ ។ ក្នុងអនុបសម្បន្ន ត្រូវតែកទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺមិនគិតនឹងលងបន្លាចឲ្យខ្លាច នាំយករូបជាដើមចូលទៅ ឬប្រាប់ទីដាច់ស្រយាលដោយចោរជាដើម នឹងភិក្ខុឆ្កួតជាដើម ទាំងអម្បាលនេះមិនត្រូវអាបត្តិ ។ ជាអនាណត្តិកៈ មិនត្រូវព្រោះបង្គាប់ ។ មានអង្គ ២ គឺ ឧបសម្បន្នតា អ្នកនោះជាឧបសម្បន្ន ១ តស្ស ទស្សនសវនវិសយេ ភឹសាបេតុកាមតាយ វាយមនំ ព្យាយាមដោយប្រាថ្នានឹងឲ្យឧបសម្បន្ននោះខ្លាចក្នុងវិស័យដែលគេបានឃើញនឹងបានឮ ១ ព្រមដោយអង្គ ២ នេះ - ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចសិក្ខាបទជាលំដាប់មក ។

ភឹសាបនសិក្ខាបទ គំរប់ ៥ ចប់

---

www.budinst.gov.kh www.elibraryofcambodia.org

ជោតិសមាទហនសិក្ខាបទ គំរប់ ៦ សេចក្តីថា ភិក្ខុណា មិនមានជម្ងឺប្រាថ្នាចង់កាំងភ្លើង បង្កាត់ខ្លួនឯង ក្តីតាំងពីកាត់តែងរកឈើព្រមនូវអណ្តាតភ្លើងមិនទាន់ឆេះឡើងដរាបណា កុំប្រយោគទាំងអស់ត្រូវទុក្កដដរាបនោះ ។ អណ្តាតភ្លើងឆេះឡើងត្រូវបាចិត្តិយ ។ ប្រើអ្នកដទៃបង្កាត់ត្រូវទុក្កដដោយបង្គាប់ បង្គាប់តែម្តងសូម្បីតែបង្កាត់ឲ្យឆេះច្រើនឡើង ត្រូវបាចិត្តិយតែ ១ ប៉ុណ្ណោះ វៀរតែមានហេតុដ៏សមគួរ គឺអុជប្រទីបឬបង្កាត់ដុតបាត្រជាដើម មិនត្រូវអាបត្តិ ។ ភិក្ខុណាមានជម្ងឺ វៀរភ្លើងចេញមិនសប្បាយ ឈ្មោះថាមានជម្ងឺ តែរងាតាមរដូវនឹងឈ្មោះថាមានជម្ងឺមិនបាន ។ ក្តីភិក្ខុមិនមានជម្ងឺត្រូវតែបាចិត្តិយ ។ មានជម្ងឺសំគាល់ថាមិនមានជម្ងឺ ឬសង្ស័យហើយបង្កាត់ភ្លើងកាំងត្រូវទុក្កដ ។ អង្កត់ភ្លើងធ្លាក់ចុះហើយលើកផ្តុំឡើងវិញត្រូវទុក្កដ ។ បើអង្កត់ភ្លើងនោះរលត់ទៅ ហើយបង្កាត់ឲ្យឆេះឡើង គង់ត្រូវបាចិត្តិយ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺដឹងថាមានជម្ងឺបង្កាត់ភ្លើងកាំង មិនត្រូវអាបត្តិ កាំងភ្លើងដែលអ្នកដទៃបង្កាត់ ភ្លើងធ្យូងមិនមានអណ្តាត មិនបង្កាត់ព្រោះហេតុដ៏សមគួរ ឬមានអន្តរាយ មិនភិក្ខុឆ្កួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាសាណត្តិកៈ ត្រូវព្រោះបង្គាប់ ។ មានអង្គ ៤ គឺ អគិលានតា មិនមានជម្ងឺ ១ អនុញ្ញាតការណាភាវោ មិនមានហេតុដែលព្រះពុទ្ធអង្គអនុញ្ញាត ១ វិសិព្វេតុកាមតា ប្រាថ្នា

www.budinst.gov.kh www.elibraryofcambodia.org

ខ្ទឹងកាំង ១ សមាទហនំ បង្កាត់ឯងឬប្រើអ្នកដទៃឲ្យបង្កាត់នេះឡើង ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម គប្បីដឹងដោយន័យដូចពោលហើយក្នុងសញ្ចរិត្តសិក្ខាបទ ។

ជោតិសមាទហនសិក្ខាបទ គំរប់ ៦ ចប់

---

នហានសិក្ខាបទ គំរប់ ៧ សេចក្តីថា ភិក្ខុណា នៅក្នុងមជ្ឈិមប្រទេស កន្លងអំពីថ្ងៃងូតទឹកមុនមក មិនទាន់គ្រប់កន្លះខែ ភិក្ខុគិតនឹងងូតទឹក តាក់តែងចុណ្ណៈគឺល្អិត ឬដី តាំងអំពីកាលតាក់តែងនោះមក ក្នុងប្រយោគ តាំងអស់ត្រូវទុក្កដ ៗ ងូតស្រេចហើយត្រូវបាចិត្តិយ វៀរតែមានសម័យ តាំងឥឡូវនេះ ណាមួយ មិនត្រូវអាបត្តិ គឺចុងរដូវក្តៅ មួយខែកន្លះ ឈ្មោះថា ឧណ្ហសមយៈ គឺសម័យក្តៅ, ដើមរដូវភ្លៀងមួយខែ ឈ្មោះថា បរិឡាហសមយៈ សម័យក្រវល់ក្រវាយ, មានជម្ងឺ មិនបានងូតទឹក មិនសប្បាយ ឈ្មោះថា គិលានសម័យ, ធ្វើការងារដោយៈហាបទៅ ស្ទើរបោសព្រាបចរិវេណ ឈ្មោះថា កម្មសម័យ, សម័យដើរផ្លូវ ប្រមាណកន្លះយោជន៍ ឬកំពុងតែដើរទៅ ឬមកដល់ហើយ ឈ្មោះថា អទ្ធានគមនសមយៈ សម័យដើរផ្លូវឆ្ងាយ, ខ្យល់បក់ធូលីជាប់ខ្លួន គឺរង ភ្លៀង២ គ្រាប់ឬ៣ គ្រាប់ធ្លាក់ត្រូវខ្លួន ឈ្មោះថា វាតវុដ្ឋិសមយៈ សម័យ

www.budinst.gov.kh www.elibraryofcambodia.org

ក្ដៀនទម្រូល ៗ សិក្ខាបទនេះ ជាបទេសបញ្ញត្តិ បញ្ញត្តចំពោះតែភិក្ខុក្នុងមជ្ឈិមប្រទេស ឯបច្ចន្តប្រទេស ងូតទឹកបានជានិច្ច មិនត្រូវអាបត្តិ ៗ

នហានសិក្ខាបទ គំរប់ ៧ ចប់

---

ទុព្វណ្ណករណសិក្ខាបទ គំរប់ ៨ សេចក្ដីថា ភិក្ខុណា បានចីវរគួរស្លៀកគួរដណ្ដប់មកថ្មី នៅមិនទាន់ធ្វើកប្បពិន្ទុ ជ្រលក់ឲ្យស្រេចហើយ គប្បីធ្វើកប្បពិន្ទុក្នុងទីណាមួយ ទើបគួរបរិភោគប្រើប្រាស់ស្លៀកដណ្ដប់ ៗ ការចុចចុះគួរជាវង់មូល ប៉ុនមណ្ឌលភ្នែកក្ងោក ឬខ្នងសង្កើច ដោយវត្ថុ ៣ ប្រការ គឺរបស់មានពណ៌ខៀវ ពណ៌ភក់ នឹងពណ៌ខ្មៅ ទាំងអម្បាលនេះណាមួយ ឈ្មោះថាធ្វើកប្បពិន្ទុ ៗ ភិក្ខុមិនបានធ្វើកប្បពិន្ទុ ដូចពោលមកនេះ ហើយបរិភោគស្លៀកដណ្ដប់ ត្រូវបាចិត្តិយ ៗ ក្នុងចីវរមិនបានធ្វើកប្បពិន្ទុ ត្រូវតិកបាចិត្តិយ ៗ ក្នុងចីវរធ្វើកប្បពិន្ទុហើយ សំគាល់ថាមិនបានធ្វើ ឬសង្ស័យ ហើយបរិភោគស្លៀកដណ្ដប់ត្រូវទុក្កដ ៗ

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺធ្វើកប្បពិន្ទុហើយដឹងថាធ្វើហើយ ប្រើប្រាស់មិនត្រូវអាបត្តិ ឬធ្វើហើយ តែកប្បពិន្ទុវិនាសបាត់ទៅ ឬកោសដែលធ្វើកប្បពិន្ទុជាប់ជាបទៅ នឹងចីវរដែលមិនបានធ្វើ កប្បពិន្ទុ ដេរភ្ជាប់គ្នាជាមួយនឹងចីវរដែលធ្វើកប្បពិន្ទុហើយ ឬចីវរចំណាស់ សំពត់អន្ទុក

www.budinst.gov.kh www.elibraryofcambodia.org

ស៊ិតក់បន្សាប ដេរភ្ជាប់ចូលជាមួយនឹងសំពត់ដែលធ្វើកប្បពិន្ទុ ហើយពេលក្រោយ បរិភោគប្រើប្រាស់ចីវរទាំងអម្បាលនេះក្តី ទុំងភិក្ខុណីជាដើម មិនត្រូវតាមបត្តិ ៗ ជាអនាណត្តិកៈ មិនត្រូវព្រោះបន្ទាប់ ៗ មានអង្គ ៣ គឺ វុត្តប្ប-ការស្ស ចីវរស្ស អកតកប្បតា ចីវរដូចពោលមកហើយមិនបានធ្វើកប្បពិន្ទុ ១ ឧ ឧដ្ឋ ចីវរភធិតា មិនមែនភិក្ខុមានចីវរបាត់ជាដើម ១ ឯកសំ ក ធារុបចំ ក ស្លៀកឬដណ្តប់ចីវរនោះ ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ៗ សមុដ្ឋានវិធីជាដើម ដូចឯឡកលោម-សិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាកិរិយាកិរិយៈ ត្រូវព្រោះធ្វើ នឹងមិនធ្វើ គឺភិក្ខុធ្វើនូវការស្លៀកដណ្តប់ នឹងមិនធ្វើនូវកប្បពិន្ទុជាមុន ។

ទុព្វណ្ណករណសិក្ខាបទ គំរប់ ៨ ចប់

---

វិកប្បនសិក្ខាបទ គំរប់ ៩ សេចក្តីថា ភិក្ខុវិកប្បចីវរទុកដល់សហ-ធម្មិកទាំង ៥ គឺភិក្ខុ ភិក្ខុនី នាងសិក្ខមានា សាមណេរ សាមណេរីណាមួយ ហើយបរិភោគស្លៀកដណ្តប់ចីវរ ដែលមិនទាន់បានដកវិកប្បនោះ ត្រូវបាចិត្តិយ ៗ ឯវិធីវិកប្បនឹងសំដែងទៅខាងមុខ ៗ ក្នុងចីវរមិនបានដកវិកប្ប ត្រូវតិកបាចិត្តិយ ៗ អធិដ្ឋានឬលះចីវរដែលមិនបានដកវិកប្បនោះត្រូវទុក្កដ ៗ ដកវិកប្បហើយ សំគាល់ថាមិនទាន់ដកវិកប្ប ឬសង្ស័យ ហើយប្រើប្រាស់ ត្រូវទុក្កដ ៗ

www.budinst.gov.kh www.elibraryofcambodia.org

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺជីវរជាដកវិកប្បហើយប្រើប្រាស់ មិនត្រូវអាបត្តិ អ្នកទទួលវិកប្បដកវិកប្បឱ្យ ឬបរិភោគដោយស្និទ្ធស្នាលនៃអ្នកដែលខ្លួនវិកប្បទុក នឹងភិក្ខុឆ្កួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ៗ ជាអនាណត្តិកៈ មិនត្រូវព្រោះបញ្ញត្តិ ៗ មានអង្គ ៣ គឺ សាមំ វិកប្បិតស្ស អបច្ចុទ្ធារកេ មិនដកចីវរដែលខ្លួនវិកប្បទុក ១ វិកប្បុបគចីវរតា សំពត់នោះទទឹងបណ្តាយល្មមវិកប្ប ១ បរិភោគោ បរិភោគស្លៀកដណ្តប់ ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ៗ សមុដ្ឋានវិធីជាដើម ដូចបឋមកឋិនសិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាកិរិយាកិរិយៈ ត្រូវព្រោះធ្វើ នឹងមិនធ្វើ គឺភិក្ខុធ្វើនូវការវិកប្ប នឹងមិនធ្វើនូវការដកវិកប្ប ហើយប្រើប្រាស់ ៗ

វិកប្បនសិក្ខាបទ គំរប់ ៩ ចប់

---

អបនិធានសិក្ខាបទ គំរប់ ១០ សេចក្តីថា បាត្រក្តី អង្គដ្ឋានក្តី ចីវរទទឹងបណ្តាយល្មមវិកប្បទៀងនោះក្តី សំពត់និសីទនៈមានជាយក្តី បំពង់ម្ជុលមានម្ជុល ឬគ្មានម្ជុលក្តី វត្តពន្ធចង្កេះជាដែន ឬជាពោះវៀនជ្រូកក្តី បរិក្ខារទាំង ៥ នេះ ជារបស់ភិក្ខុដទៃ ដោយលោចទៅ សូម្បីភិក្ខុណា គ្រាន់តែមិនសើចលេង នាំទៅលាក់ទុកដ៏ត្រូវបាចិត្តិយ ៗ ប្រើអ្នកដទៃ ឱ្យយកទៅលាក់ ត្រូវទុក្កដអាបត្តិ ៗ កាលអ្នកដទៃយកទៅលាក់

អ្នកបង្គាប់នោះ ត្រូវបាចិត្តិយ ។ ក្នុងឧបសម្បន្ន ត្រូវតិកបាចិត្តិយ ។ ឧបសម្បន្ន ត្រូវតិកទុក្កដ ។ លាក់ឯង ឬប្រើអ្នកដទៃឲ្យលាក់នូវបរិក្ខារជារបស់ឧបសម្បន្ន ឬអនុបសម្បន្នក្តី វៀរតែបរិក្ខារមានបាត្រជាដើម បពោលហើយនោះចេញ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺបរិក្ខារអ្នកដទៃទុកដាក់មិនល្អ ជួយទុកដាក់ឲ្យ ឬរើសទៅទុក ដោយគិតនឹងប្រដៅម្ចាស់របស់ហើយឲ្យ នឹងកិច្ចគេតជាដើម តាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាសាត្តិកៈ ត្រូវព្រោះបង្គាប់ ។ មានអង្គ ២ គឺ ឧបសម្បន្នស្ស សន្តកំ បត្តាទីនំ អបនិធានំ លាក់បាត្រជាដើមជារបស់ឧបសម្បន្ន ១ វិហេសេតុកាមតា ១ ហសាធិប្បាយតា ១ ជានឹងឲ្យម្ចាស់របស់លំបាក ឬនឹងសើចលេង ១ ព្រមដោយអង្គ ២ នេះ ត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ។

**អបនិធានសិក្ខាបទ គំរប់ ១០ ចប់**

---

សុរាបានវគ្គ គំរប់ ៦ ចប់

---

សប្បាណកវគ្គ គំរប់ ៧ មាន ១០ សិក្ខា[illegible]

សញ្ចិច្ចបាណសិក្ខា[illegible] ជាបឋម [illegible] បាចិត្តិយ [illegible] សម្លាប់សត្វ[illegible]នដែលមានជីវិត [illegible] ប្រមាណ [illegible] សន្តើច ឬធំក្តី

ឲ្យស្លាប់ត្រូវបាចិត្តិយ ។ បើសត្វធំ ជាអកុសលកម្មធំ ព្រោះប្រយោគធំ ។ សង្ស័យក្នុងសត្វមានជីវិត ឬមិនមែនសត្វមានជីវិត សំគាល់ថាសត្វមានជីវិត ឬសង្ស័យ ហើយសម្លាប់ ត្រូវទុក្កដ ។

ឯវត្ថុដែលមិនត្រូវអាបត្តិនោះ គឺដឹងថាមិនមែនសត្វ ជាអនាបត្តិ មិនក្លែង មិនមានសតិ មិនដឹង មិនប្រាថ្នានឹងឲ្យស្លាប់ នឹងភិក្ខុឆ្កួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ វិនិច្ឆ័យក្រៅនេះ មានន័យដូចពោល ហើយ ក្នុងមនុស្សវិគ្គហសិក្ខាបទ ។

សញ្ចិច្ចបាណសិក្ខាបទ ជាបឋម ចប់

---

សប្បាណកសិក្ខាបទ ទី២ សេចក្តីថា ភិក្ខុណា ដឹងថាទឹកមានសត្វ សត្វនឹងស្លាប់ដោយការបរិភោគទឹកនោះ ភិក្ខុបរិភោគទឹកនោះ គឺផឹក ឬងូត ឬលាងភាជនៈ ឬដាក់ស្រោច ក្នុងទីណាៗ ត្រូវបាចិត្តិយ គ្រប់ៗប្រយោគ ។ វិនិច្ឆ័យក្រៅនោះ គប្បីដឹងដោយន័យដូចពោល ហើយក្នុងសញ្ចិច្ចបាណសិក្ខាបទនោះចុះ ។

សប្បាណកសិក្ខាបទ ទី២ ចប់

---

ឧក្កោដនសិក្ខាបទ ទី៣ សេចក្តីថា អធិករណ៍ទាំង៤ គឺ វិវា ប្រកែកតវ៉ាសខែងគ្នាដោយធម្មវិន័យឈ្មោះថា វិវាទាធិករណៈ ។ ចោ

www.budinst.gov.kh www.elibraryofcambodia.org

ដោយសីលវិបត្តិ អាចារវិបត្តិ ទិដ្ឋិវិបត្តិ អាជីវវិបត្តិ ណាមួយ ឈ្មោះអនុវាទាធិករណៈ ។ អាបត្តិទាំង ៧ កងណាមួយដែលភិក្ខុត្រូវហើយ ឈ្មោះថាអាបត្តាធិករណៈ ។ អបលោកនកម្ម ញត្តិកម្ម ញត្តិទុតិយកម្ម ញត្តិចតុត្ថកម្មទាំង ៤ នេះ ណាមួយ កើតឡើងដល់សង្ឃ សង្ឃនឹងធ្វើកិច្ច ឈ្មោះថាកិច្ចាធិករណៈ ។ អធិករណ៍ទាំង ៤ នេះ ណាមួយកើតឡើង សង្ឃរម្ងាប់ហើយដោយសមថ ៧ ណាមួយ ដោយធម៌ ។ ភិក្ខុណាដឹងថា សង្ឃរម្ងាប់ស្រេចហើយ ទៅកាន់សំណាក់ភិក្ខុនោះៗ កលថាកម្មដែលរម្ងាប់អធិករណ៍នោះសង្ឃធ្វើមិនល្អទេ ត្រូវធ្វើជាថ្មីទៀតដើម ដូច្នេះហើយ សើរើចេញ ដើម្បីនឹងឲ្យធ្វើជាថ្មីទៀត ត្រូវបាចិត្តិយ ។ ភិក្ខុសន្ស័យក្នុងកម្មជាធម៌ក្តី ឬកម្មមិនជាធម៌ សំគាល់ថាធម៌ក្តី ឬសន្ស័យក្តី ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺសំគាល់ថាមិនជាធម៌ ក្នុងកម្មនោះៗ ដឹងថាសង្ឃធ្វើកម្មមិនជាធម៌ ឬធ្វើជាពួក ឬធ្វើដល់មនុស្សមិនគួរដល់កម្ម ភិក្ខុធ្វើជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិកៈ អង្គ ៣ គឺ យថាធម្មំ និហតភាវោ អធិករណ៍សង្ឃរម្ងាប់ហើយដោយធម៌ ១ ជាឧបសា មានការដឹង ១ ឧក្កោដនំ សើរើ ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាទុក្ខវេទនា

ឧក្កោដនសិក្ខាបទ ទី ៣ ចប់

www.budinst.gov.kh www.elibraryofcambodia.org

ទុដ្ឋុល្លបដិច្ឆាទនសិក្ខាបទ គំរប់ ៤ សេចក្តីថា ភិក្ខុណា ដឹងថាភិក្ខុដទៃត្រូវទុដ្ឋុល្លាបត្តិ គឺសង្ឃាទិសេស ហើយជួយបិទបាំងអាបត្តិនៃភិក្ខុនោះទុក ដោយឧបាយណាមួយ ត្រូវបាចិត្តិយ ។ បើដាក់ធុរៈថា នឹងមិនប្រាប់ដល់ភិក្ខុណាមួយ ហើយខាងក្រោយត្រឡប់ប្រាប់ ឈ្មោះថាត្រូវបាចិត្តិយហើយទើបប្រាប់ ។ បើដាក់ធុរៈដូច្នេះហើយ ប្រាប់ដល់អ្នកដទៃដើម្បីនឹងឲ្យជួយបិទតៗទៅទៀតដោយឧបាយដូច្នេះ សូម្បីសមណៈ ១ រយអង្គ កាលបើដំណឹងមិនទាន់ដាច់ដរាបណា ក៏គង់ត្រូវអាបត្តិបាចិត្តិយដរាបនោះ ៗ ធ្វើដូចម្តេចដំណឹងទើបនឹងដាច់ បើអ្នកត្រូវអាបត្តិនោះប្រាប់ដល់អ្នកម្នាក់ឲ្យជួយបិទអាបត្តិ សូម្បីអ្នកម្នាក់នោះ ក៏ប្រាប់ដល់អ្នកដទៃឲ្យជួយបិទតៗទៅទៀត ភិក្ខុដែលគេប្រាប់ឲ្យជួយបិទបាំងទី ៣ នោះមិនបាច់ត្រឡប់មកប្រាប់ដល់ភិក្ខុទី ២ វិញ ដូច្នេះហើយដំណឹងទើបនឹងដាច់ ។ កន្លងទុដ្ឋុល្លាបត្តិ ភិក្ខុសង្ស័យ ឬសំគាល់ថាមិនមែនទុដ្ឋុល្លាបត្តិ ត្រូវទុក្កដ ។ មិនមែនទុដ្ឋុល្លាបត្តិ ត្រូវតែទុក្កដ ។ ជួយបិទបាំងអជ្ឈាចារអាក្រក់នឹងមិនអាក្រក់ នៃអនុបសម្បន្ន ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺគិតថាការឈ្លោះវិវាទនឹងមានដល់សង្ឃ ឬគិតថាអ្នកនេះកាចអាក្រក់នឹងធ្វើអន្តរាយដល់ជីវិត ឬព្រហ្មចរិយ ដូច្នេះ ហើយមិនប្រាប់គ្នា មិនបាននិយាយភិក្ខុដែលសមគួរមិនទាន់ប្រាប់គ្នា ឬមិនប្រាថ្នានឹងបិទដោយគិតថាលោកនឹងប្រាកដដោយកម្ម

របស់ខ្លួនឯង ទឹងភិក្ខុគជាដើម តាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិកៈ មានអង្គ ២ គឺ ឧបសម្បន្នស្ស ទុដ្ឋុល្លាបត្តិជាធំ ដឹងថាឧបសម្បន្ន ត្រូវទុដ្ឋុល្លាបត្តិ ១ បដិច្ឆាទេតុកាមតាយ នារោចេស្សាមីតិ ធុរនិក្ខេបោ ដាក់ធុរៈថានឹងមិនប្រាប់ដោយ ព្រាន្ទាប់ចំប៉ាំង ១ ព្រមដោយអង្គ ២ នេះ ទើបត្រូវបាចិត្តិយ ។ ជាសមនុភាសនសមុដ្ឋាន អាបត្តិកើតអំពីកាយវាចាចិត្ត ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ទុក្ខវេទនា ។

ទុដ្ឋុល្លបដិច្ឆាទនសិក្ខាបទ តំរប់ ៤ ចប់

---

ឧនវីសតិវស្សសិក្ខាបទ តំរប់ ៥ សេចក្ដីថា ភិក្ខុណា ជាឧបជ្ឈាយ៍ ដឹងថាបុគ្គលមានអាយុមិនទាន់គ្រប់ ២០ ឆ្នាំ គិតរាប់តាំងអំពីចាប់បដិសន្ធិមក ហើយឲ្យឧបសម្បទាជាភិក្ខុ ឧបជ្ឈាយ៍នោះត្រូវបាចិត្តិយ ។ ភិក្ខុក្រៅនោះ ជាគណបូរកៈតាំងអស់ត្រូវទុក្កដ ។ ចំណែកបុគ្គលនោះ សូម្បីឧបជ្ឈាយ៍ ដឹង ឬមិនដឹងក្ដី ឲ្យឧបសម្បទា គង់មិនបានជាឧបសម្បទា ។ បើអ្នកនោះគន្លង ១០ វស្សាទៅ បានជាឧបជ្ឈាយ៍ឲ្យកុលបុត្រដទៃឧបសម្បទា បើលើកឧបជ្ឈាយ៍នោះចេញ គណបូរកៈគ្រប់សោត អ្នកឧបសម្បទាថ្មី ឈ្មោះថាឧបសម្បទាហើយដោយប្រពៃ សូម្បីអ្នកដែលមិនជាឧបសម្បទា

www.budinst.gov.kh www.elibraryofcambodia.org

នោះ មិនទាន់ដឹងខ្លួនដរាបណា ក៏មិនទាន់អន្តរាយសួគ៌នឹងនិព្វានដល់អ្នកនោះដរាបនោះ ដឹងហើយគប្បីឧបសម្បទាជាថ្មីទៀត ។

៙ ឩនវីសតិវស្សសិក្ខាបទ តំរប់ ៥ ចប់

---

ថេយ្យសត្ថសិក្ខាបទ តំរប់ ៦ សេចក្តីថា ពួកឈ្មួញជាចោរពន្ធ ឡាយធ្វើចោរកម្មហើយក្តី មិនទាន់បានធ្វើក្តី ដល់នូវកិរិយាលួចរបស់ព្រះរាជាក្តី គេចវាងឲ្យប្រេចពន្ធគយក្តី ពួកណាមួយ ជាពួកដើរផ្លូវ ឈ្មោះថាថេយ្យសត្ថៈ ពួកឈ្មួញជាចោរ ភិក្ខុណា ដឹងថាពួកឈ្មួញជាចោរផ្លូវនោះ ហើយបបួលកំណត់កាលជាមួយគ្នាទាំងសងខាងថា យើងនឹងទៅក្នុងថ្ងៃនេះ ឬព្រឹកនេះ ត្រូវទុក្កដ ព្រោះបបួលមុនហើយ ។ ធ្វើមិនឲ្យខុសសង្កេតកាលដែលកំណត់ទុក ដើរផ្លូវទៅជាមួយគ្នា សូម្បីខុសសង្កេតថ្ងៃ ខុសសង្កេតដងព្រៃក្តី បើដើរទៅក្នុងស្រុក មិនទាន់ចុះកាន់ឧបចារៈស្រុកដទៃ ដែលជិតគ្នាល្មមមាន់ហើរដល់ មិនទាន់ត្រូវអាបត្តិនៅឡើយ កាលកន្លងឧបចារៈស្រុកដទៃ ក្នុងជំហានជាបឋម ត្រូវទុក្កដ ។ ក្នុងជំហានជាគំរប់ ២ ត្រូវបាចិត្តិយ ។ ដើរផ្លូវក្នុងព្រៃ មិនមែនជាស្រុក កន្លងកន្លះយោជន៍ក៏ត្រូវបាចិត្តិយ ។ ត្រូវអាបត្តិច្រើនតិច រាប់ដោយកន្លងឧបចារៈស្រុកដទៃមួយ ៗ នឹងកន្លងកន្លះយោជន៍មួយ ៗ ។ មនុស្សមិនបានបបួល ភិក្ខុបបួលតែម្នាក់ ឬជាពួកចោរ ភិក្ខុសង្ស័យ ហើយបបួលក្តី ឬមិនមែនជាពួកចោរ ភិក្ខុសំគាល់ថាជាពួកចោរ ឬសង្ស័យហើយបបួលក្តី ទាំងអម្បាលនេះ ត្រូវទុក្កដ ។

www.budinst.gov.kh www.elibraryofcambodia.org

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុសំគាល់ថាមិនមែនពួកចោរក្តី មិនបានបបួលគ្រាន់តែដើរទៅជាមួយគ្នា ឬមនុស្សបបួលតែម្ខាង ភិក្ខុមិនបានបបួលក្តី ទើបទៅខុសសង្កេតកាល ឬបបួលគ្នាទៅព្រោះមានអន្តរាយក្តី ទើបភិក្ខុឧម្មត្តកជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិកៈ មានអង្គ ៤ គឺ ថេយ្យសត្ថភាវោ ពួកឈ្មួញជាចោរ ១ ជាជនបានដឹង ១ សំវិធានំ បបួលគ្នាទាំងសងខាង ១ អវិសង្កេតេន គមនំ ទៅកន្លងឧបចារៈស្រុកដទៃ ឬកន្លងកន្លះយោជន៍មិនខុសសង្កេត ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវបាចិត្តិយ ។ ជាថេយ្យសត្ថសមុដ្ឋាន អាបត្តិកើតអំពីកាយចិត្ត អំពីកាយវាចាចិត្ត ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ។

ថេយ្យសត្ថសិក្ខាបទ គំរប់ ៦ ចប់

សំវិធានសិក្ខាបទ គំរប់ ៧ សេចក្តីថា ភិក្ខុណា បបួលស្ត្រីដែលដឹងសេចក្តី ទាំងស្ត្រីក៏បបួលព្រមគ្នាទាំងសងខាង ដើរទៅកន្លងផ្លូវជាមួយគ្នា មិនខុសសង្កេតកាល ត្រូវអាបត្តិទុក្កដ ទើបបាចិត្តិយ ដូចពោលហើយក្នុងសិក្ខាបទមុន ៗ ក្នុងមាតុគ្រាមត្រូវតែកបាចិត្តិយ ។ ស្ត្រីយក្ខ ស្ត្រីប្រេត ទើបណ្ឌក ទើបតិរច្ឆានញី មានកាយដូចមនុស្ស ត្រូវទុក្កដ ។ ភិក្ខុបបួលតែម្ខាង ស្ត្រីមិនបានបបួល ឬមិនមែនស្ត្រី សំគាល់ថាស្ត្រី ឬសង្ស័យ ត្រូវទុក្កដ ។

www.budinst.gov.kh www.elibraryofcambodia.org

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺដឹងថាមិនមែនស្ត្រី ជាអនាបត្តិ ១ ក្នុងអនាបត្តិក្រោយនេះដូចសិក្ខាបទមុន លើកតែអន្តរាយម្យ៉ាង ។ ជាអនាណត្តិក: មានអង្គ ៣ គឺ ទ្វិន្នំ បិ សំវិធានំ គ្នា មគ្គបដិបន្នា បបួលជាមួយគ្នាតាំងពីសង់ខាងហើយដើរផ្លូវទៅ ១ អវិសង្កេតតា មិនខុសសង្កេត ១ គាមន្តរេ គមនំ វា អទ្ធយោជនាតិក្កមោ វា គន្លងឧបចារៈស្រុកដទៃ ឬកន្លងកន្លះយោជន ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ ជាអទ្ធានសមុដ្ឋាន អាបត្តិកើតអំពីកាយវាចា អំពីកាយចិត្ត អំពីកាយវាចាចិត្ត ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តក: បណ្ណត្តិវជ្ជ កាយកម្ម វចីកម្ម មានចិត្ត ៣ មានវេទនា ៣ ។

សំវិធានសិក្ខាបទ គំរប់ ៧ ចប់

---

អរិដ្ឋសិក្ខាបទ គំរប់ ៨ សេចក្តីថា ភិក្ខុណា មានទិដ្ឋិសេចក្តីឃើញខុសថា សម្ផស្សស្ត្រីមិនមានទោស ព្រោះដូចសម្ផស្សគ្រឿងកំរាល ដំខន់ មិនឃើញទោសក្នុងការគន្លងមេថុនធម្មៈ ហើយពោលបង្កាច់ព្រះពុទ្ធជាម្ចាស់ថា អាណាវីតិក្កមន្តរាយ ការគន្លងសិក្ខាបទបញ្ញត្តិ ដូចត្រេកអរសម្ផស្សស្ត្រីនេះ ព្រះមានព្រះភាគត្រាស់ថាជាអន្តរាយដល់សួគ៌និព្វាននោះ យើងឃើញថាមិនជាអន្តរាយដល់មនុស្ស ដែលត្រេកអរដោយសម្ផស្សស្ត្រី ភិក្ខុពោលដូច្នេះ ឲ្យភិក្ខុទាំងឡាយដទៃដែលឮ

www.budinst.gov.kh www.elibraryofcambodia.org

បានឃើញ គប្បីសំដែងទោសតាមគុណ ហាមប្រាមភិក្ខុនោះបានពីរដង បីដង កាលបើភិក្ខុនោះមិនលះទិដ្ឋិនោះចេញ ត្រូវទុក្កដ ។ សូម្បីភិក្ខុនោះមិនលះទិដ្ឋិហើយ គប្បីនាំខ្លួនភិក្ខុនោះទៅកណ្តាលសង្ឃ សង្ឃហាមប្រាមទៀត លុះភិក្ខុនោះមិនលះ ត្រូវទុក្កដទៀត កាលភិក្ខុនោះមិនលះដូច្នេះ សង្ឃគប្បីសូត្រសមនុភាសនកម្មចំពោះភិក្ខុនោះដរាបអស់វារៈបីដង ដោយញត្តិចតុត្ថកម្មវាចា ដើម្បីនឹងឲ្យលះទិដ្ឋិនោះចេញ កាលភិក្ខុនោះមិនលះបង់ចេញ ត្រូវទុក្កដ ក្នុងខណៈចប់ញត្តិជាបឋម ទាំងខណៈចប់កម្មវាចាទី ១ ទី ២ ។ កាលចប់កម្មវាចាទី ៣ ត្រូវបាចិត្តិយ ។

អរិដ្ឋសិក្ខាបទ គំរប់ ៨ ចប់

---

ឧក្ខិត្តសម្ភោគសិក្ខាបទ គំរប់ ៩ សេចក្តីថា ភិក្ខុណា ត្រូវឧក្ខេបនីយកម្ម ព្រោះមិនឃើញអាបត្តិ មិនសំដែងអាបត្តិ ឬមិនលះទិដ្ឋិ តាំង ៣ ពួកនេះណាមួយ សង្ឃមិនទាន់រម្ងាប់កម្មនោះនៅឡើយ ភិក្ខុណាបានដឹងដូច្នេះ ហើយធ្វើអាមិសសម្ភោគ គឺឲ្យអាមិស ឬទទួលអាមិសជាមួយនឹងភិក្ខុនោះ ឬធ្វើធម្មសម្ភោគ គឺប្រាប់ធម៌ រៀនធម៌នឹងភិក្ខុនោះក្តី ធ្វើសង្ឃកម្ម មានឧបោសថនិងបវារណាជាដើម នឹងដេកក្នុងទីប្រក់បាំងជាមួយគ្នា សូម្បីមានឧបចារៈផ្សេងអំពីភិក្ខុនោះ ត្រូវបាចិត្តិយគ្រប់ ១ ប្រយោគ ។ ភិក្ខុសង្ស័យក្នុងភិក្ខុ ដែលសង្ឃលើកទោស ឬសំគាល់ក្នុងភិក្ខុដែលសង្ឃមិនបានលើកទោស ថាសង្ឃលើកទោសក្តី សង្ស័យក្តី ត្រូវទុក្កដ ។

www.budinst.gov.kh www.elibraryofcambodia.org

ពាក្យដែលពោល ៗ ភិក្ខុអ្នកសិក្សាគួរតែដឹងច្បាស់ ត្រូវពិនិត្យសាកសួរ ពិចារណាឲ្យបានសេចក្តីពិត ដូច្នេះឯង ជាការគាប់ប្រសើរក្នុងសិក្ខាបទនោះ ៗ ក្នុងឧបសម្បន្ន ត្រូវតិកបាចិត្តិយ ៗ ក្នុងអនុបសម្បន្ន ត្រូវតិកទុក្កដ ៗ ឧបសម្បន្ន ឬអនុបសម្បន្ន ដាស់តឿនពោលប្រដៅដោយសេចក្តី ក្នុងព្រះសូត្រ ឬព្រះអភិធម្ម មិនមែនជាវិនយបញ្ញត្តិ ភិក្ខុពោលគេចវៀសវាងចេញ ដោយអាការណាមួយ ត្រូវទុក្កដ ប៉ុណ្ណោះ ៗ

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុពោលថា ខ្ញុំនឹងដឹង នឹងសិក្សាដូច្នេះក្តី នឹងភិក្ខុឆ្កួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ៗ ជាអនាណត្តិកៈ មិនត្រូវអាបត្តិព្រោះបង្គាប់ ៗ មានអង្គ ២ គឺ ឧបសម្បន្នស្ស បញ្ញត្តេន វចនំ ឧបសម្បន្នពោលដាស់តឿនដោយបញ្ញត្តិ ១ អសិក្ខិតុកាមតាយ ឃរំ វចនំ ពោលបញ្ចៀសទៅដូច្នោះ ដោយមិនប្រាថ្នានឹងសិក្សា ១ ព្រមដោយអង្គ ២ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ប៉ុន្តែសិក្ខាបទនេះជាទុក្ខវេទនាប៉ុណ្ណោះ ៗ

សហធម្មិកសិក្ខាបទ ទីបឋម ចប់

---

វិលេខនសិក្ខាបទ គំរប់ ២ សេចក្តីថា ភិក្ខុណា កាលភិក្ខុដទៃសំដែង ស្វាធ្យាយ សិក្ខាបាតិមោក្ខ ហើយពោលតិះដៀលសិក្ខាបទថា ប្រយោជន៍អ្វី ដោយការសូត្ររៀន សិក្ខា, សិក្ខាបទតូចនឹងតូចដោយ

www.budinst.gov.kh www.elibraryofcambodia.org

សំដាប់អម្បាលនេះ អ្នកណាស្វាធ្យាយ រៀនសូត្រ សិក្ខាបទទាំងអម្បាលនេះ រមែងប្រព្រឹត្តទៅដើម្បីនឹងកើតសេចក្ដីលំបាក រង្កៀស ក្ដៅក្រហាយ ចង្អៀតចង្អល់ចិត្ត ប៉ុណ្ណោះឯង ភិក្ខុតិះដៀលសិក្ខាបទដូច្នេះ ត្រូវបាចិត្តិយ ។ តិះដៀលក្នុងសំណាក់ឧបសម្បន្ន ត្រូវតិកបាចិត្តិយ ។ ក្នុងសំណាក់អនុបសម្បន្ន ត្រូវតិកទុក្កដ ។ តិះដៀលធម៌ដទៃ គឺព្រះសូត្រ នឹងព្រះអភិធម្ម ក្នុងសំណាក់ឧបសម្បន្ន នឹងអនុបសម្បន្នទាំង ២ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺមិនប្រាថ្នានឹងតិះដៀល ពោលថា អ្នកចូររៀនព្រះសូត្រ ឬព្រះអភិធម្ម នឹងគាថាសិនចុះ គ្រាក្រោយទើបរៀនវិន័យដូច្នេះ នឹងភិក្ខុឆ្កួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិក: មិនត្រូវអាបត្តិព្រោះបញ្ញត្តិ ។ មានអង្គ ២ គឺ គរហិតុកាមតា ច ប្រាថ្នានឹងតិះដៀល ១ ឧបសម្បន្នស្ស សន្តិកេ សិក្ខាបទវិវណ្ណនកំ ច តិះដៀលសិក្ខាបទក្នុងសំណាក់ឧបសម្បន្ន ១ ព្រមដោយអង្គ ២ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើមដូចអទិន្នាទានសិក្ខាបទ ប្លែកតែសិក្ខាបទនេះជាទុក្ខវេទនាប៉ុណ្ណោះ ។

វិលេខនសិក្ខាបទ គំរប់ ២ ចប់

---

មោហនសិក្ខាបទ គំរប់ ៣ សេចក្ដីថា ភិក្ខុណា ប្រព្រឹត្តអនាចារមុនហើយ កាលបាតិមោក្ខ ដែលសង្ឃសូត្រក្នុងថ្ងៃឧបោសថគ្រប់កន្លះខែ

www.budinst.gov.kh www.elibraryofcambodia.org

ដោយលំដាប់អស់វារៈ ២-៣ ដង ហើយបានដឹង បានឮ ប្រាជ្ញានឹងឲ្យ
ភិក្ខុដទៃសំគាល់ថា ខ្លួនត្រូវអាបត្តិដោយមិនដឹង ក្លែងពោលថា ខ្ញុំទើបនឹង
ដឹងក្នុងវេលានេះឯងថា សិក្ខាបទនេះមកក្នុងបាតិមោក្ខ មកកាន់ឧទ្ទេសត្រង់
កន្លះខែដូច្នេះ បើភិក្ខុទាំងឡាយដទៃ ក៏ដឹងថាភិក្ខុនេះធ្លាប់ស្តាប់បាតិមោក្ខ
ដែលសង្ឃសូត្រមក ២-៣ ដងហើយដូច្នេះ ភិក្ខុនោះត្រូវទុក្កដ ព្រោះ
ក្លែងធ្វើពើ ។ អាបត្តិណាដែលភិក្ខុត្រូវ ព្រោះប្រព្រឹត្តអនាចារពីមុន
ភិក្ខុនឹងរួចចាកអាបត្តិនោះដោយក្លែងធ្វើមិនដឹងក៏ទេ ឲ្យវិនយធរគប្បីកាត់
អាបត្តិតាមទោសដែលជាទេសនាគាមិនី នឹងវុដ្ឋានគាមិនីនោះចុះ ហើយ
សង្ឃគប្បីធ្វើបន្ថែមនូវមោហារោបនកម្ម ដល់ភិក្ខុនោះ ដោយញត្តិទុតិយៈ
កម្មវាចា លុះកម្មនោះសង្ឃធ្វើជាធម៌ស្រេចហើយ ភិក្ខុក្លែងធ្វើពើទៀត
ត្រូវបាចិត្តិយ ។

មោហនសិក្ខាបទ គំរប់ ៣ ចប់

---

បហារទានសិក្ខាបទ គំរប់ ៤ សេចក្តីថា ភិក្ខុណា ក្រោធខឹងហើយ
ប្រហារភិក្ខុដទៃដោយកាយ ឬរបស់ជាប់ដោយកាយ ឬចោលទៅ ត្រូវ
បាចិត្តិយ ។ សូម្បីភិក្ខុត្រូវប្រហារនោះស្លាប់ ក៏គង់ត្រូវបាចិត្តិយ ព្រោះ
ប្រាជ្ញាទីនឹងប្រហារម្យ៉ាង ។ ក្នុងឧបសម្បន្ន ត្រូវតែបាចិត្តិយ ។ ក្នុងអនុប-
សម្បន្ន ត្រូវតែទុក្កដ ។ បានចំណងនឹងធ្វើឲ្យបង់រូបកាយ គឺចៀរ កាត់
អវយវៈ មានត្រចៀកជាដើមនៃឧបសម្បន្ន ឬអនុបសម្បន្ន ត្រូវទុក្កដ ។

www.budinst.gov.kh www.elibraryofcambodia.org

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុដែលអ្នកណាមួយមកបៀតបៀន យ ដំ ដាល់ គប់ ហើយប្រាថ្នានឹងឲ្យខ្លួនរួចចាកអន្តរាយ ក៏ប្រហារដោះខ្លួនក្តី នឹងភិក្ខុឆ្កួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាទោណត្តិកៈ មិនត្រូវអាបត្តិព្រោះបង្គាប់ ៗ មានអង្គ ៣ គឺ កុបិតតា ក្រោធខឹង ១ ន មោក្ខាធិប្បាយតា មិនប្រាថ្នានឹងឲ្យខ្លួនរួចចាកអន្តរាយ ១ ឧបសម្បន្នស្ស បហារទានំ ប្រហារទៅឧបសម្បន្ន ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចបឋមបារាជិក ប្លែកតែសិក្ខាបទនេះជាទុក្ខវេទនាប៉ុណ្ណោះ ។

បហារទានសិក្ខាបទ គំរប់ ៤ ចប់

---

តលសត្តិកសិក្ខាបទ គំរប់ ៥ សេចក្តីថា ភិក្ខុណា យារលើកឡើងនូវលំពែងគឺបាតដៃ ឬរបស់ជាប់ដោយកាយ សម្រាប់ស្ទឹកឲ្យប្រលដល់ភិក្ខុដទៃដោយសេចក្តីក្រោធខឹង ត្រូវបាចិត្តិយ ។ បើភិក្ខុយារលើកដៃឡើងខឹងគំរាមហើយក្តាត់ទៅជាប្រហារ ត្រូវទុក្កដ ព្រោះមិនប្រាថ្នានឹងប្រហារ ។ បើត្រូវអវយវៈណាមួយ មានដៃជាដើម បែកបាក់ទៅ ក៏ត្រូវតែទុក្កដ ។ វិនិច្ឆ័យទាំងអស់ ក្រៅនោះ គប្បីដឹងដោយន័យដូចពោលហើយក្នុងសិក្ខាបទមុននោះចុះ ។

សិក្ខាបទទាំង ២ នេះ សម្រាប់សត្វតិរច្ឆានក៏ឈ្មោះថាអនុបសម្បន្ន ។

តលសត្តិកសិក្ខាបទ គំរប់ ៥ ចប់

---

www.budinst.gov.kh www.elibraryofcambodia.org

អមូលកសិក្ខាបទ គំរប់ ៦ សេចក្តីថា ភិក្ខុណា ចោទឯង ឬឲ្យអ្នកដទៃចោទភិក្ខុ ដោយអាបត្តិសង្ឃាទិសេស ១៣ ណាមួយ ដែលមិនមានមូល គឺមិនបានឃើញ មិនបានឮ មិនបានរង្កៀស ថាភិក្ខុនោះត្រូវអាបត្តិសង្ឃាទិសេស បើភិក្ខុដែលគេចោទនោះដឹងខ្លួនថា គេចោទយើងដូច្នេះក្នុងខណៈនោះសោត ភិក្ខុអ្នកចោទក៏ត្រូវបាចិត្តិយ ។ ក្នុងឧបសម្បន្នត្រូវតិកបាចិត្តិយ ។ ចោទដោយអាចារវិបត្តិ ឬទិដ្ឋិវិបត្តិ មិនមានមូល ត្រូវទុក្កដ ។ ក្នុងអនុបសម្បន្ន ត្រូវតិកទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺ សំគាល់ថាភិក្ខុត្រូវអាបត្តិសង្ឃាទិសេសហើយ ហើយចោទតាមសំគាល់ ទីនិភិក្ខុឆ្កួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាសាណត្តិកៈ ត្រូវព្រោះបង្គាប់ ។ មានអង្គ ៤ គឺ ឧបសម្បន្នតា អ្នកដែលគេចោទជាឧបសម្បន្ន ១ សង្ឃាទិសេសស្ស អមូលកតា អាបត្តិសង្ឃាទិសេសមិនមានមូល ១ អនុទ្ធំសនតា ចោទឯងឬឲ្យអ្នកដទៃចោទ ១ តំ ខណំ វិជាននំ អ្នកដែលគេចោទ ដឹងខ្លួនក្នុងខណៈនោះ ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចអទិន្នាទានសិក្ខាបទ ប្លែកតែសិក្ខាបទនេះជាទុក្ខវេទនាប៉ុណ្ណោះ ។

អមូលកសិក្ខាបទ គំរប់ ៦ ចប់

www.budinst.gov.kh www.elibraryofcambodia.org

សញ្ចិច្ចសិក្ខាបទ គំរប់ ៧ សេចក្ដីថា ភិក្ខុណា ក្លែងបង្កហេតុឲ្យមានសេចក្ដីរង្កៀសសង្ស័យកើតឡើងដល់ភិក្ខុដទៃ ដោយពោលពាក្យថា ខ្ញុនលោកប្រហែលជាមានអាយុមិនទាន់គ្រប់ ២០ ឆ្នាំ មិនបានជាឧបសម្បន្នទេដឹង លោកប្រហែលជាឆាន់អាមិសក្នុងវេលាវិកាលទេដឹង លោកប្រហែលជាផឹកទឹកស្រវឹងទេដឹង លោកប្រហែលជាអង្គុយក្នុងទីស្ងាត់ជាមួយមាតុគ្រាមទេដឹង ៗ គ្មានហេតុ ហើយក្លែងបង្កហេតុឲ្យមានសេចក្ដីរង្កៀសសង្ស័យដល់ភិក្ខុ ដូច្នេះ ត្រូវបាចិត្តិយគ្រប់ ១ ពាក្យ ៗ ក្នុងឧបសម្បន្ន ត្រូវតិកបាចិត្តិយ ៗ ក្នុងអនុបសម្បន្ន ត្រូវតិកទុក្កដ ៗ

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺមិនប្រាថ្នា ដើម្បីនឹងឲ្យភិក្ខុដទៃអផ្សុកចិត្ត ពោលដូច្នេះ ដោយស្វែងរកប្រយោជន៍ដល់ភិក្ខុនោះប៉ុណ្ណោះ និងភិក្ខុឆ្កួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ៗ ជាអនាណត្តិកៈ មិនត្រូវព្រោះបង្កាច់ ៗ មានអង្គ ៣ គឺ ឧបសម្បន្នតា អ្នកដទៃជាឧបសម្បន្ន ១ អផាសុកាមតា ប្រាថ្នាសេចក្ដីមិនសប្បាយដល់ភិក្ខុនោះ ១ កុក្កុច្ចុប្បាទនំ ធ្វើសេចក្ដីរង្កៀសសង្ស័យឲ្យកើតឡើង ដូចពោលហើយ ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ៗ សមុដ្ឋានវិធីជាដើម ដូចក្នុងសិក្ខាបទជាលំដាប់មក ៗ

សញ្ចិច្ចសិក្ខាបទ គំរប់ ៧ ចប់

www.budinst.gov.kh www.elibraryofcambodia.org

ឧបស្សុតិសិក្ខាបទ ទី ៨ សេចក្តីថា ភិក្ខុណា កាលភិក្ខុដទៃកំពុងឈ្លោះ ប្រកែក ទាស់ទែងគ្នា ហើយលបចាំស្តាប់ថា បើភិក្ខុទាំងនេះ និយាយដូចម្តេច យើងនឹងស្តាប់ ដោយប្រាថ្នានឹងចោទ ហើយដើរទៅ ត្រូវទុក្កដគ្រប់ៗជំហាន ៗ សូម្បីទៅខាងក្រោយ ដើរប្រញាប់ទៅមុខឲ្យឆាប់ហើស ឬទៅខាងមុខតែងធ្វើឲ្យយឺតយូរថយក្រោយមកក៏ដូចគ្នា ៗ ឈរក្នុងទីណាបានឮសំឡេង ឈរស្តាប់ក្នុងទីនោះ ត្រូវបាចិត្តិយ ៗ កាលមកកាន់ទីលំនៅភិក្ខុទាំងនោះ បានឮភិក្ខុកំពុងប្រឹក្សាគ្នា ឬភិក្ខុដើរប្រឹក្សាគ្នាមកជិតទីលំនៅរបស់ខ្លួន បានឮគប្បីក្អកក្រហែម ឬប្រាប់ថា យើងនៅក្នុងទីនេះ ឲ្យភិក្ខុនោះដឹង ៗ សូម្បីមិនធ្វើដូច្នេះ សម្ងំស្តាប់ទៅក៏គង់ត្រូវបាចិត្តិយ ៗ ក្នុងឧបសម្បន្ន ត្រូវតែបាចិត្តិយ ៗ ក្នុងអនុបសម្បន្ន ត្រូវតែទុក្កដ ៗ

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺទៅលបស្តាប់ដោយគិតថា យើងបានឮលោកទាំងនោះ យើងនឹងថយ យើងនឹងវៀរ យើងនឹងអត់ យើងនឹងរម្ងាប់ យើងនឹងដោះខ្លួនចេញដូច្នេះក្តី និងភិក្ខុឆ្កួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ៗ ជាអនាណត្តិកៈ មិនត្រូវព្រោះបណ្ណត្តិ ៗ មានអង្គ ៣ គឺ ឧបសម្បន្នតា អ្នកដទៃជាឧបសម្បន្ន ១ ចោទនាធិប្បាយោ ប្រាថ្នានឹងចោទ ១ សវនំ លបចាំស្តាប់បានឮ ១ ត្រូវដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ៗ ជាថេយ្យសត្ថសមុដ្ឋាន ជាសិយា

www.budinst.gov.kh www.elibraryofcambodia.org

កិរិយា ត្រូវព្រោះធ្វើ គឺលបស្តាប់ក៏មាន ជាកិរិយាអកិរិយា ត្រូវព្រោះមិនធ្វើ គឺមិនក្អកក្រហែមឲ្យគេដឹងក៏មាន ជាសញ្ញាវិមោក្ខ រួចចាកទោសដោយសំគាល់ ជាសចិត្តកៈ មានចិត្តក្នុងទើបត្រូវអាបត្តិ ជាលោកវជ្ជៈ មានទោសតាមធម្មតាលោក ជាកាយកម្ម ជាវចីកម្ម ជាអកុសលចិត្ត ជាទុក្ខវេទនា ។

ឧបស្សុតិសិក្ខាបទ គំរប់ ៨ ចប់

---

កម្មប្បដិពាហនសិក្ខាបទ គំរប់ ៩ សេចក្តីថា សង្ឃកម្មទាំង ៤ មានអបលោកនកម្មជាដើម សង្ឃធ្វើប្រពៃហើយដោយធម៌ ភិក្ខុណា នៅទាំងក្នុងសីមា មិនមកកាន់សង្ឃកម្មនោះដោយកិច្ចណាមួយ ឲ្យតែឆន្ទៈដើម្បីកម្មនោះមកដល់ភិក្ខុដទៃ លុះកម្មនោះសង្ឃធ្វើហើយដោយធម៌វិន័យគ្រាក្រោយត្រឡប់តិះដៀលការកសង្ឃ ត្រូវបាចិត្តិយគ្រប់ ៗ ពាក្យ ។ ភិក្ខុសង្ស័យក្នុងកម្មជាធម៌ក្តី ឬសំគាល់ក្នុងកម្មជាធម៌ ថាជាកម្មមិនប្រកបដោយធម៌ក្តី ឬសង្ស័យក្នុងកម្មមិនប្រកបដោយធម៌ក្តី ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុដឹងថាកម្មដែលសង្ឃធ្វើមិនប្រកបដោយធម៌ក្តី ប្រកបដោយពួកក្តី ដល់ភិក្ខុមិនគួរដល់កម្មក្តី ហើយតិះដៀល នឹងភិក្ខុឆ្កួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ៗ ជា

www.budinst.gov.kh www.elibraryofcambodia.org

អនាណត្តិកៈ ។ មានអង្គ ៣ គឺ ធម្មកម្មតា កម្មប្រកបដោយធម៌ ១ ធម្មកម្មសញ្ញា សំគាល់ថាកម្មជាធម៌ ១ ឆន្ទំ ទត្វា ខីយធំ ឲ្យឆន្ទៈហើយតិះដៀល ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចអវិជ្ជានានសិក្ខាបទ ប្លែកតែសិក្ខាបទនេះជា ទុក្ខវេទនា ។

កម្មប្បដិពាហនសិក្ខាបទ គំរប់ ៩ ចប់

ឆន្ទំ អទត្វា បក្កមនសិក្ខាបទ គំរប់ ១០ សេចក្តីថា សង្ឃប្រជុំគ្នា ក្នុងសីមានឹងរម្ងាប់អធិករណ៍ ភិក្ខុអ្នកតាង អ្នកចម្លើយ សំដែងរឿង របស់ខ្លួន ៗ ហើយ សង្ឃសន្មតភិក្ខុអ្នកសាកសួរឡើងហើយ តែនៅ មិនទាន់បានសាកសួរ ឬសង្ឃធ្វើសង្ឃកម្មតាំងបួនណាមួយ តាំងញត្តិ ហើយក្តី កម្មវាចាសង្ឃធ្វើមិនទាន់ចប់ក្តី យ៉ាងនេះឈ្មោះថាពាក្យវិនិច្ឆ័យ (កំពុងប្រព្រឹត្តទៅ) ក្នុងសង្ឃ ។ ភិក្ខុណាទៅក្នុងហត្ថបាសសង្ឃ ប្រាថ្នា នឹងឲ្យកម្មនោះកម្រើក មិនឲ្យឆន្ទៈមុន ក្លែងក្រោកចេញទៅ ។ កាល កំពុងលះហត្ថបាសសង្ឃបរិស័ទ ត្រូវទុក្កដ ។ លុះលះហត្ថបាសហើយ ត្រូវបាចិត្តិយ ។ សង្ស័យក្នុងកម្មជាធម៌ក្តី ឬកម្មមិនជាធម៌សំគាល់ថាជាធម៌ ឬសង្ស័យក្តី ក្រោកចេញទៅ តាំងអម្បាលនេះ ត្រូវទុក្កដ ។

www.budinst.gov.kh www.elibraryofcambodia.org

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺដឹងថាកម្មមិនជាធម៌ក្រោកទៅ មិនត្រូវអាបត្តិ ដឹងថាការជំលោះវិវាទនឹងមានដល់សង្ឃ ឬសង្ឃនឹងធ្វើកម្មមិនជាធម៌ ជាពួក នឹងធ្វើដល់មនុស្សមិនគួរដល់កម្ម ក្រោកចេញទៅក្តី ឬមានជម្ងឺ ឬក្រោកទៅដោយកិច្ចនៃភិក្ខុឈឺ ឬឧច្ចារៈបស្សាវៈ ឬមិនប្រាថ្នាឲ្យកម្មកម្រើក ឬក្រោកទៅដោយគិតថានឹងត្រឡប់មកវិញក្តី នឹងក្អួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ ជាអនាណត្តិកៈ មិនត្រូវព្រោះបង្គាប់ ។ មានអង្គ ៦ គឺ វិនិច្ឆយកថាយ វត្តមានតា ពុំកាត់សេចក្តី ឬធ្វើសង្ឃកម្ម ១ ធម្មកម្មតា កម្មនោះជាធម៌ ១ ធម្មកម្មសញ្ញិតា ដឹងថាកម្មជាធម៌ ១ សមានសីមាយ ឋិតតា ឋិតនៅក្នុងសីមាសង្ឃ ១ សមានសំវាសកតា ខ្លួនមានសំវាសស្មើនឹងសង្ឃ ១ កោបេតុកាមតាយ ហត្ថបាសវិជហំ ប្រាថ្នានឹងឲ្យកម្មកំរើកហើយក្រោកទៅលះហត្ថបាសសង្ឃ ១ ព្រមដោយអង្គ ៦ នេះ ទើបត្រូវបាចិត្តិយ ៗ ជាសមនុភាសនៈសមុដ្ឋាន អាបត្តិកើតអំពីកាយវាចាចិត្ត ជាកិរិយាកិរិយៈ ត្រូវអាបត្តិព្រោះធ្វើ នឹងមិនធ្វើ ជាសញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសល-ទុក្ខវេទនា ៗ

ឆន្ទំ អទត្វា បក្កមនសិក្ខាបទ គំរប់ ១០ ចប់

---

ទុព្វលសិក្ខាបទ គំរប់ ១១ សេចក្ដីថា ភិក្ខុណា ព្រមព្រៀងដោយសង្ឃដែលនៅក្នុងសីមា ឲ្យចីវរដែលគួរវិកប្បជាយ៉ាងតូចឡើងទៅ ដល់ភិក្ខុដែលសង្ឃសន្មតឲ្យជាភត្តុទ្ទេសកៈជាដើមដោយធម៌ គឺភិក្ខុធ្វើការសង្ឃដោយប្រពៃ ។ គ្រាក្រោយត្រឡប់តិះដៀលថា ភិក្ខុទាំងអម្បាលនេះបង្អោនលាភសង្ឃឲ្យភិក្ខុ តាមជាប់ចិត្ត តាមមិត្រ តាមសំឡាញ់ ដូច្នេះត្រូវបាចិត្តិយគ្រប់ ៗ ពាក្យ ។

ទុព្វលសិក្ខាបទ គំរប់ ១១ ចប់

---

បរិណាមនសិក្ខាបទ គំរប់ ១២ សេចក្ដីថា ភិក្ខុណា ដឹងថាលាភទាយកបង្អោនទៅហើយដល់សង្ឃ ដោយពាក្យថានឹងថ្វាយសង្ឃ ហើយបង្អោនមកដើម្បីបុគ្គល ត្រូវបាចិត្តិយ ។ វិនិច្ឆ័យក្រៅនោះ ដូចបរិណតសិក្ខាបទក្នុងនិស្សគ្គិយ ប្លែកតែបរិណតសិក្ខាបទ ត្រូវនិស្សគ្គិយ បាចិត្តិយព្រោះបង្អោនមកដើម្បីខ្លួន ក្នុងសិក្ខាបទនេះត្រូវតែសុទ្ធិកបាចិត្តិយ ព្រោះបង្អោនទៅដើម្បីបុគ្គលដទៃប៉ុណ្ណោះ ។

បរិណាមនសិក្ខាបទ គំរប់ ១២ ចប់

---

សហធម្មិកវគ្គ គំរប់ ៨ ចប់

---

រាជវគ្គ គំរប់ ៩ មាន ១០ សិក្ខាបទ ៖

អន្តេបុរសិក្ខាបទ ជាបឋម សេចក្ដីថា ម្ចាស់ផែនដីដែលជាជាតិ

www.budinst.gov.kh www.elibraryofcambodia.org

ក្សត្រិយ៍បានមុទ្ធាភិសេក សោយរាជ្យសម្បត្តិជាស្តេចផែនដីហើយ តាំងព្រះមហេសីផង នៅក្នុងក្រឡាព្រះបន្ទំតាំងពីព្រះអង្គ អង្គណាមួយមិនទាន់យាងចេញមក ។ ភិក្ខុណា មិនឲ្យគេទៅក្រាបទូលឲ្យទ្រង់ជ្រាបជាមុន កន្លងធរណីមេទ្វារល្វែងក្រឡាព្រះបន្ទំចូលទៅ ។ ក្នុងជំហានជាបឋមត្រូវទុក្កដ ។ ជំហានជាគំរប់ ២ ត្រូវបាចិត្តិយ ។

អន្តេបុរសិក្ខាបទ ១ ជាបឋម ចប់

---

រតនសិក្ខាបទ គំរប់ ២ សេចក្តីថា ភិក្ខុណា រើសយកឯង ឬឲ្យអ្នកដទៃរើសយក នូវរតនៈមានកែវមុក្តាជាដើម ឬរបស់ដែលគេសន្មតថាជារតនៈ គឺគ្រឿងប្រើប្រាស់ណាមួយ នៃមនុស្សដែលគេភ្លេចធ្លាក់ទៅលើផែនដី ជាទីដទៃ ក្រៅអំពីអារាម និងក្រៅទីសំណាក់អាស្រ័យនៅរបស់ខ្លួន ត្រូវបាចិត្តិយ ។ រើសយកខ្លួនឯង ឬឲ្យអ្នកដទៃរើសយកនូវមាសនិងប្រាក់ដើម្បីខ្លួន ត្រូវនិស្សគ្គិយបាចិត្តិយ ។ ដើម្បីសង្ឃ ឬគណៈ ឬបុគ្គល ឬចេតិយ ឬនវកម្ម ត្រូវទុក្កដ ។ ក្នុងកែវមុក្តាជាដើមដ៏សេសនោះ បើរើសដើម្បីខ្លួន ឬអ្នកដទៃមានសង្ឃជាដើម ត្រូវទុក្កដទាំងអស់ ។ កប្បិយវត្ថុ ឬអកប្បិយវត្ថុ ដោយហោចទៅ សូម្បីតែរបស់មាតា បើភិក្ខុទុកដាក់ដូចមនុស្សរក្សាឃ្លាំង ត្រូវបាចិត្តិយ ។ ធ្វើរបស់ដូច្នោះ ឲ្យជារបស់ខ្លួន ហើយទើបទុកដាក់គួរ ។ បើគ្រហស្ថពោលថា លោកចូរជួយទុកដាក់

www.budinst.gov.kh www.elibraryofcambodia.org

របស់នេះ គប្បីហាមឃាត់ដោយពាក្យថាមិនគួរ ។ បើគេនឹងតាលរបស់នោះហើយទៅ ឈ្មោះថាជាកង្វល់នៃភិក្ខុ ភិក្ខុគប្បីទុកដាក់ចុះ ។ ជាងឈើ ឬខ្ញុំកជការ ធ្វើការក្នុងវត្ត គេផ្ញើគ្រឿងឧបករណ៍ ឬចំណែកណាមួយ ឲ្យជួយទុកដាក់ឲ្យផង ។ ក៏គប្បីធ្វើដោយយល់មុខ ដោយខ្លាច ។ គួរសំដែងទុកដាក់ឲ្យ ។ សូម្បីខាងក្នុងអារាម ឬខាងក្នុងទីសំណាក់អាស្រ័យរបស់ខ្លួនណាមួយ ដែលគេមានសេចក្ដីរង្កៀសថាប្រហែលជាភិក្ខុ ឬសាមណេរ នឹងរើសយករបស់ដែលធ្លាក់ ។ បើក្នុងទីដូច្នោះ គប្បីរើសយកឯង ឬឲ្យអ្នកដទៃរើសយក ធ្វើនូវការចំណាំ ហើយទុកដាក់ ។ គប្បីប្រាប់ថារបស់អ្នកណាបាត់ អ្នកនោះចូលមកយកចុះ ។ បើអ្នកណាមក គប្បីសួរអ្នកនោះថា របស់អ្នកយ៉ាងដូចម្ដេចដែលបាត់ទៅនោះ ។ បើគេប្រាប់ត្រូវតាមចំណាំសោត ក៏គប្បីឲ្យ ។ បើគេប្រាប់មិនត្រូវសោត គប្បីពោលនឹងគេថា អ្នកចូររកខ្លួនឯងចុះ ។ បើភិក្ខុនឹងទៅចាកអាវាសនោះ គប្បីផ្ញើទុកក្នុងដៃភិក្ខុ ដ៏សមគួរ ។ កាលបើភិក្ខុដូច្នោះមិនមាន គប្បីផ្ញើទុកក្នុងដៃគហបតីដែលមានសភាពដ៏សមគួរ ហើយសឹមទៅ ។ ក៏ឯភិក្ខុណាមិនបានចៀសទៅ ចាកអាវាស ទាំងមិនបានឃើញម្ចាស់របស់ ភិក្ខុនោះគប្បីយករបស់នោះឲ្យគេធ្វើសេនាសនៈ ឬចេតិយ ឬស្រះបោក្ខរណីដែលជារបស់ថាវរៈ ។ បើកន្លងកាលយូរទៅ ម្ចាស់របស់មកសោត គប្បីចង្អុលបង្ហាញរបស់ថាវរៈនោះ ថាអ្នកចូរអនុមោទនាយកចុះ ។ បើម្ចាស់

របស់មិនបានអនុមោទនា ហើយគេទារយកសោត គប្បីញុំាងអ្នកដទៃឲ្យទទួលយកនូវរបស់ជាវរៈនោះឲ្យជារបស់ខ្លួន ហើយឲ្យអ្នកនោះសងរបស់ដែលគេទារយកនោះ ៗ ក្នុងទីដែលព្រះពុទ្ធជាម្ចាស់ទ្រង់អនុញ្ញាតឲ្យរើសទុកដាក់ ភិក្ខុមិនបានរើសទុកដាក់ ព្រោះមិនអើពើត្រូវទុក្កដ ៗ

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺរបស់គេធ្លាក់ក្នុងទីដែលព្រះពុទ្ធជាអម្ចាស់ទ្រង់អនុញ្ញាត ភិក្ខុរើសទុកដាក់ និងរបស់ណាដែលជាអាមាសៈគួរពាល់ត្រូវបាន រើសយករបស់នោះដោយស្និទ្ធស្នាល ឬកាន់យកជារបស់ខ្ចី ឬកាន់យកដោយបង្សុកូលសញ្ញា និងភិក្ខុឆ្កួតជាដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ៗ ជាសាណត្តិកៈ មានអង្គ ៤ គឺ អនជ្ញោ-តការណំ មិនមែនហេតុដែលព្រះពុទ្ធជាម្ចាស់ទ្រង់អនុញ្ញាត ១ បរសន្តកតា ជារបស់អ្នកដទៃ ១ វិស្សាសគ្គាហបង្សុកូល-សញ្ញានំ អភាវោ មិនមានការកាន់យកដោយវិស្សាសៈនិងបង្សុ-កូលសញ្ញា ១ ឧគ្គហណំ វា ឧគ្គហាបនំ វា រើសយកឯង ឬឲ្យអ្នកដទៃរើសយករបស់នោះ ១ ព្រមដោយអង្គ ៤ នេះ ទើបត្រូវបាចិត្តិយ ៗ សមុដ្ឋានវិធីជាដើម ដូចសញ្ចរិត្តសិក្ខាបទ ៗ

រតនសិក្ខាបទ គំរប់ ២ ចប់

---

www.budinst.gov.kh www.elibraryofcambodia.org

វិកាលគាមប្បវេសនសិក្ខាបទ គំរប់ ៣ សេចក្តីថា ភិក្ខុណាមួយ មិនលាភិក្ខុដទៃដែលមាននៅ ដូចពោលហើយក្នុងចារិត្តសិក្ខាបទ ហើយចូលទៅកាន់ស្រុក ក្នុងវេលាវិកាលគឺតាំងអំពីថ្ងៃជ្រេពីត្រង់ទៅ ដរាបល្ហុ ដល់អរុណរះឡើងថ្មី ។ បើស្រុកមានរបង ឬកំផែង កន្លងរបង ឬកំផែង ចូលទៅ ។ បើស្រុកមិនមានរបង ឬកំផែង កន្លងឧបចារៈស្រុកទៅ ។ ក្នុងជំហានជាបឋម ត្រូវទុក្កដ ។ ជំហានគំរប់ ២ ត្រូវបាចិត្តិយ វៀរតែមានកិច្ចប្រញាប់ គឺសព្រហ្មចារី ភិក្ខុដង្គាពស់ចឹកជាដើម ។ សូម្បីភិក្ខុច្រើនគ្នានឹងចូលទៅស្រុកដោយកិច្ចណាមួយ ភិក្ខុទាំងអស់នោះក៏គប្បីលាគ្នានឹងគ្នា បើកិច្ចក្នុងស្រុកនោះមិនទាន់សំរេច នឹងទៅស្រុកដទៃ ការដែលត្រូវលាទៀតមិនមាន ។ កាលបើម្ចាស់ឧស្សាហ៍នោះហើយដើរទៅក្តី ប្រាថ្នានឹងទៅស្រុកដទៃក្នុងចន្លោះផ្លូវ ត្រូវលាដោយពិត ។ ភិក្ខុឆាន់ក្នុងផ្ទះត្រកូលឬក្នុងរោងឆាន់ ហើយប្រាថ្នានឹងត្រាច់ទៅបិណ្ឌបាតប្រេង ឬសប្បិ បើមានភិក្ខុនៅខាងឆ្វេង ឬខាងស្តាំ គប្បីលា កាលបើភិក្ខុមិនមាន គប្បីគិតថាមិនមាន ហើយទៅចុះ ។ លុះចុះកាន់ផ្លូវហើយ សូម្បីឃើញភិក្ខុ ការដែលត្រូវលាមិនមាន ។ ក៏ឯផ្លូវណាទៅកណ្តាលស្រុក បើភិក្ខុដើរទៅតាមផ្លូវនោះ ហើយមានចិត្តគិតថា នឹងត្រាច់ទៅបិណ្ឌបាតប្រេងជាដើមកើតឡើង ឃើញភិក្ខុខាងឆ្វេង ឬខាងស្តាំ គប្បីលា បើមិនចៀសចេញអំពីផ្លូវដើរទៅសោត ការដែលត្រូវលាមិនមាន ។ ពាក្យលាថាដូច្នេះ

www.budinst.gov.kh www.elibraryofcambodia.org

វិកាលេ គាមប្បវេសនំ អាបុច្ឆាមិ ប្រែថា ខ្ញុំលាចូលទៅក្នុងស្រុក ក្នុងវេលាវិកាល ។ ក្នុងវេលាវិកាលត្រូវតិកបាចិត្តិយ ។ ក្នុងកាលសំគាល់ថា វិកាល ឬសង្ស័យ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺដឹងថាវេលាព្រឹក មានការប្រញាប់ ឬលាភិក្ខុដែលមាននៅ ឬភិក្ខុមិនមានមិនលាចូលទៅ ឬទៅកាន់អារាម ក្នុងចន្លោះស្រុក នឹងទៅលំនៅនៃនានាភិក្ខុនី ទៅលំនៅតិរ្ថិយ ឬទៅកាន់ទី[illegible] ហើយត្រឡប់វិញ ឬដើរទៅតាមផ្លូវដែលមាននៅក្នុងស្រុក ឬមានអន្តរាយ នឹងភិក្ខុឆ្កួតជាដើម ទាំងអម្បាលនេះមិនត្រូវអាបត្តិ ។ ជាអនាណត្តិកៈ មានអង្គ ៣ គឺ សន្តំ ភិក្ខុំ អនាបុច្ឆា មិនលាភិក្ខុដែលមាននៅ ១ អនុញ្ញាតការណាភាវោ មិនមានហេតុដែលព្រះពុទ្ធជាម្ចាស់ទ្រង់អនុញ្ញាត ១ វិកាលេ គាមប្បវេសនំ ចូលទៅស្រុកក្នុងវេលាវិកាល ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានវិធីជាដើម ដូចបឋមកឋិនសិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាកិរិយាកិរិយៈប៉ុណ្ណោះ ។

វិកាលគាមប្បវេសនសិក្ខាបទ គំរប់ ៣ ចប់

---

សូចិឃរសិក្ខាបទ គំរប់ ៤ សេចក្ដីថា ភិក្ខុណា ធ្វើឯង ឬប្រើអ្នកដទៃឲ្យធ្វើ ខ្ទប់ចំពង់ម្ជុល ដំហើយដោយឆ្អឹង ឬដោយភ្លុក ឬស្នែង ក្នុង

www.budinst.gov.kh www.elibraryofcambodia.org

ប្រយោគដែលធ្វើ ត្រូវទុក្កដ ។ ធ្វើហើយបានមក ត្រូវភេទនកបាចិត្តិយ ។ ត្រូវទំលាយបំពង់ម្ជុលនោះចេញជាមុន ហើយទើបសំដែងអាបត្តិនោះ ធ្លាក់ ៗ ជាចតុក្កបាចិត្តិយ គឺខ្លួនធ្វើមិនទាន់ហើយ ហើយធ្វើបង្ហើយដោយខ្លួនឯងក្តី ឬញុំាងអ្នកដទៃឲ្យធ្វើ ឲ្យហើយស្រេចក្តី អ្នកដទៃធ្វើមិនទាន់ហើយ ខ្លួនយកមកធ្វើឲ្យហើយក្តី ញុំាងអ្នកដទៃឲ្យបង្ហើយក្តី ទាំង ៤ យ៉ាងនេះ ណាមួយ ហើយបានមក ត្រូវបាចិត្តិយ ។ ធ្វើឯង ឬប្រើអ្នកដទៃឲ្យធ្វើ ដើម្បីអ្នកដទៃក្តី និងអ្នកដទៃធ្វើហើយ ខ្លួនបានមកបរិភោគប្រើប្រាស់ក្តី ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺធ្វើឡេវក្តុំ និងឈើព្រនួតភ្លើង ក្រវិលវត្តពន្ធ បំពង់ចាំក្អែក និងចង្កើសចាំក្អែក និងមៀនកាំបិត និងរបស់សម្រាប់ជូតទឹក ឬធម្មក្រក ទាំងអម្បាលនេះ ណាមួយ ដ៏ហើយដោយឆ្អឹងជាដើមក្តី និងកិច្ចគជាដើម មិនត្រូវអាបត្តិ ៗ ជាសាណត្តិកៈ មានអង្គ ៣ គឺ សូចិឃរតា បំពង់ម្ជុល ១ អដ្ឋិមយាទិតា ដ៏ហើយដោយឆ្អឹងជាដើម ១ អត្តនោ អត្ថាយ ការណំ វា ការាបេត្វា វា បដិលាភោ ធ្វើឯងឬប្រើអ្នកដទៃឲ្យធ្វើដើម្បីខ្លួន ហើយបានមក ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវបាចិត្តិយ ។ សមុដ្ឋានៈ វិធីជាដើម ដូចសញ្ចរិត្តសិក្ខាបទ ។

សូចិឃរសិក្ខាបទ ទី ៦ ចប់

ឆេទនកសិក្ខាបទ គំរប់ ៥ សេចក្ដីថា ភិក្ខុកាលនឹងធ្វើឯង ឬប្រើអ្នកដទៃឲ្យធ្វើ នូវគ្រែ ឬតាំង គប្បីធ្វើឲ្យមានជើងកំពស់ ៨ ធ្នាប់ ដោយធ្នាប់ព្រះសុគត រាប់ពីត្រឹមមៅគ្រែខាងក្រោមចុះទៅ (បើធ្វើ) ជើងឲ្យខ្ពស់ជាងប្រមាណនោះ ត្រូវឆេទនកបាចិត្តិយ ។ ត្រូវកាត់ជើងឲ្យល្មមប្រមាណមុន ទើបសំដែងអាបត្តិធ្លាក់ តាំងនោះប្រវែងមិនវែងពេកណាស់ដូចគ្រែ មិនបួនជ្រុងដូចអាសន្ទិ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺឲ្យគេធ្វើឲ្យល្មមប្រមាណ ឬបានមកលើសប្រមាណ តែកាត់ចេញឲ្យល្មមប្រមាណ នឹងបន្កប់ចុះក្នុងដីឲ្យសល់នៅល្មមប្រមាណ ឬធ្វើជាពិតាន ចងជាពនប្រើប្រាស់ក្ដី នឹងភិក្ខុឆ្កួតជាដើម តាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ មានអង្គ ២ គឺ បមាណាតិក្កន្តមញ្ចបីឋតា គ្រែ ឬតាំង កន្លងប្រមាណ ១ អត្តនោ អត្ថាយ ការណំ វា ការាបេត្វា វា បដិលាភោ ធ្វើឯងឬឲ្យអ្នកដទៃធ្វើ ដើម្បីខ្លួនហើយបានមក ១ ព្រមដោយអង្គ ២ នេះ ទើបត្រូវបាចិត្តិយ ។ វិនិច្ឆ័យក្រៅនោះដូចសូចិឃរសិក្ខាបទ ។

ឆេទនកសិក្ខាបទ គំរប់ ៥ ចប់

---

តូលោនទ្ធសិក្ខាបទ គំរប់ ៦ សេចក្ដីថា ភិក្ខុណា ធ្វើឯង ឬប្រើអ្នកដទៃឲ្យធ្វើ នូវគ្រែ ឬតាំង ញាត់ដោយសំឡីខាងក្នុង ត្រូវឧទ្ទាលនកបាចិត្តិយ ត្រូវរើសំឡីចេញមុន ទើបសំដែងអាបត្តិធ្លាក់ ។

www.budinst.gov.kh www.elibraryofcambodia.org

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុធ្វើជាសំពត់ការយោគ នឹងត្រួ·ពន្ធចង្កេះ នឹងថង់ស្ពាយបាត្រ ថង់បាត្រ សំពត់ជម្រងទឹក ខ្នើយតាំង អម្បាលនេះញាត់ដោយសំឡី មិនមានទោស ។ គ្រែ តាំង មនុស្សដទៃធ្វើញាត់ដោយសំឡី បានមករើយកសំឡីចេញប្រើប្រាស់ក្តី នឹងភិក្ខុឆ្កួតជាដើម មិនត្រូវអាបត្តិ ។ ជាអនាណត្តិកៈ មានអង្គ ២ គឺ តូលោនទ្ធ·មញ្ចបីឋតា គ្រែ ឬតាំង ញាត់ដោយសំឡី ១ អត្តនោ អត្ថាយ ករណំ វា ការាបេតា វា បដិលាភោ ធ្វើឯង ឬប្រើអ្នកដទៃឲ្យធ្វើ ដើម្បីខ្លួនហើយបានមក ១ ព្រមដោយអង្គ ២ នេះ ទើបត្រូវបាចិត្តិយ ។ វិនិច្ឆ័យក្រៅនោះ គប្បីដឹងដោយន័យដូចពោលហើយក្នុងសិក្ខាបទមុខនោះចុះ ។

តូលោនទ្ធសិក្ខាបទ គំរប់ ៦ ចប់

---

និសីទនសិក្ខាបទ គំរប់ ៧ សេចក្តីថា ភិក្ខុណា ធ្វើឯង ឬប្រើអ្នកដទៃឲ្យធ្វើ នូវនិសីទនៈ គឺសំពត់រងអង្គុយមានជាយ គប្បីធ្វើឲ្យប្រកបដោយប្រមាណ ប្រមាណនោះ បណ្តោយ ២ ចំអាម ទទឹង ១ ចំអាមកន្លះ ជាយ ១ ចំអាម ដោយចំអាម ព្រះសុគត បើធ្វើទទឹងបណ្តោយ ឲ្យលើសប្រមាណនោះទៅ ត្រូវឆេទនកបាចិត្តិយ ។ កាត់ចេញឲ្យល្មមប្រមាណ·មុន ទើបសំដែងអាបត្តិធ្លាក់ ។ និសីទនៈនោះ ជាឈ្មោះបរិក្ខារ ដើបត្តុយ

យ៉ាំងមានជាយ សម្រាប់ក្រាលដូចសន្ថត ដែលគេពុះចូលពីរកន្លែង រួមមួយចំអាមព្រះសុគត នៅត្រង់ទីបំផុតខ្នាង ធ្វើឲ្យទៅជា ៣ ជាយ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺធ្វើឲ្យល្មមប្រមាណ ឬថយជាង មាណ ឬអ្នកដទៃធ្វើហួសប្រមាណ បានមកកាត់ចេញឲ្យល្មម មាណប្រើប្រាស់ និងយកធ្វើពិតានជាដើម ណាមួយក្តី និងភិក្ខុឆ្កួត ដើម ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ មានអង្គ ២ គឺ និសីទនសន្ថ តណាភិក្ខុធ្វើ សំពត់និសីទនៈនោះកន្លងប្រមាណ ១ អត្តនោ ក្លាយ ការណំ វា ការាបេត្វា វា បដិលាភោ ធ្វើឯង ឬអ្នកដទៃឲ្យធ្វើ ហើយបានមក ១ ព្រមដោយអង្គ ២ នេះ ទើបត្រូវ ចិត្តិយ ។ វិនិច្ឆ័យក្រៅនោះ គប្បីជ្រាបដោយន័យដូចពោលហើយ ។

និសីទនសិក្ខាបទ គំរប់ ៩ ចប់

---

កណ្ឌុប្បដិច្ឆាទិសិក្ខាបទ គំរប់ ៨ សេចក្តីថា ភិក្ខុណា ធ្វើឯង ឬ អ្នកដទៃឲ្យធ្វើ នូវសំពត់បិទបូស គប្បីធ្វើឲ្យប្រកបដោយប្រមាណ កណៈនោះបណ្តាយ ៤ ចំអាម ទទឹង ២ ចំអាម ដោយចំអាមព្រះសុគត ទទឹងបណ្តាយ ឲ្យលើសប្រមាណនោះទៅ ត្រូវឆេទនកបាចិត្តិយ ។

www.budinst.gov.kh www.elibraryofcambodia.org

កាត់ចេញឲ្យល្មមប្រមាណជាមុន ទើបសំដែងអាបត្តិធ្លាក់ ។ សំពត់បិទបូសនេះ ព្រះពុទ្ធអង្គទ្រង់អនុញ្ញាតដល់ភិក្ខុដែលកើតបូសនឹងស្នាកស្នាមកមរលាយ ខាងក្រោមតាំងពីក្រោមផ្ចិតចុះទៅ ខាងលើតាំងពីជង្គង់ឡើងមក ដើម្បីនឹងបិទស្នាកស្នាមតាំងអម្បាលនោះ ។

កណ្ឌុបដិច្ឆាទិសិក្ខាបទ គំរប់ ៨ ចប់

---

វស្សិកសាដិកសិក្ខាបទ គំរប់ ៩ សេចក្តីថា ភិក្ខុណា ធ្វើឯង ឬប្រើអ្នកដទៃឲ្យធ្វើ នូវវស្សិកសាដិកា គឺសំពត់ងូតទឹកភ្លៀង គប្បីធ្វើឲ្យប្រកបដោយប្រមាណ ប្រមាណនោះបណ្តោយ ៦ ចំអាម ទទឹង ២ ចំអាមកន្លះ ដោយចំអាមព្រះសុគត ធ្វើទទឹងនឹងបណ្តោយឲ្យលើសប្រមាណនោះ ត្រូវឆេទនកបាចិត្តិយ ។ កាត់ចេញឲ្យល្មមប្រមាណជាមុន ទើបសំដែងអាបត្តិធ្លាក់ ។

វស្សិកសាដិកសិក្ខាបទ គំរប់ ៩ ចប់

---

នន្ទសិក្ខាបទ គំរប់ ១០ សេចក្តីថា ភិក្ខុណា ធ្វើឯង ឬប្រើអ្នកដទៃឲ្យធ្វើនូវចីវរធំ ប្រមាណប៉ុនចីវរព្រះសុគត ឬលើសជាងនោះ ត្រូវឆេទនកបាចិត្តិយ ។ កាត់ចេញឲ្យខ្វះជាងប្រមាណចីវរព្រះសុគត ទើបសំដែង

www.budinst.gov.kh www.elibraryofcambodia.org

តាមគត្តិញ្ញាក់ ប្រមាណនៃចីវរព្រះសុគតនោះ បណ្ដោយ ៩ ចំអាម ទទឹង ៦ ចំអាម ដោយចំអាមព្រះសុគត ។ វិនិច្ឆ័យតាំងពួនក្រោះនោះ ក្នុងសិក្ខាបទទាំង ៣ នេះ គប្បីដឹងដោយន័យដូចពោលហើយក្នុងនិស័-ទនសិក្ខាបទនោះចុះ ។

ខុទ្ទកសិក្ខាបទ គំរប់ ១០ ចប់

រាជវគ្គ គំរប់ ៩ ចប់

## ប្រមាណនៃចំអាមព្រះសុគត

សំដែងប្រមាណតាមគម្ពីរសុគតវិទត្ថិវិធានបករណៈ ចំអាមព្រះសុគតនោះ ១៦ ធ្នាប់ និង ២ អនុក្បៀសនៃជាងឈើសព្វថ្ងៃនេះ { ខ៉ុំ ចំណោះ ជាសុគតវិទត្ថិ ១ ។

ជើងគ្រែ ជើងតាំង ប្រវែង ១០ ធ្នាប់ និង ៣ ក្បៀស នៃជាងឈើសព្វថ្ងៃនេះ ។

សំពត់និស័ទនៈ បណ្ដោយ ១ ហត្ថ ៨ ធ្នាប់ និង ១ ក្បៀស ទទឹង ហត្ថ និង ៣ អនុក្បៀស ជាយ ១ ចំអាម ៤ ធ្នាប់ និង ២ អនុក្បៀស នៃជាងឈើសព្វថ្ងៃនេះ ។

សំពត់បិទបូស បណ្ដោយ ២ ហត្ថ ១ ចំអាម ៤ ធ្នាប់ ២ ក្បៀស ទទឹង ១ ហត្ថ ៨ ធ្នាប់ ១ ក្បៀស នៃជាងឈើសព្វថ្ងៃនេះ ។

www.budinst.gov.kh www.elibraryofcambodia.org

សំពត់ងូតទឹកភ្លៀង បណ្តាយ ៤ ហត្ថ ៣ ក្បៀស ទទឹង ១ ហត្ថ ១ ចំអាម ៤ ធ្នាប់ នឹង ១ ក្បៀស នឹង ១ អនុក្បៀស នៃជាងឈើសព្វថ្ងៃនេះ ។

សំពត់សុគតចីវរ បណ្តាយ ៦ ហត្ថ ១ ធ្នាប់ នឹង ២ អនុក្បៀស ទទឹង ៤ ហត្ថ ៣ ក្បៀស នៃជាងឈើសព្វថ្ងៃនេះ ។

ក្បៀសមួយចែងជា ៤ ចំណែក ចំណែកមួយឈ្មោះថាអនុក្បៀស ។

បាចិត្តិយុទ្ទេស ចប់

## បាដិទេសនិយុទ្ទេស

ពណ៌នាអំពីសិក្ខាបទនៃបាដិទេសនិយាបត្តិ ។ បាដិទេសនិយាបត្តិ មាន ៤ សិក្ខាបទ ៖

សិក្ខាបទ ជាបឋម សេចក្តីថា នាងភិក្ខុនី បានឧបសម្បទាក្នុងឧភតោសង្ឃ មិនមែនជាញាតិ នៅក្នុងលង្វែកភូមិ មានប្រែកជាដើម ប្រគេនខាទនីយៈដោយដៃខ្លួន ភិក្ខុណា នៅក្នុងស្រុក ឬនៅក្នុងទីជាវត្ត ទទួលអំពីដៃនាងភិក្ខុនីនោះដោយដៃខ្លួន ដើម្បីនឹងឆាន់ ត្រូវទុក្កដព្រោះទទួល ។ លេបចូលទៅត្រូវអាបត្តិបាដិទេសនិយៈ គ្រប់កំរៈដែលលេប ។

សិក្ខាបទ ជាបឋម ចប់

www.budinst.gov.kh www.elibraryofcambodia.org

សិក្ខាបទ គំរប់ ២ សេចក្តីថា ភិក្ខុទាំងឡាយច្រើនរូប ទាយកនិមន្តដោយភោជនទាំង ៥ ណាមួយ ទៅឆាន់ក្នុងត្រកូល ៗ ក្នុងត្រកូលនោះ បើមានភិក្ខុនីមកតឿនទាយក ឲ្យថែមសំឡ ថែមបាយ ដល់ភិក្ខុតាមមិត្រ តាមសំឡាញ់ ភិក្ខុទាំងឡាយគប្បីបណ្តេញនាងភិក្ខុនីនោះឲ្យទៅសិន ទំរាំនឹងឆាន់ហើយ សូម្បីតែភិក្ខុមួយអង្គបណ្តេញចេញ ក៏គួរ បើមិនបណ្តេញចេញទេ លុះភិក្ខុទាំងឡាយទទួលតាមិស ដើម្បីនឹងឆាន់ ត្រូវទុក្កដ គ្រាទទួល ៗ លេបចូលទៅត្រូវបាដិទេសនីយៈ គ្រប់ក្រះៈដែលលេប ។

សិក្ខាបទ គំរប់ ២ ចប់

---

សិក្ខាបទ គំរប់ ៣ សេចក្តីថា ត្រកូលណា ដែលសង្ឃឲ្យបានសម្មតិ ជាសេក្ខត្រកូល ដោយញត្តិទុតិយកម្មវាចាហើយ ភិក្ខុណា ដែលគេមិនទាន់បាននិមន្តជាមុន ហើយជាភិក្ខុមិនមានជម្ងឺ បើទៅកាន់ឧបចារផ្ទះ ទទួលតាមិសក្នុងសេក្ខត្រកូលនោះ ត្រូវទុក្កដ ការទទួល ៗ ទទួលហើយឆាន់ក្នុងទីណាមួយ ត្រូវបាដិទេសនីយៈ ចប់ក្រះៈដែលលេប ។

សិក្ខាបទ គំរប់ ៣ ចប់

---

www.budinst.gov.kh www.elibraryofcambodia.org

សិក្ខាបទ ទី៤ សេចក្តីថា អារញ្ញកសេនាសនៈ គឺវត្តក្នុងព្រៃណា ប្រកបដោយសេចក្តីរង្កៀសនឹងភ័យ ដូចពោលហើយក្នុងសាសង្កសិក្ខាបទ ភិក្ខុណាទៅក្នុងសេនាសនៈដូច្នោះ កាលបើយាវកាលិក គឺខាទនីយៈភោជនីយៈណា ដែលស្ត្រី បុរស គ្រហស្ថ នឹងបព្វជិត ណាមួយ នៅមិនបានចូលមកក្នុងអារាម ឬឧបចារៈនៃអារាម ប្រាប់ឲ្យដឹងច្បាស់ជាមុនថា ត្រកូលឈ្មោះនេះ គេនឹងនាំខាទនីយៈភោជនីយៈ មកប្រគេនដូច្នេះ ភិក្ខុមិនបានប្រាប់ឲ្យគេដឹងជាមុន ថាអន្តរាយ គឺ ចោរកំណាចនៅដើមមាននៅដូច្នេះ បើគេនាំយកខាទនីយៈ ភោជនីយៈមក ភិក្ខុមិនមានជម្ងឺ ទទួលខាទនីយៈ ភោជនីយៈដោយដៃខ្លួន ខាងក្នុងអារាម ឬឧបចារៈនៃអារាម ដើម្បីនឹងឆាន់ត្រូវទុក្កដព្រោះទទួល ៗ លេបចូលទៅត្រូវបាដិទេសនីយៈគ្រប់ករៈដែលលេប ៗ ភិក្ខុទទួលកាលិក មានយាមកាលិកជាដើម ដើម្បីជាអាហារ ឬលេបចូលទៅ ត្រូវទុក្កដ ។

ឯវិធីដែលមិនត្រូវអាបត្តិនោះ គឺភិក្ខុប្រាប់ឲ្យដឹងដូច្នោះ សំគាល់ថាមិនបានប្រាប់ឲ្យដឹងក្តី សង្ស័យក្តី ឬសំគាល់ថាប្រាប់ឲ្យដឹងហើយក្តី ឈឺក្តី នឹងបរិភោគនូវខាទនីយៈភោជនីយៈ ដែលទាយកនាំមកដោយហេតុដែលខ្លួនប្រាប់ឲ្យដឹងក្តី នឹងបរិភោគរបស់ដែលសល់អំពីភិក្ខុឈឺក្តី នឹងបរិភោគវត្ថុមានមើមឈើ នឹងផ្លែឈើជាដើម ដែលខ្លួនទទួលខាងក្រៅអារាម

បរិភោគកាលិកណាមួយ មានយាមកាលិកជាដើម ដែលខ្លួនបានហើយក្តី ឲ្យភិក្ខុគេជាដើម តាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ សិក្ខាបទនេះមានអង្គ ៧ គឺ យថាវុត្តអារញ្ញកសេនាសនតា សេនាសនៈនៅក្នុងព្រៃដូចពោលហើយ ១ យាវកាលិកស្ស អកតត្ថជាតកតា យាវកាលិកមិនបានកើតក្នុងទីនោះ ១ អគិលានតា មិនមានជម្ងឺ ១ អគិលានាវសេសកតា យាវកាលិកមិនជាសំណល់អំពីភិក្ខុឈឺ ១ អប្បដិសំវិទិតតា របស់នោះគឺគេមិនបានប្រាប់ឲ្យដឹង (ជាមុន) ១ អជ្ឈារាមេ បដិគ្គហណំ ទទួលក្នុងអារាម ១ អជ្ឈោហរណំ លេបចូលទៅ ១ ព្រមដោយអង្គ ៧ នេះ ទើបត្រូវអាបត្តិបាដិទេសនីយៈ ។ សមុដ្ឋានវិធីជាដើម ដូចបឋមកឋិនសិក្ខាបទ ប្លែកតែសិក្ខាបទនេះ ជាកិរិយាកិរិយៈ ត្រូវព្រោះធ្វើនិងមិនធ្វើ គឺភិក្ខុធ្វើនូវការទទួលយាវកាលិក និងមិនធ្វើនូវការប្រាប់រឿងឲ្យគេដឹងជាមុន ។

សិក្ខាបទ គំរប់ ៤ ចប់

---

អាបត្តិបាដិទេសនីយៈតាំង ៤ សិក្ខាបទនេះ ពាក្យសំដែងក្នុងខាងវិមថា គារយ្ហំ អាវុសោ(១) ធម្មំ អាបជ្ជឹ(២) អសប្បាយំ បាដិទេសនីយំ តំ បដិទេសេមិ(៣) ។

(១) បើភិក្ខុខ្ចីវស្សា សំដែងអាបត្តិនឹងភិក្ខុចាស់វស្សាជាងខ្លួន គប្បីថា ភន្តេ ជួស អាវុសោ ។ បើភិក្ខុច្រើនរូបត្រូវអាបត្តិជាមួយគ្នាក្នុងសិក្ខាបទទាំងពីរថា (២) អាបជ្ជិម្ហា ជួស អាបជ្ជឹ ។ (៣) បដិទេសេម ជួស បដិទេសេមិ ។

www.budinst.gov.kh www.elibraryofcambodia.org

ប្រែថា ខ្ញុំត្រូវហើយនូវអាបត្តិឈ្មោះបាដិទេសនីយ មិនជាទីសប្បាយ ដែលព្រះពុទ្ធទ្រង់តិះដៀល ខ្ញុំសំដែងនូវអាបត្តិនោះ ។ ពាក្យសួរនិងពាក្យទទួលតទៅ ដូចពាក្យសំដែងអាបត្តិដទៃ ៗ ។

បាដិទេសនីយុទ្ទេស ចប់

---

## សេខិយុទ្ទេស

ពណ៌នាអំពីសេខិយវត្ត វត្តដែលបព្វជិតគប្បីសិក្សាឲ្យដឹងជាមុន បើមិនសិក្សាឲ្យដឹង ឬដឹងហើយតែមិនបានបដិបត្តិតាម ត្រូវអនាទរិយៈទុក្កដ គឺអាបត្តិទុក្កដ ព្រោះមិនអើពើ ។

សេខិយវត្តនោះ ចែកជា ៤ ពួក គឺពួកទី ១ ឈ្មោះសារូប្យៈ ប្រកបដោយការបដិបត្តិសមគួរដល់សមណៈ, ពួកទី ២ ឈ្មោះភោជនប្បដិសំយុត្ត ប្រកបដោយភោជន, ពួកទី ៣ ឈ្មោះធម្មទេសនាបដិសំយុត្ត ប្រកបដោយធម្មទេសនា, ពួកទី ៤ ឈ្មោះបកិណ្ណកៈ ពោលអំពីកិច្ចផ្សេងៗ បន្តិចបន្តួច ។

ពួកទី ១ ឈ្មោះសារូប្យមាន ២៦ សិក្ខាបទ ៖

សិក្ខាបទ ជាបឋម សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងស្លៀក ឲ្យជាបរិមណ្ឌលជុំទុះ ស្លៀកខាងលើបិទមណ្ឌល

ខាងក្រោមបង់មណ្ឌលផ្ចិត គឺស្លៀកស្បង់ឲ្យស្រុងចុះទៅខាងក្រោម ចំពីផ្ចិតប្រមាណ ៨ ធ្នាប់ ស្លៀកដូច្នេះ ឈ្មោះថាស្លៀកជាបរិមណ្ឌល កាលបើមិនស្លៀកដូច្នេះ ស្លៀកឲ្យស្រយចុះទៅខាងមុខ ឬខាងក្រោយ ដោយសេចក្តីមិនអើពើ ត្រូវអាបត្តិទុក្កដ ។

សេខិយវត្តនេះ ក្នុងសិក្ខាបទទាំងពួង ត្រូវតែអាបត្តិទុក្កដមួយចំពូក ប្រភេទនៃអាបត្តិដទៃមិនមាន ។ ករណៈដែលមិនត្រូវអាបត្តិក្នុងសិក្ខាបទនេះមាន ៧ យ៉ាងគឺ ភិក្ខុមិនក្លែង មិនមានសតិ មិនដឹងខ្លួន មានជម្ងឺ មានអន្តរាយផ្សេងៗ ភិក្ខុឆ្កួត ភិក្ខុដើមបញ្ញត្តិ ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។ មិនក្លែងនោះ គឺគិតថានឹងស្លៀកឲ្យជាបរិមណ្ឌលប្រាកដ តែក្លាយទៅជាស្លៀកមិនបរិមណ្ឌល ដូច្នេះឈ្មោះថាមិនក្លែង មិនត្រូវអាបត្តិ ភិក្ខុបញ្ជូនចិត្តទៅកាន់ទីដទៃ ស្លៀកមិនជាបរិមណ្ឌល ដូច្នេះឈ្មោះថាមិនមានសតិ ជាអនាបត្តិ, ភិក្ខុមិនដឹងនូវខិកសេខវត្ត គឺវិធីស្លៀកឲ្យជាបរិ-មណ្ឌល ដូច្នេះឈ្មោះថាមិនដឹង ជាអនាបត្តិ តែប៉ុន្តែថា ខិកសេខវត្តទៀមក្នុងកិរិយាស្លៀកបិទ ភិក្ខុគប្បីរៀនសិក្សាឲ្យដឹងជាមុន កាលបើមិនសិក្សាឲ្យដឹង ឈ្មោះថាមិនអើពើ គង់នឹងមិនរួចចាកអាបត្តិទុក្កដ, ភិក្ខុណាស្មងវែង ឬកំភួនជើងធំ ភិក្ខុនោះនឹងស្លៀកឲ្យស្រយចុះទៅជាង ធ្នាប់ ដើម្បីឲ្យជាសារូបគួរ, ភិក្ខុណាមានដំបៅស្មង ឬដំបៅជើង ដូច្នេះឈ្មោះថាមានជម្ងឺ ភិក្ខុនោះនឹងស្លៀកឲ្យទេចឡើងមក ឬស្រុង

www.budinst.gov.kh www.elibraryofcambodia.org

ចុះទៅក៏ត្រូវ សត្វសាហាវ ឬចោរដេញ ឈ្មោះថាមានអន្តរាយ ក្នុងអន្តរាយ ដូច្នេះជាអនាបត្តិ ។ ហេតុនៃអនាបត្តិ មានមិនក្រែងជាដើម ដូចពោលមកនេះ គប្បីដឹងក្នុងសេខិយសិក្ខាបទទាំងពួង ដែលនឹងពោលទៅខាងមុខ ព្រោះហេតុនោះ បើសិក្ខាបទណាមានសេចក្ដីប្លែកគ្នា ទើបនឹងពោលក្នុងសិក្ខាបទនោះទៀត បើមិនប្លែកគ្នាទេ នឹងមិនពោល ។ ក្នុងសេខិយវគ្គ សិក្ខាបទទាំងពួងជាអនាណត្តិកៈទាំងអស់ តែមិនរួមពីអក. ប្បិយសមាទានទុក្កដ ក្នុងសិក្ខាបទជាបឋមនេះ មានអង្គ៣ គឺអនាទរិយំ មិនគោរព ១ អនាបត្តិការណាការេ មិនមានហេតុនៃអនាបត្តិ ១ អបរិមណ្ឌលំ និវាសនំ ស្លៀកមិនជាបរិមណ្ឌល ១ ព្រមដោយអង្គ ៣ នេះ ទើបត្រូវអាបត្តិទុក្កដ ។ ក្នុងមាតិកានៃសេខិយៈទាំងពួង មានអង្គ ៣ ដូចក្នុងសិក្ខាបទនេះទាំងអស់គឺ មិនគោរព ១ មិនមានហេតុនៃអនាបត្តិ ១ ធ្វើឲ្យខុសចាកសេចក្ដីដែលពោលក្នុងសិក្ខាបទនោះ ១ ។ ព្រោះហេតុនោះ គួរទៅខាងមុខ នឹងមិនពោលប្រភេទនៃអង្គទៀតទេ ។ សមុដ្ឋានវិធីជាដើម កាលបើចប់សេខិយវគ្គហើយ ទើបនឹងសំដែង ។ ក្នុងមាតិកានៃសេខិយៈទាំងពួង ៗ មិនមានឈ្មោះអាបត្តិខាងចុងសិក្ខាបទ ដូចសិក្ខាបទនៃអាបត្តិដទៃ មានតែពាក្យថា សិក្ខា ករណីយា ជាគិតគប្បីធ្វើសេចក្ដីសិក្សាដូច្នេះ គ្រប់ៗសិក្ខាបទ ដែលដឹងថាត្រូវអាបត្តិទុក្កដនោះ ដោយបាលីដែលជាបទភាជនីយ៍ថាមិនគោរព ទាំង

ត្រូវអាបត្តិទុក្កដ ។ ព្រោះហេតុនោះ គេទៅខាងមុខ សូម្បីមិនចេញឈ្មោះអាបត្តិ ក៏គប្បីដឹងថា ត្រូវអាបត្តិ ដោយមិនគេរើពើក្នុងវិធីដែលនឹងធ្វើតាមក្នុងសិក្ខាបទទាំងពួង ។

សិក្ខាបទ ទី ២ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងដណ្ដប់ចីវរឲ្យជាបរិមណ្ឌល គឺធ្វើមុំចីវរទាំង ២ ឲ្យស្មើគ្នា ហើយទើបឃ្លុំឲ្យជាបរិមណ្ឌល ដូចសំពត់ស្លៀកដូច្នោះ ។ សិក្ខាបទទាំងពីរនេះ មិនមានពាក្យថា អន្តរឃរេ ដូចគ្នា ព្រោះហេតុនោះ គប្បីស្លៀកនឹងដណ្ដប់ឲ្យជាបរិមណ្ឌល ទាំងក្នុងវត្ត ទាំងក្នុងលន្លៃកភូមិ ។

សិក្ខាបទ ទី ៣ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងបិទកាយដោយប្រពៃ គឺដាក់កុំហើយបិទក ដោយទីបំផុតនៃអន្ទាក់ក ធ្វើមុំទាំងពីរឲ្យស្មើគ្នាមូរចូលមក បិទរហូតដល់កដៃ ហើយទើបដើរទៅក្នុងលន្លៃកភូមិ កាលមិនធ្វើដូច្នេះ បើកដន្គន់ ឬបើកទ្រូងដើរទៅ ត្រូវទុក្កដ ។

សិក្ខាបទ ទី ៤ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងបិទកាយដោយប្រពៃ អង្គុយក្នុងលន្លៃកភូមិ គឺអង្គុយ [illegible]-សិរៈ (ក្បាល) អំពីកញ្ចឹងកឡើងទៅ បើកដៃអំពីកដៃចេញទៅចុងម្រាម បើកជើងតាំងអំពីចុងកំភួនជើងនឹងស្នែងចុះទៅក្រោម បិទអវយវៈដ៏សេសក្រៅនោះ ដូច្នេះឈ្មោះថាបិទដោយប្រពៃ ចូលទៅដើម្បីនឹងនៅក្នុងលន្លៃកភូមិ សូម្បីអង្គុយបើកកាយក្នុងវេលាថ្ងៃ ឬវេលាយប់ មិនត្រូវអាបត្តិ ។ ក ស្វរបតគាសស្ស

www.budinst.gov.kh www.elibraryofcambodia.org

ពាក្យនេះក្នុងអដ្ឋកថា ថាចូលទៅដើម្បីនឹងនៅ តែមិនកំណត់ថានៅយាំង រាត្រី ឬនៅដោយការងារ តែក្នុងទីដទៃ ការសូបគតោ នេះបាន សេចក្តីថាចូលទៅនៅយាំងរាត្រី ព្រោះហេតុនោះ គេទៅខាងមុខក្នុងពាក្យ ថាចូលទៅនៅក្នុងស្រុកភូមិ កប្បីដឹងដូចពោលហើយនេះចុះ ។

សិក្ខាបទ គំរប់ ៥ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹង សង្រួមដោយប្រពៃ គឺមិនគ្រវាត់ដៃ គ្រវាត់ជើង ដើរទៅក្នុងស្រុក ភូមិ ។

សិក្ខាបទ គំរប់ ៦ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹង សង្រួមៈដោយប្រពៃ គឺមិនគ្រវាត់ដៃ គ្រវាត់ជើង អង្គុយក្នុងស្រុក ភូមិ ។

សិក្ខាបទ គំរប់ ៧ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើង នឹងមានភ្នែកសំឡឹងចុះក្រោម គឺរមិលមើលខាងមុខ ចម្ងាយ ១ ជួរនឹម គឺ ៤ ហត្ថ ដើរទៅក្នុងស្រុកភូមិ កំឡុងឈប់ឈរក្នុងទីណាមួយ ហើយ រមិលមើលអន្តរាយ មាន ដំរី សេះ ជាដើម ក៏គួរ ។

សិក្ខាបទ គំរប់ ៨ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹង មានភ្នែកសំឡឹងចុះក្រោម ចម្ងាយ ១ ជួរនឹម អង្គុយក្នុងស្រុកភូមិ ។

សិក្ខាបទ គំរប់ ៩ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹង មិនលើកចីវរៈឡើងម្ខាង ឬទាំងសងខាង ដើរទៅក្នុងស្រុកភូមិ ស្លៀ

www.budinst.gov.kh www.elibraryofcambodia.org

កាលទទួលបិណ្ឌបាត ក៏កុំគប្បីសើយចីវរឡើង គប្បីនាំបាត្រចេញ ដោយស្រោបចីវរ ។

សិក្ខាបទ ទី១០ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនសើយចីវរឡើងខ្ពស់ ឬតាំងសងខាង អង្គុយក្នុងល្វែងក្នុងភូមិ ក្នុងវេលាដែលអង្គុយនោះ សូម្បីនាំធម្មក្រកចេញ ក៏កុំគប្បីសើយចីវរឡើង នាំចេញមក បើចូលទៅនៅយ៉ាងក្រៃក្នុងល្វែងក្នុងភូមិ សូម្បីសើយឡើង មិនត្រូវអាបត្តិ ។

សិក្ខាបទ ទី១១ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនសើចខ្លាំង ដើរទៅក្នុងល្វែងក្នុងភូមិ សូម្បីភិក្ខុមានជម្ងឺ ក៏មិនទោសអាបត្តិ ។

សិក្ខាបទ ទី១២ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនសើចខ្លាំង អង្គុយក្នុងល្វែងក្នុងភូមិ កាលមានហេតុគួរនឹងសើច ក៏គ្រាន់តែញញឹម មិនត្រូវអាបត្តិ ។

សិក្ខាបទ ទី១៣ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមានសំឡេងតិច មិននិយាយសំឡេងខ្លាំង សំឡេងធំ ដើរក្នុងល្វែងក្នុងភូមិ ។

សិក្ខាបទ ទី១៤ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមានសំឡេងតិច មិននិយាយសំឡេងខ្លាំង សំឡេងធំ អង្គុយក្នុងល្វែងក្នុងភូមិ ។ ក៏ឯកំណត់សំឡេងតិចដូច្នេះ ក្នុងផ្ទះមានប្រវែង ១២ ហត្ថ បើព្រះសង្ឃត្ថេរ អង្គុយនៅខាងដើមផ្ទះ ព្រះថេរៈទី ២ អង្គុយនៅកណ្តាលផ្ទះ

ព្រះថេរៈ តំរប់ ៣ អង្គុយក្នុងទីបំផុតផ្ទះដូច្នេះ ព្រះសង្ឃគ្រូនិយាយប្រាប់ពាក្យ សេចក្តីណាមួយនឹងព្រះថេរតំរប់ ២ ព្រះថេរតំរប់ ២ បានឮសំឡេងផង កំណត់ពាក្យកំណត់សេចក្តីបានផង ព្រះថេរតំរប់ ៣ បានឮតែសំឡេង ១ យ៉ាង កំណត់ពាក្យ កំណត់សេចក្តី មិនបាន តាំងអម្បាលនេះ ឈ្មោះថា សំឡេងតិច បើសំឡេងរបស់ព្រះសង្ឃគ្រូខ្លាំងឮហួសដល់ព្រះថេរតំរប់ ៣ កំណត់ពាក្យ កំណត់សេចក្តីបាន ឈ្មោះថាសំឡេងខ្លាំង ។ ក្នុង អដ្ឋកថា កំណត់សំឡេងតិចសំឡេងខ្លាំងដូច្នេះ បាននឹងមនុស្សដែលមាន សំឡេងជាប្រក្រតី មិនតូចមិនធំ ក៏ប៉ុន្តែថាមនុស្សខ្លះសំឡេងធំ មនុស្ស ខ្លះសំឡេងតូច កំណត់យកសំឡេងដោយប្រក្រតីជាប្រមាណចុះ ។

សិក្ខាបទ តំរប់ ១៥ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើង នឹងមិនដើរគ្រវែងកាយ យោងកាយ ឆ្វេង ស្តាំ មុខ ក្រោយ ចូលទៅ ក្នុងលង្វែកភូមិ ។

សិក្ខាបទ តំរប់ ១៦ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើង នឹងមិនអង្គុយគ្រវែងកាយ យោងកាយ ឆ្វេង ស្តាំ មុខ ក្រោយ ក្នុង លង្វែកភូមិ ។

សិក្ខាបទ តំរប់ ១៧ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើង នឹងមិនដើរបង់ដោយ ចូលទៅក្នុងលង្វែកភូមិ ។

សិក្ខាបទ តំរប់ ១៨ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើង នឹងមិនខ្ទាវៃង អង្គុយក្នុងលង្វែកភូមិ ។

www.budinst.gov.kh www.elibraryofcambodia.org

សិក្ខាបទ គំរប់ ១៩ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនគ្រវីក្បាល គ្រវែងក្បាល ឲ្យកមុខ ដើរទៅក្នុងលផ្ទៃកកូមិ ។

សិក្ខាបទ គំរប់ ២០ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនគ្រវីក្បាល គ្រវែងក្បាល ឲ្យកមុខ អង្គុយក្នុងលផ្ទៃកកូមិ ត្រូវតែផ្គងកម្រង់ក្បាលឲ្យស្រួល អង្គុយនឹងដើរក្នុងលផ្ទៃកកូមិ ។ ក្នុងសិក្ខាបទទាំង ៣ ដែលពោលដោយអង្គុយនោះ ភិក្ខុចូលទៅនៅក្នុងលផ្ទៃកកូមិនោះយាំងកក្រើ សូម្បីឃ្លាងកាយជាដើម មិនត្រូវអាបត្តិ ។

សិក្ខាបទ គំរប់ ២១ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនស្ទឹមចង្កេះម្ខាង ឬទាំងសងខាង ដើរទៅក្នុងលផ្ទៃកកូមិ ។

សិក្ខាបទ គំរប់ ២២ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនស្ទឹមចង្កេះម្ខាង ឬទាំងសងខាង អង្គុយក្នុងលផ្ទៃកកូមិ ។ ចូលទៅនៅក្នុងលផ្ទៃកកូមិយាំងកក្រើ សូម្បីស្ទឹមចង្កេះ មិនត្រូវអាបត្តិ ។

សិក្ខាបទ គំរប់ ២៣ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនខ្ទូរក្បាលដើរទៅក្នុងលផ្ទៃកកូមិ ។

សិក្ខាបទ គំរប់ ២៤ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនខ្ទូរក្បាលអង្គុយក្នុងលផ្ទៃកកូមិ ។ ចូលទៅនៅក្នុងលផ្ទៃកកូមិយាំងកក្រើ សូម្បីខ្ទូរក្បាល មិនត្រូវអាបត្តិ ។

សិក្ខាបទ គំរប់ ២៥ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹង

www.budinst.gov.kh www.elibraryofcambodia.org

មិនដើរចំអេតជើង ក្នុងលំនៅក្នុងភូមិ ។ លើកកែងជើងឡើង ត្រូវដើរតែចុងជើង លើកចុងជើងឡើង ត្រូវដើរតែកែងជើង ១ យ៉ាង ឈ្មោះថាចំអេតជើង ។

សិក្ខាបទ គំរប់ ២៦ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនអង្គុយត្របោមក្បាលជង្គង់ដោយដៃ ឬដោយសំពត់ក្នុងលំនៅក្នុងភូមិ។ ចូលទៅនៅក្នុងលំនៅក្នុងភូមិយ៉ាំងណាក្តី សូម្បីអង្គុយត្របោមក្បាលជង្គង់ មិនត្រូវអាបត្តិ ។

សិក្ខាបទទាំង ២៦ នេះ ភិក្ខុណា អាស្រ័យសេចក្តីមិនអើពើ ក្លែងប្រព្រឹត្តកន្លង ត្រូវអនាទរិយទុក្កដ ។ ភិក្ខុមិនក្លែង មិនមានសតិ មិនដឹងខ្លួន មានជម្ងឺ មានអន្តរាយ នឹងភិក្ខុឆ្កួតជាដើម ជាអនាបត្តិគ្រប់សិក្ខាបទ ។ កង អន្តរឃរំ នេះ បើប្រែតាមព្យញ្ជនៈ ប្រែថាទីមានផ្ទះក្នុងចន្លោះ ប្រែតាមអត្ថ ថាលំនៅក្នុងភូមិ ដើម្បីនឹងឲ្យរួចចាកសព្ទថា គាមោ ។ ឯក្នុងវិគ្គហនៃបាដិទេសនីយៈ លោកពោលទុកមិនដូច តាម សព្ទ ដូច្នេះថា អន្តរឃរំ នាម រថិកា ព្យូហំ សង្ឃាដកំ ឃរំ ប្រែថា ច្រកបររថទៅមកបាន ច្រកមិនធ្លុះរហូតទៅ ផ្លូវ ៤ ដំបន់ ឬផ្លូវ ៣ ដំបន់ ទីផ្ទះ ឈ្មោះថា អន្តរឃរំ ។

ពួកទី ១ ឈ្មោះសារុប្ប មាន ២៦ សិក្ខាបទ ចប់

www.budinst.gov.kh www.elibraryofcambodia.org

ពួកទី ២ ឈ្មោះភោជនប្បដិសំយុត្ត មាន ៣០ សិក្ខាបទ ។

សិក្ខាបទ ជាបឋម សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងទទួលបិណ្ឌបាត ដោយគោរព គឺមិនធ្វើអាការដូចជាយកទៅចាក់ចោលដោយទំនង ។

សិក្ខាបទ ទំរប់ ២ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងចំណាំមើលតែក្នុងបាត្រ ហើយទទួលបិណ្ឌបាត គឺមិនមើលក្នុងទីនោះៗ ។

សិក្ខាបទ ទំរប់ ៣ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងទទួលបិណ្ឌបាត ឲ្យល្មមគ្នានឹងសម្ល ។ ដែលហៅថាសម្ល បានដល់ម្ហូបពីរយ៉ាងគឺ សម្លសណ្តែកបាយ ១ សម្លសណ្តែកកជមាស ១ ដែលគេនឹងនាំទៅដោយដៃបាន ។ សម្លដែលមានប្រមាណប៉ុនភាគទី ៤ នៃភត្ត មានក្នុងបិណ្ឌបាតណា បិណ្ឌបាតនោះ ឈ្មោះថាមានសម្លល្មមប្រមាណ ។ កាលទទួលសម្លឲ្យលើសប្រមាណនោះ ត្រូវទុក្កដ ។ ទទួលសម្លហើយដោយសាច់នឹងត្រីនឹងស្លឹកឈើ ក្រៅអំពីសម្លសណ្តែកឲ្យច្រើន ឬទទួលសម្លសណ្តែក អំពីញាតិនឹងមនុស្សបវារណា ឬទទួលដើម្បីដទៃ ឬផ្លាស់ប្តូរដោយទ្រព្យរបស់ខ្លួន សូម្បីច្រើនក៏មិនត្រូវអាបត្តិ ។

សិក្ខាបទ ទំរប់ ៤ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងទទួលបិណ្ឌបាតដែលជាយាវកាលិកណាមួយ ឲ្យស្មើត្រឹមកណ្តាប់មាត់បាត្រ មិនឲ្យកំពូលហៀរលើសកណ្តាប់មាត់បាត្រខាងក្នុងនៃបាត្រ

www.budinst.gov.kh www.elibraryofcambodia.org

ដែលគួរអធិដ្ឋាន ។ ក៏ឯបាត្រដែលតូចនឹងធំមិនគួរអធិដ្ឋាន សូម្បី យាវកាលិក នឹងពេញកំពូនឡើងមកក្តី នឹងបាត្រដែលគួរអធិដ្ឋាន ឬ មិនគួរអធិដ្ឋានក៏ដោយ សូម្បីយាមកាលិក សត្តាហកាលិក យាវជីវិក នឹងពេញកំពូនឡើងមកក្តីក៏គួរ ។ ភិក្ខុទទួលរបស់ណាតែបាត្រ ហើយ ផ្សំដាក់ចុះក្នុងបាត្រ ១ ហើយបញ្ជូនមកវត្តក្តី ឬនំ កំណាត់អំពៅ ផ្លែឈើជាដើមណា ដែលគេដាក់ចុះកំពូនឡើង សូម្បីរលាក់ក៏ស្រុតចុះ ទៅ ឬគេយកស្លឹកគ្រក់ញជាដើម ដាក់ទាំងលើប្រគេន ឬរបស់ណា ដែលគ្របដោយស្លឹកឈើ ឬបាន គេផ្ទួសដាក់ហើយដំកល់លើមាត់ បាត្រក្តី របស់ទាំងអម្បាលនេះ ឈ្មោះថាពូនកំពូន ជាកំពូល ក៏មិន មែន ព្រោះហេតុដូច្នោះ ទទួលរបស់ទាំងពួងនោះ ក៏គួរ ។ ក្នុង សិក្ខាបទនេះ សូម្បីភិក្ខុឈឺក៏មិនរួចអាបត្តិ ទទួលពូនកំពូនមាត់បាត្រ មិនស្មើក្នុងទីទាំងពួង តែថាទទួលហើយ ក៏ឈ្មោះថាទទួលដោយប្រពៃ នឹងឆាន់ក៏គួរ ។

សិក្ខាបទ គំរប់ ៥ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹង ឆាន់បិណ្ឌបាតដោយគោរព គឺតាំងសតិទុកដោយប្រពៃ ។

សិក្ខាបទ គំរប់ ៦ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹង សំគាល់តែក្នុងបាត្រ គឺឆាន់បិណ្ឌបាត មិនក្រឡេកមើលក្នុងទីនោះៗ ។

សិក្ខាបទ គំរប់ ៧ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹង

www.budinst.gov.kh www.elibraryofcambodia.org

ឆាន់បិណ្ឌបាត ប្រមូលឲ្យស្មើដោយលំដាប់ ។ គឺមិនធ្វើបាយឲ្យខូចចុះទៅក្នុងទីនោះៗ ។ គឺនឹងឲ្យបាយទៅអ្នកដទៃ ឬនឹងដាក់បាយចុះទៅក្នុងភាជនៈដទៃ សង្កត់ឲ្យខូចទៅក្នុងទីនោះៗក្តី ឬតាប់បិទម្ហូបមិនជាលំដាប់ចុះទៅក្តី មិនត្រូវអាបត្តិ ។

សិក្ខាបទ គំរប់ ៨ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងឆាន់បិណ្ឌបាតឲ្យល្មមគ្នានឹងសម្ល ។ បើសម្លសណ្តែកត្រូវឲ្យស្មើភាគគំរប់ ៤ នៃបាយ ដូចពោលមកហើយអំពីមុន ។ ក្នុងសម្លសាច់ សម្លត្រី ឬសម្លសណ្តែករបស់ញាតិ របស់បវារណា ឬដូរមកដោយទ្រព្យរបស់ខ្លួន សូម្បីឆាន់ច្រើន ក៏មិនត្រូវអាបត្តិ ។

សិក្ខាបទ គំរប់ ៩ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនប្រមគ្រនីកំពូលបាយ ហើយឆាន់បិណ្ឌបាត ។ គឺមិនប្រមចុចចុះទៅត្រង់កណ្តាល ១ យ៉ាង ។ បាយតិចបោសប្រមូលបាយជាកំពូល តាប់ឆាន់មិនត្រូវអាបត្តិ ។

សិក្ខាបទ គំរប់ ១០ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនយកបាយបិទលុបសម្ល ឬម្ហូប ដោយអាស្រ័យសេចក្តីប្រាថ្នាចង់បានច្រើន ។ សូម្បីភិក្ខុឈឺក៏មិនរួចអាបត្តិ ។ ក្នុងមហាឃាតសម័យកាលហាមមិនឲ្យសម្លាប់សត្វ ទាយកគេបិទលុបឲ្យឯង ឬមិនអាស្រ័យសេចក្តីចង់បានច្រើន បិទលុបឯងក្តី មិនត្រូវអាបត្តិ ។

www.budinst.gov.kh www.elibraryofcambodia.org

សិក្ខាបទ ទី ១១ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងមិនឈឺនឹងមិនសូមសម្ល ឬបាយដើម្បីឆាន់ខ្លួនឯង ៗ សូមអំពីញាតិនឹងមនុស្សបវារណា ឬសូមដើម្បីអ្នកដទៃ ឬផ្លាស់ប្តូរយកដោយទ្រព្យរបស់ខ្លួនឯង មិនត្រូវអាបត្តិ ៗ

សិក្ខាបទ ទី ១២ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនសំគាល់ដើម្បីលើកទោស ហើយរមិលមើលបាត្រភិក្ខុដទៃ ៗ សូម្បីភិក្ខុឈឺ មិនរួចអាបត្តិ ៗ រមិលមើលដោយគិតថានឹងថែមរបស់អោយ ឬអោយអ្នកដទៃអោយ ឬរមិលមើលដោយមិនគិតនឹងលើកទោស មិនត្រូវអាបត្តិ ៗ

សិក្ខាបទ ទី ១៣ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនធ្វើពំនូតបាយអោយធំពេក ៗ ពំនូតបាយប៉ុនពងក្ងោក ឈ្មោះថាធំពេក តូចជាងនោះឈ្មោះថាមិនធំពេក ៗ ក្ដនរបស់ទំពាស៊ីទាំងពួង ជាដើមថាឫសឈើ ឬផលាផលនឹងសម្ល សូម្បីចំណុកធំ មិនត្រូវអាបត្តិ ៗ

សិក្ខាបទ ទី ១៤ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងធ្វើពំនូតបាយអោយជាបរិមណ្ឌល គឺអោយមូល មិនអោយវែង ៗ ក្ដនរបស់ជាខាទនីយៈទាំងពួង នឹងផលាផល នឹងសម្លសណ្តែក ជាអនាបត្តិ ៗ

សិក្ខាបទ ទី ១៥ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា កាលពំនូតបាយមិនទាន់មកដល់មាត់ យើងនឹងមិនហាមាត់ទុកមុន ៗ

សិក្ខាបទ ទី ១៦ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើង

www.budinst.gov.kh www.elibraryofcambodia.org

កាលដាក់បាយទាំងមិនញាក់ម្រាមដៃទាំងអស់ចូលទៅក្នុងមាត់ ។ ក្នុងដីកាថា ហត្ថំ សព្វំ ក្នុងទីនេះ ឲ្យគប្បីឃើញក្នុងម្រាមដៃ ដោយឯក-ទេសនៃដៃ ដូចក្នុងពាក្យថា ហត្ថមុទ្ទា ព្រោះហេតុនោះទាំងសិក សូម្បីម្រាមមួយ ឬឯកទេសនៃម្រាមនោះចូលទៅក្នុងមាត់ មិនគួរ ។

សិក្ខាបទ ទី១៧ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងមានពំនូតបាយក្នុងមាត់ នឹងមិននិយាយ ។ ព្រោះថាពំនូតបាយមាននៅក្នុងមាត់ ពាក្យនិយាយនឹងមិនច្បាស់ បើនិយាយត្រូវអាបត្តិ ។ ភិក្ខុណាសំដែងធម៌ មានសម៉ជាដើមនៅក្នុងមាត់ សំដែងទៅដោយសម៉ប៉ុន្មានពាក្យបរិបូណ៌ពិត បៀមសម៉តែត្រឹមប៉ុណ្ណោះ មាននៅក្នុងមាត់ ក៏គួរ ។

សិក្ខាបទ ទី១៨ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងមិនបោះពំនូតបាយ ចូលទៅក្នុងមាត់ឆាន់ ។ ក្នុងរបស់ទំពាស៊ីនឹងផលាផល ជាអនាបត្តិ ។

សិក្ខាបទ ទី១៩ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងមិនដាច់ខាំកាត់ពំនូតបាយ ។ ក្នុងសម្ងនឹងរបស់ទំពាស៊ីនឹងផលាផលជាអនាបត្តិ ។

សិក្ខាបទ ទី២០ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងឆាន់នឹងមិនធ្វើពំនូតបាយ ឲ្យពេញក្នុងថ្ពាល់ដូចពានរ ។ ក្នុងផលា-ផលជាអនាបត្តិ ។

www.budinst.gov.kh www.elibraryofcambodia.org

សិក្ខាបទ តំរប់ ២១ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនឆាន់រលាស់ដៃ ។ បើបេះកាកកញ្ចាក់ បេះសម្រាមចោល រលាស់ដៃ មិនត្រូវអាបត្តិ ។

សិក្ខាបទ តំរប់ ២២ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនឆាន់ធ្វើគ្រាប់បាយឲ្យធ្លាក់ពេយពាយ ។ បើបេះកាកកញ្ចាក់នឹងសម្រាមចោល គ្រាប់បាយធ្លាក់ចុះ មិនត្រូវអាបត្តិ ។

សិក្ខាបទ តំរប់ ២៣ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនឆាន់លៀនអណ្តាតចេញមក ។

សិក្ខាបទ តំរប់ ២៤ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនឆាន់ធ្វើសំឡេងឲ្យឮចបៗ ។

សិក្ខាបទ តំរប់ ២៥ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនឆាន់ធ្វើសំឡេងឮសូរគ្រូកៗ ។

សិក្ខាបទ តំរប់ ២៦ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនឆាន់លិទ្ធដៃ ។ កាលកំពុងឆាន់ សូម្បីនឹងលិទ្ធតែម្រាមដៃក៏មិនគួរ ។ ក៏ឯនឹងចាប់បាយទន់ ទឹកអំពៅ បាយបាយាសជាដើម ដែលស្អិតជាប់ដោយម្រាមដៃ ហើយសិតម្រាមដៃចូលទៅក្នុងមាត់ ក៏គួរ ។

សិក្ខាបទ តំរប់ ២៧ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនឆាន់លិទ្ធបាត្រ ។ បើកាលបើបោសបាយ ដែលសល់នៅបន្តួចបន្តិច ប្រមូលមកដើម្បីនឹងឆាន់ មិនត្រូវអាបត្តិ ។

www.budinst.gov.kh www.elibraryofcambodia.org

សិក្ខាបទ ទី២៨ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងមិនបាច់លិទ្ធបបូរមាត់ សូម្បីតែម្ខាងដោយអណ្ដាត ៗ គឺឯនឹងលិទ្ធបបូរមាត់ឲ្យអាមិសដែលជាប់នៅបូលទៅក្នុងមាត់វិញ ក៏គួរ ៗ

សិក្ខាបទ ទី២៩ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងមានដៃប្រឡាក់ដោយអាមិស នឹងមិនចាប់កាន់ភាជនៈដាក់ទឹកផឹក ៗ សេចក្ដីដែលហាមនេះ ព្រោះដៃប្រឡាក់អាមិសជាបដិកូល ព្រោះហេតុនោះ សូម្បីស័ង្ខនឹងផ្ដិលនឹងស្បៀនដាក់ទឹកជារបស់សង្ឃ ឬរបស់បុគ្គល ឬរបស់គ្រហស្ថ ឬរបស់ខ្លួនឯងក្ដី កុំគប្បីចាប់ពាល់ឡើយ កាលបើចាប់ពាល់ ត្រូវទុក្កដ ៗ បើឯកទេសនៃដៃម្ខាងដែលអាមិសមិនប្រឡាក់មាននៅសោត នឹងចាប់ដោយឯកទេសនៃដៃនោះក៏គួរ គិតថានឹងលាង ឬនឹងឲ្យគេលាង ហើយនឹងចាប់ពាល់ មិនត្រូវអាបត្តិ ៗ

សិក្ខាបទ ទី៣០ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងមិនចាក់ទឹកលាងបាត្រទាំងគ្រាប់បាយចុះក្នុងលំនៅក្នុងភូមិ ៗ បើរើសគ្រាប់បាយឡើងអំពីទឹកប្រមូលទុកមួយអន្លើ ហើយចាក់តែទឹក ឬញីគ្រាប់បាយឲ្យល្អិតទៅក្នុងទឹកហើយចាក់ចោល ឬចាក់ក្នុងកន្ថោរ ហើយយកទៅចាក់ចោល ឬនាំទៅចាក់ចោលខាងក្រៅ ទាំងអម្បាលនេះ មិនត្រូវអាបត្តិ ៗ

សិក្ខាបទ ទាំង ៣០ នេះ ភិក្ខុណា អាស្រ័យសេចក្ដីមិនអើពើ ក្នុង

www.budinst.gov.kh www.elibraryofcambodia.org

ប្រព្រឹត្តកន្លងត្រូវអាបត្តិទុក្កដ ។ មិនក្លែង មិនមានសតិ មិនដឹងខ្លួន មានជម្ងឺ មានអន្តរាយ ខឹងភិក្ខុឆ្កួតជាដើម មិនត្រូវអាបត្តិ គ្រប់សិក្ខាបទ ។ តែភិក្ខុឈឺនោះជាអនាបត្តិ ក្នុងសិក្ខាបទ ២៦ វៀរតែទទួលពេញកំពុងមាត់បាត្រ ខឹងឆាន់ប្រមូលពំនូតបាយឲ្យខ្ទង់ចុះទៅ ខឹងយកបាយបិទលុបសម្ងំខឹងរមិលមើលបាត្រភិក្ខុដទៃ ដើម្បីខឹងលើកទោស តាំង ៤ សិក្ខាបទនេះចេញ ។

ពួកទី ២ ឈ្មោះភោជនប្បដិសំយុត្ត មាន ៣០ សិក្ខាបទ ចប់

---

ធម្មទេសនាបដិសំយុត្ត មាន ១៦ សិក្ខាបទ ៖

សិក្ខាបទ ជាបឋម សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងខឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ មានឆត្រនៅក្នុងដៃ ។ គេតម្កល់ឆត្រទុកលើអវយវៈ នៃសរីរៈណាមួយ គេមិនទាន់លែងអំពីដៃ នេះឈ្មោះថាមានឆត្រក្នុងដៃ ។ ខឹងសំដែងធម៌ដល់អ្នកនោះមិនគួរ ។ បើអ្នកដទៃគេបាំងឲ្យ ឬឆត្រផ្អែកទុកខាងខ្លួន ល្មមតែឆត្រផុតចេញពីដៃហើយ ឈ្មោះថាមនុស្សមិនមានឆត្រក្នុងដៃ ។ ខឹងសំដែងធម៌ដល់អ្នកនោះក៏គួរ ។ ឯការកំណត់ធម៌ក្នុងសិក្ខាបទនេះ គប្បីដឹងដោយន័យដូចសំដែងហើយ ក្នុងបទសោធម្មសិក្ខាបទនោះចុះ ។

សិក្ខាបទ គំរប់ ២ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងខឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ មានដំបងនៅក្នុងដៃ ។ ក៏ណា

www.budinst.gov.kh www.elibraryofcambodia.org

ឈើប្រវែង ៤ ហត្ថ នៃមធ្យមបុរស ហៅថាដំបង បើវែងឬខ្លីជាងនេះ មិនហៅថាដំបងទេ ។ ឯសេចក្តីថា មនុស្សមានដំបងនៅក្នុងដៃនេះ គប្បីដឹងដោយន័យដូចសំដែងហើយ ក្នុងមនុស្សមានឆត្រនៅក្នុងដៃនោះចុះ ។

សិក្ខាបទ គំរប់ ៣ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ មានគ្រឿងសស្ត្រានៅក្នុងដៃ ។ ឯសស្ត្រានោះ ទោះមានមុខមុតម្ខាងក្តី ទាំងសងខាងក្តី ដោយលក្ខណៈដូចពោលហើយក្នុងសិក្ខាបទមុន ។ បុគ្គលគ្រាន់តែស្ពាយ ឬសៀតដាវឈរនៅ មិនរាប់ថាមនុស្សមានសស្ត្រាក្នុងដៃ ។

សិក្ខាបទ គំរប់ ៤ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ មានអាវុធនៅក្នុងដៃ ។ ធ្នូវិសេស ទាំងតួន ទាំងព្រួញផង ឈ្មោះថាអាវុធ ។ ព្រោះហេតុនោះ អ្នកកាន់ធ្នូទាំងព្រួញផង ឬកាន់តែដងធ្នូទទេ ឬកាន់តែព្រួញទទេក្តី ឬកាន់ធ្នូមានបន្ទោះ ឬមិនមានបន្ទោះក្តី អង្គុយក្តី ឈរក្តី នឹងសំដែងធម៌ដល់អ្នកនោះមិនគួរ ។ បើអ្នកនោះស្ពាយយកធ្នូពាក់ចុះខ្ទៅក មិនទាន់ចាប់ធ្នូមុន នឹងសំដែងធម៌ឲ្យក៏គួរ ។ គ្រឿងប្រហារមានមុខមុត ឈ្មោះថាសស្ត្រា មិនមានមុខមុត ឈ្មោះថាអាវុធ ព្រោះហេតុនោះ សូម្បីធ្នូខ្វៃកនឹងកាំភ្លើង ឈ្មោះថាអាវុធ ។

www.budinst.gov.kh www.elibraryofcambodia.org

សិក្ខាបទ គំរប់ ៥ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ ពាក់ទ្រនាប់ជើងសំរាប់ដើរ ។ សូម្បីមិនបានដាក់ចង្កៀកជើងចុះក្នុងបង្កោល គ្រាន់តែជាន់ ឬពាក់ ឬដោះបន្ធូរកែងបន្តិចក្ដី ក៏ឈ្មោះថាឡើងកាន់ស្បែកជើង ។

សិក្ខាបទ គំរប់ ៦ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ ពាក់ស្បែកជើង ។ ឯវិធីពាក់ដូចពោលហើយក្នុងទ្រនាប់ជើង សូម្បីស្រាយខ្សែចងកែងជើងចេញហើយឈរនៅ ក៏ឈ្មោះថាឡើងកាន់ស្បែកជើង នឹងសំដែងធម៌ដល់អ្នកនោះមិនគួរ ។ ស្បែកជើងធ្វើដោយឈើទឹងស្មៅជាដើម ហៅថាទ្រនាប់ជើង ស្បែកជើងធ្វើដោយស្បែក ហៅថាស្បែកជើង ។

សិក្ខាបទ គំរប់ ៧ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ នៅលើយាន ។ រថ រទេះ អង្រឹងស្នែង គ្រែស្នែងជាដើម ឈ្មោះថាយាន ។ សូម្បីមនុស្សពីរនាក់យកដៃកាន់គ្នាឲ្យជិះទៅក្ដី ឬឲ្យអង្គុយក្នុងអង្រឹងសំពត់ ស្ពាយទៅក្ដី ឬអង្គុយក្នុងយានដែលគេមិនបានទឹម សូម្បីនឹងអង្គុយលើគន្លងរទេះដែលគេលើកដោះចេញទុកដាក់ក្ដី ឈ្មោះថានៅលើយានទាំងអស់ ។ បើមនុស្សពីរនាក់អង្គុយក្នុងយានជាមួយគ្នា នឹងសំដែងធម៌ដល់គ្នានឹងគ្នាក៏គួរ សូម្បីអង្គុយលើយានៈផ្សេងគ្នា អ្នកអង្គុយលើយានខ្ពស់ នឹងសំដែងធម៌ឲ្យអ្នកអង្គុយក្ន

www.budinst.gov.kh www.elibraryofcambodia.org

យានតាមក៏គួរ សូម្បីភិក្ខុនីយានប្រមាណស្មើគ្នាក៏គួរ អ្នកអង្គុយក្នុងយានមុខ ទឹងសំដែងធម៌ឲ្យអ្នកអង្គុយក្នុងយានក្រោយក៏គួរ ។ អ្នកអង្គុយក្នុងយានក្រោយ សូម្បីខ្ពស់ជាងក៏ដោយ ទឹងសំដែងធម៌ដល់អ្នកអង្គុយក្នុងយានមុខ មិនគួរ ។

សិក្ខាបទ គំរប់៨ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ ហើយដេក ។ ភិក្ខុទឹងឈរ ឬអង្គុយលើគ្រែ លើតាំង ឬលើផែនដី សូម្បីខ្ពស់ ទឹងសំដែងធម៌ដល់មនុស្សដែលដេក ដោយហោចទៅ សូម្បីលើកន្ទេល ឬលើផែនដីប្រក្រតី មិនគួរ ។ ឯអ្នកដេកទឹងសំដែងធម៌ដល់អ្នកដេកផងគ្នាក៏គួរ តែដេកក្នុងទីខ្ពស់ជាង ឬស្មើគ្នាទើបគួរ ។ ក៏ឯអ្នកដេកទឹងសំដែងឲ្យអ្នកឈរ ឬអង្គុយ ឬដេកក្តី ឬអង្គុយទឹងសំដែងឲ្យអ្នកឈរ ឬអង្គុយផងគ្នាក្តី អ្នកឈរទឹងសំដែងដល់អ្នកឈរផងគ្នាក្តី ទាំងអស់នេះគួរ ។

សិក្ខាបទ គំរប់៩ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ ដែលអង្គុយគ្របោមក្បាលផ្តន់ដោយដៃ ឬដោយសំពត់ណាមួយ ។

សិក្ខាបទ គំរប់១០ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ ដែលមានក្បាលព័ទ្ធព័ទ្ធដោយសំពត់ជាដើម ទាល់តែជើងសក់មិនប្រាកដ ។ ឲ្យគេបើកឲ្យឃើញជើងសក់ហើយទើបសំដែង មិនត្រូវអាបត្តិ ។

www.budinst.gov.kh www.elibraryofcambodia.org

សិក្ខាបទ គំរប់ ១១ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ ដែលមានក្បាលខ្ទប់ទាំងអស់ ។ ឲ្យគេបើកសំពត់ខ្ទប់ក្បាលចេញហើយទើបសំដែង មិនត្រូវអាបត្តិ ។

សិក្ខាបទ គំរប់ ១២ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងអង្គុយលើផែនដី នឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ ដែលអង្គុយលើអាសនៈគ្រឿងកំរាល ដោយហោចទៅ សូម្បីសំពត់ ឬស្មៅ មិនគួរ ។

សិក្ខាបទ គំរប់ ១៣ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងអង្គុយលើអាសនៈទាប នឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ ដែលអង្គុយលើអាសនៈខ្ពស់ជាង ដោយហោចទៅ សូម្បីតែផែនដីខ្ពស់ក្តី ក៏មិនគួរ ។

សិក្ខាបទ គំរប់ ១៤ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងឈរ នឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺដែលអង្គុយស្តាប់ ។ ក្នុងសិក្ខាបទនេះ ព្រះអដ្ឋកថាចារ្យលោកពោលទុកថា សូម្បីភិក្ខុកម្លោះទៅកាន់ទីឧបដ្ឋាកព្រះថេរៈ ហើយភិក្ខុកម្លោះឈរ បើព្រះមហាថេរអង្គុយលើអាសនៈសួរបញ្ហាសោត ភិក្ខុកម្លោះកុំគប្បីសំដែងឡើយ ។ បើភិក្ខុកម្លោះមិនអាចពោលនឹងព្រះថេរៈថា សូមព្រះករុណាក្រោកឡើងហើយសឹមសួរ ដោយសេចក្តីគោរពក្នុងព្រះថេរៈ ហេតុនោះ ទើបគិតថាយើងនឹងសំដែងដល់ភិក្ខុកម្លោះដែលឈរនៅជិតខាងជួរនេះ ហើយសំដែង ក៏គួរ ។

សិក្ខាបទ គំរប់ ១៥ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើង

www.budinst.gov.kh www.elibraryofcambodia.org

ដើរទៅខាងក្រោយ នឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ ដែលដើរទៅខាងមុខ ។ ក្នុងសិក្ខាបទនេះ ព្រះអដ្ឋកថាចារ្យលោកពោលទុកថា បើអ្នកដើរទៅខាងមុខសួរបញ្ហាសោត កុំគប្បីសំដែង ។ ត្រូវគិតថា យើងនឹងសំដែងដល់អ្នកមកតាមក្រោយដូច្នេះហើយគប្បីសំដែងចុះ ។ នឹងស្វាធ្យាយធម៌ដែលរៀនមកជាមួយគ្នា ឬនឹងសំដែងដល់អ្នកដើរទៅទន្ទឹមគ្នាក៏គួរ ។

សិក្ខាបទគំរប់ ១៦ សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងដើរទៅក្រៅផ្លូវ នឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ ដែលដើរទៅក្នុងផ្លូវ ។ សូម្បីក្នុងផ្លូវនេះ ភិក្ខុពីរអង្គដើរទន្ទឹមគ្នាទៅតាមផ្លូវនេះ មួយអង្គខាង ឬក្រៅផ្លូវដូចគ្នា នឹងសំដែង ក៏គួរ ។

សិក្ខាបទទាំង ១៦ នេះ ភិក្ខុណា អាស្រ័យសេចក្តីមិនអើពើ ក្លែងប្រព្រឹត្តកន្លងត្រូវអាបត្តិទុក្កដ ។ មិនក្លែង មិនមានសតិ មិនដឹងខ្លួន អ្នកដែលស្តាប់មានជម្ងឺ មានអន្តរាយ នឹងភិក្ខុឆ្កួតជាដើម មិនត្រូវអាបត្តិគ្រប់សិក្ខាបទ ។

ពួកទី ៣ ឈ្មោះធម្មទេសនាបដិសំយុត្ត មាន ១៦ សិក្ខាបទ ចប់

---

## ពួកទី ៤ ឈ្មោះបកិណ្ណកៈមាន ៣ សិក្ខាបទ ។

សិក្ខាបទ ជាបឋម សេចក្តីថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា យើងមិនឈរ នឹងមិនឈរបន្ទោបង់ឧច្ចារៈបស្សាវៈ ។ បើភិក្ខុទៅរកទីកំបាំងមិនទាន់ ឧច្ចារៈបស្សាវៈហៀរហូរមកមុន ឈ្មោះថាមិនក្លែង មិនត្រូវអាបត្តិ ។

www.budinst.gov.kh www.elibraryofcambodia.org

សិក្ខាបទ ទី ២ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងមិនឈឺ យើងមិនបន្ទោបង់ឧច្ចារៈបស្សាវៈ ឬស្ដោះទឹកមាត់ ញើសទឹកសំបោរ ចុះក្នុងទីមានវត្ថុខៀវគឺដើមឈើ ដើមស្មៅ ដែលស្រស់ សូម្បីចុងឈើ ដែលសេរះទៅលើដីឃើញប្រាកដ ឬមែកឈើដែលពន្លកជាប់ដីទៅក្ដី ទាំងអម្បាលនេះរាប់ថាជារបស់ខៀវទាំងអស់ ។ ឯយើងឡើងអង្គុយលើដើមឈើ បន្ទោបង់ឧច្ចារៈបស្សាវៈចុះ ក្នុងទីមិនមានវត្ថុខៀវនោះក៏គួរ ។ បើដើរទៅរកទីប្រាសចាកវត្ថុខៀវ នោះបើឧច្ចារៈបស្សាវៈហៀរហូរមកជាមុនសោត ឈ្មោះថាបិតនៅក្នុងកាលជាមនុស្សឈឺ មិនមានទោស ។ សូម្បីរកទីប្រាសចាកវត្ថុខៀវមិនបាន គប្បីយកអង្កេលស្មៅ ឬស្លឹកឈើរងហើយបន្ទោបង់ចុះ សូម្បីឧច្ចារៈបស្សាវៈហូរទៅសន្ធឹកលើវត្ថុខៀវជាក្រោយ ក៏គួរដោយពិត ។

សិក្ខាបទ ទី ៣ សេចក្ដីថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា យើងមិនឈឺ យើងមិនបន្ទោបង់ឧច្ចារៈបស្សាវៈ ស្ដោះទឹកមាត់ ញើសសំបោរ ចុះក្នុងទឹក ។ ទឹកនោះសង្គ្រោះយកទឹកដែលបរិភោគប្រើប្រាស់បាន ។ ទឹកក្នុងវច្ចកុដិជាដើមដែលបរិភោគមិនបាន មិនត្រូវអាបត្តិ ។ ភ្លៀងធ្លាក់ ជន់ ជន់ ទឹកលិចទៅទាំងអស់ រកទីទួលមិនបាន ទើបបន្ទោបង់ចុះក្នុងទឹកនោះក៏គួរ បន្ទោបង់ចុះលើគោក ឧច្ចារៈបស្សាវៈហៀរហូរទៅក្នុងទឹក មិនត្រូវអាបត្តិ ។

www.budinst.gov.kh www.elibraryofcambodia.org

សិក្ខាបទទាំង ៣ នេះ ភិក្ខុណា អាស្រ័យសេចក្តីមិនអើពើ ក្លែងប្រព្រឹត្តកន្លងត្រូវអនាទរិយទុក្កដ ។ មិនក្លែង មិនមានសតិ មិនដឹងខ្លួន ឈឺ មានអន្តរាយ និងភិក្ខុឆ្កួតជាដើម មិនត្រូវអាបត្តិ គ្រប់សិក្ខាបទ ។

ពួកទី ៤ ឈ្មោះបកិណ្ណកៈមាន ៣ សិក្ខាបទ ចប់

---

សើចខ្លាំង ២ និយាយសំឡេងខ្លាំង ២ និយាយទាំងចំណុកបាយ ១ ជា ៥ សិក្ខាបទ អង្គុយលើផែនដី សំដែងធម៌ដល់មនុស្សអង្គុយលើអាសនៈ ១ អង្គុយលើអាសនៈទាប សំដែងធម៌ដល់មនុស្សអង្គុយលើអាសនៈខ្ពស់ ១ ឈរសំដែងធម៌ដល់មនុស្សអង្គុយ ១ ដើរខាងក្រោយសំដែងធម៌ដល់មនុស្សដើរទៅខាងមុខ ១ ដើរក្រៅផ្លូវសំដែងធម៌ដល់មនុស្សដើរទៅក្នុងផ្លូវ ១ ជា ៥ សិក្ខាបទ ផ្សំគ្នាត្រូវជា ១០ សិក្ខាបទ ទាំង ១០ សិក្ខាបទនេះ ជាសមនុភាសនសមុដ្ឋាន គឺអាបត្តិកើតអំពីកាយ-វាចាចិត្ត ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ទុក្ខវេទនា គ្រប់សិក្ខាបទ ។

សូបោទនវិញ្ញត្តិសិក្ខាបទ សូមសម្ល សូមបាយ ជាថេយ្យសត្ថសមុដ្ឋាន អាបត្តិកើតអំពីកាយចិត្ត កើតអំពីកាយវាចាចិត្ត ជាកិរិយា សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ កាយកម្ម វចីកម្ម អកុសលចិត្ត ទុក្ខវេទនា ។

www.budinst.gov.kh www.elibraryofcambodia.org

សំដែងធម៌ដល់មនុស្សមានឆត្រក្នុងដៃ មានដំបងក្នុងដៃ មានសស្ត្រាក្នុងដៃ មានអាវុធក្នុងដៃ ពាក់ទ្រនាប់ជើង ពាក់ស្បែកជើង មនុស្សនៅលើយាន មនុស្សដេក មនុស្សអង្គុយក្របោមក្បាលជង្គង់ មនុស្សជួតក្បាល មនុស្សទទូរក្បាល ១១ សិក្ខាបទនេះ ជាធម្មទេសនា. សមុដ្ឋាន គឺអាបត្តិកើតអំពីវាចាចិត្ត ជាកិរិយាកិរិយៈ សញ្ញាវិមោក្ខ សចិត្តកៈ លោកវជ្ជៈ វចីកម្ម អកុសលចិត្ត ទុក្ខវេទនា គ្រប់សិក្ខាបទ ។ ក្រៅអំពីនោះ ៧៣ សិក្ខាបទ មានសមុដ្ឋានវិធីជាដើម ដូចបឋមបារាជិក ។

មួយទៀត ក្នុងសេខិយៈនេះ មានដើមឧទ្ទេសនិងកុងឧទ្ទេសក្នុងបាតិមោក្ខ មិនមានសំខ្យាកំណត់ថា ៧៥ ទេ បញ្ញត្តិសេខិយា ធម្មា ដូច្នេះទេ ថាតែ ៧៥ ទេ សេខិយា ធម្មា ប៉ុណ្ណោះ ដែលមិនកំណត់នោះ សំដែងសេចក្ដីថា ឯវិធីដែលភិក្ខុនឹងគប្បីសិក្សានឹងមានតែប៉ុណ្ណោះក៏ទេ សូម្បីវត្តដែលព្រះពុទ្ធអង្គទ្រង់បញ្ញត្តទុកក្នុងវត្តខន្ធក៏ឈ្មោះថាសេខិយៈ ព្រោះជាវត្តដែលភិក្ខុគប្បីសិក្សា មួយទៀត ដែលមិនកំណត់នោះ ដើម្បីនឹងសំដែងថាវត្តន័យផង ។

សេខិយុទ្ទេសចប់

# ចីវរបដិសំយុត្តកថា

ពណ៌នាអំពីបញ្ញត្តិនៃទុក្កដាបត្តិ ដែលមានមកក្នុងខន្ធកៈជាដើម តាមលំដាប់បុព្វសិក្ខា និងថែមបញ្ចូលខ្លះ ៗ ក្នុងបញ្ញត្តិដែលមានមកក្នុងបុព្វសិក្ខា និងពោលថា ខមួយ ៗ ក្នុងពុទ្ធប្បញ្ញត្តិដែលថែមបញ្ចូលនឹងពោលថា ខមួយទៀត ឲ្យជាទីសង្កេត ៗ ហើយនឹងអញ្ជើញព្រះពុទ្ធប្បញ្ញត្តិដែលមានមកក្នុងខន្ធកៈនោះ ៗ និងមានមកក្នុងវិនីតវត្ថុជាដើម មករៀបរៀងពោលដោយន័យ ដើម្បីនឹងឲ្យយល់ ៕

សំដែងចីវរបដិសំយុត្តកថាជាមុន ៗ ខមួយ គឺភិក្ខុកុំគប្បីស្លៀកដូចគ្រហស្ថ ដ្បិតព្រះទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ គិហិនិវត្ថំ និវាសេតព្វំ ហត្ថិសោណ្ឌកំ មច្ឆវាឡកំ ចតុក្កណ្ណកំ តាលវណ្ដកំ សតវលិកំ យោ និវាសេយ្យ អាបត្តិ ទុក្កដស្ស សេចក្តីថា ភិក្ខុកុំគប្បីស្លៀកដូចគ្រហស្ថ បើស្លៀកដូចគ្រហស្ថត្រូវទុក្កដ ៗ ស្លៀកដូចគ្រហស្ថនោះដូច្នេះ ស្លៀកសំយុងចុះទៅពីផ្ចិត មានសណ្ឋានដូចប្រមោយដំរី ដូចសំលៀកនៃស្ត្រីក្នុងជោឡ-ប្រទេសក្តី ស្លៀកឲ្យទីបំផុតជាយម្ខាងនិងវង់ជាយម្ខាង សំយុងចុះទៅដូចកន្ទុយត្រីក្តី និងស្លៀកបួនមុំ គឺសំដែងមុំលើពីរ ខាងក្រោមពីរក្តី ទៀតស្លៀកឲ្យសំយុងចុះទៅ ដោយអាការដូចកំពូលត្នោត និងស្លៀកខ្ចប់សំពត់ដែលវែងឲ្យមានជាន់ច្រើនជាស្រទាប់ជាគ្របក ឬស្លៀកជា

www.budinst.gov.kh www.elibraryofcambodia.org

ល្វះជាព្រួញគេដោយលំដាប់គ្នាខាងវេងខាងស្តាំ មានត្របកស្រោបតាប់ច្រើន ប្រហាណមួយរយ ដូច្នេះ ឈ្មោះថាស្លៀកដូចគ្រហស្ថ មិនគួរ បើតាំងពី ជង្គង់ឡើងមកព្រួញគេជាល្វះ ១ ឬ ២ ក៏គួរ ។

ខមួយ ទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ សំវេល្លិយំ និវា. សេតព្វំ ជាភិក្ខុកុំគប្បីស្លៀកចងក្បិន ដោយអាការៈ ដូចអ្នកចំបាប់ និង អ្នកធ្វើការជាដើម បើស្លៀកចងក្បិនត្រូវទុក្កដ ។ ស្លៀកដូច្នេះសូម្បីមាន ជម្ងឺៈដើរផ្លូវក៏មិនគួរ ។ មនុស្សទាំងឡាយដើរផ្លូវទៅ គេលើកមុំសំពត់ ឡើងម្ខាងឬទាំងសងខាង ចុះខាងលើសំពត់ស្លៀកក្តី ស្លៀកសំពត់ខាង ក្នុងមួយជាន់ដូច្នោះ ហើយស្លៀកសន្ទត់មួយជាន់ខាងក្រៅៈទៀតក្តី ទាំង អម្បាលនេះ មិនគួរដល់ភិក្ខុ ។ ក៏ឯមានជម្ងឺ ក្នុងសំពត់ខឹងសំដែងឲ្យជា ល្វះខាងក្នុងៈហើយស្លៀកខាងលើមួយជាន់ទៀតក៏បាន មិនមានជម្ងឺ កាល ទឹងស្លៀកពីរជាន់ គប្បីតម្រួតគ្នាឲ្យជាជាន់ ហើយស្លៀកចុះ កិរិយាស្លៀក ដែលឃាត់ក្នុងបទនេះក្តី ក្នុងសេខិយៈក្តី ទាំងអម្បាលនេះ គប្បីវៀរ ចេញ គប្បីបិទមណ្ឌលបី ស្លៀកឲ្យជាបរិមណ្ឌល កុំឲ្យមានវិការៈ កាលបើភិក្ខុណា ធ្វើឲ្យមានវិការៈណាមួយ មិនរួចអាបត្តិទុក្កដ ។

ខមួយទៀត ភិក្ខុកុំគប្បីដណ្តប់ដូចគ្រហស្ថ ព្រោះទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ គិហិបារុតំ បារុបិតព្វំ ជាភិក្ខុកុំគប្បីដណ្តប់ដូចគ្រហស្ថ ៈបើដណ្តប់ត្រូវទុក្កដ ។ ដណ្តប់បទកាយពីខាងលើខាងក្រោម សំយុត្ត

www.budinst.gov.kh www.elibraryofcambodia.org

ដូចមិគ្រទ្ធក្តី នឹងដណ្តប់យកចីពរដាក់លើចង្កួយស្មាតាំងសងខាង ហើយបើកទ្រូងដូចបរិពាជកចំពូកខ្លះក្តី នឹងដណ្តប់យកជាយសំពត់ស្បៀកបិទខ្លួន យកជ្រុងតាំងសងខាងដាក់លើចង្កួយស្មាសងខាង ដូចមនុស្សមានសំពត់តែមួយក្តី នឹងដណ្តប់យកសំពត់ព័ទ្ធព័ទ្ធកសំយុងជាយតាំងពីរ ចុះមកខាងពោះ ឬបោះជាយតាំងពីរទៅខាងខ្នង ដូចអ្នកលេងស្រុកជាដើមក្តី នឹងដណ្តប់ទទូរតាំងអស់ សំដែងតែនំក្អក ដូចស្រ្តីក្តក្ទន់ជាដើម នឹងដណ្តប់សំពត់វែងយកជាយសំពត់ម្ខាងព័ទ្ធខ្លួនតាំងអស់ ដូចគហបតីអ្នកធំនឹងរុំជាយសំពត់សាជកចេញហើយសកចូលក្នុងក្លៀក ព័ទ្ធខ្លួនដោយជាយសំពត់ម្ខាង ដូចអ្នកស្រែនឹងចូលខ្ទមស្រែក្តី នឹងដណ្តប់យកសំពត់សកចូលក្នុងចន្លោះក្លៀកតាំងពីរដាក់ឡើងលើចង្កួយស្មា ដូចព្រាហ្មណ៍ក្តី នឹងដណ្តប់បើកដើមដៃឆ្វេង ដោយសំពត់ដណ្តប់ឆៀងស្មាម្ខាង នឹងឃុំហើយលើកចីវរឡើងដាក់លើចង្កួយស្មាម្ខាង ដូចភិក្ខុអ្នកតាត់វេនឲ្យអង្គុយចាស់ៗគ្នាជាលំដាប់ ដណ្តប់ដូច្នេះ ឬដណ្តប់យ៉ាងដទៃ ក្រៅតាមលក្ខណៈនៃបរិមណ្ឌលតាំងពួងនោះ ឈ្មោះថាដណ្តប់ដូចគ្រហស្ថតាំងអស់ ភិក្ខុកុំគប្បីដណ្តប់ដូច្នេះ គប្បីវៀរទោសនៃកិរិយាដណ្តប់តាំងពួងយ៉ាងនេះក្តី យ៉ាងដទៃក្រៅអំពីនេះក្តី ហើយគប្បីដណ្តប់ឲ្យជាបរិមណ្ឌលកុំឲ្យមានវិការៈ កាលមិនដណ្តប់ដូច្នោះ នឹងធ្វើឲ្យមានវិការៈណាមួយក្នុងទីគាម ឬក្នុងលំនៅក្នុងភូមិ ដោយសេចក្តីមិនអើពើ ត្រូវទុក្កដ ។

www.budinst.gov.kh www.elibraryofcambodia.org

ខមួយទៀត ភិក្ខុកុំគប្បីទ្រង់សំពត់មានពណ៌ផ្សេង ៗ មានពណ៌ខៀវជាដើម ដ្បិតព្រះពុទ្ធអង្គទ្រង់បញ្ញត្តទុកថា ន ភិក្ខវេ សព្វនីលកានិ ចីវរានិ ន សព្វបីតកានិ ន សព្វលោហិតកានិ ន សព្វមញ្ជេដ្ឋកានិ ន សព្វកណ្ហានិ ន សព្វមហារង្គរត្តានិ ន សព្វមហានាមរត្តានិ ន អច្ឆិន្នទសានិ ន ទីឃទសានិ ន បុប្ផទសានិ ន ផលទសានិ ន ផណទសានិ ចីវរានិ ធារេតព្វានិ ន កញ្ចុកំ ន តិរីដំ ន វេឋនំ ធារេតព្វំ សេចក្តីថា ភិក្ខុកុំគប្បីទ្រង់សំពត់ពណ៌ខៀវទាំងអស់ដូចផ្កាត្រកៀត ពណ៌លឿងទាំងអស់ដូចផ្កាកណ្ណិការ ពណ៌ក្រហមទាំងអស់ដូចផ្កាច្បា ពណ៌ក្រហមព្រឿងទាំងអស់ដូចចំបើង ពណ៌ខ្មៅទាំងអស់ដូចពណ៌ផ្លែផ្គាំ ពណ៌ក្រហមចាស់ទាំងអស់ដូចខ្នងក្អែប ពណ៌ក្រហមលាយត្នោតទាំងអស់ដូចស្លឹកឈើទុំ (ក្នុងអដ្ឋកថា ឈ្មោះកុរុវិន្ទ ថាពណ៌ដូចផ្កាឈូក) នឹងសំពត់មានជាយ មិនបានកាត់ សំពត់មានជាយវែង សំពត់មានជាយដូចផ្កាឈើ សំពត់មានជាយដូចផ្លែឈើ សំពត់មានជាយជាផែន នឹងអាវ នឹងមួក នឹងសំពត់ឈ្នួតក្បាល ភិក្ខុអង្គណាទ្រង់សំពត់ទាំងអម្បាលនេះ ត្រូវទុក្កដ ៗ សំពត់ខៀវជាដើម គប្បីគក់បេកទឹកជ្រលក់ចេញ ហើយជ្រលក់ជាថ្មី ស្បៀកដណ្តប់ចុះ បើមិនអាចនឹងគក់ចេញបាន ក៏គប្បីធ្វើជាសំពត់ក្រាលដេក ឬដាក់ក្នុងជាន់កណ្តាល

www.budinst.gov.kh www.elibraryofcambodia.org

ខែចីវរពីរជាន់ សំពត់មានជាយមិនបានកាត់ ទឹងមានជាយវែង គប្បីកាត់ជាយចេញស្លៀកដណ្ដប់ចុះ អាវ ទោ បានមកហែកវះចេញហើយជ្រលក់ប្រើប្រាស់ក៏គួរ សូម្បីក្នុងសំពត់ឈ្នួតក្បាលក៏ដូចគ្នា មួកដែលគេធ្វើដោយសម្បកឈើ គួរធ្វើជាសំពត់ជូតជើងបាន ។

១មួយទៀត សូម្បីសំពត់សម្បកធ្នៃ ក៏មិនគួរ ព្រោះទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ ចោដ្ឋកោ ធារេតព្វោ សេចក្ដីថា ភិក្ខុកុំគប្បីស្លៀកដណ្ដប់សំពត់សម្បកធ្នៃ បើស្លៀកត្រូវទុក្កដ ។ សំពត់ធ្វើដោយសម្បកកក់ សម្បកចេក សម្បកវែទឹកជាដើម ក៏មានគតិដូចសម្បកធ្នៃដោយពិត ។

១មួយទៀត ទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ ពាហិរៈលោមិ ឧណ្ណិ ធារេតព្វា សេចក្ដីថា ភិក្ខុគប្បីកុំស្លៀកដណ្ដប់សំពត់បាវះ ធ្វើដោយរោមចៀម ធ្វើឲ្យរោមចេញខាងក្រៅ បើដណ្ដប់ដូច្នោះត្រូវទុក្កដ ។ ដណ្ដប់ធ្វើឲ្យរោមចូលខាងក្នុងនោះគួរ ។

១មួយទៀត ភិក្ខុកុំគប្បីអង្គុយត្របោមជង្គង់ដោយសំពត់សង្ឃាដិ បើអង្គុយត្របោមដូច្នោះត្រូវទុក្កដ ។ ព្រោះទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ សង្ឃាដិបល្លត្ថិកាយ និសីទិតព្វំ ។ អង្គុយត្របោមជង្គង់ដោយការយោគគួរ ព្រោះជារបស់ដែលព្រះអង្គទ្រង់អនុញ្ញាត ។

www.budinst.gov.kh www.elibraryofcambodia.org

ម្យ៉ាងទៀត ទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ ចាតុម្មាសំ និសីទនេន វិប្បវសិតព្វំ ថាភិក្ខុកុំគប្បីនៅប្រាសចាកសំពត់រងអង្គុយមានជាយ ៣ ដែលឈ្មោះថានិសីទនៈ អស់ ៤ ខែ បើនៅប្រាសចាកផ្ទះនោះ ត្រូវទុក្កដ ។

ម្យ៉ាងទៀត ភិក្ខុកុំគប្បីមានតែសំពត់ស្លៀកសំពត់ដណ្តប់ពីរផ្ទាំប៉ុណ្ណោះ មិនគ្រប់ត្រៃចីវរចូលទៅក្នុងស្រុក បើចូលទៅដូច្នោះត្រូវទុក្កដ ៗ ដ្បិតទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ សន្តរុត្តរេន គាមោ បវិសិតព្វោ ។ បច្ច័យគឺហេតុដើម្បីនឹងទុកសំពត់សង្ឃាដិនឹងចីពរស្បង់ណាមួយ មិនត្រូវយកទៅផងនោះ មាន ៥ គឺ គិលានោ វា ហោតិ ភិក្ខុមានជម្ងឺ ១ វស្សិកសង្កេតំ វា ហោតិ មានកំណត់ដោយរដូវភ្លៀង ៤ ខែ ១ នទីបារំ គន្តុំ វា ហោតិ ភិក្ខុទៅកាន់ត្រើយស្ទឹងខាងនាយ ១ អគ្គឡគុត្តិវិហារោ វា ហោតិ វិហារមានការរក្សាទ្វារមាំមួន ១ អត្ថតកឋិនំ វា ហោតិ ភិក្ខុបានក្រាលកឋិនហើយ ១ ។ ដាក់គន្លឹះរក្សាកុដិមួយចំណែកនេះជាប្រមាណ ។ ក្នុងកិរិយាមានជម្ងឺនឹងសង្កេតថារដូវភ្លៀង នឹងទៅកាន់ត្រើយស្ទឹង នឹងបានក្រាលកឋិនហើយ ៤ នេះ កាលបើកុដិវិហាររក្សាហើយ នឹងចេញទៅក្រៅវត្តក៏គួរ ។ កាលបើមិនរក្សាមិនគួរ ។ ឯភិក្ខុនៅក្នុងព្រៃ វិហារកុដិដែលរក្សាដោយគន្លឹះសន្ទាក់មិនមាន ភិក្ខុនោះគប្បីយកសំពត់ទុកដាក់ក្នុងឆ្នាំងសំរាប់ដាក់របស់លាក់ទុកក្នុងទីកំបាំង មានក្រហែងថ្មនឹងរូងឈើជាដើម ហើយសឹមទៅ

www.budinst.gov.kh www.elibraryofcambodia.org

បច្ច័យតែហេតុដែលមិនទុកដាក់សំពត់ងូតទឹកភ្លៀងហើយទៅ ក៏មានប្រាំ ទី១ ទី៣ ទី៤ ដូចបទមុន ទី២ ថា ឯសង្ឃំ គន្ធំ ក ហោតិ ភិក្ខុ ទៅកាន់ទីឥតមានសីមា ១ ទី៥ ថា វស្សិកសាដិកា អកតា ក ហោតិ វិប្បកតា ក សំពត់ងូតទឹកភ្លៀងភិក្ខុមិនទាន់បានធ្វើ ឬធ្វើមិនទាន់ហើយ ១ ។

ចីវរបដិសំយុត្តកថា ចប់

---

## យានាទិកថា

ពណ៌នាអំពីយានជាដើម ។ ខមួយ ភិក្ខុគ្មានជម្ងឺកុំគប្បីទៅដោយយាន កនដំរី សេះ រទេះជាដើម បើទៅត្រូវទុក្កដ ។ ដ្បិតទ្រង់ហាមឃាត់ កថា ន ភិក្ខវេ យានេន យាយិតព្វំ យោ យាយេយ្យ អាបត្តិ ទុក្កដស្ស ដូច្នេះ ។ ភិក្ខុមានជម្ងឺទៅដោយយានគួរ ។ ាននោះទឹមដោយបុរស ឬគោឈ្មោល មានស្ត្រីជានាយសារថី ឬ សជានាយសារថី ក៏គួរ ។ យានទឹមដោយគោញី មិនគួរ ។ ភិក្ខុមាន ម្ងឺក៏មិនគួរ ។ ឯយានរុញអូសទៅដោយដៃ ស្ត្រី ឬបុរស រុញអូសទៅ ួរ ។ ត្រូវសែងទីនិងអង្រឹងសំពត់ចងក្នុងឫស្សី ក៏គួរ ។ ដ្បិតទ្រង់ ញ្ញាតទុកថា អនុជានាមិ ភិក្ខវេ គិលានស្ស យានំ ។ ុជានាមិ ភិក្ខវេ បុរិសយុត្តំ ហត្ថវដ្ដកំ ។ អនុជានាមិ ក្ខវេ សិវិកំ បាដង្កឹ ដូច្នេះ ។

www.budinst.gov.kh www.elibraryofcambodia.org

ខមួយទៀត ភិក្ខុគ្មានជម្ងឺ កុំពាក់ស្បែកជើងចូលស្រុក បើពាក់ចូលស្រុកត្រូវទុក្កដ ។ ដ្បិតទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ សឧបាហនេន គាមោ បវិសិតព្វោ យោ បវិសេយ្យ អាបត្តិ ទុក្កដស្ស ដូច្នេះ ។ បើមានជម្ងឺ ពាក់ស្បែកជើងចូលស្រុកក៏បាន ដ្បិតទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ គិលានេន ភិក្ខុនា សឧបាហនេន គាមំ បវិសិតុំ ដូច្នេះ ។

ខមួយទៀត ថាភិក្ខុកុំគប្បីពាក់ស្បែកជើង ២ ជាន់ ៣ ជាន់ បើពាក់ត្រូវទុក្កដ ។ ស្បែកជើង ១ ជាន់ នឹង ៤ ជាន់ គួរក្នុងប្រទេសទាំងពួង ។ ដ្បិតទ្រង់អនុញ្ញាតនឹងហាមឃាត់ទុកថា អនុជានាមិ ភិក្ខវេ ឯកបលាសិកំ ឧបាហនំ ន ភិក្ខវេ ទិគុណា ឧបាហនា ធារេតព្វា ន តិគុណា ឧបាហនា ធារេតព្វា ន គណង្គណុបាហនា ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្ស ដូច្នេះ ។ ស្បែកជើង ៤ ជាន់ជារបស់ថ្មី នៅមិនទាន់បានប្រើប្រាស់ គួរតែក្នុងបច្ចន្តប្រទេសប៉ុណ្ណោះ ក្នុងមជ្ឈិមប្រទេសមិនគួរ ដ្បិតបញ្ញត្តិនេះជាបទេសបញ្ញត្តិ ។ ឯបញ្ញត្តិដែលជាបទេសបញ្ញត្តិនោះ អនុញ្ញាតចំពោះតែក្នុងបច្ចន្តប្រទេសមួយចំពូក មាន ៤ ប្រការ ដ្បិតទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ សព្វបច្ចន្តិមេសុ ជនបទេសុ វិនយធរបញ្ចមេន គណេន ឧបសម្បទំ ។ល។ គណង្គណូបាហនំ ។ល។ ធុវនហានំ ។ល។ ចម្មានិ

អត្ថរណានិ ឯឡកចម្មំ អជចម្មំ មិគចម្មំ សេចក្តីថា តថាគតអនុញ្ញាតឲ្យគណៈសង្ឃមានវិនយធរជាគំរប់ប្រាំ ឲ្យឧបសម្បទាកុលបុត្របានប្រការ ១ អនុញ្ញាតស្បែកជើង ៤ ជាន់ ឡើងទៅប្រការ ១ អនុញ្ញាតងូតទឹកជានិច្ចប្រការ ១ អនុញ្ញាតស្បែកចៀម ស្បែកពពែ ស្បែកម្រឹគជាគ្រឿងក្រាលប្រការ ១ ទាំង ៤ ប្រការនេះ គួរក្នុងបច្ចន្តជនបទទាំងពួង ក្នុងមជ្ឈិមប្រទេស មិនគួរ ។ ក្នុងមជ្ឈិមប្រទេសគណៈសង្ឃទាំងវិនយធរផង ទាំងពី ១០ អង្គឡើងទៅ ឲ្យឧបសម្បទាកុលបុត្រទើបគួរ ព្រោះទ្រង់បញ្ញត្តទុកថា ន ភិក្ខវេ ឩនទសវគ្គេន គណេន ឧបសម្បាទេតព្វំ អនុជានាមិ ភិក្ខវេ ទសវគ្គេន វា អតិរេកទសវគ្គេន វា គណេន ឧបសម្បាទេតុំ សេចក្តីថា គណៈសង្ឃមានវគ្គ ១០ បើទុះកុំឲ្យឧបសម្បទាដល់កុលបុត្រ បើឲ្យឧបសម្បទាត្រូវទុក្កដតថាគតអនុញ្ញាតសង្ឃមានវគ្គ ១០ ឬលើសជាង ១០ ឲ្យឧបសម្បទាកុលបុត្រក្នុងមជ្ឈិមប្រទេស មជ្ឈិមប្រទេសស្បែកជើង ៤ ជាន់ជារបស់ថ្មីមិនគួរ ដូចសំដែងហើយអំពីមុននោះ ។ ក្នុងមជ្ឈិមប្រទេស មិនមានសម័យកន្លះខែទើបងូតទឹកបានម្តង ដូចសំដែងហើយក្នុងនហានសិក្ខាបទ ស្បែកណាមួយក្នុងមជ្ឈិមប្រទេសមិនគួរឡើយ ព្រោះទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ ចម្មំ ធារេតព្វំ ភិក្ខុកុំគប្បីទ្រង់ស្បែកណាមួយ បើទ្រង់ត្រូវទុក្កដ ។ ស្បែកចៀម ឬស្បែកពពែ ណាមួយ នឹងក្រាលដេក ឬក្រាលអង្គុយក្នុងបច្ចន្តប្រទេសនោះគួរ ។ ក្នុងស្បែកម្រឹគ តាមអដ្ឋកថាកំណត់

www.budinst.gov.kh www.elibraryofcambodia.org

ខុកថា ឯណិមិគោ ក្រោយ រោហិតមិគោ ស្ពាន់ បសទមិគោ ក្ដាន់
កុរុង្គមិគោ ប្រើស មិគមាតុកោ ម្រឹគក្រាស គោកណ្ណ-
មិគោ រមាំង ស្បែកម្រឹគទាំងអស់នេះ គួរគង់បច្ចុប្បន្នទោស ។ សត្វដទៃ
គឺ មក្កដោ ស្វា កាឡសីហោ កន្ធសីហ៍ខ្មៅ សរភោ កាំ-
ប្រមា កទលិមិគោ ឈ្លូស ពាឡមិគោ ម្រឹគកាច ខ្លះជា
ម្រឹគសាហាវ ស្បែកសត្វទាំងអស់នេះ មិនគួរគង់ប្រើទោសទាំងពួង ។
សីហព្យគ្ឃអច្ឆតរច្ឆា បានខាងរឿងកន្ធសីហ៍ ខ្លាធំ ខ្លាឃ្មុំ ខ្លារខិន ឈ្មោះ
ជាពាឡម្រឹគ មិនមែនតែពពួកសត្វប៉ុណ្ណោះឡើយ សូម្បីស្បែកនៃសត្វ
បំពួកណា ដែលពោលទុកថាគួរ លើកតែសត្វបំពួកនោះចេញ សត្វ
សល់ពីនោះ ដោយហោចទៅសូម្បីតែ គោ ក្របី ទន្សាយ ឆ្មា ជាដើម
ទាំងអស់នេះ ឈ្មោះជាពាលម្រឹគគង់រៀងនេះ ស្បែកនៃសត្វទាំងពួងនោះ
មិនគួរ ។ ដែលថាមិនគួរនោះ អាស្រ័យគេហៈទីតាំងទុកប្រើប្រាស់ដេក
អង្គុយ ជារបស់បុគ្គល រីឯជាគ្រឿងសំរាប់ប្រើប្រាស់ក្នុងសេនាសនៈជា
របស់សង្ឃ គួរទាំងអស់ ។ តាមពាក្យក្នុងអដ្ឋកថាថា សីហចម្មាទីនំ
ហិ បរិហរណេយេវ បដិក្ខេបោ សេនាសនបរិភោគេ បន
អកប្បិយំ នាម នត្ថិ ប៉ុណ្ណេះ ។ ស្បែកទាំងពួងជាគិហិវិកដ
ជារបស់គ្រហស្ថ ឬគ្រាន់តែជាគ្រឿងបរិភោគ ទីអង្គុយផ្ដេក ទីដេកអង្គុយ
សន្ថតក៏គួរ ទីដេកបន្ថែតមិនគួរ ដូចក្នុងអនុញ្ញាតទុកថា អនុជានាមិ
ភិក្ខវេ គិហិវិកដំ អភិនិសីទិតុំ ន ត្វេវ អភិនិបជ្ជិតុំ

www.budinst.gov.kh www.elibraryofcambodia.org

អនុជានាមិ ភិក្ខវេ ពន្ធនមត្តំ អកិលិសិទ្ធិតុំ ដូច្នេះ ៗ ក្នុងស្បែកជើង លើកតែស្បែកមនុស្សចេញ ទឹងធ្វើដោយស្បែកណាមួយ ក៏គួរទាំងអស់ សូម្បីក្នុងស្រោមស្បែកជើង ស្រោមកាំបិត ទឹងស្រោមកូនសោ ក៏ដូចគ្នា ។

មួយទៀត ភិក្ខុកុំគប្បីពាក់ស្បែកជើងព័ណ៌ផ្សេងៗ មានពណ៌ខៀវជាដើម ។ ដ្បិតទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ សព្វនីលកា ឧបាហនា ។ ល ។ ន សព្វមហានាមរត្តា ឧបាហនា ធារេតព្វា ភិក្ខុកុំគប្បីពាក់ស្បែកជើងពណ៌ខៀវទាំងអស់ ដូចព័ណ៌ផ្កាត្រកៀត ទឹងលឿងទាំងអស់ ដូចផ្កាកណ្ណិកាថ ទឹងក្រហមទាំងអស់ ដូចផ្កាចប្លា ទឹងព័ណ៌ក្រហមម្រឿងៗ ដូចក្តុកដំរី ដូចចម្បើង ទឹងខ្មៅទាំងអស់ ដូចពណ៌ថ្នាំ ទឹងក្រហមក្រមៅទាំងអស់ ដូចពណ៌ខ្នងក្អួប ទឹងស្បែកជើងពណ៌ក្រហមលាយគ្នា ដូចពណ៌ស្លឹកឈើទុំ (ក្នុងអដ្ឋកថាការន្ធី ថា ដូចព័ណ៌ផ្កាឈូក) បើភិក្ខុណា ពាក់ស្បែកជើងពណ៌ដូច្នេះ ត្រូវទុក្កដ ។ ក្នុងស្បែកជើងទាំងអស់នេះណាមួយ បានមកហើយដូតទឹកថ្នាំដោយកំណត់សំគាល់ ទំលាយពណ៌ចេញហើយពាក់ក៏គួរ ។ សូម្បីទឹងទំលាយពណ៌ចេញតែបន្តិចក៏គួរ ។

មួយទៀត សូម្បីស្បែកជើងមានខ្សែពណ៌ខៀវ លឿង ក្រហមម្រឿងៗ ពណ៌ខ្មៅ ពណ៌ក្រហម ពណ៌ព្រាលលាយគ្នា ក៏មិនគួរ ។ ដ្បិតទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ នីលវទ្ធិកា

www.budinst.gov.kh www.elibraryofcambodia.org

ឧបាហនា ។ល។ ន សព្វមហានាមរត្តវទ្ធិកា ឧបាហនា ធារេតព្វា ដូច្នេះ ។ ឯស្បែកជើងដែលមានខ្សែពណ៌ទៀតជាដើមទាំងអស់នោះ គប្បីទំលាយពណ៌នោះចេញជាមុន ទើបគួរពាក់ ។

មួយទៀត ភិក្ខុកុំគប្បីពាក់ស្បែកជើងបិទកែងជើង បិទខ្នងជើងជាដើម ។ ដូចទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ ខល្លកពទ្ធា ន បុដពទ្ធា ន បាលិគុណ្ឋិមា ន តូលបុណ្ណិកា ន តិត្តិរបត្តិកា ន មេណ្ឌវិសាណវទ្ធិកា ន អជវិសាណវទ្ធិកា ន វិច្ឆិកាឡិកា ន មោរបិញ្ឆបរិសិព្វិតា ន ចិត្រា ឧបាហនា ធារេតព្វា ភិក្ខុកុំគប្បីពាក់ស្បែកជើងដែលចងស្បែកតាំងអំពីផ្ទៃឡើងមក បិទកែង និងស្បែកជើងបិទខ្នងជើងទាំងអស់ហួសដល់ស្នង ឬដូចស្បែកជើងអ្នកស្រុកយោនកៈ និងស្បែកជើង បិទតែខ្នងជើងប៉ុណ្ណោះ មិនបានបិទស្នង និងស្បែកជើងញាត់ដោយគរ និងស្បែកជើងមានខ្សែដ៏វិចិត្រដូចស្លាបទទា និងស្បែកជើងមានខ្សែសណ្ឋានដូចស្នែងកែះក្រវីដែលធ្លាក់ និងស្បែកជើងមានខ្សែសណ្ឋានដូចស្នែងពពែក្រវីដែលធ្លាក់ និងស្បែកជើងមានខ្សែសណ្ឋានដូចកន្ទុយខ្ទួយក្រវីដែលធ្លាក់ និងស្បែកជើងដែលស្រេះដេរដោយរោមកន្ទុយក្ងោកក្រង់ខ្វៃ ឬក្រង់ខ្សែដូចដេរមិនអំពោះ និងស្បែកជើងវិចិត្រដោយសណ្ឋានផ្សេង ៗ ភិក្ខុណាពាក់

ស្បែកជើងទាំងនេះ ត្រូវទុក្កដ ។ ក្នុងស្បែកជើងណាមួយបានមក អាចនឹងទាំយកស្បែកបិទកែងជាដើមចេញបាន ក៏គប្បីនាំចេញប្រើប្រាស់ចុះ ។ ស្បែកបិទកែងជាដើមនោះមានទៅ កាលបើប្រើប្រាស់ ត្រូវទុក្កដ ។

១មួយទៀត សូម្បីស្បែកជើងប្រកបដោយស្បែករាជសីហ៍ជាដើម គ្រង់ទីបំផុតដោយជុំវិញ ដូចប្រក អនុក់តច័រ គឺមិនគួរ ។ ព្រោះព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ សីហចម្មបរិក្ខដា ឧបាហនា ធារេតព្វា ។ល។ ន ព្យគ្ឃចម្ម- ន ទីបិចម្ម- ន អជិនចម្ម- ន ឧទ្ទចម្ម- ន មជ្ជារចម្ម- ន កាឡកចម្ម- ន ឧហ្លុកចម្មបរិក្ខដា ឧបាហនា ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្ស[1] ភិក្ខុ កុំគប្បីពាក់ស្បែកជើងដែលចំព័ទ្ធដោយជុំវិញ ដោយស្បែករាជសីហ៍ ដោយស្បែកខ្លាធំ ដោយស្បែកខ្លាដំបង ដោយស្បែកខ្លារខិន ដោយស្បែកភេ ដោយស្បែកឆ្មា ដោយស្បែកកន្ហែន ដោយស្បែកមៀម បើភិក្ខុណា ពាក់ស្បែកជើងដូចសំដែងមកនេះ ត្រូវទុក្កដ ។ សូម្បីបានស្បែកជើងទាំងអម្បាលនេះណាមួយមក គប្បីយកស្បែកទាំងអម្បាលនោះចេញ ហើយប្រើចុះ ។

១មួយទៀត ព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ភិក្ខុមិនត្រូវពាក់ទ្រនាប់ជើងឈើ ទ្រនាប់ជើងធ្វើដោយស្លឹកត្នោត ធ្វើដោយស្លឹកឫស្សី ធ្វើដោយស្មៅ ធ្វើដោយស្មៅយាប្លុង ធ្វើដោយស្មៅដំណេកទន្សាយ ធ្វើ

---

១– វិនយបិដក មហាវគ្គ ទុតិយភាគ ចម្មក្ខន្ធកៈ ទំព័រ ១៣៨ ។

www.budinst.gov.kh www.elibraryofcambodia.org

ដោយស្លឹកទន្សែ ធ្វើដោយរោមមានពណ៌ដូចផ្កាឈូក ធ្វើដោយសំពត់កម្ពល ទ្រនាប់ជើងធ្វើដោយមាស ដោយប្រាក់ ដោយកែវមណី ដោយកែវពិទូរ្យ ដោយកែវផ្លេក ដោយសំរិទ្ធ ដោយកែវ ដោយសំណប៉ាហាំង ដោយសំណតក់ ដោយទង់ដែង ទាំងអម្បាលនេះ ទ្រនាប់ជើងណាមួយ ដែលនាំណានដើរទៅបាន បើភិក្ខុណាពាក់ទ្រនាប់ជើងដូច្នេះ ត្រូវទុក្កដ ។

ទមួយទៀត ព្រះពុទ្ធអង្គទ្រង់ហាមឃាត់ នឹងអនុញ្ញាតទុកថា ន ច ភិក្ខវេ កាចិ សង្កមនិយា បាទុកា ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ តិស្សោ បាទុកាយោ ធុវដ្ឋានិយា អសង្កមនិយាយោ វច្ចបាទុកំ បស្សាវបាទុកំ អាចមនបាទុកំ (១)

ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុមិនត្រូវប្រើប្រាស់ទ្រនាប់ជើង (គឺស្រញាជើង) ណាមួយ ដែលគួរនឹងឲ្យគេច្រើកទៅបាន ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតទ្រនាប់ជើងឈើ ៣ ប្រការ ដែលគេដំកល់នៅជាប់ជានិច្ច ដែលគេកំរើកឃ្លាតទៅមិនបាន គឺទ្រនាប់ជើងសម្រាប់បន្ទោបង់វច្ចៈ ១ ទ្រនាប់ជើងសម្រាប់បន្ទោបង់បស្សាវៈ ១ ទ្រនាប់ជើងសម្រាប់លាងជម្រះ (លាមក) ១ ។ បានសេចក្តីថាស្បែកជើងស្បែកមួយចំពូក ទើបត្រូវពាក់ គួរប្រើ ។

១– វិនយបិដក មហាវគ្គ ទុតិយភាគ បញ្ញត្តកៈ ទំព័រ ១៩២ ។

www.budinst.gov.kh www.elibraryofcambodia.org

មួយទៀត ភិក្ខុជាអាចារ្យ ឬភិក្ខុល្មមធ្វើជាអាចារ្យក្តី ឧបជ្ឈាយ៍ ឬភិក្ខុល្មមធ្វើជាឧបជ្ឈាយ៍ក្តី មិនបានពាក់ស្បែកជើងដើរទៅ ភិក្ខុកំឡោះពាក់ស្បែកជើងដើរទៅ ត្រូវទុក្កដ ។ ដ្បិតទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ អាចរិយេសុ អាចរិយមត្តេសុ ឧបជ្ឈាយេសុ ឧបជ្ឈាយ-មត្តេសុ អនុបាហនេសុ ចង្កមមានេសុ សឧបាហនេន ចង្កមិតព្វំ យោ ចង្កមេយ្យ អាបត្តិ ទុក្កដស្ស ដូច្នេះ ។ បព្វជាចារ្យ អ្នកឲ្យសរណគមន៍ បំបួសជាសាមណេរ ១ ឧបសម្បទាចារ្យ អ្នកសូត្រកម្មវាចា ឲ្យឧបសម្បទាជាភិក្ខុ ១ និស្សយាចារ្យ អ្នកឲ្យនិស្ស័យ ១ ឧទ្ទេសាចារ្យ អ្នកឲ្យឧទ្ទេស គឺបាលីនិងអដ្ឋកថា ១ ទាំង ៤ នេះឈ្មោះថាអាចារ្យក្នុងបទនេះ ។ ភិក្ខុមានវស្សា ៦ ឈ្មោះថាអាចរិយមត្ត ល្មមជាអាចារ្យនៃភិក្ខុដែលមិនទាន់មានវស្សា ដ្បិតថាភិក្ខុមិនទាន់មានវស្សានោះនឹង សូមនិស្ស័យលោក ក្នុងកាលដែលខ្លួនមានវស្សា ៤ ក៏បាន ភិក្ខុមានវស្សា ៧ ឈ្មោះថាអាចរិយមត្តនៃភិក្ខុ ១ វស្សា, ភិក្ខុមានវស្សា ៨ ឈ្មោះថាអាចរិយមត្តនៃភិក្ខុ ២ វស្សា, ភិក្ខុមានវស្សា ៩ ឈ្មោះថាអាចរិយមត្តនៃភិក្ខុ ៣ វស្សា, ភិក្ខុមានវស្សា ១០ ឈ្មោះថាអាចរិយមត្តនៃភិក្ខុ ៤ វស្សា, ភិក្ខុជាមិត្តជាប់ជួប ធ្លាប់គប់រក របស់ឧបជ្ឈាយ៍ខ្លួន ឬភិក្ខុណាមួយដែលចាស់ជាងខ្លួន តាំងពីវស្សា ១០ ឡើងទៅ ភិក្ខុទាំងពួងនោះ ឈ្មោះថាឧបជ្ឈាយមត្ត ល្មមជាឧបជ្ឈាយ៍បាន កាលភិក្ខុទាំងនេះ មិនបានពាក់ស្បែកជើងដើរទៅ ភិក្ខុខ្ចីវស្សា ពាក់ស្បែកជើងដើរទៅ ត្រូវទុក្កដ ។


www.budinst.gov.kh www.elibraryofcambodia.org

# មំសកថា

ពណ៌នាអំពីសាច់ ។ ១មួយ ភិក្ខុកុំទទួលសាច់ឆៅត្រីឆៅ ។ ១មួយ ភិក្ខុកុំឆាន់សាច់ឆៅត្រីឆៅ ។ បើទទួល បើឆាន់ ត្រូវទុក្កដ ។ ដ្បិតព្រះអដ្ឋកថាចារ្យលោកអាស្រ័យពាក្យក្នុងព្រះសូត្រ ដែលទ្រង់ហាមទុកថា អាមកមំសបដិគ្គហណា ភិក្ខុជាអ្នកវៀរចាកការទទួលសាច់ឆៅ ។ ទីនេះអាស្រ័យពុទ្ធានុញ្ញាតថា អនុជានាមិ ភិក្ខវេ អមនុស្សិកាពាធេន អាមកមំសំ ខាទិតុំ បាតុំ អាមកលោហិតំ គឺថាតថាគតអនុញ្ញាតឲ្យភិក្ខុដែលអមនុស្សចូលបៀតបៀន ឆាន់សាច់ឆៅ ផឹកឈាមឆៅបាន ព្រោះកាបត្តិទាំងពីរនេះឈ្មោះថាបាលីមុត្តកទុក្កដ ។

១មួយ ភិក្ខុកុំគប្បីឆាន់ឧទ្ទិស្សមំសៈ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទីនេះអនុញ្ញាតទុកថា ន ភិក្ខវេ ជានំ ឧទ្ទិស្ស កតំ មំសំ បរិភុញ្ជិតព្វំ យោ បរិភុញ្ជេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ តិកោដិបរិសុទ្ធំ មច្ឆមំសំ អទិដ្ឋំ អសុតំ អបរិសង្កិតំ (១) សាច់ដែលគេធ្វើចំពោះភិក្ខុ គឺសម្លាប់ដើម្បីភិក្ខុ កាលភិក្ខុដឹងកុំគប្បីឆាន់ បើឆាន់ត្រូវទុក្កដ ។ តថាគតអនុញ្ញាតត្រី សាច់ ដែលបរិសុទ្ធដោយចំណែក ៣ គឺមិនបានឃើញ មិន

១ វិនយបិដក មហាវគ្គ ទុតិយភាគ ភេសជ្ជក្ខន្ធកៈ ទំព័រ ៣៣៧ ។

www.budinst.gov.kh www.elibraryofcambodia.org

បានឮ មិនបានរង្កៀស ថាគេសម្លាប់ចំពោះភិក្ខុ ។ គប្បីដឹង ការរង្កៀសដោយបានឃើញ រង្កៀសដោយបានឮ និងរង្កៀសដោយមិនបានឃើញ មិនបានឮ ។ ឯរង្កៀសដោយបដិបក្ខនោះ ភិក្ខុណាឃើញមនុស្សកាន់សំណាញ់និងអន្ទ្រុតជាដើម ចេញចាកភូមិឬត្រាច់ទៅក្នុងព្រៃ វេលាព្រឹកចូលទៅបិណ្ឌបាតក្នុងស្រុកនោះ អ្នកស្រុកគេថ្វាយបិណ្ឌបាតទាំងត្រីនិងសាច់ផង ភិក្ខុនោះអាស្រ័យបានឃើញអំពីដើម ហើយរង្កៀសថា គេធ្វើដើម្បីភិក្ខុទាំងឡាយទេដឹង ដូច្នេះឈ្មោះថារង្កៀសដោយបានឃើញ ។ ភិក្ខុមិនបានឃើញសោះឡើយ គ្រាន់តែបានឮថា មនុស្សទាំងឡាយកាន់សំណាញ់និងអន្ទ្រុតជាដើម ចេញអំពីស្រុកឬត្រាច់ទៅក្នុងព្រៃ វេលាព្រឹកភិក្ខុចូលទៅបិណ្ឌបាតក្នុងស្រុកនោះ គេបង្អោនបិណ្ឌបាតទាំងត្រីនិងសាច់ចូលមកប្រគេន ភិក្ខុរង្កៀសថា គេធ្វើចំពោះភិក្ខុទេដឹង ដូច្នេះឈ្មោះថារង្កៀសដោយបានឮ ។ ឯមិនបានឃើញ មិនបានឮនោះគឺ គ្រាន់តែចូលទៅបិណ្ឌបាតក្នុងស្រុក ពាយកទទួលបាត្រទៅ ដាក់តែងបិណ្ឌបាត ទាំងត្រី ទាំងសាច់ នាំមកប្រគេន ភិក្ខុរង្កៀសថា គេធ្វើចំពោះភិក្ខុទេឬ ដូច្នេះ ឈ្មោះថារង្កៀសដោយមិនបានឃើញ មិនបានឮ ។ បើរង្កៀសដោយហេតុទាំង ៣ នេះ ក្នុងរបស់ណា និងទទួលរបស់នោះមិនគួរ របស់ណាមិនរង្កៀសដូច្នេះ របស់នោះទើបគួរ ។ ថាបើគេសួរថា ហេតុអ្វីទើបលោកមិនទទួល ភិក្ខុប្រាប់ថា អាត្មារង្កៀសដូច្នេះ ។ បើគេពោលថារបស់នេះ ខ្ញុំមិនបានធ្វើដើម្បី

www.budinst.gov.kh www.elibraryofcambodia.org

ភិក្ខុទាំងឡាយ ខ្ញុំធ្វើដើម្បីខ្លួនខ្ញុំទេ ឬពោលថា ខ្ញុំធ្វើដើម្បីពលីកម្មតាម ឲ្យដល់ឥស្សរជនៈជាដើម ដូច្នេះក្តី ។ បើភាយកពោលថា សាច់សត្វស្លាប់ ទិញបានអំពីកន្លែងផ្សារ ដូច្នេះក្តី ។ សូម្បីក្នុងសាច់នឹងត្រីដែលគេធ្វើដើម្បីបេតកិច្ច ឲ្យដល់មនុស្សស្លាប់ ឬដើម្បីមង្គលកិច្ចក្តី ។ សាច់នឹងត្រីឯណា គេមិនបានសម្លាប់ដើម្បីភិក្ខុក្តី ភិក្ខុមិនសង្ស័យក្នុងសាច់នឹងត្រីឯណាក្តី របស់ទាំងពួងនោះរមែងគួរ ។ បើគេសម្លាប់ចំពោះភិក្ខុក្នុងវិហារ ភិក្ខុនោះ មិនដឹងថាគេសម្លាប់ចំពោះខ្លួន តែភិក្ខុដទៃដឹង ភិក្ខុណាដឹងមិនគួរដល់ភិក្ខុនោះ គួរតែភិក្ខុដែលមិនដឹង ។ ភិក្ខុក្នុងវិហារដទៃមិនដឹង ភិក្ខុដែលនៅក្នុងវិហារនោះឯងដឹង រមែងមិនគួរដល់ភិក្ខុក្នុងវិហារនោះ គួរដល់តែភិក្ខុក្នុងវិហារដទៃ ។ បើភិក្ខុក្នុងវិហារនោះក៏ដឹង ភិក្ខុក្នុងវិហារដទៃក៏ដឹង មិនគួរទាំងអស់គ្នា ។ ភិក្ខុទាំងអស់មិនដឹងក៏គួរដល់ភិក្ខុទាំងអស់ ។ សាច់នឹងត្រី ដែលគេសម្លាប់ចំពោះសហធម្មិកទាំង៥ណាមួយក្តី ក៏មិនគួរដល់សហធម្មិកទាំង៥ ។ បើគេចំពោះភិក្ខុមួយអង្គ សម្លាប់សត្វ តាក់តែងបិណ្ឌបាតមកប្រគេនដល់ភិក្ខុនោះ បើភិក្ខុនោះដឹងថា គេសម្លាប់ចំពោះខ្លួន ទទួលមកឲ្យភិក្ខុដទៃ ភិក្ខុដទៃឆាន់ដោយជឿភិក្ខុនោះ ដូច្នេះមិនត្រូវអាបត្តិទាំងពីរនាក់ ព្រោះគេចំពោះភិក្ខុណា ភិក្ខុនោះមិនបានឆាន់ ភិក្ខុដែលឆាន់នោះមិនដឹង ទើបមិនត្រូវអាបត្តិ ។ នឹងត្រូវអាបត្តិ ព្រោះទទួលសាច់ជាកប្បិយមំស ក៏ទេ មិនដឹងថាគេសម្លាប់ចំពោះភិក្ខុ ភិក្ខុឆាន់ហើយទើបដឹងខាងក្រោយ កិច្ចដែលសំដែងអាបត្តិនោះមិនមាន ។ ភិក្ខុមិនដឹងថា

www.budinst.gov.kh www.elibraryofcambodia.org

អកប្បិយមំសៈហើយឆាន់ លុះខាងក្រោយទើបបានដឹង គប្បីសំដែងអាបត្តិចេញ ព្រោះថាសាច់ទាំងត្រីដែលគេសម្លាប់ចំពោះភិក្ខុ ភិក្ខុដឹងហើយឆាន់ទើបត្រូវអាបត្តិ ។ សាច់ជាអកប្បិយ សូម្បីមិនដឹង ឆាន់ហើយក៏គង់ត្រូវអាបត្តិប្រាកដ ។ ព្រោះហេតុនោះ ភិក្ខុដែលខ្លាចអាបត្តិ គប្បីកំណត់ឲ្យសមគួរ សួរមុនហើយទើបទទួលសាច់ ឬគប្បីគិតថា កាលឆាន់សឹមសួរទទួលហើយគប្បីសាកសួរឲ្យបានសេចក្ដីសឹមឆាន់ ដ្បិតថាក្រណាស់ដែលមិនដឹង ព្រោះសាច់ខ្លាឃ្មុំប្រហែលគ្នានឹងសាច់ជ្រូក សាច់ខ្លាដំបងជាដើមប្រហែលនឹងសាច់ម្រឹគជាដើម ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យពោលថាសួរមុនហើយទើបទទួលនេះឯងជាវត្ត ។

មំសកថា ចប់

## តិរច្ឆានវិជ្ជាទិកថា

ខមួយ ភិក្ខុមិនត្រូវរៀន នឹងមិនត្រូវប្រាប់ តិរច្ឆានវិជ្ជា ៈបើរៀនបើប្រាប់ ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ តិរច្ឆានវិជ្ជា បរិយាបុណិតព្វា ។ល។ ន វាចេតព្វា យោ វាចេយ្យ អាបត្តិ ទុក្កដស្ស ដូច្នេះ ។ សិល្បសាស្ត្រដំរី សេះ -អាវុធ -លេខ សែកមន្ត ជន់ជាសំពេគម យន្តស្នេហ៍ ថ្នាំស្ពោះអថព្វ វិជ្ជាផ្សេងៗ ជាខាងក្រៅ ពុទ្ធសាសនា មិនប្រកបដោយប្រយោជន៍ ជាគ្រឿងបៀតបៀនអ្នកដទៃ លើកតែវិជ្ជាលេខក្រៅនោះឈ្មោះថាតិរច្ឆានវិជ្ជាទាំងអស់ ភិក្ខុរៀន នឹងប្រាប់ ត្រូវទុក្កដ

www.budinst.gov.kh www.elibraryofcambodia.org

កាច់ដោះបេចទនឹងអក្ខរៈ ។ រៀនលេខ រៀនគម្ពីរមួយឈ្មោះថាធារណសត្តុបដិបត្តិ ហើយខំនឹងឲ្យដឹងគម្ពីរដទៃ ៗ ច្រើនក្តី ខំនឹងរៀនវិជ្ជាជាបរិត្តការពារយក្ស - បិសាច ពស់ជាដើម ដើម្បីគេក្រខ្លួនទាំងអម្បាលនេះ មិនត្រូវអាបត្តិ ។

១មួយទៀត ភិក្ខុមិនត្រូវរៀន មិនត្រូវប្រាប់គម្ពីរលោកាយតៈទេ បើរៀន បើប្រាប់ ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ លោកាយតំ បរិយាបុណិតព្វំ ។ល។ ន វាចេតព្វំ យោ វាចេយ្យ អាបត្តិ ទុក្កដស្ស[១] ដូច្នេះ ។ គម្ពីររបស់ត្រិយប្រកបដោយហេតុឥតប្រយោជន៍មានដើមថា វត្ថុទាំងពួងជារបស់ដែល (សំណល់) នឹងវត្ថុទាំងពួងមិនមែនជារបស់ដែល (គឺជារបស់ថ្មើង) ក្អែកស កុកខ្មៅ ដូច្នេះឈ្មោះថាគម្ពីរលោកាយតៈ ។

១មួយទៀត ព្រះពុទ្ធអង្គទ្រង់ហាមឃាត់នឹងអនុញ្ញាតទុកថា ន ភិក្ខវេ ពុទ្ធវចនំ ឆន្ទសោ អារោបេតព្វំ យោ អារោបេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ សកាយ និរុត្តិយា ពុទ្ធវចនំ បរិយាបុណិតុំ[២] ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវលើ ពុទ្ធវចនៈតាមឆន្ទ (ភាសាសំស្ក្រឹត) ទេ ភិក្ខុណាលើក ត្រូវអាបត្តិទុក្កដ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យរៀនពុទ្ធវចនៈតាមសកភាសា (មគធភាសា) ដែលព្រះសម្មាសម្ពុទ្ធតែងពោល ។

---

(១-២ វិន័យបិដក ចុល្លវគ្គ ទុតិយភាគ ខុទ្ទកវត្ថុក្ខន្ធកៈ ទំព័រ ២៣០

www.budinst.gov.kh www.elibraryofcambodia.org

ម្យ៉ាងទៀត ព្រះថេរៈមិនបានអាពាធទេ ក៏គប្បីសំដែងធម៌ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់នឹងអនុញ្ញាតទុកថា ន ភិក្ខវេ សង្ឃមជ្ឈេ អនជ្ឈិដ្ឋេន ធម្មោ ភាសិតព្វោ អនុជានាមិ ភិក្ខវេ ថេរេន ភិក្ខុនា សាមំ វា ធម្មំ ភាសិតុំ បរំ វា អជ្ឈេសិតុំ ភិក្ខុមិនមានថេរៈអាពាធ ក៏គប្បីសំដែងធម៌ក្នុងទីកណ្តាលសង្ឃ បើសំដែងត្រូវទុក្កដ ។ តថាគតអនុញ្ញាតឲ្យភិក្ខុជាថេរៈសំដែងធម៌ខ្លួនឯង ឬនិមន្តអ្នកដទៃឲ្យសំដែង ។ កិរិយានិមន្តសំដែងធម៌នេះជាប់នៅនឹងភិក្ខុអ្នកនិមន្តដែលសង្ឃសន្មតទុក ឬជាប់នៅនឹងព្រះសង្ឃត្ថេរ ។ កាលបើភិក្ខុអ្នកនិមន្តមិនមាន ត្រូវប្រាប់ព្រះសង្ឃត្ថេរមុនសិន ឬព្រះសង្ឃត្ថេរនិមន្តហើយ ទើបសំដែងបាន ។ សូម្បីព្រះសង្ឃត្ថេរសោត បើភិក្ខុធម្មកថិកមានច្រើនក្នុងវិហារ ក៏គប្បីបង្គាប់ទុកតាមលំដាប់វារៈធម្មកថិក គឺព្រះថេរបង្គាប់ថា លោកចូរពោលធម៌ ឬចូរសំដែងធម៌ ឬចូរឲ្យធម្មទានដូច្នេះ ហើយគប្បីសំដែងធម៌ដោយវិធី ៣ ប្រការ គឺលោកបង្គាប់ឲ្យសូត្របាលី សូត្របានតែបាលីមួយចំពូក, លោកបង្គាប់ឲ្យសំដែង បានតែសំដែងមួយចំពូក, លោកបង្គាប់ឲ្យពោលសរភញ្ញ បានតែពោលសរភញ្ញប៉ុណ្ណោះ ។ សូម្បីព្រះសង្ឃត្ថេរនឹងគង់លើអាសនៈខ្ពស់ អាពាធ ក៏មិនបានឡើយ បើមានតែឧបជ្ឈាយ៍នឹងសទ្ធិវិហារិកប៉ុណ្ណោះ ឧបជ្ឈាយ៍លោកគង់នៅលើអាសនៈខ្ពស់ បង្គាប់ថាលោកចូរសំដែងធម៌ ឲ្យសទ្ធិវិហារិកគប្បីអធិដ្ឋានជាស្វាធ្យាយ ហើយទើបសំដែង ។ បើភិក្ខុកំឡោះមាននៅក្នុង

www.budinst.gov.kh www.elibraryofcambodia.org

ទំនោះផង ក៏គប្បីធ្វើអាភោគចិត្តថា យើងនឹងសំដែងដល់ភិក្ខុកំឡោះហើយ
ទើបសំដែង ៗ បើក្នុងវិហារ ព្រះសង្ឃត្ថេរបង្គាប់តែសិស្សនៃខ្លួនប៉ុណ្ណោះ
មិនអារាធនាភិក្ខុដទៃ ដែលជាអ្នកសំដែងពីរោះខ្លះ ភិក្ខុដទៃគប្បីពោល
នឹងព្រះសង្ឃត្ថេរថា ខ្ញុំព្រះករុណា នឹងនិមន្តភិក្ខុឈ្មោះនោះឲ្យសំដែង ៗ
បើព្រះសង្ឃត្ថេរទទួលបុស្សៀមនៅក្តី នឹងអារាធនាឲ្យភិក្ខុដទៃសំដែងក៏គួរ ៗ
តាបើព្រះសង្ឃត្ថេរឃាត់ចេញសោត ក៏កុំគប្បីអារាធនាភិក្ខុដទៃឲ្យសំដែង ៗ
កាលបើព្រះសង្ឃត្ថេរនៅមិនទាន់មកឡើយ ភិក្ខុប្រាព្ធធម្មស្សវនៈឡើង
ហើយព្រះសង្ឃត្ថេរទើបនិមន្តមកទៀតសោត កិច្ចដែលនឹងឈប់ហើយនឹង
ប្តឹងមិនមាន ៗ កាលបើសូត្របាលីចប់ហើយ នឹងសំដែងសេចក្តី គប្បី
ប្តឹង ឬកុំឈប់នឹងសំដែងទៅតែម្តងក៏បាន ៗ សូម្បីកំពុងសំដែងសេចក្តី
ព្រះសង្ឃត្ថេរមកទៀតសោតក៏ដូចគ្នា សូម្បីតែក្នុងឧបនិសិន្នកថា សំដែង
ដល់មនុស្សចូលមកអង្គុយជិតហើយសាកសួរ ព្រះសង្ឃត្ថេររមែងជាធំ
ព្រោះហេតុនោះ ព្រះសង្ឃត្ថេរគប្បីសំដែងដោយខ្លួនឯង ឬបង្គាប់ភិក្ខុដទៃ
ឲ្យសំដែង ក៏ប៉ុន្តែថា ព្រះសង្ឃត្ថេរកុំអង្គុយលើឧច្ចាសនៈបង្គាប់ ក៏ឯ
ភិក្ខុកំឡោះនឹងគិតថា យើងនឹងពោលដល់គ្រហស្ថ សូម្បីនឹងសំដែង
ក៏គួរ ៗ គ្រហស្ថគេសួរបញ្ហានឹងភិក្ខុដែលគេស្គាល់ ភិក្ខុនោះគប្បីប្តឹង
ព្រះថេរៈជាមុនសិន សូមវិសជ្ជនា បើព្រះសង្ឃត្ថេរ កាលភិក្ខុកំឡោះ
ប្តឹងថា គេសួរបញ្ហានឹងខ្ញុំព្រះករុណាដូច្នេះហើយ លោកបង្គាប់ឲ្យវិសជ្ជនា
ឬលោកៈស្បៀមៈ៩៧ ភិក្ខុកំឡោះនឹងសំដែងក៏គួរ ៗ សូម្បីភិក្ខុនីការអនុមោទនា

www.budinst.gov.kh www.elibraryofcambodia.org

ជាដើម ក្នុងលេណ្ឌកកម្មិកដូចគ្នា បើព្រះសង្ឃគេអនុញ្ញាតទុកឲ្យអំពីដំបូងថា ក្នុងវិហារឬក្នុងលេណ្ឌកកម្មិក លោកកុំគប្បីប្រាប់យើងឡើយ គប្បីសំដែងតាមចុះដូច្នេះ ឈ្មោះថាមានកាលដ៏សមគួរហើយ ទឹងសំដែងធម៌ក្នុងទីតាំងពួងក៏គួរ ។ សូម្បីគួរទឹងស្វាធ្យាយក៏ត្រូវប្រាប់ព្រះថេរៈជាមុន ប្រាប់ព្រះថេរៈតែមួយអង្គ ហើយកំពុងតែស្វាធ្យាយនៅឡើយ ព្រះថេរៈអង្គដទៃនិមន្តមកទៀតលោក កិច្ចដែលទឹងត្រូវប្រាប់នោះមិនមាន បើចង់ចិត្តថាយើងទឹងឈប់សម្រាកសិនហើយ ហើយក៏ឈប់ស្ងៀម ព្រះថេរៈអង្គដទៃមកទៀត កាលបើប្រារព្ធទឹងសំដែងទៀត ក៏គប្បីប្រាប់សិន ។ សូម្បីព្រះថេរៈមិនទាន់និមន្តមក កំពុងតែប្រារព្ធស្វាធ្យាយក៏ដូចគ្នា ។ ព្រះសង្ឃគេមួយអង្គអនុញ្ញាតទុកអំពីដំបូងថា លោកកុំគប្បីប្រាប់ដល់យើងទៀតឡើយ ចូរទន្ទេញ ស្វាធ្យាយ តាមសប្បាយចុះ ដូច្នេះទឹងទន្ទេញសូត្ររៀនតាមសប្បាយក៏គួរ ។ កាលបើព្រះថេរៈអង្គដទៃនិមន្តមកទៀត លោក គប្បីប្ដឹងលោកជាមុនហើយ សឹមទន្ទេញសូត្ររៀន ។

១ មួយទៀត ថាភិក្ខុកុំគប្បីច្រៀងសូត្រសំដែងធម៌ដោយសំឡេងដំរៃង គឺទំលាយបន្ទូវវត្តនោះ ៗ ញុំាងអក្ខរៈឲ្យវិនាសទៅ បើច្រៀងសូត្រសំដែងដូច្នោះ ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ អាយតកេន គីតស្សរេន ធម្មោ គាយិតព្វោ យោ គាយេយ្យ អាបត្តិ ទុក្កដស្ស[១] ដូច្នេះ ។ វិងវត្ត

១- វិនយបិដក ចុល្លវគ្គ ទុតិយភាគ ខុទ្ទកវត្ថុក្ខន្ធកៈ ទំព័រ ១៣៨

www.budinst.gov.kh www.elibraryofcambodia.org

ឈ្មោះថា សុត្តន្តវគ្គក៏មាន ជាតកវគ្គក៏មាន ឈ្មោះថា គាថាវគ្គក៏មាន នៅក្នុងធម៌ ញ៉ាំងវគ្គនោះ ៗ ឲ្យវិនាស ធ្វើសំឡេងឲ្យវែងណាស់មិនគួរ គប្បីសំដែងបទនិងព្យញ្ជនៈឲ្យជាបរិមណ្ឌលដោយវគ្គដ៏មូល ។ សរភញ្ញ គឺសូត្រនិងពោលដោយសំឡេងជាទំនង ជាឃ្លា ៗ ដែលព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុក ។ បានឮថាក្នុងសរភញ្ញមានវគ្គ ៣២ មានតរង្គវគ្គ ទំនងដូចរលក ឱហកវគ្គ ទំនងដូចរឹកទឹកដោះគោ គលិតវគ្គ ទំនងដូចជាត្នោតដែលភ្លាត់ធ្លាក់ចុះជាដើម ។ ក្នុងទំនងវគ្គទាំងអម្បាលនោះ ភិក្ខុប្រាថ្នាធ្វើទំនងណា ធ្វើទំនងនោះក៏បាន តែថាកុំញ៉ាំងបទនិងព្យញ្ជនៈទាំងពួងឲ្យវិនាស កុំធ្វើឲ្យមានវិការៈ ហើយធ្វើសំឡេងឲ្យប្រព្រឹត្តទៅដោយន័យដ៏មានជ្រុងបួន សមគួរដល់សមណៈ នេះឯងជាលក្ខណៈក្នុងសរភញ្ញ ។

ការច្រៀងដោយសំឡេងច្រៀងដ៏វែង ៗ មានទោស ៥ ប្រការដូច្នេះ គឺអ្នកច្រៀងនោះ រមែងត្រេកអរក្នុងសំឡេងនៃខ្លួននោះ ១ អ្នកដទៃរមែងត្រេកអរក្នុងសំឡេងនោះ ១ គហបតីទាំងឡាយរមែងពោលទោស ១ បុគ្គលដែលពេញចិត្តនឹងការសូត្រលាក់លែកសម្លេង រមែងខូចសមាធិ ១ ពួកជនខាងក្រោយមានសិស្សជាដើម រមែងនឹងដល់នូវទិដ្ឋានុគតិ (យកតម្រាប់តាម) ថា សូម្បីអាចារ្យនិងឧបជ្ឈាយ៍នៃយើង លោកក៏ស្រែកសូត្រច្រៀងដូច្នេះដែរ ហើយក៏ស្រែកច្រៀងសូត្របទដូច្នោះ ១ ត្រូវជា ៥ ប្រការដូច្នេះ ។

www.budinst.gov.kh www.elibraryofcambodia.org

ខមួយទៀត ភិក្ខុដទៃខ្ចីសំពត់ជម្រងទឹកកុំកំណាញ់ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ អទ្ធានមគ្គបដិបន្នេន ភិក្ខុនា បរិស្សាវនំ យាចិយមានេន ន ទាតព្វំ យោ ន ទទេយ្យ អាបត្តិ ទុក្កដស្ស ម្នាលភិក្ខុទាំងឡាយ ភិក្ខុដើរផ្លូវឆ្ងាយជាប់ស្រយាល កាលបើគេខ្ចីសំពត់ជម្រងទឹក កុំគប្បីមិនឲ្យ បើភិក្ខុណាមិនឲ្យ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុណាមានសំពត់ជម្រងទឹកក្នុងដៃខ្លួនហើយ ក្រែងខ្ចី បើមិនប្រាថ្នានឹងឲ្យដល់ភិក្ខុនោះ កុំគប្បីឲ្យឡើយ ។

ខមួយទៀត ភិក្ខុគ្មានសំពត់ជម្រងទឹកកុំដើរផ្លូវឆ្ងាយ ភិក្ខុណាដើរទៅ ត្រូវអាបត្តិទុក្កដ ។ បើសំពត់ជម្រងទឹកនឹងធម្មក្រកមិនមានសោត សូម្បីតែមុំសង្ឃាដី ក៏គប្បីអធិដ្ឋានថា យើងនឹងត្រងដោយមុំសង្ឃាដីនេះក្រេបផឹកដូច្នេះ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់នឹងអនុញ្ញាតទុកថា ន ច ភិក្ខវេ អបរិស្សាវនកេន អទ្ធានមគ្គោ បដិបជ្ជិ-តព្វោ ។ ល ។ បរិស្សាវមីតិ ដូច្នេះ ។

**តិរច្ឆានវិជ្ជាទិកថា ចប់**

## សទ្ធាទេយ្យាទិកថា

ខមួយ ភិក្ខុកុំគប្បីធ្វើរបស់សទ្ធាទេយ្យឲ្យធ្លាក់ចុះ គឺកុំឲ្យអទាមផ្ល-បិណ្ឌបាតជាដើមដល់គ្រហស្ថ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតនឹងហាម

www.budinst.gov.kh www.elibraryofcambodia.org

ឃាត់ទុកថា អនុជានាមិ ភិក្ខវេ មាតាបិតូនំ ទាតុំ ។ ភិក្ខវេ សទ្ធាទេយ្យំ វិនិបាតេតព្វំ... ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតដើម្បីឲ្យរបស់ដែលទាយកឲ្យដោយសទ្ធា ដល់មាតាបិតា តែថាកុំញុំាងរបស់ដែលគេឲ្យដោយសទ្ធា ឲ្យធ្លាក់ចុះ ឲ្យវិនាស ឲ្យខូច គឺឲ្យដល់ញាតិដ៏សេស បើឲ្យធ្លាក់ចុះដូច្នោះ ត្រូវទុក្កដ ។ សូម្បីមាតានឹងបិតាបិតនៅក្នុងរាជសម្បត្តិ បើប្រាថ្នាហើយក៏គួរឲ្យ ។ របស់ទានដែលបានមកថ្មីនៅមិនទាន់បានទានសោះ ឈ្មោះថាអនាមដ្ឋបិណ្ឌបាត អនាមដ្ឋបិណ្ឌបាតនេះ ក៏ឈ្មោះថាសទ្ធាទេយ្យ របស់គេឲ្យដោយសទ្ធា ។ ក្នុងរឿងធ្វើថ្នាំ អដ្ឋកថាចារ្យលើកយកអនាមដ្ឋបិណ្ឌបាតមួយចំពូកឡើងពោលផង ហាក់ដូចជានឹងបង្អួលឲ្យជាប្រធាន ក្នុងបច្ច័យដ៏សេស អ្នកមានបញ្ញាគប្បីពិចារណាមើលចុះ ។

ទមួយ ភិក្ខុក៏គប្បីធ្វើថ្នាំឲ្យដល់មនុស្សមិនមែនញាតិ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកក្នុងវិនីតវត្ថុថា អាបត្តិ ទុក្កដស្ស ដូច្នេះ ។ ព្រោះហេតុនោះ អ្នកដទៃមកសូមថ្នាំ កុំគប្បីធ្វើឲ្យ បើធ្វើឲ្យត្រូវទុក្កដ ។ ភិក្ខុ ភិក្ខុនី នាងសិក្ខមានា សាមណេរ សាមណេរី ទាំង៥នេះ ឈ្មោះថាសហធម្មិក គប្បីធ្វើថ្នាំឲ្យចុះ ដ្បិតជនទាំងអម្បាលនេះ មានសីល សទ្ធា បញ្ញាស្មើគ្នា ប្រកបក្នុងត្រៃសិក្ខា ទើបមិនធ្វើថ្នាំឲ្យមិនបាន កាលនឹងធ្វើឲ្យ បើគ្រឿងថ្នាំមនុស្សអម្បាលនេះមានសោត ក៏គប្បីយកមកផ្សំឲ្យ បើមិនមានក៏គប្បីយកគ្រឿងថ្នាំរបស់ខ្លួនមកធ្វើឲ្យ បើរបស់ខ្លួនមិនមានសោត ក៏

www.budinst.gov.kh www.elibraryofcambodia.org

គប្បីស្វែងរកដោយភិក្ខាចារវត្ត ឬស្វែងរកអំពីញាតិនឹងមនុស្សបវារណា កាលបើមិនបាន ក៏គប្បីរក សូម្បីដោយអកតវិញ្ញត្តិ ដើម្បីមនុស្សឈឺនេះ ហើយគប្បីធ្វើឲ្យ សូម្បីមនុស្សទាំង ៨ ចំពូកគឺ មាតា បិតា អ្នកឧបដ្ឋាកមាតាបិតា វេយ្យាវច្ចកររបស់ខ្លួន បណ្ឌុបលាសៈ គឺមនុស្សអ្នកនឹងមកបួស ចាត់ចែងជុតបាត្រជ្រលក់ចីវរនៅក្នុងវិហារ នឹងធ្វើថ្នាំឲ្យដល់មនុស្សទាំងអម្បាលនេះក៏គួរ ៗ បើមាតាបិតាជាឥស្សរជនមិនប្រាថ្នា នឹងមិនធ្វើឲ្យក៏គួរ ៗ បើឋិតនៅក្នុងរាជសម្បត្តិហើយ តែប្រាថ្នានឹងឲ្យធ្វើ នឹងមិនធ្វើឲ្យមិនគួរ ៗ មាតាបិតាកាលបើប្រាថ្នាថ្នាំ គប្បីឲ្យថ្នាំ កាលបើមិនចេះផ្សំ គប្បីផ្សំឲ្យ គប្បីស្វែងរកថ្នាំ ដើម្បីប្រយោជន៍ដល់មនុស្ស ៨ ចំពូកនេះ ដោយន័យដូចពោលហើយក្នុងសហធម្មិកចុះ ៗ បើនាំមាតាមកបដិបត្តិក្នុងវិហារ កុំបាប់ពាល់ គប្បីធ្វើនូវបរិកម្មទាំងពួង គប្បីឲ្យខាទនីយៈភោជនីយៈដោយដៃខ្លួន ចំណែកបិតា គប្បីធ្វើការឧបដ្ឋាក មានផ្ងូតទឹកនឹងច្របាច់ដោយដៃខ្លួនជាដើម ដូចឧបដ្ឋាកសាមណេរ សូម្បីអ្នកឧបដ្ឋាកមាតាបិតា ក៏គួរធ្វើឲ្យ ដូចមាតាបិតាចុះ ៗ មនុស្សវេយ្យាវច្ចករនោះ ចំពូកណាកាន់យកឈ្នួលហើយ ទៅកាប់ឧសក្នុងព្រៃ ឬក៏ពុំតែធ្វើការណាមួយ កាលមានរោគកើតឡើង គប្បីធ្វើថ្នាំឲ្យដល់អ្នកនោះ ចាំកំញាតិគេនឹងមកឃើញ ៗ អ្នកណាជាសិស្សនៃភិក្ខុនៅធ្វើការទាំងពួង អ្នកនោះគួរភិក្ខុនឹងធ្វើថ្នាំឲ្យជាប្រាកដ សូម្បីក្នុងបណ្ឌុបលាសៈ ក៏គួរបដិបត្តិដូចសាមណេរនោះចុះ ៗ មនុស្ស ១០ ចំពូកទៀត គឺបងប្រុស ប្អូនប្រុស បងស្រី ប្អូនស្រី បង

www.budinst.gov.kh www.elibraryofcambodia.org

ស្រីមាតា ប្អូនស្រីមាតា បងប្រុសបិតា ប្អូនប្រុសបិតា បងស្រីប្អូនស្រីបិតា បងប្រុសប្អូនប្រុសមាតា ធ្វើថ្នាំឲ្យដល់មនុស្ស ១០ ចំពូកនេះក៏គួរ ។ កាលនឹងធ្វើឲ្យ គប្បីកាន់យកគ្រឿងថ្នាំរបស់មនុស្សចំពូកនោះមក គ្រាន់តែផ្សំឲ្យ បើគ្រឿងថ្នាំមនុស្សអម្បាលនោះមិនមាន គេសូមថា លោកចូរឲ្យចុះ ខ្ញុំព្រះករុណានឹងសងវិញ ក៏គប្បីឲ្យជារបស់ខ្ចី បើគេមិនសូម ក៏គប្បីប្រាប់ថា ថ្នាំរបស់យើងមាន អ្នកចូរខ្ចីយកទៅចុះ ឬគប្បីបងចិត្តថា របស់គេមានកាលណា គេនឹងឲ្យកាលណោះវិញ ដូច្នេះ ធ្វើឲ្យទៅចុះ ។ បើគេសងវិញក៏គួរកាន់យក បើគេមិនសងក៏កុំទារអំពីគេ ។ កុំគប្បីឲ្យថ្នាំដល់មនុស្សដទៃក្រៅអំពីញាតិ ១០ ចំពូកនោះ ។ ឯភិក្ខុកាលឲ្យគេយកបច្ច័យ ៤ មកឲ្យដល់ខ្លួន ដោយលំដាប់បុគ្គលនៃញាតិ ១០ នោះដរាបដល់វង្សត្រកូល ៧ ជំណា មិនជាអកតវិញ្ញត្តិ ធ្វើថ្នាំឲ្យមិនជាវេជ្ជកម្ម មិនជាអាបត្តិ ព្រោះកុលទូសកៈ ។ បើភរិយានៃបងប្អូនប្រុស ឬស្វាមីនៃបងប្អូនស្រី គេមានជម្ងឺ បើគេជាញាតិពិត ធ្វើថ្នាំឲ្យគេផងក៏គួរ បើគេមិនមែនជាញាតិ គប្បីធ្វើឲ្យដល់បងប្អូនប្រុស ឬបងប្អូនស្រីរបស់ខ្លួនថា អ្នកចូរឲ្យក្នុងទីបដិបត្តិនៃអ្នកចុះ ។ មួយទៀត គប្បីធ្វើឲ្យដល់បុគ្គលនៃមនុស្សទាំងអម្បាលនោះ ហើយប្រាប់ថា ឯងចូរឲ្យដល់មាតាបិតារបស់ឯងចុះ ។ វិនិច្ឆ័យក្នុងបទទាំងពួង គប្បីដឹងដោយឧបាយនេះ ។ កាលនឹងប្រើសាមណេរឲ្យរកថ្នាំមកអំពីព្រៃ ដើម្បីញាតិទាំងអម្បាលនោះ គប្បីប្រើសាមណេរដែលជាញាតិឲ្យរកមក ឬឲ្យរកមកដើម្បីខ្លួន សូម្បីសាមណេរ

សោក គប្បីរកមកដោយវត្តនៃសិស្សថា យើងនឹងយកមកឲ្យឧបជ្ឈាយ៍ដូច្នេះ ។ មាតាបិតានៃឧបជ្ឈាយ៍មានជម្ងឺមកកាន់វិហារ ឧបជ្ឈាយ៍ចៀសចេញទៅកាន់ទិស សទ្ធិវិហារិកគប្បីកាន់យកគ្រឿងថ្នាំរបស់ឧបជ្ឈាយ៍ធ្វើឲ្យ បើគ្រឿងថ្នាំរបស់ឧបជ្ឈាយ៍មិនមាន គប្បីលះថ្នាំរបស់ខ្លួនដើម្បីឧបជ្ឈាយ៍ហើយធ្វើឲ្យចុះ បើរបស់ខ្លួនមិនមាន គប្បីស្វែងរកដោយភិក្ខាចារវត្តជាដើមដូចពោលហើយ ធ្វើឲ្យជារបស់ឧបជ្ឈាយ៍ហើយទើបឲ្យចុះ ។ សូម្បីតែឧបជ្ឈាយ៍សោក ក៏គួរតែបដិបត្តិក្នុងមាតាបិតានៃសទ្ធិវិហារិកដូចគ្នានោះចុះ ។ ក្នុងអាចារ្យនិងអន្តេវាសិកក៏ដូចគ្នា ។ សូម្បីមនុស្សដទៃណាជាគាតុកៈ ឬជាចោរ ឬជាមនុស្សចាញ់ទ័ពគេមក ឬជាមនុស្សឥស្សរៈ ឬជាមនុស្សគឺញាតិលះបង់ចោល ជាមនុស្សដំណើរ មនុស្សទាំងអម្បាលនេះមានជម្ងឺចូលមកកាន់វត្ត ភិក្ខុកាលមិនប្រាថ្នាវត្ថុអ្វី ក៏គប្បីធ្វើថ្នាំឲ្យដល់មនុស្សទាំងអម្បាលនោះចុះ ។ ត្រកូលអ្នកមានសទ្ធាឧបដ្ឋាកដោយចតុប្បច្ច័យឋិតនៅក្នុងទីជាមាតាបិតានៃសង្ឃ ក្នុងត្រកូលនោះ បើអ្នកណាមួយមានជម្ងឺ គេអាស្រ័យមនុស្សឈឺ ពោលដោយវិស្សាសៈថា លោកចូរធ្វើថ្នាំឲ្យដូច្នេះ កុំគប្បីឲ្យ កុំគប្បីធ្វើឡើយ បើគេដឹងកាលជាសមគួរហើយសួរថា រោគដូច្នេះគេធ្វើថ្នាំដូចម្តេច នឹងពោលថា គេយកវត្ថុនេះផង វត្ថុនោះផង មកផ្សំធ្វើជាថ្នាំដូច្នេះគួរ បើគេថាមាតាខ្ញុំព្រះករុណាឈឺ លោកចូរប្រាប់ថ្នាំដល់ខ្ញុំព្រះករុណាចុះ កុំគប្បីប្រាប់ គប្បីនិយាយនូវគ្នានឹងគ្នាថា ភិក្ខុឈ្មោះឯណោះ កើតរោគដូច្នេះ គេផ្សំថ្នាំដូចម្តេច ភិក្ខុផងគ្នានិយាយ

www.budinst.gov.kh www.elibraryofcambodia.org

ទៀតថា គេយកវត្ថុខ្លះៗ មកផ្សំថ្នាំ គ្រហស្ថគេបានពុតាំបាន យកទៅ ធ្វើថ្នាំឲ្យដល់មាតាគេដូច្នេះក៏គួរ ៗ បានពុថា សូម្បីព្រះមហាបទុមត្ថេរ លោកក៏បដិបត្តិដូច្នេះដែរ គប្បីបដិបត្តិក្នុងភេសជ្ជៈ ដូច្នេះ ៗ ក៏ឯខន្ធ បរិត្ត បើគ្រហស្ថពោលថា លោកចូរធ្វើបរិត្តឲ្យដល់មនុស្សឈឺដូច្នេះ ភិក្ខុ កុំគប្បីធ្វើ កាលណាបើគេពោលថា លោកចូរសូត្របរិត្តឲ្យដល់មនុស្ស ឈឺស្តាប់ គប្បីធ្វើចុះ បើទឹងគិតថា ធម្មតាមនុស្សរមែងមិនដឹងអ្វី កាល បើយើងមិនបានធ្វើឲ្យ ក៏នឹងកើតក្តៅក្រហាយចិត្តជៀងៗ ដូច្នេះ គប្បីធ្វើ ឲ្យចុះ ៗ គេពោលថា លោកចូរធ្វើទឹកបរិត្ត ធ្វើខ្សែបរិត្តឲ្យដូច្នេះ គប្បីយក ដៃកកូរទឹកច្របាច់អម្បោះហើយឲ្យទៅគេចុះ ៗ បើឲ្យទឹកទៅអំពីវត្ត ឬឲ្យ អម្បោះរបស់ខ្លួនសោត ត្រូវទុកដ ៗ បើគេយកទឹកនិងអម្បោះមកអង្គុយ ហើយពោលថា លោកចូរសូត្របរិត្ត ដូច្នេះ គប្បីធ្វើចុះ បើគេមិនដឹង សោត ហើយប្រាប់ភិក្ខុឲ្យអង្គុយនៅ រួចយកទឹកមកដាក់លាងជើង យក អម្បោះដាក់ចុះហើយពោលថា លោកចូរធ្វើបរិត្ត ចូរសូត្របរិត្តដូច្នេះហើយ គេក៏ទៅ ភិក្ខុកុំគប្បីទាញជើងចេញ ដ្បិតថា គេនឹងមានចិត្តក្តៅក្រហាយៗ គេអាស្រ័យមនុស្សឈឺនៅក្នុងភូមិ បញ្ជូនដំណឹងមកកាន់វត្តថា ព្រះករុ- ណាទាំងឡាយចូរសូត្របរិត្តដូច្នេះ គប្បីសូត្រចុះ ៗ រោគ ឬ ឧបទ្រវៈកើត ឡើងក្នុងស្រុកនឹងទឹកជន់ជាដើម គេនិមន្តឲ្យចូលទៅសូត្របរិត្ត ក៏គប្បី សូត្រអាដានាដិយសូត្រ ជាដើម ៗ គេនិមន្តឲ្យទៅឲ្យសិក្ខាបទ ដំ បើដែលជម្ងឺក្នុងព្រះរាជវាំង ឬ ផ្ទះអាមាត្យ ក៏គប្បីទៅឲ្យសិក្ខាបទ ដំ

www.budinst.gov.kh www.elibraryofcambodia.org

សំរែងផមចុះ ។ គេនិមន្តឲ្យទៅជាបរិកកំដរមនុស្សស្លាប់ កុំគប្បីទៅ ។ បើទៅដោយកម្មដ្ឋានជាប្រធាន គឺគិតថា នឹងបានមរណស្សតិ ព្រោះឃើញព្រៃស្មសាន នឹងឃើញអសុភដូច្នេះក៏គួរ គប្បីបដិបត្តិក្នុងបរិត្ត ដូចពណ៌នាមកដូច្នេះឯង ។

ក៏ក្នុងបិណ្ឌបាតទៀតសោត របស់ឆាន់ ដែលមិនទាន់ឆាន់ឈ្មោះ ាអនាមដ្ឋបិណ្ឌបាត គួរគប្បីឲ្យដល់អ្នកណា មិនគួរគប្បីឲ្យដល់អ្នកណា រួរគប្បីឲ្យដល់មាតាបិតាប៉ុណ្ណោះ សូម្បីបិណ្ឌបាតនោះតម្លៃ ១ កហាបណៈ ក៏ មិនជាសទ្ធាទេយ្យវិនិបាត មនុស្សឲ្យបដ្ឋកមាតាបិតា វេយ្យាវច្ចករ ម្មការសង្ឃ បណ្ឌុបលាសៈ សូម្បីមនុស្សទាំងអម្បាលនេះ ក៏គប្បីឲ្យ អនាមដ្ឋបិណ្ឌបាតចុះ ។ បណ្ឌុបលាសនោះ សូម្បីដាក់ចុះក្នុងភាជនៈ របស់ខ្លួនហើយឲ្យក៏គួរ មនុស្សក្រៅនោះជាគ្រហស្ថ សូម្បីជាមាតាបិតា ាក់ចុះក្នុងភាជនៈរបស់ខ្លួនឲ្យ មិនគួរ ព្រោះជាបរិក្ខារគ្រឿងប្រើប្រាស់ របព្វជិត បិតនៅក្នុងទីជាបតិយដ្ឋាននៃគ្រហស្ថ ។

មួយទៀត អនាមដ្ឋបិណ្ឌបាត គប្បីឲ្យដល់ដាមរិកចោរ នឹងមនុស្ស ស្សរៈដែលមកដល់ ដ្បិតមនុស្សទាំងអម្បាលនោះ កាលមិនឲ្យក៏ ក្រោធទឹងថាមិនឲ្យ បើឲ្យរបស់ដែលឆាន់សល់ហើយក៏ក្រោធទឹងថា ឲ្យ សល់ជាសំណល់ ក្រោធទឹងហើយក៏នឹងសម្លាប់ នឹងធ្វើឲ្យអន្តរាយដល់ សនាផង គប្បីបដិបត្តិក្នុងអនាមដ្ឋបិណ្ឌបាតដូចពោលមកនេះ ។ ក៏ឯ វិសណ្ឋារនោះ គប្បីធ្វើដល់អ្នកណា មិនគប្បីធ្វើដល់អ្នកណា ឯ

www.budinst.gov.kh www.elibraryofcambodia.org

បដិសណ្ឋារៈនេះ គួរធ្វើដល់អាគន្តុកៈ មនុស្សមកថ្មី ឬមនុស្សក្រ ឬចោរ ឬមនុស្សជាឥស្សរៈ ណាមួយក្តី ដែលមកដល់វិហារ ទើបគួរធ្វើ ដូចម្តេច បើឃើញមនុស្សអាគន្តុកៈអស់ស្បៀងមកដល់វិហារ គប្បីឲ្យទឹកផឹក ឲ្យប្រេងលាបជើង បើគេមកដល់ក្នុងវេលាព្រឹក គប្បីឲ្យបបរនិងបាយ គេមកដល់ក្នុងវិកាល បើអង្ករមានសោតគប្បីឲ្យអង្ករ កុំគប្បីពោលថា អ្នកមកដល់ខុសពេល អ្នកចូរទៅចុះ គប្បីរកទីដំណេកឲ្យ កុំប្រាថ្នានូវវត្ថុណាមួយឡើយ គប្បីធ្វើនូវកិច្ចទាំងពួងចុះ គិតថា វិស័យមនុស្សរមែងជាអ្នកឲ្យបច្ច័យ កាលបើយើងសង្គ្រោះគេដូច្នេះ គេនឹងជ្រះថ្លាឡើង ៗ ហើយគេនឹងធ្វើឧបការៈ ដំនិតគិតដូច្នេះ កុំឲ្យបង្កើតឡើងបាន ។ ក៏ឯចោរ សូម្បីគណៈរបស់សង្ឃ ក៏គប្បីឲ្យទៅចុះ ដើម្បីនឹងការពារកុំឲ្យមានអន្តរាយខូចដល់គណៈសង្ឃដទៃបាន ។ ក្នុងអដ្ឋកថាលោកនិទានរឿង ភិក្ខុសង្គ្រោះដល់ចោរដោយគណៈសង្ឃដូច្នេះ ទុកជាច្រើនរឿង ដើម្បីនឹងសំដែងអានិសង្សនៃបដិសណ្ឋារៈ អ្នកមានប្រាថ្នាបង់ដឹងគប្បីមើលយកចុះ គប្បីបដិបត្តិក្នុងបដិសណ្ឋារៈដូចពណ៌នាមកនេះចុះ ។

សន្ថារវេយ្យាវច្ចកថា ចប់

---

## កុលទូសកកម្ម

១មួយ ភិក្ខុកុំគប្បីនាំសាសនៈទីដំណើងគ្រហស្ថ ។ ១មួយ ភិក្ខុកុំគប្បីសង្គ្រោះត្រកូលដោយឲ្យផ្កាឈើ ផ្លែឈើជាដើម ។ ដ្បិតក្នុងវិភង្គនៃកុល

www.budinst.gov.kh www.elibraryofcambodia.org

ទូសកសិក្ខាបទ ពោលថា ភិក្ខុឲ្យផ្កាឈើ ផ្លែឈើ លំអិត ឬ ឈើស្ទន់ ឬស្សី ធ្វើវេជ្ជកម្ម បួនាំសាសនៈ គឺដំណឹងនៃគ្រហស្ថមិនមែនញាតិ ទាំងអម្បាលនេះ ឈ្មោះថា កុលទូសក ប្រទូសត្រកូល គឺធ្វើសេចក្ដីជ្រះថ្លានៃត្រកូលឲ្យសាបសូន្យទៅ ដោយកិរិយាបដិបត្តិអាក្រក់ ខុសចាកកិច្ចនៃខ្លួន មិនឈ្មោះថា ធ្វើផលទានរបស់គេឲ្យសាបសូន្យទៅផង ដោយធ្វើការសង្គ្រោះដល់គេ គេមិនបានឲ្យដោយសេចក្ដីជ្រះថ្លាក្នុងគុណ មានសីលជាដើម ។ វេជ្ជកម្ម វិធីធ្វើថ្នាំនោះ គប្បីដឹងដូចពោលហើយក្នុងមុននោះចុះ ។

មួយទៀត បុគ្គលណាចាស់លោកពោលថា ត្រូវមើល ឫក្ស យាម ក៏ឈ្មោះថាវេជ្ជកម្មដែរ ។

ពណ៌នាអំពីជង្ឃបេសនិយៈជាមុន ភិក្ខុទទួលសាសនៈ គឺដំណឹងនៃគ្រហស្ថហើយដើរទៅ ត្រូវអាបត្តិទុក្កដ គ្រប់ៗបទវារៈ ។ សូម្បីទាំងភោជន ដែលខ្លួនបានមកព្រោះអាស្រ័យកម្មនោះ ក៏ត្រូវទុក្កដ គ្រប់ការៈដែលលេប ។ សូម្បីអំពីដំបូងមិនទទួលពាក្យបណ្ដាំគេ លុះត្រាក្រោយគិតថា ប្រទេសនេះជាស្រុកដែលគេផ្ដាំនោះ ឥឡូវយើងមកដល់ហើយ យើងជួយប្រាប់ឲ្យគេចុះ សូម្បីចុះតាមផ្លូវទៅ ក៏ត្រូវទុក្កដគ្រប់ៗជំហាន ។ កាលឆាន់ភោជនដែលខ្លួនបានព្រោះប្រាប់នូវពាក្យបណ្ដាំនោះក៏ត្រូវទុក្កដ ដោយន័យដូចពោលហើយក្នុងមុន ។ ក៏ឯមិនបានទទួលពាក្យបណ្ដាំគេ មកដល់ហើយគេសួរថា មនុស្សឈ្មោះនេះ

www.budinst.gov.kh www.elibraryofcambodia.org

នៅក្នុងភូមិនោះ ដំណឹងតើដូចម្តេចខ្លះ ដូច្នេះនឹងប្រាប់គេក៏គួរ ។ ក្នុងប្រស្នា ដែលគេសួរ ប្រាប់គេមិនមានទោស ។ ក៏ឯការនាំសាសនៈដំណឹងនៃ សហធម្មិកទាំង ៥ នឹងមាតាបិតាក្តី នឹងបណ្ឌុបលាស នឹងមនុស្សវេយ្យា-វច្ចករនៃខ្លួនក្តី ទាំងអម្បាលនេះក៏គួរ ។ ឬគេផ្តាំថា លោកចូរនមស្ការ ចេតិយ បដិមា ពោធិព្រឹក្ស ព្រះសង្ឃត្ថេរ តាមពាក្យខ្ញុំព្រះករុណាក្តី លោកចូរឲ្យភិក្ខុប្រជុំគ្នា ខ្ញុំព្រះករុណានឹងថ្វាយទាន នឹងស្តាប់ធម៌ក្តី ក្នុង ដំណឹងទាំងអម្បាលនេះ កុំរង្កៀសឡើយ ដំណឹងទាំងអស់នេះ ជាកប្បិយ-សាសនៈ មិនប្រកបទៅដោយកម្មនៃគ្រហស្ថ មិនជាជង្ឃបេសនិយៈ ។

ពណ៌នាអំពីការៈមានឲ្យផ្កាឈើជាដើម ភិក្ខុណា នាំទៅឯង ឬ ឲ្យអ្នកដទៃនាំទៅ ហៅមកឯង ឬឲ្យអ្នកដទៃហៅមក ឬគេមកខ្លួនឯង ឲ្យផ្កា ឈើ តែណាមួយដែលជារបស់ខ្លួនដើម្បីសង្គ្រោះដល់ត្រកូល ត្រូវទុក្កដ ។ ឲ្យផ្កាឈើរបស់អ្នកដទៃក៏ត្រូវទុក្កដ ឲ្យដោយថេយ្យចិត្ត គប្បីកាត់អាបត្តិ តាមតម្លៃរបស់ ។ សូម្បីក្នុងផ្កាឈើរបស់សង្ឃក៏ដូចគ្នា ក៏ប៉ុន្តែវិសេសប្លែក គ្នា ដោយផ្កាឈើ ដែលគេនិយមដើម្បីសេនាសនៈ ឲ្យដោយសេចក្តីជា ឥស្សរៈត្រូវថុល្លច្ច័យ ។ ផ្កាឈើនឹងគួរឲ្យដល់អ្នកណា មិនគួរឲ្យដល់អ្នក ណា គួរឲ្យដល់មាតាបិតាមុន នឹងយកទៅឲ្យដោយខ្លួនឯង ឬឲ្យអ្នកដទៃ យកទៅឲ្យ នឹងហៅមកឯង ឬឲ្យគេហៅមកឲ្យក៏គួរ ញាតិដ៏សេសឲ្យគេ ហៅមក ហើយទើបឲ្យគួរ ។ ក្នុងកិរិយាឲ្យនោះ ដើម្បីនឹងបូជាវត្ថុទាំង ៣ ទើបគួរ បើឲ្យដល់អ្នកណាមួយ ដើម្បីប្រដាប់ ឬបូជាសិវលិង្គជាដើម

www.budinst.gov.kh www.elibraryofcambodia.org

មិនគួរ ។ កាលនឹងឲ្យមនុស្សយកទៅឲ្យដល់មាតាបិតា គប្បីឲ្យសាមណេរជាញាតិយកទៅឲ្យ បើសាមណេរមិនមែនជាញាតិ ប្រាប់ថានឹងយកទៅឲ្យខ្លួនឯងសោត នឹងឲ្យយកទៅក៏គួរ ។ ភិក្ខុអ្នកចែកផ្កាឈើដែលសង្ឃសន្មតទុក នឹងឲ្យចំណែកពាក់កណ្តាលដល់សាមណេរ ដែលមកកាន់ក្នុងវេលាចែកក៏គួរ ។ ក្នុងកុរុន្ទី ថា ឲ្យដល់គ្រហស្ថពាក់កណ្តាលចំណែក ក្នុងមហាបច្ចរី ថាឲ្យតែបន្តិចក៏គួរ ។ ភិក្ខុដែលសង្ឃមិនបានសន្មតទុក គប្បីអបលោកន៍សិនសឹមឲ្យ ។ សាមណេរគោរពក្នុងអាចារ្យនឹងឧបជ្ឈាយ៍ បេះផ្កាឈើមកច្រើនគរទុក ព្រះថេរៈប្រាប់ដល់សទ្ធិវិហារិកជាដើម ឬដល់ឧបាសកដែលមកកាន់អំពីព្រឹក ថាអ្នកចូរកាន់យកផ្កាឈើនេះចុះ មិនឈ្មោះថាបុប្ផទាន (ឲ្យផ្កាឈើ) ។ ភិក្ខុកាន់យកផ្កាឈើទៅ គិតនឹងបូជាព្រះចេតិយ ឬធ្វើការបូជា ឲ្យផ្កាឈើដល់គ្រហស្ថដែលមកដល់ក្នុងទីនោះ ដើម្បីនឹងបូជាព្រះចេតិយ សូម្បីដូច្នោះក៏មិនឈ្មោះថាបុប្ផទាន ។ ភិក្ខុឃើញឧបាសក គេបូជាដោយផ្កាកក់ជាដើម ហើយពោលថាផ្កាកណ្ណិការជាដើមក៏មានទៅក្នុងវិហារ ឧបាសកចូរកាន់យកទៅបូជាចុះ ដូច្នេះក៏គួរ ។ ភិក្ខុបូជាដោយផ្កាឈើ ហើយចូលទៅស្រុកថ្ងៃណាស់ គេសួរថា ហេតុអ្វីទើបចូលមកថ្ងៃពេក ប្រាប់ថាផ្កាឈើក្នុងវិហារច្រើន យើងរវល់ធ្វើការជា មនុស្សគេគិតថា ផ្កាឈើក្នុងវិហារមានច្រើន ព្រឹកឡើងគេកាន់គ្រឿងខាទនីយភោជនីយាហារមកកាន់វិហារ ធ្វើបុប្ផបូជា ហើយថ្វាយទានក៏គួរ ។ មនុស្សទាំងឡាយគេសូមករៈបូជាផ្កាឈើថា ដល់ថ្ងៃនោះ

www.budinst.gov.kh www.elibraryofcambodia.org

ចំព្រះគុណា ទឹងទៅបូជា ហើយគេមកក្នុងថ្ងៃដល់ភិក្ខុអនុញ្ញាតឲ្យផ្កាឈើ តែផ្កាសាមណេរបេះមកទុកអំពីព្រឹកហើយ គេមកមិនឃើញផ្កានៅឡើយ គេសួរថា ផ្កាទៅណាអស់ទៅ ភិក្ខុប្រាប់ថា សាមណេរបេះមកអស់ហើយ ព្រោះរូបយកផ្កានោះទៅបូជាចុះ សង្ឃនឹងបូជាថ្ងៃដទៃដូច្នេះ គេទើបយកផ្កានោះបូជា ហើយទើបថ្វាយតាមគេទៅ ដូច្នេះក៏គួរ ។ ក្នុងមហាបច្ចរីនឹងកុរុន្ទីពោលថា ព្រះថេរៈនឹងប្រើសាមណេរឲ្យយកផ្កាឲ្យគេនោះមិនបាន បើសាមណេរឲ្យផ្កានោះដល់គេ ដោយខ្លួនឯងក៏គួរ ។ ចំណែកព្រះថេរៈគប្បីពោលត្រឹមតែពាក្យថា សាមណេរបេះអស់ទៅហើយប៉ុណ្ណោះ បើគេសួរថា ផ្កាឈើទុកហើយ ផ្កានោះនៅមិនទាន់បានបេះ គេកាន់យកបបរបាយជាដើម មកពីសាមណេរឲ្យបេះ នឹងឲ្យសាមណេរជាញាតិបេះឲ្យក៏គួរ ។ សាមណេរមិនមែនញាតិ គេលើកឡើងដាក់លើមែកឈើក៏កុំគប្បីចុះរត់ចេញទៅ នឹងបេះឲ្យក៏គួរ ។ បើធម្មកថិកណាមួយពោលថា អ្នកឧបាសកផ្កាឈើក្នុងវត្តមានច្រើន អ្នកចូរកាន់យកបបរ បាយ ទៅធ្វើការបូជាចុះដូច្នេះ ក្នុងមហាបច្ចរីនឹងកុរុន្ទីពោលថា មិនគួរ ផលធម្មកថិកតែមួយអង្គនោះ ។ ឯក្នុងមហាអដ្ឋកថាពោលមិនវិសេស ថាត្រឹមតែរបស់នោះ ជាអកប្បិយៈមិនគួរដូច្នេះ ។ សូម្បីផ្លែឈើជារបស់ខ្លួននឹងឲ្យដល់មាតាបិតានឹងញាតិដ៏សេស តាមន័យដែលពោលហើយនោះក៏គួរ ។ ក៏កាលឲ្យ ដើម្បីសង្គ្រោះត្រកូល ក្នុងផ្លែឈើជារបស់ខ្លួន នឹងជារបស់អ្នកដទៃ ឬជារបស់សង្ឃ ឬជារបស់គេនិយមទុក ដើម្បីសេនាសនៈ ឲ្យ

www.budinst.gov.kh www.elibraryofcambodia.org

ដឹងជាត្រូវអាបត្តិទុក្កដជាដើម តាមន័យដូចពោលហើយនោះចុះ ។ នឹងឲ្យផ្លែឈើរបស់ខ្លួនដល់មនុស្សឈឺ ឬមនុស្សជាឥស្សរៈ នឹងមនុស្សអស់ស្បៀងចូលមកដល់ក៏គួរ មិនជាផលទាន (ឲ្យផ្លែឈើ) ។ សូម្បីភិក្ខុអ្នកចែកផ្លែឈើ ដែលសង្ឃសន្មតទុកហើយ នឹងឲ្យកន្លះភាគដល់មនុស្សចូលមកដល់ក្នុងខណៈចែកដល់សង្ឃក៏គួរ ។ អ្នកដែលសង្ឃមិនបានសន្មតទុក គប្បីអបលោកន៍មុនសិនឲ្យ សូម្បីក្នុងសង្ឃរាម ក៏គប្បីធ្វើកតិកាទុក ដោយកំណត់ផ្លែ ឬកំណត់ដើមឈើ កាលមនុស្សឈឺ ឬមនុស្សដទៃមកសូមផ្លែឈើអំពីចំណែកនោះ គប្បីឲ្យផ្លែ ៤ ឬ ៥ ឬចង្អុលដើមឈើនោះឲ្យ តាមកំណត់ថា នឹងកាន់យកអំពីដើមនេះបានដូច្នេះ កុំពោលថាផ្លែដើមនេះល្អ អ្នកចូរកាន់យកអំពីដើមនេះចុះដូច្នេះ ។ លំអិត ឬចិត អម្ចុត់ដទៃជារបស់នៃខ្លួន យកមកឲ្យដើម្បីសង្គ្រោះត្រកូល ត្រូវទុក្កដ ។ សូម្បីលំអិតជារបស់នៃអ្នកដទៃជាដើម គប្បីវិនិច្ឆ័យតាមន័យដូចពោលហើយនោះចុះ ប៉ុន្តែបែកគ្នាដូច្នេះ គ្រឿងឈើជារបស់សង្ឃ សូម្បីមានអ្នករក្សាហួនវែន ក៏ជាគរុភណ្ឌ សូម្បីដីនឹងឈើស្ងួត ឬស្លឹកឬស្សី ក៏គប្បីដឹងវត្ថុដែលគួរជាគរុភណ្ឌ ហើយវិនិច្ឆ័យតាមន័យដូចពោលហើយក្នុងចុណ្ណៈគឺលំអិតនោះចុះ ។ ក៏ឯបណ្ណទាន ឲ្យស្លឹកឈើ មិនមានមកក្នុងបាលីនេះផង ក៏អាការៈដែលឲ្យស្លឹកឈើនោះ ក៏គប្បីដឹងតាមន័យដូចបានពណ៌នាហើយចុះ ។ បច្ច័យៈកើតអំពីកុលទូសកកម្មទាំង ៥ នេះ មិនគួរដល់សហធម្មិកទាំង ៥ ដូចបច្ច័យដែលកើតអំពីអុត្តរិមនុស្សធម្ម

www.budinst.gov.kh www.elibraryofcambodia.org

នឹងផ្លាស់ប្តូរដោយរូបិយ ។ កុសលមូលកកម្មនេះមិនគួរដល់សហធម្មិកទាំង ៥ ផង ។

កុសលមូលកកម្ម ចប់

---

## បាបសមាចារកថា

ខមួយ ភិក្ខុកុំគប្បីប្រព្រឹត្តអនាចារផ្សេង ៗ និងកុំលេងល្បែងផ្សេងៗ មានឧបត្ថម្ភជាដើម ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ឯ ភិក្ខវេ វិវិធំ អនាចារំ អាចរិតព្វំ យោ អាចរេយ្យ យថា-ធម្មោ ការេតព្វោ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកុំគប្បីប្រព្រឹត្ត អនាចារ សេចក្តីប្រព្រឹត្តិមិនគួរ មានប្រការផ្សេង ៗ បើភិក្ខុណាប្រព្រឹត្ត វិនយធរគប្បីកាត់អាបត្តិតាមធម៌ គឺវត្ថុត្រូវបាចិត្តិយ ក៏កាត់អាបត្តិបាចិត្តិយ វត្ថុត្រូវទុក្កដ ក៏កាត់អាបត្តិទុក្កដ ។ យថាធម្មោ កម្មបទនេះ មិនដូចកម្មបទដទៃទេ សង្គ្រោះយកតែបាចិត្តិយមួយបំពួក ។ កម្មវិភង្គនៃកុសលមូលកសិក្ខាបទថា ដាំឯង ឬប្រើគេឲ្យដាំនូវគុម្ពឈើ ស្រោចឯង ឬប្រើអ្នកដទៃឲ្យស្រោច បេះឯង ឬឲ្យអ្នកដទៃបេះ ដោតក្រងឯង ឬឲ្យអ្នកដទៃដោតក្រង ឈ្មោះថាបាបសមាចារៈ (ប្រព្រឹត្តមារយាទអាក្រក់) ។

ខឹងពណ៌នាតាមលំដាប់នេះជាបុន វិធីដាំឯង ឬឲ្យអ្នកដទៃដាំ ស្រោចឯង ឬឲ្យអ្នកដទៃស្រោចនេះ គប្បីដឹង អត្ថប្បយោគហារ កប្បិយពោហារ បរិយាយ ឱភាស និងនិមិត្តកម្ម ៥ ប្រការនេះជាមុន បុគ្គលដែលឯង ឬឲ្យអ្នក

ផលេចចុះបោកខ្លួនដើមឈើស្រស់ទៀត ជីកឯង ឬឲ្យអ្នកដទៃជីករណ្ដៅ ដាំឯង ឬឲ្យអ្នកដទៃដាំគុម្ពឈើ ពូនឯង ឬឲ្យអ្នកដទៃពូនគំនរដី ស្រោចឯង ឬឲ្យអ្នកដទៃស្រោចខ្លួនទឹក ធ្វើប្រឡាយឲ្យត្រង់ហូរទៅកាន់គុម្ពឈើ និងស្រោចដោយទឹកជាអកប្បិយ និងធាក់ទឹកលាងដៃលាងជើងចុះ ក្រុមមុខទីគកន៍គុម្ពឈើ ទាំងអម្បាលនេះ ឈ្មោះថាអកប្បិយវោហារមិនគួរ ៗ ពោលថា អ្នកចូរជីកខ្លួនដើមឈើនេះ ចូរជីករណ្ដៅនេះ ចូរជីកគុម្ពឈើនេះ ចូរជីកទឹកក្នុងទីនេះដូច្នេះក្ដី ហើយធ្វើប្រឡាយដែលស្ងួត ឲ្យត្រង់ទៅកាន់គុម្ពឈើក្ដី ទាំងអម្បាលនេះ ឈ្មោះថាកប្បិយវោហារ គួរ ៗ ពោលថាអ្នកដឹងគេគប្បីដាំដើមឈើជាដើមនុ៎ះ មិនយូរក៏ប្រព្រឹត្តទៅដើម្បីឧបការៈ ពាក្យដូច្នេះជាដើមឈ្មោះថាបរិយាយ ៗ ក៏គួរកាន់ចបជីក ចបកាប់ ជ្រនិក កាំបិតពូថៅ និងដើមឈើ ឈើរនៅ ឈ្មោះថាឧកាស ផ្សេងថាឈើរនៅដូច្នេះសាមណេរជាដើមបានឃើញហើយនឹងគិតថា ព្រះថេរៈមានបំណងឲ្យដាំដើមឈើ ហើយមកធ្វើឲ្យ ៗ យកចបកាប់ ចបជីក ជ្រនិក កាំបិត ពូថៅភាជនៈផងទឹកមកដាក់ទុក ក្នុងទីជិត ឈ្មោះថានិមិត្តកម្ម អាការទាំង ៤ប្រការនេះ កាលបើដាំដើម្បីសង្គ្រោះត្រកូល មិនគួរទាំងអស់ ដាំដើម្បីបរិភោគផ្លែ មិនគួរតែកប្បិយវោហារ និងអកប្បិយវោហារ ពីរប្រការចុំណោះ អាការៈ ៣ ប្រការក្រៅនោះគួរ ៗ តែក្នុងមហាបច្ចរីពោលថាសូម្បីកប្បិយវោហារក៏គួរ ៗ ដាំដោយអាការៈណាមួយ ដើម្បីនឹងបរិភោគដោយខ្លួនឯងក៏គួរ ៗ អាការៈនោះសូម្បីដើម្បីបុគ្គលដទៃ ក្នុងពិយ ប្ដុសថ្ងៃ

www.budinst.gov.kh www.elibraryofcambodia.org

គិត្តផលចិត្តា ។ ដាំដើម្បីវេរីសក្តិមួយ ដើម្បីជាធ្នាក់ឈើ ទីនេះដើម្បីជារបង មិនគួរតែអកប្បិយវោហារមួយចំនួន ៖ ក្រៅនោះគួរ ។ មិនមែនតែប៉ុណ្ណោះ សូម្បីធ្វើប្រឡាយឲ្យគ្រង់វា ទីនេះស្រោចទឹកជាកប្បិយ ដើម្បីបង្ហូរទឹក ហើយងូតចុះក្តី សូម្បីចាក់ទឹកលាងដៃលាងជើងទីនេះទឹកហូរចុះក្នុងគុម្ព ឈើនោះក្តីក៏គួរ ។ ក្នុងមហាបច្ចរី ទីនេះក្រុងពោលថា ក្នុងផែនដីជាកប្បិយ ទីនេះដាំឯងដើម្បីបូជាក៏គួរ ។ ឯដាំឯងក្តីឲ្យអ្នកដទៃដាំ ដើម្បីជាទីដេករបស់គ្រោ អជាដើម បើមានផ្លែហើយ សូម្បីបរិភោគក៏គួរ ។ ដាំដើមឈើខ្លួនឯង ក្នុងផែនដីជាអកប្បិយ ដើម្បីកុសលទូសកម្ម ត្រូវបាចិត្តិយផង ទុក្កដផង ។ ដាំដោយអកប្បិយវោហារក៏ដូចគ្នា ។ ដាំឯងក្តី ប្រើអ្នកដទៃឲ្យដាំក្នុងផែនដីជា កប្បិយ ត្រូវតែទុក្កដ ។ ក្នុងប្រយោគនេះប្រើគេឲ្យដាំអាំង ២ ៖ នោះ ប្រើឲ្យគេ ដាំតែម្តង គេដាំសូម្បីច្រើនដង ត្រូវបាចិត្តិយ ទីនេះទុក្កដ ឬទុក្កដស្មើតែ ១ ។ ឲ្យគេដាំក្នុងដីជាកប្បិយឬអកប្បិយ ដោយកប្បិយវោហារ ដើម្បីបរិភោគ មិនត្រូវអាបត្តិ ។ ដាំឯងក្នុងអកប្បិយបថវី ឬឲ្យគេដាំដោយពាក្យអកប្បិយ ដើម្បីជារមណីយដ្ឋានជាដើម ត្រូវបាចិត្តិយ ។ ទំយដូច្នេះលោកមិនបាន ថែកចុះដោយប្រពៃក្នុងមហាអដ្ឋកថា ថែកចុះតែក្នុងមហាបច្ចរី ។ គឺង ស្រោចទឹកឯងទីនេះឲ្យអ្នកដទៃស្រោចដោយទឹកជាអកប្បិយ ត្រូវបាចិត្តិយ ក្នុងទីតាំងពួង ។ ដើម្បីកុសលទូសកៈ ទីនេះដើម្បីបរិភោគ ត្រូវទុក្កដ ព្រោះ ឲ្យគេស្រោចដោយទឹកជាកប្បិយ ។ ដើម្បីកុសលទូសកៈ ទីនេះដើម្បីបរិភោគ តាំង ២ នោះត្រូវទុក្កដ ។ ឲ្យគេស្រោចដោយកប្បិយវោហារ ដើម្បីនឹង

www.budinst.gov.kh www.elibraryofcambodia.org

ភោគ មិនត្រូវអាបត្តិ ។ ក្នុងទីដែលទឹកត្រូវអាបត្តិព្រោះស្រោចទឹក គប្បីដឹងថា ត្រូវអាបត្តិ តិច-ច្រើន ដោយដាច់ឈ្នួរទឹក នឹងប្រយោគ ដែលស្រោចទឹកច្រើន-តិចចុះ ។ ក្នុងការបេះឯងនឹងប្រើអ្នកដទៃឲ្យបេះនូវផ្កាឈើ ដើម្បីកុលទូសកៈជាដើម គប្បីដឹងថា ត្រូវទុក្កដ នឹងបាចិត្តិយ តិច-ច្រើន ដោយកប់តាមផ្កាឈើ នឹងប្រយោគ នឹងពាក្យបង្គាប់ ដូចពោលមកហើយក្នុងបទមុន ។

ក្នុងការដោតក្រងផ្កាឈើជាដើម គប្បីដឹងបុប្ផវិកតិ ៦ ប្រការដូច្នេះ គណ្ឋិមំ ដោតក្រង គោប្ផិមំ ផ្គុំជាផ្កាប់ វេធិមំ ចោះដោត វេឋិមំ ផើតនូវតំរួ បូរិមំ បង្គន់ធ្វើឲ្យពេញ វាយិមំ ប្រែតាក់ស្រេះ ។ គណ្ឋិមំ នោះដោតនូវទងដោយទង គប្បីដឹងក្នុងផ្កាឧប្បលនឹងផ្កាឈូកជាដើម ដែលមានទងវែង នឹងផ្កាឈើដទៃ ដែលមានសណ្ដាន់វែង ចកទងនឹងទង ឬសណ្ដាន់នឹងសណ្ដាន់ ដោតក្រងជាកញ្ចុំ ឈ្មោះថា គណ្ឋិមំ ។ ភិក្ខុភិក្ខុនី ធ្វើខ្លួនឯង ឬឲ្យអ្នកដទៃធ្វើ ដោយពាក្យជាកប្បិយវោហារ មិនគួរ ។ ឲ្យគេធ្វើដោយពាក្យជាកប្បិយជាដើម ថាអ្នកគប្បីដឹងដូច្នេះ កាលណាបើធ្វើដូច្នេះទើបល្អ ផ្កាឈើនឹងមិនរោយកាយ ដូចម្ដេច គប្បីធ្វើដូច្នោះ ពោលដូច្នេះគួរ ។ យកអម្បោះ ឬសំបកជាដើម ដោតគួបនូវផ្កា មានផ្កាម្លិះជាដើម ឲ្យជារបៀបមានទងតែម្ខាង តាំងសងខាង ឈ្មោះថា គោប្ផិមំ ។ ធ្វើសរសៃធ្ន ឬខ្សែជាចេសតីរ ហើយយកផ្កាឈើមិនមានទង មានផ្កាកក់ជាដើមដោតចូលនឹងចេសនោះ

www.budinst.gov.kh www.elibraryofcambodia.org

ចង្ក័តទឹកត័ន្ទះទៅដោយលំដាប់គឺឈ្មោះថា ទោរ៉ង្គម៉ំ នៃ គឺរហោតាំងក្នុង
មិនគួរដូចមុន ។ យកដក់គ្នោភជាជើមៈដាក់ក្នុងទីផ្ញាម៉ះ ប្ដូរក្នុងប្រហោង
ផ្កាឈើមិនមានខ្ទង់ មានផ្កាក្នុលជាដើម ដូច្នះឈ្មោះថា វេដិម៉ ជាពោធ
ដោត ទីនដោតបន្ទាចុះក្នុងកំណាត់ដើមចេក ហើយយកផ្កាឈើដោត
ចូលក្នុងបន្ទានោះជាដើមក្តី សូម្បីចង់បន្ទាក្នុងពិតានធម្មាសនៈ ដើម្បី
ទីនដោតផ្កាឈើ ឬទីនយកបន្ទាពាក់ចុះក្នុងផ្កាឈើតែមួយក្តី ឬទីន
យកផ្កាឈើដំរូតចូលគ្នាក្តី ទាំងអម្បាលនេះ មិនគួរទាំងអស់ ។ ទីន
យកផ្កាឈើបំពាក់ក្នុងក្រឡាសំណាញ់ជាដើម ទីនបំពាក់ក្នុងចន្លោះ
កញ្ចុំផ្កាអសោក មិនមានទោស ព្រោះមិនជា វេដិម៉ សូម្បីក្នុងវិញ
ពាក់ចំកិយ ក៏ដូចជាពោលហើយដូច្នោះ ។ វេដិម៉ នោះគប្បីជ្រាប
ក្នុងកម្រងផ្កា ទីនផ្កាប់ផ្កាឈើ យកអម្បោះទីនវៀបចំក្នុងចង្កូតឲ្យល
ជាដើមធ្វើជាផ្កាប់ ។ មួយផ្កាប់ក្រៅប៉ី ។ ជាដើមក្តី ផ្កាឲ្យក្រ សាមណេរ
ដកឡើងដំកល់ទុកលើគោក ទីនយកសំពត់ចងជាបន្ទុះក្តី មិនគួរទាំង
អស់ ។ ទីនយកសំបក ឬចង្កូតផ្កាឈើនោះឯងចងចូល ឬយកសំពត់ជ័កល់
លើស្មា ចាប់ដាយទាំងពីរក្របួចចូល យកផ្កាឈើដាក់ចុះក្នុងសំពត់នោះ
ដូចដាក់ចុះក្នុងការុង ទាំងអម្បាលនេះគួរ ។ យកចង្អួលតាក់ចុះក្នុងស្នឹក
ឈើក យកស្នឹកគ្រាប់ផ្កាការទៅ ឯទីនចងស្នឹកឈើកខាងលើផ្កានោះ
ក៏គួរ ។ តែទីនចងខាងក្រោមផ្លាប់ខ្មាខាងក្រោមមិនគួរ ។ ឯ បូរ៉ម៉ ធ្វើឲ្យគ
នោះ គប្បីដឹកក្នុងក្នុងរបៀបទីនដែលផ្កាឈើ ... យកកម្រងផ្កាពាំង

www.budinst.gov.kh www.elibraryofcambodia.org

ចេតិយ ឬពោធិ ឬប្ដាក់ចេតិយ ព័ទ្ធមកឲ្យហួសទីដំបូងឈ្មោះថា បុរិមំ
ព័ទ្ធព័ទ្ធវង់ច្រើនជុំមិនត្រូវពោល យកកម្រងផ្កាឈើព័ទ្ធវង់ដៃកែវឲ្យយារ
សំយុងចុះមក ហើយព័ទ្ធព័ទ្ធទៅទៀត ក៏ឈ្មោះថា បុរិមំ ដែរ យក
កម្រងផ្កាដូចវល័យគឺកង បំពាក់កងដៃកែវ គួរ ៗ យកកម្រងផ្កាធ្វើជាផែន
ព័ទ្ធវង់ទៅមួយជុំគួរ ៗ ព័ទ្ធវង់លើសទៅទៀតឈ្មោះថា បុរិមំ មិនគួរ ៗ
បានកម្រងផ្កាដែលគេធ្វើជាកញ្ចុំមកចងខាងលើអាសនៈគួរ ៗ នឹងយក
កម្រងផ្កាដែលវែងពាក់ទៅ ឬព័ទ្ធព័ទ្ធទៅតែមួយជុំ ដល់មុខប្រសព្វខាង
ដើមហើយឲ្យទៅភិក្ខុដទៃក៏គួរ ៗ សូម្បីភិក្ខុដទៃនោះនឹងធ្វើដូច្នោះទៀត
ក៏គួរ ៗ វាយិមំ ក្រងពាក់នោះ គប្បីដឹងក្នុងក្រឡាសំណាញ់ផ្កាឈើ
ទាំងផែនផ្កា នឹងរូបធ្វើដោយផ្កាឈើចុះ កាលធ្វើនូវផ្កាឈើជាក្រឡា
សំណាញ់ក្នុងចេតិយ ត្រូវទុកដ គ្រប់ក្រឡា ៗ ផែនផ្កាឈើ សូម្បីអ្នក
ដទៃគេធ្វើឲ្យពេញទុកហើយ នឹងក្រងពាក់ចូលទៀតមិនបានឡើយ យក
ក្រឈើឈ្មោះ គោប្ផិមំ មកធ្វើជារូបដំរី រូបសេះជាដើម ក៏នៅក្នុងបទ
ឈ្មោះថា វាយិមំ ទាំងអស់ មិនគួរដូចមុន ៗ មិនមែនតែកម្រងផ្កាមួយ
ប៉ុកទេ សូម្បីកម្រងម្សៅ កម្រងផ្កាអម្បោះក៏ដូចគ្នា សូម្បីភិក្ខុនឹង
ភិក្ខុនី ធ្វើឯង ឬឲ្យអ្នកដទៃធ្វើក៏មិនគួរ ព្រោះព្រះបញ្ញត្តិនេះជា
ភណ្ឌារណបញ្ញត្តិទុកទៅ នឹងបូជា ពោលពាក្យជាកប្បិយ គួរ ក្នុងទីទាំងពួង
វោហារ ឧកាស និមិត្តកម្ម គួរ ៗ

បាបសមាចារ ចប់

# អនាចារកថា

កិរិយាប្រព្រឹត្តិផ្សេងៗ មិនសមគួរដល់ភេទសមណៈ គឺលេងបគ្រ្គ ខ្លាចាក់អណ្តូង ខ្លាស៊ីគោ ចាក់អន្ទាក់ស្កា បាយខុំ លេងចាយប៊ូ លេងផ្ទុំស្លឹកឈើ លេងចន្គលគូបៗ លេងដាំដូង លេងកន្ធារ លេងរាល់ខ្សាច់ដោយស្លឹកឈើ លេងរថតូចៗ លេងធ្នូតូចៗ លេងសរសេរតាមក្នុងអាកាសនឹងខ្នង លេងទាយចិត្ត លេងត្រាប់មនុស្សខ្វាក់ មនុស្សខ្វិន មនុស្សខ្ទក. ជាដើម ហាត់សិល្បសាស្ត្រដំរីសេះជាដើម លេងហាត់តម្រុទដំរីសេះជាដើម លេងទះដៃ លេងចំបាប់ ដាល់ជាដើម និងលេងល្បែងដោយអាការផ្សេងៗ យ៉ាងដទៃ ដែលមិនមានមកក្នុងបាលី មានដើមថា ពិណពាទ្យ ហួច ញញូកតូចៗ ផ្លុះតូចៗ តាំងអម្បាលនេះ ឈ្មោះអនាចារៈ មិនគួរសមដល់ភេទសមណៈ គឺភិក្ខុនិងសាមណេរ ។

ខមួយ ភិក្ខុកុំគប្បីប្រមៀលថ្មលេង បើប្រមៀលត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាត់ទុកក្នុងវិនិតវត្ថុថា ន ច ភិក្ខវេ នកាយ សិលា បវិជ្ឈិតព្វា.. ដូច្នេះ ។ មិនមែនតែសិលាមួយមុខ សូម្បីជារបស់ដទៃ គឺកំណាត់ឈើ ដុំឥដ្ឋ ណាមួយ និងប្រមៀល និងបោះដោយដៃ ឬដោយយន្ត ក៏មិនគួរ ។ សើចបណ្តើរ ប្រមៀលបណ្តើរ ឬលើកដុំសិលាទៅបណ្តើរ ដើម្បីប្រយោជន៍ដល់ចេតិយជាដើម ជាកម្មសម័យ ព្រោះហេតុនោះគួរ ។ ធ្វើនវកម្មដទៃដូច្នេះ ឬណានរបស់

www.budinst.gov.kh www.elibraryofcambodia.org

លើកដើមឈើ ឬកំណាត់ឈើ សំរាប់លាង សំរាប់គក់ ប្រមៀល ព្រោះទៅគួរ ៗ ក្នុងវេលាធាត់ជាដើម នឹងត្រូវរងឈើ ឬក្បឿង ផេញ ក្អែក ឬសុខ១ ក៏គួរ ៗ

១មួយ ភិក្ខុកុំគប្បីឡើងដើមឈើ បើឡើងត្រូវទុក្កដ ៗ ផ្សិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ រុក្ខោ អភិរុហិតព្វោ... ដូច្នេះ ៗ កាលបើមានកិច្ចត្រូវការកាន់យកមែកឈើស្ងួតជាដើម នឹងឡើងទៅបានកំពស់ត្រឹម ១ ជួរបុរស ឃើញសត្វកាចប្រាថ្នានឹងរត់ ឬវង្វេងផ្លូវ ប្រាថ្នានឹងមើលទិស ឬឃើញភ្លើងព្រៃនឹងជំនន់ទឹកហូរមក ក្នុង[illegible]ភ័យ ដូច្នេះនឹងឡើងដើមឈើសូម្បីឲ្យហួសក៏គួរ ៗ ផ្សិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ សតិ ករណីយេ បោរិសំ រុក្ខំ អភិរុហិតុំ អាបទាសុ យាវទត្ថំ ដូច្នេះ ៗ

១មួយ ភិក្ខុកុំគប្បីដុតព្រៃ ៗ ផ្សិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ ទាយោ អាលិម្បេតព្វោ... ភិក្ខុមិនត្រូវដុតព្រៃ បើដុតព្រៃត្រូវទុក្កដ ៗ បើដុតចំពោះវត្ថុណា វត្ថុនោះស្លាប់ ត្រូវបារាជិក នឹងអនន្តរិយកម្ម នឹងថុល្លច្ច័យ នឹងបាចិត្តិយ នឹងជាអកុសលកម្មតាមវត្ថុនោះ ៗ ៗ ដុតព្រៃចំពោះឲ្យស្មៅនឹងដើមឈើស្រស់នេះ ត្រូវបាចិត្តិយ ៗ ព្រោះឲ្យគ្រឿងទ្រព្យបករណ៍វិនាស ត្រូវទុក្កដ ៗ សូម្បីដុតដោយប្រាថ្នានឹងលេង ត្រូវទុក្កដ ៗ ពាក្យនេះពោលទុកក្នុងសង្ខេបដូចថា ដុតចំពោះដើមឈើស្រស់ នឹងវត្ថុដែលមានឥន្ទ្រិយនេះ គប្បីដឹងថា ត្រូវបារាជិក

www.budinst.gov.kh www.elibraryofcambodia.org

ថុល្លច្ច័យ បាចិត្តិយ នឹងទុក្កដ តាមត្រូវនោះៗ ចុះ ។ បើភ្លើង ឆេះព្រៃ គេដុត ឬភ្លើងកើតឡើងឯងឆេះមក នឹងមិនឲ្យក្ដិស្មៅរិពាល ហើយដុតភ្លើងទទួលទប់ទុកក្តី នឹងធ្វើការពារគាស់ដីរងដី ជីកគូរទុកជុំវិញ កុដិស្មៅក្តី ធ្វើដូចម្តេចភ្លើងមិនបានកលមក នឹងរលត់ទៅឯង ធ្វើដូច្នោះ ការនោះគឺគួរ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ ទាវទាហេ ឧយ្ហមានេ បដគ្គិំ ទាតុំ បរិត្តំ កាតុំ ដូច្នេះ ។ ធ្វើការទាំងពួងនោះ កាលភ្លើងឆេះឡើងហើយទើបគួរ កាលភ្លើងមិនទាន់ឆេះឡើង គប្បីប្រើអនុបសម្បន្នឲ្យធ្វើ កាលលត់ភ្លើងទឹក គប្បីយកទឹកដែលច្រោះសាកគ្មានសត្វ មកពាក់ស្រោចលត់ ។

អគ្គិកថា ចប់

## បរិក្ខារកថា

១ មួយ ភិក្ខុគប្បីប្រើបរិក្ខារផ្សេងៗ ដ្បិតព្រះអដ្ឋកថាចារ្យ លោកវិនិច្ឆ័យបរិក្ខារដែលគួរ នឹងមិនគួរ ជាបាលីមុត្តកៈរួចពាក្យបាលីទុកដូច្នេះថា មនុស្សពួកខ្លះគេដេរឆត្រស្លឹកត្នោត ខាងក្នុង ឬខាងក្រៅ ដោយអម្បោះ បញ្ចពណ៌ធ្វើឲ្យលើងស្អាតល្អដោយពណ៌ ឆត្រនោះមិនគួរ នឹងដេរបុក ខាងក្នុងឬខាងក្រៅ រួចធ្វើគន្លងក្បាលឆត្រ នឹងក្រាញផងដោយអម្បោះទៀត ឬលៀនណាមួយតែពណ៌មួយ ដើម្បីនឹងឲ្យខ្ជាប់ខ្ជួនគួរ ។ ដើម្បីនឹងឲ្យល្អ មិនគួរ ។ ក្នុងស្លឹកឆត្រនឹងកាត់ជាធ្មេញមករឬរូបព្រះចន្ទមួយចំហៀងមិនគួរ

www.budinst.gov.kh www.elibraryofcambodia.org

ធ្វើជារូបក្តមរូបសត្វសាហាវក្នុងដងឆត្រដូចសរសេរផ្ទះមិនគួរ ៗ សូម្បីក្នុងដងឆត្រទាំងពួងធ្មូតជាខ្សែដោយចុងដែកស្រួច ខ្សែនោះមិនគួរ គប្បីទំលាយរូបក្តមរូបសត្វកាចចេញ ជុសរូសខ្សែចេញ ឬយកគម្រោះរុំព័ទ្ធដងចេញទាំងប្រើចុះ ក្នុងគល់ដងសណ្ឋានដូចជាផ្សិតក្បាលពស់គួរ ៗ ក្នុងទីដែលយកខ្សែចងមណ្ឌលឆត្រយោងមកចងក្នុងដង ដើម្បីនឹងការពារខ្យល់នឹងរំលេចឡើងជាខ្សែដូចវល័យ ខ្សែនោះគួរ ៗ ក្នុងចីវរបើដេរភ្ជាប់គាត់ទុកបដ:ដូចខ្នងក្អែប នឹងធ្វើវិការដោយដេរចេសណាមួយមិនគួរ ឬក្នុងមែសំពត់ដែលផែនសំពត់ទាំង ២ ខ្ទប់គ្នា នឹងក្នុងទីបំផុតដោយជុំវិញនៃចីវរនឹងដេរជាប្រហោង ឬជាខ្សែប្រាក់ជាដើមដោយចេសផ្សេង ៗ ដើម្បីនឹងប្រដាប់ ទាំងពួងនោះមិនគួរទាំងអស់ ៗ ដេរទៅដោយប្រក្រតីមួយចំពូកទើបគួរ ផ្ទាំងសំពត់ក្តុំ នឹងផ្ទាំងសំពត់ក្រវិល ធ្វើជា ៨ ជ្រុង ឬ ១១ ជ្រុងក្តី ក្នុងផ្ទាំងសំពត់នោះធ្វើជាកុំឡើងដូចចេតិយ នឹងផងវែកកន្ទុយគោជាដើមក្តី រំលេចឡើងដូចជាកែកក្តាមក្តី ទាំងពួងមិនគួរ ៗ ផ្ទាំងសំពត់ក្តុំក្រវិលជា ៤ ជ្រុងមួយចំពូកទៀតទើបគួរ កន្ទួចកន្ទុយចេសក្នុងជ្រុងនោះគួរ ផ្សិតជាកាលជ្រលក់ហើយក៏នឹងបាត់ទៅ នឹងត្រាំចីវរចុះក្នុងទឹកបាយនឹងទឹកម្សៅនឹងទឹកម្ជូរជាដើមមិនគួរ ៗ តែនឹងត្រាំចុះដើម្បីនឹងគក់ជុសលាងមន្ទិលដៃនឹងចេសជាដើមដែលប្រឡាក់ក្នុងកាលដេរ នឹងចីវរចាស់ ដើម្បីបោកលាងក៏គួរ ៗ នឹងលាយរបស់ក្រអូប ឬល័ក្ត ឬប្រេង ដាក់ចុះក្នុងទឹកជ្រលក់មិនគួរ ៗ ចីវរជ្រលក់ហើយកុំគប្បីទាត់ជុសដោយស័ង្ខ ឬកែវណាមួយ

www.budinst.gov.kh www.elibraryofcambodia.org

ជ្រលក់ចីវរកុំលុតជង្គង់ចុះទាំងពីរលើផែនដី យកដៃចាប់ឈើច្រចាប់ទៅ
ក្នុងស្នូក តែខឹងយកសំពត់ក្នុងស្នូក ឬលើក្ដារ ហើយឲ្យមនុស្សចាប់ក្នុង
ទីបំផុតខុក ហើយទះដោយបាតដៃក៏គួរ តែកុំតប់ដោយដៃដែលក្ដាប់ ៗ
ព្រះថេរៈទាំងឡាយអំពីមុន លោកមិនដាក់ចីវរក្នុងស្នូក មួយអន្លើកាន់ចីវរ
ឈរ មួយអន្លើតាប់ ហើយយកដៃទះ ៗ បេសក្នុងមុំចីវរ មិនគួរ ជ្រលក់
ហើយគប្បីកាត់ចេញ បេសក្នុងមុំចីវរណា ដែលព្រះពុទ្ធអង្គទ្រង់អនុ-
ញ្ញាតទុក បេសនោះគប្បីចងធ្វើជាអន្ទាក់ក្នុងអន្ទុកត ដើម្បីនឹងបានខព្យួរក្នុង
វេលាជ្រលក់ សូម្បីក្នុងក្ដុំ ធ្វើជាតំខួស ឬជាពងក ដើម្បីឲ្យល្អមិនគួរ គប្បី
ធ្វើឲ្យវិនាសចេញប្រើប្រាស់ចុះ ៗ ក្នុងបាត្រឬថាលកកាដខៈគ្រឿងប្រើ
ប្រាស់នឹងយកដែកក្រឡឹង ក្រឡឹងជាខ្សែខាងក្នុងខាងក្រៅមិនគួរ នឹង
យកបាត្រដាក់ចូលគ្រឿងក្រឡឹងដុសខាត់ ហើយដុតដោយសេចក្ដីប្រាថ្នា
នឹងធ្វើឲ្យមានពណ៌ដូចកែវមណីមិនគួរ តែបាត្រមានពណ៌ដូចប្រេងគួរ ៗ
ក្នុងមណ្ឌលជារង្វើលនៃបាត្រនឹងធ្លាក់គូរជាតំនូរក្បាច់មិនគួរ ជាកិត្តិកម្ម
មិនគួរ ឬក្រឹកមិនគួរ តែបាក់ជាធ្មេញម្ករគួរ ខាងលើឬខាងក្រោមនៃជើង
ធម្មករក ឬក្នុងផ្ទៃធម្មករក ធ្វើជាខ្សែមិនគួរ ក៏ប៉ុន្តែខ្សែក្នុងកណ្ដាប់មាត់
អាការដូចជ្រៃនោះគួរ ៗ តែត្រូវពន្ធចង្កេះត្បាញអម្បោះគួបចុះក្នុងទីនោះៗ នឹង
រំលេចជាក្អកក្ដាមឡើង ដើម្បីនឹងឲ្យល្អមិនគួរ ៗ នឹងត្បាញអម្បោះគួបក្នុង
ទីបំផុតទាំងសងខាង ដើម្បីនឹងឲ្យរឹមជាយជាប់មាំគួរ តែក្នុងរឹមជាយនឹងធ្វើ
ជារូបក្អម ឬមរ ឬក្បាលពស់ទឹក ឲ្យជារូបដែលជាវិការៈណាមួយមិនគួរ ៗ

www.budinst.gov.kh www.elibraryofcambodia.org

សូម្បីវត្ថពន្ធដែលផាត់រំយោល ឬធ្វើជាផ្កាឈើ ដើមក្នុងទីនោះៗ មិនគួរ ។ កំប៉ុំខ្ទិនឹងត្បាញឲ្យគ្រាន់តែធ្វើជាធ្នូត្រី ឬស្លឹកបេង ឬធ្វើជាផ្លែស្រល់ នោះគួរ ។ ជាយនៃវត្ថពន្ធ ខ្សែ ១-២-៣ សូម្បីខ្សែ ៤ ក៏គួរ ។ លើសឡើងទៅជាងនោះមិនគួរ ។ វត្ថពន្ធខ្សែមួយសរសៃទើបគួរ ។ តែវត្ថពន្ធមានសណ្ឋានប៉ុនជាសង្វារស្សូម្បីតែមួយសរសៃមិនគួរ ។ តែជាយសូម្បីមានសណ្ឋានដូចសង្វារ ក៏គួរ ។ វត្ថពន្ធដែលគេបគ្គុបខ្សែច្រើនផងគ្នា ក្នុងហាងជាមួយគ្នា ហើយយកខ្សែមួយសរសៃ ព័ទ្ធចងភ្ជាប់គ្នាទៅដូចច្នេះ កុំគប្បីពោលថាមានខ្សែច្រើនឡើយ វត្ថពន្ធនោះគួរ ។ ក្នុងក្រវិលក្បាលវត្ថពន្ធ ធ្វើជារូបវិការៈណាមួយ មានមង្គល ៨ ជាដើមមិនគួរ ។ ធ្វើល្មមជាស្នាមកំណត់ទីចងគួរ ។ ក្នុងទីបំផុតទាំងពីរនៃក្បាលក្រវិល សូម្បីនឹងធ្វើជារូបក្អម ដើម្បីនឹងឲ្យជាប់មាំក៏គួរ ។ ក្នុងបំពង់ថ្នាំក្អែក នឹងធ្វើជារូបស្ត្រី ឬបុរស នឹងរូបសត្វចតុប្បាទ គឺខ្លា ឬរាជសីហ៍ ទ្វិបាទគឺសកុណបក្សី នឹងធ្វើរូបវិការៈ មានផ្កាឈើ វល្លិ ធ្មេញមករ គោមុត្រ រូបព្រះចន្ទមួយចំហៀងជាដើមមិនគួរ គប្បីដុស ឬកាត់ចេញ ឬចងព័ទ្ធដោយអម្បោះកុំឲ្យប្រាកដ ប្រើបាន ។ បំពង់ថ្នាំក្អែកដ៏ត្រង់ជា ៤ ជ្រុង ឬ ៨ ជ្រុង ១៦ ជ្រុង ក៏គួរ សូម្បីបាតបំពង់ធ្វើជាខ្សែមូលពីរ ឬបីក៏គួរ ។ សូម្បីក្នុងកបំពង់ថ្នាំក្អែក ធ្វើជាខ្សែមូលមួយគំនូសដើម្បីនឹងចងគ្រប់ក៏គួរ ។ សូម្បីចង្កើះថ្នាំក្អែក នឹងគាក់តែងឲ្យមានពណ៌លើសល្អមិនគួរ ។ ក្នុងថង់បំពង់ថ្នាំក្អែក នឹងធ្វើឲ្យល្អយ៉ាងណាមួយដោយអម្បោះមានពណ៌ផ្សេងៗ មិនគួរ ។ សូម្បីក្នុងស្រោមកូនសោ

www.budinst.gov.kh www.elibraryofcambodia.org

ក៏ដូចគ្នា ក្នុងកូនសោទៀត នឹងកាត់តែងឲ្យមានពណ៌ល្អមិនគួរ ។ ក្នុងស្រោមកាំបិតកោរក៏ដូចគ្នា ឯស្រោមនោះនឹងដេរយ៉ាងណាមួយដោយអំបោះណាមួយ តែពណ៌មួយក៏គួរ ។ សូម្បីក្នុងដែកក្រឡឹងនិងកាំបិតចុងស្រួចធ្វើជាពកមូល ឬកាត់តែងឲ្យមានពណ៌ស្អាតល្អយ៉ាងដទៃ មិនគួរ ។ តែត្រង់កធ្វើជាខ្សែរសំរាប់សំគាល់គួរ សូម្បីក្នុងកាំបិតកាត់ក្រចកនឹងរំលេចឲ្យជាម្រះ ជាផ្កា ឬជាផ្ទុំណាមួយមិនគួរ ។ តែក្នុងដងកាំបិតធ្វើជាខ្សែរសំរាប់កំណាត់នោះគួរ កាំបិតកាត់ក្រចកធ្វើជារមូលទៅដើម្បីនឹងឲ្យកាន់មាំគួរ ។ ក្នុងឈើព្រនួតតួតភ្លើង ខាងលើ ឬខាងក្រោម ឬធ្នូនឹងដងសំរាប់ទាញខាងលើនឹងកាត់តែងឲ្យល្អបែបណាមួយ មានមាលាកម្មជាដើម មិនគួរ ។ តែក្នុងមណ្ឌលកណ្តាលនៃដងសំរាប់កាន់តួតនោះ ធ្វើល្មមជាខ្សែរសំរាប់កំណាត់នោះគួរ ។ ក្នុងដំបៀតសំរាប់ថ្កៀបម្ជុលសំលៀងនោះ នឹងកាត់តែងឲ្យល្អបែបណាមួយ មានមាត់ម្ករជាដើមមិនគួរ តែធ្វើឲ្យល្មមជាមាត់ក្រាញ់ដើម្បីនឹងថ្កៀបម្ជុលនោះគួរ ។ សូម្បីក្នុងកាំបិតកាត់ឈើស្ងួន នឹងកាត់តែងឲ្យល្អបែបណាមួយក៏មិនគួរ នឹងយកលោហៈជាកង្វៀលភ្ជាប់ឲ្យត្រង់ទៅ ក្នុងខាងចាំងសងខាង ឬម្ខាងនៃដងឲ្យជា ៤ ជ្រុង ឬ ៨ ជ្រុងគួរ ។ សូម្បីឈើច្រត់ នឹងកាត់តែងឲ្យល្អបែបណាមួយ ក៏មិនគួរ តែខាងក្រោមនឹងធ្វើជាខ្សែរមូលមួយ ឬពីរក្តី ចុងខាងលើ ធ្វើល្មមជាឆ្មែក្បាលពស់ក្រពុំក្តីគួរ ។ ក្នុងភាជនៈប្រេងធ្វើដោយស្នែង ឬអំបែង ឬលលាដ៍ល្ហក ឬស្នូខដោយកាកលក្កី នឹងកាត់តែងឲ្យមានពណ៌ល្អចាំងអស់

www.budinst.gov.kh www.elibraryofcambodia.org

លើកតែរូបស្រ្តី ឬបុរសចេញ គឺគួរ ៗ ក្នុងក្រែ តាំង ពូក ខ្នើយ គ្រឿងកំរាល សំពត់ជូតជើង ពូកសំរាប់ចង្ក្រម អំបោស កន្ត្រោងសំរាប់ចាក់សំរាម ស្នូកជ្រលក់សំពត់ ពោយជងទឹក ក្អមទឹក គ្បៀងជូតជើង តាំងដំហើយដោយក្ដារ ជើងបាត្រផ្ចូចកង់ និងជើងបាត្រធ្វើដោយកំណាត់ឈើ គ្របបាត្រ ផ្ចិតស្លឹកត្នោត ផ្ចិតផែង របស់ទាំងអម្បាលនេះ និងធ្វើឲ្យល្អដោយពណ៌ទាំងពួងមានផ្កាឈើជាដើមគួរ ៗ តែក្នុងសេនា-សនៈ ក្នុងសន្ទឹកក្ដារ និងស្លឹកបង្អួចជាដើម សូម្បីគាក់តែងឲ្យល្អស្រស់ និងប្រដាប់ដោយកែវទាំងពួងក៏គួរ ៗ ក្នុងសេនាសនៈ វត្ថុណាមួយដែលនឹងគប្បីឃាត់នោះមិនមាន វៀរលែងតែនិរុទ្ធសេនាសនៈ ៗ

បាលីមុត្តកវិនិច្ឆយកថា ចប់

---

វិនិច្ឆ័យទាំងពួងនេះ មិនមែននឹងផុតចាកបាលីទៅតែម្តងទេ របស់ខ្វះអាស្រ័យបាលីថា: ន ភិក្ខវេ ឧច្ចាវចា វិថា ធារេតព្វា ... គណ្ឋិកា... អញ្ជនី ... អញ្ជនីសលាកា ... សត្ថកទណ្ឌោ ... បដិគ្គហោ.. ឧត្តរារណី... កណ្ណមលហរណីយោ ... ទុមវេត្តាធិ... បត្តមណ្ឌលាធិ ធារេតព្វាធិ... កុំក្រវិល បំពង់ថ្នាំភ្នែក ចង្កឹះថ្នាំភ្នែក ដងកាំបិត ស្លាប់ទទួលចុងមូល បំពង់ថ្នាំហិត ឈើចង្កៀលត្រចៀក ខ្សែជក់ថ្នាំ រង្វេលជើងបាត្ររបស់ទាំងអស់នេះ ជារបស់ទាប និងខ្ពស់ ដំហើយដោយមាសនិងប្រាក់

www.budinst.gov.kh www.elibraryofcambodia.org

កិត្តុំគប្បីប្រើ ជាបើប្រើត្រូវទុក្កដ ។ កុំគ្រវែលទាំងពីរនេះ ដំហើយ
ដោយឆ្អឹង នឹងភ្លុក នឹងស្នែង នឹងកាកល័ក្ត នឹងឫស្សី ដំហើយដោយ
ត្រឡោក នឹងស័ង្ខ នឹងអម្បោះ ក៏គួរ ព្រោះជារបស់ព្រះពុទ្ធអង្គទ្រង់
អនុញ្ញាត ។ បំពង់ថ្នាំភ្នែក ចង្កឹះថ្នាំភ្នែកជាដើមដំហើយដោយឆ្អឹង ភ្លុក
ស្នែង តែងតង់ នឹងឫស្សី ដំហើយដោយឈើ កាកល័ក្ត នឹងផ្លែឈើ
ដំហើយដោយលោហៈ ត្រឡោក នឹងស័ង្ខក៏គួរ ។ ដ្បិតជារបស់ព្រះពុទ្ធ
អង្គទ្រង់អនុញ្ញាត ។ រង្វេលនេត្រ ដំហើយដោយសំណនឹងស័ង្កសី
ទើបគួរ ព្រោះជារបស់ទ្រង់អនុញ្ញាត ។ ក៏ឯធ្វាវេតក្ខន្ធបាលីថា ដំហើយ
ដោយប្រាក់នឹងមាសខ្វះ មានកាលជាវត្ថុដៃខ្វះដូចជាវត្ថុពន្ធចង្កេះថា ឯ
កក្ខារវេ ឧប្បារបាទំ កាយពន្ធនំ ឯរេតព្វាឯ កាលាពុតាំ
ឆេទ្ទកកាំ មុរជ្ជំ មទុវិណាំ... ជាវត្ថុពន្ធចង្កេះ ខ្លួនឹងវាប គឺមាន
ខ្សែប្រើនឹងមានសណ្ឋានដូចក្បាលពស់ទឹក នឹងពំពូនៅមានសណ្ឋាន
ដូចត្រកួញខ្សែ នឹងមានសណ្ឋានដូចសង្វារ កិត្តុំគប្បីប្រើ បើប្រើត្រូវ
ទុក្កដ ។ តែពំពូដោយសណ្ឋានដូចត្រកួញខ្សែ សណ្ឋានដូចសង្វារនេះ
ក្នុងជាយវត្ថុពន្ធក៏គួរ ។ ដ្បិតទ្រង់អនុញ្ញាតទុកថា អនុជានាមិ
កក្ខារវេ មុរជ្ជំ មទុវិណាំ ដូច្នេះ ។ បង្កិកាំ វត្ថុពន្ធវៃផ្លូសំពត់ក្បាញ
ដោយប្រក្រតី នឹងក្បាញដូចឆ្អឹងត្រី សុត្តាវលិកាំ វត្ថុពន្ធដូចពោះវៀន
ជ្រូក នឹងស្រោមក្ខនសោ វត្ថុពន្ធទាំងពីរប្រការនេះជារបស់ព្រះពុទ្ធអង្គ
ទ្រង់អនុញ្ញាត ។

www.budinst.gov.kh www.elibraryofcambodia.org

១មួយ ទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ ចិត្រានិ បត្តមណ្ឌលានិ ធារេតព្វានិ រូបកាកិណ្ណានិ ភិត្តិកម្មកតានិ... ភិក្ខុមិនត្រូវប្រើជើងបាត្រដ៏វិចិត្រ ឆ្លាក់ជេរជាសំដោយរូបស្រីនិងប្រុសជាដើម និងលាបឲ្យមានពណ៌ផ្សេងៗទេ បើប្រើត្រូវទុក្កដ ។

១មួយ ភិក្ខុកុំគប្បីប្រើផ្លិតវែងទី ៤ ជ្រុងធ្វើដោយកេមទាមរី បើប្រើប្រាស់ត្រូវទុក្កដ ។ ព្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ ចាមរីវីជនី ធារេតព្វា ផុះបូះ ។ វិធូបនំ ផ្លិតមូលជ្រុង តាលវណ្ណំ ផ្លិតធ្វើដោយស្លឹកត្នោត ឬធ្វើដោយបន្ទោះ ឬដោយកេមកោក ឬដោយស្បែក មកសវីជនី ផ្លិតបក់មូស សូម្បីមានដងដ៏ហើយដោយភ្លុកនិងស្នែងក្តី របស់ទាំងអម្បាលនេះ ព្រះពុទ្ធអង្គទ្រង់អនុញ្ញាត ។

មួយទៀត ផ្លិត ៣ ប្រការគឺ វាកមយំ ផ្លិតធ្វើដោយសម្បកឈើ ឧសិរមយំ ផ្លិតធ្វើដោយស្បូវភ្លាំង មោរបិញ្ឆមយំ ផ្លិតធ្វើដោយកេមកន្ទុយក្ងោក របស់ទាំងអស់នេះជារបស់ព្រះពុទ្ធអង្គទ្រង់អនុញ្ញាត ។

១មួយ ភិក្ខុកុំគប្បីប្រើឈើស្ទន់វែងពេក ខ្លីពេក ។ ព្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ ទីឃំ ទន្តកដ្ឋំ ខាទិតព្វំ ។ល។ អនុជានាមិ ភិក្ខវេ អដ្ឋង្គុលបរមំ ទន្តកដ្ឋំ ។ល។ ន ភិក្ខវេ អតិមដ្ឋហកំ ទន្តកដ្ឋំ ខាទិតព្វំ ។ល។ អនុជានាមិ ភិក្ខវេ ចតុរង្គុលំ បច្ឆិមំ ទន្តកដ្ឋំ ថាភិក្ខុកុំគប្បីប្រើប្រាស់ឈើស្ទន់វែង បើប្រើប្រាស់ត្រូវទុក្កដ ។ គឺថាតែអនុញ្ញាត

www.budinst.gov.kh www.elibraryofcambodia.org

ឈើស្ទន់វែងត្រឹមតែ ៨ ធ្នាប់ ដោយធ្នាប់មនុស្សជាយ៉ាងក្រៃពេក ។ ភិក្ខុកុំគប្បីប្រើប្រាស់ឈើស្ទន់វែងពេក បើប្រើប្រាស់ត្រូវទុក្កដ ។ តថាគតអនុញ្ញាតឈើស្ទន់ ៤ ធ្នាប់ជាយ៉ាងខ្លី ។ មិនប្រើឈើស្ទន់មានទោស ៥ ប្រការគឺ អចក្ខុស្សំ មិនបានគួរដល់ភ្នែក ១ មុខំ ទុគ្គន្ធំ ហោតិ មាត់មានក្លិនស្អុយ ១ រសហរណិយោ ន វិសុជ្ឈន្តិ សរសៃទទួលរសអាហារមិនបរិសុទ្ធ ១ បិត្តំបិ សេម្ហំបិ ភត្តំ បរិយោនទ្ធន្តិ ប្រមាត់នឹងស្លេស្មរមែងរុំរឹតបាយ ១ ភត្តមស្ស ន ឆាទេតិ[១] អាហារមិនឆ្ងាញ់ដល់អ្នកនោះ ១ ត្រូវជា ៥ ប្រការ ។ បើប្រើឈើស្ទន់មានអានិសង្ស ៥ ប្រការ គប្បីដឹងដូចន័យដែលជាបដិបក្ខដល់ទោសនោះចុះ ។

ខមួយ ភិក្ខុកុំគប្បីធ្វើការសន្សំគ្រឿងធ្វើដោយលោហៈ និងគ្រឿងធ្វើដោយសំរិទ្ធ បើធ្វើការសន្សំទុក ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ លោហភណ្ឌំ កំសភណ្ឌំ សន្និចយោ កាតព្វោ... ដូច្នេះ ។ ចំពង់ថ្នាំភ្នែក ចង្កឹះថ្នាំភ្នែក ឈើចន្លៀលត្រចៀក ស្រោមកាំបិតជាដើម ដែលធ្វើហើយដោយលោហៈ និងសំរិទ្ធិនួរ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ អញ្ជនឹ អញ្ជនិសលាកំ កណ្ណមលហរណឹ ពន្ធនមត្តំ ដូច្នេះ ។

១– វិនយបិដក ចុល្លវគ្គ ទុតិយភាគ ខុទ្ទកវត្ថុក្ខន្ធកៈ ទំព័រ ២២៦

www.budinst.gov.kh www.elibraryofcambodia.org

១មួយ បព្វជិតកុំគប្បីបបួលបព្វជិត គឺសហធម្មិកទាំង ៥ ក្នុងកម្មដ៏មិនគួរ បើភិក្ខុណាបបួលនាំឲ្យធ្វើ ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ បព្វជិតេន អកប្បិយេ សមាទបេតព្វំ... ដូច្នេះ ។

១មួយ ភិក្ខុធ្លាប់ជាជាងកោរសក់អំពីមុនមកហើយ កុំគប្បីរក្សាគ្រឿងកាំបិតកោរទុក បើភិក្ខុណារក្សាទុក ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ ន្ហាបិតបុព្វេន ខុរភណ្ឌំ បរិហរិតព្វំ ដូច្នេះ ។ កាន់យករក្សាទុកមួយចំពូកមិនគួរ ក៏ប៉ុន្តែនឹងកោរដោយកាំបិតអ្នកដទៃនោះគួរ បើភិក្ខុទទួលស៊ីឈ្នួលកោរសក់ ក៏មិនគួរ ។ ភិក្ខុណាមិនធ្លាប់ជាជាងកោរសក់អំពីមុនមក ហើយភិក្ខុនោះសូម្បីនឹងរក្សាកាំបិតកោរទុកក៏គួរ សូម្បីនឹងកាន់យកកាំបិតកោរនោះ ឬកាំបិតដទៃមកកោរសក់ក៏គួរ ។

១មួយ ព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ ឋបេត្វា បហរណិំ សព្វំ លោហភណ្ឌំ ឋបេត្វា អាសន្ទឹ បល្លង្កំ ទារុបត្តំ ទារុបាទុកំ សព្វំ ទារុភណ្ឌំ ឋបេត្វា កតកញ្ច កុម្ភការិកញ្ច សព្វំ មត្តិកាភណ្ឌំ ។ តថាគតអនុញ្ញាត ទុកគ្រឿងលោហៈទាំងពួង វៀរលែងតែលោហៈដែលជាគ្រឿងសម្រាប់ប្រហារ, ទុកគ្រែទាំងពួង វៀរលែងតែអាសនៈកខ្ពង់ ហួសប្រមាណដែលហៅថាអាសន្ទិ នឹងគ្រែតាំងមានជើងវិចិត្រដោយរូប

www.budinst.gov.kh www.elibraryofcambodia.org

សត្ថសាហារ ដែលហៅថាបល្លង្ក, នូវគ្រឿងឈើទាំងពួង វៀរលែងតែបាត្រឈើ ខឹងទ្រនាប់ជើងឈើ, នូវគ្រឿងដែកទាំងពួង វៀរលែងតែគ្រឿងផ្គត់ផើងដែលគេធ្វើជាពកឲ្យស្រួច ១ ទៀត មានអាការដូចពកគ្រាប់ផ្លែឈូក នឹងកុដធ្វើដោយដីសុទ្ធ (ដូចកុដិនិយកក្កុ) ។

បរិក្ខារកថា ចប់

## មណ្ឌនាទិកថា

ទមួយ ភិក្ខុកុំគប្បីលាប ផាត់ ជ្រលក់មុខ ជ្រលក់ខ្លួន ដោយគ្រឿងលាបដោយគ្រឿងជ្រលក់ ។ ដ្បិតទ្រង់បញ្ញត្តទុកថា ន ភិក្ខវេ មុខំ អាលិម្បិតព្វំ ន មុខំ ឧម្មទ្ទិតព្វំ ន មុខំ ចុណ្ណេតព្វំ ន មនោសិលកាយ មុខំ លញ្ឆេតព្វំ ន អង្គរាគោ កាតព្វោ ន មុខរាគោ កាតព្វោ ន អង្គរាគមុខរាគោ កាតព្វោ... ភិក្ខុកុំគប្បីលាបមុខដោយគ្រឿងលាប ដែលធ្វើឲ្យមុខមានពណ៌សម្បុរស្រស់ កុំផាត់មុខដោយគ្រឿងផាត់ផ្សេង ១ កុំប្រោះមុខដោយគ្រឿងលំអិតសំរាប់ប្រោះមុខ កុំចឹមមុខដោយមនោសិលា និងហរិតាលជាដើម កុំជ្រលក់អវយវៈ កុំជ្រលក់មុខ កុំជ្រលក់ទាំងខ្លួនទាំងមុខ បើភិក្ខុណាធ្វើដូច្នេះ ត្រូវទុក្កដ ។ ដ្បិតទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ អាពាធប្បច្ចយា មុខំ អាលិម្បិតុំ ដូច្នេះ ។ ព្រោះបច្ច័យគឺអាពាធនឹងលាបមុខក៏គួរ ។ ន័យមួយទៀតថា ភិក្ខុកុំគប្បីទ្រទ្រង់គ្រឿង

www.budinst.gov.kh www.elibraryofcambodia.org

ប្រដាប់ត្រចៀកមានការជាដើម ។ ដ្បិតទ្រង់បញ្ញត្តទុកថា ន ភិក្ខវេ វល្លិកាំ ធារេតព្វំ ន បាមង្គំ ធារេតព្វំ ន កណ្ឋសុត្តកំ ន កដិសុត្តកំ ន ឱវដ្ដិកំ .. ន កាយុរំ... ន ហត្ថាភរណំ... ន អង្គុលិមុទ្ទិកំ ធារេតព្វំ... ភិក្ខុកុំគប្បីទ្រង់ការគ្រឿងប្រដាប់ត្រចៀក ដោយហេតុនោះសូម្បីតែស្លឹកត្នោត ទឹងអម្បោះសន្ធារ ទឹងគ្រឿងប្រដាប់ចង្កេះណាមួយ ដោយហេតុនោះ សូម្បីតែអម្បោះខ្សែចង្កេះក្តី ទឹងកង ទឹងខ្សែខ្នង ទឹងគ្រឿងប្រដាប់ដៃ ទឹងចិញ្ចៀន ភិក្ខុណាទ្រង់គ្រឿងប្រដាប់តាំងអម្បាលនេះ ដូចពោលមកហើយនេះ ត្រូវទុក្កដ ។

១មួយ ភិក្ខុកុំគប្បីឲ្យគេដកសក់ស្កូវ បើឲ្យគេដក ត្រូវទុក្កដ ។ ដ្បិតទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ បលិតំ គាហាបេតព្វំ ដូច្នេះ ។ រោមឯណាដែលដុះឡើងនៅចិញ្ចើម ឬនៅថ្ពាស ឬអមតាំងជារបស់គួរខ្ពើម រោមអម្បាលនេះ ទោះស្កូវក្តី មិនស្កូវក្តី សូម្បីឲ្យគេដកក៏គួរ ។

១មួយ ភិក្ខុកុំគប្បីឲ្យគេកាត់សក់ទឹងកន្ត្រៃ បើឲ្យគេកាត់ ត្រូវទុក្កដ ។ ដ្បិតទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ កត្តរិកាយ កេសា ឆេទាបេតព្វា ដូច្នេះ ។ កើតរោគមានដំបៅជាដើមលើក្បាល ទឹងឲ្យគេកាត់សក់ដោយកន្ត្រៃ ដើម្បីទឹងឲ្យគេលាបថ្នាំក៏គួរ ។ ដ្បិតទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ អាពាធប្បច្ចយា កត្តរិកាយ កេសេ ឆេទាបេតុំ ដូច្នេះ ។

www.budinst.gov.kh www.elibraryofcambodia.org

ខមួយ ភិក្ខុកុំគប្បីឲ្យគេកាត់ពុកមាត់ដោយកន្ត្រៃ បើឲ្យគេកាត់ ត្រូវទុក្កដ ៗ ដ្បិតទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ មស្សុ កប្បាបេតព្វំ ដូច្នេះ ។

ខមួយ ភិក្ខុកុំគប្បីសិតសក់ដោយស្និត កុំសិតដោយវត្ថុណាមួយ មានក្រាសស្នុកជាដើម កុំយកដៃធ្វើជាក្រាសសិតសក់នឹងម្រាមដៃ កុំសិតលាបដោយប្រេងលាយនឹងក្រមួន កុំសិតលាបដោយប្រេងលាយនឹងទឹក បើសិតដូច្នេះ ត្រូវទុក្កដ ៗ ដ្បិតទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ កោច្ឆេន កេសា ឱសណ្ឋេតព្វា ន ផណកេន... ន ហត្ថផណកេន... ន សិត្ថតេលកេន... ន ឧទកតេលកេន កេសា ឱសណ្ឋេតព្វា... ដូច្នេះ ។ សិតដើម្បីនឹងតែងខ្លួន ត្រូវទុក្កដ កន្ទីតាំងពួន ៗ ក៏ឯចុងសក់ជាប់ជះឡើងលើ គប្បីជ្រលក់ដៃឲ្យទទឹក ហើយស្ទាបក្បាលដើម្បីឲ្យធ្លាក់ចុះតាមគ្នា សូម្បីក្បាលក្តៅ ឬប្រឡាក់ដោយធូលី នឹងជូតដោយដៃទទឹកក៏គួរ ។

ខមួយ ភិក្ខុគ្មានជម្ងឺ កុំគប្បីឆ្លុះមុខនឹងកញ្ចក់នឹងភាជនៈដាក់ទឹក បើឆ្លុះត្រូវទុក្កដ ៗ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ អាទាសេ វា ឧទកបត្តេ វា មុខនិមិត្តំ ឱលោកេតព្វំ ដូច្នេះ ៗ និមិត្តនៃមុខប្រាកដក្នុងវត្ថុណា សូម្បីផែនសំរិទ្ធជាដើម វត្ថុទាំងពួងនោះរាប់ថា អាទាសៈ កញ្ចក់ទាំងអស់ សូម្បីទឹកថ្លា ទឹកជ្រក់ជាដើមក្តី ក៏រាប់ថា ឧទកបត្តទាំងអស់ ព្រោះហេតុនោះ កាលបើមើលស្រមោលមុខ

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងទីណាមួយ ត្រូវទុក្កដ ។ កើតដំបៅនៅមុខហើយមើលស្រមោលមុខក្នុងកញ្ចក់ជាដើម ដើម្បីនឹងឲ្យដឹងថា ដំបៅយើងជុះសាច់ហើយឬនៅឡើយ នេះគួរ ។ ផ្សិតទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ អាពាធប្បច្ចយា ។ល។ ឱលោកេតុំ ដូច្នេះ ។

ក្នុងអដ្ឋកថា ថាទឹងមើលដើម្បីឲ្យដឹងអាយុសង្ខារ ថាយើងចាស់ហើយ ឬនៅ នេះគួរ ។

ខមួយ ភិក្ខុកុំគប្បីសំឡឹងមើលនិមិត្តស្ត្រី ។ ផ្សិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកក្នុងវិន័យតក្កថា ន ច ភិក្ខវេ សារត្តេន មាតុគាមស្ស អង្គជាតំ ឧបនិជ្ឈាយិតព្វំ... ភិក្ខុកុំគប្បីសំឡឹងមើលអង្គជាតនៃមាតុគ្រាមដោយដំរេក បើភិក្ខុណាមើលត្រូវទុក្កដ ។ សូម្បីស្ត្រីស្លៀកសំពត់មួយរយជាន់ ឈរពីមុខ ឬពីក្រោយ រមិលមើលដោយគិតថានិមិត្តនៅក្នុងឱកាសឈ្មោះនេះ ត្រូវទុក្កដ ។ ដែលសំឡឹងមើលនិមិត្តនៃស្ត្រីក្មេងអ្នកស្រុកមិនទាន់ស្លៀកសំពត់ មិនបាច់ពោល សូម្បីសំឡឹងមើលនិមិត្តតិរច្ឆានញី ក៏ត្រូវអាបត្តិដូចគ្នា ។ បើមិនរមិលមើលខាងណោះខាងណេះ សំឡឹងមើលដោយប្រយោគតែមួយ សូម្បីអស់មួយថ្ងៃត្រូវទុក្កដតែមួយ ។ បើក្រឡេកសំឡឹងមើលរឿយ ៗ ត្រូវទុក្កដគ្រប់ប្រយោគ ។ កុំគប្បីកាត់អាបត្តិដោយភិក្ខុបិទភ្នែក ហើយបើកភ្នែកឡើងមើល សំឡឹងមើលហើយក្រឡេកគិតតាំងនៅក្នុងសំវរៈវិញដោយប្រញាប់ មិនត្រូវអាបត្តិ ។ លះសំវរៈចេញហើយ សំឡឹងមើលទៀតគង់ត្រូវអាបត្តិទុក្កដ ដោយពិត ។

www.budinst.gov.kh www.elibraryofcambodia.org

ខមួយ ភិក្ខុកាលងូតទឹក កុំគប្បីដុសកាយនឹងដើមឈើ នឹងសសរ នឹងជញ្ជាំង បើដុសកាយក្នុងទីទាំងអម្បាលនេះ ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ ន្ហាយមានេន រុក្ខេ កាយោ ន ថម្ភេ ន កុឌ្ឌេ កាយោ ឧគ្ឃំសេតព្វោ ដូច្នេះ ។

ខមួយ ភិក្ខុកុំគប្បីងូតទឹកក្នុងទីឈ្មោះអដ្ឋានៈ នឹងកុំងូតទឹកដោយឈើឈ្មោះគន្ធព្វហត្ថកៈ កុំងូតទឹកដោយកុរុវិន្ទកសុត្តិ បើងូតក្នុងទីអដ្ឋានៈ នឹងរបស់ទាំងអម្បាលនេះត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ ន្ហាយមានេន អដ្ឋានេ គន្ធព្វហត្ថកេន កុរុវិន្ទកសុត្តិយា ន្ហាយិតព្វំ ដូច្នេះ ។ អ្នកមជ្ឈិមប្រទេសទាំងឡាយ គេចាំងឈើឲ្យដូចជាក្តារហើយឆូតជាក្រឡាទទឹងបណ្តោយ ដោយអាការដូចក្រឡាចត្រង្គ ហើយគប់ក្នុងទីងូតទឹក យកលំអិតដាក់ក្នុងឈើក្តារនោះ ហើយដុសកាយក្នុងក្តារដូច្នេះឈ្មោះថា អដ្ឋានៈ, ឈើគេធ្វើដូចជាដៃដំកល់ទុកក្នុងទីងូតទឹក ឈ្មោះគន្ធព្វហត្ថកៈ បានឮថា មនុស្សទាំងឡាយ គេកាន់យកនូវលំអិតដោយឈើដូច្នោះដុសនាត់ខ្លួន ធ្ងន់អំបោះគេផ្សំលំអិតក្រួសបូចពាលកាកល័ក្ត ហើយធ្វើជាដុំបញ្ចូលឡឹកណ្តាល ហៅថាកុរុវិន្ទកសុត្តិ គេកាន់យកកុរុវិន្ទកសុត្តិនោះ ក្នុងទីបំផុតទាំងសងខាងហើយដុសនាត់ខ្លួន ។

មួយទៀត ភិក្ខុកុំគប្បីយកខ្នងនឹងខ្នងដុសគ្នា បើភិក្ខុតែអង្គដុសគ្នា

ដូចគ្នា ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ វិគ្គយ្ហ បរិកម្មំ ការាបេតព្វំ... ដូច្នេះ ។

មួយទៀត ព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ មល្លកេន ន្ហាយិតព្វំ... ភិក្ខុកុំគប្បីងូតទឹកដោយឈើឈ្មោះមល្លកៈ បើភិក្ខុណាងូតដោយឈើឈ្មោះមល្លកៈត្រូវទុក្កដ ។ ឈើគេឆ្លាក់ធ្វើជាធ្មេញមករ ធ្វើសណ្ឋានដូចចុសដំឡូងឈ្មោះថាមល្លកៈ ឈើមល្លកៈនេះ សូម្បីភិក្ខុឈឺក៏មិនគួរ ។ ឈើមល្លកៈ គេមិនបានឆ្លាក់ជាធ្មេញមករ គួរដល់ភិក្ខុឈឺ ភិក្ខុមិនឈឺមិនគួរ ។ ដ្បិតទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ គិលានស្ស អកតមល្លកំ ដូច្នេះ ។ កំណាត់ផែនក្បឿង ឬកំណាត់ថ្ម គួរដល់ភិក្ខុទាំងពួង ធុនសំពត់ខឹងបាតដៃជារបស់គួរ ។ ដ្បិតទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ ឧក្កាសិកំ ... បុថុបាណិកំ ដូច្នេះ ។ ឧក្កាសិកំ ប្រែថា ធុនសំពត់ ព្រោះហេតុនោះ ភិក្ខុណាមួយ ងូតទឹកនឹងយកធុនសំពត់ដុសខ្លួននោះក៏គួរ ។ បុថុបាណិកំ ប្រែថាហត្ថបរិកម្ម ព្រោះហេតុនោះ ភិក្ខុទាំងពួងនឹងធ្វើ បិដ្ឋិបរិកម្ម គឺដុសខ្នងគ្នាដោយដៃក៏គួរ ។ គឺឯមហាន-វគ្គ ចំនៀមងូតទឹកដូច្នេះ ទៅដល់កំពង់ទឹកហើយ កុំរះកចីវរហាលទុក ក្នុងទីណាមួយ ហើយប្រញាប់ចុះទៅ គប្បីក្រឡេកមើលក្នុងទិសទាំងពួង ដឹងថាស្ងាត់ហើយ គប្បីកំណាត់ផ្លាក់នឹងគុម្ពឈើនឹងវល្លិជាដើម ហើយ ក៏ឈរទុនខ្លួនចុះ ដោះចីពរចេញហាលទុក ស្រាយវត្តពន្ធចង្កេះដាក់ទុក

លើចីវរ បើសំពត់ងូតមិនមាន គប្បីអង្គុយប្រហោងចុះក្នុងទីជិតទឹក តើង ស្បង់ចេញ បើទីហាលមានសោត គប្បីសំដិលទុកក្នុងទីមានកំដៅថ្ងៃ បើទីហាលមិនមាន គប្បីអង្កាញ់ពាក់ទុក កាលបើចុះទៅត្រឹមផ្ចិត កុំធ្វើឲ្យជារលក ជាសំឡេង គប្បីបែរត្រឡប់មុខមកខាងទិសដែលខ្លួនមកហើយមុជចុះ កាលបើធ្វើដូច្នេះនេះក៏មិនបានរក្សាខ្វល់ចីវរនោះផង កាលបើងើបឡើង កុំធ្វើសំឡេងខ្លាំង សន្សឹមៗ ហើយងើបឡើង ងូតរួចហើយគប្បីអង្គុយប្រហោងទៀបមាត់ទឹក ពំនួសំពត់ស្លៀកហើយក្រោកឡើងស្លៀកឲ្យជាបរិមណ្ឌលដោយប្រពៃ ហើយចងវត្តពន្ធចង្កេះដណ្ដប់ចីពរឈរនៅ បើងូតមានសំពត់ងូតសោត ឡើងមកហើយគប្បីឲ្យឈ្នះទឹកធ្លាក់ដាច់ពីខ្លួន ហើយសឹមស្លៀកដណ្ដប់ ។

មួយទៀត ភិក្ខុកុំអាក្រាតកាយនឹងមិនមានស្បង់ចីពរ សំពះអ្នកអាក្រាតកាយផងគ្នា កុំអាក្រាតកាយសំពះអ្នកដទៃ កុំអាក្រាតកាយឲ្យអ្នកអាក្រាតកាយសំពះខ្លួន កុំអាក្រាតកាយឲ្យគេសំពះខ្លួន កុំអាក្រាតកាយធ្វើបរិកម្មឲ្យអ្នកអាក្រាតកាយផងគ្នា កុំអាក្រាតកាយឲ្យរបស់ដល់អ្នកអាក្រាតកាយផងគ្នា កុំអាក្រាតកាយទទួលរបស់ កុំអាក្រាតកាយទំពាឆាន់ កុំអាក្រាតកាយឆាន់ កុំអាក្រាតកាយលិទ្ធវត្ថុទាំងពួង កុំអាក្រាតកាយឆាន់ទឹក បើអាក្រាតកាយ ធ្វើនូវអាការអម្បាលនេះ ណាមួយត្រូវទុក្កដ ។ ដ្បិតទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ នគ្គេន នគ្គោ អភិវាទេតព្វោ ។ បេ ។ ន នគ្គេន ខាទិតព្វំ ដូច្នេះ ។ ព្រះ

www.budinst.gov.kh www.elibraryofcambodia.org

អនុញ្ញាតគ្រឿងបិទកាយ ៣ ប្រការ គឺ ជន្តាឃរបដិច្ឆាទិ គ្រឿងបិទកាយគឺរោងភ្លើង ១ ឧទកបដិច្ឆាទិ គ្រឿងបិទកាយ គឺទឹក ១ វត្ថបដិច្ឆាទិ គ្រឿងបិទកាយ គឺសំពត់ ១ ។ ក៏ឯគ្រឿងបិទកាយគឺរោងភ្លើង នឹងគ្រឿងបិទកាយគឺទឹក គួរក្នុងកាលដែលធ្វើបរិកម្មមានដុសខ្លួនជាដើមប៉ុណ្ណោះ មិនគួរក្នុងកម្មដ៏សេសមានអភិវាទនកម្មជាដើម ។ គ្រឿងបិទកាយគឺសំពត់ គួរក្នុងកម្មទាំងពួង ។

មួយទៀត ភិក្ខុកុំគប្បីប្រើអំបែងដូតជើង ដែលគេធ្វើជាបន្លា ជាពក មានសណ្ឋានដូចពកផ្កាឈូក ដើម្បីនឹងដូតជើង បើប្រើអំបែងដូតជើងដូច្នេះ ត្រូវទុក្កដ ។ ផ្សិតទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ កតកំ បរិភុញ្ជិតព្វំ ដូច្នេះ ។ អំបែងដូតជើងនោះ ពោះមូលក្តី បួនជ្រុងជាដើមក្តី ព្រះពុទ្ធអង្គទ្រង់ហាមឃាត់ ព្រោះជាពហុល្លានុយោគ នឹងទទួលក៏មិនគួរ នឹងប្រើប្រាស់ក៏មិនគួរ ។ គ្រឿងដូតជើង ៣ ប្រការ គឺ ក្រួសឬសិលា ១ អំបែងក្បឿងឬឥដ្ឋ ១ ផ្សិតដែលកើតពីពពុះទឹកសមុទ្ទ ១ បីនេះជារបស់គួរ ។ ផ្សិតទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ តិស្សោ បាទឃំសនិយោ សក្ខរំ កថលំ សមុទ្ទផេណកំ ដូច្នេះ ។

មួយទៀត ព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ ចេឡបដិកា អក្កមិតព្វា ភិក្ខុកុំគប្បីជាន់ដែនសំពត់ បើជាន់ត្រូវទុក្កដ ។ រឿងនេះ ព្រះពុទ្ធអង្គទ្រង់ប្រារព្ធនឹងពោធិរាជកុមារ កាល

www.budinst.gov.kh www.elibraryofcambodia.org

សាង់គោកនុទប្រាសាទទៀនថ្មី ក្រាលប្រាសាទដោយសំពត់ស ជាប់ជល់ជណ្តើរជាបឋម ហើយប្រើមនុស្សឲ្យទៅនិមន្តព្រះពុទ្ធអង្គមកសោយលើប្រាសាទ ។ គ្រានោះព្រះពុទ្ធអង្គស្តេចយាងមក ពោធិរាជកុមារនិមន្តឲ្យព្រះពុទ្ធអង្គជាន់លើសំពត់ស ព្រះពុទ្ធអង្គក៏មិនជាន់ បែរព្រះភក្ត្រទៅព្រះអានន្ទ ព្រះអានន្ទបង្គាប់ឲ្យរើចេញ ទើបយកទៅក្រាលជាអាសនៈលើប្រាសាទ ព្រះពុទ្ធអង្គសោយស្រេច ស្តេចក៏យាងត្រឡប់មក ទើបព្រះពុទ្ធអង្គទ្រង់បញ្ញត្តហាមឃាត់ដូច្នេះ ។ ក្នុងអដ្ឋកថាថា ពោធិរាជកុមារផ្សងទុកថា បើយើងនឹងមានកូន ព្រះពុទ្ធអង្គគង់នឹងជាន់លើកំរាល ថាបើមិនមានកូន ព្រះពុទ្ធអង្គនឹងមិនបានជាន់ ព្រះពុទ្ធអង្គឃើញថាមិនមានកូន បើជាន់ចុះ ពោធិរាជកុមារនឹងឃើញវិបល្លាសទៅ ទើបទ្រង់មិនជាន់ នេះជាហេតុដែលទ្រង់មិនជាន់ ។ ចំណោរមកខាងមុខភិក្ខុទាំងឡាយមិនដឹង បើជាន់សំពត់ដូច្នោះទៅ គ្រហស្ថទាំងឡាយគេនឹងមើលងាយបាន ព្រោះហេតុនោះ ព្រះពុទ្ធអង្គទើបទ្រង់បញ្ញត្តហាមឃាត់រឿងនេះទុក ។ ស្រីមានគភ៌ចាស់ ឬសំរាលកូនថ្មី ៗ អារាធនាឲ្យជាន់ចុះក្តី នឹងជាន់សំពត់ដែលគេក្រាលទុកសំរាប់ជូតជើងក្តី ទាំងអស់នេះគួរ ។ ដ្បិតទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ គិហីនំ មង្គលត្ថាយ យាចិយមានេន ។ ល ។ អនុជានាមិ ភិក្ខវេ ធោតបាទកំ អក្កមិតុំ ដូច្នេះ ។

www.budinst.gov.kh www.elibraryofcambodia.org

មួយទៀត ភិក្ខុមិនមានជម្ងឺកុំបាំងឆត្រក្រៅឧបចារវត្ត ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ ឆត្តំ ធារេតព្វំ... ភិក្ខុកុំគប្បីបាំងឆត្រ បើបាំងត្រូវទុក្កដ ។ បើខ្លួនក្តៅក្រវល់ក្រវាយ ឬឈឺក្បាលឬស្រវាំងភ្នែក ឬអាពាធដទៃណាមួយ បើរៀរឆត្រចេញហើយបង្កើតជាជម្ងឺ ភិក្ខុឈឺនោះនឹងបាំងឆត្រក្នុងស្រុកក្នុងព្រៃក៏គួរ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ គិលានស្ស ឆត្តំ ដូច្នេះ ។ បើភ្លៀងនឹងរក្សាចីវរ ឬខ្លាចសត្វសាហាវនឹងចោរ សូម្បីបាំងឆត្រដើម្បីនឹងរក្សាខ្លួនក៏គួរ ។ ឯបាំងឆត្រស្លឹកឈើគួរក្នុងទីទាំងពួង មិនឈឺបាំងបានតែក្នុងវត្ត ឬឧបចារៈនៃវត្ត ។ ដ្បិតទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ អគិលានេនបិ ភិក្ខុនា អារាមេ អារាមូបចារេ ឆត្តំ ធារេតុំ ដូច្នេះ ។

មួយទៀត ភិក្ខុកុំគប្បីឲ្យគេគូរគំនូររូបភាព បើឲ្យគេគូរ ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ បដិភាណចិត្តំ ការាបេតព្វំ ឥត្ថីរូបកំ បុរិសរូបកំ... ដូច្នេះ ។

មិនត្រឹមតែរូបស្រី រូបប្រុសមួយចំពូកប៉ុណ្ណោះទេ សូម្បីតែរូបសត្វតិរច្ឆាន ដោយហោចទៅតែរូបជន្លេន ភិក្ខុនឹងធ្វើឯង ឬបង្គាប់ឲ្យគេធ្វើ មិនគួរ ។ សូម្បីនឹងពោលថា ឧបាសកអ្នកចូលធ្វើមនុស្សរក្សាទ្វារ ដូច្នេះក៏មិនគួរ ។ ឯនឹងឲ្យអ្នកដទៃគូររឿងជាតកនឹងរឿងអសទិសទានជាដើម ឬរឿងដែលជាទីតាំងនៃសេចក្តីជ្រះថ្លា នឹងប្រកបដោយសេចក្តី

www.budinst.gov.kh www.elibraryofcambodia.org

ទៀយណាយនោះបាន ។ សូម្បីត្បូងដើមឈើវល្លិជាដើមក៏បាន ។ ដ្បិតទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ មាលាកម្មំ លតាកម្មំ មករទន្តកំ បញ្ចបដិកំ ដូច្នេះ ។

មណ្ឌតាទិកថា ចប់

## បត្តបដិសំយុត្តកថា

១មួយ ភិក្ខុកុំគប្បីយកបាត្រព្យួរក្នុងទីណាមួយ បើព្យួរត្រូវទុក្កដ ។ ដ្បិតទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ បត្តោ លគ្គេតព្វោ ដូច្នេះ ។ សូម្បីនឹងចងព្យួរក្នុងខ្សែស្បៀងចីវរទុកក៏មិនគួរ ។ មួយទៀត កុំយកបាត្រដាក់លើគ្រែ លើតាំង លើក្នុខ លើឆត្រ លើក្របផ្ទះ ទឹងក្នុងទីបំផុតនៃបរិភណ្ឌ បើដាក់ក្នុងទីទាំងអម្បាលនេះ ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ មញ្ចេ បត្តោ និក្ខិបិតព្វោ បីឋេ... អង្កេ... ឆត្តេ... មិឍន្តេ... បរិភណ្ឌន្តេ បត្តោ និក្ខិបិតព្វោ ដូច្នេះ ។ គ្រែតាំងះគេធ្វើដើម្បីនឹងដាក់របស់ ឬ ដើម្បីនឹងអង្គុយដេកក្តី កាលបើយកបាត្រដាក់លើគ្រែ លើតាំងណាមួយ ក៏គង់ត្រូវទុក្កដ ។ បើយកបាត្រចងជាមួយនឹងរបស់ដទៃដាក់ទុកក៏គួរ ឬនឹងចងក្នុងមេគ្រែ សំយុងចុះទុកក៏គួរ សូម្បីចងហើយ ទឹងដាក់លើគ្រែ-លើតាំងមិនគួរ ។ បើគេលើកគ្រែ ឬតាំងទៀងដាក់ទុកជាកងកងលើឈើស្ដុកលើដើម នឹងយកបាត្រដាក់លើគ្រែតាំងនោះ

ក៏គួរ ។ មិនយកខ្សែយោគពាក់ចូលក្នុងចុង្កៀយស្មា ហើយដំកល់លើក្អែន ក៏គួរ ។ សូម្បីបាត្រពេញដោយបាយស្ពាយលើចុង្កៀយស្មា មិនយកដំកល់ទុកលើធ្រែមិនគួរ ។ ឯមិនចងបាត្រទទេ មិនបាត្រដែលពេញដោយបាយជាមួយមិនកណ្ដ ហើយដំកល់លើធ្រែ ឬមិនដំកល់បាត្រផ្ដូះលើធ្រែ ដែលចងជាប់ខ្ជាប់ដំកល់ទុកក្ដីក៏គួរ ។ មិនដំកល់បាត្រលើគ្រប់នៃរបៀងជាដើម មិនក្ដារបន្ទឹកមិនគួរ ។ បើបាត្រសូម្បីរមៀលទៅកំបិតៈនៅក្នុងគ្រប ក្នុងក្ដាក់ដៃនោះឯង មិនដំកល់បាត្រលើគ្របដែលធំទូលាយយ៉ាងនេះគួរ ។ ទីបំផុតនៃបរិកណ្ណនោះ គឺហាងផ្ទៃក្រៅគ្របក្រៅក្ដាក់ដៃ វិនិច្ឆ័យក្នុងទីបំផុតនៃបរិកណ្ណនេះ គប្បីដឹងដោយន័យដូចសំដែងហើយក្នុងគ្របនោះចុះ ។

មួយទៀត ភិក្ខុកុំគប្បីដាក់បាត្រ ផ្កាប់បាត្រលើផ្ទៃដែលមុតដែលរឹង ៗ ផ្ទុំក្រចនអនុញ្ញាតគ្រឿងរងទុកគឺ តិណសន្ថារកាំ គ្រឿងក្រាលរងធ្វើដោយស្មៅ ១ ចោឡកាំ កំណាត់សំពត់ក្រាលរងបាត្រ ១ ។ បើកំណាត់សំពត់នោះមិនមាន មិនដាក់បាត្រលើខ្សែលដៅ ឬខ្សែលផែង ឬមិនដាក់លើផ្ទៃដែលគេលាបដីស្អិតក្នុងទីណា ដែលមិនប្រទូសក៏យបាត្រ មិនដាក់ក្នុងទីដូច្នោះ ឬលើខ្សាច់ក៏គួរ ។ កាលបើដាក់ក្នុងទីមានដីស្រួយ មិនធូលីជាដើម ឬលើផ្ទៃដែលមុតដែលរឹង ត្រូវទុកជ ។ បត្តមាឡកាំ ពេនសម្រាប់ទុកបាត្រ ធ្វើដោយឥដ្ឋ ឬឈើ បត្តកុណ្ឌលិកាំ ការសម្រាប់ដាក់របស់មានសណ្ឋានដូចផើងមាត់ធំ របស់ទាំងនេះព្រះពុទ្ធ

អង្គទ្រង់អនុញ្ញាតទុក ដើម្បីឲ្យជាទីទុកបាត្រ បត្តត្ថវិកំ ថង់បាត្រ អំសវទ្ធកំ ពន្ធនសុត្តកំ យោគបាត្រ ទីងខ្សែសម្រាប់ចង របស់ទាំងពីរនេះ ព្រះអង្គទ្រង់អនុញ្ញាតទុកឲ្យដើម្បីនឹងរក្សាបាត្រ ។ បត្តាធារកំ ជើងបាត្រនេះ ព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកជាគ្រឿងដំកល់បាត្រ ។ ក្នុងអដ្ឋកថាកុរុន្ទីពោលទុកថា ឯជើងបាត្រមានសណ្ឋានដូចកងគឺបុគ្គលៈធ្វើដោយក្អក ទីងវល្លិ ទីងផ្តៅជាដើម ទីងដំកល់បាត្រលើជម្រកលើគ្នាបាន ឬជើងបាត្រធ្វើដោយឈើ ទីងដំកល់បាត្រពីរជាន់លើគ្នាគួរ ។ តែក្នុងមហាអដ្ឋកថាពោលទុកថា ក្នុងជើងបាត្រមានសណ្ឋានដូចកង មិនមានឱកាសល្មមដំកល់បាត្របីបាន ទីងដំកល់បាត្រត្រឹមតែពីរគួរ ។ សូម្បីជើងបាត្រធ្វើដោយឈើ ឬកំណាត់ឈើក៏ដូចគ្នា ។ ជើងបាត្រធ្វើដោយឈើដូចក្រឡាចក្រឡឹង ទីងជើងបាត្រធ្វើដោយកំណាត់ឈើ គឺយកឈើបីកំណាត់ចងភ្ជាប់គ្នាក្តី ក៏មិនជាឱកាសនៃបាត្រ ។ សូម្បីតែមួយ ថាតើដំកល់បាត្រលើជើងបាត្រនោះ គប្បីអង្គុយយកដៃចាប់ទប់ទុក បើថ្ងៃគប្បីភ្ជាប់ទុកតែមួយ ហើយដំកល់ទុកចុះ ។

មួយទៀត ភិក្ខុកុំគប្បីយករបស់សំណល់ដាក់ក្នុងបាត្រ កុំលាងដៃក្នុងបាត្រ គប្បីលាងក្នុងគេនោះ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទីងអនុញ្ញាតទុកថា ន ភិក្ខវេ ចលកានិ វា អដ្ឋិកានិ វា ឧច្ឆិដ្ឋោទកំ វា បត្តេន នីហរិតព្វំ ... ។ អនុជានាមិ ភិក្ខវេ

www.budinst.gov.kh www.elibraryofcambodia.org

បដិគ្គហំ ម្នាលភិក្ខុទាំងឡាយអាមិសដែលធ្លាក់ចេញ ពីឆ្អឹងត្រី ឬឆ្អឹងសាច់ ឬទឹកខ្ពុរមាត់ ដែលជាសំណល់ណាមួយ ភិក្ខុកុំគប្បីនាំទៅដោយបាត្រ បើនាំទៅក្រៅវត្តជ ។ តថាគតអនុញ្ញាតកន្ថោរជាគ្រឿងរងទទួល សម្បីនឹងយកបាត្រធ្វើជាកន្ថោរលាងដៃ មិនបានឡើយ ។ សម្បីនឹងដាក់ទឹកលាងដៃលាងជើងក្នុងបាត្រ ហើយនាំយកទៅចាក់ចោលក៏មិនគួរ នឹងចាប់បាត្រដែលស្អាតមិនប្រឡាក់ ដោយដៃដែលប្រឡាក់ក៏មិនគួរ ។ ដែលនឹងយកដៃឆ្វេងចាក់ទឹកក្នុងបាត្រ ហើយយកដៃស្តាំដែលប្រឡាក់ ចាប់យកទឹកខ្ពុរមាត់នោះគួរ ព្រោះបាត្រនោះឈ្មោះថាបាត្រប្រឡាក់ ដោយហេតុមានប្រមាណប៉ុណ្ណោះ ។ នឹងយកដៃដែលប្រឡាក់ លាងទឹកខាងក្រៅឲ្យប្រាសចាកអាមិសសិន ហើយកាន់យកក៏គួរ ។ កាលឆាន់ត្រីសាច់ផលាផលជាដើម ក្នុងរបស់ទាំងអម្បាលនេះ ឬវត្ថុណាមួយជាឆ្អឹងក្តី សំណល់ក្តី ប្រាថ្នានឹងចោលនឹងយកដាក់ក្នុងបាត្រនោះ មិនបានឡើយ ។ របស់ណាដែលប្រាថ្នានឹងចង់ឆាន់តទៅទៀត នឹងយករបស់នោះដាក់ក្នុងបាត្រនោះបាន នឹងដាក់ឆ្អឹងត្រីជាដើមទុកក្នុងបាត្រហើយយកដៃហូតចេញឆាន់ក៏គួរ ។ របស់ណាមួយនាំចេញអំពីមាត់ហើយ ប្រាថ្នាចង់ឆាន់ទៀត នឹងយករបស់នោះដាក់ក្នុងបាត្រ មិនបាន ។ ចំណិតទ្វី នឹងចំណិតជូនជាដើមទាំឆាន់ហើយដាក់ចុះវិញនោះបាន ។

មួយទៀត ភិក្ខុកុំគប្បីឆាន់ក្នុង អាសិត្តកូបធាន ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ អាសិត្តកូបធានេ

www.budinst.gov.kh www.elibraryofcambodia.org

កុញ្ចិកាតុំ... ភិក្ខុកុំគប្បីឆាន់ក្នុងអាសិត្តកុបធាន បើឆាន់ត្រូវទុក្កដ ។ អាសិត្តកុបធាននេះ ប្រែថា ទៀបខ្លះ ថាប្រអប់ខ្លះ តែក្នុងវិមតិពោល ថាជាឈ្មោះនៃជ្រញ់សម្រាប់រងភាជនៈ មានអាការៈដូចភាជនៈមួយយ៉ាង គេធ្វើជា ៨ ជ្រុងខ្លះ ជា ១៦ ជ្រុងខ្លះ ដាក់បាយបាយាសជាដើមដែលនៅក្តៅ ហើយដំកល់ថាសរងភាជនទាំងលើ ដើម្បីនឹងមិនឲ្យបាយដែលក្តៅនោះបាត់ក្តៅ ជ្រញ់សម្រាប់រងដូច្នេះ គេធ្វើដោយទង់ដែងខ្លះ ដោយប្រាក់ខ្លះ ព្រោះជារបស់ព្រះពុទ្ធអង្គទ្រង់ហាមឃាត់ហើយ សូម្បីធ្វើដោយឈើក៏មិនគួរ គួរតែគ្រឿងរងដែលធ្វើដោយកំណាត់ឈើដែលឈ្មោះថាមល្លោរិកៈ ជារបស់ទ្រង់អនុញ្ញាតដល់ភិក្ខុណី ដែលមិនអាចនឹងកាន់បាត្រទុកឆាន់បាន ។ ជើងបាត្រព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកក្នុងបទមុននេះ ដើម្បីនឹងឲ្យរក្សាបាត្រ មល្លោរិកៈនេះ ទ្រង់អនុញ្ញាតដើម្បីនឹងឲ្យរងឆាន់ សូម្បីគ្រឿងរងធ្វើនឹងឈើសារនឹងស្លឹកឈើនឹងកញ្ជើនឹងជាល ក៏រាប់ចូលក្នុងមល្លោរិកៈទាំងអស់ គ្រឿងរងនោះប្រហោងក្តី ធុះធ្លាយក្តី មិនធុះធ្លាយក្តី នេះគួរដោយពិត ។

មួយទៀត ភិក្ខុកុំគប្បីយកលលាដ៍ឃ្លោកធ្វើជាបាត្រ ដើរបិណ្ឌបាត កុំយកអំបែងពាង អំបែងឆ្នាំងធ្វើជាបាត្រដើរបិណ្ឌបាត បើបិណ្ឌបាតដោយរបស់ទាំងអម្បាលនេះ ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ តុម្ពកដាហេន បិណ្ឌាយ ចរិតព្វំ... ដូច្នេះ ។ លលាដ៍ឃ្លោកនឹងរក្សាទុកមិនគួរ បើបានមកហើយ ធ្វើជារបស់[illegible]ប្រើ

www.budinst.gov.kh www.elibraryofcambodia.org

បែក ៗ សូម្បីសាកសពណាកាលរស់នៅឡើយ កើតបូស ឃ្លង់រលក កែរ ឬដំបៅ សាកសពនោះក៏ឈ្មោះថាបែកហើយ ៗ សូម្បីសាក-សពណាអំពីថ្ងៃគំរប់ ៣ ឡើងទៅ ហើយហើមឡើង ក៏ឈ្មោះថាបែកដោយពិត ៗ សូម្បីសាកសពដែលមិនទាន់បែកដោយប្រការទាំងពួង ភិក្ខុនឹងប្រើអ្នកក្រុបាធា ឬមនុស្សដទៃឲ្យកាន់យកក៏គួរដោយពិត ថាបើមិនមានអ្នកដទៃ គប្បីធ្វើដោយសស្ត្រា ឬវត្ថុដទៃ ធ្វើឲ្យដាច់ជាស្នាមហើយ គប្បីកាន់យកបង្សុកូលចុះ ៗ ឯគន្ធសារៈជាវិសភាគ គឺសាក-សពស្ត្រី នឹងតាំងស្មារតីញុំាងសមណសញ្ញា ឲ្យកើតឡើង ហើយធ្វើឲ្យដាច់ជាស្នាមត្រង់ក្បាល ឬខ្នងដៃ ខ្នងជើង ទើបកាន់យកគួរ ៗ

មួយទៀត ភិក្ខុក៏គប្បីប្រើបាត្រឈើ បាត្រមាស បាត្រប្រាក់ បាត្រកែវមណី បាត្រកែវពិទូរ្យ បាត្រកែវថ្លុក បាត្រសំរិទ្ធ បាត្រកែវស្ល បាត្រសំណរគក់ បាត្រសំណរសី បាត្រទង់ដែង ទាំងអស់នេះបើប្រើប្រាស់ត្រូវទុក្កដ ៗ បាត្រពីរប្រការ គឺបាត្រដែក ១ បាត្រដី ១ ប្រើគួរ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់នឹងអនុញ្ញាតទុកថា ន ភិក្ខវេ ទារុ-បត្តោ ធារេតព្វោ យោ ធារេយ្យ អាបត្តិ ទុក្កដស្ស ន សោ-វណ្ណមយោ... ន រូបិយមយោ... ន មណិមយោ... ន វេឡុ-រិយមយោ... ន ផលិកមយោ... ន កំសមយោ... ន កាច-មយោ... ន តិបុកមយោ... ន សីសមយោ... ន តម្ពលោ-ហមយោ បត្តោ ធារេតព្វោ... ។ អនុជានាមិ ភិក្ខវេ ទ្វេ

www.budinst.gov.kh www.elibraryofcambodia.org

បត្តំ អយោបត្តំ មត្តិកាបត្តំ ដូច្នេះ ។ ក្ដុងកេងទាន់ៈប័ត្រហស្ត គេដាក់ម្ហូបក្ដុងថាសមាសជាដើម បង្អោនបូលមកប្រគេន សូម្បីខឹងតាប់ពាល់ក៏មិនគួរ ។ ភាជនៈមានថាសជាដើម ធ្វើដោយកែវថ្មក កែវស្លូ ខឹងសំរិទ្ធជាដើម ជាបុគ្គលិកបរិភោគ មិនគួរ ។ ជាសង្ឃិកបរិភោគ ឬជាគំហ៊ីរិកដ (គ្រឿងប្រើនៃគ្រហស្ថ) នោះគួរ ។ បាត្រដំហើយដោយទង់ដែងមិនគួរ ។ តែបើជាតាន ឬជាតែងក៏គួរ ពាក្យទាំងអម្បាលនេះពោលទុកក្នុងគម្ពីរអដ្ឋកថា ។

មួយទៀត ភិក្ខុកុំគប្បីយកបាត្រទាំងទទឹកទៅទុកដាក់ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ សោទកោ បត្តោ បដិសាមេតព្វោ... ភិក្ខុកុំគប្បីយកបាត្រទាំងទទឹកទៅទុកដាក់ បើទុកដាក់ត្រូវទុក្កដ ។ គប្បីហាលថ្ងៃឲ្យស្ងួតជាមុនៈហើយសឹមទុក ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ ឱតាបេត្វា បត្តំ បដិសាមេតុំ ដូច្នេះ ។

មួយទៀត ភិក្ខុកុំគប្បីហាលបាត្រទាំងទទឹក បើហាលត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ សឧទកោ បត្តោ ឱតាបេតព្វោ . ដូច្នេះ ។ គប្បីធ្វើឲ្យស្រស់ដាច់ទឹកជាមុន ហើយសឹមហាល ។ ដ្បិតទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ វោទកំ កាតុំ ។ល។ ដូច្នេះ ។

www.budinst.gov.kh www.elibraryofcambodia.org

មួយទៀត ភិក្ខុកុំគប្បីហាលបាត្រឲ្យក្តៅយូរពេក ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ ឧណ្ហោ បត្តោ និទហិតព្វោ... ភិក្ខុកុំគប្បីដំកល់បាត្រទុកក្នុងទីក្តៅ បើដំកល់ទុក គួរទុកដ ។ គប្បីហាលទុកកណ្តាលថ្ងៃ ដែលក្តៅបន្តិចហើយទុកដាក់ ។ ដ្បិតទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ មុហុត្តំ ឧណ្ហេ ឱតាបេត្វា ។ល។ ដូច្នេះ ។

បត្តបដិសំយុត្តកថា ចប់

## សេនាសនបដិសំយុត្តកថា

១មួយ ភិក្ខុកុំគប្បីអង្គុយលើអាសនៈវែងជាមួយនឹងស្ត្រី នឹងខ្ទើយ នឹងបណ្ឌក នឹងឧភតោព្យញ្ជនក ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ ឋបេត្វា បណ្ឌកំ មាតុគាមំ ឧភតោព្យញ្ជនកំ អសមានាសនិកេហិ សហ ទីឃាសនេ និសីទិតុំ គឺថាតថាគតអនុញ្ញាតឲ្យអង្គុយលើអាសនៈវែង ជាមួយនឹងអ្នកមានអាសនៈមិនស្មើគ្នាបាន វៀរលែងតែបណ្ឌកគឺខ្ទើយ នឹងស្ត្រី នឹងឧភតោព្យញ្ជនក (មនុស្សមានទាំងភេទស្រីភេទប្រុស) អម្បាលនេះចេញ ព្រោះព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា អាសនៈណាល្មមអង្គុយបាន ៣ នាក់ អាសនៈដូច្នេះឈ្មោះថាអាសនៈវែងយ៉ាងតូច ដ្បិតពាក្យថា អនុជានាមិ ភិក្ខវេ យំ តិណ្ណន្នំ បហោតិ ឯត្តកំ បច្ឆិមំ ទីឃាសនំ

www.budinst.gov.kh www.elibraryofcambodia.org

អាសនៈ មិនមែនជាគ្រែ ជាតាំង នោះបាន តែគ្រែ តាំង អង្គុយបានតែ ពីរអង្គ គ្រែនឹងតាំងមិនមែនជាអាសនៈវិញ ភិក្ខុមានអាសនៈស្មើគ្នា អង្គុយបានតែពីរអង្គប៉ុណ្ណោះ ព្រោះព្រះអង្គទ្រង់អនុញ្ញាតគ្រែនឹងតាំងដល់ ភិក្ខុមានពួកពីរ មួយយ៉ាងប៉ុណ្ណោះ ព្រោះហេតុនោះ សាមណេរនឹង អង្គុយ ឬដេក លើគ្រែតាំងតែ ១ ជាមួយគ្នា ស្មើនឹងភិក្ខុមិនបាន ។ ភិក្ខុកម្លោះកាលសំដែងធម៌ នឹងអង្គុយលើអាសនៈស្មើគ្នា ឬខ្ពស់ជាងគ្នា ដោយគោរពក្នុងធម្មិកថា នឹងភិក្ខុដែលជាថេរៈ កាលបើឲ្យភិក្ខុកម្លោះ សំដែងធម៌ នឹងអង្គុយលើអាសនៈស្មើគ្នា ឬទាបជាង ដោយគោរពក្នុង ធម្មិកថា ក៏គួរ ៗ ដូចព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ ថេរេន ភិក្ខុនា ។ល។ ធម្មគារវេន ដូច្នេះ ។

មួយទៀត ភិក្ខុគង់បរិភោគលើអាសនៈធំ ៗ ដូចព្រះពុទ្ធអង្គទ្រង់ ហាមឃាត់ទុកថា ន ភិក្ខវេ ឧច្ចាសយនមហាសយនានិ ធារេតព្វានិ សេយ្យថីទំ អាសន្ទិ... ឧកគោលោមកំ ក្រុប: ជាដំ ភិក្ខុគង់បរិភោគទ្រង់ គឺដេកអង្គុយ លើទីដេក ទីអង្គុយ ដ៏ខ្ពស់ដ៏ធំ បើទ្រង់ត្រូវទុក្កដ ៗ ទីដំណេកខ្ពស់ ទីដំណេកធំនោះដូច្នេះ គឺ អាសន្ទិ អាសនៈ គ្រែ តាំង ខ្ពស់ហួសប្រមាណ បល្ល័ង្ក បល្លង្ក ទីអង្គុយ ដែលគេធ្វើប្រដាប់ដោយរូបសត្វសាហាវនៅជើង គោណកោ សំពត់ កោជវៈធំ (ក្រាំ) មានរោមវែង បានពួជាជាងរោមនៃសំពត់នោះវែងជាង ៤ ធ្នាប់ ចិត្តកា គ្រឿងក្រាលធ្វើដោយរោមសត្វ វិចិត្រដោយរូបសត្វសាហាវ

www.budinst.gov.kh www.elibraryofcambodia.org

បដិកា គ្រឿងកម្រាលមានពណ៌សធ្វើពីរោមសត្វ បដលិកា គ្រឿងកម្រាលធ្វើដោយរោមសត្វមានក្បាច់ល្អជាផ្កាបង្កើម គេហៅថាសំពត់អ្នកស្រុកយោនកៈខ្លះ សំពត់ទមិលខ្លះ តូលិកា កម្រាលដែលញាត់គរប្រក់មួយចំពូក វិកដិកា គ្រឿងកម្រាលធ្វើដោយរោមសត្វវិចិត្រដោយរូបរាជសីហ៍នឹងរូបខ្លាធំជាដើម ឧទ្ធលោមី គ្រឿងកម្រាលធ្វើដោយរោមសត្វ មានរោមប្រាងឡើងតែម្ខាង ឯកន្តលោមី គ្រឿងកម្រាលធ្វើដោយរោមសត្វ មានរោមប្រាងឡើងទាំងពីរខាង កដិស្សំ កម្រាលដែលធ្វើពីខិនបាសឬខ្សែស្រយតាក់តែស្រះដោយរតនវត្ថុ កោសេយ្យំ គ្រឿងកម្រាលដែលធ្វើពីសរសៃសូត្រ នឹងអំបោះ តាក់តែស្រះដោយរតនវត្ថុ កុត្តកំ គ្រឿងកម្រាលធ្វើដោយរោមសត្វ ធំល្មមចំណុះស្រីរបាំ ១៦ នាក់ឈររាំបាន ហត្ថត្ថរំ គ្រឿងកម្រាលសម្រាប់ក្រាលលើខ្នងដំរី អស្សត្ថរំ គ្រឿងកម្រាលសម្រាប់ក្រាលលើខ្នងសេះ រថត្ថរំ គ្រឿងកម្រាលសម្រាប់ក្រាលរថ អជិនប្បវេណិ គ្រឿងកម្រាលធ្វើដោយស្បែកខ្លា ឈ្មោះថាអជិនៈ ធំប្រមាណប៉ុនគ្រែ ដ្បិតថាស្បែកសត្វចំពូកនោះ សាច់ទន់សុខុមល្អណាស់ ទើបដេរជុំគ្នាបាន កាទលិមិគបវរបច្ចត្ថរណំ គ្រឿងកម្រាលយ៉ាងល្អ គេធ្វើពីស្បែកឈ្លូស បានឮថាមនុស្សទាំងឡាយ គេក្រាលស្បែកឈ្លូសចុះលើសំពត់សធ្វើជាគ្រឿងកម្រាលខាងលើ សឧត្តរច្ឆទំ គ្រឿងកម្រាលមានពិតានក្រហមពាសខាងលើផង សូម្បីពិតានស តែខាងក្រោម

www.budinst.gov.kh www.elibraryofcambodia.org

មានគ្រឿងក្រាលជាអកប្បិយក៏មិនគួរ កាលបើមិនមានទើបគួរ ទក-
គោលោហិតក្រុបជាដំ ទីដេកមានខ្នើយក្រហមនៅខាងចាំងពីរនៃ
គ្រែដេក គឺខ្នើយក្បាលនិងខ្នើយជើង ទីដំណេកនោះមិនគួរ ។ ថាបើខ្នើយ
ណា តែមួយប៉ុណ្ណោះ ក្នុងខាងចាំងពីរ សូម្បីក្រហម ឬពណ៌ផ្កា
ឈូក ឬវិចិត្រក្ដី បើប្រកបដោយប្រមាណហើយក៏គួរ យកតែខ្នើយ
ធំមួយមុខ ។ ក្នុងដីកានៃខន្ធកសិក្ខាកំណត់ទុកថា អាសន្ទិនិងបល្ល័ង្កឈ្មោះ
ថាឧច្ចាសនៈ ក្រៅពីនោះឈ្មោះមហាសយនៈ ។ អាសនៈខ្ពស់ អាសនៈធំ
ដូចពោលមកនេះមិនគួរ តែងទោមួយសន្លឹកហៅថាគ្រែឬតាំង ។ គ្រែនិង
តាំងទាំងពួង បាក់ទាក់ដោយផ្តៅនិងបន្ទោះ ឬចងដោយសំពត់ធ្វើដោយ
ក្តារមានជើងកោង ជើងត្រង់ ជើងប្រែទក្តី តែជើងកំពស់ ៨ ធ្នាប់ដោយ
ធ្នាប់ព្រះសុគត លើកតែជើងឯខាងក្រោមចេញ គួរចាំងអស់ ។
ទ្រនាប់ជើងគ្រែកំពស់ត្រឹម ៨ ធ្នាប់ជាងលើ ទើបគួរ ខ្ពស់លើសជាង
នោះមិនគួរ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់និងអនុញ្ញាតទុកថា ន
ភិក្ខវេ ឧច្ចា មញ្ចបដិបាទកា ធារេតព្វា... ។ អនុជានាមិ
ភិក្ខវេ អដ្ឋង្គុលបរមំ មញ្ចបដិបាទកំ ភិក្ខុគប្បីប្រើប្រាស់
ទ្រនាប់ជើងគ្រែខ្ពស់ បើប្រើប្រាស់ ត្រូវទុក្កដ ។ តថាគតអនុញ្ញាតទ្រនាប់
ជើងគ្រែត្រឹម ៨ ធ្នាប់ជាងលើជាយ៉ាងក្រៃភាគ ។ អាសន្ទិ គឺតាំងបួនជ្រុង
សូម្បីជើងខ្ពស់ជាង ៨ ធ្នាប់ព្រះសុគតក៏គួរ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាត
ទុកថា អនុជានាមិ ភិក្ខវេ ឧច្ចកម្បិ អាសន្ទិកំ កថា

www.budinst.gov.kh www.elibraryofcambodia.org

អនុញ្ញាតតាំងបួនជ្រុង សូម្បីមានជើងខ្ពស់ ៗ គ្រែបួនជ្រុងធ្វើបន្ថែមបីជ្រុង សូម្បីខ្ពស់ក្រៃលែងប្រមាណក៏គួរ ៗ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ ឧច្ចកម្បិ សត្តង្គំ តថាគតអនុញ្ញាតគ្រែមានអង្គ ៧ សូម្បីខ្ពស់ ៗ ចំពោះ ៤ ជ្រុងទើបគួរ វែងលើសប្រមាណមិនគួរ ៗ ព្រះពុទ្ធអង្គទ្រង់អនុញ្ញាតគរ ៣ យ៉ាង រុក្ខតូលំ គរនៃដើមឈើបានដល់ដើមគរ ដើមរកាជាដើម ១ លតាតូលំ គរនៃវល្លិមានប្រឡៅអំពែនឹងផ្ទុងអង្ករជាដើម ១ បោដកតូលំ គរនៃតិណជាតិណាមួយមានផ្កាអំពៅព្រៃជាដើម ដោយហោចទៅសូម្បីផ្កាអំពៅ ផ្កាបបុសជាដើមក៏ឈ្មោះថាផ្កាស្មៅ ១ ដ្បិតគរ ៣ ប្រការនេះ សង្គ្រោះយកក្នុងពូកតាមតាំងអស់ ដ្បិតថាហួសជាតិនៃដើមឈើនឹងវល្លិនឹងស្មៅផងអំពីពូកតាមមិនមាន ព្រោះហេតុនោះ គរនៃពូកតាមណាមួយ រមែងគួរក្នុងខ្នើយតែមួយចំពូក គរទាំងពួងនេះ សូម្បីប្រកពូក ឈ្មោះថាអកប្បិយតូលទាំងអស់ មិនមែនតែគរនោះគួរក្នុងខ្នើយមួយមុខទេ សូម្បីរោមនៃសត្វទាំងពួង មានហង្សនឹងក្ងោកជាដើម នឹងរោមនៃសត្វចតុប្បាទមានពពែជាដើមនេះក៏គួរ ៗ ក៏ឯផ្កាឈើណាមួយ មានផ្កាប្រយង៍នឹងផ្កាក្លូលជាដើមធ្វើជាគរមិនគួរ ឬសឹកឈើ តមាលបត្ត ស្លឹកតុំសែនសុទ្ធមិនគួរ បើលាយដោយស្លឹកដទៃទើបគួរ ៗ សូម្បីគរ ៥ ចំពូកមានគរនៃរោមកែះជាដើម ដែលព្រះពុទ្ធអង្គទ្រង់អនុញ្ញាតក្នុងពូក ក៏គួរក្នុងខ្នើយផង ព្រះពុទ្ធអង្គអនុញ្ញាតពូក ៥ យ៉ាងគឺ ឧណ្ណភិសិ ពូកញាត់ដោយ

www.budinst.gov.kh www.elibraryofcambodia.org

កេមកែះ ១ កោធ្សកិសិ ពួកញាត់ដោយកំណាត់សំពត់ បាកាកិសិ ពួកញាត់ដោយសំបកឈើ ១ តិណកិសិ ពួកញាត់ដោយស្មៅ ១ បណ្ណកិសិ ពួកញាត់ដោយស្លឹកឈើ ១ ។ ឈ្មោះពួកទាំង ៤ នេះ កប់តាមរបស់ដែលជាគរដាក់ខាងក្នុង ។ ដែលពោលថាកេមកែះនោះ មិនមែនតែកេមកែះមួយមុខទេ សម្បីកេមនៃសត្វស្លាបនិងសត្វជើងបួន ដែលជាជាតិនៃសត្វមានសាច់ជាកប្បិយ ឬអកប្បិយណាមួយមិនឃាត់ លើកតែកេមមនុស្សចេញ កេមក្រៅពីនោះសង្គ្រោះចូលជាកេមកែះក្នុងបទនេះទាំងអស់ ។ ព្រោះហេតុនោះ ទិនធ្វើបិរដោយកំណាត់សំពត់ ៦ យ៉ាង គឺសំពត់ដែលអនុលោម ៦ ប្រការ ណាមួយធ្វើជាសំបកពួកហើយ ញាត់ដោយកេមសត្វទាំងពួងចូលខាងក្នុង ហើយធ្វើជាពួកក៏គួរ សម្បីពួកដែលបត់សំពត់កម្ពលចូលជា ៤ ជាន់ ឬ ៥ ជាន់មិនបានញាត់ដោយកេមសត្វ ហើយធ្វើជាពួកក៏កប់ថាពួកកេមកែះដែរ ។ ឯពួកញាត់ដោយស្លឹកឈើនោះ លើកតែស្លឹកតុំសែនចេញ ស្លឹកឈើក្រៅពីនោះគួរទាំងអស់ តែស្លឹកតុំសែនលាយដោយស្លឹកឈើដទៃ គួរស្លឹកតុំសែនសុទ្ធមិនគួរ ។ ក្នុងអដ្ឋកថាកុរុន្ទីពោលថា គរ ៥ យ៉ាងមានកេមកែះជាដើម ដែលគួរក្នុងពួក គរនោះ សម្បីក្នុងមស្សុរកៈក៏គួរដូចគ្នា ដ្បិតពាក្យនោះជាការសម្រេចសេចក្តីថាទិនបរិភោគប្រើប្រាស់មស្សុរកៈក៏គួរ ។ ក្នុងសារត្ថទីបនីថាបទមស្សុរកៈជាចម្មយកសិ ប្រែថាពួកស្បែក កំណត់ប្រមាណនៃពួកមិនមាន ពួកវែង ពួកតាំង ពួកកំពល

www.budinst.gov.kh www.elibraryofcambodia.org

ពួកក្រាលថ្ម ពួកទីបច្រើម ពួកជួតជើង ទាំងអម្បាលនេះ គប្បីកំណត់តាមសមគួរ ហើយធ្វើប្រមាណតាមគាប់ចិត្តចុះ ។.

មួយទៀត ភិក្ខុគប្បីទ្រង់ខ្នើយធំប្រមាណពាក់កណ្ដាលកាយ ។ ព្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ នឹងកំណត់អនុញ្ញាតទុកថា ន ភិក្ខវេ អឌ្ឍកាយិកានិ ពិម្ពោហនានិ ធារេតព្វានិ យោ ធារេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ សីសប្បមាណំ ពិម្ពោហនំ កាតុំ ភិក្ខុគប្បីទ្រង់ខ្នើយប្រមាណពាក់កណ្ដាលកាយ គឺកាយតាំងអំពីចង្កេះដរាបដល់ក្បាល បើទ្រង់ត្រូវទុក្កដ ។ តថាគតអនុញ្ញាតខ្នើយប្រមាណល្មមប៉ុនក្បាល តឹងទទឹងល្មមដាក់ក្បាលទាំងអស់ជាមួយនឹងកផងបាន ។ លក្ខណៈធ្វើខ្នើយ យកសំពត់ស្បង់ខ្នើយបួនជ្រុង បត់កាច់ជ្រុងឲ្យជា ៣ ជ្រុង ក់សុំចន្លោះជ្រុងជាន់ទាំងពីរ ទទឹង ១ ចំអាម ៤ ធ្នាប់ ទីពាក់កណ្ដាល ១ តក់ ប្រវែងតួខ្នើយ ១ តក់កន្លះ ឬពីរតក់ក៏បាន ខ្នើយទទឹងបណ្ដោយប្រមាណប៉ុណ្ណោះ ឈ្មោះថាខ្នើយប្រមាណប៉ុនក្បាល ពាក្យនេះពោលទុកក្នុងកុរុន្ទី បើខ្នើយផ្លែក ឬខ្នើយប៉ាក់ថៅ ដូចក្នុងប្រទេសខ្មែរ.សៀមនេះ គប្បីធ្វើចំណែកទទឹងអំពីកឡៀងទៅដល់ក្បាល ឲ្យបាន ១ ចំអាម ៤ ធ្នាប់ ពាក្យនេះជាពាក្យអត្តនោមតិ អាស្រ័យន័យក្នុងវិមតិវិនោទនី ថាខ្នើយមូលនឹងដេរឲ្យមូល ឬឲ្យជា ៤ ជ្រុងក្ដី គប្បីដេរដោយទទឹងកាត់ជ្រុងស្បង់ខ្នើយ ឲ្យបានប្រមាណ ១ តក់ដូច្នេះ កំណត់យ៉ាងក្រៃងនៃខ្នើយមាន

www.budinst.gov.kh www.elibraryofcambodia.org

ក្បាលជាប្រមាណ ខាងលើអំពីប្រមាណនោះឡើងទៅមិនគួរ ចាប់ពី
មកទើបគួរ ។ កំពុំមិនមានជម្ងឺនឹងប្រើខ្នើយក្បាល ខ្នើយជើងទាំងពីរនេះ
ក៏គួរ ព្រះបុស្សទេវត្ថេរ លោកពោលថា ខ្នើយធ្វើដោយគរ ជាកប្បិយ ៤
ដែលព្រះពុទ្ធទ្រង់អនុញ្ញាតក្នុងពូកសម្បីធំក៏គួរ ព្រះឧបតិស្សត្ថេរ លោក
ទ្រង់វិន័យ លោកពោលទុកថា កាលបើគិតនឹងធ្វើខ្នើយ ហើយញាត់គរ
ជាកប្បិយភ័ណ្ឌអកប្បិយភ័ណ្ឌ ប្រកបដោយប្រមាណទើបគួរ ។ ឯគ្រឿងកំរាល
ជាអកប្បិយមានព្រំធំ មានរោមវែង ដូចសំដែងហើយក្នុងបទមុនជាដើម
នឹងក្រាលប្រើប្រាស់លើគ្រែ ឬតាំងក្នុងវិហាររបស់សង្ឃ ឬរបស់បុគ្គល
មិនគួរ ។ បើក្រាលប្រើប្រាស់លើធម្មាសនៈដោយនិយមនៃគិហិវិកដរបស់
គ្រហស្ថរមែងបាន តែនឹងដេកក្នុងទីនោះមិនគួរ ។ ក្នុងគ្រឿងកំរាល
ជាអកប្បិយដូច្នោះ ជាគិហិវិកដ របស់គ្រហស្ថ នៅលើធម្មាសនៈ ឬក្នុង
រោងឆាន់ ឬក្នុងលំនៅផ្ទះក្ដី រមែងនឹងអង្គុយលើក៏គួរ ដេកលើមិនគួរ ។ ព្រោះ
ព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ ឋបេត្វា
តីណិ អាសន្ទឹ បល្លង្កំ តូលិកំ អវសេសំ គិហិវិកតំ
អភិនិសីទិតុំ ន ត្វេវ អភិនិបជ្ជិតុំ គឺថាតថាគតអនុញ្ញាតឲ្យអង្គុយលើ
គ្រឿងកំរាលដ៏សេសជាគិហិវិកដ គឺអាសនៈដែលប្លែកសម្រាប់គ្រហស្ថ
បាន តែដេកមិនបាន វៀរលែងតែរបស់ ៣ ប្រការ គឺគ្រែកាំងខ្ពស់ក្រៃ
លែងប្រមាណ ទីនាំងបល្លង្កដែលច្រឹជាប់ដោយរូបសត្វសាហាវនៅជើង
និងពូកញាត់ដោយគរ ៣ ប្រការ ទាំងអម្បាលនេះ ។ ចាំះបើនឹងអង្គុយ

www.budinst.gov.kh www.elibraryofcambodia.org

ខ្ញុំស្រី ស្រែ ចំការ ដី គោ ក្របី ដើម្បីប្រាសាទដូច្នេះ កិច្ចដែលខ្លួនទទួលផ្សេងគ្នាមិនមាន កាលបើទទួលប្រាសាទហើយ ក៏ឈ្មោះថាទទួលដោយពិត ។

មួយទៀត ទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ អាសន្ទិយា បាទេ ឆិន្ទិត្វា បរិភុញ្ជិតុំ បល្លង្កស្ស វាឡេ ភិន្ទិត្វា បរិភុញ្ជិតុំ តូលិកំ វិជដេត្វា ពិម្ពោហនំ កាតុំ អវសេសំ ភុម្មត្ថរណំ កាតុំ គឺថាត្រង់ អនុញ្ញាតឲ្យកាត់ជើងគ្រែ ជើងតាំងដែលខ្ពស់ហួសប្រមាណចេញ ហើយទើបបរិភោគ នឹងឲ្យទំលាយរូបសត្វសាហាវ ដែលជាប់នៅជើងបល្ល័ង្កចេញ ហើយទើបបរិភោគ ពូកគេឲ្យរើរុះយកកៃគរចេញធ្វើជាខ្នើយ គ្រឿងកំរាលជាអកប្បិយក្រៅនោះ មានសំពត់កោជវៈរោមវែង នឹងគ្រឿងកំរាលធ្វើដោយរោមកែវ វិចិត្រដោយភ្ញីវល្លិដេរបាក់ជាដើម ឲ្យធ្វើជាគ្រឿងកំរាលផ្ទៃក្នុងសេនាសនៈ ។

មួយទៀត អាសនៈដែលគេក្រាលទុក មិនបានពិចារណាមុន កុំអង្គុយចុះ បើអង្គុយចុះ ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកក្នុងវិនីតវត្ថុថា ន ភិក្ខវេ អប្បច្ចវេក្ខិត្វា អាសនេ និសីទិតព្វំ ដូច្នេះ ។ អាសនៈ ដូចម្តេច ទើបត្រូវពិចារណា អាសនៈដូចម្តេច មិនត្រូវពិចារណា? អាសនៈ ណា ជាអាសនៈទទេ មិនមានកំរាលក្តី នឹងអាសនៈណា កាលគេក្រាល ភិក្ខុមកដល់ ឃើញ ហើយបានឃើញក្តី អាសនៈ អម្បាលនេះ មិនបានពិចារណា នឹងអង្គុយ

គំនូរ ៗ សូម្បីអាសនៈណា មនុស្សទាំងឡាយគេយកដៃទះចុះដោយខ្លួនឯងហើយស្រែកនិមន្តថា លោកចូរអង្គុយក្នុងទីនេះ សូម្បីក្នុងអាសនៈនោះគំនូរ ៗ បើភិក្ខុទាំងឡាយអង្គុយមុនហើយ គ្រាក្រោយទើបឡើងលើឬខាងក្រោម ភិក្ខុដែលនឹងពិចារណានោះគ្មាន ៗ សូម្បីអាសនៈណា គេយកសំពត់ស្តើងក្រាលបិទទុក ឃើញផ្ទៃខាងក្រោមប្រាកដ ភិក្ខុដែលពិចារណាក្នុងអាសនៈនោះមិនមាន ៗ ក៏ឯអាសនៈណា គេក្រាលដោយសំពត់បាវារៈ នឹងសំពត់កោជវៈជាដើមទុកមុនហើយ អាសនៈនោះត្រូវពិចារណា គឺយកដៃស្ទាបកំណត់មើលហើយ សឹមអង្គុយ ៗ ក្នុងអដ្ឋកថាមហាបច្ចរីពោលទុកថា ក្នុងអាសនៈដែលគេក្រាលដោយសំពត់ក្រាលមានជ្រួញ ៗ មិនបានប្រាកដ អាសនៈនោះត្រូវពិចារណា ៗ

មួយទៀត ភិក្ខុកុំគប្បីដេកលើទីដំណេកទាំងឡាយ ដំរោយកាយដោយផ្កាឈើ បើភិក្ខុណាដេកត្រូវទុក្កដ ៗ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ បុប្ផាភិកិណ្ណេសុ សយនេសុ សយិតព្វំ... ដូច្នេះ ៗ ព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា បានរបស់ក្រអូបហើយឲ្យចំមកក្នុងសន្ទឹកទ្វារ បានផ្កាឈើឲ្យដាក់កល់ទុកក្នុងកុដិ វិហារ ៗ

មួយទៀត ភិក្ខុកុំគប្បីឃាត់អាសនៈភិក្ខុចាស់ ៗ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតនឹងហាមឃាត់ទុកថា អនុជានាមិ ភិក្ខវេ យថាវុឌ្ឍំ អភិវាទនំ ។ល។ នមេ ភោ ភិក្ខវេ តយោ វុឌ្ឍយា កថាគត. អនុញ្ញាតកិរិយាសំពះ នឹងកិរិយាក្រោកទទួល នឹងអញ្ជលិកម្ម

www.budinst.gov.kh www.elibraryofcambodia.org

និងសាមីចិកម្ម និងអាសនៈដ៏ប្រសើរ និងទឹកដ៏ប្រសើរ គឺទឹក ទក្ខិណោទក និងដុំបាយដ៏ប្រសើរ គឺដុំបាយដែលគួរដល់ព្រះមហាថេរ ទាំងឡាយនេះ តាមលំដាប់នៃភិក្ខុចាស់វស្សា ភិក្ខុកុំគប្បីឃាត់អាសនៈ របស់សង្ឃ តាមលំដាប់ភិក្ខុចាស់វស្សា បើភិក្ខុណាឃាត់ត្រូវអាបត្តិទុក្កដ ។ តទៅព្រះពុទ្ធអង្គទ្រង់សំដែង អំពីបុគ្គលមិនគួរសំពះ និងបុគ្គលគួរសំពះ ទុកថា ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលភិក្ខុមិនគួរសំពះមាន ១០ ពួកគឺ បុរេ ឧបសម្បន្នេន បច្ឆា ឧបសម្បន្នោ អវន្ទិយោ អ្នកឧបសម្បទាក្រោយ គឺអ្នកឧបសម្បទាមុនមិនគួរសំពះ ១ អនុបសម្បន្នោ សាមណេរនិងគ្រហស្ថ ១ នានាសំវាសកោ វុឌ្ឍតរោ អធម្មវាទី អ្នកមានសំវាសផ្សេងគ្នាដោយលទ្ធិ សូម្បីចាស់ជាង តែជាអ្នកពោលនូវពាក្យមិនមែនជាធម៌ ១ មាតុគាមោ ស្រី ១ បណ្ឌកោ ខ្ទើយ ១ បារិវាសិកោ ភិក្ខុត្រូវគរុកាបត្តិ កំពុងនៅបរិវាស ១ មូលាយបដិកស្សនារហោ ភិក្ខុត្រូវគរុកាបត្តិ ហើយកំពុងតែប្រព្រឹត្តវត្ត ត្រឡប់ត្រូវគរុកាបត្តិទៀតក្នុងចន្លោះនោះ គួរនឹងទទួលបដិកស្សនៈទាញត្រឡប់មកកាន់អាបត្តិដើមទៀត ១ មានត្តារហោ ភិក្ខុនៅបរិវាសហើយគួរនឹងទទួលមានត្ត ១ មានត្តចារិកោ ភិក្ខុដែលកំពុងប្រព្រឹត្តមានត្ត ១ អព្ភានារហោ ភិក្ខុដែលប្រព្រឹត្តមានត្តគ្រប់ ៦ រាត្រី ហើយគួរដល់អព្ភានកម្ម ១ ។ ទាំង ១០ ពួកនេះឈ្មោះថាអវន្ទិយៈជាបុគ្គលដែលភិក្ខុមិនគួរសំពះ ។ បុគ្គលដែលភិក្ខុគួរសំពះមាន ៣ ពួកគឺ

www.budinst.gov.kh www.elibraryofcambodia.org

ឧច្ចា ឧបសម្បន្នេន បុរេ ឧបសម្បន្នោ វន្ទិយោ ភិក្ខុឧបសម្ប-ទាមុន គឺភិក្ខុឧបសម្បទាក្រោយ គប្បីសំពះ ១ នានាសំវាសកោ វុឌ្ឍតរោ ធម្មវាទី បុគ្គលមានសំវាសផ្សេងគ្នាដោយលទ្ធិ តែជាអ្នកពោលធម៌ គឺពោលពាក្យដែលជាធម៌ថាជាធម៌ ១ សទេវកេ លោកេ ភិក្ខវេ ។ ល ។ តថាគតោ អរហំ សម្មាសម្ពុទ្ធោ វន្ទិយោ ព្រះតថាគត ជាអរហន្ត សម្មាសម្ពុទ្ធ ជាបុគ្គលគួរសំពះក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វព្រមទាំងសមណ-ព្រាហ្មណ៍ នឹងមនុស្សជាសម្មតិទេព នឹងមនុស្សដ៏សេស ១ ទាំង ៣ ពួកនេះឈ្មោះថាវន្ទិយបុគ្គល ។ ភិក្ខុ ៤ ចំពួកមានបរិវាសិកជាដើម មិនគួរសំពះ នៃភិក្ខុជាបកតត្ត ។ សំពះបុគ្គលមិនគួរសំពះទាំង ១០ នេះ ត្រូវអាបត្តិទុក្កដ ។ ក្នុងគម្ពីរបរិវារៈពោលថា បុគ្គលដែលភិក្ខុមិនគួរសំពះ មាន ៣ ពួកទៀត ពួកមួយៗមាន ៤ៗ ជា ១៤ ដូច្នេះគឺ អន្តរឃរំ បវិដ្ឋោ ភិក្ខុកំពុងចូលទៅកាន់ចន្លោះផ្ទះ ១ រច្ឆាគតោ ភិក្ខុកំពុងដើរតាមច្រកផ្លូវ ១ ឱតមសិកោ ភិក្ខុនៅក្នុងទីងងឹត ១ (សំពះភិក្ខុនោះច្បាស់នឹងទង្គិចដោយគ្រែជាដើម ព្រោះហេតុនោះ ភិក្ខុនៅក្នុងទីងងឹតមិនគួរសំពះ) អសមន្នាហរន្តោ ភិក្ខុដែលកំពុងខ្វល់ខ្វាយដោយការងារមិនបានអើពើនឹងការសំពះ ១ សុត្តោ ភិក្ខុកំពុងដេកលក់ ១ ជា ៤ ។ យាគុបានេ ភិក្ខុកំពុងផឹកបបរ ១ ភត្តគ្គេ ភិក្ខុនៅក្នុងរោងទាន ១ ឯកាវត្តោ ភិក្ខុងាកទៅក្នុងទិសម្ខាង គឺមនុស្សជាសត្រូវនឹងគ្នា

www.budinst.gov.kh www.elibraryofcambodia.org

មនុស្សមានរោគ ១ (អ្នកនេះបើសំពះ ទើបអាចប្រហារអ្នកសំពះដោយជើងបាន ព្រោះហេតុនោះ ទើបមិនគួរសំពះ) អញ្ញវាទកោ ភិក្ខុបញ្ចុះបិត្តទៅតាមទំនង ១ នគ្គោ ភិក្ខុអាក្រាតកាយមិនមានសំពត់ស្លៀកដណ្ដប់ ១ ជា៥ ៗ ខាទន្តោ ភិក្ខុកំពុងឆាន់ខាទនីយៈមាននំជាដើម ១ ភុញ្ជន្តោ ភិក្ខុកំពុងឆាន់ភោជនទាំងប្រាំណាមួយ ១ ឧច្ចារំ ករោន្តោ ភិក្ខុកំពុងបន្ទោបង់ឧច្ចារៈ ១ បស្សាវំ ករោន្តោ ភិក្ខុកំពុងបន្ទោបង់បស្សាវៈ ១ (ពីរនេះ មិនគួរសំពះ ព្រោះជានៅក្នុងទីមិនមែនជាឱកាស) ឧក្ខិត្តកោ ភិក្ខុដែលសង្ឃលើកវត្តដោយឧក្ខេបនីយកម្មទាំងបី ១ និងភិក្ខុដែលសង្ឃលើកវត្តដោយកម្មដទៃមានតជ្ជនីយកម្មជាដើម ៤ ពួកនេះ គួរនឹងសំពះ ដ្បិតបាននឹងធ្វើឧបោសថ បវារណា ជាមួយនឹងភិក្ខុទាំងឡាយនេះក៏បាន ជា៥ ៗ ក្នុងអវន្ទិយបុគ្គល ១៥ ទាំងអំពីដើមមកនេះ បើសំពះបុគ្គលពីរពួក គឺភិក្ខុអាក្រាតកាយនឹងភិក្ខុដែលសង្ឃលើកវត្តទើបត្រូវអាបត្តិ ៗ និងការឃាត់មិនឲ្យសំពះភិក្ខុ ១៣ ពួកក្រៅនោះ ដ្បិតជាអសារុប្បៈ មិនសមគួរ មិនល្អ ទើបឃាត់ព្រោះហេតុដូចសំដែងហើយក្នុងចន្លោះវង់ក្រចក ៗ

មួយទៀត. សម្ប៉ែសេនាសនៈដែលទាយកគេតាក់តែងទុកសម្រាប់ព្រះសង្ឃ ក៏មិនគួរឃាត់ទាំង ៗ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ ឧទ្ទិស្សកតម្បិ យថាវុឌ្ឍំ បដិពាហិតព្វំ...ម្នាលភិក្ខុទាំងឡាយ សម្ប៉ែសេនាសនៈដែលគេធ្វើឧទ្ទិស្សដល់សង្ឃ ភិក្ខុមិនត្រូវឃាត់ទាំងនេះតាមលំដាប់វស្សាចាស់ខ្ចី ភិក្ខុណា ឃាត់ទាំង ត្រូវទុក្កដ

www.budinst.gov.kh www.elibraryofcambodia.org

មួយទៀត ភិក្ខុកុំគប្បីយកគ្រឿងសេនាសនៈដែលខ្លួនគប្បីប្រើប្រាស់ក្នុងទីឯទៀត ទៅបរិភោគក្នុងទីឯទៀតឡើយ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ អញ្ញត្រ បរិភោគោ អញ្ញត្រ បរិភុញ្ជិតព្វោ... ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវយកគ្រឿងប្រើប្រាស់ក្នុងទីឯទៀត ទៅប្រើប្រាស់ក្នុងទីឯទៀតទេ ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។ ឯខ្លួនសូម្បីទៅប្រើប្រាស់ ឬយកទៅថែរក្សាទុកក្នុងទីដទៃដើម្បីខ្លួនមិនឲ្យវិនាសអន្តរាយក៏គួរ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ តាវកាលិកំ ហរិតុំ អនុជានាមិ ភិក្ខវេ គុត្តត្ថាយ ហរិតុំ ដូច្នេះ ។ ព្រោះហេតុនោះ កាលយកទៅប្រើប្រាស់ជាសង្ឃិកបរិភោគក្នុងទីដទៃ សូម្បីបាត់ទៅ ឬគ្រាំគ្រាទៅៈ ឈ្មោះថាបាត់ ខ្លួនគ្រាំគ្រាទៅដោយប្រពៃ បើមិនគ្រាំគ្រាខូចទេ កាលបើវិហារកុដិនោះ គេជួសជុលឡើងជាថ្មី ក៏គប្បីធ្វើរបស់នោះឲ្យជាប្រក្រតីឡើងវិញ ។ កាលបើយកៈប្រើប្រាស់ជារបស់បុគ្គល របស់នោះបាត់ទៅ ឬគ្រាំគ្រាទៅរមែងជាសំណង កាលវិហារកុដិនោះ គេត្រឡប់ជួសជុលឡើងជាថ្មីហើយ គប្បីសងវិញ បើយកគ្រឿងអាវាស មានបន្ទំជាដើម មកអំពីសេនាសនៈចាស់មកប្រគបផ្គុំចូលក្នុងអាវាសជារបស់សង្ឃដទៃហើយសោត ឈ្មោះថាប្រគបចូលដោយប្រពៃ បើយកមកប្រគបចូលក្នុងអាវាសជារបស់បុគ្គល គប្បីឲ្យដំឡៃ ឬគប្បីធ្វើឲ្យជាប្រក្រតី កាលកាន់យកគ្រែនិងតាំងជាដើម មកអំពីវិហារ

www.budinst.gov.kh www.elibraryofcambodia.org

ដែលគេហាល ដោយបេយ្យចិត្ត ឲ្យវិនយធរគប្បីកាត់អាបត្តិតាមតម្លៃរបស់ក្នុងខណៈលើករបស់នោះ កាលបើកាន់យកដោយគិតថា នឹងឲ្យក្នុងសម័យដែលភិក្ខុមកនៅក្នុងអាវាសនោះទៀត ហើយយកមកបរិភោគរេប្រើប្រាស់ជារបស់សង្ឃ របស់នោះវិនាសបាត់ទៅ ឬគ្រាំគ្រាទៅ ក៏ឈ្មោះជាវិនាសនឹងគ្រាំគ្រាទៅដោយប្រពៃ បើមិនវិនាសទេ ក៏គប្បីធ្វើឲ្យជាប្រក្រតីចុះ កាលយកមកបរិភោគជារបស់បុគ្គល បើបាត់ទៅត្រូវសង បើយកសន្ទឹកក្តារឬសសន្ទឹកបង្អួចជាដើម អំពីវិហារដែលគេហាល មកប្រកបប្រើក្នុងអាវាសជារបស់សង្ឃ ឬជារបស់បុគ្គល ត្រូវបង្វែរឲ្យទៅវិញ នឹងយកបរិក្ខាររបស់សង្ឃមានសំពត់កម្ពលជាដើម ទៅផ្លាស់ប្តូរសេនាសនៈមានគ្រែនឹងតាំងជាដើមមកក៏គួរ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ ផាតិកម្មត្ថាយ បរិវត្តេតុំ គឺថាតថាគតអនុញ្ញាតឲ្យផ្លាស់ប្តូរ ដើម្បីប្រយោជន៍ជាផាតិកម្ម គឺឲ្យចំរើនបរិក្ខាររបស់សង្ឃឡើងបាន ។ ក៏ឯផាតិកម្មផ្លាស់ប្តូរឲ្យចំរើនរបស់សង្ឃនេះ បើតម្លៃស្មើគ្នាឬលើសជាង ជាសេនាសនៈមានគ្រែនឹងតាំងជាដើម មួយយ៉ាងទើបគួរ ។

មួយទៀត ភិក្ខុមិនត្រូវបណ្តេញភិក្ខុដែលកំពុងនៅឆាន់មិនទាន់ហើយ ឲ្យក្រោកចេញទេ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ វិប្បកតភោជនោ ភិក្ខុ វុដ្ឋាបេតព្វោ ។ល។ វទាមិ ភិក្ខុមិនត្រូវបណ្តេញភិក្ខុកំពុងឆាន់ ក្នុងលានវត្តកុដិ ឬក្នុងវិហារ ឬក្នុងព្រៃ ទីណាមួយដែលមិនទាន់លែងឆ្អែ

ក្រោកចេញទេ បើភិក្ខុណាបណ្តេញ ឲ្យក្រោកចេញត្រូវទុក្កដ ។ គិលានភិក្ខុក្តី ភិក្ខុអ្នកមកក្នុងខាងក្រោយ កាន់យកភិក្ខាហើយគប្បីទៅកាន់ទីសមគួរ បើមនុស្ស ឬភិក្ខុទាំងឡាយ ស្រែកនិមន្តឲ្យចូលទៅក្នុងរោងឆាន់ គប្បីប្រាប់ថា កាលបើយើងចូលទៅភិក្ខុទាំងឡាយនឹងក្រោកឡើង លុះគេពោលថានិមន្តចូលមកចុះ អាសនៈមាននៅជូខ្ទះ គប្បីចូលទៅចុះ ។ ថាបើគ្មានអ្នកណាពោលពាក្យតិចតួចសោះទេ គប្បីទៅក្នុងរោងឆាន់ហើយឈរនៅក្នុងទីសមគួរ កុំឲ្យជិតពេក កាលគេធ្វើឱកាសហើយស្រែកនិមន្តឲ្យចូលទៅ គប្បីចូលទៅចុះ ។ បើភិក្ខុមិនបានឆាន់ អង្គុយនៅលើអាសនៈដែលនឹងដល់ភិក្ខុនោះសោត នឹងឲ្យភិក្ខុអង្គុយនោះក្រោកចេញក៏គួរ ។ ក៏ឯភិក្ខុឆាន់វត្តណាមួយមានបវរនឹងបន្ថែមជាដើម ហើយអង្គុយរង់ចាំទាក់ភិក្ខុថ្មីទើបនិមន្តមក សូម្បីមានដៃទទេនឹងឲ្យភិក្ខុនោះក្រោកទៅមិនគួរ ដ្បិតថាភិក្ខុនោះ ក៏ឈ្មោះថាឆាន់មិនទាន់ហើយ បើក្នុងកន្លងអាបត្តិ ធ្វើឲ្យភិក្ខុអ្នកឆាន់មិនទាន់រួចក្រោកចេញ ថាបើភិក្ខុដែលក្រោកឡើងនោះឃាត់បាយសោត ភិក្ខុនោះគប្បីបង្គាប់ភិក្ខុអ្នកបណ្តេញនោះឲ្យទៅយកទឹកមកឲ្យ ។ ការដែលភិក្ខុកម្លោះបង្គាប់ភិក្ខុចាស់បាន មានតែមួយនេះឯង ។ បើបានទឹកមកក៏ជាការល្អ បើភិក្ខុនោះមិនយកមកឲ្យទេ ភិក្ខុអ្នកឃាត់បាយនោះ គប្បីលេបគ្រាប់បាយឲ្យអស់ដោយប្រពៃ ហើយគប្បីឲ្យអាសនៈដល់ភិក្ខុចាស់ចុះ ព្រោះព្រះអង្គមិនបានអនុញ្ញាតឲ្យភិក្ខុកម្លោះឃាត់អាសនៈភិក្ខុចាស់ ដោយបរិយាយណាមួយឡើយ បើភិក្ខុកម្លោះណាឃាត់ ត្រូវអាបត្តិទុក្កដ ។

www.budinst.gov.kh www.elibraryofcambodia.org

មួយទៀត ទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ ភណ្ឌាគារិកោ វុដ្ឋាបេតព្វោ...ភិក្ខុកុំគប្បីបណ្តេញភិក្ខុអ្នករក្សាឃ្លាំងឲ្យក្រោកចេញទៅ បើភិក្ខុណាបណ្តេញ ត្រូវអាបត្តិទុក្កដ ។

មួយទៀត ភិក្ខុកុំគប្បីបណ្តេញភិក្ខុមានជម្ងឺឲ្យក្រោកចេញ បើភិក្ខុណាបណ្តេញ ត្រូវអាបត្តិទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ គិលានោ វុដ្ឋាបេតព្វោ ដូច្នេះ ។ ភិក្ខុ ៤ ពួក មិនគួរនឹងបណ្តេញឲ្យក្រោកគឺ ភិក្ខុចាស់វស្សាជាង ភិក្ខុក្មេងមិនគួរបណ្តេញឲ្យក្រោក ព្រោះជាភិក្ខុចាស់វស្សាជាង ១ ភិក្ខុអ្នករក្សាឃ្លាំង មិនគួរបណ្តេញឲ្យក្រោកចេញទៅ ដ្បិតជាឃ្លាំងនោះ សង្ឃសម្មតឲ្យលោកហើយ ១ ភិក្ខុជាពហុស្សុត មានឧបការៈច្រើនដោយឧទ្ទេស នឹងបរិបុច្ឆាជាដើម ហើយជាអ្នកទទួលធុរៈសង្ឃ សង្ឃឲ្យទីលំនៅជាទីសប្បាយ មិនគួរនឹងបណ្តេញឲ្យក្រោកចេញទៅ ដ្បិតលោកមានឧបការៈ នឹងបានទីលំនៅអំពីសង្ឃហើយ ១ ភិក្ខុមានជម្ងឺ មិនគួរនឹងបណ្តេញឲ្យក្រោកចេញ ដ្បិតភិក្ខុនោះមានជម្ងឺ គប្បីកំណត់ទីដំណេក ដែលគួរឲ្យដល់ភិក្ខុឈឺនោះ ១ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ គិលានស្ស បដិរូបំ សេយ្យំ ទាតុំ ដូច្នេះ ។ ភិក្ខុណាមានគេតហ៊ឹក ឬបុសដូងបាត ឬម្ជុលជាដើម នឹងត្រូវដំកល់កន្ទោរ នឹងអំបែងក្បឿងឥដ្ឋលាមកជាដើម ទុកសម្រាប់ ថ្ងៃកើតកេតយូរ នឹងប្រមូលក៏យសេនាសនៈ គប្បីឲ្យសេនាសនៈមួយចំណែក

www.budinst.gov.kh www.elibraryofcambodia.org

បើមិនឧបដ្ឋាកទេ ត្រូវទុកដូចទាំងអស់គ្នា ។ កាលបើភិក្ខុទាំងអស់គ្នា ដាក់វេនគ្នាបដិបត្តិ ភិក្ខុណាមិនបដិបត្តិក្នុងវេនខ្លួន ត្រូវអាបត្តិដល់ភិក្ខុនោះ ។ សូម្បីសង្ឃគេក៏មិនរួចវេនបាន ។ ថាបើសង្ឃទាំងអស់ ប្រគល់ភារៈ ដល់ភិក្ខុមួយអង្គ ឬភិក្ខុមួយអង្គប្រកបដោយវត្តបដិបត្តិទទួល ថា ខ្ញុំនឹងបដិបត្តិតែម្នាក់ឯងសោត ព្រោះសង្ឃក៏រួចអាបត្តិបាន ។ ភិក្ខុឈឺ ដែលអ្នកបំរើលំបាក ប្រកបដោយអង្គ ៥ គឺ មិនធ្វើសេចក្ដីសប្បាយ ១ មិនដឹងប្រមាណក្នុងការសប្បាយ ១ មិនខ្ជះខ្ជែងប្រើភេសជ្ជៈ ១ មិនធ្វើឲ្យច្បាស់នូវជម្ងឺតាមពិត គឺកើតឡើង ក៏មិនប្រាប់ថាឡើង ឬថយចុះ ក៏មិនប្រាប់ថាថយចុះ ឬនៅនឹងក៏មិនប្រាប់ថានៅនឹង ដល់អ្នកឧបដ្ឋាក ដែលប្រាថ្នានូវប្រយោជន៍ ១ ជាមនុស្សមិនអត់ធន់នូវទុក្ខវេទនា ដ៏រឹងក្លា ផ្សា ក្ដៅ ដែលកើតឡើងក្នុងសរីរកាយ មិនឆ្ងាញ់ពិសា មិនគាប់ចិត្តជាទី នាំឲ្យខូចជីវិត ១ ។ ភិក្ខុឈឺដែលប្រកបដោយអង្គ ៥ ងាយគេបំរើ គឺ បុគ្គលចេះធ្វើខ្លួនឲ្យសប្បាយ ១ ដឹងប្រមាណក្នុងការសប្បាយ ១ ខ្ជះខ្ជែងប្រើភេសជ្ជៈ ១ ធ្វើឲ្យច្បាស់នូវជម្ងឺតាមពិត ... ១ ជាមនុស្សអត់ធន់នូវទុក្ខវេទនា ... ១ ។ ភិក្ខុអ្នកឧបដ្ឋាកភិក្ខុឈឺ ប្រកបដោយអង្គ ៥ មិនគួរនឹងឧបដ្ឋាកអ្នកជម្ងឺទេ គឺជាអ្នកមិនប្រសប់ចាត់ចែងថ្នាំ ១ មិនស្គាល់ហេតុសប្បាយ និងមិនសប្បាយ ១ នាំវត្ថុដែលមិនសប្បាយចូលទៅ នាំវត្ថុដែលសប្បាយចេញមក ១ ឧបដ្ឋាកមនុស្សឈឺ ដោយឃើញតែអាមិស មិនមានចិត្តប្រកបដោយមេត្តា មានតែខ្ពើមរអើម ក្នុងការនាំទៅនូវឧច្ចារៈ

www.budinst.gov.kh www.elibraryofcambodia.org

បស្សាវៈ ឬទឹកមាត់ ទឹកសំអួត ១ មិនអាចនឹងពន្យល់អ្នកជម្ងឺ ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មិកថា សព្វកាល ១ ភិក្ខុប្រកបដោយអង្គ ៥ រួចចាកអង្គដែលជាទោស ៥ ដូចពោលហើយ ទើបសមគួរ នឹងឧបដ្ឋាកភិក្ខុឈឺបាន ។

មួយទៀត ភិក្ខុសាមណេរធ្វើមរណកាលហើយ បរិក្ខារក៏ទៅជារបស់សង្ឃ ។ ដ្បិតព្រះទ្រង់អនុញ្ញាតទុកថា ភិក្ខុស្ស ភិក្ខវេ កាលកតេ សង្ឃោ សាមី បត្តចីវរេ ។ល។ អបេក្តិកាំ ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុធ្វើមរណកាលហើយ (សាមណេរធ្វើមរណកាលហើយ) ត្រូវសង្ឃជាម្ចាស់របស់ ក្នុងបាត្រនឹងចីវរ ប៉ុន្តែថា អ្នកឧបដ្ឋាកបុគ្គលឈឺ មានឧបការៈច្រើនជាងគេ ។ តថាគតអនុញ្ញាតឲ្យសង្ឃឲ្យបាត្រ នឹងត្រៃចីវរនៃភិក្ខុដែលធ្វើមរណកាលហើយ (នឹងបាត្រនឹងចីវរនៃសាមណេរដែលធ្វើមរណកាលហើយ) ដល់អ្នកឧបដ្ឋាកជម្ងឺចុះ ក្នុងរបស់អម្បាលនេះ បើរបស់ណាមួយជាលហុភណ្ឌ ជាលហុបរិក្ខារ របស់អម្បាលនោះ តថាគតអនុញ្ញាតឲ្យសង្ឃដែលមានក្នុងទីចំពោះមុខ ព្រមព្រៀងគ្នាចែកគ្នាប្រើប្រាស់ក្នុងរបស់អម្បាលនោះ របស់ណាជាគរុភណ្ឌ ជាគរុបរិក្ខារ របស់ទាំងនោះត្រូវជារបស់ចាតុទ្ទិសសង្ឃ ដែលមកហើយ នឹងមិនទាន់បានមក ជារបស់លះមិនបាន ចែកគ្នាមិនបាន ។

ក៏ឯវិធីឲ្យបាត្រ ចីវរដល់ភិក្ខុអ្នកឧបដ្ឋាកជម្ងឺនោះដូច្នេះ គឺអ្នកឧបដ្ឋាកនោះ គប្បីចូលទៅរកសង្ឃ ហើយពោលថា ឥត្ថន្នាមោ ភន្តេ ភិក្ខុ

www.budinst.gov.kh www.elibraryofcambodia.org

កាលកតោ ឥធំ តស្ស តិចីវរញ្ច បត្តោ ច... ។ បើជារបស់សាមណេរថា ឥត្ថន្នាមោ ភន្តេ សាមណេរោ កាលកតោ ឥធំ តស្ស ចីវរញ្ច បត្តោ ច... ។ បាលីទាំងពីរនេះ ប្រែថា បពិត្រព្រះសង្ឃដ៏ចំរើន ភិក្ខុឈ្មោះនេះធ្វើមរណកាលហើយ ត្រៃចីវរនិងបាត្រនេះរបស់ភិក្ខុនោះ (សាមណេរឈ្មោះនេះធ្វើមរណកាលហើយ ចីវរនិងបាត្រនេះ របស់សាមណេរនោះ) គប្បីធ្វើដូច្នេះជាមុនហើយ សង្ឃគប្បីសូត្រប្រកាសដោយញត្តិទុតិយកម្មថា ប្រគល់របស់នោះឲ្យថា សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមោ ភិក្ខុ កាល·កតោ ឥធំ តស្ស តិចីវរញ្ច បត្តោ ច ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥមំ ចីវរញ្ច បត្តញ្ច គិលានុបដ្ឋាកានំ ទទេយ្យ... ។ បើរបស់សាមណេរឲ្យថាតែ ចីវរំ ។

មួយទៀត និងឲ្យដោយអបលោកនកម្មក៏គួរ សូម្បីសាមណេរ អ្នកបដ្ឋាកភិក្ខុឈឺ ក៏បានចំណែកស្មើនឹងភិក្ខុ ។ ដ្បិតទ្រង់អនុញ្ញាតទុកដូច្នេះថា អនុជានាមិ ភិក្ខវេ គិលានុបដ្ឋាកស្ស សាមណេរស្ស សមកំ បដិវីសំ ទាតុំ ដូច្នេះ ។ ពាក្យទាំងអម្បាលនេះពោលដោយសង្ខេបតាមបាលី បើចង់ដឹងដោយពិស្តារ គប្បីមើលក្នុងគម្ពីរសមន្តបាសាទិកាចុះ ។

មួយទៀត ភិក្ខុឈឺតិចតួច មានឈឺក្បាលជាដើម និងឃាត់សេនា·សនៈមិនគួរ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ

អាគច្ឆតិ ន អកាមា ទាតព្វោ ដូច្នេះ ។ លុះចំណែកថែម ភិក្ខុសង្ឃគប្បានបន្ទាប់ឲ្យគាត់យកហើយ បើភិក្ខុដទៃមកដល់មិនត្រូវការ មិនត្រូវឲ្យទេ ។ បើភិក្ខុអង្គណាកាន់យកហើយ ភិក្ខុអង្គនោះ ទឹនឲ្យចំណែកថែមឬចំណែកដំបូង តាមគាប់ចិត្តនៃខ្លួនក៏គួរ ។

មួយទៀត ភិក្ខុកុំគប្បីឲ្យភិក្ខុអ្នកឋិតនៅក្រៅឧបចារៈសីមា កាន់យកសេនាសនៈផង បើឲ្យកាន់យកត្រូវទុក្កដ ។ ដ្បិតទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ និស្សីមេ ឋិតស្ស សេនាសនំ គាហេតព្វំ ដូច្នេះ ។ ឲ្យបានតែភិក្ខុដែលឋិតនៅខាងក្នុងឧបចារៈសីមាមួយចំពួក កាន់យក សូម្បីឆ្ងាយក៏បាន ។

មួយទៀត ភិក្ខុបានចំណែកសេនាសនៈ ដែលចែកហើយនោះ កុំគប្បីឃាត់ទាំងទុកអស់កាលទាំងពួង បើឃាត់ទាំងទុកដូច្នេះ ត្រូវទុក្កដ ។ ឃាត់ទាំងបានតែត្រឹម ៣ ខែ ក្នុងវស្សានរដូវ (ប៉ុណ្ណោះ) មិនត្រូវឃាត់ទាំងគ្រប់រដូវទេ ។ ដ្បិតព្រះភគ្គអង្គទ្រង់ហាមឃាត់មិនអនុញ្ញាតទុកថា ន ភិក្ខវេ សេនាសនំ គហេត្វា សព្វកាលំ បដិពាហិតព្វំ ។ បេ ។ អនុជានាមិ ភិក្ខវេ វស្សំ តេមាសំ បដិពាហេតុំ ឧតុកាលំ ន បដិពាហេតុំ ដូច្នេះ ។ ការប្រគល់សេនាសនៈនេះមាន ៣ ប្រការគឺ បុរិមកោ ត្រូវភិក្ខុប្រគល់ឲ្យតាំងអំពីថ្ងៃ ១ កើតខែអាសាឍទៅ ១ បច្ឆិមកោ ត្រូវភិក្ខុប្រគល់ឲ្យតាំងអំពីថ្ងៃ ១ រោចខែស្រាពណ៍ទៅ ១ អន្តរាមុត្តកោ ត្រូវភិក្ខុប្រគល់

www.budinst.gov.kh www.elibraryofcambodia.org

ឲ្យតាំងអំពីថ្ងៃបវារណាក្នុងខែអស្សុជទៅ ដើម្បីនៅចាំវស្សាតទៅ ១ ដោយព្រះបាលីថា តយោ ប ភិក្ខវេ សេនាសនគ្គាហា បុរិមកោ ។ល។ ឥមេ ខោ ភិក្ខវេ តយោ សេនាសនគ្គាហា ដូច្នេះ ។ សេនាសនៈណាមានលាភច្រើន គឺទាយកម្ចាស់របស់គេប្រគេនសំពត់ចំណាំវស្សា នឹងសមណបរិក្ខារច្រើនដល់ភិក្ខុដែលនៅក្នុងសេនាសនៈ មហាថេរមកអំពីចម្ងាយចាំវស្សា ចេញវស្សាបានលាភហើយក៏ទៅ សេនាសនៈនោះក៏ទ្រុឌទ្រោម ម្ចាស់អាវាសមិនមើលថែទាំ ព្រះពុទ្ធអង្គទ្រង់អនុញ្ញាតឲ្យកាន់យកសេនាសនៈនោះ ជាអន្តរមុត្តកៈ ដើម្បីនឹងនៅតទៅទៀតក្នុងវស្សាខាងមុខ ដើម្បីនឹងបានបដិបត្តិសេនាសនៈនោះ ដល់វស្សាខាងមុខ។ ហើយព្រះថេរៈមកអំពីទីដទៃ នឹងមកកាន់យកមិនបាន តែភិក្ខុដែលបានសេនាសនៈក្នុងឧតុកាល នឹងអាស្រ័យនៅក្នុងវេលាថ្ងៃ វេលាយប់បាន បើភិក្ខុដែលចាស់មក កុំឃាត់កុំហួងហែង ។ មួយទៀត កាលកាន់សេនាសនៈមានពីរ ក្នុងឧតុកាលប្រាំបីខែ ១ ក្នុងវស្សកាលបីខែ ១ ។ ក្នុងឧតុកាល អាគន្តុកៈមកដល់កាលណា គប្បីឲ្យភិក្ខុដែលនៅមុនចៀសចេញ ឲ្យសេនាសនៈដល់អាគន្តុកៈ ។ ក្នុងវស្សកាល ភិក្ខុជាអាគន្តុកៈនឹងចេញចាកទីលំនៅខ្លួន ទៅនៅទីដទៃកុំទៅក្នុងថ្ងៃចូលវស្សា នឹងមានការចង្អៀតចង្អល់លំបាក នៅប្រមាណ ១ ខែទៀតនឹងចូលវស្សាគួរទៅ នឹងមិនលំបាកដោយទីលំនៅជាដើម ។ ចំណែកភិក្ខុម្ចាស់អាវាសសោត គប្បីជម្រះវិហារ ជួសជុលទីបាក់បែក

www.budinst.gov.kh www.elibraryofcambodia.org

មុនថ្ងៃចូលវស្សា ភិក្ខុជាអាគន្តុកៈមកអាស្រ័យនៅ មិនបានសួររៀប សិក្សាសប្បាយ ហើយភិក្ខុទៅអាវាស គប្បីប្រជុំគ្នាសន្មតសេនាសនគ្គាហាបកៈអ្នកប្រគល់សេនាសនៈឡើង ប្រមាណពីរអង្គ ឬ បីអង្គ ភិក្ខុកម្លោះមិនបានប្រគល់ឲ្យភិក្ខុចាស់ ភិក្ខុចាស់មិនបានប្រគល់ឲ្យភិក្ខុកម្លោះ ។ ឯភិក្ខុបានសម្មតិនោះ គប្បីកំណត់ស្គាល់វិសេនាសនៈ មិនទីមិនមែនសេនាសនៈ ដល់ថ្ងៃចូលវស្សាគប្បីកំណត់លាភដែលកើតក្នុងសេនាសនៈនោះ ហើយប្រគល់ឲ្យតាំងអំពីថេរៈចុះទៅដោយកំណត់សេនាសនៈតិចមិនច្រើន ដូចពោលហើយអំពីមុន បើមានទាយកគេប្រគេនសំពត់ចំណាំវស្សាដល់ភិក្ខុ ដែលនៅក្នុងសេនាសនៈនោះ គប្បីប្រគល់ឲ្យដោយវិធីដូចនេះ ។

បើលោកចាស់ប្រគល់ឲ្យលោកខ្ចី គប្បីសូត្រថា

អាវុសោ តុយ្ហំ អសុកំ(១) សេនាសនំ បាបុណាតិ បច្ចយំ គណ្ហ ម្នាលលោកដ៏មានអាយុ សេនាសនៈឯណោះ (ត្រូវបាន) ដល់លោក លោកចូរកាន់យកបច្ច័យ ។

បើលោកខ្ចីប្រគល់ឲ្យលោកចាស់ គប្បីសូត្រថា

ភន្តេ តុម្ហាកំ អសុកំ(២) សេនាសនំ បាបុណាតិ បច្ចយំ គណ្ហថ បពិត្រព្រះករុណាដ៏ចំរើន សេនាសនៈឯណោះ (ត្រូវបាន) ដល់ព្រះករុណា ព្រះករុណាចូរកាន់យកបច្ច័យ ។

---

១-២- បើសេនាសនៈនៅជិតថា ឥទំ (សេនាសនំ បាបុណាតិ) ជួស អសុកំ ។

www.budinst.gov.kh www.elibraryofcambodia.org

បើពុំមានលាភផងទេ ត្រូវថា តុម្ហាកំ អមុកសេនាសនំ បាបុណាតិ ដូច្នេះ ៗ ថេរៈគប្បីទទួលថា គណ្ហាមិ អាវុសោ ៗ ភិក្ខុកម្លោះគប្បីទទួលថា គណ្ហាមិ ភន្តេ ថាខ្ញុំកាន់យកដូច្នេះ ៗ ភិក្ខុទទួលយកសេនាសនៈហើយ គប្បីរក់និងបដិបត្តិសេនាសនៈនោះចាំកំនីន ចេញអំពីទីនោះ ពាក្យនេះពោលដោយសង្ខេប បើចង់ដឹងដោយពិស្តារ គប្បីមើលក្នុងចក្កសមន្តបាសាទិកាចុះ ៗ

មួយទៀត ភិក្ខុមួយអង្គ កុំគប្បីហួងហែងសេនាសនៈពីរកន្លែង បើហួងហែង ត្រូវទុក្កដ ៗ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ ឯកេន ទ្វេ បដិពាហិតព្វា... ដូច្នេះ ៗ ភិក្ខុអង្គខ្លះ ក្នុងថ្ងៃចូលវស្សាកាន់យកសេនាសនៈក្នុងវិហារមួយកន្លែងហើយ ទៅកាន់យកសេនាសនៈក្នុងវិហារដទៃទៀត ការកាន់យកសេនាសនៈមុននៃភិក្ខុនោះ រមែងរម្ងាប់ដោយការកាន់យកសេនាសនៈថ្មី ឬមួយធ្វើអាល័យថានឹងនៅក្នុងវិហារនេះ ហើយទៅកាន់យកសេនាសនៈក្នុងវិហារដទៃទៀត អាល័យមុននៃភិក្ខុនោះ រមែងរម្ងាប់ដោយការកាន់យកសេនាសនៈថ្មីនេះ ៗ មួយទៀត ការកាន់យកសេនាសនៈ ឬធ្វើអាល័យថានឹងនៅក្នុងវិហារនេះ ហើយទៅកាន់យកសេនាសនៈ ឬធ្វើអាល័យថានឹងនៅក្នុងវិហារដទៃដូច្នេះ ការកាន់យកសេនាសនៈនៃភិក្ខុនោះរមែងរម្ងាប់ដោយអាល័យ ឬអាល័យរមែងរម្ងាប់ដោយអាល័យ ភិក្ខុនោះរមែងឋិតនៅតែក្នុងការកាន់យកសេនា-សនៈ ឬអាល័យខាងក្រោយ តែមួយយ៉ាងគ្រប់កន្លែង ៗ ភិក្ខុណា

www.budinst.gov.kh www.elibraryofcambodia.org

កាន់យកសេនាសនៈក្នុងវិហារមួយកន្លែង ហើយទៅដោយគិតថាខ្ញុំនឹងទៅក្នុងវិហារដទៃ លុះកន្លងនូវឧបចារៈសីមានៃវិហារនោះចេញទៅ អាការដែលកាន់យកសេនាសនៈក្នុងវិហារមុននៃភិក្ខុនោះក៏រម្ងាប់ ។ បើភិក្ខុទៅដោយគិតថា សប្បាយក្នុងវិហារឯណោះក៏នឹងនៅ បើមិនសប្បាយទេក៏នឹងត្រឡប់មកវិញ ដូច្នេះហើយទៅ ដឹងថាមិនសប្បាយហើយត្រឡប់មកវិញដូច្នេះ ក៏គួរ ។

សេនាសនប្បដិសំយុត្តកថា ចប់

---

## អនាមាសាទិកថា

ខមួយ ភិក្ខុចាប់ពាល់មាតាជាដើម ដោយប្រកាន់ថាជាមាតា ធីតា បងស្រី ឬប្អូនស្រី ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកក្នុងវិភង្គនៃកាយសំសគ្គសិក្ខាបទថា អាបត្តិ ទុក្កដស្ស ដូច្នេះ ។ ព្រោះមាតុគ្រាមរមែងជាសត្រូវដល់ព្រហ្មចរិយៈ ហេតុនោះ កាលរឭកដល់អាជ្ញាព្រះពុទ្ធអង្គ សូម្បីឃើញមាតាធ្លាក់ទឹក អណ្តែតទៅតាមខ្សែទឹក ក៏កុំគប្បីចាប់ពាល់ដោយដៃឡើយ ភិក្ខុអ្នកឆ្លាត គប្បីយកទូក ឬក្តារ ឬកំណាត់ដើមចេក ឬកំណាត់ឈើបោះទៅ កាលរបស់នោះមិនមាន សូម្បីសំពត់កាសាវៈ ក៏គប្បីបោះទៅអំពីខាងមុខចុះ តែកុំប្រាប់ឲ្យចាប់យក លុះមាតាចាប់សំពត់ដោយខ្លួនឯង ក៏គប្បីទាញមកដោយគិតថា យើងទាញបរិក្ខាររបស់យើង បើមាតាខ្លាច ក៏គប្បីហែលៈទៅអំពីមុខ

www.budinst.gov.kh www.elibraryofcambodia.org

លួងលោមថាកុំខ្លាចឡើយ បើមាតាទៀនជះក ឬគោងដៃសោក កុំគប្បីរលាស់ចេញឡើយ គប្បីបញ្ជូនឲ្យដល់គោក សូម្បីមាតាជាប់ភក់ទឹង ធ្លាក់ចុះក្នុងអណ្ដូងក៏ដូចគ្នា គប្បីយកខ្សែ ឬសំពត់បោះចុះទៅក្នុងទីនោះ ដឹងថាមាតាចាប់យកហើយ គប្បីទាញឡើងមក តែកុំចាប់ពាល់ ៗ មិនមែនតែសរីរៈ នៃមាតុគ្រាមប៉ុណ្ណោះទេ ដែលជាអនាមាស សូម្បីសំពត់ស្លៀកសំពត់ដណ្ដប់ទឹងគ្រឿងប្រដាប់ ដោយហោចទៅ គ្រាន់តែក្រវិលស្មៅទឹងចិញ្ចៀនស្លឹកត្នោត ជារបស់ដែលស្ត្រីហួងហែង ដើម្បីជាគ្រឿងប្រដាប់ ក៏ជាអនាមាសទាំងអស់ ចាប់ពាល់មិនបាន ៗ ថាបើសំពត់ស្លៀកសំពត់ដណ្ដប់គេផ្លាស់ដាក់ទុកទៀបបាទមូលេ ដើម្បីថ្វាយជាចីវរ ចាប់ពាល់ក៏គួរ ៗ ក្នុងគ្រឿងប្រដាប់ វត្ថុដែលជាគប្បិយមានពិណក្នុងជាដើម ជាបើគេថ្វាយ គប្បីទទួលមកជាគ្រឿងឧបការ មានកន្ទាស់ក្ទាស់សិងជាដើមចុះ តែវត្ថុដ៏ហើយដោយមាសទឹងប្រាក់តែមុក្ដាទឹងត្បូងពេជ្រ ជាអនាមាសពិត សូម្បីគេឲ្យ ក៏កុំគប្បីទទួល ៗ

មួយទៀត បើចាប់ពាល់រូបភាពឈើ ដែលធ្វើជារូបស្ត្រី ត្រូវទុក្កដ ៗ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកក្នុងវិនីតវត្ថុថា អាបត្តិ ទុក្កដស្ស ដូច្នេះ ៗ សូម្បីរូបភក់ រូបដែក រូបលោហៈ រូបសំណាក់ រូបស្មឹករីត រូបសូនដោយកំបោរ រូបកែវទាំងពួង ដោយហោចទៅ សូម្បីតែរូបសូនដោយម្សៅ ដែលគេធ្វើសណ្ឋានដូចស្ត្រី ក៏ជាអនាមាសទាំងអស់ ចាប់ពាល់មិនបាន គេថ្វាយដើម្បីបរិភោគ រូបដ៏សេស វៀរតែរូប

www.budinst.gov.kh www.elibraryofcambodia.org

ជំរះហើយដោយកែវទាំងពួង បើទឹងរលាយចេញ គួរជាឧបការៈបាន គប្បីនាំចូលទៅជាគ្រឿងឧបការៈ ដែលគួរបរិភោគ បង្អែមចូលទៅជាគ្រឿងបរិភោគក៏គួរ ។ មិនមែនតែប្រស្រ័មួយយ៉ាង សូម្បីស្រូវ ៧ ប្រការ ក៏ជាអខាមាសទាំងអស់ដូចគ្នា ។ ព្រោះហេតុនោះ កាលដើរទៅកណ្តាលស្រែកុំគប្បីបាច់ពាល់ផ្លែស្រូវ សូម្បីកើតក្នុងស្រែនោះ ។ បើគេហាលស្រូវទុកប្របផ្លូវស្រុក ឬកណ្តាលផ្លូវ ផ្លូវដែលទៅដោយខាងៗ នោះមានកុំគប្បីជាន់ហើយដើរទៅ កាលបើផ្លូវមិនមាន គប្បីអធិដ្ឋានថាផ្លូវហើយដើរទៅចុះ ។ ក្នុងលំនៅក្នុងភូមិ គេក្រាលអាសនៈលើគំនរស្រូវឲ្យអង្គុយ ទឹងអង្គុយក៏គួរ ។ មនុស្សចំពួកខ្លះ គេដាក់ស្រូវទុកក្នុងរោងទាំង ថាបើអាចឲ្យគេជញ្ជូនចេញបាន ក៏គប្បីឲ្យគេជញ្ជូនចេញ ថាបើមិនអាចជញ្ជូនចេញ កុំគប្បីជាន់ញាំញាក់ គប្បីឲ្យគេដំកល់កាំងក្នុងទីម្ងាំងហើយអង្គុយចុះ ។ ថាបើឱកាសមិនមាន គេក្រាលអាសនៈក្នុងកណ្តាលគំនរស្រូវ គប្បីអង្គុយចុះ សូម្បីស្រូវនៅក្នុងទូកក៏ដូចគ្នា សូម្បីអបរណ្ណជាតិ មានសណ្តែកបាយនឹងសណ្តែកកន្ធមាសជាដើម ឬផ្លែឃ្លោកផ្លែខ្នុរជាដើម ដែលកើតនៅក្នុងដើមនោះ ក៏កុំគប្បីបញ្ចោសអង្រួលលេង សូម្បីគេធ្វើជាគំនរទុកក៏ដូចគ្នា ។ ផ្លែឈើជ្រុះចុះក្នុងព្រៃទឹងកាន់យកដោយគិតថានឹងឲ្យអនុបសម្បន្ន គួរ ។

កែវមុក្តា កែវមណី កែវពិទូរ្យ ស័ង្ខ សិលា កែវពពាល ប្រាក់ មាស កែវទទឹម កែវផ្តុក ទាំង ១០ នេះឈ្មោះថារតនៈ ។ កែវមុក្តា គេមិនទាន់

www.budinst.gov.kh www.elibraryofcambodia.org

បានខាត់ មិនទាន់បានខាត់នោះ នៅដូចដើមតាប់ពាល់បាន ក្រៅនោះជាអនា-មាសតាប់ពាល់មិនបាន ។ ក្នុងមហាបច្ចរីពោលថា កែវមុត្តា សូម្បីគេខាត់ហើយឬនៅមិនទាន់បានខាត់ក្តី ក៏ជាអនាមាស ទឹងទទួលដើម្បីដំឡៃនៃភណ្ឌមិនគួរ តែទឹងទទួលដើម្បីជាថ្នាំរក្សាកុដ្ឋរោគក៏គួរ ។ កែវមណីជាដើមមានពណ៌ខៀវលឿងទាំងអស់ ដោយហោចទៅ ជាតិនៃកែវផ្ទុកគេខាត់នោះផ្ទៃហើយក៏ជាអនាមាស តែបើនៅជាកំណើតដើម លោកពោលថាទឹងទទួលដើម្បីជាដំឡៃបាត្រជាដើមក៏គួរ ។ ក្នុងមហាបច្ចរី លោកឃាត់ថាមិនគួរ លោកពោលថា តែកញ្ចក់ដែលគេសូមមួយយ៉ាងប៉ុណ្ណោះគួរ ក្នុងកែវពិទូរ្យឲ្យវិនិច្ឆ័យដូចកែវមណីចុះ ។ ស័ង្ខសំរាប់ផ្លុំគេខាត់នោះហើយវិចិត្រលាយដោយរតនៈជាអនាមាស ។ ស័ង្ខសំរាប់ដាក់ទឹក សូម្បីគេខាត់ហើយឬមិនទាន់បានខាត់ក្តី តាប់ពាល់បាន ស័ង្ខក្រៅនោះទឹងទទួលដើម្បីជាថ្នាំភ្នែកឬដំឡៃភណ្ឌក៏គួរ ។ សិលាមានពណ៌ដូចសណ្ដែកបាយ គេដុសខាត់នោះហើយ គេប្រកបរតនៈចូលផងជាអនាមាស ។ សិលាក្រៅនោះទឹងទទួលដើម្បីជាថ្មសំលៀងកាំបិត ថ្មកិនជាដើមក៏គួរ ។ កែវពពាលគេខាត់នោះហើយជាអនាមាស ។ ក្រៅនោះជាអាមាស ទឹងទទួលដើម្បីដំឡៃភណ្ឌក៏គួរ ។ តែក្នុងមហាបច្ចរីពោលថា សូម្បីគេខាត់ហើយ ឬនៅមិនទាន់បានខាត់ក្តី ទាំងអស់នេះជាអនាមាស ទឹងទទួលក៏មិនគួរ ។ ប្រាក់មាស គេធ្វើជារូបភាពហើយ ឬនៅមិនទាន់បានធ្វើក្តី តាំងតែអំពីពូជទៅរ៉ែទៅ ជាអនាមាស មិនគួរទទួលដោយប្រការទាំងពួង ។ បានឮថា

www.budinst.gov.kh www.elibraryofcambodia.org

ត្រកជុំត្រសាន់ចេតិយមាស ហើយបញ្ជូនទៅដល់ព្រះមហាបទុមត្ថេរ ព្រះមហាបទុមត្ថេរ លោកឃាត់ថា មិនគួរ ៗ ក្ដីផ្ទះចេតិយមានឈ្នួតមាសខឹងផ្កាមាសជាដើម សូម្បីរបស់ទាំងអម្បាលនោះក៏ជាអនាមាស ៗ តែភិក្ខុជាអ្នករក្សាផ្ទះចេតិយ តាំងនៅក្ដីទីជាអ្នកពោលរួចិយ ព្រោះហេតុនោះ លោកពោលថា ភិក្ខុនោះនឹងចាប់ពាល់កិលរបស់នោះក៏គួរ ៗ តែក្ដីក្រុន្ទីលោកឃាត់ថាមិនគួរ លោករមែងអនុញ្ញាតតែត្រឹមថា នឹងនាំសំរាមក្ដីចេតិយទៅពេលបានប៉ុណ្ណោះ ។ សូម្បីសំរិទ្ធវិសេសមានពណ៌ដូចមាស មានតម្លៃមាសក៏ជាអនាមាស ៗ ពាក្យទាំងអម្បាលនេះ ពោលទុកក្ដីអដ្ឋកថាទាំងឡាយ ៗ គ្រឿងបរិភោគក្ដីសេនាសនៈជាកប្បិយទាំងអស់ ព្រោះហេតុនោះ បរិក្ខាររបស់សេនាសនៈទាំងអស់ សូម្បីវិចិត្រដោយថ្នាក់ នឹងមាស ក៏ចាប់ពាល់បាន ៗ គេធ្វើតែងមណ្ឌប ជាទីសំដែងធម៌នឹងវិន័យរបស់ភិក្ខុ មានសសរដំហើយដោយតែរផ្លុក ប្រដាប់ដោយកម្រងផ្កាតេងៈ គ្រឿងបរិភោគក្ដីមណ្ឌបនោះ ភិក្ខុនឹងសំអាតក៏គួរ ៗ តែទទឹម ១ តែរផ្លុក ១ គេខាត់ហោះហើយជាអនាមាស ៗ ក្រៅនោះជាអាមាស លោកពោលថានឹងចូលដើម្បីជាដំឡៀនៃកណ្ដុកក៏គួរ ៗ តែក្ដីមហាបច្ចរី ពោលថា សូម្បីគេខាត់ហើយនៅមិនទាន់ខាត់ក្ដី ជាអនាមាសទាំងអស់ នឹងចូលក៏មិនគួរ ៗ

គ្រឿងអាវុធទាំងអស់ជាអនាមាស សូម្បីគេថ្វាយដើម្បីជាដំឡៀងក្ដី ក៏កុំគប្បីចូល ពីងទៅជាឈ្មោះថា លក់គ្រឿងសស្ត្រាជាការមិនគួរ ៗ

ដងឆ័ត្រ ឬខ្សែប្រឡោះខាង ទាំងកន្ត្រៃ ផន្ទួញ ដោយហោចទៅ សម្បកកាំបិត ទាំងរូបទៅជាដើម ដែលគេធ្វើសន្មតថាជាអាវុធ ក៏ចាប់ពាល់មិនបាន ។ ថាបើគេយកលំពែង ឬលំពែងពួយ មកដំកល់ទុកក្នុងវិហារ កាលទាំងសំអាតនូវវិហារ គប្បីប្រាប់ម្ចាស់របស់ឲ្យគេយកទៅវិញ ថាបើគេមិនយកទៅវិញ កុំគប្បីធ្វើឲ្យរបស់នោះកម្រើក សំអាតតែវិហារនោះចុះ ។ ឃើញដាវ លំពែង ឬ លំពែងពួយ ធ្លាក់ចុះក្នុងទីចម្បាំង យកថ្មសិលាទំលាយដាវចេញ ដកដងលំពែងចេញ ថ្ងដាវកាន់យកទៅ ដើម្បីធ្វើជាកាំបិត ដងដើម្បីធ្វើជាឈើច្រកជាដើមក៏គួរ ។ បើគេប្រគេន ទាំងធ្វើឲ្យវិនាសចេញហើយ ទទួលយកទៅធ្វើជាកប្បិយ-ភណ្ឌក៏គួរ ។ សម្បីសំណាញ់ បន្ទាត់ ជាគ្រឿងដាក់ត្រីដាក់សត្វជាដើម គ្រឿងការពារខ្លួនសមានខែលជាដើមក្តី តាំងអស់មិនគួរចាប់ពាល់ជាអនាមាស បានមកដើម្បីបរិភោគ បន្ទាត់ទាំងយកមកចងជាអាសនៈ ឬចេតិយ ឬដងឆ័ត្រក៏គួរ ។ គ្រឿងការពារខ្លួនតាំងអស់ ទាំងទទួលដើម្បីដាក់ថ្ងៃនៃភណ្ឌក៏គួរ ដ្បិតថារបស់នោះ គ្រាន់តែជាគ្រឿងការពារសេចក្តីបៀតបៀន មិនបានធ្វើសេចក្តីបៀតបៀនអ្នកដទៃ ។ ខែលទាំងទទួលមកធ្វើជាភាជនៈរងឈើស្ទួនក៏គួរ ។

គ្រឿងដន្ត្រីមានពិណទាំងស្គរជាដើម ដែលគេដាសដោយស្បែកមិនគួរចាប់ពាល់ ជាអនាមាស ។ តែក្នុងកុរុន្ទីពោលថា សម្បកពិណ ភងស្គរទាំងស្ទូកខាង ទាំងស្បែកដែលគេដាសក្នុងកណ្តាប់មាត់ ទាំងដងពិណក្តី

www.budinst.gov.kh www.elibraryofcambodia.org

ភាជនអស់ទាំងពាល់មិនបាន ជាអនាមាស ។ ទឹងជាសងទឹប្រើឲ្យគេដាស

ប្រគេនឯង ឬប្រើគេឲ្យប្រគេន មិនបានឡើយ សូម្បីគ្រឿងដង្រ្កើដែលគេបូជា

ហើយ ពោលទុក្កដណាខះបដិសេធ ក៏កុំគប្បីធ្វើឲ្យកម្រើក គប្បីបោសពៃ

គ្រឹបទ្វារៈ ។ តែក្នុងខណៈ ទឹងពោលសក្ការទឹងនាំទៅដោយទិយមជាជា

សក្ការហើយតាំងទុកខាងមុខកំគួរ ។ ពាក្យនេះពោលទុក្កដមហាបច្ចរីជា

សូម្បីទឹងទទួលគ្រឿងដង្រ្កើ ដើម្បីជាដំរៀងនៃភណ្ឌកំគួរ តែដែលបានមក

ដើម្បីបរិភោគ ទឹងកាន់យកដើម្បីធ្វើបរិក្ខារនោះ ។ តឹកង់ពំណាកង់ស្គាល់

ជាកាដខះរង់ឈើសូន តែស្បែកទឹងធ្វើជាស្រោមកាំបិតកំគួរ ។

មួយទៀត កុំចាប់ពាល់ផ្លែឈើមានចេកទឹងផូងជាដើម ដែលជាប់

នៅទឹងដើម ឬមែក ជាប៉ះចាប់ពាល់ ត្រូវទុរុបចិណ្ណទុក្កដ ។

មួយទៀត ដើរទៅបិណ្ឌបាត ឆ្លុំផ្លាក់ចុះក្នុងបាត្រ គប្បីឲ្យគេ

ប្រគេនបាត្រជាថ្មី ឬលាងចេញមុនសឹមទទួលកំគួរ ជាប៉ះ ត្រូវប្រគេន

ឬលាងចេញមុនហើយទទួល ក៏ត្រូវវិន័យទុក្កដ ។

អនាមាសាទិកថា ចប់

---

តាំងអំពីកិច្ចការគម្ពុក ទឹងចុះពោលឃ្លាំងរៀងទៅ រហូតដល់ចៀសចេញ

ទៅកាន់ទិស ទឹងទុកពោលក្នុងក្ខន្ធកខាងមុខ ដែលព្រះពុទ្ធអង្គ

ទ្រង់បញ្ញត្តិនៃទុក្កដាបត្តិ ។ តាំងអំពីដើមមកលុះដល់វិន័យទុក្កដនេះ ជា

សចិត្តកៈ តែមិនប្រព្រឹត្តក្នុងដោយចិត្តដែលដឹង ទើបត្រូវអាបត្តិ ។

សចិត្តកវណ្ណនា ចប់

---

ខមួយទៀត ភិក្ខុមិនចងវត្តពន្ធចង្កេះ កុំចូលទៅក្នុងស្រុក បើចូលទៅត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ អកាយពន្ធនេន គាមោ បវិសិតព្វោ ដូច្នេះ ។ មិនបានចងវត្តពន្ធចង្កេះចេញទៅក្រៅ ភ្លេចបានក្នុងទីណា គប្បីចងក្នុងទីនោះ គិតថា ខំទៅចងទៀបកេងធាន់ ជិតភូមិ ហើយទៅ ក៏គួរ ។ ភ្លេចបានហើយ មិនបានចង កុំគប្បីត្រាច់ទៅបិណ្ឌបាត ។

ទមួយទៀត ភិក្ខុមានបាត្រក្នុងដៃ កុំគប្បីច្រានសន្លឹកទ្វារ បើច្រាន ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ បត្តហត្ថេន កវាដំ បណាមេតព្វំ ដូច្នេះ ។ បាត្រនៅក្នុងដៃ ភិក្ខុណា ភិក្ខុនោះឈ្មោះថាមានបាត្រក្នុងដៃ មិនត្រឹមតែមានបាត្រក្នុងដៃប៉ុណ្ណោះ កុំគប្បីច្រានសន្លឹកទ្វារ មិនត្រឹមតែសន្លឹកទ្វារប៉ុណ្ណោះទេ បើមានបាត្រនៅក្នុងដៃ ឬខ្នងជើង ឬសរីរាវយវៈណាមួយក្តី នឹងច្រានសន្លឹកទ្វារ ឬដកបង្ហាស់ ឬគន្លឹះ ទាក់សោដោយដៃ ដោយខ្នងជើង ដោយក្បាល ឬដោយសរីរាវយវៈណាមួយក៏មិនបានទាំងអស់ ។ តែបើយកបាត្រត្បៀតចូលក្នុងចន្លោះភ្លៅ បើកទ្វារ ទាក់សោ ក៏បាន ។

ខមួយទៀត ភិក្ខុកុំគប្បីដេកលើគ្រែជាមួយគ្នា កុំគប្បីដេកលើគ្រឿងកំរាលជាមួយគ្នា កុំគប្បីដេកលើទីមានសំពត់ដណ្តប់ជាមួយគ្នា កុំគប្បីដេកលើទីមានគ្រឿងកំរាលនិងសំពត់ដណ្តប់ជាមួយគ្នា បើដេកដូច្នោះ ត្រូវទុក្កដ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ឯកមញ្ចេ

www.budinst.gov.kh www.elibraryofcambodia.org

ឯមួយទៀត ភិក្ខុមានជើងមិនបានលាងកុំជាន់សេនាសនៈ មានគ្រែនិងតាំងជាដើម និងផ្ទៃដែលគេធ្វើបរិកម្មជារបស់សង្ឃ ៗ ឯមួយទៀត ជើងទទឹកដោយទឹក កុំជាន់សេនាសនៈដូច្នោះ ៗ ឯមួយទៀត បើពាក់ស្បែកជើង កុំជាន់សេនាសនៈដូច្នោះ បើជាន់ត្រូវទុក្កដ ៗ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ អធោតេហិ បាទេហិ អល្លេហិ បាទេហិ សឧបាហនេន សេនាសនំ អក្កមិតព្វំ ដូច្នេះ ៗ កន្លែងដែលជាន់ចុះដោយជើង ទឹកប្រាកដនៅដូច្នោះឈ្មោះថាជើងទទឹក កុំគប្បីជាន់ផ្ទៃដែលគេធ្វើបរិកម្ម ឬសេនាសនៈ បើគ្រាន់តែសើមប្រាកដ ទឹកមិនប្រាកដនឹងជាន់ក៏គួរ ៗ ជើងប្រឡាក់ និងជាន់សំពត់ជូតជើងក៏គួរពិត ៗ

ឯមួយទៀត ភិក្ខុកុំគប្បីស្ដោះទឹកមាត់ លើផ្ទៃដែលគេធ្វើបរិកម្ម បើស្ដោះត្រូវទុក្កដ ៗ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ បរិកម្មកតាយ ភូមិយា និដ្ឋុភិតព្វំ ដូច្នេះ ៗ ស្ដោះទឹកមាត់តៀសសំពោរ ក្នុងកន្ថោរក៏គួរ ដ្បិតជារបស់ទ្រង់អនុញ្ញាត ៗ

ឯមួយទៀត ភិក្ខុកុំគប្បីផ្អែកទីនជញ្ជាំង ដែលគេធ្វើបរិកម្ម និងជញ្ជាំងដែលគេធ្វើចិត្រកម្មគឺគូររស បើផ្អែកត្រូវទុក្កដ ៗ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ បរិកម្មកតា ភិត្តិ អបស្សេតព្វា ដូច្នេះ ៗ មិនមែនតែជញ្ជាំងមួយចំពូកឡើយ សូម្បីសន្ទឹកទ្វារ និងសន្ទឹកបង្អួច ក្ដារបង្អែក សសរថ្ម សសរឈើក្ដី មិនបានប្រាប់ដោយសំគត់

www.budinst.gov.kh www.elibraryofcambodia.org

ឬវត្ថុណាមួយមុនហើយ ផ្អែកមិនបានឡើយ ។ មួយទៀត កាលនឹងដំកល់ទុកនូវគ្រែនឹងតាំងលើផ្ទៃលាបដោយកំបោរ ឬផ្ទៃដែលគេប្រោះព្រំ បើគេខ្វល់ផែនឹងគេខ្វល់វេចក ដែលនឹងក្រាលមិនមាន គប្បីយកសំពត់ព័ទ្ធព័ទ្ធជើងគ្រែ ជើងតាំងជាមុនសិន ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ ចោឡកេន បលិវេឋេតុំ (១) ដូច្នេះ ។ កាលបើសំពត់ព័ទ្ធព័ទ្ធមិនមាន សូម្បីយកឈើនឹកគួរ កាលបើមិនបាន កាន់យករបស់ណាមួយរើមុន ដំកល់គ្រែ តាំង ត្រូវទុកដ ។ បើទៅ-កាន់សដំកល់ទុកគ្រែនឹងតាំងលើផ្ទៃ មិនមានរបស់អ្វីមួយរង នឹងប្រើប្រាស់ជាន់ដោយជើងមិនបានលាង នឹងប្រើប្រាស់ដូចទៅកាន់សក៏គួរ ។

១មួយទៀត គ្រែនឹងតាំងរបស់សង្ឃ ឬទីដែលគេធ្វើប្រោះព្រំ ឬគ្រឿងកំរាល សេនាសនៈដែលនឹងគប្បីជាន់ដោយជើងដែលលាងហើយ គប្បីយករបស់ជារបស់ខ្លួនក្រាលមុន សិមដេក ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ បច្ចត្ថរិត្វា និបជ្ជិតុំ ដូច្នេះ ។ ក្រាលហើយសូម្បីដេកលក់ទៅ គ្រឿងកំរាលនោះរមូរចូល សរីរាវយវៈណាមួយពាល់ត្រូវគ្រែ ឬតាំង ត្រូវអាបត្តិដោយពិត ។ តែកេមពាល់ត្រូវ ក៏ត្រូវអាបត្តិរបស់ដោយកេម ។ សូម្បីផ្អែកនឹងគ្រែនឹងតាំងដោយអាការនៃការបរិភោគក៏ដូចគ្នា តែពាល់ត្រូវដោយបាទដៃ ឬជាន់ដោយបាទជើងក៏គួរ ។ កាលបើនាំគ្រែនឹងតាំងទៅហើយប៉ះពាល់ នឹងកាយមិនត្រូវអាបត្តិ ។

១– [illegible]

www.budinst.gov.kh www.elibraryofcambodia.org

ខមួយទៀត ភិក្ខុកុំគប្បីទុកសក់វែង ៗ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាម-ឃាត់ មិនអនុញ្ញាតទុកថា ន ភិក្ខវេ ទីឃា កេសា ធារេតព្វា... អនុជានាមិ ភិក្ខវេ ទុមាសិកំ[១] វា ទុវង្គុលំ វា ភិក្ខុ គប្បីទុកសក់ឲ្យវែង បើទុកឲ្យវែង ត្រូវទុក្កដ ៗ តថាគត អនុញ្ញាតឲ្យទុកសក់ត្រឹម ២ ខែ ឬវែងប្រវែង ២ ធ្នាប់ ៗ បើទាន់កន្លង ២ ខែ សក់វែងដល់ ២ ធ្នាប់ គប្បីកោរចេញក្នុងខាងក្នុង ២ ខែ បើមិនឲ្យលើស ២ ធ្នាប់ឡើងទៅមិនគួរ ៗ បើមិនទាន់វែងដល់ ២ ធ្នាប់ មិនឲ្យកន្លងហួស ២ ខែទៅ សូម្បីមួយថ្ងៃ ក៏មិនបានឡើយ ដ្បិតពាក្យទាំង ២ នេះ កំណត់ ចំណែកជាឧក្រិដ្ឋ ក៏តែទុំចុះមកជាធំនោះ ដែលថាមិនគួរនោះ មិនមាន ៗ

ខមួយទៀត ភិក្ខុកុំគប្បីទុកពុកមាត់ មិនពុកចង្កាឲ្យវែង ៗ ដ្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ មស្សុ កប្បាបេតព្វំ ន មស្សុ វឌ្ឍាបេតព្វំ ន គោលោមិកំ... ន ចតុរស្សកំ... ន បរិមុខំ... ន អឌ្ឍុរកំ ឋាបេតព្វំ ន ទាឋិកា ឋបេតព្វា... ភិក្ខុមិនត្រូវឲ្យគេកាត់ពុកមាត់ (ដោយកន្ត្រៃ) កុំទុកពុកមាត់ឲ្យវែង កុំឲ្យគេធ្វើពុកចង្កាឲ្យវែង (ដូចពុកចង្កាពពែ) កុំឲ្យគេធ្វើពុកមាត់ជាបួនជ្រុង គឺថាមិនប្រាកដជា ៤ ជ្រុង ឬ ៤ អន្លើយ៉ាងណា កុំឲ្យគេធ្វើយ៉ាងនោះ កុំឲ្យគេប្រមូលរោមទ្រូងឲ្យជាដូចជាកំពូល កុំឲ្យគេធ្វើរោមពោះ កាន់ទុកជាដូចជាកំពូល កុំទុកពុកមាត់ដូចចង្កូម កុំឲ្យគេដករោមក្នុងចំបចៀក ថាបើឲ្យគេធ្វើដូចពោលមកនេះ ត្រូវទុក្កដ ៗ

---

១– វិនយវណ្ណនា ប្រាប់ដើមថា ទ្វេមាសិកំ ៗ

www.budinst.gov.kh www.elibraryofcambodia.org

ខ មួយទៀត ភិក្ខុកុំគប្បីទុករោមច្រមុះឲ្យវែង បើទុកឲ្យវែងត្រូវទុក្កដ ។ ព្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ ទីឃំ នាសិកា-លោមំ ធារេតព្វំ ដូច្នេះ ។ រោមច្រមុះគប្បីដកចេញដោយសណ្ដាស់ដែលជារបស់ព្រះពុទ្ធអង្គទ្រង់អនុញ្ញាត តែមិនឲ្យគេដករោមច្រមុះដោយក្រួសជាដើមមិនត្រូវអាបត្តិ តែព្រះពុទ្ធអង្គទ្រង់អនុញ្ញាត សណ្ដាស់ទុកដើម្បីនឹងឲ្យរក្សាខ្លួន ។

ខ មួយទៀត ភិក្ខុកុំគប្បីទុកក្រចកឲ្យវែង បើទុកឲ្យវែងត្រូវទុក្កដ ។ គប្បីកាត់ចេញដោយកាំបិតកាត់ក្រចក ឲ្យស្មើនឹងសាច់ ។ ព្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់នឹងអនុញ្ញាតទុកថា ន ភិក្ខវេ ទីឃា នខា ធារេតព្វា អនុជានាមិ ភិក្ខវេ នខច្ឆេទនំ អនុ-ជានាមិ ភិក្ខវេ មំសប្បមាណេន នខំ ឆិន្ទិតុំ ដូច្នេះ ។ កាត់ក្រចកដោយក្រចកជាដើម មិនត្រូវអាបត្តិ ។ ព្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតកាំបិតកាត់ក្រចកទុកដើម្បីនឹងឲ្យរក្សាខ្លួន ។

ខ មួយទៀត ភិក្ខុកុំគប្បីឲ្យគេខាត់ក្រចកទាំង ២០ បើឲ្យគេខាត់ត្រូវទុក្កដ គប្បីនាំតែមន្ទិលក្រចកចេញចាកក្រចក ។ ព្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់នឹងអនុញ្ញាតទុកថា ន ភិក្ខវេ វីសតិមដ្ឋំ ការាបេតព្វំ អនុជានាមិ ភិក្ខវេ មលមត្តំ អបកឌ្ឍិតុំ ដូច្នេះ ។

មួយទៀត ភិក្ខុគ្មានជម្ងឺកុំគប្បីឲ្យគេដករោមក្នុងចង្កៀក ។ ព្បិតព្រះពុទ្ធអង្គទ្រង់ហាមឃាត់នឹងអនុញ្ញាតទុកថា ន ភិក្ខវេ សម្ពាធេ

www.budinst.gov.kh www.elibraryofcambodia.org

លោមំ សំហរាបេតុំ អនុជានាមិ ភិក្ខវេ អាពាធប្បច្ចយា សម្ពាធេ លោមំ សំហរាបេតុំ ភិក្ខុកុំគប្បីឲ្យគេដករោមក្នុងទីចង្អៀតទីដ៏ទៀត បើឲ្យគេដកត្រូវទុក្កដ តថាគតអនុញ្ញាតឲ្យប្រើគេដកនូវរោមក្នុងទីចង្អៀត ព្រោះអាពាធគឺបូសនឹងដំបៅ ដើម្បីលាបថ្នាំ ។

មួយទៀត ភិក្ខុកុំគប្បីចោលឯង នឹងកុំឲ្យគេចោល នូវឧច្ចារៈ បស្សាវៈ សំរាម របស់សំណល់ ក្រៅជញ្ជាំង ក្រៅកំពែង ។

មួយទៀត ភិក្ខុកុំគប្បីចោលឯង នឹងកុំឲ្យគេចោល របស់ ៤ យ៉ាងនោះ លើទីទៀត គឺចំការ ស្រែ របស់គេ ក្នុងសិក្ខាបទ ២ នេះ មកក្នុងបាចិត្តិយខាងភិក្ខុនី ព្រះអដ្ឋកថាចារ្យ លោកពោលថា ក្នុងភិក្ខុត្រូវទុក្កដ ។ ចោលឯងនូវរបស់ ៤ យ៉ាង ក្រៅជញ្ជាំង ឬក្រៅកំពែងដោយប្រយោគតែមួយ ត្រូវទុក្កដតែមួយ ។ កាលបើចោលផ្សេងៗ គ្នាត្រូវទុក្កដ រាប់ដោយវត្ថុ ។ ក្នុងការបង្គាប់ឲ្យគេចោលក៏ដូចគ្នា សូម្បីចោលឈើស្ទន់គឺគង់ត្រូវទុក្កដ ។ បើមើលសិនហើយចោលឧច្ចារៈជាដើម ឬចោលក្នុងទីមិនមានមនុស្សទៅមក ជាទីធ្លាប់ចោល មិនត្រូវអាបត្តិ ។ ចំការស្រែជាទីព្រោះដាំពូជផ្លែរបស់មនុស្ស ឬសួនដូងជាដើមក្តី ក្នុងទីណាមួយជាទីមានរបស់ទៀត គឺពូជផ្លែគេសាបព្រោះដាំទុកហើយ នឹងចោលរបស់ ៤ យ៉ាងនោះ មិនគួរ ។ កាលបើចោលឲ្យគប្បីដឹងប្រភេទអាបត្តិដោយន័យមុន ។ អង្គុយធាន ឬចំការពោតជាដើម ក្នុងចំការស្រែ ឬសួន កាលបើនឹងនោះហើយ ចាក់ចោលទឹកសំណល់នឹងភាជនជាដើម

www.budinst.gov.kh www.elibraryofcambodia.org

ទុកក្នុងទីមានរបស់ទៀត ដោយហោចទៅ សូម្បីផ្ទុងដូងដែលពោះក្បាល ដីកចំកហើយចោល គឺគង់ត្រូវទុក្កដ ។ ក្នុងស្រែគេភ្ជួរហើយសាបពូជទុកហើយ ពន្លកបែកឡើងហើយ ឬនៅមិនទាន់បែកក្តី គឺគង់ត្រូវទុក្កដ ។ ចោលក្នុងចំការស្រែដែលគេមិនទាន់សាបពូជ ឬក្នុងមុំចំការស្រែ ឬក្តីដែលគេមិនបានព្រោះដាំ នឹងចោលក្នុងទីដែលមនុស្សគេចោលសំរាម គឺគួរ ។ មនុស្សគេច្រូតស្រូវចេញអស់ហើយ ៖ឈ្មោះថាស្រែគេលែងធ្វើ ក្នុងស្រែដូច្នោះគឺគួរ ។ បើស្រែណាមានបុព្វណ្ណជាតិជាដើម សូម្បីគេច្រូតកាត់ហើយ តែគេនៅរក្សាជានឹងដុះឡើងទៀត ក្នុងចំការស្រែដូច្នោះមិនគួរ ។

ខមួយទៀត ភិក្ខុមិនបានពិចារណាសួរមុន កុំគប្បីឆាន់សាច់ បើឆាន់ត្រូវទុក្កដ ។ ព្រោះព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ច ភិក្ខវេ អប្បដិវេក្ខិត្វា មំសំ បរិភុញ្ជិតព្វំ ដូច្នេះ ។ បើដឹងថាជាសាច់ឈ្មោះនេះហើយ ភិក្ខុដែលនឹងសាកសួរមិនមាន បើមិនដឹងគប្បីសួរមុនសិមឆាន់ ។

ខមួយទៀត ភិក្ខុកុំគប្បីឆាន់សាច់ដំរី សាច់សេះ សាច់ឆ្កែ សាច់ពស់ សាច់រាជសីហ៍ សាច់ខ្លាធំ សាច់ខ្លាដំបង សាច់ខ្លាឃ្មុំ សាច់ឆ្កែព្រៃ (សាច់ខ្លាត្រី) បើឆាន់សាច់ទាំងអម្បាលនេះ ត្រូវទុក្កដ ។ ព្រោះព្រះពុទ្ធអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ ហត្ថិមំសំ-អស្ស-សុនខ · អហិ · សីហ ព្យគ្ឃ · ទីបិ · អច្ឆ · តរច្ឆមំសំ បរិភុញ្ជិតព្វំ ដូច្នេះ ។ សុនខព្រៃឈ្មោះថាកោកៈដូចឆ្កែស្រុក

www.budinst.gov.kh www.elibraryofcambodia.org

សាច់នៃផ្លែព្រៃនោះគួរ ។ ផ្លែណាកើតដោយមេផ្លែស្រុក បាជាផ្លែព្រៃ ឬមេផ្លែព្រៃ បាជាផ្លែស្រុក ផ្សំគ្នា សាច់នៃផ្លែនោះមិនគួរ ដ្បិតថាផ្លែនោះ សេពជាតិពីរពួក ។ សាច់នៃទីឃជាតិ សត្វវែងមិនមានជើងចំពួកណាមួយ ទាំងអស់ឈ្មោះថាសាច់ពស់ មិនគួរ ។ សាច់រាជសីហ៍ជាដើមជារបស់ប្រាកដដោយពិត ។ សាច់មនុស្សដែលជាវត្ថុនៃថុល្លច្ច័យ ដូចពោលមកហើយខាងដើម ព្រះពុទ្ធអង្គទ្រង់ហាម ព្រោះមានជាតិស្មើគ្នា ។ សាច់ដំរី សាច់សេះ ទ្រង់ហាម ព្រោះជារាជយាន ។ សាច់ឆ្កែ សាច់ពស់ ទ្រង់ហាម ព្រោះជារបស់បដិកូល សាច់ ៥ យ៉ាង មានរាជសីហ៍ជាដើម ទ្រង់ហាម ដើម្បីមិនឲ្យបៀតបៀនខ្លួន ។ សូម្បីឆ្អឹងឈាមស្បែករោមនៃសត្វ ១០ ចំពួក មានមនុស្សជាដើមទាំងពួង មិនគួរទាំងអស់ ។ សាច់ទាំងអម្បាលនោះណាមួយ ភិក្ខុដឹងក្ដី មិនដឹងក្ដី ឆាន់គង់ត្រូវអាបត្តិ ។ ដឹងច្បាស់កាលណា គប្បីសំដែងអាបត្តិចេញក្នុងកាលនោះ ។ គិតថានឹងមិនសួរ ហើយទទួលដើម្បីនឹងឆាន់ ត្រូវទុក្កដ ព្រោះទទួល ។ ទទួលដោយគិតថានឹងសួរ ហើយទើបឆាន់ មិនត្រូវអាបត្តិ ។ តែសាច់ដែលគេសម្លាប់មកចំពោះភិក្ខុ ដឹងហើយឆាន់ ទើបត្រូវអាបត្តិ ។ បើមិនដឹងហើយឆាន់ មិនត្រូវអាបត្តិ ។

ខមួយទៀត ភិក្ខុដេកក្នុងវេលាថ្ងៃត្រូវបិទទ្វារ ។ ដ្បិតព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកក្នុងខន្ធកវគ្គថា អនុជានាមិ ភិក្ខវេ ទិវា បដិសល្លិយន្តេន ទ្វារំ សំវរិត្វា បដិសល្លិយិតុំ ដូច្នេះ ។ ព្រោះ

www.budinst.gov.kh www.elibraryofcambodia.org

ពាក្យនេះ កាលបើមិនបិទទ្វារដេកក្នុងវេលាថ្ងៃ លោកពោលថា ត្រូវទុក្កដ ។ ដ្បិតថាព្រះឧបាលិត្ថេរជាដើម លោកដឹងអធិប្បាយនៃព្រះពុទ្ធអង្គ តែងតាំងអដ្ឋកថាទុក ។ ដែលពោលថាត្រូវទុក្កដនោះ សម្រេចដោយពាក្យក្នុងបរិវារៈថា អត្ថាបត្តិ ទិវា អាបជ្ជតិ នោ រត្តិ អាបត្តិដែលភិក្ខុត្រូវតែក្នុងវេលាថ្ងៃ មិនត្រូវក្នុងវេលារាត្រី ដូច្នេះ ។ ទ្វារដូចម្តេចដែលត្រូវបិទ ? ទ្វារដូចម្តេចដែលមិនត្រូវបិទ ? ទ្វារដែលគេធ្វើដោយបន្ទះឈើ ឬដោយប្រជីស្លទាប ឬដោយបន្ទះផែង ឬដោយស្លឹកឈើណាមួយ បញ្ចូលទៅក្នុងដំណាប់ខាងក្រោម បញ្ចូលទៅក្នុងក្រវិលខាងលើ វិលទៅបាន ទ្វារដូច្នេះត្រូវបិទ ។ ទ្វារដទៃដូចទ្វារក្រោលគោ នឹងទ្វារប្រកបដោយដើងគុលសំកប់បិទស្រុក ទ្វារដែលគេប្រកបដោយក្រវិល ២ ឬ ៣ អន្ទើ ក្នុងផែនក្តារ ឬប្រជីស្លគេទៅមកបាន ទ្វារប្រជីស្លដែលគេវល់ទៀនដូចក្នុងកនផ្សារ ទ្វារបន្ទះឫស្សីដែលគេក្រងនូវបន្ទះឫស្សីក្នុងទី២អន្ទើ ៣ អន្ទើ ធ្វើទុកក្នុងបណ្តាកុដិក្តី ទ្វារសំពត់ក្តី ដូច្នេះមិនត្រូវបិទ ។ ឯក្នុងបទថាភិក្ខុមានបាត្រទៅក្នុងដៃ ប្រានសន្ទឹកទ្វារនោះ ទ្វារសំពត់មួយចំពួក មិនធ្វើឲ្យត្រូវអាបត្តិ ប្រានទ្វារក្រៅនោះត្រូវអាបត្តិ ។ ឯដេកក្នុងវេលាថ្ងៃ ទ្វារដែលវិលបានមួយយ៉ាង ធ្វើឲ្យត្រូវអាបត្តិ ទ្វារដ៏សេសនឹងបិទក្តី មិនបិទក្តី ដេកមិនត្រូវអាបត្តិ តែគប្បីបិទហើយដេកចុះ នេះជាវត្ត ។ ទ្វារដែលបង្វិលទៅបាន បិទដូចម្តេច ទើបនឹងបានហៅថាជាការបិទ ដាក់ចន្លាស់នឹងដាក់គន្លឹះជាដើមហើយ ឈ្មោះថាជាការបិទដោយ

www.budinst.gov.kh www.elibraryofcambodia.org

ប្រពៃ  ឯងកាស់ដៃបាស់ឯងគន្ធឹះ ដៃមួយយ៉ាំងក៏គួរ  ឬបង់ដៃល្មមឲ្យ មេទ្វារពាល់គ្នាបន្តិចក៏គួរ  ថយចុះសូម្បីមិនជិតគ្នាល្មមក្បាលចូលមិនបាន ក៏គួរ ៗ  បើជាទ្វារប្រើប្រាស់របស់មនុស្សប្រើខ្ជា  សូម្បីឯងផ្តាំកិច្ច ឬសាមណេរឲ្យជួយបិទហើយដេក  ក៏គួរ ៗ បើកិច្ចចាំងឲ្យយកអគ្គិយធ្វើ ចីវរកម្ម  ឬការងារដទៃ  សូម្បីឯងចង់ចិត្តថា កិច្ចចាំងអម្បាលនោះ គង់ ឯងជួយរក្សាទ្វារ  ហើយដេកក៏គួរ ៗ តែកុំអង្គុយបាកុរខ្វីថា  ឯងប្រាប់ សូម្បីផលសោភាសក  ឬចង់ចិត្តថា  គេគង់ឯងជួយថែទាំហើយដេកក៏គួរ ៗ ឯងផ្តាំទាំងកិច្ចទី  ឬស្ត្រី  មិនគួរ ៗ  បើជរណី  ឬក្រៅលានលើ ខ្ទទ្វារ  ថែកទ្វាក់ចេញ  ឬគេមិនទាន់បានផ្តុំ  មិនអាចបិទបាន  ឬគេ គរផ្ទួ  គរជី  ជាដើមទុកបៀតទ្វារ  ឬគេចង់រទ្ធាដើម្បីឯងធ្វើនវកម្មណា មួយ  មិនអាចបិទបាន មានអន្តរាយដូច្នេះ សូម្បីឯងមិនបិទហើយដេកក៏គួរ បើសទ្ធិកទ្វារនោះពុំមានសោក  ឈ្មោះថាបានកប្បៈដោយពិត  កាល ឯងដេកក្នុងជាន់ខាងលើ គប្បីលើកជណ្ដើរចេញសិន ទើបដេក គួរ ៗ បើ គ្រឿងបិទនៅក្បាលជណ្ដើរមានសោក គប្បីបិទសិនហើយដេកចុះ កាល បើឯងដេកក្នុងវល្លិង  បិទទ្វារវល្លិង  ឬទ្វារមុខណាមួយហើយដេកក៏គួរ ៗ បើផ្ទះជញ្ជាំងជាប់គ្នា គេធ្វើទ្វារខាងចាំង២ប្រើប្រាស់ គប្បីបិទទ្វារទាំង២ សូម្បីក្នុងប្រាសាទ ៣ ជាន់ ក៏ត្រូវបិទទ្វារដោយពិត ៗ  កិច្ចប្រើខ្ជឹង គ្នាត្រឡប់មកអំពីភិក្ខាចារ  ចូលទៅក្នុងប្រាសាទ  ដូចលោហប្រាសាទ ដើម្បីដេកក្នុងវេលាថ្ងៃ  ព្រះសង្ឃថេរគប្បីផ្តាំមនុស្សអ្នករក្សាទ្វារឲ្យបិទ

www.budinst.gov.kh  www.elibraryofcambodia.org

ធ្វើអាភោគចិត្តថា ឯការបិទទ្វារជាធុរៈរបស់គេ ហើយទើបចូលទៅដេក ចុះ គប្បីធ្វើយ៉ាងនេះ ត្រង់អង្គដេកបដិសល្លីនកៈ ។

មួយទៀត សូម្បីអ្នកចូលទៅមុននឹងធ្វើអាភោគចិត្តថា ការបិទទ្វារជាការៈរបស់មនុស្សខាងក្រោយក៏គួរ ។ កាលបើមិនផ្ដាំ ឬមិនធ្វើអាភោគចិត្ត ហើយចូលទៅដេកខាងក្នុងល្វែង ដែលមិនបានបិទទ្វារ ឬដេកខាងក្រៅល្វែង គង់ត្រូវអាបត្តិ ។ សូម្បីក្នុងវេលាកាលដេកក្នុងល្វែង ឬក្រៅល្វែងនឹងចងចិត្តថា ឯការបិទទ្វារជាការៈរបស់អ្នកចាំទ្វារ នៅទ្វារធំ ហើយដេកក៏គួរ ។ សូម្បីដេកក្នុងទីវាល ក្នុងលោហៈប្រាសាទជាដើម ត្រូវបិទទ្វារដោយពិត ។ សេចក្ដីសង្ខេបដូច្នេះ ដេកក្នុងវេលាថ្ងៃនេះ ពោលក្នុងទីដែលគេប្រកបទ្វារ នឹងបិទបាំងដោយវត្ថុណាមួយ ព្រោះហេតុនោះ កាលនឹងដេកក្នុងកណ្ដាលវាល ឬគល់ឈើ ឬម្លប់ទីកន្លែងណាមួយដែលគេប្រកបទ្វារ គប្បីបិទទ្វារសិន សឹមដេក ថាបើបរិវេណធំដូចលានមហាពោធិ៍ នឹងលានលោហៈប្រាសាទ ជាទីប្រជុំមនុស្សច្រើន ក្នុងទីឯណា សូម្បីនឹងបិទទ្វារ ក៏មិនបានឈ្មោះថាបិទ មនុស្សទាំងឡាយមិនបានចូលតាមទ្វារ រមែងឡើងលើកំពែងដើរទៅ ក្នុងទីដូច្នោះ កិច្ចដែលនឹងបិទមិនមាន ។ បើកទ្វារដេកក្នុងវេលាយប់ អរុណរះឡើងមក ក្រោកឡើងមិនត្រូវអាបត្តិ បើភ្ញាក់ហើយត្រឡប់ដេកថែមទៀត ក៏ត្រូវអាបត្តិ ។ ភិក្ខុណាកំណត់ទុកថា អរុណរះឡើងមកយើងនឹងក្រោក ហើយបើកទ្វារដេកក្នុងវេលាយប់ មិនបានក្រោកឡើងតាមកំណត់ ត្រូវអាបត្តិដល់ភិក្ខុ

www.budinst.gov.kh www.elibraryofcambodia.org

នោះដោយពិត ៗ តែក្នុងមហាបច្ចរីពោលថា កាលបើដេកយ៉ាំងនេះមិនរួចអំពីទុក្កដ ៗ បើភិក្ខុណាក្នុងវេលាយប់បដិបត្តិសមណធម៌ច្រើន ហើយដើរផ្លូវហាលថ្ងៃនឿយណាស់ អង្គុយលើគ្រែមិនឲ្យជើងផុតអំពីផ្ទៃឡើយដេកលក់ទៅ មិនមានអាបត្តិដល់ភិក្ខុនោះ បើភិក្ខុដេកលក់ហើយសូម្បីមិនដឹង លើកជើងឡើងលើគ្រែ ត្រូវអាបត្តិពិត ៗ អង្គុយផ្អែកលក់ទៅមិនមានអាបត្តិ ៗ ភិក្ខុណាគិតនឹងបន្ទោបង់នូវងងុយ ដើរចង្ក្រមដួលចុះ ហើយក្រោកឡើងដោយប្រញាប់ មិនមានអាបត្តិដល់ភិក្ខុនោះ ៗ បើភិក្ខុណាដួលចុះហើយដេកបណ្តោយក្នុងទីនោះមិនក្រោកឡើង មានអាបត្តិដល់ភិក្ខុនោះ ៗ ភិក្ខុណារួចចាកអាបត្តិ? ភិក្ខុណាមិនរួចចាកអាបត្តិ? ក្នុងមហា-បច្ចរីពោលថា ភិក្ខុដេកសំយុងជើង មិនលើកជើងឲ្យផុតចាកផ្ទៃប៉ុណ្ណោះរួចចាកអាបត្តិបាន ។ ភិក្ខុលើកជើងឲ្យផុតចាកផ្ទៃហើយដេក សូម្បីសន្លប់ទៅ ក៏មិនរួចចាកអាបត្តិបាន ៗ តែក្នុងមហាអដ្ឋកថា ព្រះមហាបទុ-មត្ថេរពោលថា អ្នកដើរចង្ក្រមងុយងប់ដួលចុះទៅក្នុងទីនោះ អាបត្តិមិនមានដល់លោកនោះ ព្រោះមិនមែនជាវិស័យ តែអាចារ្យទាំងឡាយមិនបានពោលយ៉ាំងនោះ ព្រោះហេតុនោះ ជាអាបត្តិពិត ៗ តែភិក្ខុខ្មោចចូលនឹងភិក្ខុដែលគេចងឲ្យដេកទៅ ពីរនេះរួចចាកអាបត្តិ ៗ ក្នុងអដ្ឋកថាកុរុន្ទីថា បើភិក្ខុខ្មោចចូលនឹងភិក្ខុដែលគេចងឲ្យដេក ពីរពួកនេះ ទើបរួចចាកអាបត្តិបាន ៗ តាំងអំពីមើលរបាំស្តាប់ច្រៀងមក រហូតដល់ព្រះពុទ្ធបញ្ញត្តិនេះជាអចិត្តកៈ សូម្បីមិនដឹងក្តី បើប្រព្រឹត្តកន្លងក៏ត្រូវអាបត្តិ ៗ មួយទៀត

www.budinst.gov.kh www.elibraryofcambodia.org

គន្ថព្ពកសិក្ខាបទដែលជាសចិត្តកៈមុន ៈរៀនតិរច្ឆានវិជ្ជា ប្រាប់តិរច្ឆានវិជ្ជា ពីរនេះក្នុងបាចិត្តិយនៃភិក្ខុនី ជាអចិត្តកៈ តែក្នុងមូលសិក្ខាពាក់ជាសចិត្តកៈ ដែលកំណត់សិក្ខាបទជាសចិត្តកៈនិងអចិត្តកៈនេះ តាមបែបក្នុងមូលសិក្ខា តែក្នុងសចិត្តកសិក្ខាបទ សិក្ខាបទទ្វះមិនមានក្នុងមូលសិក្ខា គ្រាន់តែសង្កេតឃើញថាជាសចិត្តកៈហើយពោលទុក ដើម្បីនឹងមិនឲ្យខ្វល់ជាប់ ។ អ្នកប្រាជ្ញ (អ្នកមានបញ្ញា) គប្បីផ្ទៀងផ្ទាត់ពិនិត្យមើលយកចុះ ។

អចិត្តកបញ្ញត្តិកថា ចប់

## វិញ្ញត្តិកថា

ពោលអំពីការសូម ដែលមកក្នុងអដ្ឋកថានៃកុដិការសិក្ខាបទ ។

សេចក្តីថា នឹងសូមបុរសមកជាប់ថ្ងៃមិនគួរ ។ សូមដើម្បីជាសំឡាញ់ដើម្បីធ្វើការក៏គួរ ។ នឹងសូមហត្ថកម្មកម្លាំងដៃក៏គួរ ។ ឯហត្ថកម្មនេះជាតែអ្វីក៏ដោយ ព្រោះហេតុនោះ ហត្ថកម្មទាំងអស់ លើកតែកម្មរបស់ព្រានម្រឹគ ព្រានបក្សី ជាដើមចេញ ក្រៅនោះគួរទាំងអស់ ភិក្ខុទៅដល់ហើយគេសួរក្តី មិនសួរក្តី នឹងសូមក៏គួរ ដែលជាៈទាសព្រោះវិញ្ញត្តិក៏មិនមាន ។ ព្រោះហេតុនោះ កុំគប្បីសូមហត្ថកម្មមិននិយម នឹងព្រានម្រឹគជាដើមថា អ្នកចូរឲ្យហត្ថកម្ម ព្រោះថាសូមមិននិយមដូច្នេះ គេនឹងគប្បីបញ្ជូនភិក្ខុទៅហើយ សម្លាប់ម្រឹគនាំមកឲ្យ ។ គប្បីសូមមាននិយមថាការដែលគួរគប្បីធ្វើក្នុងវត្តមាន អ្នកចូរឲ្យហត្ថកម្មក្នុងការនោះ ដូច្នេះចុះ ។

www.budinst.gov.kh www.elibraryofcambodia.org

អ្នកប្រែគេកាន់គ្រឿងឧបការៈមានផាលនឹងនង្គ័លជាដើម ដើម្បីនឹងភ្ជួរ ឬព្រោះ ឬច្រូត ឬគេខ្វល់ខ្វាយក្នុងកិច្ចរបស់គេហើយ ឬមនុស្សពួកដទៃ នឹងសូមហត្ថកម្មនឹងគេ ក៏គួរដោយពិត ៗ មនុស្សស៊ីថ្លៃ ឬមនុស្សដទៃ មិនមានការងារ ពោលតែពាក្យលេងមិនមានប្រយោជន៍ ឬចូលចិត្តតែដេក មនុស្សដូច្នេះ សូម្បីមិនសូម នឹងប្រើឲ្យធ្វើតាមប្រាថ្នាក៏គួរ ៗ គាថាឲ្យតាំងឡាយសំដែងក្នុងយានិទុក ដើម្បីប្រកាសហត្ថកម្មថាគួរ ដូច្នេះថា បើភិក្ខុប្រាថ្នានឹងឲ្យគេធ្វើប្រាសាទសោត ត្រូវការដោយសសរ គប្បីទៅកាន់ផ្ទះជាងសិលាពោលថា ម្នាលឧបាសក ឲ្យហត្ថកម្មដ៏គួរ គេសួរថា នឹងគប្បីធ្វើនូវរបស់អ្វី គប្បីប្រាប់ថាអ្នកចូរជួយរើសសរសិលាឡើងឲ្យ ថាបើគេរើឡើងឲ្យ ឬគេឲ្យសសរដែលគេរើឡើងទុកស្រាប់ ក៏គួរ ថាបើគេពោលថា ឱកាសដើម្បីនឹងធ្វើនូវកម្មមិនមាន លោកចូរឲ្យអ្នកដទៃរើឡើងចុះ ខ្ញុំនឹងឲ្យថ្លៃឲ្យដល់គេ ក៏គួរឲ្យអ្នកដទៃរើឡើងហើយប្រាប់ថាអ្នកចូរឲ្យថ្លៃឲ្យដល់អ្នករើចុះ ដូច្នេះក៏គួរ ដោយឧបាយនោះ ត្រូវការដោយឈើធ្វើប្រាសាទនឹងទៅរកជាងឈើ ត្រូវការឥដ្ឋនឹងទៅរកជាងឥដ្ឋ ត្រូវការគ្រឿងប្រក់នឹងទៅរកជាងប្រក់ ត្រូវការចិត្តកម្មទៅរកជាងគំនូរ ត្រូវការរបស់អ្វីនឹងទៅរកជាងពួកនោះដូច្នេះ ហើយសូមហត្ថកម្មក៏គួរ ៗ ជៀកសូមហត្ថកម្ម សូម្បីបានជាប់ថ្លៃមក ឬបានថ្លៃឈ្នួលដែលជាកប្បិយមក នឹងទទួលក៏គួរ នឹងឲ្យគេយករបស់មកអំពីព្រៃ គប្បីឲ្យគេយករបស់តាំងពួនដែលមិនមានម្ចាស់របស់ហួងហែងមក មិនមែនតែឲ្យគេធ្វើប្រាសាទមួយយ៉ាង

www.budinst.gov.kh www.elibraryofcambodia.org

ឡើយ សូម្បីទឹកឲ្យគេធ្វើក្រែ តាំង បាត្រ សំពត់ជម្រះទឹក ធម្មក្រក ចីវរជាដើម បានរបស់មានឈើ និងលោហៈ និងអំបោះ ជាដើមហើយ គប្បីទៅរកជាងចំពូកនោះៗ ហើយសូមហត្ថកម្ម ដូចពោលហើយនោះចុះ ថ្បិតសូមហត្ថកម្មបានមកជាថ្លៃ ឬបានថ្លៃឈ្នួលជាកប្បិយមកតាំងតួង គប្បីទទួលចុះ ថាបើជាងគេមិនចង់ធ្វើ គេប្រាថ្នាថ្លៃឈ្នួលសោតរបស់ជាអកប្បិយ មានកហាបណៈជាដើម កុំគប្បីឲ្យ និងស្វែងរកអគ្គជាដើមដោយភិក្ខាចារវត្តហើយឲ្យគំគួរ ៗ ឲ្យគេធ្វើបាត្រថ្មី ឬឲ្យគេដុតបាត្រថ្មី ដោយសូមហត្ថកម្មហើយ ត្រូវការប្រេងលាបបាត្រដែលដុតថ្មី ចូលទៅក្នុងភូមិដើម្បីប្រយោជន៍ដល់ប្រេងលាបបាត្រ គេសំគាល់ថាមកបិណ្ឌបាត គេបង្អោនបបរ ឬបាយចូលមក គប្បីយកដៃបិទបាត្រ បើឧបាសិកាគេសួរថា ហេតុអ្វីទើបបិទបាត្រ គប្បីប្រាប់ថា បាត្រដុតថ្មីត្រូវការប្រេងលាប បើគេទទួលយកបាត្រទៅលាបប្រេងហើយ នាំមកប្រគេន ព្រមទាំងបបរនិងបាយ មិនឈ្មោះថាជាវិញ្ញត្តិ គួរទទួល ៗ

ភិក្ខុទៅបិណ្ឌបាតអំពីព្រឹក ទៅកាន់រោងទាន មិនឃើញអាសនៈក៏ឈរនៅ ឧបាសិកាទាំងឡាយ គេឃើញឈរនៅ គេឲ្យមនុស្សនាំអាសនៈមកក្រាល បើអង្គុយហើយ កាលនឹងទៅគប្បីប្រាប់មុនហើយសឹមទៅ សូម្បីមិនបានប្រាប់មុនហើយទៅ អាសនៈបាត់ទៅ ត្រូវសងគេ ឯប្រាប់មុនហើយទើបទៅជាវត្ត ៗ ថាបើភិក្ខុប្រើឲ្យគេនាំអាសនៈមក ទើបគេនាំមក កាលនឹងទៅគប្បីប្រាប់មុន ហើយសឹមទៅ មិនប្រាប់មុនហើយ

www.budinst.gov.kh www.elibraryofcambodia.org

ជៀសទៅជាវត្ថុគេចផង បាត់ទៅត្រូវសងគេផង សូម្បីក្នុងគ្រឿងក្រោល ដទៃ ៗ ក៏ដូចគ្នា ។

បើមានខមមង់ច្រើន គប្បីពោលថា អ្នកចូរយកផ្លិតបក់មមង់មក ឬ យកមែកស្ដៅជាដើមមក គប្បីឲ្យគេធ្វើកប្បិយមុនសិន សឹមទទួល ។

ភាជនៈទឹកក្នុងរោងឆាន់ទទេ មិនមានទឹក កុំគប្បីពោលថាអ្នកចូរកាន់ យកធម្មក្រក ដោយហេតុថា គេហាប់ធម្មក្រកផ្អៀងចុះក្នុងភាជនៈទទេ ទឹងគប្បីបែកទៅ បើទៅកាន់ស្ទឹងឬបឹងទឹងពោលថា អ្នកចូរនាំទឹកមកក៏គួរ ទឹងពោលថាអ្នកចូរនាំទឹកមកអំពីផ្ទះ មិនគួរឡើយ កាលបើគេនាំមក អំពីផ្ទះដោយបង្អាប់ដូច្នោះ កុំឆាន់ ។

ធ្វើភត្តកិច្ចក្នុងរោងឆាន់ឬក្នុងព្រៃ ទឹងប្រើអ្នកធ្វើការណាមួយឲ្យយក ស្លឹកឈើឬផ្លែឈើដែលគួរជាអន្លក់ណាមួយ ដែលកើតក្នុងទីនោះ មិន មានអ្នកណាហួងហែងមក ដោយសូមហត្ថកម្មហើយទើបឆាន់ក៏គួរ តែ កុំប្រើភិក្ខុឬសាមណេរដែលជាគលដ្ឋិឲ្យធ្វើហត្ថកម្ម ដូច្នេះជាបែបយ៉ាងក្នុង ហត្ថកម្ម ។

ទឹងឲ្យគេនាំគោមកអំពីទីមិនមែនជាញាតិ មិនមែនបវារណា មិនគួរ កាលបើឲ្យគេនាំមកត្រូវទុក្កដ ។ ទឹងសូមអំពីញាតិ អំពីមនុស្សបវារណា ដើម្បីឲ្យជាប់ថ្លៃមិនគួរ ទឹងសូមខ្ចីមកគួរក្នុងទីតាំងតួង ៗ ខ្ចីគោគេមក ដូច្នោះហើយ គប្បីរក្សាថែចាំហើយប្រគល់ឲ្យម្ចាស់របស់វិញ ថាបើជើងឬ ស្នែងនៃគោនោះបាក់ទៅ ឬគោបាត់ទៅ បើម្ចាស់របស់គេទទួលក៏ជាការ

www.budinst.gov.kh www.elibraryofcambodia.org

ល្អ បើគេមិនទទួលក៏ជាសំណាង បើគេពោលថា ខ្ញុំអម្ចាស់ថ្វាយដល់លោកតែម្តង កុំគប្បីទទួល បើគេថាខ្ញុំថ្វាយដល់វិហារ គប្បីប្រាប់ថា អ្នកចូរប្រាប់មនុស្សរក្សាវត្ត ដើម្បីឲ្យគេរក្សាថែទាំចុះ សូម្បីនឹងពោលជាមួយមនុស្សមិនមែនញាតិ មិនមែនបវារណាថា អ្នកចូរឲ្យរទេះដូច្នេះ មិនគួរ ជាវិញ្ញត្តិ ត្រូវទុក្កដ ។ សូមអំពីញាតិនិងមនុស្សបវារណាគួរ នឹងខ្ចីក៏គួរ ធ្វើការហើយគប្បីប្រគល់ឲ្យគេវិញ ជាបើគង់ជាដើមបាក់ទៅគប្បីធ្វើឲ្យជាប្រក្រតីហើយប្រគល់ឲ្យ កាលបើបាត់ទៅជាសំណាង កាលបើគេថា ថ្វាយដល់លោកតែម្តង ឈ្មោះថាជាគ្រឿងឈើ នឹងទទួលក៏គួរ សូម្បីកាំបិតនឹងប៉ូវថៅ ចបជីក ចបកាប់ ដែកស្ទាន ក៏ដូចគ្នា វល្លិ៍ជាដើមដែលមនុស្សដទៃហួងហែងទុក ល្មមជាគរុភណ្ឌបាន ឈ្មោះថាជាវិញ្ញត្តិ តូចចុះទៅជាងនោះ មិនជាវិញ្ញត្តិ តែនឹងឲ្យគេយកវត្ថុណាមួយ ដែលមិនមានមនុស្សហួងហែងទុកក៏គួរ ព្រោះថា ពាក្យពោលជាវិញ្ញត្តិនោះបានក្នុងរបស់ដែលគេរក្សា និងហួងហែងទុកមួយយ៉ាង ។

បច្ច័យពីរ គឺ ចីវរនឹងបិណ្ឌបាត វិញ្ញត្តិការសូមមិនគួរដោយប្រការទាំងពួង ។ ឯក្នុងសេនាសនបច្ច័យ សូមថាអ្នកចូរយកមកឲ្យមួយយ៉ាងមិនគួរ បើពោលថា បរិកថា ឱភាស និមិត្តកម្ម ក៏គួរ ។

ចង់បានកើតឧបោសថ ឬរោងឆាន់ ឬសេនាសនៈណាមួយ ពោលពាក្យបញ្ចៀងថា ក្នុងឱកាសនេះនឹងធ្វើសេនាសនៈ ដូច្នេះគួរឬ ដូច្នេះឈ្មោះថាបរិកថា ។ សួរឧបាសកថា អ្នកនៅក្នុងទីណា គេប្រាប់ថានៅ

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងប្រាសាទ ពោលតទៅទៀតថា ប្រាសាទមិនគួរដល់ភិក្ខុនេះទេ ដូច្នេះឈ្មោះថាឱភាស ។ បើញោមនុស្សមក ឲ្យគេទាញខ្សែនឹងឲ្យគេ ចោះច្បោះ នេះសួរថា លោកម្ចាស់នឹងធ្វើអ្វី ពោលថា នឹងធ្វើការស ក្នុងទីនេះ ធ្វើការដូច្នេះជាដើម ឈ្មោះថានិមិត្តកម្ម ។ ក្នុងគិលាន-ប្បច្ច័យ សូម្បីវិញ្ញត្តិ សូមគេក៏គួរ ។ បរិកថាជាដើមមិនត្រូវពោល ។

វិញ្ញត្តិកថា ចប់

## មេណ្ឌកបញ្ញត្តិ

ខមួយទៀត ព្រះពុទ្ធអង្គ ទ្រង់អនុញ្ញាតទុកក្នុងមេណ្ឌកបញ្ញត្តិ ថា សន្តិ ភិក្ខវេ មគ្គា កន្តារា អប្បោទកា អប្ប-ភក្ខា ន សុករា អបាថេយ្យេន គន្តុំ ។ អនុជានាមិ ភិក្ខវេ បាថេយ្យំ បរិយេសិតុំ ។ល។ សន្តិ ភិក្ខវេ មនុស្សា សទ្ធា បសន្នា តេ កប្បិយការកានំ ហត្ថេ ហិរញ្ញសុវណ្ណំ ឧបនិក្ខិបន្តិ ។ល។ អនុជានាមិ ភិក្ខវេ យំ តតោ កប្បិយំ តំ សាទិតុំ ។ល។ វទាមិ

ម្នាលភិក្ខុទាំងឡាយ បើមានការដើរផ្លូវដាច់ស្រយាល ដែលមានទឹកតិច មានភក្ខាហារតិច ដែលអ្នកគ្មានស្បៀងមិនអាចនឹងទៅបាន តថាគត អនុញ្ញាតឲ្យភិក្ខុស្វែងរកស្បៀងបាន ត្រូវការដោយអង្ករ ស្វែងរកអង្ករបាន ត្រូវការដោយអំបិល ស្វែងរកអំបិលបាន ត្រូវការដោយសណ្ដែកបាយ

សុវណ្ណកកដមាស ទឹកអំពៅ ប្រេង ឬសប្បិ ស្វែងរកវត្ថុមានសុវណ្ណក ថ្វាយជាដើមបាន តាមត្រូវការចុះ ។ ម្នាលភិក្ខុទាំងឡាយ បើមាន មនុស្សទាំងឡាយដែលមានសទ្ធាជ្រះថ្លា គេទុកដាក់ប្រាក់និងមាសក្នុង ដៃនៃកប្បិយការកទាំងឡាយថា វត្ថុណាគួរដល់លោកម្ចាស់ អ្នកចូរ ប្រគេននូវវត្ថុនោះ ដោយទ្រព្យនេះចុះ ដូច្នេះ ។ តថាគតអនុញ្ញាត ឲ្យភិក្ខុត្រេកអរចំពោះវត្ថុជាកប្បិយ (ដែលកើត) អំពីមាសប្រាក់នោះបាន ម្នាលភិក្ខុទាំងឡាយ តែថា តថាគតមិនពោលថា ត្រូវអ្នកត្រេកអរ ត្រូវអ្នកស្វែងរកមាសនិងប្រាក់ដូច្នេះ ដោយបរិយាយណាមួយឡើយ ក្នុងការស្វែងរកស្បៀងនោះ ។ អដ្ឋកថា ពោលថាបើតាយកចំពូក ខ្ទះគេជីក គេថ្វាយឯងក៏ជាការល្អ បើគេមិនថ្វាយសោត គប្បីស្វែង រកអំពីញាតិ អំពីមនុស្សបវារណា ឬដោយភិក្ខាចារវត្ត ។ កាល បើមិនបានដោយប្រការដូច្នេះ អដ្ឋកថាចារ្យលោកពោលថា គប្បីសូម អំពីបុគ្គលមិនមែនញាតិ មិនមែនបវារណា កាន់យកចុះ ។ ផ្លូវនឹងគប្បីទៅ ត្រឹមមួយថ្ងៃ គប្បីស្វែងរកដើម្បីថ្វាយក្នុងមួយវេលា ។ ផ្លូវដាច់ស្រយាល ឆ្ងាយ ជាផ្លូវកន្តារៈ ស្បៀងប៉ុន្មានទើបល្មមគ្រាន់ ស្វែងរកប៉ុណ្ណោះបាន ។ ក្នុងកប្បិយការកទទួលមាសប្រាក់ទុកនោះ បើម្ចាស់របស់ដើមគេប្រាប់ឲ្យ ភិក្ខុដឹង ឬគេប្រើទូតឲ្យទៅប្រាប់ ភិក្ខុមិនត្រេកអរនឹងដំរៀ ត្រេកអរ តែកប្បិយភណ្ឌមួយយ៉ាង នឹងតារសូម្បីមួយពាន់ដងក៏គួរ មិនមានកំណត់ រួចក្នុងកជសិក្ខាបទ ។ បើកប្បិយការកនោះ គេមិនឲ្យកប្បិយភណ្ឌ លោក គប្បីតាំងមនុស្សដទៃឲ្យជាកប្បិយការកនាំមកក៏បាន បើភិក្ខុ

www.budinst.gov.kh www.elibraryofcambodia.org

នៅចង់បាន ក៏គប្បីប្រាប់ដល់ម្ចាស់របស់ដំបូងដើម បើមិនចង់បានសោត ក៏គប្បីប្រាប់ទៀត កប្បិយការកដែលម្ចាស់ដំបូងមិនបានប្រាប់ដល់ភិក្ខុ ឬមិនបានផ្តាំទុកឲ្យប្រាប់ដល់ភិក្ខុ គ្រាន់តែគេឲ្យគ្នាឯងចំពោះមុខភិក្ខុ ឬកំបាំងមុខភិក្ខុហើយគេក៏ទៅ ក្នុងកប្បិយការកដូច្នេះ គប្បីបដិបត្តិដូចមនុស្សមិនមែនញាតិ មិនមែនបវារណា បើគេឲ្យកប្បិយភណ្ឌដោយខ្លួនឯង ក៏គប្បីទទួល បើគេមិនឲ្យ ក៏គប្បីពោលពាក្យអ្វីឡើយ ។

មេណ្ឌកបញ្ញត្តិ ចប់

## គោបកទានកថា

ខមួយ ទ្រង់អនុញ្ញាតទុកក្នុងវិធីតវតនៃអទិន្នាទានថា អនាបត្តិ ភិក្ខវេ គោបកស្ស ទានេ ថាមិនត្រូវអាបត្តិ ព្រោះមនុស្សរក្សាសួនគេឲ្យ ។ អ្នករក្សាសួនគេឲ្យដូចម្តេចទើបគួរ? ឲ្យដូចម្តេចមិនគួរ? ព្រះមហាសុមនត្ថេរពោលថា របស់ណាមួយម្ចាស់របស់គេកំណត់ឲ្យមនុស្សអ្នករក្សាថា អ្នកចូរកាន់យកតែប៉ុណ្ណេះសព្វថ្ងៃ ។ របស់នោះគួរ ច្រើនលើសជាងនោះមិនគួរ ។ តែព្រះមហាបទុមត្ថេរពោលថា ម្ចាស់របស់គេធ្វើសំបុត្រ ឬធ្វើនិមិត្តកំណត់ឲ្យដល់មនុស្សអ្នកនៅរក្សា ឬម្ចាស់របស់គេប្រគល់ឲ្យជាធំ ក្នុងរបស់ដែលគេលះទុកក្នុងដៃនៃអ្នករក្សា ព្រោះហេតុនោះ មនុស្សអ្នករក្សាឲ្យរបស់ណា របស់នោះសូម្បីច្រើនក៏គួរ ។ ក្នុងអដ្ឋកថាកុរុន្ទីពោលថា ក្នុងភ្នំរក្សាសួនឬផលាផលដំរៃ ជារបស់មនុស្ស

របស់ដែលគេនាំឱ្យនោះក៏គួរ តែកុំបង្គាប់ឱ្យគេនាំយកមកឱ្យ ។ អ្នករក្សាសួនរបស់សង្ឃឬរបស់ចេតិយ កាលបើទៅនោះរក្សា គេឱ្យក៏គួរ អ្នកស៊ីឈ្នួលរក្សាឱ្យតែចំណែកដែលដល់ខ្លួនទើបគួរ ។ ក្នុងមហាបច្ចរី ថាមនុស្សរក្សាសួននៃគ្រហស្ថ គេឱ្យចំណែកណាដល់ភិក្ខុ ចំណែកនោះគួរ ឯមនុស្សជាអ្នករក្សាសួនរបស់សង្ឃ គេចែងចំណែករបស់ណាអំពីថ្លៃឈ្នួលខ្លួនមកឱ្យ ចំណែកនោះទើបគួរ សូម្បីអ្នកណាស៊ីឈ្នួលរក្សាសួន ពាក់កណ្តាលចំណែក ឬដើមឈើមួយដើម អ្នកនោះឱ្យចំណែកអំពីដើមឈើដែលដល់ខ្លួនទើបគួរ បើអ្នករក្សាសួននោះរក្សាហើយឱ្យ គួរទាំងអស់ពាក្យទាំងអម្បាលនោះផ្សេងអំពីគ្នាតែព្យញ្ជនៈ ឯសេចក្តីក៏ដូចគ្នា ព្រោះហេតុនោះ អ្នកមានបញ្ញាគប្បីជ្រាបអធិប្បាយ កាន់យកចុះ ។

មួយទៀត គប្បីជ្រាបវិនិច្ឆ័យ ក្នុងការបរិភោគផលដូច្នេះ ក្នុងទីណាទៅអាក់សមិនឱ្យដល់អាគន្តុកៈ កាលបើករៈផ្លែឈើដល់ហើយ ឃើញថាភិក្ខុដទៃមិនមាន ទើបចែកគ្នាឆាន់តែពួកខ្លួនក្នុងទីនោះ អាគន្តុកៈទាំង-ឡាយ នឹងក់យកគាំងនេះហើយចែកគ្នាឆាន់ក៏គួរ ក្នុងទីណាទៅអាក់សរក្សាដើមឈើ កាលបើករៈផ្លែឈើចូលមកដល់ហើយចែកគ្នាឆាន់ នឹងបង្អួនចូលទៅដោយប្រពៃក្នុងបច្ច័យទាំង ៤ ក្នុងទីនោះ អាគន្តុកៈមិនបានជាធំ ។ សូម្បីដើមឈើណាគេនិយមថ្វាយដើម្បីជាជំនៀវចីវរ ដើមឈើនោះអាគន្តុកៈ ក៏មិនបានជាធំ ក្នុងដើមឈើដែលគេនិយមថ្វាយដើម្បីជាជំនៀវមទុំយដ៏សេស ក៏ដូចគ្នាដែរ ។ តែដើមឈើណាគេមិនបាននិយមដូច្នោះ

www.budinst.gov.kh www.elibraryofcambodia.org

តែទៅកាត់សក្ររហូតហែងដើមឈើនោះ លុះចាស់ផ្លែក្នុងដើមឈើនោះ ភាគទុក:កុំឲ្យតាំងនៅក្នុងកត្តិកាខែទៅអាកាសទៀត ៗ ដើមឈើណា គេនិយមថ្វាយដើម្បីបរិភោគផ្លែ តែទៅកាត់សក្ររហូតហែងទុក ហើយបង្អោនចូលទៅដោយប្រពៃក្នុងបច្ច័យ ក្នុងដើមឈើនោះ ភាគទុក:ឲ្យតាំងនៅក្នុងកត្តិកាខែទៅអាកាស ៗ តែក្នុងមហាបច្ច័យ ជាដើមឈើគេនិយមថ្វាយដើម្បីបច្ច័យ ៤ បើលួចចាន់ដោយថេយ្យចិត្ត ឲ្យវិនិយធរគប្បីអាយថ្លៃរបស់ហើយកាត់ទោសក្នុងដល់ភិក្ខុ កាលបើភិក្ខុចែកគ្នាចាន់ដោយអំណាចបរិភោគ ជាកណ្ឌទេយ្យ តែដើមឈើណាគេនិយមដើម្បីសេនាសនៈ ដើមឈើនោះ កាលបើចែកគ្នាចាន់ដោយអំណាចបរិភោគ ត្រូវថុល្លច្ច័យផង ជាកណ្ឌទេយ្យផង ៗ ដើមឈើគេឧទ្ទិសថ្វាយដើម្បីជាដំរៃចីវរ គប្បីបង្អោនចូលទៅក្នុងចីវរតែមួយយ៉ាង ៗ បើស្រូវថ្លៃ ភិក្ខុលំបាកដោយបិណ្ឌបាត តែចីវរកបានងាយ ខិនធ្វើអបលោកនកម្មដើម្បីសង្ឃឃើញជាប្រពៃ ហើយបង្អោនចូលទៅក្នុងបិណ្ឌបាតក៏គួរ ៗ កាលបើភិក្ខុលំបាកដោយសេនាសនៈ ឬគិលានប្បច្ច័យ ខិនធ្វើអបលោកនកម្មដើម្បីសង្ឃឃើញជាល្អ ហើយបង្អោនចូលទៅដើម្បីបច្ច័យនោះក៏គួរ ៗ សូម្បីរបស់គេឧទ្ទិសថ្វាយ ដើម្បីជាដំរៃបិណ្ឌបាតឬគិលានប្បច្ច័យ ក៏ដូចគ្នាយ៉ាងនោះ ៗ តែរបស់គេឧទ្ទិសថ្វាយ ដើម្បីជាដំរៃសេនាសនៈជាគរុភណ្ឌ គប្បីរក្សាហ្លួនតែងទុក ហើយបង្អោនចូលទៅដើម្បីសេនាសនៈប៉ុណ្ណោះ បើស្រូវថ្លៃ ភិក្ខុទាំងឡាយចាំញុំមិនតែដោយបិណ្ឌបាតមិនបាន ភិក្ខុទាំង

www.budinst.gov.kh www.elibraryofcambodia.org

ផល្លាលនោះចេញទៅកាន់ទិសនៃព្រោះកថភ័យ រោគភ័យ ចោរភ័យក្តី វិហារនោះវិនាសទៅ មនុស្សទាំងឡាយធ្វើភ្លោកនឹងដូងជាដើមឲ្យវិនាសផង តែបើបានអាស្រ័យសេនាសនបច្ច័យអាចចិញ្ចឹមជីវិតក្នុងកាលដូច្នេះ សូម្បីនឹងលះសេនាសនបរិភោគ ដើម្បីនឹងប្រតិបត្តិថែទាំសេនាសនៈ ព្រះពុទ្ធអង្គទ្រង់អនុញ្ញាត ។ ព្រោះហេតុនោះ សេនាសនៈ១ឬ២ដែលអាក្រក់ លើកតែសេនាសនៈដែលល្អចេញ គួរនឹងលះដើម្បីជាជំនៀសបិណ្ឌបាត តែកុំធ្វើឲ្យដាច់ថ្លៃ តែចំណែកណាដែលគេនិយមថ្វាយដើម្បីបច្ច័យទាំង៤ ក្នុងចំណែកនោះ មិនគួរធ្វើអបលោកនកម្ម ខ្វះខាតដោយបច្ច័យណា នឹងបង្អោនទៅដើម្បីបច្ច័យនោះគួរ ។ អ្នកដទៃបដិបត្តិថែទាំសួន សូម្បីនឹងឲ្យថ្លៃឈ្នួលដល់គេ ឲ្យគេប្រតិបត្តិថែទាំក៏គួរ ។ អ្នកណាបានថ្លៃឈ្នួលហើយធ្វើផ្ទះនៅក្នុងអារាមហើយរក្សាសួន បើអ្នកនោះឲ្យផ្លែដូង ឬផ្លែត្នោតដល់ភិក្ខុដែលមកដល់ ចំណែកណាដែលសង្ឃអនុញ្ញាតឲ្យដល់អ្នកនោះ ថាអ្នកចូរស៊ីតែប៉ុណ្ណោះសព្វថ្ងៃ អ្នកនោះឯងចំណែកនោះបាន សូម្បីអ្នកនោះនឹងឲ្យច្រើនឡើងទៅជាងនោះ ទទួលនគួរ ។ តែអ្នកណាជួលទៅហើយឲ្យកប្បិយភណ្ឌដល់សង្ឃដើម្បីច្ច័យ ៤ អ្នកនោះនឹងឲ្យសូម្បីច្រើនក៏បាន សូម្បីសួនគេថ្វាយដល់ចេតិយដើម្បីជាជំនៀសប្រទីប ឬសម្រាប់ជួសជុលខូចទីបាក់បែក ត្រូវតិបត្តិថែទាំឬឲ្យឈ្នួលឲ្យគេប្រតិបត្តិថែទាំតែក្នុងសួននោះ មិនឲ្យឈ្នួលដែលជារបស់ចេតិយនឹងសង្ឃក៏គួរ ។ អ្នកនៅរក្សាសួនដោយឈ្នួលនឹងអ្នក

www.budinst.gov.kh www.elibraryofcambodia.org

ផលសុខ ឲ្យគប្បីយកណ្ដាក្ដី ប៉ុគេឲ្យផ្លែឈើដែលកើតក្នុងសួននោះក្ដី ឲ្យគប្បីធ្វើដោយន័យដូចសំដែងមកហើយនោះចុះ ។

គោបកទានកថា ចប់

## អារក្ខាយាចនកថា

ពណ៌នាអំពីធម្មិការក្ខា ដែលមានមកក្នុងអនាបត្តិវារៈនៃភិក្ខុនី បឋមសង្ឃាទិសេស ។

សេចក្ដីថា ភិក្ខុកាលបើនឹងសូមអារក្ខា គឺការរក្សាត្រូវតាមគន្លងធម៌ មិនប្រារព្ធកាលជាអតីតឬអនាគត ប្រាប់ចំពោះខ្លួនមិនគួរ ប្រារព្ធកាលជាអតីត ប្រាប់ចំពោះក៏មាន មិនចំពោះក៏មាន ប្រារព្ធកាលជាអនាគត ប្រាប់ចំពោះក៏មាន មិនចំពោះក៏មាន ក្រុងអ្នកស្រុកឬក្រុងអ្នកលេងជាដើមណាមួយ មកប្រព្រឹត្តអនាចារក្នុងវត្ត គឺកាប់ដើមឈើឬលួចផលាផលទៅ ឬដណ្ដើមបរិក្ខារក្នុងវិហារនៃភិក្ខុ ភិក្ខុចូលទៅរកតុលាការពោលថា ក្នុងវិហាររបស់យើង គេមកធ្វើយ៉ាងនេះៗ តុលាការសួរថាអ្នកណា ប្រាប់ថាមនុស្សឯណោះៗ ដូច្នេះឈ្មោះថាប្រារព្ធកាលជាអតីត ប្រាប់ចំពោះខ្លួនមិនគួរ បើតុលាការគេបានឮពាក្យនោះ គេពិន័យដល់អ្នកធ្វើការក្រក់នោះ របស់ដែលគេពិន័យប៉ុន្មាន ត្រូវភិក្ខុសងទាំងអស់ សូម្បីកាលបើមានបំណងនឹងឲ្យគេពិន័យលក់ត្រូវតែសងមួយយ៉ាង បើពោលថា អ្នក

www.budinst.gov.kh www.elibraryofcambodia.org

ចូរពិន័យលក់ដល់អ្នកនោះ កាលបើគេលក់យកថ្លៃ ៥ មាសកក៏ត្រូវបារាជិក តែកាលបើតុលាការសួរថា អ្នកណាមកធ្វើអាក្រក់ បើប្រាប់ថាមនុស្សឈ្មោះឯណោះ ៗ ដូច្នេះមិនគួរ ព្រោះតុលាការនឹងដឹង គប្បីពោលថា អាត្មាគ្រាន់តែសូមសេចក្ដីក្រុណាប៉ុណ្ណោះ លោកចូរឲ្យការក្ដានោះហើយ ចូរយកកណ្ដាំដែលគេលួចយកទៅ មកឲ្យផង ដូច្នេះឈ្មោះថាប្រារព្ធកាលជាអតីត ប្រាប់មិនចំពោះគួរ ៗ កាលៈបើពោលដូច្នេះ តុលាការគេចាប់បានខ្លួនមនុស្សអាក្រក់ហើយពិន័យលក់ សូម្បីគេកាន់យកទ្រព្យទាំងអស់ ភិក្ខុមិនត្រូវសង មិនត្រូវអាបត្តិ ៗ ភិក្ខុឃើញចោរលួចយកបរិក្ខារទៅ ប្រាប់ថាវត្ថុមិនជាប្រយោជន៍ដល់ចោរ សូម្បីពោលថាចោរ ៗ ដូច្នេះមិនគួរ ព្រោះថាកាលពោលដូច្នេះ គេពិន័យលក់របស់ណាដល់ចោរនោះ ភិក្ខុត្រូវសងរបស់ពិន័យទាំងអស់ តែនឹងពោលជាមួយនឹងមនុស្សអ្នកធ្វើតាមពាក្យរបស់ខ្លួនថាបរិក្ខាររបស់យើង មនុស្សឈ្មោះនេះគេកាន់យកទៅ អ្នកចូរឲ្យគេយកបរិក្ខារនោះមកឲ្យ តែអ្នកកុំពិន័យលក់ដល់គេឡើយ ដូច្នេះក៏គួរ ៗ កើតក្ដីនឹងគ្នា ដើម្បីទាសាទាសីជាដើមឈ្មោះថាក្ដីជាអកប្បិយ មិនគួរ ៗ មនុស្សដទៃមកធ្វើអនាចារជាដើមក្នុងវិហារដូចពោលហើយ ប្រាប់ដល់តុលាការថា គេមកធ្វើយ៉ាងនេះៗ ក្នុងវិហារ លោកចូរឲ្យសេចក្ដីរក្សាដើម្បីនឹងមិនឲ្យធ្វើតទៅទៀត ដូច្នេះកាលបើតុលាការសួរថា អ្នកណាធ្វើយ៉ាងនេះ ភិក្ខុប្រាប់ថាមនុស្សឈ្មោះឯណោះ ៗ ដូច្នេះឈ្មោះថាប្រារព្ធកាលជាអនាគត ប្រាប់ចំពោះដូច្នេះក៏មិនគួរ ៗ ផ្សេង

www.budinst.gov.kh www.elibraryofcambodia.org

ថា កាលបើគេពិន័យដល់អ្នកធ្វើអាក្រក់នោះ ភិក្ខុត្រូវសងរបស់ពិន័យទាំងអស់ដូចន័យមុន វិនិច្ឆ័យក្រៅនោះដូចពោលហើយក្នុងបទមុន ។ បើតុលាការគេប្រកាសទុកថា យើងនឹងពិន័យយ៉ាងនេះ ដល់អ្នកធ្វើអាក្រក់យ៉ាងនេះ ក្នុងវិហាររបស់ភិក្ខុ ហើយគេស្វែងរកមនុស្សដែលមិនបានតាំងនៅតាមអាជ្ញា បានខ្លួនហើយពិន័យលក់ ភិក្ខុមិនត្រូវសង មិនត្រូវអាបត្តិឡើយ ។ មនុស្សដទៃកាប់ដើមឈើជាដើមក្នុងវត្ត ភិក្ខុនឹងដណ្តើមយកកាំបិតនិងពូថៅជាដើម មកគប់ប្លុក ឬបំបែកដោយសំណ មិនគួរ បើមុខថែបទៅ គប្បីធ្វើឲ្យគេ ឬស្ទុះទៅដណ្តើមយកបរិក្ខាររបស់អ្នកមកកាប់ដើមឈើនោះ សូម្បីដូច្នេះ ក៏ភិក្ខុគប្បីធ្វើ ដ្បិតថាចិត្តប្រែប្រួលទៅរហ័សណាស់ កាលបើថេយ្យចេតនាកើតឡើង ក៏នឹងដល់នូវមូលច្ឆេទ ដាច់បួសទៅផង ។

អារក្ខាយាចនកថា ចប់

---

## បរិភោគកថា

ពណ៌នាអំពីការបរិភោគដែលមានមកក្នុងអដ្ឋកថានៃរូបិយសិក្ខាបទ

សេចក្តីថា បរិភោគមាន ៤ គឺ លជ្ជីបរិភោគ គប់ជាមួយលជ្ជី ១ អលជ្ជីបរិភោគ គប់ជាមួយអលជ្ជី ១ ធម្មិយបរិភោគ បរិភោគរបស់ដែលកើតឡើងប្រកបដោយធម៌ ១ អធម្មិយបរិភោគ បរិភោគរបស់ដែលកើតឡើងមិនប្រកបដោយធម៌ ១ ជា ៤ ។ ភិក្ខុជាអលជ្ជី បរិភោគជាមួយនឹងភិក្ខុ

www.budinst.gov.kh www.elibraryofcambodia.org

លជ្ជីគួរ ព្រះវិនយធរកុំគប្បីកាត់អាបត្តិ លជ្ជីបរិភោគជាមួយអលជ្ជី ភិក្ខុលជ្ជីមិនបានដឹងដកបណា ក៏គួរដកហានោះ ៗ ព្រោះថាភិក្ខុដែលឈ្មោះថាអលជ្ជីមកអំពីដើមក៏មិនមាន ព្រោះហេតុនោះ ភិក្ខុលជ្ជីដឹងថាភិក្ខុនោះអលជ្ជីកាលណា គប្បីឃាត់ភិក្ខុនោះចេញកាលនោះ ថាអ្នកកុំប្រព្រឹត្តកន្លងសិក្ខាបទក្នុងកាយទ្វារនិងវចីទ្វារ កម្មដូច្នេះមិនសមគួរ អ្នកកុំធ្វើឡើយ បើភិក្ខុនោះមិនអើពើចចេសតែធ្វើ នោះបើអ្នកលជ្ជីក៏នៅធ្វើការបរិភោគជាមួយនឹងភិក្ខុនោះ ភិក្ខុជាលជ្ជីនោះក៏ជាអលជ្ជីទៅផងគ្នាដោយពិត ៗ ភិក្ខុណាបរិភោគជាមួយនឹងអលជ្ជី ដែលជាមនុស្សទទួលភារៈរបស់ខ្លួន សូម្បីភិក្ខុនេះឲ្យភិក្ខុជាលជ្ជីគប្បីហាមប្រាម បើភិក្ខុអលជ្ជីមិនលះចេញទេ ភិក្ខុលជ្ជីនេះក៏ទៅជាអលជ្ជីដូចគ្នា ហេតុនោះឯង អលជ្ជីម្នាក់ ធ្វើភិក្ខុដទៃឲ្យទៅជាអលជ្ជីបានរាប់រយ តែអលជ្ជីនឹងអលជ្ជី បរិភោគជាមួយគ្នាមិនត្រូវអាបត្តិ ៗ លជ្ជីនឹងលជ្ជីបរិភោគជាមួយគ្នាល្អរុងរឿងដូចទត្តិយកុមារទាំងពីរសោយរួមភាជនៈជាមួយគ្នា ៗ ធម្មិយបរិភោគនឹងអធម្មិយបរិភោគពីរនេះគប្បីដឹងតាមបច្ច័យ បើបុគ្គលជាអលជ្ជីផង បិណ្ឌបាតក៏មិនប្រកបដោយធម៌ផង គប្បីខ្ពើមទាំងពីរចំណែក ៗ បុគ្គលជាអលជ្ជី តែបិណ្ឌបាតប្រកបដោយធម៌ គប្បីខ្ពើមតែបុគ្គល កុំគប្បីទទួលបិណ្ឌបាត ៗ ក្នុងមហាបច្ចរីពោលថា ភិក្ខុទ្រុស្តសីល បានឧទ្ទេសភត្តជាដើម អំពីសង្ឃមកថ្វាយដល់សង្ឃ បិណ្ឌបាតជាដើមនោះគួរ ព្រោះថា កាលដើមជារបស់សង្ឃហើយត្រឡប់ទៅជារបស់សង្ឃទៀត ៗ បុគ្គលជាលជ្ជី តែបិណ្ឌបាត

www.budinst.gov.kh www.elibraryofcambodia.org

មិនប្រកបដោយធម៌ បិណ្ឌបាតជារបស់គួរខ្ពើម កុំគប្បីទទួល ។ បុគ្គលលជ្ជី បិណ្ឌបាតក៏ប្រកបដោយធម៌ផង ទើបគួរ ។ សេចក្តីកាន់ទ្រង់ទៀតមានពីរយ៉ាងគឺ លជ្ជីបគ្គហៈ កាន់ទ្រង់លជ្ជី១ អលជ្ជីបគ្គហៈ កាន់ទ្រង់អលជ្ជី១ ។ ឯបរិភោគទៀតមានពីរគឺ ធម្មបរិភោគ បរិភោគរួមធម៌១ អាមិសបរិភោគ បរិភោគរួមអាមិស១ ។ អលជ្ជីខំកាន់ទ្រង់លជ្ជីគួរ វិនយធរកុំគប្បីកាត់អាបត្តិដល់ភិក្ខុនោះ ។ បើលជ្ជីកាន់ទ្រង់អលជ្ជី គប្បីដឹងថា គឺខំមកឲ្យអនុមោទនា ឲ្យសំដែងធម៌ ទំនងបក្ខមុក្ខក្នុងត្រកូលទាំងឡាយ ស្តាប់អលជ្ជីក៏ខំសរសើរគុណនៃលជ្ជីនោះ ក្នុងពពួកនៃបរិស័ទថា អាចារ្យនៃខ្ញុំល្អដូច្នេះៗ គប្បីដឹងច្បាស់ថា ភិក្ខុជាលជ្ជីនេះ ធ្វើសាសនាឲ្យទន់ទាបឲ្យសាបសូន្យទៅ ។ ក៏ឯក្នុងធម្មបរិភោគនិងអាមិសបរិភោគនោះ រួមអាមិសគួរក្នុងអ្នកណា រួមធម៌ក៏គួរក្នុងអ្នកនោះផង តែគម្ពីរណាកាំងនៅក្នុងទីបំផុត មានតែមនុស្សទ្រុស្តសីលទ្រទ្រង់ទុក កាលបើគន្ថមនុស្សទ្រុស្តសីលនោះហើយនឹងវិនាស ខំរៀនយកគម្ពីរនោះ ក្នុងសំណាក់មនុស្សទ្រុស្តសីលដោយអនុគ្រោះដល់ធម៌ លោកពោលថាគួរ ។

ដូចបាននិទានថា ភិក្ខុទ្រុស្តសីលមួយអង្គ ទ្រង់គម្ពីរមហានិទ្ទេសស្ទាត់តែម្នាក់ឯង មិនមានអ្នកដទៃទ្រទ្រង់ទុកបាន ព្រះតិស្សត្ថេរជាចៅបដ្ឋាយ៍បណ្តាប់មហារក្ខិតត្ថេរឲ្យទៅរៀន លោកទៅរៀនមួយវិញចប់គម្ពីរមហានិទ្ទេស ហើយបានរំពេញស្តីរនៅក្រោមគ្រែ ។

បរិភោគកថា ចប់

# វត្តកថា

ពណ៌នាអំពីវត្ត ១៤ មានអាគន្តុកវត្តជាដើម ។ សម្ដេចព្រះពុទ្ធអង្គទ្រង់បញ្ញត្តិទុកថា ភិក្ខុអាគន្តុកៈជាដើម គប្បីបដិបត្តិប្រព្រឹត្តដោយប្រការដូចម្ដេច តថាគតទ្រង់បញ្ញត្តិអាគន្តុកវត្តជាដើម ដោយប្រការដូច្នេះ ។

## អាគន្តុកវត្ត

វត្តរបស់ភិក្ខុអ្នកមកដល់ថ្មី ៗ សេចក្ដីថា អាគន្តុកៈមកអំពីវត្តដទៃ មកដល់ទ្វារសីមានៃអារាម ដែលខ្លួនបំណងនឹងចូលទៅ គប្បីធ្វើសេចក្ដីគោរព បើពាក់ស្បែកជើងមក គប្បីដោះស្បែកជើងនោះ ហុចគូលីចេញ ហើយពាក់លើឈើច្រត់កាន់ចូលទៅ បើបាំងឆ័ត្រមកគប្បីដម្លោះចេញ បើទូរក្បាលមកគប្បីបើកចេញ បើយកសំពត់ចីវរដាក់លើសិរសាមកគប្បីយកចុះចេញដាក់លើស្មា អំពីក្រៅទ្វារនៃអារាមឲ្យហើយ កុំប្រញាប់ គប្បីសន្សឹមៗ ចូលទៅក្នុងអារាមដោយប្រពៃ កាលបើចូលទៅគប្បីកំណត់ថា ភិក្ខុទៅអាស្រ័យប្រជុំគ្នានៅក្នុងទីណា ក្នុងរោងឆាន់ ឬមណ្ឌប ឬគល់ឈើ ហើយគប្បីទៅក្នុងទីនោះ លុះទៅដល់ហើយ គប្បីដាក់ល់បាត្រទុកក្នុងទីទម្ងាន ដាក់ល់ចីវរទុកក្នុងទីទម្ងាន គប្បីកាន់យកអាសនៈដ៏សមគួរ ហើយសឹមអង្គុយចុះ គប្បីសួរទឹកឆាន់នឹងទឹកប្រើ ថាឯណាទឹកឆាន់ ឯណាទឹកប្រើ បើត្រូវការដោយទឹកឆាន់ គប្បីកាន់យកឆាន់ បើត្រូវការដោយទឹកប្រើ គប្បីកាន់យកលាងជើង កាលបើលាង គប្បីស្រោចដោយ

www.budinst.gov.kh www.elibraryofcambodia.org

ដៃម្ខាង លាងជើងដោយដៃម្ខាង ស្រោចទឹកដោយដៃខាងណា កុំលាង ជើងដោយដៃខាងណោះ លាងជើងដោយដៃខាងណា កុំស្រោចទឹក ដោយដៃខាងណោះ ហើយគប្បីសួររកសំពត់ជូតស្បែកជើងនឹងនៅអាកាស ហើយគប្បីយកមកជូតស្បែកជើង កាលជូតស្បែកជើង គប្បីយកសំពត់ស្ងួតជូតមុន ហើយសឹមយកសំពត់ទទឹកជូតជាខាងក្រោយ ហើយគប្បីគក់សំពត់នោះចេញ ព្ធួរលាស់ហាលទុកក្នុងទីម្ខាង ។ បើភិក្ខុនៅអាកាសចាស់ជាងគប្បីក្រាបសំពះភិក្ខុនៅអាកាសនោះ បើនៅអាកាសខ្ចីវស្សាជាងក៏គប្បីឲ្យសំពះខ្លួន គប្បីសួរសេនាសនៈថា សេនាសនៈណាគួរដល់ខ្ញុំ ហើយគប្បីសួរថា សេនាសនៈក្នុងនោះភិក្ខុអាស្រ័យនៅខ្លះ ឬមិនបានអាស្រ័យនៅ គប្បីសួរគោចរគ្រាម ថាភិក្ខាចារជិតឬឆ្ងាយ នឹងគួរទៅពីព្រឹកឬថ្ងៃ គប្បីសួរអគោចរ គឺស្រុកនៃមិច្ឆាទិដ្ឋិ នឹងស្រុកដែលគេកំណត់ភិក្ខុ ឲ្យតែបិណ្ឌបាតប្រមាណមួយវែក ឬឲ្យតែមួយអន្ទឬពីរអន្ទ គប្បីសួរសេក្ខត្រកូល ដែលសង្ឃសន្មតទុក គប្បីសួរទីបន្ទោបង់ឧច្ចារៈបស្សាវៈ គប្បីសួរទឹកប្រើទឹកឆាន់ ថាទឹកតាំងប្រើតាំងឆាន់ក្នុងស្រះបោក្ខរណីតែមួយនេះទេឬ គប្បីសួរទីតាំងទុកឈើច្រត់នឹងកតិកានៃសង្ឃ ក្នុងទីខ្លះដែលមានសត្វកាចឬអមនុស្សនោះ ។ គប្បីសួរថា នៅនឹងចូលវេលាណា ចេញវេលាណា បើក្នុងនោះទំនេរ គប្បីគោះសន្ទឹកទ្វារ ឈររង់ចាំមួយរំពេច ហើយរកចង្កឹះ ស្រាយសន្ទឹកទ្វារ ហើយនៅខាងក្រៅ ក្រឡេកមើលក្រែងសត្វឬអមនុស្ស ដែលនឹងចេញមកឲ្យសព្វគ្រប់ ។ បើក្នុងនោះមាន

ស្រោម ត្រូវផ្សម្រកទៅលើគ្រែ តាំងពីម្រកទៅលើតាំង ទាំងលើសេនា-
សនៈពេញពាសទៅដោយសំបុកសរសៃពីងពាង បើអាចនឹងសំអាតបាន
គប្បីសំអាតឲ្យល្អ កាលបើមិនអាចនឹងសំអាតបាន គប្បីសំអាតតែទី
សំរាប់របស់ខ្លួន បើអាចសំអាតឲ្យស្អាតទាំងអស់បានសោត ក៏គប្បីសំអាត
ដោយន័យដូចពោលក្នុងសេនាសនវត្ត តាំងអំពីបញ្ចេញនូវគ្រឿងក្រាលលើ
ផ្ទៃចេញ ហើយបដិបត្តិដូចន័យសេនាសនវត្ត ដែលនឹងពោលខាងមុខ
រហូតដល់សេចក្តីថា បើទឹកក្នុងភាជនៈគ្មាន គប្បីដងមកទុកដាក់ដូច្នេះ
នេះឯងជាវត្តនៃភិក្ខុជាអាគន្តុកៈ គឺភិក្ខុជាអាគន្តុកៈ គប្បីបដិបត្តិដោយ
ប្រពៃ ថាបើអាស្រ័យសេចក្តីមិនអើពើនឹងបដិបត្តិតាម ត្រូវអាបត្តិទុក្កដ
ក្នុងខណៈដាក់ចិត្តថាមិនធ្វើតាម គប្បីដឹងដូច្នេះ គ្រប់ ៗ វត្តចុះ ៗ

អាគន្តុកវត្ត ចប់

## អាវាសិកវត្ត

វត្តរបស់ភិក្ខុនៅអាវាស ៗ សេចក្តីថា ភិក្ខុនៅអាវាសបានឃើញភិក្ខុ
អាគន្តុកៈចាស់ជាងខ្លួនមកដល់ គប្បីក្រាលអាសនៈ ដំកល់ទឹកលាងជើង
ដំកល់តាំងរងជើង គ្រឿងជូតជើងទុកជិតមុខហើយក្រោកទៅទទួលបាត្រ
ចីវរ ហើយគប្បីសួរដោយទឹកផឹកទឹកប្រើ បើឧស្សាហ៍មាន គប្បីជូតស្បែក
ជើងឲ្យ កាលជូតគប្បីជូតដោយសំពត់ស្ងួតជាមុន ហើយសឹមជូត ដោយ
សំពត់ទទឹកជាខាងក្រោយ ហើយគប្បីគក់សំពត់នោះពូតលាស់ហាលទុក
ក្នុងទីសមគួរ គប្បីក្រាបសំពះអាគន្តុកៈភិក្ខុដែលចាស់ គប្បីរៀបចំក្រាល

www.budinst.gov.kh www.elibraryofcambodia.org

សេនាសនៈ ហើយប្រាប់ថា សេនាសនៈនោះបានដល់លោក បើ
អាគន្តុកៈខ្ចីជាងខ្លួន គប្បីអង្គុយប្រាប់ថា លោកចូរដាក់បាត្រក្នុងទីនោះ
ដាក់ចីវរក្នុងទីនោះ នេះជាទីអង្គុយ ចូរអង្គុយចុះ គប្បីប្រាប់ទឹកប្រើ
ទឹកឆាន់ ទីងសំពត់ជូតស្បែកជើង គប្បីឲ្យអាគន្តុកភិក្ខុដែលខ្ចីវស្សាជាង
ក្រាបសំពះខ្លួន គប្បីប្រាប់សេនាសនៈ ថាសេនាសនៈនោះគួរដល់លោក
គៈទៅតាំងពីចាស់តាំងខ្ចី គប្បីប្រាប់សេនាសនៈដែលមានអ្នកគ្រប់គ្រងមក
ហើយ ឬមិនមានគេគ្រប់គ្រងមកហើយ ហើយគប្បីប្រាប់គោចរគ្រាមនិង
អគោចរគ្រាម ប្រាប់សក្ខត្រកូលដែលបានសន្មតអំពីសង្ឃ ប្រាប់ទីបន្ទោ
បង់ឧច្ចារបស្សាវៈ ទឹកប្រើទឹកឆាន់ ទីឈើច្រត់ ប្រាប់កតិកាសង្ឃដែល
តាំងទុកថាគប្បីចូលក្នុងកាលនេះ ចេញក្នុងកាលនេះដូច្នេះ ៗ កាលដែល
អាគន្តុកៈភិក្ខុចាស់ជាងមកដល់ហើយ សូម្បីកំពុងធ្វើចីវរកម្មឬនវកម្ម ក៏
គប្បីបញ្ឈប់សិន ធ្វើអាគន្តុកវត្តទាំងពួងទៅចុះ កាលកំពុងបោសលាន
ចេតិយគប្បីទុកអំបោសសិន ប្រារព្ធដើម្បីនឹងធ្វើអាគន្តុកវត្តដល់ភិក្ខុចាស់
បើអាគន្តុកៈជាអ្នកឈ្លាសក៏នឹងពោលថា លោកចូរបោសលានព្រះចេតិយ
ទៅសិនចុះ ៗ កាលកំពុងធ្វើថ្នាំឲ្យភិក្ខុមានជម្ងឺ បើជម្ងឺមិនធ្ងន់ទេ កុំកាល
ធ្វើថ្នាំ គប្បីធ្វើវត្តដល់អាគន្តុកៈសិន តែបើឈឺជាទម្ងន់ គប្បីធ្វើថ្នាំសិន
បើអាគន្តុកៈជាអ្នកឈ្លាសសោត ក៏នឹងពោលថា លោកចូរធ្វើថ្នាំសិនចុះ ៗ
ដែលសួរដោយទឹកឆាន់នោះ បើយកមកឲ្យតែម្ដង អាគន្តុកៈក៏ឆាន់អស់ទៅ
គប្បីសួរទៀត ៗ មួយទៀត កាលបក់គប្បីបក់ឲ្យ គប្បីបក់ពីខាងខ្នងជើង

www.budinst.gov.kh www.elibraryofcambodia.org

អស់ករៈម្ដង កណ្ដាលខ្លួនអស់ករៈម្ដង សិរសាអស់ករៈម្ដង បើលោកឃាត់ គប្បីបក់ឲ្យស្រោលចុះ បើលោកឃាត់ម្ដងទៀត គប្បីបក់ឲ្យស្រោលចុះជាង នោះ បើឃាត់ជាគំរប់៣ គប្បីដាក់ផ្ទិតចុះ ។ គប្បីលាងជើងឲ្យអាគន្តុកៈផង បើប្រេងរបស់ខ្លួនមាន គប្បីយកមកលាបជើងឲ្យ បើមិនមានទេ គប្បីយក ប្រេងអាគន្តុកៈនោះលាបឲ្យ ឯការជូតស្បែកជើងនោះ គប្បីធ្វើតាមចូល ចិត្តខ្លួនចុះ បើមិនជូតឲ្យ ក៏មិនត្រូវអាបត្តិ ព្រោះក្នុងបាលីពោលទុកថា សចេ ឧស្សហតិ ឧបាហនា បុញ្ឆិតព្វា កាលបើឧស្សាហ៍ គប្បីជូតស្បែកជើងឲ្យ ។ បើអាគន្តុកៈសួររកសេនាសនៈ ត្រូវក្រាល បោសព្រាសហើយសឹមប្រាប់ទើបគួរ សេចក្ដីនេះសំដែងចំពោះអាគន្តុកៈ ចាស់ជាង ។ បើអាគន្តុកៈខ្ចីជាងខ្លួន គប្បីអង្គុយនៅលើអាសនៈប្រាប់ថា លោកចូរកាន់យកទីកន្លែងនោះនាងចុះ ដូច្នេះជាដើមទៅ ។

បើអាវាសធំ អាគន្តុកៈមកដល់សំណាក់ខ្លួន ទឹងមិនធ្វើវត្តនោះមិន បាន នេះជាវត្តនៃភិក្ខុនៅអាវាស ភិក្ខុនៅអាវាស គប្បីប្រព្រឹត្តដោយ ប្រពៃចុះ ។

អាវាសិកវត្ត ចប់

---

## គមិកវត្ត

វត្តរបស់ភិក្ខុអ្នកធ្វើដំណើរ ។ សេចក្ដីថា គមិកភិក្ខុ ភិក្ខុអ្នកនឹងចេញ ចាកអាវាសទៅកាន់ទីដទៃគប្បីទុកដាក់គ្រឿងឈើមានគ្រែនិងតាំងជាដើម

www.budinst.gov.kh www.elibraryofcambodia.org

ដែលជារបស់សង្ឃ ទឹងគ្រឿងដី ហើយបិទទ្វារ បិទបង្អួច ប្រគល់សេនា
សនៈឲ្យស្រេច បើមិនមានភិក្ខុ គប្បីប្រគល់ឲ្យសាមណេរ បើសាមណេរ
មិនមាន គប្បីប្រគល់ឲ្យអ្នកវេយ្យាវច្ច បើអ្នកវេយ្យាវច្ចមិនមាន គប្បីប្រាប់
ដល់ឧបាសក បើមិនមានឧបាសកទាយក គប្បីដំកល់គ្រែលើដុំសិលា ៤ ដុំ
ហើយលើកគ្រែដម្រួតលើគ្នា ដាក់តាំងលើតាំង ដាក់គ្រឿងសេនាសនៈ
នេះមានពូកខ្នើយជាដើមទុកខាងលើ ទុកដាក់គ្រឿងឈើ គ្រឿងដី បិទ
ទ្វារបង្អួចហើយសឹមចៀសចេញទៅ បើកុដិភ្លៀងលិចបាន កាលអាចនឹង
ប្រក់បានគប្បីប្រក់ ឬគប្បីធ្វើឧស្សាហ៍ថា ធ្វើម្ដេចគប្បីនឹងប្រក់បាន បើ
បានយ៉ាងនេះជាការល្អ បើមិនបានសោតគប្បីដំកល់គ្រែលើដុំថ្ម ៤ ដុំ ទុក
ក្នុងឱកាសដែលភ្លៀងមិនបានលិច ហើយរៀបចំទុកដាក់ដូចមុននោះចុះ
បើកុដិវិហារទាំងអស់ភ្លៀងលិចបាន កាលអាចនឹងនាំទៅបាន ក៏គប្បីនាំ
សេនាសនៈទៅផ្ញើទុកក្នុងស្រុក ឬគប្បីធ្វើឧស្សាហ៍ថា ដូចម្ដេចនឹងគប្បីនាំ
សេនាសនៈចូលទៅផ្ញើទុកក្នុងស្រុកបាន បើបានដូច្នេះជាការល្អ បើមិន
បានទេ គប្បីដំកល់គ្រែតាំងលើដុំសិលា ៤ ដុំក្នុងទីវាល ហើយរៀប
ទុកដាក់របស់ទាំងពួងដូចមុន ហើយគ្របដោយស្មៅឬស្លឹកឈើ ហើយ
សឹមចៀសទៅដោយគិតថា ធ្វើម្ដេចហ្ន៎ សូម្បីអវយវៈមានមៃគ្រែ មេ
តាំងជាដើមនឹងគប្បីសល់នៅខ្លះដូច្នេះ ៗ សេនាសនៈដែលត្រូវប្រគល់នោះ
ចំពោះតែសេនាសនៈដែលធ្វើដោយស្មៅនឹងស្លឹកឈើ ដែលគួរគេល្មៀ
កាត់នឹងទៀងបាន សេនាសនៈណាគេធ្វើលើខ្នងសិលា ឬលើសសរថ្ម

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងទីដែលគណ្ឋៀររទៀនមិនបាន សេនាសនៈនោះ សូម្បីមិនប្រាប់ មិនប្រគល់ហើយទៅ ក៏មិនត្រូវអាបត្តិ នេះជាវត្តរបស់គមិកភិក្ខុ គមិក-ភិក្ខុ គប្បីបដិបត្តិដោយប្រពៃចុះ ។

គមិកវត្ត ចប់

---

# អនុមោទនវត្ត

វត្តគឺការធ្វើអនុមោទនា ៗ ខមួយ ទ្រង់អនុញ្ញាតទុកថា អនុជា-នាមិ ភិក្ខវេ ភត្តគ្គេ អនុមោទិតុំ តថាគតអនុញ្ញាតឲ្យអនុមោ-ទនាក្នុងរោងឆាន់ ៗ ខមួយ ទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ ថេរេន ភិក្ខុនា ភត្តគ្គេ អនុមោទិតុំ តថាគត អនុញ្ញាតឲ្យភិក្ខុជាថេរៈអនុមោទនាក្នុងរោងឆាន់ ។ ខមួយ ទ្រង់អនុញ្ញាត ទុកថា អនុជានាមិ ភិក្ខវេ ភត្តគ្គេ ចតូហិ បញ្ចហិ ថេរានុថេរេហិ ភិក្ខូហិ អាគមេតុំ តថាគតអនុញ្ញាតឲ្យភិក្ខុជា ៈថេរានុថេរ ៤ អង្គ ៥ អង្គ អង្គុយចាំនៅក្នុងរោងឆាន់ ៗ

អដ្ឋកថាថា ព្រះសង្ឃត្ថេរអង្គុយចាំ ដើម្បីនឹងអនុមោទនា ភិក្ខុជាលំដាប់ចុះទៅ គប្បីអង្គុយចាំ ៤ អង្គដោយលំដាប់ កាលអនុត្ថេរអង្គុយចាំ ដើម្បីអនុមោទនា ឲ្យព្រះមហាថេរជាមួយនឹងភិក្ខុបន្ទាប់ចុះទៅទៀត ៣ អង្គ អង្គុយរង់ចាំ កាលថេរៈទី ៥ អង្គុយដើម្បីអនុមោទនា ឲ្យថេរៈ ៤ អង្គ ខាងលើអង្គុយរង់ចាំ កាលព្រះសង្ឃត្ថេរនិមន្តឲ្យភិក្ខុកំឡោះអង្គុយខាង

www.budinst.gov.kh www.elibraryofcambodia.org

ចុងអនុមោទនា ៖ នោះទាំង ៤ អង្គតាំងអំពីព្រះសង្ឃត្ថេរចុះទៅ គប្បី
អង្គុយរង់ចាំ បើភិក្ខុអ្នកអនុមោទនាពោលថា លោកចូរទៅចុះ ដូច្នេះ
កិច្ចដែលនឹងគប្បីចាំមិនមាន ដូច្នេះនឹងទៅក៏គួរ ។ កាលព្រះថេរៈ
ពោលថា យើងនឹងទៅ លោកចូរនៅចុះ អ្នកអនុមោទនាពោលថា
លោកចូរទៅចុះ សូម្បីដូច្នេះក៏គួរ ។ សូម្បីចងចិត្តថាយើងនឹងទៅរង់ចាំនៅ
ក្រៅភូមិ ទោះក្រៅភូមិហើយ សូម្បីនឹងបង្គាប់ភិក្ខុជាសិស្សរបស់ខ្លួនឲ្យ
អង្គុយនៅចាំអ្នកអនុមោទនា ហើយទៅក៏គួរ ។ បើគ្រហស្ថគេនិមន្តភិក្ខុ
មួយអង្គឲ្យអនុមោទនាតាមគាប់ចិត្តរបស់គេ ភិក្ខុនោះកាលបើអនុមោទនា
ក៏មិនត្រូវអាបត្តិ ព្រោះមិនជាភារៈរបស់មហាថេរ តែថាគន្ថិបទិសិទ្ធ-
កថាពោលថា កាលមនុស្សគេនិមន្តឲ្យសំដែងធម៌ ត្រូវប្រាប់ព្រះមហា-
ថេរជាមុន ។ ដែលត្រូវរង់ចាំនោះ ចំពោះតែភិក្ខុដែលព្រះមហាថេរ
និមន្តឲ្យអនុមោទនា នេះឯងជាលក្ខណៈក្នុងវត្តចំពូកនេះ ។

ខមួយ ទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ សតិ
ករណីយេ អនន្តរិកំ ភិក្ខុំ អាបុច្ឆិត្វា គន្តុំ គឺថាទ្រង់
អនុញ្ញាតឲ្យភិក្ខុដែលរង់ចាំនោះ បើមានករណីយកិច្ចមានការឈឺបន្ទោបង់
ឧច្ចារៈជាដើម គប្បីលាភិក្ខុដែលអង្គុយជាលំដាប់សិនហើយសឹមទៅ ។

អនុមោទនវត្ត ចប់

www.budinst.gov.kh www.elibraryofcambodia.org

# ភត្តគ្គវត្ត

វត្តក្នុងរោងភត្ត ។ សេចក្ដីថា បើគេចូលមកប្រាប់ភត្តកាលក្នុងអារាម និមន្តឲ្យទៅកាន់រោងឆាន់ គប្បីបិទកាយឲ្យជាបរិមណ្ឌល ៣ យ៉ាង ស្លៀកឲ្យជាបរិមណ្ឌល ក្រវាត់វត្ថពន្ធចង្កេះ គម្រួតសង្ឃាដិ នឹងទុក្ដកសន្ទជាពីរជាន់ ដណ្ដប់ពាក់ក្ដុំ លាងបាត្រ កាន់យកបាត្រហើយ កុំប្រញាប់ គប្បីដើរសមខ្យឹម ៗ ចូលទៅក្នុងភូមិដោយប្រពៃ ។ ក្នុងអដ្ឋកថាថា ក្នុងភូមិក្ដីក្នុងវត្តក្ដី កាលនឹងទៅកាន់ទីអង្គាសចង្ហាន់នៃមនុស្ស គប្បីដណ្ដប់ ឃ្លុំ ក្រវាត់វត្ថពន្ធចង្កេះ ទើបគួរ កាលដើរទៅ កុំដណ្ដើមដើរមុនភិក្ខុចាស់ គប្បីបិទកាយដោយប្រពៃ ដើរទៅក្នុងលន្វែកភូមិ រក្សាសេខិយវត្តគ្រប់ ៗ សិក្ខាបទ ដរាបដល់កុំដើរចំអើតជើងក្នុងលន្វែកភូមិ កាលអង្គុយក្នុងលន្វែកភូមិ គប្បីបិទកាយដោយប្រពៃ រក្សាសេខិយវត្តគ្រប់ ៗ សិក្ខាបទ ដរាបដល់កុំអង្គុយត្របោមជង្គង់ ។ មួយទៀត កុំអង្គុយប្រជ្រៀតភិក្ខុចាស់ បើអាសនៈស្មើគ្នា នឹងអាសនៈដែលព្រះមហាថេរអង្គុយ បើទីអង្គុយមានច្រើន គប្បីអង្គុយឲ្យឆ្ងាយ វៀរទុកឲ្យសល់អាសនៈ ១ ឬ ២ អាសនៈដែលគេក្រាលទុកតាមចំនួនភិក្ខុ ភិក្ខុកំឡោះមិនហ៊ានអង្គុយ បើព្រះមហាថេរប្រាប់ឲ្យអង្គុយ ក៏គប្បីអង្គុយចុះ តែបើព្រះមហាថេ មិនប្រាប់ឲ្យអង្គុយទេ ក៏គប្បីពោលថាអាសនៈនេះខ្ពស់ កាលបើព្រះមហាថេរប្រាប់ឲ្យអង្គុយក៏គប្បីអង្គុយចុះ បើប្រាប់យ៉ាងនេះហើយ ព្រះមហាថេរមិនប្រាប់ឲ្យអង្គុយ សូម្បី

www.budinst.gov.kh www.elibraryofcambodia.org

អង្គុយក៏មិនត្រូវអាបត្តិ ត្រូវអាបត្តិចំពោះតែព្រះមហាថេរមួយអង្គ ព្រោះជាអាសនៈដូចគ្នា ភិក្ខុកំឡោះមិនប្រាប់មុនហើយអង្គុយចុះ ត្រូវអាបត្តិដូចព្រះមហាថេរដែលភិក្ខុកំឡោះបានប្រាប់ហើយ មិនអនុញ្ញាត ត្រូវអាបត្តិដូចគ្នា ។

មួយៈទៀត ភិក្ខុចាស់កុំគប្បីឃាត់អាសនៈភិក្ខុកំឡោះ ទើងកុំអង្គុយសង្កត់លើសំពត់សង្ឃាដិក្នុងលន្វែកភូមិ កាលបើគេប្រគេនទឹកលាងបាត្រ គប្បីផ្គងបាត្រដោយដៃទាំងពីរទទួលទឹកដោយគោរព កុំឲ្យខ្ទាំងខូចបាត្រ លាងបាត្រដោយប្រពៃ បើមានកន្ទោរគប្បីដាក់ចុះក្នុងកន្ទោរដោយគោរព កុំឲ្យទឹកខ្ទប់កន្ទោរខ្ទាតខ្វៀងទៅត្រូវភិក្ខុអង្គុយជិត ឬត្រូវសំពត់សង្ឃាដិ បើមិនមានកន្ទោរ គប្បីដាក់ចុះលើដីដោយគោរព កុំឲ្យទឹកខ្ទាតត្រូវភិក្ខុដែលអង្គុយជិត ឬត្រូវសំពត់សង្ឃាដិ កាលទាយកប្រគេនបាយ គប្បីផ្គងបាត្រដោយដៃទាំងពីរទទួលចុះ គប្បីទុកឱកាសដើម្បីទទួលសូបៈ សប្បិ ប្រេង ឬសម្ល ក៏គួរ ។ ព្រះមហាថេរគប្បីពោលនឹងទាយកថា អ្នកចូរប្រគេនឲ្យស្មើគ្នាដល់ភិក្ខុទាំងពួង បើរបស់តិចល្មមគ្រាន់តែភិក្ខុ ១ អង្គ ឬ ២ អង្គប៉ុណ្ណោះ កាលប្រាប់ថាចូរប្រគេនស្មើគ្នាទៅ ជាការបៀតបៀនទាយក ព្រោះហេតុនោះ គប្បីទទួលរបស់នោះតែបន្តិច ឬពីរផង សល់អំពីនោះកុំទទួល គប្បីតាំងសតិ មានសេចក្ដីសំគាល់តែក្នុងបាត្រ ទទួលបិណ្ឌបាត គប្បីទទួលសម្លសមភាគ ប្រមាណមួយភាគបួននៃបិណ្ឌបាត គប្បីទទួលបិណ្ឌបាតត្រឹមស្មើកណ្ដាប់មាត់បាត្រខាងក្រោម

www.budinst.gov.kh www.elibraryofcambodia.org

ចង្ហាន់នៅមិនទាន់បានគ្រប់ភិក្ខុទាំងពួងដរាបណា ព្រះថេរកុំគប្បីឆាន់មុន រឿងនេះអាស្រ័យភេនឆាន់តូចហើយមានកំណត់ភិក្ខុ គឺភេនឆាន់ណាដែលទាយកគេប្រាប់ថានឹងប្រគេនឲ្យទូទៅដល់ភិក្ខុដទៃផង ៗ តែបើភេនឆាន់ធំ កន្លែងមួយភិក្ខុកំពុងឆាន់ កន្លែងមួយៈគេប្រគេនទឹក ក្នុងភេនឆាន់ដូច្នេះ គប្បីឆាន់តាមសប្បាយចុះ ៗ កាលឆាន់បិណ្ឌបាត គប្បីតាំងសតិបដិបត្តិតាមសេខិយវត្តគ្រប់ ៗ សិក្ខាបទ ដរាបដល់លាងដៃប្រឡាក់អាមិស កុំបាច កុំទទួលភាជនៈដាក់ទឹកឆាន់ ៗ មួយទៀត ភិក្ខុទាំងពួងឆាន់មិនទាន់រួចដរាបណា ព្រះថេរៈកុំអាលទទួលទឹកលាងបាត្រដរាបនោះ កាលទាយកប្រគេនទឹកលាងបាត្រ គប្បីផ្គងបាត្រដោយដៃទាំងពីរទទួលទឹកមកលាងបាត្រ បដិបត្តិដូចលាងបាត្រនោះចុះ ទឹកកុំគប្បីចាក់ទឹកលាងបាត្រទាំងគ្រាប់បាយក្នុងលានផ្នែកផ្ទះ កាលត្រឡប់មកអំពីភេនឆាន់ ភិក្ខុកំឡោះគប្បីត្រឡប់មកមុន ព្រះថេរៈគប្បីត្រឡប់មកជាក្រោយ គឺថាផ្ទះចង្អៀតមិនមានឱកាសដែលព្រះមហាថេរចេញមុនបាន គប្បីបដិបត្តិចុះ ៗ កាលចេញមកហើយ ភិក្ខុកំឡោះគប្បីឈរនៅទីប្របទ្វារផ្ទះ ព្រះថេរៈចេញមកដល់សឹមទៅតាមលំដាប់ បើព្រះមហាថេរអង្គុយនៅ ភិក្ខុកំឡោះអង្គុយនៅខាងក្នុងផ្ទះ គប្បីចេញទៅតាមលំដាប់ តាំងអាសនៈនៃព្រះថេរ កុំឲ្យកាយនឹងកាយប៉ះគ្នា ដើរឲ្យជាជួរទុករយៈល្មមមនុស្សដើរឆ្លងបាន គប្បីបិទកាយឲ្យប្រពៃ ដើរទៅក្នុងលានផ្នែក បដិបត្តិតាមសេខិយវត្តគ្រប់ ៗ សិក្ខាបទ រហូតដល់ថាកុំដើរចំអើត

www.budinst.gov.kh www.elibraryofcambodia.org

ដើរក្នុងល្វៃទកផ្ទះនោះចុះ នេះឯងជាវត្តក្នុងរោងចាន់ ភិក្ខុគប្បីប្រតិបត្តិដោយប្រពៃចុះ ។

ភត្តគ្គវត្ត ចប់

## បិណ្ឌចារិកវត្ត

វត្តរបស់ភិក្ខុអ្នកត្រាច់ទៅដើម្បីបិណ្ឌបាត ។ សេចក្ដីថា ភិក្ខុត្រាច់ទៅដើម្បីបិណ្ឌបាត គិតថាយើងនឹងចូលទៅកាន់ភូមិ ក្នុងកាលនេះហើយ គប្បីបិទកាយឲ្យមានមណ្ឌលបី ស្លៀកឲ្យជាបរិមណ្ឌល ចងវត្តពន្ធចង្កេះ ដំរួតសំពត់សង្ឃាដីនឹងឧត្តរាសង្គៈជាពីរជាន់ ដណ្ដប់ឃ្លុំពាក់ក្ដុំ លាងបាត្រ ហើយកាន់យកបាត្រកុំប្រញាប់ សន្សឹមៗ ចូលទៅក្នុងភូមិដោយប្រពៃ គប្បីបិទកាយដោយល្អដើរទៅក្នុងល្វៃទកភូមិ បដិបត្តិតាមសេខិយវត្ត សម្រាប់ចូលទៅក្នុងល្វៃទកផ្ទះគ្រប់ៗ សិក្ខាបទ របៀបដល់ថាកុំដើរចំអើត ដើរ ក្នុងល្វៃទកភូមិ កាលចូលទៅកាន់ផ្ទះ គប្បីកំណត់សំគាល់ថា គាត់អញនឹងចូលតាមផ្លូវនេះនឹងចេញតាមផ្លូវនេះ ហើយកុំចូលទៅហួសពេក កុំចេញមកហួសពេក កុំឈរឲ្យឆ្ងាយពេកជិតពេក កុំត្រឡប់ឲ្យឆាប់ពេក យឺតយូរពេក គប្បីឈរកំណត់មើលទាយកគេប្រាថ្នានឹងឲ្យ ឬមិនឲ្យ បើទាយកគេបញ្ឈប់ការងារ ឬក្រោកចាកអាសនៈចាប់វែក ឬហាប់គាផង រុំកស្រែកនិមន្តឲ្យឈប់សិន ។ កាលដឹងថាគេប្រាថ្នានឹងឲ្យហើយ ឈ្លី ឈរនោះចុះ កាលដែលទាយកប្រគេនចង្ហាន់ គប្បីវែកសង្ឃាដីដោយ

www.budinst.gov.kh www.elibraryofcambodia.org

ដៃឆ្វេង បង្អោនបាត្រចេញដោយដៃស្តាំ ផ្គងបាត្រដោយដៃទាំងពីរ ទទួលបង្ហាន់ចុះ តែកុំសំឡឹងមើលមុខទាយកអ្នកប្រគេនបង្ហាន់ថាស្រី ឬប្រុស ហើយគប្បីកំណត់មើលថា គេនឹងឲ្យម្ហូបចំណី ឬមិនឲ្យ បើគេចាប់វែកឬកាជនៈ ឬក៏ស្រែកទំបន្តិចឲ្យឈប់នៅសិន កាលដឹងថាគេប្រាថ្នានឹងឲ្យហើយ គួរឈប់នៅចុះ កាលគេឲ្យបង្ហាន់រួចហើយ គប្បីបិទបាត្រដោយសង្ឃាដី កុំប្រញាប់ សន្សឹមៗ ត្រឡប់ដោយប្រពៃ ហើយត្រូវសេខិយវត្តក្នុងល្វែកភូមិគ្រប់ៗ សិក្ខាបទ រហូតដល់ថាកុំដើរចំអើតដើរក្នុងល្វែកភូមិ ។ ភិក្ខុណាត្រឡប់អំពីបិណ្ឌបាតមកដល់វត្តមុន ភិក្ខុនោះគប្បីក្រាលអាសនៈទុកក្នុងរោងឆាន់ ដំកល់ទឹកលាងជើង ដំកល់តាំងរងជើង កន្សែងជូតជើងទុក ហើយលាងភាជនៈដាក់របស់ឆាន់តាំងទុក ដំកល់ទឹកប្រើ ទឹកឆាន់ទុក ។ បើភិក្ខុណាត្រឡប់មកអំពីភូមិជាខាងក្រោយ បើមានរបស់ឆាន់ ប្រាថ្នានឹងឆាន់សោត គប្បីឆាន់ចុះ បើមិនប្រាថ្នានឹងឆាន់ទេ ភិក្ខុនោះគប្បីយកទៅដាក់ចោលក្នុងទីប្រាសចាកវត្តទៀត គឺដើមឈើឬដើមស្មៅឬយកទៅបំផ្លិចចោលក្នុងទឹកដែលមិនមានសត្វ ភិក្ខុនោះគប្បីរើអាសនៈទុកដាក់ទឹងទុកដាក់ទឹកលាងជើង តាំងរងជើង កន្សែងជូតជើង នឹងលាងភាជនៈដាក់របស់ឆាន់ទុកចុះ រៀបចំទឹកឆាន់ ទឹកប្រើទុក ហើយបោសសំអាតរោងឆាន់ចេញ ភិក្ខុណាឃើញក្អមទឹកឆាន់ ទឹកប្រើ ឬក្អមទឹកក្នុងវច្ចកុដិទទេ មិនមានទឹក ភិក្ខុនោះគប្បីដងមកដំកល់ទុក បើម្នាក់ឯងលើកមិនរួច គប្បីបោយដៃហៅគ្នា បានជាពីរនាក់ឲ្យមកជួយ

www.budinst.gov.kh www.elibraryofcambodia.org

លើកតាំងទុក តែកុំបះទង្គិចញញក់ចាប់អ៊ូអៀប នេះឯងជាវត្តនៃភិក្ខុអ្នក ត្រាច់ទៅបិណ្ឌបាត ភិក្ខុគប្បីបដិបត្តិដោយប្រពៃចុះ ។

បិណ្ឌបាតិកវត្ត ចប់

## អរញ្ញិកវត្ត

វត្តរបស់ភិក្ខុអ្នកនៅក្នុងព្រៃ ៗ សេចក្ដីថា ភិក្ខុអ្នកនៅព្រៃ គប្បីក្រោក ឡើងអំពីព្រឹក យកបាត្រដាក់ថង់ ហើយយកចីវរយោគពាក់លើចង្កួយស្មា ពាក់ចីវរលើស្មា ពាក់ស្បែកជើង ហើយរៀបចំទុកដាក់ គ្រឿងឈើ គ្រឿងដី បិទទ្វារបង្អួច ហើយគប្បីចុះអំពីទីលំនៅមក ដឹងថាទីដែលចូលទៅកាន់ភូមិ ក្នុងកាលនេះហើយគប្បីដោះស្បែកជើងចេញដោយគោរព ហើយ ដាក់ក្នុងស្បោងបាត្រយកចីវរយោគពាក់លើចង្កួយស្មា បិទកាយឲ្យមាន មណ្ឌលបី ស្លៀកឲ្យជាបរិមណ្ឌល តទៅគប្បីប្រតិបត្តិដូចពោលហើយ ក្នុងបិណ្ឌបាតិកវត្តគ្រប់ៗសិក្ខាបទ ដរាបដល់ត្រឡប់អំពីភូមិមក បើ ខាងក្រៅភូមិមិនមានទឹក គប្បីធ្វើភត្តកិច្ចនៅក្នុងភូមិ បើខាងក្រៅភូមិមានទឹក គប្បីចេញទៅធ្វើភត្តកិច្ចខាងក្រៅភូមិ ហើយលាងបាត្រ ធ្វើឲ្យប្រាសចាក ទឹក ហើយប្រកបាត្រក្នុងថង់ ពាក់ចីវរយោគលើចង្កួយស្មា បត់ចីវរពាក់ លើក្បាល ពាក់ស្បែកជើង ដើរមកកាន់សេនាសនៈវិញ ៗ មួយទៀត ភិក្ខុនៅព្រៃ ត្រូវដំកល់ទឹកឆាន់ ទឹកប្រើទុក បើខ្វះភាជនៈ ក៏គប្បីធ្វើទឹក ឆាន់នោះឯងឲ្យជាទឹកប្រើតាំងទុកចុះ កាលបើមិនមានភាជនៈ គប្បីដំកល់

www.budinst.gov.kh www.elibraryofcambodia.org

ទុកក្នុងបំពង់ឫស្សី បើមិនមានបំពង់ឫស្សី គប្បីឲ្យអនុបសម្បន្នធ្វើអណ្ដូងក្នុងទីជិតហើយបំពក់ភ្លើងទុក ឬដំកល់ពំនួតភ្លើងទុក បើពំនួតភ្លើងមានហើយ មិនបាច់បំពក់ភ្លើងទុកក៏គួរ ។ សូម្បីភិក្ខុឥតដើរផ្លូវឆ្ងាយដាច់ស្រយាល ក៏គប្បីប្រាថ្នាពំនួតភ្លើងដូចភិក្ខុនៅព្រៃដូច្នោះដែរ តែបើនៅជាពួក ជាគណៈសូម្បីប្រាសចាកពំនួតភ្លើងក៏គួរ ។ មួយទៀត ភិក្ខុនៅព្រៃត្រូវដំកល់ឈើច្រត់ទុក ហើយត្រូវរៀនឲ្យដឹងផ្កាយនក្ខត្តឫក្សទាំងអស់ ឬដោយឯកទេសក៏បាន ហើយត្រូវជាអ្នកឈ្លាសស្គាល់ជាក់នូវទិសនោះៗ តាំងអំពីដំកល់ទឹកឆាន់ជាដើម ទាំងអម្បាលនេះ ត្រូវធ្វើដើម្បីក្សេមខ្លួនឲ្យរួចចាកអន្តរាយអំពីចោរ នេះឯងជាវត្តនៃភិក្ខុអ្នកនៅព្រៃ ភិក្ខុអ្នកនៅព្រៃគប្បីបដិបត្តិដូច្នេះចុះ ។

**អរញ្ញិកវត្ត ចប់**

---

## សេនាសនវត្ត

វត្តដែលភិក្ខុត្រូវធ្វើចំពោះទីសេនាសនៈ ។ សេចក្ដីថា ភិក្ខុអ្នកនៅក្នុងវិហារ ក្ដី ណា បើកុដិនោះខ្ពាំងដោយសម្រាម បើអាចនឹងបោសព្រោសបាន គប្បីបោសព្រោសចេញ កាលៈបោសព្រោសកុដិ គប្បីជញ្ជូនបាត្រចីវរចេញ យកទៅទុកដាក់ឲ្យសមគួរម្ខាងអង្គជាមុន ហើយជញ្ជូនសំពត់និសីទនៈ គ្រឿងកំរាលលើគ្រែ លើតាំង យកទៅតម្កល់ទុកក្នុងទីដ៏សមគួរ គប្បីជញ្ជូនពូក ខ្នើយ យកទៅតម្កល់ក្នុងទីសមគួរ គ្រែតាំង

www.budinst.gov.kh www.elibraryofcambodia.org

គប្បីធ្វើដោយគោរព កុំឲ្យប៉ះទង្គិចកោសសរសរទ្ធឹកទ្វារ ផ្ញាខចេញដោយប្រពៃ តាំងទុកមួយចំណែក ហើយផ្ញាខទ្រនាប់ជើងគ្រែ កន្ទេល ទីងក្តារបន្ទឹក ចេញទៅដាក់ទុកមួយចំណែក គ្រឿងកំរាលផ្ទៃ គប្បីកំណត់ទីក្រោលហើយផ្ញាខចេញទៅដាក់ទុកមួយចំណែក បើក្នុងវិហារមានសសៃពីងពាងទ្រស់យុង គប្បីបោសអំពីពិតានចុះមកមុន ។ បង្អួចដុះផ្សិតសៅហ្មង គប្បីជូតចេញ ។ បើជញ្ជាំងគេធ្វើបរិកម្មដោយវង្គ ឬផ្ទៃគេលាបពណ៌ខ្មៅ ដុះផ្សិតឡើង គប្បីយកកំណាត់សំពត់ជ្រលក់ទឹកពូតឲ្យស្រស់ជូតចេញ បើផ្ទៃគេមិនលាបពណ៌ទេ គប្បីយកទឹកបាចព្រំចុះមុនហើយសឹមជូត ។ កុំឲ្យល្អងធូលីហុយឡើងធ្លាក់ប្រឡាក់កុដិ គប្បីរើសសំរាមទៅចាក់ចោលក្នុងទីសមគួរ កុំបោកកុំគោះសេនាសនៈគ្រឿងកម្រាលជិតកុដិជិតវិហារ កុដិ ឬជិតទឹកបានទឹកប្រើ កុំបោក គោះក្នុងទីខ្ពស់លើខ្យល់ គប្បីបោក-គោះក្នុងទីក្រោមខ្យល់ ។ គ្រឿងកំរាលផ្ទៃ គប្បីហាលក្នុងទីសមគួរ ហើយបោសប្រោសចេញផ្ញាខក្រឡប់ទៅក្រាលទុកដូចដើមវិញ ។ ទ្រនាប់ជើងគ្រែ គប្បីហាលទុកមួយចំណែក ហើយជុសជូតផ្ញាខក្រឡប់ចូលទៅតាំងទុកដូចដើម គ្រែតាំងក៏គប្បីគោះបោសហាល ធ្វើដោយគោរព កុំឲ្យប៉ះពាល់ផល់ទង្គិច ផ្ញាខក្រឡប់យកទៅទុកកន្លែងដើម ។ ពូកខ្នើយនិងនិសីទនៈគ្រឿងកម្រាល លើគ្រែលើតាំង គប្បីហាលទុកមួយចំណែក ហើយគោះបោសផ្ញាខក្រឡប់ចូលទៅតាំងទុកតាមកន្លែងដើម ។ កន្ទេល ក្តារបន្ទឹក ក៏គប្បីហាលជូត

www.budinst.gov.kh www.elibraryofcambodia.org

ដុសលាន ហើយជញ្ជូនទៅតាំងទុកដូចដើម ៗ បាត្រចីវរក៏គប្បីដំកល់ទុក ដាក់ ៗ កាលទុកបាត្រ ដៃម្ខាងកាន់បាត្រ ដៃម្ខាងស្ទាបក្រោមគ្រែ ក្រោមតាំង ហើយសឹមទុកដាក់ កុំដំកល់បាត្រលើផ្ទៃ ដែលមិនមានរបស់ណាមួយរនាបមានស្លឹកឈើជាដើម ៗ កាលទុកដាក់ចីវរយកដៃម្ខាងកាន់ចីវរ ដៃម្ខាងជូតស្នងចីវរ ឬខ្សែស្បៀង លូកដៃពីខាងក្រោមស្នងចីវរសន្សឹមៗ ហើយពាក់បត់ជាយចីវរខាងនាយមកខាងមុខខ្លួន ៗ បើខ្យល់ប្រកបដោយល្អងធូលី បក់មកអំពីទិសណា គឺទិសខាងកើត ទិសខាងត្បូង ទិសខាងលិច ឬទិសខាងជើង គប្បីបិទបង្អួចខាងទិសនោះចេញ ៗ បើក្នុងរដូវរងា វេលាថ្ងៃគប្បីបើកបង្អួច វេលាយប់គប្បីបិទបង្អួច បើក្នុងរដូវក្តៅ វេលាថ្ងៃគប្បីបិទបង្អួច វេលាយប់គប្បីបើកទុក ៗ បើបរិវេណ បន្ទប់ទឹក រោងឆាន់ រោងភ្លើង ឬវច្ចកុដិ ទាំងនេះ ណាមួយពេញស្មុកដោយសម្រាម គប្បីបោសចេញ បើមិនមានទឹកឆាន់ ទឹកប្រើគប្បីដងមកតាំងទុក បើទឹកក្នុងក្អមជម្រះមិនមាន គប្បីដងមកដាក់ទុក ៗ បើនៅក្នុងកុដិជាមួយនឹងភិក្ខុចាស់ជាង មិនប្រាប់ភិក្ខុចាស់មុន កុំឲ្យឧទ្ទេសនឹងបរិបុច្ឆា គឺកុំប្រាប់បាលីនឹងអដ្ឋកថា កុំស្វាធ្យាយទន្ទេញសូត្រ កុំសំដែងធម៌ កុំអុជប្រទីប កុំលត់ប្រទីប កុំបើក កុំបិទបង្អួច តែទ្វារជាធំក្នុងការប្រើប្រាស់ ត្រូវការបិទត្រូវការបើក កិច្ចដែលនឹងប្រាប់ភិក្ខុចាស់ជាមុនមិនមាន តែការឲ្យឧទ្ទេសជាដើមក្រៅពីនោះ ត្រូវប្រាប់ភិក្ខុចាស់ជាមុនទើបធ្វើបាន នឹងប្រាប់រាល់ៗថ្ងៃក៏គួរ ៗ បើភិក្ខុចាស់នោះប្រាប់ទុកឲ្យស្រេច

www.budinst.gov.kh www.elibraryofcambodia.org

តែម្តង គឺជាមិនបាច់ប្រាប់ទៀត បើភិក្ខុចាស់ទទួលថាសាធុ ឬភិក្ខុចាស់ពោលខ្លួនឯងថា លោកចូរទៅតាមសប្បាយចុះ បើអនុញ្ញាតដូច្នេះហើយក៏គួរ ឬជាសភាគៈស្និទ្ធស្នាលគ្នា បើមិនប្រាប់ ព្រោះសេចក្តីស្និទ្ធស្នាលក៏គួរ ។ បើដើរក្នុងទីចង្រ្កមជាមួយនឹងភិក្ខុចាស់ជាងសោត កុំគប្បីត្រឡប់ឲ្យជួបមុខនឹងភិក្ខុចាស់ជាង កុំឲ្យប៉ះភិក្ខុចាស់ជាងដោយជាយសង្ឃាដី នេះឯងជាសេនាសនវត្ត ភិក្ខុទាំងឡាយ គប្បីប្រតិបត្តិដោយប្រពៃចុះ ។

សេនាសនវត្ត ចប់

## ជន្តាឃរវត្ត

វត្តដែលភិក្ខុត្រូវធ្វើចំពោះផ្ទះជាទីរក្សាកាយ ។ ខមួយ ព្រះអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ ជន្តាឃរេ ថេរេន ភិក្ខុនា និការិយមានេន អនាទរិយំ បដិច្ច បហុតំ កដ្ឋំ អារោ-បេត្វា អគ្គិ ទាតព្វោ យោ ទទេយ្យ អាបត្តិ ទុក្កដស្ស [១] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុជាព្រះថេរៈហាមឃាត់ក្នុងផ្ទះជាទីរក្សាកាយហើយ មិនត្រូវនាំគ្នាដាក់ឧសច្រើនបង្កាត់ភ្លើង ព្រោះអាស្រ័យសេចក្តីមិនអើពើទេ ភិក្ខុណាដាក់ ត្រូវអាបត្តិទុក្កដ ។

ខមួយ ព្រះអង្គទ្រង់ហាមឃាត់ទុកថា ន ច ភិក្ខវេ ទ្វារំ ថកេត្វា ទ្វារេ និសីទិតព្វំ យោ និសីទេយ្យ អាបត្តិ ទុក្កដស្ស [២] ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុមិនគប្បីបិទ

១-២-៣. ចុល្លវគ្គ តតិយភាគ វត្តក្ខន្ធៈ ទំព័រ ១២៩ ។

www.budinst.gov.kh www.elibraryofcambodia.org

ទ្វារ ហើយអង្គុយនៅប្រែបទ្វារទៀយ បើភិក្ខុណាអង្គុយត្រូវអាបត្តិទុក្កដ ៗ

សេចក្ដីកន្លងជន្តាឃរវត្តថា ភិក្ខុណាទៅកាន់ជន្តាឃរៈ គឺរោងភ្លើង ជាទីតាំងកាយឲ្យរំងាប់រោគមុនគេ បើមានផេះក្នុងរោងភ្លើងគ្រាសគោក ភិក្ខុនោះ គប្បីកើបចាក់ចោលចេញ បើរោងភ្លើងទីងប់ភក្ដ: គឺលានខាងក្រៅរោងភ្លើង ទីងប់វេណា បន្ទប់ឬសាលានៃរោងភ្លើង អម្បាលនេះ ធ្លាក់ទៅដោយសម្រាម គប្បីបោសចោលចេញ គប្បីកំទចុណ្ណ: គឺលំអិតជ័ទុក គប្បីយកដីសម្រាប់លាបមុខត្រាំទឹកទុក គប្បីយកទឹកដាក់ស្នុកទុកមុនហើយសឹមចូលទៅកាន់រោងភ្លើង កាលចូលទៅកាន់រោងភ្លើងត្រូវលាបមុខដោយដីស្អិត ហើយបិទបាំងខាងមុខខាងក្រោយ ហើយសឹមចូលទៅ កុំអង្គុយប្រជ្រៀតភិក្ខុជាថេរ: នឹងកុំហាមអាសនៈភិក្ខុកំឡោះ បើអាចគប្បីធ្វើបរិកម្ម គក់ច្របាច់ឲ្យភិក្ខុជាថេរៈក្នុងរោងភ្លើង កាលចេញចាករោងភ្លើង គប្បីកាន់យកតាំងសំរាប់រោងភ្លើងហើយបិទបាំងខាងមុខខាងក្រោយ ចេញចាករោងភ្លើង ៗ បើអាចគប្បីធ្វើបរិកម្មគឺដុសខាត់ខ្នងឲ្យភិក្ខុជាថេរៈក្នុងទឹកផង នឹងកុំងូតខាងមុខនៃភិក្ខុទាំងឡាយជាថេរៈ កុំងូតទឹកខាងលើព្រះថេរៈ កាលងូតរួចហើយនឹងឡើងមកវិញ គប្បីឲ្យផ្លូវដល់ភិក្ខុទាំងឡាយដែលកំពុងចុះទៅ ៗ ភិក្ខុណាចេញចាករោងភ្លើងក្រោយគេ បើរោងភ្លើងរអិលប្រឡាក់ ភិក្ខុនោះត្រូវលាងចេញ គប្បីលាងស្នូកដាក់ដីស្អិតរៀបទុកដាក់តាំងសម្រាប់រោងភ្លើង លត់ភ្លើងបិទទ្វារហើយគប្បីចៀសទៅ នេះឯង ជាជន្តាឃរវត្ត ភិក្ខុទាំងឡាយ គប្បីបដិបត្តិដោយ

www.budinst.gov.kh www.elibraryofcambodia.org

ប្រពៃចុះ ភេងភ្លើងនេះព្រះអង្គទ្រង់អនុញ្ញាតទុកដើម្បីដាំទឹកអាំងកាយ ដែលក្រាសដោយទោសធាតុអាហារដ៏ប្រណីត តាមពាក្យពេទ្យជីវកៈកោមារភ័ត ក្រាបទូល សព្វថ្ងៃនេះមិនប្រើភេងភ្លើង តែគប្បីប្រតិបត្តិក្នុងទំនៀមផ្ទុកទឹកនោះចុះ ។

ជន្តាឃរវគ្គ ចប់

---

## វច្ចកុដិវគ្គ

វត្តដែលភិក្ខុត្រូវធ្វើចំពោះវច្ចកុដិ (បង្គន់) ១ ខមួយ ព្រះអង្គទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ វច្ចំ កត្វា សតិ ឧទកេ ន អាចមេតព្វំ យោ នាចមេយ្យ អាបត្តិ ទុក្កដស្ស ម្នាលភិក្ខុទាំងឡាយ ភិក្ខុបន្ទោបង់ឧច្ចារៈហើយ កាលមានទឹកគប្បីលាងជម្រះ បើភិក្ខុណាមិនលាងជម្រះ ត្រូវទុក្កដ ។ បើមានទឹកតែមិនមានទឹកផ្តាំង គប្បីដងទឹកទៅដោយភាជនៈលាងជម្រះចេញក្នុងទឹកផ្តាំងចុះ ។ បើមិនមានភាជនៈ គប្បីដងទឹកទៅដោយបាត្រ បើមិនមានបាត្រ មិនមានភាជនៈឯទៀត គប្បីតាំងចិត្តថា ទ័រនេះរលណាស់ ទៅឯមុខគង់នឹងមានទឹកទៀត ហើយទៅ កាលទៅពុំបានទឹកសោះ បើវេលាប្រញាប់នឹងទៅកិច្ចការទៀត គឺគប្បីជូតកិតិដោយឈើ ឬដោយវត្ថុណាមួយហើយសិមទៅ សូម្បីឆាន់ ឬធ្វើអនុមោទនាក៏គួរ ។

www.budinst.gov.kh www.elibraryofcambodia.org

ខមួយ ព្រះអង្គទ្រង់ហាមឃាត់នឹងអនុញ្ញាតទុកថា ន ភិក្ខវេ វច្ចកុដិយា យថាវុឌ្ឍំ វច្ចោ កាតព្វោ យោ កាតេយ្យ អាបត្តិ ទុក្កដស្ស អនុជានាមិ ភិក្ខវេ អាគតបដិបាដិយា វច្ចំ កាតុំ ក្នុងវច្ចកុដិ ភិក្ខុកុំគប្បីទៅបន្ទោបង់ឧច្ចារៈតាមលំដាប់វស្សា បើភិក្ខុណាទៅបន្ទោបង់ឧច្ចារៈតាមលំដាប់ភិក្ខុចាស់ទុំ ត្រូវអាបត្តិទុក្កដ ។ តថាគតអនុញ្ញាតឲ្យទៅបន្ទោបង់ឧច្ចារៈតាមលំដាប់ដែលមកមុនក្រោយ ។ ក្នុងវច្ចកុដិ នឹងទីបន្ទោបង់បស្សាវៈ ទឹងកំពង់ទឹក ទាំង ៣ ស្ថាននេះ យកលំដាប់ភិក្ខុមកដល់មុននោះឯង ជាប្រមាណ ។

សេចក្តីក្នុងវច្ចកុដិវត្តថា ភិក្ខុណាទៅវច្ចកុដិ ភិក្ខុនោះគប្បីឈរនៅខាងក្រៅ ក្អកគ្រហែមទៀងមុខ ស្រាប់ភិក្ខុអង្គុយខាងក្នុង ក៏គប្បីក្អកគ្រហែមទទួល ហើយគប្បីពាក់ចីវរលើឈើស្នួ ខ្សែស្បៀង ហើយកុំប្រញាប់ សន្សឹមៗ ចូលទៅក្នុងវច្ចកុដិដោយប្រពៃ កុំចូលទៅឲ្យរហ័សពេក កុំសើយស្បង់ចូលទៅ គប្បីឈរលើទ្រនាប់ជើងសម្រាប់បន្ទោបង់វច្ចៈ ហើយសឹមសើយស្បង់ កុំប្រឹងរមាក់ក្អឹះៗ បន្ទោបង់ឧច្ចារៈ កុំបន្ទោបង់ឧច្ចារៈទាំងទំពាឈើស្ទន់ ។

មួយទៀត កុំបន្ទោបង់ឧច្ចារៈក្រៅទ្រនាប់វច្ចៈ កុំបន្ទោបង់បស្សាវៈក្រៅទ្របស្សាវៈ កុំស្តោះទឹកមាត់ ទឹកសំបោរចុះក្នុងទ្របស្សាវៈ កុំជូតកិតដោយឈើចំរៀក ឈើមុត ឈើបន្លា ឈើពក ឬឈើប្រហោង ឈើពុក ឈើរម្សូលនេះ កុំជូតកិត បើមានទឹកហើយមិនគាន់យកឈើជម្រះចូលទៅក្នុងវច្ចកុដិ មិនត្រូវអាបត្តិ ។

www.budinst.gov.kh www.elibraryofcambodia.org

មួយទៀត កុំពោលឈើជម្រះចុះក្នុងរណ្តៅវច្ចៈ បន្ទោបង់ឧច្ចារៈហើយ គប្បីឈរលើទ្រនាប់សម្រាប់បន្ទោបង់ បិទស្បង់ឲ្យជិតសិន កុំទាញមកជាប់ពេក កុំសើយស្បង់ចេញមក គប្បីឈរលើទ្រនាប់សម្រាប់ជម្រះហើយ សឹមសើយស្បង់ ជម្រះដោយទឹកកុំធ្វើឲ្យឮសំឡេងចបុះៗ កុំឲ្យទឹកសល់នៅក្នុងភាជនៈដាក់ទឹកជម្រះ រឿងនេះសង្គ្រោះតែក្នុងទីសាធារណៈទូទៅដល់ភិក្ខុទាំងពួង ដ្បិតបើក្នុងទីដូច្នោះ ភិក្ខុដទៃ ៗ មកក្រោយ ៗ ទៀតមិនមានសេចក្តីរង្កៀសក្នុងទឹកដែលសល់នោះនោះ ព្រោះហេតុនោះ ជម្រះហើយកុំធ្វើឲ្យទឹកសល់នៅក្នុងទីណាមួយឡើយ ប៉ុន្តែបើទីណាគេធ្វើទុកជាឯកទេសក្នុងវិហារសូម្បីរបស់បង្ស សម្រាប់ទៅបន្ទោបង់ឧច្ចារៈជានិច្ច ឬវច្ចកុដិរបស់បុគ្គល ក្នុងទីដូច្នោះមិនទុកទឹកឲ្យសល់នៅក្នុង បើធានចាំបញ្ចុះទៅបន្ទោបង់ឧច្ចារៈរឿយៗ មិនឲ្យសល់នៅក្នុងដោយពិត ។

មួយទៀត ជម្រះហើយ គប្បីឈរលើទ្រនាប់សម្រាប់ជម្រះ បិទដោយសំពត់ បើវច្ចកុដិប្រឡាក់ដោយឧច្ចារៈ គប្បីដងទឹកមកលាងចេញ ទឹកមាន តែភាជនៈមិនមាន ឬភាជនៈមាន តែទឹកមិនមាន កំឈ្មោះថា មិនមាន កាលមិនមានទាំង ២ ឈ្មោះថា មិនមានដោយពិត ។ គប្បីដុសដោយឈើ ឬវត្ថុណាមួយហើយសឹមទៅ បើកញ្ជើដាក់ឈើជម្រះពេញសោត គប្បីយកទៅចាក់ចេញ បើវច្ចកុដិឬទីបរិភណ្ឌៈ គឺទីកល ឬក្លោងទ្វារ ឬបរិវេណនៃវច្ចកុដិ ទាំងអម្បាលនេះណាមួយ ស្មុគដោយសម្រាម គប្បីបោសចោលចេញ បើទឹកក្នុងក្អមជម្រះមិនមានសោត គប្បីដងទឹក

www.budinst.gov.kh www.elibraryofcambodia.org

យកមកដាក់ នេះឯង ជាវច្ចកុដិវត្តនៃភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយ គប្បីបដិបត្តិដោយប្រពៃចុះ ។

វច្ចកុដិវត្ត ចប់

## ឧបជ្ឈាយវត្ត

វត្តដែលភិក្ខុត្រូវធ្វើចំពោះឧបជ្ឈាយ៍ ។ សេចក្ដីថា ភិក្ខុជាសទ្ធិវិហារិក គប្បីបដិបត្តិដោយប្រពៃក្នុងឧបជ្ឈាយ៍ ។ ឯសេចក្ដីបដិបត្តិប្រពៃនោះដូច្នេះ សទ្ធិវិហារិក គឺភិក្ខុនឹងសាមណេរ គប្បីក្រោកឡើងអំពីព្រឹក បើពាក់ស្បែកជើងដើរបង្ក្រម គប្បីដោះចេញ ហើយឃុំចីវរឆៀងស្មាម្ខាង គប្បីប្រគេនឈើស្ទន់ ប្រគេនទឹកលុបមុខ ទឹកខ្ពុរមាត់ ហើយក្រាលអាសនៈទុក បើបបរមាន គប្បីលាងភាជនៈ ដួសដាក់បបរនាំចូលទៅប្រគេន លុះព្រះឧបជ្ឈាយ៍ឆាន់បបររួចហើយ គប្បីប្រគេនទឹកឆាន់ ហើយទទួលភាជន បបរមកដោយគោរព កុំធ្វើឲ្យប៉ះទង្គិចអ្វី ៗ លាងទុកដាក់ឲ្យល្អ កាលឧបជ្ឈាយ៍ក្រោកឡើងហើយ គប្បីមូរអាសនៈទុក បើឧបជ្ឈាយ៍រៀបចូលទៅកាន់ស្រុក គប្បីប្រគេនស្បង់ នឹងទទួលស្បង់បន្លាស់ គប្បីប្រគេនវត្ថពន្ធចង្កេះ គប្បីគម្រួតឧត្តរាសង្គៈជាមួយនឹងសង្ឃាដិ ជាតំរដាន់ ហើយប្រគេន គប្បីជូតបាត្រដែលទទឹករួចហើយសឹមប្រគេន បើឧបជ្ឈាយ៍ត្រូវការឲ្យជាបច្ឆាសមណៈតាមទៅផង គប្បីបិទកាយឲ្យជាបរិមណ្ឌល បិទស្លៀកឲ្យជាបរិមណ្ឌលហើយ ចងវត្ថពន្ធចង្កេះ គម្រួតចីវរនឹងសង្ឃាដិ

www.budinst.gov.kh www.elibraryofcambodia.org

ផាតិជាន់ ឃុំពាក់ក្តី លាងបាត្រ កាន់យកបាត្រហើយ ជាបច្ឆា-
សមណៈទៅតាមក្រោយនៃឧបជ្ឈាយ៍ កុំដើរឲ្យជិតពេក ឲ្យឆ្ងាយពេក
ប្រមាណឲ្យល្មមឧបជ្ឈាយ៍បែរមកនិយាយផងបាន គឺល្មមឈានទៅមួយ
ជំហាន ពីរជំហានក៏ដល់ បើបាត្រឧបជ្ឈាយ៍ក្តៅ ឬពេញដោយបរ
ប្តាយ គប្បីទទួលបាត្រឧបជ្ឈាយ៍មក ផ្លាស់ប្រគេនបាត្ររបស់ខ្លួនឲ្យ
ទៅឧបជ្ឈាយ៍ កាលឧបជ្ឈាយ៍និយាយផង កុំពោលទទឹងស្កាក់ទៀងក្នុង
ចន្លោះៗ កាលឧបជ្ឈាយ៍ពោលពាក្យជិតនឹងត្រូវអាបត្តិ ក៏ធ្វើជាសួរថា
ពោលដូច្នេះគួរឬទេ មិនត្រូវអាបត្តិទេឬ គប្បីឃាត់ដូច្នេះ កុំឃាត់
ដោយពាក្យផ្ចួញផ្ចាល់ កាលត្រឡប់មកអំពីភូមិ គប្បីត្រឡប់មកមុន
ហើយក្រាលអាសនៈបម្រុងទុក ដំកល់ទឹកលាងជើង តាំងទើងជើង នឹង
ក្រនាប់ជូតជើងបម្រុងទុក ហើយក្រោកទៅទទួលបាត្រចីវរ គប្បី
ប្រគេនសំពត់ផ្លាស់ ហើយទៅទទួលសំពត់ដែលស្លៀកនោះមក បើចីវរ
ទទឹកដោយញើស គប្បីសំងួតក្នុងទីក្តៅមួយពេច តែកុំហាលទុក
ឲ្យយូរពេក ហើយគប្បីបត់ កាលនឹងបត់ចីវរ គប្បីបន្ថយជាយម្ខាងឲ្យ
ហួសៈទៅក្នុងជាយម្ខាង ប្រមាណ ៤ ធ្នាប់ហើយសឹមបត់ កុំឲ្យបាក់ពាក់
កណ្តាល គប្បីយកវត្តពន្ធចង្កេះទុកក្នុងផត់ចីវរ ។ បើបិណ្ឌបាតមាន
ឧបជ្ឈាយ៍ប្រាថ្នានឹងឆាន់ គប្បីប្រគេនទឹក ហើយគប្បីបង្អោនបិណ្ឌបាត
ចូលទៅ គប្បីសួរឧបជ្ឈាយ៍ដោយទឹកឆាន់ លុះឧបជ្ឈាយ៍ឆាន់រួច
ហើយ គប្បីប្រគេនទឹក ហើយគប្បីទទួលបាត្រមកកាន់បន្ទាបដោយប្រយ័ត

www.budinst.gov.kh www.elibraryofcambodia.org

កុំឲ្យជះទង្គិច ហើយលាងចេញធ្វើឲ្យស្អាតល្អដោយប្រពៃ ឲ្យអស់ទឹក ហើយទើបហាលទុក ក្នុងទីក្តៅមួយរំពេច តែកុំហាលបាត្រទោលទុកក្នុងទីក្តៅឲ្យយូរពេក ហើយគប្បីទុកដាក់បាត្រ ចីវរ កាលទុកដាក់បាត្រ ចីវរ គប្បីទុកដូចពោលហើយក្នុងសេនាសនវត្តនោះចុះ ។ កាលឧបជ្ឈាយ៍ក្រោកឡើងហើយ គប្បីសាអាសនៈនោះចេញ ទុកទឹកលាងជើង តាំងរងជើង ក្រទាប់ជូតជើង បើទីនោះខ្វាំដោយសម្រាម គប្បីបោសច្រាសចេញ ។ បើឧបជ្ឈាយ៍ចង់ស្រង់ទឹក គប្បីតាក់តែងទឹកប្រគេន បើត្រូវការដោយទឹកត្រជាក់ គប្បីតាក់តែងទឹកត្រជាក់ប្រគេន បើត្រូវការដោយទឹកក្តៅ គប្បីតាក់តែងទឹកក្តៅប្រគេន បើឧបជ្ឈាយ៍ប្រាថ្នានឹងចូលទៅកាន់រោងភ្លើង គប្បីកិនចុណ្ណៈគលំអិត យកដីស្អិតសម្រាប់លាបមុខត្រាំទឹកទុកហើយ កាន់តាំងសម្រាប់រោងភ្លើងដើរតាមក្រោយឧបជ្ឈាយ៍ទៅ ហើយប្រគេនតាំងសម្រាប់រោងភ្លើងដល់ឧបជ្ឈាយ៍ ទទួលយកចីវរមកទុកក្នុងទីសមគួរ គប្បីប្រគេនចុណ្ណៈ គលំអិតនឹងដីស្អិតសម្រាប់លាបមុខ បើអាចគប្បីចូលទៅក្នុងរោងភ្លើងជាមួយ កាលនឹងចូលទៅគប្បីប្រតិបត្តិដូចពោលហើយក្នុងវត្តនោះចុះ គប្បីធ្វើបរិកម្មកក់ប្រេងបាចប្រគេនឧបជ្ឈាយ៍ក្នុងរោងភ្លើង កាលនឹងចេញមកគប្បីប្រតិបត្តិដូចពោលហើយក្នុងវត្តនោះចុះ គប្បីធ្វើបរិកម្មដុសលាងប្រគេនឧបជ្ឈាយ៍ក្នុងទឹកផង ស្រង់ទឹករួចគប្បីឡើងមកមុន ជូតកាយរបស់ខ្លួនស្រស់ទឹកហើយផ្លាស់ស្បង់ ហើយគប្បីជូតទឹកប្រគេនឧបជ្ឈាយ៍ ហើយ

www.budinst.gov.kh www.elibraryofcambodia.org

គប្បីប្រគេនស្បង់បន្លាស់ ប្រគេនសំពត់សង្ឃាដី ហើយគប្បីកាន់យកតាំងសម្រាប់រោងភ្លើងមកតាំងទុកមុន គប្បីដាក់ទឹកលាងជើង ទ្រនាប់ជូតជើងទុកមុន គប្បីសួរឧបជ្ឈាយ៍ដោយទឹកឆាន់ ។

បើប្រាថ្នារៀនបាលី គប្បីឲ្យឧបជ្ឈាយ៍បង្រៀនចុះ បើប្រាថ្នាសាកសួរអដ្ឋកថា ក៏គប្បីសាកសួរអដ្ឋកថាចុះ ឧបជ្ឈាយ៍នៅក្នុងវិហារក្នុងណា បើវិហារក្នុងនោះ ខ្មាំដោយសំរាម បើអាចគប្បីបោសចេញ កាលនឹងជម្រះក្នុង គប្បីប្រតិបត្តិដូចពោលហើយក្នុងសេនាសនវត្តគ្រប់ប្រការរហូតដល់ដងទឹកដាក់ក្នុងក្អមជម្រះទុកចុះ ។

បើសេចក្តីអផ្សុក មិនត្រេកអរក្នុងព្រហ្មចរិយៈចង់លាសិក្ខា កើតឡើងដល់ឧបជ្ឈាយ៍សោត សទ្ធិវិហារិកគប្បីរម្ងាប់ ឬពឹងភិក្ខុដទៃឲ្យជួយរម្ងាប់ ឬធ្វើធម្មកថាលួងលោមឲ្យឧបជ្ឈាយ៍បាត់អផ្សុក បើសេចក្តីរង្កៀសសង្ស័យកើតឡើងដល់ឧបជ្ឈាយ៍ សទ្ធិវិហារិកគប្បីបន្ទោបង់ចេញ ឬពឹងគេឲ្យជួយបន្ទោបង់ឬធ្វើធម្មកថាឲ្យឧបជ្ឈាយ៍រម្ងាប់ចេញ បើទិដ្ឋិសេចក្តីយល់ខុសកើតឡើងដល់ឧបជ្ឈាយ៍ សទ្ធិវិហារិកគប្បីណែនាំឲ្យលះបង់ចេញ ឬពឹងភិក្ខុដទៃឲ្យណែនាំ ឬធ្វើធម្មកថាឲ្យឧបជ្ឈាយ៍រម្ងាប់បង់ចេញ ។

បើឧបជ្ឈាយ៍ត្រូវគរុកាបត្តិ គឺសង្ឃាទិសេស គួរនៅបរិវាស ឬនៅបរិវាសត្រូវអន្តរាបត្តិ ជាអ្នកគួរដល់មូលាយប្បដិកស្សនៈគឺទាញមកដាក់ក្នុងមូលាបត្តិ ឬនៅបរិវាសហើយ ជាអ្នកគួរដល់មានត្ត ឬនៅមានត្តហើយ ជាអ្នកគួរដល់អព្ភានកម្ម ក្នុង[illegible]នេះ សទ្ធិវិហារិកគប្បីធ្វើសេចក្តីខ្វល់

ខ្វាយថា សង្ឃនឹងគប្បីឲ្យបរិវាស នឹងមូលាយបដិកស្សនៈ នឹងមានត្ត នឹងអព្ភានកម្មដល់ឧបជ្ឈាយ៍ ដោយឧបាយដូចម្ដេចហ្ន៎ ដូច្នេះ ។

បើសង្ឃប្រាថ្នានឹងធ្វើនូវតជ្ជនីយកម្មក្តី និយស្សកម្មក្តី បព្វាជនីយកម្មក្តី បដិសារណីយកម្មក្តី ឧក្ខេបនីយកម្មក្តី ដល់ឧបជ្ឈាយ៍សោត សទ្ធិវិហារិកគប្បីខ្វល់ខ្វាយថា ធ្វើដូចម្ដេចសង្ឃនឹងមិនគប្បីធ្វើកម្មដល់ឧបជ្ឈាយ៍ ឬនឹងបង្អោនទៅដើម្បីកម្មស្រាល ដូច្នេះ ។ បើកម្មនោះ សង្ឃធ្វើដល់ឧបជ្ឈាយ៍ហើយសោត សទ្ធិវិហារិកគប្បីធ្វើសេចក្ដីខ្វល់ខ្វាយថា ធ្វើដូចម្ដេចហ្ន៎ ឧបជ្ឈាយ៍នឹងគប្បីបដិបត្តិប្រពៃ សង្ឃនឹងគប្បីរម្ងាប់កម្មនោះឲ្យ ដូច្នេះ ។

បើចីវរឧបជ្ឈាយ៍ល្មមនឹងលាង ចីវរឧបជ្ឈាយ៍គួរនឹងធ្វើ ទឹកជ្រលក់ឧបជ្ឈាយ៍គួរនឹងស្ងោរ ឬចីវរឧបជ្ឈាយ៍គួរនឹងជ្រលក់ កិច្ចទាំងអម្បាលនេះ សទ្ធិវិហារិកគប្បីធ្វើ ឬសទ្ធិវិហារិកគប្បីធ្វើសេចក្ដីខ្វល់ខ្វាយ ក្នុងកិច្ចទាំងអម្បាលនេះ ។ កាលដែលជ្រលក់ចីវរនៃឧបជ្ឈាយ៍ គប្បីជ្រលក់ថ្នមៗ ត្រឡប់ចុះឡើងដោយប្រពៃ កាលហាលគន់មើលឈ្នួរទឹកក្នុងចីវរ នៅមិនទាន់ដាច់ កុំអាលចៀសចេញទៅ ត្រូវនៅចាំសិន ។

មិនបានប្រាប់ឧបជ្ឈាយ៍មុន កុំឲ្យបាត្រចីវរបរិក្ខារ កុំអាលកោរសក់ ធ្វើបរិកម្មនឹងធ្វើសេចក្ដីខ្វល់ខ្វាយឲ្យដល់ភិក្ខុណាមួយ នឹងកុំទទួលបាត្រចីវរភិក្ខុណាមួយ កុំឲ្យភិក្ខុដទៃកោរសក់ឲ្យ ធ្វើបរិកម្មឲ្យ ធ្វើសេចក្ដីខ្វល់ខ្វាយឲ្យដល់ខ្លួន នឹងកុំធ្វើបច្ឆាសមណៈតាមក្រោយភិក្ខុដទៃទៅ កុំកាន់

www.budinst.gov.kh www.elibraryofcambodia.org

យកភិក្ខុដទៃជាបច្ឆាសមណៈ កុំនាំបិណ្ឌបាតទៅឲ្យភិក្ខុដទៃ កុំឲ្យភិក្ខុដទៃនាំបិណ្ឌបាតមកឲ្យ ដែលថាភិក្ខុដទៃនោះ គឺកំណត់យកភិក្ខុដែលជាវិសភាគ មិនត្រូវនឹងឧបជ្ឈាយ៍ គប្បីក្តីនឹងឧបជ្ឈាយ៍ជាមុនទើបធ្វើការទាំងអម្បាលនេះបាន ។

បើមិនលាឧបជ្ឈាយ៍ជាមុន កុំគប្បីចូលទៅក្នុងភូមិ កុំគប្បីទៅកាន់សុសានប្រទេស គឺទីផុតខ្មោច ដើម្បីនឹងទៅឬនឹងមើល កុំគប្បីទៅកាន់ទិស បើប្រាថ្នានឹងចូលទៅភូមិ ឬបិណ្ឌបាត ឬក៏ទៅដោយកិច្ចដទៃ គប្បីលាឧបជ្ឈាយ៍ជាមុនហើយសឹមទៅ ។ បើឧបជ្ឈាយ៍ប្រាថ្នានឹងក្រោកឡើងអំពីព្រឹកទៅកាន់ទីភិក្ខាចារឆ្ងាយសោត ឧបជ្ឈាយ៍ក៏គប្បីប្រាប់ភិក្ខុឈ្មោះថា អ្នកចូលទៅបិណ្ឌបាតចុះ ប្រាប់ដូច្នេះជាមុនហើយសឹមទៅ កាលបើមិនប្រាប់ដូច្នេះហើយទៅ សទ្ធិវិហារិកចូលទៅក្នុងបរិវេណមិនឃើញឧបជ្ឈាយ៍ នឹងចូលទៅក្នុងស្រុកក៏គួរ បើចូលទៅឃើញសោតតាំងអំពីទីដែលឃើញនឹងលាក៏គួរ សទ្ធិវិហារិកចង់ទៀសចេញទៅកាន់ទិសដទៃ គប្បីប្រាប់កាលហើយអង្វរលា ៣ ដង បើឧបជ្ឈាយ៍អនុញ្ញាតក៏ជាការល្អ បើមិនអនុញ្ញាតទេ តែបើនៅអាស្រ័យនឹងឧបជ្ឈាយ៍ហើយរៀន ឧទ្ទេស ឬបរិបុច្ឆា ឬកម្មដ្ឋាន ឬប្រារព្ធសេចក្តីព្យាយាម ទាំងអម្បាលនេះ មិនបានបរិបូណ៌ ព្រោះឧបជ្ឈាយ៍ជាមនុស្សល្ងង់មិនឆ្លាត មិនព្រមអនុញ្ញាត ចង់ឲ្យនៅតែក្នុងសំណាក់នៃខ្លួនម្យ៉ាងប៉ុណ្ណោះ ឧបជ្ឈាយ៍ដូច្នេះ សូម្បីហាមឃាត់ឲ្យនៅ បើនឹងទៅក៏គួរ ។

www.budinst.gov.kh www.elibraryofcambodia.org

បើឧបជ្ឈាយ៍មានជម្ងឺសោត សទ្ធិវិហារិកគប្បីឧបដ្ឋាកដរាបអស់កាលដែលលោកមានជីវិតរស់នៅ ឬចាំអាពាធសះជា កុំគប្បីទៅក្នុងទីណា ៗ បើមានកិច្ចអ្នកឧបដ្ឋាកដទៃនៅសោត គប្បីស្វែងរកភិក្ខុមកទុកក្នុងដៃកិច្ចនោះ ហើយប្រាប់ថា ភិក្ខុអង្គនេះនឹងឧបដ្ឋាកបំរើព្រះករុណា ហើយសឹមទៅ ៗ សទ្ធិវិហារិក គប្បីបដិបត្តិប្រពៃក្នុងឧបជ្ឈាយ៍ទាំងឡាយ យ៉ាងណា នេះឯង ជាឧបជ្ឈាយវត្តនៃសទ្ធិវិហារិក ៗ

ឧបជ្ឈាយវត្ត ចប់

## សទ្ធិវិហារិកវត្ត

វត្តដែលឧបជ្ឈាយ៍គប្បីធ្វើចំពោះសទ្ធិវិហារិក ៗ សេចក្តីថា ឧបជ្ឈាយ៍គប្បីបដិបត្តិប្រពៃ ក្នុងសទ្ធិវិហារិកទាំងឡាយ ៗ សេចក្តីបដិបត្តិដោយប្រពៃនោះដូច្នេះ ឧបជ្ឈាយ៍គប្បីសង្គ្រោះ គប្បីអនុគ្រោះ សទ្ធិវិហារិក ដោយឧទ្ទេស គឺប្រាប់បាលី ដោយបរិបុច្ឆា គឺប្រាប់សេចក្តីនៃបាលី ដោយឱវាទ គឺដំបូន្មាន ដោយអនុសាសនី គឺពាក្យប្រៀនប្រដៅ ៗ បើឧបជ្ឈាយ៍មានបាត្រចីវរនឹងសមណបរិក្ខារ ហើយសទ្ធិវិហារិកមិនមានសោត ឧបជ្ឈាយ៍គប្បីឲ្យ ឬគប្បីធ្វើសេចក្តីខ្វល់ខ្វាយថា ដូចម្តេចហ្ន៎ បាត្រ ចីវរ នឹងសមណបរិក្ខារ គប្បីកើតឡើងដល់សទ្ធិវិហារិកដូច្នេះ ៗ បើសទ្ធិវិហារិកឈឺ ឧបជ្ឈាយ៍គប្បីបដិបត្តិដូចពោលហើយក្នុងឧបជ្ឈាយវត្តគ្រប់ ១ ប្រការចុះ ផ្សេងតែទាំងអំពីឲ្យ

www.budinst.gov.kh www.elibraryofcambodia.org

ឈើស្ទន់ទៅ ដូចឧបជ្ឈាយវត្តគ្រប់ៗ រឿង រៀរតែឧបជ្ឈាយ៍ មិនត្រូវសំពះលាសទ្ធិវិហារិក គ្រាន់តែប្រាប់ប៉ុណ្ណោះ តាំងអំពីឲ្យឈើស្ទន់ទៅ លុះដល់ដងទឹកទុកក្នុងក្អមជម្រះ វត្តទាំងអម្បាលនេះ ឧបជ្ឈាយ៍គប្បីធ្វើដល់សទ្ធិវិហារិក ក្នុងកាលដែលមានជម្ងឺមួយចំពួក ៗ តែការដែលនាំសទ្ធិវិហារិកទៅ ដើម្បីរម្ងាប់សេចក្តីរសាប់រសល់ក្រវល់ក្រវាយជាដើមទៅ សូម្បីសទ្ធិវិហារិកមិនឈឺ ឧបជ្ឈាយ៍ក៏ត្រូវធ្វើដោយពិត ៗ ការគក់លាងចីវរ ស្ងោរទឹកជ្រលក់ ជ្រលក់ចីវរ ទាំងអម្បាលនេះ ឧបជ្ឈាយ៍គប្បីប្រដៅសទ្ធិវិហារិកឲ្យធ្វើដោយគោរពចុះ ឧបជ្ឈាយ៍ទាំង-ឡាយ គប្បីបដិបត្តិប្រពៃ ក្នុងសទ្ធិវិហារិកយ៉ាងណា នេះឯង ជាសទ្ធិវិហារិកវត្ត របស់ឧបជ្ឈាយ៍ ។

សទ្ធិវិហារិកវត្ត ចប់

## អាចរិយវត្ត

វត្តដែលអន្តេវាសិក គប្បីធ្វើចំពោះអាចារ្យ ។ សេចក្តីថា អន្តេវាសិកអ្នកកាន់និស្ស័យនៅជាមួយនឹងអាចារ្យ គប្បីបដិបត្តិដោយប្រពៃក្នុងអាចារ្យ សេចក្តីបដិបត្តិដោយប្រពៃក្នុងអាចារ្យ ដូចឧបជ្ឈាយវត្តគ្រប់ប្រការ ។

អាចរិយវត្ត ចប់

www.budinst.gov.kh www.elibraryofcambodia.org

## អន្តេវាសិកវត្ត

វត្តដែលអាចារ្យគប្បីធ្វើចំពោះអន្តេវាសិក ៗ សេចក្តីថា អាចារ្យអ្នកឲ្យនិស្ស័យ គប្បីបដិបត្តិប្រពៃក្នុងអន្តេវាសិក សេចក្តីបដិបត្តិប្រពៃក្នុងអន្តេវាសិក ដូចសទ្ធិវិហារិកវត្តគ្រប់ប្រការ ។

អន្តេវាសិកវត្ត ចប់

វត្តទាំង ១៤ នេះ ភិក្ខុអាស្រ័យសេចក្តីមិនអើពើ មិនធ្វើតាម ត្រូវទុក្កដ ក្នុងខណៈកាលដាក់ធុរៈថានឹងមិនធ្វើគ្រប់វត្តទៅ ៗ តែក្នុងរឿងណាជាពាក្យបដិសេធហាមប្រកបដោយ ន អក្ខរៈ ថាកុំ ៗ មិន ៗ បើព្យាយាមធ្វើក្នុងរឿងនោះ ៗ ត្រូវទុក្កដ ក្នុងខណៈកាលប្រព្រឹត្តកន្លងគ្រប់ ៗ ខ ។

## វិធីកាន់យកនិស្ស័យ

កុលបុត្រអ្នកទើបនឹងបួស គប្បីកោរសក់ កោរពុកមាត់ ហើយទទួលសំពត់កាសាវពស្ត្រអំពីភិក្ខុ រួចស្លៀកដណ្តប់ហើយ ទទួលសរណៈគមន៍ក្នុងសំណាក់ភិក្ខុ ហើយអង្គុយច្រហោង ថ្វាយបង្គំបាទាទាំងពីរ លើកដៃប្រណម្យ ក្នុងសំណាក់ភិក្ខុណា ហើយពោលថា ឧបជ្ឈាយោ មេ ភន្តេ ហោហិ អស់វារៈ ៣ ដង សេចក្តីថា លោកចូរជាឧបជ្ឈាយ៍នៃខ្ញុំផងចុះ ៗ ភិក្ខុនោះឲ្យកុលបុត្រនោះដឹងសេចក្តីដោយពាក្យថា សាហុ ឬ លហុ ឬឱបាយិកំ ឬ បដិរូបំ ឬបាសាទិកេន

www.budinst.gov.kh www.elibraryofcambodia.org

សម្បាទេមិ ពាក្យទាំងអម្បាលនេះ ដោយបទណាមួយ ភិក្ខុអ្នកឲ្យ កុលបុត្រឯនោះឈ្មោះថាឧបជ្ឈាយ៍ កុលបុត្រអ្នកសូមនោះជាសាមណេរក្តី ឬបានឧបសម្បទាជាភិក្ខុក្តី ឈ្មោះថាសទ្ធិវិហារិក ។ សទ្ធិវិហារិកនោះគប្បីបដិបត្តិដោយប្រពៃក្នុងឧបជ្ឈាយ៍ បើជាភិក្ខុមិនបដិបត្តិដោយប្រពៃ ត្រូវទុក្កដ ។ សទ្ធិវិហារិក កាលមិនធ្វើវត្តតាំងអំពីឲ្យឈើស្ទន់ជាដើម រហូតដល់ជ្រលក់ចីវរ សេចក្តីសាបសូន្យរមែងមានដល់ឧបជ្ឈាយ៍ ព្រោះហេតុនោះ សទ្ធិវិហារិក កាលមិនធ្វើវត្តនោះ សូម្បីជានិស្ស័យមុត្តក (រួចនិស្ស័យហើយ) ក្តី នៅមិនទាន់រួចក្តី គង់ត្រូវអាបត្តិដោយពិត ។ កាលមិនធ្វើវត្តតាំងអំពីមិនប្រាប់ឧបជ្ឈាយ៍មុន ហើយឲ្យបាត្រចីវរជាដើមដល់បុគ្គលពួកខ្លះ ចំពោះតែដែលនៅមិនទាន់រួចនិស្ស័យម្យ៉ាង ទើបត្រូវអាបត្តិ ។ ឧបជ្ឈាយ៍មិនបដិបត្តិប្រពៃក្នុងសទ្ធិវិហារិក ក៏ត្រូវអាបត្តិទុក្កដដល់ឧបជ្ឈាយ៍ ។ ឧបជ្ឈាយ៍បដិបត្តិល្អ សទ្ធិវិហារិកទាំងឡាយមិនបដិបត្តិល្អ ត្រូវអាបត្តិដល់សទ្ធិវិហារិកទាំងឡាយនោះ ។ កាលឧបជ្ឈាយ៍ត្រេកអរនឹងវត្ត សទ្ធិវិហារិកសូម្បីច្រើនគ្នាមិនធ្វើ ក៏ត្រូវអាបត្តិដូចគ្នាទាំងអស់ ។ បើឧបជ្ឈាយ៍ពោលថា មនុស្សអ្នកឧបដ្ឋាកយើងមាន លោកទាំងឡាយចូរធ្វើសេចក្តីព្យាយាម ក្នុងការស្វាធ្យាយនិងមនសិការៈកម្មដ្ឋានជាដើមនៃខ្លួនចុះ ដូច្នេះមិនត្រូវអាបត្តិ ដល់សទ្ធិវិហារិកទាំងឡាយ ។ ឧបជ្ឈាយ៍ជាមនុស្សខ្ជិល មិនដឹងនូវការដែលគួរត្រេកអរ ឬមិនគួរត្រេកអរនឹងវត្ត កាលសទ្ធិវិហារិកច្រើនគ្នា អង្គណាមួយ ជាអ្នកបរិបូណ៌ដោយវត្តៈ

www.budinst.gov.kh www.elibraryofcambodia.org

បដិបត្តិធ្វើឲ្យជាការៈលើខ្លួនថា ខ្ញុំនឹងធ្វើកិច្ចដល់ឧបជ្ឈាយ៍ដោយខ្លួនខ្ញុំ លោកទាំងឡាយ ចូរមានសេចក្ដីខ្វល់ខ្វាយតិចចុះ ដូច្នេះចាប់តាំងអំពីលោកអង្គនោះធ្វើឲ្យជាការៈខ្លួនហើយ មិនមានអាបត្តិដល់សទ្ធិវិហារិកទាំងអម្បាលនោះទៀយ ។

ភិក្ខុមិនមានឧបជ្ឈាយ៍ សូមនិស្ស័យដោយអាការដូចពោលមកហើយខាងដើម ក្នុងសំណាក់នៃភិក្ខុដែលជាពហុស្សុត មានវស្សា ១០ ឡើងទៅ អង្គណាមួយ ដោយពាក្យថា អាចរិយោ មេ ភន្តេ ហោហិ អាយស្មតោ និស្សាយ វច្ឆាមិ ដូច្នេះ (អស់វារៈ ៣ ដង) ហើយភិក្ខុនោះឲ្យដឹងសេចក្ដីដោយពាក្យថា សាធុ ជាដើម ពាក្យណាមួយ លោកនោះឈ្មោះថាអាចារ្យអ្នកឲ្យនិស្ស័យ ។ អ្នកសូមនិស្ស័យ ឈ្មោះថានិស្សយន្តេវាសិក ជាសិស្សនៅក្នុងខាងក្នុងដោយនិស្ស័យ ដែលនឹងត្រូវអាបត្តិដល់អន្តេវាសិកបែបនេះ គប្បីដឹងដោយលក្ខណៈដូចពោលហើយក្នុងសទ្ធិវិហារិក ដែលមិនធ្វើវត្តដល់ឧបជ្ឈាយ៍នោះចុះ ព្រោះថានិស្សយន្តេវាសិក អ្នកអាស្រ័យនៅ នៅអាស្រ័យអាចារ្យដកបណា ត្រូវធ្វើអាចរិយវត្តដកបនោះ ។ តែបព្វជ្ជន្តេវាសិក សិស្សអ្នកចូលសរណគមន៍បួសជាសាមណេរ ឬឧបសម្បទន្តេវាសិក សិស្សដែលលោកសូត្រកម្មវាចា ឲ្យជាឧបសម្បន្នភិក្ខុ ឬធម្មន្តេវាសិក សិស្សអ្នករៀនធម៌ ៣ នេះ សូម្បីជានិស្សយមុត្ត រួចនិស្ស័យហើយ ក៏នៅត្រូវធ្វើអាចរិយវត្ត តាំងអំពីដើមលុះដល់ផ្តលក់ចីវរ តែក្នុងវត្តជាដើមថា

www.budinst.gov.kh www.elibraryofcambodia.org

មិនប្រាប់អាចារ្យជាមុន កុំឲ្យបាត្រចីវរដល់មនុស្សដទៃជាដើម ដកបទ៧ មិនមានអាបត្តិ ដល់អន្តេវាសិក ៣ ចំពួកនោះទេ ។ បព្វជ្ជន្តេវាសិក នឹងឧបសម្បទន្តេវាសិក ២ នេះ ជាការនៅលើអាចារ្យដរាបដល់អស់ជីវិត ។ តែនិស្សយន្តេវាសិក នឹងធម្មន្តេវាសិក ២ នេះ នៅក្នុងទីជិតអាចារ្យដរាបណា ជាការលើអាចារ្យដរាបនោះ ។ ព្រោះហេតុនោះ សូម្បីអាចារ្យក៏គប្បីប្រតិបត្តិប្រពៃក្នុងអន្តេវាសិកទាំងអម្បាលនេះ ព្រោះថា បណ្ដាអាចារ្យ នឹងអន្តេវាសិកទាំងឡាយ អ្នកណា មិនប្រតិបត្តិប្រពៃតាមវត្តត្រូវអាបត្តិដល់អ្នកនោះ ព្រោះថាព្រះអង្គទ្រង់ប្រាថ្នានឹងឲ្យគោរពដល់គ្នានឹងគ្នា ទើបបានទ្រង់អនុញ្ញាតឧបជ្ឈាយ៍នឹងអាចារ្យទុកដូច្នេះថា តថាគតអនុញ្ញាតឧបជ្ឈាយ៍ តថាគតអនុញ្ញាតអាចារ្យ ម្នាលភិក្ខុទាំងឡាយ ឧបជ្ឈាយ៍នឹងអាចារ្យ គប្បីតាំងចិត្តដោយសេចក្ដីស្រឡាញ់ក្នុងសទ្ធិវិហារិក នឹងអន្តេវាសិក ថាជាបុត្ររបស់ខ្លួន ៗ សទ្ធិវិហារិកនឹងអន្តេវាសិក គប្បីតាំងចិត្តដោយសេចក្ដីស្រឡាញ់ ក្នុងឧបជ្ឈាយ៍នឹងអាចារ្យ ថាជាបិតារបស់ខ្លួន ៗ កាលបើបដិបត្តិដូច្នេះ ភិក្ខុទាំងឡាយនោះ នឹងគោរពកោតក្រែងដល់គ្នានឹងគ្នា នឹងមានការចិញ្ចឹមជីវិតស្មើគ្នា ហើយនឹងដល់នូវសេចក្ដីចំរើនលូតលាស់ល្អពេញបរិបូណ៌ក្នុងធម្មវិន័យនេះ ព្រោះហេតុនោះ គួរប្រតិបត្តិឲ្យប្រពៃដល់គ្នានឹងគ្នា ។

•

វិធីកាន់យកនិស្ស័យ ចប់

# ការរម្ងាប់និស្ស័យ

ការរម្ងាប់និស្ស័យចាកឧបជ្ឈាយ៍មាន ៥ គឺ បក្កន្តោ វា ហោតិ ឧបជ្ឈាយ៍ចៀសចេញទៅកាន់ទិស ចាកអាវាស ១ វិព្ភន្តោ វា ឧបជ្ឈាយ៍សឹកទៅ ១ កាលង្កតោ វា ឧបជ្ឈាយ៍ ធ្វើមរណកាល ១ បក្ខសង្កន្តោ វា ឧបជ្ឈាយ៍ទៅជាពួកអន្យតិរ្ថិយ ១ អាណត្តិយេវ បញ្ចមី សទ្ធិវិហារិកប្រកបដោយអង្គជាទោសប្រាំ (១) ដែលឧបជ្ឈាយ៍ប្រណាមចេញ ជាគំរប់ ៥ ។ ដែលជានិស្ស័យរម្ងាប់ដោយឧបជ្ឈាយ៍ព្រាសចាកអាវាសចៀសទៅកាន់ទិសដទៃនោះ កាលលោកទៅហើយ បើក្នុងវិហារនោះអាចារ្យអ្នកឲ្យនិស្ស័យណាមួយមាននៅសោត គឺក្នុងកាលមុនធ្លាប់កាន់និស្ស័យនៅក្នុងសំណាក់ លោកអង្គណា ឬថាលោកអង្គណាដែលមានសម្ភោគៈនឹងបរិភោគជាមួយគ្នា ក៏គប្បីកាន់និស្ស័យក្នុងសំណាក់នៃលោកអង្គនោះ ៗ ព្រោះសូម្បីតែមួយថ្ងៃក៏ពុំមានការបរិហារឡើយ ។ បើអាចារ្យបែបនោះ មិនមានសោត ក៏ក្នុងដទៃជាលជ្ជីមានសីលជាទីស្រឡាញ់មាននៅ កាលដឹងថាលោកនោះជាអ្នកមានសីលជាទីស្រឡាញ់ហើយ ក៏គប្បីសូមនិស្ស័យនឹងលោកនោះក្នុងថ្ងៃនោះ បើលោកនោះឲ្យជាការល្អ តែបើលោកសួរថា ឧបជ្ឈាយ៍

(១) អង្គ ៥ នោះសទ្ធិវិហារិក គ្មានសេចក្ដីស្រឡាញ់ឧបជ្ឈាយ៍ដោយពិត ១ គ្មានសេចក្ដីជ្រះថ្លាដោយពិត ១ គ្មានសេចក្ដីអៀនខ្មាសដោយពិត ១ គ្មានសេចក្ដីគោរពដោយពិត ១ គ្មានសេចក្ដីចំរើនមេត្តាភាវនាដោយពិត ១ ។ វិន័យបិដក មហាវគ្គ បឋមភាគ ទំព័រ ១៦៨ ។

www.budinst.gov.kh www.elibraryofcambodia.org

នៃអ្នកនឹងមកឆាប់ឬ ហើយបើឧបជ្ឈាយ៍ផ្ដាំទុកថា នឹងមកឆាប់សោត ក៏គប្បីប្រាប់ថា លោកនឹងមកឆាប់ បើលោកប្រាប់ថា បើដូច្នេះ លោកចូររង់ចាំឧបជ្ឈាយ៍លោកមកចុះ ដូច្នេះក៏គួរ ។ បើមិនដឹងថា ភិក្ខុនោះមានសីលជាទីស្រឡាញ់ ក៏គប្បីសង្កេតមើលថា ភិក្ខុនោះ ជាសភាគៈ ឬមិនជាសភាគៈ ប្រមាណ ៤-៥ ថ្ងៃសិនហើយ សឹមឲ្យ ធ្វើឱកាស រួចកាន់និស្ស័យក្នុងសំណាក់ភិក្ខុនោះ ថាបើក្នុងវិហារ ភិក្ខុឲ្យ និស្ស័យមិនមានសោត តែឧបជ្ឈាយ៍ប្រាប់ទុកថា យើងនឹងទៅប្រមាណ ពីរបីថ្ងៃ លោកកុំអផ្សុកឡើយ ដូច្នេះរមែងមានការបរិហារដរាបដល់ ឧបជ្ឈាយ៍ត្រឡប់មក ។ ថាបើទាយកគេនិមន្តឧបជ្ឈាយ៍ ឲ្យនៅក្នុងទីនោះ ទៀត ៥ ថ្ងៃ ឬ ១០ ថ្ងៃ លើសជាងកាលកំណត់ឡើងទៅ ឧបជ្ឈាយ៍នោះ គប្បីបញ្ជូនដំណឹងមកកាន់វិហារថា ភិក្ខុកំឡោះទាំងឡាយ កុំអផ្សុកឡើយ យើងនឹងមកក្នុងថ្ងៃឯណោះ សូម្បីដូច្នេះក៏នៅមានការបរិហារទៀត ។ កាលឧបជ្ឈាយ៍ត្រឡប់មក បើមានសេចក្ដីអន្តរាយកើតឡើងកណ្ដាលផ្លូវ ដោយទឹកជន់ពេញក្នុងស្ទឹង ឬចោរជាដើមសោត ឧបជ្ឈាយ៍រង់ចាំទឹក ស្រកទៅ ឬស្វែងរកមិត្រសំឡាញ់ បើភិក្ខុកំឡោះបានឮដំណឹងដូច្នោះ សោត ក៏នៅមានបរិហារដរាបដល់ឧបជ្ឈាយ៍មក ។ បើឧបជ្ឈាយ៍ផ្ដាំថា យើងនឹងនៅក្នុងទីនោះសោត ដូច្នេះការបរិហារមិនមានឡើយ ។ បាន និស្ស័យក្នុងទីណា គប្បីទៅទីនោះ ៗ កាលបើឧបជ្ឈាយ៍សឹកឃ្លាតចាក សាសនា ឬចូលអនិច្ចធម្ម ឬត្រឡប់ទៅជាអន្យតិរ្ថិយ ៗ យ៉ាងនេះ

www.budinst.gov.kh www.elibraryofcambodia.org

ការបរិហារសម្បូរតែមួយថ្ងៃ ក៏គ្មានទៀយ ធ្លាប់បាននិស្ស័យក្នុងទីណា គប្បីទៅក្នុងទីនោះចុះ ។ ដែលថានិស្ស័យរម្ងាប់ដោយឧបជ្ឈាយ៍ប្រណាមនោះ សទ្ធិវិហារិកមិនប្រតិបត្តិប្រពៃ ឧបជ្ឈាយ៍គប្បីប្រណាមចេញដោយពាក្យថា បណាមេមិ តំ ឬថា មាយិធ បដិក្កមិ ឬថា នីហារ តេ បត្តចីវរំ ឬថា នាហំ តយា ឧបដ្ឋាតព្វោ ដូច្នេះ បទណាមួយ ឬពោលពាក្យផុតពាក្យបាលីថា ដើមថា អ្នកកាលចូលទៅស្រុក កុំប្រាប់ដល់យើងទៀតដូច្នេះ ឈ្មោះថាប្រណាមចេញចាកនិស្ស័យ និស្ស័យរម្ងាប់ ។ ភិក្ខុនោះគប្បីសូមឧបជ្ឈាយ៍ឲ្យអត់ទោស បើឧបជ្ឈាយ៍មិនអត់ទោសអំពីដើមទៅសោត ភិក្ខុនោះគប្បីធ្វើទណ្ឌកម្មខ្លួនឯង មានដងទឹកជញ្ជូនខ្សាច់ជាដើម ហើយសូមខមាទោសខ្លួនឯង ៣ ដងសិន បើឧបជ្ឈាយ៍មិនអត់ទោសឲ្យសោត គប្បីនាំមហាថេរ ក្នុងវិហារនោះទៅជួយសូមខមាទោសឲ្យ ។ ថាបើឧបជ្ឈាយ៍មិនអត់ទោសឲ្យទៀតសោត គប្បីនាំភិក្ខុទាំងឡាយ ក្នុងវិហារជិតមកឲ្យជួយសូមខមាទោសឲ្យ ថាបើធ្វើដូច្នេះហើយ ឧបជ្ឈាយ៍មិនអត់ទោសឲ្យទៀតសោត គប្បីទៅក្នុងទីដទៃហើយនៅក្នុងទីសំណាក់ភិក្ខុទាំងឡាយដែលជាសភាគៈដល់ឧបជ្ឈាយ៍ ដោយគិតថា ក្រែងឧបជ្ឈាយ៍ដឹងថានៅក្នុងសំណាក់ភិក្ខុជាសភាគៈរបស់លោកហើយ នឹងអត់ទោសឲ្យ សូម្បីដូច្នេះ លោកនៅតែមិនអត់ទោសឲ្យ គឺគប្បីនៅក្នុងទីនោះចុះ ។ បើមិនអាចនៅក្នុងទីនោះបាន ដោយទោសមានអត់បាយ

www.budinst.gov.kh www.elibraryofcambodia.org

ជាដើម នឹងត្រឡប់មកវិហារដើមនោះ រួចកាន់និស្ស័យក្នុងសំណាក់ភិក្ខុដទៃក៏គួរ ៗ នេះជាសេចក្តីវិនិច្ឆ័យនិស្ស័យរម្ងាប់ចាកឧបជ្ឈាយ៍ ៗ

ឯការរម្ងាប់និស្ស័យចាកអាចារ្យមាន ៦ គឺ អាចារ្យចៀសចេញទៅកាន់ទិស ១ សឹកទៅ ១ ធ្វើមរណកាល ១ ទៅជាពួកអន្យតិរ្ថិយ ១ នឹងប្រណាមចេញជាគំរប់ ៥ ឧបជ្ឈាយេន វា សមោធានគតោ ឬបានជួប បានឃើញឧបជ្ឈាយ៍ បានឮសំឡេងឧបជ្ឈាយ៍ហើយក៏ចាំបាន ជាគំរប់ ៦ ៗ ដែលថាចៀសចេញទៅកាន់ទិសនោះ មានកាលអាចារ្យ ប្រាប់មុនទើបចៀសទៅ ៗ មានកាលអាចារ្យមិនប្រាប់ សូម្បីអន្តេវាសិកក៏ ដូចគ្នា ៗ ថាបើអន្តេវាសិកលាអាចារ្យថា ខ្ញុំប្រាថ្នានឹងទៅកាន់ទីឯណោះ ដោយកិច្ចណាមួយ អាចារ្យសួរថានឹងទៅក្នុងកាលណា ប្រាប់ថានឹង ទៅវេលាល្ងាច ឬនឹងក្រោកឡើងទៅក្នុងវេលាយប់ សូម្បីអាចារ្យទទួល ថាប្រពៃហើយ និស្ស័យក៏រម្ងាប់ក្នុងខណៈនោះ ៗ បើលាថា ខ្ញុំប្រាថ្នានឹង ទៅកាន់ទីឯណោះ អាចារ្យប្រាប់ថា លោកទៅបិណ្ឌបាតក្នុងភូមិឯណោះ ហើយ ទើបនឹងដឹងក្នុងកាលជាខាងក្រោយ ទាំងអន្តេវាសិកនោះក៏ទទួល ថាប្រពៃហើយ បើទៅតាមភូមិនោះឈ្មោះថាទៅដោយប្រពៃ បើមិនទៅ និស្ស័យក៏មិនរម្ងាប់ ៗ បើលាថានឹងទៅ អាចារ្យថាកុំអាលទៅ ចាំវេលា យប់ យើងនឹងប្រឹក្សាមើលសិនទើបដឹង ប្រឹក្សាហើយទៅ ឈ្មោះថាទៅ ដោយប្រពៃ ថាបើមិនទៅសោត និស្ស័យក៏មិនរម្ងាប់ ៗ ឯមិនលាអាចារ្យ ហើយចៀសចេញទៅ សូម្បីគ្រាន់តែផុតឧបចារសីមា និស្ស័យក៏រម្ងាប់ កាល

www.budinst.gov.kh www.elibraryofcambodia.org

ត្រឡប់មកវិញចាកខាងក្នុងឧបចារសីមា មិនរម្ងាប់ បើអាចារ្យប្រាប់អន្តេ-វាសិកថា យើងនឹងទៅកាន់ទីឯណោះ តែអន្តេវាសិកសួរថាលោកនឹងទៅវេលាណា ប្រាប់ថានឹងទៅក្នុងវេលារសៀល ឬព្រឹក សូម្បីអន្តេវាសិកទទួលថាប្រពៃហើយ និស្ស័យក៏រម្ងាប់ក្នុងខណៈនោះ ៗ បើអាចារ្យប្រាប់ថាព្រឹកស្អែកទៅបិណ្ឌបាតហើយសឹមទៅ ឯអន្តេវាសិកក៏ទទួលថាប្រពៃហើយ និស្ស័យនៅមិនទាន់រម្ងាប់ ក្នុងថ្ងៃមួយនោះទេ លុះដល់ក្នុងថ្ងៃព្រឹកស្អែកទើបបានរម្ងាប់ ៗ បើអាចារ្យប្រាប់ថានឹងទៅបិណ្ឌបាតក្នុងភូមិឯណោះ ហើយទើបនឹងដឹងថាទៅឬមិនទៅ ថាបើមិនទៅទេ និស្ស័យក៏មិនរម្ងាប់ ៗ បើប្រាប់ថានឹងទៅ អន្តេវាសិកឃាត់ថាកុំអាលទៅចាំវេលាក្រោយប្រឹក្សាមើលទើបនឹងដឹង បើប្រឹក្សាហើយមិនទៅ និស្ស័យមិនរម្ងាប់ ៗ កាលអាចារ្យនឹងអន្តេវាសិក ទាំងពីរទៅក្រៅសីមា ដោយកិច្ចណាមួយ បើអាចារ្យមានចិត្តគិតនឹងទៅកើតឡើងក្នុងទីនោះ មិនប្រាប់ហើយទៅ រួចត្រឡប់មកវិញក្នុងខាងក្នុង ២ លេឌ្ឌុបាតសោត និស្ស័យមិនរម្ងាប់ បើកន្លង ២ លេឌ្ឌុបាតចេញទៅហើយត្រឡប់មក និស្ស័យទើបរម្ងាប់ អាចារ្យនឹងឧបជ្ឈាយ៍ កន្លង ២ លេឌ្ឌុបាតចេញទៅ ហើយនៅក្នុងវិហារដទៃ និស្ស័យក៏រម្ងាប់ ៗ កាលអាចារ្យឃ្លាតចាកសាសនា នឹងទទួលអនិច្ចធម្ម ឬត្រឡប់ទៅជាអន្យតិរ្ថិយ និស្ស័យរម្ងាប់ក្នុងខណៈនោះឯង ៗ ឯក្នុងការប្រណាមអន្តេវាសិក ដែលមិនបានប្រព្រឹត្តល្អ ដោយពាក្យ ជាដើមថា បណាមេមិ តំ នោះ ថាបើអាចារ្យប្រាថ្នានឹងបោះ

www.budinst.gov.kh www.elibraryofcambodia.org

បន្ទោល ដោយប្រណាមនិស្ស័យ តែអន្តេវាសិកនៅមានអាល័យចំ
អាចារ្យប្រណាមហើយក៏ពិតមែនហើយ ប៉ុន្តែលោកនៅមានចិត្តទន់នៅ
ឡើយដូច្នេះ និស្ស័យមិនរម្ងាប់ ៗ បើអាចារ្យមានអាល័យនៅឡើយ
តែអន្តេវាសិកមិនមានអាល័យ ដាក់ធុរៈថា ឥឡូវនេះ យើងមិនអាស្រ័យ
លោកទេ សូម្បីដូច្នេះក៏មិនទាន់រម្ងាប់ ៗ បើមានអាល័យទាំងសងខាង
និស្ស័យក៏មិនរម្ងាប់ កាលអ្នកទាំងពីរដាក់ធុរៈទាំងសងខាង ទើបរម្ងាប់ ៗ
អន្តេវាសិកដែលត្រូវអាចារ្យប្រណាមចេញហើយ គប្បីធ្វើណ្ដកម្មខ្លួនឯង
ឲ្យលោកអត់ទោសអស់វារៈ ៣ ដង បើលោកមិនអត់ទោសទេ គប្បី
បដិបត្តិដោយន័យដូចពោលហើយក្នុងឧបជ្ឈាយ៍នោះចុះ ៗ ដែលពោលថា
បានជួបនឹងឧបជ្ឈាយ៍នោះ គប្បីដឹងដោយកិរិយាឃើញ មិនត្រូវនោះចុះ
បើសទ្ធិវិហារិកនៅអាស្រ័យនឹងអាចារ្យ បានឃើញឧបជ្ឈាយ៍ថ្វាយបង្គំ
ព្រះចេតិយនៅក្នុងវិហារជាមួយគ្នា ឬទៅបិណ្ឌបាតក្នុងស្រុកជាមួយគ្នា
និស្ស័យក៏រម្ងាប់ចាកអាចារ្យ ៗ បើឧបជ្ឈាយ៍ឃើញ តែសទ្ធិវិហារិកមិន
ឃើញមិនរម្ងាប់ ឃើញឧបជ្ឈាយ៍ដើរទៅឬទៅដោយអាកាស ស្គាល់ថាជា
ភិក្ខុអំពីចម្ងាយ មិនស្គាល់ថាជាឧបជ្ឈាយ៍ និស្ស័យមិនរម្ងាប់ បើស្គាល់ទើប
រម្ងាប់ ៗ ឧបជ្ឈាយ៍នៅលើប្រាសាទ សទ្ធិវិហារិកនៅខាងក្រោម មិន
ឃើញឧបជ្ឈាយ៍ឡើយ ឆាន់បបរហើយក៏ចៀសចេញទៅ ឬឧបជ្ឈាយ៍
អង្គុយក្នុងរោងឆាន់ មិនឃើញឧបជ្ឈាយ៍ឡើយ ឆាន់នៅក្នុងទីម្ខាង
ហើយក៏ចៀសទៅ ឬឧបជ្ឈាយ៍អង្គុយក្នុងមណ្ឌបជាទីស្ដាប់ធម៌ មិនឃើញ

www.budinst.gov.kh www.elibraryofcambodia.org

លោកឡើយ ស្តាប់ធម៌ហើយ ក៏ចៀសចេញទៅ និស្ស័យមិនរម្ងាប់ យ៉ាងនេះឯង គប្បីដឹងថា បានជួបឧបជ្ឈាយ៍ដោយកិរិយាបានឃើញ ។ បានឮសំឡេងឧបជ្ឈាយ៍សំដែងធម៌ ឬក្នុងអនុមោទនាក្នុងវិហារ ឬក្នុងល្វែងកផ្ទះ បើចាំបានថាសំឡេងឧបជ្ឈាយ៍យើងដូច្នេះ និស្ស័យរម្ងាប់ បើចាំមិនបាន មិនរម្ងាប់ ។ វិនិច្ឆ័យក្នុងនិស្ស័យរម្ងាប់ចាកអាចារ្យដូច្នេះឯង ។

សទ្ធិវិហារិកនឹងអន្តេវាសិក ប្រកបដោយអង្គជាទោស ៥ ដូច្នេះគឺ នាធិមត្តំ បេមំ ហោតិ មិនស្រឡាញ់ឧបជ្ឈាយ៍អាចារ្យដោយពិត ១ នាធិមត្តោ បសាទោ ហោតិ មិនជ្រះថ្លាដោយពិត ១ នាធិមត្តា ហិរី ហោតិ មិនអៀនខ្មាស់ដោយពិត ១ នាធិមត្តោ គារវោ ហោតិ មិនគោរពដោយពិត ១ នាធិមត្តា ភាវនា ហោតិ មិនចំរើនមេត្តាភាវនាដោយពិត ១ ។ សទ្ធិវិហារិក អន្តេវាសិក ប្រកបដោយអង្គជាទោស ៥ ប្រការដូច្នេះ គួរប្រណាម បើឧបជ្ឈាយ៍អាចារ្យមិនប្រណាមទេ ត្រូវទុក្កដ ។

សទ្ធិវិហារិកអន្តេវាសិក ប្រកបដោយអង្គជាគុណ ៥ គឺស្រឡាញ់ឧបជ្ឈាយ៍អាចារ្យដោយពិត ១ ជ្រះថ្លាដោយពិត ១ អៀនខ្មាស់ដោយពិត ១ គោរពដោយពិត ១ ចំរើនមេត្តា ភាវនាដោយពិត ១ ព្រមដោយអង្គជាគុណ ៥ ប្រការដូច្នេះ មិនគួរប្រណាម បើឧបជ្ឈាយ៍អាចារ្យប្រណាម ត្រូវទុក្កដ ។ សទ្ធិវិហារិកអន្តេវាសិក ដែលឧបជ្ឈាយ៍អាចារ្យប្រណាមហើយ គប្បីសូមខមាទោសលោកដូចពោលមកហើយខាងដើម បើមិនសូមខមា

www.budinst.gov.kh www.elibraryofcambodia.org

ទោស ត្រូវទុក្កដ ។ ឧបជ្ឈាយ៍អាចារ្យទៀត ដែលសទ្ធិវិហារិក អន្តេវាសិក សូមខមាទោស មិនអត់ទោសឲ្យក៏ត្រូវទុក្កដ ។

មួយទៀត ភិក្ខុជាមនុស្សឈ្លាសអង់អាចជាពហុស្សូត ច្រើនគុណ ជាដើមថា ដឹងអាបត្តិនឹងអនាបត្តិ រក្សាខ្លួនឯងនឹងអ្នកដទៃបាន មាន វស្សាអំពី ១០ ឡើងទៅ ទើបគួរជាឧបជ្ឈាយ៍ ជាអាចារ្យ ឲ្យនិស្ស័យ ដល់ភិក្ខុ នឹងសាមណេរបាន ។

មួយទៀត ភិក្ខុជាមនុស្សឈ្លាសអង់អាច ជាពហុស្សូត ច្រើនគុណ ជាដើមថា ដឹងអាបត្តិនឹងអនាបត្តិ រក្សាខ្លួនឯងបាន ហើយមានវស្សាអំពី ៥ ឡើងទៅ ទើបជានិស្ស័យមុត្តក រួចពាកនិស្ស័យបាន ។ បើមិនឈ្លាស សូម្បីមានវស្សាដល់ ១០ ក៏មិនជានិស្ស័យមុត្តក រួចពាកនិស្ស័យបាន ។ ភិក្ខុមិនទាន់បាននិស្ស័យមុត្តក មិនកាន់យកនិស្ស័យនៅបាន ចំពោះតែភិក្ខុ ឈឺ នឹងភិក្ខុអ្នកឧបដ្ឋាកភិក្ខុឈឺដែលភិក្ខុឈឺអង្វរ (ឲ្យនៅកំដរ) ភិក្ខុដើរផ្លូវ នឹងភិក្ខុនៅព្រៃកំណត់ជាសុខវិហារ គឺបានសមថៈ នឹងវិបស្សនាឡើងថ្មី ទាំងអម្បាលនេះ កាលមិនមានអ្នកឲ្យនិស្ស័យ មិនកាន់យកនិស្ស័យ ក៏គួរ ព្រោះព្រះអង្គទ្រង់អនុញ្ញាត ។ ភិក្ខុក្រៅនោះ បើមិនកាន់យក និស្ស័យមិនគួរ ។ តែភិក្ខុនៅព្រៃឲ្យចងចិត្តថា កាលណាមានអ្នកឲ្យ និស្ស័យដ៏សមគួរមក យើងនឹងអាស្រ័យលោកនោះ ។ ឯអាចារ្យអ្នកឲ្យ និស្ស័យ បើឲ្យនិស្ស័យដល់ភិក្ខុដែលជាអលជ្ជី ត្រូវអាបត្តិទុក្កដ ។ ឯភិក្ខុ កម្លោះបើកាន់និស្ស័យក្នុងសំណាក់ភិក្ខុជាអលជ្ជី ត្រូវអាបត្តិទុក្កដ ។ ព្រោះ

www.budinst.gov.kh www.elibraryofcambodia.org

ហេតុនោះ ទាំងអាចារ្យនិងភិក្ខុកម្លោះ កាលមិនធ្លាប់ឲ្យនិស្ស័យនិងមិនធ្លាប់នៅជាមួយគ្នា គប្បីរង់ចាំមើលថាជាសភាគៈ ឬមិនជាសភាគៈ បានចំនួន ៦-៨ ថ្ងៃសិន ព្រោះព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ ចតូហបញ្ចាហំ អាគមេតុំ យាវ ភិក្ខុសភាគំ ជានាមិ ដូច្នេះ ។ ថាមិនត្រូវអាបត្តិដល់ភិក្ខុកម្លោះដែលរង់ចាំមើលនោះ ។

វត្តកថា ចប់

---

## ប្រភេទនៃទុក្កដាបត្តិ

ប្រភេទនៃទុក្កដាបត្តិនោះ ពោលដោយអាគតដ្ឋាន គឺទីមក ដោយសង្ខេបមាន ២ ប្រការគឺ មកក្នុងបាលីដែលព្រះពុទ្ធអង្គទ្រង់បញ្ញត្ត ហៅថាបាលីទុក្កដ ១ មកក្នុងអដ្ឋកថា ក្រៅពីបាលី ដែលព្រះសង្គីតិកាចារ្យ លោកជាអ្នកដឹងពុទ្ធាធិប្បាយ តែងតាំងទុក ហៅថា បាលិមុត្តកទុក្កដ ១ ។ បាលីទុក្កដ ពោលដោយទីមកមាន ៨ ស្ថាន គឺ មកក្នុងសេខិយៈ ឈ្មោះថា សេខិយទុក្កដ ១ មកក្នុងនិទាននៃសិក្ខាបទៈ ឈ្មោះថា និទានទុក្កដ ១ មកក្នុងវិនីតវត្ថុនៃបារាជិក និងសង្ឃាទិសេស ឈ្មោះថា វិនីតវត្ថុទុក្កដ ១ មកក្នុងវិភង្គនៃបារាជិកជាដើមឈ្មោះថា វិភង្គទុក្កដ ១ មកក្នុងមហាខន្ធកជាដើម ឈ្មោះថាខន្ធកទុក្កដ ១ ។

www.budinst.gov.kh www.elibraryofcambodia.org

# បាលីទុក្កដ

សេខិយទុក្កដ មកក្នុងបាលីនៃសេខិយសិក្ខាបទ ៧៥ ដូចបានពោល ហើយក្នុងសេខិយវគ្គ ។ និទានទុក្កដ មាន ៦ ប្រការ ១មួយ មកក្នុងនិទាននៃទុតិយបារាជិក ថាព្រះអង្គឃើញព្រះធនិយត្ថេរធ្វើកុដិដោយដីសុទ្ធ ត្រាស់បង្គាប់ឲ្យភិក្ខុទាំងឡាយទៅទំលាយចេញ ហើយទ្រង់បញ្ញត្តទុកថា ន ច ភិក្ខវេ សព្វមត្តិកាមយា កុដិ កាតព្វា... ថាភិក្ខុកុំគប្បីធ្វើកុដិដោយដីសុទ្ធ បើធ្វើត្រូវទុក្កដ ។ សូម្បីបានកុដិដីសុទ្ធ ដែលអ្នកដទៃកន្លងសិក្ខាបទធ្វើទុកហើយ ទៅនៅក្នុងកុដិនោះ ត្រូវទុក្កដ ។ តែបើលាយដោយគ្រឿងទព្វសម្ភារៈ ឬលាយដោយរបស់ណាមួយក៏គួរ ធ្វើដោយដីសុទ្ធមិនគួរ ។ សូម្បីកុដិនោះគេធ្វើសន្លឹកថា ជាផ្ទះដោយឥដ្ឋក៏គួរ ។ ព្រោះព្រះអង្គត្រាស់បង្គាប់ឲ្យភិក្ខុទៅទំលាយចេញ សូម្បីក្នុងកាលឥឡូវនេះ ភិក្ខុជាពហុស្សូតចេះដឹងវិន័យ បើឃើញភិក្ខុដទៃកាន់គ្រឿងបរិក្ខារ ដែលមិនគួរដើរទៅ កាត់ទំលាយចេញខ្លួនឯង ឬឲ្យអ្នកដទៃកាត់ទំលាយនូវបរិក្ខារនោះ ភិក្ខុជាម្ចាស់របស់តិះដៀលមិនបាន កុំគប្បីចោទភិក្ខុនោះ កុំគប្បីពោលរំលឹកថាបរិក្ខាររបស់យើង លោកធ្វើឲ្យវិនាសហើយ លោកចូរសងយើងវិញដូច្នេះឡើយ ។ រឿងនេះក្នុងអដ្ឋកថា លោកវិនិច្ឆ័យ កប្បិយាកប្បិយបរិក្ខារ ជាបាលីមុត្តកៈ ដូចពោលហើយក្នុងបរិក្ខារកថា ។ ១មួយ ព្រះពុទ្ធអង្គទ្រង់បញ្ញត្តទុក

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងនិទាននៃសុរុសុរុសិក្ខាបទថា ន ភិក្ខវេ ពុទ្ធំ វា ធម្មំ វា សង្ឃំ វា អារព្ភ ទវោ កាតព្វោ... ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវនិយាយឡកលេងប្រារព្ធព្រះពុទ្ធ ព្រះធម៌ ឬព្រះសង្ឃ ដោយបរិយាយណាមួយជាដើម ថាព្រះពុទ្ធអ្វី ព្រះអង្គទើបនឹងភ្ញាក់អំពីសិង នឹងមិនទាន់ភ្ញាក់អំពីសិង ព្រះធម៌អ្វី ព្រះធម៌គោ ព្រះធម៌ពពែ ព្រះសង្ឃថាពួក ពួកអ្វី ពួកម្រឹគ ពួកសត្វចិញ្ចឹម បើភិក្ខុណានិយាយឡកលេងដូច្នេះ ត្រូវទុក្កដ ។

វិទីតវត្ថុទុក្កដនោះ បានពោលអំពីមុនខ្លះហើយ គប្បីដឹងក្នុងពាក្យដែលពោលអាងថា ព្រះអង្គទ្រង់បញ្ញត្តទុក ក្នុងវិទីតវត្ថុទុក្កដនោះចុះ ។ ដែលសល់នៅនោះគឺ ១មួយ ក្នុងវិទីតវត្ថុនៃទុតិយបារាជិក ទ្រង់ហាមឃាត់ទុកថា ន ច ភិក្ខវេ វុត្តោ វជ្ជេមីតិ វត្តព្វោ ន ច វុត្តោ វជ្ជេហីតិ វត្តព្វោ យោ វទេយ្យ អាបត្តិ ទុក្កដស្ស ម្នាលភិក្ខុទាំងឡាយ តែភិក្ខុកុំគប្បីពោលថាលោកផ្តាំនឹងខ្ញុំហើយ ខ្ញុំនឹងប្រាប់ដូច្នេះ ម្យ៉ាងទៀត កុំគប្បីពោលថា ខ្ញុំផ្តាំនឹងលោកហើយលោកប្រាប់ចុះ តែភិក្ខុណាពោល ភិក្ខុនោះត្រូវទុក្កដ ។

១មួយ ទ្រង់ហាមឃាត់ទុកថា ភិក្ខុកុំគប្បីពោលនឹងភិក្ខុដទៃថា យើងពោលបង្គាប់លោក លោកចូរនិយាយតាមពាក្យយើង បើភិក្ខុណាពោលសេចក្តីមិនច្បាស់ចេញទៅដូច្នេះ ត្រូវទុក្កដ ។ ក្នុងបទទាំងពីរ

www.budinst.gov.kh www.elibraryofcambodia.org

នេះ  កំណត់ពាក្យពោលឲ្យច្បាស់ចេញទៅជាដើមថា  យើងបង្គាប់លោកឲ្យទៅកាន់យកវត្ថុនេះ ៗ  លោកចូរទៅកាន់យកវត្ថុនេះ ៗ  ក្នុងទីឯណោះដូច្នេះក៏គួរ ដ្បិតពោលប៉ុណ្ណោះទើបរួចចាកទោសទុក្កដៈបាន ។

ខមួយ ក្នុងវិនីតវត្ថុនៃតតិយបារាជិក ទ្រង់ហាមឃាត់ទុកថា ន ច ភិក្ខវេ អត្តានំ បាតេតព្វំ យោ បាតេយ្យ អាបត្តិ ទុក្កដស្ស ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែភិក្ខុកុំគប្បីធ្វើខ្លួនឲ្យធ្លាក់ចុះ (គឺលោតទម្លាក់ក្នុងជ្រោះ ឲ្យស្លាប់ជាដើម) ភិក្ខុណាទម្លាក់សម្លាប់ខ្លួនឯង (ភិក្ខុនោះ) ត្រូវទុក្កដ ៗ មិនមែនគ្រាន់តែមិនឲ្យទម្លាក់ខ្លួនទៅមួយចំពូកប៉ុណ្ណោះទេ គឺកុំគប្បីសម្លាប់ខ្លួនដោយសេចក្តីព្យាយាមណាមួយ ឬដោយហេតុដទៃ ដោយហោចទៅ សូម្បីដោយអាហារ សូម្បីមានជម្ងឺ កាលបើមានថ្នាំនិងមនុស្សទំនុកបំរើ តែចង់ឲ្យស្លាប់ ផ្តាច់អាហារចេញ ត្រូវទុក្កដ ៗ តែបើមានអាពាធធ្ងន់គ្រាំគ្រាមកយូរ ភិក្ខុទាំងឡាយអ្នកទំនុកបំរុងលំបាកក៏នឿយណាយ បើភិក្ខុនោះគិតថា អត្តភាពនេះ សូម្បីនឹងបដិបត្តិទៅក៏មិនឋិតនៅយូរប៉ុន្មាន ភិក្ខុទាំងអម្បាលនោះនឹងមានសេចក្តីលំបាកផង ហើយភិក្ខុនោះផ្តាច់អាហារចេញ មិនបរិភោគថ្នាំក៏គួរ ៗ ភិក្ខុណាផ្តាច់អាហារចេញគិតថា រោគនេះក៏រឹតខ្លាំងឡើងណាស់ អាយុសង្ខារនឹងតាំងនៅមិនបាន ឯសេចក្តីត្រាស់ដឹងវិសេស ហាក់បីដូចជានឹងដល់ក្នុងដៃដូច្នេះគួរពិត. សូម្បីមិនមានជម្ងឺកើតសេចក្តីសង្វេគឡើងគិតថា គ្រាប់ស្វែងរកអាហារជាដំណើរយឺតយូរ យើងនឹងប្រកបតែកម្មដ្ឋាន

www.budinst.gov.kh www.elibraryofcambodia.org

មួយបំពុក នឹងឆ្អាប់អាហារដោយកម្មដ្ឋានជាប្រធានដូច្នេះ ក៏គួរ តែបើឆ្អាប់អាហារចេញ ព្រោះនឹងព្យាករសេចក្តីត្រាស់ដឹងវិសេសមិនគួរ ផ្សិតជាបើនិយាយគ្នានឹងភិក្ខុជាលជ្ជីដែលជាសភាគៈស្មើគ្នា ទើបគួរ ។

ខមួយទៀត ក្នុងវិនីតវត្ថុ នៃចតុត្ថបារាជិក ទ្រង់បញ្ញត្តទុកថា ន ច ភិក្ខវេ បណិធាយ អរញ្ញេ វត្ថព្វំ យោ វសេយ្យ អាបត្តិ ទុក្កដស្ស ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែ អ្នកទាំងឡាយ មិនត្រូវតាំងចិត្តនឹងនៅក្នុងព្រៃ ឲ្យគេសរសើរឡើយ ភិក្ខុណានៅ (ដោយតាំងចិត្តយ៉ាងនេះ) ភិក្ខុនោះ ត្រូវទុក្កដ ។ ប្រាថ្នានឹងឲ្យគេសរសើរទៅនៅក្នុងព្រៃ ដើរទៅត្រូវទុក្កដគ្រប់ៗ ករៈនៃជំហាន ប្រាថ្នាដូច្នោះទៅនៅក្នុងព្រៃ ក្នុងកិច្ចទាំងពួង ជាដើមថា ធ្វើកុដិ ដើរចង្ក្រម អង្គុយស្លៀក ដណ្តប់ ត្រូវទុក្កដគ្រប់ៗប្រយោគ ព្រោះហេតុនោះ ភិក្ខុកុំនៅព្រៃដោយសេចក្តីប្រាថ្នាយ៉ាងនេះ ផ្សិតថា នៅយ៉ាងនេះបានសេចក្តីសរសើរក្តី មិនបានក្តី ត្រូវទុក្កដ ។ តែបើភិក្ខុណាសមាទានធុតង្គហើយ គិតថានឹងរក្សាធុតង្គ ឬគិតថានៅជិតស្រុក ចិត្តរមែងរវើរវាយនៅព្រៃជាទីសប្បាយ ឬគិតថានឹងបានដល់នូវវិវេកទាំង ៣ ណាមួយក្នុងព្រៃណាប្រាកដ ឬគិតថាចូលទៅក្នុងព្រៃហើយមិនបានដល់ព្រះអរហត្តនឹងមិនចេញមក ឬគិតថាអាការដែលនៅក្នុងព្រៃនេះ ព្រះមានព្រះភាគទ្រង់សរសើរ កាលបើយើងទៅនៅព្រៃ មិត្រសំឡាញ់សព្រហ្មចារី

www.budinst.gov.kh www.elibraryofcambodia.org

ជាច្រើន ខ្ទឹមលះសេនាសនៈដ៏ស្រេកទៅនៅព្រៃតាមគ្នា ប្រាថ្នាខ្ទឹមទៅជួរេច្ចៈ មិនមានទោស ភិក្ខុនោះគប្បីនៅចុះ ៗ

ខមួយទៀត ភិក្ខុគុំគប្បីគ្រាប់ទៅបិណ្ឌបាត ខ្ទឹមបង្ក្រម ខ្ទឹមឈើ ខ្ទឹមអង្គុយ ខ្ទឹមសម្រេចឥរិយាបថដេក ដោយសេចក្តីប្រាថ្នាខ្ទឹមឲ្យគេសរសើរដូច្នោះ បើភិក្ខុណាប្រាថ្នាដូច្នោះ ហើយគ្រាប់ទៅបិណ្ឌបាតជាដើម ត្រូវទុក្កដ ៗ តិតថាខ្ទឹមធ្វើអាការជាដើមថាគ្រាប់ទៅបិណ្ឌបាត ដោយសេចក្តីប្រាថ្នាខ្ទឹមឲ្យគេសរសើរ តាំងអំពីស្លៀកដណ្តប់ទៅ រហូតដល់ឆាន់ហើយត្រូវទុក្កដគ្រប់ៗប្រយោគ តោះបើបានសេចក្តីសរសើរក្តី មិនបានក្តី ក៏ត្រូវទុក្កដ ៗ តែគ្រាប់ទៅដើម្បីបិណ្ឌបាត ដោយមារយាទជាដើមថា ឈានទៅ ត្រឡប់ថយមកដែលគួរជាទីជ្រះថ្លា ដើម្បីខ្ទឹមបំពេញខន្ធកវត្ត ខ្ទឹមសេចិយវត្តឲ្យបរិបូណ៌ ឬដើម្បីខ្ទឹមឲ្យពួកសព្រហ្មចារីដល់នូវចិត្តាខុតតិឃើញជាគួយ៉ាង មិនមានទោស អ្នកប្រាជ្ញលោកមិនបានតិះដៀលសូម្បីដើរបង្ក្រមជាដើម ក៏មានន័យដូចពោលមកនោះឯង ៗ

វិតក្កទុក្កដ ចប់

---

## វិកត្តទុក្កដ

វិកត្តទុក្កដនោះមានច្រើន គឺជាញាតទុក្កដខ្លះ ញត្តិទុក្កដខ្លះ អនុស្សាវនទុក្កដខ្លះ គណត្តិទុក្កដខ្លះ វិមតិទុក្កដខ្លះ សញ្ញាទុក្កដខ្លះ យថា-ទេត្តទុក្កដខ្លះ យថាវត្តទុក្កដខ្លះ យថាប្រយោគទុក្កដខ្លះ យថាវត្ថុទុក្កដខ្លះ ៗ

www.budinst.gov.kh www.elibraryofcambodia.org

ញាតទុក្កដនោះ ដូចជាភិក្ខុបានឃើញ ឬបានឮ ភិក្ខុដទៃព្យាយាម ដើម្បីនឹងទំលាយសង្ឃជាដើម នឹងបានឃើញ ឬបានឮ ភិក្ខុដទៃមានទិដ្ឋិខុស ដូចជាអរិដ្ឋភិក្ខុ ហើយមិនហាមឃាត់ត្រូវទុក្កដ ។

ញត្តិទុក្កដនោះ ដូចភិក្ខុព្យាយាម ដើម្បីនឹងទំលាយសង្ឃជាដើម សង្ឃធ្វើសមនុភាសនកម្ម ចប់ញត្តិចុះ មិនលះកម្មនោះចេញត្រូវទុក្កដ ។ ទុក្កដដូច្នេះ ចំណែកសមនុភាសនកម្មក្នុងសង្ឃាទិសេសថា កាលបើចប់អនុសាវនាគំរប់ ៣ ដង ត្រូវគរុកាបត្តិ ហើយរំងាប់ទៅឯង ។ ចំណែកក្នុងសមនុភាសនៈដទៃមិនពោលការរំងាប់ទៅទេ ។

អនុសាវនទុក្កដនោះ ដូចភិក្ខុមានទិដ្ឋិឃើញខុស សង្ឃសូត្រសមនុភាសនៈចប់អនុសាវនាទី ១ ទី ២ ត្រូវទុក្កដ ។

អាណត្តិទុក្កដនោះ ដូចជាភិក្ខុប្រើនាងភិក្ខុនីមិនមែនញាតិ ឲ្យបោកគក់ចីវរបស់ ត្រូវទុក្កដ ដោយការបង្គាប់មុន ជាតួយ៉ាង ។

វិមតិទុក្កដនោះ ដូចសំពត់អតិរេកចីវរនៅមិនទាន់កន្លង ១០ ថ្ងៃ ភិក្ខុមានសេចក្តីរង្កៀសសង្ស័យ ហើយបរិភោគប្រើប្រាស់ ត្រូវទុក្កដ ព្រោះការសង្ស័យ ជាតួយ៉ាង ។

សញ្ញាទុក្កដនោះ ដូចភិក្ខុសំគាល់ថាស្រ័ក្នុងបណ្ណាក ចាប់ពាល់ត្រូវដោយសេចក្តីតម្រេកក្តី នឹងសំពត់អតិរេកចីវរនៅមិនទាន់កន្លង ១០ ថ្ងៃ សំគាល់ថាកន្លងហើយ យកមកបរិភោគក្តី តាំងអម្បាលនេះជាដើម ត្រូវទុក្កដ ដោយសញ្ញា ។

www.budinst.gov.kh www.elibraryofcambodia.org

យថាខេត្តទុក្កដនោះ ដូចភិក្ខុសាមណេរ បុគ្គលដទៃលើកស្រែអំពី ជនកាំបិតឡើងទៅអំពីក្បាលជន្ទីលចុះមក ត្រូវទុក្កដ តាមខេត្តជាប្រមាណ ។

យថាវត្ថុទុក្កដនោះ ដូចភិក្ខុចាប់តាលត្រកាយទុកសោដោយសេចក្តីជាស្រូក ត្រូវទុក្កដតាមវត្ថុ ជាតួយ៉ាង ។

យថាបយោគទុក្កដនោះ បានដូចកន្លងបយោគ ថៃចារាផិត ទីនសម្បាទំសេស ទីនបាចិត្តិយ ដូចភិក្ខុមានចេយ្យចិត្ត ចាប់ពាល់បព្ចាសអន្ទិលកណ្ណៈរបស់អ្នកដទៃ ត្រូវទុក្កដ ជាតួយ៉ាង ។

យថាវជ្ជទុក្កដនោះ ដូចភិក្ខុអ្នកចង្កាមនុស្សធម៌ដោយបរិយាយ អ្នកស្តាប់មិនដឹងសេចក្តីក្នុងខណៈនោះ ត្រូវទុក្កដតាមទោស ជាតួយ៉ាង ។

វិភង្គទុក្កដ ចប់

## ខន្ធកទុក្កដ

ខន្ធកទុក្កដនោះ បានពោលមកអំពីមុនខ្លះហើយ គប្បីដឹងក្នុងព្រះពុទ្ធបញ្ញត្តិ ដែលបានពោលហើយនោះចុះ បទដែលមិនបានកាន់ចាំមកជាខន្ធកទុក្កដទាំងអស់ បទដែលសល់នៅនោះដូច្នេះ បទណាគួរទីងដឹងគួរបដិបត្តិបានខ្លះ ខ្ញុំនឹងពោលបទនោះដោយសង្ខេប ៖

ខមួយទៀត ព្រះពុទ្ធអង្គទ្រង់បញ្ញត្តទុក្កដថា ន ភិក្ខវេ បញ្ចហិ អាការេហិ ឧរេវ្ហា បត្តាន្នេតព្វោ... ម្នាលភិក្ខុទាំងឡាយ មនុស្សប្រកបដោយអាការ៥ ប្រការ គឺ ឃ្លង់ រេក ស្រែង កេតរោគ ឆ្កួតជ្រូក កុំគប្បីបំបួស បើភិក្ខុណាបំបួស ត្រូវអាបត្តិទុក្កដ ។

www.budinst.gov.kh www.elibraryofcambodia.org

១មួយ ថាមនុស្សដែលស្ដេចផែនដីចិញ្ចឹមជាខ្ញុំរាជការ កុំគប្បីបំបួស .. ។ ១មួយ ថាចោរប្រាកដដូចជាទង់ជ័យ កុំគប្បីបំបួស... ។ ១មួយ ថាចោរទំលាយគុករត់មក... ។ ១មួយ ថាចោរដែលម្ចាស់ផែនដីប្រកាសទុកថា បើឃើញចូលទៅក្នុងទីកន្លែងណាឲ្យសម្លាប់ចេញ ... ។ ១មួយ ថាចោរដែលគេវាយដោយរំពាត់មានស្នាម ធ្វើទណ្ឌកម្មហើយ .. ។ ១មួយ ថាមនុស្សដែលគេបៀតបៀនឲ្យមានស្នាកស្នាម មានសាក់មុខ សាក់ថ្ងាសជាដើម ធ្វើទណ្ឌកម្មហើយ ... ។ ១មួយ ថាមនុស្សជំពាក់បំណុលគេ... ។ ១មួយថា មនុស្សជាខ្ញុំគេ... ។ ១មួយ ថាកូនដែលមាតាបិតាមិនទាន់អនុញ្ញាត មនុស្សទាំង៩ម្យ៉ាងនេះ ភិក្ខុកុំគប្បីបំបួស បើភិក្ខុណាបំបួស ត្រូវទុក្កដ ។

១មួយ មនុស្សកំបុតដៃ មនុស្សកំបុតជើង មនុស្សកំបុតទាំងដៃទាំងជើង មនុស្សកំបុតត្រចៀក មនុស្សកំបុតច្រមុះ មនុស្សកំបុតទាំងត្រចៀកទាំងច្រមុះ មនុស្សកំបុតម្រាមដៃ មនុស្សកំបុតមេដៃមេជើង មនុស្សដាច់សរសៃធំ មនុស្សមានម្រាមដៃជាប់គ្នា មនុស្សគម មនុស្សគៀ មនុស្សពកក មនុស្សខ្វិន មនុស្សជើងស្វក់ មនុស្សមានរោគអាក្រក់ជាដើមថា ឬសដូង មនុស្សមានរូបទ្រូស្តចរំសើង ព្រោះមានរូបប្លែកអំពីមនុស្សផងគ្នា មនុស្សខ្វាក់ម្ខាង មនុស្សកែងដៃ-ជើង មនុស្សខ្វក មនុស្សស្លាប់កាយម្ខាង មនុស្សមានឥរិយាបថដាច់ មនុស្សចាស់ទុព្វល មនុស្សខ្វាក់ទាំងសងខាង មនុស្សគ មនុស្សថ្លង់ មនុស្សទាំងខ្វាក់ទាំងគ

www.budinst.gov.kh www.elibraryofcambodia.org

មនុស្សខាំងខ្ទាក់ខាំងធ្ងន់ មនុស្សខាំងក ខាំងធ្ងន់ មនុស្សរាំងខ្ទាក់ខាំងខាំងធ្ងន់ មនុស្សខាំងអម្បាលនេះ ភិក្ខុកុំគប្បីឲ្យបព្វជ្ជា បើភិក្ខុណាឲ្យបព្វជ្ជា ត្រូវទុក្កដ ។ មនុស្សបណ្ឌក មនុស្សលួចសង្វាស មនុស្សដែលបួសជាភិក្ខុហើយ ត្រឡប់ចូលទៅជាតិរ្ថិយ សត្វតិរច្ឆាន មនុស្សសម្លាប់មាតា មនុស្សសម្លាប់បិតា មនុស្សសម្លាប់ព្រះអរហន្ត មនុស្សប្រទូសនាងភិក្ខុនី មនុស្សធ្វើសង្ឃភេទ មនុស្សមានចិត្តប្រទូសរកធ្វើលោហិតុប្បាទក្នុងកាយព្រះពុទ្ធអង្គ មនុស្សមានភេទ ២ គឺភេទប្រុសនិងភេទស្រី មនុស្សទាំងអម្បាលនេះ សូម្បីបួសក៏មិនជាឧបសម្បន្ន បើបួសហើយគប្បីឲ្យសឹកចេញ ។

១មួយ សាមណេរគ្មានឧបជ្ឈាយ៍ ភិក្ខុកុំគប្បីឲ្យឧបសម្បទាជាភិក្ខុ ១មួយ កុំយកសង្ឃជាឧបជ្ឈាយ៍ ។ ១មួយ កុំយកគណៈជាឧបជ្ឈាយ៍ ១មួយ កុំយកបណ្ឌកជាដើមជាឧបជ្ឈាយ៍ ។ បើភិក្ខុណាយកបុគ្គលទាំងអម្បាលនេះ ធ្វើជាឧបជ្ឈាយ៍ ឲ្យឧបសម្បទាដល់កុលបុត្រជាភិក្ខុត្រូវទុក្កដ ។

១មួយ ទ្រង់អនុញ្ញាតឲ្យអបលោកន៍ប្រាប់សង្ឃ ដើម្បីធ្វើភណ្ឌុកម្មគឺការសក់មនុស្សអ្នកបព្វជ្ជា វិធីអបលោកន៍ដោយសង្ខេប ដូច្នេះ ត្រូវប្រភិក្ខុដែលនៅក្នុងសីមា ហើយនាំកុលបុត្រអ្នកបព្វជ្ជាទៅក្នុងទីប្រជុំនោះហើយគប្បីបញ្ចេញវាចាថា សង្ឃំ ភន្តេ ឥមស្ស ទារកស្ស ភណ្ឌុកម្មំ អាបុច្ឆាមិ ប្រែថា ខ្ញុំព្រះករុណាប្រាប់ភណ្ឌុកម្ម ដៃ

ទារកនេះដល់សង្ឃ ដូច្នេះ អស់ការៈ ៣ ដង - ២ ដង ឬតែម្តងក៏បាន តែអ្នកណាកោរសក់ថ្មី ឬសឹកថ្មី ឬជានិគ្រន្ថជាដើម ឬជាមនុស្សមានសក់ទ្វីជាង ២ ធ្នាប់ ឬត្រឹម ២ ធ្នាប់ក្តី កិច្ចដែលនឹងកោរសក់នៃកុលបុត្រនោះមិនមាន ព្រោះហេតុនោះ សង្ឃមិនប្រាប់ភណ្ឌុកម្ម នឹងឲ្យកុលបុត្រដូច្នោះបព្វជ្ជា ក៏គួរ ។ តែបើអ្នកណាមានសក់វែងលើសជាងពីរធ្នាប់ ដោយហោចទៅ សង្ឃទ្រទ្រង់ត្រឹមតែកំប៉ោយដក់មួយក្តី គប្បីប្រាប់ភណ្ឌុកម្មជាមុនសិន សូមឲ្យអ្នកនោះបព្វជ្ជា ។ ខមួយ នឹងធ្វើទណ្ឌកម្មដល់សាមណេរកុំគប្បីធ្វើអាការមានកំនិកអាកបសង្ឃតាំងមូល សាមណេរធ្លាប់ទៅ ឬធ្លាប់ចូលទៅក្នុងទីណា គប្បីកំនត់ក្នុងទីនោះ ។ ខមួយ កុំធ្វើអាការឃាត់អាហារ គឺឃាត់មិនឲ្យឆាន់ ។ ខមួយ មិនប្រាប់ឧបជ្ឈាយ៍មុន កុំធ្វើការហាមឃាត់ បើភិក្ខុណាធ្វើការហាមឃាត់កំនត់ដល់សាមណេរដូច្នេះ ត្រូវទុក្កដ ។ ខមួយ កុំប្រលោមលួងលោមបរិស័ទនៃភិក្ខុដទៃ ដើម្បីឲ្យមកឧបដ្ឋាកចក់ខ្លួនដោយពាក្យថា យើងនឹងឲ្យបាត្រចីវរដល់អ្នក ភិក្ខុណាប្រលោមលួងលោមដូច្នេះ ត្រូវទុក្កដ ។ បរិស័ទនៃភិក្ខុដទៃជាសាមណេរក្តី ជាភិក្ខុក្តី ដោយហោចទៅ សង្ឃជាបរិស័ទនៃភិក្ខុទ្រុស្តសីល នឹងញុះញង់ឲ្យបែកនាំយកមកជាបរិស័ទរបស់ខ្លួនមិនគួរ ។ តែនឹងសំដែងទោសថាអ្នកអាស្រ័យនឹងមនុស្សទ្រុស្តសីល បើដូចជាមកប្រាប់ថានឹងទូកលាងជម្រះត្រឡប់ជាយកលាមកលាបខ្លួនដូច្នេះ ក៏គួរ ។ បើអ្នកនោះនឹងមកសូមឧបជ្ឈាយ៍ ឬនិស្ស័យខ្លួនឯង នឹងឲ្យក៏គួរ ។

www.budinst.gov.kh www.elibraryofcambodia.org

ខមួយ មិនឲ្យភិក្ខុដទៃធ្វើឱកាសមុនសិនះហើយ កុំចោទភិក្ខុដោយអាបត្តិ បើភិក្ខុណាចោទដូច្នោះត្រូវទុក្កដ ។ ទ្រង់អនុញ្ញាតឲ្យសូមឱកាសមុនថា ករោតុ មេ អាយស្មា ឱកាសំ អហន្តំ វត្តុកាមោ ថាលោកមានអាយុ ចូរធ្វើឱកាសដល់ខ្ញុំ ខ្ញុំប្រាថ្នានឹងពោលដល់លោកដូច្នេះ ហើយសឹមចោទដោយអាបត្តិ ។

ខមួយ កុំទ្រង់ទណ្ឌៈ គឺឈើវែង ៤ ហត្ថ (ឈើច្រត់) នឹងសារែក បើភិក្ខុណាទ្រង់ទណ្ឌៈនឹងសារែក ត្រូវទុក្កដ ។ ភិក្ខុមានជម្ងឺ ប្រាសចាកទណ្ឌៈ ត្រាច់ទៅមិនបាន ព្រះអង្គទ្រង់អនុញ្ញាតឲ្យសូមទណ្ឌសម្មតិអំពីសង្ឃ ។ ភិក្ខុមានជម្ងឺវៀរសារែកចេញ បរិហាររក្សាទាំបាត្រទៅមិនបាន ព្រះអង្គទ្រង់អនុញ្ញាតឲ្យសូមសិក្កាសម្មតិអំពីសង្ឃ ។ បើមានជម្ងឺវៀររបស់ទាំងពីរយ៉ាងនោះត្រាច់ទៅនឹងនាំបាត្រទៅមិនបាន ព្រះអង្គទ្រង់អនុញ្ញាតឲ្យសូមទណ្ឌសិក្កាសម្មតិអំពីសង្ឃ បានសម្មតិវត្ថុណាមួយះហើយប្រើវត្ថុនោះបាន ។

ខមួយ ដងរែកមានរបស់ព្យួរទាំងសងខាង ភិក្ខុកុំគប្បីរែកនាំទៅ បើភិក្ខុណារែកនាំទៅត្រូវទុក្កដ ។ ដងរែកមានរបស់ម្ខាង (ពុនទៅផង) យករបស់ព្យួរកណ្តាល ពីរអង្គសែងទៅ ទូលដោយក្បាល លីដោយស្មា កណ្តៀតដោយចង្កេះ យួរដោយដៃ ទាំងអម្បាលនេះនាំទៅក៏គួរ ព្រោះព្រះអង្គទ្រង់អនុញ្ញាត ។

www.budinst.gov.kh www.elibraryofcambodia.org

១មួយ កាលអ្នកជំងឺកណ្តាស់ កុំពោលថាអ្នកចូររស់នៅ ចូររួចចុះ បើពោលដូច្នេះ ត្រូវទុក្កដ ។ គ្រហស្ថអ្នកប្រាថ្នាមង្គលគេពោលនឹងភិក្ខុថា លោកចូររស់នៅ នឹងពោលតបទៅថា អ្នកចូររស់នៅអស់កាលអង្វែង ដូច្នេះក្តី ដ្បិតទ្រង់អនុញ្ញាតឲ្យពោល ។

ខន្ធកទុក្កដ ចប់

ទុក្កដាបត្តិទាំងអម្បាលនេះ មានមកក្នុងបាលី ដូចពោលហើយ ទើបឈ្មោះថាបាលីទុក្កដ ។

បាលីទុក្កដ ចប់

## បាលីមុត្តកទុក្កដ

បាលីមុត្តកទុក្កដនោះ បានពោលហើយក្នុងខាងដើមនោះខ្លះ ដូចទុក្កដត្រូវព្រោះទទួលនឹងឆាន់សាច់ ត្រីស្រស់ នឹងអនាមាសទុក្កដនៃភិក្ខុអ្នកចាប់ពាល់បបោសអង្អែលរតនៈ ១០ យ៉ាង ស្រូវ ៧ ប្រការ នឹងគ្រឿងតូរ្យតន្ត្រីជាដើមដែលនឹងពោលទៅខាងមុខ នឹងទុរុបចិណ្ណទុក្កដ វិនយទុក្កដ ដែលសល់នៅ ដូច្នេះ ៖

១មួយ ភិក្ខុកុំទទួលស្រូវខ្ចី ។ ១មួយ កុំទទួលចំការស្រែ ទីដីជាដើម បើទាយកណាមួយពោលថា បឹងធំសំរេចខ្ញុំបានមួយឆ្នាំ ៣ ដង របស់ខ្ញុំព្រះករុណាមាន ខ្ញុំព្រះករុណានឹងថ្វាយបឹងនោះដល់សង្ឃ បើ

www.budinst.gov.kh www.elibraryofcambodia.org

សង្ឃទទួលបឹងនោះត្រូវអាបត្តិ ព្រោះទទួល ព្រោះបរិភោគ បើភិក្ខុណា ឃាត់ទៅទាយក ភិក្ខុនោះ គឺភិក្ខុណាមួយ កុំគប្បីពោលពាក្យអ្វី នឹងភិក្ខុអ្នកឃាត់នោះឡើយ ដ្បិតថាបោមភិក្ខុអ្នកឃាត់នោះ ភិក្ខុនោះឯងត្រូវអាបត្តិ ព្រោះភិក្ខុមួយអង្គនោះធ្វើភិក្ខុច្រើនមិនឱ្យត្រូវអាបត្តិ ។ ទាយកណាសូមពោលថា ខ្ញុំព្រះករុណាថ្វាយបឹងធំប្រាកដដូច្នោះ ភិក្ខុទាំងឡាយឃាត់គេ ថាមិនគួរ បើគេសួរថាបឹងរបស់សង្ឃឯណោះ ៗ ក៏មាន នោះហេតុថ្វីក៏គួរ គប្បីពោលតបទៅគេថា ប្រហែលជាគេធ្វើឱ្យជាកប្បិយហើយថ្វាយ ៗ បើគេសួរថាថ្វាយដូចម្តេចទើបជាកប្បិយ គប្បីពោលតបទៅគេថា គេថ្វាយថា លោកចូរបរិភោគបច្ច័យទាំង ៤ ដូច្នេះ ទើបបានជាកប្បិយ ថាបើទាយកត្រឡប់ថ្វាយ ដោយពាក្យថាប្រពៃហើយព្រះករុណា លោកចូរបរិភោគបច្ច័យទាំង៤ នោះចុះ ដូច្នេះគួរ ៗ ថាបើពោលថាព្រះករុណាចូរទទួលបឹង ឃាត់គេថា មិនគួរ គេសួរថាមានកប្បិយការកឬទេ ប្រាប់ថាមិនមាន គេពោលថាមនុស្សឯណោះនឹងចាត់ចែងបឹងនោះ ឬថានឹងនៅក្នុងដៃអ្នកនោះ ឬថានឹងនៅក្នុងដៃខ្ញុំព្រះករុណា សង្ឃចូរបរិភោគរបស់ដែលគួរចុះ ដូច្នេះក៏គួរ ៗ បើឃាត់គេថាមិនគួរដូច្នេះ គេពោល មនុស្សទាំងឡាយ នឹងបានបរិភោគទឹក នឹងបានលាងរបស់ សត្វម្រឹគ បក្សីនឹងបានផឹក សូមពោលដូច្នេះក៏គួរ ៗ បើឃាត់គេថាមិនគួរដូច្នោះហើយ គេពោលថាលោកចូរកាន់យកដោយប្រពាទនៃកប្បិយការកៈចុះ ភិក្ខុពោលថាល្អហើយឧបាសក សង្ឃនឹងបានក្រេបផឹកទឹក នឹងលាងរបស់

ទ្រឹត បក្សីនឹងបានផឹកដូច្នេះ ហើយបរិភោគគឺគួរ ។ មួយទៀត បើគេពោលថា ខ្ញុំព្រះករុណាថ្វាយបឹង ថ្វាយស្រះបោក្ខរណីរបស់ខ្ញុំព្រះករុណាដល់សង្ឃ ភិក្ខុនឹងពោលថាល្អហើយឧបាសក សង្ឃនឹងបានផឹកទឹកដូច្នេះជាដើម ហើយបរិភោគគឺគួរ ។ ថាបើភិក្ខុសូមហត្ថកម្មគេក្តី នឹងជីកដីជាកប្បិយដោយដៃខ្លួនក្តី ធ្វើជាបឹងដើម្បីបរិភោគទឹក បើមនុស្សមកអាស្រ័យបឹងត្រពាំងនោះ សំរេចស្រូវសន្ទូងហើយ ឱ្យកប្បិយ-កណ្តុរនៃវិហារគឺគួរ ។ ក្នុងរឿងនេះ ព្រះអដ្ឋកថាចារ្យពោលពិស្តារ តែសេចក្តីសង្ខេបថា នឹងធ្វើចំការស្រែខ្លួនឯង ឬឱ្យអ្នកដទៃធ្វើ មិនគួរ ។ បឹងត្រពាំងដែលគេថ្វាយ ដើម្បីបច្ច័យទាំង ៤ ទទួលហើយ នឹងតាំងកប្បិយ-ការកទុក គឺគួរ ប៉ុន្តែបើធ្វើការជីកដីពូនជាភ្លឺមិនគួរ ។ បើត្រពាំងដែលទទួលទុកដើម្បីនឹងបរិភោគទឹក ចិត្តបរិសុទ្ធនឹងធ្វើការជីកដីនឹងពូនទប់ភ្លឺទៀងថ្មីដោយកប្បិយវោហារគួរ តែឃើញគេមកអាស្រ័យធ្វើសន្ទូង នឹងតាំងកប្បិយការកទុកមិនគួរ ។ មួយវិញទៀត គេពោលថាខ្ញុំព្រះករុណាថ្វាយចំការ ស្រែ ភូមិ គ្រាន់ជាទីបណ្តុះសណ្តែកល្ពៅដូងជាដើម គប្បីឃាត់ថាមិនគួរ ហើយបដិបត្តិដូចពោលមកហើយក្នុងបឹងនោះចុះ ។ កាលណាបើគេពោលដោយកប្បិយវោហារថា ខ្ញុំព្រះករុណាថ្វាយដើម្បីបរិភោគបច្ច័យ ៤ កាលនោះគប្បីទទួលចុះ ។ បើគេពោលថា ខ្ញុំព្រះករុណាថ្វាយព្នុកឈើ ថ្វាយព្រៃគឺគួរ ។ គេអាស្រ័យទីធ្វើសន្ទូង ហើយពោលថាខ្ញុំព្រះករុណាថ្វាយសីមា ដូច្នេះគឺគួរ តែកុំបោះគោលឈើ កុំបោះគោល

www.budinst.gov.kh www.elibraryofcambodia.org

សិលា ដើម្បីនឹងកំណត់ផែនដោយខ្លួនឯង ព្រោះផែនដីមានដំឡៃច្រើន ទើបគប្បីត្រូវបារាជិក ដោយរបស់បន្តិចបន្តួច គប្បីប្រាប់អ្នករក្សាវត្តថា សីមារបស់យើងទៅតាមទីត្រង់នេះ ថាបើមនុស្សរក្សាវត្តបោះគោលយកលើសទៅ មិនត្រូវអាបត្តិ ព្រោះពោលដោយបរិយាយថា បើមហាក្សត្រទ្រង់មហាមាត្យ ជាដើម លោកឲ្យមនុស្សបោះគោលខ្លួនឯងហើយថ្វាយ ជាលោកប្ដូរបរិភោគបច្ច័យ ៤ ដូច្នេះ គឺគួរ ៗ ១មួយ ភិក្ខុកុំគប្បីទទួលខ្ញុំស្រី ខ្ញុំប្រុស គោ ក្របី ដំរី សេះ ពពែ ជ្រូក ទឹង មាន់ ជាដើម បើទទួលត្រូវទុក្កដ ៗ គេពោលថា ខ្ញុំព្រះករុណាថ្វាយទាស មិនគួរ ៗ បើគេពោលថា ខ្ញុំព្រះករុណាថ្វាយមនុស្សរក្សាអារាម ថ្វាយវេយ្យាវច្ចករ ថ្វាយកប្បិយការក ដូច្នេះ គឺគួរ ៗ បើមនុស្សដែលរក្សាអារាមនោះធ្វើការសង្ឃទាំងវេលាព្រឹកវេលាល្ងាច ភិក្ខុគប្បីធ្វើការបដិបត្តិដោយភេសជ្ជៈទាំងពួងដល់អ្នកនោះ បីដូចជាធ្វើដល់សាមណេរចុះ ៗ ថាបើអ្នករក្សាវត្តនោះ ធ្វើការរបស់សង្ឃតែវេលាព្រឹក វេលាបច្ឆាភត្តធ្វើការរបស់ខ្លួនវេលាល្ងាចភិក្ខុកុំគប្បីឲ្យគ្រឿងបរិភោគ សូម្បីមនុស្សរក្សាវត្តធ្វើការសង្ឃជាវេន ៥ ថ្ងៃ ប្ដូរឆ្នះវេន កាលក្រៅពីនោះធ្វើការរបស់ខ្លួន គប្បីឲ្យបាយទឹងគ្រឿងបរិភោគដល់អ្នកនោះ តែក្នុងវេលាធ្វើកិច្ចការសង្ឃមួយចំពួក បើកិច្ចការសង្ឃមិនមាន គេទៅធ្វើកិច្ចការរបស់ខ្លួនគេចិញ្ចឹមជីវិត បើគេយកដំរីឲ្យហត្ថកម្មមកថ្វាយគប្បីទទួលចុះ បើគេមិនឲ្យកុំគប្បីពោលពាក្យកុំឡើយ ៗ ទឹងទទួលទាសៈ ជាជាងស្រលក់ ឬជាងកម្សាញណាមួយ

ដោយឈ្មោះថាអាកាមិកៈ មនុស្សក្រោកាកមនឹងព្រោមវត្តគួរ ។ ថាបើគេពោលថា ខ្ញុំព្រះករុណាថ្វាយគោ គឺគប្បីឃាត់ថាមិនគួរ បើគេសួរថា គោទាំងអម្បាលនេះ បានមកអំពីណា គប្បីប្រាប់ថា មនុស្សឈ្មោសគេថ្វាយដើម្បីបរិភោគបញ្ចគោរស កាលបើគេពោលថា ខ្ញុំព្រះករុណាថ្វាយដើម្បីបរិភោគបញ្ចគោរសផែរ ដូច្នេះគួរ សូម្បីក្នុងសត្វទាំងឡាយ មានពពែជាដើមក៏ដូចគ្នា ។ គេពោលថា ខ្ញុំព្រះករុណាថ្វាយដំរី ថ្វាយសេះ ក្របី មាន់ ជ្រូក មិនទទួលមិនគួរ ។ បើមនុស្សចំពូកខ្លះពោលថា លោកទាំងឡាយ ចូរមានសេចក្ដីខ្វល់ខ្វាយតិចចុះ ខ្ញុំព្រះករុណា នឹងកាន់យកសត្វទាំងអម្បាលនេះទៅហើយ នឹងឲ្យកប្បិយភណ្ឌដល់លោក ហើយគេកាន់យកទៅក៏គួរ ។ មាន់ ជ្រូក នឹងលែងក្នុងព្រៃដោយគិតថា ចូរចិញ្ចឹមជីវិតតាមសប្បាយចុះដូច្នេះក៏គួរ ។ កាលបើគេពោលថា ខ្ញុំព្រះករុណាថ្វាយបឹងនេះ ស្រែនេះ ចំការនេះ ទីភូមិនេះ ដល់វិហារ នឹងឃាត់មិនបាន ត្រូវការដោយពិស្ដារចូលមើលក្នុងទុតិយសមន្តបាសាទិកាចុះ ។

បទដែលហាមឃាត់ តាំងអំពីចំការស្រែមកនេះ ព្រះអដ្ឋកថាចារ្យលោកអាស្រ័យបាលីក្នុងព្រះសូត្រជាដើមថា ខេត្តវត្ថុបដិគ្គហណា វៀរចាកការទទួលស្រែនឹងច្បារជាគោលទុក ។

មួយទៀត ទុក្កដាបត្តិ មិនមានមកក្នុងបាលី តែថាអនុលោមនៃថុល្លច្ចយាបត្តិជាដើម អដ្ឋកថាចារ្យលោកតែងតាំងទុក ក៏ឈ្មោះថាបាលិ-មុត្តក ទុក្កដ ដូចជាកិច្ចកាត់អង្គជាតខ្លួន ត្រូវថុល្លច្ច័យ ។ កាត់អវយវៈដទៃ

www.budinst.gov.kh www.elibraryofcambodia.org

មានគ្រែបៀក ប្រមុះ ស្រោមដៃ ណាមួយជាដើម ឬធ្វើទុកដូច្នោះឲ្យកើតឡើង ត្រូវទុក្កដ ៗ តែក្នុងអវយវៈដែលពស់ខឹងមូសទាំជាដើម ឬការពារដទៃ កាលបើកាត់អវយវៈ ឬឈាមខ្ទន់ មិនត្រូវអាបត្តិ ៗ

មួយទៀត ក្នុងខាងភិក្ខុនី ត្រូវបាចិត្តិយ ក្នុងភិក្ខុ ព្រះអដ្ឋកថាចារ្យពោលថា ត្រូវទុក្កដ ដូចភិក្ខុបោលទុច្ចារៈជាដើមខាងក្រៅជញ្ជាំង ក្រៅកំផែង ទឹងក្នុងស្រែចំការ ដូចពោលហើយខាងដើម តាំងអម្បាលនេះ ទើបហៅថាបាលិមុត្តកទុក្កដដ៏កំបាន ដែលសល់នៅមិនទាន់បានពោលនោះមានន័យដូចតទៅ ៖

១មួយថា ភិក្ខុឲ្យសមណចីវរ គឺសំពត់ដែលគួរស្លៀកដណ្ដប់បាន ដែលធ្វើកប្បៈហើយដល់គ្រហស្ថ ឬបរិព្វាជកណាមួយ ដទៃក្រៅតាកសហធម្មិកទាំង ៥ ទឹងមាតាបិតា ត្រូវទុក្កដ ៗ លះឲ្យដល់មាតាបិតា ទឹងឲ្យដល់មនុស្សដទៃជារបស់ខ្ចី មិនត្រូវអាបត្តិ ៗ

១មួយទៀត ភិក្ខុទៅដើម្បីទឹងមើលផ្ទះជាទីប្រជាគ្រសាលលេងនៃព្រះមហាក្សត្រ ទឹងផ្ទះសាលាដែលវិចិត្រដោយគំនូរ ទឹងច្បារជាទីមនោរម្យ ជំរើកចិត្ត ទឹងឧទ្យាន ឬស្រះបោក្ខរណី អម្បាលនេះ ដែលជាទីលេងសប្បាយ កាលដើរទៅត្រូវទុក្កដគ្រប់បទវារៈ ឈប់ក្នុងទីណាមិនបានលើកជើងឡើង បើមើលទៅទីទាំង ៥ ក្នុងទីនោះ ត្រូវអាបត្តិទុក្កដតែមួយ ៗ បើក្រឡេកមើលទៅក្នុងទីនោះ ៗ ត្រូវអាបត្តិកប់ដោយប្រយោគដែលងាកមើល មិនកប់ដោយរេចក្ខុក ហើយបើកឡើង ៗ

www.budinst.gov.kh www.elibraryofcambodia.org

បើមានកិច្ចដោយសលាកភត្តជាដើម ហើយដើរទៅក្តី ឬទៅព្រោះអន្តរាយក្តី មិនត្រូវអាបត្តិ ។

មួយទៀត សូម្បីទុក្កដ ព្រោះបើអកប្បិយបរិក្ខារវត្ថុខ្លះ ដូចពោលហើយ ក្នុងបរិក្ខារកថា ទើងពោលថាជាបាលិមុត្តកទុក្កដផងក៏បាន ។

បាលិមុត្តកទុក្កដ ចប់

---

ទុក្កដាបត្តិ ដែលពណ៌នាមកនេះ ទើងអស់តែប៉ុណ្ណេះក៏ទេ ដែលពោលមកនេះចំពោះតែបទដែលគួរដឹង ទើងគួរបដិបត្តិខ្លះ មានសល់នៅនៅខាងមុខខ្លះ ព្រោះទុក្កដាបត្តិមានច្រើនដូច្នេះ ទើបបានពោលថាមិនមានកំណត់ ។

ទុក្កដវណ្ណនា ចប់

---

ទើងពណ៌នាក្នុងទុព្ភាសិតាបត្តិ ថាភិក្ខុនិយាយឡកឡឺយ ចំអកចំអន់ឧបសម្បន្ន ឬអនុបសម្បន្ន ដោយអក្កោសវត្ថុទាំង ១០ មានជាតិជាដើម ត្រូវអាបត្តិទុព្ភាសិត វិនិច្ឆ័យក្រៅអំពីនោះ គប្បីដឹងដូចក្នុងឱមសវាទសិក្ខាបទនោះចុះ ប៉ុន្តែទុព្ភាសិតាបត្តិនេះ ជាធម្មទេសនា-សមុដ្ឋាន អាបត្តិកើតអំពីវាចាចិត្ត ជាកិរិយា ត្រូវព្រោះធ្វើ គឺនិយាយចំអកចំអន់គ្នាលេង សញ្ញាវិមោក្ខ សចិត្តកៈ វចីកម្ម អកុសលចិត្ត មានវេទនាពីរ គឺសុខនឹងឧបេក្ខាប៉ុណ្ណោះ ។

ទុព្ភាសិតវណ្ណនា ចប់

---

www.budinst.gov.kh www.elibraryofcambodia.org

សេចក្តីតរប់ ៤ ឈ្មោះកាលិកបព្វៈ ពណ៌នាអំពីកាលិក របស់ប្រកបដោយកាល ៗ កាលិកមាន ៤ គឺយាវកាលិក ១ យាមកាលិក ១ សត្តាហកាលិក ១ យាវជីវិក ១ ៗ ការរៀនលំដាប់ដូច្នេះនេះ តាមក្បួនសិក្សា ៗ តែក្នុងទីនេះនឹងពោលអំពីយាវជីវិកជាមុន ដើម្បីនឹងឲ្យវិជ្ជជួយបានដោយងាយ ហើយនឹងពោលឲ្យពិស្តារជាងបុព្វសិក្សាបន្តិច ៗ

## យាវជីវិក

ថ្នាំកើតអំពីដើមឈើដើមស្មៅ ដែលព្រះពុទ្ធអង្គទ្រង់អនុញ្ញាតមាន ៥ ប្រការ គឺ ឫស ១ ទឹកអម្ពត់ ១ ស្លឹក ១ ផ្លែ ១ ជ័រ ១ នឹងអំបិលផង ត្រូវជា ៦ ឈ្មោះថា យាវជីវិក ៗ ឫសឈើមើមឈើជាថ្នាំដែលទ្រង់អនុញ្ញាត នោះគឺ ហលិទ្ទំ រមៀត ១ សិង្គិវេរំ ខ្ញី ១ វចំ លំពាន់ ១ វចត្តំ ប្រស់ ១. អតិវិសំ តាចម្តួស ១ កដុករោហិណី រំដេង ១ ឧសីរំ ស្បូវភ្លាំង ១ ភទ្ទមុត្តកំ ក្រវាញជ្រូក ១ ជាវគ្គ ៨ មិនមែនតែមើម ឫស វល្លិ ក្នុងវគ្គទាំង ៨ មួយចំពួកប៉ុណ្ណោះទេ សូម្បីដើម សម្បក ផ្កា នឹងផ្លែ ក្នុងវគ្គទាំង ៨ នោះ ក៏ឈ្មោះថា យាវជីវិកដែរ ៗ

ទឹកអម្ពត់ជាថ្នាំដែលទ្រង់អនុញ្ញាតនោះ គឺ និម្ពកសាវោ ទឹកអម្ពត់ស្ដៅ ១ កុដជកសាវោ ទឹកអម្ពត់ក្លូងគន់ ១ បដោលកសាវោ ទឹកអម្ពត់អំបែងព្រៃ ឬពុលឯក ១ បក្កវកសាវោ ទឹកអម្ពត់បណ្តូលពេជ ឬអង្គាញ់ ១ នត្តមាលកសាវោ ទឹកអម្ពត់ខ្ទា ឬថាំង (សំបុរៈខស) ១ ត្រូវជា ៥ ដូច្នេះ ៗ

www.budinst.gov.kh www.elibraryofcambodia.org

ស្លឹកឈើ ជាភេសជ្ជៈ ដែលទ្រង់អនុញ្ញាតនោះ គឺ ជម្ពុបណ្ណំ ស្លឹកស្តៅ កកុដជបណ្ណំ ស្លឹកក្រូងគង់ បដោលបណ្ណំ ស្លឹកអំពែងថ្ម ឬពុលឯក សុលសិបណ្ណំ ស្លឹកម្រះព្រៅឬស្លឹកដំលិងលាក់ កប្បាសិបណ្ណំ ស្លឹកកប្បាស ត្រូវជាវគ្គ ៨ មិនមែនតែស្លឹកនៃវគ្គតាំង ៨ នេះ មួយចំពូកប៉ុណ្ណោះទៀយ ស្លឹកផ្កាទឹងផ្លែជាដើមនៃវគ្គតាំង ៨ នោះ ក៏ឈ្មោះថាយាវជីវិកដែរ ។

ផ្លែឈើដែលជាភេសជ្ជៈ គឺផ្កាំដែលទ្រង់អនុញ្ញាតនោះគឺ វិលង្គំ ផ្លែពិលង្គ បិប្ផលិ ដីប្លី មរិចំ ម្រេច ហរីតកំ សម៉ៃ ឬសម៉ូរ វិភីតកំ សម៉ីតកេត អាមលកំ កន្ទួតព្រៃ គោដ្ឋផលំ ផ្លែក្រវាញ ត្រូវជាវគ្គ ៧ ។

ជ័រឈើដែលជាភេសជ្ជៈ ជាផ្កាំ ដែលព្រះអង្គទ្រង់អនុញ្ញាតនោះគឺ ហិង្គុ ជ័រឈើដែលហូរចេញអំពីដើមហិង្គុ ១ ហិង្គុជតុ ជ័រឈើដែលគេយកមែកនិងស្លឹក នៃដើមហិង្គុមកស្ងោរ ១ ហិង្គុសិបាតិកា ជ័រដែលគេយកត្រួយនៃហិង្គុមកស្ងោរ ឬជ័រដែលគេយកស្លឹកហិង្គុមកស្ងោរ ហើយលាយដោយរបស់ដទៃក៏ថា ១ តកំ ជ័រដែលហូរចេញអំពីត្រួយឈើ ១ តកបត្តិ ជ័រដែលហូរចេញអំពីស្លឹកឈើ ១ តកបណ្ណិ ជ័រដែលគេបេះស្លឹកឈើយកមកស្ងោរ ១ សជ្ជុលសំ កញ្ញាណ ១ ត្រូវជាវគ្គ ៧ ប្រការ ។

www.budinst.gov.kh www.elibraryofcambodia.org

កំបិលដែលព្រះអង្គទ្រង់អនុញ្ញាតនោះ គឺ សាមុទ្ទំ អំបិលកើតក្បែរឆ្នេរសមុទ្រមានបែបដូចដីខ្សាច់ ១ កាឡលោណំ អំបិលមានពណ៌ខ្មៅ (គឺអំបិលប្រក្រតី) ១ សិន្ធវំ គឺសិន្ធៅលោកពោលថាអំបិលពណ៌សកើតលើភ្នំ ១ ឧព្ភិទំ អំបិលដែលមានពន្លកដុះអំពីផែនដី (គឺអំបិលដែលកើតអំពីអាចម៍ដីមានរសប្រៃ) ១ ពិលំ អំបិលវិសេស លោកពោលថា អំបិលស្ងួតដោយសម្ភារៈទាំងពួងមានពណ៌ក្រហម ១ ។

កិឯភេសជ្ជៈ គឺថ្នាំវត្ថុទាំង ៦ ប្រការមានឫសជាដើម ព្រះអង្គទ្រង់អនុញ្ញាតបន្ទូលបង្ហាញឈ្មោះដូច្នេះហើយ តទៅទៀតព្រះអង្គមានប្រាថ្នាដើម្បីនឹងសំដែងលក្ខណៈនៃឫសឈើជាដើមដទៃ ដែលមិនមានមកក្នុងបាលីក្នុងថ្នាំបាន ទើបពោលបាលីថា យានិ វា បនញ្ញានិបិ អត្ថិ មូលានិ កសាវានិ បណ្ណានិ ផលានិ ជតូនិ លោណានិ ភេសជ្ជានិ នេវ ខាទនីយេ ខាទនីយត្ថំ ផរន្តិ ន ភោជនីយេ ភោជនីយត្ថំ ផរន្តិ ម្យ៉ាងទៀត ឫសឈើ ទឹកអមួត ស្លឹកឈើ ផ្លែឈើ ជ័រឈើ អំបិល វត្ថុដទៃឯណាមួយ ដែលមិនបានចេញឈ្មោះក្នុងបាលី ដែលមិនបានផ្សាយចូលទៅ ដើម្បីខាទនីយៈក្នុងខាទនីយៈ វត្ថុទាំងនោះ មិនបានផ្សាយទៅ ដើម្បីភោជនីយៈ ក្នុងភោជនីយ វត្ថុបរិភោគ ធ្វើជាថ្នាំបាន ។ នៅមានទៀតគឺ ឫសឈើដទៃជាដើម ដែលមិនបានសម្រេចអាហារកិច្ច បរិភោគជាអាហារដោយប្រក្រតីនៃមនុស្សក្នុងជនបទណា ឫសឈើជាដើមនោះឈ្មោះថាជា

www.budinst.gov.kh www.elibraryofcambodia.org

ភេសជ្ជៈក្នុងបទនោះ ព្រោះហេតុនោះ មើម ឫស ក្រឹន ក្រួយ ពន្លក សម្បក ស្លឹក ផ្កា ផ្លែ គ្រាប់ មៀម ជ័រ នៃដើមឈើ វល្លិ ស្មៅ វត្ថុណាមួយក្ដី ទឹកអំបិលណាមួយក្ដី ដែលមិនមានមកក្នុងបាលី មិនបានសម្រេចអាហារកិច្ចនៃមនុស្សក្នុងប្រទេសនោះៗ ដូចមើមក្ដាតក្រហម មើមក្ដាតស ឫសត្នោត ឫសដូង ស្លឹកម្រុំ ស្លឹកឈូក ផ្កាបុស្សនាគ ផ្កាចម្បា ផ្កាចន្ទន៍ ផ្លែក្រវាញ ជាដើម ជាភេសជ្ជៈក្នុងប្រទេសយើងនេះ ឫសឈើជាដើមដូចពោលមកនេះ ឈ្មោះថាយាវជីវិក ទទួលប្រគេនហើយ កាលមានជម្ងឺណាមួយ ឆាន់បានដរាបតែអស់ជីវិតក្នុងកាលទាំងពួង បើធ្វើសន្និធិទុក ឬឆាន់ក្នុងវេលាវិកាល ដើម្បីជាអាហារ មិនឆាន់ដើម្បីថ្នាំត្រូវអាបត្តិទុក្កដ ។ ព្រោះបាលីដែលព្រះពុទ្ធជាអម្ចាស់ពោលទុកក្នុងទាំងពួងគ្រប់ៗ ភេសជ្ជៈថា តានិ បដិគ្គហេត្វា យាវជីវំ បរិហរិតុំ សតិ បច្ចយេ បរិភុញ្ជិតុំ អសតិ បច្ចយេ បរិភុញ្ជន្តស្ស អាបត្តិ ទុក្កដស្ស សេចក្ដីថា តថាគតអនុញ្ញាតឲ្យទទួល ឫសឈើ ទឹកអម្ចត់ ស្លឹកឈើ ផ្លែឈើ ជ័រឈើ អំបិល វត្ថុឯណានីមួយ អម្បាលនេះហើយ បរិហាររក្សាទុកដរាបអស់ជីវិត កាលមានបច្ច័យ គឺហេតុ ឲ្យបរិភោគឆាន់ចុះ កាលមិនមានបច្ច័យ គឺហេតុ ឆាន់ត្រូវទុក្កដ ដូច្នេះ ។

**យាវជីវិក ចប់**

www.budinst.gov.kh www.elibraryofcambodia.org

និងសំដែងក្នុងយាវកាលិក របស់ឆាន់ ដែលមានអាយុត្រឹមកាល គឺពីព្រឹកដល់ថ្ងៃត្រង់ ។ កាលបើពោលយាវកាលិកហើយ យាវជីវិកក៏នឹងពឹងផងទៀត មានខាទនីយំ របស់ទំពាស៊ី ភោជនីយំ របស់ស៊ី ឈ្មោះថាយាវកាលិក ។ ភោជន ៥ គឺបាយ នំកុម្មាស សត្តុ ត្រី សាច់ ឈ្មោះថាភោជនីយៈរបស់ស៊ី ។ លើកតែភោជន ៥ យាមកាលិក សត្តាហៈកាលិក និងយាវជីវិកចេញ អាមិសក្រៅនោះ ឈ្មោះថាខាទនីយៈរបស់ទំពាស៊ីទាំងអស់ ។ ក្នុងរបស់ទំពាស៊ី ដែលធ្វើដោយបុព្វណ្ណជាតិ គឺបាយ និងអបរណ្ណជាតិ គឺសណ្តែក ល្ង ស្លៀនជាន់ ជាដើម ទាំងអម្បាលនេះ មិនត្រូវពោល ។ សូម្បីបួស មើម ក្រអៅ ក្រួយ ដើម សម្បក ស្លឹក ផ្កា ផ្លែ គ្រាប់ មៀម ជ័រ នៃដើមឈើ គុម្ពឈើ វល្លិ ស្មៅ ណាដែលជាគតិនៃអាមិស សូម្បីរបស់ទាំងអម្បាលនេះ ក៏សង្គ្រោះជាខាទនីយៈដោយពិត ។

និងសំដែងក្នុងរបស់ទំពាស៊ី គឺមើមជាមុន មើមដំឡូងទៀន ដំឡូងបរោស ដំឡូងបាស ដំឡូងឈាមមាន់ ដំឡូងជួង ដំឡូងស្វា ស្លែ ដំឡូងឈើជាដើម និងដំឡូងមានស្លឹកគួរស្លបាន ឈ្មោះថាគតិនៃអាមិស បួសសំយាយក្នុងមើមក្រោរ ដែលគេកាត់ពាលចេញ ជាយាវជីវិក សូម្បីបួសសំយាយដទៃដូច្នេះ បណ្ឌិតគប្បីដឹងដោយន័យនោះចុះ ។ តែបួសសំយាយនៃដំឡូងទៀន ដំឡូងបរោស និងបួសស្លែជាគតិនៃអាមិស មើមរមៀតជាដើមដែលជាយាវជីវិក ដូចពោលហើយអំពីមុននោះ និងកប់ជាបួសគួចបួសធំទៅក៏មិនមានទីបំផុត ដែលមិនសំរេចកិច្ចជាខាទនីយ

www.budinst.gov.kh www.elibraryofcambodia.org

គោធូមយវៈនោះផង ជាលក្ខណៈនៃយាវជីវិក ព្រោះហេតុនោះ មើម ឫស ណាមួយ ផ្សាយទៅជារបស់ទំពាស៊ី របស់ស៊ីនៃមនុស្ស ដោយអំណាចជាអាហារប្រក្រតី មិនត្រូវប្រកបដោយយាវកាលិកដទៃ ក្នុងជនបទនោះៗ មើម ឫសនោះ ឈ្មោះថាជាយាវកាលិក ក្នុងជនបទនោះៗ ។ ឫស មើម ក្រៅនោះ គប្បីដឹងថាជាយាវជីវិកចុះ ។ សូម្បីពោលដោយច្រើនទៅ គឺគង់តាំងនៅក្នុងលក្ខណៈនេះឯង ។ កាលបើលើកឈ្មោះឡើងពោល គឺវង្វេងព្រោះមិនស្គាល់ឈ្មោះនោះៗ ហេតុដូច្នោះខ្ញុំមិនលើកឈ្មោះនោះ ខ្ញុំសំដែងតែលក្ខណៈមួយយ៉ាង សំដែងលក្ខណៈក្នុងឫសដូចម្ដេច ក្នុងមើមក៏វិនិច្ឆ័យដូច្នោះ ។ មើមមាន២គឺវ៉ែង ១ មូល ១ ។ ឯមើមវ៉ែងនោះមានក្រទុំឈូក ខ្ញីតាវជាដើម ។ មើមមូលនោះ គឺមើមត្រប្បល ខ្ញីមើមប្ដុនជាដើម ។ មើមតាស់ខ្ញីស់បក ខ្ញីឫសល្អិតនៃមើមតាំងអម្បាលនេះ ជាយាវជីវិក ។ តែមើមខ្ចីខ្ញីគប្បីទំពាស៊ីបានដូចក្ដៅនាង តាវ ម្នាក់ ក្ដួច ខ្ញីគល់ចេកជាដើម ខ្ញីមើមណាមួយដែលសម្រេចជាអាហារកិច្ច ដោយប្រក្រតីបាន ជាយាវកាលិក ។ មើមក្ដួចដែលគេមិនបានយកសេតុលចេញ ជាយាវជីវិក ។ គេយកសេកាចចេញហើយ ជាយាវកាលិក ។ មើមតាល់ក្រហមតាល់សជាដើម ជាយាវជីវិកសង្គ្រោះក្នុងមូលភេសជ្ជៈ ។ ខ្ញីសំដែងក្នុងក្រមុំក្ដួច ដូចក្រមុំឈូកក្រហមឈូកស ក៏ដូចគ្នា ។ ឫសវែងក្ដី ឫសដទៃដែលសម្រេចជាអាហារកិច្ចបានក្ដី ជាយាវកាលិក ឫសរមៀត ខ្ញី បណ្ដូលពេជ្រ វល្លិគ្រឡុង ឫស

www.budinst.gov.kh www.elibraryofcambodia.org

ស្លា ជាដើម ជាយាវជីវិក សង្គ្រោះក្នុងមូលភេសជ្ជៈ ។ ទឹកសំបែង ក្នុងត្រួយ ទឹកកំពូល ត្នោត ខ្ញៃ តាក ជាដើម ទឹកត្រួយ អំពៅ ស្ពៃ ស្រូវ៧ប្រការ នៃដើមឈើទាំងវល្លិ៍ជាដើម វត្ថុណាដែលសម្រេចអាហារ-កិច្ចបាន ជាយាវកាលិក ។ គល់ត្រួយចាស់នៃរមៀត ខ្ញី លំពាន់ ខ្ទឹមក្តី នៃត្នោត ខ្ញៃ ស្លា ដូងក្តី ជាគល់ត្រួយដែលចាស់ គេកាត់ចោលចេញ ជាយាវជីវិក ។ ទាំងពោលដើមក្តៅធាងដែលចាក់ចុះទៅក្នុងដី ដើមអំពៅ ដើមឧប្បលខៀវ ឧប្បលក្រហម កុមុទ ចន្ទុលណ៍ ដើមណាដែល សម្រេចអាហារកិច្ចបាន ជាយាវកាលិក ។ ដង ស្លឹក នៃឧប្បលជាតិ ទាំង ដងស្លឹក នៃបទុមជាតិទាំងពួងក្តី ទាំងដើមទាំងពួងដ៏សេសមានដើមសម្បូរ-មាសជាដើម ដែលមិនសម្រេចអាហារកិច្ចបាន ជាយាវជីវិក ។

ទាំងពោលក្នុងសម្បក សំបកអំពៅមួយចំពូក ដែលមានរសជាប់ ទៅជាយាវកាលិក ។ សំបកឈើទាំងពួងដ៏សេសជាយាវជីវិក សង្គ្រោះ ក្នុងកសាវៈ គឺទឹកអម្ចត់ ។ ទាំងពោលក្នុងស្លឹក ស្លឹកដំឡូងទៀនជាដើម ទាំងស្លឹកស្ពៃ ស្លឹកក្រុំ ស្លឹកសណ្តែកបាយ ស្លឹកសណ្តែកកផមាស ស្លឹកញាព្រៃ ស្លឹកបាស ទាំងស្លឹកណាដែលសម្រេចអាហារកិច្ចបាន ជា យាវកាលិក អ្នកស្រុកលង្កាថា ព្រម្ម គឺស្លឹកកំពីងពួយឈើ ជាយាវជីវិក ស្លឹកស្វាយខ្ចី ជាយាវកាលិក ស្លឹកសោកខ្ចី ជាយាវជីវិក ។ ទាំងពោល ក្នុងផ្កា ផ្កាដំឡូងទៀន ជាដើម។ ទាំងផ្កាស្ពៃ ផ្កាញាព្រៃ ផ្កាញស្រុក ផ្កាខ្ចីនៃដូងត្នោតទាំងគេត ផ្កាឧប្បល ផ្កាឈូក ទាំងផ្កាឈើណាដែល

www.budinst.gov.kh www.elibraryofcambodia.org

សម្រេចអាហារកិច្ចបានជាយាវកាលិក ផ្កាសោក ផ្កាកុល ផ្កាស្មី ផ្កាបុស្សនាគ ផ្កាចម្បា ជាដើម ជាយាវជីវិក សង្គ្រោះក្នុងកសាវភេសជ្ជៈ ។ ចំណែកពួកផ្លែ ផ្លែខ្នុរ សាគេរ ត្នោត ដូង ស្វាយ ព្រីង ជាដើម ចំណែកផ្លែឈើដទៃ ដែលសម្រេចអាហារកិច្ចបាន ជាយាវកាលិក ។ ផ្លែចន្ទន៍ ចំណែកផ្លែក្រោយ ចំណែកផ្លែដែលមិនសម្រេចអាហារកិច្ចបាន ជាយាវជីវិក ។ ចំណែកពួកគ្រាប់ គ្រាប់នៃខ្នុរសម្មុរ គ្រាប់នៃខ្នុរណាំង គ្រាប់នៃម្កាក់ជាដើម ចំណែកគ្រាប់ដទៃដែលសម្រេចអាហារកិច្ចបាន ជាយាវកាលិក គ្រាប់បុស្សនាគ ស្រគុំ ស្រមំ ជាដើម ចំណែកគ្រាប់ដទៃដែលមិនសម្រេចអាហារកិច្ចបាន ជាយាវជីវិក សង្គ្រោះក្នុងផលភេសជ្ជៈ ។ ចំណែកពួកម្សៅនៃស្រូវ ៧ ប្រការ ចំណែកស្រូវអនុលោម ចំណែកម្សៅនៃសណ្តែក ល្ង ជាដើម ម្សៅខ្នុរ ម្សៅសាគេរ ចំណែកម្សៅម្កាក់ ម្សៅត្នោត ម្សៅក្តួច ដែលជម្រះចេញហើយ ចំណែកម្សៅដទៃ ដែលសម្រេចអាហារកិច្ចបាន ជាយាវកាលិក ។ ម្សៅត្នោត ម្សៅក្តួច ដែលមិនទាន់ជម្រះរសកំណាច ជាយាវជីវិក សង្គ្រោះក្នុងទឹកអម្ពត់ ចំណែកចូស ចំណែកផ្លែ ដែលមានមកក្នុងបាលី ។ ចំណែកពួកជ័រ ជ័រនៃអំពៅមួយចំពូក ជាសត្តាហកាលិក នៃឈើក្រៅនោះ ជាយាវជីវិកទាំងអស់ សង្គ្រោះក្នុងជតុភេសជ្ជៈ ។ មើមនៃក្រចៅជាដើម ដែលជាយាវកាលិក ដូចពោលមកនេះ សង្គ្រោះក្នុងខាទនីយៈរបស់ទំពាស៊ី ចំណែកភោជនីយៈរបស់ស៊ី នេះឈ្មោះថាយាវកាលិក

www.budinst.gov.kh www.elibraryofcambodia.org

ឆាន់បានតពីព្រឹកដល់ថ្ងៃត្រង់ រសៀលហើយឆាន់ត្រូវបាចិត្តិយ ទទួលប្រគេនទុកឲ្យកន្លងរាត្រី ជាសន្និធិ ឆាន់ត្រូវបាចិត្តិយ ។

យាវកាលិក ចប់

## យាមកាលិក

ទឹកសំរាប់ផឹកក្នុងយាមកាលិក ។ ទឹក ៨ ប្រការដែលគួរក្រេបផឹកគឺ អម្ពបានំ ទឹកធ្វើដោយផ្លែស្វាយខ្ចី ឬទុំ ១ ជម្ពុបានំ ទឹកធ្វើដោយផ្លែព្រីងផ្លែជម្ពូក៏បាន ១ ចោចបានំ ទឹកធ្វើដោយផ្លែចេកមានគ្រាប់ ១ មោចបានំ ទឹកធ្វើដោយផ្លែចេកគ្មានគ្រាប់ ១ មធុបានំ ទឹកធ្វើដោយរសជាតិនៃស្រស់ ១ មុទ្ទិកាបានំ ទឹកធ្វើដោយផ្លែចាន់ផ្លែទំពាំងបាយជូរក៏បាន ១ សាលុកបានំ ទឹកធ្វើដោយឫស ទីក្រអៅនៃឈូក ឧប្បលក្រហម ឧប្បលខៀវជាដើម ១ ផារុសកបានំ ទឹកធ្វើដោយផ្លែមាក់ប្រាង ផ្លែគូលេនក៏បាន ១ ទឹកអដ្ឋបានទាំង ៨ ប្រការនេះ ឈ្មោះជាយាមកាលិក មានយាម ១ ជាកាល គឺមានអាយុត្រឹមថ្ងៃ ១ យប់ ១ ប៉ុណ្ណោះ ។

នឹងពោលដោយវិធីធ្វើទឹកស្វាយជាមុន កាលមិនធ្វើដោយផ្លែស្វាយខ្ចី គប្បីបុកចំលាយស្វាយទុំដាក់ក្នុងទឹក ហើយហាលថ្ងៃទុកឲ្យឆ្អិនដោយកំដៅព្រះអាទិត្យ ហើយត្រងចេញ ផ្សំដោយទឹកឃ្មុំ ឬស្ករកប្បូរ បញ្ចូលគ្នាជាដើម ដែលទទួលប្រគេនក្នុងថ្ងៃនោះហើយធ្វើចុះ ។ ធ្វើរួចឯងគួរគង់ប្រគេន ក៏វេលាព្រឹកមួយយាម ។ បើអនុបសម្បន្នធ្វើបានមក

www.budinst.gov.kh www.elibraryofcambodia.org

ទទួលប្រគេនក្នុងបុរេភត្ត សម្បីបរិភោគជាមួយនឹងអាមិសក្នុងបុរេភត្តក៏គួរ ក្នុងបច្ឆាភត្ត គួរបរិភោគប្រាសចាកអាមិស ត្រាតែអរុណរះឡើងមក ។ ក្នុងទឹកជម្ពូជាដើម ក៏ដូចគ្នា ។ តែមធុបានៈធ្វើដោយស្រស់នោះ លាយដោយទឹកទេបគួរ តែទឹកស្រស់សុទ្ធមិនគួរ ។ ដ្បិតក្នុងអដ្ឋកថា មធុក-បានន្តិ មុទ្ទិកានំ ជាតិរសេន កតបានំ បន ឧទក-សម្ភិន្នំ វដ្តតិ សុទ្ធំ ន វដ្តតិ ដូច្នេះ ។ មុទ្ទិកាបានំ បុកណាជាទឹកផ្លែហាន់ តែអ្នកស្រុកលង្កាថាទឹកទំពាំងបាយជូរ បើទឹកទំពាំងបាយជូរហើយសោត គួរតែទឹកស្រស់ ទឹកទំពាំងបាយជូរដូចប្រទេសអឺរ៉ុបជាដើមគេផឹកសព្វថ្ងៃនេះ ជាមេរ័យមិនគួរ គួរតែទឹកស្រស់ សំដូចជាពាក្យក្នុងអដ្ឋកថាថា មុទ្ទិកាបានន្តិ មុទ្ទិកា ឧទកេ មទ្ទិត្វា អម្ព-បានំ វិយ កាតព្វា ដូច្នេះ ។ អដ្ឋបានអម្បាលនោះ សម្បីគ្រាន់ជាក់ឬឆ្អិន ដោយព្រះអាទិត្យគួរ ចំអិនដោយភ្លើងមិនគួរ ។

មួយទៀត ព្រះអង្គទ្រង់អនុញ្ញាតទុកថា អនុ... សព្វំ ផលរសំ ឋបេត្វា ធញ្ញផលរសំ ។ អនុ...សព្វំ បត្តរសំ ឋបេត្វា បក្កដាករសំ ។ អនុ..សព្វំ បុប្ផរសំ ឋបេត្វា មធុក-បុប្ផរសំ ។ អនុ... ឧច្ឆុរសំ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសេវនផ្លែឈើទាំងពួង លើកតែស្រូវ ៧ ប្រការចេញ ។ មួយទៀត តថា-គតអនុញ្ញាតសេវនស្លឹកឈើទាំងពួង លើកតែសេវនស្លឹកអន្លក់ឆ្អិនចេញ ។

www.budinst.gov.kh www.elibraryofcambodia.org

មួយទៀត គឺថាគតអនុញ្ញាតរសនៃផ្កាឈើ ទាំងពួង លើកតែផ្កាស្រគំ ចេញ ។ មួយទៀត គឺថាគតអនុញ្ញាតរសនៃទឹកអំពៅសុទ្ធ ។

រឿងដែលអនុញ្ញាតរសនៃផ្លែឈើទាំងពួង វៀរតែរសនៃផ្លែស្រូវ ៧ ប្រការចេញ នោះនឹងដឹងច្បាស់ក្នុងមហាបទេស ៤ ខាងមុខ ។ រឿងដែលទ្រង់អនុញ្ញាតរសនៃស្លឹកឈើទាំងពួង លើកតែរសនៃស្លឹកឆ្អិន ចេញនោះ ព្រោះថារសនៃស្លឹកឈើដែលជាយាវកាលិក គួរតែក្នុង បុរេភត្តមួយយ៉ាង ។ រសនៃស្លឹកឈើជាយាវជីវិក គេធ្វើឲ្យឆ្អិនលាយគ្នា នឹងសប្បិជាដើម ដែលទទួលប្រគេនទុកនេះ គួរ ៧ ថ្ងៃ បើគេចំអិនដោយ ទឹកទទេសុទ្ធ គួរដរាបដល់អស់ជីវិត ។ នឹងស្លោររសនៃស្លឹកឈើជាយាវ-ជីវិក មួយអន្លើនឹងទឹកដោះស្រស់ជាដើមមិនគួរ សម្បីគេស្លោរជាមួយនឹង របស់ដទៃ ដែលហៅថាជារសនៃស្លឹកអន្លក់ឆ្អិន ។ តែក្នុងគម្ពីរខ្លះពោលថា រសនៃស្លឹកឈើ សម្បីជាយាវកាលិក គេប្រញាប់ដោយទឹកត្រជាក់ធ្វើមក ឬឲ្យឆ្អិនដោយកំដៅព្រះអាទិត្យក៏គួរ ។ រឿងដែលអនុញ្ញាតរសនៃផ្កា ឈើទាំងពួង លើកតែរសនៃផ្កាស្រគំចេញនោះ រសនៃផ្កាស្រគំ នឹងឆ្អិន ដោយភ្លើង ឬដោយព្រះអាទិត្យក្តី មិនគួរក្នុងបច្ឆាភត្ត ។ រសស្រគំណា ដែលចំអិន ហើយគេគាប់យកធ្វើជាទឹកស្រវឹង រសនោះតាំងអំពីដំបូងទៅ សម្បីក្នុងបុរេភត្តក៏មិនគួរ ឬផ្កាស្រគំស្រស់ ឬស្លូតគេលាយហើយក្តី ឬផា-ណិត គេធ្វើដោយផ្កាស្រគំ គឺផ្កាស្រគំដែន តែវត្ថុណា គេមិនបាន ធ្វើជាទឹកស្រវឹង វត្ថុទាំងពួងនោះ រមែងគួរក្នុងបុរេភត្តមួយយ៉ាង ។ ទឹក

www.budinst.gov.kh www.elibraryofcambodia.org

ៅស្រស់ដែលទ្រង់អនុញ្ញាតនោះ មិនមានកាក ក្នុងបច្ឆាភត្ត ព្រះ
ុកាលទ្រង់អនុញ្ញាតបានៈ គឺទឹកក្រេបផឹក ព្រះអង្គបានទ្រង់អនុញ្ញាត
រនៃផ្លែឈើស្ងួតឈើផ្កា ឈើអំពៅបួននេះ ដោយប្រការដូច្នេះ ៗ ក្នុងវិមតិ-
នោទនីដែលពោលថាទឹកអំពៅស្រស់មិនមានកាក ក្នុងយាមកាលិកកថា
ារះពោលដោយសាមញ្ញថា ជារបស់ឈើគប្បីក្រេបផឹក តែឲ្យគប្បី
ន់យកថា ទឹកអំពៅស្រស់នោះ ជាសត្តាហកាលិកចុះ ៗ យាមកាលិក
ះទទួលប្រគេនហើយ ឆាន់បានតែមួយថ្ងៃមួយយប់ អរុណថ្មីរះឡើង
រ ជាសន្និធិ ឆាន់ត្រូវទុក្កដ ៗ

យាមកាលិក ចប់

## សត្តាហកាលិក

ឈើពណ៌នាក្នុងសត្តាហកាលិក ថ្នាំមានអាយុកាលត្រឹម ៧ ថ្ងៃ គឺ
រប្បិ ខ្លាញ់រាវ នវនីត ខ្លាញ់ខាប់ តេលំ ប្រេង មធុ ទឹកឃ្មុំ
ាណិតំ ទឹកអំពៅ ថ្នាំ ៥ នេះឈ្មោះថាសត្តាហកាលិក ទទួលប្រគេន
ើយទុកឆាន់បាន ៧ ថ្ងៃ កន្លង ៧ ថ្ងៃទៅ ដល់អរុណគំរប់ ៨ រះឡើងមក
និស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ជានិស្សគ្គិយហើយឆាន់ត្រូវទុក្កដ បរិភោគ
ងកាយមិនគួរ ៗ សប្បិគោ សប្បិពពែ សប្បិក្របី សាច់នៃ សត្វចំពូក
ាគួរ សប្បិនៃសត្វចំពូកនោះឈ្មោះថាសប្បិ ៗ នវនីត នៃសត្វចំពូក
ោះឯងឈ្មោះថានវនីត ។ គប្បីដឹងក្នុងគោរស ៥ ជាមុន ទឹកដោះស្រស់
ៃគោ នៃពពែ នៃក្របី នៃសត្វ ដែលមានសាច់គួរ ឈ្មោះថា ខីរំ ជា

www.budinst.gov.kh www.elibraryofcambodia.org

ទឹកដោះស្រស់ ទឹកដោះស្រស់នោះទុកពេលយូរ លុះជូរឈ្មោះថា ទធិ ទឹកដោះជូរ ទឹកដោះជូរនោះគេចំរាញ់ឡើងឈ្មោះថា តក្កំ ប្រេង ប្រេងនោះ គេចំរាញ់ឡើងទៀតឈ្មោះថា នវនីតំ គឺខ្លាញ់ខាប់ ខ្លាញ់ខាប់នោះ គេចំរាញ់ឡើងទៀតឈ្មោះថា សប្បិ គឺខ្លាញ់រាវ ទឹកដោះស្រស់ ទឹកដោះជូរ ប្រេង ជាយាវកាលិក គួរតែក្នុងវេលាព្រឹក ៗ នវនីត សប្បិ ជាសត្តាហកាលិក ខ្លាញ់ទាំង ២ នេះ ក្នុងប្រទេសយើងមានប្រើតិច ព្រោះហេតុនោះ ខ្ញុំមិនបានវិនិច្ឆ័យឲ្យពិស្តារទេ ខ្ញុំវិនិច្ឆ័យតែថ្នាំ ៣ យ៉ាងក្រៅនោះ តេលំ គឺប្រេង មធុ ទឹកឃ្មុំ ផាណិតំ ស្ករអំពៅ ៗ សប្បិ នឹង នវនីត ទទួលប្រគេនក្នុងវេលាព្រឹក គួរឆាន់ជាយអាមិសបានក្នុងវេលាព្រឹក រសៀលទៅហើយមិនគួរ ៗ បើឆាន់ប្រាសចាកអាមិសបាន ៧ ថ្ងៃ ក្នុង ៧ ថ្ងៃទៅ ត្រូវនិស្សគ្គិយកប់តាមវត្ថុនិងភាជនដែលដាក់ទុក ៗ ប្រេងកើតអំពីល្ង កើតអំពីគ្រាប់ស្ពៃ គ្រាប់ស្រគំ គ្រាប់ល្ហុង និងកើតអំពីករខ្សាមខ្លាញ់សត្វ ទាំងអម្បាលនេះមានក្នុងបាលី ៗ គ្រាប់ល្ង គ្រាប់ស្រគំ គ្រាប់ល្ហុង ករខ្សាមខ្លាញ់ ជាយាវកាលិក ៗ គ្រាប់ក្រៅនោះ គឺគ្រាប់ស្ពៃជាយាវជីវិក ៗ ខ្ញុំពោលក្នុងប្រេងល្ងជាមុន ប្រេងល្ងទទួលប្រគេនក្នុងវេលាព្រឹក សុម្បីឆាន់ជាមួយអាមិស ក្នុងវេលាព្រឹកថ្ងៃនោះក៏គួរ តែរសៀលទៅឆាន់ប្រាសចាកអាមិសទើបគួរ ក្នុង ៧ ថ្ងៃទៅ ត្រូវនិស្សគ្គិយកប់តាមភាជនៈដែលដាក់ទុក ៗ ប្រេងល្ងទទួលប្រគេនក្នុងបច្ឆាភត្ត គឺវេលាល្ងាច គួរឆាន់ប្រាសចាកអាមិសមួយចំពូក បាន ៧ ថ្ងៃ

www.budinst.gov.kh www.elibraryofcambodia.org

ធ្វើឲ្យជាឧគ្គហិតហើយ ទុកដាក់នឹងបរិភោគមិនគួរ គប្បីបន្ថែមចូលទៅក្នុងកិច្ចដទៃមានលាបសរីរជាដើម ក្នុង ៧ ថ្ងៃទៅមិនត្រូវអាបត្តិ ។ ទទួលប្រគេនគ្រាប់ល្ងក្នុងបុរេភត្ត គឺវេលាព្រឹក ហើយធ្វើជាប្រេងគួរឆាន់បាន សូម្បីដោយអាមិសក្នុងបុរេភត្ត អំពីបច្ឆាភត្តទៅជារបស់មិនគួរលេបស៊ី គប្បីបន្ថែមចូលទៅក្នុងកិច្ចដទៃមានលាបសរីរជាដើម បើក្នុង ៧ ថ្ងៃទៅមិនត្រូវអាបត្តិ ។ ទទួលប្រគេនគ្រាប់ល្ងក្នុងបច្ឆាភត្តធ្វើឡើងជាប្រេង ជារបស់មិនគួរបរិភោគឡើយ ព្រោះទទួលតាំងទុក បើក្នុង ៧ ថ្ងៃទៅមិនត្រូវអាបត្តិ គប្បីបន្ថែមចូលទៅក្នុងកិច្ចដទៃ មានលាបសរីរជាដើម សូម្បីក្នុងប្រេងដែលធ្វើដោយគ្រាប់ល្ងឧគ្គហិត ក្នុងបុរេភត្តឬបច្ឆាភត្តក៏ដូចគ្នាដូច្នោះ ។ ប្រេងចំរាញ់គ្រាប់ល្ង ឬចំហុយម្សៅល្ងដែលទទួលប្រគេនក្នុងបុរេភត្ត ឬឲ្យទទឹកសើមដោយទឹកក្ដៅធ្វើក្ដី បើអនុបសម្បន្នធ្វើគួរ សូម្បីឆាន់លាយដោយអាមិសក្នុងបុរេភត្តក៏គួរ ធ្វើខ្លួនឯងគួរឆាន់ប្រាសចាកអាមិសក្នុងបុរេភត្ត ព្រោះកិច្ចបកខ្លួនឯងឆាន់ជាមួយអាមិសមិនគួរ ព្រោះហេតុឲ្យឆ្អិនឯង អំពីបច្ឆាភត្តទៅ ប្រេងតាំង ២ យ៉ាងនោះមិនគួរឆាន់ ព្រោះទទួលតាំងទុក គប្បីបន្ថែមចូលទៅ ក្នុងកិច្ចដទៃមានលាបសរីរជាដើម ក្នុង ៧ ថ្ងៃទៅមិនត្រូវអាបត្តិ ចាំបើទឹកក្ដៅតិច ល្មមតែបំព្រំចុះប៉ុណ្ណោះ រមែងជាអព្វោហារិក មិនដល់នូវការរាប់ថាជាសាមបក្ក ។ បើក្នុងប្រេងគ្រាប់ស្ពៃជាដើម ដែលទទួលតាំងទុកក៏និច្ឆ័យដូចពោលហើយ ក្នុងប្រេងល្ងដែលមិនបានទទួលតាំងទុក តែ

www.budinst.gov.kh www.elibraryofcambodia.org

ជាអាចយកលំអិតនៃគ្រាប់ស្ពៃជាដើម ដែលទទួលប្រគេនហើយក្នុង
បុរេភត្តមកធ្វើជាប្រេង ចំអិនដោយកំដៅព្រះអាទិត្យ ប្រេងនោះគួរឆាន់
សូម្បីដោយអាមិសបានក្នុងបុរេភត្ត តែអំពីបច្ឆាភត្តទៅ គួរឆាន់ប្រាស
ចាកអាមិស ក្នុង ៧ ថ្ងៃទៅតាមត្រូវនិស្សគ្គិយ ។ គេចំហុយលំអិតគ្រាប់ស្ពៃ
នឹងស្រស់ជាដើម ឬលីងគ្រាប់ល្ហុងធ្វើជាប្រេងយ៉ាងនោះ ព្រោះហេតុនោះ
ប្រេងនៃរបស់អម្បាលនោះ អនុបសម្បន្នធ្វើ សូម្បីឆាន់ដោយអាមិស
ក្នុងបុរេភត្តក៏គួរ ដែលនឹងមានទោស ព្រោះទទួលទាំងវត្ថុនោះមិនមាន
ព្រោះគ្រាប់ស្ពៃជាដើម ជាយាវជីវិក ។ ភិក្ខុធ្វើឯងគប្បីបរិភោគប្រាស
ចាកអាមិស ប្រេងដែលធ្វើដោយគ្រាប់ស្ពៃជាដើម ដែលជាឧគ្គហិត
មិនគួរនឹងបរិភោគ គួរបរិភោគតែខាងក្រៅ ក្នុង ៧ ថ្ងៃទៅមិនត្រូវអាបត្តិ
ទទួលប្រគេនគ្រាប់ស្ពៃ ស្រស់ ល្ហុង ទុកដើម្បីធ្វើជាប្រេងហើយ ធ្វើឡើង
ជាប្រេងក្នុងថ្ងៃនោះ គួរ ៧ ថ្ងៃ ។ ធ្វើក្នុងថ្ងៃគំរប់ ២ គួរ ៦ ថ្ងៃ ។ ធ្វើក្នុង
ថ្ងៃគំរប់ ៣ គួរ ៥ ថ្ងៃ ។ ធ្វើក្នុងថ្ងៃគំរប់ ៤ គួរ ៤ ថ្ងៃ ។ ធ្វើក្នុងថ្ងៃគំរប់ ៥ គួរ
៣ ថ្ងៃ ។ ធ្វើក្នុងថ្ងៃគំរប់ ៦ គួរ ២ ថ្ងៃ ។ ធ្វើក្នុងថ្ងៃគំរប់ ៧ គួរ ក្នុងថ្ងៃ ១ នោះ ។
បើទុកឱ្យអរុណរះឡើងមក ត្រូវនិស្សគ្គិយ ។ ធ្វើក្នុងថ្ងៃគំរប់ ៨ ជារបស់
មិនគួរនឹងបរិភោគ គួរតែបរិភោគប្រើប្រាស់ខាងក្រៅ ព្រោះមិនមែន
ជានិស្សគ្គិយ ។ បើមិនធ្វើគ្រាប់ស្ពៃជាដើម ដែលទទួលទុកដើម្បីធ្វើជា
ប្រេងនោះ ក្នុង ៧ ថ្ងៃទៅត្រូវទុក្កដ ។ តែប្រេងនៃដូង នឹងនៃស្ពៃ ពង្រ
សង្ស៊ែរ សំរោង ជាដើមដទៃ ដែលមិនមានក្នុងបាលី ទទួលប្រគេនទុកឱ្យ

www.budinst.gov.kh www.elibraryofcambodia.org

ហួសពីថ្ងៃ ត្រូវទុក្កដ ។ នេះឯងជាសេចក្តីថ្លែកត្តាក្នុងប្រេងទាំងអម្បាលនេះ គប្បីកំណត់ប្រេងក្រៅនោះ ដែលមានវត្ថុជាយាវកាលិក ឬមានវត្ថុជាយាវជីវិក ហើយគប្បីដឹងដោយវិធីទាំងពួង គឺសាមបក្ក នឹងទទួលទាំងវត្ថុ ទទួលក្នុងវេលាព្រឹក ឬល្ងាច ឬមានវត្ថុជាឧគ្គហិត ដោយន័យដូចពោលហើយនោះចុះ ។ ខ្លាញ់នៃកន្សោមសត្វ ដែលព្រះអង្គទ្រង់អនុញ្ញាតទុក ៥ យ៉ាង គឺកន្សោមខ្លាញ់ខ្លាឃ្មុំ កន្សោមខ្លាញ់ត្រី កន្សោមខ្លាញ់ឆ្លាម កន្សោមខ្លាញ់ជ្រូក កន្សោមខ្លាញ់លា ដ្បិតទ្រង់អនុញ្ញាតកន្សោមខ្លាញ់ខ្លាឃ្មុំ នឹងកន្សោមខ្លាញ់នៃសត្វមានសាច់ជាអកប្បិយទាំងពួងនោះព្រះអង្គទ្រង់អនុញ្ញាតផង វៀរតែកន្សោមខ្លាញ់មនុស្សមួយចំពូក ។ ដ្បិតកាន់យកត្រីទៀងពោល សូម្បីឆ្លាមក៏ជាសេចក្តីកាន់យកទៀងពោលផង ព្រោះរាប់បញ្ចូលក្នុងពួកត្រី តែព្រះអង្គទ្រង់ពោលថាឆ្លាមថ្លែកចេញទៅ ព្រោះជាត្រីកំណាច ដ្បិតកាន់យកត្រីជាដើមទៀងពោល ខ្លាញ់នៃសត្វមានសាច់ជាកប្បិយទាំងពួង ឈ្មោះថាទ្រង់អនុញ្ញាតផង ដ្បិតថាក្នុងសាច់សត្វទាំងឡាយ សាច់នៃមនុស្ស នឹងដំរី សេះ ឆ្កែ ពស់ រាជសីហ៍ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ខ្លារខិន ១០ នេះជាអកប្បិយ ។ ចំណែកក្នុងខ្លាញ់ ខ្លាញ់នៃមនុស្សមួយចំពូកជាអកប្បិយ ។ ចំណែកក្នុងទឹកដោះស្រស់ជាដើមវត្ថុដែលជាអកប្បិយមិនមាន ។ ប្រេងនៃខ្លាញ់ដែលអនុបសម្បន្នធ្វើហើយត្រូវទទួលប្រគេនក្នុងវេលាព្រឹក គួរឆាន់សូម្បីដោយអាមិសក្នុងវេលាព្រឹកបាន តែសៀលទៅហើយ គួរឆាន់ប្រាសចាកអាមិសសម្ភិន

www.budinst.gov.kh www.elibraryofcambodia.org

បាន ៧ ថ្ងៃ ។ គឺឯសាច់សរសៃខ្លាញ់ឈាមឯណាដែលល្អិតដូចធូលីដីល្អិត មានក្នុងប្រេងនោះ របស់អម្បាលនោះ គឺជាអព្វោហារិក ថាបើទទួលប្រគេនខ្លាញ់ធ្វើដោយខ្លួនឯង ទទួលហើយចំរាញ់ ហើយត្រងឲ្យស្រេចក្នុងវេលាព្រឹកនោះ គប្បីបរិភោគប្រាសចាកអាមិសបាន ៧ ថ្ងៃ ព្រោះព្រះអង្គទ្រង់អនុញ្ញាតចំពោះខ្លាញ់ឲ្យជាភេសជ្ជៈ ។ រឿងដែលព្រះអង្គទ្រង់អនុញ្ញាតឲ្យទទួលខ្លាញ់ក្នុងកាល ចំរាញ់ក្នុងកាល ត្រងក្នុងកាល បរិភោគប្រេងនោះ អាស្រ័យបរិភោគប្រាសចាកអាមិស សូម្បីក្នុងប្រេងនោះមានសាច់ជាដើមដ៏ល្អិតជាអព្វោហារិកពិត តែទីនទទួល ឬចំរាញ់ក្នុងបច្ឆាភត្តមិនគួរឡើយ ។ ដ្បិតទ្រង់ហាមឃាត់ទុកថា វិកាលេ ចេ ភិក្ខវេ បដិគ្គហិតំ ។ល។ អាបត្តិ តិណ្ណំ ទុក្កដានំ ម្នាលភិក្ខុទាំងឡាយ បើទទួលខ្លាញ់ក្នុងវិកាល ចំរាញ់ក្នុងវិកាល ត្រងក្នុងវិកាលបរិភោគត្រូវអាបត្តិទុក្កដ ៣ ។ បើទទួលក្នុងកាល ចំរាញ់ក្នុងវិកាល ត្រងក្នុងវិកាល បរិភោគត្រូវអាបត្តិទុក្កដ ២ ។ ទទួលក្នុងកាល ចំរាញ់ក្នុងកាល ត្រងក្នុងវិកាល បរិភោគត្រូវអាបត្តិទុក្កដ ១ ។ បើទទួល ចំរាញ់ ត្រងក្នុងកាល បរិភោគមិនត្រូវអាបត្តិ ។ សប្បិ នវនីត លាយគ្នា ចំរាញ់ត្រងជាមួយគ្នា មានតេជៈសង្កត់សង្កិនកេតបាន គួរ ។ សូម្បីខ្លាញ់នៃខ្លាឃ្មុំ ខឹងខ្លាញ់ជ្រូកដាក់ចុះក្នុងបបរ ដែលលាយដោយឫសឈើ ខឹងទឹកអម្ពត់ ជាទមានតេជៈក្លា អាចសង្កត់កេតខ្យល់បាន ក៏គួរ ។ ខឹងពោលក្នុងទឹកឃ្មុំ ទឹកឃ្មុំដែលមេឃ្មុំធំ តូចក៏ធ្វើ ទើបឈ្មោះថាមធុ

www.budinst.gov.kh www.elibraryofcambodia.org

•ទឹកឃ្មុំនោះទទួលប្រគេនក្នុងកាល គួរឆាន់ជាមួយអាមិសបានក្នុងកាល តែរសៀលទៅហើយ គួរឆាន់ប្រាសចាកអាមិសបាន ៧ ថ្ងៃ កន្លង ៧ ថ្ងៃទៅ បើជាទឹកឃ្មុំនៃឃ្មុំធំស្អិតដូចជាជ័រឈើធ្វើជាដុំ ៗ ដំកល់ទុក ឬទឹកឃ្មុំរាវដាក់នៅក្នុងភាជនៈផ្សេង ៗ ត្រូវនិស្សគ្គិយ រាប់តាមវត្ថុ ៗ បើជាដុំតែមួយប៉ុណ្ណោះ ឬរាវនៅក្នុងភាជនៈតែមួយ ត្រូវនិស្សគ្គិយ តែមួយប៉ុណ្ណោះ ។ ទឹកឃ្មុំជាឧគ្គហិត គប្បីដឹងដោយន័យដូចពោលហើយនោះចុះ ។ គប្បីបង្អោនចូលទៅក្នុងកិច្ចមានលាបដំបៅជាដើម សំណុកឃ្មុំ ឬក្រមួនមិនបានប្រឡាក់ដោយទឹកឃ្មុំ ដ៏បរិសុទ្ធជាយាវជីវិក បើប្រឡាក់ដោយទឹកឃ្មុំក៏ជាគតិនៃទឹកឃ្មុំពិត ។ ឃ្មុំវែងមានស្លាបម្យ៉ាងឈ្មោះបិរិកៈ ខ្លួនធំពណ៌ខ្មៅម្យ៉ាងមានឆ្អឹងជាស្លាប ឈ្មោះតុម្ពលៈ ក្នុងទីលំនៅនៃសត្វទាំងអម្បាលនោះ មានទឹកផ្អែមស្អិតដូចជ័រឈើ ទឹកផ្អែមនោះជាយាវជីវិក ។

ចំណែកពណ៌នាក្នុងផាណិត ផាណិតកើតអំពីអំពៅតាំងអំពីទឹកអំពៅឆៅទៅ ឬឆ្អិនមិនបានលាយដោយកាក ទឹកអំពៅគេធ្វើវិសេសទាំងពួងមិនលាយដោយកាក គប្បីដឹងថាជាផាណិតចុះ ទឹកអំពៅនោះទទួលប្រគេនក្នុងកាល គួរឆាន់សូម្បីដោយអាមិសបានក្នុងកាល តែរសៀលទៅគួរឆាន់ប្រាសចាកអាមិសបាន ៧ ថ្ងៃ កន្លង ៧ ថ្ងៃទៅ ត្រូវនិស្សគ្គិយរាប់តាមវត្ថុ ៗ ដុំស្ករអំពៅ សូម្បីច្រើន គេកិនល្អិតដាក់ក្នុងភាជនៈតែមួយ ណែនបង្អៀតគ្នា ត្រូវនិស្សគ្គិយតែមួយប៉ុណ្ណោះ ។ ទឹកអំពៅជាឧគ្គហិត គប្បីដឹងដូចន័យដែលបានពោលហើយនោះ គប្បីបង្អោនចូលទៅក្នុងកិច្ចមាន

www.budinst.gov.kh www.elibraryofcambodia.org

លាមកុជជាដើម ។ ស្ករអំពៅផែនធ្វើដោយទឹកអំពៅមិនទាន់បានគ្រាន ទទួលប្រគេនក្នុងកាល បើអនុបសម្បន្នធ្វើ សូម្បីទាន់ប្រកបដោយអាមិស គួរ បើធ្វើខ្លួនឯងនឹងទាន់ប្រាសចាកអាមិសតែម្យ៉ាងគួរ រសៀលទៅហើយជា របស់មិនគួរបរិភោគ ព្រោះទទួលតាំងពីវេក សូម្បីក្នុង ៧ ថ្ងៃទៅមិនត្រូវ អាបត្តិ ។ ស្ករអំពៅផែនគេធ្វើដោយទឹកអំពៅឆៅ តែទៅមិនទាន់បានគ្រាន ទទួលប្រគេនក្នុងវិកាលជារបស់មិនគួរបរិភោគឡើយ សូម្បីក្នុង៧ថ្ងៃទៅ ក៏មិនត្រូវអាបត្តិ ។ សូម្បីក្នុងផាណិត ទទួលប្រគេនដើមអំពៅមកធ្វើក៏ដូច គ្នាយ៉ាងនោះ ផាណិតដែលធ្វើដោយទឹកអំពៅឆៅគ្រន់ហើយ ទទួលប្រគេនក្នុងកាល បើអនុបសម្បន្នធ្វើ សូម្បីទាន់ប្រកបដោយអាមិសក្នុងកាលក៏ គួរ តែរសៀលទៅហើយ គួរទាន់ប្រាសចាកអាមិស បាន៧ថ្ងៃ ធ្វើខ្លួនឯង សូម្បីក្នុងកាល ទាន់ប្រាសចាកអាមិសតែម្យ៉ាងក៏គួរ បើវិកាលទៅហើយ គួរទាន់ប្រាសចាកអាមិសបាន ៧ ថ្ងៃ ឯផាណិតធ្វើដោយទឹកអំពៅស្រស់ ដែលគ្រន់ហើយ ទទួលប្រគេនក្នុងវិកាល ទាន់ប្រាសចាកអាមិសបាន៧ ថ្ងៃ ផាណិតជាទក្តហិតមានន័យដូចពោលមកហើយនោះឯង ។ ក្នុងមហា- អដ្ឋកថាពោលថា ផាណិតធ្វើដោយអំពៅដុត ឬធ្វើដោយអំពៅជាំម្ចាស់ គួរក្នុងកាល តែក្នុងមហាបច្ចរី សួរថា ផាណិតចំអិនតាំងវេកគួរឬមិនគួរ ? ឆ្លើយថា ផាណិតធ្វើដោយទឹកអំពៅ ដែលមិនពោលថាមិនគួរក្នុងវិកាល នោះ មិនមាន ដូច្នេះពាក្យនេះគួរ ។ ផាណិតផ្កាស្រស់ ធ្វើដោយទឹក ត្រជាក់ សូម្បីទាន់លាយដោយអាមិសក្នុងកាលក៏គួរ តែរសៀលទៅហើយ

www.budinst.gov.kh www.elibraryofcambodia.org

គួរឆាន់ប្រាសចាកអាមិសបាន ៧ ថ្ងៃ កន្លងពី ៧ ថ្ងៃទៅត្រូវទុក្កដ រាប់ដោយថ្ងៃ ៗ តែផាណិតផ្កាស្រត់គេលាយទឹកដោះស្រស់ចុះផង ជាយាវកាលិក តែខណ្ឌសក្ករៈគឺស្ករជុំ ស្ករគ្រួស គេយកទឹកដោះស្រស់ចេញហើយ ធ្វើឲ្យបរិសុទ្ធ ព្រោះហេតុនោះ ខណ្ឌសក្ករៈនោះទើបគួរក្នុងវេលាវិកាល តែផ្កាស្រត់ស្រស់ឬគេលីងហើយ លុះលីងហើយចុកលាយដោយរបស់ដទៃ ឬមិនលាយក្តីក៏គួរក្នុងកាល ៗ ថាបើគេកាន់យកផ្កាស្រត់នោះផ្សំដើម្បីជាមេរ័យ គេផ្សំហើយតាំងអំពីពូជទៅ មិនគួរ ៗ ផាណិតនៃផ្លែឈើជាយាវកាលិកតាំងពីពួន មានផ្លែបេក ផ្លែលមើ ផ្លែស្វាយ ផ្លែសាគេ ផ្លែខ្នុរ អំពិល ជាយាវកាលិកពិត ៗ ផងតាំងឡាយគេធ្វើផាណិតដោយម្ទេសទំ ផាណិតគឺម្ទេសផែននោះជាយាវជីវិក ៗ

មួយទៀត ស្ករតាំងស៊ិន ស្ករស ស្ករក្រហម ស្ករផែន សក្គ្រោះក្នុងផាណិត ថ្នាំ ៥ យ៉ាងនោះ ទទួលប្រគេនហើយមិនឲ្យកន្លង ៧ ថ្ងៃទៅ សូម្បីមានធម៌ឬមិនមានធម៌ក្តី គប្បីឆាន់តាមស្រួលចុះ ផ្សិតរបស់ដែលព្រះអង្គទ្រង់អនុញ្ញាតចំពោះមាន ៧ ប្រការគឺ ចំពោះព្យាធិ ១ ចំពោះបុគ្គល ១ ចំពោះកាល ១ ចំពោះសម័យ ១ ចំពោះប្រទេស ១ ចំពោះកន្សោមខ្ញាញ់ ១ ចំពោះថ្នាំ ១ ៗ អនុញ្ញាតចំពោះព្យាធិនោះ ដូចទ្រង់អនុញ្ញាតឲ្យភិក្ខុដែលខ្មោចចូលឆាន់សាច់ស្រស់ ឈាមស្រស់ក៏បាន សាច់ស្រស់ឈាមស្រស់នោះ គួរដល់ភិក្ខុដែលមានអាពាធដូច្នោះ តែមួយចំណែកប៉ុណ្ណោះ មិនគួរដល់ភិក្ខុដទៃ ៗ សាច់ឈាមនោះជាកប្បិយ ឬជា

www.budinst.gov.kh www.elibraryofcambodia.org

អកប្បិយ គួរដល់ភិក្ខុអាពាធនោះតាំងពីព្រឹកតាំងល្ងាច ។ អនុញ្ញាតចំពោះបុគ្គលនោះ ដូចទ្រង់អនុញ្ញាតអាហារដែលគេរើចេញដល់បំពង់ក ហើយត្រឡប់ចូលទៅវិញ មិនត្រូវអាបត្តិ ដល់ភិក្ខុអ្នកធ្លាប់គេរើ អនុញ្ញាតនោះគួរដល់ភិក្ខុអ្នកធ្លាប់គេរើតែមួយចំពូក មិនគួរដល់ភិក្ខុដទៃ តែរើចេញមកដល់ក្រៅមាត់ហើយ កុំត្រឡប់លេបចូលទៅ ។ អនុញ្ញាតចំពោះកាលនោះ ដូចទ្រង់អនុញ្ញាតថ្នាំមហាវិកដ ៤ គឺ លាមក មូត្រ ផេះ ដី ចំពោះក្នុងកាលភិក្ខុពស់ចឹកប៉ុណ្ណោះ សូម្បីមិនបានទទួលប្រគេន ឆាន់ក៏គួរ ក្នុងកាលដទៃមិនគួរ ។ អនុញ្ញាតចំពោះសម័យនោះ ដូចអនុញ្ញាតមិនឲ្យត្រូវអាបត្តិ ព្រោះឆាន់គណភោជន ក្នុងសម័យអាពាធជាដើម មិនត្រូវអាបត្តិ តែក្នុងសម័យដូច្នោះមួយចំពូក ក្នុងសម័យដទៃត្រូវអាបត្តិ ។ អនុញ្ញាតចំពោះប្រទេសនោះ ដូចទ្រង់អនុញ្ញាតការឧបសម្បទាដោយគណៈសង្ឃ មានវិនយធរជាគំរប់ ៥ ជាដើម ក្នុងបច្ចន្តប្រទេសប៉ុណ្ណោះ ក្នុងមជ្ឈិមប្រទេសមិនគួរ ។ អនុញ្ញាតចំពោះកន្ទ្រោមខ្លាញ់នោះ ដូចទ្រង់អនុញ្ញាតខ្លាញ់ ៥ ប្រការ ដើម្បីឲ្យជាថ្នាំ ដោយឈ្មោះនៃកន្ទ្រោមខ្លាញ់ កន្ទ្រោមខ្លាញ់នោះ ទទួលចំអិនត្រងក្នុងកាល ឆាន់បានតែខ្លាញ់ករ ។ ដែលទ្រង់អនុញ្ញាតនោះ គួរតែភិក្ខុដែលត្រូវការដោយខ្លាញ់ករ យកខ្លាញ់នៃសត្វមានសាច់ជាកប្បិយ ឬអកប្បិយតាំងពួង វៀរតែខ្លាញ់នៃមនុស្សចេញ ឆ្អិនក្រៅអំពីនោះ មកធ្វើជាខ្លាញ់ឆាន់បាន ។ អនុញ្ញាតចំពោះថ្នាំនោះ ទ្រង់អនុញ្ញាត សប្បិ នវនីត ប្រេង

www.budinst.gov.kh www.elibraryofcambodia.org

ទឹកឃ្មុំ ទឹកអំពៅ សម្រាប់សម្រេចអាហារកិច្ចបាន គឺទ្រង់អនុញ្ញាតដោយឈ្មោះថាជាភេសជ្ជៈ ថ្នាំនោះទទួលប្រគេនហើយ គប្បីឆាន់តាមគាប់ចិត្តចុះ ក្នុងវេលាព្រឹកថ្ងៃនោះ តែរសៀលទៅ កាលបើមានហេតុគប្បីឆាន់បាន ៧ ថ្ងៃ តែស្ករអំពៅ ស្ករតាំងស៊ិន ស្ករស ស្ករក្អម ដែលរឹងខាប់ ថាបើមានអាពាធ គប្បីទំពារបរិភោគបាន មិនមានអាពាធមិនគួរបរិភោគ គប្បីលាយដោយទឹកឆាន់ ។ ដ្បិតទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ គិលានស្ស គុឡំ អគិលានស្ស គុឡោទកំ ដូច្នេះ ។ ថ្នាំ ៥ ប្រការនេះ បើមិនឆាន់ នឹងទុកបរិភោគខាងក្រៅ មានលាបសរិរ នឹងអុចប្រទីបជាដើម គប្បីអធិដ្ឋានថានឹងទុកបរិភោគខាងក្រៅ ក្នុង ៧ ថ្ងៃ បើនឹងយកប្រេងដែលអធិដ្ឋាននោះ ដាក់ក្នុងភាជនៈប្រេងដែលមិនទាន់អធិដ្ឋាន បើក្នុងភាជនៈប្រហោងតូចល្អិត ប្រេងថ្មីជ្រាបហូរចូលទៅ ប្រេងចាស់សង្កត់លិចបាន គប្បីអធិដ្ឋានជាថ្មី បើប្រហោងមាត់ធំ ប្រេងច្រើនចូលទៅឆាប់សង្កត់ប្រេងចាស់បាន កិច្ចដែលនឹងត្រូវអធិដ្ឋានទៀតមិនមាន ព្រោះថាប្រេងថ្មីក៏ជារបស់មានគតិនៃប្រេងដែលអធិដ្ឋានហើយ សម្រាប់តាក់ប្រេងដែលមិនបានអធិដ្ឋានចុះក្នុងភាជនៈប្រេងដែលបានអធិដ្ឋានហើយ ក៏គប្បីដឹងដោយន័យនោះចុះ ។

មួយទៀត ថ្នាំ ៥ ប្រការនេះ ដែលទទួលប្រគេនទុកហើយ បើឆាន់ពុំអស់ គប្បីលះចេញក្នុង ៧ ថ្ងៃ បើជារបស់មានម្ចាស់ពីរនាក់ ម្នាក់ទទួលប្រគេនទុកនោះមិនទាន់បានចែកគ្នា កន្លង ៧ ថ្ងៃទៅ មិនត្រូវអាបត្តិផងគ្នា

www.budinst.gov.kh www.elibraryofcambodia.org

ទាំងពីរនាក់ ប៉ុន្តែទឹកដាច់មិនគួរ សូម្បីអ្នកទទួលប្រគេនប្រាប់អ្នកដទៃឲ្យដាច់ អ្នកនោះមិនដាច់ កន្លង ៧ ថ្ងៃទៅ ក៏មិនត្រូវអាបត្តិដល់ភិក្ខុទាំងពីរនាក់ ព្រោះអ្នកទទួលគិលានៈទៅហើយ អ្នកម្ចាស់នោះ ក៏ពុំបានទទួលៗ

សត្តាហកាលិក ចប់

---

## កាលិកសំសគ្គកថា

ទីនេះពោលក្នុងកាលិកសំសគ្គកថាទាំង ៤ ដែលលាយច្រឡំគ្នាដោយបាលីថា យាវកាលិកេន ភិក្ខវេ យាមកាលិកំ តទហុបដិគ្គហិតំ ។ល។ សត្តាហាតិក្កន្តេ ន កប្បតិ ម្នាលភិក្ខុទាំងឡាយ យាមកាលិក សត្តាហកាលិក យាវជីវិក ទាំង ៣ នេះ វត្ថុណាមួយ ទទួលប្រគេនទុកក្នុងថ្ងៃនោះជាមួយគ្នា នឹងយាវកាលិក ហើយនឹងគួរតែក្នុងកាល មិនគួរក្នុងវិកាល ។ សត្តាហកាលិក យាវជីវិកទាំងពីរនេះ វត្ថុណាមួយ ទទួលប្រគេនក្នុងថ្ងៃនោះ ជាមួយគ្នាដោយយាមកាលិក គួរតែក្នុងយាម គឺថ្ងៃ ១ យប់ ១ កន្លងយាមទៅ គឺដល់អរុណរះឡើងមក មិនគួរ ។ យាវជីវិកទទួលប្រគេនជាមួយនឹងសត្តាហកាលិក គួរ ៧ ថ្ងៃ កន្លង ៧ ថ្ងៃទៅមិនគួរ ។ ក្នុងអដ្ឋកថា ថាពាក្យទាំងពួងក្នុងបាលីនោះ អាស្រ័យយកកាលិកទាំងអម្បាលនោះ ដែលមានរសលាយចូលគ្នា ពោលដោយសេចក្ដីថា បើទឹកអដ្ឋបាន លាយនឹងផ្លែដូងទាំងផ្លែ មិនបានយកសំបកចេញ ទទួលប្រគេនជាមួយគ្នា ហើយយកផ្លែដូងចេញ ទឹកអដ្ឋបាននោះ សូម្បីក្នុងវិកាលក៏គួរ ។ តាយកទាំង

www.budinst.gov.kh www.elibraryofcambodia.org

ឲ្យគេដាក់ជុំសប្បិលើបាយបាយាសដែលគេដាក់ប្រគេន សប្បិណា ដែលមិនប្រឡំដោយបាយបាយាស សប្បិនោះ នឹងយកចេញ ទុកឆាន់ បាន ៧ ថ្ងៃគួរ សូម្បីក្នុងទឹកឃ្មុំដែលស្អិតនឹងស្ករអំពៅ ដាក់លើបាយបាយាសក៏ដូចគ្នាដូច្នោះ ទាយកគេយកក្រវាញនឹងផ្លែចន្ទន៍ជាដើម ប្រដាប់តាក់តែងបិណ្ឌបាតមកថ្វាយ គប្បីលើកយកក្រវាញ នឹងផ្លែនៃចន្ទន៍ នោះឡើងមកលាងចេញ ទុកឆាន់ដរាបលុះត្រាតែអស់ជីវិត ។ សូម្បីគេយកខ្ញីជាដើមដាក់ចុះក្នុងយាគូ គឺបបរ ប្រគេន នឹងយកឈើឯមជាដើមដាក់ចុះក្នុងវត្ថុទាំងឡាយមានប្រេងជាដើម ក៏ដូចជាន័យនោះ ។ កាលិកណា ៗ ដែលមានរសមិនលាយចូលគ្នា កាលិកនោះ ៗ សូម្បីទទួលប្រគេនជាមួយគ្នា នឹងបរិសុទ្ធិដោយប្រការដូចម្តេច លាងឬចិតចោលដោយប្រការដូច្នោះ ហើយបរិភោគតាមកាលកំណត់នៃកាលិកនោះៗក៏គួរ ថាបើមានរសលាយប្រឡំចូលគ្នាមិនគួរ ។ ដ្បិតថា យាវកាលិករមែងទាញកាលិកទាំង ៣ មានយាមកាលិកជាដើម ដែលមានរសលាយប្រឡំគ្នានឹងខ្លួន ចូលទៅកាន់សភាវៈសេចក្តីកើតឯងនៃខ្លួន ឲ្យជាយាវកាលិកទៅ ។ សូម្បីយាមកាលិកក៏ទាញកាលិកទាំង ២ មានសត្តាហកាលិកជាដើម ចូលទៅកាន់សភាវៈសេចក្តីកើតឯងនៃខ្លួន ឲ្យជាយាមកាលិកទៅ សូម្បីសត្តាហកាលិកក៏រមែងទាញយាវជីវិក ដែលប្រឡំនឹងខ្លួន ចូលទៅកាន់សភាវៈសេចក្តីកើតឯងនៃខ្លួន ឲ្យជាសត្តាហកាលិកទៅ ។ ព្រោះហេតុនោះ យាវជីវិក ដែលភិក្ខុទទួលប្រគេនក្នុងថ្ងៃនោះ ឬទទួលប្រគេនក្នុងថ្ងៃមុន លាយគ្នាដោយ

www.budinst.gov.kh www.elibraryofcambodia.org

សត្តាហកាលិក ដែលទទួលប្រគេនក្នុងថ្ងៃនោះ រមែងគួរ ក្នុងរវាង ៧ ថ្ងៃ ៗ យាវជីវិកនោះ លាយគ្នាដោយសត្តាហកាលិក ដែលទទួលប្រគេនហើយ២ថ្ងៃ រមែងគួរ ក្នុងរវាង ៦ ថ្ងៃ ៗ លាយដោយសត្តាហកាលិក ដែលទទួលប្រគេនហើយ ៣ ថ្ងៃ រមែងគួរ តែក្នុងរវាង ៤ ថ្ងៃ ៗ លាយគ្នាដោយសត្តាហកាលិក ដែលទទួលប្រគេនហើយ ៧ ថ្ងៃ គប្បីដឹងថាគួរក្នុងថ្ងៃ ១ នោះចុះ ៗ ព្រោះហេតុនោះ ទើបក្នុងបាលីព្រះអង្គមិនពោលថា យាវជីវិក ទទួលប្រគេនក្នុងថ្ងៃនោះ ជាមួយគ្នានឹងសត្តាហកាលិក នឹងពោលតែត្រឹមថាទទួលប្រគេនជាមួយសត្តាហកាលិក · រមែងគួរ ក្នុងរវាង ៧ ថ្ងៃប៉ុណ្ណោះ ថាបើកាលិកនោះ ៗ កន្លងកាល នឹងយាម នឹង ៧ ថ្ងៃទៅ គប្បីដឹងថាត្រូវអាបត្តិដោយវិកាលភោជនសិក្ខាបទ នឹងសន្និធិការក-សិក្ខាបទនោះចុះ ៗ ក៏ឯកាលិកទាំង ៤ នេះ យាវកាលិក យាមកាលិក ទាំង ២ នេះ ជាអន្តោវុត្ថបានផង ជាសន្និធិបានផង ៗ តែសត្តាហកាលិក នឹងយាវជីវិក សូម្បីនឹងទុកដាក់ក្នុងអកប្បិយកុដិក៏គួរ មិនឲ្យកើតសន្និធិបានផង ៗ

កាលិកសំសន្ទកថា ចប់

---

នឹងពណ៌នាក្នុងអន្តោវុត្ថ ៗ យាវកាលិក យាមកាលិក ២ នេះ ទុកក្នុងអកប្បិយកុដិ ឈ្មោះថាអន្តោវុត្ថ ៗ ដណ្តាំ ស្ល ឲ្យឆ្អិនក្នុងអកប្បិយកុដិនោះ ឈ្មោះថាអន្តោបក្កៈ ៗ ភិក្ខុដណ្តាំស្លឲ្យឆ្អិនឯងឈ្មោះថាសាមបក្កៈ ៗ ទាំង៣យ៉ាងនេះ ធាត់ត្រូវទុកដ ៣ បើធាត់តែ ២ យ៉ាង ត្រូវទុកដ ២ បើធាត់

តែ១ យ៉ាងត្រូវទុកជា១ ដូចទ្រង់ហាមឃាត់ទុកថា ន ភិក្ខវេ អន្តោ វុត្ថំ អន្តោ បក្កំ សាមំ បក្កំ បរិភុញ្ជិតព្វំ ។ ល ។ អន្តោ ចេ ភិក្ខវេ វុត្ថំ អន្តោ បក្កំ សាមំ បក្កំ តញ្ចេ បរិភុញ្ជេយ្យ អាបត្តិ តិណ្ណំ ទុក្កដានំ ។ ល ។ ពហិ ចេ ភិក្ខវេ វុត្ថំ ។ ល ។ អនាបត្តិ ដូច្នេះ ។ ភិក្ខុនឹងដណ្តាំស្ងោរនូវអាមិសវត្ថុណាមួយមិនគួរ នឹងដណ្តាំស្ងក់ដៅនូវរបស់ដែលឆ្អិនហើយទើបគួរ ។ បើទាយកគេដាក់ស្លឹកម្រះព្រៅម្ទេសអំបិលចុះក្នុងបបរក្តៅ ឲ្យដល់ភិក្ខុលោក សូម្បីភិក្ខុនឹងកូរបបរនោះដើម្បីឲ្យឆ្អិនមិនគួរ តែនឹងកូរដោយគិតថានឹងឲ្យបបរត្រជាក់ក៏គួរ ។ សូម្បីបានបាយជាពនបន្លយមកនឹងគ្របទុកឲ្យឆ្អិនមិនគួរ ថាបើទាយកគេគ្របប្រគេន នឹងគ្របដោយគិតថា មិនឲ្យបាយត្រជាក់ក៏គួរ តែទឹកដោះស្រស់នឹងប្រេងជាដើម កាលពុះលោកឡើងម្តងហើយ នឹងដុតភ្លើងក៏គួរ ព្រោះរបស់ឆ្អិនស្រាប់ហើយនឹងឲ្យឆ្អិនទៀតក៏គួរ ។ ដូចព្រះអង្គទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ បុនបាកំ បចិតុំ ដូច្នេះ ។

## កប្បិយភូមិកថា

លំដាប់នេះនឹងបានសំដែងក្នុងរឿងកប្បិយភូមិ ដែលជាទីធ្វើអាមិសឲ្យរួចចាកអន្តោវុត្ថៈ អន្តោបក្កៈ តទៅ ។ ព្រះអង្គទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ ចតស្សោ កប្បិយភូមិយោ

www.budinst.gov.kh www.elibraryofcambodia.org

ឧស្សាវនន្តិកំ គោនិសាទិកំ គហបតិកំ សម្មុតិកំ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត នូវកប្បិយភូមិ ៤ យ៉ាង គឺ ឧស្សាវនន្តិកា ទីដែលឲ្យបានឮឡើងថា កប្បិយកុដិជាទីបំផុត ១ គោនិសាទិកា ទីដែលជាទីអាស្រ័យនៃគោ ១ គហបតិកា ទីជារបស់គហបតី ១ សម្មុតិកា ទីគឺសង្ឃសម្មតិ ១ ។ នឹងពោលកន្លងឧស្សាវនន្តិកានេះជាមុន គប្បីធ្វើដូច្នេះ កុដិណា នឹងធ្វើលើសសរទាំងឡាយ ឬនឹងកប់ជើងជញ្ជាំងចុះទៅ សិលាសំរាប់ទ្រជើងសសរខាងក្រោមនៃកុដិនោះ ជាគតិនៃផ្លូវនៃចរណវិមនពិត តែកាលនឹងដំកល់សសរជាដំបូង ឬជើងជញ្ជាំងជាដំបូង ភិក្ខុទាំងអំពី ៣ អង្គ ឬ ៤ អង្គឡើងទៅ កាលឈរព័ទ្ធជុំវិញសសរ បញ្ចេញវាចាថា កប្បិយ-កុដឹ ករោម ដូច្នេះ ៣ ដង ឬនឹងថាតែ កប្បិយកុដឹ ៗ ប៉ុណ្ណោះក៏បាន កាលមនុស្សទាំងឡាយគេលើកឡើង នឹងឲ្យសសរនឹងជើងជញ្ជាំងដំកល់ចុះ គប្បីពោលត្រូវ ឬលើកដោយខ្លួនឯងនូវសសរនឹងជើងជញ្ជាំងហើយដំកល់ចុះ ។ តែក្នុងកុរុន្ទីនិងមហាបច្ចរី ពោលថា ឲ្យភិក្ខុទាំងឡាយគប្បីពោលថា កប្បិយកុដឹ ៗ ដូច្នេះ ហើយដំកល់ចុះ ។ ក្នុងអដ្ឋកថាថា ឲ្យភិក្ខុទាំងឡាយគប្បីពោលថា សង្ឃស្ស កប្បិយ-កុដឹ អធិដ្ឋាម ដូច្នេះ ។ សូម្បីនឹងមិនពោលនូវពាក្យនោះ នឹងពោលតាមន័យដូចសំដែងហើយ ក៏ក្នុងអដ្ឋកថាទាំងឡាយក៏មិនមានទោស តែន័យនេះជាលក្ខណៈទូទៅ ។ ក្នុងអដ្ឋកថាទាំងឡាយនោះ ជាគឺដំកល់

www.budinst.gov.kh www.elibraryofcambodia.org

សសរចុះដល់ផែនដី នឹងចប់ពាក្យដែលពោលព្រមជាមួយគ្នាទើបគួរ ។ ដ្បិតថាកាលបើពាក្យមិនទាន់ចប់ សសរដល់ផែនដីមុន ឬសសរមិនទាន់ដល់ផែនដី ពាក្យពោលចប់មុន ក៏មិនឈ្មោះថាធ្វើកប្បិយកុដិ ។ ព្រោះហេតុនោះ ក្នុងមហាបច្ចរី ទើបពោលថា ឲ្យភិក្ខុច្រើនអង្គគប្បីឈរព័ទ្ធជុំវិញពោលចុះ ដ្បិតថាក្នុងភិក្ខុទាំងអម្បាលនោះ ការចប់ពាក្យជាមួយនឹងដំកល់សសរចុះដល់ផែនដី គង់មានព្រមគ្នា ដោយពាក្យនៃភិក្ខុមួយអង្គដោយពិត ។ តែក្នុងកុដិមានជញ្ជាំងធ្វើដោយឥដ្ឋ ឬសិលា ឬដីក្តី នឹងធ្វើកឡៀង ឬមិនកឡៀងក្តី ប្រាថ្នានឹងបណ្តុះជញ្ជាំងឡើងអំពីឥដ្ឋ នឹងសិលា នឹងដុំដីណា គប្បីកាន់យកឥដ្ឋ ឬសិលា ឬដុំដីទាំងពួងនោះ ជាដំបូងជាសំគាល់ហើយ ទើបធ្វើកប្បិយកុដិ ដោយន័យដូចពោលមកហើយនោះចុះ ដ្បិតថាឥដ្ឋនឹងសិលានឹងដុំដី ដែលនៅខាងក្រោមនៃឥដ្ឋនឹងសិលានឹងដុំដី ដែលគជាជញ្ជាំងដំបូងនោះ នឹងធ្វើឲ្យជាសំគាល់មិនគួរ ព្រោះជាជារបស់លិចនៅក្នុងដី អំពីសសរដែលដំកល់ចុះខ្ពស់ឡើងមកលើដី ។ ព្រោះហេតុនោះ នឹងតាំងសសរនោះបញ្ចេញពាក្យថា កប្បិយកុដិករោម ទើបគួរ ។ ក្នុងអន្ធកដ្ឋកថា ពោលថាកុដិកាលនឹងធ្វើដោយសសរទាំងឡាយ គប្បីអធិដ្ឋានសសរទាំង ៤ ដើម ក្នុងមុមទាំង ៤ កាលនឹងធ្វើដោយឥដ្ឋជាដើម គប្បីអធិដ្ឋានឥដ្ឋ ២ ដុំ ឬ ៣ ដុំ ក្នុងមុមទាំង ៤ សូម្បីមិនធ្វើដូច្នោះក៏មិនមានទោស ។ ដ្បិតថាពាក្យដែលពោលក្នុងអដ្ឋកថាទាំងឡាយនោះជាប្រមាណ ។ នឹងពោលក្នុង គោធិ-

www.budinst.gov.kh www.elibraryofcambodia.org

**សាធិកា** កប្បិយកុដិឈ្មោះថាគោនិសាទិកា មាន ២ យ៉ាង គឺ
អារាមគោធិសាធិកា១ វិហារគោធិសាធិកា១ ។ អារាមក្នុង
ទីណាដែលគេមិនបានព័ទ្ធព័ទ្ធ សេនាសនៈគឺកុដិក៏មិនបានព័ទ្ធព័ទ្ធ ដូច្នេះ
ឈ្មោះថា អារាមគោនិសាទិកា ។ ក្នុងទីណាសេនាសនៈទាំងអស់ក្តី
មួយដំបន់ក្តី ដែលគេព័ទ្ធព័ទ្ធ តែអារាមគេមិនបានព័ទ្ធព័ទ្ធ ដូច្នេះ ឈ្មោះថា
វិហារគោនិសាទិកា ។ សេចក្តីថា ទីអារាមមិនបានព័ទ្ធព័ទ្ធនោះ ជាប្រមាណ
ក្នុងកប្បិយកុដិឈ្មោះថា គោនិសាទិកាទាំង ២ ។ ក៏ឯអារាម ដែលគេ
ព័ទ្ធព័ទ្ធពាក់កណ្តាល ឬព័ទ្ធព័ទ្ធជាច្រើន ឈ្មោះថាព័ទ្ធព័ទ្ធ ពាក្យនេះ
ពោលទុកក្នុងកុរុន្ទី នឹងមហាបច្ចរី ព្រោះហេតុនោះ មិនជាកប្បិយកុដិ គួរ
នឹងបានជាកប្បិយកុដិជាយ៉ាងដទៃ ក្នុងអារាមដែលឈ្មោះថាព័ទ្ធព័ទ្ធនោះ ។
នឹងពោលក្នុងកប្បិយកុដិឈ្មោះថា គហបតិកា មនុស្សទាំងឡាយធ្វើ
អាវាសហើយពោលថា ខ្ញុំព្រះករុណាថ្វាយកប្បិយកុដិនេះ លោកប្ល
បរិភោគចុះ ដូច្នេះ កប្បិយកុដិនោះឈ្មោះថា គហបតិកា សូម្បីគេ
ពោលថា ខ្ញុំព្រះករុណាថ្វាយ ដើម្បីធ្វើជាកប្បិយកុដិដូច្នេះក៏គួរ ។ តែក្នុង
អដ្ឋកថាពោលថា ទទួលប្រគេនអំពីដៃនៃសហធម្មិកដ៏សេស វៀរ
លែងតែភិក្ខុចេញ ឬទទួលប្រគេនអំពីដៃទេវតា មនុស្សទាំងពួងក្តី នឹង
សន្និធិ នឹងអន្តោវុត្ថ ដែលជារបស់នៃជនអម្បាលនេះ រមែងគួរដល់ភិក្ខុ
ព្រោះហេតុនោះ ផ្ទះនៃជនអម្បាលនោះជាដើម សហធម្មិកដ៏សេសក្តី
ឬកប្បិយកុដិដែលជនអម្បាលនោះថ្វាយក្តី ឈ្មោះថា គហបតិកា

www.budinst.gov.kh www.elibraryofcambodia.org

តាំងអស់ ៗ ក្នុងអដ្ឋកថានោះ លោកពោលទៀតថា លើកតែវិហារនៃភិក្ខុសង្ឃចេញ ទីលំនៅនៃនាងភិក្ខុនី នឹងទីលំនៅនៃមនុស្សគ្រហស្ថ នឹងទីលំនៅនៃក្សត្រិយ៍ នៃទេវតា នៃនាគ សូម្បីវិមាននៃព្រហ្ម ក៏ឈ្មោះថាជាកប្បិយកុដិ ៗ ពាក្យក្នុងអន្ធកដ្ឋកថានេះ ឈ្មោះថាលោកពោលដោយប្រពៃ ព្បិតថាកុដិជារបស់សង្ឃ ឬជារបស់ភិក្ខុម្យ៉ាង មិនឈ្មោះថាគហបតិកុដិបាន ៗ នឹងពោលក្នុងកប្បិយភូមិឈ្មោះថាសម្មតិកា កប្បិយកុដិដែលសង្ឃសន្មតសម្មតិដោយញត្តិទុតិយកម្មវាចា ឈ្មោះថាសម្មតិកា ដើមហេតុព្រះអង្គទ្រង់អនុញ្ញាត កប្បិយកុដិឈ្មោះថាសម្មតិកានេះ មានព្រះបន្ទូលនឹងព្រះអានន្ទត្ថេរថា ម្នាលអានន្ទ ថាបើដូច្នោះ ចូរសង្ឃសន្មតវិហារគឺកុដិដែលតាំងនៅក្នុងទីចុងបំផុត ឲ្យជាកប្បិយភូមិ ហើយឲ្យតាយកយកអាមិសចូលទៅទុកក្នុងកប្បិយភូមិនោះ សង្ឃនឹងប្រាថ្នាសេនាសនៈណា ជាវិហារ ឬអឌ្ឍយោគ ឬប្រាសាទ ឬហម្មិយៈក្តី គប្បីសន្មតកប្បិយភូមិដូច្នេះ ឲ្យភិក្ខុអ្នកឈ្លាសអាចញ៉ាំងសង្ឃឲ្យដឹង ដោយញត្តិទុតិយកម្មវាចាដូច្នេះថា សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ វិហារំ កប្បិយភូមឹ សម្មន្នេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ ឥត្ថន្នាមំ វិហារំ កប្បិយភូមឹ សម្មន្នតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស វិហារស្ស កប្បិយភូមិយា សម្មតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភា-

សេយ្យ ។ សម្មុតោ សង្ឃេន ឥត្ថន្នាមោ វិហារោ កប្បិយ-
ភូមិ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមិ ។
បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំព្រះករុណា បើកម្ម
មានកាលសមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតវិហារឈ្មោះនេះ ឲ្យ
ជាកប្បិយភូមិ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះ
សង្ឃស្តាប់ខ្ញុំ សង្ឃសន្មតវិហារឈ្មោះនេះឲ្យជាកប្បិយភូមិ ។ ការ
សន្មតវិហារឈ្មោះនេះជាកប្បិយភូមិ សមគួរដល់លោកដ៏មានអាយុអង្គ
ណា លោកដ៏មានអាយុអង្គនោះ គប្បីស្ងៀមនៅ បើមិនសមគួរដល់
លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ គប្បីពោល
ឡើង ។ សង្ឃបានសន្មតវិហារឈ្មោះនេះ ឲ្យជាកប្បិយភូមិហើយ ។
ការសន្មតនេះសមគួរដល់សង្ឃ ហេតុនោះទើបសង្ឃស្ងៀមនៅ ។ ខ្ញុំព្រះ
ករុណាសូមចាំទុកនូវសេចក្តីនេះ ដោយអាការសង្ឃស្ងៀមនៅដូច្នេះ ។

ក្នុងអដ្ឋកថា ថាពាក្យដែលថា បច្ចន្តិមំ វិហារតាំងនៅក្នុងទីបំផុត
នោះ គ្រាន់តែថាជាពាក្យពោលទេ ព្រោះព្រះអង្គត្រាស់ថា សង្ឃ
នឹងប្រាថ្នាសេនាសនៈណាដែលជាវិហារ ឬអឌ្ឍយោគជាដើមក្តី ដូច្នេះ
សូម្បីទីនៃសន្មតក្នុងដំបូងក៏គួរ ។ ទីនៃមិនពោលកម្មវាចាសូម្បីទីនៃសន្មតកប្បិ-
យក្នុងនេះ ដោយអបលោកនកម្មក៏គួរ ។ អាមិសណាដែលទុកដាក់ក្នុង
កប្បិយភូមិទាំង ៤ ដូចពោលមកនេះ អាមិសទាំងអស់នោះ មិនដល់
នូវការហៅថាជាអន្តោវុត្ថ ។ ព្រះអង្គទ្រង់អនុញ្ញាតកប្បិយភូមិ ៤ នេះ ដើម្បី

www.budinst.gov.kh www.elibraryofcambodia.org

នឹងឲ្យរួចចាកអន្តោវុត្ត អន្តោបក្កៈ ដល់ភិក្ខុនិងភិក្ខុនីទាំងឡាយ តែអាមិសណាដែលជារបស់សង្ឃ ឬរបស់បុគ្គល របស់ភិក្ខុ ឬរបស់ភិក្ខុនី ទុកដាក់ក្នុងផ្ទះ ដើម្បីនឹងឲ្យកើតសហសេយ្យក្នុងកប្បិយភូមិ សូម្បីតាំងទុកអស់រាត្រី ១ អាមិសនោះ បានឈ្មោះថាជាអន្តោវុត្ត ដណ្តាំស្លក្នុងទីផ្ទះនោះក៏ឈ្មោះថាជាអន្តោបក្កៈផង អាមិសនោះមិនគួរ ៗ តែសត្តាហកាលិកមានសប្បិជាដើម និងយាវជីវិក ទាំង ២ នេះរមែងគួរ គឺថាទុកដាក់ក្នុងទីផ្ទះនោះបាន មិនជាអន្តោវុត្ត ៗ

នឹងវិនិច្ឆ័យ ក្នុងសេចក្តីអម្បាលនោះ ដូចសាមណេរនាំយកអាមិសមានអង្ករជាដើមជារបស់ភិក្ខុ ទៅទុកដាក់ក្នុងកប្បិយកុដិ ព្រឹកឡើងដណ្តាំមកប្រគេន អាមិសនោះមិនជាអន្តោវុត្ត ៗ យកសត្តាហកា-លិក មានសប្បិជាដើម វត្ថុណាមួយ ដែលទុកដាក់ក្នុងអកប្បិយកុដិលាយនឹងអាមិសនោះផង ហើយយកមកប្រគេន ឈ្មោះថាមុខសន្និធិ មិនគួរ ឆាន់ត្រូវទុក្កដ ៗ តែក្នុងមហាបច្ចរីពោលថា ជាអន្តោវុត្ត ក្នុងពាក្យអម្បាលនោះ ប្លែកគ្នាតែត្រឹមឈ្មោះប៉ុណ្ណោះឯង ៗ ភិក្ខុយកសប្បិ ដែលជាសត្តាហកាលិក និងស្លឹកឈើ ដែលជាយាវជីវិកយកទៅទុកដាក់ក្នុងអកប្បិយកុដិ ចំអិនជាមួយគ្នាទុកបរិភោគ របស់នោះគួរឆាន់ប្រាសចាកអាមិស បាន ៧ ថ្ងៃ ៗ បើធ្វើសប្បិនឹងស្លឹកឈើនោះឲ្យច្រឡំនឹងអាមិស បរិភោគ ជាអន្តោវុត្តផង ជាសាមបក្កៈផង ៗ ការលាយឡំគ្នា ដោយកាលិកទាំងពួង គប្បីដឹងដោយឧបាយ

www.budinst.gov.kh www.elibraryofcambodia.org

នោះចុះ ។ ក៏ឯកប្បិយកុដិទាំង ៤ នោះ កាលណានឹងលះវត្ថុ គឺថា កាលណានឹងវិនាសក្លាយទៅជាអកប្បិយកុដិ ? នឹងពោលក្នុងឧស្សាវនន្តិកាជាមុន កប្បិយកុដិ ឈ្មោះថាឧស្សាវនន្តិកាណា ដែលធ្វើលើសសរ ឬកប់ជើងផ្ទាំងចុះទៅធ្វើឡើង កប្បិយកុដិនោះ កាលសសរនឹងជើងផ្ទាំងទាំងអស់ គេដកចេញអស់ ទើបឈ្មោះថាលះវត្ថុ លះទី មិនជាកប្បិយកុដិ ។ បើមនុស្សទាំងឡាយគេផ្តួលសសរ នឹងជើងផ្ទាំងចេញ សសរនឹងជើងផ្ទាំងណាដែលឋិតនៅ ភាពដែលជាកប្បិយកុដិ គឺឋិតនៅក្នុងសសរនឹងជើងផ្ទាំងនោះ កាលសសរនឹងជើងផ្ទាំងទាំងអស់ គេផ្តួលឲ្យរលំចេញអស់ កប្បិយកុដិនោះ ឈ្មោះថាលះវត្ថុ លះទី មិនជាកប្បិយកុដិ ។ តែកុដិដែលគេកសាងដោយឥដ្ឋនោះ កាលវិនាសទាំងអស់ ដរាបដល់ឥដ្ឋ ឬសិលា ឬដុំដីដំបូង ដែលកសាងឡើងលើហាន ដើម្បីនឹងធ្វើជាផ្ទាំងអស់ហើយកាលណា កាលនោះទើបឈ្មោះថាលះវត្ថុ លះទី គឺមិនជាកប្បិយកុដិ ។ តែឥដ្ឋនឹងសិលា នឹងដុំដីជាបឋម ដែលអធិដ្ឋានទុកនោះ សូម្បីគេរើយកទៅអស់ ឥដ្ឋជាដើមដែលគេកសាងផ្ទាំងដទៃមាននៅសល់ ភាពជា កប្បិយកុដិនោះ ក៏គង់ឋិតនៅក្នុងឥដ្ឋសិលា ឬដុំដីដទៃដែលសល់នៅនោះ មិនទាន់ឈ្មោះថាលះទីនៅឡើយ ។ កប្បិយកុដិឈ្មោះថា គោនិសាទិកា នោះ កាលបើគេព័ទ្ធព័ទ្ធដោយកំពែងជាដើមហើយ ក៏ឈ្មោះថាលះវត្ថុ ត្រឡប់ទៅជាអកប្បិយកុដិវិញ ឬ នឹងបានកប្បិយកុដិដទៃ ក្នុងកាលនោះថ្មីទៀត ។ បើកំពែងវត្តជាដើម

www.budinst.gov.kh www.elibraryofcambodia.org

ប្លាក់ដាច់ក្នុងទីនោះ ៗ គោទាំងឡាយចូលបានអំពីទីនោះ ៗ ក៏ត្រឡប់ជាកប្បិយកុដិវិញទៀត ។ ចំណែកកប្បិយកុដិទាំងពីរក្រៅនោះ គឺគហបតិកា និង សម្មតិកា កាលដំបូលទាំងអស់វិនាសរបើកអស់ទៅហើយ នៅសល់តែបង្កង់ ទើបឈ្មោះថាលះវត្ត បើបក្ខបាសកមណ្ឌល សូម្បីតែមួយខាងលើ នៃបង្កង់ទាំងឡាយសល់នៅ ក៏នៅក្យាបាននៅឡើយ មិនទាន់លះវត្ត គ្រឿងប្រក់មានស្មៅនិងស្លឹកឈើជាដើម ដែលតាំងនៅខាងលើនៃបង្កង់ទាំងឡាយ ៣ កណ្ដាបម្ខាង ៗ នោះ ឈ្មោះថាបក្ខបាសកមណ្ឌល ។

បុច្ឆាសួរថា កប្បិយភូមិទាំង ៤ នេះ មិនមានក្នុងទីណា ក្នុងទីនោះ ភិក្ខុនឹងគប្បីបដិបត្តិធ្វើដូចម្ដេច?

វិសជ្ជនាថា ភិក្ខុគប្បីឲ្យអាមិសដល់អនុបសម្បន្ន ធ្វើអាមិសនោះ ឲ្យជារបស់អនុបសម្បន្ន ឲ្យដាច់អាល័យហើយ គប្បីបរិភោគចុះ ។

កប្បិយភូមិកថា ចប់

## ខុទ្ទកកថា

ពោលអំពីខុទ្ទកកថារបស់ធាន់បន្តិចបន្តួច ដែលព្រះអង្គទ្រង់អនុញ្ញាតខុទ្ទកក្នុងកេសច្ឆេទ ដែលគួរនឹងគប្បីដឹង ៗ រឿងមួយ ភិក្ខុកើតរោគខ្យល់ ព្រះអង្គទ្រង់អនុញ្ញាតឲ្យស្ទូប្រេង ។

www.budinst.gov.kh www.elibraryofcambodia.org

រឿងមួយ ប្រេងនោះ នឹងត្រូវលាយដោយគ្រឿងស្រវឹងមានសុរាជាដើម ព្រោះព្រះអង្គទ្រង់អនុញ្ញាត ឲ្យលាយក្នុងប្រេងដែលស្លនោះបាន ។

រឿងមួយ ទ្រង់ឃាត់ថា ប្រេងលាយរបស់ស្រវឹងច្រើនពេក កុំគប្បីក្រេបផឹក បើភិក្ខុណាក្រេបផឹក ឲ្យវិនយធរគប្បីកាត់អាបត្តិភិក្ខុនោះតាមធម៌ (១) ហើយទ្រង់អនុញ្ញាតថា ក្នុងប្រេងដែលស្លណា ពណ៌ និងរស ក្លិនទៃគ្រឿងស្រវឹងមិនប្រាកដ ឲ្យក្រេបផឹកប្រេងដែលលាយរបស់ស្រវឹងដូច្នោះបាន ។

រឿងមួយ ទ្រង់អនុញ្ញាតឲ្យភិក្ខុដែលពស់ចឹក ឆាន់ថ្នាំមហាវិកដ ៤ គឺលាមក ១ មូត្រ ១ ផេះ ១ ដី ១ ដូចពោលហើយ ។

រឿងមួយ ទ្រង់អនុញ្ញាត ឲ្យភិក្ខុដែលផឹកថ្នាំពិសចូលទៅហើយ ឲ្យក្រេបផឹកលាមក និងទ្រង់អនុញ្ញាតថា កាលរបស់ណាជាប់នៅនឹងកាយ មិនទាន់របូតចាកកាយ របស់នោះឈ្មោះថាទទួលប្រគេនហើយ មិនបាច់ទទួលប្រគេនទៀតទេ បើលាមកនោះធ្លាក់ដល់ផែនដីហើយ ឲ្យគប្បីទទួលប្រគេនជាថ្មី បើមិនទាន់ដល់ដីនឹងកាន់យកខ្លួនឯងក៏គួរ ។

រឿងមួយ ទ្រង់អនុញ្ញាត ឲ្យភិក្ខុដែលមានអាពាធព្រោះត្រូវថ្នាំស្នេហ៍ ឲ្យកាន់យកដីដែលជាប់ក្នុងផាលភ្ជួរស្រែមកលាយនឹងទឹកក្រេបផឹក ។

រឿងមួយ ទ្រង់អនុញ្ញាត ឲ្យភិក្ខុដែលកើតរោគបក់គិច ឧច្ចារៈចេញដោយលំបាក ក្រេបផឹកទឹកក្បុងអាមិស ទឹកក្បុងនោះដែលគេយកបាយដុតនឹងភ្លើងឲ្យឆេះជាផេះហើយច្រោះត្រង ឈ្មោះថាទឹកក្បុងអាមិស ។

---

១ ត្រូវភិក្ខុនោះសំដែងអាបត្តិបាចិត្តិយ ។

www.budinst.gov.kh www.elibraryofcambodia.org

រឿងមួយ ទ្រង់អនុញ្ញាត ឲ្យភិក្ខុដែលមានរោគស្គមលឿង ក្រេបផឹកទឹកជ្រក់គ្រាំដោយមូត្រគោ ។

រឿងមួយ ទ្រង់អនុញ្ញាតឲ្យភិក្ខុ ដែលមានអាពាធគឺខូចសម្បុរ ឲ្យធ្វើការលាប ដោយគ្រឿងក្រអូបបាន ។

រឿងមួយ ទ្រង់អនុញ្ញាត ឲ្យភិក្ខុដែលមានកាយប្រកបដោយរោគទល់ (លាមក) ក្រេបផឹកថ្នាំបញ្ចុះបាន ។

រឿងមួយ ភិក្ខុត្រូវការដោយ អច្ឆកញ្ជិក គឺទឹកលាងអង្ករ ដែលថ្លា ព្រះអង្គក៏ទ្រង់អនុញ្ញាត ។

រឿងមួយ ភិក្ខុត្រូវការដោយ អកដយូសក ទឹកសណ្ដែកបាយស្ងោរ ដែលគេមិនបានធ្វើឲ្យស្អិត (គឺគេមិនបានត្រងឲ្យស្អាត) ព្រះអង្គទ្រង់អនុញ្ញាតឲ្យឆាន់បាន ។

រឿងមួយ ភិក្ខុត្រូវការដោយ កដាកដ ទឹកសណ្ដែកបាយស្ងោរ ដែលគេធ្វើឲ្យស្អិត (គឺគេបានត្រងឲ្យស្អាត) ព្រះអង្គទ្រង់អនុញ្ញាតឲ្យឆាន់បាន ។

រឿងមួយ ភិក្ខុមានសេចក្ដីត្រូវការដោយ បដិច្ឆាទនិយ គឺទឹកសាច់ដែលគេចំកញ្ញ់ប្ញគៀប ព្រះអង្គទ្រង់អនុញ្ញាត ។

រឿងមួយ ព្រះអង្គត្រាស់ថា បើគេលាយម្សៅទឹនផេះក្នុងទឹកអំពៅ ដើម្បីឲ្យជាប់ ដើម្បីឲ្យស្អិតរឹង ទឹកអំពៅនោះក៏រាប់ថា ជាទឹកអំពៅសុទ្ធ តថាគតអនុញ្ញាតឲ្យបរិភោគទឹកអំពៅដូច្នោះ តាមសប្បាយ ។

www.budinst.gov.kh www.elibraryofcambodia.org

រឿងមួយ ព្រះអង្គត្រាស់ថា បើសណ្តែកឆ្អិនហើយត្រឡប់ដុះបាន ទៀត តថាគតអនុញ្ញាតឲ្យបរិភោគសណ្តែកនោះតាមសប្បាយ ។

រឿងមួយ ព្រះអង្គទ្រង់អនុញ្ញាត ឲ្យភិក្ខុមានជម្ងឺដោយពោះខ្យល់ក្នុងពោះ បរិភោគថ្នាំ លោណសោចិរកា មិនមានជម្ងឺឲ្យលាយទឹក បរិភោគដូច បាន ទឹកគួរផឹក ។

រឿងមួយ ទ្រង់អនុញ្ញាតស្ករអំពៅដុំដល់ភិក្ខុឈឺ មិនឈឺឲ្យលាយ ដោយទឹកហើយបរិភោគ ។

របស់ឆាន់ដែលព្រះអង្គទ្រង់អនុញ្ញាតដូចពោលមកនេះ ក្នុងបាលី មិនកំណត់ថា ឲ្យឆាន់ក្នុងកាល ឬក្នុងវិកាល តែក្នុងអដ្ឋកថាខ្លះ កំណត់ របស់ឲ្យឆាន់ក្នុងវិកាលបាន ដូចថ្នាំ មហាវិកដ តែទឹកលាងអង្ករថ្ង នឹងទឹកសាច់ ទឹកសណ្តែកស្ងោរនោះ ក្នុងអដ្ឋកថាក៏មិនកំណត់កាល តែ ទឹកលាងអង្ករថ្ងនោះ ជាយាវជីវិក ឬយាវកាលិក ក៏មិនប្រាកដ ក៏ប៉ុន្តែ ឃើញថាគួរកាន់ទុកក្នុងចំណែកយាវកាលិកចុះ ទើបនឹងអស់សង្ស័យ តែទឹកសាច់ ទឹកសណ្តែកស្ងោរ នេះជាយាវកាលិកមែន តែទឹកអំពៅ ដែលលាយមេស្រានោះ ជាសត្តាហកាលិក របស់ក្រៅនោះ ជាយាវជីវិក អ្នកមានប្រាជ្ញាគប្បីពិចារណាយកចុះ ។

រឿងមួយថា សម័យនោះ ក្នុងនគរសាវត្ថី មានរបស់ចំពាស៊ី គឺផ្លែឈើកើតឡើងច្រើន តែកប្បិយការកៈ មនុស្សអ្នកធ្វើឲ្យជា កប្បិយគ្មាន ភិក្ខុទាំងឡាយរង្កៀស មិនហ៊ានឆាន់ផ្លែឈើ ទើបទូល

www.budinst.gov.kh www.elibraryofcambodia.org

សេចក្តីនោះដល់ព្រះពុទ្ធអង្គ ព្រះអង្គទ្រង់អនុញ្ញាតថា អនុជានាមិ ភិក្ខវេ អពីជំ និព្វដ្ដពីជំ អកាតកប្បំ ផលំ បរិភុញ្ជិតុំ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យឆាន់ផ្លែឈើដែលមិនមានពីជៈ (គឺគ្រាប់មិនពន្លក) និងផ្លែដែលគេបកបន្ទោចយកគ្រាប់ចេញបាន (ដូចខ្នុរជាដើម) សូម្បីមិនបានធ្វើឲ្យជាកប្បិយក៏គួរ (ឆាន់បាន) ។ ដែលពោលថា ភិក្ខុទាំងឡាយរង្កៀសមិនហ៊ានឆាន់នោះ ប្រហែលជារង្កៀសថាជាភូត-គាម និងពីជគាមសមារម្ភៈ គឺធ្វើភូតគាម និងពីជគាមឲ្យកំរើក ក្នុងខន្ធក. ខន្ធកថា ថាព្រះអង្គទ្រង់ប្រារព្ធនិងឆព្វគ្គិយភិក្ខុ ដែលឆាន់ផ្លែស្វាយក្នុងឧទ្យានស្តេចដែលព្រះបាទពិម្ពិសារទ្រង់អនុញ្ញាត ឆាន់តែអស់ទាំងអំពីនៅខ្ចីនៅឡើយ ហើយទ្រង់បញ្ញត្តិយាក់ថា កុំគប្បីឆាន់ផ្លែស្វាយ បើឆាន់ត្រូវទុក្កដ ។ សម័យនោះទាយកមួយពួក ថ្វាយសង្ឃភត្ត យកចំណិតស្វាយលាយក្នុងសូបៈ គឺសម្លមកផង ភិក្ខុទាំងឡាយរង្កៀសមិនហ៊ានទទួល ព្រះអង្គត្រាស់ថា ទទួលចុះ ឆាន់ចុះ ហើយទ្រង់អនុញ្ញាតថា អនុជានាមិ ភិក្ខវេ អម្ពបេសិកំ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតចំណិតស្វាយ ។ សម័យនោះទាយកមួយពួកថ្វាយសង្ឃភត្តដល់សង្ឃម្តងទៀត ទាយកទាំងឡាយនោះ មិនទាន់ធ្វើស្វាយនោះឲ្យជាចំណិត ទើបអង្គាសផ្លែស្វាយទាំងមូលក្នុងភោជនទាន ភិក្ខុទាំងឡាយរង្កៀសមិនហ៊ានទទួល ព្រះអង្គត្រាស់ថា ទទួលចុះ ឆាន់ចុះ ហើយទ្រង់អនុញ្ញាតថា អនុជានាមិ ភិក្ខវេ បញ្ចហិ សម-

www.budinst.gov.kh www.elibraryofcambodia.org

ណកប្បេហិ ផលំ បរិភុញ្ជិតុំ អគ្គិបរិចិតំ សត្ថបរិចិតំ នខបរិចិតំ អពីជំ និព្វដ្ដពីជញ្ចេវ បញ្ចមំ

ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យបរិភោគផ្លែឈើដោយសមណកប្បៈ គឺផ្លែដែលគួរដល់សមណៈ ៥ ប្រការ គឺផ្លែដុតដោយភ្លើង ១ ផ្លែចាក់ដោយគ្រឿងសស្ត្រា ១ ផ្លែចុចដោយក្រចក ១ ផ្លែមិនមានពីជៈ ១ នឹងផ្លែមានពីជៈដែលគប្បីបន្ទោចចេញបាន ១ ត្រូវជា ៥ ប្រការ ។

ក្នុងអដ្ឋកថានៃភូតគាមសិក្ខាបទ លើកយកបាលីនេះទៅពោលថា ពីជៈមានឫសឈើជាដើម ដែលកើតនៅក្នុងទីឈ្មោះថាភូតគាម ជាវត្ថុនៃបាចិត្តិយ ។ ពីជៈនោះ កាលធ្វើឲ្យឃ្លាតចាកទីហើយ ឈ្មោះថាពីជគាម ជាវត្ថុនៃទុក្កដ ។ ពីជគាមនោះ កាលបរិភោគ គប្បីបង្គាប់អនុបសម្បន្នថា កប្បិយំ ករោហិ អ្នកចូរធ្វើឲ្យជារបស់គួរ ដូច្នេះសិនហើយសឹមបរិភោគ កាលធ្វើដូច្នេះឈ្មោះថារួចចាកពីជគាម ។

ឯនឹងធ្វើកប្បិយនោះ គប្បីធ្វើដោយភ្លើង សស្ត្រា ឬក្រចក ។ កាលនឹងធ្វើកប្បិយដោយភ្លើង គប្បីយកភ្លើងណាមួយ អុចចុះក្នុងប្រទេសនៃពីជៈនោះ ហើយពោលថា កប្បិយំ ដូច្នេះហើយធ្វើចុះ ។ កាលនឹងធ្វើដោយសស្ត្រា គប្បីសំដែងនូវអាការៈចាក់ឬកាត់ដោយដែកស្រួច ឬមុខនៃសស្ត្រាដែលមុត ណាមួយ ដោយហោចទៅ សូម្បីម្ជុលនឹងកាំបិតកាត់ក្រចកជាដើម ដូចធ្វើដោយភ្លើងនោះចុះ ។ កាលធ្វើកប្បិយដោយក្រចក គប្បីយកក្រចកនៃមនុស្ស ឬក្រចកនៃសត្វតិរច្ឆានណាមួយ ដែលមិនពុក

www.budinst.gov.kh www.elibraryofcambodia.org

ទៀតតែក្រចកគោនឹងក្រចកក្របីជាដើមចេញ ក្រចកក្រោះនោះដោយ
ហោចទៅ កាត់យកមកក៏បាន គប្បីធ្វើដោយន័យដូចពោលហើយក្នុង
សង្គ្រោះនោះចុះ ។ ម្ទេសស្រស់គេដាក់ក្នុងបបរមកមិនជាប់ជិតគ្នា គប្បី
ចាក់គ្រប់ ៗ គ្រាប់ធ្វើកប្បិយ ។ ផ្លែទ្វិតជាដើម បើពីជៈមានក្នុងសន្ដោះ
ចាកលលាដ៍រលុងទៅ គប្បីឲ្យគេបំបែកចេញធ្វើកប្បិយ បើនៅជាប់គ្នាពិត
សូម្បីនឹងធ្វើកប្បិយក្នុងលលាដ៍ក៏គួរ ។ ឯផ្លែណាជារបស់ខ្ចី មិនមានពីជៈ
នឹងផ្លែណាដែលមានពីជៈបន្តិចចេញបរិភោគបាន កិច្ចដែលនឹងធ្វើកប្បិយ
ក្នុងផ្លែនោះមិនមាន ដ្បិតទ្រង់អនុញ្ញាតទុក តែប៉ុណ្ណោះ គប្បីដឹងចុះថា
ផ្លែស្វាយនឹងផ្លែឈើដទៃ នឹងពីជតាមចំនួន ខ្ចី ឬចាស់ ណា ៗ ជារបស់
គួរតាមកាលនៃខ្លួន ៗ ។

ខុទ្ទកកថា ចប់

---

## មហាបទេស

មហាបទេស ៤ ជាគ្រឿងកាន់ដ៏ធំមាន ៤ ប្រការ ។ មានពាក្យព្រះ
បាលីថា យំ ភិក្ខវេ មយា ឥទំ ន កប្បតីតិ អប្បដិ-
ក្ខិត្តំ តញ្ចេ អកប្បិយំ អនុលោមេតិ កប្បិយំ បដិ-
ពាហតិ តំ វោ ន កប្បតិ ។ល។ យំ ភិក្ខវេ មយា ឥទំ
កប្បតីតិ អននុញ្ញាតំ តញ្ចេ កប្បិយំ អនុលោមេតិ

www.budinst.gov.kh www.elibraryofcambodia.org

អកប្បិយំ បដិពាហតិ តំ វោ កប្បតីតិ ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគតមិនបានហាមទុកថា របស់នេះមិនគួរទេ បើរបស់នោះអនុលោមចូលរបស់មិនគួរ ឃាត់របស់គួរ របស់នោះមិនគួរដល់អ្នកទាំងឡាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគតមិនបានហាមទុកថា របស់នេះមិនគួរ បើរបស់នោះអនុលោមចូលរបស់គួរ ឃាត់របស់មិនគួរ របស់នោះគួរដល់អ្នកទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគតមិនបានអនុញ្ញាតទុកថា របស់នេះគួរ បើរបស់នោះអនុលោមចូលរបស់មិនគួរ ឃាត់របស់គួរ របស់នោះមិនគួរដល់អ្នកទាំងឡាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគតមិនបានអនុញ្ញាតទុកថា របស់នេះគួរ បើរបស់នោះអនុលោមចូលរបស់គួរ ឃាត់របស់មិនគួរ របស់នោះគួរដល់អ្នកទាំងឡាយ ។

ក្នុងមហាបទេស ៤ ប្រការនេះ ពីរប្រការខាងដើម ពោលដោយបញ្ញត្តិ ពីរប្រការខាងចុងពោលដោយអនុញ្ញាត ។

ក្នុងអដ្ឋកថា ថាព្រះអង្គទ្រង់សំដែងមហាបទេស ៤ នេះ ដើម្បីនឹងឲ្យភិក្ខុទាំងឡាយកាន់យកន័យ គឺឲ្យជាគួយ៉ាង ។

ព្រះធម្មសង្គាហកត្ថេរទាំងឡាយ លោកកាន់យកសូត្រគឺបាលី ដែលទ្រង់បញ្ញត្តិនិងអនុញ្ញាតក្នុងទីនោះ ៗ មករួបរួមបញ្ចូលក្នុងមហាបទេស ៤ នេះ ឲ្យឃើញសេចក្តីដូច្នេះថា បាលីដែលទ្រង់អនុញ្ញាតរសនៃផ្លែឈើទាំងពួងថា ជាដ: ឃាត់តែរសនៃផ្លែស្រូវថា បបេញ្ញា

ជញ្ជលរស់ ដូច្នេះ ផ្សិតពាក្យនេះឈ្មោះថាឃាត់ស្រូវ ៧ ប្រការ ថាមិនគួរក្នុងបច្ឆាភត្ត ឯនិងមហាផល ៩ ទៀត គឺផ្លែត្នោត ផ្លែដូង ផ្លែខ្នុរ ផ្លែសាគេរ ផ្លែឃ្លោក ផ្លែត្រឡាច ផ្លែត្រសក់ ផ្លែខ្ទិក ផ្លែល្ពៅក្តី ឯនិងអបរណ្ណជាតិទាំងពួង មានសណ្តែកល្ងជាដើមក្តី ជាគតិនៃស្រូវមែនពិតរបស់អម្បាលនោះ សូម្បីព្រះអង្គមិនបានឃាត់ក៏ពិតមែន តែរមែងអនុលោមតាមរបស់ដែលជាអកប្បិយ គឺស្រូវ ៧ ប្រការ ព្រោះហេតុនោះមហាផលឯនិងអបរណ្ណជាតិទាំងពួង រមែងមិនគួរក្នុងបច្ឆាភត្ត ។ ព្រះអង្គទ្រង់អនុញ្ញាត អដ្ឋបាន ៨ ជាទឹកគួរក្រេបផឹក ហើយឯនិងទឹកធ្វើដោយផ្លែឈើតូច ១ ក្រៅពីនោះ មានផ្លែផ្តៅ ផ្លែអម្ពិល ផ្លែក្របកា ផ្លែទិត ផ្លែពុទ្រា ផ្លែសន្ទូរជាដើម អម្បាលនេះក៏ជាគតិនៃអដ្ឋបាន ៨ ដោយពិត ។ ទឹកផឹកធ្វើដោយផ្លែឈើតូច ១ អម្បាលនោះ សូម្បីព្រះអង្គមិនបានទ្រង់អនុញ្ញាតក៏ពិតមែន តែរមែងអនុលោមតាមវត្ថុដែលជាកប្បិយ គឺអដ្ឋបាន ៨ ប្រការ ព្រោះហេតុនោះ ទឹកផឹកធ្វើដោយផ្លែឈើតូចៗ នោះរមែងគួរ លើកតែរសនៃផ្លែស្រូវ មួយធ្វើដោយវត្ថុដែលជាអនុលោមតាមធញ្ញជាតិចេញ ទឹកផឹកធ្វើដោយផ្លែឈើដទៃ ឈ្មោះថាមិនគួរនោះមិនមាន ជាយាមកាលិកបានប្រាកដ ពាក្យនេះពោលទុកក្នុងកុរុន្ទី ។

ឯព្រះអង្គទ្រង់អនុញ្ញាតចីវរ ៦ គឺសំពត់ខោមៈ ១ កប្បាសិកៈ ១ កោសេយ្យៈ ១ កម្ពលៈ ១ សាណៈ ១ ភង្គៈ ១ ទុកដូច្នេះ ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះធម្មសង្គាហកត្ថេរទាំងឡាយ លោកអនុញ្ញាតសំពត់ដទៃ ៦ យ៉ាង គឺសំពត់ ទុកូលៈ ១ សំពត់ បត្តុណ្ណៈ ១ សំពត់ ចីនបដៈ ១ សំពត់ សោមារបដៈ ១ សំពត់ ឥទ្ធិមយិកៈ ១ សំពត់ ទេវទត្តិយៈ ១ អម្បាលនេះ ឲ្យជាអនុលោមដល់ចីវរ ៦ យ៉ាងខាងដើមនោះ ។ សំពត់ដែលកើតដោយសត្វទាំងឡាយ ក្នុងបត្តុណ្ណប្រទេស ឈ្មោះថាបត្តុណ្ណៈ ។ ឯសំពត់ចីនបដៈ សោមារបដៈ ២ នេះ ហៅតាមឈ្មោះនៃប្រទេស ។ សំពត់ ៣ យ៉ាងមុននោះ ជាអនុលោមតាមសំពត់កោសេយ្យៈ ។ សំពត់ទុកូលៈ ជាអនុលោមតាមសំពត់សាណៈ ។ សំពត់ ២ ក្រៅនោះ អនុលោមតាមសំពត់កប្បាសិកៈ ឬអនុលោមតាម សំពត់ទាំងពួងក៏បាន ។

ព្រះអង្គទ្រង់ហាមឃាត់បាត្រ ១១ យ៉ាង មានបាត្រឈើជាដើម ទ្រង់អនុញ្ញាតបាត្រ ២ យ៉ាងគឺបាត្រដែក ១ បាត្រដី ១ ។ ចំណែកថាលកៈ គឺភាជនៈគ្រឿងប្រើប្រាស់ដែលធ្វើដោយលោហៈ ឬធ្វើដោយដី ធ្វើដោយទង់ដែង ៣ នេះ អនុលោមតាមបាត្រ ២ យ៉ាងនោះប្រាកដ ។

ព្រះអង្គទ្រង់អនុញ្ញាតតុម្ពៈ គឺភាជនៈសម្រាប់រាល់ ៣ យ៉ាង គឺធ្វើដោយលោហៈ ធ្វើដោយឈើ ធ្វើដោយផ្លែឈើដូច្នេះ ។

ចំណែកកុណ្ឌីទឹក និងផ្តិលស្ពាន់ និងក្អមទឹក អនុលោមតាមតុម្ពៈ ៣ នោះ ដោយពិត តែក្នុងកុរុន្ទី ពោលថាស័ង្ខ សម្រាប់ដាក់ទឹកផឹក និងផ្តិលទឹក អនុលោមតាមតុម្ពៈ ៣ នេះ ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះអង្គទ្រង់អនុញ្ញាតវត្តពន្ធបង្កើះ ២ ប្រការ គឺវត្តពន្ធដែលត្បាញជាផែន និងវត្តពន្ធដែលត្បាញដូចពោះវៀនជ្រូកទុកដូច្នេះ ។ ចំណែកវត្តពន្ធធ្វើដោយផែនសំពត់ និងធ្វើដោយខ្សែ អនុលោមតាមវត្តពន្ធ ២ ប្រការនោះ ។

ព្រះអង្គទ្រង់អនុញ្ញាតធក្រក ៣ ប្រការ គឺធក្រកពាសសំពត់ស់ និងធក្រកត្បាញដោយបន្ទូសម្បស្ស៍ និងធក្រកធ្វើដោយស្នឹកឈើទុកដូច្នេះ ។

ធក្រកស្នឹកឈើមួយចំពូក ដូចស្នឹកគោក ស្នឹកកក អនុលោមតាមធក្រក ៣ ប្រការនោះពិត សម្បូរបស់ផងទៃដែលអនុលោមតាមវត្ថុដែលជាកប្បិយនិងអកប្បិយ វិនយធរគប្បីពិចារណាមើលតាមបាលីនិងអដ្ឋកថាឲ្យដឹងច្បាស់ ដោយន័យដូចពោលមកនោះចុះ ។

មហាបទេស ៤ ចប់

កាលិកបព្វៈគំរប់ ៤ ចប់

## ពិន្ទុធិដ្ឋានធាតុបព្វៈគំរប់ ៥

### វិធីអធិដ្ឋាននិងបច្ចុទ្ធរសំពត់

ពោលអំពីសំពត់គួរអធិដ្ឋានជាមុន ៗ សំពត់គួរអធិដ្ឋានមាន ៧ យ៉ាងគឺ តិចីវរ ចីវរតាំងថ ១ វស្សិកសាដិកា សំពត់ងូតទឹកភ្លៀង ១ និសីទនៈ សំពត់ក្រាលអង្គុយ ១ បច្ចត្ថរណៈ កម្រាល ១ កណ្ឌុប្បដិច្ឆាទិ សំពត់បិទបូស ១ មុខបុញ្ឆនចោល សំពត់ជូតមុខ ១ បរិក្ខារ-

www.budinst.gov.kh www.elibraryofcambodia.org

ចោលំ សំពត់បរិក្ខារសម្រាប់ប្រើបន្តិចបន្តួច មានតម្រងទឹកនិងថង់យាម ថង់បាត្រជាដើម ១ សំពត់អំបាលនេះត្រូវអធិដ្ឋានតាមឈ្មោះ ដូចតទ្រន៍ អនុញ្ញាតថា អនុជានាមិ ភិក្ខវេ តិចីវរំ អធិដ្ឋាតុំ ន វិកប្បេតុំ វស្សិកសាដិកំ វស្សានំ ចាតុម្មាសំ អធិដ្ឋាតុំ តតោ បរំ វិកប្បេតុំ និសីទនំ អធិដ្ឋាតុំ ន វិកប្បេតុំ បច្ចត្ថរណំ អធិដ្ឋាតុំ ន វិកប្បេតុំ កណ្ឌុប្បដិច្ឆាទឹ យាវ អាពាធា អធិដ្ឋាតុំ តតោ បរំ វិកប្បេតុំ មុខបុញ្ឆនចោលំ អធិដ្ឋាតុំ ន វិកប្បេតុំ បរិក្ខារចោលំ អធិដ្ឋាតុំ ន វិកប្បេតុំ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុអធិដ្ឋានត្រៃចីវរ មិនឲ្យវិកប្បទេ ឲ្យអធិដ្ឋានសំពត់ សម្រាប់ងូតទឹកភ្លៀង អស់ ៤ ខែនៃរដូវភ្លៀង ខាងមុខអំពី ៤ ខែនោះទៅ ត្រូវវិកប្បទុក ឲ្យអធិដ្ឋានសំពត់សម្រាប់ទ្រាប់អង្គុយ មិនឲ្យវិកប្បទេ ឲ្យអធិដ្ឋានសំពត់គម្រាល មិនឲ្យវិកប្បទេ ឲ្យអធិដ្ឋានសំពត់សម្រាប់គ្របកម ដរាបអំពីមានអាពាធ ខាងមុខអំពីអាពាធជាហើយ ត្រូវវិកប្បទុក ឲ្យអធិដ្ឋានសំពត់ សម្រាប់ជូតមុខ មិនឲ្យវិកប្បទេ ឲ្យអធិដ្ឋានសំពត់ បរិក្ខារចោល មិនឲ្យវិកប្បទេ ។

ត្រៃចីវរនោះ គឺសង្ឃាដិ សំពត់សម្រាប់គម្រួតដណ្តប់ ១ ឧត្តរាសង្គៈ សំពត់ដណ្តប់ អន្តរវាសកៈ សំពត់ស្លៀក សំពត់ទាំង ៣ នេះត្រូវគាត់ជាប

ធ្វើឲ្យត្រូវតាមលក្ខណៈ ឲ្យបានប្រមាណហើយផ្តល់ឲ្យបានពណ៌ ធ្វើកប្បពិន្ទុ ហើយទើបអធិដ្ឋាន បើមិនកាត់មិនគួរ ។ ដ្បិតទ្រង់ហាមឃាត់ថា ន ភិក្ខវេ អច្ឆិន្នកានិ ចីវរានិ ធារេតព្វានិ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកុំគប្បីប្រើប្រាស់ ចីវរមិនបានកាត់ បើភិក្ខុណាប្រើប្រាស់ ចីវរមិនបានកាត់ ត្រូវអាបត្តិទុក្កដ ។

កាលធ្វើឲ្យត្រូវលក្ខណៈ គប្បីធ្វើដូចព្រះអង្គត្រាស់ចំពោះនឹងព្រះអានន្ទថា បណ្ឌិតោ ភិក្ខវេ អានន្ទោ ។ល។ កុសិម្បិ នាម ករិស្សតិ អឌ្ឍកុសិម្បិ នាម ករិស្សតិ ។ល។ ឆិន្នកំ អន្តរវាសកំ ម្នាលភិក្ខុទាំងឡាយ អានន្ទជាអ្នកមានបញ្ញាច្រើន ព្រោះពាក្យដែលតថាគតពោលហើយដោយសង្ខេប អានន្ទអាចដឹងសេចក្តីដោយពិស្តារបាន ហើយបេះធ្វើសំពត់កុសិ ទាំងអឌ្ឍកុសិផង ធ្វើសំពត់មណ្ឌលទាំងអឌ្ឍមណ្ឌលផង ធ្វើសំពត់វិវដ្ដៈទាំងអនុវិវដ្ដៈផង ធ្វើសំពត់គីវេយ្យកៈ ទាំងជង្ឃេយ្យកៈផង ធ្វើសំពត់ពាហន្តៈផង ជាសំពត់កាត់ដាច់ ឲ្យសៅហ្មងដោយមុខកាំបិត ជាសមណសារុប្ប ឲ្យជាសំពត់ដែលមនុស្សជាសត្រូវ គឺចោរមិនប្រាថ្នាចង់បាន តថាគតអនុញ្ញាតសង្ឃាដិកាត់ ឧត្តរសង្គៈកាត់ អន្តរវាសកៈកាត់ ដូច្នេះ ។

នឹងពោលតាមអដ្ឋកថាជាមុន កុសិ នោះជាឈ្មោះនៃផ្ទាំងសំពត់ដែលវែងមានអនុវាតជាដើម ដោយបានបណ្តោយនឹងទទឹង ។ អឌ្ឍកុសិ នោះ ជាឈ្មោះនៃផ្ទាំងសំពត់ខ្លីដែលមាន ក្នុងចន្លោះ ៗ ។

www.budinst.gov.kh www.elibraryofcambodia.org

មណ្ឌលធំ ក្នុងខណ្ឌមួយ ៗ នៃចីវរប្រកបដោយខណ្ឌ ៥ នេះឈ្មោះថាមណ្ឌល ៗ មណ្ឌលតូច ក្នុងខណ្ឌមួយ ៗ នៃចីវរដូច្នោះ ឈ្មោះថាអឌ្ឍមណ្ឌល ៗ ខណ្ឌគឺផ្ទាំងកណ្ដាលដែលដេរមណ្ឌលនិងអឌ្ឍមណ្ឌល ភ្ជាប់ជាមួយគ្នាឈ្មោះថាវិវដ្ដៈ ៗ ខណ្ឌគឺផ្ទាំងទាំង ២ អមសងខាងនៃវិវដ្ដៈនោះឈ្មោះថាអនុវិវដ្ដៈ ៗ គាតន្ធកបដៈ គឺផ្ទាំងសំពត់ដទៃ ដែលដេរ ដោយទេសដើម្បីឲ្យមាំក្នុងទីដែលព័ទ្ធព័ទ្ធក ឈ្មោះថាគីវេយ្យកៈ ៗ ផ្ទាំងសំពត់ដែលដេរភ្ជាប់ដោយទេសដូច្នោះ ក្នុងទីដែលត្រូវប៉ះស្មងឈ្មោះថាជង្ឃេយ្យកៈ ៗ អាចារ្យពួកខ្លះថាគីវេយ្យកៈ និងជង្ឃេយ្យកៈនោះ ជាឈ្មោះនៃផ្ទាំងសំពត់ទាំងឡាយ ដែលដាក់ទុកក្នុងទីព័ទ្ធព័ទ្ធក និងក្នុងទីត្រូវប៉ះស្មងដូច្នេះ ៗ ខណ្ឌគឺផ្ទាំងមួយ ៗ បំផុតខាងក្រៅនៃអនុវិវដ្ដៈនេះ ឈ្មោះថាពាហន្ត ៗ ពាក្យដូច្នេះនោះពិចារណាទៅ គឺពោលសំដៅចីវរប្រកបដោយខណ្ឌ ៥ ៗ មួយយ៉ាងទៀត អនុវិវដ្ដៈនោះ ជាឈ្មោះនៃខណ្ឌគឺផ្ទាំងទាំងពីរអមសងខាងនៃវិវដ្ដៈ និងជាឈ្មោះនៃខណ្ឌ គឺផ្ទាំងទាំង ៣ ឬ ៤ ក្នុងម្ខាង ៗ នៃវិវដ្ដៈនោះ ៗ កាលឃុំចីវរមានប្រមាណស្មើគ្នា ប្រមូលមូរឡើងព័ទ្ធដាក់លើដើមដៃ ចុងបំផុតទាំងពីរនៃខណ្ឌនោះរមែងមានមុខចេញមកខាងក្រៅ ក៏ឯពាហន្តនោះជាឈ្មោះនៃខណ្ឌនោះដែលមានចុងបំផុតទាំងពីរមានមុខខាងក្រៅនោះឯង ៗ ន័យដូច្នេះ លោកពោលទុកក្នុងមហាអដ្ឋកថា ៗ ដែលព្រះអដ្ឋកថាចារ្យ លើកយកអនុវាតជាសំពត់ដែលព្រះអង្គទ្រង់អនុញ្ញាតខាងក្រោយវិធីធ្វើចីវរនេះ មកពោលថាជាកុសិផងនោះ

ដើម្បីសំដែងថា ខ្ទង់សំពត់ដែលតូចវែង ឈ្មោះថា កុសិទាំងអស់ តែថា តាមវិធីធ្វើចីវរនេះ ខ្ទង់សំពត់ដែលតូចវែងស្មើមណ្ឌល ឈ្មោះថាកុសិ ខ្ទង់សំពត់ដែលតូចខ្លី បញ្ឈរតាមអឌ្ឍមណ្ឌលក្តី នៅក្នុងចន្លោះមណ្ឌលនិងអឌ្ឍមណ្ឌលក្តី ឈ្មោះថាអឌ្ឍកុសិទាំងអស់ ។ ផ្ទាំងកណ្តាល ឈ្មោះថាវិវដ្ដៈ ។ ផ្ទាំងទាំង ២ អមសងខាង ឈ្មោះថាអនុវិវដ្ដៈ ។ សំពត់អឌ្ឍមណ្ឌលដែលប៉ះព័ទ្ធកក្នុងវេលាឃ្លុំ ឈ្មោះគីវេយ្យកៈ ។ សំពត់អឌ្ឍមណ្ឌល ដែលប៉ះស្មង ឈ្មោះថា ជង្ឃេយ្យកៈ ។ សំពត់អឌ្ឍមណ្ឌលដែលប៉ះត្រូវដៃ ឈ្មោះថា ពាហន្តៈ ។ រួមសេចក្តីតាម[illegible]ៈក្នុងអដ្ឋកថា បានសេចក្តីដូច្នេះឯង ។

ទីនេះពោលតាមអ្នកប្រាជ្ញដែលឈ្លាសវៃ លោកគិតទុកថា កុសិនោះ ជាឈ្មោះខ្ទង់សំពត់ដែលតូចវែងបញ្ឈរឡើងទៅ ជាខទទឹងតាមមណ្ឌល ។ អឌ្ឍកុសិជាឈ្មោះខ្ទង់សំពត់ដែលតូចខ្លី បញ្ឈរឡើងទៅ ជាខទទឹងតាមអឌ្ឍមណ្ឌល ។ មណ្ឌលនោះជាឈ្មោះនៃកំណាត់សំពត់ដែលធំវែងបញ្ឈរឡើងទៅ ជាខទទឹងតាមកុសិ ។ អឌ្ឍមណ្ឌល ជាឈ្មោះកំណាត់សំពត់ដែលធំខ្លី បញ្ឈរឡើងទៅ ជាខទទឹងតាមអឌ្ឍកុសិ ។ វិវដ្ដៈនោះជាឈ្មោះផ្ទាំងសំពត់ដែលតូចវែងទៅតាមដាខវែង នៅក្នុងចន្លោះមណ្ឌលនិងអឌ្ឍមណ្ឌលនិងចន្លោះកុសិនិងអឌ្ឍកុសិ ក្នុងខណ្ឌកណ្តាល ។ អនុវិវដ្ដៈ ជាឈ្មោះផ្ទាំងសំពត់ដែលតូចវែង ទៅតាមដាខវែងក្នុងចន្លោះមណ្ឌលនិងអឌ្ឍមណ្ឌល តែនៅក្នុងចន្លោះនៃកុសិ និងអឌ្ឍកុសិខាងក្រៅ ក្នុងផ្ទាំងទាំងពីរអមសងខាង ។ គីវេយ្យកៈនោះ គឺខណ្ឌកណ្តាល ព្រោះអឌ្ឍមណ្ឌល

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងផ្ទាំងនោះប៉ះគ្រប់ក្នុងពេលឃុំ ។ ជង្ឃេយ្យកៈនោះ គឺផ្ទាំងតាំងពីរអមសងខាង ព្រោះអន្លូវមណ្ឌលក្នុងផ្ទាំងអំបាលនោះ ប៉ះគ្រប់ស្មងក្នុងពេលឃុំ ។ ពាហន្តៈនោះ គឺផ្ទាំងតាំងពីរក្នុងចុងបំផុត ព្រោះអន្លូមណ្ឌលក្នុងផ្ទាំងនោះទៅក្នុងចុងបំផុតដើមដៃក្នុងពេលឃុំ ។ ពាក្យនេះពិចារណាក្នុងចីវរដែលប្រកបដោយខណ្ឌ ៥ គឺ ៥ ផ្ទាំង អ្នកប្រាជ្ញដែលមានប្រាជ្ញាគប្បីពិចារណាមើលចុះ ។

ខមួយ ព្រះអង្គទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ តិចីវរំ ទិគុណំ សង្ឃាដឹ ឯកច្ចិយំ ឧត្តរាសង្គំ ឯកច្ចិយំ អន្តរវាសកំ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតចីវរ ៣ គឺសំពត់សង្ឃាដិពីរជាន់ ឧត្តរាសង្គៈចីពរមួយជាន់ អន្តរវាសកៈស្បង់ ១ ជាន់ ។

ខមួយទៀត ទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ អហតានំ ទុស្សានំ អហតកប្បានំ ទិគុណំ សង្ឃាដឹ ។ល។ ឧតុទ្ធតានំ ទុស្សានំ ចតុគ្គុណំ សង្ឃាដឹ ទិគុណំ ឧត្តរាសង្គំ ទិគុណំ អន្តរវាសកំ បំសុក្កូលេ យាវទត្ថំ បាបណិកេ ឧស្សាហោ ករណីយោ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអ្នកទាំងឡាយធ្វើសង្ឃាដិពីរជាន់ ឧត្តរាសង្គៈមួយជាន់ អន្តរវាសកៈមួយជាន់ ដោយសំពត់ថ្មី ទឹងសំពត់ដែលគក់ម្តងហើយ ។ បើសំពត់ហួសចាករដូវ (គឺសំពត់ចាស់ហើយ) ឲ្យធ្វើ

www.budinst.gov.kh www.elibraryofcambodia.org

សង្ឃាដី ៤ ជាន់ ឧត្តរាសង្គៈ ២ ជាន់ អន្តរវាសកៈ ២ ជាន់ ។ អ្នកទាំងឡាយ គួរធ្វើចីវរសេចក្តីប្រឹងប្រែងស្វែងរកសំពត់បង្សុកូល សំពត់ធ្លាក់ចុះក្បែរកេនផ្សារតាមត្រូវការ ។ ក៏ឯសំពត់បង្សុកូល នឹងសំពត់ធ្លាក់ចុះក្បែរកេនផ្សារ មិនមានកំណត់ សូម្បីមួយរយជាន់ក៏គួរ សំពត់ទាំងអម្បាលនេះព្រះអង្គអនុញ្ញាតទុកដល់ភិក្ខុដែលត្រេកអរ ។

ក៏ឯត្រៃចីវរនេះ កាលសំពត់ដែលនឹងកាត់ទាំង ៣ ផ្ទត់មិនគ្រាន់ គប្បីធ្វើជាសំពត់កាត់ ២ ផ្ទត់ ធ្វើសំពត់មិនបានកាត់មួយផ្ទត់ ។ បើសំពត់ដែលនឹងកាត់មិនគ្រាន់ ២ ផ្ទត់សោត ឲ្យធ្វើជាសំពត់មិនបានកាត់ ២ ផ្ទត់ ធ្វើជាសំពត់កាត់មួយផ្ទត់ ។ ដ្បិតទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ ទ្វេ ឆិន្នកានិ ឯកំ អច្ឆិន្នកំ ។ អនុជានាមិ ភិក្ខវេ ទ្វេ អច្ឆិន្នកានិ ឯកំ ឆិន្នកំ ដូច្នេះ ។ បើកាត់សូម្បីតែមួយផ្ទត់មិនគ្រាន់ ឲ្យភ្ជាប់សំពត់អន្វាធិកៈ គឺកាតត្តកបដៈ ផ្ទាំងសំពត់បន្ទាបចូល នឹងមិនកាត់សោះ សូម្បីមួយផ្ទត់មិនគួរ ។ ដ្បិតទ្រង់អនុញ្ញាតនឹងឃាត់ទុកថា អនុជានាមិ ភិក្ខវេ អន្វាធិកំ បិ អារោបេតុំ ន ច ភិក្ខវេ សព្វំ អច្ឆិន្នកំ ធារេតព្វំ ... ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុលើកឡើង (គឺបះ) បន្ទាបទៀត ក៏ប៉ុន្តែ ភិក្ខុកុំគប្បីទ្រទ្រង់សំពត់មិនបានកាត់ទាំងអស់ឡើយ បើភិក្ខុណាទ្រទ្រង់សំពត់ដូច្នោះ ត្រូវទុក្កដ ។ ក៏ឯសំពត់បន្ទាបនេះ បើសំពត់

www.budinst.gov.kh www.elibraryofcambodia.org

ដែលនឹងធ្វើមិនល្មមគ្រាន់ គប្បីលើកឡើងបន្ទាប់ចុះ បើសំពត់ដែលនឹងធ្វើ ល្មមគ្រាន់ អាគន្តុកបដៈគឺសំពត់បន្ទាប់មិនគួរ គប្បីកាត់ឲ្យបានតែម្យ៉ាង ។

នឹងពោលអំពីប្រមាណ ឯប្រមាណនៃត្រៃចីវរនោះ កំណត់ដោយ ឧក្រិដ្ឋយ៉ាងធំ ត្រូវឲ្យតូចជាងសុគតចីវរទើបគួរ កំណត់យ៉ាងតូចសំពត់ សង្ឃាដីនិងសំពត់ឧត្តរាសង្គៈ ពីរនេះ ដោយវែង ៤ ហត្ថ ១ តក់ គឺកំស់ បាន ៤ ហត្ថហើយ មួយតក់ទៀតជាតំរប់ ៥ ទទឹង ២ ហត្ថ និងមួយតក់ ដូចមុនទើបគួរ ។ ចំណែកសំពត់អន្តរវាសកៈ ដោយវែង ៤ ហត្ថនិងមួយតក់ ទទឹងសូម្បី ២ ហត្ថក៏គួរ ដ្បិតជាគាបដើម្បីបិទនូវមណ្ឌលផ្ចិត ដោយ ស្បៀកនិងដណ្តប់ ។ សំពត់ដែលធំនិងតូចជាងប្រមាណ ដូចពោល ហើយនោះ មិនគួរអធិដ្ឋានជាត្រៃចីវរ ។

សំពត់ដែលធ្វើហើយ គប្បីជ្រលក់ដោយទឹកជ្រលក់ ៦ យ៉ាង គឺ ទឹកជ្រលក់កើតអំពីឫស និងមើមនៃឈើទាំងពួង លើកតែ ហលិទ្ទ រមៀតនិងព្រះអង្កោលចេញ ក្រៅពីនោះគួរទាំងអស់ ។ ទឹកជ្រលក់ កើតអំពីដើមឈើទាំងពួង លើកតែ មញ្ជដ្ឋ ស្បែង តុង្គហារ យ៉ៅ ពីនេះចេញ ក្រៅនោះគួរទាំងអស់ ។ ឈើមានបន្លាមួយយ៉ាងនោះ ឈ្មោះថា តុង្គហារ ទឹកជ្រលក់កើតអំពីដើមឈើនោះ ពណ៌ដូចហរ-ដាល ។ ទឹកជ្រលក់កើតអំពីសម្បកឈើទាំងពួង លើកតែ លោទ្ធ សម្បកលោទ្ធ គណ្ឌាលី សម្បកព្រហូត ទាំងពីរនេះចេញ ក្រៅពី នោះគួរទាំងអស់ ។ ទឹកជ្រលក់កើតអំពីស្លឹកឈើទាំងពួង លើកតែ

www.budinst.gov.kh www.elibraryofcambodia.org

អល្លិបត្តំ ស្លឹកមក្រៀ ឯលបត្តំ ស្លឹកត្រុំ ពីរនេះចេញ ក្រៅពីនោះគួរទាំងអស់ ។ តែសំពត់ដែលគ្រហស្ថបរិភោគហើយនោះ នឹងជ្រលក់ដោយស្លឹកអល្លិបត្តមុនក៏គួរ ។

ទឹកជ្រលក់កើតអំពីផ្កាឈើទាំងពួង លើកតែ កិំសុកបុប្ផំ ផ្កាចារ ១ កុសុម្ភបុប្ផំ ផ្កាដកគាំ ១ ទាំង ២ នេះចេញ ក្រៅពីនោះគួរទាំងអស់ ។

ទឹកជ្រលក់កើតអំពីផ្លែឈើទាំងពួង ដែលមិនគួរនោះមិនមានឡើយ បាលីដែលទ្រង់អនុញ្ញាតទឹកជ្រលក់នោះថា អនុជានាមិ ភិក្ខវេ ឆ រជនានិ មូលរជនំ ខន្ធរជនំ តចរជនំ បត្តរជនំ បុប្ផរជនំ ផលរជនន្តិ ដូច្នេះ ។

ទឹកជ្រលក់ដែលឃាត់នោះ តាមអដ្ឋកថា ថា ទឹកជ្រលក់ទាំង ៦ នេះ ជ្រលក់ទៅហើយឲ្យផុតចាកពណ៌ដែលទ្រង់ឃាត់ទុក ៧ ប្រការ មានពណ៌ខៀវជាដើម ដូចពោលហើយក្នុងចីវរបដិសំយុត្ត ទើបឲ្យផុតចាកពណ៌ដូចក្នុកដំរី ទើបចំរើន អម្បាលនេះចេញទើបគួរ អាការដែលនឹងជ្រលក់សំពត់នោះ គប្បីបដិបត្តិដូចពោលហើយក្នុងបរិក្ខារកថានោះចុះ ។

ជ្រលក់ហើយគប្បីធ្វើកប្បពិន្ទុ ដោយវត្ថុខៀវ ឬភក់ ឬវត្ថុខ្មៅណាមួយ ក្នុងទីណាមួយ លើកតែក្រវិលក្តុំចេញ ឲ្យធំប៉ុនភ្នែកក្ងោកដោយពាក្យថា ឥមំ ពិន្ទុកប្បំ ករោមិ ដូច្នេះហើយគប្បីអធិដ្ឋានចុះ ។

www.budinst.gov.kh www.elibraryofcambodia.org

គឺឯអធិដ្ឋានបរិក្ខារមានពីរ គឺអធិដ្ឋានដោយកាយ ១ អធិដ្ឋានដោយវាចា ១ ។ បើសំពត់សង្ឃាដីចាស់មាន គប្បីដកអធិដ្ឋានចេញដោយពាក្យថា ឥមំ សង្ឃាដឹ បច្ចុទ្ធរាមិ ខ្ញុំដកនូវសំពត់សង្ឃាដីនេះ ហើយយកដៃពាល់សំពត់សង្ឃាដីថ្មី ឬដំកល់ទុកលើអវយវៈខ្លួនហើយ ធ្វើការភោគចិត្តថា ឥមំ សង្ឃាដឹ អធិដ្ឋាមិ យើងអធិដ្ឋានសំពត់សង្ឃាដីផ្ទត់នេះ ធ្វើនូវកាយវិការ អធិដ្ឋានដោយកាយចុះ ដូច្នេះឈ្មោះថាអធិដ្ឋានដោយកាយ អធិដ្ឋានដោយកាយនោះ ទឹងមិនពាល់ត្រូវដោយអវយវៈខ្លួនណាមួយមិនគួរ ។ ឯអធិដ្ឋានដោយវាចានោះ គប្បីធ្វើវិកេចអធិដ្ឋានដោយពាក្យថា ឥមំ សង្ឃាដឹ អធិដ្ឋាមិ ដូច្នេះ ។ អធិដ្ឋានដោយវាចាមាន ២ គឺ ក្នុងហត្ថបាស ១ ក្រៅហត្ថបាស ១ ។ បើសំពត់នៅក្នុងហត្ថបាសឲ្យបញ្ចេញវាចាថា ឥមំ សង្ឃាដឹ អធិដ្ឋាមិ ដូច្នេះ ។ បើសំពត់នៅខាងក្នុងល្វែង ឬលើប្រាសាទ ឬក្នុងកុដិ ជិតឆ្ងាយ ត្រូវកំណត់ទីដែលដំកល់ទុក ហើយបញ្ចេញវាចាថា ឯតំ សង្ឃាដឹ អធិដ្ឋាមិ យើងអធិដ្ឋានសំពត់សង្ឃាដីផ្ទត់នុ៎ះដូច្នេះចុះ ។ ការអធិដ្ឋានឧត្តរាសង្គៈនិងអន្តរវាសកៈ ក៏ដូចគ្នាដែរ ប្លែកគ្នាតែឈ្មោះប៉ុណ្ណោះ ព្រោះហេតុនោះ សំពត់ទាំងពួង គប្បីបច្ចុទ្ធរនិងអធិដ្ឋានតាមឈ្មោះសំពត់នោះៗ ចុះ ។

ឯវិធីបច្ចុទ្ធរ (ដកអធិដ្ឋាន) នោះដូច្នេះគឺ :

បើចីពរទៅដកថា ឥមំ ឧត្តរាសង្គំ បច្ចុទ្ធរាមិ ។

www.budinst.gov.kh www.elibraryofcambodia.org

បើចីវរនៅឆ្ងាយថា ឯតំ ឧត្តរាសង្គំ បច្ចុទ្ធរាមិ ។

បើស្បង់នៅជិតថា ឥមំ អន្តរវាសកំ បច្ចុទ្ធរាមិ ។

បើស្បង់នៅឆ្ងាយថា ឯតំ អន្តរវាសកំ បច្ចុទ្ធរាមិ ។

ឯវិធីអធិដ្ឋាននោះដូច្នេះគឺ :

បើចីវរនៅជិតថា ឥមំ ឧត្តរាសង្គំ អធិដ្ឋាមិ ។

បើចីវរនៅឆ្ងាយថា ឯតំ ឧត្តរាសង្គំ អធិដ្ឋាមិ ។

បើស្បង់នៅជិតថា ឥមំ អន្តរវាសកំ អធិដ្ឋាមិ ។

បើស្បង់នៅឆ្ងាយថា ឯតំ អន្តរវាសកំ អធិដ្ឋាមិ ។

ត្រៃចីវរទាំងអធិដ្ឋានជាបរិក្ខារចោលៈ គួរ ឬមិនគួរ ?

មិនគួរ ។ ដ្បិតបានឮថា ព្រះមហាបទុមត្ថេរ លោកពោលទុកថា ត្រៃចីវរត្រូវអធិដ្ឋានជាត្រៃចីវរពិត ថាបើត្រៃចីវរអធិដ្ឋានជាបរិក្ខារចោលៈ បានសោត បរិហារការរក្សាត្រៃចីវរក្នុងឧទ្ទោសិតសិក្ខាបទ គឺនឹងទៅជាការឥតប្រយោជន៍ ពាក្យព្រះមហាបទុមត្ថេរពោលនេះប្រពៃពិត ។

គឺឯសំពត់ផ្ទិតទឹកភ្លៀងនឹងសំពត់គ្រាប់អង្គុយ នឹងសំពត់បិទបូស គម ៣ នេះ អាការដែលនឹងធ្វើ នឹងប្រមាណ គប្បីដឹងដូចពោលហើយក្នុងបាចិត្តិយនោះចុះ ។ តែសំពត់ក្រាលដេក សំពត់ជូតមុខ សំពត់បរិក្ខារចោលៈ ៣ នេះ វិធីដែលនឹងធ្វើ នឹងប្រមាណ ព្រះអដ្ឋកថាមិនបានពោលទុកក៏ទេ ។ សំពត់ផ្ទិតទឹកភ្លៀងដែលមិនលើសប្រមាណ គប្បីអធិដ្ឋានអស់ ៤ ខែក្នុងរដូវភ្លៀង ដោយន័យដូចពោលហើយនោះចុះ ។ ពាក្យ

www.budinst.gov.kh www.elibraryofcambodia.org

អធិដ្ឋានថា ឥមំ វស្សិកសាដិកំ អធិដ្ឋាមិ ដូច្នេះ ។ តាំងពីដើមខែភ្លៀងនោះទៅ គប្បីដកអធិដ្ឋានហើយវិកប្បទុក សំពត់ងូតទឹកភ្លៀងនេះ សូម្បីជ្រលក់ល្អមទំលាយពណ៌ក៏គួរ តែពីរផ្ទត់មិនគួរ ។

សំពត់ក្រាបអង្គុយ គប្បីអធិដ្ឋានដោយពាក្យថា ឥមំ និសីទនំ អធិដ្ឋាមិ ដូច្នេះ ។ ក៏ឯសំពត់ក្រាបអង្គុយនោះ ប្រកបដោយប្រមាណទើប មួយផ្ទត់ទើបគួរ ពីរផ្ទត់មិនគួរ ។ សូម្បីសំពត់ក្រាលដេកត្រូវអធិដ្ឋានពិត ពាក្យអធិដ្ឋានថា ឥមំ បច្ចត្ថរណំ អធិដ្ឋាមិ ដូច្នេះ ។ តែសំពត់ក្រាលដេក សូម្បីធំក៏គួរ សូម្បីមួយផ្ទត់ឬច្រើនក៏គួរ ។ ច្រើនគប្បីអធិដ្ឋានថា ឥមានិ បច្ចត្ថរណានិ អធិដ្ឋាមិ ដូច្នេះ ។ សំពត់ក្រាលដេកនេះ សូម្បីខៀវ ឬលឿង មានផាយ ឬមិនមានផាយ ដូចផ្កាឈើទាំងពួង គួរទាំងអស់ អធិដ្ឋានម្តងហើយក៏ឈ្មោះថា អធិដ្ឋានដោយពិត ។

សំពត់បិទបូស ប្រកបដោយប្រមាណ អាពាធមាននៅដរាបណា គប្បីអធិដ្ឋានដរាបនោះ ពាក្យអធិដ្ឋានថា ឥមំ កណ្ឌុបដិច្ឆាទឹ អធិដ្ឋាមិ ដូច្នេះ ។ កាលអាពាធរម្ងាប់ហើយ គប្បីបច្ចុទ្ធរដកចេញហើយ វិកប្បទុក សំពត់បិទបូសនេះគួរតែមួយផ្ទត់ប៉ុណ្ណោះ ។ សំពត់ជូតមុខត្រូវអធិដ្ឋានប្រាកដ ពាក្យអធិដ្ឋានថា ឥមំ មុខបុញ្ឆនចោលំ អធិដ្ឋាមិ ដូច្នេះ ។ សំពត់មួយបោកគក់នៅដរាបណា បើត្រូវការប្រើប្រាស់សំពត់ដទៃទៀត ប្រើប្រាស់បានដរាបនោះ ព្រោះហេតុនោះ សំពត់ជូតមុខនេះ សូម្បីពីរផ្ទត់ក៏គួរ ។

www.budinst.gov.kh www.elibraryofcambodia.org

សំពត់បរិក្ខារចោលៈ សម្បីជាថង់បាត្រ នឹងសំពត់ត្រងទឹក ដែលមានប្រមាណប៉ុនបច្ចិមចីវរដែលគួរវិកប្ប ត្រូវអធិដ្ឋានជាបរិក្ខារចោលៈ ដោយពិត ពាក្យអធិដ្ឋានថា ឥមំ ចីវរំ បរិក្ខារចោឡំ អធិដ្ឋាមិ ដូច្នេះ ។ បើច្រើនសម្បីនឹងរួមចូលគ្នាអធិដ្ឋានថា ឥមានិ ចីវរានិ បរិក្ខារចោឡានិ អធិដ្ឋាមិ ដូច្នេះ ក៏គួរពិត ។ តែកង ពូក ខ្នើយ គ្រែ តាំង សំពត់បាវារៈ សំពត់កោជវៈ អម្បាលនេះក្តី នឹងសំពត់បច្ចត្ថរណៈ គ្រឿងក្រាល ដែលគេប្រគេន ដើម្បីជាបរិក្ខារនៃសេនាសនៈក្តី អម្បាលនេះ កិច្ចដែលនឹងអធិដ្ឋានមិនមានឡើយ ។ សំពត់ដែលអធិដ្ឋានទាំងពួង បើមួយផ្ទត់នៅក្រៅហត្ថបាសឲ្យថា ឯតំ ជូស ឥមំ បើច្រើនផ្ទត់ឲ្យថា ឯតានិ ជូស ឥមានិ ដូច្នេះចុះ ។

វិធីផ្ទត់របស់អធិដ្ឋានមួយ ៗ ថាដូច្នេះ ៖

ឥមំ សង្ឃាដឹ បច្ចុទ្ធរាមិ ។

ឥមំ ឧត្តរាសង្គំ បច្ចុទ្ធរាមិ ។

ឥមំ អន្តរវាសកំ បច្ចុទ្ធរាមិ ។

ឥមំ និសីទនំ បច្ចុទ្ធរាមិ ។

ឥមំ វស្សិកសាដិកំ បច្ចុទ្ធរាមិ ។

ឥមំ កណ្ឌុប្បដិច្ឆាទឹ បច្ចុទ្ធរាមិ ។

ឥមំ បច្ចត្ថរណំ បច្ចុទ្ធរាមិ ។

ឥមំ មុខបុញ្ឆនចោឡំ បច្ចុទ្ធរាមិ ។

www.budinst.gov.kh www.elibraryofcambodia.org

ឥមំ បរិក្ខារចោឡំ បច្ចុទ្ធរាមិ ។ បើដកកម្រាល ច្រើនថា ឥមានិ បច្ចត្ថរណានិ បច្ចុទ្ធរាមិ ។ បើដកកន្សែងជូតមុខច្រើនថា ឥមានិ មុខបុញ្ឆនចោឡានិ បច្ចុទ្ធរាមិ ។ បើដកបរិក្ខារចោឡៈច្រើនថា ឥមានិ បរិក្ខារចោឡានិ បច្ចុទ្ធរាមិ ។

វិធីអធិដ្ឋាននិងបច្ចុទ្ធរសំពត់ចប់

## វិកប្បនកថា

ពណ៌នាអំពីវិធីវិកប្បសំពត់ ។ ឯវិធីវិកប្បនោះ គប្បីដឹងដូច្នេះ សំពត់ក្រៅពីសំពត់ដែលទ្រង់អនុញ្ញាតឲ្យអធិដ្ឋានទាំង ៧ យ៉ាង មានប្រមាណល្មមបានបច្ឆិមចីវរ ត្រូវវិកប្បទានក្នុង ១០ ថ្ងៃ ព្រោះទ្រង់អនុញ្ញាតថា អនុជានាមិ ភិក្ខវេ អតិរេកចីវរំ វិកប្បេតុំ ។ អនុជានាមិ ភិក្ខវេ អាយាមេន អដ្ឋង្គុលំ សុគតង្គុលេន ចតុរង្គុលវិត្ថតំ បច្ឆិមំ ចីវរំ វិកប្បេតុំ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យវិកប្បសំពត់អតិរេកចីវរ ។ តថាគតអនុញ្ញាតឲ្យវិកប្បសំពត់បច្ឆិមចីវរ គឺសំពត់យ៉ាងតូចបំផុតបណ្ដោយ ៨ ធ្នាប់ ទទឹង ៤ ធ្នាប់ ដោយធ្នាប់ព្រះសុគត ។ គឺសំពត់យ៉ាងតូចគួរវិកប្បនោះ ពោលតាមសុគតវិទត្ថិបានបករណៈថា ប្រមាណដោយធ្នាប់ផងឈើសព្វថ្ងៃនេះ *បណ្ដោយ ១០ ធ្នាប់ និង ៣ ក្បៀស ទទឹង ៥ ធ្នាប់ និង ១ ក្បៀស ២ អនុក្បៀស ។

www.budinst.gov.kh www.elibraryofcambodia.org

មួយទៀត សំពត់ឆ្នូតទឹកភ្លៀង សំពត់ប៉ះបូស ផុតកាលអធិដ្ឋាន ហើយ គប្បីវិកប្បដូចគ្នាដែរ ។

វិធីវិកប្បមាន ២ យ៉ាងគឺ វិកប្បចំពោះមុខ ១ វិកប្បកំបាំងមុខ ១ ។ វិកប្បចំពោះមុខនោះដូច្នេះ គប្បីដឹងថាសំពត់មួយផ្នត់ ឬច្រើនផ្នត់ ទីង តាំងនៅក្នុងទីជិតហត្ថបាសឬឆ្ងាយហត្ថបាស ។ បើមួយផ្នត់នៅក្នុងហត្ថ-បាស គប្បីពោលថា ឥមំ ចីវរំ ។ ច្រើនផ្នត់ថា ឥមានិ ចីវរានិ ។ បើមួយផ្នត់នៅឆ្ងាយគប្បីពោលថា ឯតំ ចីវរំ ។ ច្រើនផ្នត់ថា ឯតានិ ចីវរានិ ហើយចុះចុងពាក្យថា តុយ្ហំ វិកប្បេមិ ដូច្នេះគ្រប់ៗបទក្នុងសំណាក់ភិក្ខុមួយអង្គចុះ នេះឈ្មោះថាវិកប្បចំពោះមុខម្យ៉ាង ដោយវិកប្បប៉ុណ្ណេះនឹងទុកដាក់ក៏គួរ នឹងបរិភោគ ឬលះបង់ ឬអធិដ្ឋាន មិនគួរការលុះបើអ្នកទទួលវិកប្បពោលថា ឥមំ ចីវរំ មយ្ហំ សន្តកំ ឬថា ឥមានិ ចីវរានិ មយ្ហំ សន្តកានិ តាមផ្នត់មួយ នឹងច្រើន ហើយចុះចុងពាក្យថា បរិភុញ្ជ វា វិស្សជ្ជេហិ វា យថាបច្ចយំ វា ករោហិ ដូច្នេះហើយ ឈ្មោះថាបច្ចុទ្ធរេក តាំងអំពីបច្ចុទ្ធរេកហើយ សូម្បីនឹងបរិភោគ ជាដើមក៏គួរ ។

ម្យ៉ាងទៀត គប្បីដឹងថា សំពត់មួយផ្នត់ ឬច្រើនផ្នត់ ដែលតាំងនៅក្នុងទីជិត ឬឆ្ងាយ ។ ជិតពោលថា ឥមំ ចីវរំ ឬថា ឥមានិ ចីវរានិ ។ ឆ្ងាយថា ឯតំ ចីវរំ ឬថា ឯតានិ ចីវរានិ ដូចមុនក្នុងសំណាក់ភិក្ខុមួយអង្គ ហើយកាន់យកឈ្មោះនៃសហធម្មិកទាំង ៥ ណា

www.budinst.gov.kh www.elibraryofcambodia.org

មួយ ដែលខ្លួនគាប់ចិត្ត ដែលមិននៅក្នុងទីនោះ ទើបចុះចុងពាក្យថា តិស្សស្ស ភិក្ខុនោ វិកប្បេមិ ឬថា តិស្សស្ស សាមណេរស្ស វិកប្បេមិ ដូច្នេះ តាមឈ្មោះសហធម្មិក ដែលខ្លួនគាប់ចិត្តនោះគ្រប់ ៗ បទ ក្នុងសំណាក់ភិក្ខុមួយអង្គនោះ សូម្បីដូច្នេះក៏ឈ្មោះថា វិកប្បចំពោះមុខ ម្យ៉ាងទៀតដូចគ្នា ។ ប៉ុន្តែទុកដាក់ ដោយវិកប្បប៉ុណ្ណោះក៏គួរ តែក្នុងកិច្ចមានបរិភោគជាដើម សូម្បីតែវត្ថុណាមួយ ក៏មិនគួរ កាលបើភិក្ខុដែលទទួលវិកប្បចំពោះមុខនោះ ពោលថា តិស្សស្ស ភិក្ខុនោ សន្តកំ ។ល។ តិស្សស្ស សាមណេរស្ស សន្តកំ បរិភុញ្ជ វា វិស្សជ្ជេហិ វា យថាបច្ចយំ វា ករោហិ ដូច្នេះ តាមឈ្មោះសហធម្មិកដែលវិកប្បទុកនោះហើយ ទើបបានឈ្មោះថាបច្ចុទ្ធរក តាំងអំពីបច្ចុទ្ធរកហើយ សូម្បីនឹងបរិភោគជាដើមក៏គួរ ។

វិកប្បកំបាំងមុខនោះដូច្នេះ គប្បីដឹងថា សំពត់មួយផ្ទត់ ឬច្រើនផ្ទត់ ដែលតាំងនៅក្នុងទីជិត ឬឆ្ងាយ ។ បើនៅជិតពោលថា ឥមំ ចីវរំ ឬថា ឥមានិ ចីវរានិ ។ បើនៅឆ្ងាយពោលថា ឯតំ ចីវរំ ឬថា ឯតានិ ចីវរានិ ដូចមុន ហើយទើបចុះចុងពាក្យថា តុយ្ហំ វិកប្បនត្ថាយ ទម្មិ ដូច្នេះ ក្នុងសំណាក់ភិក្ខុមួយអង្គចុះ ភិក្ខុនោះគប្បីសួរម្ចាស់សំពត់ថា សហធម្មិកណាធ្លាប់ជាមិត្ត ជាសំឡាញ់គ្នា ឬជាមិត្តធ្លាប់បរិភោគជាមួយគ្នានឹងលោកដូច្នេះ ហើយម្ចាស់សំពត់គប្បីប្រាប់ឈ្មោះតាមគាប់ចិត្ត

ថាភិក្ខុឈ្មោះតិស្ស ឬសាមណេរឈ្មោះតិស្ស ជាមិត្រសំឡាញ់នៃខ្ញុំដូច្នេះ តាមគាប់ចិត្តខ្លួនហើយ ភិក្ខុអ្នកទទួលវិកប្បនោះ គប្បីពោលទៀតថា អហំ តិស្សស្ស ភិក្ខុនោ ធម្មំ ឬថា អហំ តិស្សស្ស សាមណេរស្ស ធម្មំ ដូច្នេះ តាមឈ្មោះដែលម្ចាស់សំពត់ប្រាប់នោះចុះ ដូច្នេះឈ្មោះថា វិកប្បកំបាំងមុខ នឹងទុកដាក់ដោយវិកប្បប៉ុណ្ណោះក៏គួរ ៗ កិច្ចមានបរិភោគជាដើម សូម្បីតែកិច្ចណាមួយក៏មិនគួរ លុះតែកាលណាភិក្ខុអ្នកជួយទទួលវិកប្បនោះ ពោលពាក្យជាដើមថា តិស្ស-ស្ស ភិក្ខុនោ សន្តកំ បរិភុញ្ជ វា វិស្សជ្ជេហិ វា យថា-បច្ចយំ វា ករោហិ ដោយន័យដូចពោលហើយក្នុងវិកប្បចំពោះមុខបទគំរប់ ២ នោះហើយ ទើបឈ្មោះថាបច្ចុទ្ធរដក តាំងអំពីបច្ចុទ្ធរដកហើយ សូម្បីនឹងបរិភោគជាដើមក៏គួរ ៗ

បុ. វិកប្បចំពោះមុខនឹងកំបាំងមុខ ទាំង ២ នោះ ប្លែកគ្នាដូចម្តេច ?

វិ. ក្នុងវិកប្បចំពោះមុខនោះ វិកប្បដោយខ្លួនឯងនឹងឲ្យអ្នកដទៃដក ក្នុងវិកប្បកំបាំងមុខនោះ ឲ្យអ្នកដទៃវិកប្បឲ្យ ឲ្យអ្នកដទៃដកឲ្យ វិកប្បពីរយ៉ាងនេះ ប្លែកគ្នាដូច្នេះ បើនឹងវិកប្បដល់អ្នកណា អ្នកនោះជាមនុស្សមិនឈ្លាសក្នុងបញ្ញត្តិ មិនដឹងនូវកិច្ចដែលដក គប្បីកាន់យកសំពត់នោះទៅរកភិក្ខុដទៃដែលជាមនុស្សឈ្លាស គប្បីវិកប្បថែមទៀតហើយ ឲ្យភិក្ខុនោះដកឲ្យ វិកប្បថែមទៀត នូវសំពត់ដែលវិកប្បទុកហើយនោះរមែងគួរ ៗ ក្នុងវិមតិវិនោទនីពោលថា ឯពាក្យក្នុងអដ្ឋកថា ពោលថាតាំងអំពី

www.budinst.gov.kh www.elibraryofcambodia.org

បច្ចុទ្ធរដកហើយទៅ សូម្បីនឹងបរិភោគជាដើមរមែងគួរ ពាក្យនេះសំដែងថាសូម្បីធ្វើការបច្ចុទ្ធរដកហើយ សំពត់នោះក៏គង់ជាសំពត់វិកប្បនៅដូចដែល នឹងត្រឡប់ទៅជាអតិរេកចីវរវិញមិនបាន តែសំពត់នោះភិក្ខុប្រាថ្នានឹងអធិដ្ឋានដោយឈ្មោះនៃត្រៃចីវរជាដើម គប្បីអធិដ្ឋានចុះ បើភិក្ខុមិនប្រាថ្នានឹងអធិដ្ឋាន ក៏គប្បីធ្វើឲ្យជាសំពត់វិកប្បនៅដូចនោះ បរិភោគចុះ ពោលដូច្នេះហើយឃាត់ពាក្យអាចារ្យពួកខ្លះ ដែលពោលថា វិកប្បហើយបានតែទុកមួយយ៉ាង បើដកវិកប្បហើយ គប្បីអធិដ្ឋានបរិភោគដូច្នេះ ព្រោះអាងហេតុនឹងឧទាហរណ៍ផ្សេង ៗ សេចក្ដីសន្និដ្ឋថា វិកប្បហើយឲ្យដកវិកប្បចេញ ហើយបរិភោគចុះ សូម្បីកន្លង ១០ ថ្ងៃទៅមិនត្រូវនិស្សគ្គិយ អ្នកមានបញ្ញាគប្បីពិចារណាយកចុះ ។

វិកប្បកថា ចប់

---

អធិដ្ឋាននឹងវិកប្ប ២ នេះ គប្បីធ្វើក្នុងសំពត់អតិរេកចីវរតែខាងក្នុង ១០ ថ្ងៃ បើទុកឲ្យកន្លង ១០ ថ្ងៃទៅ សំពត់នោះជានិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយ ដោយឧបមាកឋិនសិក្ខាបទ ។

វិធីអធិដ្ឋាននិងវិកប្បចីវរ ចប់

---

## វិធីអធិដ្ឋានបាត្រ

ពណ៌នាអំពីវិធីអធិដ្ឋានបាត្រ ។ បាត្រដែក បាត្រដី ប្រកបដោយប្រមាណ ទើបគួរអធិដ្ឋាននឹងវិកប្ប ។ ប្រមាណនៃបាត្រ មាន ៣ គឺ

www.budinst.gov.kh www.elibraryofcambodia.org

ឧក្កដ្ឋោ បាត្រខ្នាតធំ១ មជ្ឈិមោ បាត្រខ្នាតកណ្ដាល១ ឱមកោ បាត្រខ្នាតតូច១ ។ បាត្រខ្នាតធំនោះ ចុះបាយនៃអង្ករកន្លះអាឡ្ហកៈ គឺអង្ករ២នាឡិមគធៈ ។ ក្នុងអន្ធកដ្ឋកថា គោលទុកថា ឯនាឡិមគធៈនោះ១២បលៈកន្លះ ។ ក្នុងមហាអដ្ឋកថា គោល បកតិណាឡី នាឡិដោយប្រក្រតី ក្នុងសីហឡទ្វីបគឺធំពេកទៅ ទមិឡនាឡី នាឡិទមិឡៈគឺតូចពេកទៅ មគធនាឡី នាឡិមគធទើបប្រកបដោយប្រមាណ មួយនាឡិកន្លះនៃនាឡិមគធៈនោះ ត្រូវជាមួយនាឡិក្នុងសីហឡៈ ។ ឯវិធីដែលនឹងគិតបលៈនឹងប្រមាណ មគធនាឡិតាមដីកា នឹងគម្ពីរដ៏សេស នឹងទុកគោលក្នុងទីបំផុតនៃវណ្ណនាទាំងពួង ។ ប្រមាណបាត្រខ្នាតធំ ឲ្យយកអង្ករនៃស្រូវសាលីដែលមិនបាក់ ដែលចាស់កន្លងឆ្នាំ គេស្រិតបរិសុទ្ធល្អ ហើយវាល់ឲ្យបាន ២ នាឡិមគធៈដូចពោលហើយនោះ ដណ្ដាំកុំឲ្យដាក់ទឹកចេញ កុំឲ្យនៅពន់បន្តិយ កុំឲ្យជ្រាយ កុំឲ្យជាដុំ ឲ្យស្រួយស្រស់ដាច់ចាកគ្នា បីដូចកន្ទ្រុន នឹងផ្កាម្លិះក្រពុំ ហើយដាក់ចុះក្នុងបាត្រឲ្យអស់ យកសំឡសណ្ដែកដែលផ្សំដោយគ្រឿងទាំងពួង មិនខាប់ណាស់ មិនរាវណាស់ល្មមចាប់ដោយដៃបាន ស្មើចំណែកគំរប់ ៤ នៃបាយនោះដាក់ចុះផង ហើយយកម្ហូបមានត្រីនឹងសាច់ជាដើម ដ៏សមគួរដល់ពំនូត ។ ដរាបល្មមគ្រាន់ដល់ពំនូតជាបំផុត គឺស្មើចំណែកគំរប់ ៤ នៃបាយដាក់ចុះផង វៀរសប្បិនឹងប្រេងនឹងខ្លាញ់នឹងទឹកសំឡ នឹងទឹកជ្រក់ជាដើម នឹងរាប់ចូលផងមិនបាន ដ្បិតជាវត្ថុទាំងអម្បាលនោះ ជាគតិនៃបាយ

www.budinst.gov.kh www.elibraryofcambodia.org

មិនកេចឲ្យបាយជាយនឹងចំរើនឡើងបាន វត្ថុតាំងពួងនោះដាក់ចុះហើយ ផ្ងូរច្បាះបើល្មមស្មើកណ្ដាប់មាត់បាត្រខាងក្រោម យកអម្បោះ ឬដក់ត្នោត គៀរទៅល្មមចំណែកខាងក្រោមនៃអម្បោះទីងដក់ត្នោត ត្រូវវត្ថុក្នុងបាត្រ ដោយពិត បាត្រដូច្នេះឈ្មោះថាបាត្រខ្នាតធំយ៉ាងកណ្ដាល ។ បើវត្ថុក្នុងបាត្រនោះពូនលើសកណ្ដាប់មាត់បាត្រឡើងមកលោក បាត្រដូច្នេះឈ្មោះថាបាត្រខ្នាតធំយ៉ាងតូច ។ បើវត្ថុក្នុងបាត្រនោះមិនដល់កណ្ដាប់មាត់បាត្រ ស្រុតចុះទៅនៅក្នុងបាត្រលោក បាត្រដូច្នេះឈ្មោះថាបាត្រខ្នាតធំយ៉ាងធំ ។

បាត្រខ្នាតកណ្ដាលនោះ ឲ្យយកអង្ករមួយនាឡិមគធៈ ដណ្ដាំឡើងដូចមុនដាក់ចុះ យកសំឡសណ្ដែកស្មើចំណែកគំរប់ ៤ នៃបាយ ទីងមួយមានគ្រឿសាច់ជាដើម ក៏ស្មើចំណែកគំរប់ ៤ នៃបាយ វត្ថុអម្បាលនេះដាក់ចុះក្នុងបាត្រទាំងអស់ បើស្មើកណ្ដាប់មាត់បាត្រខាងក្រោមដូចពោលហើយក្នុងមុន បាត្រដូច្នេះឈ្មោះថាបាត្រខ្នាតកណ្ដាលយ៉ាងកណ្ដាល ។ បើវត្ថុនោះកំពូនមាត់បាត្រឡើងមកលោក បាត្រដូច្នេះឈ្មោះថាបាត្រខ្នាតកណ្ដាលយ៉ាងតូច ។ បើវត្ថុនោះមិនដល់កណ្ដាប់មាត់បាត្រស្រុតចុះទៅនៅក្នុងបាត្រលោក បាត្រដូច្នេះឈ្មោះថាបាត្រខ្នាតកណ្ដាលយ៉ាងធំ ។

បាត្រខ្នាតតូចនោះ ឲ្យយកអង្ករកន្លះនាឡិមគធៈ ដណ្ដាំឡើងដូចមុនដាក់ចុះក្នុងបាត្រ យកសំឡសណ្ដែកស្មើចំណែកគំរប់ ៤ នៃបាយ ទីងមួយមានគ្រឿសាច់ជាដើម ក៏ស្មើចំណែកគំរប់ ៤ នៃបាយ វត្ថុទាំងពួងនេះ

www.budinst.gov.kh www.elibraryofcambodia.org

ដាក់ចុះក្នុងបាត្រទាំងអស់ហើយ បើស្មើកណ្ដាប់មាត់បាត្រខាងក្រោមដូចមុន បាត្រដូច្នេះឈ្មោះថា បាត្រខ្នាតតូចយ៉ាងកណ្ដាល ។ បើវត្ថុនោះកំពុងមាត់បាត្រឡើងមកសោត បាត្រដូច្នេះឈ្មោះថាបាត្រខ្នាតតូចយ៉ាងតូច ។ បើវត្ថុនោះមិនដល់កណ្ដាប់មាត់បាត្រ ស្រុតចុះទៅនៅក្នុងបាត្រសោត បាត្រដូច្នេះឈ្មោះថាបាត្រខ្នាតតូចយ៉ាងធំ ។ ត្រូវជាបាត្រប្រកបដោយខ្នាត ៩ យ៉ាងដូច្នេះ ។

ឯបាត្រខ្នាតធំយ៉ាងធំ បាត្រខ្នាតតូចយ៉ាងតូច ពីរនេះមិនឈ្មោះថាជាបាត្រ គប្បីប្រើជាភាជនៈចុះ មិនគួរអធិដ្ឋាន មិនគួរវិកប្ប តែបាត្រ ៧ ក្រៅនោះ គប្បីអធិដ្ឋាន ឬវិកប្ប អំពីខាងក្នុង ១០ ថ្ងៃបរិភោគចុះ បើទុកឲ្យកន្លង ១០ ថ្ងៃទៅ បាត្រនោះត្រូវនិស្សគ្គិយ ភិក្ខុត្រូវបាចិត្តិយដោយបត្តសិក្ខាបទ ។

បាត្រសូម្បីប្រកបដោយប្រមាណ គឺគប្បីដឹងថាគួរអធិដ្ឋាននិងវិកប្បដូច្នេះទៀត បាត្រដែកដុតហើយ ៥ ភ្លើង បាត្រដីដុតហើយ ២ ភ្លើង ទើបគួរអធិដ្ឋាន ។ បាត្រទាំង ២ នោះ សូម្បីដំឡៃ គឺគប្បីឲ្យឲ្យហើយ បើដុតសូម្បីខ្វះមួយភ្លើង ឬដំឡៃខ្វះសូម្បីមួយកាកណិកមិនទាន់បានឲ្យ គឺនៅមិនគួរអធិដ្ឋាន បើម្ចាស់បាត្រ គេពោលថា កាលណាដំឡៃរបស់លោកមាន លោកគឺចូរឲ្យកាលនោះ លោកចូរអធិដ្ឋានបរិភោគចុះ សូម្បីដូច្នេះ គឺមិនគួរអធិដ្ឋានឡើយ ដ្បិតនឹងរាប់ថាជាបាត្រមិនបាន ព្រោះដុតនៅស្មើរភ្លើង នឹងនៅមិនទាន់ជារបស់នៃខ្លួន

www.budinst.gov.kh www.elibraryofcambodia.org

នៅជារបស់អ្នកដទៃនៅឡើយ ព្រោះដាំខ្យល់ឲ្យតាំងអស់ ឬតែមួយចំណែក មិនទាន់បានឲ្យ ព្រោះហេតុនោះ កាលដុតហើយ ឬមានដាំខ្យល់ឲ្យអស់ហើយ ទើបគួរអធិដ្ឋាន ។

បាត្រណាគួរអធិដ្ឋាន បាត្រនោះឯងគួរវិកប្ប បាត្រនោះមកដល់ដៃហើយ ឬនៅមិនទាន់មកដល់ក្តី គប្បីអធិដ្ឋានឬវិកប្ប អំពីខាងក្នុង ១០ ថ្ងៃ ។ បើជាងបាត្រគេបានថ្លៃឈ្នួលហើយ ឬគេប្រាថ្នាដើម្បីធ្វើប្រគេនដោយខ្លួនឯង គេប្រាប់ថា ខ្ញុំព្រះករុណានឹងធ្វើបាត្រហើយនឹងដុតក្នុងថ្ងៃឯណោះ តាំងទុកដូច្នេះ តាំងអំពីថ្ងៃដែលជាងបាត្រគេកំណត់ទុក ភិក្ខុឲ្យកន្លង ១០ ថ្ងៃទៅ បាត្រនោះជានិស្សគ្គិយ ខ្លួនត្រូវបាចិត្តិយ ។ ថាបើជាងបាត្រគេពោលថា ខ្ញុំព្រះករុណានឹងធ្វើបាត្រដុតស្រេចហើយ នឹងបញ្ជូនដំណឹងទៅដល់លោកដូច្នេះ ហើយគេធ្វើដូច្នោះ តែភិក្ខុដែលជាងបាត្រផ្ញើមក មិនប្រាប់ដល់ភិក្ខុម្ចាស់បាត្រនោះ ភិក្ខុដទៃបានឃើញ ឬបានឮ មកប្រាប់ថាបាត្ររបស់លោកសម្រេចហើយដូច្នេះ ពាក្យនៃភិក្ខុដទៃនោះ មិនជាប្រមាណ លុះតែកាលណាភិក្ខុដែលជាងបាត្រគេផ្ញើមកឲ្យប្រាប់ បានប្រាប់ដល់ម្ចាស់របស់បាត្រហើយ តាំងអំពីថ្ងៃបានឮពាក្យនៃភិក្ខុប្រាប់នោះទៅ កាលឲ្យកន្លង ១០ ថ្ងៃទៅ ជានិស្សគ្គិយបាចិត្តិយ ។ បើជាងបាត្រគេថា ខ្ញុំព្រះករុណានឹងធ្វើបាត្រ ដុតស្រេចហើយនឹងផ្ញើក្នុងដៃនៃភិក្ខុឲ្យនាំបាត្រនោះមកប្រគេនដល់លោក ដូច្នេះហើយ គេធ្វើដូច្នោះ តែភិក្ខុអ្នកទទួលបាត្រមក យកទៅទុកដាក់ក្នុងបរិវេណនៃខ្លួន

www.budinst.gov.kh www.elibraryofcambodia.org

សិន មិនប្រាប់ដល់ភិក្ខុម្ចាស់បាត្រ ភិក្ខុដទៃសួរថាបាត្ររបស់លោកដែលបានមកថ្មីល្អឬអាក្រក់ ភិក្ខុនោះត្រឡប់សួរថាបាត្រឯណា ភិក្ខុដទៃប្រាប់ថា គេផ្ញើមកក្នុងដៃនៃភិក្ខុឈ្មោះនេះ សូម្បីពាក្យនៃភិក្ខុដទៃនោះក៏មិនជាប្រមាណ លុះតែកាលណាភិក្ខុអ្នកទទួល នាំយកបាត្រនោះមកឲ្យ តាំងអំពីថ្ងៃដែលបានមកហើយនោះ កាលឲ្យកន្លង ១០ ថ្ងៃទៅ ជានិស្សគ្គិយ-បាចិត្តិយ ។ ព្រោះហេតុនោះ កុំឲ្យកន្លង ១០ ថ្ងៃ គប្បីអធិដ្ឋានឬវិកប្បទុក ។ ក្នុងបាត្រដែលជាងបាត្រទទួលធ្វើប្រគេននេះយ៉ាងណា សូម្បីក្នុងសំពត់ ដែលជួលជាងតម្បាញឲ្យត្បាញ ឬជាងតម្បាញត្បាញប្រគេនដោយខ្លួនឯង ក៏ដូចគ្នាយ៉ាងនោះ ។ ព្រោះហេតុនោះ សំពត់នោះកុំឲ្យកន្លង ១០ ថ្ងៃទៅ គប្បីអធិដ្ឋានឬវិកប្បទុកក្នុងខាងក្នុង ១០ ថ្ងៃ ។

វិធីអធិដ្ឋានបាត្រមាន ២ យ៉ាងគឺ ដោយកាយ ១ ដោយវាចា ១ ។ កាលនឹងអធិដ្ឋានដោយវិធីទាំង ២ បើបាត្រចាស់មាននៅក្នុងទីចំពោះមុខ គប្បីបច្ចុទ្ធរដកចេញថា ឥមំ បត្តំ បច្ចុទ្ធរាមិ ដូច្នេះ ។ បើនៅក្នុងទីកំបាំងមុខ (ក្រៅហត្ថបាស) គប្បីបច្ចុទ្ធរថា ឯតំ បត្តំ បច្ចុទ្ធរាមិ ដូច្នេះ ។ ឬឲ្យបាត្រនោះដល់ភិក្ខុដទៃហើយ យកដៃស្ទាបបាត្រថ្មីដែលដំកល់ទុកក្នុងតំបន់ណាមួយហើយធ្វើអាភោគចិត្តថា ឥមំ បត្តំ អធិដ្ឋាមិ ធ្វើកាយវិការគឺស្ទាបផង នេះឈ្មោះថាអធិដ្ឋានដោយកាយ ឬបញ្ចេញវាចាឲ្យឮថា ឥមំ បត្តំ អធិដ្ឋាមិ ដូច្នេះ ឈ្មោះថាអធិដ្ឋានដោយវាចា ។ អធិដ្ឋានដោយវាចា មាន ២ យ៉ាងគឺ នៅក្នុងហត្ថបាស១ ក្រៅហត្ថ-

www.budinst.gov.kh www.elibraryofcambodia.org

ជាសុខ ។ បើបាត្រនៅក្នុងហត្ថបាស គប្បីបញ្ចេញវាចាថា ឥមំ បត្តំ អធិដ្ឋាមិ ។ បើនៅខាងក្នុងល្វែង ឬលើប្រាសាទ ឬនៅក្នុងវិហារឆ្ងាយសោត គប្បីកំណត់ទីតាំងហើយបញ្ចេញវាចាថា ឯតំ បត្តំ អធិដ្ឋាមិ ។ កាលនឹងអធិដ្ឋាន សូម្បីនឹងអធិដ្ឋានម្នាក់ឯងក៏គួរ ឬនឹងអធិដ្ឋានក្នុងសំណាក់នៃភិក្ខុដទៃក៏គួរ ។ ឯអធិដ្ឋានក្នុងសំណាក់នៃភិក្ខុដទៃ មានអានិសង្សដូច្នេះ បើសង្ស័យថា យើងអធិដ្ឋានហើយឬនៅ គេគង់ឡើងដល់ភិក្ខុនោះសោត នោះភិក្ខុដទៃនឹងជួយរំឭកកាត់សេចក្ដីសង្ស័យឲ្យបាន ។ បើភិក្ខុមួយអង្គបានបាត្រមក ១០ ភិក្ខុនោះ ប្រាថ្នានឹងបរិភោគឲ្យអស់ទាំង ១០ សោត ក៏គប្បីអធិដ្ឋានឲ្យអស់ទាំង ១០ គប្បីអធិដ្ឋានបាត្រមួយឡើងមុន ហើយព្រឹកឡើងទៀត គប្បីបច្ចុទ្ធរបាត្រនោះចេញទៅ អធិដ្ឋានបាត្រដទៃឡើងទៀត ដោយឧបាយដូច្នេះ អាចនឹងបរិហាររក្សាបានសូម្បីអស់មួយរយឆ្នាំក៏បាន ។

វិធីអធិដ្ឋានបាត្រ ចប់

## វិធីវិកប្បបាត្រ

ឯវិធីវិកប្បបាត្រនោះ មាន ២ យ៉ាងគឺ វិកប្បក្នុងទីចំពោះមុខ ១ កំបាំងមុខ ១ ដូចវិកប្បចីវរដែរ ។

វិកប្បចំពោះមុខទី ១ បើបាត្រមួយនៅជិតថា ឥមំ បត្តំ យ្ហំ វិកប្បេមិ ។ បើបាត្រច្រើននៅជិតថា ឥមេ បត្តេ តុយ្ហំ វិកប្បេមិ ។

វិកប្បចំពោះមុខទី ២ បើវិកប្បនឹងសហធម្មិកទាំង ៥ ណាមួយ គប្បីបញ្ចេញឈ្មោះសហធម្មិកនោះ ដូចវិកប្បនឹងភិក្ខុឈ្មោះតិស្សៈថា ឥមំ បត្តំ តិស្សស្ស ភិក្ខុនោ វិកប្បេមិ ។

វិកប្បកំបាំងមុខថា ឥមំ បត្តំ តុយ្ហំ វិកប្បនត្ថាយ ទម្មិ ។ អ្នកជួយទទួលវិកប្បគប្បីសួរម្ចាស់បាត្រថា វិកប្បនឹងលោកណា? អ្នកម្ចាស់បាត្រ គប្បីប្រាប់ឈ្មោះសហធម្មិកទាំង ៥ ណាមួយតាមគាប់ចិត្តរបស់ខ្លួន ដូចឈ្មោះតិស្សៈជាដើម ។ អ្នកជួយទទួលវិកប្ប គប្បីយកបាត្រទៅវិកប្បនឹងលោកតិស្សៈនោះ ហើយប្រាប់ម្ចាស់បាត្រថា អហំ តិស្សស្ស ភិក្ខុនោ ទម្មិ ។ វិកប្បហើយទឹងទុកក៏គួរ បើបរិភោគជាដើមមិនគួរ លុះតែដកវិកប្បហើយដូចបានពោលក្នុងវិធីដកសំពត់ ទើបគួរបរិភោគជាដើមបាន ។ ឯនៅជិតឬនៅឆ្ងាយ បាត្រមួយ ឬបាត្រច្រើន នឹងឈ្មោះនៃសហធម្មិក ត្រូវផ្លាស់ដូចពោលហើយក្នុងចីវរនោះចុះ ។

**វិធីវិកប្បបាត្រ ចប់**

## សេចក្តីប្រែអំពីវិធីមានពិន្ទុជាដើម

ឥមំ ពិន្ទុកប្បំ ករោមិ ប្រែថា យើងធ្វើនូវវង់មូលដ៏គួរនេះ ។
ឥមំ ចីវរំ បច្ចុទ្ធរាមិ ប្រែថា យើងដកនូវចីវរនេះ ។
ឥមំ បត្តំ បច្ចុទ្ធរាមិ ប្រែថា យើងដកនូវបាត្រនេះ ។

www.budinst.gov.kh www.elibraryofcambodia.org

ឥមំ សង្ឃាដឹ អធិដ្ឋាមិ ប្រែថា យើងតាំងទុកនូវសង្ឃាដីនេះ ។

ឥមំ បត្តំ អធិដ្ឋាមិ ប្រែថា យើងតាំងទុកនូវបាត្រនេះ ។

ឥមំ ចីវរំ បរិក្ខារចោលំ អធិដ្ឋាមិ ប្រែថា យើងតាំងទុកនូវសំពត់នេះ ជាកំណាត់សំពត់បរិក្ខារ ។

ឥមំ ចីវរំ តុយ្ហំ វិកប្បេមិ ប្រែថា ខ្ញុំកំណត់ពិសេសទុកនូវសំពត់នេះដល់លោក ។

ឥមំ បត្តំ តុយ្ហំ វិកប្បេមិ ប្រែថា ខ្ញុំកំណត់ពិសេសទុកនូវបាត្រនេះដល់លោក ។

ឥមំ ចីវរំ តិស្សស្ស ភិក្ខុនោ វិកប្បេមិ ប្រែថា ខ្ញុំកំណត់ពិសេសទុកនូវចីវរនេះដល់តិស្សភិក្ខុ ។

ឥមំ បត្តំ តិស្សស្ស ភិក្ខុនោ វិកប្បេមិ ប្រែថា ខ្ញុំកំណត់ពិសេសទុកនូវបាត្រនេះដល់តិស្សភិក្ខុ ។

ឥមំ ចីវរំ តុយ្ហំ វិកប្បនត្ថាយ ទម្មិ ប្រែថា ខ្ញុំឲ្យនូវសំពត់នេះដល់លោក ដើម្បីវិកប្ប (កំណត់ពិសេសទុក) ។

ឥមំ បត្តំ តុយ្ហំ វិកប្បនត្ថាយ ទម្មិ ប្រែថា ខ្ញុំឲ្យនូវបាត្រនេះដល់លោក ដើម្បីវិកប្ប (កំណត់ពិសេសទុក) ។

អហំ តិស្សស្ស ភិក្ខុនោ ទម្មិ ប្រែថា ខ្ញុំឲ្យដល់តិស្សភិក្ខុ ។

www.budinst.gov.kh www.elibraryofcambodia.org

មយ្ហំ សន្តកំ បរិភុញ្ជ វា វិសជ្ជេហិ វា យថាបច្ច-
យំ វា ករោហិ ប្រែថា លោកចូរបរិភោគ ឬចូរលះបង់ ឬចូរធ្វើ
តាមហេតុ នូវវត្ថុជារបស់នៃខ្ញុំ ។

តិស្សស្ស ភិក្ខុនោ សន្តកំ បរិភុញ្ជ វា វិសជ្ជេហិ វា យថាបច្ចយំ វា ករោហិ ប្រែថា លោកចូរបរិភោគ ឬចូរលះបង់ ឬចូរធ្វើតាមហេតុ នូវវត្ថុជារបស់នៃតិស្សភិក្ខុ ។

មួយទៀត ក្នុងពាក្យផគបាត្រ ចីវរនេះ គួរប្រកបឈ្មោះសំពត់ ឈ្មោះបាត្រចូលផងថា

ឥមំ ចីវរំ មយ្ហំ សន្តកំ បរិភុញ្ជ វា វិសជ្ជេហិ វា យថាបច្ចយំ វា ករោហិ ។

ឥមំ ចីវរំ តិស្សស្ស ភិក្ខុនោ សន្តកំ បរិភុញ្ជ វា វិសជ្ជេហិ វា យថាបច្ចយំ វា ករោហិ ។

ឥមំ បត្តំ មយ្ហំ សន្តកំ បរិភុញ្ជ វា វិសជ្ជេហិ វា យថាបច្ចយំ វា ករោហិ ។

ឥមំ បត្តំ តិស្សស្ស ភិក្ខុនោ សន្តកំ បរិភុញ្ជ វា វិសជ្ជេហិ វា យថាបច្ចយំ វា ករោហិ ។

បើសំពត់ច្រើនថា ឥមានិ ចីវរានិ មយ្ហំ សន្តកានិ បរិភុញ្ជ វា ។ល។ ករោហិ ។

www.budinst.gov.kh www.elibraryofcambodia.org

បើបាត្រច្រើនថា ឥមេ បត្តេ មយ្ហំ សន្តកេ បរិភុញ្ជ វា ។ល។ ករោហិ ។

បើអ្នកដកវិកប្បខ្ពស់វស្សាជាងម្ចាស់របស់ គប្បីពោលដោយពហុវចនៈថា... បរិភុញ្ជថ វា វិសជ្ជេថ វា យថាបច្ចយំ វា ករោថ ។

មួយទៀត នឹងពោលតែបទថា បរិភុញ្ជ ឬ បរិភុញ្ជថ, វិសជ្ជេហិ ឬ វិសជ្ជេថ, យថាបច្ចយំ វា ករោហិ ឬ យថាបច្ចយំ វា ករោថ បទណាមួយក៏បាន ។

មួយទៀត ការវិកប្បចីវរនឹងបាត្រដល់សហធម្មិកទាំង ៥ នោះណាមួយ បើសហធម្មិកអ្នកទទួលវិកប្បនោះជាមនុស្សស្និទ្ធស្នាលនឹងគ្នា នឹងកាន់យកដោយសេចក្តីស្និទ្ធស្នាលក្នុងទីចំពោះមុខឬកំបាំងមុខក៏គួរ ។

ពិន្ទាធិដ្ឋានាទិបញ្ហៈគំរប់ ៥ ចប់

---

## វិជហនាទិបញ្ហៈ គំរប់ ២

## វិជហនកថា

ពោលអំពីវិធីដាច់អធិដ្ឋាន ។ ចីវរដែលភិក្ខុអធិដ្ឋានដោយឈ្មោះដូចពោលហើយនោះ នឹងដាច់អធិដ្ឋានដោយហេតុ ៩ ប្រការគឺ អញ្ញស្ស ទានេន ឲ្យដល់អ្នកដទៃ ១ អច្ឆិន្ទិត្វា គហណេន ចោរ

www.budinst.gov.kh www.elibraryofcambodia.org

ដណ្តើមយកទៅ ១ វិស្សាសគាហេន មិត្រសំឡាញ់កាន់យកទៅដោយវិស្សាសៈ ១ ហីនាយាវត្តនេន ត្រឡប់ទៅដើម្បីជាមនុស្សថោកទាប ១ សិក្ខាបច្ចក្ខានេន លាសិក្ខា ១ កាលកិរិយាយ ធ្វើកាលកិរិយាស្លាប់ទៅ ១ លិង្គបរិវត្តនេន ភេទត្រឡប់ គឺភេទបុរសត្រឡប់ជាស្ត្រី ភេទស្ត្រីត្រឡប់ជាបុរស ១ បក្ខន្តរេណន ដកអធិដ្ឋាន ១ ឆិទ្ទភាវេន ធ្លុះប្រហោង ១ ត្រូវជា ៩ ប្រការ ។ ក្នុងវិមតិវិនោទនីពោលថា ឯដែលថាត្រឡប់ទៅដើម្បីជាមនុស្សថោកទាបនោះ សំដៅយកភិក្ខុត្រូវបារាជិក ហើយស្លៀកនៅក្នុងភិក្ខុបដិញ្ញា ហើយទៅកាន់ភេទគ្រហស្ថក្តី ឬទៅកាន់លទ្ធិតិរ្ថិយ ជាតិត្ថិយបក្កន្តកៈក្តី ខឹងនាងភិក្ខុនីអស់សេចក្តីប្រាថ្នាក្នុងភេទជាភិក្ខុនីទៅកាន់ភេទគ្រហស្ថក្តី ឈ្មោះថាត្រឡប់ទៅដើម្បីជាមនុស្សថោកទាប ។ អាចារ្យខ្លះពោលថា សំដៅយកមិនបានលាសិក្ខាបទទៅជាគ្រហស្ថ ឈ្មោះថាត្រឡប់ទៅដើម្បីជាមនុស្សថោកទាប ។ លោកជំទាស់ថា ពាក្យអាចារ្យនោះមិនត្រឹមត្រូវទេ ព្រោះថា សូម្បីទៅកាន់ភេទជាគ្រហស្ថដូច្នេះ កាលអ្នកនោះនៅជាឧបសម្បន្នទៅឡើយ ចីវរនោះនៅមិនបានលះនូវភាព ជារបស់អ្នកនោះ ។ ឯចីវរទាំងពីរ ដាច់អធិដ្ឋានដោយហេតុ ៨ ប្រការខាងដើម តែដាច់អធិដ្ឋាន ដោយធ្លុះប្រហោងនោះ ក្នុងអដ្ឋកថាទាំងពីរ លោកពោលចំពោះតែត្រៃចីវរមួយយ៉ាងប៉ុណ្ណោះ ។ ក៏ឯធ្លុះប្រហោងនោះប្រមាណប៉ុនខ្នងក្រចកកូនដៃ ប្រហោងនោះ គឺ ធ្លុះដាច់ ទើបដាច់

www.budinst.gov.kh www.elibraryofcambodia.org

អធិដ្ឋាន ៗ ជ្រឹតជាក្នុងចន្លោះប្រហោងនោះ បើអម្បោះ ឬម្សីមួយសរសៃ នៅមិនទាន់ដាច់ទេ ក៏គង់នៅរក្សាបាននៅឡើយ ៗ សង្ឃាដិនិងឧត្តរាសង្គៈ ដានវែងអំពីទីបំផុតជាយចូលទៅ ប្រមាណមួយចំអាម ដានទទឹងអំពីទីបំផុតជាយចូលទៅប្រមាណ ៨ ធ្នាប់ ធ្លុះប្រហោងខាងក្នុងកំណត់នោះចូលទៅ ទើបដាច់អធិដ្ឋាន ៗ ឯអន្តរវាសកៈនោះ ដានវែងអំពីទីបំផុតជាយចូលទៅ ប្រមាណមួយចំអាម ដានទទឹងអំពីទីបំផុតជាយចូលទៅ ប្រមាណ ៤ ធ្នាប់ ធ្លុះប្រហោងខាងក្នុងកំណត់នោះចូលទៅ ទើបដាច់អធិដ្ឋាន ក្រៅនោះចេញមកក្នុងទីកំណត់ មិនបានដាច់អធិដ្ឋាន ៗ ព្រោះហេតុនោះ កាលបើធ្លុះប្រហោងហើយ ចីវរនោះរមែងតាំងនៅក្នុងទីជាអតិរេកចីវរ គប្បីធ្វើសូចិកម្មបិទផុលសិន ហើយអធិដ្ឋានឡើងជាថ្មីចុះ (ក្នុងខាងក្នុង ១០ ថ្ងៃ) ៗ ភិក្ខុណាមានចីវរចាស់គ្រាំគ្រា យកសំពត់មកបិទមុនហើយ ទើបកាត់សំពត់ចាស់ចេញជាក្រោយ ចីវរនោះមិនដាច់អធិដ្ឋាន សូម្បីក្នុងការផ្លាស់ប្តូរសំពត់មណ្ឌលក៏ដូចគ្នាដែរ ៗ ចីវរពីរជាន់ធ្លុះមួយជាន់ ឬឃ្លាតលឿនមួយជាន់ ក៏មិនដាច់អធិដ្ឋាន ៗ ធ្វើចីវរតូចឲ្យជាចីវរធំ ឬធ្វើចីវរធំឲ្យជាចីវរតូច ក៏មិនដាច់អធិដ្ឋាន ៗ កាលបើនឹងផ្គួញចីវរឲ្យជាយជាប់គ្នា បើកាត់មុនទើបផ្គួញតចូលខាងក្រោយសោត ក៏ដាច់អធិដ្ឋាន ៗ ថាបើផ្គួញតគ្នាមុនសិនហើយ ទើបកាត់ខាងក្រោយសោត មិនដាច់អធិដ្ឋាន សូម្បីឲ្យជាងគេគក់លាងធ្វើឲ្យសទៅ អធិដ្ឋានក៏គង់ជាអធិដ្ឋាននៅដូចដើម ៗ សូម្បីបាត្រដែលអធិដ្ឋានទុក

ហើយ គឺដាច់អធិដ្ឋាន ដោយហេតុ ៩ ប្រការដូចគ្នា តែក្នុងប្រហារទី នោះធំប៉ុនគ្រាប់ល្ពៅចូលចេញបាន ទើបដាច់អធិដ្ឋាន ព្រោះជាធញ្ញជាតិទាំង ៧ ប្រការ គ្រាប់ល្ពៅនេះជាយ៉ាងតូច ប្រហារក្នុងនោះ កាលបើបិទដោយកំទេចដែក ឬព្រមរហើយ គប្បីអធិដ្ឋានទៀត ក្នុងខាងក្នុង ១០ ថ្ងៃចុះ ។

វិធិហានកថា ចប់

## ទានាទិកថា

ពោលអំពីការឲ្យនឹងការកាន់យកជាដើម ។ ដូចម្ដេចឈ្មោះថាការឲ្យ? ដូចម្ដេចឈ្មោះថាការកាន់យក?

អ្នកឲ្យពោលថា យើងឲ្យវត្ថុនេះដល់លោក ឬយើងប្រគល់ឲ្យ ឬយើងបរិច្ចាគ យើងលះវត្ថុនេះ ឲ្យដល់លោក ក្នុងទីចំពោះមុខ ។ ពោលថា យើងឲ្យ ឬយើងប្រគល់ឲ្យ ឬយើងបរិច្ចាគ យើងលះវត្ថុនេះ ឲ្យដល់បុគ្គលឈ្មោះនេះ ក្នុងទីកំបាំងមុខ ដូច្នេះជាការឲ្យពិត ។ អ្នកឲ្យពោលថា លោកចូរកាន់យកដើម្បីខ្លួនលោកចុះ អ្នកទទួលពោលថា ខ្ញុំកាន់យកដើម្បីខ្លួនខ្ញុំដូច្នេះ (អ្នកឲ្យក៏ឲ្យដោយបច្ចុប្បន្នកាល អ្នកទទួលក៏កាន់យកដោយបច្ចុប្បន្នកាល) ឈ្មោះថាឲ្យ (នឹងកាន់យក) ដោយប្រពៃ ។ អ្នកឲ្យពោលថា លោកចូរទទួលវត្ថុនេះធ្វើជារបស់

www.budinst.gov.kh www.elibraryofcambodia.org

លោកចុះ · ឬពោលថាវត្ថុនេះ ចូរជារបស់លោកចុះ ឬពោលថា លោកនឹងធ្វើវត្ថុនេះឲ្យជារបស់លោក អ្នកទទួលពោលថា ខ្ញុំធ្វើវត្ថុនេះឲ្យជារបស់ខ្ញុំ ឬពោលថាវត្ថុនេះ ចូរជារបស់ខ្ញុំ ឬពោលថាខ្ញុំនឹងធ្វើវត្ថុនេះឲ្យជារបស់ខ្ញុំ ដូច្នេះឈ្មោះថាឲ្យ និងកាន់យកមិនប្រពៃ ព្រោះអ្នកឲ្យមិនបេះឲ្យ អ្នកទទួលមិនបេះទទួល (គឺឲ្យនឹងទទួលខុសពាក្យបច្ចុប្បន្នកាល) ។ តែបើអ្នកឲ្យពោលថា លោកចូរធ្វើវត្ថុនេះឲ្យជារបស់លោកចុះ អ្នកទទួលពោលថាប្រពៃហើយ ខ្ញុំកាន់យកដើម្បីខ្លួនខ្ញុំ ដូច្នេះ ឈ្មោះថាឲ្យមិនប្រពៃ កាន់យកប្រពៃ ។ បើអ្នកទទួលម្នាក់ពោលថាលោកចូរកាន់យកចុះ អ្នកម្នាក់ទៀតពោលថាខ្ញុំមិនកាន់យកទេ អ្នកឲ្យគ្រឡប់ពោលទៀតថា យើងឲ្យហើយ លោកចូរកាន់យកដើម្បីខ្លួនលោកចុះ សូម្បីអ្នកទទួលពោលថា ខ្ញុំមិនត្រូវការដោយវត្ថុនេះទេ សូម្បីអ្នកឲ្យមុនក៏សំគាល់ថាយើងឲ្យទៅគេហើយ នឹងឲ្យអតិរេកចីវរនោះកន្លង ១០ ថ្ងៃទៅ សូម្បីអ្នកទទួលក៏សំគាល់ថា យើងហាមឃាត់គេហើយ ដូច្នេះ មិនត្រូវអាបត្តិដល់អ្នកណាមួយឡើយ ព្រោះថាអ្នកណាចូលចិត្ត អ្នកនោះក៏គប្បីអធិដ្ឋានឡើងបរិភោគៗ ក្នុងអដ្ឋកថានៃចីវរច្ឆិន្ទនសិក្ខាបទពោលថា ឲ្យចីវរដល់ភិក្ខុដោយពាក្យថា យើងឲ្យដល់លោកដែលកាន់យកៗ បច្ច័យក្នុងសំណាក់យើង យើងមិនឲ្យដល់លោកដែលកាន់យកៗ បច្ច័យក្នុងទីដទៃ យើងឲ្យដល់អ្នកធ្វើវត្តក្នុងសំណាក់យើងមួយចំពួក យើងមិនឲ្យដល់អ្នកមិនធ្វើវត្តក្នុងសំណាក់យើងទេ យើងឲ្យដល់អ្នករៀនធម៌ក្នុងសំណាក់យើង

www.budinst.gov.kh www.elibraryofcambodia.org

ប៉ុណ្ណោះ យើងមិនឲ្យដល់អ្នកមិនរៀនធម៌ក្នុងសំណាក់យើងទេ យើងឲ្យដល់អ្នកមិនលាសិក្ខាប៉ុណ្ណោះ យើងមិនឲ្យដល់អ្នកដែលមិនលាសិក្ខា ឲ្យដូច្នេះ មិនគួរ កាលបើឲ្យដូច្នេះ ត្រូវទុក្កដ តែមិនឲ្យយកត្រឡប់មកវិញក៏គួរ ។ កាលបើត្រឡប់ដណ្តើមកាន់យកចីវរដែលលះឲ្យដាច់ហើយ ឲ្យវិនយធរគេប្បីកាត់តាមដំរៀវកណ្ឌៈ ។

ខមួយ ព្រះអង្គទ្រង់អនុញ្ញាតដល់ភិក្ខុ ឲ្យកាន់យកដោយវិស្សាសៈ ព្រមដោយអង្គ ៥ គឺ សន្ទិដ្ឋោ ច ហោតិ ជាមិត្រធ្លាប់ឃើញគ្នាមក ១ សម្ភត្តោ ច ហោតិ ជាមិត្រមាំមួនធ្លាប់បរិភោគជាមួយគ្នាមក ១ អាលបិតោ ច បាននិយាយគ្នាទុកថា ទ្រព្យរបស់យើង បើលោកចង់បានរបស់អ្វី គប្បីកាន់យកនូវរបស់នោះចុះ ១ ជីវតិ ច មានជីវិតរស់នៅ ១ គហិតេ អត្តមនោ ហោតិ ដឹងថាយើងកាន់យកហើយ ហើយត្រេកអរ ១ ។ ក្នុងអដ្ឋកថា ថាវិស្សាសៈរមែងឡើងដោយអង្គ ៣ គឺ មិត្រធ្លាប់ឃើញ មិត្រធ្លាប់ស៊ី និងមិត្រដែលផ្តាំទុកថា ចង់បានរបស់អ្វី គប្បីកាន់យករបស់នោះ ទាំង ៣ ពួកនេះណាមួយ បាត់ជាអង្គ ១ កំពុងរស់នៅជាអង្គ ១ កាន់យកហើយត្រេកអរជាអង្គ ១ ។

ខមួយទៀត ព្រះអង្គទ្រង់អនុញ្ញាត ឲ្យកាន់យកដោយវិស្សាសៈ ដូច្នេះថា ភិក្ខុផ្ញើចីវរទៅក្នុងដៃនៃភិក្ខុ ផ្តាំថាលោកចូរឲ្យចីវរនេះ ដល់ភិក្ខុឈ្មោះនេះ អ្នកទទួលទៅ ទៅដល់កណ្តាលផ្លូវកាន់យកដោយវិស្សាសៈនៃអ្នកផ្ញើ ឈ្មោះថាកាន់យកដោយប្រពៃ ម្ចាស់របស់ផ្ញើទៅភិក្ខុណា

www.budinst.gov.kh www.elibraryofcambodia.org

កាន់យកដោយវិស្សាសៈនៃភិក្ខុនោះ ឈ្មោះថាកាន់យកមិនប្រពៃ ថាបើបានពតិមានកណ្តាលផ្លូវថា ភិក្ខុអ្នកផ្ញើទៅនោះដល់អនិច្ចធម្មទៅហើយ ទឹងអធិដ្ឋានយកជាចីវរមតកនៃភិក្ខុនោះ ឈ្មោះថាអធិដ្ឋានដោយប្រពៃ បើកាន់យកដោយវិស្សាសៈ នៃភិក្ខុដែលម្ចាស់របស់ផ្ញើទៅឲ្យ ឈ្មោះថាកាន់យកមិនប្រពៃ ថាបើបានឮថាផ្ញើទៅដល់ភិក្ខុណា ភិក្ខុនោះដល់នូវអនិច្ចធម្មហើយ ទឹងអធិដ្ឋានយកជាចីវរមតកនៃភិក្ខុនោះ ឈ្មោះថាអធិដ្ឋានយកមិនប្រពៃ បើកាន់យកដោយវិស្សាសៈ នៃអ្នកផ្ញើទៅ ឈ្មោះថាកាន់យកដោយប្រពៃ បើបានឮថាអ្នកទាំងពីរនាក់ អនិច្ចធម្មទៅហើយ ទឹងអធិដ្ឋានយកជាចីវរមតកនៃភិក្ខុអ្នកផ្ញើទៅនោះ ឈ្មោះថាអធិដ្ឋានយកដោយប្រពៃ ផ្ញើទៅដើម្បីភិក្ខុណា អធិដ្ឋានយកជាចីវរមតកនៃភិក្ខុនោះ ឈ្មោះថាអធិដ្ឋានយកមិនប្រពៃ ។ មួយទៀត ភិក្ខុផ្ញើចីវរទៅក្នុងដៃនៃភិក្ខុ ថាយើងឲ្យចីវរនោះដល់ភិក្ខុឈ្មោះនេះ ភិក្ខុទទួលទៅ ទៅដល់កណ្តាលផ្លូវ កាន់យកដោយវិស្សាសៈនៃភិក្ខុអ្នកផ្ញើ ឈ្មោះថាកាន់យកមិនប្រពៃ ផ្ញើទៅដើម្បីភិក្ខុណា កាន់យកដោយវិស្សាសៈនៃភិក្ខុនោះ ឈ្មោះថាកាន់យកដោយប្រពៃ ថាបើបានឮថា ភិក្ខុអ្នកផ្ញើ ឬភិក្ខុដែលត្រូវបាន ដល់នូវអនិច្ចធម្ម ឬដល់នូវអនិច្ចធម្មទាំងពីរនាក់ក្តី ថាបើកាន់យកដោយវិស្សាសៈរបស់ភិក្ខុដែលត្រូវបាន ឬអធិដ្ឋានយកជាចីវរមតកនៃភិក្ខុដែលត្រូវបាន ឈ្មោះថាកាន់យកដោយប្រពៃ អធិដ្ឋានយកដោយប្រពៃ ថាបើកាន់យកដោយវិស្សាសៈ នៃភិក្ខុដែលផ្ញើទៅ ឬអធិដ្ឋានយកជា

www.budinst.gov.kh www.elibraryofcambodia.org

ចីវរមតិកៈរបស់ភិក្ខុអ្នកផ្ញើ ឈ្មោះថាកាន់យកមិនប្រពៃ អធិដ្ឋានយកមិនប្រពៃ ។

ទានាទិកថា ចប់

---

## បដិគ្គហណកថា

ពោលអំពីការទទួលប្រគេន ។ ការប្រគេនប្រកបដោយអង្គ ៥ ទើបឡើងគឺ ឋាមមជ្ឈិមស្ស បុរិសស្ស ឧច្ចារណមត្តំ ហោតិ របស់ល្មមមជ្ឈិមបុរសលើកឡើងបាន ១ ហត្ថបាសោ បញ្ញាយតិ ហត្ថបាសប្រាកដ ១ អភិហារោ បញ្ញាយតិ បង្អោនចូលមកចំពោះប្រាកដ ១ ទេវោ វា មនុស្សោ វា តិរច្ឆានគតោ វា កាយេន វា កាយបដិពទ្ធេន វា និស្សគ្គិយេន វា ទេតិ ទេវតា ឬមនុស្ស ឬសត្វតិរច្ឆាន ឲ្យដោយកាយ ឬវត្ថុជាប់ដោយកាយ ឬបោះឲ្យ ១ តំ ចេ ភិក្ខុ កាយេន វា កាយបដិពទ្ធេន វា បដិគ្គណ្ហាតិ ភិក្ខុទទួលរបស់នោះ ដោយកាយ ឬវត្ថុជាប់ដោយកាយ ១ ទទួលប្រគេនព្រមដោយអង្គ ៥ នេះ ទើបឡើង ។ ក៏ឯហត្ថបាសកំណត់ត្រឹម ២ ហត្ថ ១ ចំអាម ទីនេះដេកទទួល ឬឈរ - អង្គុយទទួលក្តី គប្បីឲ្យបាន ២ ហត្ថ ១ ចំអាមទើបគួរ វៀរលែងតែដៃដែលលូកហុចទៅទទួល ទីនៃដៃដែល

គេហុចមកឲ្យ មិនកប់បញ្ចូលក្នុងហត្ថបាស គប្បីដឹងដោយន័យដូចពោល
ហើយក្នុងបឋមបរិវណាសិក្ខាបទនោះចុះ បើអ្នកឲ្យ ឬអ្នកទទួលម្នាក់នៅ
លើអាកាស ម្នាក់នៅលើផែនដី គប្បីកំណត់ប្រមាណហត្ថបាសដោយ
ក្បាល នៃអ្នកឈរនៅលើផែនដី ដោយចុងបំផុតខាងក្នុងនៃអវយវៈដ៏ជិតនៃ
អ្នកឈរនៅលើអាកាស វៀរតែដៃដែលនឹងលូកចេញទៅ ដើម្បីនឹងប្រ-
គេន នឹងទទួល ឲ្យបាន ២ ហត្ថ ១ ចំអាម ថាបើអ្នកម្នាក់នៅក្នុងអណ្តូង នឹង
ម្នាក់នៅលើមាត់អណ្តូង ឬអ្នកម្នាក់នៅលើដើមឈើ ម្នាក់ឈរលើផែនដី
ក៏គប្បីកំណត់ប្រមាណហត្ថបាស ដោយន័យដូចពោលហើយនោះចុះ ។
ឈរនៅក្នុងហត្ថបាសដូច្នេះហើយ បើជាសត្វបក្សីឲ្យដោយចំពុះ មាត់ ឬ
ដំរីកាន់យកដោយប្រមោយឲ្យផ្កាឈើ ឬផ្លែឈើ ទទួលប្រគេន ក៏
ឡើង ថាបើអង្គុយលើកដំរី សូម្បីខ្ពស់ពេក ៧ ហត្ថមួយចំអាម ទទួលរបស់
ដែលដំរីនោះប្រគេនដោយប្រមោយក៏គួរពិត ៗ បើទាយកម្នាក់យកភាជនៈ
បាយនឹងម្ហូបតម្រួតគ្នា ទូលលើក្បាលមកឈរជិតភិក្ខុ ប្រាប់ឲ្យភិក្ខុ
ទទួលយក ការបង្អោនមកមិនទាន់ប្រាកដជាមុន ព្រោះហេតុនោះ
កុំគប្បីទទួលឡើយ ថាបើគេបង្អោនមកសូម្បីបន្តិច ភិក្ខុគប្បីលូកដៃទៅ
ចាប់ភាជនៈខាងក្រោម សូម្បីប្រទេសមួយប៉ុណ្ណោះ ភាជនៈទាំងមូល
ឈ្មោះថាទទួលប្រគេនទាំងអស់ គេទៅនឹងឲ្យគេដាក់ចុះ ឬបើគេឡើង
ប្រាប់ថាគេណា នឹងចាប់យកតែនោះក៏គួរ ៗ ឯក្នុងភាជនៈជាមួយជាដើមជា
គរញ្ញូបាយមិនទាំងបាច់ពោលឡើយ សូម្បីតែគេបាយមកបើគេបង្អោន

www.budinst.gov.kh www.elibraryofcambodia.org

អព្រែកមកឲ្យ នឹងទទួលក៏គួរ សូម្បីឫស្សីវែង ៣០ ហត្ថ ខាងម្ខាងបង្ផាំង ទឹកអំពៅ ខាងម្ខាងបង្ផាំងសប្បៀ បើទទួលដងវែកនោះ របស់ទាំងពួង ឈ្មោះថាទទួលទាំងអស់ ។ គេប្រាប់ឲ្យទទួលទឹកអំពៅដែលហូរចេញចាក ឃ្នាប ការបង្ហូរទទួលមកចំពោះមិនប្រាកដ ព្រោះហេតុនោះ កុំគប្បីទទួល បើគេរើសកាកចោលចេញ យកដៃសន្សើមក្បន់ឲ្យក៏គួរ បាត្រប្រេងផង គ្នា ដែកល់ទុកលើគ្រែ ឬតាំង ឬកន្ទេល ឬស្នាប ឬផែនក្ដារ ភិក្ខុនៅលើ ទីណា ចាប់យកនៅក្នុងហត្ថបាស នៅលើទីនោះ ឈរ ឬអង្គុយ ឬដេកក្ដី គិតនឹងទទួល យកម្រាមដៃពាល់គ្រែជាដើម របស់ណាគេដាក់ចុះក្នុង បាត្រអម្បាលនោះ របស់ទាំងពួងនោះ ឈ្មោះថាទទួលប្រគេនទាំងអស់ ថាបើគិតនឹងទទួលក្រោកឡើងអង្គុយលើគ្រែជាដើមក៏គួរពិត ។ ថាបើបាត្រ តាំងនៅលើផែនដី ក្អួននឹងក្អួនប្រកិតជិតជាប់គ្នាហោង ភិក្ខុអង្គុយ យកម្រាមដៃ ឬម្ជុល ឬវត្ថុណាមួយ ពាល់ត្រូវបាត្រណា ៗ របស់គេ ឲ្យក្នុងបាត្រនោះ ៗ ឈ្មោះថាជារបស់ទទួលប្រគេន លោកពោលទុកថា ក្នុងបាត្រដែលតាំងនៅលើគ្រឿងកំពល មានកន្ទេលដ៏ធំ នឹងគ្រឿង កំពលលើខ្នងដំរីជាដើមណាមួយ ទទួលប្រគេនមិនឡើង ពាក្យនោះគប្បី ដឹងថាលោកពោលទុកព្រោះអាស្រ័យកន្លងហត្ថបាស ពោលទុកតែកាល បានហត្ថបាស ទទួលក្នុងគ្រឿងកំពលណាមួយរមែងគួរ វៀរតែរបស់កើត ក្នុងទីនោះ ៗ ឯរបស់កើតក្នុងទីនោះ ដូចស្លឹកឈូកឬស្លឹកចារជាដើម យក មករនឹងទទួលមិនគួរ ផ្សិតពោលថា របស់នោះមិនរាប់ថាជារបស់ជាប់

www.budinst.gov.kh www.elibraryofcambodia.org

ដោយកាយ គឺឯរបស់កើតក្នុងទីនោះយ៉ាងណា ក្នុងព្រៃគជាដើម ដែលគេចង់ភ្ជាប់ទុកនឹងបង្គោល ឬក្តារ ឬថ្មដែលលើកមិនរួច យកមកនឹងទទួលគឺមិនឡើងដូច្នោះ ព្រោះថាព្រៃគជាដើមនោះ គឺសន្មតថាជារបស់កើតក្នុងទីនោះ សូម្បីស្លឹកអម្ពិលជាដើមដែលតូច យកមកក្រាលលើផែនដីនឹងទទួលប្រគេនក៏មិនឡើង ព្រោះថាស្លឹកនោះមិនអាចនឹងទ្ររបស់បានទទួលឡើងតែនឹងស្លឹកឈូកជាដើមដែលធំ ៗ ថាបើគេឈរនៅក្រៅហត្ថបាស យកបោយដងវែងដួសបាយចូលមកឲ្យ គប្បីពោលនឹងគេឲ្យចូលមកជិត គេមិនបានឮ ឬមិនបានអើពើឡើយ គេចាក់ចុះក្នុងបាត្រ គប្បីទទួលប្រគេនជាថ្មី ។ គេឈរនៅឆ្ងាយ បោះដុំបាយចូលមកក៏ដូចគ្នា ។ ថាបើនាំបាត្រចេញអំពីថង់បាត្រ លំអិតគ្រឿងជ្រលក់ធ្លាក់ចុះក្នុងបាត្រសោត កាលបើទឹកមានគប្បីលាងចេញ កាលបើមិនមានគប្បីជូតលំអិតនោះចេញ ឬទទួលប្រគេនទៀតជាមុនហើយទើបទៅបិណ្ឌបាត ។ ថាបើដើរទៅបិណ្ឌបាតធូលីធ្លាក់ចុះសោត គប្បីទទួលប្រគេនបាត្រទៀតហើយទើបទទួលភិក្ខៈ កាលបើមិនបានទទួលប្រគេនបាត្រ ទៅទទួលភិក្ខៈត្រូវវិនយទុក្កដ តែកាលបើទទួលប្រគេនរបស់នោះទៀតហើយឆាន់ មិនត្រូវអាបត្តិ កាលបើពឹងគេឲ្យប្រគេនគេមិនឮ ឬគេមិនបានអើពើនឹងពាក្យទំឲ្យភិក្ខៈសោត មិនត្រូវវិនយទុក្កដ គួរគប្បីទទួលជាថ្មីហើយសូមទទួលភិក្ខៈផងចុះ ។ ថាបើខ្យល់ព្យុះបក់ធូលីមកអំពីទីនោះ ៗ មិនអាចនឹងទទួលភិក្ខៈបាន មានចិត្តបរិសុទ្ធចង់ចិត្តថា នឹងយកទៅឲ្យអនុបសម្បន្នហើយទទួលក៏គួរ ។ ដើរ

www.budinst.gov.kh www.elibraryofcambodia.org

ទៅបិណ្ឌបាតហើយត្រឡប់ទៅវិហារឬកេនឹងឆាន់ ឲ្យរបស់នោះដាច់ដល់អនុបសម្បន្នហើយ អនុបសម្បន្នត្រឡប់ឲ្យមកវិញ ឬនឹងកាន់យកដោយវិស្សាសៈនៃអនុបសម្បន្នហើយបរិភោគក៏គួរ ។ ថាបើភិក្ខុឲ្យបាត្រព្រមទាំងបាយដែលធូលីធ្លាក់ក្នុងវេលាដើរទៅបិណ្ឌបាតដល់ភិក្ខុផងគ្នា គប្បីប្រាប់ភិក្ខុថា លោកគប្បីទទួលប្រគេនជាថ្មីទៀត កាន់យកនូវភិក្ខៈចុះ ឬឆាន់ចុះ ភិក្ខុនោះក៏គប្បីធ្វើតាមដូច្នោះ ។ ថាបើធូលីធ្លាក់ចុះអវណ្ណកនៅខាងលើ គប្បីសំរិតទឹកខាងលើចេញ ដែលសល់នៅនោះគប្បីឆាន់ចុះ ។ ថាបើធូលីចូលចុះទៅខាងក្នុងសោត គប្បីទទួលប្រគេនទៀត ។ កាលបើអនុបសម្បន្នមិនមាន កុំលែងឲ្យផុតអំពីដៃ គប្បីនាំទៅកាន់ទីដែលមានអនុបសម្បន្នឲ្យប្រគេនទៀត ។ ធូលីធ្លាក់ចុះក្នុងបាយនឹងនាំធូលីចេញហើយឆាន់ក៏គួរ ។ ថាបើធូលីល្អិតណាស់គប្បីនាំចេញទាំងបាយខាងលើ ឬគប្បីទទួលប្រគេនទៀតហើយឆាន់ចុះ ។ កាលបើគេយកបបរឬសំឡ ដក់លអំពីមុខនៃខ្លួន គេក្ដីមានពពុះធ្លាក់ចាកភាជនៈមកធ្លាក់ចុះក្នុងបាត្រ គប្បីទទួលប្រគេនបាត្រទៀត ។ កាលបើយកបាយដួសចូលមកប្រគេន ពពុះស្រក់អំពីបាយធ្លាក់ចុះក្នុងបាត្រមុន ឈ្មោះថាធ្លាក់ចុះដោយប្រពៃ មិនមានទោស ព្រោះគេបង្អោនចូលមកចំពោះហើយ ថាបើគេយកបាយព្រមទាំងចង្ក្រានបង្អោនចូលមក ផ្សែងឬផេះធ្លាក់ចុះក្នុងបាត្រមិនមានទោស . ព្រោះគេបង្អោនចូលមកជិតហើយ ។ កាលបើប្រគេនដល់ភិក្ខុនៅក្នុងលំដាប់ របស់ខ្ទាត់ចេញចាកបាត្រទៅធ្លាក់ចុះក្នុងបាត្រនៃភិក្ខុដទៃ ឈ្មោះថាធ្លាក់ចុះដោយប្រពៃ

www.budinst.gov.kh www.elibraryofcambodia.org

ជាកិរិយាទទួលពិត ។ ជាបើគេពុះគ្រាប់ទឹងក្រឡាបជាដើមឲ្យដល់ភិក្ខុមួយ
អង្គ បំណែកកំទេចខ្ទាត់ទៅធ្លាក់ចុះក្នុងបាត្រនៃភិក្ខុដទៃ គប្បីទទួលប្រគេន
បាត្រទៀត ។ គេពុះលើបាត្រភិក្ខុណា កាលបើបំណែកតូចធ្លាក់ចុះក្នុង
បាត្រនៃភិក្ខុនោះមិនមានទោស ព្រោះគេបង្អោនចូលទៅដើម្បីនឹងឲ្យ
ហើយ ទាយកគេយកបាត្រដ៏ពេញដោយបាយបាយាសមកប្រគេន ភិក្ខុ
មិនអាចនឹងទប់ខាងក្រោមបាន ព្រោះកំពុងក្តៅ នឹងទប់សូម្បីក្នុង
កណ្តាប់ មាត់បាត្រក៏គួរពិត ជាបើមិនអាចនឹងទប់កណ្តាប់មាត់បាត្របាន
ក៏គប្បីយកជើងបាត្រនឹងទទួល ៗ ភិក្ខុកាន់បាត្រអង្គុយនៅក្នុងរោងឆាន់ហើយ
លក់ទៅ គេបង្អោនរបស់ចូលមកក៏មិនដឹង គេឲ្យក៏មិនដឹង មិនមែនជា
ការទទួលប្រគេន ។ ជាបើចងចិត្តទុកថា នឹងទទួលហើយអង្គុយងោ
ងោកក៏គួរ ។ ជាបើភិក្ខុអង្គុយលែងដៃចាកជើងបាត្រ យកជើងជាន់ទុក
អង្គុយលក់ទៅងោក ជាការទទួលប្រគេនពិត តែយកជើងជាន់ជើង
បាត្រទទួល សូម្បីដល់ភ្ញាក់ឡើងក៏ឈ្មោះថាជាការទទួលដោយមិនអើពើ
ព្រោះហេតុនោះ កុំគប្បីធ្វើ ។ អាចារ្យទាំងឡាយចំពួកខ្លះពោល
ថា ទទួលដោយជើងបាត្រដូច្នោះ ឈ្មោះថាទទួលដោយរបស់ជាប់
ជាមួយនឹងរបស់ដែលជាប់ដោយកាយ ព្រោះហេតុនោះមិនគួរ ។ ពាក្យ
អាចារ្យអម្បាលនោះគ្រាន់តែជាពាក្យពោលប៉ុណ្ណោះ តែថាដោយសេចក្តី
របស់ទាំងពួងនោះឈ្មោះថាជារបស់ជាប់ដោយកាយពិត សូម្បីក្នុងកាយ-
សំសគ្គៈលោកក៏សំដែងន័យដូច្នោះ សូម្បីរបស់ណាមួយគេប្រគេនដល់ភិក្ខុ

www.budinst.gov.kh www.elibraryofcambodia.org

ហើយធ្លាក់ចុះ នឹងរើសយករបស់នោះខ្លួនឯងដាក់ក៏គួរ ៗ ព្រោះព្រះអង្គទ្រង់អនុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ យំ ធិយមានំ បតតិ តំ សាមំ គហេត្វា បរិភុញ្ជិតុំ ។ ល ។ ឆាយកោហិតំ ម្នាលភិក្ខុទាំងឡាយរបស់ណាកាលបើគេឲ្យហើយធ្លាក់ចុះ គប្បីកាន់យកដោយខ្លួនឯងដាក់ចុះ ព្រោះរបស់នោះទាយកគេលះហើយ ៗ ក៏ឯសូត្រនេះជានេយ្យត្ថៈ ព្រោះហេតុនោះ គប្បីដឹងអធិប្បាយក្នុងសូត្រដូច្នេះថា របស់ណាគេឲ្យ របូតអំពីដៃទាយកធ្លាក់ចុះលើផែនដីដែលស្អាត ឬលើស្លឹកឈូកនឹងសំពត់ នឹងកន្ទេលជាដើម នឹងរើសខ្លួនឯងនូវរបស់នោះដាក់ក៏គួរ តែរបស់ណាធ្លាក់ចុះលើផែនដីដែលមានធូលី របស់នោះគប្បីជូត ឬលាងចេញ ឬឲ្យគេប្រគេនទៀតហើយដាក់ចុះៗ ថាបើរបស់នោះរមៀលទៅដល់ភិក្ខុដទៃ សូម្បីនឹងឲ្យភិក្ខុដទៃនោះរើសមកឲ្យក៏គួរ ៗ ថាបើប្រាប់ឲ្យភិក្ខុដទៃនោះដាក់ សូម្បីភិក្ខុដទៃនោះនឹងដាក់ក៏គួរ តែភិក្ខុដទៃនោះម្ចាស់របស់មិនបានបង្គាប់ក៏គប្បីកាន់យក សូម្បីម្ចាស់របស់មិនបានបង្គាប់នឹងកាន់យកដោយគិតថានឹងឲ្យដល់ម្ចាស់របស់ក៏គួរពិត ពាក្យនេះពោលទុកក្នុងកុរុន្ទី ក៏ឯភិក្ខុដទៃកាន់យករបស់នោះ មិនគួរ ព្រោះព្រះអង្គមិនទ្រង់អនុញ្ញាត វៀតព្រះអង្គពោលទុកថា ឲ្យកាន់យកដាក់ខ្លួនឯងនេះ គឺថា អនុញ្ញាតថា របស់ដាក់នោះគេឲ្យដល់ភិក្ខុណាហើយធ្លាក់ចុះ សូម្បីមិនបានប្រគេន ភិក្ខុនោះកាន់យកដាក់បាន ក៏តែដោយពាក្យថារបស់នោះទាយកគេលះហើយ នេះសំដែងថា របស់នោះនៅជារបស់អ្នកដទៃនៅឡើយ ព្រោះហេតុ

www.budinst.gov.kh www.elibraryofcambodia.org

នោះ កិច្ចដែលកាន់យកធាន់ខ្លួនឯងមិនគួរ តែទឹងកាន់យកធាន់ដោយបង្គាប់នៃភិក្ខុម្ចាស់របស់នោះក៏គួរ បានឮថានេះឯងជាពាក្យអធិប្បាយក្នុងសូត្រនេះ ។ ក៏ឯរបស់នោះព្រះអង្គទ្រង់អនុញ្ញាតព្រោះមិនបានទទួលប្រគេន ព្រោះហេតុដូច្នោះ របស់នោះដែកលំនៅដូចម្ដេចមិនបានពាល់ត្រូវឡើយ យកវត្ថុណាមួយគ្របបិទទុក សូម្បីក្នុងថ្ងៃតរប់ ២ ទឹងធាន់ក៏គួរ មិនត្រូវអាបត្តិព្រោះសន្និធិ តែគប្បីទទួលប្រគេនហើយធាន់ចុះ ។ ដ្បិតថាព្រះអង្គអនុញ្ញាត ឲ្យភិក្ខុនោះកាន់យកធាន់ដោយខ្លួនឯងតែក្នុងថ្ងៃនោះប៉ុណ្ណោះ ខាងមុខអំពីថ្ងៃនោះទៅ មិនអនុញ្ញាត បានឮថាពាក្យដូច្នេះក៏ជាអធិប្បាយក្នុងសូត្រនេះ ។

អំពីនេះទឹងពោលអំពីអព្ភោហារិកន័យ កាលបើធាន់ ឆ្ងេញទឹងក្រចកនិងស្នាមនៃបាត្រសិករចអស់ទៅ របស់ទាំងពួងជាអព្ភោហារិកទាំងអស់ កាលបើយកកាំបិតមុតល្អសអំពៅ ស្នាមក៏ប្រាកដនៅ ស្នាមនោះឈ្មោះថាកើតឡើងថ្មី គប្បីទទួលប្រគេនហើយធាន់ ។ កាលបើសំលៀងកាំបិតហើយទើបល្អស ស្នាមមិនប្រាកដ គ្រាន់តែធំក្លិនប៉ុណ្ណោះ របស់នោះជាអព្ភោហារិក សូម្បីអំពៅដែលល្អសដោយកាំបិតដែលកាន់យកវត្ថុទុកក៏ដូចគ្នា ព្រោះថាមិនបានរក្សាកាំបិតទុកដើម្បីទឹងបរិភោគ ។ កាលបើកិនថ្នាំបុកថ្នាំឬសឈើជាដើម ដុំទឹងក្ដួនដុំកិន ឬត្បាល់ ឬអង្រែរសិករលទៅអស់ក្តី ឬយកកាំបិតដែលរក្សាទុកពេលគ្លើងជ្រលក់ក្នុងខ្ទាញ់ ទឹងទឹកដោះស្រស់ ដើម្បីទឹងឲ្យជាថ្នាំក្តី បើពណ៌ទៀវប្រាកដក្នុងរបស់នោះ

www.budinst.gov.kh www.elibraryofcambodia.org

វិនិច្ឆ័យដូចពោលហើយក្នុងកាំចិតល្អួសអំពៅ តែខ្លាញ់ជាដើម ដែលជារបស់ទៅ កុំគប្បីដាក់កាំបិតនោះចុះដោយខ្លួនឯង ថាបើដាក់ចុះដោយខ្លួនឯងមិនរួចអំពីសាមបក្កៈ ។ កាលទៅបិណ្ឌបាតក្នុងពេលកំពុងភ្លៀង ទឹកភ្លៀងហូរអំពីខ្លួន ឬចីវរ ស្រក់ចុះទៅក្នុងបាត្រ គប្បីទទួលប្រគេនបាត្រ សូម្បីកំពុងឆាន់ក្រោមម្លប់ឈើជាដើម ទឹកភ្លៀងធ្លាក់ចុះក៏ដូចគ្នា ។ បើភ្លៀងធ្លាក់៧ថ្ងៃ ទឹកភ្លៀងថ្លា ឬទឹកភ្លៀងធ្លាក់អំពីអាកាសក៏គួរ ។ កាលនឹងឲ្យបាយដល់សាមណេរ កុំគប្បីពាល់ត្រូវរបស់នៅក្នុងបាត្រនៃសាម-ណេរនោះឡើយ ឬគប្បីទទួលប្រគេនបាត្រនៃសាមណេរសិន ព្រោះថាពាល់ត្រូវបាយក្នុងបាត្រដែលមិនបានប្រគេនហើយ មកកាន់យកបាយក្នុងបាត្រនៃខ្លួនទៀត បាយដែលជាប់មកនោះជាឧគ្គហិត បើប្រាថ្នានឹងឲ្យហើយពោលថា ម្នាលសាមណេរ អ្នកចូរយកបាត្រមកទទួលយកបាយចុះ ចំណែកខាងសាមណេរក៏ឃាត់ថាល្មមហើយ សូម្បីភិក្ខុនឹងពោលទៀតថា របស់នេះយើងលះដល់អ្នកហើយ សាមណេរពោលថាខ្ញុំមិនត្រូវការ សូម្បីនឹងលះដល់មួយរយដង របស់នោះក៏គង់នៅក្នុងដៃរបស់ខ្លួន ក៏គង់ជារបស់ប្រគេននៅដោយពិត ថាបើបាត្រតាំងទុកលើជើងបាត្រមិនមានអាល័យ ប្រាប់ឲ្យសាមណេរកាន់យកហើយ គប្បីទទួលប្រគេនជាថ្មី ថាបើមានអាល័យតាំងទុកលើជើងបាត្រ ប្រាប់ដល់សាមណេរថា ម្នាលសាមណេរ អ្នកចូរកាន់យកនំ ឬបាយអំពីបាត្រនោះ សាមណេរលាងដៃហើយកាន់យកសូម្បីមួយរយដង ថាបើដាក់ចុះក្នុងបាត្រខ្លួន

www.budinst.gov.kh www.elibraryofcambodia.org

ដៃមិនបានពាល់បាយក្នុងបាត្រខ្លួនឡើយ កិច្ចដែលនឹងទទួលប្រគេនទៀតមិនមាន ថាបើពាល់បាយក្នុងបាត្រខ្លួនហើយ មកកាន់យកបាយអំពីបាត្រភិក្ខុនោះ បាយនោះក៏ប្រឡំដោយបាយរបស់សាមណេរ គប្បីទទួលប្រគេនជាថ្មីទៀត តែអាចារ្យទាំងឡាយជំពូកខ្លះពោលថា បើសូម្បីបាយដែលសាមណេរកាន់យកដាច់ ហើយធ្លាក់ចុះក្នុងបាត្ររបស់ភិក្ខុ គប្បីទទួលប្រគេនជាថ្មី ពាក្យនោះគប្បីដឹងក្នុងរបស់ដែលភិក្ខុកំណត់ថា អ្នកចូរកាន់យកដុំបាយមួយដុំ អ្នកចូរកាន់យកនំមួយ ចូរកាន់យកក្នុងប្រទេសចុះណោះនៃដុំស្ករនេះដូច្នេះ តែក្នុងពាក្យមុននេះ មិនមានកំណត់ ព្រោះហេតុនោះ របស់ណាធ្លាក់ចុះក្នុងបាត្រនៃសាមណេរ របស់នោះគង់ដាច់ប្រគេន តែរបស់ដែលនៅក្នុងដៃសាមណេរ សាមណេរមិនបានពោលថាល្មមហើយ ឬភិក្ខុមិនទាន់ឃាត់ចេញដកចេញ របស់នោះនៅជារបស់ភិក្ខុនៅឡើយ ព្រោះហេតុនោះ មិនដាច់ប្រគេន ។ ថាបើដាក់បាយចុះក្នុងផ្ទាំងរបរនៃខ្លួនឬភិក្ខុដទៃ ដើម្បីដណ្តាំ គប្បីនិយាយនឹងសាមណេរឲ្យយកដៃទទួលទុកលើមាត់ផ្ទាំង ហើយដាក់ចុះក្នុងដៃសាមណេរនោះ បាយនោះធ្លាក់ចុះតាមដៃសាមណេរ ធ្លាក់ចុះក្នុងផ្ទាំងបាយនោះមិនធ្វើផ្ទាំងឲ្យជាអកប្បិយទៅក្នុងថ្ងៃគំរប់ ២ ព្រោះថាលះហើយ ថាបើមិនធ្វើដូច្នេះដាក់ចុះទេ គប្បីធ្វើផ្ទាំងឲ្យប្រាសចាកអាមិសដូចបាត្រ បរិភោគចុះ ។ ទាយកទាំងឡាយគេដំកល់ផ្ទាំងបាយទុកហើយចេញទៅ សាមណេរមិនអាចនឹងលើកផ្ទាំងនោះឡើងប្រគេនបាន ភិក្ខុផ្អៀងបាត្រចូលទៅ សាមណេរ-

ណោះស្មៀនមាត់ផ្តាំងចុះលើមាត់បាត្រសំរិតចុះ បបរដែលធ្លាក់ចុះក្នុងបាត្រ ថាការប្រគេនដោយពិត្រ ។

ម្យ៉ាងទៀត ភិក្ខុដាក់ដៃចុះលើផែនដី សាមណេររំកិលផ្តាំងឲ្យទៀងលើ ដៃៈខាងក៏គួរ ។ ស្លម្បក្នុងកញ្ចើរបាយ បាច់អំពៅ ក៏ដូចគ្នាយ៉ាងនោះ ថា បើបាច់អំពៅល្មមធ្ងន់មបុរសម្នាក់លើកប្រគេនបាន សាមណេរពីរនាក់ បីនាក់ជួយលើកគ្នាប្រគេន ឬម្នាក់ឯងមានកម្លាំងលើករួច ភិក្ខុពីរអង្គ បីអង្គ ជួយទទួលគ្នាក៏គួរ ។ យកផ្តាំងប្រេងឬផ្តាំងទឹកអំពៅព្យួរទុកនឹងដងរែក ឬ ដងតាំង ភិក្ខុទៀងអង្គុយលើរែកនឹងតាំងក៏គួរ មិនជាទុគ្គហិត ។ ផ្តាំងពីរ ចំរួតគ្នាព្យួរនឹងដៃកែវឬចំពក់ ផ្តាំងខាងលើទទួលប្រគេនហើយ ផ្តាំង ក្រោមមិនបានទទួលប្រគេន នឹងកាន់យកផ្តាំងខាងលើក៏គួរ ។ ផ្តាំងខាង ក្រោមទទួលប្រគេនហើយ ផ្តាំងខាងលើមិនបានទទួលប្រគេន កាលបើ លើកផ្តាំងខាងលើឡើងកាន់យកផ្តាំងខាងក្រោម ផ្តាំងលើក៏ជាទុគ្គហិត ។ កាជនៈដាក់ប្រេងមិនបានទទួលប្រគេននៅក្រោមរែក ថាបើបោសទៅ យកអំបោសទាំងខ្ចប់កាជនៈនោះមិនជាទុគ្គហិត ។ គិតនឹងកាន់យក របស់ដែលទទួលប្រគេនហើយ ទៅចាប់យករបស់ដែលមិនបានទទួល ប្រគេន ដឹងហើយត្រឡប់ដាក់លើទុកក្នុងទីដូចដើមវិញ មិនជាទុគ្គហិត ។ នាំចេញទៅខាងក្រៅហើយទើបដឹង កុំគប្បីដាក់លើទុកខាងក្រៅ គប្បីនាំ មកដាក់លើទុកក្នុងទីដើម មិនមានទោសឡើយ ។ ថាបើរបស់នោះគេបើក គ្រប់មុនហើយដាក់លើទុក ក៏កុំគប្បីគ្របចុះ កាលដើមតាំងទុកយ៉ាងណា

www.budinst.gov.kh www.elibraryofcambodia.org

គប្បីតាំងទុកយ៉ាងនោះ ថាបើតាំងទុកខាងក្រៅកុំគប្បីពាល់ត្រូវទៀត ។ ថាបើនាំយកចុះមកខាងក្រោមប្រាសាទ ដល់ពាក់កណ្ដាលជណ្ដើរទើបដឹង ព្រោះមិនមានឱកាស គប្បីនាំទៅខាងលើឬខាងក្រោម តាំងទុកចុះមិនជាឧគ្គហិត ។ ផ្សិតកើតឡើងក្នុងប្រេងដែលទទួលប្រគេនទុកហើយ លំអិតខ្ទិតកើតឡើងក្នុងទឹជាដើមដែលទទួលប្រគេនហើយ របស់នោះឈ្មោះថាកើតឡើងក្នុងទីនោះឯង កិច្ចដែលទទួលប្រគេនទៀតមិនមាន មនុស្សឡើងទៅលើដើមត្នោតឬដើមដូង យកខ្សែចងធ្លាយសំរូតចុះមក មនុស្សដែលនៅលើស្រែកប្រាប់ឲ្យទទួលយកកុំគប្បីទទួល ថាបើមនុស្សដទៃនៅលើផែនដីគេកាន់ក្រវិលខ្សែលើកប្រគេនឲ្យក៏គួរ ។ ឲ្យគេធ្វើគញ្ជើយមែកឈើធំដែលមានផ្លែហើយទទួលប្រគេន ផ្លែឈើតាំងឡាយជារបស់ទទួលប្រគេនដោយពិត ឆាន់បរិភោគតាមសប្បាយក៏គួរ ។ មនុស្សឈរនៅខាងក្នុងរបងដែលធ្លុះប្រហោង លូកដៃចេញទៅប្រគេនអំពៅឬទន្លាប់ កាលបើបានហត្ថបាសហើយឆាន់ទទួលក៏គួរ របស់នោះមិនបានទង្គិចនឹងបង្គោលរបងចេញទៅ កាលបើទទួលយកក៏គួរ ក្នុងរបស់ដែលទាំងខ្ទប់នឹងរបងចេញទៅ លោកមិនបានសំដែងទោសទុកក្នុងអដ្ឋកថាតាំងឡាយ តែយើងតាំងឡាយពិចារណាឃើញថា របស់នោះទាំងខ្ទប់នឹងទីណា មើលទៅដូចជារបស់ធ្លាក់ចុះឯងតាមទីនោះ សូម្បីពាក្យនោះកាលបើរបស់នោះមិនឈប់លឿនទៅក៏ត្រឹមត្រូវ ដូចយ៉ាងកណ្ដៈដែលរមៀលចេញទៅខាងក្រៅផ្ទះគេ មនុស្សបោះរបស់លែងរបងឬកំពែងមកឲ្យ ថាបើកំពែងមិន

www.budinst.gov.kh www.elibraryofcambodia.org

បានក្រាស  កាលបើឈើនៅក្នុងកំពែងឬក្រៅកំពែងល្មមបានហត្ថបាស របស់នោះអវិណ្ណតឡើងទៅសូម្បីមួយរយហត្ថធ្លាក់ចូលមកដល់ នឹងទទួលយកក៏គួរ ។ ភិក្ខុបញ្ជិះសាមណេរលើស្មាទៅ  សាមណេរឃើញផលាផលក៏បេះ  អង្គុយនៅលើស្មានោះហុចឲ្យក៏គួរ  សាមណេរបញ្ជិះភិក្ខុទៅប្រគេនរបស់ឲ្យដល់ភិក្ខុអង្គុយនៅលើស្មាក៏គួរពិត ៗ ភិក្ខុកាន់មែកឈើមានផ្លែដើម្បីជាគ្រែដើរទៅ  ចិត្តចង់នឹងឆាន់ផ្លែឈើនោះ  នឹងឲ្យគេប្រគេនហើយឆាន់ក៏គួរ ឲ្យគេធ្វើកប្បិយហើយទទួលប្រគេនមែកឈើដើម្បីបក់រុយបើចង់ឆាន់សោត ទទួលប្រគេនមុននោះក៏គួរ  កាលឆាន់មិនមានទោស ។ ភិក្ខុដាក់កល់របស់គួរប្រគេន ក្នុងរទេះនៃមនុស្សបើយដើរផ្លូវទៅ  រទេះជាប់ភក់  ភិក្ខុចាប់កង់រទេះលើកឡើងក៏គួរ  មិនឈ្មោះជាឧគ្គហិត ៗ ដាក់កល់របស់ទុកក្នុងទូក  ដោលទូកទៅឬគូសទៅដោយដៃក៏គួរ  សូម្បីក្នុងក្បូនក្នុងផែក៏ដូចគ្នា  សូម្បីនឹងយករបស់ទុកក្នុងពាង ឬខ្ទិន ឬក្នុងថ្លាងហើយឲ្យអនុបសម្បន្នកាន់ភាជនៈនោះ  ហើយចាប់ជើងដៃ  អនុបសម្បន្នទាំងនឹងទឹកទៅក៏គួរ ៗ  សូម្បីកាលបើភាជនៈនោះមិនមាន  នឹងឲ្យអនុបសម្បន្នកាន់របស់នោះ  ហើយចាប់ជើងដៃអនុបសម្បន្នទាំងនឹងទឹកទៅក៏គួរ ៗ ឧបាសកទាំងឡាយ  ប្រគេនអង្ករជាស្បៀងដល់ភិក្ខុដើរផ្លូវ  សាមណេរកាន់យកអង្ករនៃភិក្ខុហើយ  មិនអាចកាន់យកនូវអង្កររបស់ខ្លួនទៅបាន ភិក្ខុទាំងឡាយកាន់យកអង្ករនៃសាមណេរទៅ  សាមណេរទាំងឡាយ  កាលបើអង្ករដែលខ្លួនកាន់យកទៅអស់ហើយ  យកអង្ករដែលភិក្ខុកាន់ទៅដណ្តាំ

www.budinst.gov.kh www.elibraryofcambodia.org

ឡើងហើយ យកបាត្រនៃភិក្ខុនឹងបាត្រនៃខ្លួនដាក់លាក់ទុកដោយលំដាប់ហើយ ដួសបបរដាក់ចុះ សាមណេរជាមនុស្សឈ្លាសយកបាត្ររបស់ខ្លួនប្រគេនដល់ព្រះមហាថេរ យកបាត្រមហាថេរប្រគេនដល់អនុថេរ ផ្លាស់ប្តូរដូច្នេះរៀងរាបដរាបដល់អស់ទៅ ភិក្ខុទាំងពួងឈ្មោះថាឆាន់វត្តជារបស់សាម-ណេរគួរ បើសាមណេរមិនឈ្លាស ប្រារព្ធនឹងឆាន់នូវបបរក្នុងបាត្ររបស់ខ្លួន ព្រះថេរទាំងឡាយនឹងសួមថាអ្នកចូរឲ្យបបររបស់អ្នកដល់យើងដូច្នេះដោយលំដាប់ហើយឆាន់ក៏គួរ ភិក្ខុទាំងពួងឈ្មោះថាឆាន់វត្តជារបស់សាម-ណេរនោះឯង មិនត្រូវទោស ព្រោះឧគ្គហិត មិនត្រូវទោសព្រោះសន្និធិ ។ ឯក្នុងទីនេះភិក្ខុយករបស់មានប្រេងជាដើមទៅដើម្បីឲ្យដល់មាតាបិតា នឹងកាន់យកមែកឈើទៅដើម្បីនឹងធ្វើគ្រែជាដើម ជាមួយនឹងភិក្ខុដែលកាន់អង្ករសាមណេរទៅនោះ ឃើញដូចមិនថ្លៃគ្នា ព្រោះហេតុនោះ គប្បីពិចារណាមើលហេតុចុះ ។ សាមណេរប្រាថ្នានឹងដណ្តាំបាយហើយលើកឆ្នាំងឡើង ភិក្ខុគប្បីទទួលប្រគេនអង្ករ នឹងឆ្នាំងហើយប្រគេនអង្ករ លើកឆ្នាំងឡើងដាក់លើចង្ក្រាន កុំបន្តក់ភ្លើង កាលបើឆ្អិនហើយ គប្បីបើកឡើងមើលឲ្យដឹងថាឆ្អិនហើយឬនៅ ថាបើមិនទាន់ឆ្អិនទេនឹងគ្របចុះដើម្បីឲ្យឆ្អិនមិនគួរ បើគ្របចុះដើម្បីមិនឲ្យធូលី ឬផេះធ្លាក់ចុះក៏គួរ កាលបើឆ្អិនហើយនឹងដាក់ចុះហើយនឹងឆាន់ក៏គួរ តៈទៅកិច្ចដែលនឹងប្រគេនទៀតមិនមាន ។ សាមណេរអាចនឹងចំអិនបាន តែគ្មានឱកាសទំនេរដោយប្រាថ្នានឹងទៅទីណាមួយ ភិក្ខុគប្បីនិយាយថា អ្នកចូរប្រគេន

www.budinst.gov.kh www.elibraryofcambodia.org

ឆ្នាំងដាំងអង្ករនឹងទឹកសិន ហើយលើកឆ្នាំងដាក់លើចង្រ្កាន បង្កាត់ភ្លើងឲ្យឆេះ ហើយទៅចុះផ្លូវចុះ គេទៅភិក្ខុធ្វើកិច្ចតាំងពួងដោយន័យដូចមុនក៏គួរ ៗ ភិក្ខុត្រូវការដោយបបរ លើកឆ្នាំងដែលលាងស្អាតឡើងដាក់លើចង្រ្កាន ហើយដាំទឹកឲ្យក្តៅក៏គួរ កាលបើទឹកក្តៅហើយ សាមណេរច្រកអង្ករចុះតែគតែនោះទៅ ភិក្ខុកុំគប្បីបង្កាត់ភ្លើង បបរឆ្អិនហើយនឹងទទួលប្រគេនឆាន់ក៏គួរ ។ សាមណេរកំពុងបបរ ភិក្ខុពើសវៃ យកដៃស្ទាបឆ្នាំង ស្ទាបគ្របឆ្នាំង គៀរពពុះ ដែលពោរឡើងលើង ភិក្ខុនោះនឹងឆាន់មិនគួរ ឈ្មោះថាទុរុបចិណ្ណសន្សំគាត្រក់ ៗ ថាបើកាន់វែក ឬចាយ មិនលើកឡើង គ្រាន់តែកូរសោត មិនគួរដល់ភិក្ខុតាំងពួង ព្រោះជាសាមបក្កៈផង ជាទុរុបចិណ្ណៈផង ថាបើលើកឡើងចេញសោតជាទុគ្គហិតផង ៗ ភិក្ខុដើរទៅបិណ្ឌបាត មកហើយយកបាត្រមកដំកល់ទុកលើជើងបាត្រ របស់នោះដាច់ប្រគេនហើយ ថាបើភិក្ខុរឡេះរឡោះ លូកដៃទៅស្ទាបបាត្រ ស្ទាបគ្របបាត្រលេងសោត បាយដែលបានមកក្នុងបាត្រនោះ មិនគួរដល់ភិក្ខុនោះតែមួយអង្គ ថាបើភិក្ខុនោះលើកបាត្រឡើងហើយដាក់ចុះវិញ បាយនោះមិនគួរដល់ភិក្ខុតាំងពួង ។ ភិក្ខុពាប់មែកឈើ ឬវល្លិ៍ មានផ្លែដែលកើតនៅក្នុងទីនោះ អង្រ្រួនឲ្យរញ្ជួយ ផ្លែឈើដែលបានមកអំពីអង្រ្រួនដើមនោះ មិនគួរដល់ភិក្ខុតែមួយអង្គ ត្រូវទុរុបចិណ្ណទុក្កដផង ឯផ្នែកឬពាប់តាល់ត្រូវដើមឈើដែលមានផ្លែ ឬបន្ទា ក្នុងដើមឈើនោះ ក៏គួរមិនត្រូវទុរុបចិណ្ណ ពាក្យនេះពោលទុកក្នុងមហាបច្ចរី ភិក្ខុឃើញផ្លែ

www.budinst.gov.kh www.elibraryofcambodia.org

ស្វាយជាដើមជ្រុះចុះក្នុងព្រៃ គិតនឹងឲ្យដល់សាមណេរ នាំយកមកឲ្យក៏គួរ ឃើញសាច់ជាអំពាកដសីហ៍ជាដើម គិតនឹងឲ្យដល់សាមណេរ នឹងទទួលប្រគេន ឬមិនទទួលប្រគេនក្តី យកមកឲ្យក៏គួរ ថាបើកាចនឹងដំរះវិតក្កបានសោត សូម្បីនឹងឆាន់របស់ដែលបានមកអំពីសំណល់នោះក៏គួរ មិនត្រូវទោសព្រោះទទួលសាច់ស្រស់ នឹងមិនត្រូវទោស ព្រោះឧគ្គហិត កាលបើកាន់យកប្រេងជាដើមដើរទៅ ដើម្បីនឹងឲ្យដល់មាតាបិតា ព្យាធិបង្កើតឡើងកណ្តាលផ្លូវ របស់អម្បាលនោះខ្លួនប្រាថ្នារបស់ណា នឹងទទួលប្រគេនរបស់នោះបរិភោគក៏គួរ តែបើទទួលទុកហើយអំពីដើម កិច្ចដែលនឹងទទួលទៀតមិនមាន ។ ប្រាថ្នានឹងឲ្យដល់មាតាបិតានាំអង្ករនោះទៅ កាលបើឲ្យទៅហើយ មាតាបិតាគាត់តែងបបរជាដើមដោយអង្ករនោះ ប្រគេនដល់ភិក្ខុនោះក៏គួរ មិនត្រូវទោសព្រោះសន្និធិឬឧគ្គហិត ។ ភិក្ខុគ្របមាត់ឆ្នាំងហើយដាំទឹកក្តៅ នឹងឆាន់ទៅត្រាតែរស់ក៏គួរ ថាបើផេះធ្លាក់ចុះក្នុងទឹកនោះគប្បីទទួលប្រគេនទៀត យកដំបៀតវែងកៀតកាជនរំងាស់ប្រេង ផេះធ្លាក់ចុះកុំលែងដៃចេញ រំងាស់ហើយគប្បីដាក់ចុះ ហើយទទួលប្រគេនទៀតចុះ ថាបើព្យង់ឬឧស ទទួលប្រគេនទុកហើយសោត ទទួលប្រគេននោះក៏គួរ ។ ភិក្ខុកំពុងឆាន់អំពៅ សាមណេរសូមអំពៅភិក្ខុប្រាប់ឲ្យគាត់យកប្រវែងណោះ សាមណេរក៏កាត់យកតាមបង្គាប់ ដែលសល់នៅនោះ កិច្ចដែលនឹងឲ្យប្រគេនទៀតមិនមាន ។ សូម្បីភិក្ខុកំពុងឆាន់ស្ករអំពៅក៏ដូចគ្នាយ៉ាងនោះ ព្រោះថារបស់

www.budinst.gov.kh www.elibraryofcambodia.org

ដែលសល់នៅ ចាកចំណែកដែលអនុបសម្បន្នកាន់យកអំពីគេកាសដែល
ភិក្ខុប្រាប់ឲ្យនោះ មិនជាប់ប្រគេនពិត ៗ ភិក្ខុចែកជុំស្លាអំពៅទទួលប្រគេន
ហើយចាត់ជាចំណែកៗទុក ភិក្ខុខ្លះសាមណេរខ្លះមកទទួលចំណែក សាម-
ណេរនោះ មកកាន់យកចំណែកមួយ ៗ ចាប់តែម្តងហើយទៅ ចំណែក
ដែលសេសសល់នៅនោះជារបស់ទទួលប្រគេនហើយពិត ៗ ជាបើសាមណេរខ្សេះ
ខ្សោះកាន់យកហើយដាក់ចុះវិញ ចំណែកដែលសាមណេរកាន់យកសល់
នៅនោះជាប់ប្រគេន ៗ ភិក្ខុទទួលបារីមកដក់ មាត់នឹងកជាប់ផ្សែងដូច
មនោសិលា ជាបើនឹងឆាន់យាវកាលិកក៏គួរ នឹងមានទោសព្រោះប្រឡំ
យាវជីវិកជាមួយនឹងយាវកាលិក មិនមាន ៗ កាលបើផុតបាត្រ ឬដាំទឹក
ជ្រលក់ ផ្សែងចូលទៅក្នុងប្រហោងត្រចៀកប្រហោងច្រមុះប្រហោងមាត់
នឹងបើបផ្កាឈើ ឬផ្លែឈើ ព្រោះអាពាធក្តីរមែងគួរ ព្រោះរបស់អម្បាល
នោះ ជាអព្វោហារិកទាំងអស់ ៗ កើរបង្អែរ ឲ្យរបស់ឆាន់ចេញមកទល់នឹង
ពិតាន ហើយត្រឡប់ចូលទៅទាំងក្នុងក៏គួរ ព្រោះមិនមែនវិស័យ ៗ ចេញ
មកដល់មាត់ហើយ ត្រឡប់លេបទៅទៀត ក្នុងវិកាលត្រូវអាបត្តិ សូម្បី
សេនៃគាមិសជាប់នៅក្នុងចន្លោះធ្មេញ ត្រឡប់ចូលទៅក៏ត្រូវអាបត្តិដោយ
ពិត ៗ ជាបើគាមិសល្អិតមិនប្រាកដ គង់ជាចំណែកទាំងអព្វោហារិក
កាលវេលាផឹកថ្មៃត្រង់ឆាន់បង្ហាន់ក្នុងថ្ងៃមិនមានទឹកហើយ គប្បីខាកស្តោះ
ទឹកមាត់ចេញ ២ ដុំ ៣ ដុំ ហើយទៅកាន់ទីមានទឹកលាងមាត់ចេញ ៗ ទីជា
ដើមទទួលប្រគេនហើយ ដំកល់ទុកពន្លកវែកចេញ ភិក្ខុដែលនឹងទទួល

www.budinst.gov.kh www.elibraryofcambodia.org

ប្រគេនទៀតមិនមាន ។ កាលបើអំបិលមិនមាន យកទឹកសមុទ្រមកធ្វើអំបិលក៏គួរ ទឹកប្រៃទទួលប្រគេនហើយ ដំកល់ទុកត្រឡប់ទៅជាអំបិល ឬអំបិលរលាយទៅជាទឹកអស់ ឬទឹកអំពៅទៅជាស្ករឬស្ករអំពៅរលាយទៅជាទឹកក្តី ទទួលប្រគេនពេលមុននោះឯងរមែងគួរ ។ គ្រាប់ព្រឹលក៏ជាគតិនៃទឹកពិត យកគ្រាប់ផ្លែល្ងៀតដែលរក្សាទុក ត្រាំក្នុងទឹកដើម្បីនឹងឲ្យថ្លា របស់នោះជាអព្វោហារិក ឆាន់ទឹកនោះជាមួយនឹងអាមិសក៏គួរ ។ ទឹកដែលយកផ្លែខ្ទិតជាដើម ដែលជាគតិនៃអាមិស ដាក់ក្នុងទឹកឲ្យថ្លារមែងគួរ តែក្នុងវេលាព្រឹកមួយយ៉ាង ។ ទឹកក្នុងស្រះបោក្ខរណីជាដើមជាទឹកល្អក់ក៏គួរ ថាបើជាប់មាត់ជាប់ដៃបានសោតមិនគួរ ទឹកនោះគប្បីទទួលប្រគេនចុះ ថាបើទឹកនោះហូរចុះទៅកាន់ប្រឡាយ ... កៈទៅពេញក្នុងស្មឹងរមែងគួរ ។ ត្រពាំងជាដើម ដែលមាន... នោះដេរដាសទៅដោយផ្កាទន្លាដែលជ្រុះចាកដើម ... ប្រាកដសោត កិច្ចដែលនឹងទទួលប្រគេននោះមិនមាន ។ ... ប្រាកដគប្បីទទួលប្រគេនសិន សម្បកក្នុងទឹកដែលមានស្លឹកឈើតាសផ... ខ្ទៅពាសពេញនៅក្នុងជ្រោះទៀបភ្នំជាដើមក៏ដូចគ្នា យកផ្កាឈើដែលមានកេសរឬដក់ក្នុងទង ដាក់ចុះក្នុងក្អមទឹកឆាន់ គប្បីទទួលប្រគេនទឹកសិន ឬទទួលប្រគេនផ្កាឈើហើយ គប្បីដាក់ទុកចុះ ។ គេដាក់ផ្កាប្រទៀងនឹងផ្កាម្ទេះចុះគ្រាន់តែអប់ក្លិន របស់នោះជាអព្វោហារិក សម្បកក្នុងផ្ទៃរបស់ទាំងនឹងឆាន់ទឹកនោះជាមួយអាមិសក៏គួរ សាមណេរដងទឹកអំពីទឹកដែលអប់ដោយ

www.budinst.gov.kh www.elibraryofcambodia.org

ផ្កាឈើដែលភិក្ខុដំកល់ទុក ហើយត្រឡប់តាក់ទឹកដែលខ្លួនឆាន់សល់ចុះក្នុងទឹកនោះៗ គប្បីប្រគេនសិន ។ ក្នុងស្រះឈូកជាដើម គេសរផ្កាឈើថេរជាសនៅលើទឹក ទើបយកក្អមប្រមុចចុះដងយកទឹកក៏គួរ ។ ឈើស្ងួនដែលភិក្ខុឲ្យគេធ្វើកប្បិយទទួលប្រគេនតាំងទុក ថាបើភិក្ខុទើបក្រោយសៅនៃឈើស្ងួននោះសោត ទទួលប្រគេនមុននោះឯងក៏គួរ ។ ឈើស្ងួនដែលមិនបានទទួលប្រគេនតាំងទុក កាលបើមិនដឹងរសចូលទៅក្នុងក ត្រូវអាបត្តិដោយពិត ថ្បិតជាសិក្ខាបទនេះជាអចិត្តកៈ ។ ក្នុងមហាកូត វត្ថុណាគួរវត្ថុណាមិនគួរ ទឹកដោះរមែងគួរ ជាទឹកដោះនៃសត្វមានសាច់ជាកប្បិយឬនៃសត្វមានសាច់ជាអកប្បិយក្ដី កាលបើក្រេបផឹកមិនត្រូវអាបត្តិ ។ ទឹកក្អែក ទឹកមាត់ ទឹកសំបោរ ទឹកមូត្រ អាហារចាស់ សេម្ហៈ មន្ទិលនៃធ្មេញពពឹកក្អែក អាចម៍ត្រចៀក ញើសដែលកើតក្នុងកាយ របស់ទាំងអម្បាលនេះ រមែងគួរទាំងអស់ ។ ឯរបស់អម្បាលនោះ វត្ថុណាជ្រុះចាកទីហើយធ្លាក់ចុះក្នុងបាត្រ ឬក្នុងដៃ របស់នោះគប្បីទទួលប្រគេនសិន វត្ថុដែលជាប់នៅក្នុងខ្លួន ជារបស់ទទួលប្រគេនស្រាប់ហើយ កាលបើឆាន់បាយបាយាសដែលក្ដៅ ញើសហូរតាមម្រាមដៃជាប់ជិតគ្នាចុះទៅ តាំងនៅក្នុងបាយបាយាស ឬកាលដើរទៅបិណ្ឌបាត ញើសហូរចាកដៃចុះទៅដល់គណ្ដាប់មាត់បាត្រ ទើបហូរអំពីគណ្ដាប់មាត់បាត្រចុះទៅកាន់ផ្ទៃបាត្រក្នុងញើសនោះ កិច្ចដែលទើបប្រគេនមិនមាន ។ ក្នុងមហាកូត ដែលផុតភ្លើងឆេះហើយ វត្ថុដែលទើបមិនគួរមិនមាន តែវត្ថុដែលផុតភ្លើងឆេះមិនល្អ

www.budinst.gov.kh www.elibraryofcambodia.org

មិនគួរ តែផុតហើយដោយប្រពៃ សូម្បីជាធម្មីនមនុស្សខំនឹងធ្វើឲ្យជាលំអិត ទំនងបង្អោនចូលទៅក្នុងរបស់លិង្គសុីគ្នា ៗ

បដិគ្គហណកថាចប់

វិធិហនាទិបព្វៈ គំរប់ ៦ ចប់

---

## អាបត្តិទេសនាទិបព្វៈគំរប់ ៧

### អាបត្តិទេសនាកថា

ពោលអំពីវិធីសំដែងអាបត្តិ ៗ អាបត្តិទាំងពួង ភិក្ខុក្លែងត្រូវហើយ រមែងជាអាណាវីតិក្កមន្តរាយិកៈ គឺធ្វើអន្តរាយដល់សួគ៌ និងមគ្គផលនិព្វាន ព្រោះទោសដែលកន្លងអាជ្ញាព្រះពុទ្ធអង្គ ព្រោះហេតុនោះ ភិក្ខុត្រូវហើយ ចំណែកអាបត្តិដែលជាវុដ្ឋានគាមិនី គប្បីប្រាប់ប្តឹងដល់ភិក្ខុដែលជាសភាគ ហើយ គប្បីរួចចេញដោយនៅបរិវាស និងប្រព្រឹត្តមានត្ត ៗ ចំណែកអាបត្តិដែលជាទេសនាគាមិនី តាំងអំពីថុល្លច្ច័យទៅ ដរាបដល់ទុក្កដ ត្រូវហើយគប្បីសំដែងនឹងសង្ឃ ឬគណៈ ឬបុគ្គល សំដែងនឹងសង្ឃ-គណៈ និងលើកទុក និងពោលតែសំដែងនឹងបុគ្គល ៗ ភិក្ខុអ្នកត្រូវនោះ គប្បីចូលទៅរកភិក្ខុមួយអង្គ អង្គុយច្រហោងលើកដៃប្រណម្យ ថាបើចាស់ជាងអ្នកទទួល គប្បីពោលថា អហំ អាវុសោ ឯកំ ថុល្លច្ច័យំ

www.budinst.gov.kh www.elibraryofcambodia.org

អាបត្តឹ អាបន្នោ ភន្តេ បដិទេសេមិ ដូច្នេះ ៗ ថាបើខ្ចីជាងអ្នក
ទទួល គប្បីពោលថា អហំ ភន្តេ បកាំ ៗ ល ៗ បដិទេសេមិ
ទាំងពីរយ៉ាង ប្រែថា បពិត្រលោកដ៏មានអាយុ-លោកដ៏ចំរើន ខ្ញុំត្រូវហើយ
នូវអាបត្តិថុល្លច្ច័យមួយ ឥឡូវនេះ ខ្ញុំសំដែងចំពោះនូវអាបត្តិនោះ ៗ
អ្នកទទួលបើខ្ចីជាង គប្បីពោលថា បស្សថ ភន្តេ ប្រែថា បពិត្រ
ព្រះករុណាដ៏ចំរើន ព្រះករុណាឃើញឬ? ថាបើចាស់ជាង គប្បីពោលថា
បស្សសិ អាវុសោ ប្រែថា ម្នាលអ្នកដ៏មានអាយុ អ្នកឃើញ ឬ?
អ្នកសំដែងចាស់ជាង គប្បីពោលថា អាម អាវុសោ បស្សាមិ ប្រែថា
ម្នាលអ្នកដ៏មានអាយុ អើខ្ញុំឃើញ ៗ ថាបើខ្ចីជាងគប្បីពោលថា អាម
ភន្តេ បស្សាមិ ប្រែថា បពិត្រព្រះករុណាដ៏ចំរើន អើខ្ញុំព្រះករុណា
ឃើញ ៗ អ្នកទទួលខ្ចីជាង គប្បីពោលថា អាយតឹ ភន្តេ សំវរេ-
យ្យាថ ប្រែថា បពិត្រលោកដ៏ចំរើន លោកទាំងឡាយគប្បីសង្រួម
តទៅចុះ ៗ ថាបើចាស់ជាង គប្បីពោលថា អាយតឹ អាវុសោ សំវ-
រេយ្យាសិ ប្រែថា ម្នាលលោកដ៏មានអាយុ លោកគប្បីសង្រួមតទៅចុះ ៗ
អ្នកសំដែងចាស់ជាង គប្បីពោលថា សាធុ សុដ្ឋុ អាវុសោ សំវ-
រិស្សាមិ ៗ ថាបើខ្ចីជាង គប្បីពោលថា សាធុ សុដ្ឋុ ភន្តេ សំវរិ-
ស្សាមិ ៗ ទាំងពីរយ៉ាង ប្រែថា បពិត្រលោកដ៏មានអាយុ លោកដ៏ចំរើន
ល្អហើយ ខ្ញុំនឹងសង្រួមដោយប្រពៃ ៗ បើអាបត្តិពីរ គប្បីពោលតាមចាស់
ថា អហំ អាវុសោ ខ្ចីថា អហំ ភន្តេ · ចាស់ថា អាវុសោ

www.budinst.gov.kh www.elibraryofcambodia.org

ឬថា ភន្តេ សំផែនថា ទ្វេ ថុល្លច្ចយាយោ អាបត្តិយោ អាបន្នោ តា បដិទេសេមិ ដូច្នេះ កាលបើអ្នកទទួលពោលតាម តស់តាមឬថា បស្សថ ភន្តេ ឬ បស្សសិ អាវុសោ ដូច្នេះហើយ គប្បីពោលតាមតស់ថា អាម អាវុសោ បស្សាមិ ឬថា អាម ភន្តេ បស្សាមិ ដូច្នេះ កាលបើអ្នកទទួលពោលតាមតស់ថា អាយតឹ អាវុសោ សំវរេយ្យាសិ ឬថា អាយតឹ ភន្តេ សំវរេយ្យាថ ដូច្នេះហើយ គប្បីពោលតាមតស់ថា សាធុ សុដ្ឋុ អាវុសោ សំវរិស្សាមិ ឬថា សាធុ សុដ្ឋុ ភន្តេ សំវរិស្សាមិ ដូច្នេះ ៗ ផងជាការប្រពៃ ។ ថាបើ អាបត្តិ ៣ ឡើងទៅ គប្បីពោលថា អហំ អាវុសោ សម្ពហុលា ថុល្លច្ចយាយោ អាបត្តិយោ អាបន្នោ តា បដិទេសេមិ ឬថា អហំ ភន្តេ សម្ពហុលា ថុល្លច្ចយាយោ អាបត្តិយោ អាបន្នោ តា បដិទេសេមិ ។ ល ។ សំវរិស្សាមិ ។ ថាបើអាបត្តិ មានវត្ថុផ្សេងៗ គ្នា គប្បីពោលថា អហំ អាវុសោ សម្ពហុលា នានាវត្ថុកាយោ ថុល្លច្ចយាយោ អាបត្តិយោ អាបន្នោ តា បដិទេសេមិ ។ ល ។ សំវរិស្សាមិ ។ អហំ ភន្តេ សម្ពហុលា នានាវត្ថុកាយោ ថុល្លច្ចយាយោ អាបត្តិយោ អាបន្នោ តា បដិទេសេមិ ។ ល ។ សំវរិស្សាមិ ។

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងអាបត្តិដទៃក៏ឲ្យផ្លាស់ឈ្មោះដូច្នេះថា អហំ ភន្តេ(១) ឯកំ និស្សគ្គិយំ បាចិត្តិយំ ។ ល ។ ឯកំ ទុក្កដំ ។ ល ។ ឯកំ ទុព្ភាសិតំ អាបត្តឹ អាបន្នោ តំ ។ ល ។ សំវរស្សាមិ ។ ថាបើពីរ ឲ្យថា ទ្វេ ថាបើច្រើនអំពីបីឡើងទៅ ឲ្យថា សម្ពហុលា ថាបើមានវត្ថុផ្សេងៗគ្នា ឲ្យថា សម្ពហុលា នានាវត្ថុកាយោ ដូច្នេះចុះ ។ តែអាបត្តិទុព្ភាសិតមិនត្រូវថា នានាវត្ថុកាយោ ព្រោះមានសិក្ខាបទតែមួយ ។ អាបត្តិបាដិទេសនិយៈនោះ ពាក្យសំដែងនៅខាងចុង ក្នុងសិក្ខាបទនោះឯង គប្បីដឹងដូចពោលហើយ ក្នុងបាដិទេសនិយវណ្ណនានោះចុះ ។ ឯនិស្សគ្គិយបាចិត្តិយាបត្តិនោះ កាលបើត្រូវហើយ គប្បីលះរបស់ដែលជានិស្សគ្គិយដល់សង្ឃ ឬគណៈ ឬបុគ្គលជាមុនសិន ហើយទើបសំដែងអាបត្តិនោះចុះ ។ លះដល់សង្ឃដល់គណៈមិនលើកទុក មិនពោលតែកិរិយាលះដល់បុគ្គល ។ សំពត់អតិរេកចីវរនៃភិក្ខុ កន្លង ១០ ថ្ងៃ ជានិស្សគ្គិយ ភិក្ខុនោះគប្បីចូលទៅរកភិក្ខុមួយអង្គ ធ្វើចីវរឆៀងស្មាម្ខាង អង្គុយច្រហោង លើកដៃប្រណម្យ ពោលថា ឥទំ មេ ភន្តេ(២) ចីវរំ ទសាហាតិក្កន្តំ និស្សគ្គិយំ ឥមាហំ អាយស្មតោ និស្សជ្ជាមិ ដូច្នេះ ឬកាន់យកសេចក្តីនោះ ពោលជាខេមរភាសាក៏បាន

(១-២) បើភិក្ខុអ្នកសំដែងអាបត្តិ ឬលះចីវរ ចាស់វស្សាជាងភិក្ខុអ្នកទទួល គប្បីថាអាវុសោ ជួស ភន្តេ ។

www.budinst.gov.kh www.elibraryofcambodia.org

ជាបពិត្រព្រះករុណាដ៏ចំរើន ចីវររបស់ខ្ញុំព្រះករុណានេះ កន្លង ១០ ថ្ងៃ ហើយ ជានិស្សគ្គិយ ខ្ញុំព្រះករុណាលះចីវរនេះ ដល់ព្រះករុណា ។ លះដូច្នេះហើយគប្បីសំដែងអាបត្តិនោះដល់អ្នកទទួល ដូចពោលហើយក្នុង មុននោះចុះ ។ ហើយអ្នកទទួលគប្បីប្រគល់សំពត់នោះឲ្យវិញ ដោយ ពាក្យថា ឥមំ ចីវរំ អាយស្មតោ ទម្មិ ដូច្នេះ ឬនឹងប្រគល់ ដោយភាសារបស់ខ្លួនក៏បាន ថាខ្ញុំឲ្យចីវរនេះដល់លោក ថាបើអ្នកទទួល មិនប្រគល់ឲ្យវិញត្រូវទុក្កដ ។ បើសំពត់ច្រើន គប្បីលះថា ឥមានិ មេ ភន្តេ ចីវរានិ ទសាហាតិក្កន្តានិ និស្សគ្គិយានិ ឥមា. នាហំ អាយស្មតោ និស្សជ្ជាមិ ដូច្នេះ ។ បាលីប្រគល់ឲ្យ វិញថា ឥមានិ ចីវរានិ អាយស្មតោ ទម្មិ ដូច្នេះ ។ ថាបើ សំពត់មួយនៅឆ្ងាយ ក្រៅហត្ថបាស គប្បីលះថា ឯតំ មេ ភន្តេ ចីវរំ ។ល។ ឯតាហំ អាយស្មតោ និស្សជ្ជាមិ ដូច្នេះ ។ ប្រគល់សំពត់ឲ្យវិញថា ឯតំ ចីវរំ អាយស្មតោ ទម្មិ ដូច្នេះ ។ សំពត់ច្រើនគប្បីពោលថា ឯតានិ មេ ភន្តេ ចីវរានិ ។ល។ ឯតានាហំ អាយស្មតោ និស្សជ្ជាមិ ដូច្នេះ ។ ប្រគល់ សំពត់ឲ្យថា ឯតានិ ចីវរានិ អាយស្មតោ ទម្មិ ដូច្នេះ ។ គប្បីដឹង សេចក្តីនៃបាលីអម្បាលនោះចុះ ។ ឬនឹងកាន់យកផ្លូវសេចក្តីនោះ ពោល ដោយខេមរភាសាក៏បាន ឥមានិ ចីវរានិ ប្រែថាសំពត់ទាំងឡាយនេះ

www.budinst.gov.kh www.elibraryofcambodia.org

ឯតំ ចីវរំ ប្រែថាសំពត់នុ៎ះ ឯតានិ ចីវរានិ ប្រែថាសំពត់ទាំងឡាយអម្បាលនុ៎ះ ។ ថាបើត្រៃចីវរទាំង ៣ ត្រូវនិស្សគ្គិយ គប្បីលះថា ឥទំ មេ ភន្តេ តិចីវរំ ឯការត្តិ វិប្បវុត្ថំ អញ្ញត្រ ភិក្ខុសម្មតិយា និស្សគ្គិយំ ឥមាហំ អាយស្មតោ និស្សជ្ជាមិ ប្រែថា ត្រៃចីវររបស់ខ្ញុំព្រះករុណានេះ នៅប្រាសចាកហើយ អស់រាត្រីមួយ ត្រូវនិស្សគ្គិយ វៀរចាកភិក្ខុដែលបានសម្មតិ ខ្ញុំលះត្រៃចីវរនេះដល់ព្រះករុណា ។ មួយទៀត ក្នុងត្រៃចីវរទាំង ៣ នេះ ចីវរណាមួយត្រូវនិស្សគ្គិយ នឹងពោលតាមឈ្មោះក៏បាន បើសង្ឃាដីថា អយំ មេ ភន្តេ សង្ឃាដិ ឯការត្តិ វិប្បវុត្ថា អញ្ញត្រ ភិក្ខុសម្មតិយា និស្សគ្គិយា ឥមាហំ អាយស្មតោ និស្សជ្ជាមិ ដូច្នេះ ។ បើចីពរថា អយំ មេ ភន្តេ ឧត្តរាសង្គោ(១) ឯការត្តិ វិប្បវុត្ថោ អញ្ញត្រ ភិក្ខុសម្មតិយា និស្សគ្គិយោ ឥមាហំ អាយស្មតោ និស្សជ្ជាមិ ដូច្នេះ ។ បើទៅឡាយ គប្បីពោលថា ឯតំ.... ឯតានិ.... ឯសា.... ឯសោ.... ជំនួសឥមស័ព្ទ ឲ្យត្រូវតាមលិង្គវចនវិភត្តិ របស់វត្ថុដែលត្រូវលះ ។ បាត្រកន្លង១០ថ្ងៃ ជានិស្សគ្គិយ គប្បីលះថា អយំ មេ ភន្តេ បត្តោ ទសាហាតិក្កន្តោ និស្សគ្គិយោ ឥមាហំ អាយស្មតោ និស្សជ្ជាមិ ប្រែថាបាត្ររបស់ខ្ញុំនេះ

---

(១) ឯការលះស្បង់ក៏ដូចគ្នានឹងការលះចីវរដែរ ប្លែកតែថាអន្តរវាសកោ ដូចឧត្តរាសង្គោ ។

ក្នុង ១០ ថ្ងៃហើយ ត្រូវនិស្សគ្គិយ ខ្ញុំលះបាត្រនេះ ដល់លោកដ៏មាន
អាយុ ។ បាត្រច្រើនថា ឥមេ មេ ភន្តេ បត្តា
ទសាហាតិក្កន្តា និស្សគ្គិយា ឥមាហំ អាយស្មតោ
និស្សជ្ជាមិ ដូច្នេះ ។ របស់ផ្លាស់ប្តូរគ្នានឹងគ្រហស្ថ ត្រូវនិស្សគ្គិយ
គប្បីលះថា អហំ ភន្តេ នានប្បការកំ កយវិក្កយំ
សមាបជ្ជឹ ឥទំ មេ ភន្តេ និស្សគ្គិយំ ឥមាហំ
អាយស្មតោ និស្សជ្ជាមិ ដូច្នេះ ។ សម្បត្តិរបស់ដែលត្រូវនិស្សគ្គិយ
គប្បីកាន់យកបាលីក្នុងវិភង្គនៃសិក្ខាបទនោះៗ មកលះតាមវត្ថុ មួយនឹង
ច្រើន នៅជិតនឹងឆ្ងាយចុះ ។ វិធីដែលទទួលអាបត្តិនឹងប្រគល់ឲ្យក៏ដូចគ្នា
ដោយន័យដែលពោលមកហើយ ។ ឯរូបិយនឹងរបស់ដែលទិញមកដោយ
រូបិយ នឹងបាត្រថ្មី ដែលភិក្ខុសូមមកអំពីមនុស្សមិនមែនញាតិ ក្នុងកាល
បាត្រចាស់មានចំណាំមិនទាន់គ្រប់ ៥ ចាំង ៧ នេះ គប្បីលះដល់-
សង្ឃមួយពួក ។ ថាបើសង្ស័យគប្បីប្រាប់សេចក្តីសង្ស័យមុនហើយ
ទើបលះ ដូចសំពត់អតិរេកចីវរសង្ស័យថាមិនបានអធិដ្ឋាន ក្នុង ១០
ថ្ងៃៗ គប្បីប្រាប់ថា បើសំពត់នេះច្បាស់ជាមិនបានអធិដ្ឋានហើយ
កាលបើលះបង់ដូច្នេះ ក៏នឹងជាកប្បិយគួរដល់ខ្ញុំ ប្រាថ្នាដូច្នេះហើយគប្បី
លះដូចន័យមុននោះចុះ ព្រោះថា កាលប្រាប់ឲ្យដឹងដូច្នេះហើយធ្វើ
វិនយកម្ម មិនត្រូវមុសាវាទ ។ មួយទៀត ក្នុងថ្ងៃឧបោសថ

www.budinst.gov.kh www.elibraryofcambodia.org

បវារណា សង្ស័យនឹងអាបត្តិ គប្បីប្រាប់តាមសេចក្តីសង្ស័យមុនសិន ហើយគប្បីធ្វើនូវបោសថ ឬបវារណា ៗ ស្តាប់បាតិមោក្ខ ឬបវារណា កុំគប្បីធ្វើអន្តរាយដល់នូវបោសថ ដល់បវារណា ព្រោះមិនបានសំដែងអាបត្តិហើយសៀមនៅ គប្បីចូលទៅរកភិក្ខុមួយអង្គ ធ្វើចីវរឆៀងស្មាម្ខាង អង្គុយច្រហោងលើកដៃប្រណម្យពោលថា អហំ ភន្តេ[១] ឯកិស្សា ថុលច្ចយាយ អាបត្តិយា វេមតិកោ យទា និព្វេមតិកោ ភវិស្សាមិ តទា តំ អាបត្តឹ បដិករិស្សាមិ ប្រែថា បពិត្រព្រះករុណាដ៏ចំរើន ខ្ញុំសង្ស័យក្នុងអាបត្តិថុល្លច្ច័យ កាលណាអស់សង្ស័យ កាលនោះទើបនឹងសំដែងនូវអាបត្តិនោះ ក្នុងកាលនោះ ៗ អាបត្តិពីរថា អហំ ភន្តេ[២] ទ្វីសុ ថុល្លច្ចយាសុ អាបត្តីសុ វេមតិកោ ។ល។ តទា តា អាបត្តិយោ បដិករិស្សាមិ ៗ ច្រើនថា សម្ពហុលាសុ ថុល្លច្ចយាសុ ៗ មានវត្ថុផ្សេង ៗ ថា សម្ពហុលាសុ នានាវត្ថុកាសុ ថុល្លច្ចយាសុ ៗ សូម្បីអាបត្តិដទៃ ក៏ឲ្យផ្លាស់ឈ្មោះសំដែងដូចក្នុងបទថុល្លច្ច័យ តាមអាបត្តិមួយនឹងពីរនឹងច្រើននឹងវត្ថុផ្សេង ៗ គ្នានោះចុះ ៗ ក្នុងអដ្ឋកថា ពោលថា បើមិនមានសេចក្តីសង្ស័យ សូម្បីមិនកាន់វត្ថុហើយសំដែងក៏គួរ ៗ វិធីសំដែងដូច្នេះ កាលបើ

---

(១.២) បើភិក្ខុចាស់វស្សា សំដែងអាបត្តិ នឹងភិក្ខុខ្ចីវស្សា គប្បីថាអាវុសោ ជំនួស ភន្តេ ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះអាចារ្យ គឺពពកបិទបាំង សង្ស័យថាជាព្រឹក ឬរសៀល ហើយឆាន់យាវកាលិកសោត ភិក្ខុនោះ គប្បីអាងវត្ថុប្រាប់ថា ខ្ញុំសង្ស័យហើយឆាន់យាវកាលិក បើជាវេលាព្រឹកសោត ប្រាប់ថាខ្ញុំត្រូវទុក្កដាបត្តិទាំងឡាយច្រើនព្រោះសង្ស័យ ថាបើជាវិកាល ក៏ប្រាប់ថាខ្ញុំត្រូវបាចិត្តិយាបត្តិទាំងឡាយច្រើន ដូច្នេះហើយ គប្បីសំដែងថា អហំ ភន្តេ(១) យា តស្មឹ វត្ថុស្មឹ សម្ពហុលា ទុក្កដា វា បាចិត្តិយា វា អាបត្តិយោ អាបន្នោ តា បដិទេសេមិ ប្រែថា ខ្ញុំត្រូវហើយ នូវអាបត្តិណា ជាទុក្កដ ឬបាចិត្តិយច្រើនជាមួយគ្នា ព្រោះវត្ថុនោះ ខ្ញុំសំដែងអាបត្តិទាំងឡាយនោះ តទៅអ្នកទទួល ក៏គប្បីពោលដូចមុនចុះ ក្នុងអាបត្តិទាំងពួងក្រៅនោះ ក៏ដូចគ្នាដូច្នោះ ៗ មួយទៀត ភិក្ខុសំដែង ឬទទួលសភាគាបត្តិ ត្រូវទុក្កដ ដ្បិតព្រះអង្គទ្រង់ឃាត់ទុកថា ន ភិក្ខវេ សភាគា អាបត្តិ ទេសេតព្វា ។ល។ បដិគ្គហេតព្វា សេចក្តីថា អាបត្តិជាសភាគៈស្មើគ្នា ភិក្ខុកុំគប្បីសំដែង ឬទទួល បើសំដែង ឬទទួលត្រូវទុក្កដ ៗ ភិក្ខុពីរអង្គត្រូវអាបត្តិណា ដោយវត្ថុជាសភាគៈ គឺរឿងជាមួយគ្នាមានឆាន់ក្នុងវិកាលដូចគ្នា ជាដើម អាបត្តិដែលមានវត្ថុជាសភាគៈស្មើគ្នាដូច្នេះនេះ ហៅថាសភាគាបត្តិ នឹងសំដែងនឹងទទួលគ្នាមិនគួរ ឯអ្នកត្រូវអាបត្តិព្រោះឆាន់ក្នុងវិកាល នឹងសំដែងក្នុងសំណាក់ នៃភិក្ខុអ្នកត្រូវអាបត្តិព្រោះឆាន

---

(១) បើភិក្ខុចាស់វស្សាសំដែងអាបត្តិនឹងភិក្ខុខ្ចីវស្សា គប្បីថា អាវុសោ ជំនួស ភន្តេ ។

www.budinst.gov.kh www.elibraryofcambodia.org

អនតិរិត្តភោជនកិច្ច ។ ក៏ឯអាបត្តិណា ដែលមានវត្ថុជាសភាគៈ ស្មើគ្នា សូម្បីអាបត្តិនោះ សំដែងរួចហើយ ក៏ឈ្មោះថាសំដែងដោយប្រពៃ ឯអ្នកសំដែងក៏ត្រឡប់ត្រូវទុក្កដដទៃទៀត ព្រោះសំដែង អ្នកទទួលក៏ត្រូវទុក្កដដទៃទៀត ព្រោះទទួល អាបត្តិនោះឈ្មោះថាមានវត្ថុផ្សេង ៗ អំពីគ្នាវិញ ព្រោះហេតុនោះ នឹងត្រឡប់សំដែងដល់គ្នានឹងគ្នាទៀតក៏គួរ ។ មួយទៀត កាលបើស្តាប់បាតិមោក្ខ ឬបវារណា បើរឭកអាបត្តិបាន ក៏គប្បីប្រាប់ដល់ភិក្ខុដែលនៅជិតតាមឈ្មោះអាបត្តិនោះ ៗ ថា អហំ ភន្តេ ឯកំ ថុល្លច្ចយំ អាបត្តឹ អាបន្នោ ឥតោ វុដ្ឋហិត្វា តំ អាបត្តឹ បដិការិស្សាមិ ប្រែថាខ្ញុំត្រូវអាបត្តិថុល្លច្ច័យមួយ ក្រោកអំពីទីនេះហើយ នឹងធ្វើឲ្យច្បាស់នូវអាបត្តិនោះ ។ អាបត្តិពីរ នឹងច្រើន នឹងវត្ថុផ្សេង ៗ គ្នា នឹងអាបត្តិដទៃ ៗ ក៏គប្បីប្រកបពាក្យដូចមុនចុះ គប្បីប្រាប់ដូច្នេះដល់ភិក្ខុដែលជាសភាគៈ កុំគប្បីប្រាប់ដល់ភិក្ខុដែលជាវិសភាគៈ ដ្បិតថា កាលបើប្រាប់ដល់ភិក្ខុដែលជាវិសភាគៈ វិវាទនឹងសន្សំកើតជាដើម នឹងមានឡើង ព្រោះហេតុនោះ កុំប្រាប់ដល់ភិក្ខុដែលជាវិសភាគៈ គប្បីចងចិត្តថា យើងក្រោកអំពីទីនេះហើយ នឹងសំដែងហើយធ្វើឧបោសថ ធ្វើបវារណាទៅចុះ ។ បើនៅមានសង្ស័យ ក៏គប្បីប្រាប់ដល់ភិក្ខុអង្គុយជិត តាមសេចក្តីសង្ស័យដូចមុននោះចុះ ។ ថាបើភិក្ខុអាវាសជាមួយគ្នា ក្នុងថ្ងៃឧបោសថ ថ្ងៃបវារណា សង្ឃទាំងពួងត្រូវសភាគាបត្តិដូចគ្នាទាំងអស់ គប្បីបញ្ជូនភិក្ខុមួយអង្គ ទៅកាន់អាវាស

www.budinst.gov.kh www.elibraryofcambodia.org

ជិតក្នុងថ្ងៃនោះថា អ្នកចូរទៅសំដែងអាបត្តិមក យើងនឹងសំដែងអាបត្តិក្នុងសំណាក់អ្នក ថាបើបានដូច្នេះ ជាការប្រពៃ ថាបើមិនបានទេ គប្បីឲ្យភិក្ខុអ្នកឈ្លាសសូត្រប្រកាសសង្ឃថា សុណាតុ មេ ភន្តេ សង្ឃោ អយំ សព្វោ សង្ឃោ សភាគំ អាបត្តឹ អាបន្នោ យទា អញ្ញំ ភិក្ខុំ សុទ្ធំ អនាបត្តិកំ បស្សិស្សតិ តទា តស្ស សន្តិកេ តំ អាបត្តឹ បដិករិស្សតិ ដូច្នេះ ហើយធ្វើឧបោសថ បវារណាចុះ ។ ថាបើសង្ស័យ គប្បីសូត្រប្រកាសសង្ឃថា សុណាតុ មេ ភន្តេ សង្ឃោ អយំ សព្វោ សង្ឃោ សភាគាយ អាបត្តិយា វេមតិកោ យទា និព្វេមតិកោ ភវិស្សតិ តទា តំ អាបត្តឹ បដិករិស្សតិ ដូច្នេះ ហើយធ្វើឧបោសថ បវារណាចុះ ។ ថាបើភិក្ខុទាំងអម្បាលនោះ ភិក្ខុមួយអង្គ សំគាល់ថា សំដែងសភាគាបត្តិនោះគួរ ទើបសំដែងក្នុងសំណាក់ភិក្ខុអង្គនោះសោត សំដែងហើយ ឈ្មោះថាសំដែងដោយប្រពៃពិត ភិក្ខុទាំងពីរនោះ ក៏ត្រូវអាបត្តិផ្សេងៗគ្នាទៅ ដូចពោលហើយក្នុងមុខ ។ ព្រោះហេតុនោះ គប្បីត្រឡប់សំដែងដល់គ្នានឹងគ្នាទៀតចុះ ។ ភិក្ខុទាំងពីរអង្គក៏ជាអ្នកមិនមានអាបត្តិ ភិក្ខុទាំងឡាយដ៏សេស គប្បីសំដែងឬប្រាប់សភាគាបត្តិ ក្នុងសំណាក់ភិក្ខុទាំងពីរនោះចុះ ។ ភិក្ខុមានអាបត្តិមិនទាន់សំដែង ស្តាប់បាតិមោក្ខឬបវារណា ត្រូវទុក្កដ ។ ក្នុងខុទ្ទកសិក្ខាពោលថា បារាជិក សង្ឃាទិសេសទាំងពីរនេះ ជាអទេសនាគាមិនី កុំសំដែង ទឹងកុំសំដែងអនាបត្តិ អាបត្តិសំដែងហើយ

កុំសំដែងទៀត កុំសំដែងនឹងភិក្ខុជានានាសំវាស និងកុំសំដែងក្នុងសំណាក់ភិក្ខុ ៤-៥ អង្គ នៅក្រៅសីមា កុំសំដែងក្នុងសំណាក់ភិក្ខុមួយអង្គគួនព្រមគ្នា កុំសំដែងដោយចិត្តមួយយ៉ាងដោយមិនធ្វើបរិកេទ គប្បីសំដែងក្នុងសំណាក់នៃភិក្ខុដែលជាបកតត្ត: គឺភិក្ខុមិនត្រូវអន្តិមវត្ថុ ឬភិក្ខុដែលសង្ឃមិនបានលើកវត្ត លើកឧបោសថ និងបវារណា ។

មួយទៀត អាបត្តិផ្សេងៗ កុំសំដែងជាអាបត្តិមួយ បើអាបត្តិមួយសំដែងជាអាបត្តិច្រើនឈ្មោះថាសំដែងដោយប្រែត ។ ត្រូវបាកផិតហើយបដិញ្ញាខ្លួនតាមត្រង់ ហើយលះគេចភិក្ខុចេញ ឈ្មោះថាសំដែងបាកផិត ។

អាបត្តិទេសនាកថា ចប់

## ឧបោសថកថា

វិធីធ្វើឧបោសថព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតថា អនុជានាមិ ភិក្ខវេ ឧបោសថេ បាតិមោក្ខំ ឧទ្ទិសិតុំ តថាគតអនុញ្ញាតឲ្យសំដែងបាតិមោក្ខក្នុងថ្ងៃឧបោសថ ។ ឯថ្ងៃឧបោសថនោះមាន ៣ គឺចាតុទ្ទសិកោ ឧបោសថក្នុងថ្ងៃ ១៤ បណ្ណរសិកោ ឧបោសថក្នុងថ្ងៃ ១៥ និងសាមគ្គី គឺថ្ងៃសង្ឃព្រមព្រៀងគ្នា ។ រាប់តាំងអំពីថ្ងៃឧបោសថ ឬថ្ងៃបវារណាមុនមក បើថ្ងៃ ១៤ ឈ្មោះថាចាតុទ្ទសិកោ គប្បី

www.budinst.gov.kh www.elibraryofcambodia.org

តាំងញត្តិថា អជ្ជុបោសថោ ចាតុទ្ទសោ ដូច្នេះ ។ បើបក្ខបាន ១៥ ថ្ងៃ ឈ្មោះថាបណ្ណរសិកោ គប្បីតាំងញត្តិថា អជ្ជុបោសថោ បណ្ណរសោ ដូច្នេះ ។ សង្ឃបែកបាក់គ្នាដោយវិវាទាធិករណៈ ដូចភិក្ខុក្នុងស្រុកកោសម្ពី ដល់ថ្ងៃឧបោសថមិនបានធ្វើឧបោសថ ដល់ថ្ងៃបវារណា មិនបានធ្វើបវារណា ហើយត្រឡប់ព្រមព្រៀងគ្នា រម្ងាប់អធិករណៈស្រេចក្នុងថ្ងៃណា ថ្ងៃនោះឈ្មោះថាជាថ្ងៃសាមគ្គី គប្បីធ្វើឧបោសថក្នុងថ្ងៃនោះ តាំងញត្តិថា អជ្ជុបោសថោ សាមគ្គី ដូច្នេះ ។ ក្នុងរនោចខែអស្សុជ នឹងខ្នើតខែកត្តិក ជាខែមួយនេះ គប្បីធ្វើបវារណា ។ មួយទៀត ឧបោសថពោលដោយបុគ្គលអ្នកធ្វើមាន ៣ គឺសង្ឃឧបោសថ ១ គណឧបោសថ ១ បុគ្គលឧបោសថ ១ ។ ភិក្ខុតាំងអំពី ៤ អង្គឡើងទៅ គប្បីធ្វើសង្ឃឧបោសថ សូត្របាតិមោក្ខ ។ ភិក្ខុ ២-៣ អង្គគប្បីធ្វើគណឧបោសថ ប្រាប់បារិសុទ្ធិ ។ ភិក្ខុមួយអង្គ គប្បីធ្វើបុគ្គលឧបោសថ គឺអធិដ្ឋាន ។ មួយទៀត ពោលដោយអាការនឹងគប្បីធ្វើមាន ៣ គឺសុត្តុទ្ទេសឧបោសថ ១ បារិសុទ្ធិឧបោសថ ១ អធិដ្ឋានឧបោសថ ១ ។ ភិក្ខុតាំងអំពី ៤ អង្គទៅ ឲ្យតាំងសង្ឃញត្តិថា សុណាតុ មេ ភន្តេ សង្ឃោ ដូច្នេះជាដើម ហើយសូត្របាតិមោក្ខ ឈ្មោះថាសុត្តុទ្ទេសឧបោសថ ។ បារិសុទ្ធិឧបោសថនោះមាន ២ គឺប្រាប់ដល់គ្នានឹងគ្នា ១ ប្រាប់ក្នុងសំណាក់ភិក្ខុដទៃ ១ ។ ប្រាប់ដល់គ្នានឹងគ្នាមាន ២ គឺតាំងញត្តិ ១ មិនតាំងញត្តិ ១ ។ ក្នុងអាវាសណា ដល់ថ្ងៃឧបោសថ ភិក្ខុមានតែ ៣ អង្គ ភិក្ខុទាំងឡាយ

www.budinst.gov.kh www.elibraryofcambodia.org

នោះ គប្បីប្រជុំគ្នាហើយ ភិក្ខុអ្នកឈ្លាសមួយអង្គ គប្បីតាំងញត្តិថា សុណាតុ មេ ភន្តេ អាយស្មន្តា អជ្ជុបោសថោ បណ្ណរសោ យទាយស្មន្តានំ បត្តកល្លំ មយំ អញ្ញមញ្ញំ បារិសុទ្ធិឧបោសថំ ករេយ្យាម ដូច្នេះហើយ ភិក្ខុជាថេរៈគប្បីឃុំចីវរឆៀងស្មាម្ខាងអង្គុយច្រហោង លើកដៃប្រណម្យ ពោលប្រាប់សេចក្ដីជាអ្នកបរិសុទ្ធ ដល់ភិក្ខុតាំងឡាយនោះថា បរិសុទ្ធោ អហំ អាវុសោ បរិសុទ្ធោតិ មំ ធារេថ ដូច្នេះ ៣ ដង ហើយភិក្ខុកំឡោះគប្បីធ្វើយ៉ាងនោះ ប្រាប់ដោយលំដាប់គ្នាថា បរិសុទ្ធោ អហំ ភន្តេ បរិសុទ្ធោតិ មំ ធារេថ ដូច្នេះ ៣ ដងដូចគ្នា ដូច្នេះឈ្មោះថាតាំងញត្តិ ។ បើនៅតែពីរអង្គ មិនត្រូវតាំងញត្តិ ប្រជុំគ្នាក្នុងសីមាហើយ ភិក្ខុជាថេរៈ គប្បីឃុំចីវរឆៀងស្មាម្ខាង អង្គុយច្រហោងលើកដៃប្រណម្យ ពោលប្រាប់សេចក្ដីជាអ្នកបរិសុទ្ធដល់ភិក្ខុកំឡោះថា បរិសុទ្ធោ អហំ អាវុសោ បរិសុទ្ធោតិ មំ ធារេហិ ដូច្នេះ ៣ ដង ហើយភិក្ខុកំឡោះគប្បីធ្វើយ៉ាងនោះ ពោលប្រាប់ព្រះថេរៈថា បរិសុទ្ធោ អហំ ភន្តេ បរិសុទ្ធោតិ មំ ធារេថ ដូច្នេះ ៣ ដង ដូច្នេះឈ្មោះថាមិនតាំងញត្តិ ។ ប្រាប់បរិសុទ្ធិក្នុងសំណាក់ភិក្ខុដទៃនោះក៏មាន ២ គឺប្រាប់ក្នុងសំណាក់នៃភិក្ខុដែលបវារណាហើយ ១ ប្រាប់ក្នុងសំណាក់នៃភិក្ខុដែលមិនបានបវារណា ១ ។ ភិក្ខុចូលបច្ឆិមិកាវស្សា ឬចូលបុរិមិកាវស្សា តែវស្សាដាច់ លុះដល់ថ្ងៃបវារណា តិចជាងភិក្ខុអ្នកបវារណា គប្បីឲ្យ-

www.budinst.gov.kh www.elibraryofcambodia.org

កាយសាមគ្គី ភិក្ខុដទៃបវារណាហើយ គប្បីប្រាប់សេចក្តីបរិសុទ្ធិរបស់ខ្លួន ក្នុងសំណាក់នៃភិក្ខុដែលបវារណាហើយនោះថា បរិសុទ្ធោ អហំ អាវុសោ បរិសុទ្ធោតិ មំ ធារេថ ដូច្នេះ ៣ ដង ដូច្នេះ ឈ្មោះថាប្រាប់ក្នុងសំណាក់នៃភិក្ខុ ដែលបវារណាហើយ ។ ក្នុងថ្ងៃដទៃមិនមែនថ្ងៃបវារណា ភិក្ខុទៅកាន់សង្ឃគ្រាបាតិមោក្ខចប់ហើយ នៅមិនទាន់ក្រោក ឬក្រោកទៅខ្លះហើយ ភិក្ខុអាគន្តុកៈដទៃស្មើគ្នា ឬតិចជាងទៅកាន់សមកដល់ ភិក្ខុនោះគប្បីប្រាប់បរិសុទ្ធិក្នុងសំណាក់ទៅកាន់ស ដោយន័យដូចពោលមកហើយ ដូច្នេះឈ្មោះថាប្រាប់ក្នុងសំណាក់នៃភិក្ខុ ដែលមិនបានបវារណា ប្រាប់យ៉ាងនេះឈ្មោះថាបរិសុទ្ធិឧបោសថ ។

អធិដ្ឋានឧបោសថនោះដូច្នេះ បើភិក្ខុនៅតែមួយអង្គ គប្បីធ្វើបុព្វ-ករណៈតាំងពួនមានបោសកេនឧបោសថជាដើម ហើយអង្គុយរង់ចាំភិក្ខុដទៃដែលជាអាគន្តុកៈ ដឹងថាមិនមកហើយគប្បីអធិដ្ឋានថា អជ្ជ មេ ឧបោសថោ ដូច្នេះ ។ ក្នុងអដ្ឋកថាបង្គាប់ឲ្យពោលពាក្យអធិដ្ឋានតាមថ្ងៃ បើថ្ងៃ១៤ថា អជ្ជ មេ ឧបោសថោ ចាតុទ្ទសោតិ អធិដ្ឋាមិ ។ បើថ្ងៃ១៥ថា អជ្ជ មេ ឧបោសថោ បណ្ណរសោតិ អធិដ្ឋាមិ ដូច្នេះ ឈ្មោះថា អធិដ្ឋានឧបោសថ ។

ឧបោសថពោលដោយថ្ងៃមាន ៣ ពោលដោយអ្នកធ្វើមាន ៣ ដោយអាការៈនឹងគប្បីធ្វើមាន ៣ ដូច្នេះ ត្រូវជាឧបោសថ ៩ ផងគ្នា កាលដល់ថ្ងៃឧបោសថ ថ្ងៃបវារណា ព្រមដោយលក្ខណៈដូច្នេះ ភិក្ខុមិនធ្វើ

www.budinst.gov.kh www.elibraryofcambodia.org

ឧបោសថ មិនធ្វើបវារណា ក្នុងថ្ងៃឧបោសថ ថ្ងៃបវារណានោះ ទឹង ចេញចាកអាវាស ឬចាកទីមិនមែនអាវាស ទៅកាន់អាវាស ឬកាន់ទីមិនមែនអាវាសដទៃ ដែលមិនមានភិក្ខុ ឬមានភិក្ខុ តែជានានាសំវាស ដើម្បីទៅនៅ ត្រូវទុក្កដ វៀរតែទៅជាមួយនឹងសង្ឃ ឬមានអន្តរាយ ៗ កិច្ចដែលគប្បីធ្វើមុនអំពីប្រជុំ ដើម្បីនឹងធ្វើឧបោសថ ធ្វើបវារណា មាន គឺ បោសរោងឧបោសថ រោងបវារណា ១ បើវេលាយប់អុជប្រទីប ១ ដំកល់ទឹកឆាន់ទឹកប្រើ ១ ក្រាលអាសនៈដើម្បីអង្គុយធ្វើឧបោសថ ធ្វើបវារណា ១ ទាំង ៤ នេះលោកហៅថា បុព្វករណៈ ៗ ភិក្ខុមិនមានជម្ងឺ បើថេរៈបង្គាប់ហើយ មិនធ្វើបុព្វករណៈនោះ ត្រូវទុក្កដ ៗ កិច្ចដែលនឹងគប្បីធ្វើមុនអំពីសូត្របាតិមោក្ខ បវារណា មាន ៥ គឺ នាំឆន្ទៈនៃភិក្ខុដែលគួរនាំឆន្ទៈ ១ នាំបារិសុទ្ធិ នាំបវារណា នៃភិក្ខុគួរបារិសុទ្ធិ គួរបវារណា ១ ប្រាប់រដូវថា រដូវនេះឈ្មោះនេះ ថ្ងៃឧបោសថក្នុងរដូវនេះ កន្លងទៅហើយប៉ុណ្ណេះ ថ្ងៃឧបោសថ ថ្ងៃបវារណា មកដល់ថ្ងៃនេះ នៅសល់តែប៉ុណ្ណេះដូច្នេះ ១ រាប់ភិក្ខុថាប៉ុណ្ណេះៗ ប្រជុំគ្នាក្នុងរោងឧបោសថ ក្នុងរោងបវារណា ១ ឲ្យឱវាទដល់នាងភិក្ខុនី ១ ទាំង ៥ នេះ លោកហៅថា បុព្វកិច្ច ៗ ភិក្ខុនៅក្នុងខាងក្នុងសីមា ឈឺ ឬប្រកបដោយកិច្ចធំ មកកាន់រោងឧបោសថ រោងបវារណាមិនបាន ដល់ថ្ងៃឧបោសថត្រូវឲ្យឆន្ទៈ ឲ្យបារិសុទ្ធិ ៗ ដល់ថ្ងៃបវារណា ត្រូវឲ្យឆន្ទៈ ឲ្យបវារណាដល់ភិក្ខុមួយអង្គ កិរិយាឲ្យឆន្ទៈនោះ ឲ្យសម្រេចការធ្វើឧបោសថ ធ្វើបវារណា នឹងសង្ឃ

www.budinst.gov.kh www.elibraryofcambodia.org

កម្មដ៏សេសនៃសង្ឃម្យ៉ាង ឧបោសថ បវារណានៃខ្លួនមិនឈ្មោះថាធ្វើ ។ ចំណែកនាំបារិសុទ្ធិ នាំបវារណានោះ ឲ្យសម្រេច ការធ្វើឧបោសថ ធ្វើបវារណា របស់ខ្លួនទាំងរបស់សង្ឃផង តែមិនសម្រេចសង្ឃកម្មដ៏សេសនៃសង្ឃបាន ព្រោះហេតុនោះ កាលឲ្យបារិសុទ្ធិ ឲ្យបវារណា ត្រូវឲ្យឆន្ទៈផង ។ តែសព្វថ្ងៃនេះ ប្រើសីមាតូច ភិក្ខុនៅក្នុងសីមា មិនមាន កិច្ចដែលនាំឆន្ទៈ នាំបារិសុទ្ធិ នាំបវារណា ក៏មិនត្រូវធ្វើ ៖ ខាងភិក្ខុឈឺសព្វថ្ងៃនេះក៏មិនមាន ព្រោះហេតុនោះ ការឲ្យឧត់ចដល់ខាងភិក្ខុឈឺ ក៏មិនត្រូវធ្វើ ។

អង្គនៃឧបោសថ អង្គនៃបវារណា មាន ៤ គឺ ថ្ងៃនោះជាថ្ងៃឧបោសថ ថ្ងៃបវារណា តាំង ៣ គឺ ថ្ងៃ ១៤ ថ្ងៃ ១៥ ថ្ងៃសាមគ្គី ថ្ងៃណាមួយ ១ ភិក្ខុប៉ុន្មានគួរធ្វើសង្ឃឧបោសថ គណឧបោសថ ទាំងសង្ឃបវារណា គណៈបវារណាបាន ភិក្ខុអម្បាលនោះ មិនលះហត្ថបាសគ្នា នៅក្នុងសីមាជាមួយគ្នា ១ អាបត្តិជាសភាគៈមានវត្ថុស្មើគ្នា ដូចឆាន់ភោជន ក្នុងវិកាលដូចគ្នាមិនមានដល់សង្ឃ ១ វជ្ជនីយបុគ្គល ២១ មិនមានក្នុងហត្ថបាស ១ ឧបោសថ បវារណាព្រមដោយអង្គ ៤ នេះ ទើបគួរធ្វើ គួរពោលថា បត្តកល្លំ បាន ។ ក៏ឯវជ្ជនីយបុគ្គល ២១ នោះគឺ គ្រហស្ថ ១ ភិក្ខុនី ១ នាងសិក្ខមានា ១ សាមណេរ ១ សាមណេរី ១ មនុស្សលាសិក្ខាហើយ ១ មនុស្សត្រូវអន្តិមវត្ថុ ១ ភិក្ខុគឺសង្ឃលើកវត្តព្រោះមិនឃើញអាបត្តិ ១ ភិក្ខុគឺសង្ឃលើកវត្តព្រោះមិនសំដែងអាបត្តិ ១ ភិក្ខុគឺសង្ឃលើក

www.budinst.gov.kh www.elibraryofcambodia.org

វត្ថុព្រោះមិនបានលះទិដ្ឋិអាក្រក់ចេញ ១ បណ្ឌក ១ ថេយ្យសំវាស មនុស្សលួចភេទ លួចសំវាស ១ ភិក្ខុដែលចូលទៅកាន់លទ្ធិតិត្ថិយ ១ សត្វតិរច្ឆាន ១ មនុស្សសម្លាប់មាតា ១ មនុស្សសម្លាប់បិតា ១ មនុស្សសម្លាប់ព្រះអរហន្ត ១ មនុស្សប្រទូស្តនាងភិក្ខុនី ១ មនុស្សទំលាយសង្ឃ ១ មនុស្សធ្វើលោហិតក្នុងព្រះកាយនៃព្រះពុទ្ធអង្គឲ្យកើតឡើង ១ មនុស្សភេទ ២ គឺមានទាំងភេទប្រុស ភេទស្រី ១ មនុស្ស ២១ នេះឈ្មោះថា វជ្ជនីយបុគ្គល ព្រោះសង្ឃគប្បីវៀរ គឺកុំឲ្យនៅរួមហត្ថបាស ។ ក្នុងមនុស្សទាំងអម្បាលនោះ កាលមនុស្សសង្ឃលើកវត្ត ៣ ចំពួក នៅក្នុងហត្ថបាស សង្ឃធ្វើឧបោសថ ធ្វើបវារណាត្រូវបាចិត្តិយ ។ កាលមនុស្សដ៏សេសក្រៅអំពីមនុស្សទាំង ៣ ចំពួកនោះ មាននៅក្នុងហត្ថបាស សង្ឃធ្វើឧបោសថ ឬបវារណា ត្រូវទុក្កដ ។

ឧបោសថកម្មមាន ៤ ដូច្នេះ ជាវគ្គតែមិនជាធម៌ ១ ព្រមព្រៀងគ្នាតែមិនជាធម៌ ១ ជាវគ្គដោយធម៌ ១ ព្រមព្រៀងគ្នាដោយធម៌ ១ ។ ក្នុងវិហារមួយ ភិក្ខុនៅ ៤ អង្គ នាំឆន្ទៈនាំបារិសុទ្ធិនៃភិក្ខុមួយអង្គទៅ តែ ៣ អង្គធ្វើបារិសុទ្ធិឧបោសថ ឬនៅ ៣ អង្គនាំឆន្ទៈបារិសុទ្ធិនៃភិក្ខុមួយអង្គទៅ តែពីរអង្គសូត្របាតិមោក្ខ ដូច្នេះឈ្មោះថា អធម្មេន វគ្គំ ជាវគ្គតែមិនមែនជាធម៌ ។ បើ ៤ អង្គប្រជុំគ្នា ធ្វើបារិសុទ្ធិឧបោសថ ឬ ២ អង្គ ឬ ៣ អង្គសូត្របាតិមោក្ខ ដូច្នេះឈ្មោះថា អធម្មេន សមគ្គំ ព្រមព្រៀងគ្នា តែមិនជាធម៌ ។ បើនៅ ៤ អង្គ នាំបារិសុទ្ធិនៃភិក្ខុមួយអង្គទៅ

www.budinst.gov.kh www.elibraryofcambodia.org

តែ ៣ អង្គសូត្របាតិមោក្ខ ឬនៅ ៣ អង្គ នាំបារិសុទ្ធិនៃភិក្ខុមួយអង្គទៅ
តែ ២ អង្គធ្វើបារិសុទ្ធិឧបោសថ ដូច្នេះឈ្មោះថា ធម្មេន វគ្គំ ជាវគ្គ
ដោយធម៌ ។ បើ ៤ អង្គនៅក្នុងទីជាមួយគ្នាទាំងអស់ ប្រជុំគ្នាសូត្របាតិមោក្ខ
ទីនៅ ៣ អង្គ ធ្វើបារិសុទ្ធិឧបោសថ ទីនៅ ២ អង្គប្រាប់បារិសុទ្ធិដល់
គ្នានឹងគ្នា ដូច្នេះឈ្មោះថា ធម្មេន សមគ្គំ ព្រមព្រៀងគ្នាដោយ
ធម៌ ។ កម្ម ៣ ខាងដើម មិនគួរធ្វើ គួរតែកម្មខាងចុង ១ យ៉ាង ។ មួយទៀត
ភិក្ខុកុំគប្បីធ្វើកម្មមិនជាធម៌ ក្នុងកណ្តាលសង្ឃ បើធ្វើត្រូវទុក្កដ ។ ដ្បិត
ទ្រង់អនុញ្ញាតទុកថា កាលភិក្ខុដទៃធ្វើកម្មមិនជាធម៌ ភិក្ខុនៅ ៤ ៥ អង្គគប្បី
ហាមប្រាម មាននៅ ២-៣ អង្គគប្បីធ្វើឲ្យច្បាស់ នូវទិដ្ឋិសេចក្តីឃើញ ។
មួយអង្គ គប្បីអធិដ្ឋានថា កម្មនោះមិនគួរដូច្នេះ ។ មួយទៀត ភិក្ខុដទៃ
សូត្របាតិមោក្ខ ក្លែងធ្វើមិនឲ្យសង្ឃបានឮ ត្រូវទុក្កដ បើសំឡេងស្អក-
ស្អារ ទំព្យាយាមថា នឹងឲ្យបានឮ មិនត្រូវអាបត្តិ ។ មួយទៀត ភិក្ខុ
គឺព្រះថេរៈមិនបានអារាធនាមុន សំដែងបាតិមោក្ខឡើងក្នុងកណ្តាលសង្ឃ
ត្រូវទុក្កដ ។ សូត្របាតិមោក្ខជាធុរៈនៃព្រះថេរៈ ព្រះថេរៈគប្បីសូត្រឯង
ឬអារាធនាឲ្យអ្នកដទៃសូត្រ ដ្បិតថា ការសំដែងបាតិមោក្ខជាភារៈនៃភិក្ខុអ្នក
ឈ្លាស វិធីដែលអារាធនាឲ្យសូត្របាតិមោក្ខ គប្បីដឹងដូចពោលហើយ
ក្នុងអារាធនាឲ្យសំដែងធម៌នោះចុះ ។ អ្នកណាដឹងឧបោសថ ៩ នឹងដឹង
ឧបោសថកម្ម ៤ បាតិមោក្ខ ២ បាតិមោក្ខុទ្ទេស ៩ ឬ ៥ អ្នកនោះឈ្មោះ
ជាអ្នកឈ្លាស ។ បាតិមោក្ខុទ្ទេស ៥ នោះដូច្នេះ សូត្រនិទានុទ្ទេស

www.budinst.gov.kh www.elibraryofcambodia.org

តាំងអំពី សុណាតុ មេ ភន្តេ សង្ឃោ ដរាបដល់ ផាសុ ហោតិ ហើយស្រែក ឧទ្ទិដ្ឋំ ខោ អាយស្មន្តោ និទានំ ។ល។ ឯវមេតំ ធារយាមិ ចប់និទានុទ្ទេសដូច្នេះហើយ ឧទ្ទេសក្រោយនោះ ប្រកាសយកដោយសូត្រថា សុតា ខោ បនាយស្មន្តេហិ ចត្តារោ បារាជិកា ធម្មា ។ សុតា ខោ អាយស្មន្តេហិ តេរស សង្ឃាទិសេសា ធម្មា ។ល។ អវិវទមានេហិ សិក្ខិតព្វំ ដូច្នេះ ឈ្មោះថាឧទ្ទេសជាបឋម ។

សូត្រដរាបដល់ចប់បារាជិកុទ្ទេសហើយ ឧទ្ទេសក្រោយនោះ ប្រកាសយកដោយសុតៈដូចមុន ដូច្នេះឈ្មោះថាជាឧទ្ទេសគំរប់ ២ ។

សូត្រដរាបដល់ចប់ សង្ឃាទិសេសុទ្ទេសហើយ ឧទ្ទេសក្រោយនោះ ប្រកាសយកដោយសុតៈដូចមុនដូច្នេះឈ្មោះថាជាឧទ្ទេសគំរប់ ៣ ។

សូត្រដរាបដល់ចប់អនិយតុទ្ទេសហើយ ឧទ្ទេសក្រោយនោះ ប្រកាសយកដោយសុត ដូចមុន ដូច្នេះឈ្មោះថាជាឧទ្ទេសគំរប់ ៤ ។

តាំងអំពីនិស្សគ្គិយុទ្ទេសទៅដរាបដល់ចប់បាតិមោក្ខទាំងអស់ដូច្នេះជាឧទ្ទេសគំរប់ ៥ ឈ្មោះថាវិត្ថារុទ្ទេស ។

ក្នុងអាវាសណា ភិក្ខុអ្នកឈ្លាសដូច្នេះមិនមាន គប្បីសាកពមាតាំងអំពីព្រះមហាថេរ ចុះទៅដរាបដល់សង្ឃនវកៈ បើមិនមានភិក្ខុណាស្ទាត់បាតិមោក្ខបាន ព្រះថេរៈគប្បីបង្គាប់ភិក្ខុកំឡោះមួយអង្គ ឲ្យទៅកាន់អាវាសជិតក្នុងថ្ងៃនោះ ឲ្យរៀនបាតិមោក្ខមកដោយសង្ខេបឬដោយពិស្ដារ

www.budinst.gov.kh www.elibraryofcambodia.org

បើមិនបានដូច្នោះ ក្នុងអាវាសណាភិក្ខុឈ្លាសមាន ឲ្យភិក្ខុទាំងអម្បាលនោះ ទៅក្នុងអាវាសនោះ បើមិនទៅត្រូវទុក្កដ ៗ មួយវិញទៀត បើមានភិក្ខុអ្នកឈ្លាសជាពហុស្សុត ជាលជ្ជីមកក្នុងអាវាសសោត ភិក្ខុទៅអាវាសដើម្បីសង្គ្រោះអនុគ្រោះ និងលួងលោមដោយឲ្យចុណ្ណៈជាដើម បើមិនធ្វើដូច្នោះ ត្រូវទុក្កដ ៗ

មួយទៀត កាលនៅចាំវស្សា ភិក្ខុអ្នកឈ្លាសដូច្នោះមិនមាន គប្បីបញ្ជូនភិក្ខុមួយអង្គទៅក្នុង ៧ ថ្ងៃ ឲ្យរៀនបាតិមោក្ខមកដោយសង្ខេប ឬពិស្តារ កាលមិនបានយ៉ាងនោះ បើនៅក្នុងវស្សានដូច្នោះក្នុងអាវាសនោះ ត្រូវទុក្កដ ៗ មួយទៀតមិនមានអន្តរាយ បើសូត្របាតិមោក្ខដោយសង្ខេប ត្រូវទុក្កដ ៗ អន្តរាយមាន ១០ ប្រការគឺ កាលភិក្ខុប្រជុំគ្នាធ្វើឧបោសថ ម្ចាស់ផែនដីស្តេចយាងមក ឈ្មោះថារាជន្តរាយ ១ ចោរទាំងឡាយមកឈ្មោះថាចោរន្តរាយ ១ ភ្លើងព្រៃឆេះមកឬភ្លើងឆេះឡើងក្នុងអាវាស ឈ្មោះថាអគ្យន្តរាយ ១ មេឃតាំងឡើងឬទឹកជន់មក ឈ្មោះថាឧទកន្តរាយ១ មនុស្សទាំងឡាយមកច្រើនឈ្មោះថាមនុស្សន្តរាយ១ យក្សឬខ្មោចចាប់ភិក្ខុ ឈ្មោះថាអមនុស្សន្តរាយ ១ សត្វកាចមានខ្លាធំជាដើមចូលមក ឈ្មោះថាវាឡន្តរាយ១ ពស់ជាដើមចឹកភិក្ខុឈ្មោះថាសរីសបន្តរាយ ១ ភិក្ខុឈឺ ឬ ភិក្ខុធ្វើកាលកិរិយា ឬមនុស្សមានវេរចាប់ភិក្ខុសម្លាប់ ឈ្មោះថាជីវិតន្តរាយ ១ មនុស្សទាំងឡាយចាប់ភិក្ខុមួយអង្គ ឬច្រើន ដើម្បីនឹងឲ្យឃ្លាតចាកព្រហ្មចរិយៈ ឈ្មោះថាព្រហ្មចរិយន្តរាយ ១ កាលមាន

www.budinst.gov.kh www.elibraryofcambodia.org

អន្តរាយទាំង ១០ ប្រការដូច្នេះណាមួយ គប្បីសូត្របាតិមោក្ខដោយសង្ខេប គប្បីសូត្រតែឧទ្ទេស ជាបឋម ឬ តំរប់ ២ ៣ - ៤ តែគួរឧទ្ទេស តំរប់ ២ ជាដើម ឧទ្ទេសណា សូត្រមិនទាន់ចប់ អន្តរាយមានមក សូម្បីឧទ្ទេសនោះ គប្បីប្រកាសយកដោយសុតៈ តែនិទានុទ្ទេស សូត្រមិនទាន់ចប់ កុំគប្បីប្រកាសដោយសុតៈ គប្បីសូត្រទៅឲ្យចប់ ឧទ្ទេសក្រៅនោះ គប្បីប្រកាសយកដោយសុតៈ កាលមិនមានអន្តរាយ គប្បីសូត្រដោយពិស្តារដរាបដល់ចប់ចុះ ។

មួយទៀត គួរថ្ងៃឧបោសថ ថ្ងៃបវារណា ទៅកាន់សង្ឃអាគន្តុកៈ មិនដឹងថាកិច្ចក្នុងខាងក្នុងសីមាមាន ធ្វើឧបោសថ ធ្វើបវារណា មិនត្រូវអាបត្តិ បើដឹងថាមាន នឹងជៀសសង្ស័យថានឹងគួរ ឬមិនគួរ ហើយធ្វើត្រូវទុក្កដ ។ បើគិតនឹងឲ្យកិច្ចទាំងអម្បាលនោះវិនាស ហើយធ្វើត្រូវថុល្លច្ច័យ ។ បើកំពុងសូត្របាតិមោក្ខ ឬបវារណា ឬសូត្របាតិមោក្ខ ឬបវារណាចប់ហើយ នៅមិនទាន់ក្រោក ឬក្រោកអស់ហើយ ទៅកាន់សង្ឃអាគន្តុកៈមកច្រើនជាង គប្បីសូត្របាតិមោក្ខ បវារណា ជាថ្មីទៀត បើស្មើគ្នា ឬតិចជាង កំពុងសូត្របាតិមោក្ខ បវារណា អ្នកមកថ្មី គប្បីស្តាប់បាតិមោក្ខ បវារណាតទៅ ។ បើសូត្របាតិមោក្ខ ឬបវារណាចប់ហើយនៅមិនទាន់ក្រោក ឬក្រោកទៅហើយ អ្នកមកថ្មីគប្បីប្រាប់បារិសុទ្ធិ គប្បីប្រាប់បវារណា ក្នុងសំណាក់អ្នកសូត្របាតិមោក្ខ អ្នកបវារណា ៗ

មួយទៀត ថ្ងៃឧបោសថ ថ្ងៃបវារណា ទៅកាន់សជា ថ្ងៃចាតុទ្ទសី

www.budinst.gov.kh www.elibraryofcambodia.org

អាគន្តុកៈ ជាថ្ងៃបណ្ណរសី បើពួកអាវាសច្រើនជាង ឬស្មើគ្នា អាគន្តុកៈគប្បីអនុវត្ត គឺប្រព្រឹត្តតាម គឺឲ្យតាំងញត្តិថា ចាតុទ្ទសោ ឬ ចាតុទ្ទសី បើអាគន្តុកៈច្រើនជាង ឲ្យពួកអាវាសគប្បីអនុវត្ត គឺប្រព្រឹត្តតាមអាគន្តុកៈ ឲ្យតាំងញត្តិថា បណ្ណរសោ ឬ បណ្ណរសី ។ ថ្ងៃឧបោសថ ថ្ងៃបវារណា ពួកអាវាសជាថ្ងៃបណ្ណរសី អាគន្តុកៈជា ថ្ងៃចាតុទ្ទសី គប្បីដឹងដូចន័យដែលសំដែងមកហើយ បើពួកអាវាសជាថ្ងៃ ១ កើត ថ្ងៃ ១ រោច អាគន្តុកៈជាថ្ងៃបណ្ណរសី បើពួកអាវាសច្រើនជាង ឬ ស្មើគ្នា ពួកអាវាសកុំគប្បីឲ្យកាយសាមគ្គីដល់អាគន្តុកៈ គប្បីឲ្យអាគន្តុកៈទៅខាងក្រៅសីមា ពួកអាវាសធ្វើឧបោសថ ធ្វើបវារណាទៅចុះ ។ បើអាគន្តុកច្រើនជាងឲ្យពួកអាវាស គប្បីឲ្យកាយសាមគ្គីដល់អាគន្តុកៈ ឬទៅខាងក្រៅសីមា បើពួកអាវាសជាថ្ងៃបណ្ណរសី អាគន្តុកៈជាថ្ងៃ ១ កើត ថ្ងៃ ១ រោច ក៏ដូចគ្នា ។

មួយវិញទៀត ធ្វើឧបោសថ ធ្វើបវារណា ក្នុងថ្ងៃដទៃក្រៅតាកថ្ងៃគំរប់ ១៤ · ១៥ ថ្ងៃសាមគ្គី ត្រូវទុក្កដ ។ មួយទៀត ទ្រង់អនុញ្ញាតទុកថា ក្នុងថ្ងៃឧបោសថ ឲ្យភិក្ខុជាថេរៈប្រជុំមុន ក្នុងអដ្ឋកថា ថាព្រះថេរៈមិនទៅប្រជុំមុន ត្រូវទុក្កដ ។

មិនសន្មតខ្លួនមុន សួរ ឬឆ្លើយ វិន័យក្នុងកណ្តាលសង្ឃ ត្រូវទុក្កដ សន្មតខ្លួនឯងក៏បាន ឲ្យអ្នកដទៃសន្មតក៏បាន អ្នកសួរសន្មតខ្លួនឯងដោយញត្តិថា សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ អហំ ឥត្ថន្នាមំ វិនយំ បុច្ឆេយ្យំ

ដូច្នេះ ។ អ្នកដទៃសន្មតឲ្យថា សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកាលំ ឥត្ថន្នាមោ ឥត្ថន្នាមំ វិនយំ បុច្ឆេយ្យ ដូច្នេះ ។ អ្នកឆ្លើយសន្មតខ្លួនឯងថា សុណាតុ មេ ។ល។ បត្តកាលំ អហំ ឥត្ថន្នាមេន វិនយំ បុដ្ឋោ វិសជ្ជេយ្យំ ដូច្នេះ ។ អ្នកដទៃសន្មតឲ្យថា សុណាតុ មេ ។ល។ បត្តកាលំ ឥត្ថន្នាមោ ឥត្ថន្នាមេន វិនយំ បុដ្ឋោ វិសជ្ជេយ្យ ដូច្នេះ ។ ក្នុងពាក្យថា ឥត្ថន្នាមោ ឥត្ថន្នាមេន នេះ ភិក្ខុឈ្មោះអ្វីឲ្យបញ្ចូលឈ្មោះនោះជំនួស ។ ពាក្យថា បរិសុទ្ធោ អហំ ភន្តេ បរិសុទ្ធោតិ មំ ធារេថ នឹងពាក្យថា បរិសុទ្ធោ អហំ អាវុសោ បរិសុទ្ធោតិ មំ ធារេហិ ទាំងពីរនេះ ប្រែថា ខ្ញុំព្រះករុណាជាអ្នកបរិសុទ្ធមិនមានអាបត្តិ លោកចូរទ្រទ្រង់ទាំងទុកថា ខ្ញុំព្រះករុណាជាអ្នកបរិសុទ្ធចុះ ។ ឧបោសថនឹងបវារណានេះដូចគ្នា តែបវារណាដែលមានប្លែកនោះនឹងពោលទៅខាងមុខ ។

ឧបោសថកថា ចប់

---

## វស្សូបនាយិកាកថា

ពោលអំពីវិធីចូលវស្សា ។ ការចូលវស្សាមានពុទ្ធានុញ្ញាតទុកថា អនុជានាមិ ភិក្ខវេ វស្សានេ វស្សំ ឧបគន្តុំ

www.budinst.gov.kh www.elibraryofcambodia.org

។ល។ ទ្វេ វស្សូបនាយិកា គឺថាគេអនុញ្ញាតឲ្យចូលវស្សា ក្នុងវេលាភ្លៀង ។ ការចូលវស្សាមាន ២ គឺ បុរិមិកា វស្សូបនាយិកា ចូលវស្សាអំពីដំបូង គឺថ្ងៃព្រះចន្ទពេញវង់ សោយអាសាឡ្ហបក្សគន្លងទៅ ហើយ គឺជាថ្ងៃ ១ រោចខែអាសាឡ្ហតាមកម្ពុជប្រទេសតាំងនេះ ជាថ្ងៃ ចូលវស្សាអំពីដំបូង ១ បច្ឆិមិកា វស្សូបនាយិកា ចូលវស្សាខាង ក្រោយ គឺថ្ងៃព្រះចន្ទពេញវង់ សោយបក្សឈ្មោះថា អាសាឡ្ហៈគន្លងទៅ ហើយមួយខែ គឺថ្ងៃ ១ រោចខែស្រាពណ៍ នេះជាថ្ងៃចូលវស្សាខាង ក្រោយ ១ ។ កាលចូលវស្សាគប្បីបដិបត្តិវិហារបោសប្រោសតាំងទឹកឆាន់ ទឹកប្រើទុក ធ្វើសាមីចិកម្មតាំងឡាយមានថ្វាយបង្គំព្រះចេតិយជាដើម ស្រេចហើយ គប្បីបញ្ចេញវាចាថា ឥមស្មឹ វិហារេ ឥមំ តេមាសំ វស្សំ ឧបេមិ ដូច្នេះ ១ ដង ២ ដង ឬ ៣ ដង ចូលវស្សាចុះ ។ បើមាន អាល័យថា យើងនឹងនៅក្នុងទីនេះ តែដោយមិនមានសតិ មិនបានចូល វស្សាដោយបញ្ចេញវាចា សេនាសនៈដែលខ្លួនកាន់យកហើយអំពីសង្ឃ ក៏ឈ្មោះថាកាន់យកដោយប្រពៃ វស្សាមិនដាច់ គួរបានដើម្បីបវារណា ពិត ដ្បិតថាទោះវៀរចាកវចីភេទ សូម្បីដោយមាត្រាថា ធ្វើសេចក្តី អាល័យ ក៏ឈ្មោះថាចូលវស្សាដោយពិត ចិត្តុប្បាទដែលគិតថា យើងនឹង នៅចាំវស្សាក្នុងទីនេះដូច្នេះ ឈ្មោះថាមានអាល័យក្នុងទីនេះ ។ ដល់ថ្ងៃចូល វស្សា មិនបានប្រាថ្នានឹងចូលវស្សា ក្រែងគន្លងដើរចៀសទៅចាកអាវាស ត្រូវទុក្កដ ។ កាលមិនបានចូលវស្សាអំពីដំបូងដោយមានអន្តរាយណាមួយ

www.budinst.gov.kh www.elibraryofcambodia.org

គប្បីចូលវស្សាខាងក្រោយ ព្រោះថាមិនចូលវស្សានោះ ត្រូវទុក្កដ ។ ចាំវស្សាមិនមានសេនាសនៈ ត្រូវទុក្កដ ។ សេនាសនៈប្រកបដោយគ្រឿងប្រកបទាំង ៥ ណាមួយ ដែលប្រកបដោយទ្វារសម្រាប់បិទបើកបាន មិនមានដល់ភិក្ខុណា ភិក្ខុនោះឈ្មោះថា មិនមានសេនាសនៈ ។ ចាំវស្សាក្នុងខ្ទមខ្មោច ក្នុងឆត្រ ក្នុងពាង ក្នុងរូងឈើ ក្នុងប្រគាបឈើ ទាំងអម្បាលនេះ ត្រូវទុក្កដ ។ តែក្នុងប៉ាឆាដែលធ្វើកុដិផងខែឡើង ចាំវស្សាក៏គួរ ។ តែក្នុងឆត្រ ដែលពាង ដែលរូងឈើ ប្រគាបឈើ ទាំងអម្បាលនេះ មិនគួរ ។ បើទីទាំងអម្បាលនោះ មានដំបូល ដែលផ្ញាំងទ្វារបើកបិទបាននេះគួរ ។ ដែលចូលវស្សាក្នុងវជៈ គឺទីអាស្រ័យនៅនៃមនុស្សចិញ្ចឹមគោ ដែលក្នុងពួករទេះ ក្នុងទូកក៏គួរ ។ ទីអាស្រ័យនៅ នៃមនុស្សចិញ្ចឹមគោនោះ គេលើកទៅខាងណា កាលបើទៅជាមួយ វស្សាមិនដាច់ មិនត្រូវអាបត្តិ ព្រោះទ្រង់អនុញ្ញាតឲ្យទៅជាមួយ តែកាលដែលចូលវស្សាក្នុងពួករទេះនោះ ដល់ថ្ងៃចូលវស្សា គប្បីនិយាយនឹងឧបាសកថា បើបានកុដិទើបគួរ បើគេធ្វើថ្វាយ គប្បីចូលទៅក្នុងកុដិនោះ ពោលថា ឥធ វស្សំ ឧបេមិ ដូច្នេះ ៣ ដង បើគេមិនធ្វើប្រគេនទេ គប្បីចូលវស្សាក្នុងខាងក្រោមរទេះ ទីតាំងនៅដោយសន្មតថាជាសាលា កាលមិនបាននូវទីដូច្នោះ គប្បីធ្វើសេចក្តីអាល័យចុះ ដែលចូលតែក្នុងពួករទេះមិនមានកុដិមិនគួរ ពាក្យថាចិត្តុប្បាទដែលគិតថា យើងនឹងនៅក្នុងទីនេះ ដូច្នេះឈ្មោះថាអាល័យ ។ កាលពួករទេះគេបររទេះទៅតាមផ្លូវ

www.budinst.gov.kh www.elibraryofcambodia.org

ថ្ងៃនោះជាថ្ងៃបវារណាលោក គប្បីបវារណា ក្នុងពួករទេះនោះចុះ ។ បើពួករទេះដល់ទីដែលភិក្ខុប្រាថ្នាខាងក្នុងវស្សាហើយ គេចៀសចេញទៅ ភិក្ខុគប្បីនៅក្នុងទីដែលខ្លួនប្រាថ្នា ហើយបវារណាជាមួយនឹងភិក្ខុទាំងឡាយក្នុងទីនោះចុះ សូម្បីពួករទេះគេឈប់នៅក្នុងស្រុកមួយ ឬព្រាត់ប្រាសខ្ចាត់ខ្ចាយគ្នាទៅ ក្នុងរវាងខាងក្នុងវស្សា ក៏គប្បីនៅជាមួយនឹងភិក្ខុទាំងឡាយក្នុងស្រុកនោះ ហើយបវារណាចុះ នឹងមិនបវារណានឹងទៅតទៅមិនគួរ ។ សូម្បីកាលនឹងចូលវស្សាក្នុងទូក ក៏ត្រូវចូលក្នុងកុដិតែកាលស្វែងរកកុដិមិនបាន គប្បីធ្វើសេចក្ដីអាល័យចុះ បើក្នុងខាងក្នុង ៣ ខែ ទូកទៅក្នុងសមុទ្រនោះឯង ក៏គប្បីបវារណាក្នុងទូកនោះចុះ ថាបើទូកដល់ច្រាំង ភិក្ខុប្រាថ្នានឹងទៅខាងមុខទៀត នឹងទៅមិនគួរ គប្បីនៅក្នុងស្រុកដែលទូកដល់ ហើយបវារណាជាមួយនឹងភិក្ខុទាំងឡាយចុះ ។ ថាបើទូកទៅក្នុងទីដទៃតាមមាត់ច្រាំង សូម្បីភិក្ខុប្រាថ្នានឹងនៅក្នុងភូមិដែលទូកចូលដល់មុនពិត ទូកចូរទៅចុះ ភិក្ខុគប្បីនៅក្នុងភូមិនោះ ហើយបវារណាជាមួយនឹងភិក្ខុទាំងឡាយចុះ ។ ក្នុងវជៈនឹងក្នុងពួករទេះ ក្នុងទូក ទាំង ៣ នេះ មិនត្រូវអាបត្តិ ព្រោះដាច់វស្សា រមែងបានដើម្បីបវារណាដោយប្រការដូច្នេះ ។

ចូលវស្សាមិននៅអស់ ៣ ខែជាដំបូង ឬ ៣ ខែខាងក្រោយ ចៀសចេញទៅកាន់ចារិក ត្រូវទុក្កដ ។ តែចូលវស្សាហើយ សូម្បីមិនញ៉ាំងអរុណឲ្យតាំងឡើង នឹងចៀសទៅតាកកាក់សក្នុងថ្ងៃនោះដោយសត្តាហ-

www.budinst.gov.kh www.elibraryofcambodia.org

ករណីយ គឺកិច្ចនឹងគប្បីធ្វើ៧ថ្ងៃ នឹងត្រឡប់មកទាន់ក្នុង៧ថ្ងៃ មិនត្រូវ តាមបត្តិ ៗ នៅ ២ ៣ ថ្ងៃហើយទើបចៀសទៅដោយសត្តាហករណីយ-កិច្ចនឹងត្រឡប់មកទាន់ក្នុង ៧ ថ្ងៃ នឹងបាច់ពោលទៅថ្វី ៗ ឯនឹងទៅដោយសត្តាហករណីយកិច្ចបាននោះដូច្នេះ មនុស្ស ៧ ពួក គឺ ភិក្ខុ ១ ភិក្ខុនី ១ នាងសិក្ខមានា ១ សាមណេរ ១ សាមណេរី ១ មាតា ១ បិតា ១ តាំងអម្បាលនេះមានជម្ងឺ ឬមានហេតុដទៃ មានកើតសេចក្ដីសោប់សល់ឡើងជាដើម សូម្បីមិនបញ្ជូនទូតមកនិមន្ត នឹងទៅដោយសត្តាហករណីយកិច្ច ដើម្បីនឹងរក្សាជម្ងឺ នឹងរម្ងាប់សេចក្ដីសោប់សល់ជាដើមក៏គួរ ៗ តែមនុស្ស ២ ពួក គឺឧបាសក ឧបាសិកា គេសាងវិហារជាដើមនឹងបញ្ជូនទូតមកឲ្យនិមន្តភិក្ខុទៅ ដើម្បីនឹងថ្វាយទាននឹងស្ដាប់ធម៌ជាដើម គប្បីទៅដោយសត្តាហករណីយកិច្ចចុះ កាលគេមិនបញ្ជូនទូតមកនិមន្ត កុំគប្បីទៅ ។ មួយទៀត នឹងទៅដោយកិច្ចសង្ឃ មានកាប់ឈើមកជួសជុលសេនា-សនៈជាដើមក៏គួរ ៗ

មួយទៀត នៅចាំវស្សាហើយ សត្វកាច ឬពស់ ចោរ ឬបិសាច បៀតបៀន នឹងគោចរគ្រាមក្ដីនេះ ឬទឹកលិចបន្សាត់ទៅក្ដី ឬសេនា-សនៈក្ដីនេះ ឬអណ្ដូកទឹកទៅក្ដី ភិក្ខុលំបាកដោយបិណ្ឌបាត នឹងសេនាសនៈ នឹងមិនបានរបស់ឆាន់ល្មមឆ្អែត ឬរបស់ឆាន់ដែលជារបស់សប្បាយ ឬមិនបានភេសជ្ជៈដែលជារបស់សប្បាយ នឹងមនុស្សឧបដ្ឋាកដែលសមគួរ ហើយចៀសចេញទៅដោយគិតថា នេះជាអន្តរាយដូច្នេះ

www.budinst.gov.kh www.elibraryofcambodia.org

មួយទៀត ស្រុកគោចរគ្រាម គេរត់ខ្លួនពីចោរទៅអស់ ភិក្ខុខ្លួននឹងទៅតាមអ្នកស្រុកក៏គួរ មួយទៀត នៅចាំវស្សា ស្រី ឬស្រីពេស្យាជាដើម មកលួងលោមថានឹងឲ្យប្រាក់មាសស្រែចំការគោខ្ញុំទាសៈ ធីតាភរិយា ឬឃើញកំណប់ទ្រព្យមិនមានម្ចាស់របស់ក្តី ខ្ញុំគិតថា ព្រះពុទ្ធអង្គទ្រង់ត្រាស់ទុកថា ចិត្តរមែងប្រែប្រួលរហ័ស អន្តរាយដល់ព្រហ្មចរិយៈខ្ញុំគប្បីមានដល់យើង ដូច្នេះ ហើយចៀសចេញទៅ មិនត្រូវអាបត្តិ តែវស្សាដាច់ ។

មួយទៀត បានឃើញឬបានឮភិក្ខុចាំងល្បាយ ព្យាយាមនឹងទំលាយសង្ឃ ខ្ញុំគិតថា ព្រះអង្គទ្រង់ត្រាស់ទុកថា សង្ឃភេទជាគរុកម្ម កាលយើងនៅចំពោះមុខ កុំឲ្យសង្ឃបែកឡើយដូច្នេះ ហើយចៀសចេញទៅក្តី ឬបានឮថាក្នុងអាវាសឯណោះ ភិក្ខុនឹងភិក្ខុនីព្យាយាមនឹងទំលាយសង្ឃ ខ្ញុំគិតថាភិក្ខុទាំងអម្បាលនោះជាមិត្តសំឡាញ់នៃយើង យើងនឹងទៅជាសំគៀងហាមប្រាមលោក លោកគង់នឹងស្តាប់ពាក្យយើងដូច្នេះ ហើយចៀសចេញទៅមិនត្រូវអាបត្តិ តែវស្សាដាច់ ហើយនឹងបវារណាមិនបានទេ ។

មួយទៀត គេនិមន្តឲ្យចាំវស្សា ៣ ខែ ខ្ញុំទទួលនិមន្តគេហើយធ្វើឲ្យឃ្លាតទៅត្រូវបដិស្សវទុក្កដ មិនមែនតែធ្វើសេចក្តីនិមន្តចូលវស្សាឲ្យឃ្លាតម្យ៉ាងប៉ុណ្ណោះទេ សូម្បីគេនិមន្តថា លោកចូរទទួលភិក្ខាអស់ ៣ ខែ ឬបញ្ជាក់ថា យើងទាំងពីរនឹងចាំវស្សាក្នុងទីនេះ ខ្ញុំរៀនបាលីក្នុងទីជាមួយគ្នាក្តី ទទួលហើយ ធ្វើឲ្យឃ្លាតទៅត្រូវទុក្កដ តែទុក្កដនោះ ព្រោះបឋមចិត្តបរិសុទ្ធ ចំណែកខាងក្រោយធ្វើឲ្យឃ្លាត បើដំបូងមានចិត្តមិន

www.budinst.gov.kh www.elibraryofcambodia.org

បរិសុទ្ធ ត្រូវបាចិត្តិយ ព្រោះទទួលបេក្ខជា ត្រូវទុក្កដ ព្រោះធ្វើសេចក្ដីទទួលឲ្យឃាត ។

មួយទៀត លោកប្រាប់ទុកថា ភិក្ខុអ្នកចូលវស្សា គប្បីពោលដល់ភិក្ខុដែលជាកល់ទីពន្លត្តទុកកុដិខាងក្នុងវស្សា ឲ្យចងអំបោសទុក បើដងនិងបន្ទោះរកបានងាយ មួយអន្លើៗ គប្បីចងអំបោសទុក ៨ ៦ បាច់ ធ្វើដងទុកបាន ២ ឬ ៣ បើដងនិងបន្ទោះរកក្រ គប្បីចងអំបោស ២-៣ បាច់ ចងអំបោសដែលមានដងទុកបាន ១ សាមណេរទាំងឡាយគប្បីសាចម៉ី គប់ទុកម្នាក់បាន ៨ បាច់ៗ ក្នុងទីលំនៅ គប្បីព្រោះព្រំដោយទឹកអម្ចត់ សូម្បីកាលនឹងកតិកាគ្នា ក៏គប្បីធ្វើអធម្មិកវត្ត គឺហាមគ្នាថា កុំប្រាប់បាលី កុំរៀនបាលី កុំស្វាធ្យាយ កុំបំបួសកុលបុត្រ នឹងកុំឲ្យឧបសម្បទា កុំឲ្យនិស្ស័យ កុំធ្វើធម្មស្សវនៈ ផ្សិតថាគាការដែលធ្វើទាំងពួងនោះ ជាការយឺតយូរ បើទាំងឡាយជាមនុស្សមិនយឺតយូរ នឹងធ្វើតែសមណធម៌ម្យ៉ាងចុះ ឬទាំងអស់គ្នាចូរសមាទានកាន់ធុតង្គទាំង ១៣ យ៉ាង កុំសម្រេចការដេក ចូរឲ្យថ្ងៃយប់កន្លងទៅដោយការឈរនឹងចង្ក្រមចុះ ចូរកាន់យកមូគវត្ត សូម្បីអ្នកទៅដោយសត្តាហករណីយកិច្ច កុំគប្បីបានរបស់ដែក ដូច្នេះឈ្មោះថាអធម្មិកវត្ត បើធ្វើត្រូវទុក្កដ ។ មូគវត្តនោះ គឺប្រកាន់មិននិយាយគ្នា ធ្វើដូច្នោះត្រូវទុក្កដ ។ គប្បីធ្វើកតិកាគ្នាដូច្នេះថា ធម្មតាបរិយត្តិធម៌ រមែងញ៉ាំងសទ្ធម្មទាំង ៣ ឲ្យខ្ជាប់ខ្ជួន ព្រោះហេតុនោះ លោកទាំងឡាយ ចូរសំដែង និងរៀន ស្វាធ្យាយ ដោយគោរពចុះ

www.budinst.gov.kh www.elibraryofcambodia.org

កុំធ្វើសេចក្តីខ្វាំងខ្វប់ ដល់ភិក្ខុដែលនៅក្នុងបឆានយៈ គឺទីបំរើ សមណៈធម៌ គប្បីទៅកាន់ក្នុងវិហារប្រាប់រៀនស្វាធ្យាយចុះ ចូរធ្វើធម្មស្សវនៈឱ្យមាំមួន កាលនឹងឱ្យកុលបុត្របួស គប្បីជម្រះឱ្យផុតបព្វជ្ជាទោស ជម្រះហើយឱ្យបព្វជ្ជា ជម្រះឱ្យផុតទោសហើយ ឱ្យឧបសម្បទា ជម្រះហើយឱ្យនិស្ស័យ ផ្សិតជាកុលបុត្រម្នាក់បានបព្វជ្ជានឹងឧបសម្បទា ទើបញុំាងសាសនាទាំងអស់ឱ្យឋិតថេរនៅបាន អ្នកទាំងឡាយ គប្បីសមាទានធុតង្គប៉ុន្មានដោយកំលាំងរបស់ខ្លួនបាន គប្បីសមាទានធុតង្គប៉ុណ្ណោះចុះ ក្នុងកាន់ក្នុងវស្សា ថ្ងៃទាំងអស់ នឹងយប់ក្នុងយាមដំបូងនឹងបំផុត ចូរកុំប្រមាទ គប្បីប្រារព្ធសេចក្តីព្យាយាមចុះ សូម្បីព្រះមហាថេរទាំងឡាយអំពីមុន លោកក៏រមែងកាត់បលិពោធទាំងពួង ហើយបំពេញឯកចារិយវត្ត នៅតែម្នាក់ឯងកាន់ក្នុងវស្សា ។

មួយទៀត គប្បីដឹងប្រមាណក្នុងការពោលការប្រារព្ធពោលកថាវត្ថុ ១០ ប្រារព្ធអសុភ ១០ ប្រារព្ធអនុស្សតិ ១០ ប្រារព្ធអារម្មណ៍ ៣៨ ទើបគួរ គប្បីធ្វើវត្តដល់អាគន្តុកៈ នឹងអបលោកន៍ ឱ្យរបស់ដល់ភិក្ខុទៅដោយសង្គហករណីយកិច្ច ទើបគួរ កតិកាគ្នាខ្លះ ឈ្មោះថាធម្មិកវត្ត គប្បីធ្វើចុះ ។

មួយទៀត គប្បីប្រដៅភិក្ខុទាំងឡាយ កុំឱ្យពោលពាក្យពាសវែង ពាក្យញុះញង់ចាក់ដោត ពាក្យគ្រគោះ ចូរពិចារណាដល់សីលកុំឱ្យចតុរារក្ខសាបសូន្យទៅ ចូរមានមនសិការៈ គឺធ្វើទុកក្នុងចិត្តឱ្យច្រើនរាល់ថ្ងៃ ៗ ចុះ ។

www.budinst.gov.kh www.elibraryofcambodia.org

មួយទៀត គប្បីប្រាប់វត្តក្នុងទីដែលមិនទំពារឈើស្ទន់ កាលថ្វាយបង្គំព្រះចេតិយ ឬពោធិព្រឹក្ស ឬបូជាដោយគន្ធមាលាគ្រឿងក្រអូបកម្រងផ្កា ឬយកបាត្រច្រកក្នុងថង់កុំនិយាយ គប្បីប្រាប់កិច្ចាចារវត្ត កុំគប្បីនិយាយប្រកបដោយបច្ច័យ ឬពាក្យមិនសមគួរ ជាមួយនឹងមនុស្សខាងក្នុងស្រុក គប្បីរក្សាឥន្ទ្រិយ គប្បីបំពេញខន្ធកវត្ត និងសេខិយវត្ត ។ ពាក្យពោលជានិយ្យានិកៈ ដែលនឹងនាំចេញចាកទោស ទុក្ខដូច្នេះ គប្បីនិយាយ គប្បីប្រាប់ដល់គ្នានឹងគ្នា ។

ពាក្យថា ឥមស្មឹ វិហារេ ឥមំ តេមាសំ វស្សំ ឧបេមិ ប្រែថា យើងចូលទៅជិតកាន់វស្សាអស់ត្រៃមាស ក្នុងវិហារនេះ ។ ក៏ឯវិហារស័ព្ទនេះ ក្នុងបាលីច្រើនជាឈ្មោះនៃកុដិ ក្នុងអដ្ឋកថាខ្លះថា ជាឈ្មោះនៃកុដិ ខ្លះថាជាឈ្មោះនៃវត្ត ក្នុងបទនេះជាឈ្មោះនៃកុដិឬវត្តក៏មិនប្រាកដ ព្រោះហេតុនោះ អធិដ្ឋានវស្សាព្រមគ្នាក្នុងទីប្រជុំហើយ មកដល់កុដិអធិដ្ឋានដោយពាក្យនោះទៀត ទើបជាការល្អ សមដូចបាលីថា បាដិបទេ វិហារំ ឧបេតិ សេនាសនំ បញ្ញាបេតិ ដូច្នេះ ។ មួយទៀត ក្នុងទីប្រជុំពោលព្រមគ្នាថា ឥមស្មឹ អាវាសេ ឥមំ តេមាសំ វស្សំ ឧបេមិ ដូច្នេះក៏បាន ព្រោះថា អាវាសស័ព្ទ ក្នុងបាលីថាឈ្មោះនៃវត្តដោយច្រើន ។

មួយទៀត ពោលដូច្នោះ ក៏សមក្នុងបាលីថា ឥធ វសុ អាវាសេ វសុ វស្សំ វសាមិ ។ ដូច្នេះ ក៏ឯប្រជុំគ្នាហើយពោលពាក្យអធិដ្ឋានព្រមគ្នានេះជាបុរាណគតិ ដើម្បីនឹងសំដែងសាមគ្គី គឺសេចក្ដីព្រមព្រៀង ។

www.budinst.gov.kh www.elibraryofcambodia.org

មួយទៀត ពាក្យអធិដ្ឋានវស្សាសោត ក៏មិនមែនបាលីព្រះពុទ្ធដីកា គ្រាន់តែជាពាក្យអដ្ឋកថា ព្រោះហេតុនោះ ទើបលោកពោលថា ធ្វើតែសេចក្តីអាល័យក៏បាន ។

មួយទៀត បូរាណគតិតមក លោកប្រាប់ខេត្តវត្ត ទីដែលប្រាប់ឲ្យស្គាល់អរុណ អរុណក្រហមរះឡើងមកហើយ ភិក្ខុអាចចេញចាកវត្តបាន បើចូលវត្តវិញ ឲ្យទាន់អរុណស មុនអរុណក្រហម ។

វស្សូបនាយិកាកថា ចប់

## បវារណាកថា

ពោលអំពីការបវារណា មានពុទ្ធានុញ្ញាតថា អនុជានាមិ ភិក្ខវេ វស្សំ វុត្ថានំ ភិក្ខូនំ ។ល។ បដិការិស្សាមិ គឺថាតថាគតអនុញ្ញាត ឲ្យភិក្ខុដែលនៅចាំវស្សាអស់ផ្លូវត្រៀនហើយ បវារណាដោយបទ ៣ សណ្ឋាន គឺដោយបានឃើញ ដោយបានឮ ដោយបានរង្កៀស បវារណានោះ ជាសេចក្តីអនុលោមដល់គ្នានឹងគ្នា នឹងជាសេចក្តីញ៉ាំងគ្នានឹងគ្នា ឲ្យចេញចាកអាបត្តិ នឹងជាសេចក្តីធ្វើវិន័យក្នុងខាងមុខដល់គ្នានឹងគ្នា នៃអ្នកទាំងឡាយ ភិក្ខុទាំងឡាយ គប្បីបវារណាយ៉ាងនេះ ឲ្យភិក្ខុដែលឈ្លាសគប្បីប្រកាសឲ្យសង្ឃដឹងដោយញត្តិថា សុណាតុ

www.budinst.gov.kh www.elibraryofcambodia.org

មេ ភន្តេ សង្ឃោ អជ្ជ បវារណា បណ្ណរសី ។ យទិ សង្ឃស្ស បត្តកល្លំ, សង្ឃោ បវារេយ្យ ។ ដូច្នេះហើយ ភិក្ខុជាថេរៈគប្បីធ្វើចីវរឆៀងស្មាម្ខាង អង្គុយច្រហោងលើកដៃប្រណម្យ ពោលនឹងសង្ឃថា សង្ឃំ អាវុសោ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា, វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ, បស្សន្តោ បដិករិស្សាមិ ។ ទុតិយម្បិ អាវុសោ ។ល។ តតិយម្បិ អាវុសោ ។ល។ បវារេមិ។ល។ បដិករិស្សាមិ។ ដូច្នេះហើយ ភិក្ខុកំឡោះមួយអង្គៗ គប្បីធ្វើសំពត់ឧត្តរាសង្គឆៀងស្មាម្ខាង អង្គុយច្រហោងលើកដៃប្រណម្យ ពោលនឹងសង្ឃថា សង្ឃម្ភន្តេ បវារេមិ ។ល។ បដិ-ករិស្សាមិ ។ ទុតិយម្បិ ភន្តេ ។ល។ តតិយម្បិ ភន្តេ សង្ឃំ ។ល។ បដិករិស្សាមិ វិធីដូច្នេះ ឈ្មោះថាបវារណា ។ គឺឯបវារណានោះ ពោលដោយថ្ងៃមាន ៣ គឺ ចាតុទ្ទសី ថ្ងៃ ១៤ បណ្ណរសី ថ្ងៃ ១៥ នឹងសាមគ្គី ថ្ងៃដែលសង្ឃព្រមព្រៀង ។ កប់អំពីថ្ងៃឧបោសថមុនមកបាន ១៤ ថ្ងៃ ឲ្យតាំងញត្តិថា អជ្ជ បវារណា ចាតុទ្ទសី ។ បើបាន ១៥ ថ្ងៃឲ្យតាំងញត្តិថា អជ្ជ បវារណា បណ្ណរសី ដូច្នេះ ។ បើចាំបុរិមិកាវស្សា ឲ្យធ្វើបវារណា ក្នុងថ្ងៃពេញបូណ៌មីខែអស្សុជ ។ បើវិវាទដោយការជំលោះឲ្យពន្យាបវារណាទៅដល់ថ្ងៃដាច់នៃខែអស្សុជ ឬ ថ្ងៃពេញបូណ៌មីខែកត្តិក ។ បើចាំបច្ឆិមិកាវស្សា ឲ្យធ្វើបវារណាក្នុងថ្ងៃ

www.budinst.gov.kh www.elibraryofcambodia.org

ពេញបូណ៌មីខែកត្តិក ក្នុងចន្លោះ ១ ខែ លើកថ្ងៃ ២ ចេញ ជាខែច្រនៃ ថ្ងៃសាមគ្គីបវារណា ដូចពោលហើយក្នុងឧបោសថ ។

មួយទៀត បវារណា៖ពោលដោយអ្នកធ្វើមាន ៣ គឺសង្ឃបវារណា ១ គណបវារណា ១ បុគ្គលបវារណា ១ ។ ភិក្ខុតាំងអំពី ៥ អង្គឡើងទៅឈ្មោះថាសង្ឃ គប្បីធ្វើបវារណា ដូចពោលហើយអំពីមុខនោះចុះ ។ ភិក្ខុ ៤ - ៣ - ២ អង្គឈ្មោះថាគណៈ គប្បីធ្វើបវារណាដូច្នេះ បើ ៤-៣ អង្គ ឲ្យភិក្ខុអ្នកឈ្លាសគប្បីប្រកាសឲ្យដឹងដោយគណញត្តិថា ៖

សុណន្តុ មេ អាយស្មន្តោ អជ្ជ បវារណា បណ្ណរសី ។ យទាយស្មន្តានំ បត្តកល្លំ, មយំ អញ្ញមញ្ញំ បវារេយ្យាម ។

ដូច្នេះ ហើយភិក្ខុជាថេរៈគប្បីធ្វើចីវរឆៀងស្មាម្ខាង អង្គុយច្រហោងលើកដៃប្រណម្យពោលនឹងភិក្ខុទាំងឡាយនោះថា អហំ អាវុសោ អាយស្មន្តេ បវារេមិ ។ល។ បដិករិស្សាមិ ។ ទុតិយម្បិ អាវុសោ ។ល។ តតិយម្បិ អាវុសោ អាយស្មន្តេ បវារេមិ ។ល។ បដិករិស្សាមិ ។ ដូច្នេះ ហើយភិក្ខុកំឡោះគ្រប់ៗអង្គ គប្បីធ្វើដូច្នោះដោយលំដាប់ ពោលថា អហំ ភន្តេ អាយស្មន្តេ ។ល។ បដិករិស្សាមិ ។ល។ ទុតិយម្បិ ភន្តេ ។ល។ តតិយម្បិ ភន្តេ អាយស្មន្តេ បវារេមិ ។ល។ បដិករិស្សាមិ ដូច្នេះ ។ បើ ២ អង្គមិនត្រូវតាំងញត្តិ ប្រជុំគ្នាហើយ ភិក្ខុជាថេរ គប្បីឃុំចីវរឆៀងស្មាម្ខាង អង្គុយច្រហោងលើកដៃប្រណម្យ ពោលនឹងភិក្ខុ

www.budinst.gov.kh www.elibraryofcambodia.org

កាំឡោះថា អហំ អាវុសោ អាយស្មន្តំ បវារេមិ ។ល។ វទន្តុ មំ អាយស្មា ។ល។ បដិករិស្សាមិ ។ ទុតិយម្បិ អាវុសោ ។ល។ តតិយម្បិ អាវុសោ អាយស្មន្តំ បវារេមិ ។ល។ បដិករិស្សាមិ ។ ដូច្នេះហើយ ភិក្ខុកាំឡោះគប្បីធ្វើដូច្នោះ ពោលនឹងព្រះថេរថា អហំ ភន្តេ អាយស្មន្តំ បវារេមិ ។ល។ បដិករិស្សាមិ ។ ទុតិយម្បិ ភន្តេ ។ល។ តតិយម្បិ ភន្តេ អាយស្មន្តំ បវារេមិ ។ល។ បដិករិស្សាមិ ដូច្នេះ ។ យ៉ាងនេះឈ្មោះថាគណបវារណា ។ មួយអន្លើឈ្មោះថាបុគ្គល នៅមួយអន្លើដល់ថ្ងៃបវារណា គប្បីធ្វើបុព្វករណៈមានបោសវេនិងបវារណាជាដើម ហើយអង្គុយចាំភិក្ខុដទៃក្នុងសីមា ភិក្ខុដទៃមកគប្បីធ្វើសង្ឃបវារណា ឬគណបវារណាជាមួយនឹងភិក្ខុនោះ តាមច្រើនតាមតិច បើឃើញថាមិនមក គប្បីអធិដ្ឋានថា អជ្ជ មេ បវារណា ដូច្នេះ ក្នុងអដ្ឋកថា ប្រាប់ថាឲ្យថែមថ្ងៃចូលផងថា អជ្ជ មេ បវារណា ចាតុទ្ទសីតិ(១) អធិដ្ឋាមិ ដូច្នេះ តាមថ្ងៃ ១៤ - ១៥ យ៉ាងនេះ ឈ្មោះថាបុគ្គលបវារណា ។ មួយទៀត បុរាណាចារ្យ លោកពោលទុកថា បវារណាមាន ៩ ប្រការ ដូចឧបោសថ តែមិនបញ្ញត្តិឈ្មោះទុកឲ្យអស់ ចំណែកក្នុងមូលសិក្ខា ពោលថាបវារណា ពោលដោយអាការនឹងគប្បីធ្វើមាន ៣ គឺ តេវាចិកបវារណា ១ ទ្វេវាចិកបវារណា ១ ឯកវាចិកបវារណា ១ ។

---

(១) បើថ្ងៃ ១៥ ថាបណ្ណរសីតិ ជួស ចាតុទ្ទសីតិ ។

www.budinst.gov.kh www.elibraryofcambodia.org

មួយទៀត បើពោលថាញត្តិបវារណា អញត្តិបវារណា ទាំងអធិដ្ឋានបវារណាដូច្នេះក៏បាន ។ ញត្តិបវារណាមាន ២ គឺសង្ឃញត្តិបវារណា ១ គណញត្តិបវារណា ១ ។ អញត្តិបវារណាក៏មាន ២ គឺភិក្ខុ ២ អង្គបវារណាផល់គ្នា ១ ភិក្ខុមួយអង្គ ឬពីរអង្គ ឬអំពីបីអង្គឡើងទៅ បវារណាក្នុងសំណាក់ភិក្ខុដទៃដែលច្រើនជាង ធ្វើ។ បោសបហើយ ១ ជា ២ ។ អធិដ្ឋានបវារណា គឺបុគ្គលបវារណានោះឯង ។

មួយទៀត តាំងសង្ឃញត្តិមាន ៥ គឺតាំងជាសព្វសង្គាហិកា ១ តាំងជា តេវាចិកា ១ តាំងជាទ្វេវាចិកា ១ តាំងជាឯកវាចិកា ១ តាំងជាសមានវស្សិកា ១ ។ តាំងសូត្រថា សុណាតុ ។ល។ បត្តកាលំ ហើយចុះខាងចុងថា សង្ឃោ បវារេយ្យ ដូច្នេះ ឈ្មោះថាសព្វសង្គាហិកញត្តិ កាលតាំងញត្តិដូច្នេះហើយ បវារណាមួយអង្គ ៗ ៣ ដង ទាំងមួយអង្គ ៗ ២ ដង មួយអង្គ ៗ ម្ដងក៏គួរ តែវស្សាស្មើគ្នា ទាំងបវារណាព្រមគ្នាម្យ៉ាងមិនគួរ ។ កាលតាំងញត្តិចុះខាងចុងថា សង្ឃោ តេវាចិកំ បវារេយ្យ ដូច្នេះហើយ បវារណាមួយអង្គ ៣ ដងទើបគួរ យ៉ាងដទៃមិនគួរ ។ កាលតាំងញត្តិថា សង្ឃោ ទ្វេវាចិកំ បវារេយ្យ ដូច្នេះហើយ ទាំងបវារណាមួយអង្គ ២ ដង ឬមួយអង្គ ៣ ដងក៏គួរ តែបវារណាមួយអង្គអស់វារៈម្ដង ទាំងវស្សាស្មើគ្នាជាព្រមគ្នាមិនគួរ ។ កាលតាំងញត្តិចុះខាងចុងថា សង្ឃោ ឯកវាចិកំ បវារេយ្យ ដូច្នេះហើយ ទាំងបវារណាមួយអង្គអស់វារៈម្ដង ឬមួយអង្គអស់វារៈ ២ ដង ឬ ៣ ដងក៏គួរ តែវស្សា

www.budinst.gov.kh www.elibraryofcambodia.org

ស្មើគ្នាជាព្រហ្មគ្នា ម្យ៉ាងមិនគួរ ។ កាលតាំងញត្តិចុះខាងចុងថា សង្ឃោ សមានសំវាសកំ បវារេយ្យ ដូច្នេះហើយបវារណាទាំងអស់គ្នាក៏គួរ ។ ដែលបវារណាមួយអន្លើអស់វារៈ ២ ដង មួយអន្លើអស់វារៈមួង និងវស្សាស្មើគ្នាជាព្រហ្មគ្នាដូច្នេះ លុះតែមានហេតុទើបធ្វើបាន កាលមិនមានហេតុនឹងធ្វើមិនគួរ ហេតុនោះជាដើមថា ទាយកកំពង់ថ្វាយទាន ឬភិក្ខុកំពុងស្តាប់ធម៌ រាត្រីទៀបនឹងអស់ទៅ បវារណាមួយអន្លើ ៣ ដងមិនទាន់ ឬមានអន្តរាយទាំង ១០ ប្រការណាមួយ បវារណាមួយអន្លើ ៣ ដងមិនទាន់ ឲ្យបវារណាមួយអន្លើ ២ ដង កាលបវារណាមួយអន្លើ ២ ដងមិនទាន់ ឲ្យបវារណាមួយអន្លើម្តង ។ កាលថាមួយអន្លើម្តង ។ មិនទាន់ ដែលមានវស្សាស្មើគ្នាឲ្យថាព្រហ្មគ្នា តែត្រូវតាំងញត្តិដូច្នេះជាមុនថា សុណាតុ មេ ភន្តេ សង្ឃោ អយំ ព្រហ្មចរិយន្តរាយោ ។ សចេ សង្ឃោ តេវាចិកំ បវារេស្សតិ, អប្បវារិតោវ សង្ឃោ ភវិស្សតិ, អថាយំ ព្រហ្មចរិយន្តរាយោ ភវិស្សតិ ។ យទិ សង្ឃស្ស បត្តកល្លំ, សង្ឃោ ទ្វេវាចិកំ ។ល។ ឯកវាចិកំ ។ល។ សមានវស្សិកំ បវារេយ្យ ។ ដូច្នេះ ហើយគប្បីបវារ-ណាតាមញត្តិនោះចុះ ដូច្នេះពោលល្មមជាបែបយ៉ាង កាលបើមានហេតុដទៃ គប្បីតាំងញត្តិផ្លាស់ទៅតាមហេតុនោះចុះ ។

មួយទៀត បវារណាកម្មមាន ៤ បើក្នុងអាវាសមួយកាលភិក្ខុនៅ ៥ អង្គ នាំបវារណានៃភិក្ខុមួយអង្គទៅ ភិក្ខុ ៤ អង្គតាំងគណញត្តិហើយបវារណាគ្នា

www.budinst.gov.kh www.elibraryofcambodia.org

ឬនៅ ៤ ៣ អង្គ នាំបវារណានៃភិក្ខុមួយអង្គទៅ ភិក្ខុ ៣ អង្គ ឬ ២ អង្គតាំងសញ្ញត្តិហើយបវារណាគ្នានឹងគ្នា បវារណាកម្មទាំងពួងនេះឈ្មោះថា អធម្មេន. វគ្គំ ជាវគ្គមិនតាមធម៌ ។ ថាបើ ៥ អង្គប្រជុំក្នុងទីជាមួយគ្នាទាំងអស់ តាំងគណញត្តិហើយបវារណា ឬ ៤-៣-២ អង្គនៅជាមួយគ្នាប្រជុំក្នុងទីជាមួយគ្នា តាំងសញ្ញត្តិហើយបវារណាគ្នា បវារណាកម្មទាំងពួងនេះឈ្មោះថា អធម្មេន សមគ្គំ ព្រមព្រៀងគ្នា តែមិនតាមធម៌ ។ ថាបើភិក្ខុ ៥ អង្គ នាំបវារណានៃភិក្ខុមួយអង្គទៅ ភិក្ខុ ៤ អង្គតាំងសញ្ញត្តិហើយបវារណា ឬ ៤-៣ អង្គ នាំបវារណានៃភិក្ខុមួយអង្គទៅ ភិក្ខុ ៣ អង្គ ឬ ២ អង្គតាំងគណញត្តិ ហើយបវារណាគ្នានឹងគ្នា បវារណាកម្មទាំងពួងនេះឈ្មោះថា ធម្មេន វគ្គំ ជាវគ្គតែតាមធម៌ ។ ថាបើភិក្ខុ ៥ អង្គប្រជុំគ្នាក្នុងទីមួយ តាំងសញ្ញត្តិហើយបវារណា ភិក្ខុ ៤ អង្គ ឬ ៣ អង្គប្រជុំក្នុងទីជាមួយគ្នា តាំងគណញត្តិហើយបវារណា នឹងភិក្ខុ ២ អង្គបវារណាដល់គ្នានឹងគ្នា នៅតែមួយអង្គ ធ្វើអធិដ្ឋានបវារណា បវារណា-កម្មទាំងពួងនោះឈ្មោះថា ធម្មេន សមគ្គំ ព្រមព្រៀងគ្នាតាមធម៌ក្នុងកម្មទាំង ៤ នេះ ៣ ខាងដើមមិនគួរ គួរតែខាងចុងប៉ុណ្ណោះ ។

មួយទៀត កាលព្រះថេរៈអង្គុយប្រហោងកំពុងបវារណា ភិក្ខុកំឡោះ អង្គុយកបចុះលើអាសនៈត្រូវទុក្កដ ។ ផ្សិតច្រងំឃាត់ទុកថា ន ភិក្ខវេ ថេរេសុ ភិក្ខូសុ ឧក្កុដិកំ និសិន្នេសុ បវារ-

www.budinst.gov.kh www.elibraryofcambodia.org

យមាឆេសុ អច្ចិតព្ពំ យោ អច្ចេយ្យ អាបត្តិ ទុក្កដស្ស ដូច្នេះ ។ ហើយទ្រង់អនុញ្ញាតឲ្យអគ្គិយប្រហោងបវារណាតទៅ ក្នុងសម័យនោះ ព្រះថេរមួយរូបទុព្វលដោយជក អគ្គិយប្រហោង រងចាំភិក្ខុដែលបវារណា ហើយសន្លប់ដួលចុះ ព្រះអង្គទ្រង់អនុញ្ញាតទៀត ឲ្យអគ្គិយប្រហោងក្នុងលំដាប់នោះ ចំកំពូលបវារណាហើយ បវារណាហើយ ឲ្យអគ្គិយកបលើតាសន: វិនិច្ឆ័យក្រៅនោះ គប្បីដឹងដូចពោលហើយក្នុងឧបោសថ ។

នឹងពោលបាលិមុត្តក: វិនិច្ឆ័យតាមអដ្ឋកថា បើភិក្ខុចាំបុរិមិកាវស្សា ៥ អង្គ ចាំបច្ឆិមិកាវស្សា ៥ អង្គ កាលអ្នកចាំវស្សាអំពីដំបូង តាំងញត្តិបវារណាហើយ ភិក្ខុចាំវស្សាខាងក្រោយ គប្បីធ្វើបារិសុទ្ធិឧបោសថក្នុងសំណាក់នៃភិក្ខុចាំវស្សាអំពីដំបូងនោះចុះ កុំគប្បីតាំងញត្តិ ២ ដង ក្នុងរោងឧបោសថ ១ សូម្បីភិក្ខុចាំវស្សាខាងក្រោយ ៤ អង្គ ឬ ៣ - ២ - ១ អង្គ ន័យនោះក៏ដូចគ្នាពិត បើភិក្ខុចាំវស្សាអំពីដំបូង ៤ អង្គ ភិក្ខុចាំវស្សាខាងក្រោយ ៤ អង្គ ឬ ៣ ២ - ១ អង្គ ន័យនោះក៏ដូចគ្នាពិត បើភិក្ខុចាំវស្សាដំបូង ៣ អង្គ ចាំវស្សាខាងក្រោយ ៣ - ២ - ១ អង្គ ន័យនោះក៏ដូចគ្នាដែរ ដូច្នេះឯងជាលក្ខណៈ ក្នុងបវារណាកម្មនេះ ។ បើភិក្ខុចាំវស្សាខាងក្រោយតិចជាង ឬស្មើគ្នានឹងភិក្ខុចាំវស្សាអំពីដំបូងសោត រមែងជាគណបូរក:នៃសង្ឃបវារណាបាន គប្បីតាំងញត្តិជាសង្ឃបវារណាចុះ ។ បើភិក្ខុចាំវស្សាអំពីដំបូង ៣ អង្គ ជា ៤ នឹងភិក្ខុចាំវស្សាខាងក្រោយ ១ អង្គ

www.budinst.gov.kh www.elibraryofcambodia.org

ភិក្ខុ ៤ អង្គ នឹងតាំងសង្ឃញត្តិហើយបវារណាមិនគួរ តែភិក្ខុ ១ អង្គនោះ រមែងជាគណបូរកៈនៃគណញត្តិបាន ព្រោះហេតុនោះ ភិក្ខុចាំវស្សាដំបូង ៣ អង្គ តាំងគណញត្តិហើយ គប្បីបវារណាចុះ ភិក្ខុចាំវស្សាខាងក្រោយ ១ អង្គ គប្បីធ្វើបារិសុទ្ធិឧបោសថ ក្នុងសំណាក់នៃភិក្ខុទាំងឡាយនោះចុះ ។ ភិក្ខុចាំវស្សាអំពីដំបូង ២ អង្គ ភិក្ខុចាំវស្សាខាងក្រោយ ២ អង្គ ឬ ១ អង្គ ន័យនោះក៏ដូចគ្នាដែរ ។ ភិក្ខុចាំវស្សាអំពីដំបូង ១ អង្គ ភិក្ខុចាំវស្សាខាងក្រោយ ១ អង្គ ដូច្នេះ ឲ្យភិក្ខុ ១ អង្គ គប្បីបវារណាក្នុងសំណាក់នៃភិក្ខុ ១ អង្គ ភិក្ខុ ១ អង្គ ធ្វើបារិសុទ្ធិឧបោសថ ក្នុងសំណាក់នៃភិក្ខុ ១ អង្គនោះចុះ ។ បើភិក្ខុចាំវស្សាខាងក្រោយច្រើនជាងភិក្ខុចាំវស្សាអំពីដំបូងសូម្បី ១ អង្គ គប្បីសូត្របាតិមោក្ខឡើងមុន ខាងក្រោយភិក្ខុតិចជាងគប្បីបវារណាក្នុងសំណាក់នៃភិក្ខុច្រើននោះចុះ ។ តែក្នុងថ្ងៃបវារណា ពេញបូណ៌មីខែកត្តិក បើភិក្ខុចាំវស្សាខាងក្រោយច្រើនជាង ឬស្មើគ្នានឹងភិក្ខុចាំវស្សាអំពីដំបូង ដែលបានបវារណាហើយក្នុងថ្ងៃមហាបវារណានោះសោត គប្បីតាំងញត្តិបវារណា ហើយបវារណាចុះ ។ កាលភិក្ខុចាំវស្សាខាងក្រោយបវារណាហើយ ភិក្ខុចាំវស្សាអំពីដំបូង គប្បីធ្វើបារិសុទ្ធិឧបោសថក្នុងសំណាក់នៃលោកទាំងឡាយនោះចុះ ។ បើភិក្ខុច្រើនបវារណាហើយក្នុងថ្ងៃមហាបវារណា ភិក្ខុចូលវស្សាខាងក្រោយតិចជាង សូម្បី ១ អង្គ កាលសូត្របាតិមោក្ខហើយ ខាងក្រោយភិក្ខុតិចជាងនោះ គប្បីបវារណាក្នុងសំណាក់នៃភិក្ខុច្រើននោះចុះ ។

www.budinst.gov.kh www.elibraryofcambodia.org

មួយទៀត ភិក្ខុចាំវស្សាអំពីដំបូងនៅជាផាសុវិហារ គឺនៅដោយសប្បាយ ឃើញថាបវារណា ក្នុងថ្ងៃមហាបវារណា មិនសូវឲ្យផាសុវិហារបង់ ហើយនឹងធ្វើបវារណាសង្គហៈ គឺធ្វើឧបោសថក្នុងថ្ងៃនោះ បង្អង់ថ្ងៃបវារណាទៅក្នុងថ្ងៃពេញបូណ៌មីខែកត្តិក ដោយញត្តិកម្មក៏បាន ។

បាលីបវារណាថា សង្ឃម្ភន្តេ បវារេមិ ។ល។ បដិការិស្សាមិ ប្រែថា ខ្ញុំព្រះករុណាសូមបវារណានឹងសង្ឃដោយការបានឃើញ ឬដោយបានឮ ឬដោយបានរង្កៀស លោកទាំងឡាយដ៏មានអាយុ អាស្រ័យនូវសេចក្ដីអនុគ្រោះ ចូរពោលដាស់តឿនខ្ញុំព្រះករុណាចុះ កាលខ្ញុំព្រះករុណាឃើញនឹងធ្វើតាម ។ បវារណាដោយពាក្យប៉ុណ្ណោះ ទើបជាសេចក្ដីអនុលោមដល់គ្នានឹងគ្នា មិនញាំងគ្នានឹងគ្នាឲ្យចេញចាកអាបត្តិ នឹងធ្វើវិន័យក្នុងខាងមុខ ។

បវារណាកថា ចប់

## សីមាកថា

គោលអំពីសីមាដោយសង្ខេប ។ ឧបោសថ បវារណា នឹងសង្ឃកម្មទាំងពួង ភិក្ខុត្រូវធ្វើក្នុងខាងក្នុងសីមា ព្រះអង្គទ្រង់អនុញ្ញាតសីមាទុកដើម្បីនឹងឲ្យដឹងថាជាដែនសាមគ្គី ដោយពាក្យថា អនុជានាមិ ភិក្ខវេ

www.budinst.gov.kh www.elibraryofcambodia.org

សីមំ សម្មន្និកុំ ។ល។ ធារយាមិ ដូច្នេះ ៗ ឯសីមានោះមាន ២ គឺពទ្ធសីមា ១ អពទ្ធសីមា ១ ៗ សីមាដែលសន្មតនឹងនិមិត្តដោយនិមិត្តសម្បត្តិ ឲ្យផុតចាកសីមាវិបត្តិ ១១ ប្រកបដោយសម្បត្តិ ៣ ឈ្មោះថាពទ្ធសីមា ៗ សីមាវិបត្តិ ១១ នោះ គឺ សីមាតូចណាស់មិនល្មមភិក្ខុ ២០ អង្គអង្គុយបាន ១ សីមាធំហួសលើស ៣ យោជន៍ឡើងទៅ សូម្បីត្រឹមមួយសរសៃសក់ ១ សីមាមាននិមិត្តមិនតគ្នា គឺសួរនិមិត្តដើមហើយ មិនត្រឡប់មកសួរនិមិត្តដើមទៀត ឬយកវត្ថុណាមួយមិនគួរជានិមិត្តបាន មកធ្វើជានិមិត្តក្នុងចន្លោះ ១ យកស្រមោលភ្នំជាដើមជានិមិត្ត ១ មិនមាននិមិត្ត ១ សួរនិមិត្តហើយឈរខាងក្រៅនិមិត្តសម្មតិ ១ សម្មតិក្នុងស្ទឹង ១ ក្នុងសមុទ្ទ ១ ក្នុងជាតស្រះ ១ សម្មតិចំលាយសីមាចាស់នៃភិក្ខុដទៃដោយសីមាខ្លួន ១ សម្មតិគ្របសង្កត់សីមាចាស់នៃភិក្ខុដទៃ ១ ដូច្នេះ ឈ្មោះថាសីមាវិបត្តិ ៗ សម្មតិសីមាធំហួស ចំលាយ នឹងសង្កត់សីមាចាស់នៃភិក្ខុដទៃ ៣ នេះ ត្រូវអាបត្តិទុក្កដ ៗ សីមាចាស់ជាធម៌ សីមាថ្មីមិនជាធម៌ ៗ កាលនឹងសម្មតិសីមាជិតគ្នា គប្បីដំកល់សីមន្តរិក គឺទីជាចន្លោះនៃដែនចុះទុកមុនសិន សឹមសម្មតិ ៗ សម្បត្តិ ៣ នោះគឺនិមិត្តសម្បត្តិ ១ បរិសសម្បត្តិ ១ កម្មវាចាសម្បត្តិ ១ ៗ

និមិត្តមាន ៨ គឺ បព្វតោ ភ្នំធំប៉ុនដំរីឡើងទៅ ១ បាសាណោ ថ្មប៉ុនដុំស្ករគំពៅធ្ងន់ ៣២ បលៈឡើងទៅ ១ វនំ ព្រៃឈើដែលមានខ្លឹមខាងក្នុង ១ រុក្ខោ ជាតិដើមឈើដែលមានខ្លឹមខាងក្នុងដែលរស់នៅ ៖

www.budinst.gov.kh www.elibraryofcambodia.org

មគ្គោ ផ្លូវដើរដោយជើងទឹងផ្លូវរទេះ ១ វម្មិកោ ដំបូក ១ នទី ស្ទឹង ផ្លូវពោលហើយខាងដើម ១ ឧទកំ ទឹកដក់នៅក្នុងរណ្ដៅជាដើមដែលមិនហូរ ១ វត្ថុទាំង ៨ នេះ វត្ថុណាមួយយកជានិមិត្ត មិនយករបស់ដទៃជានិមិត្ត សូត្រក្នុងទិសនោះៗ ឈ្មោះថានិមិត្តសម្បត្តិ ។ ភិក្ខុ ៤ អង្គដោយកំណត់យ៉ាងតិចប្រជុំគ្នា ភិក្ខុក្រៅនោះនៅក្នុងគាមខេត្រនោះទាំងប៉ុន្មានមិនបានមកចូលក្នុងហត្ថបាស គប្បីនាំឆន្ទៈមក ឬឲ្យចូលក្នុងពទ្ធសីមាខែខ្មួន ឬឲ្យចុះទៅក្នុងស្ទឹង ឬក្នុងសមុទ្រ ក្នុងជាតស្រះ ហើយសម្មតិសីមា ឈ្មោះថាបរិសសម្បត្តិ ។

ភិក្ខុអ្នកឈ្លាសស្លូត្រសម្មតិ ដោយញត្តិទុតិយកម្មវាចា បរិសុទ្ធ មិនបានវិបត្តិអក្ខរៈមានសិថិលជាធនិតជាដើម ដូច្នេះឈ្មោះថាកម្មវាចាសម្បត្តិ ។

មួយទៀត ពទ្ធសីមា ក្នុងបាលីមាន ២ គឺ សមានសំវាសសី-មា សីមាមានសំវាសស្មើគ្នា ជាដែនសម្រាប់ធ្វើសង្ឃកម្មបានមួយដំបន់ ១ អវិប្បវាសសីមា សីមាដែលសង្ឃសម្មតិគ្របសង្កត់សមានសំវាសសីមានោះចុះ ដោយញត្តិទុតិយកម្មវាចាដទៃទៀត ដើម្បីនឹងនៅប្រាសចាកត្រៃចីវរបានផង ១ ត្រូវជា ២ ។ បើពោលតាមអដ្ឋកថា មាន ៣ គឺបន្ថែមខណ្ឌសីមាចូលផង ខណ្ឌសីមានោះគឺសីមាតូចសម្មតិទុកក្នុងបន្ទោះពទ្ធ-សីមាធំនោះ ដើម្បីនឹងធ្វើសង្ឃកម្មងាយ មិនរង្កៀសដោយភិក្ខុដទៃ ដែលនឹងចូលមកក្នុងសីមានោះ ។ ឯអពទ្ធសីមានោះ គឺសីមាដែលសង្ឃមិនបានចង មាន ៣ គឺគាមសីមា ១ សត្តព្ភន្តរសីមា ១ ឧទកុក្ខេបសីមា ១ ។

www.budinst.gov.kh www.elibraryofcambodia.org

គាមខេត្តមួយទំហំប៉ុន្មាន ឈ្មោះថាគាមសីមា ដោយបាលីថា អសម្ម-
តាយ ភិក្ខវេ សីមាយ អដ្ឋបិតាយ យំ គាមំ វា និគមំ វា
ឧបនិស្សាយ វិហរតិ យា គាមស្ស វា គាមសីមា
និគមស្ស វា និគមសីមា អយំ តត្ថ សមានសំវាសា
ឯកុបោសថា សេចក្តីថា កាលសីមាសង្ឃមិនបានសម្មតិ មិនបាន
ដំកល់ទុក ភិក្ខុចូលទៅអាស្រ័យនៅក្នុងស្រុក ឬនិគមណា គាមសីមា
ដែលនៃស្រុក និគមសីមា ដែលនៃនិគមណា ដែលក្នុងស្រុកឬនិគមនោះ
ឈ្មោះថាសីមាមានសំវាសស្មើគ្នា មានឧបោសថជាមួយគ្នា ។ ព្រៃ
មិនមែនស្រុកប្រមាណ ៧ អព្ភន្តរៈដោយជុំវិញ ឈ្មោះថាសត្តព្ភន្តរសីមា
ដោយបាលីថា អគាមកេ ភិក្ខវេ អរញ្ញេ សមន្តា សត្តព្ភន្តរា
អយំ តត្ថ សមានសំវាសា ឯកុបោសថា ដូច្នេះ ។ កាល
ឈរនៅកណ្តាល ៧ អព្ភន្តរៈ ក្នុងទិសទាំងពួងដោយចុះរហូតទៅត្រូវជា
១៤ អព្ភន្តរៈ អព្ភន្តរៈ ១ មានប្រមាណ ២៨ ហត្ថ ។ ក្នុងស្ទឹងជាដើម
ទីខាងក្នុងកំណត់ដោយសាចទឹក ឈ្មោះថាឧទកុក្ខេបសីមា ដោយ
បាលីថា សព្វា ភិក្ខវេ នទី អសីមា សព្វោ សមុទ្ទោ
អសីមោ សព្វោ ជាតសរោ អសីមោ នទិយា វា
ភិក្ខវេ សមុទ្ទេ វា ជាតសរេ វា យំ មជ្ឈិមស្ស
បុរិសស្ស សមន្តា ឧទកុក្ខេបា អយំ តត្ថ សមាន-
សំវាសា ឯកុបោសថា ។

www.budinst.gov.kh www.elibraryofcambodia.org

សេចក្ដីថា ស្ទឹងទាំងមូលមិនមែនជាសីមា សមុទ្ទទាំងមូលមិនមែនជាសីមា ស្រះកើតឯងទាំងមូលមិនមែនជាសីមា គឺថាមិនមែនដូចជាគាមខេត្ត សូម្បីសម្មតិសីមា ក៏មិនជាការសម្មតិ ទីឯណាក្នុងស្ទឹងកើតឯងមិនមែនស្ទឹងជីក ឬក្នុងសមុទ្ទ ឬក្នុងស្រះកើតឯងមិនមែនស្រះមនុស្សជីក កំណត់ដោយសាចទឹកនៃមជ្ឈិមបុរសដោយជុំវិញក្នុងទីនោះ ដូច្នេះឯងជាសីមា មានសំរាំសស្មើគ្នា មានទោសជាមួយគ្នា ដូច្នេះ ៗ ក្នុងរដូវភ្លៀង ៤ ខែ ភ្លៀង ៧ ថ្ងៃធ្លាក់គ្រប់កន្លះខែ ក្នុងស្ទឹងណា ក្នុងស្រះកើតឯងណា ទឹកមិនដាច់ ទាន់ភិក្ខុនីស្លៀកជាបរិមណ្ឌលមិនបានលើកជាយស្បង់ចុះឆ្លង ល្មមជាយស្បង់ទទឹកមាត្រាមួយធ្នាប់ឬពីរធ្នាប់ ដូច្នេះឈ្មោះថាស្ទឹង ឈ្មោះថាស្រះកើតឯង ៗ ក្នុងស្ទឹង ក្នុងជាតស្រះក្នុងរដូវភ្លៀងស្រួល ៤ ខែ ឯក្នុងសមុទ្ទវេលារលកប្រែក្រតី លិចទីចុងខ្នាន អំពីទីចុះណ្ណោះចុះទៅ ជាកប្បិយភូមិ ធ្វើសង្ឃកម្មក្នុងទីនោះបាន ភ្លៀងមិនស្រួលរដូវរាំងប្រាំង សូម្បីរីងស្ងួតទៅទីអម្បាលនោះក៏គង់នៅជាកប្បិយភូមិ បើគេជីកជាអណ្ដូងចុះទៅ ឬសាចពូជចុះ ទីនោះជាគាមខេត្ត ៗ ឧទុក្ខេបសីមាមិនបានចេញទៅក្រៅកប្បិយភូមិទេ នៅតែក្នុងខាងក្នុង ៗ អព្ភន្តរសីមានឹងឧទុក្ខេបសីមា ២ នេះ កំណត់អំពីឱកាសភិក្ខុឈរចេញទៅ ៗ

បើសង្ឃ ២ ពួកនឹងធ្វើសង្ឃកម្ម ឲ្យកំណត់ ៧ អព្ភន្តរៈនឹងដូរសាចទឹកដទៃទៀតចុះ ក្នុងចន្លោះជាឧបចារៈ ភិក្ខុនៅខាងក្នុងទីកំណត់លះហត្ថ-បាសគ្នាចេញក្ដី នឹងខាងក្រៅទីកំណត់ឈរ មិនទុកចន្លោះជាឧបចារៈក្ដី

www.budinst.gov.kh www.elibraryofcambodia.org

ឲ្យកម្ពក់រើកបាន ។ មែកឈើក្នុងមហាសីមាទោរចូលទៅចុចផ្ទៃក្នុងខណ្ឌ-សីមាឬមែកឈើក្នុងខណ្ឌសីមាទោរចូលទៅចុចផ្ទៃក្នុងមហាសីមាមាននៅកាលនឹងធ្វើសង្ឃកម្ម គប្បីជំរះចេញមុន ។ នឹងធ្វើសង្ឃកម្មក្នុងឧទកុក្ខេប-សីមាគប្បីចុះធ្វើក្នុងទឹក ឬធ្វើលើកន លើផែ លើទូក ដែលបោះបង្គោលចុះក្នុងទឹកនោះ កុំបោះសសរ បោះបង្គោលលើច្រាំង នឹងចងដោយមែកឈើដែលដុះឡើងលើច្រាំង នឹងកុំចងក្នុងដើមឈើដែលដុះឡើងក្នុងទឹក នឹងមែកដែលគងទៅលើច្រាំង នឹងគងមួយអន្ទើរដោយមែកឈើលើច្រាំង ដ្បិតថាកាលបើដូច្នេះ ឈ្មោះថាព័ន្ធព័ទ្ធគ្នា ។

មួយទៀត កុំបណ្តែតទូក-ផែ ធ្វើសង្ឃកម្ម ដ្បិតថាញត្តិនឹងទៅនៅក្នុងទីដទៃ ១ អនុសាវនៈនឹងទៅនៅក្នុងទីដទៃ ១ ។

មួយទៀត សម្មតិសីមាសន្ធឹកច្រាំងស្ទឹង ត្រូវទុក្កដ ។ ក្នុងច្រាំងស្ទឹងណាមានទូកជានិច្ច មានស្ពានជានិច្ច នឹងសម្មតិសីមាគ្របសន្ធឹកច្រាំងស្ទឹងនោះគួរ ។

មួយទៀត សូត្របាតិមោក្ខតាមបរិវេណ មិនជាទីសង្កេត ត្រូវទុក្កដ ។ ទ្រង់អនុញ្ញាតឲ្យសម្មតិរោងឧបោសថទុកក្នុងទី ១ ដោយញត្តិ-ទុតិយកម្មវាចា ក្នុងអាវាស ១ មានសីមាមួយ សម្មតិរោងឧបោសថ ២ ជំបន់ ត្រូវអាបត្តិទុក្កដ ទ្រង់អនុញ្ញាតឲ្យរើមួយចេញ ។

សីមាកថា ចប់

www.budinst.gov.kh www.elibraryofcambodia.org

# អធិករណសមថគាថា

## ពោលអំពីវិធីរម្ងាប់អធិករណ៍

ឯអធិករណសមថ នោះ មាន ៧ យ៉ាងគឺ សម្មុខាវិន័យ ១ សតិវិន័យ ១ អមូឡ្ហវិន័យ ១ បដិញ្ញាតករណៈ ១ យេភុយ្យសិកា ១ តស្សបាបិយសិកា ១ តិណវត្ថារកៈ ១ ឈ្មោះថា អធិករណសមថៈ ព្រោះជាធម៌រម្ងាប់អធិករណ៍ ៤ ។

ភិក្ខុវិវាទឈ្លោះគ្នាដោយភេទករវត្ថុ ១៨ យ៉ាង មានដើមថា នេះធម៌ នេះមិនមែនធម៌ នេះវិន័យ នេះមិនមែនវិន័យ ដូច្នេះឈ្មោះថា វិវាទាធិករណ៍ ។ ឈ្លោះវិវាទជាល់តប់គ្នា មិនឈ្មោះថាវិវាទាធិករណ៍ទេ ។

ចោទគ្នាដោយសីលវិបត្តិ ទិដ្ឋិវិបត្តិ អាចារវិបត្តិ អាជីវវិបត្តិ ណាមួយ ឈ្មោះថា អនុវាទាធិករណ៍ ។

អាបត្តិទាំង ៧ ឈ្មោះថា អាបត្តាធិករណ៍ ។

សង្ឃកម្មទាំង ៤ គឺ អបលោកនកម្ម ១ ញត្តិកម្ម ១ ញត្តិទុតិយកម្ម ១ ញត្តិចតុត្ថកម្ម ១ ឈ្មោះថាកិច្ចាធិករណ៍ កម្មទាំង ៤ នេះ ឈ្មោះថា អធិករណ៍នោះ ព្រោះនឹងគប្បីរម្ងាប់ ដោយសមថ ៧ ។

វិវាទាធិករណ៍ រម្ងាប់ដោយសមថ ២ គឺ សម្មុខាវិន័យ ១ យេភុយ្យសិកា ១ ។ កាលនឹងរម្ងាប់ដោយសម្មុខាវិន័យម្យ៉ាងនោះ វិវាទកើតឡើងក្នុងវិហារណា សង្ឃកាត់សេចក្តីក្នុងវិហារនោះ ឬ ភិក្ខុ

www.budinst.gov.kh www.elibraryofcambodia.org

ទាំងឡាយ ទៅដើម្បីរម្ងាប់ក្នុងវិហារដទៃ នឹងគាត់សេចក្តីរម្ងាប់ក្នុងកណ្តាលផ្លូវក្តី ឬភិក្ខុទៅប្រគល់ដល់សង្ឃក្នុងវិហារឯណា សង្ឃក្នុងវិហារនោះគាត់សេចក្តីរម្ងាប់បង់ ឬសង្ឃក្នុងវិហារនោះមិនអាចរម្ងាប់បាន សម្មតិភិក្ខុឡើង ដោយឧព្វាហិកាកម្មវាចា ឲ្យជាភិក្ខុអ្នកវិនិច្ឆ័យគាត់សេចក្តី ភិក្ខុអ្នកដែលបានសម្មតិនោះ គាត់សេចក្តីរម្ងាប់ទៅក្នុងវិហារនោះខ្លួនឯងក្តី កាលបើវិវាទាធិករណ៍នោះរម្ងាប់ទៅដូច្នោះ ណា ជាភាពចំពោះមុខសង្ឃ ចំពោះមុខធម៌ ចំពោះមុខវិន័យ ចំពោះមុខបុគ្គល នេះឈ្មោះថា សម្មុខាវិន័យ ។ ការដែលការកសង្ឃព្រមព្រៀងចំពោះមុខគ្នាដោយសង្ឃសាមគ្គី នេះឈ្មោះថាភាពចំពោះមុខសង្ឃ ។ ភាពនៃវត្ថុដែលនឹងគប្បីរម្ងាប់នោះជារបស់ពិត ឈ្មោះថាភាពចំពោះមុខធម៌ ។ វត្ថុនឹងគប្បីរម្ងាប់ដោយប្រការយ៉ាងណា ភាពវត្ថុនោះមានចំពោះមុខដោយប្រការយ៉ាងនោះឯង ឈ្មោះថាភាពចំពោះមុខវិន័យ ។

អ្នកណាវិវាទនឹងអ្នកណា សេចក្តីថាមនុស្សទាំងពីរ ដែលជាសត្រូវនឹងគ្នាដោយអត្ថនោះ ជាអ្នកនៅចំពោះមុខគ្នានឹងគ្នា ឈ្មោះថាភាពចំពោះមុខបុគ្គល តែក្នុងវិវាទដែលរម្ងាប់ទៅ ដោយឧព្វាហិកាកម្មវាចានោះ ភាពចំពោះមុខសង្ឃ រមែងសាបសូន្យទៅ ។ យ៉ាងនេះឯងឈ្មោះថាវិវាទាធិករណ៍ រម្ងាប់ទៅដោយសម្មុខាវិន័យប៉ុណ្ណោះ ។ ថាបើមិនរម្ងាប់ដូច្នោះទេ ហើយភិក្ខុដែលសង្ឃសម្មតិដោយឧព្វាហិកាកម្មវាចា ប្រគល់អធិករណ៍នោះ ឲ្យដល់សង្ឃ ដោយពាក្យថា

www.budinst.gov.kh www.elibraryofcambodia.org

ខ្ញុំព្រះករុណាទាំងឡាយមិនអាចរម្ងាប់ដូច្នេះ គេទៅ សង្ឃសម្មតិភិក្ខុព្រម ដោយអង្គ ៥ ឲ្យជាអ្នកចែកស្លាក ហើយឲ្យភិក្ខុនោះចែកស្លាកដោយ អាការ ៣ គឺ លាក់១ បើក១ ខ្សឹបដាក់ត្រចៀក ១ ក្នុងបរិស័ទដែលប្រជុំនោះ ភិក្ខុជាធម្មវាទីបានស្លាកនៃធម្មវាទីច្រើន ភិក្ខុទាំងឡាយនោះពោលកាត់ សេចក្តីដូចម្តេច អធិករណ៍រម្ងាប់ទៅយ៉ាងនោះ ដូច្នេះ ឈ្មោះថារម្ងាប់ ដោយសម្មុខាវិន័យផង ដោយយេភុយ្យសិកា គឺធម្មវាទីច្រើនជាងផង ក្នុងចំណែកនេះសម្មុខាវិន័យ មានន័យដូចពោលហើយពិត តែដែលធ្វើ យេភុយ្យសិកាកម្ម គឺចែកស្លាកគេធម្មវាទីបានច្រើននេះឯង ឈ្មោះថាយេ-ភុយ្យសិកា វិវាទាធិករណ៍រម្ងាប់ដោយសមថៈ ២ ដូចពោលមកនេះឯង ។

អនុវាទាធិករណ៍រម្ងាប់ដោយសមថៈ ៤ គឺ សម្មុខាវិន័យ ១ សតិ-វិន័យ ១ អមូឡ្ហវិន័យ ១ តស្សបាបិយសិកា ១ ។ កាលរម្ងាប់ដោយ សម្មុខាវិន័យម្យ៉ាង អ្នកណាចោទ ឬនិងចោទអ្នកណា ព្រះវិនយធរគប្បី ស្តាប់ពាក្យនៃអ្នកទាំងពីរនោះ បើឃើញថាមិនមានអាបត្តិណាមួយ ឲ្យ អ្នកទាំងពីរអត់ទោសគ្នាចុះ បើឃើញថាមានអាបត្តិហើយ កាត់សេចក្តីថា ក្នុងសេចក្តីនោះជាអាបត្តិឈ្មោះនេះ អធិករណ៍នោះរម្ងាប់ទៅ ឈ្មោះថា រម្ងាប់ទៅដោយសម្មុខាវិន័យម្យ៉ាង លក្ខណៈនៃសម្មុខាវិន័យក្នុងចំណែកនេះក៏ មានន័យដូចពោលហើយពិត ៗ ក៏ឯភិក្ខុជាព្រះខីណាស្រព អ្នកដទៃចោទ ដោយសីលវិបត្តិមិនមានមូល ហើយមកសូមសតិវិន័យនឹងសង្ឃ សង្ឃ

www.budinst.gov.kh www.elibraryofcambodia.org

ឲ្យសតិវិន័យដោយញត្តិចតុត្ថកម្មវាចាក្នុងកាលណា ក្នុងកាលនោះ អនុវា-ទាធិករណ៍ ឈ្មោះថារម្ងាប់ដោយសម្មុខាវិន័យផង ដោយសតិវិន័យផង ក្នុងកាលសង្ឃឲ្យសតិវិន័យហើយ ភិក្ខុអន្តណា នឹងចោទលោកនោះទៀត មិនឡើងឡើយ ៗ ក៏ឯភិក្ខុឆ្កួត ប្រព្រឹត្តអជ្ឈាចារ ដោយសេចក្ដីជាមនុស្សឆ្កួត ភិក្ខុដទៃចោទថា លោកចូររលឹកអាបត្តិដូច្នេះៗ សូម្បីភិក្ខុនោះពោលថា កម្មដូច្នេះខ្ញុំព្រះករុណាជាមនុស្សឆ្កួតធ្វើ រលឹកមិនបានដូច្នេះ ភិក្ខុដទៃនៅចំចោទក្ដី ហើយភិក្ខុឆ្កួតមកសូមអមូឡ្ហវិន័យ ដើម្បីនឹងមិនឲ្យចោទបានទៀត សង្ឃក៏ឲ្យអមូឡ្ហវិន័យដោយញត្តិចតុត្ថកម្មវាចាដល់ភិក្ខុនោះ ក្នុងកាលណា ក្នុងកាលនោះ អនុវាទាធិករណ៍ ឈ្មោះថារម្ងាប់ដោយសម្មុខាវិន័យផង ដោយអមូឡ្ហវិន័យផង គ្រាកាលសង្ឃឲ្យអមូឡ្ហវិន័យហើយ ភិក្ខុអន្តណា នឹងចោទភិក្ខុនោះទៀត ដោយហេតុនោះមិនឡើងឡើយ ៗ ក៏ឯភិក្ខុប្រព្រឹត្តអជ្ឈាចារ កាលត្រូវចោទដោយអាបត្តិបារាជិក ឬដោយអាបត្តិក្បែរបារាជិក កាលភិក្ខុនិយាយយកពាក្យដទៃមកគ្របបាំងចេញព្រោះជាមនុស្សលាមកណាស់ គ្រាសដោយបាប សង្ឃកាលសំគាល់ថាបើលោកនេះ នឹងមានមូលមិនដាច់ ហើយលោកនឹងបដិបត្តិប្រពៃ នឹងបានឧសារណា (ការទាញចូល) បើលោកមានមូលដាច់ហើយសោត នេះឯងនឹងជានាសនា ការឲ្យវិនាសដល់លោកនោះ សង្ឃសំគាល់ដូច្នេះហើយ ធ្វើតស្សបាបិយសិកាកម្មដល់លោកនោះ ដោយញត្តិចតុត្ថ-កម្មវាចា ក្នុងកាលណា ក្នុងកាលនោះ អនុវាទាធិករណ៍ឈ្មោះថារម្ងាប់

www.budinst.gov.kh www.elibraryofcambodia.org

ដោយសម្មុខាវិន័យផង ដោយតស្សបាបិយសិកាផង ។ អនុវាទាធិ-
ករណ៍រម្ងាប់ដោយសមថៈ ៤ ដូចពោលមកនេះឯង ។

អាបត្តាធិករណ៍ រមែងរម្ងាប់ដោយសមថៈ ៣ គឺសម្មុខាវិន័យ ១ បដិញ្ញាតករណៈ ១ តិណវត្ថារកៈ ១ ។ អាបត្តាធិករណ៍នោះ ដែលនឹងរម្ងាប់ដោយសម្មុខាវិន័យម្យ៉ាងមិនមាន លុះតែក្នុងកាលណាភិក្ខុសំដែងលហុកាបត្តិ ក្នុងសំណាក់ភិក្ខុ ១ អង្គ ឬក្នុងកណ្តាលសង្ឃនឹងគណៈ ក្នុងកាលនោះ អាបត្តាធិករណ៍រមែងរម្ងាប់ដោយសម្មុខាវិន័យផង ដោយបដិញ្ញាតករណៈផង ។ អ្នកណាសំដែង សំដែងនឹងអ្នកណា ការដែលមនុស្សទាំងពីរនោះនៅចំពោះមុខគ្នា ឈ្មោះថាការនៅចំពោះមុខបុគ្គលក្នុងសម្មុខាវិន័យនោះ ។ ការនៅចំពោះមុខក្រៅនោះ មានន័យដូចពោលហើយ ។ ក្នុងវេលាសំដែងអាបត្តិ ចំពោះបុគ្គលនឹងគណៈ ការនៅព្រមចំពោះមុខសង្ឃក៏សាបសូន្យទៅ ។ ក្នុងការសំដែងអាបត្តិនោះ ការប្តេជ្ញាថា ខ្ញុំព្រះករុណាត្រូវអាបត្តិឈ្មោះនេះក្តី នឹងប្តេជ្ញាថា ខ្ញុំព្រះករុណាឃើញអាបត្តិក្តី យ៉ាងណា ភិក្ខុអ្នកទទួលធ្វើតាមការប្តេជ្ញានោះ ពោលថា លោកគប្បីសង្រួមតទៅ នេះឯងឈ្មោះថាបដិញ្ញាតករណៈ ធ្វើតាមប្តេជ្ញា ។ ការសូមបរិវាសជាដើម នឹងឲ្យបរិវាសជាដើម តាមប្តេជ្ញា ឈ្មោះថាបដិញ្ញាតករណៈក្នុងសង្ឃាទិសេស ។

ក៏ឯភិក្ខុទាំងឡាយ ២ ពួក ធ្វើការឈ្លោះគ្នា បានប្រព្រឹត្តអជ្ឈាចារ មិនជាកម្មនៃសមណៈដ៏ច្រើន កាលលដ្ឋធម៌ សេចក្តីខ្មាសកើតឡើងវិញ

www.budinst.gov.kh www.elibraryofcambodia.org

ហើយ លោកតាំងអម្បាលនោះគិតថា បើយើងតាំងឡាយ នឹងញ៉ាំងគ្នានឹងគ្នា ឲ្យសំដែងអាបត្តិតាំងអម្បាលនេះ អធិករណ៍នោះ គប្បីប្រព្រឹត្តទៅដើម្បីការរឹងរូសកាចសាហាវឡើង លោកឃើញទោសក្នុងការញ៉ាំងគ្នាឲ្យសំដែងអាបត្តិដូច្នេះហើយ ទើបព្រមគ្នាធ្វើតិណវត្ថារកកម្មគឺសង្ឃកម្មតែមួយ សង្កត់ទោសនោះទុកដូចស្មៅ គ្របលាមក ក្នុងកាលណា ក្នុងកាលនោះ អាបត្តាធិករណ៍ឈ្មោះថា រម្ងាប់ដោយសម្មុខាវិន័យផង ដោយតិណវត្ថារកៈផង ដ្បិតថាភិក្ខុតាំងប៉ុន្មានចូលទៅនៅក្នុងហត្ថបាស ក្នុងខណៈធ្វើតិណវត្ថារកកម្មនោះ លោកមិនធ្វើឲ្យច្បាស់នូវទិដ្ឋិថា កម្មនោះមិនគួរដូច្នេះ សូម្បីលោកដេកលក់នៅក្តី អាបត្តិតាំងពួងនៃលោកនោះ លើកតែអាបត្តិដែលជាទោសធ្ងន់ចាប គឺសង្ឃាទិសេស និងអាបត្តិជាគិហិបដិសំយុត្ត ប្រកបដោយគ្រហស្ថចេញ អាបត្តិក្រៅនោះបានធ្លាក់ទៅអស់ ។ អាបត្តាធិករណ៍រម្ងាប់ដោយសមថៈ៣ ដូចពោលមកនេះឯង ។

កិច្ចាធិករណ៍ រមែងរម្ងាប់ដោយសម្មុខាវិន័យម្យ៉ាង ។ អធិករណៈ៤ រមែងរម្ងាប់ដោយសមថៈ ៧ តាមសមគួរដោយប្រការដូច្នេះឯង ។ អធិករណសមថកថា ដែលបានពោលមកនេះ ជាយ៉ាងសង្ខេប ។

អធិករណសមថកថា ចប់

www.budinst.gov.kh www.elibraryofcambodia.org

## ពោលអំពីសេចក្ដីគោរពនិងមិនគោរព

ពោលអំពីសេចក្ដីមិនគោរពជាមុន សេចក្ដីមិនគោរពមាន ៦ យ៉ាង គឺ មិនគោរពក្នុងព្រះពុទ្ធ ១ មិនគោរពក្នុងព្រះធម៌ ១ មិនគោរពក្នុងព្រះសង្ឃ ១ មិនគោរពក្នុងសិក្ខា ១ មិនគោរពក្នុងអប្បមាទ ១ មិនគោរពក្នុងបដិសណ្ឋារៈ ១ ត្រូវជា ៦ យ៉ាង ។

អ្នកណាកាលព្រះដ៏មានបុណ្យជាអម្ចាស់គង់ព្រះធរមាននៅ មិនបានទៅកាន់ទីឧបដ្ឋាក កាលព្រះអង្គបរិនិព្វានហើយ មិនទៅកាន់ទីចេតិយ ទីពោធិព្រឹក្ស ដើម្បីឧបដ្ឋាន និងមិនថ្វាយបង្គំនូវព្រះចេតិយ ឬនូវពោធិព្រឹក្ស និងបាំងឆត្រពាក់ស្បែកជើងដើរទៅក្នុងលានព្រះចេតិយក្ដី គប្បីដឹងថាសេចក្ដីគោរពក្នុងព្រះពុទ្ធអង្គនៃអ្នកនោះមិនមានៗ ក៏ឯអ្នកណាជាអ្នកអាចពិត ហើយមិនទៅកាន់ទីស្ដាប់ធម៌ មិនពោលនូវសរភញ្ញៈ មិនពោលធម្មកថា និងទំលាយធម្មស្សវនៈទៅក្ដី ឬចិត្តអណ្ដែតអណ្ដូង ឬមិនអើពើ អន្តើយនៅក្នុងរោងធម្មស្សវនៈក្ដី ដូច្នេះគប្បីដឹងចុះថា សេចក្ដីគោរពក្នុងព្រះធម៌នៃអ្នកនោះមិនមាន ។ អ្នកណាមិនតាំងទុកចំពោះនូវការធ្វើសេចក្ដីគោរពក្រែងក្នុងព្រះថេរៈនិងភិក្ខុកម្លោះ ឬភិក្ខុកណ្ដាលក្ដី និងសំដែងសេចក្ដីកាមមនុស្សក្រហាប់កាយក្នុងទីទាំងឡាយ មានរោងឧបោសថ និងវិតក្កមាលកៈគឺទីឈរយុំចរ និងទៅបិណ្ឌបាតជាដើម និងមិនថ្វាយបង្គំ

www.budinst.gov.kh www.elibraryofcambodia.org

តាមលំដាប់ភិក្ខុចាស់ ដូច្នេះគប្បីដឹងចុះថា សេចក្តីគោរពក្នុងព្រះសង្ឃនៃអ្នកនោះមិនមាន ។ អ្នកណាមិនសមាទាននូវសិក្ខាទាំង៣ គឺសីល សមាធិ បញ្ញា នេះ គប្បីដឹងចុះថា អ្នកនោះមិនគោរពក្នុងសិក្ខា ។ អ្នកណាតាំងនៅក្នុងសេចក្តីប្រមាទ ប្រាសចាកសតិ មិនញុំាងអប្បមាទលក្ខណៈឲ្យចំរើនឡើង គប្បីដឹងចុះថា អ្នកនោះមិនគោរពក្នុងអប្បមាទ ។ អ្នកណាមិនធ្វើនូវបដិសណ្ឋារៈទាំង ២ គឺអាមិសបដិសណ្ឋារៈ ការទទួលដោយអាមិស និងធម្មបដិសណ្ឋារៈ ការទទួលដោយធម៌ នេះគប្បីដឹងចុះថា អ្នកនោះ មិនគោរពក្នុងបដិសណ្ឋារៈ ។

ឯសេចក្តីគោរពក៏មាន ៦ ប្រការដែរ គឺគោរពក្នុងព្រះពុទ្ធ គោរពក្នុងព្រះធម៌ គោរពក្នុងព្រះសង្ឃ គោរពក្នុងសិក្ខា គោរពក្នុងអប្បមាទ គោរពក្នុងបដិសណ្ឋារៈ ត្រូវជា ៦ ប្រការ ។ សេចក្តីគោរពទាំង ៦ ប្រការនេះ គប្បីដឹងដោយពិស្តារ ដោយបរិយាយផ្សេងអំពីអគារវៈ ដែលមានន័យក្នុងព្រះសូត្រថា សេចក្តីមិនគោរព ប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យ សេចក្តីគោរព ប្រព្រឹត្តទៅដើម្បីសេចក្តីចំរើននោះចុះ ។

គារវកថា ចប់

## កម្មដ្ឋានានិសង្សកថា

សេចក្តីក្នុងកថា ដែលពោលមកក្នុងបទនោះៗ សំដែងនូវបដិបត្តិជាគ្រឿងជំរះផុះខាត់សន្តាននៃអ្នកបដិបត្តិ ឲ្យស្អាតផូរផង់ដូចអំបោសបោស

www.budinst.gov.kh www.elibraryofcambodia.org

ប្រាសទីដែលមានសម្រាម ឲ្យសម្រេចអានិសង្ស ៤ ប្រការ ។ គឺឯអានិសង្ស
នៃកិរិយាបោសប្រាសលានព្រះចេតិយជាដើម លោកពោលទុកក្នុងគម្ពីរ
បរិវារៈដូច្នេះថា អានិសង្សនៃកិរិយាបោសប្រាសមាន ៤ ប្រការ គឺ សក-
ចិត្តំ បសីទតិ ចិត្តរបស់ខ្លួនរមែងជ្រះថ្លាផូរផង់ ដូចទត្តភិក្ខុបោសលាន
ព្រះចេតិយ ហើយឈរសំឡឹងមើល បានឱកាសកសិណហើយសម្រេច
ផលទាំងបី ១ បរចិត្តំ បសីទតិ ចិត្តអ្នកដទៃរមែងជ្រះថ្លាផូរផង់ដូច
តិស្សភិក្ខុបោសលានព្រះចេតិយ ហើយឈរកាន់កញ្ច្រែង ព្រះតិស្សទត្ត-
ត្ថេរចុះពីទូកឃើញលានព្រះចេតិយបោសហើយត្រេកអរមកសួរបញ្ហា ១
ទេវតា អត្តមនា ហោតិ ទេវតាត្រេកអរគាប់ចិត្តផង ដូចភិក្ខុមួយអង្គ
បោសលានព្រះចេតិយ នឹងលានពោធិព្រឹក្សហើយទៅងូតទឹក ទេវតា
ក៏ជ្រះថ្លាមកឈរកាន់ផ្កាឈើ ១ បាសាទិកា សំវត្តតិ យំ កម្មំ ឧប-
ចិតំ អ្នកបោសប្រាសឈ្មោះថាសន្សំនូវកម្មដែលប្រព្រឹត្តទៅដើម្បីសេចក្ដី
ជាអ្នកគួរជ្រះថ្លាដោយរូបក្នុងភពខាងមុខ ដូចព្រះអភយថេរ កាលជាតិ
អំពីមុនជាថេរៈចាស់ បានបោសលានព្រះចេតិយ នឹងបុត្រនៃអាមាត្យម្នាក់
កាលជាតិអំពីមុនជាទាសក បានចាក់សម្រាមដែលគេបោស អ្នកទាំង ២
នាក់មកក្នុងភពខាងមុខ ជាមនុស្សមានរូបល្អគួរឲ្យជ្រះថ្លា ១ កាយស្ស
ភេទា បរំ មរណា សុគតិំ សគ្គំ លោកំ ឧបបជ្ជតិ អ្នក
បោសប្រាសខាងមុខអំពីមរណៈ ព្រោះបែកធ្លាយនៃរាងកាយ រមែងទៅ
កាន់សួគ៌ទេវលោក ជាគតិដំណើរល្អ ១ ត្រូវជា ៤ ប្រការ ។

www.budinst.gov.kh www.elibraryofcambodia.org

ការមិនសង្ស័យនៃកិរិយាបោសប្រាសមាន ៥ ប្រការទៀត គឺចិត្តនៃខ្លួនជ្រះថ្លាផូរផង់ ១ ចិត្តនៃអ្នកដទៃជ្រះថ្លាផូរផង់ ១ ទេវតាត្រេកអររីករាយផង ១ សត្ថុ សាសនំ កតំ ហោតិ អ្នកបោសប្រាសឈ្មោះថាធ្វើតាមពាក្យប្រដៅនៃព្រះសាស្តា ដ្បិតថាវត្តគឺកិរិយាបោសប្រាសនេះព្រះពុទ្ធទាំងឡាយ បានទ្រង់សរសើរទុកហើយ ព្រោះហេតុនោះ កាលបើមិនបោសប្រាស ក៏ឈ្មោះថាធ្វើតាមនូវពាក្យប្រដៅនៃព្រះសាស្តា ដូចលោកពោលទុកថា ព្រះសារីបុត្រភ្លេចមិនបានបោស ទៅចូលនិរោធនៅក្នុងព្រៃហិមវន្ត ព្រះពុទ្ធអង្គទ្រង់ជ្រាបថាភ្លេច ស្ដេចយាងទៅសំដែងស្នាមព្រះបាទទុក អំពីនោះមកព្រះថេរជាម្ចាស់ សូម្បីលោកឈរក្នុងទីដែលដោះក្តុំ លោកក៏យកជើងបោសសម្រាមមុនសិនហើយទើបឈរ ១ បច្ឆិមា ជនតា ទិដ្ឋានុគតិ អាបជ្ជតិ ប្រជុំជនដែលមានក្នុងអនាគត រមែងដល់នូវទិដ្ឋានុគតិ ប្រព្រឹត្តទៅតាម គឺធ្វើតាមបែបដែលខ្លួនធ្លាប់ឃើញ ១ រួមត្រូវជា ៥ ប្រការ ។

សម្មប្បធានិសង្ខេបកថា ចប់

កថាទាំងពួងក្នុងបទនោះ ៗ កថាណាដែលពោលដោយសង្ខេបនោះ បើកុលបុត្រចង់ដឹងពិស្តារ គប្បីមើលក្នុងបាលីវគ្គ ខន្ធកៈ និងបរិវារៈ អដ្ឋកថា ដីកាចុះ ៗ

អាបត្តិទេសនាទិបព្វៈ គំរប់ ៧ ចប់

www.budinst.gov.kh www.elibraryofcambodia.org

ចាឆក្កជា

សំដែងអំពីបាទ ក្នុងអទិន្នាទាន និងបលៈ ដែលបានអាងទុកអំពីមុន ដែលជានិងវិនិច្ឆ័យក្នុងទីបំផុតនៃវណ្ណនាតាំងតួងនោះ ៗ គឺឯបាទក្នុងអទិន្នាទាននោះ ក្នុងបាលីថា ៥ មាសក ជា ១ បាទ ក្នុងនគររាជគ្រឹះក្នុងកាលនោះ ព្រោះបាលីថា តេន ខោ បន សមយេន រាជគហេ បញ្ចមាសកោ បាទោ ហោតិ ដូច្នេះ ៗ កាលបើចង់ដឹងមាសក គប្បីដឹងមាត្រាក្នុងគម្ពីរអភិធានប្បទីបិកាថា ៖

ចត្តារោ វីហយោ គុញ្ជា ទ្វេ គុញ្ជា មាសកោ ភវេ

ដូច្នេះជាមុន ថាទម្ងន់ ៤ គ្រាប់ស្រូវ ជា ១ គុញ្ជា គឺ ១ បិច ៗ ទម្ងន់ ២ គុញ្ជា ជា ១ មាសក ហៅថាសណ្តែកសក៏បាន ហៅថាមួយចិបក៏បាន ៗ ៥ មាសកនោះ ជា ១ បាទ មាត្រានេះជាកណ្តាល និងប្រើក្នុងមាសនិងទង់ដែងនិងប្រាក់ និងវត្ថុណា ៗ ក៏បាន ៗ មាសកក្នុងបាលីដែលជាមាសកនៃមាសឬទង់ដែងឬប្រាក់ ក៏មិនបានពោលទុកក្នុងបាលីនិងអដ្ឋកថា តែក្នុងអដ្ឋកថាពោលថា ២០ មាសក ជា ១ កហាបណៈ ព្រោះហេតុនោះ ៥ មាសកដែលជាបំណែកគំរប់ ៤ នៃកហាបណៈ ទើបជា ១ បាទ ក្នុងនគររាជគ្រឹះ នាសម័យនោះ ហើយលោកពោលតទៅទៀតថា ដោយលក្ខណៈនោះ ក្នុងជនបទទាំងពួង គប្បីដឹងថា ភាគគំរប់ ៤ នៃនីលកហាបណៈជារបស់

បុកណា ជា ១ បាទ មិនមែនភាគគំរប់ ៤ នៃកហាបណៈដទៃ មានស្រូវ-តាមកកហាបណៈជាដើម ។ សូម្បីព្រះពុទ្ធទាំងឡាយដែលជាអតីត អនាគត ព្រះអង្គក៏ទ្រង់បញ្ញត្តបារាជិក ដោយបាទដែលជាភាគគំរប់ ៤ នៃ នីលកហាបណៈនោះ ព្រោះអដ្ឋកថាបាឋៈពោលថា បញ្ចមាសកោ ចាតោតិ តទា រាជគហេ វីសតិមាសកោ កហាបណោ ហោតិ តស្មា បញ្ចមាសកោ បាទោ ឯតេន លក្ខណេន សព្វជនបទេសុ កហាបណស្ស ចតុត្ថោ ភាគោ បាទោតិ វេទិតព្វោ ។ សោ ច ខោ បោរាណស្ស នីលកហាបណស្ស វសេន ន ឥតរេសំ រុទ្រទាមកាទីនំ ។ តេន ហិ បាទេន អតីតា ពុទ្ធាបិ បារាជិកំ បញ្ញបេសុំ ។ អនាគតាបិ បញ្ញាបេស្សន្តិ ដូច្នេះ ។ នីលកហាបណៈនោះ ក្នុងអដ្ឋកថា ក៏មិនប្រាប់ គម្រោធ្វើនិងប្រមាណដំឡៃទុក តែក្នុងវិមតិវិនោទនីដីកា ប្រាប់ប្រមាណ ដំឡៃនៃនីលកហាបណៈ និងស្រូវតាមកកហាបណៈទុកដូច្នេះថា គប្បី ដឹងនីលកហាបណៈនោះ គេធ្វើឲ្យកើតឡើងតាមគម្រោចាស់ ដល់ព្រម ដោយលក្ខណៈ មានដំឡៃស្មើនឹងមាសឧត្តមប្រមាណ ២០ មាសក ។ បាន ឮថា ស្រូវតាមកកហាបណៈ ដំឡៃដល់ភាគ ៣ នៃនីលកហាបណៈ ហើយលោកពោលតទៅថា ក្នុងប្រទេសណាមិនមាននីលកហាបណៈ ក្នុងប្រទេសនោះ គប្បីកំណត់បាទដោយកល្ហាៈស្មើដំឡៃ ៥ មាសក នៃ

www.budinst.gov.kh www.elibraryofcambodia.org

មាស ដែលគេដេញហើយច្រាសចាកទោសនោះចុះ ដោយបាឋៈក្នុងវិមតិវិនោទនីថា បោរាណសត្ថានុរូបំ ឧប្បាទិតោ វីសតិមាសប្បមាណោ ឧត្តមសុវណ្ណក្ខន្ធកោ លក្ខណសម្បន្នោ នីលកហាបណោតិ វេទិតព្វោ ។ រុទ្រទាមេន ឧប្បាទិតោ រុទ្រទាមកោ ។ សោ ហិ នីលកហាបណស្ស តិភាគំ អគ្ឃតិ យស្មិំ បន បទេសេ នីលកហាបណា ន សន្តិ តត្ថាបិ ការទៀកាវហិតស្ស ធិទ្ធុសុវណ្ណស្ស បញ្ចមាសគ្ឃនកេន ភណ្ឌេន ថានបរិច្ឆេទោ កាតព្វោ ដូច្នេះ ។ បើនឹងគិតបាទតាមវិមតិវិនោទនីនេះ គប្បីដឹងមាត្រាជាមុនសិន មាត្រាស្យាមក៏មានច្រើនប្រការមិនត្រូវគ្នា នឹងអាស្រ័យមាត្រាក្នុងគម្ពីរអភិធានប្បទីបិកា គាំងជាមាត្រាស្យាមទុកដូច្នេះ ១ ហ្វឿង ជា ៤ ពៃ ។ ១ ពៃជា ២ ចិបគឺ២មាសក ។ ១ ចិប ជា ២ចិប គឺពីរកញ្ជា ។ ១ ចិបទម្ងន់៤ គ្រាប់ស្រូវ ដូច្នេះ ។ មាត្រានេះមិនខុសពេកអំពីមាត្រាចិន តែមាត្រាចិននោះល្អិតពេកណាស់ មាស ១ ចិបជាថ្លៃប្រាក់ ១៦ ចិប ហៅថា ១៦ ទម្ងន់ ។ មាសដេញហើយច្រាសចាកទោស ឧត្តមល្អ ៥ ចិប ១៦ ទម្ងន់ ជាប្រាក់ ៥ ស្លឹងក្នុងស្យាមប្រទេស ជា ១ បាទក្នុងអទិន្នាទានសិក្ខាបទ តាមវិមតិវិនោទនី ។ តែក្នុងដីកានៃឧត្តរវិនិច្ឆ័យ ប្រាប់តម្រាធ្វើនីលកហាបណៈ នឹងប្រមាណថ្លៃបាទទុកដូច្នេះថា កហាបណៈដែលលាយគ្នានោះឯង ឈ្មោះថានីលកហាបណៈ ឬតថា លក្ខណៈត្រូវតាមតម្រាបស់រមែង

www.budinst.gov.kh www.elibraryofcambodia.org

ប្រាកដទៅក្នុងនីលកហាបណៈនោះពិត ឲ្យយកមាស ៥ មាសក ប្រាក់ ៥ មាសក ទង់ដែង ១០ មាសក ជា ២០ មាសកផងគ្នា មកផ្សំគ្នាជាមួយលោហៈគឺដែកប៉ុនគ្រាប់ស្រូវ ១ ផង ដើម្បីនឹងបញ្ចុះសាច់ យកដាក់ចុះក្នុងផាវរំលាយ ធ្វើជារូបបោះត្រាអក្សរ នឹងរូបដើមដំរីជាដើមណាមួយ ដូច្នេះឯងឈ្មោះថានីលកហាបណៈ ព្រោះជារបស់មិនមានទោស ។ ក្នុងប្រទេសណាមិនមាននីលកហាបណៈ ក្នុងប្រទេសនោះ ឲ្យយកមាសទម្ងន់ ២០ គ្រាប់ស្រូវ ជាដំឡៃ ១ បាទ ។ កិច្ចលួចរបស់ដំឡៃស្មើនឹងដំឡៃមាសទម្ងន់ ២០ គ្រាប់ស្រូវ ត្រូវបារាជិក ។ ពាក្យនេះអាចារ្យឈ្មោះវាចិស្សរ លោកពោលទុក ព្រោះដីកាបាឋៈថា៖ មិស្សកា កហាបណាយេវ នីលកហាបណោ នត្ថេវ ហិ ភោគណសន្តាវិហិតលក្ខណំ និស្សិតំ បញ្ចមាសា សុវណ្ណស្ស តថា រជតស្ស ទស មាសា តម្ពស្សាតំ ឯតេ វីសតិមាសេ មិស្សេត្វា ពន្ធិត្វាយ វីហិមត្តំ លោហំ បក្ខិបិត្វា អក្ខរានំ ច ហត្ថិចាទាទីនមញ្ញតរញ្ច រូបំ ឧស្សេត្វា កតោ និទ្ទោសត្តា នីលកហាបណោ នាម ហោតិ ។ ហោន្តិ ចេត្ថ ។

ហេមរជតតម្ពេហិ សត្តេ និទ្ទិដ្ឋលក្ខណំ
អហាបេត្វា កតោ វីស មាសោ នីលកហាបណោ
ហេមចានំ សជ្ឈុចានំ តម្ពចានឧទ្ទយំ ហិ សោ

មំសេស្សត្វា រូបមេត្វា    កាតុំ សរត្ថេសុ ធស្សិតោ ។
ឯសោភាតិ វុច្ចតេ បោសោ    ធំន្លោសត្តា តជេរិតោ
តស្ស ធាតោ សុវណ្ណស្ស    វីសវីហគ្ឃុតាមតោ ។
យស្មឹ បជ បមេសេ សោ    ជ វត្តតិ កហាបណោ
វីសវសោវណ្ណាវីហគ្ឃំ    តប្បាធគ្ឃត្តិ វេធិយំ ។
វីសវសោវណ្ណាវីហគ្ឃំ    ថេរេត្តា កិត្តកេ តតោ
ចវត្តិ សភាមញ្ញាតុណា    ឥច្ចាហុ វិនយញ្ញុនោតិ ។
ភិចិស្សរបាមកោ ចរំយេជ វុត្តំ ជួរបុះ ។

មាសទម្ងន់ ២០ គ្រាប់ស្រូវ ជា ៤ បាទ គិត ១៦ ទម្ងន់ ត្រូវជា ប្រាក់ ២ ស្លឹង ១ ហ៊ុន ក្នុងប្រទេសស្យាមនេះ ជា ១ បាទ ក្នុង អដ្ឋកថាទាងសិក្ខាបទ តាមទំនុកវិនិច្ឆ័យដីកា ។

តំឯរបស់ក្នុងស្យាមប្រទេសនេះដាំថ្លៃតម្លៃមិនទាន់ ដូចកាលលក់ ១៦ ទម្ងន់ខ្លះ ១៧ ទម្ងន់ខ្លះ ដូចកាលលក់ ១៨ ទម្ងន់ខ្លះ ៩ ទម្ងន់ខ្លះ ដែល គិតមកតែ ១៦ ទម្ងន់នេះ ដើម្បីនឹងឲ្យសមគ្នា នឹងនិលកហាបណៈ ដែល លោកប្រាប់តម្រាទុកនោះ ។ តំឯនិលកហាបណៈនោះ តីវនឹងហ៊ុ ជាន ២ នាក់បានធ្វើតាមតម្រានោះ ២ ដង ជាន់ម្នាក់ធ្វើបានជាសាច់ទន់ហ៊ុ ទម្ងន់ ៥ ស្លឹងថយចុះ ១ បាទ ទាត ២ ថៃទីទ ១ បាទ សាច់គំទន់តាម ជាន់ម្នាក់ធ្វើ បានទម្ងន់ ១ ស្លឹង ២ ថៃ តទំនៅតាមទម្ងន់ដើម ទាកតែដែក សាច់តឹង ល្អ ជាន់មាសក្នុងស្យាមប្រទេសនេះ។ ពយដថ្លៃទន់ហ៊ុនោះផ្សេង ១ គ្នា ពយដំថ្លៃ ៦ ទម្ងន់ខ្លះ ៧ ទម្ងន់ខ្លះ ១០ ទម្ងន់ខ្លះ ។

www.budinst.gov.kh www.elibraryofcambodia.org

ក៏ប៉ុន្តែក្នុងគម្ពីរសំឡាបកាសកៈ ទាំងគម្ពីរវិនយសារៈច្រាក់តម្រោធ្វើក៏ដូចគ្នា តែមិនលាយដែក ចំណែកគម្ពីរវិនយសារៈក់យដំឡៃទុកថា ៧ ខម្ទ ខម្ទជាប្រាក់ ២ ស្លឹង ១ តៃ ទាំង ១ ចិប ជា ១ បាទ ៗ ថាបើ ៨ ខម្ទ បានជាប្រាក់ ២ ស្លឹង ១ ហ្វឿង ជាបាទក្នុងអទិន្នាទានសិក្ខាបទ ៗ ថាបើ ១០ ខម្ទក៏លើសថ្លៃទង់ហ៊ុយ ហាំងល្អក្នុងស្យាមប្រទេសនេះទៅ ដ្បិតថា ទង់ហ៊ុយ ហាំងល្អក្នុងស្យាមប្រទេសនោះក៏ត្រឹមតែ ៩ ខម្ទ បើកំយដំឡៃ ៩ ខម្ទ ក៏លើសលាប់ទង់ហ៊ុយនោះទៅ ថាបើកំយដំឡៃត្រឹមតែ ៨ ខម្ទ ឃើញថាសមគួរ ដ្បិតថាតម្រាក្នុងដីកានោះ ពោលថែកធងចេញលាប់ល្អឡើង ក់យដំឡៃ ៨ ខម្ទ ទើបត្រូវល្អ សមគួរនឹងដំឡៃមាសខម្ទ ២០ គ្រាប់ស្រូវធំ ព្រោះឃើញថា ក្នុងកាលនៃដីកានោះ គេនឹងកប់អានទង់ហ៊ុយ ដែលជាខ័លកហាបណៈនោះ ពាងដំឡៃច្រើនជាងប្រាក់ ៨ ខម្ទ ថយជាងមាស ៨ ខម្ទ ព្រោះហេតុនោះ គួរគិតមាស ១៦ ខម្ទ ទង់ហ៊ុយ ៨ ខម្ទ ដូចបានគិតមកហើយនេះ តែក្នុងដីកានៃគម្ពីរវៃតរណី ពោលថាភាគតំរប់ ២០ នៃបុកណកហាបណៈ ឈ្មោះថាមាសក មាសកនោះហៅថាមញ្ជដ្ឋក៏បាន ដោយដីកាបុាប់ថា មាសកោ ចោកណកស្ស កហាបណស្ស វីសតិមោ ភាគោ យោ លោកេ មញ្ជដ្ឋិកាតិ វុច្ចតិ ដូច្នេះ ។ អ្នកស្រុកលង្កាម្នាក់ប្រាប់ថា មញ្ជដ្ឋ នោះ ជាប្រាក់ ១ ហ្វឿងក្នុងស្យាមប្រទេស បើគិតតាមន័យនេះ ២ ស្លឹង ១ ហ្វឿងប្រាក់សៀម (ថៃ) ត្រូវជា ១ បាទក្នុងអទិន្នាទានសិក្ខាបទនេះ ៗ បានព្ញថា ក្នុងប្រទេសកម្ពុជា

www.budinst.gov.kh www.elibraryofcambodia.org

ត្រូវនុះជាមាសក ១ ជាប្រាក់ ១ ស្លឹង ៗ ៥ មាសកជាប្រាក់ ៥ ស្លឹង ៗ ពោលតាមវិមតិវិនោទនី នឹងត្រូវមា ៥ ស្លឹងជា ១ បាទ ៗ ពោលតាមដីកាវិនយត្ថវិនិច្ឆ័យ នឹងពាក្យដែលអ្នកស្រុកលង្កាម្នាក់ពោលថា មញ្ជេដ្ឋី ជាហ្វៀននេះ ២ ស្លឹង ១ ហ្វៀន ជា ១ បាទ ៗ តាមគម្ពីរវិនយសារៈ ២ ស្លឹងនឹង ១ ពែ ១ ចិបជា ១ បាទ ៗ បាទក្នុងអទិន្នាទានសិក្ខាបទ គិតតាមវាទៈវិនយាចារ្យផ្សេងៗគ្នាដូច្នេះ ឲ្យអ្នកប្រាជ្ញដែលមានបញ្ញាពិចារណាតាមគម្ពីរនោះៗ នឹងសាកសួរមើលក្នុងប្រទេសផ្សេងៗ គប្បីកាន់យកតែត្រឹមត្រូវតាមគួរចុះ ។ (លោកអ្នកតែងគិតដំរៀលមាសនឹងទម្ងន់ហ្វាដូច្នេះ តាមដំរៀលដែលប្រើទិញដូរគ្នាក្នុងវេលាដែលតែងសៀវភៅនេះ) សេចក្តីដំនុំអំពីដំរៀលបាទក្នុងអទិន្នាទានសិក្ខាបទ ដែលភិក្ខុលួចទ្រព្យអ្នកដទៃដំរៀលអំពីមួយបាទឡើងទៅត្រូវបារាជិក ៗ ឯដំរៀលមួយបាទក្នុងអទិន្នាទាន គឺ ៥ មាសក ជាមួយបាទនោះក្នុងស្រុកប្រទេសបានវិនិច្ឆ័យថា ៥ មាសកនោះ គឺ ២ ស្លឹង ១ ហ្វៀន ត្រូវជា ១ បាទក្នុងអទិន្នាទាន ។ ក៏ក្នុងសម័យដែលព្រះសង្ឃថេរានុថេរ នឹងយកក់ សហានានុសក្តិ ទាំងពួកដែលបានជួបជុំជាសង្គីតិកាផ្ទៀងផ្ទាត់សិក្ខាវណ្ណនាក្នុងកម្ពុជប្រទេសនេះ យល់ឃើញព្រមគ្នាថា ប្រាក់រូបដំរីជាប្រាក់ក្នុងរាជសម្តេចព្រះហោមកៅ ដែលទ្រង់រៀបរយផ្ទៀងផ្ទាត់ព្រះវិន័យតាំងគណៈធម្មយុត្តិកក្នុងស្រុកប្រទេស ដែលកំណត់ថា ២ ស្លឹង ១ ហ្វៀន ជា ១ បាទនោះ យើងត្រូវយកប្រាក់រូបដំរីនោះជាសម្រេច ៖ យើងបានយកប្រាក់រូបដំរីនោះមកថ្លឹងធៀបនឹងប្រាក់ ១០ សេនបារាំងសែស ត្រូវជា

www.budinst.gov.kh www.elibraryofcambodia.org

ប្រាក់ ៤០ សេន គឺជា ១ បាទ ក្នុងអចិន្ត្រាតាមសិក្ខាបទ កំណត់ក្នុងកម្ពុជប្រទេស ដែលប្រើក្នុងសម័យនេះ ។

បាទកថា ចប់

---

# ប្រមាណបាត្រនិងបលៈ

ពណ៌នាអំពីប្រមាណបាត្រ និងបលៈ តទៅ ។ បាត្រមាន ២ គឺបាត្រដែក ១ បាត្រដី ១ ។ បាត្រទាំង ២ នេះ ប្រកបដោយប្រមាណ ទើបគួរអធិដ្ឋាននិងវិកប្ប ។ ប្រមាណនៃបាត្រមាន ៣ គឺ ឧក្កដ្ឋោ បាត្រខ្នាតធំ ១ មជ្ឈិមោ បាត្រខ្នាតកណ្ដាល ១ ឱមកោ បាត្រខ្នាតតូច ១ ។ បាត្រខ្នាតធំនោះ ចុះបាយនៃអង្ករកន្លះអាឡ្ហកៈ និងចុះខាទនីយៈ ស្មើនឹងភាគតំរប់ ៤ នៃបាយ និងព្យញ្ជនៈអន្លក់ (ម្ហូប) ល្មមសមគួរដល់បាយនោះ ។ បាត្រខ្នាតកណ្ដាលចុះបាយនៃអង្ករ ១ នាឡិ បាត្រខ្នាតតូចចុះបាយនៃអង្ករ ១ បត្ថៈ ទាំង ២ នេះក៏ចុះខាទនីយៈនិងព្យញ្ជនៈដូចពោលមកហើយអំពីមុន ព្រោះបាលីថា ឧក្កដ្ឋោ នាម បត្តោ អឌ្ឍាឡ្ហកោទនំ គណ្ហាតិ ។ល។ មជ្ឈិមោ នាម បត្តោ នាឡិកោទនំ គណ្ហាតិ ។ល។ ឱមកោ នាម បត្តោ បត្ថោទនំ គណ្ហាតិ ចតុភាគំ ខាទនីយំ តទុបិយញ្ច ព្យញ្ជនំ ដូច្នេះ ។

www.budinst.gov.kh www.elibraryofcambodia.org

គន្ធះអាទ្យក្ខរៈនោះ គឺអក្សរ ៤ ខាងមុខគណៈ គម្ពីរអនុគណ្ឋិកថាពោល ថា ឈ្មោះថាខាងមុខគណៈនោះ ១៤ ហលៈគន្ធៈ ១ គម្ពីរមហាអដ្ឋកថា ពោលថា បក្ខាតិជាទ្យ ខាងដោយប្រក្រតី គម្ពីរសីហឡទីបក៏ធំទៅ ធម្មិឡជាទ្យ ខាងទំងល់ៈក៏គួរទៅ មគធជាទ្យ ខាងមុខគណៈ ទើបប្រកបដោយប្រមាណ ១ ខាងគន្ធៈ នៃខាងមុខគណៈ ជាទាំង សីហឡទីប ១ ព្រោះអដ្ឋកថាចាប់ៈថា អន្ធ្យាធម្យកោទធំ តណ្ហាតីតិ មគធជាទ្យយោ ចុំធ្នំ តណ្ហលជាទ្យធំ ទិធធំ តណ្ហាតំ ។ មគធជាទ្យ ជាម អន្ធ្យកោសបណា បោតីតិ អដ្ឋក- ដ្ឋកថាយំ វុត្តំ ។ សីហឡធីបេ បក្ខាតិជាទ្យ បហព្ហា, ធម្មិឡជាទ្យ ខុទ្ទកា, មគធជាទ្យ បមាណយុត្តា, តាបេ មគធជាទ្យយោ ធិយន្ធ្យជាទ្យ ឯកា សីហឡជាទ្យ បោតីតិ មហាអដ្ឋកថាយំ វុត្តំ ។

ពណ៌នាអំពីហលៈជាមុខ មាគ្រាគម្ពីរគម្ពីរអភិធានប្បទីបិកាថាដូច្នេះ

ចក្កាកេ វិហាយោ កន្ទុញ្ញា ធេ. កន្ទុញ្ញា មាសកោ កបេ
ទ្វេ អក្ខា មាសកា បញ្ច- ក្ខាធំ ធរណមដ្ឋកំ
សុវណ្ណា បញ្ចធរណំ ធំក្ខុធ្ធំធិក្ខំ បញ្ច តេ
ទាលោ កាកេ ចតុទ្ទស ធរណានិ បលំ ធស
តុលា បលសតំ ខារ កាកេ វីសតិ តា តុលា
អឌ្ឍោ កាបោបណោ ធំតំ កាថ្យកេ កាវីសាបណោ ។

ដោយអធិប្បាយតាមដីកាជា ៤ ន័យ ន័យមុខថាខមួន ៤ គ្រាប់ស្រូវជា

កុញ្ជា ៗ ២ កុញ្ជាជាមាសក ៗ ២ មាសក ជាអង្គុះ ៗ ៤ អង្គុះ ជាធរណៈ ៗ ៨ ធរណៈជាសុវណ្ណ ៤ ធរណៈ ជានិក្ខៈ ៗ ៤ និក្ខៈជា ១ បាទ ៗ បាទនោះប្រព្រឹត្តទៅក្នុងចំណែកទី ៤ ៗ ន័យនេះជាមតិនៃអាចារ្យចំពួកខ្លះ ៗ ន័យ ១ ទៀត ៤ គ្រាប់ស្រូវជាកុញ្ជា ៗ ២ កុញ្ជាជាមាសក ៗ ១០ មាសក ជាអង្គុះ ៗ ៨ អង្គុះជាធរណៈ ៗ ៤ ធរណៈ ជាសុ-វណ្ណៈ ៗ ៤ សុវណ្ណៈ ជានិក្ខៈ ន័យដូច្នេះជាមតិនៃយើងទាំងឡាយ ៗ បាទមួយប្រព្រឹត្តទៅក្នុងភាគគំរប់ ៤ នៃវត្ថុណាមួយ គឺថាវត្ថុទាំងពួងនោះបែងចេញទៅជា ៤ ភាគ ដូចសត្វចតុបាទ ភាគគំរប់ ៤ ឈ្មោះថាបាទ ៗ ១០ ធរណៈ ជាបលៈ ៗ ១០០ បលៈ ជាតុលា ៗ ២០ តុលាជាភារៈ ៗ កហាបណៈ និងកំសាបណៈ ស័ព្ទទាំង ២ នេះ ជាឈ្មោះនៃវត្ថុតែមួយ កំរិសៈប្រែថារបស់សំរាប់ចាយវិញ-ដូរ ដែលគេធ្វើប៉ុនផ្លែកំរិសៈ ផ្លែកំរិសៈនោះថា ប៉ុនកូនស្កា ៗ គិតតាមន័យមុន ១ បលៈ ជាប្រាក់ទម្ងន់ ១ បាទ ២ ស្លឹង ២ ពៃ ៗ ១២ បលៈកន្លះ ទម្ងន់ ៤ ដំឡឹង ៣ បាទ ២ ស្លឹង ១ ពៃជាទម្ងន់មគធនាឡិ ១ នាឡិមគធៈ ៗ គិតតាមន័យខាងក្រោយ ១ បលៈ ទម្ងន់ ៣ ដំឡឹង ២ ស្លឹង ៗ ១២ បលៈកន្លះនោះ ជាប្រាក់ ១ ជញ្ជីង ១៩ ដំឡឹង និង ១ ស្លឹង ជាទម្ងន់មគធនាឡិ ១ នាឡិមគធៈ ៗ តែគម្ពីរសំឡាបកាសកៈ ថា ៤ គ្រាប់ស្រូវ ជា ១ ចិច ៗ ២ ចិច ជា ១ ចិច ៗ ៤ ចិច ជា ២ អង្គុះ ៗ ៨ អង្គុះ ជាធរណៈ ៗ ១០ ធរណៈ ជាបលៈ ព្រោះបាឋៈថា ។

មាសកោ វីហយោ អដ្ឋ   អក្ខំ ភ វីហិវីសតិ

ថាមាសក ១ ជា ៨ គ្រាប់ស្រូវ អក្ខ: ១ ជា ២០ គ្រាប់ស្រូវដូច្នេះ ។ តិតតាមន័យនេះ ១ បល: ទម្ងន់ ៣ បាទ ១ ហ្វឿន ។ ១៦ បល:កន្លះ ទម្ងន់ ៩ ដំឡឹង ៣ បាទ ខឹង ២ កៃ ជាទម្ងន់មគធនាឡិ ១ នាឡិមគធ: ។ សម្រាប់សិលាដែលជានិមិត្តនៃសីមា ដែលលោកធ្វើយ៉ាងតូចទំហំធំប៉ុនដុំស្ករអំពៅ ទម្ងន់ ៣២ បល: គឺគួរតិតដោយបល:នេះ តែបើជាអ្នកប្រាជ្ញរង្កៀសថាតូចពេកណាស់ មើលទៅមិនល្អ តាមន័យនៃដីកាប្រាប់ទុកថា ឲ្យយកទឹកឬសណ្តែកសថ្លឹង ឲ្យបានទម្ងន់ដូចពោលមកនេះបញ្ចុះពេញក្នុងនាឡិណា នាឡិនោះឈ្មោះថាមគធនាឡិ ជា ១ នាឡិមគធ: ។ បល: មានផ្សេង ៗ គ្នាដូច្នេះ អ្នកប្រាជ្ញដែលមានបញ្ញាគប្បីពិចារណាផ្សៀងផ្ទាត់យកចុះ ។

គ្រានេះនឹងពណ៌នាមគធនាឡិតាមដីកាទៀត ក្នុងសារត្ថទីបនី· ដីកាពោលថា ៦ បសត: គឺ ៦ ចូកដៃ ឈ្មោះថាមគធនាឡិ ជា ១ នាឡិ. មគធ: ។ អាចារ្យដទៃឯទៀតពោលថា ៨ ចូកដៃ ឈ្មោះថាមគធនាឡិ ជា ១ នាឡិមគធ: ។ ពោលតាមអធិប្បាយនៃអាចារ្យមុន · ៣ ចូកដៃជានាឡិ គឺ ១ នាឡិ ។ ២ នាឡិនោះជាមគធនាឡិ គឺ ១ នាឡិមគធ: ។ ពោលតាមអធិប្បាយនៃអាចារ្យខាងក្រោយ ៤ ចូកដៃជា ១ នាឡិ ។ នាឡិនោះ ជាមគធនាឡិ គឺ ១ នាឡិមគធ: ។ តែព្រះអាចារ្យធម្មបាលត្ថេរ លោកពោលទុកថា អាចារ្យទាំងឡាយ លោកពោលដូច្នេះ ៤ មុដ្ឋិក:

www.budinst.gov.kh www.elibraryofcambodia.org

គឺ ៤ ក្តាប់ដោយប្រក្រតី ជាកុឌវៈ គឺ ១ ខ្ទូកដៃ ។ ៤ ខ្ទូកដៃជានាឡិ គឺ ១ នាឡិ ។ ១៦ នាឡិនោះជា ១ ទោណៈ ។ កំឯទោណៈ នោះជា ១២ មគធនាឡិ ព្រោះហេតុនោះ គប្បីដឹងដោយន័យដូច្នេះ ១ នាឡិមគធៈ នោះ ចុះ ៥ ខ្ទូកដៃ និង ១ ក្តាប់ និង ១ ក្តាប់ទៀត បែងចែកជា ៣ ភាគ យកតែភាគតំបែ ៣ ដូច្នេះចុះ ព្រោះដីកាបាឋៈថា ៖

មគធនាឡិ នាម ឧ បសតា នាឡិតំ ហោតិ, អឌ្ឍ បស. តាតំ អបរេ ។ តត្ថ បុរិមាទំ មគេធ តំបសតាយ នាឡិ-យា ទ្វេ នាឡិយោ ឯកា មគធនាឡិ ហោតិ, បច្ឆិមាទំ មគេធ ចតុបសតាយ នាឡិយា ទ្វេ នាឡិយោ ឯកា មគធនាឡិ ។ អាចរិយធម្មបាលត្ថេរេន បន បតតំយា ចតុមុដ្ឋិកា កុឌុវំ, ចតុកុឌុវំ នាឡិ. តាយ នាឡិយា សោឡសនាឡិយោ ទោណំ, តំ បន មគធនាឡិយា ទ្វាទសនាឡិយោ ហោន្តីតិ វទន្តីតិ វុត្តំ; តស្មា តេន នយេន មគធនាឡិ នាម បញ្ច កុឌុវានិ ឯកញ្ច មុដ្ឋឹ ឯកាយ មុដ្ឋិយា តតិយញ្ច ភាគំ គណ្ហាតីតិ វេទិតព្វំ ដូច្នេះ ។

ក្នុងវិមតិវិនោទនីដីកាពោលថា អាចារ្យទាំងឡាយលោកពោលថា នាឡិបូរាណនៃទមិឡៈនោះ ៨ កុឌុវៈ គឺ ៨ ខ្ទូកដៃ មុដ្ឋិកៈ គឺក្តាប់ ៤ ក្តាប់ ជា ១ ខ្ទូកដៃ ១ នាឡិមគធៈ ចុះ ២ នាឡិទមិឡៈនោះ គឺឯ នាឡិបូរាណ នៃអ្នកស្រុកសីហឡៈ ចុះ ៣ នាឡិទមិឡៈនោះ ពោល

www.budinst.gov.kh www.elibraryofcambodia.org

តាមអធិប្បាយនៃអាចារ្យទាំងឡាយនោះ ៗ ១ នាឡិមគធៈជា ៤ នាឡិទមិឡៈ សព្វថ្ងៃនេះ ដែលចំណុះ ៤ ខ្ទុកដៃនោះ ៗ ក៏ឯកន្លះនាឡិមគធៈនោះឈ្មោះថា បត្តៈ ដែលគេហៅថា បុរាណធមិឡនាឡិ ជានាឡិទមិឡៈចាស់ ៗ ក៏ឯពាក្យបាលី ជាបាត្រខ្នាតតូចចុះបាយនៃអឌ្ឍកៈ ១ បត្តៈនោះក៏សមដូចពាក្យនៃអាចារ្យទាំងឡាយ ព្រោះថាសូម្បីលោកទាំងឡាយក៏កំណត់បត្តៈទុកជា ២ គឺលោកិកបត្តៈ និងមាគធបត្តៈ ៗ លោកិកបត្តៈនោះ ១៦ បលៈ មាគធបត្តៈគុណ ២ ភាគ គឺជា ៣២ បលៈ ដូច្នេះសំដែងថា នាឡិមគធៈគុណ ២ ភាគដោយនាឡិលោកដូច្នេះ កាលបើកាន់យកដូច្នេះ សេចក្ដីដែលពោលថា បាត្រខ្នាតតូច ចុះបាយល្មមយាបនមត្ត ក៏ជាការសម្រេចប្រាកដបាន ព្បិតថាមិនអាចយកបាត្រដែលចុះបាយនៃអឌ្ឍកៈ ៨ ខ្ទុកដៃ ចរទៅស្វែងរកបិណ្ឌបាត ធ្វើមិនឲ្យជាក់ពូលមកចិញ្ចឹមជីវិតបាន ព្រោះហេតុនោះ គណ្ឋិអដ្ឋកថានៃវេរញ្ជកណ្ឌ ទើបពោលថាដែលហៅថា ១ បត្តៈនោះ ប្រមាណនាឡិ គឺ ១ នាឡិ ល្មមចិញ្ចឹមជីវិតនៃបុរស ១ នាក់បាន ពាក្យនោះសមដូចពាក្យពោលថា បាយនៃអឌ្ឍកៈ ១ បត្តៈ មិនល្មមដល់មនុស្ស ២ នាក់ ពាក្យថាល្មមមនុស្ស ១ នាក់ ២ នាក់ ៣ នាក់ ក៏មានមកដូច្នេះ អ្នកប្រាជ្ញគប្បីរលឹកតាមន័យដែលលោកពោលហើយ គណ្ឋិអដ្ឋកថាវេរញ្ជកណ្ឌនេះចុះ ដោយដីកាបាឋៈថា ធមិឡនាឡីតិ បុរាណនាឡី សន្ធាយ វុត្តំ ។ សា ច ចតុមុដ្ឋិកោ ហោតិ កុឌុពោ ហោតិ អដ្ឋ កុឌុពា,

www.budinst.gov.kh www.elibraryofcambodia.org

តាយ ជាឝ្យា ទេ្វ ឆាឝ្យោ មគធជាឝ្យ គណ្ហាតិ, បុកណា បន ស័ហាឝ្យជាឝ្យ តំស្សោ ជាឝ្យោ គណ្ហាតីតំ វុធត្តិ ។ តេសម្មតេធ មគធជាឝ្យ ឥធាធំ បវត្តមាជាយ ចតុក្កុឌ្ឍាយ ធម៌ឝ្យជាឝ្យា ចតុ-ជាឝ្យ៍កា ហោតិ, តតោ មគធជាឝ្យ៍តោ ឧបស្ស្រុញ្ញ បុរាណធម៌ឝ្យជាឝ្យ៍សំទាតំ បត្តំ ជាម ហោតិ, ឯតេន ច ឧ៎បកោ ជាម បត្តោ បត្តោធធំ គណ្ហាតីតិ ចាឝ្យ៍វចនញ្ញ សមេតិ. លោកិយកោហាំបំ លោកិតំ មាគធញ្ញេតិ បត្តុទ្ធយំ សមុជាបាជំ; លោកិតំ សោឝ្យសបលំ, មាគធំ ទ្វំកុណំ មគត្តំ ឯវំ លោកិយជាឝ្យា មគធ-ជាឝ្យ ធំកុណាតំ ឧស្សិតា; ឯវញ្ញ គយ្ហមាធេ ឧ៎ម-កាបត្តស្ស យាបឧមត្តោធឧកាហំតា សំទ្ធា ហោតិ; ន ហំ សក្កា អឌ្ឍកុឌ្ឍកោធឧកាហំជា បត្តេន អដ្ឋបំកាតំ បំណ្ឌាចាតំ បរិយេសំត្វា យាបេតុំ; តេនេវ វេរញ្ញកណ្ឌដ្ឋកជាយំ បត្តោ ជាម ជាឝ្យ៍មត្តំ ហោតិ, ឯកស្ស បុរិសស្ស អលំ យាបជាយ; វុត្តម្ស៍ ហោតំ បត្តោឌធោ ជាលមយំ ទ្វំឌ្ធត្តិ វុត្តំ; ឯកស្ស ទ្វំឌ្ធំ តំណ្ណាម្ស៍ ហោតីតិ ច អាគតំ; តស្មា ឥធ វុត្តនយាឧសារេន គហេតព្វំ ផ្លូវប្រះ ។

ក្នុងអដ្ឋកថាពោលថា បាត្រឆ្នាំងកណ្តាលចុះបាយនៃអង្ករ ១ នាឡិមគធៈ បាត្រឆ្នាំងតូចចុះបាយនៃអង្ករកន្លះនាឡិមគធៈ ដោយអដ្ឋកថាបាឋៈថា នាឡិកោទនគ្គំ មគធនាឡិយា ឯកាយ តណ្ឌុលនាឡិយា ឱទនំ ។ បត្ថោទនគ្គំ មគធនាឡិយា ឧបឌ្ឍនាឡិកោទនំ ដូច្នេះ ។

ក្នុងសារត្ថទីបនីដីកាពោលថា ព្រះសង្គីតិកាចារ្យយើញថា ប្រមាណកន្លះនាឡិមគធៈ ជាបត្ថៈមួយក្នុងបទនេះ ព្រោះពាក្យអដ្ឋកថាថាបាត្រឆ្នាំងតូចចុះបាយនៃអង្ករកន្លះនាឡិមគធៈនេះ សំដែងថា ៤ បត្ថៈជា ១ នាឡិមគធ គឺឯបត្ថៈនោះ គប្បីដឹងដោយលោកវោហារដូច្នេះថា ៤ បលៈ ជាកុឌវៈ គឺ ១ ខ្ទូកដៃ ។ ៤ ខ្ទូកដៃជា ១ បត្ថៈដូច្នេះ ដោយដីកាបាឋៈថា មគធនាឡិយា ឧបឌ្ឍប្បមាណោ ឥធ បត្ថោតិ អាហ បត្ថោទនគ្គំ មគធនាឡិយា ឧបឌ្ឍនាឡិកោទនគ្គំ ។ ឥមិនា ច បត្ថទ្វយំ មគធនាឡីតិ ទស្សិតំ ហោតិ ។ បត្ថោ ច ចតុបលោ កុឌវោ ចតុកុឌវោ បត្ថោតិ ឥមិនា លោកិយវោហារេន វេទិតព្វោ ដូច្នេះ ។

ត្រានេះនឹងពណ៌នា មាត្រាសំរាប់វាល់ ដើម្បីនឹងឲ្យស្គាល់ឈ្មោះក្នុងលំដាប់នៃគ្រឿងវាល់ តាមគម្ពីរអភិធានប្បទីបិកាថា ៖

កុឌវោ បសតោ ឯកោ បត្ថោ តេ ចតុរោ សិយុំ
អាឡ្ហកោ ចតុរោ បត្ថា ទោណំ វា ចតុរាឡ្ហកំ ។

www.budinst.gov.kh www.elibraryofcambodia.org

មាណិកា ចតុរោ ទោណា   ខារិក្តី ចតុមាណិកំ
ខារិយោ វីស វាហោ ច   សិយា តុម្ពោ ទសម្ពណំ ។
អាឡ្ហកោ ចតុត្ថយំ តុម្ពោ   បត្ថោ តុ ឆាឡ្ហិ ឆារិយំ
វាហោ សកដោ ចេកោ   ទស ទោណា តុ អម្ពណំ ។

ដូច្នេះ ។

ជា ១ ខូកដៃ ជា ១ កុឌវៈ, ៤ កុឌវៈ ជាបត្ថៈ, ៤ បត្ថៈ ជាអាឡ្ហកៈ, ៤ អាឡ្ហកៈជាទោណៈ, ៤ ទោណៈ ជាមាណិកា, ៤ មាណិកា ជាខារី, ២០ ខារី ជាវាហៈ, ១០ អម្ពណៈ ជាតុម្ពៈ, ១ អម្ពណៈ ជា ១០ ទោណៈ អាឡ្ហកៈនិងតុម្ពៈ សព្ទ ២ នេះជាឈ្មោះជាមួយគ្នា បត្ថៈនិងនាឡិ សព្ទ ២ នេះជាឈ្មោះជាមួយគ្នា ។ វាហៈនិងសកដៈ សព្ទ ២ នេះជាឈ្មោះជាមួយគ្នាប្រែថា ទេះ ។ កាលបើពោលតាមលំដាប់ដូច្នេះ មើលទៅដូចជាមិនត្រូវនឹងព្រះបាលីប្រមាណបាត្រ ។ ប្រមាណបាត្រក្នុងបត្ថៈនោះ ម្យ៉ាង នាឡិនោះម្យ៉ាងដូច្នេះ អឌ្ឍាឡ្ហកោទនំ ឆាឡ្ហិកោទនំ បត្ថោទនំ ដូចប្រែមកហើយក្នុងមុននោះ ។

ក្នុងគម្ពីរសំឡាបកាសកៈពោលថា មួយខូកដៃ ជាកុឌវៈ ១, ម្យ៉ាងទៀត ៤ មុដ្ឋិកៈ គឺ ៤ ក្ដាប់ឈ្មោះថាកុឌវៈ ១, ៥ កុឌវៈ នោះជាមុដ្ឋិ ១ មុដ្ឋិនោះចែកជា ៣ ភាគ ភាគនំបេ ៣ ជា ១ នាឡិមគធៈ ៣ នាឡិមគធៈ ជា ១ អាឡ្ហកៈ, ៤ កុឌវៈជា ១ បត្ថៈ ។ ន័យ ១ ទៀត ៦ បសតៈ គឺ ៦ ខូកដៃ ជា ១ បត្ថៈ ។ ន័យ ១ ទៀត ១ ខូកដៃ ជា ១ បត្ថៈ ។ បត្ថៈណា

www.budinst.gov.kh www.elibraryofcambodia.org

ដែលហៅថានាឡិ នាឡិនោះជានាឡិតូច ៤ នាឡិតូចៈនោះជាអាឡ្ហកៈ ដោយបាឋៈថា ៖

កុឌវោ បសតោ ឯកោ អឋកា ចតុមុដ្ឋិកំ
បញ្ច តេ កុឌវា ឯកា មុដ្ឋិ មេកាយ មុដ្ឋិយា ។
ភាគេ ច តតិយេ មេកា ធាញ្ញមាគធិកា មតា
មាគធិកាយ ធាញ្ញយា តិធាញ្ញំ វុច្ចតាឡ្ហកោ ។
កុឌវា ចតុរោ ភាបិ បត្ថោ ធាមាគំ កក្តិតា
ជប្បសតា ឋកា បត្ថោ អឋកា បសតោ ភវេ ។
យោ បត្ថោ វុច្ចតេ ធាញ្ញំ សា ធាញ្ញំ ទុគ្ឃកា មតា
កាយ ទុគ្ឃកធាញ្ញយា ចតុធាញ្ញំ មតាឡ្ហកោ ។
ដូច្នេះ ។

បានសេចក្តីថា នាឡិមាន ៤ គឺ នាឡិខ្នាតកណ្តាលចុះ ៤ ចូកដៃម្យ៉ាង នាឡិខ្នាតធំចុះ ៦ ចូកដៃម្យ៉ាង នាឡិខ្នាតតូចចុះ ១ ចូកដៃម្យ៉ាង នាឡិមគធចុះ ១ ចូកដៃ នឹង ២ ក្តាប់ នឹង ១ ក្តាប់ទៀត បែងជា ៣ ភាគ យកតែ ២ ភាគម្យ៉ាង ដូច្នេះ ។

ក្នុងអដ្ឋកថានៃខុទ្ទសិក្ខាថា ៤ បត្ថៈមគធៈ ជាបត្ថៈក្នុងដែនកោសល ១ ។ ៤ បត្ថៈនោះ ជាអាឡ្ហកៈ ១ ដោយបាឋៈថា មាគធិកេន បត្ថេន ចត្តារោ បត្ថា កោសលរដ្ឋេ ឯកោ បត្ថោ ហោតិ តេន បត្ថេន ចត្តារោ បត្ថា អាឡ្ហកំ ដូច្នេះ ។

www.budinst.gov.kh www.elibraryofcambodia.org

ដែលពោលមកនេះ ដើម្បីនឹងឲ្យឃើញថាបក្ខៈ នាឡិ មានផ្សេងៗគ្នា រួមនាឡិមគធៈដែលពោលមកនេះ តាមសេចក្តីក្នុងអដ្ឋកថា ដ័កានឹងគម្ពីរដីសេស មាន ៨ យ៉ាង គឺចម្លូន់ ៤ ជំឡឹង ៣ បាទ ២ ស្លឹង ១ ពៃម្យ៉ាង; ចម្លូន់ ១ ជញ្ជីង ១៩ ជំឡឹង ១ ស្លឹងម្យ៉ាង; ចម្លូន់ ៩ ជំឡឹង ៣ បាទ ២ ពៃម្យ៉ាង; ២១ ក្តាប់នឹងភាគគត់រេប ៣ នៃក្តាប់ ១ ម្យ៉ាង; ២៤ ក្តាប់ម្យ៉ាង; ១២ ក្តាប់ម្យ៉ាង; ៦៤ ក្តាប់ម្យ៉ាង; ៦ ក្តាប់ នឹង ១ ក្តាប់ទៀត បែងជា ៣ ភាគ យកតែ ២ ភាគម្យ៉ាង; ជា ៨ យ៉ាងដូច្នេះ ។ នាឡិមគធៈដែលមានផ្សេងៗគ្នាដូច្នេះ អ្នកប្រាជ្ញគប្បីពិចារណា សាកសួរកាន់យកចុះ តែគួរនឹងកាន់ថា បាយនៃអង្ករ ១ បក្ខៈ ល្មមបុរសម្នាក់ស៊ីឆ្អែត, បាយនៃអង្ករ ១ នាឡិ ល្មមបុរសពីរនាក់ស៊ីឆ្អែត, បាយនៃអង្ករ ២ នាឡិល្មមបុរស ៤ នាក់ស៊ីឆ្អែត, នេះជាលក្ខណៈ សមគួរនឹងយកក្នុងអដ្ឋកថានៃវេរញ្ជកណ្ឌ អង្ករដែលកល់ដោយនាឡិចុះចម្លូន់ ៩ ជំឡឹង ៣ បាទ ២ ពៃ ល្មមបុរសម្នាក់ អង្ករ ២៤ ក្តាប់ ល្មមមនុស្ស ២ នាក់បរិភោគ ។

ប្រមាណជាគ្រឿងបលៈ ចប់

---

## អក្ខាសំខ្យា មាត្រាភស់

ពណ៌នាអំពីអក្ខាសំខ្យា មាត្រាសំរាប់ភស់ ដើម្បីឲ្យដឹងតាមគនឹងយោជន៍ជាដើម ដែលមានមកក្នុងសិក្ខាបទខ្លះ មាត្រាក្នុងគម្ពីរអភិធានប្បទីបិកាថា ។

ឆត្តឹសបរមាណូនំ- ឯកោ អណុ ច ឆត្តឹស តេ

តជ្ជារី តាបិ ឆត្តឹស រថរេណុ ឆត្តឹស តេ

លិក្ខា តា សត្ត ឩកា តា ធញ្ញមាសោបិ សត្ត តេ

សត្តង្គុលិមថុំ ទ្វិជ្ជ វិទត្ថិ តា ទុវេ សិយុំ

រតនំ តានិ សត្តេវ យដ្ឋិ តា វីសតូសភំ

គាវុតមុសភាសីតិ យោជនំ ចតុគាវុតំ

ធនុបញ្ចសតំ កោសោ ករីសំ ចតុរម្មណំ

អព្ភន្តរ ហត្ថាធ- មដ្ឋវីសប្បមាណតោ ជូវេទ្ធៈ ។

សេចក្តីថា ៣៦ បរមាណូដែលជាវិស័យនៃទិព្វចក្ខុ ជាអណូ ៣៦ អណូ ជាតជ្ជារី ៣៦ តជ្ជារី ជារថរេណូ ៣៦ រថរេណូ ជាលិក្ខា ៧ លិក្ខា ជាឩកា ៧ ឩកា ជាធញ្ញមាសៈ គឺគ្រាប់ស្រូវ ៧ ធញ្ញមាសៈ ជាអង្គុលិ គឺធ្នាប់ ១២ អង្គុលិ ជាវិទត្ថិ គឺចំអាម ២ វិទត្ថិ ជារតនៈ គឺហត្ថ ៧ រតនៈ ជាយដ្ឋិ ២០ យដ្ឋិ គឺ ១ សិន ១៥ ព្យាម ជាឧសភៈ ៨០ ឧសភៈ គឺ ១៤០ សិន ជាគាវុត ៤ គាវុតគឺ ៥៦០ សិន ជាយោជន៍ ៥០០ ធ្នូ ជាកោសៈ ៤ អម្មណៈ ជាករីស ២៨ ហត្ថ ជាអព្ភន្តរៈ ។

ក្នុងគម្ពីរសំខ្យាបកាសកៈ ថា ៤ ហត្ថជា ១ ព្យាម ២៥ ព្យាមជា ១ ឧសភៈ ៨០ ឧសភៈ គឺ ១០០ សិន ជា ១ គាវុត ៤ គាវុតគឺ ៤០០ សិន ជា ១ យោជន៍ ១២៥ ហត្ថ ជាករីស ៦៤ ករីស ជាគាវុត ៤ គាវុតគឺ ៤០០

www.budinst.gov.kh www.elibraryofcambodia.org

សិន ជាយោជន៍ ៥០០ ជួរធ្នូ គឺ ២.០០០ ហត្ថ ជាកោសៈ ៤ កោសៈ ជាគាវុត ៤ គាវុត គឺ ៤០០ សិន ជាយោជន៍ ចម្ងាយ ១០០០ ហត្ថ ជួរសំឡេងរៃស្រែកនៃគោសកកជ ជាសុរុសកៈ ៨ សុរុសកៈ ជាគាវុត ៤ គាវុត គឺ ៤០០ សិន ជាយោជន៍ ជួរកំឡាំងគោគសកកជ គឺ ១៤ ហត្ថ ជាពលុសកៈ ៨ ពលុសកៈ ជាគាវុត ៤ គាវុតគឺ ៥ សិន ១២ ព្យាម ជាយោជន៍ ១ ជួរខ្ទមគោគសកកជ គឺ ៧ ហត្ថ ជាសរីរុសកៈ ៨០ សរីរុសកៈជា ១ គាវុត ៤ គាវុត គឺ ២៨ សិន ជាយោជន៍ ១៧៥ ហត្ថ ជាករីសៈ ៦៤ ករីសៈ ជាគាវុត ៤ គាវុត គឺ ៥៦០ សិន ជាយោជន៍ ២៨ ហត្ថ ជាអក្ខតៈ ៤០០ អក្ខតៈ ជាគាវុត ៤ គាវុត គឺ ៥៦០ សិន ជាយោជន៍ ប្រមាណនេះតាមរូបនេះ គប្បីចេះប្រើ ប្រមាណយ៉ាងតូចមិនយ៉ាងទៀ ប្រើក្នុងការកាត់សំពត់ផ្តាយខ្ទីង (ផ្តក) ជួចកាត់ផ្ទៃជាដើម ប្រមាណយ៉ាងធំ យ៉ាងវែង ប្រើកាត់សំពត់ដែលខ្ពស់ឡើង-ទៅ (បញ្ឈរ) ដូចកាត់ដើមឈើនិងភ្នំជាដើម ។

ប្រមាណបាត្រ មាត្រាវាស់ ចប់

# ប្រមាណបាត្រ

សេចក្តីដំនុំ ក្នុងខាងចុងអត្ថៈដែលប្រមាណបាត្រប្រកែក ៣ យ៉ាង ឲ្យយល់ ព្រះសង្ឃថេរានុថេរៈនិងយកកាសហៈនាមុសក្តិទាំងពួង ដែល

www.budinst.gov.kh www.elibraryofcambodia.org

បានជួបជុំសង្គីតិកាផ្ទៀងផ្ទាត់សិក្ខាវណ្ណនាក្នុងកម្ពុជប្រទេសនេះ យល់ឃើញព្រមគ្នាថា បាត្របរិក្ខារខ្នាតធំដែលចុះបាយនៃអង្ករកន្លះអាឡ្ហកៈនោះ គឺអង្ករ ២ នាឡិមគធៈ ដែលថា ២ នាឡិមគធៈនោះ គិតជានាឡិដែលប្រើក្នុងកម្ពុជប្រទេសនេះ ត្រូវជា ៤ នាឡិ ៗ បាត្រខ្នាតកណ្តាលដែលចុះបាយនៃអង្ករមួយនាឡិមគធៈ គិតជានាឡិដែលប្រើក្នុងកម្ពុជ-ប្រទេសនេះ ត្រូវជា ២ នាឡិ ៗ បាត្រខ្នាតតូច ដែលចុះបាយនៃអង្ករមួយបត្ថៈគឺកន្លះនាឡិមគធៈ គិតជានាឡិដែលប្រើក្នុងកម្ពុជប្រទេសនេះ ត្រូវជា ១ នាឡិ ៗ មួយនាឡិមគធៈយើងវិនិច្ឆ័យថា ត្រូវជា ២ នាឡិប្រក្រតីនោះ ព្រោះយើងកាន់បាលីក្នុងដីកាបាឋៈថា ចោឡិយ ណាឡិយា មគធណាឡិ ទ្វិកុឌវាតិ ទស្សិតា យើងបានយកស្រូវមកថ្លឹងធៀបមើលតាមក្រាដូវខ្មែរ ទាំងជញ្ជីងចិន ទាំងជញ្ជីងបារាំងសេស ស្រូវមួយនាឡិប្រក្រតី គិតជាក្រាមបារាំងសេសត្រូវជា ៦០០ ក្រាម ២ នាឡិប្រក្រតី ត្រូវជា ១២០០ ក្រាម ៗ

ប្រមាណបាត្រ ចប់

---

# ប្រមាណសុគតវិទត្ថិ

ពណ៌នាអំពីសុគតវិទត្ថិ ចំអាមនៃព្រះសុគត ទាំងសុគតង្គុលីធ្នាប់នៃព្រះសុគត ដោយសង្ខេប ៗ សិក្ខាបទខ្លះ កំណត់ដោយចំអាម

ព្រះសុគត សិក្ខាបទខ្លះ កំណត់ដោយធ្នាប់ព្រះសុគត ។ ក្នុងអដ្ឋកថា
នៃសញ្ញាបិកកុដិសិក្ខាបទពោលថា សុគតវិទត្ថិ នាម ឥទានិ
មជ្ឈិមស្ស បុរិសស្ស តិស្សោ វិទត្ថិយោ, វឌ្ឍកីហត្ថេន
ទិយឌ្ឍោ ហត្ថោ ហោតិ ។ សេចក្តីថា ១ ចំអាមព្រះសុគតនោះ
ត្រូវជា ៣ ចំអាមមជ្ឈិមបុរសសព្វថ្ងៃនេះ ជា ១ ហត្ថ ១ ចំអាមជាងឈើ
បើនឹងពោលតាមន័យនេះ ព្រះកាយព្រះពុទ្ធអង្គ កំពស់ ១២ ហត្ថ
ជាងឈើសព្វថ្ងៃនេះ ចំអាមជាងឈើសព្វថ្ងៃនេះយក ៣ គុណ
ទើបជាចំអាមព្រះសុគត អ្នកប្រាជ្ញសព្វថ្ងៃនេះឃើញថា ព្រះពុទ្ធអង្គ
ខ្ពស់ ១២ ហត្ថនោះ មើលទៅបីដូចជាលើសប្រក្រតីមនុស្សពេកណាស់
ទើបបានជារង្កៀសថា ដែលថាយក ៣ គុណចំអាមមជ្ឈិមបុរសសព្វ
ថ្ងៃនេះ ជាចំអាមព្រះសុគតនោះ ព្រះអដ្ឋកថាចារ្យ ប្រហែលជាលោក
ភ្លាត់ទេដឹង ប្រហែលជាយក ៣ ហារទេដឹង ដ្បិតថា ពាក្យក្នុងអដ្ឋកថា
ចំពួកខ្លះថា អដ្ឋកថាដទៃពោលភ្លាត់ទៅក៏មាននៅខ្លះ ទំនងបានឃើញសំ-
ណៅពាក្យអដ្ឋកថាជាន់ចាស់ ពោលដោយកសិណថា មណ្ឌលនៃកសិណ
យ៉ាងតូច គប្បីធ្វើឲ្យមូលទទឹង ១ ចំអាម ៤ ធ្នាប់ ដូច្នេះឃើញពាក្យនេះ
ជាសំណៅ ទើបបានគិតតាមក្បួនលេខ តាំងចំអាមជាងឈើ គឺ ១២ ធ្នាប់
ចុះជា ២ ហ៊ុន ហ៊ុនក្រោមយក ៣ ហារ លទ្ធបូកហ៊ុនលើជាចំអាមព្រះ
សុគត ជា ១៦ ធ្នាប់ជាងឈើសព្វថ្ងៃនេះ ហើយទើបគិតឲ្យល្អិតទៅទៀត
ជាកាយមជ្ឈិមបុរសសព្វថ្ងៃនេះ ៧៨ ធ្នាប់ ។ ១០០ ឆ្នាំ កាយមជ្ឈិម

www.budinst.gov.kh www.elibraryofcambodia.org

បុរសថយចាបចុះ ៣ ក្បៀស តាំងអំពីព្រះពុទ្ធអង្គនិព្វានហើយមកដល់ ២៤៥៦ ព្រះវស្សានេះ គិតជារយឆ្នាំបាន ២៤ ដងកន្លះ គិតថែមទៀតទៅ ១០០ ឆ្នាំ ៣ ក្បៀស ២៤ ដងកន្លះ ត្រូវជា ១៨ ធ្នាប់ទឹង ២ ក្បៀស ២ អនុក្បៀស ក៏ដឹងជាមធ្យមបុរសក្នុងសម័យពុទ្ធកាលកាយខ្ពស់ ៩២ ធ្នាប់ទឹង ១ ក្បៀសម្ចាស់ខ្លួន ជា ៩៦ ធ្នាប់ជាងឈើសេស កាយមធ្យម-បុរសនោះ ចែកចេញជា ៣ ភាគ យកភាគ ២ ថែមបញ្ចូលជាកាយព្រះសុគត ខ្ពស់ ១២៩ ធ្នាប់ជាងឈើ ជា ៥ ហត្ថ ៩ ធ្នាប់ជាងឈើ ។ ១៦ ធ្នាប់ទឹង ២ អនុក្បៀសជាងឈើសព្វថ្ងៃនេះ ជា ១ ចំអាមព្រះសុគត ។ ១ ក្បៀសចែកជា ៤ ភាគហៅជាអនុក្បៀស ៥ ក្បៀសទឹងអនុក្បៀសជំសេសជាងឈើ ជា ១ ធ្នាប់ព្រះសុគត ។

ទឹងសំដែងអំពីប្រមាណក្នុងសិក្ខាបទបញ្ញត្តិ ដែលកំណត់ដោយចំអាមទឹងធ្នាប់ព្រះសុគត ក្នុងសញ្ញាចិកកុដិសិក្ខាបទ ថាភិក្ខុគប្បីធ្វើកុដិ ដោយគ្រឿងទព្វសម្ភារៈដែលសូមគេមកដោយខ្លួនឯង បណ្តាយ ១២ ចំអាម ទទឹង ៧ ចំអាម ដោយចំអាមព្រះសុគត លោកកំណត់ទុកថា ទីឃតោ វឌ្ឍកីហត្ថេន ទ្វិកហត្ថាធិក ឯកង្គុលុត្តរអដ្ឋហត្ថប្បមា-ណា ហោតិ, តិរិយតោ បន ទ្វាទសង្គុលុត្តរតិកហត្ថាធិក-ចតុរង្គុលុត្តរវិទត្ថាធិកចតុហត្ថប្បមាណា ហោតិ ។ ជាសញ្ញាចិកកុដិ បណ្តាយ ៨ ហត្ថ ទឹង ១ ធ្នាប់ ទឹង ២ ក្បៀស ទទឹង ៤ ហត្ថ ១ ចំអាម ទឹង ៤ ធ្នាប់ ទឹង ៣ ក្បៀស ទឹង ២ អនុក្បៀសជាងឈើ ។

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងនិសីទនសន្ថតសិក្ខាបទថា  ភិក្ខុគប្បីកាន់យកសន្ថតចាស់ដោយជុំវិញ ឲ្យបាន ១ ចំអាមព្រះសុគត  លាយនឹងសន្ថតថ្មី  លោកកំណត់ទុកថា វិទត្ថិមត្តន្តិ ឥធាតិ  វឌ្ឍកង្គុលេន  ទ្វីហង្គុលេហិ សហ  សោឡសង្គុលានិ  គហេតព្វានិ  ជាចំអាមព្រះសុគត នោះ ១៦ ធ្នាប់ នឹង ២ អនុក្បៀសជាងឈើ ។ ក្នុងមញ្ចសិក្ខាបទថា ប្រមាណជើងគ្រែ ៨ ធ្នាប់  ដោយធ្នាប់ព្រះសុគត  លោកកំណត់ទុកថា តិភាគាធិកទសង្គុលបាទកំ  ហោតិ  ដូច្នេះ  ជាជើង គ្រែកំពស់ ១០ ធ្នាប់ជាងឈើ នឹង ៣ ក្បៀស ។ ក្នុងនិសីទនសិក្ខាបទ ជាប្រមាណនិសីទនៈ បណ្តោយ ២ ចំអាម  ទទឹង ១ ចំអាមកន្លះ ជាយ ១ ចំអាម  ដោយចំអាមព្រះសុគត  លោកកំណត់ទុកថា  ទីឃតោ វឌ្ឍកង្គុលេន  ឯកង្គុលាធិកតេត្តិំសង្គុលំ  ហោតិ វិត្ថារតោ  តីហង្គុលេហិ  សហ  ហត្ថប្បមាណំ ហោតិ, ទសា  បន  ទ្វីហង្គុលេហិ  សហ  សោឡសង្គុលា ហោតិ  ដូច្នេះ ។ ជាសំពត់និសីទនៈ  បណ្តោយ ៣២ ធ្នាប់ជាងឈើ នឹង ១ ក្បៀស ទទឹង ១ ហត្ថ នឹង ៣ អនុក្បៀស ជាយ ១៦ ធ្នាប់ជាងឈើ នឹង ២ អនុក្បៀស ។ ក្នុងកណ្ឌុប្បដិច្ឆាទិសិក្ខាបទថា  ប្រមាណសំពត់ បិទបួស  បណ្តោយ ៤ ចំអាម  ទទឹង ២ ចំអាម  ដោយចំអាមព្រះសុគត លោកកំណត់ទុកថា  ទីឃតោ  វឌ្ឍកីហត្ថេន  ទ្វង្គុលាធិក. ចតុរង្គុលវិទត្ថ្យាធិកទ្វិហត្ថប្បមាណា ហោតិ, វិត្ថារតោ

បង ឯកា កាលាជិកា អដ្ឋង្គុលុត្តរហត្ថប្បមាណា ហោតិ ដូច្នេះ ។ ថាសំពត់ប៉ទបូស បណ្តោយ ២ ហត្ថ ១ ចំអាម ៤ ធ្នាប់ ២ ក្បៀស ជាន់ឈើ ទទឹង ១ ហត្ថ ៨ ធ្នាប់ទឹង ១ ក្បៀស ។ ក្នុងវស្សិកសាដិកាសិក្ខាបទ ប្រមាណសំពត់ងូតទឹកភ្លៀង បណ្តោយ ៦ ចំអាម ទទឹង ២ ចំអាមកន្លះ ដោយចំអាមព្រះសុគត លោកកំណត់ទុកថា ដីឃតោ វឌ្ឍកីហត្ថេន តីហិ កាលាហិ សហ ចតុហត្ថប្បមាណា ហោតិ, តិរិយតោ ឯកាធុកកាលុត្តរេកកាលាជិកាចតុរង្គុលុត្តរវិធត្ថ្យាជិកាហត្ថប្បមាណា ហោតិ ដូច្នេះ ។ ថាសំពត់ងូតទឹកភ្លៀង បណ្តោយ ៤ ហត្ថ ទឹង ៣ ក្បៀសជាន់ឈើ ទទឹង ១ ហត្ថ ១ ចំអាម ៤ ធ្នាប់ ទឹង ៩ ក្បៀស ទឹង ១ អនុក្បៀសទៀត ។ ក្នុងខន្ធសិក្ខាបទថា ធ្វើចីវរឲ្យប៉ុនសុគតចីវរ ឬធំលើសជាងនោះ ត្រូវឆេទនកបាចិត្តិយ ប្រមាណសុគតចីវរ បណ្តោយ ៩ ចំអាម ទទឹង ៦ ចំអាមដោយចំអាមព្រះសុគត លោកកំណត់ទុកថា វឌ្ឍកីហត្ថេន ដីឃតោ ឆ្មាធុកកាលាជិកាឯកង្គុលុត្តរេហត្ថប្បមាណំ ហោតិ, វិត្ថារតោ តីហិ កាលាហិ សហ ចតុហត្ថប្បមាណំ ហោតិ ដូច្នេះ ។ ថាសុគតចីវរ បណ្តោយ ៦ ហត្ថ ១ ធ្នាប់ ទឹង ២ អនុក្បៀសទៀត ទទឹង ៤ ហត្ថ ទឹង ៣ ក្បៀសជាន់ឈើ ។ ប្រមាណចីវរត្រូវកប្បយ៉ាងតូច បណ្តោយ ៨ ធ្នាប់ ទទឹង ៤ ធ្នាប់ដោយធ្នាប់ព្រះសុគត លោកកំណត់ទុកថា អាយាមតោ វឌ្ឍកង្គុលេន

www.budinst.gov.kh www.elibraryofcambodia.org

តិកកាលាធិកកាធសត្តុលំ ហោតិ, វិត្ថារតោ បន ទ្វាទុកាំ.
លាធិកាយ ឯកកកលាយ សហ បញ្ចត្តុលំ ដូច្នេះ ។
ថាបច្ឆិមចីវរ បណ្តោយ ១០ ធ្នាប់ នឹង ៣ ក្បៀស ទទឹង ៤ ធ្នាប់ ១ ក្បៀសនឹង ២ អនុក្បៀសជាងនេះទៀត ។ ពាក្យដែលពណ៌នាមកនេះកាត់សេចក្តីដោយសង្ខេប ល្មមឲ្យដឹងហេតុដែលលោកបានគិតសុគតវិទត្ថិ ។ នឹងតែងគម្ពីរសុគតវិទត្ថិវិធានបករណៈ បើបណ្ឌិតជាតិប្រាថ្នាចង់ដឹងពិស្តារ គប្បីមើលក្នុងគម្ពីរសុគតវិទត្ថិវិធានបករណៈចុះ ដ្បិតថាហេតុ ឧទាហរណ៍ ដែលសាធកៈឲ្យឃើញថា ព្រះកាយនៃព្រះពុទ្ធអង្គមិនខ្ពស់ពេកជាងកាយប្រក្រតីមនុស្ស នឹងវិធីលេខដោយពិស្តារ នឹងកំណត់អវយវៈនៃព្រះពុទ្ធអង្គ នឹងកំណត់ប្រមាណក្នុងសិក្ខាបទទាំងពួងលោកសំដែងទុកក្នុងគម្ពីរនោះ ដោយពិស្តារ ឬអ្នកប្រាជ្ញដែលមានបញ្ញាបានហេតុដទៃដែលនឹងសាធកៈឲ្យឃើញច្បាស់ថា កាយព្រះពុទ្ធអង្គខ្ពស់ប៉ុណ្ណេះ ៗ ក៏គប្បីគិតតាមហេតុន័យដែលបានពណ៌នាមកនោះចុះ ។

សេចក្តីជំនុំ ក្នុងសុគតវិទត្ថិ ចំអាមព្រះសុគត ដែលព្រះសង្ឃថេរានុថេរៈនឹងយកកំសហានានុសត្តិទាំងពួង ដែលបានសមូហៈជួបជុំសង្គីតិកាជឿនិងធ្លាក់សិក្ខាវណ្ណនា ក្នុងកម្ពុជប្រទេសនេះ យល់ឃើញព្រមគ្នាថា
១ ធ្នាប់ព្រះសុគត ត្រូវជា ២៨ មិល្លីម៉ែត្រ នឹង ២ ទសមិល្លីម៉ែត្រ[១] ។

១ ចំអាមព្រះសុគត ត្រូវជា ៣៤ សង្ទីម៉ែត្រ ។

(១) មួយធ្នាប់ព្រះសុគត ត្រូវជា ០ម,០២៨៣ ... ។

www.budinst.gov.kh www.elibraryofcambodia.org

កុដិ បណ្តោយ ១២ ចំអាមព្រះសុគត ត្រូវជា ៤ ម៉ែត្រ ៨ សន្ទីម៉ែត្រ ទទឹង ៧ ចំអាមព្រះសុគត ត្រូវជា ២ ម៉ែត្រ ៣៨ សន្ទីម៉ែត្រ ។

ជើងក្រែកំពស់ ៨ ធ្នាប់ព្រះសុគត ត្រូវជា ២២ សន្ទីម៉ែត្រ ៥ មិល្លីម៉ែត្រ ។

និសីទនៈបណ្តោយ ២ ចំអាមព្រះសុគត ត្រូវជា ៦៨ សន្ទីម៉ែត្រ ទទឹង ១ ចំអាម ៦ ធ្នាប់ព្រះសុគត ត្រូវជា ៥១ សន្ទីម៉ែត្រ ជាយ ១ ចំអាម ត្រូវជា ៣៤ សន្ទីម៉ែត្រ ។

សំពត់បិទបូសបណ្តោយ ៤ ចំអាមព្រះសុគត ត្រូវជា ១ ម៉ែត្រ ៣៦ សន្ទីម៉ែត្រ ទទឹង ២ ចំអាមព្រះសុគត ត្រូវជា ៦៨ សន្ទីម៉ែត្រ ។

វស្សិកសាដិកាបណ្តោយ ៦ ចំអាមព្រះសុគត ត្រូវជា ២ ម៉ែត្រ ៤ សន្ទីម៉ែត្រ ទទឹង ២ ចំអាម ៦ ធ្នាប់ព្រះសុគត ត្រូវជា ៨៥ សន្ទីម៉ែត្រ ។

សុគតចីវរ បណ្តោយ ៩ ចំអាមព្រះសុគត ត្រូវជា ៣ ម៉ែត្រ ៦ សន្ទីម៉ែត្រ ទទឹង ៦ ចំអាមព្រះសុគត ត្រូវជា ២ ម៉ែត្រ ៤ សន្ទីម៉ែត្រ ។

ប្រមាណសុគតវិទត្ថិ ចប់

ឯត្តាវតា បុព្វសិក្ខាវណ្ណនា និដ្ឋិតា

បុព្វសិក្ខាវណ្ណនា ចប់តែប៉ុណ្ណេះ

www.budinst.gov.kh www.elibraryofcambodia.org

# សន្លឹកបង្អួលប្រាប់មាតិកា


| មាតិកាធម៌ | បន្ទាត់ | ទំព័រ |
|---|---|---|
| ធម្មសម្បត្តិ | អក្សរ ក | ដល់ រ |

## វត្តឆដ្ឋយបត្ត

| | | |
|---|---|---|
| ពុទ្ធវត្តកថា | ៨ | ៤ |
| ធម្មវត្តកថា | ១ | ៥៧ |
| សង្ឃវត្តកថា | ១ | ១០៦ |

## អាបត្តិឆាមាធិបត្ត

| | | |
|---|---|---|
| អាបត្តិនាមកថា | ១៣ | ១៣១ |
| សិក្ខាបទបរិច្ឆេទកថា | ១ | ១៣៧ |
| សមុដ្ឋានាទិកថា | ៥ | ១៤៣ |
| អាការៈដែលភិក្ខុនឹងត្រូវអាបត្តិ | ៦ | ១៥២ |

## បដិបត្តិមុខបត្ត

*បារាជិកុទ្ទេស*

| | | |
|---|---|---|
| មេថុនសិក្ខាបទដំបូង | ៣ | ១៥៦ |
| អទិន្នាទានសិក្ខាបទទីរបំ ២ | ១៣ | ១៦៣ |
| មនុស្សវិគ្គហសិក្ខាបទទីរបំ ៣ | ១៦ | ១៧១ |
| ឧត្តរិមនុស្សធម្មសិក្ខាបទទីរបំ ៤ | ១១ | ១៨៧ |

*សង្ឃាទិសេសុទ្ទេស*

| | | |
|---|---|---|
| សញ្ចេតនិកសិក្ខាបទ | ១៣ | ១៩២ |
| កាយសំសគ្គសិក្ខាបទ | ៥ | ១៩៤ |




www.budinst.gov.kh www.elibraryofcambodia.org

# សន្លឹកបង្អួលប្រាប់មាតិកា


| មាតិកាធម៌ | បន្ទាត់ | ទំព័រ |
|---|---|---|
| ***សង្ឃាទិសេសុទ្ទេស*** | | |
| ទុដ្ឋុល្លវាចសិក្ខាបទ | ៣ | ១៩៦ |
| អត្តកាមបារិចរិយសិក្ខាបទ | ១២ | ១៩៨ |
| សញ្ចរិតសិក្ខាបទ | ៨ | ១៩៩ |
| កុដិការសិក្ខាបទ | ១០ | ២០២ |
| មហល្លកសិក្ខាបទ | ៦ | ២០៤ |
| អមូលកសិក្ខាបទ | ១២ | ២០៤ |
| អញ្ញភាគិយសិក្ខាបទ | ៩ | ២០៨ |
| សង្ឃភេទសិក្ខាបទ | ១៣ | ២០៩ |
| ភេទានុវត្តកសិក្ខាបទ | ១៨ | ២១០ |
| ទុព្វចជាតិកសិក្ខាបទ | ១៣ | ២១១ |
| កុលទូសកសិក្ខាបទ | ៣ | ២១២ |
| ***អនិយតុទ្ទេស*** | | |
| អលំកម្មនិយសិក្ខាបទ | ៤១ | ២១៤ |
| នាលំកម្មនិយសិក្ខាបទ | ៩ | ២១៦ |
| ផ្សព្វផ្សាយបត្តិ | ១ | ២១៨ |
| ***និស្សគ្គិយុទ្ទេស ចីវរវគ្គទី ១*** | | |
| បឋមកឋិនសិក្ខាបទ | ១៦ | ២២៨ |
| ទុតិយកឋិនសិក្ខាបទ | ៨ | ២២៨ |
| តតិយកឋិនសិក្ខាបទ | ១២ | ២៣០ |




www.budinst.gov.kh www.elibraryofcambodia.org

# សន្លឹកបង្គុលប្រាប់មាតិកា


| មាតិកាធម៌ | បន្ទាត់ | ទំព័រ |
|---|---|---|
| **និស្សគ្គិយុទ្ទេស ចីវរវគ្គទី ១** | | |
| បុរាណចីវរសិក្ខាបទ | ៦ | ២៣១ |
| ចីវរបដិគ្គហណសិក្ខាបទ | ១១ | ២៣១ |
| អញ្ញាតកវិញ្ញត្តិសិក្ខាបទ | ១៦ | ២៣១ |
| តទុត្តរិសិក្ខាបទ | ១០ | ២៣៤ |
| បឋមឧបក្ខដសិក្ខាបទ | ១៥ | ២៣៥ |
| ទុតិយឧបក្ខដសិក្ខាបទ | ១៨ | ២៣៦ |
| រាជសិក្ខាបទ | ៦ | ២៣៧ |
| **និស្សគ្គិយុទ្ទេស កោសិយវគ្គទី ២** | | |
| កោសិយសិក្ខាបទ | ១៨ | ២៤០ |
| សុទ្ធកាឡកសិក្ខាបទ | ១ | ២៤២ |
| ទ្វេភាគសិក្ខាបទ | ៦ | ២៤២ |
| ឆព្វស្សសិក្ខាបទ | ១៣ | ២៤២ |
| និសីទនសន្ថតសិក្ខាបទ | ១ | ២៤៣ |
| ឯឡកលោមសិក្ខាបទ | ១០ | ២៤៣ |
| ឯឡកលោមធោវាបនសិក្ខាបទ | ១៧ | ២៤៣ |
| រូបិយសិក្ខាបទ | ៧ | ២៤៤ |
| រូបិយសំវោហារសិក្ខាបទ | ២ | ២៤៨ |
| កយវិក្កយសិក្ខាបទ | ២ | ២៤៩ |
| **និស្សគ្គិយុទ្ទេស បត្តវគ្គទី ៣** | | |
| បត្តសិក្ខាបទ | ៣ | ២៥០ |




www.budinst.gov.kh www.elibraryofcambodia.org

# សន្លឹកបង្គុលប្រាប់មាតិកា


| មាតិកាធម៌ | បន្ទាត់ | ទំព័រ |
|---|---|---|
| **និស្សគ្គិយុទ្ទេស បត្តវគ្គទី ៣** | | |
| ឧនបញ្ចពន្ធនសិក្ខាបទ | ១២ | ២៤១ |
| ភេសជ្ជសិក្ខាបទ | ២ | ២៤៣ |
| វស្សិកសាដិកសិក្ខាបទ | ៥ | ២៤៤ |
| ចីវរាច្ឆិន្ទនសិក្ខាបទ | ១៣ | ២៤៥ |
| សុត្តវិញ្ញត្តិសិក្ខាបទ | ២ | ២៤៧ |
| មហាបេសការសិក្ខាបទ | ២ | ២៤៨ |
| អច្ចេកចីវរសិក្ខាបទ | ២ | ២៤៩ |
| សាសង្កសិក្ខាបទ | ២ | ២៥០ |
| បរិណតសិក្ខាបទ | ២ | ២៥០ |
| **បាចិត្តិយុទ្ទេស មុសាវាទវគ្គទី ១** | | |
| មុសាវាទសិក្ខាបទ | ១៧ | ២៥២ |
| ឱមសវាទសិក្ខាបទ | ៦ | ២៥៤ |
| បេសុញ្ញសិក្ខាបទ | ២ | ២៥៨ |
| បទសោធម្មសិក្ខាបទ | ៨ | ២៥៩ |
| សហសេយ្យសិក្ខាបទ | ៥ | ២៦២ |
| ទុតិយសហសេយ្យសិក្ខាបទ | ៨ | ២៦៤ |
| ធម្មទេសនាសិក្ខាបទ | ២ | ២៦៥ |
| ភូតារោចនសិក្ខាបទ | ១២ | ២៦៦ |
| ទុដ្ឋុល្លារោចនសិក្ខាបទ | ១៦ | ២៦៦ |
| បឋវីខណនសិក្ខាបទ | ១១ | ២៦៨ |




www.budinst.gov.kh www.elibraryofcambodia.org

# សន្លឹកបង្កុលប្រាប់មាតិកា


| មាតិកាធម៌ | បន្ទាត់ | ទំព័រ |
|---|---|---|
| **បាចិត្តិយុទ្ទេស ភូតគាមវគ្គទី ២** | | |
| ភូតគាមសិក្ខាបទ | ២០ | ២៨០ |
| អញ្ញវាទកសិក្ខាបទ | ៨ | ២៨៣ |
| ឧជ្ឈាបនកសិក្ខាបទ | ១០ | ២៨៤ |
| បឋមសេនាសនសិក្ខាបទ | ១៨ | ២៨៥ |
| ទុតិយសេនាសនសិក្ខាបទ | ១៧ | ២៨៨ |
| អនុបខជ្ជសិក្ខាបទ | ២ | ២៩១ |
| និក្កឌ្ឍនសិក្ខាបទ | ១៣ | ២៩២ |
| វេហាសកុដិសិក្ខាបទ | ៨ | ២៩៤ |
| មហល្លកវិហារសិក្ខាបទ | ១៤ | ២៩៦ |
| សប្បាណកសិក្ខាបទ | ១៧ | ២៩៥ |
| **បាចិត្តិយុទ្ទេស ឱវាទវគ្គទី ៣** | | |
| ឱវាទសិក្ខាបទ | ៩ | ២៩៧ |
| អត្ថង្គតសិក្ខាបទ | ១២ | ២៩៨ |
| ឧបស្សយសិក្ខាបទ | ១៦ | ២៩៨ |
| អាមិសសិក្ខាបទ | ២ | ២៩៩ |
| ចីវរទានសិក្ខាបទ | ៦ | ២៩៩ |
| ចីវរសិព្វនសិក្ខាបទ | ១០ | ២៩៩ |
| សំវិធានសិក្ខាបទ | ១៣ | ២៩៩ |
| នាវាភិរូហនសិក្ខាបទ | ២ | ៣០០ |
| បរិបាចនសិក្ខាបទ | ៧ | ៣០០ |
| រហោនិសជ្ជសិក្ខាបទ | ១២ | ៣០០ |




www.budinst.gov.kh www.elibraryofcambodia.org

# សន្លឹកបង្គោលប្រាប់មាតិកា

| មាតិកាធម៌ | បន្ទាត់ | ទំព័រ |
|---|---|---|


បាចិត្តិយុទ្ទេស ភោជនវគ្គទី ៤

| | | |
|---|---|---|
| អាវសថបិណ្ឌសិក្ខាបទ | ៣ | ៣០១ |
| គណភោជនសិក្ខាបទ | ១២ | ៣០២ |
| បរម្បរភោជនសិក្ខាបទ | ២ | ៣០៥ |
| កាណមាតាសិក្ខាបទ | ១៤ | ៣០៦ |
| បឋមបវារណាសិក្ខាបទ | ១៧ | ៣០៧ |
| ទុតិយបវារណាសិក្ខាបទ | ៦ | ៣១៦ |
| វិកាលភោជនសិក្ខាបទ | ១១ | ៣១៧ |
| សន្និធិការកសិក្ខាបទ | ១២ | ៣១៨ |
| បណីតភោជនសិក្ខាបទ | ១៨ | ៣១៩ |
| ទន្តបោណសិក្ខាបទ | ១០ | ៣២១ |

បាចិត្តិយុទ្ទេស អចេលកវគ្គទី ៥

| | | |
|---|---|---|
| អចេលកសិក្ខាបទ | ៨ | ៣២៣ |
| ឧយ្យោជនសិក្ខាបទ | ១៤ | ៣២៣ |
| សភោជនសិក្ខាបទ | ៧ | ៣២៤ |
| បឋមរហោនិសជ្ជសិក្ខាបទ | ១៤ | ៣២៥ |
| ទុតិយរហោនិសជ្ជសិក្ខាបទ | ៤ | ៣២៦ |
| ចារិត្តសិក្ខាបទ | ៩ | ៣២៦ |
| មហានាមសិក្ខាបទ | ៦ | ៣២៨ |
| ឧយ្យុត្តសិក្ខាបទ | ៩ | ៣២៩ |
| សេនាវាសសិក្ខាបទ | ១៨ | ៣៣០ |
| ឧយ្យោធិកសិក្ខាបទ | ៦ | ៣៣១ |




www.budinst.gov.kh www.elibraryofcambodia.org

# សន្លឹកចង្អុលប្រាប់មាតិកា


| មាតិកាធម៌ | បន្ទាត់ | ទំព័រ |
|---|---|---|
| បាចិត្តិយុទ្ទេស សុរាបានវគ្គទី ៦ | | |
| សុរាបានសិក្ខាបទ . . . . . . . . . . . . . . . . . . | ៣ | ៣៣២ |
| អង្គុលិបតោទកសិក្ខាបទ . . . . . . . . . . . . . . . | ២ | ៣៣៣ |
| ហស្សធម្មសិក្ខាបទ . . . . . . . . . . . . . . . . . | ១៧ | ៣៣៣ |
| អនាទរិយសិក្ខាបទ . . . . . . . . . . . . . . . . . | ២ | ៣៣៥ |
| ភឹសាបនសិក្ខាបទ . . . . . . . . . . . . . . . . . | ៥ | ៣៣៦ |
| ជោតិសមាទហនសិក្ខាបទ . . . . . . . . . . . . . . . | ២ | ៣៣៧ |
| នហានសិក្ខាបទ . . . . . . . . . . . . . . . . . . | ៦ | ៣៣៨ |
| ទុព្វណ្ណករណសិក្ខាបទ . . . . . . . . . . . . . . . | ៥ | ៣៣៩ |
| វិកប្បនសិក្ខាបទ . . . . . . . . . . . . . . . . . | ១២ | ៣៤០ |
| អបនិធានសិក្ខាបទ . . . . . . . . . . . . . . . . . | ១៣ | ៣៤១ |
| បាចិត្តិយុទ្ទេស សប្បាណកវគ្គទី ៧ | | |
| សញ្ចិច្ចបាណសិក្ខាបទ . . . . . . . . . . . . . . . . | ១៧ | ៣៤២ |
| សប្បាណកសិក្ខាបទ . . . . . . . . . . . . . . . . . | ១០ | ៣៤៣ |
| ឧក្កោដនសិក្ខាបទ . . . . . . . . . . . . . . . . . | ១៦ | ៣៤៤ |
| ទុដ្ឋុល្លបដិច្ឆាទនសិក្ខាបទ . . . . . . . . . . . . . | ២ | ៣៤៥ |
| ឩនវីសតិវស្សសិក្ខាបទ . . . . . . . . . . . . . . . | ១០ | ៣៤៦ |
| ថេយ្យសត្ថសិក្ខាបទ . . . . . . . . . . . . . . . . | ៥ | ៣៤៧ |
| សំវិធានសិក្ខាបទ . . . . . . . . . . . . . . . . . | ១៣ | ៣៤៨ |
| អរិដ្ឋសិក្ខាបទ . . . . . . . . . . . . . . . . . . | ១២ | ៣៤៩ |
| ឧក្ខិត្តសម្ភោគសិក្ខាបទ . . . . . . . . . . . . . . | ១០ | ៣៥០ |
| កណ្ដកសិក្ខាបទ . . . . . . . . . . . . . . . . . . | ១១ | ៣៥១ |




www.budinst.gov.kh www.elibraryofcambodia.org

# សន្លឹកបង្គលប្រាប់មាតិកា


| មាតិកាធម៌ | បន្ទាត់ | ទំព័រ |
| --- | --- | --- |
| **បាចិត្តិយខណ្ឌ សហធម្មិកវគ្គទី ៨** | | |
| សហធម្មិកសិក្ខាបទ | ១៤ | ៣៥២ |
| វិលេខនសិក្ខាបទ | ១៧ | ៣៥៣ |
| មោហនសិក្ខាបទ | ១៧ | ៣៥៤ |
| បហារទានសិក្ខាបទ | ១៤ | ៣៥៥ |
| តលសត្តិកសិក្ខាបទ | ១០ | ៣៥៦ |
| អមូលកសិក្ខាបទ | ២ | ៣៥៧ |
| សញ្ចិច្ចសិក្ខាបទ | ២ | ៣៥៨ |
| ឧបស្សុតិសិក្ខាបទ | ២ | ៣៥៩ |
| កម្មប្បដិពាហនសិក្ខាបទ | ៨ | ៣៦០ |
| ឆន្ទំអទត្វាគមនសិក្ខាបទ | ៨ | ៣៦០ |
| ទព្វសិក្ខាបទ | ២ | ៣៦៣ |
| បរិណាមនសិក្ខាបទ | ៩ | ៣៦៣ |
| **បាចិត្តិយខណ្ឌ រតនវគ្គទី ៩** | | |
| អន្តេបុរសិក្ខាបទ | ១៨ | ៣៦៣ |
| រតនសិក្ខាបទ | ៨ | ៣៦៤ |
| វិកាលគាមប្បវេសនសិក្ខាបទ | ២ | ៣៦៧ |
| សូចិឃរសិក្ខាបទ | ១៦ | ៣៦៨ |
| ឆេទនកសិក្ខាបទ | ២ | ៣៧០ |
| តុលោនទ្ធសិក្ខាបទ | ១៧ | ៣៧០ |
| និសីទនសិក្ខាបទ | ១៣ | ៣៧២ |




www.budinst.gov.kh www.elibraryofcambodia.org

# សន្ទឹកបង្គុលប្រាប់មាតិកា

| មាតិកាធម៌ | បន្ទាត់ | ទំព័រ |
|---|---|---|
| *បាចិត្តិយុទ្ទេស រតនវគ្គទី៩* | | |
| កណ្ឌុបដិច្ឆាទិសិក្ខាបទ . . . . . . . . . . . . . . . . . . | ១៣ | ៣៧២ |
| វស្សិកសាដិកសិក្ខាបទ . . . . . . . . . . . . . . . . . | ៧ | ៣៧៣ |
| នន្ទសិក្ខាបទ . . . . . . . . . . . . . . . . . . . . . . | ១៤ | ៣៧៣ |
| ប្រមាណនៃចំអាមព្រះសុគត . . . . . . . . . . . . . . . . | ៨ | ៣៧៤ |
| *បាដិទេសនីយុទ្ទេស មាន ៤ សិក្ខាបទ* | | |
| សិក្ខាបទជាបឋម . . . . . . . . . . . . . . . . . . . . | ១២ | ៣៧៥ |
| សិក្ខាបទគំរប់ ២ . . . . . . . . . . . . . . . . . . . . | ២ | ៣៧៦ |
| សិក្ខាបទគំរប់ ៣ . . . . . . . . . . . . . . . . . . . . | ១១ | ៣៧៦ |
| សិក្ខាបទគំរប់ ៤ . . . . . . . . . . . . . . . . . . . . | ២ | ៣៧៧ |
| *សេខិយុទ្ទេស សារុប្ប មាន ២៦ សិក្ខាបទ* | | |
| សិក្ខាបទជាបឋម . . . . . . . . . . . . . . . . . . . . | ១៦ | ៣៧៩ |
| សិក្ខាបទគំរប់ ២ . . . . . . . . . . . . . . . . . . . . | ៥ | ៣៨២ |
| សិក្ខាបទគំរប់ ៣ . . . . . . . . . . . . . . . . . . . . | ១០ | ៣៨២ |
| សិក្ខាបទគំរប់ ៤ . . . . . . . . . . . . . . . . . . . . | ១៤ | ៣៨២ |
| សិក្ខាបទគំរប់ ៥ . . . . . . . . . . . . . . . . . . . . | ៦ | ៣៨៣ |
| សិក្ខាបទគំរប់ ៦ . . . . . . . . . . . . . . . . . . . . | ៩ | ៣៨៣ |
| សិក្ខាបទគំរប់ ៧ . . . . . . . . . . . . . . . . . . . . | ១២ | ៣៨៣ |
| សិក្ខាបទគំរប់ ៨ . . . . . . . . . . . . . . . . . . . . | ១៦ | ៣៨៣ |
| សិក្ខាបទគំរប់ ៩ . . . . . . . . . . . . . . . . . . . . | ១៨ | ៣៨៣ |
| សិក្ខាបទគំរប់ ១០ . . . . . . . . . . . . . . . . . . . | ៤ | ៣៨៤ |



www.budinst.gov.kh www.elibraryofcambodia.org

# សន្លឹកបង្គុលប្រាប់មាតិកា


| មាតិកាធម៌ | បន្ទាត់ | ទំព័រ |
|---|---|---|
| **សេខិយខន្ធ សារុប្បា មាន ២៦ សិក្ខាបទ** | | |
| សិក្ខាបទគំរប់ ១១ | ៩ | ៣៨៤ |
| សិក្ខាបទគំរប់ ១២ | ១១ | ៣៨៤ |
| សិក្ខាបទគំរប់ ១៣ | ១៤ | ៣៨៤ |
| សិក្ខាបទគំរប់ ១៤ | ១៦ | ៣៨៤ |
| សិក្ខាបទគំរប់ ១៥ | ១១ | ៣៨៥ |
| សិក្ខាបទគំរប់ ១៦ | ១៤ | ៣៨៥ |
| សិក្ខាបទគំរប់ ១៧ | ១៧ | ៣៨៥ |
| សិក្ខាបទគំរប់ ១៨ | ១៩ | ៣៨៥ |
| សិក្ខាបទគំរប់ ១៩ | ២ | ៣៨៦ |
| សិក្ខាបទគំរប់ ២០ | ៤ | ៣៨៦ |
| សិក្ខាបទគំរប់ ២១ | ៩ | ៣៨៦ |
| សិក្ខាបទគំរប់ ២២ | ១១ | ៣៨៦ |
| សិក្ខាបទគំរប់ ២៣ | ១៤ | ៣៨៦ |
| សិក្ខាបទគំរប់ ២៤ | ១៦ | ៣៨៦ |
| សិក្ខាបទគំរប់ ២៥ | ១៩ | ៣៨៦ |
| សិក្ខាបទគំរប់ ២៦ | ៤ | ៣៨៧ |
| **សេខិយខន្ធ ភោជនប្បដិសំយុត្ត មាន ៣០ សិក្ខាបទ** | | |
| សិក្ខាបទដំបូង | ៣ | ៣៨៨ |
| សិក្ខាបទគំរប់ ២ | ៦ | ៣៨៨ |
| សិក្ខាបទគំរប់ ៣ | ៨ | ៣៨៨ |
| សិក្ខាបទគំរប់ ៤ | ១៧ | ៣៨៨ |




www.budinst.gov.kh www.elibraryofcambodia.org

# សន្លឹកបង្គុលប្រាប់មាតិកា


| មាតិកាធម៌ | បន្ទាត់ | ទំព័រ |
|---|---|---|
| *សេខិយវត្ត ភោជនប្បដិសំយុត្ត មាន ៣០ សិក្ខាបទ* | | |
| សិក្ខាបទគំរប់ ៥ | ១៥ | ៣៨៩ |
| សិក្ខាបទគំរប់ ៦ | ១៧ | ៣៨៩ |
| សិក្ខាបទគំរប់ ៧ | ១៩ | ៣៨៩ |
| សិក្ខាបទគំរប់ ៨ | ៦ | ៣៩០ |
| សិក្ខាបទគំរប់ ៩ | ១១ | ៣៩០ |
| សិក្ខាបទគំរប់ ១០ | ១៥ | ៣៩០ |
| សិក្ខាបទគំរប់ ១១ | ២ | ៣៩១ |
| សិក្ខាបទគំរប់ ១២ | ៦ | ៣៩១ |
| សិក្ខាបទគំរប់ ១៣ | ១០ | ៣៩១ |
| សិក្ខាបទគំរប់ ១៤ | ១៤ | ៣៩១ |
| សិក្ខាបទគំរប់ ១៥ | ១៧ | ៣៩១ |
| សិក្ខាបទគំរប់ ១៦ | ១៩ | ៣៩១ |
| សិក្ខាបទគំរប់ ១៧ | ៦ | ៣៩២ |
| សិក្ខាបទគំរប់ ១៨ | ១០ | ៣៩២ |
| សិក្ខាបទគំរប់ ១៩ | ១៤ | ៣៩២ |
| សិក្ខាបទគំរប់ ២០ | ១៧ | ៣៩២ |
| សិក្ខាបទគំរប់ ២១ | ២ | ៣៩៣ |
| សិក្ខាបទគំរប់ ២២ | ៥ | ៣៩៣ |
| សិក្ខាបទគំរប់ ២៣ | ៨ | ៣៩៣ |
| សិក្ខាបទគំរប់ ២៤ | ១១ | ៣៩៣ |
| សិក្ខាបទគំរប់ ២៥ | ១២ | ៣៩៣ |




www.budinst.gov.kh www.elibraryofcambodia.org

# សន្លឹកបង្គុលប្រាប់មាតិកា


| មាតិកាធម៌ | បន្ទាត់ | ទំព័រ |
|---|---|---|
| **សេខិយវគ្គ ភោជនប្បដិសំយុត្ត មាន ៣០ សិក្ខាបទ** | | |
| សិក្ខាបទគំរប់ ២៦ | ១៤ | ៣៩៣ |
| សិក្ខាបទគំរប់ ២៧ | ១៨ | ៣៩៣ |
| សិក្ខាបទគំរប់ ២៨ | ២ | ៣៩៤ |
| សិក្ខាបទគំរប់ ២៩ | ៥ | ៣៩៤ |
| សិក្ខាបទគំរប់ ៣០ | ១៣ | ៣៩៤ |
| **សេខិយវគ្គ ធម្មទេសនាបដិសំយុត្ត មាន ១៦ សិក្ខាបទ** | | |
| សិក្ខាបទដំបូង | ១០ | ៣៩៥ |
| សិក្ខាបទគំរប់ ២ | ១៨ | ៣៩៥ |
| សិក្ខាបទគំរប់ ៣ | ៥ | ៣៩៦ |
| សិក្ខាបទគំរប់ ៤ | ១០ | ៣៩៦ |
| សិក្ខាបទគំរប់ ៥ | ២ | ៣៩៧ |
| សិក្ខាបទគំរប់ ៦ | ៦ | ៣៩៧ |
| សិក្ខាបទគំរប់ ៧ | ១២ | ៣៩៧ |
| សិក្ខាបទគំរប់ ៨ | ៦ | ៣៩៨ |
| សិក្ខាបទគំរប់ ៩ | ១៤ | ៣៩៨ |
| សិក្ខាបទគំរប់ ១០ | ១៧ | ៣៩៨ |
| សិក្ខាបទគំរប់ ១១ | ២ | ៣៩៩ |
| សិក្ខាបទគំរប់ ១២ | ៥ | ៣៩៩ |
| សិក្ខាបទគំរប់ ១៣ | ៨ | ៣៩៩ |
| សិក្ខាបទគំរប់ ១៤ | ១១ | ៣៩៩ |




www.budinst.gov.kh www.elibraryofcambodia.org

# សន្លឹកបង្អួលប្រាប់មាតិកា


| មាតិកាធម៌ | បន្ទាត់ | ទំព័រ |
|---|---|---|
| **សេខិយវគ្គ ធម្មទេសនាបដិសំយុត្ត មាន ១៦ សិក្ខាបទ** | | |
| សិក្ខាបទគំរប់ ៥ | ១៩ | ៣៩៩ |
| សិក្ខាបទគំរប់ ១៦ | ៧ | ៤០០ |
| **សេខិយវគ្គ បកិណ្ណកៈ មាន ៣ សិក្ខាបទ** | | |
| សិក្ខាបទដាបឋៈ | ១៧ | ៤០០ |
| សិក្ខាបទគំរប់ ២ | ២ | ៤០១ |
| សិក្ខាបទគំរប់ ៣ | ១៣ | ៤០១ |
| ចីវរបដិសំយុត្តកថា | ១ | ៤០៤ |
| ឃាតាទិកថា | ៨ | ៤១០ |
| មំសកថា | ១ | ៤១៩ |
| តិរច្ឆានវិជ្ជាទិកថា | ១២ | ៤២២ |
| សទ្ធាទេយ្យាទិកថា | ១៧ | ៤២៨ |
| កុលទូសកកម្ម | ៤៧ | ៤៣៨ |
| បាបសមាចារកថា | ៥ | ៤៤១ |
| អនាចារកថា | ១ | ៤៤៧ |
| បរិក្ខារកថា | ១២ | ៤៤៩ |
| មណ្ឌនាទិកថា | ៧ | ៤៥៩ |
| បត្តបដិសំយុត្តកថា | ៦ | ៤៦៩ |
| សេនាសនបដិសំយុត្តកថា | ៩ | ៤៧៧ |
| អនាមាសាទិកថា | ៩ | ៥០៥ |
| អចិត្តកបញ្ញត្តិកថា | ១ | ៥១២ |




www.budinst.gov.kh www.elibraryofcambodia.org

# សន្លឹកបង្គុលប្រាប់មាតិកា


| មាតិកាធម៌ | បន្ទាត់ | ទំព័រ |
|---|---|---|
| វិញ្ញត្តិកថា | ៩ | ៥២៦ |
| មេណ្ឌកបញ្ញត្តិ | ៨ | ៥៣១ |
| គោបកទានកថា | ៩ | ៥៣៣ |
| អារក្ខាយាចនកថា | ៥ | ៥៣៧ |
| បរិភោគកថា | ១៤ | ៥៣៩ |


## វគ្គកថា


| | | |
|---|---|---|
| អាគន្តុកវត្ត | ៥ | ៥៤២ |
| អាវាសិកវត្ត | ១៣ | ៥៤៤ |
| គមិកវត្ត | ១៧ | ៥៤៦ |
| អនុមោទនវត្ត | ៦ | ៥៤៨ |
| ភត្តគ្គវត្ត | ១ | ៥៥០ |
| បិណ្ឌចារិកវត្ត | ៥ | ៥៥៣ |
| អារញ្ញិកវត្ត | ៥ | ៥៥៥ |
| សេនាសនវត្ត | ១៣ | ៥៥៦ |
| ជន្តាឃរវត្ត | ៩ | ៥៥៩ |
| វច្ចកុដិវត្ត | ៧ | ៥៦១ |
| ឧបជ្ឈាយវត្ត | ៥ | ៥៦៤ |
| សទ្ធិវិហារិកវត្ត | ៩ | ៥៧០ |
| អាចរិយវត្ត | ១៣ | ៥៧១ |
| អន្តេវាសិកវត្ត | ១ | ៥៧២ |




www.budinst.gov.kh www.elibraryofcambodia.org

# សន្ទឹកបង្គុលប្រាប់មាតិកា


| មាតិកាធម៌ | បន្ទាត់ | ទំព័រ |
|---|---|---|
| **វត្តកថា** | | |
| វិធីកាន់យកនិស្ស័យ | ១១ | ៥៧២ |
| ការរម្ងាប់និស្ស័យ | ១ | ៥៧៦ |
| ប្រភេទនៃទុក្កដាបត្តិ | ៨ | ៥៨៤ |
| **ទាលីទុក្កដ** | | |
| វិនីតវត្ថុទុក្កដ | ៩ | ៥៨៦ |
| វិភង្គទុក្កដ | ១៦ | ៥៨៩ |
| ខន្ធកទុក្កដ | ១២ | ៥៩០ |
| បាលីមុត្តកទុក្កដ | ១០ | ៥៩៦ |
| ទំនងពណ៌នាក្នុងទុព្ភាសិតាបត្តិ | ១២ | ៦០២ |
| **កាលិកបព្វៈ** | | |
| យាវជីវិក | ៧ | ៦០៣ |
| យាវកាលិក | ១ | ៦០៧ |
| យាមកាលិក | ៥ | ៦១១ |
| សត្តាហកាលិក | ១១ | ៦១៤ |
| កាលិកសំសគ្គកថា | ៦ | ៦២៥ |
| ទំនងពណ៌នាក្នុងអន្តោវុត្ថ | ១៧ | ៦២៧ |
| កប្បិយភូមិកថា | ១៦ | ៦២៨ |
| ខុទ្ទកកថា | ១៥ | ៦៣៦ |
| មហាបទេស | ១៣ | ៦៤២ |




www.budinst.gov.kh www.elibraryofcambodia.org

# សន្លឹកបង្គុលប្រាប់មាតិកា


| មាតិកាធម៌ | បន្ទាត់ | ទំព័រ |
|---|---|---|

## ពិន្ទាធិដ្ឋានាធិប្បាយៈ

| | | |
|---|---|---|
| វិធីអធិដ្ឋាននឹងបច្ចុទ្ធរសំពត់ | ១៥ | ៦៤៦ |
| វិកប្បនកថា | ៧ | ៦៥៩ |
| វិធីអធិដ្ឋានបាត្រ | ១៧ | ៦៦៣ |
| វិធីវិកប្បបាត្រ | ១៥ | ៦៦៩ |
| សេចក្តីប្រែអំពីវិធីមានតិត្ថុជាដើម | ១៦ | ៦៧០ |

## វិជហនាធិប្បាយៈ

| | | |
|---|---|---|
| វិជហនកថា | ១៤ | ៦៧៣ |
| ទានាទិកថា | ៨ | ៦៧៦ |
| បដិគ្គហណកថា | ៥ | ៦៨០ |

## អាបត្តិទេសនាធិប្បាយៈ

| | | |
|---|---|---|
| អាបត្តិទេសនាកថា | ៧ | ៦៩៩ |
| ឧបោសថកថា | ១១ | ៧១១ |
| វស្សូបនាយិកាកថា | ១៦ | ៧២២ |
| បវារណាកថា | ៩ | ៧៣០ |
| សីមាកថា | ១៤ | ៧៤១ |
| អធិករណសមថកថា | ១ | ៧៤៦ |
| ការាការកថា | ១ | ៧៥២ |
| សម្មជ្ជនានិសង្សកថា | ១៧ | ៧៥៣ |




www.budinst.gov.kh www.elibraryofcambodia.org

# សន្លឹកបង្គួលប្រាប់មាតិកា

## អាបត្តិទេសនាផ្សេងៗ


| មាតិកាធម៌ | បន្ទាត់ | ទំព័រ |
|---|---|---|
| ជាទកថា . . . . . . . . . . . . . . . . . . . . . . | ១ | ៧៥៦ |
| ប្រមាណបាត្រ និង បលះ . . . . . . . . . . . . . . . . | ៤ | ៧៦៣ |
| អន្ទាស់ទ្យា មាត្រាវាស់ . . . . . . . . . . . . . . . . | ១៦ | ៧៧៣ |
| ប្រមាណបាត្រ . . . . . . . . . . . . . . . . . . . . . | ១៦ | ៧៧៤ |
| ប្រមាណសុគតវិទត្ថិ . . . . . . . . . . . . . . . . . . | ១៦ | ៧៧៦ |
| បរមពុទ្ធានុស្សាសន៍អធិប្បាយ . . . . . . . . . . . . . . . | ៩ | ៧៨៣ |


(ចប់)

www.budinst.gov.kh www.elibraryofcambodia.org

រោងពុម្ពវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

www.budinst.gov.kh www.elibraryofcambodia.org